# មាតិកា


| ចំណងជើង | | | ពាក្យកាត់ ទំព័រ |
|---|---|---|---|
| **ធម្មនុញ្ញ** | | | |
| ១- | Lumen Gentium | ព្រះសហគមន៍ជាពន្លឺបំភ្លឺពិភពលោក (អំពីព្រះសហគមន៍) | ពន្លឺ................ ១១ |
| ២- | Dei Verbum | ព្រះបន្ទូលព្រះជាម្ចាស់ | ព្រះបន្ទូល........៧៧ |
| ៣- | Sacrosanctun Concilium | មហាសន្និបាតដ៏វិសុទ្ធ (អំពីពិធីគោរពប្រណិប័តន៍) | ពិធី................៩៣ |
| ៤- | Gaudium et Spes | អំណរ និង សេចក្តីសង្ឃឹម (អំពីមុខងារព្រះសហគមន៍ក្នុងពិភពលោក) | អំណរ ......... ១៣៧ |
| **ក្រឹត្យក្រម** | | | |
| ៥- | Christus Dominus | ព្រះគ្រីស្តជាអម្ចាស់ (អំពីមុខងារបម្រើរបស់អស់លោកអភិបាល) | អភិបាល.......២៣៣ |
| ៦- | Presbyterorum Ordinis | ក្រុមលោកគង្វាល (អំពីមុខងារបម្រើ និងការរស់នៅរបស់លោកគង្វាល) | គង្វាល ..........២៦១ |
| ៧- | Optatam Totius Ecclesiae | ការប្រែប្រួលនៃព្រះសហគមន៍តាមសេចក្តីប៉ងប្រាថ្នា (អំពីការហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យ) | ហ្វឹកហ្វឺន ......២៩៣ |
| ៨- | Perfectae Caritatis | សេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ (អំពីការកែសម្រួលការរស់នៅជាបព្វជិតបព្វជិតា) | បព្វជិត......... ៣០៧ |
| ៩- | Apostolicam Actositatem | សកម្មភាពរបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូត | គ្រីស្តទូត....... ៣២១ |
| ១០- | Ad Gentes | ព្រះអម្ចាស់ចាត់ព្រះសហគមន៍ឲ្យទៅកាន់សាសន៍ដទៃ (អំពីសកម្មភាពរបស់ព្រះសហគមន៍ជាសាសនទូត) | សាសនទូត.....៣៥១ |

| | | | |
|---|---|---|---|
| ១១- Unitatis Redintegratio | គ្រីស្តបរិស័ទត្រូវរួបរួមគ្នាជាធ្លុងតែមួយ (អំពីការបង្រួបបង្រួមគ្រីស្តបរិស័ទ) | បង្រួម | ៣៩៣ |
| ១២- Orientalium Ecclesiarum | ព្រះសហគមន៍នៅបូព៌ាប្រទេស | បូព៌ា | ៤១៣ |
| ១៣- Inter Mirifica | ក្នុងចំណោមការអស្ចារ្យ (អំពីមធ្យោបាយទូរគមនាគមន៍) | ទូរ | ៤២៣ |


## សេចក្តីប្រកាស


| | | | |
|---|---|---|---|
| ១៤- Dignitatis Humanae | តម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស | តម្លៃ | ៤៣៥ |
| ១៥- Nostra Aestate | នៅសម័យយើងនេះ (អំពីទំនាក់ទំនងជាមួយសាសនាដទៃ) | សាសនា | ៤៤៧ |
| ១៦- Gravissimum Momentum | បញ្ហាដ៏ធ្ងន់ធ្ងរបំផុត (អំពីការអប់រំតាមបែបគ្រីស្តសាសនា) | អប់រំ | ៤៥៣ |

**សារបញ្ចប់** .................................................. ៤៦៣

# ពាក្យណែនាំរបស់អ្នកបកប្រែ

តាំងពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៦២ រហូតដល់ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៦៥ អភិបាលព្រះសហគមន៍កាតូលិកទូទាំងសាកលលោក ៣៥០០នាក់ បានជួបជុំគ្នាជាមហាសន្និបាតសាកល លើកទី២១ តាមទំនៀមទម្លាប់ព្រះសហគមន៍ពីបុរាណ។

អស់លោកមានគោលបំណងរិះគិត អំពីរបៀបសម្ដែងលទ្ធិនៃជំនឿគ្រីស្ដសាសនា ឲ្យបានស្របតាមសម័យទំនើប។ អស់លោកចែង និងប្រកាសឯកសារ ១៧ច្បាប់ ដែលបញ្ជាក់លទ្ធិនៃជំនឿរបស់ព្រះសហគមន៍កាតូលិកយើង ជាផ្លូវការនៅសតវត្សទី ២០។ ឯកសារទាំងនោះ ចែងជាភាសាឡាតាំង ហើយមានសារៈសំខាន់ណាស់ តែពិបាកស្ដាប់បន្តិច។ អស់លោកអភិបាល បានជ្រើសរើសពាក្យនីមួយៗ ដោយប្រយ័ត្នប្រយែង គឺរកពាក្យណាដែលចំនឹងអត្ថន័យនៃជំនឿ។ ពេលយើងបកប្រែមកជាភាសាខ្មែរ ក៏មានគោលបំណងដូចអស់លោកដែរ គឺយើងខិតខំរកពាក្យ ដែលចំនឹងអត្ថន័យដើម។ ជួនកាល យើងយកពាក្យដែលគ្រីស្ដបរិស័ទខ្មែរយើងមិនធ្លាប់ប្រើ តែពាក្យដែលយើងប្រើនោះ ចំនឹងអត្ថន័យជាង។ បងប្អូនអ្នកអាន ត្រូវចាត់ពាក្យថ្មីទាំងនោះ ទុកជាជំនួយសម្រាប់ឲ្យបងប្អូន រិះគិតអំពីអត្ថន័យដ៏ជ្រៅនៃជំនឿរបស់យើង។ យើងគ្រាន់តែផ្ដល់យោបល់ជូនបងប្អូនប៉ុណ្ណោះ មិនមែនបង្ខំបងប្អូនឲ្យប្រើពាក្យទាំងនោះទេ។

១- Creare, Creator, Creatio ៖ ក្នុងគម្ពីរភាសាហេប្រឺ មានពាក្យពិសេសមួយគឺ *(បារ៉ា)* សំដៅលើព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ ដែលប្រទានឲ្យអ្វីៗទាំងអស់កើតឡើង ដោយព្រះអង្គគ្រាន់តែមានព្រះបន្ទូល ប្រកបដោយព្រះប្រាជ្ញាញាណប៉ុណ្ណោះ។ មានពាក្យផ្សេង សំដៅទៅលើឪពុកម្ដាយដែលបន្ដជីវិតឲ្យកូន។ ហេតុនេះហើយ បានជាយើងសន្មតប្រែពាក្យ Creare ថា *"ប្រតិស្ឋាន"* ដែលមានន័យថា *"ចាត់ចែងរៀបចំដោយប្រាជ្ញា"*។

- Creator ៖ យើងសន្មតប្រែពាក្យនេះថា *"ព្រះអាទិករ"* ដែលមានអត្ថន័យថា *"អ្នកផ្ដើមធ្វើមុន អ្នកកសាងលោក"*។
- Creatio ៖ យើងសន្មតប្រែពាក្យនេះថា *"សត្វលោកទាំងឡាយ"* ឬអ្វីៗដែលព្រះជាម្ចាស់ប្រតិស្ឋានមក។

២- Credere, Fides, Fideles, Doctrina ៖ យើងបានសន្មតប្រែពាក្យ Credere ថា "ផ្ញើជីវិតលើព្រះគ្រីស្ដ" ជាអត្ថន័យ សមនឹងពាក្យដើម។ ពាក្យ *"ជឿ"* *"ជំនឿ"* ដែលគ្រីស្ដបរិស័ទ តែងប្រើតាំងពីដើមរៀងមក មានអត្ថន័យទូលំទូលាយពេក មិនសូវច្បាស់ នាំឲ្យពុទ្ធបរិស័ទយល់ឃើញថា គ្រីស្ដបរិស័ទយើងជាមនុស្សល្ងង់ ជឿដោយមិនរិះគិតពិចារណា។

- Fides ៖ យើងសន្មតប្រែពាក្យនេះថា *"ជំនឿ"*។
- Fideles ៖ យើងសន្មតប្រែពាក្យនេះថា *"គ្រីស្ដបរិស័ទ"* គឺអ្នកផ្ញើជីវិតលើព្រះគ្រីស្ដ។
- Doctrina ៖ យើងសន្មតប្រែពាក្យនេះថា *"លទ្ធិ"* លទ្ធិនៃជំនឿ លទ្ធិនៃគ្រីស្ដសាសនា។

៣- Laïcus ៖ ក្នុងភាសាក្រិក ជាភាសាដើមពាក្យ Laïcos សំដៅទៅលើសមាជិកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ តាំងពីយូរយារមកហើយ គ្រីស្តបរិស័ទខ្មែរ តែងតែបកប្រែពាក្យនេះថា "គ្រហស្ថ" ដែលសំដៅទៅលើពុទ្ធបរិស័ទ ដែលមិនបួសជាព្រះសង្ឃ។ តែពាក្យនេះ នាំឲ្យច្រឡំ និងស្មានថា ក្នុងព្រះសហគមន៍មានគ្រីស្តបរិស័ទខ្លះឋានៈទាបជាងលោកគង្វាល ឬទាបជាងបព្វជិត បព្វជិតា ដែលជាអ្នកមានបុណ្យ។ តាមជំនឿនៃគ្រីស្តសាសនា គ្រីស្តបរិស័ទទាំងអស់ ជាបងប្អូនដែលមានឋានៈស្មើគ្នាទាំងអស់ ជា "ក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ" (១សល ២, ៨)។ តែក្នុងព្រះសហគមន៍ មានគ្រីស្តបរិស័ទខ្លះ ទទួលមុខងារបម្រើព្រះសហគមន៍ (១ករ ១២, ៥)។ អ្នកបំពេញមុខងារបម្រើទាំងនោះ មិនមែនជាគ្រីស្តបរិស័ទដ៏ប្រសើរជាងគេ ឬមានឋានៈខ្ពស់ជាងគ្រីស្តបរិស័ទឯទៀតៗទេ។ តាមព្រះសហគមន៍ ដែលកាន់តាមរបៀបរបបពិធីផ្សេងៗ បូជាចារ្យមានគ្រួសារ។ រីឯបព្វជិត បព្វជិតា ជាគ្រីស្តបរិស័ទដែលរស់នៅតាមរបៀបប្លែកពីគេ ដោយថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់ តែគ្មានឋានៈប្រសើរជាងគ្រីស្តបរិស័ទឯទៀតៗទេ។ ហេតុនេះហើយ បានជាយើងសន្មតប្រើពាក្យ Laïcus នេះថា *"គ្រីស្តបរិស័ទធម្មតា"*។

៤- Liturgia ៖ តាមភាសាដើមពាក្យនេះ សំដៅទៅលើកិច្ចការរួមរបស់ប្រជាជន ដែលគោរពព្រះរបស់ខ្លួន។ តាំងពីដើមរៀងមក គ្រីស្តបរិស័ទខ្មែរតែងបកប្រែថា *"ពិធីបុណ្យ"*។ ប៉ុន្តែ យើងជាគ្រីស្តបរិស័ទត្រូវដឹងថា យើងមិនពឹងលើកុសលផលបុណ្យ ឬលើផលអានិសង្សនៃបុណ្យទេ តែយើងផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូជាអម្ចាស់ និងជាព្រះសង្គ្រោះ។ ហេតុនេះហើយ បានជាយើងសន្មតប្រែពាក្យនេះថា *"ពិធីគោរពប្រណិប័តន៍"* ដែលមិននាំឲ្យនរណាច្រឡំឡើយ។

- Cultum ៖ យើងសន្មតប្រែពាក្យនេះថា *"ការ ឬពិធីគោរពបម្រើព្រះជាម្ចាស់"*។
- Rituum, ceremonia ៖ យើងសន្មតប្រែពាក្យនេះថា *"ពិធី"*។
- OrientaleRitum ៖ ក្នុងព្រះសហគមន៍កាតូលិកយើង មានក្រុមគ្រីស្តបរិស័ទ តែងតែគោរពប្រណិប័តន៍ព្រះជាម្ចាស់តាមពិធីប្លែកពីគ្នា គឺមានរបៀបគោរពប្រណិប័តន៍តាមព្រះសហគមន៍ក្រុងរ៉ូម មានរបៀបគោរពប្រណិប័តន៍ តាមព្រះសហគមន៍ក្រិកស្លាវ៉ុង ។ល។ និង ។ល។ យើងសន្មតប្រែពាក្យនេះថា *"របៀបរបបពិធី"*។
- Divinum Officium ៖ យើងសន្មតប្រែពាក្យនេះថា *"ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់"*។
- Rituale ៖ យើងសន្មតប្រែពាក្យនេះថា *"ក្បួនពិធី" "សៀវភៅក្បួនពិធី"*។
- Predicatio ៖ យើងសន្មតប្រែពាក្យនេះថា *"ពិធីអត្ថាធិប្បាយគម្ពីរ"* ព្រោះពាក្យ *"ធម្មទេសនា"* ដែលយើងធ្លាប់ប្រើនោះ សំដៅតែលើការពន្យល់ធម៌ប៉ុណ្ណោះ រីឯអ្នកធ្វើពិធីអត្ថាធិប្បាយគម្ពីរយកចិត្តទុកដាក់ បកស្រាយបន្ទូល ធ្វើជាពន្លឺបំភ្លឺការរស់នៅរបស់គ្រីស្តបរិស័ទ។ ក្នុងឯកសារ *"ពិធីគោរពប្រណិប័តន៍"* អស់លោកចែងថា ការអត្ថាធិប្បាយគម្ពីរ ពិតជាពិធីមួយក្នុងអភិបូជា (ពិធី ៥២)។

៥- Magisterium, Traditio ៖ យើងសន្មតប្រែពាក្យ Magisterium នេះថា *"ការបង្រៀន"* (មិនគ្រាន់តែអភិបាលព្រះសហគមន៍ក្រុងរ៉ូមប៉ុណ្ណោះ)។ Traditio ៖ *"ការបញ្ជូនបន្ត"*។

៦- Mysterium ៖ អត្ថន័យដើម គឺគម្រោងការដ៏លាក់កំបាំង ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្ស លោកស្គាល់

ដោយសារព្រះគ្រីស្ត (អភ ៣, ៣-៤) ឥឡូវលែងលាក់បាំងហើយ។ ហេតុនេះហើយ បានជាយើងសន្មតប្រែពាក្យនេះថា *"គម្រោងការដ៏អស្ចារ្យ"*។ ជួនកាលយើងប្រែថា *"ព្រឹត្តិការណ៍"* គឺសំដៅទៅលើហេតុការណ៍ ដែលកើតក្នុងប្រវត្តិជីវិតព្រះយេស៊ូ (កំណើតសោយទិវង្គត។ល។)។ ជួនកាល យើងប្រែថា *"ការអាថ៌កំបាំង"*។

៧- Ministerium, Munus, officium ៖ យើងសន្មតប្រែពាក្យទាំងបីនេះថា *"មុខងារបម្រើបន្ទុកការងារ"*។

៨- PontifexSummus ៖ ពាក្យនេះ សម្រាប់បញ្ជាក់អំពីឋានន្តរសក្តិ របស់ព្រះចៅអធិរាជក្រុងរ៉ូម ដែលមានន័យថា *"មហាបូជាចារ្យ"* នៃព្រះទាំងប៉ុន្មានរបស់ប្រជាជនក្រុងរ៉ូម។ មហាសន្និបាត ចែងពាក្យ PontifexSummus ច្រើនជាងគេ។ ជួនកាលមានចែង RomanusEpiscopus គឺ *"អភិបាលព្រះសហគមន៍ក្រុងរ៉ូម"* (ពន្លឺ ២២)។ មិនដែលមានចែងពាក្យ Papa (គឺ *"លោកតា"*) ទេ។ ក្នុងឯកសារទាំងនោះ មានចែងអំពីអំណាចរបស់លោកដែលជា *"មេដឹកនាំ"* (Caput) ជា *"ប្រធាន"* (Praesidium) របស់ក្រុមអភិបាល គឺមានបញ្ជាក់ អំពីទំនាក់ទំនងរបស់លោក ជាមួយនឹងអភិបាលឯទៀតៗ ក្នុងឋានៈលោក ជាអ្នកបន្តមុខងារពីគ្រីស្តទូតសិលាមក រីឯអភិបាលឯទៀតៗ បន្តមុខងារពីក្រុមគ្រីស្តទូតវិញ។ ហេតុនេះហើយ បានជាយើងសន្មតប្រែពាក្យទាំងពីរនោះ ដោយពាក្យតែមួយគឺ *"អភិបាលព្រះសហគមន៍ក្រុងរ៉ូម"*។ នៅខាងដើមឯកសារទាំងប៉ុន្មាន លោកប៉ូលទី៦ សរសេរថា *"ខ្ញុំប៉ូលជាអភិបាល"* លោកក៏ ចុះហត្ថលេខាក្រោមឯកសារនីមួយៗ ដោយសរសេរថា *"ខ្ញុំប៉ូលអភិបាលព្រះសហគមន៍កាតូលិក រួមជាមួយអភិបាលឯទៀតៗ"*។ តាំងពីដើមរៀងមកគ្រីស្តបរិស័ទខ្មែរយើងតែងប្រើពាក្យ *"សម្តេចប៉ាប"* ដោយមានបំណងប្រៀបធៀបអភិបាលព្រះសហគមន៍ក្រុងរ៉ូម ទៅនឹងសម្តេចសង្ឃ តែគំនិតនេះ ខុសនឹងព្រះបន្ទូលផ្តែផ្តាំរបស់ព្រះយេស៊ូ។

៩- Presbyter, Sacerdos ៖ ក្នុងភាសាដើម (ហេប្រឺ-ក្រិក-ឡាតាំង) មានចែងពាក្យ Cohen, Iereus, Sacerdos។ តាំងពីឆ្នាំ១៩៧០ គ្រីស្តបរិស័ទ តែងតែបកប្រែពាក្យនេះថា *"បូជាចារ្យ"* ជាពាក្យចំនឹងអត្ថន័យដើម គឺសំដៅទៅលើអ្នកដែលបូជាយញ្ញ ដុតថ្វាយព្រះជាម្ចាស់តាមរបៀបគម្ពីរសម្ពន្ធមេត្រីចាស់។ ពាក្យនេះ ក៏ចំនឹងព្រះយេស៊ូជាមហាបូជាចារ្យរបស់យើង (ហប ៧, ១១-២៨) ហើយក៏ចំនឹងគ្រីស្តបរិស័ទ ដែលយកអ្វីទាំងអស់ក្នុងលោកនេះ មកថ្វាយព្រះបិតា (១សល ២,៨)។

ក្នុងភាសាដើមទាំងបីនោះ ក៏មានពាក្យមួយទៀតគឺ៖ Zichn-Presbyteros-Presbyter។ តាំងពីឆ្នាំ១៩៧០ គ្រីស្តបរិស័ទតែងតែបកប្រែពាក្យនេះថា *"បូជាចារ្យ"* ដែរ តែរបៀបបកប្រែនេះ ខុសនឹងអត្ថន័យដើម។ ក្នុងគម្ពីរអន្តរនិកាយ យើងបកប្រែថា *"ព្រឹទ្ធាចារ្យ"* ដែលចំនឹងអត្ថន័យដើម។ តែតាំងពីពេលរដ្ឋាភិបាល បង្កើតព្រឹទ្ធសភាមក យើងមិនអាចប្រើពាក្យនេះបានទេ។

ឯកសារនៃមហាសន្និបាតស្តី *"ពិធីគោរពប្រណិប័តន៍"* មានប្រើតែពាក្យ Sacerdos ប៉ុណ្ណោះ។ ក្នុងឯកសារ "ការរស់នៅរបស់លោកគង្វាល" មានប្រើពាក្យ Sacerdos ប្រហែលម្ភៃដង ហើយពាក្យ Presbyter ច្រើនជាង។ ក្នុងឯកសារឯទៀតៗមានចែងពាក្យ Sacerdos និង Presbyter លាយឡំគ្នា។ ក្នុងឯកសារខ្លះមានចែងពាក្យ Pastor (គង្វាល) សំដៅទៅលើលោកអភិបាល ហើយជួនកាលទៅលើ Presbyter តែម្តង (ពិធី ៤២)។

ហេតុនេះ បានជាយើងសន្មតបកប្រែពាក្យ Presbyter ថា *"លោកគង្វាល"* តាមភាសា (កក ២០, ៣៨) និងតាមទម្លាប់ប្រទេសខ្លះ ដែលនិយាយភាសាអង់គ្លេស។ លោកគង្វាលនេះ ជាសហការីរបស់លោកអភិបាល ក្នុងឋានៈលោកជាគង្វាល ហើយទទួលចំណែកក្នុងមុខងារបីរបស់លោក គឺបង្រៀន នាំឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ និងគ្រប់គ្រងព្រះសហគមន៍។

- Clergé ៖ យើងបានបកប្រែ *"ក្រុមបូជាចារ្យ"* ឬ *"ក្រុមគង្វាល"* តាមកន្លែង។

១០- Resurrectio ៖ ពាក្យនេះមានន័យថា *"ក្រោកឈរឡើង"*។ ព្រះសហគមន៍យកពាក្យនេះ មកសំដៅទៅលើព្រឹត្តិការណ៍ដ៏អស្ចារ្យ ដែលកើតមកលើលោកយេស៊ូ ក្រោយពីលោកស្លាប់ គឺព្រះជាម្ចាស់ប្រោសឲ្យលោកមានជីវិតវិញ ព្រះអង្គលើកលោកឡើង តែងតាំងជាព្រះគ្រីស្តនិងជាព្រះអម្ចាស់ ហើយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យព្រះយេស៊ូចាក់បង្ហូរលើក្រុមសាវ័ក។ តាមគម្ពីរដំណឹងល្អទាំងបួនកណ្ឌ ការទាំងបីនោះ ជាព្រឹត្តិការណ៍តែមួយគត់។ តែលោកលូកាដែលបានបំបែកព្រឹត្តិការណ៍តែមួយនេះ ហាក់ដូចជាព្រឹត្តិការណ៍បីវិញ (កក ១, ១-២) ក្នុងគោលបំណង លាតត្រដាងអត្ថន័យតាមរបៀបរបបនៃថ្ងៃបុណ្យរបស់ជនជាតិយូដា។ ដូច្នេះ យើងសន្មតបកប្រែពាក្យនេះថា *"ព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង"* ឬ *"មានព្រះជន្មថ្មី"*។ យើងជៀសវាងពាក្យ *"ឡើងវិញ"* កុំនាំឲ្យមានទរណាច្រឡំ ដោយគិតថា ព្រះយេស៊ូមានព្រះជន្មឡើងវិញ ដូចពីមុន ឬចាប់ជាតិឡើយ។

១១- Vocatio ៖ ធម្មតាយើងបកប្រែពាក្យនេះថា *"ព្រះជាម្ចាស់ត្រាស់ហៅ"* ជួនកាល *"ទិសដៅកំណត់"* ជួនកាល *"ឧបនិស្ស័យ"*។

ការបកប្រែនេះ គ្រាន់តែជាការល្បងលមើលប៉ុណ្ណោះ។ អ្នកមានយោបល់ផ្សេងៗចង់កែសម្រួល សូមផ្ញើសេចក្ដីទាំងនោះទៅ fponchaud@gmail.com ។

សូមអរគុណ!

François PONCHAUD

ភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២

# សារនៃមហាសន្និបាត ផ្ញើជូនមនុស្សទាំងអស់ នៅពេលបើកមហាសន្និបាត

## ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦២

យើងជាអភិបាលព្រះសហគមន៍កាតូលិកទាំងប៉ុន្មាន សូមគោរពជូនមកប្រជាជាតិនានា។ យើងសូមសម្តែងសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ចំពោះមនុស្សទាំងអស់ សូមឲ្យមនុស្សទាំងអស់ បានប្រកបដោយសេចក្តីសុខសាន្ត ដែលព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ នាំមកក្នុងពិភពលោកយើង និងបានផ្ញើឲ្យព្រះសហគមន៍របស់ព្រះអង្គ។

យើងជួបជុំគ្នាតាមសេចក្តីអញ្ជើញរបស់លោកអភិបាលព្រះសហគមន៍ក្រុងរ៉ូម យ៉ូហាន ទី២៣ និងយើងព្យាយាមអធិដ្ឋានរួមគ្នា ដោយមាននាងម៉ារី ជាមាតាព្រះយេស៊ូ រួមជាមួយផងដែរ។ យើងនៅទីនេះ ក្នុងឋានៈ ជាអ្នកបន្តមុខងារពីក្រុមគ្រីស្តទូតមក ដោយមានអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាជាប្រធាន។

### សូមពន្លឺនៃព្រះភ័ក្ត្រព្រះគ្រីស្តចាំងឡើង

ពេលយើងប្រជុំគ្នានៅទីនេះ យើងរិះគិតក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ រករបៀបកែសម្រួលខ្លួនយើងផ្ទាល់ឲ្យបានជាថ្មី *"ឲ្យកាន់តែស្មោះភក្តី តាមដំណឹងល្អរបស់ព្រះគ្រីស្ត"*។ យើងនឹងខិតខំយកចិត្តទុកដាក់ រៀបរាប់សេចក្តីពិតទាំងស្រុងរបស់ព្រះជាម្ចាស់យ៉ាងសុទ្ធសាធ ដោយមិនលាក់លៀមអ្វីឡើយ ជូនមនុស្សនាបច្ចុប្បន្នកាល ដើម្បីឲ្យគេអាចយល់យ៉ាងច្បាស់ និងភ្ជាប់ចិត្តនឹងសេចក្តីពិតនេះដោយចិត្តស្មោះ។

ក្នុងឋានៈយើងជាគង្វាល យើងមានបំណងប្រាថ្នា ចង់តបឆ្លើយនឹងតម្រូវការរបស់អស់អ្នក ដែលស្វែងរកព្រះជាម្ចាស់ *"ដោយសង្ឃឹមថា នឹងរកឃើញទាំងស្ទាបស្ទង់។ តាមពិតព្រះអង្គ មិនគង់នៅឆ្ងាយពីយើងម្នាក់ៗទេ"*។

ហេតុនេះហើយ បានជាយើងសុខចិត្ត ប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះគ្រីស្ត ដែលបានបូជាព្រះជន្ម *"ដើម្បីនាំព្រះសហគមន៍មួយដ៏ឥតស្លាកស្នាម ឥតជ្រីវជ្រួញ ឥតសៅហ្មង ថ្វាយព្រះអង្គផ្ទាល់"* គឺយើងខិតខំអស់ពីសមត្ថភាព កែសម្រួលព្រះសហគមន៍នេះឲ្យបានជាថ្មី ខាងព្រះវិញ្ញាណទាំងអ្នកដឹកនាំទាំងសមាជិក ដើម្បីឲ្យព្រះសហគមន៍ បង្ហាញមុខរបស់ព្រះគ្រីស្ត ដែលអាចទាក់ទាញចិត្តមនុស្សលោកបាន គឺបង្ហាញព្រះភ័ក្ត្ររបស់ព្រះគ្រីស្ត ដែលភ្លឺក្នុងចិត្តយើង *"ដើម្បីឲ្យចំណេះអំពីសិរីរុងរឿងនៃព្រះជាម្ចាស់ចាំងពន្លឺឡើង"*។

### ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង

យើងជឿថា ព្រះបិតាស្រឡាញ់មនុស្សលោកយ៉ាងក្រៃលែង ទើបព្រះអង្គចាត់ព្រះបុត្រារបស់ព្រះអង្គ មកសង្គ្រោះមនុស្សលោក គឺរំដោះយើងឲ្យបានរួចពីបាបកម្ម និងរួចពីធ្វើទាសករនៃបាបកម្មនោះទៀតផង។ ព្រះបុត្រាបាន *"សម្រុះ*

*សម្រួលមនុស្សយើង ឲ្យបានជានាជាមួយព្រះបិតា និងតែងតាំងសេចក្តីសុខសាន្ត ដោយបានបូជាព្រះជន្ម*"។ ហេតុនេះហើយ បានជាយើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់មែន គឺមិនគ្រាន់តែមានឈ្មោះថា ជាបុត្រធីតាប៉ុណ្ណោះទេ តែយើងពិតជាបុត្រធីតារបស់ព្រះអង្គប្រាកដមែន។ ព្រះគ្រីស្ត បានចាត់ព្រះវិញ្ញាណក្នុងនាមព្រះបិតាឲ្យយាងមក ដើម្បីឲ្យយើងអាចរស់នៅបានដោយមានព្រះជន្មផ្ទាល់របស់ព្រះអង្គ ទាំងស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់បងប្អូន ហើយរួបរួមទាំងអស់គ្នាក្នុងអង្គព្រះគ្រីស្ត។

ទោះបីយើងផ្ញើជីវិតលើព្រះគ្រីស្តក្តី ក៏យើងយកចិត្តទុកដាក់នឹងបន្ទុករបស់ខ្លួន នៅលើផែនដីនេះដែរ គឺជំនឿសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ជំរុញយើងឲ្យបម្រើបងប្អូនទាំងស្រុង ដោយយកតម្រាប់តាមព្រះបរមគ្រូដ៏ជាទីសក្ការៈរបស់យើង ដែលព្រះអង្គយាងមក *"មិនមែនដើម្បីឲ្យគេបម្រើព្រះអង្គទេ តែដើម្បីបម្រើគេវិញ"*។ ហេតុនេះហើយបានជាព្រះអង្គតែងតាំងសហគមន៍មិនមែន ដើម្បីធ្វើជាម្ចាស់មនុស្សលោកទេ តែដើម្បីបម្រើគេវិញ។ *"ព្រះគ្រីស្តបានបូជាព្រះជន្មសម្រាប់យើង ហេតុនេះហើយ យើងក៏ត្រូវបូជាជីវិតសម្រាប់បងប្អូនយើងដែរ"*។

យើងមានសេចក្តីសង្ឃឹមថា ការរិះគិតរបស់មហាសន្និបាតនេះ មុខជានឹងជួយឲ្យជំនឿចាំងពន្លឺកាន់តែភ្លឺត្រចះត្រចង់ឡើង និងជួយកែសម្រួលជីវិតខាងព្រះវិញ្ញាណឲ្យបានជាថ្មីដែរ។ ដូច្នេះការរិះគិតរបស់មហាសន្និបាតយើងនេះ មុខជានឹងធ្វើឲ្យសេចក្តីដែលវិទ្យាសាស្ត្របានរកឃើញថ្មីៗ និងការចម្រើនឡើងនៃបច្ចេកទេស ហើយការផ្សព្វផ្សាយវប្បធម៌ស្ទុះឡើង និងបង្កើតផលដ៏ល្អប្រសើរ ព្រោះការទាំងបីនោះ សុទ្ធតែជាទ្រព្យដែលមានតម្លៃដ៏ថ្លៃថ្នូររបស់មនុស្សជាតិ។

## ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជំរុញយើង

យើងមកប្រជុំគ្នានៅទីនេះ ទាំងនាំយកបញ្ហាមនុស្សលោកមករិះគិត គឺទុក្ខវេទនាទាំងខាងជីវភាពទាំងខាងវិញ្ញាណទុក្ខលំបាក និងសេចក្តីប៉ងប្រាថ្នានៃប្រជាជាតិនានា ពីគ្រប់មជ្ឈដ្ឋាននៃផែនដី ដែលព្រះជាម្ចាស់បានផ្ញើទុកមកយើង។ យើងក៏យកចិត្តទុកដាក់នឹងបញ្ហាដ៏ធ្ងន់ធ្ងររបស់មនុស្សលោកទៀតផង យើងសូមសម្តែងសេចក្តីស្រឡាញ់ និងសេចក្តីទុកចិត្ត ចំពោះមនុស្សទាបជាងគេ ចំពោះអ្នកក្រីក្រជាងគេ និងចំពោះអ្នកទន់ខ្សោយជាងគេ។ ពេលព្រះគ្រីស្តទតឃើញបណ្តាជនទាំងឡាយឃ្លានអាហារ មានជំងឺគ្រប់យ៉ាង វង្វេងមិនស្គាល់ផ្លូវ ព្រះអង្គរំជួលព្រះហឫទ័យ អាណិតមេត្តាគេយ៉ាងណា យើងក៏រំជួលចិត្តអាណិតមេត្តាមនុស្សលោកនាបច្ចុប្បន្នយ៉ាងនោះដែរ។ យើងរួមសាមគ្គីជាមួយអស់អ្នក ដែលមិនអាចទៅដល់ការអភិវឌ្ឍន៍ ដែលមានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ ព្រោះគ្មាននរណា បានជួយយ៉ាងគ្រប់គ្រាន់ដល់គេនៅឡើយទេ។

ហេតុនេះហើយ បានជានៅក្នុងមហាសន្និបាតនេះ យើងនឹងលើកបញ្ហាលោកីយ៍ទាំងនោះមករិះគិតយ៉ាងយូរ គឺជាបញ្ហាទាក់ទិននឹងតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស និងទាក់ទិននឹងសហគមន៍ដ៏ពិតប្រាកដ នៃប្រជាជាតិនានា។ *"ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជំរុញយើង"* *"ប្រសិនបើ នរណាម្នាក់ឃើញបងប្អូនខ្វះខាត តែមិនអើពើនឹងគេទេ តើសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ស្ថិតនៅក្នុងអ្នកនោះដូចម្តេចកើត?"*។

## គម្រោងការណ៍ពីរដ៏សំខាន់

ក្នុងសារផ្សព្វផ្សាយតាមវិទ្យុនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦២ លោកយ៉ូហាន ទី២៣ ជាអភិបាល ព្រះសហគមន៍ក្រុងរ៉ូម បានគូសសង្កត់លើបញ្ហាពីរ ដែលមានដូចតទៅ៖

- មុនដំបូងលោកសូមលើកបញ្ហាសន្តិភាពរវាងប្រជាជននានាមករិះគិត។ តើនរណាមិនស្អប់សង្គ្រាម? តើនរណាមិនចង់បានសន្តិភាព? ព្រះសហគមន៍ ចង់បានសន្តិភាពច្រើនជាងអ្នកឯទៀតៗទាំងអស់ ព្រោះព្រះសហគមន៍ ជាមាតារបស់មនុស្សទាំងអស់។ តាមប្រសាសន៍ ជាញឹកញាប់របស់លោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមនោះ ព្រះសហគមន៍នៅតែប្រកាសថា ខ្លួនស្រឡាញ់សន្តិភាព ប៉ងចង់បានសន្តិភាព ចង់រួមសហការយ៉ាងស្មោះ ជាមួយអស់លោក អ្នកដែលខិតខំកសាងសន្តិភាពដោយចិត្តទៀងត្រង់។ ព្រះសហគមន៍ខិតខំអស់ពីសមត្ថភាព ធ្វើឲ្យប្រជាជាតិនានាទាក់ទងគ្នាទៅវិញទៅមក ឲ្យយល់ចិត្តគ្នា ឲ្យរាប់រកគ្នាទៀតដែរ។ មហាសន្និបាតយើងនេះ ក៏ផ្តល់សក្ខីភាពដ៏រស់រវើក ដែលអាចមើលឃើញបានថា ខ្លួនជាសញ្ញាសម្គាល់អំពីមនុស្ស ដែលមានជាតិសាសន៍ប្លែកពីគ្នាប្រជាជាតិ និងភាសាប្លែកពីគ្នា ពិតជាសហគមន៍ ដែលស្រឡាញ់គ្នាដូចបងប្អូនបង្កើតមែន។ យើងសូមប្រកាសថា មនុស្សគ្រប់ៗគ្នា អាចរួបរួមគ្នា ដូចជាបងប្អូនបង្កើត បានដោយគ្មានព្រំដែន និងគ្មានអរិយធម៌ណាមកបំបែកគេបានឡើយ។
- បន្ទាប់មក លោក យ៉ូហាន ទី២៣ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម រំឭកយើងអំពីបញ្ហាយុត្តិធម៌ក្នុងសង្គម។ សារលិខិតរបស់លោក ក្រោមចំណងជើងថា *"ព្រះសហគមន៍ជាមាតា និងជាគ្រូ"* បញ្ជាក់យ៉ាងជាក់ច្បាស់ថា មនុស្សលោកទំនើប ត្រូវការព្រះសហគមន៍ ជាងសម័យមុនៗទៅទៀត ដើម្បីបង្ហាញបញ្ជាក់អំពីភាពអយុត្តិធម៌ និងភាពមិនស្មើគ្នា ដែលមនុស្សទ្រាំមិនបាន។ ព្រះសហគមន៍អាចជួយមនុស្សលោកឲ្យដឹងថា មានសេចក្តីខ្លះ ដែលជាតម្លៃដ៏ថ្លៃថ្នូរតាមលំដាប់លំដោយយ៉ាងពិតប្រាកដ ដែលអាចណែនាំការរស់នៅរបស់គេ។ ព្រះសហគមន៍អាចជួយមនុស្ស ឲ្យរស់នៅតាមលក្ខណៈរបស់ខ្លួន ជាមនុស្សកាន់តែប្រសើរឡើងៗ និងស្របតាមគោលការណ៍នៃដំណឹងល្អបាន។

## ឫទ្ធានុភាពនៃព្រះវិញ្ញាណ

តាមពិត យើងគ្មានមធ្យោបាយខាងសេដ្ឋកិច្ចទេ ហើយយើងក៏គ្មានអំណាចខាងលោកីយ៍ដែរ តែយើងជឿសង្ឃឹមលើឫទ្ធានុភាពនៃព្រះវិញ្ញាណ ដែលព្រះអម្ចាស់យេស៊ូបានសន្យា ប្រទានឲ្យព្រះសហគមន៍របស់ព្រះអង្គ។ ហេតុនេះហើយ បានជាយើងសូមអង្វរបងប្អូនដោយចិត្តសុភាពរាបសា អង្វរបងប្អូន ដែលយើងបម្រើក្នុងឋានៈជាគង្វាល និងអង្វរបងប្អូនឯទៀតៗ ដែលផ្ញើជីវិតលើព្រះគ្រីស្ត ព្រមទាំងអង្វរមនុស្សទាំងអស់ ដែលមានឆន្ទៈល្អ *"ដែលព្រះជាម្ចាស់ សព្វព្រះហឫទ័យសង្គ្រោះ និងនាំឲ្យស្គាល់សេចក្តីពិត"* សូមបងប្អូនសុខចិត្តរួមជាមួយយើង ជួយកសាងពិភពលោក ប្រកបដោយយុត្តិធម៌ សូមឲ្យមនុស្សស្រឡាញ់គ្នាទៅវិញទៅមក ដូចជាបងប្អូនឲ្យកាន់តែខ្លាំងឡើងៗផង។ គម្រោងការរបស់ព្រះជាម្ចាស់ ពិតជាមានដូច្នោះមែន គឺដោយសារមនុស្សស្រឡាញ់គ្នាទៅវិញទៅមកនោះ គឺព្រះអង្គគ្រងរាជ្យលើពិភពលោកយើង និងដូចជាប្រផ្នូលយ៉ាងឆ្ងាយ អំពីលោកខាងមុខដែរ។

យើងរស់នៅក្នុងពិភពលោក ដែលមិនទាន់មានសន្តិភាពដ៏ពិតប្រាកដ តាមសេចក្តីប៉ងប្រាថ្នារបស់យើងនៅឡើយ។ មនុស្សក៏ចេះតែតប់ប្រមល់ ដោយយល់ឃើញថា មានបច្ចេកទេសចម្រើនយ៉ាងល្អប្រសើរមែន តែបើគ្មានធម្មវិន័យដ៏ខ្ពង់ខ្ពស់ណាមួយណែនាំទេ ការចម្រើននៃបច្ចេកទេសនោះ អាច បណ្តាលឲ្យមានគ្រោះកាចដ៏ធ្ងន់ធ្ងរបំផុត។ សូមពន្លឺនៃសេចក្តីសង្ឃឹមដ៏ខ្លាំងក្លាចំពោះព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះតែមួយព្រះអង្គគត់ ភ្លឺឡើងក្នុងពិភពលោកយើងនេះកុំខានឡើយ។

# ព្រះសហគមន៍ជាពន្លឺបំភ្លឺពិភពលោក

## (អំពីព្រះសហគមន៍)

## LUMENGENTIUM

## ខ្ញុំប៉ូលជាអភិបាលជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលនៃមហាសន្និបាតដ៏វិសុទ្ធ សូមប្រកាសធម្មនុញ្ញគោលលទ្ធិនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។ ធម្មនុញ្ញគោលលទ្ធិ អំពីព្រះសហគមន៍

## ជំពូក១

### ១- អារម្ភកថា

ព្រះគ្រីស្ដជាពន្លឺបំភ្លឺប្រជាជាតិនានា។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានប្រជុំមហាសន្និបាតដ៏វិសុទ្ធនេះ ដែលប្រាថ្នាយ៉ាងខ្លាំង ចង់ផ្សព្វផ្សាយពន្លឺរបស់ព្រះគ្រីស្ដទៅលើមនុស្សទាំងអស់ គឺជាពន្លឺដែលចែងចាំងលើមុខព្រះសហគមន៍ ដោយប្រកាសដំណឹងល្អឲ្យសត្វលោកទាំងឡាយ (មក ១៦, ១៥)។ ព្រះសហគមន៍រួមក្នុងអង្គព្រះគ្រីស្ដ ហាក់ដូចជាអគ្គសញ្ញាម៉្យាង គឺជាសញ្ញាសម្គាល់បង្ហាញព្រះជាម្ចាស់ និងជាមធ្យោបាយ នាំឲ្យមនុស្សអាចរួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះអង្គបាន។ ព្រះសហគមន៍ក៏ជាសញ្ញាសម្គាល់ និងជាមធ្យោបាយនាំឲ្យមនុស្សជាតិទាំងមូល រួមគ្នាជាធ្លុងតែមួយដែរ (អំណរ ៤២)។ ក្នុងធម្មនុញ្ញនេះ ព្រះសហគមន៍មានគោលបំណង ចង់បញ្ជាក់កាន់តែជាក់ច្បាស់នូវលក្ខណៈ និងបេសកកម្មរបស់ខ្លួន ស្របតាមការប្រៀនប្រដៅរបស់មហាសន្និបាតកាលពីមុនៗមក ដើម្បីឲ្យគ្រីស្ដបរិស័ទ និងមនុស្សទូទៅយល់។ នេះជាភារកិច្ចរបស់ព្រះសហគមន៍ ប៉ុន្តែ សភាពការណ៍នៃពិភពលោកសព្វថ្ងៃ ធ្វើឲ្យភារកិច្ចនេះមានលក្ខណៈជាបន្ទាន់ ព្រោះមនុស្សទាំងអស់ភ្ជាប់ជាមួយគ្នាកាន់តែជិតស្និទ្ធ ដោយចំណងផ្សេងៗជាច្រើនក្នុងសង្គម គឺមានចំណងបច្ចេកទេស និងចំណងវប្បធម៌ជាដើម។ ដូច្នេះ ត្រូវឲ្យមនុស្សទាំងអស់រួបរួមគ្នាយ៉ាងពេញលេញ ក្នុងអង្គព្រះគ្រីស្ដដែរ។

### ២- គម្រោងការរបស់ព្រះបិតា ដែលសព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់

ព្រះបិតាដែលមានព្រះជន្មមុនកាលសម័យទាំងអស់ ព្រះអង្គមានសេរីភាពពេញទី សម្រេចបំណងដ៏អាថ៌កំបាំង គឺប្រតិស្ឋានពិភពលោក ដោយព្រះប្រាជ្ញាញាណ និងដោយព្រះហឫទ័យសប្បុរស។ ព្រះអង្គក៏សម្រេច ព្រះហឫទ័យលើកមនុស្សលោក ឲ្យទទួលចំណែកនៃព្រះជន្មផ្ទាល់របស់ព្រះអង្គថែមទៀតដែរ។ ក្រោយពីមនុស្សលោកប្រព្រឹត្តអំពើបាប ដោយរួមជាមួយលោក អាដាំ ព្រះអង្គមិនលះបង់គេចោលទេ តែព្រះអង្គបានជួយសង្គ្រោះគេ ដោយនឹកគិតដល់ព្រះគ្រីស្ដ

ដែលរំដោះមនុស្សលោក។ *"ព្រះគ្រីស្ត ជារូបតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលពុំឃើញព្រះអង្គ ជារៀមច្បងនៃអ្វីៗទាំងអស់ ដែលព្រះជាម្ចាស់បានប្រតិស្ឋានមក"* (កូឡ ១, ១៥)។ *"អស់អ្នក ដែលព្រះបិតាបានជ្រើសរើស មុនកាលសម័យទាំងអស់ ព្រះអង្គក៏បានតម្រូវគេទុកជាមុនឲ្យមានលក្ខណៈ ដូចព្រះបុត្រាព្រះអង្គដែរ ដើម្បីឲ្យព្រះបុត្រា បានទៅជារៀមច្បង ក្នុងបណ្តាបងប្អូនជាច្រើន"* (រម ៨, ២៩)។ ចំពោះអស់អ្នក ដែលផ្ញើជីវិតលើព្រះគ្រីស្ត ព្រះបិតាសព្វព្រះហឫទ័យត្រាស់ហៅគេ ឲ្យទៅជាព្រះសហគមន៍ដ៏វិសុទ្ធ។ ព្រះជាម្ចាស់ប្រទានដំណឹង អំពីព្រះសហគមន៍នេះ តាមនិមិត្តសញ្ញាជាច្រើន តាំងពីកំណើតពិភពលោករៀងមក ក៏បានព្រះអង្គបានរៀបចំព្រះសហគមន៍នេះយ៉ាងអស្ចារ្យ តាមប្រវត្តិសាស្ត្រប្រជាជនអ៊ីស្រាអែល និងតាមសម្ពន្ធមេត្រីចាស់។ ព្រះអង្គ ក៏បានតែងតាំងព្រះសហគមន៍នៅសម័យឥឡូវជាជំនាន់ចុងក្រោយបំផុត។ ព្រះគ្រីស្តបង្ហាញព្រះសហគមន៍ ដោយបង្ហូរព្រះវិញ្ញាណ ហើយព្រះសហគមន៍នឹងបានទៅជាពេញលក្ខណៈជាស្ថាពរ ក្នុងសិរីរុងរឿងនៅពេលចុងក្រោយបំផុត។ នៅពេលនោះ អស់មនុស្សសុចរិតតាំងពីជំនាន់លោក អាដាំ មក គឺ *"តាំងពីលោក អាបែល ជាមនុស្សសុចរិត រហូតដល់ជនចុងក្រោយបង្អស់ ដែលព្រះជាម្ចាស់ជ្រើសរើស"* ក៏នឹងរួបរួមគ្នានៅក្បែរព្រះបិតាក្នុងព្រះសហគមន៍សាកល ស្របតាមសេចក្តី ដែលអស់គ្រូបាធ្យាយដ៏វិសុទ្ធបានចែងទុកមក។

## ៣- បេសកកម្មរបស់ព្រះបុត្រា

ហេតុនេះហើយ បានជាព្រះបិតា ចាត់ព្រះបុត្រាឲ្យយាងមក។ ព្រះបិតា បានជ្រើសរើសយើង ក្នុងអង្គព្រះបុត្រានេះ មុនទ្រង់ប្រតិស្ឋានពិភពលោកមកម្លេះ ហើយតម្រូវទុកឲ្យយើង ទៅជាបុត្រធីតា តាមព្រះអង្គគ្រោងទុក ពោលគឺ ប្រមូលអ្វីៗទាំងអស់ ឲ្យរួមគ្នាក្នុងអង្គព្រះបុត្រា (អភ ១, ៤-៥ និង ១០)។ ហេតុនេះហើយ បានជាព្រះគ្រីស្តធ្វើឲ្យព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត ចាប់ផ្តើមគ្រងរាជ្យនៅលើផែនដី ដើម្បីឲ្យព្រះហឫទ័យព្រះបិតាកើតជារូបរាង។ ព្រះគ្រីស្ត ក៏បានសម្តែងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលគ្រងរាជ្យនោះ។ ព្រះអង្គបានរំដោះមនុស្សជាស្ថាពរ ដោយប្រព្រឹត្តតាមបញ្ជាព្រះបិតា។ ព្រះសហគមន៍ ជាព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលោកនេះ យ៉ាងអាថ៌កំបាំងរួចស្រាប់ហើយ គឺព្រះសហគមន៍ធ្វើឲ្យមនុស្សឃើញព្រះរាជ្យនេះចម្រើនឡើង ដោយមានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ជួយឧបត្ថម្ភផង។ ដើមកំណើត និងការអភិវឌ្ឍន៍នៃព្រះរាជ្យនេះ មកពីព្រះលោហិត និងទឹកដែលហូរចេញពីរបួសត្រង់ឆ្អឹងជំនីររបស់ព្រះយេស៊ូ ដែលត្រូវគេឆ្កាង (យហ ១៩, ៣៤)។ ព្រះអម្ចាស់ ក៏មានព្រះបន្ទូលប្រាប់ឲ្យដឹងជាមុន អំពីដើមកំណើត និងអំពីការអភិវឌ្ឍន៍នៃព្រះរាជ្យនេះ នៅពេលព្រះអង្គមានព្រះបន្ទូល អំពីព្រះអង្គសោយទិវង្គត នៅលើឈើឆ្កាងថា *"កាលណាគេលើកខ្ញុំឡើងពីដី ខ្ញុំនឹងទាញមនុស្សទាំងអស់មក"* ឯខ្ញុំ (យហ ១២, ៣២)។ គ្រប់ពេលព្រះសហគមន៍ថ្វាយអភិបូជា គឺថ្វាយសក្ការបូជារបស់ព្រះយេស៊ូ ដែលបូជាព្រះជន្មនៅលើឈើឆ្កាង ព្រះអង្គរំដោះយើង ព្រោះព្រះអង្គជាយញ្ញរបស់យើង ក្នុងឱកាសបុណ្យចម្លង (១ករ ៥, ៧)។ នៅពេលនោះ ក៏មានសម្តែង និងសម្រេចថា គ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ ដោយអគ្គសញ្ញានៃនំបុ័ង ដែលគេយកទៅអរព្រះគុណនោះ គឺគ្រីស្តបរិស័ទរួបរួមគ្នាជាព្រះកាយតែមួយ ក្នុងអង្គព្រះគ្រីស្ត (១ករ ១០, ១៧)។ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ ឲ្យរួបរួមជាមួយព្រះគ្រីស្ត គឺព្រះគ្រីស្តដែលជាពន្លឺបំភ្លឺមនុស្សលោក។ យើងទាំងអស់គ្នា ក៏កើតចេញមកពីព្រះគ្រីស្តមានជីវិត ដោយសារព្រះគ្រីស្ត និងតម្រង់ខ្លួនទៅកាន់ព្រះគ្រីស្តផងដែរ។

## ៤- ព្រះវិញ្ញាណប្រោសឲ្យព្រះសហគមន៍បានវិសុទ្ធ

ក្រោយពីព្រះបុត្រាបានបង្ហើយព្រះរាជកិច្ច ដែលព្រះបិតាផ្ញើឲ្យព្រះអង្គ បំពេញនៅលើផែនដីសព្វគ្រប់ហើយ

(យហ ១៧, ៤) ព្រះបិតាចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅបុណ្យថ្ងៃទីហាសិប ដើម្បីប្រោសឲ្យព្រះសហគមន៍បានវិសុទ្ធជានិច្ច ព្រមទាំងប្រោសប្រទានឲ្យអស់អ្នកផ្ញើជីវិតលើព្រះគ្រីស្ត មានផ្លូវចូលទៅកាន់ព្រះបិតា ដោយសារព្រះគ្រីស្ត និងដោយរួមក្នុងព្រះវិញ្ញាណតែមួយ (អភ ២, ១៨) គឺព្រះវិញ្ញាណនៃជីវិតនេះហើយ ជាប្រភពទឹកដែលផុសឡើង ហើយផ្តល់ព្រះជន្មរបស់ព្រះជាម្ចាស់ (យហ ៤, ១៤; ៧, ៣៨-៣៩)។ ដោយសារព្រះវិញ្ញាណនេះ ព្រះបិតាប្រទានជីវិតឲ្យមនុស្សដែលត្រូវស្លាប់ដោយសារអំពើបាប ទាំងរង់ចាំឲ្យរូបកាយរបស់គេ ដែលរមែងតែងតែស្លាប់ ទទួលជីវិតថ្មីដ៏រុងរឿងក្នុងអង្គព្រះគ្រីស្ត (រម ៨, ១០-១១)។ ព្រះវិញ្ញាណគង់នៅក្នុងព្រះសហគមន៍ និងក្នុងចិត្តអ្នកផ្ញើជីវិតលើព្រះគ្រីស្ត ដូចជាគង់នៅក្នុងព្រះវិហារមួយ (១ករ ៣, ១៦; ៦, ១៩)។ ព្រះវិញ្ញាណអធិដ្ឋាននៅក្នុងខ្លួនគេ និងបញ្ជាក់ថា គេមានលក្ខណៈជាបុត្រធីតារបស់ព្រះបិតា (កឡ ៤, ៦; រម ៨, ១៥-១៦ និង ២៦)។ ព្រះវិញ្ញាណណែនាំព្រះសហគមន៍ឲ្យស្គាល់សេចក្តីពិតគ្រប់ជំពូក (យហ ១៦, ១៣)។ ព្រះវិញ្ញាណបង្រួបបង្រួមព្រះសហគមន៍ ឲ្យរួបរួមគ្នាជាធ្លុងតែមួយ និងឲ្យមានមុខងារបម្រើផ្សេងៗ។ ព្រះវិញ្ញាណណែនាំហើយចាត់ចែងព្រះសហគមន៍ ឲ្យមានរចនាសម្ពន្ធតាមលំដាប់លំដោយ និងសម្តែងសកម្មភាពរបស់ព្រះអង្គផ្ទាល់ ដោយប្រទានព្រះអំណោយទានផ្សេងៗ។ ព្រះវិញ្ញាណក៏ប្រទានផលផ្លែជាច្រើន ជាគ្រឿងតុបតែងព្រះសហគមន៍ផងដែរ (អភ ៤, ១១-១២; ១ករ ១២, ៤; កឡ ៥, ២២)។ ព្រះវិញ្ញាណ ប្រោសឲ្យព្រះសហគមន៍មានកម្លាំងថ្មី មិនដែលចាស់ឡើយ និងឲ្យប្រែខ្លួនជាថ្មីជានិច្ចដោយសារអានុភាពនៃដំណឹងល្អ ទាំងណែនាំព្រះសហគមន៍ ឲ្យទៅរួមរស់យ៉ាងពេញលេញជាមួយព្រះគ្រីស្តជាព្រះស្វាមី។ ទាំងព្រះវិញ្ញាណ ទាំងព្រះសហគមន៍ ជាព្រះមហេសីទូលទៅកាន់ព្រះអម្ចាស់យេស៊ូថា *"សូមយាងមក!"* (វវ ២២, ១៧)។

ហេតុនេះហើយ បានជាមនុស្សឃើញថាព្រះសហគមន៍ជា *"ប្រជាជនមួយ ដែលរួបរួមគ្នាជាធ្លុងតែមួយ មកពីព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ រួបរួមគ្នាជាអង្គតែមួយ"*។

## ៥- ព្រះរាជ្យរបស់ព្រះជាម្ចាស់

ដើមកំណើតនៃព្រះសហគមន៍ សម្តែងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ចំពោះព្រះសហគមន៍ដ៏វិសុទ្ធ។ ព្រះអម្ចាស់យេស៊ូ បង្កើតព្រះសហគមន៍ដោយប្រកាសដំណឹង ដែលផ្តល់អំណរសប្បាយថា ព្រះជាម្ចាស់យាងមកគ្រងរាជ្យហើយ តាមព្រះបន្ទូលសន្យាជាយូរសតវត្សមកគឺ ព្រះអង្គប្រកាសថា៖ *"ពេលកំណត់ពេញសព្វគ្រប់អស់ហើយ ព្រះជាម្ចាស់គ្រងរាជ្យហើយ!"* (មក ១, ១៥; មថ ៤, ១៧)។ ព្រះគ្រីស្ត បញ្ចាំងពន្លឺនៃព្រះរាជ្យនោះ ដោយមានព្រះបន្ទូល និងប្រព្រឹត្តព្រះរាជកិច្ចផ្សេងៗ ព្រមទាំងគង់នៅជាមួយមនុស្សលោកផង។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ ប្រៀបដូចជាគ្រាប់ពូជម៉្យាង ព្រោះក្នុងចម្ការមួយ (មក ៤, ១៤)។ អស់អ្នកស្តាប់ព្រះបន្ទូល ដោយផ្ញើជីវិតលើព្រះអង្គ ចូលរួមក្នុងក្រុមតូចរបស់ព្រះគ្រីស្ត (លក ១២, ៣២) និងទទួលព្រះរាជ្យនោះ។ បន្ទាប់មកគ្រាប់ពូជនោះ ដុះពន្លកឡើង ដោយកម្លាំងខ្លួនឯង និងចម្រើនឡើងរហូតដល់ពេលចម្រូត (មក ៤, ២៦-២៩)។ ព្រះយេស៊ូក៏ធ្វើការអស្ចារ្យនានាសម្តែងសញ្ញាសម្គាល់ថា ព្រះជាម្ចាស់គ្រងរាជ្យនៅលើផែនដីនេះហើយ៖ *"ប្រសិនបើខ្ញុំដេញខ្មោច ដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់នោះ បានសេចក្តីថា ព្រះអង្គយាងមកគ្រងរាជ្យលើអ្នករាល់គ្នាហើយ។"* (លក ១១, ២០; មថ ១២, ២៨)។ ក៏ប៉ុន្តែព្រះជាម្ចាស់សម្តែងថា ព្រះអង្គគ្រងរាជ្យយ៉ាងពិសេសបំផុត ក្នុងអង្គព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះអង្គ និងជាបុត្រមនុស្ស ដែលយាងមក *"បម្រើគេ ព្រមទាំងបូជាជីវិត ដើម្បីរំដោះមនុស្សទាំងអស់ផង"* (មក ១០, ៤៥)។

ព្រះយេស៊ូរងទុក្ខ និងសោយទិវង្គតនៅលើឈើឆ្កាង ដើម្បីជាប្រយោជន៍ដល់មនុស្សលោក។ ក្រោយមក ព្រះអង្គ

ទទួលព្រះជន្មថ្មីដ៏រុងរឿង។ ព្រឹត្តិការណ៍នេះសរឲ្យគេឃើញថា ព្រះជាម្ចាស់បានតែងតាំងលោក ជាព្រះអម្ចាស់ ជាព្រះគ្រីស្ត និងជាមហាបូជាចារ្យ ដែលស្ថិតនៅអស់កល្បជានិច្ច (កក ២, ៣៦; ហប ៥, ៦; ៧, ១៧- ២១)។ ព្រះគ្រីស្ត ក៏ចាក់បង្ហូរព្រះវិញ្ញាណលើក្រុមសាវ័ក តាមព្រះបន្ទូលសន្យារបស់ព្រះបិតា (កក ២, ៣៣)។ ដូច្នេះ ព្រះសហគមន៍បានទទួលព្រះអំណោយទានផ្សេងៗពីព្រះគ្រីស្ត ដែលបានបង្កើតព្រះសហគមន៍។ ព្រះសហគមន៍ក៏យកចិត្តទុកដាក់ កាន់តាមបទបញ្ញារបស់ព្រះអង្គ ដោយចិត្តស្មោះ ពោលគឺ ឲ្យមានចិត្តស្រឡាញ់ ឲ្យមានចិត្តសុភាពរាបសាឲ្យមានចិត្តលះបង់។ ព្រះសហគមន៍ ក៏ទទួលបេសកកម្មប្រកាសថា ព្រះគ្រីស្ត និងព្រះជាម្ចាស់គ្រងរាជ្យ និងមានមុខងារតែងតាំងព្រះរាជ្យក្នុងប្រជាជាតិនានា។ ព្រះសហគមន៍ជាពន្លក និងជាដើមកំណើតនៃព្រះរាជ្យនេះនៅលើផែនដី។ ក៏ប៉ុន្តែ នៅពេលព្រះសហគមន៍ចម្រើនឡើងបន្តិចម្តងៗ ព្រះសហគមន៍ប្រាថ្នាចង់ឲ្យព្រះរាជ្យនេះ បានពេញលេញឲ្យបានសព្វគ្រប់ ទាំងសង្ឃឹមអស់ពីសមត្ថភាព និងផ្ចង់ចិត្តយ៉ាងខ្លាំង ឲ្យបានរួមជាមួយព្រះមហាក្សត្ររបស់ខ្លួនក្នុងសិរីរុងរឿង។

## ៦- និមិត្តសញ្ញាអំពីព្រះសហគមន៍

តាមគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់ តែងតែសម្តែងអំពីព្រះអង្គគ្រងរាជ្យ តាមនិមិត្តសញ្ញាផ្សេងៗ។ សព្វថ្ងៃព្រះអង្គក៏សម្តែងឲ្យយើង ស្គាល់អំពីលក្ខណៈពិសេសដ៏ជ្រៅបំផុតរបស់ព្រះសហគមន៍ តាមនិមិត្តរូបផ្សេងៗដែរ គឺជានិមិត្តរូបដកស្រង់ពីការរស់នៅរបស់គង្វាលសត្វ ពីការរស់នៅរបស់កសិករពីការសាងសង់សំណង់ ពីការរស់នៅក្នុងក្រុមគ្រួសារ និងពីអាពាហ៍ពិពាហ៍ដូចមានចែងក្នុងគម្ពីរព្យាការីជាប្រផ្នូលស្រាប់។ ព្រះសហគមន៍ប្រៀបដូចជាក្រោលសត្វ រីឯព្រះគ្រីស្តវិញ ព្រះអង្គប្រៀបដូចជា ទ្វារចេញចូលតែមួយ ដែលត្រូវការជាចាំបាច់ (យហ ១០, ១-១០)។ ព្រះសហគមន៍ជាហ្វូងសត្វ ដែលព្រះជាម្ចាស់បានប្រកាសជាមុនថា ព្រះអង្គនឹងទៅជាគង្វាល (អស ៤០, ១១; អគ ៣៤, ១១ត)។ ទោះបីមានមនុស្សជាគង្វាលណែនាំក្តី ក៏ព្រះគ្រីស្តផ្ទាល់ណែនាំ និងចិញ្ចឹមចៀមទាំងនោះជានិច្ចដែរ ព្រះអង្គជាគង្វាលដ៏សប្បុរស ជាម្ចាស់លើគង្វាលទាំងប៉ុន្មាន (យហ ១០, ១១; ១សល ៥, ៤) ព្រះអង្គបានស៊ូប្តូរជីវិត ដើម្បីចៀមរបស់ខ្លួន (យហ ១៩, ១១-១៥)។

ព្រះសហគមន៍ប្រៀបដូចស្រែចម្ការ គឺជាស្រែចម្ការរបស់ព្រះជាម្ចាស់ (១ករ ៣, ៩)។ ក្នុងចម្ការនោះមានដើមអូលីវមួយដើម ដុះឡើងតាំងពីដើមមក គឺដើមអូលីវ ដែលមានអស់លោកបុព្វបុរស ជាឫសដ៏វិសុទ្ធ។ នៅលើដើមអូលីវនោះ មានផ្សាំមែកថ្មីជាជនជាតិយូដា និងសាសន៍ដទៃ ដែលកំពុងសម្រុះសម្រួលគ្នា និងគង់តែនឹងស្រុះស្រួលគ្នាជាស្ថាពរនៅថ្ងៃណាមួយមិនខាន (រម ១១, ១៣-២៦)។ ព្រះជាម្ចាស់ ប្រៀបដូចជាម្ចាស់ចម្ការនៃស្ថានបរមសុខ ព្រះអង្គបានដាំដើមទំពាំងបាយជូរ ដែលទ្រង់បានជ្រើសរើស (មថ ២១, ៣៣-៤៣; អស ៥, ១ក)។ ដើមទំពាំងបាយជូរដ៏ពិតប្រាកដគឺព្រះគ្រីស្ត។ ព្រះអង្គប្រទានឲ្យយើងទៅជាមែក ដែលមានជីវិត និងដែលអាចបង្កើតផលផ្លែបាន។ ដោយសារព្រះសហគមន៍ យើងស្ថិតនៅក្នុងអង្គព្រះគ្រីស្ត។ បើដាច់ពីព្រះអង្គ យើងពុំអាចធ្វើអ្វីបានឡើយ (យហ ១៥, ១-៥)។

ក្នុងគម្ពីរមានចែងជាញឹកថា ព្រះសហគមន៍ជាសំណង់របស់ព្រះជាម្ចាស់ (១ករ ៣, ៩)។ ព្រះយេស៊ូជាអម្ចាស់បានប្រៀបព្រះអង្គផ្ទាល់ ទុកដូចជាថ្មដែលជាងសំណង់បោះបង់ចោល តែត្រឡប់ទៅជាថ្មគ្រឹះ ដ៏សំខាន់បំផុតវិញ (មថ ២១, ៤២; កក ៤, ១១; ១សល ២, ៧; ទន ១១៧, ២២)។ ក្រុមគ្រីស្តទូតបានសង់ព្រះសហគមន៍លើគ្រឹះនោះ (១ករ ៣, ១១) ព្រះសហគមន៍ក៏រឹងប៉ឹង និងភ្ជាប់គ្នាយ៉ាងមាំ ដោយសារគ្រឹះនោះដែរ។ សំណង់នេះមានឈ្មោះផ្សេងៗពីគ្នា គឺជាព្រះដំណាក់របស់ព្រះជាម្ចាស់ (១ធម ៣, ១៥) ដែលមានក្រុមគ្រួសាររបស់ព្រះអង្គរស់នៅក្នុងដំណាក់នោះ ជាព្រះ

ដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណ (អភ ២, ១៩-២២) ជាព្រះពន្លារបស់ព្រះជាម្ចាស់ ដែលស្ថិតនៅជាមួយមនុស្សលោក (វវ ២១, ៣) ជាពិសេស ជាព្រះវិហារដ៏វិសុទ្ធដែលមានកន្លែងគោរពបូជា សាងសង់អំពីថ្មជានិមិត្តរូប។ អស់គ្រូបាធ្យាយ តែងតែលើកតម្កើងព្រះវិហារនេះ។ ពិធីគោរពប្រណិប័តន៍នានា ក៏តែងប្រៀបផ្ទឹមយ៉ាងត្រឹមត្រូវ អំពីព្រះវិហារនោះ ទៅនឹងក្រុងដ៏វិសុទ្ធ គឺក្រុងយេរូសាឡឹមថ្មី។ យើងដែលកំពុងតែរស់នៅលើផែនដីនេះប្រៀបដូចជាថ្ម ដែលមានជីវិតផ្គុំគ្នាកសាងសំណង់ (១សល ២, ៥)។ គ្រីស្តទូតយ៉ូហាន នឹកសញ្ជឹងគិតអំពីទីក្រុងដ៏វិសុទ្ធ ដែលចុះពីស្ថានបរមសុខ មកទុកជាភរិយាថ្មោងថ្មី ដែលតុបតែងខ្លួនទទួលស្វាមី នៅពេលព្រះជាម្ចាស់ប្រែពិភពលោកជាថ្មី (វវ ២១, ១ត)។

ព្រះសហគមន៍ក៏មានឈ្មោះទៀតថា *"ទីក្រុងយេរូសាឡឹមនៅស្ថានលើ"* និង *"មាតារបស់យើង"* (កាឡ ៤, ២៦; វវ ១២, ១៧)។ គេរៀបរាប់អំពីព្រះសហគមន៍ ទុកដូចជាភរិយាដ៏និមល របស់កូនចៀមដ៏និមល (វវ ១៩, ៧; ២១, ២ និង ៩; ២២, ១៧) ជាភរិយាដែលព្រះគ្រីស្ត *"បានស្រឡាញ់ និងបូជាព្រះជន្ម ដើម្បីប្រោសឲ្យបានទៅជាវិសុទ្ធ"* (អភ ៥, ២៦) ព្រះអង្គក៏ភ្ជាប់នឹងព្រះសហគមន៍ ដោយសន្ធិសញ្ញា ដែលស្រាយមិនបានព្រះអង្គនៅតែ *"ចិញ្ចឹមបីបាច់ថែរក្សាព្រះសហគមន៍ឥតឈប់ឈរ"*។ (អភ ៥, ២៩) ព្រះអង្គលាងជម្រះព្រះសហគមន៍ឲ្យបានស្អាតបរិសុទ្ធ ហើយទ្រង់សព្វព្រះហឫទ័យឲ្យព្រះសហគមន៍ភ្ជាប់នឹងព្រះអង្គ ហើយគោរពចុះចូលនឹងព្រះអង្គដោយសេចក្ដីស្រឡាញ់ និងដោយចិត្តស្មោះត្រង់ភក្ដី (អភ ៥, ២៤)។ ព្រះអង្គប្រោសប្រទានឲ្យព្រះសហគមន៍នូវសម្បត្តិលោកខាងមុខ អស់កល្បជានិច្ច ដើម្បីឲ្យយើងអាចយល់នូវព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្តចំពោះយើង ជាព្រះហឫទ័យស្រឡាញ់ដ៏ប្រសើរហួសពីការយល់ឃើញរបស់មនុស្ស (អភ ៣, ១៩)។

ក្នុងរយៈពេល ព្រះសហគមន៍ធ្វើដំណើរក្នុងលោកនេះ ឆ្ងាយពីព្រះជាម្ចាស់ (២ករ ៥, ៦) ព្រះសហគមន៍ ចាត់ទុកខ្លួនជាជនដែលត្រូវគេនិរទេស។ ហេតុនេះហើយ បានជាព្រះសហគមន៍ស្វះស្វែងរកសម្បត្តិលោកខាងមុខ ដែលមានកប់ទុកក្នុងជម្រៅចិត្តយើង ប្រៀបដូចជាឱជារសដែលទាក់ទាញខ្លួន ទៅស្ថានដែលព្រះគ្រីស្តគង់នៅ គឺព្រះអង្គគង់នៅខាងស្ដាំព្រះបិតា។ ជីវិតព្រះសហគមន៍កប់ទុកជាមួយព្រះគ្រីស្ត ក្នុងព្រះជាម្ចាស់ទាំងរង់ចាំ ពេលខ្លួននឹងលេចចេញមក រួមជាមួយព្រះស្វាមី ប្រកបដោយសិរីរុងរឿង (កូឡ ៣, ១-៤)។

## ៧- ព្រះសហគមន៍ ជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត

ព្រះបុត្រារបស់ព្រះជាម្ចាស់ បានរំដោះមនុស្សលោក ដោយមានជ័យជម្នះលើសេចក្ដីស្លាប់ និងដោយទទួលព្រះជន្មថ្មីដ៏រុងរឿង។ ក្នុងសភាពជាមនុស្ស ដែលព្រះអង្គយកមកភ្ជាប់នឹងសភាព ជាព្រះជាម្ចាស់ ព្រះអង្គបានប្រែមនុស្ស ឲ្យកើតជាថ្មីទាំងស្រុង (កាឡ ៦, ១៥; ២ករ ៥, ១៧)។ ដោយព្រះអង្គចែករំលែកព្រះវិញ្ញាណរបស់ព្រះអង្គ ឲ្យបងប្អូនដែលព្រះអង្គប្រមែប្រមូលពីប្រជាតិជាតិទាំងឡាយ ព្រះអង្គប្រោសគេឲ្យទៅជាព្រះកាយព្រះអង្គតាមរបៀបមួយដ៏អាថ៌កំបាំង។

ព្រះគ្រីស្តបញ្ចូលព្រះជន្មរបស់ព្រះអង្គ ឲ្យសុសសាយក្នុងព្រះកាយនេះ គឺក្នុងអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ។ អគ្គសញ្ញានានា បង្រួបបង្រួមគ្រីស្តបរិស័ទ ជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក និងមានព្រះជន្មថ្មីដ៏រុងរឿង តាមរបៀបដ៏អាថ៌កំបាំងម៉្យាង ក៏ប៉ុន្តែ យ៉ាងពិតប្រាកដមែន។ ដោយអគ្គសញ្ញាជ្រមុជទឹកយើងបានដូចព្រះគ្រីស្តដែរគឺថា *"យើងទាំងអស់គ្នា បានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណតែមួយព្រះអង្គ ដើម្បីផ្សំគ្នាឡើងជាព្រះកាយតែមួយ"* (១ករ ១២, ១៣)។ ក្នុងពិធីដ៏សក្ការៈនេះ អ្នកផ្ញើជីវិតលើព្រះគ្រីស្តធ្វើសញ្ញាសម្គាល់បញ្ជាក់ថា គេរួបរួមជាមួយព្រះអង្គដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ហើយគេរួបរួមជាមួយព្រះអង្គពិតប្រាកដមែនហើយ។ *"ដោយពិធីជ្រមុជទឹក យើងរួមស្លាប់ជាមួយ*

*ព្រះអង្គ យើងក៏បានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ"* និង *"ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត យើងក៏នឹងរួមជាមួយព្រះអង្គ ដែលមានព្រះជន្មថ្មីដ៏រុងរឿងដែរ"* (រម ៦, ៤-៥)។

ពេលយើងចូលរួមក្នុងពិធីកាច់នំប៉័ង ដែលយើងយកទៅអរព្រះគុណ យើងក៏ចូលរួមក្នុងព្រះកាយរបស់ព្រះអម្ចាស់យ៉ាងពិតប្រាកដដែរ គឺព្រះអង្គប្រោសយើង ឲ្យរួបរួមជាមួយព្រះអង្គ និងឲ្យរួបរួមជាមួយគ្នាដែរ។ *"ដោយមាននំប៉័ងតែមួយប៉ុណ្ណោះ យើងទាំងអស់គ្នា ក៏រួមគ្នាជាព្រះកាយតែមួយដែរ ព្រោះយើងទាំងអស់គ្នា ទទួលចំណែកពីនំប៉័ងតែមួយនោះ"* (១ករ ១០, ១៧)។ ដូច្នេះ យើងទៅជាសរីរាង្គនៃព្រះកាយនោះ (១ករ ១២, ២៧)។ *"យើងម្នាក់ៗ ជាសរីរាង្គរបស់គ្នាទៅវិញទៅមក"* (រម ១២, ៥)។

ប៉ុន្តែ ទោះបីរូបកាយមនុស្សមានសរីរាង្គជាច្រើនយ៉ាងណាក្តី ក៏សរីរាង្គទាំងនោះ ផ្សំគ្នាជារូបកាយតែមួយដែរ។ ចំពោះអ្នកផ្ញើជីវិតលើព្រះគ្រីស្តក៏ដូច្នោះដែរ (១ករ ១២, ១២) ទោះបីមានសរីរាង្គ និងអវយវៈដែលមានមុខងារផ្សេងៗជាច្រើនក្តី ក៏គេផ្តុំគ្នាកសាងព្រះកាយព្រះគ្រីស្តតែមួយដែរ។ មានព្រះវិញ្ញាណតែមួយព្រះអង្គ ដែលចែកអំណោយទានផ្សេងៗពីគ្នា ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍តាមព្រះហឫទ័យទូលំទូលាយរបស់ព្រះអង្គ និងតាមសេចក្តីត្រូវការនៃកិច្ចបម្រើទាំងឡាយ (១ករ ១២, ១-១១)។ ក្នុងចំណោមព្រះអំណោយទានទាំងនោះ ព្រះវិញ្ញាណប្រណីសន្តោសប្រទានមុខងារជាគ្រីស្តទូត ជាព្រះអំណោយទានដ៏ប្រសើរជាងគេ សូម្បីតែអ្នកទទួលព្រះអំណោយទានផ្សេងៗក្តី ក៏ព្រះវិញ្ញាណឲ្យគេចុះចូល ក្រោមអំណាចរបស់គ្រីស្តទូតដែរ (១ករ ១៤)។ ព្រះវិញ្ញាណដដែលនោះ ធ្វើឲ្យព្រះកាយ រួមជាអង្គតែមួយ ដោយអានុភាពរបស់ព្រះអង្គ។ ព្រះអង្គធ្វើឲ្យសរីរាង្គ មានទំនាក់ទំនងជាមួយគ្នាពីខាងក្នុង ព្រះអង្គក៏បង្កើតនិងពង្រឹងសេចក្តីស្រឡាញ់ រវាងគ្រីស្តបរិស័ទដូចគ្នា។ ដូច្នេះ ប្រសិនបើមានសរីរាង្គណាមួយរងទុក្ខលំបាក សរីរាង្គទាំងអស់ក៏រងទុក្ខលំបាកជាមួយដែរ ប្រសិនបើមានសរីរាង្គណាមួយ បានទទួលកិត្តិយស សរីរាង្គទាំងអស់ក៏ទទួលកិត្តិយសជាមួយដែរ (១ករ ១២, ២៦)។

ព្រះគ្រីស្តជាសិរសានៃរូបកាយនេះ។ ព្រះអង្គជារូបតំណាងនៃព្រះជាម្ចាស់ ដែលមនុស្សមើលពុំឃើញ ហើយព្រះជាម្ចាស់ក៏បានប្រតិស្ឋានអ្វីៗសព្វសារពើ ក្នុងអង្គព្រះគ្រីស្តដែរ។ ព្រះគ្រីស្តមានព្រះជន្មមុនអ្វីៗទាំងអស់ ហើយអ្វីៗទាំងអស់ ក៏នៅស្ថិតស្ថេររួមគ្នាដោយសារព្រះអង្គដែរ។ ព្រះអង្គជាសិរសានៃព្រះកាយ ពោលគឺព្រះសហគមន៍។ ព្រះអង្គជាដើមកំណើតនៃអ្វីៗទាំងអស់។ ក្នុងចំណោមមនុស្សស្លាប់ទាំងអស់ ព្រះអង្គមានព្រះជន្មថ្មីដ៏រុងរឿងមុនគេ ដើម្បីធ្វើជាប្រមុខក្នុងគ្រប់វិស័យទាំងអស់ (កូឡ ១, ១៥-១៨)។ មហិទ្ធិឫទ្ធិរបស់ព្រះគ្រីស្ត ផ្តល់ឲ្យព្រះអង្គគ្រប់គ្រងលើអ្វីៗ ដែលនៅលើមេឃ និងនៅលើផែនដី។ ដោយព្រះអង្គពេញលក្ខណៈ និងមានសកម្មភាពដ៏ខ្លាំងក្លាក្នុងឋានៈជាព្រះអម្ចាស់ ព្រះអង្គប្រទានគ្រប់លក្ខណសម្បត្តិនៃសិរីរុងរឿងរបស់ព្រះអង្គ ដល់ព្រះកាយទាំងមូល (អភ ១, ១៨-២៣)។

សរីរាង្គទាំងអស់ ត្រូវខិតខំឲ្យបានដូចព្រះគ្រីស្ត រហូតទាល់តែព្រះគ្រីស្តបានកើតជារូបរាងឡើងក្នុងគេ (កាឡ ៤, ១៩)។ ហេតុនេះហើយ បានជាព្រះជាម្ចាស់ បានប្រោសយើងឲ្យចូលក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះជន្មរបស់ព្រះគ្រីស្ត គឺយើងបានដូចព្រះគ្រីស្តរួមជាមួយព្រះអង្គ ដែលសោយទិវង្គត ហើយក៏រួមជាមួយព្រះអង្គ ដែលមានព្រះជន្មថ្មីដ៏រុងរឿងទាំងរង់ចាំឲ្យបានរួមជាមួយព្រះអង្គដែលសោយរាជ្យផងដែរ (ភល ៣, ២១; ២ធម ២, ១១; អភ ២, ៦; កូឡ ២, ១២។ល។ យើងដែលនៅតែធ្វើបូជនីយេសក៍នៅលើផែនដីនេះ ក៏ត្រូវដាក់ជើងតាមស្នាមព្រះបាទារបស់ព្រះអង្គដែរ។ ពេលយើងត្រូវរងទុក្ខលំបាក និងត្រូវគេបៀតបៀន យើងរួមជាមួយព្រះអង្គដែលរងទុក្ខលំបាកដូចដងខ្លួនរួមជាមួយក្បាល គឺយើងរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក ដើម្បីឲ្យបានរួមជាមួយព្រះអង្គ ប្រកបដោយសិរីរុងរឿងដែរ (រម ៨, ១៧)។

ព្រះគ្រីស្ត *"ផ្គត់ផ្គង់ឲ្យព្រះកាយទាំងមូលមានអាហារ និងភ្ជាប់គ្នាដោយសន្លាក់ឆ្អឹង និងសរសៃព្រមទាំងធ្វើឲ្យរូបកាយចម្រើនឡើងក្នុងព្រះជាម្ចាស់"* (កូឡ ២, ១៩)។ ព្រះអង្គ នៅតែចាត់ចែងព្រះអំណោយទានជានិច្ច ជាមុខងារបម្រើព្រះកាយព្រះអង្គ គឺព្រះសហគមន៍។ តាមព្រះអំណោយទាននៃមុខងារបម្រើទាំងនោះ និងតាមអានុភាពរបស់ព្រះអង្គផង យើងជួយបម្រើគ្នាទៅវិញទៅមក តាមសេចក្តីត្រូវការ ដើម្បីឲ្យយើងទទួលការសង្គ្រោះ។ ដោយយើងមានចិត្តស្មោះ ស្រឡាញ់គ្នាទៅវិញទៅមក *"យើងនឹងអាចចម្រើនឡើងគ្រប់វិស័យទាំងអស់ ឆ្ពោះទៅកាន់ព្រះគ្រីស្តជាសិរសា"* (អភ ៤, ១១-១៦)។

ព្រះគ្រីស្តប្រទានព្រះវិញ្ញាណរបស់ព្រះអង្គឲ្យយើង ដើម្បីឲ្យយើងអាចប្រែខ្លួនឲ្យបានជាថ្មី ឥតឈប់ឈរក្នុងព្រះអង្គ។ មានព្រះវិញ្ញាណតែមួយដដែល ក្នុងព្រះសិរសា និងក្នុងសរីរាង្គទាំងប៉ុន្មាន ព្រះអង្គផ្តល់ជីវិតដល់ព្រះកាយទាំងមូល ទ្រង់ប្រោសឲ្យព្រះកាយភ្ជាប់គ្នា និងកម្រើកឡើងបាន។ ហេតុនេះហើយ បានជាគ្រូបាធ្យាយដ៏វិសុទ្ធ តែងតែប្រៀបធៀបសកម្មភាពរបស់ព្រះវិញ្ញាណនោះ ទៅនឹងដើមកំណើតនៃជីវិត គឺវិញ្ញាណក្នុងរូបកាយមនុស្ស។

ព្រះគ្រីស្តស្រឡាញ់ព្រះសហគមន៍ ក្នុងឋានៈជាព្រះមហេសី និងតាំងព្រះអង្គទុកជាស្វាមីគំរូ ដែលស្រឡាញ់ភរិយាដូចស្រឡាញ់រូបកាយរបស់ខ្លួនផ្ទាល់ (អភ ៥, ២៥-២៨)។ រីឯព្រះសហគមន៍ គោរពចុះចូលនឹងព្រះគ្រីស្តជាម្ចាស់របស់ខ្លួន (អភ ៥, ២៣.២៤)។ *"ដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ស្ថិតនៅពោរពេញក្នុងរូបកាយព្រះគ្រីស្ត"* (កូឡ ២, ៩) ព្រះអង្គបំពេញព្រះសហគមន៍ជាព្រះកាយ ដោយព្រះអំណោយទាន និងដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ (អភ ១, ២២-២៣) ដើម្បីឲ្យព្រះសហគមន៍បានពោរពេញ ដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ (អភ ៣, ១៩)។

## ៨- ព្រះសហគមន៍មានរូបរាង ដែលមើលឃើញ និងមានលក្ខណៈជាវិញ្ញាណ ដែលមើលមិនឃើញ

ព្រះគ្រីស្តជាស្ពានមេត្រីតែមួយ ព្រះអង្គគត់ព្រះអង្គបង្កើត និងនៅតែទ្រទ្រង់ព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះអង្គនៅលើផែនដីជានិច្ច ជាក្រុមដែលមនុស្សលោកមើលឃើញបាន។ ព្រះសហគមន៍ជាសហគមន៍របស់មនុស្ស ដែលមានជំនឿមានសេចក្តីសង្ឃឹម និងមានសេចក្តីស្រឡាញ់។ ព្រះគ្រីស្តផ្សព្វផ្សាយសេចក្តីពិត និងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ តាមរយៈព្រះសហគមន៍ ដើម្បីជាប្រយោជន៍ ដល់មនុស្សទាំងអស់។ ព្រះសហគមន៍ជាសង្គមមួយ ដែលមានរចនាសម្ព័ន្ធតាមលំដាប់លំដោយ និងជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តផងដែរ ជាក្រុមដែលគេអាចមើលឃើញបានផង និងជាសហគមន៍ខាងវិញ្ញាណដែលមើលមិនឃើញផង (អំណរ ៤០)។ មិនត្រូវយល់ថា ព្រះសហគមន៍នៅលើផែនដីនេះ និងព្រះសហគមន៍ ប្រកបដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានបរមសុខ ជាព្រះសហគមន៍ពីរទេ ប៉ុន្តែត្រូវយល់ថា ជាព្រះសហគមន៍តែមួយរួមគ្នាជាអង្គតែមួយ ដែលមានផ្នែកជាច្រើន គឺមានសភាពជាមនុស្សផង និងមានសភាពជាព្រះជាម្ចាស់ផង។ ហេតុនេះហើយ បានជាយើងធ្លាប់ប្រៀបធៀបព្រះសហគមន៍ ទៅនឹងគម្រោងការដ៏អស្ចារ្យរបស់ព្រះបន្ទូល ដែលប្រសូតជាមនុស្ស។ ការប្រៀបធៀបនេះ មានប្រយោជន៍សម្រាប់ពន្យល់លក្ខណៈរបស់ព្រះសហគមន៍គឺថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យកសភាពជាមនុស្សមកភ្ជាប់នឹងព្រះអង្គជាច់ចេញមិនបាន ហើយមកបម្រើព្រះអង្គ ទុកជាគ្រឿងមានជីវិតសម្រាប់សង្គ្រោះមនុស្សលោក។ តាមបែបដដែលនេះ អ្វីៗដែលមានលក្ខណៈជាសង្គម ក្នុងព្រះសហគមន៍ ក៏សុទ្ធតែបម្រើព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ដែលផ្តល់ជីវិតដល់ព្រះសហគមន៍ ដើម្បីឲ្យព្រះកាយចម្រើនឡើង (អភ ៤, ១៦)។

នេះជាព្រះសហគមន៍តែមួយរបស់ព្រះគ្រីស្ត។ ក្នុងធម៌ប្រកាសជំនឿយើងតែងតែប្រកាសថា ព្រះសហគមន៍មានតែមួយដ៏វិសុទ្ធសកល និងមានជំនឿស្របតាមក្រុមគ្រីស្តទូត។ ក្រោយពីព្រះយេស៊ូ ជាព្រះសង្គ្រោះមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គបានប្រគល់ព្រះសហគមន៍នេះ ឲ្យលោកសិលាឃ្វាលថែទាំ (យហ ២១, ១៧)។ ព្រះអង្គក៏ផ្តាំផ្ញើឲ្យលោក និងឲ្យគ្រីស្តទូតឯទៀតៗផ្សព្វផ្សាយ និងគ្រប់គ្រងដែរ (មថ ២៨, ១៨ត)។ ព្រះអង្គតែងតាំងព្រះសហគមន៍នេះទុកជា *"សសរ និងជាគ្រឹះទ្រទ្រង់សេចក្តីពិត"* (១ធម ៣, ១៥)។ ព្រះសហគមន៍បែបនេះ តែងតាំងទុកជាសង្គមម៉្យាង ក្នុងលោកនេះ ដោយមានរបៀបរៀបរយ គឺពិតជាព្រះសហគមន៍កាតូលិក ដែលមានអភិបាលព្រះសហគមន៍ក្រុងរ៉ូម គ្រប់គ្រងក្នុងឋានៈជាអ្នកបន្តមុខងារពីគ្រីស្តទូតសិលាមក និងដែលមានអស់លោកអភិបាល គ្រប់គ្រងរួបរួមជាមួយលោកដែរ។ ទោះបីនៅខាងក្រៅរចនាសម្ពន្ធ នៃព្រះសហគមន៍មានកត្តាជាច្រើនអាចនាំឲ្យមនុស្សបានវិសុទ្ធ និងឲ្យស្គាល់សេចក្តីពិតក្តី ក៏កត្តាទាំងនោះ ជាកម្មសិទ្ធិនៃព្រះសហគមន៍របស់ព្រះគ្រីស្ត តាមព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែរ។ កត្តាទាំងនោះដាស់តឿនមនុស្សលោក ឲ្យរួបរួមគ្នាជាធ្លុងតែមួយ ក្នុងព្រះសហគមន៍កាតូលិក។

ប៉ុន្តែ ព្រះគ្រីស្តបានរំដោះមនុស្សលោក ដោយព្រះអង្គរស់នៅជាអ្នកក្រីក្រ និងដោយត្រូវគេបៀតបៀនយ៉ាងណា ព្រះជាម្ចាស់ក៏ត្រាស់ហៅព្រះសហគមន៍ ឲ្យរស់នៅតាមផ្លូវនេះដែរ គឺរស់នៅជាអ្នកក្រីក្រ និងត្រូវគេបៀតបៀនយ៉ាងនោះដែរ ដើម្បីចែករំលែកផលនៃការសង្គ្រោះឲ្យមនុស្សលោក។ *"ព្រះគ្រីស្តយេស៊ូ ដែលមានសភាពជាព្រះជាម្ចាស់បានលះបង់អ្វីៗទាំងអស់ មកយកសភាពជាទាសករវិញ"* (ភល ២, ៦) *"ព្រះអង្គដែលមានសម្បត្តិដ៏ច្រើន ទ្រង់ដាក់ខ្លួនជាអ្នកក្រីក្រ"* ព្រោះតែយើង (២ករ ៨, ៩)។ ហេតុនេះហើយ ទោះបីព្រះសហគមន៍ត្រូវការធនធានមនុស្ស ដើម្បីបំពេញបេសកកម្មរបស់ខ្លួនក្តី ក៏ព្រះសហគមន៍មិនកើតមក ដើម្បីស្វែងរកមុខមាត់ក្នុងលោកនេះទេ តែដើម្បីបញ្ជាំងឲ្យមនុស្សលោកស្គាល់តម្លៃនៃចិត្តសុភាពរាបសា និងនៃការលះបង់ ដោយធ្វើជាគំរូឲ្យគេឃើញ។ ព្រះបិតាចាត់ព្រះគ្រីស្តឲ្យយាងមកនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ ព្យាបាលអស់អ្នកមានចិត្តក្រៀមក្រំ (លក ៤, ១៨)។ "ស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់" (លក ១៩, ១០)។ ព្រះសហគមន៍ក៏មានចិត្តមេត្តាករុណា ចំពោះអស់អ្នកដែលរងទុក្ខ ដោយភាពទន់ខ្សោយរបស់ខ្លួនជាមនុស្សដែរ។ លើសពីនេះទៅទៀត ពេលព្រះសហគមន៍ឃើញអ្នកក្រីក្រ និងអ្នកកើតទុក្ខ ព្រះសហគមន៍ក៏ទទួលស្គាល់ព្រះភ័ក្ត្ររបស់ព្រះយេស៊ូជាអ្នកក្រីក្រ និងជាអ្នករងទុក្ខលំបាក ដែលបានបង្កើតព្រះសហគមន៍នោះដែរ។ ព្រះសហគមន៍ក៏ខិតខំជួយសម្រាលទុក្ខគេ ព្រោះព្រះសហគមន៍ចង់បម្រើព្រះគ្រីស្តក្នុងគេ។ ព្រះគ្រីស្តជាអ្នកដ៏វិសុទ្ធឥតសៅហ្មង គ្មានទោសអ្វីឡើយ (ហប ៧, ២៦) ព្រះអង្គមិនដែលប្រព្រឹត្តអំពើបាបណាសោះឡើយ (២ករ ៥, ២១) ព្រះអង្គយាងមករំដោះប្រជាជនឲ្យបានរួចពីបាប (ហប ២, ១៧)។ ព្រះសហគមន៍ក៏ដូច្នេះដែរ ទោះបីមានអ្នកបាបនៅក្នុងផ្ទៃក្តី ក៏ព្រះសហគមន៍នៅតែវិសុទ្ធ និងត្រូវជម្រះខ្លួនជានិច្ច ហើយនៅតែបន្តខិតខំប្រែចិត្តគំនិត និងឲ្យបានជាថ្មីជានិច្ចដែរ។ *"ព្រះសហគមន៍ធ្វើបូជនីយេសក៏ដោយ ត្រូវគេបៀតបៀនធ្វើបាបក្នុងលោកនេះ និងដោយមានព្រះជាម្ចាស់លួងលោមផង"* (សន្តៈ អូគូស្តាំង) ទាំងប្រកាសថា ព្រះអម្ចាស់សោយទិវង្គតនៅលើឈើឆ្កាង គឺប្រកាសសេចក្តីនេះ រហូតដល់ពេលព្រះអង្គយាងមក (១ករ ១១, ២៦)។

ឫទ្ធានុភាពរបស់ព្រះអម្ចាស់ ដែលមានព្រះជន្មថ្មីដ៏រុងរឿង ជាកម្លាំងរបស់ព្រះសហគមន៍ដើម្បីឲ្យព្រះសហគមន៍មានចិត្តអត់ធ្មត់ ខន្តី និងចិត្តស្រឡាញ់អាចពុះពារទុក្ខលំបាក និងឧបសគ្គនានា មកពីខាងក្នុងផង និងមកពីខាងក្រៅផង។ ព្រះសហគមន៍អាចសម្តែងយ៉ាងស្មោះ នៅកណ្តាលចំណោមមនុស្សលោក អំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ដែលយើងមិនទាន់ស្គាល់យ៉ាងច្បាស់នៅឡើយ រហូតដល់ថ្ងៃគម្រោងការដ៏អស្ចារ្យនេះលេចធ្លោក្នុងពន្លឺយ៉ាងច្បាស់។

# ជំពូក ២

## ប្រជារាស្ត្ររបស់ព្រះជាម្ចាស់

### ៩- សម្ពន្ធមេត្រីថ្មីនិងប្រជារាស្ត្រថ្មី

នៅគ្រប់សម័យ ក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយ ឲ្យតែគោរពកោតខ្លាចព្រះជាម្ចាស់ ហើយប្រព្រឹត្តអំពើសុចរិត ព្រះអង្គក៏គាប់ព្រះហឫទ័យនឹងអ្នកនោះដែរ (កក ១០, ៣៥)។ ក៏ប៉ុន្តែ ព្រះជាម្ចាស់សព្វព្រះហឫទ័យតែងតាំងឲ្យមនុស្សទៅជាប្រជារាស្ត្រមួយ ដែលនឹងស្គាល់ព្រះអង្គតាមសេចក្តីពិត និងបម្រើព្រះអង្គយ៉ាងវិសុទ្ធ ព្រះអង្គមិនសព្វព្រះហឫទ័យ ប្រោសឲ្យមនុស្សបានវិសុទ្ធ និងសង្គ្រោះគេម្នាក់ៗ ដោយគេគ្មានចំណងទាក់ទងជាមួយអ្នកដទៃទៅវិញទៅមកនោះទេ (អំណរ ៣២)។ ហេតុនេះហើយ បានជាព្រះអង្គបានជ្រើសរើសប្រជាជនអ៊ីស្រាអែល និងចងសម្ពន្ធមេត្រីជាមួយគេ ឲ្យទៅជាប្រជារាស្ត្រផ្ទាល់របស់ព្រះអង្គ។ ព្រះអង្គបានបង្រៀនគេបន្តិចម្តងៗ គឺសម្តែងឲ្យគេស្គាល់ព្រះអង្គផ្ទាល់ ស្គាល់គម្រោងការរបស់ព្រះអង្គតាមប្រវត្តិសាស្ត្រប្រជាជននេះ និងដោយញែកគេឲ្យបានទៅជាកម្មសិទ្ធិដ៏សក្ការៈរបស់ព្រះអង្គ។ ហេតុការណ៍ទាំងប៉ុន្មាននោះ គ្រាន់តែរៀបចំផ្លូវជូនសម្ពន្ធមេត្រីថ្មី និងជាប្រផ្នូលនៃសម្ពន្ធមេត្រីថ្មីនោះ ដែលជាសម្ពន្ធមេត្រីដ៏ពេញលក្ខណៈចងក្នុងអង្គព្រះគ្រីស្ត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់ ដែលប្រសូតជាមនុស្ស បានសម្តែងឲ្យមនុស្សស្គាល់ព្រះអង្គយ៉ាងច្បាស់ជាងពីមុន។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ *"នៅគ្រាខាងមុខ យើងនឹងចងសម្ពន្ធមេត្រីថ្មីជាមួយប្រជាជនអ៊ីស្រាអែល និងប្រជាជនយូដា"* យើងនឹងដាក់ធម្មវិន័យរបស់យើងនៅក្នុងជម្រៅចិត្តរបស់គេ ហើយចារវិន័យនោះ ក្នុងចិត្តគំនិតរបស់គេ។ ពេលនោះ យើងនឹងធ្វើជាព្រះរបស់គេ គេក៏នឹងធ្វើជាប្រជារាស្ត្ររបស់យើង។ តាំងពីអ្នកតូចបំផុត រហូតដល់អ្នកធំបំផុត គេនឹងស្គាល់យើងគ្រប់ៗគ្នា (យរ ៣១, ៣១-៣៤)។ ព្រះគ្រីស្ត បានចងសម្ពន្ធមេត្រីថ្មីនេះ ហើយគឺជាសម្ពន្ធមេត្រីថ្មី ចងឡើងដោយព្រះលោហិតព្រះអង្គ (១ករ ១១, ២៥)។ ព្រះអង្គត្រាស់ហៅ មនុស្សទាំងអស់ពីក្នុងចំណោមសាសន៍យូដាផង និងពីក្នុងចំណោមសាសន៍ដទៃផងឲ្យរួមគ្នា ជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ មិនមែនជាប្រជារាស្ត្រតាមសាច់ឈាមទេ តែជាប្រជារាស្ត្រក្នុងព្រះវិញ្ញាណវិញ។ អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តបានកើតជាថ្មី មិនមែនដោយពូជដែលតែងតែរលួយទេ តែដោយពូជដែលមិនចេះរលួយ គឺពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ (១សល ១, ២៣)។ គេមិនកើតពីសាច់ឈាមទេ តែគេកើតពីទឹក និងពីព្រះវិញ្ញាណដ៏វិសុទ្ធវិញ (យហ ៣, ៥-៦) គេនឹងទៅជា *"ពូជសាសន៍ ដែលព្រះជាម្ចាស់បានជ្រើសរើសជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះអង្គបានយកមកធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ។ ពីដើមគេមិនមែនជាប្រជារាស្ត្ររបស់ព្រះអង្គទេ តែឥឡូវនេះ គេជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ហើយ"* (១សល ២, ៩-១០)។

ព្រះគ្រីស្ត ជាសិរសា គឺជាមេដឹកនាំរបស់ប្រជាជននៃពេលចុងក្រោយនោះ *"ព្រះអង្គត្រូវគេបញ្ជូនទៅឲ្យគេធ្វើគុត ព្រោះតែអំពើបាបរបស់យើង ហើយព្រះជាម្ចាស់ ប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មីដ៏រុងរឿង ដើម្បីឲ្យយើងបានសុចរិត"* (រម ៤, ២៥)។ ព្រះអង្គមានព្រះនាមដ៏ប្រសើរលើសនាមឯទៀតៗទាំងអស់ និងសោយរាជ្យ ប្រកបដោយសិរីរុងរឿងនៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត។ ប្រជាជននោះ មានលក្ខណៈពិសេស គឺមានកិត្តិយសដ៏ថ្លៃថ្នូរ និងសេរីភាពក្នុងឋានៈជាបុត្រធីតារបស់

ព្រះជាម្ចាស់ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងចិត្តគេ ដូចជាគង់នៅក្នុងព្រះវិហារមួយដែរ។ ធម្មវិន័យនៃប្រជាជននោះ ជាវិន័យថ្មីរបស់ព្រះយេស៊ូពោលគឺ ត្រូវស្រឡាញ់គ្នា ដូចព្រះគ្រីស្តបានស្រឡាញ់យើងដែរ (យហ ១៣, ៣៤)។ ប្រជាជននោះ មានទិសដៅតែមួយគឺ ឲ្យព្រះជាម្ចាស់គ្រងរាជ្យលើគេដូចព្រះអង្គផ្ទាល់ ចាប់ផ្តើមគ្រងរាជ្យនៅលើផែនដីនេះ ព្រះរាជ្យនេះ ត្រូវលាតសន្ធឹងឲ្យបានកាន់តែឆ្ងាយទៅៗ រហូតដល់អវសានកាលនៃពិភពលោក។ នៅពេលនោះ ព្រះជាម្ចាស់នឹងគ្រងរាជ្យយ៉ាងពេញលក្ខណៈគឺ នៅពេលព្រះគ្រីស្ត ដែលជាជីវិតរបស់យើងនឹងលេចចេញមកប្រកបដោយសិរីរុងរឿង (កូឡ ៣, ៤) នៅពេលព្រះអង្គរំដោះសត្វលោក ឲ្យរួចផុតពីធ្វើជាទាសករនៃសេចក្តីរលួយ ហើយបែរជាមានសេរីភាពដ៏រុងរឿង នៃបុត្រធីតារបស់ព្រះជាម្ចាស់ (រម ៨, ២១)។ ហេតុនេះហើយ បានជាប្រជាជននៃពេលចុងក្រោយនោះ ទោះបីមនុស្សទាំងអស់មិនទាន់បានចូលរួមក្រោមអំណាចនៃព្រះរាជ្យនេះនៅឡើយក្តី និងមានសភាពជាហ្វូងចៀមដ៏តូចមួយក្តី ក៏ជាពូជដ៏មានកម្លាំងខ្លាំងជាងគេ អាចធ្វើឲ្យមនុស្សជាតិរួបរួមគ្នា មានសេចក្តីសង្ឃឹម និងអាចទទួលការសង្គ្រោះបានផងដែរ។ ព្រះគ្រីស្តបានតែងតាំងព្រះរាជ្យនេះ ដើម្បីឲ្យមនុស្សលោករួបរួមគ្នា ដោយមានជីវិតដោយមានសេចក្តីស្រឡាញ់ និងដោយស្គាល់សេចក្តីពិត។ ព្រះគ្រីស្តក៏យកព្រះរាជ្យនេះធ្វើជាមធ្យោបាយ សម្រាប់រំដោះមនុស្សទាំងអស់ ព្រោះព្រះបិតាបានចាត់ព្រះរាជ្យនេះ ទៅមនុស្សលោកទាំងអស់ឲ្យទៅជាពន្លឺបំភ្លឺពិភពលោក និងទៅជាអំបិលនៃផែនដី (មថ ៥, ១៣-១៦)។

កាលពីមុន នៅពេលប្រជាជនអ៊ីស្រាអែលធ្វើដំណើរក្នុងវាលរហោស្ថាន គេទទួលនាមថា ជា *"ព្រះសហគមន៍របស់ព្រះជាម្ចាស់"* (២អរ ១៣, ១; ជរ ២០, ៤; ទក ២៣, ១ត)។ ប្រជាជនអ៊ីស្រាអែលថ្មី កំពុងធ្វើដំណើរក្នុងលោកនាបច្ចុប្បន្ននេះ ទាំងសង្វាត ស្វែងរកបុរីនៃលោកខាងមុខគឺ បុរីដែលស្ថិតស្ថេរគង់វង្សរហូត (ហប ១៣, ១៤) ក៏មានឈ្មោះថា *"ព្រះសហគមន៍របស់ព្រះគ្រីស្ត"* ដែរ (មថ ១៦, ១៨)។ គឺព្រះគ្រីស្តនេះហើយ ដែលបានរំដោះព្រះសហគមន៍មកធ្វើជាកម្មសិទ្ធិ ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់ (កក ២០, ២៨) ព្រះអង្គបានចាក់បង្ហូរព្រះវិញ្ញាណព្រះអង្គលើព្រះសហគមន៍ ឲ្យបានពេញបរិបូណ៌ និងប្រទានមធ្យោបាយគ្រប់គ្រាន់ ឲ្យព្រះសហគមន៍អាចរួបរួមគ្នា និងជាសង្គម ដែលមើលឃើញបាន (អំណរ ៤០)។ ព្រះជាម្ចាស់ត្រាស់ហៅ ក្រុមអស់អ្នកដែលសម្លឹងមើលព្រះយេស៊ូ ទាំងផ្ញើជីវិតលើព្រះអង្គគឺ ព្រះយេស៊ូដែលសង្គ្រោះមនុស្សលោក ហើយប្រមែប្រមូលគេឲ្យរួបរួមគ្នាជាធ្លុងតែមួយ និងប្រទានសេចក្តីសុខសាន្ត។ ព្រះអង្គបានតែងតាំងគេជាព្រះសហគមន៍ ដែលជាអគ្គសញ្ញាឲ្យមនុស្សម្នាក់ៗ និងឲ្យមនុស្សទាំងអស់ឃើញថា គេអាចទទួលការសង្គ្រោះ ដោយរួបរួមគ្នាជាធ្លុងតែមួយបាន។ ព្រះជាម្ចាស់បម្រុងទុកព្រះសហគមន៍ ឲ្យលាតសន្ធឹងក្នុងពិភពលោកទាំងមូល។ ទោះបីព្រះសហគមន៍មិនជាប់នឹងប្រជាជនណាមួយ និងមិនជាប់នឹងសម័យណាមួយ ហើយក៏មិនជាប់នឹងទឹកដីណាមួយក្តី ក៏ព្រះសហគមន៍ស្ថិតនៅជាប់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិដែរ។ ព្រះសហគមន៍ ធ្វើដំណើរ ទាំងជួបការល្បួង ទាំងប្រឈមមុខនឹងទុក្ខវេទនា តែឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ប្រកបដោយព្រះហឫទ័យប្រណីសន្តោស ទ្រទ្រង់ព្រះសហគមន៍ជានិច្ច តាមព្រះបន្ទូលសន្យារបស់ព្រះអម្ចាស់។ ព្រះអង្គទ្រទ្រង់ដូច្នេះ ក្រែងព្រះសហគមន៍ ដែលមានភាពទន់ខ្សោយ លែងមានចិត្តស្មោះត្រង់ និងឃ្លាតពីសេចក្តីពេញលក្ខណៈ។ ព្រះអង្គប្រោសព្រះសហគមន៍ ឲ្យនៅតែជាព្រះមហេសីដ៏ថ្លៃថ្នូរនៃព្រះអម្ចាស់របស់ខ្លួន ហើយប្រែខ្លួនជាថ្មីឥតឈប់ឈរ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ជួយឧបត្ថម្ភរហូតដល់ទៅកាន់ពន្លឺ ដែលមិនចេះរលត់ ក្រោយពីបានរងទុក្ខនៅលើឈើឆ្កាង។

## ១០- គ្រីស្តបរិស័ទរួមគ្នាជាបូជាចារ្យ

ព្រះគ្រីស្តជាអម្ចាស់ ជាមហាបូជាចារ្យ ជ្រើសរើសពីចំណោមមនុស្ស (ហប ៥, ១-៥) បានលើកប្រជារាស្ត្រថ្មីនោះ

ឲ្យធ្វើជា *"រាជាណាចក្រមួយ និងជាក្រុមបូជាចារ្យបម្រើព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះអង្គ"* (វវ ១, ៦; ៥, ៩-១០)។ អស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក បានកើតជាថ្មី និងទទួលពិធីអភិសេកពីព្រះវិញ្ញាណដ៏វិសុទ្ធពួកគេ ញែកខ្លួនថ្វាយព្រះជាម្ចាស់ ដើម្បីទៅជាព្រះដំណាក់ខាងព្រះវិញ្ញាណ និងទៅជាក្រុមបូជាចារ្យដ៏វិសុទ្ធ ហើយថ្វាយកិច្ចការទាំងប៉ុន្មានដែលគេធ្វើជារៀងរាល់ថ្ងៃទៅព្រះជាម្ចាស់ ទុកជាសក្ការបូជាខាងព្រះវិញ្ញាណ។ គេក៏ប្រកាសអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ ដែលត្រាស់ហៅគេ ឲ្យចេញពីភាពងងឹតមកកាន់ពន្លឺដ៏រុងរឿងរបស់ព្រះអង្គ (១សល ២, ៤-១០)។ ហេតុនេះហើយ បានជាអស់សាវ័ករបស់ព្រះគ្រីស្តព្យាយាមអធិដ្ឋាន និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (កក ២, ៤២-៤៧) គេត្រូវថ្វាយខ្លួនទុកជាយញ្ញ ដែលមានជីវិតជាយញ្ញដ៏វិសុទ្ធ ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ (រម ១២, ១)។ គេក៏ត្រូវផ្តល់សក្ខីភាព អំពីព្រះគ្រីស្តនៅលើផែនដីទាំងមូល ហើយប្រុងប្រៀបខ្លួន ឆ្លើយតទល់នឹងអស់អ្នក ដែលសួរ អំពីសេចក្តីសង្ឃឹមរបស់ខ្លួនជានិច្ចថា គេនឹងបានទទួលជីវិតអស់កល្បជានិច្ច (១សល ៣, ១៥)។

គ្រីស្តបរិស័ទទាំងអស់ មានឋានៈជាបូជាចារ្យរួម។ តែមានគ្រីស្តបរិស័ទខ្លះ មានមុខងារជាបូជាចារ្យបម្រើព្រះសហគមន៍ ឬមុខងារតាមលំដាប់លំដោយ។ ទោះបីឋានៈជាបូជាចារ្យទាំងពីរនោះ ប្លែកពីគ្នាទាំងស្រុងក្តី មិនគ្រាន់តែមានកម្រិតប្លែកពីគ្នាប៉ុណ្ណោះទេ ក៏ឋានៈជាបូជាចារ្យទាំងពីរបែបនោះ ជាប់ទាក់ទិនគ្នាដែរ គឺឋានៈទាំងពីរទទួលចំណែកពីមុខងាររបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យតែមួយព្រះអង្គគត់តាមរបៀបរៀងៗខ្លួន។ គ្រីស្តបរិស័ទដែលបានទទួលមុខងារ ជាបូជាចារ្យបម្រើព្រះសហគមន៍ មានអំណាចដ៏សក្ការៈ ដើម្បីអប់រំ និងណែនាំប្រជារាស្ត្រដែលសុទ្ធតែជាបូជាចារ្យ។ អស់លោកជាតួរបស់ព្រះគ្រីស្ត ថ្វាយសក្ការបូជាអរព្រះគុណព្រះជាម្ចាស់ ក្នុងនាមប្រជាជនទាំងមូល។ រីឯគ្រីស្តបរិស័ទធម្មតាវិញ ជាបូជាចារ្យរបស់ព្រះមហាក្សត្រ ក៏ចូលរួមក្នុងសក្ការបូជាអរព្រះគុណនោះដែរ។ គេក៏ប្រតិបត្តិតាមឋានៈរបស់ខ្លួន ជាបូជាចារ្យ ដោយទទួលអគ្គសញ្ញានានា ដោយអធិដ្ឋាន ដោយអរព្រះគុណ ដោយរស់នៅយ៉ាងវិសុទ្ធ ទុកជាសក្ខីភាព ដោយលះបង់ និងដោយប្រព្រឹត្តតាមសេចក្តីស្រឡាញ់យ៉ាងសកម្មដែរ។

## ១១- គ្រីស្តបរិស័ទ ប្រតិបត្តិតាមឋានៈរបស់ខ្លួនជាបូជាចារ្យរួមនៅពេលទទួលអគ្គសញ្ញានានា

សហគមន៍ ដែលសុទ្ធតែជាបូជាចារ្យ បង្ហាញលក្ខណៈដ៏សក្ការៈរបស់ខ្លួន តាមរចនាសម្ពន្ធដ៏មានរបៀបរៀបរយនៅពេលគេទទួលអគ្គសញ្ញា និងរស់នៅតាមព្រហ្មវិហារធម៌។ គ្រីស្តបរិស័ទចូលរួមក្នុង ព្រះសហគមន៍ ដោយអគ្គសញ្ញាជ្រមុជទឹក។ នៅពេលនោះ គេទទួលលក្ខណៈជាតំណាងរបស់ព្រះគ្រីស្ត អាចគោរពបម្រើព្រះជាម្ចាស់ បែបជាគ្រីស្តបរិស័ទ។ គេកើតជាថ្មី និងទៅជាបុត្រធីតារបស់ព្រះបិតា គេត្រូវតែប្រកាសនៅចំពោះមុខមនុស្សលោក នូវជំនឿដែលគេបានទទួលពីព្រះជាម្ចាស់ តាមរយៈព្រះសហគមន៍។ ដោយអគ្គសញ្ញាលាបថ្ងាស ចំណងរបស់គេជាមួយព្រះសហគមន៍កាន់តែប្រសើរឡើង គេក៏ទទួលកម្លាំងពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ និងទទួលភារកិច្ចផ្សព្វផ្សាយ និងការពារជំនឿកាន់តែខ្លាំងឡើងៗ ដោយពាក្យសម្តី និងដោយប្រតិបត្តិតាមជំនឿនេះដែរ ក្នុងឋានៈខ្លួនជាសាក្សីដ៏ពិតប្រាកដរបស់ព្រះគ្រីស្ត។

ពេលគេចូលរួមក្នុងសក្ការបូជាអរព្រះគុណ ដែលជាប្រភព និងជាកំពូលនៃការរស់នៅរបស់គ្រីស្តបរិស័ទ គេលើកព្រះយេស៊ូជាយញ្ញថ្វាយព្រះបិតា ហើយថ្វាយខ្លួនរួមជាមួយព្រះអង្គដែរ។ ហេតុនេះហើយ ដោយថ្វាយយញ្ញផង និងដោយរួបរួមទទួលព្រះកាយផង គ្រីស្តបរិស័ទទាំងអស់ចូលរួមក្នុងពិធីនោះយ៉ាងប្លែកៗពីគ្នា គឺមិនមែនចូលរួមដូចគ្នាទេ តែម្នាក់ៗមានរបៀបរបស់ខ្លួនផ្ទាល់តាមផ្នែករបស់គេក្នុងពិធី។ ហេតុនេះ គ្រីស្តបរិស័ទដែលទទួលព្រះកាយរបស់ព្រះគ្រីស្ត ជាអាហារក្នុងពិធីអរព្រះគុណដ៏វិសុទ្ធនេះ បង្ហាញយ៉ាងជាក់ស្តែងថា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ រួបរួមគ្នាជាធ្លុង

តែមួយ ដូចអគ្គសញ្ញាដ៏ឧត្តុងឧត្តមបំផុតនេះ សម្ដែងយ៉ាងពេញលេញឲ្យគេឃើញ និងធ្វើឲ្យកើតជារូបរាងយ៉ាងអស្ចារ្យថែមទៀត។

អស់អ្នកដែលទទួលអគ្គសញ្ញាលើកលែងទោស ក៏ទទួលការលើកលែងទោសពីព្រះជាម្ចាស់ ប្រកបដោយព្រះហឫទ័យមេត្តាករុណា ចំពោះអំពើដែលគេបានប្រព្រឹត្តខុសនឹងព្រះហឫទ័យព្រះអង្គ។ នៅពេលជាមួយគ្នានោះ គេក៏ស្រុះស្រួលជាមួយព្រះសហគមន៍ ដែលត្រូវរបួសដោយអំពើបាបរបស់គេដែរ។ ព្រះសហគមន៍ជួយឲ្យគេប្រែចិត្តគំនិត ដោយស្រឡាញ់គេ ដោយធ្វើជាគំរូល្អដាក់គេ និងដោយអង្វរព្រះបិតា ឲ្យគេទៀតផង។

ដោយអស់លោកគង្វាលធ្វើអគ្គសញ្ញាលាបប្រេងជូនអ្នកជំងឺ និងអង្វរព្រះជាម្ចាស់ ព្រះសហគមន៍ទាំងមូល ផ្ញើអ្នកជំងឺ ទៅលើព្រះអម្ចាស់យេស៊ូដែលបានរងទុក្ខលំបាក និងដែលមានព្រះជន្មថ្មីដ៏រុងរឿង សូមព្រះអង្គសម្រាលទុក្ខគេ និងសង្គ្រោះគេផង (យក ៥, ១៤-១៦)។ លើសពីនេះទៅទៀត ព្រះសហគមន៍ដាស់តឿនអ្នកជំងឺទាំងនោះ ឲ្យមានសេរីភាពស្ម័គ្រចិត្តរួមជាមួយព្រះគ្រីស្ត ដែលរងទុក្ខលំបាក និងសោយទិវង្គត (រម ៨, ១៧; កឡ ១, ២៤; ២ធម ២, ១១-១២; ១សល ៤, ១៣) ដើម្បីឲ្យអ្នកជំងឺទាំងនោះជួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមចំណែករបស់ខ្លួន។

ក្នុងចំណោមគ្រីស្តបរិស័ទ អ្នកដែលមានកិត្តិយសទទួលអគ្គសញ្ញាតែងតាំង ជាអ្នកបម្រើព្រះសហគមន៍ គឺគេទទួលការតែងតាំងក្នុងនាមព្រះគ្រីស្ត ដើម្បីទៅជាគង្វាលរបស់ព្រះសហគមន៍ ដោយចែកព្រះបន្ទូល និងដោយព្រះជាម្ចាស់ប្រណីសន្ដោសផង។

ដោយអនុភាពនៃអគ្គសញ្ញាអាពាហ៍ពិពាហ៍ គូស្វាមីភរិយាជាគ្រីស្តបរិស័ទ ទទួលភារកិច្ច សម្ដែងអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងព្រះសហគមន៍ដែលរួមគ្នាជាអង្គតែមួយ និងអំពីសេចក្ដីស្រឡាញ់ដែលបង្កើតផល (អភ ៥, ៣២) ពួកគេក៏រួមចំណែកក្នុងគម្រោងការណ៍ដ៏អស្ចារ្យនេះដែរ។ គូស្វាមីភរិយាជួយគ្នាទៅវិញទៅមកឲ្យទៅជាជនដ៏វិសុទ្ធ ដោយរស់នៅក្នុងឋានៈជាគូស្វាមីភរិយា គឺដោយបង្កើតកូន និងអប់រំកូន។ គ្រីស្តបរិស័ទជាគូស្វាមីភរិយា ទទួលព្រះអំណោយទានផ្ទាល់ក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ (១ករ ៧, ៧) តាមរបៀបរស់នៅរបស់ខ្លួន និងតាមឋានៈរបស់គេ។ ដោយគូស្វាមីភរិយារួមរស់ជាមួយគ្នាគេបង្កើតក្រុមគ្រួសារឡើង ហើយក្នុងក្រុមគ្រួសារនោះ ក៏កើតប្រជាពលរដ្ឋថ្មី ក្នុងចំណោមមនុស្សលោកដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រណីសន្ដោសឲ្យប្រជាពលរដ្ឋថ្មីទាំងនោះ ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ដោយអគ្គសញ្ញាជ្រមុជទឹក ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់អាចស្ថិតនៅតទៅអនាគត។ ឪពុកម្ដាយ ជាអ្នកប្រកាសជំនឿមុនគេដល់កូនរបស់ខ្លួន ដោយពាក្យសម្ដី និងដោយធ្វើជាគំរូដល់កូនក្នុងក្រុមគ្រួសារដែលប្រៀបដូចជាព្រះសហគមន៍ដ៏តូចម៉្យាង។ ឪពុកម្ដាយជួយកូនម្នាក់ៗ ឲ្យតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគេ ឲ្យបំពេញមុខងាររបស់ខ្លួន ជាពិសេសឲ្យទៅជាបូជាចារ្យ។

អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទោះជាមានឋានៈណាក្ដីជាគ្រីស្តបរិស័ទធម្មតាក្ដីជាបូជាចារ្យ ឬជាបព្វជិតបព្វជិតាក្ដី ក៏មានមធ្យោបាយយ៉ាងលើសលប់ និងដ៏ប្រសើរបំផុតដែលនាំការសង្គ្រោះដល់គេ។ ព្រះជាម្ចាស់ត្រាស់ហៅគេម្នាក់ៗ តាមមាគ៌ារបស់ខ្លួនឲ្យបានវិសុទ្ធយ៉ាងពេញលក្ខណៈ ដូចព្រះបិតាពេញលក្ខណៈដូច្នោះដែរ។

## ១២- ប្រជាជនគ្រីស្តបរិស័ទយល់ស្របគ្នាអំពីជំនឿ

ប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ រួមចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាព្យាការី គឺប្រជារាស្ត្រនេះ ផ្សព្វផ្សាយ

សក្ខីភាពដ៏រស់រវើករបស់ខ្លួន ជាពិសេសដោយរស់នៅតាមជំនឿ និងតាមសេចក្ដីស្រឡាញ់។ គេថ្វាយសក្ការបូជា លើកតម្កើងព្រះជាម្ចាស់ និងកោតសរសើរព្រះនាមព្រះអង្គ (ហប ១៣, ១៥)។ ដោយព្រះដ៏វិសុទ្ធ បានចាក់ប្រេងអភិសេកសហគមន៍របស់គ្រីស្តបរិស័ទទាំងមូល (១យហ ២, ២០ និង ២៧) សហគមន៍នោះ មិនអាចវង្វេងជំនឿបានឡើយ។ សហគមន៍របស់គ្រីស្តបរិស័ទ បង្ហាញបញ្ជាក់អំពីព្រះអំណោយទានដ៏ពិសេសនេះ ជាព្រះអំណោយទានរបស់ប្រជារាស្ត្រទាំងមូល ដោយយល់ស្របគ្រប់គ្នាអំពីជំនឿ។ ការយល់ស្របបែបនេះ មិនមកពីមនុស្សលោកនេះ តែមកពីព្រះជាម្ចាស់ប្រទានឲ្យគឺ *"តាំងពីអស់លោកអភិបាល រហូតដល់គ្រីស្តបរិស័ទធម្មតាតូចជាងគេបំផុត"* គេយល់ស្របគ្រប់គ្នាត្រង់ជំនឿ និងត្រង់សីលធម៌។ ព្រះវិញ្ញាណនៃសេចក្ដីពិតដាស់តឿនជំនឿគ្រីស្តបរិស័ទ និងគាំទ្រឲ្យគេយល់ស្របគ្រប់គ្នា ក្រោមការណែនាំរបស់ព្រះសហគមន៍។ អ្នកសុខចិត្តស្ដាប់តាមការណែនាំរបស់ ព្រះសហគមន៍នោះដោយចិត្តស្មោះ ក៏ពុំចាត់សេចក្ដីដែលគេទទួលទុកជាពាក្យសម្ដីរបស់មនុស្សទៀតឡើយ តែគេចាត់ទុកថា ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតមែន (១ថស ២, ១៣)។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក៏ភ្ជាប់ចិត្តនឹងលទ្ធិនៃជំនឿជាចំណងដាច់មិនបាន គឺភ្ជាប់ចិត្តនឹងជំនឿដែលព្រះជាម្ចាស់បានប្រទានមកប្រជាជនដ៏វិសុទ្ធម្ដងជាស្រេច (យដ ៣) គេក៏យល់អំពីអត្ថន័យជំនឿនេះកាន់តែជ្រៅ និងបកស្រាយយ៉ាងត្រឹមត្រូវ ហើយប្រព្រឹត្តកាន់តែប្រសើរទៀតផង។

ព្រះវិញ្ញាណដ៏វិសុទ្ធដដែលនេះ មិនគ្រាន់តែប្រោសឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានវិសុទ្ធ ដោយអគ្គសញ្ញា និងដោយមុខងារបម្រើផ្សេងៗប៉ុណ្ណោះទេ ហើយព្រះអង្គក៏មិនគ្រាន់តែណែនាំប្រជារាស្ត្រ ដោយតុបតែងឲ្យមានព្រហ្មវិហារធម៌ប៉ុណ្ណោះដែរ តែព្រះអង្គក៏ប្រណីសន្ដោសយ៉ាងពិសេស គឺប្រទានព្រះអំណោយទាន ឲ្យគ្រីស្តបរិស័ទគ្រប់ឋានៈថែមទៀតផងគឺ *"ព្រះអង្គចែកប្រទានឲ្យគ្រីស្តបរិស័ទម្នាក់ៗ គ្រប់ជាន់ថ្នាក់ មានព្រះអំណោយទានផ្សេងៗពីគ្នា តាមព្រះហឫទ័យរបស់ព្រះអង្គ"* (១ករ ១២, ១១)។ ព្រះអំណោយទានពិសេសទាំងនោះ ផ្ដល់សមត្ថភាពឲ្យម្នាក់ៗអាចបំពេញមុខងារ និងទទួលបន្ទុក ដែលមានប្រយោជន៍សម្រាប់ឲ្យព្រះសហគមន៍ប្រែជាថ្មីជានិច្ច និងចម្រើនឡើងទៀតផង ស្របតាមសេចក្ដី ដែលមានចែងថា *"ព្រះជាម្ចាស់ប្រទានឲ្យមនុស្សម្នាក់ៗសម្ដែងព្រះវិញ្ញាណ ដើម្បីជាប្រយោជន៍រួមជានិច្ច"* (១ករ ១២, ៧)។ ទោះបីជាព្រះអំណោយទានដ៏ភ្លឺថ្លាក្ដី ទោះបីជាព្រះអំណោយទានទាបជាងគេក្ដី ទោះបីជាព្រះអំណោយទានចែកចាយយ៉ាងទូលំទូលាយក្ដី ក៏គ្រីស្តបរិស័ទត្រូវតែអរព្រះគុណចំពោះព្រះអំណោយទានទាំងនោះដែរ។ ព្រះអំណោយទានទាំងនោះ ជួយសម្រាលទុក្ខគ្រីស្តបរិស័ទ និងស្របតាមសេចក្ដីត្រូវការរបស់ព្រះសហគមន៍ ព្រមទាំងមានគោលដៅតបឆ្លើយនឹងតម្រូវការទាំងនោះ។ ប៉ុន្តែ គ្រីស្តបរិស័ទមិនត្រូវគិតតែពីចង់បានព្រះអំណោយទានដ៏អស្ចារ្យ ដោយប្រាថ្នាចង់បានកេរ្ដិ៍ឈ្មោះនោះទេ ហើយក៏មិនត្រូវអួតខ្លួនដោយសង្ឃឹមថា កិច្ចការជាគ្រីស្តទូតនឹងបានផលល្អ មកពីព្រះអំណោយដ៏អស្ចារ្យទាំងនោះដែរ។ អស់លោកដែលទទួលបន្ទុកណែនាំព្រះសហគមន៍ ត្រូវរិះគិតពិចារណាអំពីព្រះអំណោយទានទាំងនោះ ដើម្បីឲ្យដឹងថា តើជាព្រះអំណោយទានពិតប្រាកដឬក៏អត់។ អស់លោកក៏ត្រូវរិះគិតពិចារណា អំពីរបៀបប្រើអំណោយទាននោះយ៉ាងត្រឹមត្រូវទៀតផង។ ជាពិសេស អស់លោកមានភារកិច្ចពិចារណាមើលគ្រប់ការទាំងអស់ ហើយស្រង់យកការណាដែលល្អ អស់លោកមិនត្រូវរារាំងសកម្មភាព របស់ព្រះវិញ្ញាណឡើយ (១ថស ៥, ១២. ១៩-២១)។

## ១៣- ប្រជារាស្ត្រតែមួយរបស់ព្រះជាម្ចាស់ពិតជាមានលក្ខណៈសកល ឬ "កាតូលិក"

ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ ឲ្យចូលរួមក្នុងប្រជារាស្ត្រថ្មីរបស់ព្រះអង្គ។ ទោះបីប្រជារាស្ត្រនេះ រួមគ្នាជាផ្លូងតែមួយនិងមានតែមួយគត់ក្ដី ក៏ប្រជារាស្ត្រនេះមានគោលដៅលាតសន្ធឹងក្នុងពិភពលោកទាំងមូល និងនៅគ្រប់

សម័យរហូតតរៀងទៅ។ ដូច្នេះ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលប្រតិស្ឋានមនុស្សជាតិកាលពីដើមដំបូងមក នឹងកើតជារូបរាង គឺប្រមែប្រមូលបុត្រធីតារបស់ព្រះអង្គ ដែលបែកខ្ញែកគ្នា មករួបរួមគ្នាជាប្រជាជនតែមួយ (យហ ១១, ៥២)។ ព្រះអង្គចាត់ព្រះបុត្រា ឲ្យយាងមកបំពេញព្រះបំណងនេះ និងប្រគល់អ្វីៗទាំងអស់ ឲ្យព្រះបុត្រាគ្រប់គ្រងទុកជាមរតក (ហប ១, ២)។ ព្រះអង្គក៏តែងតាំងព្រះបុត្រាឲ្យធ្វើជាព្រះអម្ចាស់ ជាព្រះមហាក្សត្រ ជាមហាបូជាចារ្យរបស់មនុស្សទាំងអស់ និងជាមេដឹកនាំប្រជារាស្ត្រថ្មីនៃបុត្រធីតារបស់ព្រះជាម្ចាស់ ដែលលាតសន្ធឹងរហូតដល់ទីដាច់ស្រយាលនៃពិភពទាំងមូល។ នៅពេលចុងក្រោយបំផុត ព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណនៃព្រះបុត្រាព្រះអង្គឲ្យយាងមក គឺព្រះវិញ្ញាណ ដែលជាព្រះអម្ចាស់ និងជាប្រភពនៃជីវិត។ ព្រះអង្គប្រមូលព្រះសហគមន៍ទាំងមូល គឺអ្នកជឿទាំងអស់ និងអ្នកជឿម្នាក់ៗ ឲ្យរួបរួមគ្នាក្នុងលទ្ធិរបស់ក្រុមគ្រីស្តទូត និងរួបរួមគ្នាជាបងប្អូនឲ្យកាច់នំប៉័ង និងអធិដ្ឋានផង (កក ២, ៤២)។

ដូច្នេះ ដោយមានប្រជាពលរដ្ឋនៃប្រជាជាតិទាំងអស់ចូលមក ប្រជារាស្ត្រតែមួយគត់របស់ព្រះជាម្ចាស់ ស្ថិតនៅក្នុងចំណោមប្រជាជាតិនានានៅលើផែនដី។ គេជាប្រជារាស្ត្រនៃព្រះរាជាណាចក្រមួយ ដែលគ្មានលក្ខណៈខាងលោកីយ៍ទេ តែមានលក្ខណៈជាលោកខាងមុខវិញ។ អស់អ្នកផ្ញើជីវិតលើព្រះគ្រីស្ត ដែលខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូល រួបរួមជាមួយគ្នាក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធបានជា *"លោកដែលនៅក្រុងរ៉ូមជ្រាបថា អស់អ្នកដែលនៅប្រទេសឥណ្ឌា ពិតជាសរីរាង្គកាយរបស់ខ្លួន"*។ ប៉ុន្តែ ដោយព្រះរាជាណាចក្ររបស់ព្រះគ្រីស្ត មិនមែននៅក្នុងលោកនេះទេ (យហ ១៨, ៣៦) ព្រះសហគមន៍ គឺប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលធ្វើឲ្យព្រះរាជាណាចក្រនេះ មានរូបរាងមិនដកហូតធនធានខាងលោកីយ៍ ពីប្រជាជាតិណាមួយឡើយ ផ្ទុយទៅវិញ ព្រះសហគមន៍បម្រើ និងលើកស្ទួយតម្លៃដ៏ថ្លៃថ្នូរគ្រប់យ៉ាងនៃអារ្យធម៌របស់គេ បម្រើ និងលើកស្ទួយធនធានមនុស្ស បម្រើ និងលើកស្ទួយរបៀបរស់នៅដ៏ល្អរបស់ប្រជាជាតិទាំងនោះទៀតផង។ ដោយព្រះសហគមន៍យកសេចក្តីទាំងនោះ ព្រះសហគមន៍ជម្រះ និងពង្រឹង ហើយលើកសេចក្តីទាំងនោះឡើងទៀតផង។ ព្រះសហគមន៍នឹកចងចាំថា ខ្លួនមានភារកិច្ចប្រមែប្រមូលប្រជាជាតិនានា ឲ្យភ្ជាប់នឹងព្រះមហាក្សត្រដែលទទួលប្រជាជាតិទាំងអស់ទុកជាមរតក (ទន ២, ៨) ប្រជាជាតិទាំងនោះ ក៏យកតង្វាយ និងអំណោយមកថ្វាយនៅក្នុងទីក្រុងរបស់ព្រះមហាក្សត្រនោះផង (ទន ៧២, ១០; អស ៦០, ៤-៧; វវ ២១, ២៤)។ ព្រះអម្ចាស់ផ្ទាល់ ប្រោសប្រទានឲ្យប្រជារាស្ត្ររបស់ព្រះអង្គមានលក្ខណៈសកលនេះ។ ដោយមានលក្ខណៈសកលនេះ ព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់ជានិច្ច និងយ៉ាងស័ក្តិសិទ្ធិ ប្រមែប្រមូលមនុស្សជាតិទាំងមូល និងធនធានទាំងអស់ដែលនៅក្នុងមនុស្សជាតិនោះ ឲ្យមកស្ថិតនៅក្រោមអំណាចរបស់ព្រះគ្រីស្តជាព្រះសិរសា រួបរួមក្នុងព្រះវិញ្ញាណព្រះអង្គ។

ដោយអនុភាពនៃលក្ខណៈសកលនេះ ផ្នែកនីមួយៗនាំយកផលនៃព្រះអំណោយទានរបស់ខ្លួន មកចែកឲ្យផ្នែកឯទៀតៗ និងឲ្យព្រះសហគមន៍ទាំងមូលដែរ។ ហេតុនេះហើយបានជាមនុស្សលោកទាំងមូល និងផ្នែកនីមួយៗចម្រើនឡើង ដោយចែកផលទៅវិញទៅមក និងដោយខិតខំរួបរួមគ្នាជាធ្លុងតែមួយយ៉ាងពេញលក្ខណៈ។ ដូច្នេះហើយ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់កើតមក មិនគ្រាន់តែដោយមានប្រជាជាតិផ្សេងៗរួបរួមគ្នាប៉ុណ្ណោះទេ តែកើតមកដោយមានមុខងារផ្សេងៗតែងតាំងប្រជារាស្ត្រ នៅផ្ទៃក្នុងទៀតផង។ សមាជិកប្រជារាស្ត្រនេះប្លែកពីគ្នាតាមបន្ទុក គឺអ្នកខ្លះ បំពេញមុខងារដ៏សក្ការៈបម្រើបងប្អូនក្នុងឋានៈជាអភិបាល ជាបូជាចារ្យ និងជាឧបដ្ឋាក។ គេក៏ប្លែកពីគ្នា តាមឋានៈ និងតាមរបៀបរស់នៅរបស់គេថែមទៀត គឺមានគ្នាច្រើន ជាបព្វជិត បព្វជិតា ដែលស្វែងរកឲ្យបានវិសុទ្ធតាមផ្លូវចង្អៀតជាង ធ្វើជាគំរូដាស់តឿនបងប្អូនឯទៀតៗ។ ហេតុនេះហើយ បានជាក្នុងព្រះសហគមន៍សកល មានព្រះសហគមន៍ដោយឡែកត្រឹមត្រូវតាមច្បាប់ ដែលកាន់តាមប្រពៃណីរបស់ខ្លួនផ្ទាល់ រួបរួមគ្នាក្នុងព្រះសហគមន៍តែមួយ ទាំងគោរពអាសនៈរបស់

គ្រីស្តទូតសិលា ដែលជា *"ប្រធានអង្គប្រជុំរបស់អស់អ្នកដែលមានចិត្តស្រឡាញ់"*។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម ធានារ៉ាប់រងសេចក្តីប្លែក ៗពីគ្នាដែលគួរឲ្យមាន ហើយនៅពេលជាមួយគ្នានេះ លោកប្រយ័ត្នប្រយែងកុំឲ្យសេចក្តីប្លែក ៗពីគ្នា ដោយឡែកទាំងនោះ បណ្តាលឲ្យព្រះសហគមន៍ពិបាករួបរួមគ្នា ផ្ទុយទៅវិញ លោកខិតខំឲ្យសេចក្តីប្លែក ៗពីគ្នា ដោយឡែកទាំងនោះ បម្រើការរួបរួមគ្នាវិញ។ លើសពីនេះទៅទៀត មានចំណងមេត្រីយ៉ាងស្និទ្ធស្នាល ធ្វើឲ្យផ្នែកនីមួយ ៗនៃព្រះសហគមន៍ រួបរួមទាក់ទងគ្នា ដោយចែករំលែកធនធានខាងព្រះវិញ្ញាណ គឺចែកអ្នកបំពេញមុខងារជាគ្រីស្តទូត និងចែកធនធានសម្ភារៈផងដែរ។ ព្រះជាម្ចាស់ត្រាស់ហៅ សមាជិកនៃប្រជារាស្ត្ររបស់ព្រះអង្គ ឲ្យចែករំលែកធនធានរបស់ខ្លួនយ៉ាងណា ព្រះសហគមន៍នីមួយ ៗក៏ត្រូវប្រព្រឹត្តយ៉ាងនោះដែរ តាមពាក្យទូន្មានរបស់គ្រីស្តទូតថា "សូមបងប្អូនម្នាក់ ៗបានទទួលព្រះអំណោយទានផ្សេង ៗពីគ្នា ដូច្នេះ ចូរយកព្រះអំណោយទានទាំងនោះ ទៅបម្រើអ្នកឯទៀត ៗ ឲ្យសមនឹងតួនាទីរបស់បងប្អូន ជាអ្នកចាត់ចែងដ៏ល្អដែលចែក ព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់" (១សល ៤,១០)។

ដូច្នេះ ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ ឲ្យចូលរួមក្នុងប្រជារាស្ត្រសាកលរបស់ព្រះអង្គ។ ព្រះសហគមន៍កាតូលិកនេះ គឺជាប្រផ្នូលអំពីសន្តិភាពសកល និងជួយបង្កើតសន្តិភាពសកលនេះថែមទៀតផង។ ព្រះជាម្ចាស់ប្រណីសន្តោស ហៅមនុស្សទាំងអស់ឲ្យទទួលការសង្គ្រោះ ទាំងគ្រីស្តបរិស័ទកាតូលិក ទាំងអស់អ្នកឯទៀត ៗ ដែលផ្ញើជីវិតលើព្រះគ្រីស្ត។ សរុបសេចក្តីមក ឥតមានចោលនរណាសោះ គឺព្រះអង្គត្រាស់ហៅមនុស្សទាំងអស់ ឲ្យភ្ជាប់នឹងព្រះសហគមន៍សកល តាមបែបផ្សេង ៗ ហើយតម្រង់ទៅកាន់ព្រះសហគមន៍សាកលនោះ។

## ១៤- គ្រីស្តបរិស័ទកាតូលិក

មហាសន្និបាតដ៏វិសុទ្ធ បែរទៅរកគ្រីស្តបរិស័ទកាតូលិកមុនគេ។ មហាសន្និបាតនេះ សំអាងលើព្រះគម្ពីរ និងលើការបញ្ជូនបន្តមកបង្រៀនថា ព្រះសហគមន៍ដែលកំពុងធ្វើដំណើរនៅលើផែនដីនេះ មានសារៈសំខាន់ជាចាំបាច់ ដើម្បីឲ្យមនុស្សលោកទទួលការសង្គ្រោះ។ មានតែព្រះគ្រីស្តមួយព្រះអង្គគត់ ជាស្ពានមេត្រី និងជាមាគ៌ាទៅកាន់ការសង្គ្រោះ។ ព្រះអង្គមានវត្តមាន គង់នៅជាមួយយើងក្នុងព្រះកាយព្រះអង្គ គឺក្នុងព្រះសហគមន៍។ ព្រះអង្គផ្ទាល់បង្រៀនយ៉ាងជាក់ច្បាស់ថា មនុស្សត្រូវតែផ្ញើជីវិតលើព្រះអង្គ និងទទួលអគ្គសញ្ញាជ្រមុជទឹកជាចាំបាច់ (មក ១៦, ១៦; យហ ៣, ៥)។ នៅពេលជាមួយគ្នានោះ ព្រះអង្គក៏បញ្ជាក់ថា ត្រូវតែមានព្រះសហគមន៍ជាចាំបាច់ដែរ។ មនុស្សចូលក្នុងព្រះសហគមន៍ដោយអគ្គសញ្ញាជ្រមុជទឹកដែលជាទ្វារ។ ហេតុនេះហើយបានជា អស់អ្នកដែលដឹងថា ព្រះជាម្ចាស់បានតែងតាំងព្រះសហគមន៍កាតូលិក ដោយសារព្រះយេស៊ូគ្រីស្តទុកជាមធ្យោបាយដ៏ចាំបាច់ ដើម្បីទទួលការសង្គ្រោះ ប៉ុន្តែបដិសេធមិនព្រមចូលព្រះសហគមន៍កាតូលិក ឬបដិសេធមិនព្រមព្យាយាមស្ថិតនៅជាប់នឹងព្រះសហគមន៍នោះ ពុំអាចទទួលការសង្គ្រោះបានឡើយ។

អស់អ្នកដែលទទួលព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ហើយសុខចិត្តទទួលស្គាល់ការចាត់ចែងទាំងស្រុងរបស់ព្រះសហគមន៍ និងសុខចិត្តទទួលស្គាល់មធ្យោបាយទាំងប៉ុន្មានដែលផ្តល់ការសង្គ្រោះ ដូចមានចាត់ចែងក្នុងព្រះសហគមន៍នោះ ពិតជាចូលរួមយ៉ាងពេញលេញក្នុងសង្គមនៃព្រះសហគមន៍មែន។ លើសពីនេះទៅទៀត ដោយប្រកាសជំនឿ ដោយទទួលអគ្គសញ្ញានានា ដោយការត្រួតត្រារបស់អស់លោកអភិបាល និងដោយការរួបរួមគ្នា គេជាប់ចំណងរួបរួមជាមួយព្រះគ្រីស្ត ក្នុងព្រះសហគមន៍ជាអង្គប្រជុំដែលមើលឃើញ។ គេរួបរួមជាមួយព្រះគ្រីស្ត ដែលណែនាំព្រះសហគមន៍ដោយសារអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងដោយអភិបាលនានា។ ក៏ប៉ុន្តែ ការចូលរួមក្នុងព្រះសហគមន៍ មិនធានាថា

នឹងទទួលការសង្គ្រោះបានទេ។ ប្រសិនបើគេមិនព្យាយាមក្នុងសេចក្តីស្រឡាញ់ គេនៅជាសមាជិកនៃព្រះសហគមន៍ខាងរូបកាយ តែមិនមែនខាងផ្លូវចិត្តទេ។ អស់បុត្រធីតានៃព្រះសហគមន៍ត្រូវនឹកចងចាំថា លក្ខណៈដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរបស់ខ្លួន មកពីព្រះគ្រីស្តប្រោសប្រណីគេយ៉ាងពិសេស មិនមែនមកពីបុណ្យកុសលរបស់ខ្លួនគេឡើយ។ ប្រសិនបើចិត្តគំនិតគេ ពាក្យសម្តីរបស់គេ និងការប្រព្រឹត្តរបស់គេ មិនស្របតាមលក្ខណៈដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមទេនោះ គេមុខជាត្រូវទទួលទោសជាទម្ងន់ មិនទទួលការសង្គ្រោះទេ។

ចំពោះបងប្អូនដែលកំពុងស្តាប់ព្រះបន្ទូលលាន់ឮឡើង ហើយដែលបានសម្រេចចិត្តយ៉ាងច្បាស់ សូមចូលរួមក្នុងព្រះសហគមន៍ ដោយព្រះវិញ្ញាណដ៏វិសុទ្ធឧបត្ថម្ភផង ដោយគេបានធ្វើសំណូមពរនេះ គេចូលរួមក្នុងព្រះសហគមន៍រួចហើយ។ ព្រះសហគមន៍ជាមាតា យកចិត្តទុកដាក់នឹងគេជាបុត្រធីតា ថ្នាក់ថ្នមថែទាំគេដោយចិត្តស្រឡាញ់។

## ១៥- ចំណងរបស់ព្រះសហគមន៍ ជាមួយគ្រីស្តបរិស័ទដែលមិនមែនជាកាតូលិក

ចំពោះបងប្អូនដែលមានឈ្មោះដ៏ប្រសើរថា ជាគ្រីស្តបរិស័ទ តែមិនប្រកាន់ជំនឿគ្រប់ប្រការ ហើយមិនរួបរួម ក្រោមការដឹកនាំអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ព្រះសហគមន៍ដឹងថា ខ្លួនមានចំណងជាច្រើនភ្ជាប់ជាមួយបងប្អូនទាំងនោះ គឺមានបងប្អូនជាច្រើនគោរពព្រះគម្ពីរទុកជាគ្រឹះណែនាំជំនឿរបស់គេ និងទុកជាវិន័យឲ្យគេ រស់នៅតាមគេមានចិត្តខ្នះខ្នែងយ៉ាងស្មោះចំពោះគ្រីស្តសាសនា គេធ្វើជីវិតដោយអស់ពីក្នុងចិត្តទៅលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានតេជានុភាពសព្វប្រការ គេក៏ផ្ញើជីវិតទៅលើព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះសង្គ្រោះដែរ។ ព្រះជាម្ចាស់បានដៅបងប្អូនទាំងនោះ ដោយអគ្គសញ្ញាជ្រមុជទឹក ដែលធ្វើឲ្យគេរួបរួមជាមួយព្រះគ្រីស្ត។ មានបងប្អូនខ្លះក៏ទទួលស្គាល់អគ្គសញ្ញាឯទៀត ហើយទទួលអគ្គសញ្ញាទាំងនោះក្នុងព្រះសហគមន៍ ឬក្រុមជំនុំរបស់គេរៀងៗខ្លួនផង។ ក្រុមគ្រីស្តបរិស័ទខ្លះក៏មានក្រុមអភិបាលណែនាំ ហើយក៏ធ្លាប់ធ្វើពិធីអរព្រះគុណដ៏វិសុទ្ធ និងគោរពប្រណិប័តន៍នាងម៉ារីជាព្រះមាតាព្រះអម្ចាស់ដែរ។ គេរួបរួមជាមួយយើង ដោយអធិដ្ឋាន និងដោយបានទទួលព្រះអំណោយទានខាងព្រះវិញ្ញាណថែមទៀត។ លើសពីនេះទៅទៀត គេរួបរួមគ្នាយ៉ាងពិតប្រាកដក្នុងព្រះវិញ្ញាណ ព្រោះព្រះអង្គប្រោសឲ្យគេបានវិសុទ្ធ ដោយអានុភាពនៃព្រះហឫទ័យ ប្រណីសន្តោសរបស់ព្រះអង្គ ព្រមទាំងប្រទានព្រះអំណោយទានផ្សេងៗឲ្យគេដែរ។ ព្រះអង្គប្រោសឲ្យបងប្អូនខ្លះមានចិត្តក្លាហាន រហូតដល់ហ៊ានបូជាជីវិត ព្រោះតែព្រះអង្គ។ ដូច្នេះ ព្រះវិញ្ញាណជំរុញឲ្យសាវ័កទាំងអស់របស់ព្រះគ្រីស្ត មានបំណងហើយខិតខំធ្វើឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នា ដោយសេចក្តីសុខសាន្ត តាមរបៀបដែលព្រះគ្រីស្តសព្វព្រះហឫទ័យ គឺឲ្យរួបរួមក្នុងហ្វូងតែមួយក្រោមការណែនាំរបស់គង្វាលតែមួយព្រះអង្គ។ ព្រះសហគមន៍ជាមាតា នៅតែអង្វរព្រះបិតា នៅតែសង្ឃឹម និងនៅតែបំពេញសកម្មភាពជានិច្ច ដើម្បីឲ្យគោលបំណងនេះបានសម្រេច។ ព្រះសហគមន៍ក៏នៅតែដាស់តឿនបុត្រធីតាជម្រះខ្លួនឲ្យបានបរិសុទ្ធ និងឲ្យប្រែជាថ្មី ដើម្បីឲ្យសញ្ញាសម្គាល់របស់ព្រះគ្រីស្ត ចាំងនៅលើមុខព្រះសហគមន៍ឲ្យកាន់តែភ្លឺស្វាងឡើងៗ។

## ១៦- អស់អ្នកដែលមិនមែនជាគ្រីស្តបរិស័ទ

ចំពោះអស់អ្នកដែលមិនទាន់ទទួលដំណឹងល្អ ជីវិតគេក៏មានទិសដៅតម្រង់ទៅកាន់ប្រជារាស្ត្រ របស់ព្រះជាម្ចាស់តាមរបៀបផ្សេងៗដែរ។ ជាបឋម មានប្រជាជនអ៊ីស្រាអែលដែលទទួលសម្ពន្ធមេត្រី និងព្រះបន្ទូលសន្យានានា ហើយដែលមានព្រះគ្រីស្តប្រសូតមកជាមនុស្សក្នុងពូជពង្សរបស់គេ (រម ៩, ៤-៥)។ *"បើគិតតាមការជ្រើសរើស ព្រះជាម្ចាស់ស្រឡាញ់គេខ្លាំងណាស់ មកពីព្រះអង្គគិតដល់បុព្វបុរសរបស់គេ។ ប្រសិនបើ ព្រះជាម្ចាស់ប្រទានព្រះអំណោយទាន*

*ហើយព្រះអង្គមិនដកហូតវិញទេ ប្រសិនបើព្រះអង្គត្រាស់ហៅ ទ្រង់ក៏មិនប្រែប្រួលដែរ។"* (រម ១១, ២៨-២៩)។ ប៉ុន្តែព្រះជាម្ចាស់មានគម្រោងការសង្គ្រោះអស់មនុស្សណា ដែលទទួលស្គាល់ព្រះអង្គ ទុកជាព្រះអាទិករនៃអ្វីៗទាំងអស់ មានបងប្អូនអ៊ីស្លាមជាដើម ដែលប្រកាសជំនឿរបស់លោកអាប្រាហាំ គេក្រាបថ្វាយបង្គំព្រះជាម្ចាស់តែមួយព្រះអង្គគត់ ដូចយើងជាព្រះ ប្រកបដោយព្រះហឫទ័យមេត្តាករុណា ជាចៅក្រមដែលនឹងវិនិច្ឆ័យមនុស្សនៅថ្ងៃចុងក្រោយបំផុត។

សូម្បីតែបងប្អូនឯទៀតៗ ដែលស្វះស្វែងរកព្រះមួយអង្គដែលគេមិនស្គាល់ គឺស្វែងរក *"តាមស្រមោល និងតាមនិមិត្តរូប"* ព្រះជាម្ចាស់ក៏មិនស្ថិតនៅឆ្ងាយពីគេដែរ ព្រោះព្រះអង្គទេតើ ដែលបានប្រទានជីវិត ប្រទានដង្ហើម និងប្រទានអ្វីៗសព្វគ្រប់ទាំងអស់មកមនុស្ស (កក ១៧, ២៥-២៨)។ ព្រះអង្គជាព្រះសង្គ្រោះ ទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ (១ធម ២, ៤)។ អស់អ្នកដែលមិនស្គាល់ដំណឹងល្អរបស់ព្រះគ្រីស្ត និងមិនស្គាល់ព្រះសហគមន៍របស់ព្រះអង្គ ដោយគេគ្មានកំហុសអ្វី តែស្វែងរកព្រះជាម្ចាស់ដោយចិត្តស្មោះ និងខិតខំប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គ ស្របតាមមនសិការបង្ហាញ និងបញ្ជាឲ្យប្រព្រឹត្តនោះ អ្នកទាំងនោះ ក៏អាចឈានទៅដល់ការសង្គ្រោះ អស់កល្បជានិច្ច ដោយព្រះអង្គប្រណីសន្តោសគេដែរ។ ចំពោះអស់អ្នកដែលមិនទាន់ស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់នៅឡើយ ដោយគេគ្មានកំហុស តែខិតខំរស់នៅតាមរបៀបសុចរិតទៀងត្រង់ ដោយព្រះអង្គប្រោសប្រណីផង ព្រះជាម្ចាស់ ដែលណែនាំថែរក្សាមនុស្សលោក មុខជានឹងប្រទានជំនួយដល់អ្នកទាំងនោះ តាមតម្រូវការឲ្យគេទៅកាន់ការសង្គ្រោះបាន។ ព្រះសហគមន៍យល់ឃើញថា អ្វីៗដ៏ល្អនិងដ៏ពិតប្រាកដនៅក្នុងចំណោមពួកគេសុទ្ធតែរៀបចំឲ្យគេទទួលដំណឹងល្អ ឬទុកជាព្រះអំណោយទានរបស់ព្រះអង្គដែលបំភ្លឺចិត្តគំនិតមនុស្សគ្រប់ៗគ្នា ដើម្បីឲ្យគេមានជីវិត។ គួរឲ្យស្ដាយណាស់ មារកំណាចបានបញ្ឆោតមនុស្សជាច្រើន និងជាញឹកញាប់ឲ្យវង្វេងទៅតាមការរិះគិតរបស់ខ្លួន។ គេក៏បោះបង់សេចក្ដីពិតរបស់ព្រះជាម្ចាស់ចោល បែរទៅរកសេចក្ដីភូតភរ ហើយនាំគ្នាគោរពបម្រើសត្វលោកជាជាងគោរពបម្រើព្រះអាទិករ (រម ១,២១ និង ២១)។ ដោយគេរស់នៅ និងស្លាប់ក្នុងលោកនេះទាំងមិនគោរពបម្រើព្រះណាមួយសោះ គេមុខជាអស់សង្ឃឹមខ្លាំងណាស់។ ហេតុនេះហើយ បានជាព្រះសហគមន៍យកចិត្តទុកដាក់គោរពសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងចង់ឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ ចេះតែនឹកដល់ព្រះបញ្ញារបស់ព្រះអម្ចាស់ថា *"ចូរចេញទៅប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់"* (មក ១៦, ១៥)។ ព្រះសហគមន៍ក៏យកចិត្តទុកដាក់ទ្រទ្រង់កិច្ចការជាសាសនទូត។

## ១៧- ព្រះសហគមន៍មានលក្ខណៈជាសាសនទូត

ព្រះបិតាចាត់ព្រះបុត្រាឲ្យយាងមកយ៉ាងណា ព្រះបុត្រាក៏ចាត់សាវ័ករបស់ព្រះអង្គឲ្យទៅយ៉ាងនោះដែរ (យហ ២០, ២១) ដោយមានព្រះបន្ទូលថា *"ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័កហើយធ្វើពិធីជ្រមុជទឹកជូនគេ ដើម្បីឲ្យគេរួមជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក"* (មថ ២៨, ១៨-២០)។ ព្រះសហគមន៍បាន ទទួលព្រះបញ្ញាដ៏ឱឡារិករបស់ព្រះគ្រីស្តនេះពីក្រុមគ្រីស្តទូតមក ពោលគឺឲ្យប្រកាសសេចក្ដីពិតអំពីការសង្គ្រោះ បន្តរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី (កក ១,៨)។ ហេតុនេះហើយ បានជាព្រះសហគមន៍យល់ដូចគ្រីស្តទូតប៉ូលដែលថែងថា៖ *"ប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អទេ សូមឲ្យខ្ញុំវេទនាទៅចុះ!"* (១ករ ៩, ១៦)។ ព្រះសហគមន៍ក៏នៅតែចាត់អ្នកចេញទៅប្រកាសដំណឹងល្អតទៅទៀត ដោយឥតឈប់ឈរ រហូតដល់ពេលព្រះសហគមន៍ថ្មីៗ ដែលតែងតាំងសព្វគ្រប់ហើយ អាចបន្តកិច្ចប្រកាសដំណឹងល្អដោយខ្លួនឯងផ្ទាល់បាន។ ព្រះវិញ្ញាណដ៏វិសុទ្ធ ជំរុញព្រះសហគមន៍ឲ្យរួមសហការ ដើម្បីឲ្យបំណងប្រាថ្នារបស់ព្រះជាម្ចាស់បានកើតជារូបរាងជាស្ថាពរ។

តាមព្រះបំណងប្រាថ្នានោះ ព្រះជាម្ចាស់តែងតាំងព្រះគ្រីស្ដទុកជាដើមកំណើតនៃការសង្គ្រោះមនុស្សលោកទាំងអស់។

ពេលព្រះសហគមន៍ប្រកាសដំណឹងល្អ ព្រះសហគមន៍ណែនាំអស់អ្នកស្ដាប់ ឲ្យផ្ញើជីវិតលើព្រះគ្រីស្ដ និងប្រកាសជំនឿរបស់គេផង។ ព្រះសហគមន៍រៀបចំចិត្តគំនិតគេឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក រំដោះគេឲ្យរួចពីទាសភាពនៃការវង្វេង ព្រមទាំងបញ្ចូលគេក្នុងព្រះកាយព្រះគ្រីស្ដ ដើម្បីឲ្យគេចម្រើនឡើងក្នុងអង្គព្រះគ្រីស្ដដោយសេចក្ដីស្រឡាញ់ រហូតដល់គេបានពេញលក្ខណៈ។ ព្រះសហគមន៍បំពេញការទាំងអស់ដោយមានគោលដៅតែមួយគឺថា ប្រសិនបើ ព្រះសហគមន៍រកឃើញពូជដ៏ល្អសាបព្រោះក្នុងចិត្តគំនិតរបស់មនុស្សលោក ឬក្នុងពិធីគោរពប្រណិប័តន៍នានារបស់គេ និងក្នុងអរិយធម៌ប្រជាជាតិនានា ព្រះសហគមន៍មិនគ្រាន់តែរក្សាទុកឲ្យនៅគង់វង្ស មិនឲ្យវិនាសបាត់បង់ប៉ុណ្ណោះទេ តែព្រះសហគមន៍ក៏ព្យាបាលពូជទាំងនោះឲ្យបានជា និងនាំឲ្យបានពេញលក្ខណៈដែរ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ កិច្ចនោះបណ្ដាលឲ្យមារត្រូវអាម៉ាស់ ហើយក៏នាំឲ្យមនុស្សលោកបានសុភមង្គលទៀតផង។ សាវ័ករបស់ព្រះគ្រីស្ដមានភារកិច្ចពង្រីក និងពង្រឹងជំនឿ តាមចំណែករៀងៗខ្លួន។ នរណាក៏ដោយ ក៏អាចធ្វើអគ្គសញ្ញាជ្រមុជទឹកជូនអ្នកផ្ញើជីវិតលើព្រះគ្រីស្ដបាន ប៉ុន្តែ មានតែក្រុមបូជាចារ្យប៉ុណ្ណោះទេ ដែលមានមុខងារសាងសង់ព្រះកាយដោយថ្វាយសក្ការបូជាអរព្រះគុណ ទាំងធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងតាមព្យាការី បានកើតជារូបរាងថា *"ចាប់ពីទិសខាងកើតរហូតដល់ទិសខាងលិច នាមរបស់យើងប្រសើរឧត្ដុង្គឧត្ដមក្នុងចំណោមប្រជាជាតិនានា។ នៅគ្រប់ទីកន្លែងគេនាំគ្នាថ្វាយសក្ការបូជា និងយកតង្វាយដ៏បរិសុទ្ធមកថ្វាយយើង"* (មគ ១, ១១)។ ដូច្នេះ ព្រះសហគមន៍អង្វរព្រះជាម្ចាស់ផង និងធ្វើកិច្ចការនៅពេលជាមួយគ្នាផង ដើម្បីឲ្យមនុស្សលោកទាំងអស់ប្រែទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ទៅជាព្រះកាយរបស់ព្រះអម្ចាស់ និងទៅជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះសហគមន៍ក៏នឹងលើកតម្កើងសិរីរុងរឿងព្រះបិតា ដែលប្រតិស្ឋានពិភពលោក ក្នុងអង្គព្រះគ្រីស្ដ ជាព្រះសិរសារបស់មនុស្សទាំងអស់។

# ជំពូក ៣

## ព្រះសហគមន៍មានរចនាសម្ព័ន្ធតាមលំដាប់លំដោយ ជាពិសេសមានក្រុមអភិបាល

### ១៨- អារម្ភកថា

ព្រះគ្រីស្ដជាអម្ចាស់ តែងតាំងមុខងារបម្រើផ្សេងៗក្នុងព្រះសហគមន៍របស់ព្រះអង្គ ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានគង្វាលណែនាំ និងមានមធ្យោបាយអាចចម្រើនឡើងបានជានិច្ច។ មុខងារទាំងនោះមានគោលដៅតែមួយ គឺរកប្រយោជន៍ដល់រូបកាយទាំងមូល។ អស់លោកដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ មានអំណាចមកពីព្រះជាម្ចាស់គឺ អស់លោកបម្រើបងប្អូន ដើម្បីណែនាំសមាជិកទាំងអស់នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលមានកិត្តិយសដ៏ថ្លៃថ្នូរយ៉ាងពិតប្រាកដ ជាគ្រីស្តបរិស័ទ អាចទៅកាន់ការសង្គ្រោះ ទាំងខិតខំរួមគ្នា ដោយស្ម័គ្រចិត្ត និងដោយមានសណ្ដាប់ធ្នាប់ ទៅរកទិសដៅតែមួយ។

មហាសន្និបាតដ៏វិសុទ្ធនេះ បង្រៀនតាមមហាសន្និបាតវ៉ាទីកង់ទី១ និងប្រកាសថា ព្រះយេស៊ូគ្រីស្ដជាគង្វាល ស្ថិតនៅអស់កល្បជានិច្ច បានសាងសង់ព្រះសហគមន៍ដ៏វិសុទ្ធ ដោយចាត់ក្រុមគ្រីស្ដទូតរបស់ព្រះអង្គឲ្យទៅ ដូចព្រះបិតា បានចាត់ព្រះអង្គឲ្យមកដូច្នេះដែរ (យហ ២០, ២១)។ ព្រះអង្គក៏សព្វព្រះហឫទ័យ ឲ្យអស់លោកដែលបន្តមុខងាររបស់ក្រុមគ្រីស្ដទូតមក ពោលគឺអស់លោកអភិបាល បានទៅជាគង្វាលក្នុងព្រះសហគមន៍របស់ព្រះអង្គ រហូតដល់អវសានកាល នៃពិភពលោក។ ប៉ុន្តែ ព្រះអង្គតែងតាំងលោកសិលាឲ្យនាំមុខគ្រីស្ដទូតឯទៀតៗ ដើម្បីឲ្យក្រុមអភិបាលរួមជាធ្លុងតែមួយមិនអាចបំបែកបានឡើយ។ ព្រះអង្គផ្ទាល់ក៏តែងតាំងលោកសិលា ទុកជាគោល និងជាគ្រឹះស្ថិតនៅជានិច្ចនិរន្តរ៍ សម្ដែងឲ្យមនុស្សឃើញច្បាស់ថា ព្រះសហគមន៍រួបរួមគ្នាក្នុងជំនឿ និងរួបរួមគ្នាជាធ្លុងតែមួយផង។ មហាសន្និបាតដ៏វិសុទ្ធ ប្រកាសសាជាថ្មីនូវលទ្ធិស្ដីអំពីអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាប្រធានក្រុមអភិបាល ហើយក៏ប្រកាសទៀតថា លោកបង្រៀនព្រះសហគមន៍ដោយមិនអាចភាន់ច្រឡំបានឡើយ ព្រះយេស៊ូពិតជាតែងតាំងលោកឲ្យមានមុខងារនៅស្ថិតស្ថេររហូតជាមុខងារដែលមានអនុភាព ហើយក៏ត្រូវមានទស្សនៈដូច្នេះ។ មហាសន្និបាតសូមឲ្យគ្រីស្តបរិស័ទទាំងអស់ត្រូវជឿលទ្ធិនេះ ទុកជាសេចក្ដីដ៏ពិតប្រាកដ។ លើសពីនេះទៅទៀត មហាសន្និបាតបន្តកិច្ចការ ដែលមហាសន្និបាតចាប់ផ្ដើមរិះគិតកាលពីមុន ហើយចង់ប្រកាស និងលាតសន្ធឹងនូវលទ្ធិស្ដីអំពីអស់លោកអភិបាល ជាអ្នកបន្តមុខងារក្រុមគ្រីស្ដទូតនៅចំពោះគ្រីស្តបរិស័ទទាំងអស់ គឺថា អស់លោកមានបន្ទុកណែនាំព្រះដំណាក់របស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅរួមជាមួយលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្ដទូតសិលាមក ក្នុងឋានៈលោកជាតំណាងព្រះគ្រីស្ដ និងជាមេដឹកនាំដែលគេអាចមើលឃើញបាន គឺជាមេដឹកនាំរបស់ព្រះសហគមន៍ទាំងមូល។

### ១៩- ព្រះយេស៊ូតែងតាំងក្រុមគ្រីស្ដទូត១២នាក់

ក្រោយពីព្រះអម្ចាស់យេស៊ូអង្វរព្រះបិតាយ៉ាងយូរ ព្រះអង្គត្រាស់ហៅអស់អ្នកដែល ទ្រង់សព្វព្រះហឫទ័យជ្រើស

រើស ហើយតែងតាំងក្រុមដប់ពីរនាក់នោះឲ្យនៅជាមួយព្រះអង្គ និងដើម្បីចាត់ឲ្យគេទៅប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ (មក ៣, ១៣-១៩; មថ ១០, ១-៤២)។ ព្រះអង្គតែងតាំងអស់លោកជាទូតរបស់ព្រះអង្គ (លក ៦, ១៣) ដូចជាក្រុមមួយដែលនៅស្ថិតស្ថេរ។ ព្រះអង្គក៏តែងតាំងលោកសិលា ដែលទ្រង់បានជ្រើសរើសក្នុងចំណោមអស់លោក ឲ្យនាំមុខអស់លោក (យហ ២១, ១៥-១៧)។ ព្រះអង្គចាត់អស់លោកឲ្យទៅរកជនជាតិអ៊ីស្រាអែលមុនគេ រួចឲ្យទៅរកមនុស្សគ្រប់ជាតិគ្រប់សាសន៍ (រម ១,១៦)។ គ្រីស្តទូតរួមចំណែកក្នុងអំណាចរបស់ព្រះអង្គ ដើម្បីណែនាំមនុស្សគ្រប់ប្រជាជាតិឲ្យទៅជាសាវ័ករបស់ព្រះអង្គ ប្រោសឲ្យគេបានវិសុទ្ធ និងគ្រប់គ្រងគេ (មថ ២៨, ១៦-២០; មក ១៦, ១៥; លក ២៤, ៤៥-៤៨) ព្រមទាំងលាតសន្ធឹងព្រះសហគមន៍ផង។ អស់លោកបម្រើព្រះសហគមន៍ក្នុងឋានៈជាគង្វាល ក្រោមការណែនាំរបស់ព្រះអម្ចាស់ ជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក (មថ ២៨, ២០)។ នៅបុណ្យថ្ងៃទីហាសិបព្រះអង្គបញ្ជាក់យ៉ាងច្បាស់ថា អស់លោកត្រូវបំពេញបេសកកម្មនេះ (កក ២, ១-២៦) តាមព្រះបន្ទូលសន្យា របស់ព្រះអម្ចាស់ថា៖ *"អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាសាក្សីរបស់ខ្ញុំនៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូលក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី"* (កក ១, ៨)។

ក្រុមគ្រីស្តទូតប្រកាសដំណឹងល្អនៅគ្រប់កន្លែង (មក ១៦, ២០) មានអ្នកស្តាប់ខ្លះ សុខចិត្តទទួលដំណឹងល្អនេះដោយព្រះវិញ្ញាណដ៏វិសុទ្ធប្រណីសន្តោស។ ដូច្នេះក្រុមគ្រីស្តទូតប្រមែប្រមូលព្រះសហគមន៍សកល ដែលព្រះអម្ចាស់បានតែងតាំងដោយក្រុមគ្រីស្តទូត និងសាងឡើងលើគ្រីស្តទូតសិលាជាមេដឹកនាំរបស់អស់លោក។ ប៉ុន្តែ ព្រះយេស៊ូផ្ទាល់ជាសរសរទ្រូងដ៏មាំវិញ (វវ ២១, ១៤; មថ ១៦, ១៨; អភ ២, ២០)។

## ២០- ក្រុមអភិបាលបន្តមុខងារពីក្រុមគ្រីស្តទូតមក

ព្រះគ្រីស្តផ្ញើបេសកកម្មឲ្យក្រុមគ្រីស្តទូត ជាបេសកកម្មមកពីព្រះជាម្ចាស់ ហើយដែលនៅស្ថិតស្ថេររហូតដល់អវសានកាលនៃពិភពលោក (មថ ២៨, ២០) ព្រោះអស់លោក ត្រូវបញ្ជូនបន្តដំណឹងល្អដែលពិតជាគោលនៃការរស់នៅទាំងមូលរបស់ព្រះសហគមន៍រហូតតរៀងទៅ។ ហេតុនេះហើយបានជាក្រុមគ្រីស្តទូត យកចិត្តទុកដាក់ តែងតាំងអ្នកបន្តមុខងាររបស់អស់លោក ក្នុងព្រះសហគមន៍ដែលជាសង្គមមានរចនាសម្ព័ន្ធ តាមលំដាប់លំដោយ។

អស់លោកមិនគ្រាន់តែមានសហការីផ្សេងៗ ជួយបំពេញមុខងារបម្រើរបស់លោកប៉ុណ្ណោះទេ តែអស់លោកហាក់ដូចជា ផ្ដែផ្ដាំឲ្យសហការីយ៉ាងជិតស្និទ្ធបង្ហើយនិងពង្រឹងកិច្ចការដែលអស់លោកបានចាប់ផ្តើមធ្វើ។ ដូច្នេះ បេសកកម្មដែលព្រះគ្រីស្តបានផ្ញើទុកមកឲ្យអស់លោក អាចបន្តបានក្រោយពីអស់លោកទទួលមរណភាពទៅ។ អស់លោកផ្ដែផ្ដាំឲ្យគេថែរក្សាហ្វូងចៀមទាំងមូល ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធ បានផ្ទុកផ្ដាក់គាត់ឲ្យឃ្វាលព្រះសហគមន៍របស់ព្រះជាម្ចាស់ក្នុងហ្វូងនោះ (កក ២០,២៨)។ ហេតុនេះ អស់លោកតែងតាំងមនុស្សបែបនេះ និងផ្ដាំថា ក្រោយពីគេទទួលមរណភាពទៅ ឲ្យតែងតាំងមនុស្សផ្សេងទៀត ដែលគេបានល្បងលមើលរួចហើយ ទទួលមុខងារបម្រើព្រះសហគមន៍បន្តពីគេ។ តាំងពីដើមដំបូងមក ក្នុងចំណោមមុខងារបម្រើព្រះសហគមន៍ មុខងារដ៏សំខាន់ជាងគេ គឺមុខងារជាអភិបាល តាមការបញ្ជូនបន្តធ្វើជាសាក្សីស្រាប់។ អស់លោកដែលទទួលមុខងារជាអភិបាល មានខ្សែស្រឡាយតាំងពីដើមដំបូងរៀងមកម្ល៉េះ។ អស់លោកប្រៀបដូចជាខ្នែងដែលគេផ្សាំសម្រាប់បន្តពូជជាគ្រីស្តទូតរហូតមក។ តាមសន្តៈ អ៊ីរេណេ ជាសាក្សី ការបញ្ជូនបន្តមុខងារជាគ្រីស្តទូត មានជាក់ច្បាស់បន្តបន្ទាប់ក្នុងពិភពលោកទាំងមូល ដោយសារអស់លោក ដែលក្រុមគ្រីស្តទូតបានតែងតាំងជាអភិបាល និងដោយសារអស់អ្នក ដែលបន្តមុខងាររបស់អស់លោករហូតមកដល់យើងនេះ។

ហេតុនេះហើយ បានជាក្រុមអភិបាលទទួលបន្ទុកបម្រើព្រះសហគមន៍ ដោយមានបូជាចារ្យ (អាចារ្យ) និងឧបដ្ឋាកជួយជាសហការីផង។ អស់លោកធ្វើជាអធិបតីព្រះសហគមន៍ក្នុងនាមព្រះជាម្ចាស់។ អស់លោកជាគង្វាល គឺមានមុខងារបម្រើព្រះសហគមន៍ ដោយបង្រៀន ដោយធ្វើជាបូជាចារ្យក្នុងពិធីបុណ្យនានា និងដោយគ្រប់គ្រងទៀតផង។ ព្រះអម្ចាស់ បានផ្ញើបន្ទុកឲ្យគ្រីស្តទូតសិលាផ្ទាល់ ជាគ្រីស្តទូតទីមួយក្នុងចំណោមគ្រីស្តទូតឯទៀតៗ។ បន្ទុកនេះត្រូវតែបញ្ជូនឲ្យអ្នកបន្តមុខងាររបស់លោក ពិតជាបន្ទុកដែលនៅស្ថិតស្ថេររហូតយ៉ាងណា ក៏បន្ទុកព្រះគ្រីស្ត ផ្ញើឲ្យក្រុមគ្រីស្តទូតជាគង្វាលព្រះសហគមន៍ ក៏ជាបន្ទុកដែលត្រូវស្ថិតស្ថេររហូតយ៉ាងនោះដែរ ដោយសារអគ្គសញ្ញាតែងតាំងជាអភិបាល។ ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធបង្រៀនថា ព្រះជាម្ចាស់ចាត់ចែងក្រុមអភិបាលឲ្យបន្តមុខងារក្រុមគ្រីស្តទូតក្នុងឋានៈជាគង្វាលព្រះសហគមន៍។ អ្នកណាស្តាប់អស់លោក ក៏ដូចជាស្តាប់ព្រះគ្រីស្តដែរ។ អ្នកណាបដិសេធមិនទទួលអស់លោក ក៏ដូចជាបដិសេធមិនទទួលព្រះគ្រីស្តដែរ ហើយថែមទាំងមិនទទួលព្រះបិតា ដែលចាត់ព្រះគ្រីស្តឲ្យមកនោះទៀតផង (លក ១០, ១៦)។

## ២១- មុខងារក្រុមអភិបាលជាអគ្គសញ្ញា

ហេតុនេះហើយ បានជាព្រះអម្ចាស់យេស៊ូគ្រីស្តជាមហាបូជាចារ្យ គង់នៅក្នុងចំណោមអស់អ្នកដែលផ្ញើជីវិត លើព្រះអង្គ ដោយសារក្រុមអភិបាល ដែលមានបូជាចារ្យជាសហការីជួយផង។ ព្រះអង្គដែលគង់ខាងស្តាំព្រះបិតា ក៏គង់នៅជាមួយក្រុមអភិបាលជានិច្ចដែរ។ ជាបឋមព្រះអង្គប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យមនុស្សគ្រប់ជាតិសាសន៍ និងប្រទានអគ្គសញ្ញានៃជំនឿឲ្យអ្នកផ្ញើជីវិតលើព្រះអង្គ ដោយសារមុខងារដ៏ប្រសើររបស់អស់លោក (១ករ ៤, ១៥)។ ព្រះអង្គក៏បញ្ចូលសមាជិកថ្មី ក្នុងព្រះកាយព្រះអង្គដោយប្រោសគេឲ្យកើតជាថ្មី ដោយមុខងាររបស់អស់លោកក្នុងឋានៈជាឪពុក។ ព្រះអង្គណែនាំនិងដាក់ទិសឲ្យប្រជារាស្ត្រនៃសម្ពន្ធមេត្រីថ្មីនៅពេលធ្វើបូជនីយេសក៏ចរ ឆ្ពោះទៅកាន់ស្ថានបរមសុខ ដោយសារប្រាជ្ញានិងការប្រុងប្រយ័ត្នរបស់អស់លោក។ ព្រះអម្ចាស់បានជ្រើសរើសគង្វាលទាំងនោះ ដើម្បីឃ្វាលថែរក្សាហ្វូងចៀមរបស់ព្រះអង្គ។ អស់លោកជាអ្នកបម្រើរបស់ព្រះគ្រីស្ត និងជាអ្នកមើលខុសត្រូវលើគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ (១ករ ៤, ១)។ ព្រះអង្គបានផ្ញើឲ្យអស់លោក មានបន្ទុកផ្តល់សក្ខីភាពអំពីដំណឹងល្អ ស្តីពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ (រម ១៥, ១៦; កក ២០, ២៤) ព្រមទាំងឲ្យអស់លោកបំពេញមុខងារបម្រើព្រះវិញ្ញាណ និងបំពេញមុខងារដែលធ្វើឲ្យមនុស្សបានសុចរិត ជាមុខងារប្រកបដោយសិរីរុងរឿង (២ករ ៣, ៨-៩)។

ព្រះគ្រីស្តបានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយាងមកសណ្ឋិតយ៉ាងពិសេស លើក្រុមគ្រីស្តទូតដើម្បីឲ្យអស់លោកអាចបំពេញបន្ទុកដ៏ខ្ពង់ខ្ពស់ទាំងនេះ (កក ១, ៨; ២, ៤; យហ ២០, ២២-២៣)។ ក្រុមគ្រីស្តទូតក៏បញ្ជូនបន្តព្រះអំណោយទានខាងព្រះវិញ្ញាណនេះ ឲ្យសហការីរបស់អស់លោក ដោយពិធីដាក់ដៃលើគេ (១ធម ៤, ១៤; ២ធម ១, ៦-៧)។ ព្រះអំណោយទាននេះត្រូវបញ្ជូនបន្តមក រហូតដល់សម័យឥឡូវ ដោយញែកអស់លោកប្រសិទ្ធជាអភិបាល។ មហាសន្និបាតដ៏វិសុទ្ធបង្រៀនថា ដោយព្រះជាម្ចាស់ញែកអស់លោកប្រសិទ្ធជាអភិបាល អស់លោកទទួលមុខងារជាបូជាចារ្យយ៉ាងពេញលេញ។ ប្រពៃណីខាងពិធីគោរពប្រណិប័តន៍របស់ព្រះសហគមន៍ និងគ្រូបាធ្យាយដ៏វិសុទ្ធតែងតែបញ្ជាក់ថា ពេលលោកអភិបាលទទួលអគ្គសញ្ញាតែងតាំងជាអភិបាល លោកទទួលមុខងារជាបូជាចារ្យយ៉ាងខ្ពង់ខ្ពស់បំផុត គឺទទួលមុខងារជាបូជាចារ្យយ៉ាងពេញកម្រិត។

ពិធីញែកប្រសិទ្ធឲ្យទៅជាអភិបាល ផ្តល់ឲ្យលោកមានបន្ទុកប្រោសឲ្យព្រះសហគមន៍បានវិសុទ្ធ ហើយក៏ធ្វើឲ្យលោកមានបន្ទុកបង្រៀននិងគ្រប់គ្រងព្រះសហគមន៍ដែរ។ តាមលក្ខណៈនៃបន្ទុកទាំងនោះ លោកអាចបំពេញបន្ទុកទាំង

នោះបាន លុះត្រាតែខ្លួនរួបរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំក្រុមអភិបាល និងរួបរួមជាមួយអភិបាលឯទៀតៗ តាមលំដាប់លំដោយទៀតផង។ ការបញ្ជូនបន្តមក ជាពិសេសពិធីបុណ្យនានា និងទម្លាប់ព្រះសហគមន៍ទាំងនៅបស្ចិមប្រទេស ទាំងនៅបូព៌ាប្រទេស បញ្ជាក់យ៉ាងជាក់ច្បាស់ថា ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានព្រះអំណោយទានដល់អស់លោក ដោយសារពិធីដាក់ដៃ និងដោយពាក្យក្នុងពិធីញែកអស់លោកប្រសិទ្ធជាអភិបាល ព្រមទាំងដៅលក្ខណៈដ៏សក្ការៈនៅក្នុងលោកទៀតដែរ។ ហេតុនេះហើយ បានជាអស់លោកអភិបាលពិតជាតំណាងរបស់ព្រះគ្រីស្ដផ្ទាល់យ៉ាងប្រសើរឲ្យមនុស្សលោកឃើញ គឺជាតំណាងរបស់ព្រះអង្គ ជាព្រះបរមគ្រូ ជាគង្វាល និងជាមហាបូជាចារ្យ។ អស់លោកក៏បំពេញតួនាទីរបស់ព្រះអង្គដែរ។ អស់លោកអភិបាលមានភារកិច្ចបញ្ចូលអ្នកដែលត្រូវគេជ្រើសថ្មី ឲ្យចូលក្នុងក្រុមអភិបាលដោយធ្វើអគ្គសញ្ញាតែងតាំងអស់លោក។

## ២២- ក្រុមអភិបាលនិងមេដឹកនាំក្រុម

ព្រះអម្ចាស់តែងតាំងគ្រីស្តទូតសិលា និងគ្រីស្តទូតឯទៀតៗ ជាក្រុមគ្រីស្តទូតតែមួយយ៉ាងណា អភិបាលព្រះសហគមន៍ក្រុងរ៉ូមដែលបន្តមុខងារពីគ្រីស្តទូតសិលាមក និងអភិបាលទាំងប៉ុន្មានដែលបន្តមុខងារពីគ្រីស្តទូតឯទៀតៗ ក៏រួមគ្នាជាក្រុមតែមួយយ៉ាងនោះដែរ។ តាមវិន័យព្រះសហគមន៍តាំងពីបរមបុរាណមក អស់លោកអភិបាលដែលត្រូវបានតែងតាំងក្នុងពិភពលោកទាំងមូល តែងតែមានទំនាក់ទំនងជាមួយគ្នា និងជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម គឺមានចំណងរួបរួមគ្នាដោយសេចក្តីស្រឡាញ់ និងដោយសេចក្តីសុខសាន្ត។ ពេលអស់លោកជួបជុំគ្នាជាមហាសន្និបាត អស់លោកក៏តែងតែរួមគ្នាសម្រេចបញ្ហាសំខាន់ៗ ដោយអស់លោកចែកចាយយោបល់គ្នាទៅវិញទៅមក នាំឲ្យអស់លោកបញ្ចេញគំនិតរួមយ៉ាងសមរម្យ។ ការណ៍ទាំងនោះ សរឲ្យឃើញថា ក្រុមអភិបាលមានលក្ខណៈជាក្រុមណែនាំព្រះសហគមន៍រួមគ្នា។ តាមប្រវត្តិសាស្ត្ររៀងមក មហាសន្និបាតសកលនានា ក៏បញ្ជាក់យ៉ាងច្បាស់អំពីលក្ខណៈរួមរបស់ក្រុមអភិបាល។ តាមទម្លាប់តាំងពីបរមបុរាណមក គេតែងតែហៅអភិបាលជាច្រើន ឲ្យចូលរួមក្នុងពិធីធ្វើអគ្គសញ្ញាតែងតាំងអភិបាលដែលត្រូវបានជ្រើសរើសថ្មី ឲ្យបំពេញមុខងារបម្រើជាបូជាចារ្យតាមកម្រិតដ៏ខ្ពង់ខ្ពស់។ ទម្លាប់នេះ ក៏ជាសញ្ញាសម្គាល់បញ្ជាក់អំពីលក្ខណៈរួមរបស់ក្រុមអភិបាល។ គ្រីស្តបរិស័ទម្នាក់ បានទៅជាសមាជិកនៃក្រុមអភិបាល ដោយអានុភាពនៃអគ្គសញ្ញាតែងតាំង ដែលញែកប្រសិទ្ធលោកធ្វើជាអភិបាល និងដោយសារគេរួបរួមជាមួយមេដឹកនាំនៃក្រុមអភិបាល ព្រមទាំងរួបរួមជាមួយអភិបាលឯទៀតៗ តាមលំដាប់លំដោយដែរ។

ក៏ប៉ុន្តែ ក្រុមអភិបាលមានអំណាច លុះត្រាតែក្រុមនោះរួបរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ក្នុងឋានៈលោកជាមេដឹកនាំ។ ត្រូវយល់ថា អំណាចក្រុមអភិបាលនោះមិនបន្ថយអំណាចរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលនៅតែមានអំណាចដដែល គឺជាប្រធានលើគ្រីស្តបរិស័ទទាំងអស់ ទាំងលើអភិបាលឯទៀតៗជាគង្វាល ទាំងលើគ្រីស្តបរិស័ទធម្មតាផងដែរ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម មានអំណាចពេញលេញលើព្រះសហគមន៍ គឺអំណាចដ៏ខ្ពង់ខ្ពស់បំផុតនិងសកល ដែលលោកមានសេរីភាពអាចប្រើបានជានិច្ច ដោយអានុភាពនៃបន្ទុករបស់លោកជាតំណាងព្រះគ្រីស្ត និងជាគង្វាលនៃព្រះសហគមន៍ទាំងមូល។ ក្រុមអភិបាលបន្តមុខងារបម្រើពីក្រុមគ្រីស្តទូតមក គឺមុខងារបង្រៀននិងគ្រប់គ្រងក្នុងឋានៈជាគង្វាល (បើនិយាយយ៉ាងប្រសើរជាង ក្រុមគ្រីស្តទូតបន្តជីវិតរបស់ខ្លួន ដោយសារក្រុមអភិបាល)។ អស់លោកក៏មានអំណាចដ៏ខ្ពង់ខ្ពស់បំផុត និងអំណាចពេញទីលើព្រះសហគមន៍សកលដែរ លុះត្រាតែក្រុមអភិបាលរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំក្រុមអភិបាលនោះ គឺមិនត្រូវដាច់ពីអភិបាលព្រះសហគមន៍ក្រុងរ៉ូមឡើយ។ ក្រុមអភិបាលអាចប្រើអំណាចនេះបាន លុះត្រាតែអភិបាល

ព្រះសហគមន៍ក្រុងរ៉ូមយល់ស្រប។ ព្រះអម្ចាស់តែងតាំងតែលោកស៊ីម៉ូនម្នាក់ប៉ុណ្ណោះ ជាផ្ទាំងសិលាសម្រាប់សាងសង់ព្រះសហគមន៍របស់ព្រះអង្គ ហើយក៏បានប្រគល់កូនសោរនៃព្រះសហគ-មន៍ឲ្យលោកស៊ីម៉ូនតែម្នាក់គត់ដែរ (មថ ១៦, ១៨.១៩) ព្រះអង្គតែងតាំងលោកជាគង្វាលនៃហ្វូងចៀមទាំងមូល (យហ ២១, ១៥ត)។ ព្រះអង្គ ប្រទានឲ្យលោកសិលាមានបន្ទុកចងនិងស្រាយ (មថ ១៦, ១៩) ប៉ុន្តែ ព្រះអង្គក៏បានប្រទានបន្ទុកនេះយ៉ាងពិតប្រាកដ ឲ្យក្រុមគ្រីស្តទូតដែលរួមជាមួយមេដឹកនាំរបស់អស់លោកដែរ (មថ ១៨, ១៨; ២៨, ១៦-២០)។

ដោយក្រុមអភិបាលនេះ មានសមាជិកច្រើនប្លែកៗពីគ្នាយ៉ាងណា ក្រុមនេះបង្ហាញបញ្ជាក់ថា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក៏ប្លែកៗពីគ្នាជាសកលយ៉ាងនោះដែរ។ ដោយក្រុមអភិបាលនោះ រួមគ្នាក្រោមអំណាចមេដឹកនាំតែមួយយ៉ាងណា ក្រុមនេះក៏បង្ហាញបញ្ជាក់ថា ហ្វូងចៀមរបស់ព្រះគ្រីស្តរួមគ្នាជាធ្លុងតែមួយយ៉ាងនោះដែរ។ ក្នុងក្រុមអភិបាលនេះ អស់លោកដែលគោរពអំណាចអភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងឋានៈជាប្រធាន និងជាមេដឹកនាំដោយចិត្តស្មោះ អស់លោកក៏មានអំណាចផ្ទាល់ ដើម្បីជាប្រយោជន៍ដល់គ្រីស្តបរិស័ទរបស់ខ្លួន និងរបស់ព្រះសហគមន៍ទាំងមូលដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធនៅតែពង្រឹងរចនាសម្ពន្ធរបស់ព្រះសហគមន៍តាមលំដាប់លំដោយ និងប្រោសព្រះសហគមន៍ ឲ្យចុះសម្រុងគ្នាជានិច្ចបាន ដោយឫទ្ធានុភាពរបស់ព្រះអង្គ។ ក្រុមអភិបាលប្រើអំណាចដ៏ខ្ពង់ខ្ពស់បំផុតលើព្រះសហគមន៍សកល យ៉ាងឱឡារិកនៅពេលអស់លោកប្រជុំគ្នាជាមហាសន្និបាតសកល។ មហាសន្និបាតសកលកើតឡើង លុះត្រាតែអភិបាលដែលបន្តមុខងារពីគ្រីស្តទូតសិលាមក បញ្ជាក់ ឬយ៉ាងហោចណាស់ សុខចិត្តទទួលស្គាល់មហាសន្និបាតនោះ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម មានឯកសិទ្ធិកោះហៅមហាសន្និបាតសកលទាំងនោះ និងធ្វើជាអធិបតីមហាសន្និបាតហើយបញ្ជាក់សេចក្តីសម្រេចនៃមហាសន្និបាតទាំងនោះ។ អស់លោកអភិបាលដែលរស់នៅលើផែនដីទាំងមូល អាចប្រើអំណាចរួមនេះ រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូមបាន លុះត្រាតែអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំក្រុមអភិបាល កោះហៅអស់លោកឲ្យបំពេញការងាររួម ឬយ៉ាងហោចណាស់ លុះត្រាតែលោកយល់ស្របឲ្យអភិបាលដែលខ្ចាត់ខ្ចាយនៅលើផែនដីទាំងមូលបំពេញការងាររួមនេះ ឬសុខចិត្តទទួលស្គាល់នូវសេចក្តីសម្រេចនៃមហាសន្និបាតនោះ ដោយលោកមានសេរីភាពពេញទី ទើបកិច្ចការរបស់អស់លោក ពិតទៅជាកិច្ចរួមនៃក្រុមអភិបាលបាន។

## ២៣- ទំនាក់ទំនងក្នុងក្រុមអភិបាល

អភិបាលម្នាក់ៗមានទំនាក់ទំនងជាមួយព្រះសហគមន៍ភូមិភាគនានា ហើយជាមួយព្រះសហគមន៍សកលដែរ។ ទំនាក់ទំនងគ្នាទៅវិញទៅមកទាំងនេះ បង្ហាញឲ្យដឹងថា ក្រុមអភិបាលរួមគ្នាជាធ្លុងតែមួយ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងឋានៈលោកបន្តមុខងារពីគ្រីស្តទូតសិលាមក លោកជាគោលអចិន្ត្រៃយ៍ដែលមើលឃើញបាន ហើយជាគ្រឹះធ្វើជាចំណងចងអស់អភិបាលប៉ុន្មានឲ្យភ្ជាប់ជាមួយគ្នា និងឲ្យគ្រីស្តបរិស័ទទាំងអស់រួមគ្នាជាធ្លុងតែមួយដែរ។ អភិបាលម្នាក់ៗតាមចំណែករៀងៗខ្លួន ក៏ជាគោល និងជាគ្រឹះធ្វើឲ្យព្រះសហគមន៍ភូមិភាគរបស់ខ្លួន រួបរួមជាធ្លុងតែមួយដែរ។ ព្រះសហគមន៍ភូមិភាគនីមួយៗក៏មានការចាត់ចែងដូចព្រះសហគមន៍សកលដែរ។ មានព្រះសហគមន៍សកលតែមួយគត់ ដោយសារមានព្រះសហគមន៍ភូមិភាគនានា និងនៅក្នុងព្រះសហគមន៍ភូមិភាគនានា។ ហេតុនេះហើយបានជាអភិបាលម្នាក់ៗ ជាតំណាងព្រះសហគមន៍របស់ខ្លួន ហើយអភិបាលទាំងអស់ រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាតំណាងព្រះសហគមន៍សកល ដោយជាប់ចំណងគ្នាដោយសន្តិភាព ដោយសេចក្តីស្រឡាញ់ និងដោយរួបរួមគ្នា។

អស់លោកអភិបាល ត្រូវបានតែងតាំងធ្វើជាប្រមុខព្រះសហគមន៍ភូមិភាគនីមួយៗ។ អស់លោកប្រើអំណាចតាមចំណែករៀងៗខ្លួន ក្នុងឋានៈជាគង្វាលនៃផ្នែកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានផ្ញើទុកមកលោក។

អស់លោកមិនអាចប្រើអំណាចនេះលើព្រះសហគមន៍ដទៃទៀត ឬលើព្រះសហគមន៍សកលបានឡើយ។ ប៉ុន្តែ ក្នុងឋានៈអស់លោកជាសមាជិកក្រុមអភិបាល និងក្នុងឋានៈជាអ្នកបន្តមុខងារពីក្រុមគ្រីស្តទូតយ៉ាងពេញច្បាប់អភិបាលម្នាក់ៗ ក៏ត្រូវតែយកចិត្តទុកដាក់នឹងព្រះសហគមន៍សកលដែរ តាមការតែងតាំងនិងតាមបញ្ជារបស់ព្រះគ្រីស្ត។ ទោះបីអភិបាលព្រះសហគមន៍ភូមិភាគ មិនធ្វើកិច្ចការអ្វី សម្រាប់គ្រប់គ្រងព្រះសហគមន៍សកលក្តី ក៏ការយកចិត្តទុកដាក់នេះ មានប្រយោជន៍ដល់ព្រះសហគមន៍សកលយ៉ាងខ្លាំងដែរ។ អស់លោកអភិបាលត្រូវពង្រឹង និងរក្សាការពារឯកភាពនៃជំនឿនិងវិន័យរួម ក្នុងព្រះសហគមន៍ទាំងឡាយ ត្រូវអប់រំគ្រីស្តបរិស័ទ ឲ្យស្រឡាញ់ព្រះកាយដ៏អាថ៌កំបាំងទាំងមូល របស់ព្រះគ្រីស្ត ជាពិសេសឲ្យមានចិត្តស្រឡាញ់ជនក្រីក្រ ជនរងទុក្ខលំបាក និងអស់អ្នកដែលត្រូវគេបៀតបៀនធ្វើបាបព្រោះតែយុត្តិធម៌ (មថ ៥,១០)។ មិនតែប៉ុណ្ណោះ អស់លោកត្រូវពង្រីក និងពង្រឹងសកម្មភាពរួមរបស់ព្រះសហគមន៍ទាំងមូល ជាពិសេសដោយមានបំណងចង់ឲ្យជំនឿចម្រើនឡើង ដើម្បីឲ្យពន្លឺនៃសេចក្តីពិតដ៏គ្រប់លក្ខណៈរះឡើងបំភ្លឺមនុស្សទាំងអស់។ យើងដឹងច្បាស់ថា ដោយអស់លោកគ្រប់គ្រងព្រះសហ-គមន៍របស់ខ្លួនផ្ទាល់ ទុកជាចំណែកមួយនៃព្រះសហគមន៍សកល អស់លោករួមសហការយ៉ាងសកម្ម ដើម្បីជាប្រយោជន៍របស់ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត ដែលជាព្រះកាយរបស់ព្រះសហគមន៍ទាំងឡាយដែរ។

ក្រុមអភិបាលជាគង្វាល មានភារកិច្ចប្រកាសដំណឹងល្អនៅលើផែនដីទាំងមូល។ ព្រះគ្រីស្តបានផ្តាំ បញ្ជាឲ្យអស់លោកអភិបាល មានភារកិច្ចរួម តាមសេចក្តីដែលលោកសេឡេស្តាំង ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម រំឭកអស់លោកដែលចូលរួមក្នុងមហាសន្និបាតក្រុងអេភេសូកាលពីដើម។

ហេតុនេះហើយ បានជាលោកអភិបាលម្នាក់ៗ តាមចំណែករៀងៗខ្លួននិងតាមបន្ទុករបស់ខ្លួនផ្ទាល់អនុញ្ញាតឲ្យត្រូវសុខចិត្តខិតខំធ្វើការរួមគ្នា និងរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបានទទួលបន្ទុកពិសេសយ៉ាងធ្ងន់ ពីព្រះអម្ចាស់ គឺផ្សព្វផ្សាយនាមជាគ្រីស្តបរិស័ទ។ ហេតុនេះហើយ បានជាអស់លោកត្រូវខិតខំឲ្យអស់ពីសមត្ថភាព ជួយដល់ព្រះសហគមន៍ក្នុងប្រទេស ដែលមានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត ឲ្យមានអ្នកទៅច្រូតស្រូវក្នុងស្រែរបស់ព្រះអម្ចាស់។ ត្រូវផ្តល់ជំនួយខាងព្រះវិញ្ញាណ និងខាងសម្ភារៈ ដោយខ្លួនលោកផ្ទាល់ ឬដោយដាស់តឿនគ្រីស្តបរិស័ទឲ្យខ្នះខ្នែងរួមសហការជាមួយព្រះសហគមន៍ទាំងនោះ។ អស់លោកអភិបាល ក៏ត្រូវមានចិត្តទូលាយជួយផ្តល់ជំនួយដល់ព្រះសហគមន៍ឯទៀតៗជាបងប្អូន ជាពិសេសដល់ព្រះសហគមន៍នៅជិតខាងដែលខ្វះខាត។ ត្រូវរួបរួមគ្នា ជាមួយព្រះសហគមន៍ទាំងនោះដោយសេចក្តីស្រឡាញ់ តាមគំរូដ៏ប្រសើររបស់ព្រះសហគមន៍ពីដើម។

ក្រុមគ្រីស្តទូត និងអស់លោកដែលបន្តមុខងារពីក្រុមគ្រីស្តទូតមក បានតែងតាំងព្រះសហគមន៍នៅកន្លែងផ្សេងៗ។ តាមប្រវត្តិសាស្ត្រ ព្រះជាម្ចាស់ដែលថែទាំមនុស្សលោក ទ្រង់សព្វព្រះហឫទ័យឲ្យព្រះសហគមន៍ទាំងនោះរួបរួមគ្នាជាក្រុមតាមតំបន់។ ក្រុមព្រះសហហគមន៍ទាំងនោះមានរចនាសម្ពន្ធត្រឹមត្រូវ មានវិន័យ មានក្បួនពិធីគោរពប្រណិប័តន៍របស់ខ្លួនផ្ទាល់ មានបេតិកភ័ណ្ឌខាងទេវវិទ្យា និងខាងព្រះវិញ្ញាណផ្ទាល់ដែរ។ ទោះបី មានក្រុមព្រះសហគមន៍ជាច្រើនប្លែកៗពីគ្នាដូច្នេះក្តី ក៏គេមិនធ្វើឲ្យជំនឿអន់ថយ និងមិនបែកចេញពីរចនាសម្ពន្ធតែមួយដែលព្រះជាម្ចាស់សព្វព្រះហឫទ័យតែងតាំងសម្រាប់ព្រះសហគមន៍សកលឡើយ។ មានព្រះសហគមន៍ខ្លះពីបុរាណ ជាពិសេសព្រះសហគមន៍នៅបូព៌ាប្រទេស ដែលមានអភិបាលដ៏ប្រសើរឧត្តមណែនាំ បានទៅជា *"ស្បូន"* ខាងជំនឿ ហើយបង្កើតព្រះសហគមន៍ឯទៀតៗដែលប្រៀបដូចជាកូនស្រីរបស់គេ។ ព្រះសហគមន៍ទាំងនោះ ជាប់ចំណងដោយសេចក្តីស្រឡាញ់យ៉ាងជិតស្និទ្ធ ភ្ជាប់គ្នាដោយធ្វើអគ្គសញ្ញាដូចគ្នា ហើយគោរពសិទ្ធិ និងភារកិច្ចរបស់ខ្លួនទៅវិញទៅមក រហូតដល់សព្វថ្ងៃ។ ដោយព្រះសហគមន៍

តាមតំបន់ប្លែកៗពីគ្នាច្រើនយ៉ាងនេះ តែរួមគ្នាជាធ្លុងតែមួយ សរឲ្យឃើញកាន់តែច្បាស់ថា ព្រះសហគមន៍មានលក្ខណៈជា *"កាតូលិក"* គឺសកល ដែលមិនអាចបំបែកបានឡើយ។ យ៉ាងណាមិញ សព្វថ្ងៃ ក្រុមអភិបាលតាមប្រទេសនីមួយៗ ដែលរួមសហការតាមរបៀបផ្សេងៗដែលបង្កើតផល ធ្វើឲ្យគោលគំនិតនៃការណែនាំរួមរបស់ក្រុមអភិបាល កើតជារូបរាង យ៉ាងជាក់ច្បាស់។

## ២៤- មុខងារបម្រើរបស់លោកអភិបាល

ព្រះអម្ចាស់ដែលទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ព្រះអង្គប្រទានឲ្យអស់លោកអភិបាល ក្នុងឋានៈជាអ្នកបន្តមុខងារពីក្រុមគ្រីស្តទូតមក មានបេសកកម្មបង្រៀនមនុស្សគ្រប់ជាតិសាសន៍ និងប្រកាសដំណឹងល្អដល់សត្វលោកទាំងឡាយ ដើម្បីឲ្យមនុស្សលោកទាំងអស់ទទួលការសង្គ្រោះដោយផ្ញើជីវិតលើព្រះគ្រីស្ត ដោយទទួលអគ្គសញ្ញាជ្រមុជទឹក និងដោយប្រតិបត្តិតាមវិន័យទាំងប៉ុន្មាន (មថ ២៨, ១៨; មក ១៦, ១៥-១៦; កក ២៦, ១៧ត)។ ព្រះគ្រីស្តសន្យាថា នឹងប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យក្រុមគ្រីស្តទូត ដើម្បីឲ្យអស់លោកអាចបំពេញបេសកកម្មនោះបាន។ នៅបុណ្យថ្ងៃទីហាសិប ព្រះអង្គចាត់ព្រះវិញ្ញាណពីស្ថានបរមសុខមក ដើម្បីឲ្យក្រុមគ្រីស្តទូត ធ្វើជាសាក្សីរបស់ព្រះអង្គ រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី នៅចំពោះមុខប្រជាជាតិ ប្រជាជន និងស្តេចនានា ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណនោះ (កក ១, ៨; ២, ១ត; ៩, ១៥)។ ព្រះអម្ចាស់បានផ្ញើបន្ទុកនេះ ឲ្យគង្វាលនៃប្រជារាស្ត្ររបស់ព្រះអង្គ ទុកជាកិច្ចបម្រើដ៏ពិតប្រាកដ។ ក្នុងគម្ពីរមានចែងយ៉ាងជាក់ច្បាស់ថា បន្ទុកនេះពិតជា *"មុខងារបម្រើ"* (កក ១, ១៧ និង ២៥; ២១, ១៩; រម ១១, ១៣; ១ធម ១, ១២)។

### ព្រះសហគមន៍ប្រគល់បេសកកម្មជាអភិបាល តាមរបៀបផ្សេងៗពីគ្នាគឺ៖

- តាមប្រពៃណីដ៏ត្រឹមត្រូវ ដែលអភិបាលព្រះសហគមន៍ក្រុងរ៉ូមមិនបានលុបចោល ក្នុងឋានៈលោកកាន់អំណាចដ៏ខ្ពង់ខ្ពស់និងសកលលើព្រះសហគមន៍ទាំងមូល។
- តាមច្បាប់អភិបាលព្រះសហគមន៍ក្រុងរ៉ូមបានបង្កើត ឬទទួលស្គាល់។

ដោយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ប្រគល់ដោយខ្លួនលោកផ្ទាល់។ ប្រសិនបើ អភិបាលព្រះសហគមន៍ក្រុងរ៉ូម ជំទាស់នឹងការតែងតាំងអភិបាលណាម្នាក់ ឬមិនព្រមឲ្យអភិបាលណាម្នាក់រួបរួមជាមួយក្រុមគ្រីស្តទូត អភិបាលនោះមិនអាចបំពេញមុខងារជាអភិបាលបានឡើយ។

## ២៥- អភិបាលមានមុខងារបង្រៀនព្រះសហគមន៍

ក្នុងចំណោមបន្ទុកដ៏សំខាន់ទាំងប៉ុន្មាន លោកអភិបាលមានបន្ទុកប្រកាសដំណឹងល្អជាបន្ទុកចម្បង។ អភិបាលប្រកាសជំនឿ គឺណែនាំសាវ័កថ្មីឲ្យមករកព្រះគ្រីស្ត។ អស់លោកក៏ជាគ្រូគួរឲ្យទុកចិត្ត គឺជាគ្រូដែលទទួលអំណាចរបស់ព្រះគ្រីស្ត។ អស់លោកប្រកាសជំនឿឲ្យប្រជារាស្ត្រ ដែលព្រះជាម្ចាស់បានផ្ញើទុកមកឲ្យអស់លោក គឺជំនឿដែលបំភ្លឺ និងណែនាំចិត្តគំនិត និងកិរិយាមារយាទរបស់គេ ព្រមទាំងបញ្ចាំងរស្មីនៃជំនឿនេះក្រោមពន្លឺនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ លោកយកទ្រព្យថ្មី និងទ្រព្យចាស់ពីឃ្លាំងនៃសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ មកចែកឲ្យគេ (មថ ១៣, ៥២) លោកនាំឲ្យជំនឿបង្កើតផលផ្លែ ទាំងប្រុងប្រយ័ត្ន កុំឲ្យសេចក្តីមិនពិតទាំងប៉ុន្មាន បណ្តាលឲ្យហ្វូងចៀមរបស់ខ្លួនវង្វេងឡើយ (២ធម ៤, ១-៤)។

គ្រីស្តបរិស័ទ ត្រូវតែគោរពអស់លោកអភិបាលដែលបង្រៀនគេ ទាំងរួបរួមជាមួយនឹងអភិបាលព្រះសហគមន៍ក្រុងរ៉ូម គឺត្រូវគោរពអស់លោកក្នុងឋានៈជាសាក្សីនៃសេចក្តីពិត អំពីព្រះជាម្ចាស់ និងសេចក្តីពិតកាតូលិកដែរ។ គ្រីស្តបរិស័ទត្រូវភ្ជាប់ចិត្តនឹងគំនិតរបស់លោកអភិបាល ក្នុងវិស័យលទ្ធិនៃជំនឿ និងសីលធម៌ដែលលោកបញ្ចេញ ក្នុងនាមព្រះគ្រីស្ត គេត្រូវភ្ជាប់ចិត្តនឹងសេចក្តីទាំងនោះដោយគោរពក្នុងនាមសាសនា។ គ្រីស្តបរិស័ទក៏ត្រូវភ្ជាប់សេចក្តីប៉ងប្រាថ្នាជាមួយនឹងប្រាជ្ញា យ៉ាងពិសេសនឹងការបង្រៀនយ៉ាងពិតប្រាកដរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម សូម្បីតែនៅពេលដែលលោកមិនប្រកាសសេចក្តីក្នុងឋានៈលោក ជាអ្នកបន្តមុខងាររបស់គ្រីស្តទូតសិលាមកក៏ដោយ ក៏ត្រូវភ្ជាប់ចិត្តនឹងសេចក្តីទាំងនោះដែរ។ គ្រីស្តបរិស័ទ ត្រូវទទួលស្គាល់មុខងារបង្រៀនដ៏ខ្ពង់ខ្ពស់របស់លោកដោយគោរព។ គេក៏ត្រូវភ្ជាប់ចិត្តយ៉ាងស្មោះ នូវសេចក្តីដែលលោកប្រកាសស្របតាមគំនិត និងតាមបំណងប្រាថ្នារបស់លោក។ គ្រីស្តបរិស័ទអាចស្គាល់គំនិត និងតាមបំណងប្រាថ្នា ដោយពិនិត្យពិច័យលក្ខណៈនៃឯកសារ ឬរបៀបដែលលោកទទូចបង្រៀនលទ្ធិមួយ និងរបៀបដែលលោកបញ្ចេញយោបល់ដែរ។

អភិបាលម្នាក់ៗអាចភាន់ច្រឡំបាន គឺគ្មានឯកសិទ្ធិជៀសវៀងមិនឲ្យភាន់ច្រឡំបាន។ ក៏ប៉ុន្តែ ពេលអស់លោកដែលខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូល រក្សាចំណងនៃការរួបរួមគ្នាទៅវិញទៅមក និងរួបរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក នៅពេលនោះ ប្រសិនបើអស់លោកព្រមព្រៀងគ្នា បង្រៀនសេចក្តីណាមួយក្នុងវិស័យលទ្ធិនៃជំនឿ និងវិស័យសីលធម៌យ៉ាងពិតប្រាកដ ហើយប្រកាសទៀតថា សេចក្តីនេះគ្រីស្តបរិស័ទត្រូវតែជឿជាដាច់ខាត គឺពេលនោះអស់លោក ពិតជាប្រកាសលទ្ធិរបស់ព្រះគ្រីស្តមែន ដោយមិនអាចភាន់ច្រឡំបានឡើយ។ ច្បាស់ជាងនេះទៅទៀត នៅពេលអស់លោកប្រជុំគ្នាជាមហាសន្និបាតសកល អស់លោកពិតជាបំពេញមុខងារជាគ្រូបង្រៀន និងជាចៅក្រមសម្រាប់ព្រះសហគមន៍ទាំងមូល ក្នុងវិស័យលទ្ធិនៃជំនឿនិងសីលធម៌។ គ្រីស្តបរិស័ទត្រូវតែភ្ជាប់ចិត្តនឹងសេចក្តីបញ្ជាក់គោលលទ្ធិទាំងនោះដោយគោរព ក្នុងនាមខ្លួនជាអ្នកជឿលើព្រះគ្រីស្ត។

ព្រះយេស៊ូជាព្រះសង្គ្រោះ ទ្រង់សព្វព្រះហឫទ័យប្រោសឲ្យព្រះសហគមន៍ មិនអាចភាន់ច្រឡំបាន ក្នុងវិស័យបញ្ជាក់លទ្ធិនៃជំនឿនិងសីលធម៌។ ព្រះសហគមន៍ក៏មិនអាចភាន់ច្រឡំបាន ក្នុងករណីថែរក្សាឲ្យបានវិសុទ្ធ និងពន្យល់យ៉ាងស្មោះនូវសេចក្តីទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ និងផ្ញើទុកឲ្យព្រះសហគមន៍ដែរ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម មានឯកសិទ្ធិមិនអាចភាន់ច្រឡំបាន ក្នុងឋានៈលោកទទួលបន្ទុកជាមេដឹកនាំក្រុមអភិបាល និងក្នុងឋានៈជាគង្វាល និងជាគ្រូដ៏ខ្ពង់ខ្ពស់បំផុតរបស់គ្រីស្តបរិស័ទទាំងឡាយ។ លោកទទួលភារកិច្ចគាំទ្របងប្អូនក្នុងជំនឿ (លក ២២, ៣២)។ នៅពេលលោកប្រកាសអំពីប្រការមួយ ក្នុងវិស័យលទ្ធិនៃជំនឿនិងសីលធម៌ទុកជាកិច្ចសម្រេចជាស្ថាពរ លោកមិនអាចភាន់ច្រឡំបានឡើយ។ ហេតុនេះហើយ បានជាគេធ្លាប់និយាយយ៉ាងត្រឹមត្រូវថា សេចក្តីទាំងប៉ុន្មានដែលលោកប្រកាសបញ្ជាក់របៀបនេះ មិនអាចប្រែប្រួលបាន ព្រោះសេចក្តីទាំងនោះ មិនមែនមកពីព្រះសហគមន៍យល់ស្របទេ តែមកពីលោកបានប្រកាសបញ្ជាក់ដោយព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភ តាមព្រះបន្ទូលសន្យា ក្នុងឋានៈលោកបន្តមុខងារពីគ្រីស្តទូតសិលាមក។ ហេតុនេះហើយ បានជាលោកមិនត្រូវការអ្នកឯទៀតៗយល់ស្របទេ ហើយក៏គ្មាននរណាទៅប្តឹងឲ្យអ្នកខ្ពស់ជាងលោកវិនិច្ឆ័យបានដែរ។ ឯកសិទ្ធិនេះមកពីអភិបាលព្រះសហគមន៍ក្រុងរ៉ូម មិនប្រកាសសេចក្តីក្នុងឋានៈជាបុគ្គលទេ តែលោកបកស្រាយ និងការពារលទ្ធិនៃជំនឿកាតូលិកក្នុងឋានៈលោកជាគ្រូដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះសហគមន៍សកល ហើយក្នុងឋានៈលោកបានទទួលព្រះអំណោយទានយ៉ាងពិសេស ក្នុងខ្លួនលោកផ្ទាល់ មិនអាចភាន់ច្រឡំបាន ជាព្រះអំណោយទានរបស់ព្រះសហគមន៍ដែលមិនអាចភាន់ច្រឡំបានឡើយ។ ក្រុមអភិបាលក៏មានឯកសិទ្ធិមិនអាចភាន់ច្រឡំបាននោះ តាមព្រះបន្ទូលសន្យារបស់ព្រះគ្រីស្តមកព្រះសហគមន៍ នៅពេល

ក្រុមអភិបាលបំពេញមុខងារបង្រៀនយ៉ាងខ្ពង់ខ្ពស់ រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក។ ព្រះសហគមន៍ត្រូវតែយល់ស្របតាមសេចក្តីប្រកាសបញ្ជាក់ទាំងនោះជានិច្ច ព្រោះមានព្រះវិញ្ញាណដ៏វិសុទ្ធថែរក្សាហ្វូងចៀមទាំងមូលរបស់ព្រះគ្រីស្ត ឲ្យរួបរួមគ្នាក្នុងជំនឿតែមួយ និងប្រោសឲ្យហ្វូងចៀមនោះចម្រើនឡើង។

ពេលអភិបាលព្រះសហគមន៍ក្រុងរ៉ូម ឬក្រុមអភិបាលទាំងអស់រួមជាមួយលោក ប្រកាសសេចក្តីបញ្ជាក់ណាមួយ អស់លោកប្រកាសស្របតាមសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ គ្រីស្តបរិស័ទទាំងអស់ក៏ត្រូវជឿ និងអនុវត្តតាមសេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់នោះ តាមព្រះសហគមន៍បានបញ្ជូនបន្តមកយ៉ាងពេញលេញ ជាលាយលក្ខអក្សរ ឬជាពាក្យសម្តីនិយាយតៗគ្នា តាមរយៈក្រុមអភិបាលដែលបន្តមុខងារពីក្រុមគ្រីស្តទូតមកយ៉ាងត្រឹមត្រូវតាមច្បាប់ ហើយជាពិសេស តាមរយៈអភិបាលព្រះសហគមន៍ក្រុងរ៉ូមផ្ទាល់ដែលយកចិត្តទុកដាក់ប្រកាសបញ្ជាក់សេចក្តីទាំងនោះ។ ព្រះសហគមន៍ថែរក្សាសេចក្តីទាំងអស់ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ដោយឥតល្អៀង ហើយពន្យល់សេចក្តីទាំងនោះ ដោយមិនប្រែប្រួល តាមព្រះវិញ្ញាណនៃសេចក្តីពិតបំភ្លឺ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម និងក្រុមអភិបាលត្រូវយកចិត្តទុកដាក់ខិតខំពិនិត្យពិច័យ និងបកស្រាយសេចក្តីទាំងនោះ យ៉ាងសមរម្យ ទាំងប្រើគ្រប់មធ្យោបាយដែលអស់លោកត្រូវការ ដោយយល់ឃើញថា ជាភារកិច្ចជាទម្ងន់របស់ខ្លួន និងមានសារៈសំខាន់ផង។ ក៏ប៉ុន្តែ អស់លោកមិនត្រូវទទួលសេចក្តីថ្មីជាសាធារណៈ ទុកជាសេចក្តីដែលព្រះជាម្ចាស់បានផ្ញើមកព្រះសហគមន៍នោះទេ។

## ២៦- លោកអភិបាលមានមុខងារណែនាំគ្រីស្តបរិស័ទឲ្យបានវិសុទ្ធ

លោកអភិបាល ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យយ៉ាងពេញលេញរួចហើយ ហេតុនេះហើយបានជាលោកទទួលខុសត្រូវនិងចែករំលែកព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ក្នុងឋានៈលោកជាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត ជាពិសេសក្នុងអគ្គសញ្ញាអរព្រះគុណ ដែលលោកថ្វាយដោយខ្លួនលោកផ្ទាល់ ឬដោយចាត់ចែងឲ្យគេថ្វាយ ព្រោះអគ្គសញ្ញាអរព្រះគុណនេះ ជាប្រភពមិនចេះរីងស្ងួតនៃជីវិតរបស់ព្រះសហគមន៍ និងធ្វើឲ្យព្រះសហគមន៍ចម្រើនឡើងផង។ ព្រះសហគមន៍របស់ព្រះគ្រីស្តនេះ ពិតជាស្ថិតនៅក្នុងគ្រប់អង្គប្រជុំត្រឹមត្រូវតាមវិន័យរបស់គ្រីស្តបរិស័ទ នៅតាមភូមិនានា បើគេរួមជាមួយគង្វាលរបស់គេ។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី អង្គប្រជុំទាំងនោះ ទទួលឈ្មោះថា *"ព្រះសហគមន៍"*។

នៅកន្លែងមួយ ព្រះសហគមន៍នីមួយៗ ពិតជាប្រជារាស្ត្រថ្មី ដែលព្រះជាម្ចាស់បានត្រាស់ហៅ ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យមានចិត្តនឹងនយ៉ាងខ្លាំង (១ថស ១, ៥)។ ការប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ត ប្រមែប្រមូលគ្រីស្តបរិស័ទក្នុងព្រះសហគមន៍ទាំងនោះ គេក៏នាំគ្នាលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃពិធីជប់លៀងរបស់ព្រះអម្ចាស់ "ដើម្បីឲ្យក្រុមបងប្អូនទាំងអស់រួបរួមគ្នាកាន់តែជិតស្និទ្ធក្នុងព្រះកាយតែមួយ ដោយសាច់និងព្រះលោហិតរបស់ព្រះអម្ចាស់"។ ពេលណាព្រះសហគមន៍ថ្វាយអភិបូជា ក្រោមការណែនាំរបស់លោកអភិបាល ដែលទទួលអគ្គសញ្ញាតែងតាំងដ៏សក្ការៈ ពេលនោះនិមិត្តរូបនៃសេចក្តីស្រឡាញ់ លេចធ្លោឡើងយ៉ាងច្បាស់ ហើយ *"គ្រីស្តបរិស័ទ ក៏រួបរួមគ្នាជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត។ ក្រៅពីការរួមក្នុងព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តនេះ គ្មាននរណាអាចទទួលការសង្គ្រោះបានឡើយ"*។ ទោះបីសហគមន៍ទាំងនេះតូច ឬក្រីក្រយ៉ាងណាក្តី ខ្ចាត់ខ្ចាយយ៉ាងណាក្តី ក៏ព្រះគ្រីស្តគង់នៅជាមួយដែរ។ ឫទ្ធានុភាពរបស់ព្រះអង្គ តែងតាំងឲ្យព្រះសហគមន៍ឲ្យមានលក្ខណៈបួន គឺរួបរួមជាអង្គតែមួយ ជាព្រះសហគមន៍ដ៏វិសុទ្ធ ជាកាតូលិកសកល និងកាន់តាមជំនឿរបស់គ្រីស្តទូត។ *"ពេលយើងទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត យើងផ្លាស់ប្រែឲ្យទៅជាព្រះកាយដែលយើងទទួលនោះ"*។

ក៏ប៉ុន្តែ លោកអភិបាលណែនាំគ្រប់អភិបូជាត្រឹមត្រូវតាមច្បាប់ ព្រោះលោកបានទទួលបន្ទុកគោរព បម្រើព្រះជាម្ចាស់ដ៏ប្រសើរឧត្ដមបំផុតតាមរបៀបគ្រីស្តសាសនា និងបានទទួលការចាត់ចែង និងគ្រប់គ្រងតាមព្រះបញ្ញារបស់ព្រះអម្ចាស់ផង និងតាមច្បាប់របស់ព្រះសហគមន៍ផងដែរ។ លោកបញ្ជាក់ច្បាប់ទាំងនោះ សម្រាប់ភូមិភាគរបស់លោកតាមលោករិះគិតពិចារណា។

ហេតុនេះហើយ បានជាអស់លោកអភិបាលដែលអធិដ្ឋាន និងធ្វើការ ដើម្បីជាប្រយោជន៍ដល់ប្រជាជនរបស់ខ្លួនមុខជានឹងចាក់បង្ហូរគ្រប់លក្ខណៈសម្បត្តិនៃភាពដ៏វិសុទ្ធរបស់ព្រះគ្រីស្ត លើប្រជាជននោះយ៉ាងបរិបូរណ៍ តាមរបៀបផ្សេងៗ។ ពេលអស់លោកបំពេញមុខងារបម្រើព្រះបន្ទូល អស់លោកបញ្ជូនឫទ្ធានុភាពរបស់ព្រះជាម្ចាស់សម្រាប់សង្គ្រោះអស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ (រម ១, ១៦)។ ពេលអស់លោកចាត់ចែងឲ្យបូជាចារ្យធ្វើអគ្គសញ្ញានានាយ៉ាងទៀងទាត់ និងតាមរបៀបដែលអាចបង្កើតផល ក្រោមអំណាចរបស់អស់លោក អស់លោកអភិបាលក៏ធ្វើឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ។ អស់លោកចាត់ចែងពិធីជ្រមុជទឹក ជាពិធីប្រោសឲ្យអ្នកជឿ រួមជាមួយព្រះគ្រីស្ត ក្នុងឋានៈជាបូជាចារ្យរបស់ព្រះមហាក្សត្រ។ ធម្មតាអស់លោកធ្វើអគ្គសញ្ញាលាបប្រេងសជូនគ្រីស្តបរិស័ទ។ អស់លោកក៏ធ្វើអគ្គសញ្ញាតែងតាំងឧបដ្ឋាក និងបូជាចារ្យ ព្រមទាំងចាត់ចែងវិន័យនៃអគ្គសញ្ញាលើកលែងទោសផងដែរ។ អស់លោកដាស់តឿននិងបង្រៀនគ្រីស្តបរិស័ទដោយយកចិត្តទុកដាក់ ដើម្បីឲ្យប្រជាជនរបស់អស់លោក ចូលរួមក្នុងពិធីគោរពប្រណិប័តន៍យ៉ាងសកម្ម ជាពិសេសចូលរួមក្នុងអភិបូជាដ៏សក្ការៈ ដោយមានជំនឿ និងដោយសេចក្ដីគោរព។ អស់លោកត្រូវធ្វើជាគំរូសម្រាប់គ្រីស្តបរិស័ទដែលនៅក្រោមអំណាចរបស់អស់លោក ត្រូវជៀសវាងអំពើអាក្រក់គ្រប់យ៉ាង និងប្រែមកធ្វើអំពើល្អវិញ តាមតែអស់លោកអាចធ្វើបាន ដោយមានព្រះអម្ចាស់ជួយឧបត្ថម្ភផង ដើម្បីឲ្យអស់លោកអាចឈានទៅដល់ព្រះជន្មអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ រួមជាមួយហ្វូងចៀមដែលព្រះអង្គបានផ្ញើទុកមកអស់លោក។

## ២៧- លោកអភិបាលមានមុខងារណែនាំនិងគ្រប់គ្រងព្រះសហគមន៍

អស់លោកអភិបាល ទទួលបន្ទុកលើព្រះសហគមន៍តាមភូមិភាគ ក្នុងឋានៈលោកជាតំណាង និងជាទូតរបស់ព្រះគ្រីស្ត។ ដូច្នេះ អស់លោកណែនាំព្រះសហគមន៍ភូមិភាគដោយទូន្មាន ដោយលើកទឹកចិត្ត ដោយធ្វើជាគំរូឲ្យគេ ហើយដោយប្រើអំណាច និងដោយអានុភាពដ៏សក្ការៈរបស់អស់លោក។ ប៉ុន្តែ អស់លោកមិនអាចប្រើអំណាចនេះតាមអំពើចិត្តបានទេ គឺអស់លោកត្រូវប្រើអំណាចនេះដើម្បីកសាងហ្វូងចៀមរបស់អស់លោកក្នុងសេចក្ដីពិត និងដើម្បីឲ្យគេបានវិសុទ្ធ។ អស់លោកត្រូវចងចាំជានិច្ចថា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេ ហើយអ្នកដែលដឹកនាំគេ ត្រូវបម្រើគេវិញ (លក ២២, ២៦-២៧)។

អស់លោកអភិបាលប្រើអំណាចនេះក្នុងនាមព្រះគ្រីស្ត គឺជាអំណាចរបស់លោកផ្ទាល់ ជាអំណាចធម្មតា និងជាអំណាចលើគេ។ ក៏ប៉ុន្តែ នៅពេលប្រើអំណាចនេះ អស់លោកត្រូវអនុវត្តតាមការគ្រប់គ្រងនៃអំណាចដ៏ខ្ពង់ខ្ពស់បំផុតរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម។ ជួនកាលអភិបាលព្រះសហគមន៍ក្រុងរ៉ូម អាចដកអំណាចខ្លះពីអភិបាលភូមិភាគចេញបាន ដោយនឹកគិតដល់ប្រយោជន៍របស់ព្រះសហគមន៍និងរបស់គ្រីស្តបរិស័ទ។ ដោយសារអំណាចនេះ អស់លោកអភិបាលមានសិទ្ធិដ៏សក្ការៈ (ហើយមានភារកិច្ចទៀតផង) នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ និងបង្កើតច្បាប់សម្រាប់ប្រជាជនរបស់គេ ហើយវិនិច្ឆ័យទោស ព្រមទាំងចាត់ចែងអ្វីៗទាំងអស់ ដែលមានពាក់ព័ន្ធនឹងរបៀបរៀបរយ នៃការគោរពបម្រើព្រះជាម្ចាស់ និងអំពីកិច្ចការជាគ្រីស្តទូតទៀតដែរ។

អស់លោកទទួលមុខងារយ៉ាងពេញលេញ ដើម្បីឃ្វាលហ្វូងចៀមរបស់ខ្លួន គឺថែរក្សាកូនចៅជាធម្មតារៀងរាល់ថ្ងៃ។ មិនត្រូវចាត់ទុកអស់លោក គ្រាន់តែជាតំណាងអភិបាលព្រះសហគមន៍ក្រុងរ៉ូមប៉ុណ្ណោះទេ ដ្បិតអស់លោកប្រើអំណាចរបស់អស់លោកផ្ទាល់ ហើយអស់លោកក៏ជាមេដឹកនាំដ៏ពិតប្រាកដរបស់ប្រជាជន ដែលអស់លោកដឹកនាំ។ ដូច្នេះអំណាចរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលជាអំណាចដ៏ខ្ពង់ខ្ពស់បំផុតនិងជាអំណាចសកល មិនបំបាត់អំណាចរបស់អស់លោកទេ ផ្ទុយទៅវិញ អំណាចរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូមបញ្ជាក់ ពង្រឹង និងការពារអំណាចរបស់អស់លោក។ ព្រះវិញ្ញាណដ៏វិសុទ្ធ នៅតែរក្សាការពាររចនាសម្ពន្ធ ដែលព្រះគ្រីស្តជាអម្ចាស់បានតែងតាំង ដើម្បីណែនាំព្រះសហគមន៍របស់ព្រះអង្គ មិនដែលអាក់ខានឡើយ។

ព្រះបិតានៃក្រុមគ្រួសារទាំងមូល ចាត់លោកអភិបាលឲ្យគ្រប់គ្រងបុត្រធីតារបស់ព្រះអង្គ។ លោកត្រូវនឹកគិតដល់ព្រះយេស៊ូជាគង្វាលដ៏ល្អ គឺយកធ្វើជាគំរូជានិច្ច។ ព្រះអង្គជាគង្វាលដែលមកក្នុងពិភពលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោកទេ តែលោកមកបម្រើគេវិញ (មថ ២០, ២៨; មក ១៩, ៤៥) និងស៊ូប្តូរជីវិតដើម្បីចៀមរបស់ខ្លួន (យហ ១០, ១១)។ ដោយគេជ្រើសរើសលោកពីចំណោមមនុស្ស ហើយដោយលោកផ្ទាល់ក៏ទន់ខ្សោយដែរ លោកអាចអធ្យាស្រ័យដល់មនុស្សល្ងង់ និងមនុស្សវង្វេងបាន (ហប ៥, ១-២)។ ហេតុនេះ លោកអភិបាលត្រូវយកចិត្តទុកដាក់ស្តាប់អ្នកដែលស្ថិតនៅក្រោមអំណាចរបស់លោក និងយកចិត្តទុកដាក់ស្រឡាញ់គេ ទុកជាកូនដ៏ពិតប្រាកដ ទាំងដាស់តឿនគេ ឲ្យធ្វើការរួមជាមួយលោកដោយចិត្តឧស្សាហ៍ផង។ ដោយលោកអភិបាលត្រូវទទួលខុសត្រូវលើគេ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ (ហប ១៣, ១៧) លោកត្រូវអធិដ្ឋាន បកស្រាយគម្ពីរ និងប្រព្រឹត្តគ្រប់កិច្ចការសម្តែងសេចក្តីស្រឡាញ់ គឺត្រូវយកចិត្តទុកដាក់ដល់កូនចៅរបស់លោក និងដល់អស់អ្នកដែលមិនទាន់ចូលក្នុងហ្វូងចៀមតែមួយ។ លោកត្រូវរាប់គេទុកជាអ្នកដែលព្រះអម្ចាស់បានផ្ញើទុកមកលោកដែរ។

លោកអភិបាលក៏ដូចគ្រីស្តទូតប៉ូលដែរ គឺលោកត្រូវមានបំណងនាំដំណឹងល្អមកជូនមនុស្សទាំងអស់ ព្រោះជាមុខងារ ដែលលោកត្រូវធ្វើសម្រាប់មនុស្សទាំងអស់ (រម ១, ១៤-១៥) ទាំងជំរុញគ្រីស្តបរិស័ទទាំងអស់ឲ្យបំពេញសកម្មភាពជាគ្រីស្តទូត និងជាសាសនទូតដែរ។ រីឯគ្រីស្តបរិស័ទវិញ គេត្រូវភ្ជាប់ចិត្តស្រឡាញ់អភិបាលរបស់ខ្លួន ដូចព្រះសហគមន៍ភ្ជាប់ចិត្តស្រឡាញ់ព្រះគ្រីស្ត និងដូចព្រះគ្រីស្តភ្ជាប់ចិត្តស្រឡាញ់ព្រះបិតា ដើម្បីឲ្យអ្វីៗទាំងអស់រួមគ្នា ជាធ្លុងតែមួយ និងបង្កើតផល ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (២ករ ៤, ១៥)។

## ២៨- អស់លោកគង្វាលនិងទំនាក់ទំនងជាមួយលោកអភិបាល

ព្រះបិតាបានប្រសិទ្ធិព្រះគ្រីស្តឲ្យបានវិសុទ្ធ ហើយចាត់ព្រះអង្គឲ្យយាងមកក្នុងពិភពលោក (យហ ១០, ៣៦)។ តាមរយៈក្រុមគ្រីស្តទូត ព្រះគ្រីស្តក៏បានញែកអស់លោកអភិបាលដែលបន្តមុខងារពីក្រុមគ្រីស្តទូតមក ប្រសិទ្ធិឲ្យបានវិសុទ្ធរួមជាមួយព្រះអង្គ ហើយក៏ចែករំលែកបេសកកម្មរបស់ព្រះអង្គឲ្យអស់លោកដែរ។ រីឯក្រុមអភិបាលវិញ អស់លោកបានបញ្ជូនបន្តយ៉ាងត្រឹមត្រូវ នូវបន្ទុកនៃមុខងារបម្រើរបស់អស់លោក ឲ្យគ្រីស្តបរិស័ទខ្លះតាមកម្រិតផ្សេងៗ ក្នុងព្រះសហគមន៍។ ដូច្នេះមានគ្រីស្តបរិស័ទខ្លះ បំពេញមុខងារបម្រើ ដែលព្រះជាម្ចាស់បានចាត់ចែងក្នុងព្រះសហគមន៍តាមកម្រិតផ្សេងៗ ដែលគ្រីស្តបរិស័ទតាំងពីដើមរៀងមកធ្លាប់ហៅថា *"អភិបាល គង្វាល និងឧបដ្ឋាក"*។ ទោះបីគង្វាលមិនទទួលបន្ទុកពេញទីជាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុតក្តី ទោះបីគង្វាល ស្ថិតនៅក្រោមចំណុះអភិបាលនៅពេលប្រើអំណាចរបស់ខ្លួនក្តី ក៏លោកគង្វាល មានកិត្តិយសរួមជាមួយលោកអភិបាលក្នុងឋានៈលោកជាបូជាចារ្យ។ ដោយអានុភាពនៃ

អគ្គសញ្ញាតែងតាំងជាអ្នកបម្រើ អស់លោកបានដូចព្រះគ្រីស្តជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុតដែលស្ថិតនៅអស់កល្បជានិច្ច (ហប ៥, ១-១០; ៧, ២៤; ៩, ១១-២៨) ព្រះអង្គបានញែកប្រសិទ្ធិអស់លោក ជាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មីយ៉ាងពិតប្រាកដ ឲ្យប្រកាសដំណឹងល្អ និងឲ្យធ្វើជាគង្វាលរបស់គ្រីស្តបរិស័ទ ហើយឲ្យធ្វើពិធីគោរពប្រណិប័តន៍នានាគោរពបម្រើព្រះជាម្ចាស់។ អស់លោករួមចំណែកក្នុងបន្ទុករបស់ព្រះគ្រីស្ត ដែលជាស្ពានមេត្រីតែមួយគត់ (១ធម ២, ៥) តាមកម្រិតនៃមុខងារបម្រើរបស់ខ្លួន។ អស់លោកគង្វាល ក៏ប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យមនុស្សទាំងអស់ស្តាប់ដែរ។

អស់លោកបំពេញបន្ទុកដ៏សក្ការៈរបស់អស់លោកយ៉ាងពិសេស ក្នុងពិធីអរព្រះគុណ គឺនៅពេលនោះ អស់លោកប្រព្រឹត្តកិច្ចការក្នុងនាមព្រះគ្រីស្ត និងជំនួសព្រះអង្គ ហើយប្រកាសគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ។ អស់លោកប្រមូលពាក្យអង្វររបស់គ្រីស្តបរិស័ទឲ្យរួមជាមួយសក្ការបូជានៃម្ចាស់របស់អស់លោក។ អស់លោកធ្វើឲ្យសក្ការបូជារបស់ព្រះគ្រីស្តមានវត្តមាននៅពេលអស់លោកថ្វាយអភិបូជានោះ រហូតដល់ព្រះអម្ចាស់យាងមក (១ករ ១១, ២៦)។ សក្ការបូជានៃសម្ពន្ធមេត្រីនេះមានតែមួយគត់ គឺសក្ការបូជារបស់ព្រះគ្រីស្ត ដែលបានបូជាព្រះជន្មទុកជាយញ្ញដ៏ឥតសៅហ្មង ថ្វាយទៅព្រះបិតាម្តងជាស្រេច (ហប ៩, ១១-២៨)។ អស់លោកបំពេញមុខងារបម្រើដ៏ប្រសើរបំផុត គឺមុខងារសម្រុះសម្រួល និងសម្រាលទុក្ខគ្រីស្តបរិស័ទដែលមានជំងឺ និងដែលសូមព្រះជាម្ចាស់លើកលែងទោស។ អស់លោកថ្វាយសេចក្តីត្រូវការ និងពាក្យអង្វររបស់គ្រីស្តបរិស័ទ ទៅព្រះបិតាជាអម្ចាស់ (ហប ៥, ១-៤)។ អស់លោកបំពេញបន្ទុករបស់ព្រះគ្រីស្តជាគង្វាលនិងជាមេដឹកនាំ តាមចំណែកនៃអំណាចរបស់ខ្លួន គឺអស់លោកប្រមែប្រមូលមហាគ្រួសាររបស់ព្រះជាម្ចាស់ ជាក្រុមបងប្អូន ដែលមានចិត្តថ្លើមតែមួយ ព្រមទាំងណែនាំក្រុមគ្រួសារនេះទៅកាន់ព្រះបិតាដោយសារព្រះគ្រីស្តជាអម្ចាស់ក្នុងព្រះវិញ្ញាណ។ អស់លោកក្រាបថ្វាយបង្គំព្រះបិតាជាអម្ចាស់តាមព្រះវិញ្ញាណ និងតាមសេចក្តីពិត នៅកណ្តាលហ្វូងចៀមរបស់អស់លោក (យហ ៤, ២៤)។ អស់លោកនឿយហត់ក្នុងការប្រកាសព្រះបន្ទូល និងបង្រៀនគេ (១ធម ៥, ១៧)។ អស់លោកជឿសេចក្តីដែលអស់លោករកឃើញ នៅពេលអាននិងស្ញឹងស្មាធិ៍រិះគិតអំពីធម្មវិន័យរបស់ព្រះអម្ចាស់ គឺអស់លោកបង្រៀនសេចក្តីដែលអស់លោកជឿ និងប្រតិបត្តិតាមសេចក្តី ដែលអស់លោកបង្រៀនផងដែរ។

អស់លោកជាសហការីដ៏ឈ្លាសវៃរបស់ក្រុមអភិបាល ក្នុងឋានៈជាអ្នកជួយនិងជាអ្នកដែលលោកអភិបាលអាចប្រើបាន។ ព្រះជាម្ចាស់បានត្រាស់ហៅ អស់លោកគង្វាលឲ្យបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយរួមជាមួយអភិបាលរបស់ខ្លួន ជាក្រុមគង្វាលតែមួយ ដែលមានមុខងារផ្សេងៗពីគ្នា។ នៅគ្រប់កន្លែងដែលមានសហគមន៍គ្រីស្តបរិស័ទ អស់លោកប្រៀបដូចជាវត្តមានរបស់លោកអភិបាល និងរួមសហការជាមួយលោកអភិបាលដោយទុកចិត្ត ដោយមានចិត្តទូលំទូលាយ ទាំងសុខចិត្តទទួលចំណែកនៃបន្ទុកនិងកង្វល់របស់លោក។ អស់លោកក៏អនុវត្តតាមបន្ទុកនិងកង្វល់នោះនៅពេលបម្រើគ្រីស្តបរិស័ទជារៀងរាល់ថ្ងៃ។ អស់លោកគ្រប់គ្រងចំណែកនៃហ្វូងចៀម ដែលព្រះអម្ចាស់បានផ្ញើទុកមកអស់លោកឲ្យបានវិសុទ្ធ ក្រោមអំណាចរបស់លោកអភិបាល។ អស់លោក ធ្វើឲ្យមនុស្សលោកឃើញព្រះសហគមន៍សកល នៅកន្លែងអស់លោករស់នៅ។ អស់លោកក៏សហការ ប្រកបដោយប្រសិទ្ធភាព ក្នុងការកសាងព្រះកាយទាំងមូលរបស់ព្រះគ្រីស្ត (អភ ៤, ១២)។ អស់លោកតម្រង់ចិត្តគំនិតស្វែងប្រយោជន៍សម្រាប់បុត្រធីតារបស់ព្រះជាម្ចាស់ជានិច្ច ហើយត្រូវមានចិត្តឧស្សាហ៍សហការ ក្នុងកិច្ចការណែនាំនៃភូមិភាគទាំងមូល ឬនិយាយយ៉ាងប្រសើរជាងទៅទៀតនោះ គឺសហការក្នុងកិច្ចការណែនាំរបស់ព្រះសហគមន៍ទាំងមូល។ ដោយអស់លោករួមចំណែកក្នុងមុខងារជាបូជាចារ្យ និងរួម

ចំណែកក្នុងបេសកកម្មអភិបាលរបស់ខ្លួន អស់លោកគង្វាល ត្រូវរាប់លោកអភិបាលទុកជាឪពុកខ្លួន និងស្តាប់បង្គាប់លោកដោយគោរព។ រីឯលោកអភិបាលវិញ លោកត្រូវរាប់អស់លោកគង្វាល ទុកជាសហការី ទុកជាកូន និងទុកជាមិត្តសម្លាញ់ ដូចព្រះគ្រីស្តដែលលែងចាត់ទុកក្រុមសាវ័កជាអ្នកបម្រើទៀតដែរ តែព្រះអង្គចាត់គេទុកជាមិត្តសម្លាញ់វិញ (យហ ១៥, ១៥)។ អស់លោកគង្វាល ទោះជាគង្វាល ភូមិភាគក្តី ជាបព្វជិតក្តី គឺមានទំនាក់ទំនងភ្ជាប់ជាមួយក្រុមអភិបាល ព្រោះអស់លោកទទួលអគ្គ សញ្ញាតែងតាំង និងទទួលមុខងារបម្រើដូចគ្នា។ អស់លោកម្នាក់ៗទទួលមុខងារតាមព្រះអំណោយទាន និងតាមតែព្រះជាម្ចាស់ត្រាស់ហៅឲ្យបម្រើប្រយោជន៍ព្រះសហគមន៍ទាំងមូល។

អស់លោកគង្វាល ជាប់ចំណងជាមួយគ្នាទុកជាបងប្អូនយ៉ាងស្និទ្ធស្នាល ព្រោះអស់លោកទទួលអគ្គសញ្ញា តែងតាំង និងមានបេសកកម្មតែមួយរួមគ្នា។ អស់លោកត្រូវបង្ហាញចិត្តស្រឡាញ់គ្នា ជាបងប្អូនដោយស្មោះស្ម័គ្រ និងដោយចិត្តរីករាយ គឺអស់លោកគង្វាលត្រូវជួយគ្នាទៅវិញទៅមកខាងសម្ភារៈក្តី ខាងវិញ្ញាណក្តី ទាំងក្នុងការណែនាំក្តី ទាំងក្នុងការរស់នៅផ្ទាល់ខ្លួនក្តី នៅពេលជួបជុំគ្នា ដោយប្រជុំគ្នា ដោយរួមរស់ជាមួយគ្នា ធ្វើការរួមជាមួយគ្នា និងស្រឡាញ់គ្នាទៅវិញទៅមកទៀតផង។

អស់លោកគង្វាល ត្រូវចាប់អារម្មណ៍នឹងគ្រីស្តបរិស័ទដែលអស់លោកបានបង្កើតដោយអគ្គសញ្ញាជ្រមុជទឹក និងដោយបង្រៀនគេ (១ករ ៤, ១៥ ; ១សល ១, ២៣) ក្នុងឋានៈជាឪពុករបស់គេ ក្នុងអង្គព្រះគ្រីស្ត។ ត្រូវធ្វើគំរូល្អដល់ហ្វូងចៀម (១សល ៥,៣) ហើយណែនាំ និងបម្រើសហគមន៍នានាតាមភូមិ ដើម្បីឲ្យសហគមន៍ទាំងនោះសមនឹងទទួលនាមនៃប្រជារាស្ត្រតែមួយគត់របស់ព្រះជាម្ចាស់ទាំងមូលថា *"ព្រះសហគមន៍របស់ព្រះជាម្ចាស់"* (១ករ ១, ២; ២ករ ១, ១)។ សូមអស់លោកនឹកចងចាំថា អស់លោកត្រូវបង្ហាញមុខងារបម្រើជាបូជាចារ្យនិងជាគង្វាលដ៏ពិតប្រាកដ ឲ្យអ្នកធ្វើជីវិតលើព្រះគ្រីស្ត និងឲ្យអ្នកគ្មានជំនឿលើព្រះអង្គ ទាំងឲ្យគ្រីស្តបរិស័ទកាតូលិក ទាំងឲ្យគ្រីស្តបរិស័ទនិកាយឯទៀតៗ ឃើញកិរិយាមារយាទប្រចាំថ្ងៃរបស់អស់លោក និងឃើញការយកចិត្តទុកដាក់របស់អស់លោកចំពោះមនុស្សទាំងអស់ទៀតដែរ។ ធ្វើដូច្នេះ អស់លោកមុខជានឹងផ្តល់សក្ខីភាពអំពីសេចក្តីពិត និងអំពីជីវិត។ អស់លោកក៏ត្រូវប្រព្រឹត្តដូចគង្វាលដែលស្វែងរកកូនចៀម (លក ១៥, ៤-៧) គឺស្វែងរកអស់អ្នកដែលឈប់ទទួលអគ្គសញ្ញានានា ឬក៏លះបង់ជំនឿដែរ ទោះបីគេបានទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយក៏ដោយ។

សព្វថ្ងៃមនុស្សជាតិរួមគ្នាជាប្រជាពលរដ្ឋ តាមសេដ្ឋកិច្ច និងតាមសង្គម កាន់តែខ្លាំងឡើងៗ។ ហេតុនេះហើយបានជាអស់លោកបូជាចារ្យមានភារៈកិច្ចជាបន្ទាន់បំផុត រួមគ្នាខិតខំគិតគូរអស់ពីសមត្ថភាព និងប្រើគ្រប់មធ្យោបាយ ក្រោមការណែនាំរបស់ក្រុមអភិបាល និងរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ដើម្បីជៀសវាងកុំឲ្យមានមូលហេតុណាមួយ បណ្តាលឲ្យមនុស្សលោកបែកបាក់គ្នាឡើយ។ អស់លោកក៏មានភារកិច្ចណែនាំមនុស្សជាតិទាំងមូល ឲ្យរួបរួមគ្នាជាធ្លុងតែមួយ ជាមហាគ្រួសាររបស់ព្រះជាម្ចាស់។

### ២៩- លោកឧបដ្ឋាក

ក្នុងរចនាសម្ពន្ធនៃមុខងារបម្រើព្រះសហគមន៍តាមលំដាប់លំដោយ ក្រុមឧបដ្ឋាកស្ថិតនៅកម្រិតទាបជាងគេ។ លោកអភិបាលដាក់ដៃលើគេ "មិនមែនដើម្បីឲ្យទៅជាបូជាចារ្យទេ តែឲ្យគេមានមុខងារបម្រើ"។ តាមអានុភាពនៃអគ្គសញ្ញាតែងតាំង គេទទួលកម្លាំងដើម្បីបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយបម្រើក្នុងពិធីគោរពប្រណិប័តន៍ ដោយប្រកាសព្រះបន្ទូល និងដោយសម្តែងសេចក្តីស្រឡាញ់ ទាំងរួបរួមជាមួយលោកអភិបាល និងក្រុមគង្វាលរបស់លោកទៀត

ផង។ តាមអស់លោកដែលទទួលខុសត្រូវ និងមានសមត្ថកិច្ចចាត់ចែងក្រុមឧបដ្ឋាក ឧបដ្ឋាកមានមុខងារធ្វើអគ្គសញ្ញាជ្រមុជទឹកយ៉ាងឱឡារិក មានមុខងាររក្សានិងចែកនំប៉ុងប្រសិទ្ធិក្នុងពិធីអរព្រះគុណ។ ក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍ អស់លោកឧបដ្ឋាកធ្វើជាសាក្សីក្នុងនាមព្រះសហគមន៍ និងប្រទានពរដល់គូស្វាមីភរិយា។ អស់លោកនាំនំប៉ុងប្រសិទ្ធិចែកឲ្យអ្នកហៀបនឹងទទួលមរណភាព ប្រកាសព្រះគម្ពីរឲ្យគ្រីស្តបរិស័ទស្តាប់ បង្រៀននិងដាស់តឿនប្រជាជន ធ្វើជាអធិបតី ក្នុងពេលគ្រីស្តបរិស័ទធ្វើពិធីគោរពបម្រើព្រះជាម្ចាស់និងអធិដ្ឋាន បម្រើអនុសញ្ញា ធ្វើប្រធានក្នុងពិធីគោរពបុគ្គល ដែលចែកឋាន និងក្នុងពិធីបញ្ចុះសព។ អស់លោកឧបដ្ឋាកប្តេជ្ញាចិត្តបម្រើកិច្ចការសម្តែងធម៌មេត្តាករុណា និងកិច្ចការរដ្ឋបាលរបស់ព្រះសហគមន៍។ អស់លោកត្រូវនឹកពាក្យទូន្មានរបស់សន្តៈប៉ូលីកាវប៉ូសថា៖ *"ត្រូវមានចិត្តមេត្តាករុណា ចិត្តឧស្សាហ៍ ដើរតាមសេចក្តីពិតរបស់ព្រះអម្ចាស់ ដែលព្រះអង្គដាក់ខ្លួនបម្រើមនុស្សទាំងអស់"*។

ទោះបីមុខងារឧបដ្ឋាក មានសារៈសំខាន់ជាចាំបាច់ សម្រាប់ឲ្យព្រះសហគមន៍មានជីវិតរស់រវើកក្តី ក៏វិន័យព្រះសហគមន៍ ដែលកាន់តាមក្បួនព្រះសហគមន៍ក្រុងរ៉ូមសព្វថ្ងៃ បណ្តាលឲ្យពិបាកតែងតាំងមុខងារនោះ ក្នុងតំបន់ជាច្រើនដែរ។ ប៉ុន្តែ នៅពេលអនាគត ព្រះសហគមន៍មុខជានឹងអាចតែងតាំងមុខងារជា ឧបដ្ឋាកឡើងវិញ តាមកម្រិតនិងទុកជាមុខងារអចិន្ត្រៃយ៍ក្នុងរចនាសម្ពន្ធតាមលំដាប់លំដោយនៃព្រះសហគមន៍។ ក្រុមអភិបាលតាមតំបន់ដែលមានសមត្ថកិច្ចសម្រេចតែងតាំងមុខងារជាឧបដ្ឋាក តាមសេចក្តីត្រូវការ ដើម្បីជាប្រយោជន៍ដល់គ្រីស្តបរិស័ទ ដោយមានការយល់ស្របពីអភិបាលព្រះសហគមន៍ក្រុងរ៉ូម។ ប្រសិនបើ អភិបាលព្រះសហគមន៍ក្រុងរ៉ូម យល់ស្រប ក្រុមអភិបាលតាមតំបន់អាចតែងតាំងបុរសពេញវ័យជាឧបដ្ឋាក ទោះបីបុរសទាំងនោះមានគ្រួសារក្តី។ ក្រុមអភិបាលក៏អាចតែងតាំងយុវជនឲ្យទៅជាឧបដ្ឋាកដែរ តែយុវជនទាំងនោះត្រូវព្រហ្មចរិយធម៌។ វិន័យឲ្យគេកាន់ព្រហ្មចរិយធម៌នោះ មិនប្រែប្រួល គឺត្រូវនៅស្ថិតស្ថេរឲ្យរឹងប៉ឹងជានិច្ច។

# ជំពូក ៤

## គ្រីស្តបរិស័ទធម្មតា

### ៣០- អារម្ភកថា

ក្រោយពីបានបញ្ជាក់បន្ទុករបស់អ្នកទទួលខុសត្រូវលើព្រះសហគមន៍តាមលំដាប់លំដោយ មហាសន្និបាតបែរគំនិតទៅរិះគិតអំពីគ្រីស្តបរិស័ទធម្មតា។ អ្វីៗដែលចែងអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក៏មានអត្ថន័យដូចគ្នា សម្រាប់គ្រីស្តបរិស័ទធម្មតា សម្រាប់បព្វជិតបព្វជិតា និងសម្រាប់អស់លោកដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ដែរ។ ប៉ុន្តែ សភាពការណ៍និងបេសកកម្មរបស់គ្រីស្តបរិស័ទធម្មតា ទាំងបុរសទាំងស្ត្រី នាំឲ្យយើងត្រូវរិះគិតអំពីគ្រឹះនៃលក្ខណៈ និងអំពីបេសកកម្មរបស់បុរសនិងស្ត្រីទាំងនោះ។

អស់លោកអភិបាលជាគង្វាលដឹងច្បាស់ថា ការសហការរបស់គ្រីស្តបរិស័ទធម្មតាជាមួយអស់លោក មានសារៈសំខាន់ណាស់ ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។ អស់លោកដឹងច្បាស់ទៀតថា ព្រះគ្រីស្ត មិនបានតែងតាំងអស់លោក ឲ្យបំពេញបេសកកម្មសង្គ្រោះមនុស្សលោក ដោយសារតែខ្លួនអស់លោកប៉ុណ្ណោះទេ។ អស់លោកមានមុខងារដ៏ប្រសើរ គឺយល់អំពីបេសកកម្មរបស់អស់លោក ជាគង្វាលរបស់គ្រីស្តបរិស័ទ ព្រមទាំងទទួលស្គាល់មុខងារបម្រើ និងព្រះអំណោយទានរបស់គ្រីស្តបរិស័ទដែរ។ ធ្វើដូច្នេះ គ្រីស្តបរិស័ទទាំងអស់ នឹងសហការក្នុងកិច្ចការរួមរបស់ព្រះសហគមន៍ គឺម្នាក់ៗតាមរបៀបរៀងៗខ្លួន។

*"យើងទាំងអស់គ្នាត្រូវប្រព្រឹត្តតាមសេចក្ដីពិត និងដោយចិត្តស្រឡាញ់យ៉ាងស្មោះ ដើម្បីចម្រើនឡើងក្នុងអង្គព្រះគ្រីស្តនៅគ្រប់វិស័យ។ ព្រះគ្រីស្តជាសិរសា គឺព្រះអង្គហើយដែលធ្វើឲ្យព្រះកាយទាំងមូលផ្គុំគ្នា និងភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មាន ដែលបម្រើព្រះកាយ តាមកម្រិតសមត្ថភាពរបស់សរីរាង្គនីមួយៗ ដើម្បីឲ្យព្រះកាយនោះចម្រើន និងកសាងឡើងក្នុងសេចក្ដីស្រឡាញ់"* (អភ ៤, ១៥-១៦)។

### ៣១- ឈ្មោះ "គ្រីស្តបរិស័ទធម្មតា"

ឈ្មោះ *"គ្រីស្តបរិស័ទធម្មតា"* ជាគ្រីស្តបរិស័ទដែលមិនបានទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ហើយក៏មិនមែនជាបព្វជិតបព្វជិតា ដែលព្រះសហគមន៍ទទួលស្គាល់ជាផ្លូវការទេ។ *"គ្រីស្តបរិស័ទធម្មតា"* គឺជាអ្នករួមក្នុងអង្គព្រះគ្រីស្ត ដោយអគ្គសញ្ញាជ្រមុជទឹក ទៅជាគ្រីស្តបរិស័ទដែលចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ គេរួម ចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រតាមរបៀបរបស់គេ។ គេបំពេញបេសកកម្មរបស់ប្រជាជនគ្រីស្តបរិស័ទទាំងមូល នៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោក តាមចំណែករៀងៗខ្លួន។

"គ្រីស្តបរិស័ទធម្មតា" មានលក្ខណៈពិសេសដោយឡែកពីគេ គឺគេរស់នៅក្នុងសង្គមមនុស្ស។ ជួនកាលគ្រីស្តបរិស័ទ ដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ក៏ធ្វើកិច្ចការលោកីយ៍ដែរ។ ប៉ុន្តែ ទោះបីអស់លោក

ធ្វើកិច្ចការលោកីយ៍ក្តី ឬទោះបីអស់លោកមានមុខរបរខាងលោកីយ៍ក្តី ក៏អស់លោកនៅតែមានមុខងារពិសេស គឺបម្រើព្រះសហគមន៍។ នេះជាអាទិភាពយ៉ាងច្បាស់របស់អស់លោក តាមព្រះជាម្ចាស់ត្រាស់ហៅអស់លោក។ រីឯបព្វជិតបព្វជិតាវិញ គេរស់នៅតាមសភាពរបស់គេ ដែលបញ្ជាក់យ៉ាងច្បាស់និងយ៉ាងពិសេសថា មនុស្សលោកមិនអាចផ្លាស់ប្រែបាន ហើយក៏មិនអាចយកទៅថ្វាយព្រះជាម្ចាស់បាន ក្រៅពីការប្រៀនប្រដៅរបស់ព្រះយេស៊ូ អំពីសុភមង្គលដ៏ពិតប្រាកដ។

រីឯគ្រីស្តបរិស័ទធម្មតាវិញ ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យបំពេញមុខងារមួយយ៉ាងពិសេសគឺស្វែងរកព្រះរាជ្យរបស់ព្រះអង្គដោយត្រួតត្រានិងចាត់ចែងអ្វីៗទាំងអស់ក្នុងលោកនេះ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ គេរស់នៅក្នុងលោកនេះ ទាំងបំពេញកិច្ចការនិងការងារផ្សេងៗរបស់លោកីយ៍ ហើយរស់នៅតាមសភាពការណ៍ធម្មតាក្នុងរង្វង់គ្រួសារនិងក្នុងសង្គម ដែលជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធ នឹងការរស់នៅរបស់គេ។ ព្រះជាម្ចាស់ត្រាស់ហៅគេ នៅកន្លែងទាំងនោះ ដើម្បីជួយឲ្យមនុស្សលោកបានវិសុទ្ធ ពីខាងក្នុងចំណោមមនុស្ស ដូចមេក្នុងម្សៅ។ គេបំពេញបន្ទុករបស់ខ្លួនផ្ទាល់ តាមគំនិតដែលហូរចេញពីដំណឹងល្អដើម្បីបង្ហាញព្រះគ្រីស្តឲ្យអ្នកដទៃ ដោយផ្តល់សក្ខីភាពអំពីព្រះអង្គ តាមការរស់នៅរបស់គេជាដើម។ គេបញ្ចាំងរស្មីនៃជំនឿ នៃសេចក្តីសង្ឃឹម និងនៃសេចក្តីស្រឡាញ់។ គ្រីស្តបរិស័ទធម្មតាទាំងនោះ មានភារកិច្ចយ៉ាងពិសេស គឺបំភ្លឺនិងតម្រង់អ្វីៗទាំងអស់ក្នុងលោកីយ៍ ដែលភ្ជាប់យ៉ាងជិតស្និទ្ធនឹងការរស់នៅរបស់គេ ដើម្បីឲ្យអ្វីៗទាំងនោះកើតឡើង និងចម្រើនតាមព្រះគ្រីស្តជានិច្ច និងលើកតម្កើងសិរីរុងរឿងព្រះអាទិករ និងព្រះសង្គ្រោះរបស់មនុស្សលោក។

## ៣២- កិត្តិយសដ៏ថ្លៃថ្នូររបស់គ្រីស្តបរិស័ទធម្មតា

ព្រះជាម្ចាស់តែងតាំង ចាត់ចែង ហើយណែនាំព្រះសហគមន៍ដ៏វិសុទ្ធ ឲ្យមានបែបបទប្លែកៗពីគ្នាយ៉ាងអស្ចារ្យ ដូចមានចែងថា «រូបកាយមនុស្សយើងមានសរីរាង្គច្រើន។ សរីរាង្គនីមួយៗមានមុខងារប្លែកៗពីគ្នាយ៉ាងណា យើងក៏ដូច្នោះដែរ គឺយើងដែលមានគ្នាច្រើន ក៏រួមជាព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត ហើយម្នាក់ៗ ជាសរីរាង្គរបស់គ្នាទៅវិញទៅមកដែរ។» (រម១២,៤-៥)។

ហេតុនេះហើយ បានជាមានប្រជារាស្ត្ររបស់ព្រះជាម្ចាស់តែមួយ ដែលព្រះអង្គបានជ្រើសរើស «ព្រះអម្ចាស់មានតែមួយ ជំនឿមានតែមួយ ពិធីជ្រមុជទឹកមានតែមួយ» (អភ ៤,៥)។ សមាជិកនៃប្រជារាស្ត្រនេះមានកិត្តិយសដ៏ថ្លៃថ្នូររួមគ្នា ព្រោះគេសុទ្ធតែកើតជាថ្មីក្នុងអង្គព្រះគ្រីស្ត។ ព្រះបិតាប្រណីសន្តោសឲ្យគេទៅជាបុត្រធីតាដូចគ្នា ព្រះជាម្ចាស់ត្រាស់ហៅគេទាំងអស់គ្នា ឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈដូចគ្នា។ មានការសង្គ្រោះតែមួយ មានសេចក្តីសង្ឃឹមតែមួយ មានសេចក្តីស្រឡាញ់តែមួយដែលមិនចេះបែកចេញពីគ្នា។ ហេតុនេះហើយ បានជានៅក្នុងអង្គព្រះគ្រីស្ត និងក្នុងព្រះសហគមន៍ គ្រីស្តបរិស័ទមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នាទាំងអស់ គ្មានប្រកាន់ជាតិសាសន៍ ឋានៈវណ្ណៈ ឬភេទឡើយ ដ្បិត «គ្មានសាសន៍យូដា គ្មានសាសន៍ក្រិកទៀតទេ គ្មានទាសករ គ្មានអ្នកជា ហើយក៏គ្មានបុរសគ្មានស្ត្រីទៀតដែរ គឺបងប្អូនទាំងអស់រួមគ្នាមកជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ។» (កឡ ៣, ២៨; កូឡ ៣, ១១)។

ដូច្នេះ ក្នុងព្រះសហគមន៍ទោះបីគ្រីស្តបរិស័ទមានរបៀបរស់នៅប្លែកៗពីគ្នាក្តី ក៏ព្រះជាម្ចាស់ត្រាស់ហៅគេទាំងអស់ឲ្យបានវិសុទ្ធ និងបានទទួលជំនឿដូចៗគ្នា គឺជំនឿដែលនាំមនុស្សឲ្យចូលទៅក្នុងសេចក្តីសុចរិតរបស់ព្រះអង្គ (២សល ១, ១)។ ទោះបីព្រះគ្រីស្តសព្វព្រះហឫទ័យតែងតាំង គ្រីស្តបរិស័ទខ្លះឲ្យធ្វើជាអ្នកបង្រៀនក្តី ខ្លះឲ្យធ្វើជាអ្នកមើលការ

ខុសត្រូវលើគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ក្ដី និងខ្លះធ្វើជាគង្វាលដើម្បីជាប្រយោជន៍ដល់បងប្អូនឯទៀតៗក្ដី ក៏គេស្មើគ្នាទាំងអស់យ៉ាងពិតប្រាកដដែរ គេមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នា គេបំពេញសកម្មភាពរួមរបស់គ្រីស្តបរិស័ទទាំងអស់គ្នា ពោលគឺកសាងព្រះកាយព្រះគ្រីស្ត។ ព្រះអម្ចាស់ចាត់ចែងឲ្យអស់លោកដែលបម្រើព្រះសហគមន៍បានប្លែកពីសមាជិកឯទៀតៗ នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ តែអស់លោករួបរួមយ៉ាងជិតស្និទ្ធជាមួយសមាជិកទាំងនោះ ព្រោះអស់លោក និងគ្រីស្តបរិស័ទឯទៀតៗជាប់ចំណងជាមួយគ្នា ដោយមានទំនាក់ទំនង់ជាមួយគ្នាជាច្រើន គឺអស់លោកអភិបាលជាគង្វាលនៃព្រះសហគមន៍ យកតម្រាប់តាមព្រះអម្ចាស់ បម្រើគ្នាទៅវិញទៅមក ហើយក៏បម្រើគ្រីស្តបរិស័ទឯទៀតៗដែរ។ រីឯគ្រីស្តបរិស័ទឯទៀតៗវិញ ក៏យកចិត្តទុកដាក់ជួយឧបត្ថម្ភអស់លោកគង្វាលនិងអ្នកបង្រៀនដែរ។ ដូច្នេះហើយ ដោយគ្រីស្តបរិស័ទប្លែកៗពីគ្នាយ៉ាងនេះ គេផ្ដល់សក្ខីភាពទាំងអស់គ្នាថា គេរួបរួមគ្នាយ៉ាងអស្ចារ្យក្នុងព្រះកាយព្រះគ្រីស្ត។ ព្រះអំណោយទានប្លែកៗពីគ្នា មុខងារបម្រើប្លែកៗពីគ្នា សកម្មភាពប្លែកៗពីគ្នា ជួយបុត្រធីតារបស់ព្រះជាម្ចាស់ឲ្យជាប់ចំណងជាមួយគ្នាជាអង្គតែមួយ ដ្បិត «មានព្រះវិញ្ញាណមានតែមួយព្រះអង្គដដែល ដែលបំពេញការទាំងអស់នេះ» (១ករ ១២, ១១)។

ហេតុនេះហើយបានជា តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ គ្រីស្តបរិស័ទមានព្រះគ្រីស្តជារៀមច្បង។ ទោះបីព្រះអង្គជាព្រះអម្ចាស់លើអ្វីៗទាំងអស់ក៏ដោយ ក៏ព្រះអង្គយាងមកក្នុងពិភពលោកនេះ "មិនមែនដើម្បីឲ្យគេបម្រើលោកទេ តែលោកមកបម្រើគេវិញ" (មថ ២០, ២៨)។ យ៉ាងណាមិញ គ្រីស្តបរិស័ទធម្មតារាប់អស់លោក ដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ទុកជាបងប្អូន។ អស់លោកបំពេញមុខងារជាគង្វាលនៃក្រុមគ្រួសាររបស់ព្រះជាម្ចាស់ គឺអស់លោកបង្រៀនគេ ធ្វើឲ្យគេបានវិសុទ្ធ គ្រប់គ្រងគេដោយអំណាចរបស់ព្រះគ្រីស្ត ដើម្បីឲ្យគ្រីស្តបរិស័ទទាំងអស់ ប្រតិបត្តិតាមវិន័យថ្មីស្ដីអំពីសេចក្ដីស្រឡាញ់។ សន្តអូគូស្តាំងមានប្រសាសន៍អំពីសេចក្ដីនេះយ៉ាងពិរោះថា «មុខងាររបស់ខ្ញុំគឺបម្រើបងប្អូន បណ្ដាលឲ្យខ្ញុំតប់ប្រមល់ តែឋានៈរបស់ខ្លួនជាគ្រីស្តបរិស័ទ រួមជាមួយបងប្អូននាំឲ្យខ្ញុំធូរចិត្តវិញ។ ខ្ញុំជាអភិបាលសម្រាប់ណែនាំបងប្អូន តែខ្ញុំជាគ្រីស្តបរិស័ទរួមជាមួយបងប្អូន។ "អភិបាល" ជាពាក្យស្ដីអំពីមុខងារដែលយើងខិតខំបំពេញ រីឯ "គ្រីស្តបរិស័ទ" ជានាមដែលយើងទទួលពីព្រះហឫទ័យ ប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ មុខងារជាអភិបាលនាំឲ្យទទួលទោស រីឯឈ្មោះជាគ្រីស្តបរិស័ទវិញ នាំឲ្យទទួលការសង្គ្រោះ»។

## ៣៣- គ្រីស្តបរិស័ទធម្មតាទទួលចំណែកនៃកិច្ចជាគ្រីស្តទូត

គ្រីស្តបរិស័ទធម្មតារួបរួមគ្នាក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ និងត្រូវចាត់ចែងឲ្យមានរបៀបរៀបរយក្នុងព្រះកាយព្រះគ្រីស្តតែមួយគត់ ក្រោមអំណាចនៃសិរសាតែមួយ។ ទោះបីគេជានរណាក៏ដោយ ក៏ព្រះជាម្ចាស់ត្រាស់ហៅគេក្នុងឋានៈជាសមាជិកដែលមានជីវិតរស់រវើក ឲ្យសហការគ្នាដើម្បីឲ្យព្រះសហគមន៍ចម្រើនឡើងនិងកាន់តែវិសុទ្ធជានិច្ច ដោយខិតខំអស់ពីកម្លាំងដែលព្រះអាទិករបានប្រោសប្រទានឲ្យគេ និងដោយព្រះសង្គ្រោះប្រណីសន្ដោសផង។

គ្រីស្តបរិស័ទធម្មតាទទួលបេសកកម្មជាគ្រីស្តទូត គឺទទួលចំណែកក្នុងបេសកកម្មរបស់ព្រះសហគមន៍ ដែលនាំការសង្គ្រោះដល់មនុស្សលោក។ ព្រះអម្ចាស់ផ្ទាល់បានផ្ញើបេសកកម្មនេះឲ្យគ្រីស្តបរិស័ទទាំងអស់ នៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាស។ អគ្គសញ្ញាទាំងប៉ុន្មាន ជាពិសេសអគ្គសញ្ញាអរព្រះគុណ សុទ្ធតែផ្ដល់ និងពង្រឹងសេចក្ដីស្រឡាញ់របស់គេចំពោះព្រះជាម្ចាស់និងចំពោះមនុស្សលោក គឺសេចក្ដីស្រឡាញ់នេះហើយ ដែលជាកម្លាំងជំរុញគេឲ្យបំពេញបេសកកម្មគ្រប់យ៉ាងជាគ្រីស្តទូត។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតា ជាពិសេសឲ្យគេបង្ហាញ

វត្តមាននិងសកម្មភាពរបស់ព្រះសហគមន៍ នៅកន្លែងនិងតាមសភាពការណ៍ផ្សេងៗ។ មានតែគ្រីស្តបរិស័ទធម្មតាទេ ដែលអាចធ្វើឲ្យព្រះសហគមន៍ ទៅជាអំបិលសម្រាប់មនុស្សលោក នៅកន្លែងនិងតាមសភាពការណ៍ទាំងនោះបាន។ ដូច្នេះ គ្រីស្តបរិស័ទម្នាក់ៗជាសាក្សីតាមព្រះអំណោយទានដែលខ្លួនបានទទួល។ នៅពេលជាមួយគ្នានោះ គេបំពេញបេសកកម្មរបស់ព្រះសហគមន៍ផ្ទាល់ «តាមកម្រិតនៃព្រះអំណោយទានដែលព្រះគ្រីស្តប្រទានមក» (អភ ៤, ៧)។

លើសពីបេសកកម្មជាគ្រីស្តទូត ដែលគ្រីស្តបរិស័ទត្រូវបំពេញគ្រប់ៗគ្នានោះ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាខ្លះ ឲ្យរួមសហការជាមួយអស់លោកអភិបាលតាមរបៀបផ្សេងៗក្នុងបេសកកម្មរបស់អស់លោកជាគ្រីស្តទូត ដូចកាលពីដើម មានទាំងបុរស ទាំងស្ត្រី ជាសហការីរបស់គ្រីស្តទូតប៉ូល ក្នុងការប្រកាសដំណឹងល្អ ហើយនិងធ្វើការជាទម្ងន់ក្នុងព្រះអម្ចាស់ទៀតផង (ភព ៤, ៣; រម ១៦, ៣)។ ម្យ៉ាងទៀត គ្រីស្តបរិស័ទធម្មតាមានសមត្ថភាព បណ្ដោយឲ្យលោកអភិបាលជ្រើសរើសគេ ដើម្បីបំពេញមុខងារខ្លះខាងវិញ្ញាណក្នុងព្រះសហគមន៍។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទធម្មតាទាំងអស់ មានភារកិច្ចដ៏ប្រសើរ គឺខិតខំធ្វើឲ្យគម្រោងការរបស់ព្រះជាម្ចាស់ដែលសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក ឈានទៅដល់មនុស្សទាំងអស់ នៅគ្រប់ពេលវេលា និងនៅលើផែនដីទាំងមូល។ ដូច្នេះត្រូវតែបើកផ្លូវនៅគ្រប់កន្លែងឲ្យគ្រីស្តបរិស័ទធម្មតាអាចរួមចំណែកយ៉ាងសកម្ម ក្នុងកិច្ចសង្គ្រោះរបស់ព្រះសហគមន៍ តាមកម្លាំងរៀងៗខ្លួន និងតាមសេចក្ដីត្រូវការនៅជំនាន់នីមួយៗផង។

## ៣៤- គ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាមហាបូជាចារ្យ

ព្រះគ្រីស្តយេស៊ូជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត ស្ថិតនៅអស់កល្បជានិច្ច ព្រះអង្គសព្វព្រះហឫទ័យបន្តសក្ខីភាព និងកិច្ចបម្រើរបស់ព្រះអង្គដោយសារគ្រីស្តបរិស័ទធម្មតា។ ព្រះអង្គក៏ប្រទានជីវិតឲ្យគេ ដោយព្រះវិញ្ញាណរបស់ព្រះអង្គ និងនៅតែជំរុញគេឥតឈប់ឈរឲ្យសម្រេចការល្អគ្រប់យ៉ាង និងឲ្យខ្លួនគេបានពេញលក្ខណៈដែរ។ ព្រះគ្រីស្តក៏ចែកបន្ទុកជាបូជាចារ្យរបស់ព្រះអង្គមួយចំណែក ដល់អស់អ្នកដែលព្រះអង្គភ្ជាប់ឲ្យរួមជាមួយព្រះអង្គ យ៉ាងស្អិតល្មួតក្នុងជីវិត និងក្នុងបេសកកម្មរបស់ព្រះអង្គ។ ដូច្នេះពួកគេអាចលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយគោរពបម្រើព្រះអង្គតាមវិញ្ញាណ និងសង្គ្រោះមនុស្សលោកទៀតផង។ ដោយគ្រីស្តបរិស័ទធម្មតាថ្វាយខ្លួនទៅព្រះគ្រីស្ត និងដោយព្រះវិញ្ញាណដ៏វិសុទ្ធចាក់ប្រេងអភិសេកគេ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាឲ្យមានបេសកកម្មដ៏ល្អប្រសើរ និងមានគ្រប់មធ្យោបាយ បណ្ដោយឲ្យព្រះវិញ្ញាណបង្កើតផលកាន់តែច្រើនឡើងៗនៅក្នុងខ្លួនគេជានិច្ច។ កិច្ចការដែលគេប្រព្រឹត្តប្រចាំថ្ងៃ ការអធិដ្ឋាន សកម្មភាពរបស់គេក្នុងឋានៈជាគ្រីស្តទូត ការរស់នៅក្នុងឋានៈជាគូស្វាមីភរិយា ការរស់នៅក្នុងក្រុមគ្រួសារ ការនឿយហត់សម្រាប់ចិញ្ចឹមជីវិត ការសម្រាកទាំងរូបកាយក្ដី ទាំងចិត្តគំនិតក្ដី (លុះត្រាតែគេប្រព្រឹត្តិការណ៍ទាំងនោះរួមក្នុងព្រះវិញ្ញាណ) សូម្បីតែទុក្ខលំបាកប្រចាំជីវិត (លុះត្រាតែគេស៊ូទ្រាំដោយអត់ធ្មត់ខន្តី) គឺសុទ្ធតែត្រឡប់ទៅជា «យញ្ញបូជាតាមព្រះវិញ្ញាណជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដោយសារព្រះយេស៊ូគ្រីស្ត» (១សល ២, ៥)។ ពេលគេថ្វាយអភិបូជា គេថ្វាយតង្វាយទាំងនោះទៅព្រះបិតា រួមជាមួយព្រះកាយព្រះអម្ចាស់ ដោយគោរពប្រណិប័តន៍។ ធ្វើដូច្នោះ គ្រីស្តបរិស័ទធម្មតាដែលរស់នៅបែបវិសុទ្ធ ប្រសិទ្ធិពិភពលោកទាំងមូលឲ្យបានវិសុទ្ធថ្វាយទៅព្រះបិតា និងគោរពក្រាបថ្វាយបង្គំព្រះបិតានៅគ្រប់ទីកន្លែង។

## ៣៥- គ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាព្យាការី

ព្រះគ្រីស្តជាព្យាការីដ៏ប្រសើរឧត្តម ព្រះអង្គបានប្រកាសព្រះរាជ្យរបស់ព្រះបិតា ដោយយកការរស់នៅរបស់ព្រះអង្គ

ធ្វើជាសក្ខីភាព និងមានព្រះបន្ទូលប្រកបដោយអំណាច។ ព្រះអង្គបំពេញបន្ទុកជាព្យាការីរហូតដល់ពេលព្រះអង្គសម្តែងសិរីរុងរឿងរបស់ព្រះអង្គយ៉ាងពេញលេញនៅគ្រាចុងក្រោយបំផុត។ ព្រះអង្គបន្តបំពេញបន្ទុកនោះ មិនគ្រាន់តែតាមរយៈអស់លោកអភិបាល ដែលបង្រៀនក្នុងព្រះនាមព្រះអង្គ និងដែលប្រកបដោយអំណាចរបស់ព្រះអង្គប៉ុណ្ណោះទេ តែព្រះអង្គក៏បន្តបំពេញការងារនេះតាមរយៈគ្រីស្តបរិស័ទធម្មតាដែរ គឺព្រះអង្គតែងតាំងឲ្យគ្រីស្តបរិស័ទទាំងនោះទៅជាសាក្សីរបស់ព្រះអង្គ។ ព្រះអង្គប្រោសឲ្យគេមានជំនឿស្របគ្នាយ៉ាងជ្រៅក្នុងចិត្ត និងអាចថ្លែងព្រះបន្ទូលបានផង (កក ២, ១៧-១៨; វវ ១៩, ១០) ដើម្បីឲ្យអានុភាពនៃដំណឹងល្អភ្លឺនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងក្នុងការរស់នៅជាក្រុមគ្រួសារ និងក្នុងសង្គមទៀតផង។ គ្រីស្តបរិស័ទធម្មតាបង្ហាញខ្លួនទុកជាបុត្រធីតាដែលកើតតាមព្រះបន្ទូលសន្យា ដោយមានជំនឿ និងសេចក្តីសង្ឃឹមរឹងប៉ឹង គេចេះប្រើប្រាស់ពេលវេលានៅសម័យឥឡូវ (អភ ៥, ១៦; កូឡ ៤, ៥) ហើយព្យាយាមខន្តីទន្ទឹងរង់ចាំសិរីរុងរឿងដែលត្រូវលេចមកនៅពេលខាងមុខ (រម ៨,២៥)។ ពួកគេមិនត្រូវលាក់ទុកសេចក្តីសង្ឃឹមនេះកប់នៅក្នុងជម្រៅចិត្តគេទេ តែត្រូវសម្តែងចេញតាមរចនាសម្ពន្ធនៃការរស់នៅក្នុងលោកនេះ ដោយខិតខំប្រែចិត្តគំនិតជានិច្ច «ទាំងប្រឆាំងប្រយុទ្ធទល់នឹងមេត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយប្រយុទ្ធទល់នឹងឥទ្ធិពលអរូបិយដ៏អាក្រក់ទាំងឡាយផងដែរ» (អភ ៦, ១២)។

អគ្គសញ្ញាទាំងប៉ុន្មាននៃសម្ពន្ធមេត្រីថ្មីដែលប្រៀបដូចជាជាអាហារចិញ្ចឹមជីវិត និងពង្រឹងមុខងារជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទធម្មតា ពិតជាប្រផ្នូលអំពីមេឃនិងផែនដីថ្មីយ៉ាងណា (វវ ២១, ១) គ្រីស្តបរិស័ទធម្មតាក៏ទៅជាអ្នកប្រកាសដ៏ពូកែអំពីជំនឿលើអ្វីៗដែលយើងសង្ឃឹមថានឹងបានយ៉ាងនោះដែរ (ហប ១១, ១) គឺគេឥតរួញរាប្រកាសជំនឿនេះ ទាំងខិតខំរស់នៅត្រឹមត្រូវស្របតាមជំនឿនេះថែមទៀត។ គ្រីស្តបរិស័ទធម្មតាប្រកាសដំណឹងល្អអំពីព្រះគ្រីស្ត ដោយផ្តល់សក្ខីភាពតាមការរស់នៅ និងដោយពោលពាក្យសម្តីអំពីព្រះគ្រីស្តទៀតផង។ ការប្រកាសដំណឹងល្អនេះមានលក្ខណៈពិសេស និងប្រកបដោយប្រសិទ្ធភាពយ៉ាងខ្លាំង ព្រោះគេប្រកាសដំណឹងល្អក្នុងសភាពការណ៍ធម្មតារបស់មនុស្សលោក។

ក្នុងចំណោមបន្ទុកទាំងប៉ុន្មានរបស់គ្រីស្តបរិស័ទធម្មតា របៀបរស់នៅជាគូស្វាមីភរិយា មានតម្លៃដ៏ថ្លៃថ្នូរយ៉ាងខ្លាំង។ មានអគ្គសញ្ញាពិសេសមួយ គឺអគ្គសញ្ញាអាពាហ៍ពិពាហ៍ ធ្វើឲ្យការរស់នៅជាគូស្វាមីភរិយា និងការរស់នៅជាក្រុមគ្រួសារបានវិសុទ្ធ។ ក្រុមគ្រួសារពិតជាកន្លែងដែលគ្រីស្តបរិស័ទធម្មតាប្រព្រឹត្តិកិច្ចការជាគ្រីស្តទូតរបស់ខ្លួន និងជាសាលារៀនពិសេសអប់រំអំពីកិច្ចការជាគ្រីស្តទូតនេះ គឺគ្រីស្តសាសនាជ្រាបចូលក្នុងការចាត់ចែងនៃរបៀបរស់នៅ និងផ្លាស់ប្រែរបៀបរស់នៅនោះជារៀងរាល់ថ្ងៃឲ្យកាន់តែប្រសើរឡើងៗ។ ព្រះជាម្ចាស់ត្រាស់ហៅគូស្វាមីភរិយាឲ្យមានបេសកកម្មពិសេសក្នុងក្រុមគ្រួសារ គឺម្នាក់ៗធ្វើជាសាក្សីចំពោះគ្នាទៅវិញទៅមកនិងចំពោះកូន អំពីជំនឿ និងអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ត។ ក្រុមគ្រួសារគ្រីស្តបរិស័ទ ប្រកាសយ៉ាងច្បាស់នូវរបៀបរស់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់សព្វថ្ងៃផង និងសេចក្តីសង្ឃឹមនឹងបានបរមសុខនៅលោកខាងមុខទៀតផងដែរ។ ដូច្នេះដោយធ្វើជាគំរូ និងដោយផ្តល់សក្ខីភាព ក្រុមគ្រួសារគ្រីស្តបរិស័ទស្តីបន្ទោសមនុស្សលោក ដែលជាប់នឹងបាប ហើយធ្វើជាពន្លឺសម្រាប់អស់អ្នកដែលស្វែងរកសេចក្តីពិតទៀតផង។

ហេតុនេះហើយ ដោយគ្រីស្តបរិស័ទធម្មតាធ្វើកិច្ចការប្រចាំថ្ងៃ និងដោយមានកង្វល់អំពីជីវិតក្នុងលោកីយ៍ គេអាចបំពេញ (និងត្រូវបំពេញ) កិច្ចការមួយដ៏សំខាន់ ក្នុងការនាំដំណឹងល្អដល់មនុស្សលោក។ គ្រីស្តបរិស័ទធម្មតាខ្លះ ជួយណែនាំពិធីតាមសមត្ថភាពរបស់ខ្លួន នៅពេលខ្វះលោកគង្វាល ឬនៅពេលអស់លោកគង្វាលមិនអាចធ្វើជាប្រធានក្នុងពិធីទាំងនោះបាន ព្រោះត្រូវគេបៀតបៀនធ្វើបាប។ គ្រីស្តបរិស័ទធម្មតាជាច្រើនទៀត ចំណាយកម្លាំងរបស់ខ្លួនអស់ ក្នុង

កិច្ចការជាគ្រីស្តទូត។ ប៉ុន្តែ គ្រីស្តបរិស័ទធម្មតាទាំងអស់ មានភារកិច្ចសហការលាតសន្ធឹងព្រះរាជ្យព្រះគ្រីស្ត ឲ្យចម្រើនឡើងក្នុងពិភពលោកទាំងមូល។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទធម្មតា ត្រូវខិតខំស្វែងរកឲ្យស្គាល់កាន់តែច្បាស់ នូវសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងមក និងទទួចអង្វរព្រះជាម្ចាស់ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រទានប្រាជ្ញាញាណដល់ខ្លួនគេផង។

## ៣៦- គ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាព្រះមហាក្សត្រ

ព្រះគ្រីស្តធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត ហេតុនេះហើយ បានជាព្រះបិតាលើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត (ភល ២, ៨-៩) ហើយទ្រង់ចូលក្នុងសិរីរុងរឿងនៃព្រះរាជ្យព្រះអង្គ។ ព្រះជាម្ចាស់បានបញ្ចុះបញ្ចូលអ្វីៗទាំងអស់ក្រោមអំណាចរបស់ព្រះគ្រីស្ត ទម្រាំព្រះបុត្រាផ្ទាល់នឹងចុះចូលក្រោមអំណាចព្រះបិតា រួមជាមួយសត្វលោកទាំងឡាយ ដើម្បីឲ្យព្រះជាម្ចាស់បំពេញអ្វីៗទាំងអស់ក្នុងមនុស្សទាំងអស់ (១ករ ១៥, ២៧-២៨)។ ព្រះគ្រីស្តបានប្រគល់អំណាចនេះឲ្យក្រុមសាវ័ក ហើយតែងតាំងគេឲ្យមានសេរីភាពក្នុងឋានៈគេជាព្រះមហាក្សត្រ ដើម្បីឲ្យគេរំដោះខ្លួនរួចពីអំណាចនៃបាប ដែលសោយរាជ្យលើខ្លួនគេផ្ទាល់ ដោយគេមានចិត្តលះបង់ និងរស់នៅយ៉ាងវិសុទ្ធ (រម ៦, ១២)។ លើសពីនេះទៅទៀត ដោយបម្រើព្រះគ្រីស្តក្នុងការបម្រើអ្នកដទៃ គេអាចណែនាំបងប្អូនរបស់ខ្លួន ទាំងមានចិត្តសុភាពរាបសា និងចិត្តអត់ធ្មត់ខន្តី ទៅគាល់ព្រះមហាក្សត្រ។ អ្នកបម្រើព្រះមហាក្សត្រនេះ ក៏ជាព្រះមហាក្សត្រដែរ។

ព្រះអម្ចាស់សព្វព្រះហឫទ័យលាតសន្ធឹងព្រះរាជ្យរបស់ព្រះអង្គ តាមរយៈគ្រីស្តបរិស័ទធម្មតាគឺ ក្រោមព្រះរាជ្យនេះ សេចក្តីពិតនិងជីវិត ភាពវិសុទ្ធនិងព្រះហឫទ័យប្រណីសន្តោស យុត្តិធម៌ សេចក្តីស្រឡាញ់ និងសន្តិភាព គ្រងរាជ្យហើយ។ ក្រោមរាជ្យនោះ សត្វលោកបានរួចពីការធ្វើជាទាសករនៃការវិនាសអន្តរាយ ហើយមានសេរីភាពប្រកបដោយសិរីរុងរឿងក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ (រម ៨,២១)។ ព្រះបន្ទូលសន្យា ពិតជាប្រសើរណាស់ វិន័យដែលព្រះយេស៊ូប្រទានឲ្យក្រុមសាវ័កក៏ពិតជាប្រសើរឧត្តុង្គឧត្តមដែរគឺថា៖ *"អ្វីៗទាំងអស់សុទ្ធតែបម្រើបងប្អូនទាំងអស់ រីឯបងប្អូនវិញ បងប្អូនបម្រើព្រះគ្រីស្ត ហើយព្រះគ្រីស្តបម្រើព្រះជាម្ចាស់"* (១ករ ៣, ២៣)។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទត្រូវទទួលស្គាល់លក្ខណៈដ៏ជ្រៅបំផុតនៃសត្វលោកទាំងអស់។ តម្លៃដ៏ថ្លៃថ្នូរ និងទិសដៅនៃសត្វលោកទាំងនោះ គឺលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ គ្រីស្តបរិស័ទក៏ត្រូវជួយគ្នាទៅវិញទៅមក តាមកិច្ចការនៃលោកនេះ ដើម្បីឲ្យបានរស់នៅតាមរបៀបកាន់តែវិសុទ្ធឡើងៗ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្តនឹងជ្រាបចូលក្នុងពិភពលោក ហើយពិភពលោកឈានទៅកាន់ទិសដៅរបស់ខ្លួនយ៉ាងជោគជ័យ ដោយមានយុត្តិធម៌ សេចក្តីស្រឡាញ់ និងសន្តិភាព។ ក្នុងចំណោមគ្រីស្តបរិស័ទទាំងអស់ គ្រីស្តបរិស័ទធម្មតាមានតួនាទីពិសេសជាងគេ គឺធ្វើឲ្យសត្វលោកទាំងអស់ទៅដល់ទិសដៅរបស់ខ្លួន។ ដោយគ្រីស្តបរិស័ទធម្មតា មានសមត្ថភាពក្នុងគ្រប់វិស័យខាងលោកីយ៍ និងមានសកម្មភាពផ្សេងៗ ដែលមានព្រះគ្រីស្តណែនាំ គេត្រូវខិតខំឲ្យអស់ពីសមត្ថភាព ធ្វើឲ្យមនុស្សលោកថែទាំធនធានធម្មជាតិ ដែលព្រះអង្គបានប្រតិស្ឋានមក ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ ដោយមិនចោលនរណាម្នាក់សោះឡើយ។ ដោយសារកិច្ចការរបស់មនុស្ស ដោយសារបច្ចេកទេស និងវប្បធម៌លោកីយ៍ គ្រីស្តបរិស័ទធម្មតាត្រូវខិតខំចែករំលែកធនធានទាំងនោះ ដល់មនុស្សទាំងអស់ឲ្យកាន់តែប្រសើរឡើង ស្របតាមគោលបំណងនៃព្រះអាទិករ និងតាមព្រះបន្ទូលរបស់ព្រះអង្គបំភ្លឺ។ ត្រូវធ្វើឲ្យធនធានទាំងនោះ ជួយការអភិវឌ្ឍន៍ជាសកល ឲ្យមនុស្សមានសេរីភាព តាមលក្ខណៈជាមនុស្ស និងជាគ្រីស្តបរិស័ទ។ ដូច្នេះ តាមរយៈសមាជិកនៃ ព្រះសហគមន៍ ព្រះគ្រីស្តមុខជានឹងបំភ្លឺសង្គមមនុស្សទាំងមូលឲ្យកាន់តែភ្លឺឡើងៗ តាមពន្លឺរបស់ព្រះអង្គដែលសង្គ្រោះមនុស្សលោក ។

លើសពីនេះទៅទៀត ប្រសិនបើស្ថាប័ននានា និងសភាពការណ៍នៃការរស់នៅក្នុងពិភពលោក បណ្តាលឲ្យប្រព្រឹត្តអំពើបាប សូមឲ្យគ្រីស្តបរិស័ទធម្មតា រួមកម្លាំងគ្នាជួយប្រែ និងព្យាបាលសភាពការណ៍និងស្ថាប័នទាំងនោះ ឲ្យបានសមរម្យ។ ដូច្នេះស្ថាប័ន និងសភាពការណ៍ទាំងនោះ បានស្របតាមក្បួននៃយុត្តិធម៌ ហើយជួយមនុស្សឲ្យប្រព្រឹត្តតាមព្រហ្មវិហារធម៌ លែងរារាំងយុត្តិធម៌និងព្រហ្មវិហារធម៌ទៀតហើយ។ ប្រសិនបើគេប្រព្រឹត្តដូច្នេះ គ្រីស្តបរិស័ទនិងនាំតម្លៃដ៏ថ្លៃថ្នូរនៃសីលធម៌ឲ្យជ្រាបចូលក្នុងវប្បធម៌និងក្នុងគ្រប់កិច្ចការរបស់មនុស្ស។ ដូច្នេះ គ្រីស្តបរិស័ទរៀបចំមនុស្សលោកដែលប្រៀបដូចជាដីចម្ការមួយឲ្យបានល្អ ដើម្បីទទួលពូជនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ទ្វារនៃព្រះសហគមន៍ ក៏នឹងបើកចំហ បណ្តោយឲ្យដំណឹងអំពីសេចក្តីសុខសាន្តអាចចូលក្នុងពិភពលោកបាន។

តាមព្រះជាម្ចាស់ចាត់ចែងការសង្គ្រោះ គ្រីស្តបរិស័ទ ត្រូវបង្ហាត់ខ្លួនឲ្យចេះវែកញែកយ៉ាងច្បាស់អំពីសិទ្ធិ និងជាភារកិច្ចរបស់ខ្លួន ក្នុងឋានៈជាសមាជិកនៃព្រះសហគមន៍ និងក្នុងឋានៈជាសមាជិកនៃសង្គមមនុស្ស។ សូមយកចិត្តទុកដាក់ខិតខំធ្វើឲ្យសិទ្ធិនិងភារកិច្ចទាំងពីរយ៉ាងនេះស៊ីចង្វាក់ទៅវិញទៅមកយ៉ាងស្រួល។ ត្រូវនឹកជានិច្ចថា មនសិការរបស់គ្រីស្តបរិស័ទត្រូវណែនាំគេ ក្នុងគ្រប់វិស័យខាងលោកីយ៍ ដ្បិតគ្មានកិច្ចការណាមួយរបស់មនុស្ស សូម្បីតែកិច្ចការខាងលោកីយ៍ក្តី អាចជៀសផុតពីអំណាចរបស់ព្រះជាម្ចាស់បានសោះឡើយ។ នាសម័យបច្ចុប្បន្ន តាមរបៀបគ្រីស្តបរិស័ទធ្វើការ គេត្រូវញែកសិទ្ធិនិងភារកិច្ចទាំងពីរយ៉ាងនោះឲ្យបានច្បាស់ ហើយក៏ត្រូវឲ្យសិទ្ធិ និងភារកិច្ចទាំងនោះស៊ីចង្វាក់គ្នាយ៉ាងស្រួលដែរ។ នេះជាការណ៍ដ៏សំខាន់ ដើម្បីឲ្យព្រះសហគមន៍អាចតបឆ្លើយយ៉ាងពេញលេញ នឹងសភាពការណ៍ពិសេសនៃពិភពលោកយើងនាបច្ចុប្បន្ននេះ តាមបេសកកម្មរបស់ខ្លួន។ យើងក៏ត្រូវទទួលស្គាល់ថា អ្នកកាន់អំណាចខាងនយោបាយ មានសិទ្ធិពេញទីក្នុងការណែនាំខាងលោកីយ៍ គេក៏មានគោលការណ៍ណែនាំផ្ទាល់របស់គេដែរ។ ក៏ប៉ុន្តែនៅពេលជាមួយគ្នានោះ គ្រីស្តបរិស័ទត្រូវបដិសេធលទ្ធិដ៏អាក្រក់ដែលអះអាងថា គេអាចសាងសង់សង្គមមនុស្សដោយមិនអើពើនឹងសាសនាទាល់តែសោះ មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពខាងសាសនា ព្រមទាំងបំបាត់សេរីភាពនោះផង។

## ៣៧- ទំនាក់ទំនងជាមួយក្រុមអភិបាល

គ្រីស្តបរិស័ទធម្មតា ក៏ដូចគ្រីស្តបរិស័ទឯទៀតៗទាំងអស់ដែរ មានសិទ្ធិទទួលធនធានយ៉ាងបរិបូរណ៍ ខាងព្រះវិញ្ញាណ ដែលហូរមកពីទ្រព្យដ៏មានតម្លៃរបស់ព្រះសហគមន៍ ជាពិសេសគេមានសិទ្ធិទទួលជំនួយមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងពីអគ្គសញ្ញានានាដែលអភិបាលនិងបូជាចារ្យចែកឲ្យ។ សូមឲ្យគេមានសេរីភាពជម្រាបគង្វាលទាំងនោះឲ្យជ្រាបអំពីសេចក្តីត្រូវការ និងអ្វីៗដែលគេចង់បាន ទាំងទុកចិត្តអស់លោកក្នុងឋានៈ អស់លោកជាបុត្រធីតារបស់ព្រះជាម្ចាស់ និងជាបងប្អូនក្នុងអង្គព្រះគ្រីស្ត។ គេក៏មានលទ្ធភាព (ហើយជួនកាលមានភារកិច្ច) បញ្ចេញយោបល់អំពីអ្វីៗដែលជាប្រយោជន៍ដល់ព្រះសហគមន៍ តាមចំណេះចេះដឹង តាមសមត្ថភាព និងតាមឋានៈរបស់ខ្លួនទៀតផងដែរ។ ប្រសិនបើគេចង់ផ្តល់យោបល់ ត្រូវផ្តល់តាមរចនាសម្ពន្ធដែលព្រះសហគមន៍បានចាត់ចែងឲ្យ ដោយចិត្តស្មោះ ដោយចិត្តក្លាហាន និងដោយប្រុងប្រយ័ត្នជានិច្ច ទាំងមានសេចក្តីគោរព និងសេចក្តីស្រឡាញ់ដែលត្រូវបង្ហាញចំពោះអស់លោកដែលជាតំណាងព្រះគ្រីស្ត ព្រោះអស់លោកបានទទួលអគ្គសញ្ញាតែងតាំង។

គ្រីស្តបរិស័ទធម្មតា ក៏ដូចគ្រីស្តបរិស័ទឯទៀតៗទាំងអស់ដែរ គេត្រូវតែសុខចិត្តទទួលសេចក្តីដែលអស់លោកអភិបាលជាគង្វាល បានសម្រេចក្នុងឋានៈជាតំណាងព្រះគ្រីស្ត ក្នុងនាមអស់លោកជាក្រុមណែនាំ និងតាមអំណាចរបស់

អស់លោកក្នុងព្រះសហគមន៍។ ត្រូវតែសុខចិត្តទទួលភ្លាម តាមរបៀបគ្រីស្តបរិស័ទធ្លាប់ស្តាប់បង្គាប់។ ធ្វើដូច្នេះ គេយកតម្រាប់តាមព្រះគ្រីស្តជាបរមគ្រូរបស់គេ ដែលបានស្តាប់តាមបញ្ជារហូតដល់សោយទិវង្គត និងដែលបានបើកមាគ៌ាដ៏សែនសុខសាន្តឆ្ពោះទៅកាន់សេរីភាពនៃបុត្រធីតារបស់ព្រះជាម្ចាស់។ សូមឲ្យគ្រីស្តបរិស័ទធម្មតាអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់អស់មេដឹកនាំ ដែលព្រះអង្គតែងតាំងឲ្យថែរក្សាជីវិតខាងវិញ្ញាណរបស់យើង ព្រោះអស់លោកនឹងត្រូវទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ សូមឲ្យអស់លោកបំពេញមុខងារនេះដោយអំណរ មិនមែនដោយថ្ងូរទេ (ហប ១៣, ១៧)។

ចំពោះអស់លោកជាគង្វាលវិញ ត្រូវទទួលស្គាល់និងលើកស្ទួយកិត្តិយសដ៏ថ្លៃថ្នូររបស់គ្រីស្តបរិស័ទធម្មតា ដែលអាចទទួលខុសត្រូវក្នុងព្រះសហគមន៍។ សូមឲ្យអស់លោកសួរយោបល់ដ៏វាងវៃរបស់គេ ផ្ញើមុខងារបម្រើព្រះសហគមន៍ឲ្យគេទាំងទុកចិត្ត ទុកសេរីភាពឲ្យគេប្រព្រឹត្តកិច្ចការរបស់គេ ដាស់តឿនគេឲ្យមានចិត្តក្លាហានចាប់ផ្តើមធ្វើការផ្សេងៗដោយគំនិតគេផ្ទាល់។ សូមអស់លោកមានចិត្តស្រឡាញ់គ្រីស្តបរិស័ទធម្មតា ដូចឪពុកស្រឡាញ់កូន សូមរាប់អានគេក្នុងអង្គព្រះគ្រីស្ត និងចាប់អារម្មណ៍នូវអ្វីៗដែលគេសាកល្បងចង់ធ្វើតាមបំណងប្រាថ្នារបស់គេ។ សូមទទួលស្គាល់ និងគោរពសិទ្ធិសេរីភាពដ៏ត្រឹមត្រូវរបស់គ្រីស្តបរិស័ទធម្មតា ជាសេរីភាពរបស់មនុស្សទាំងអស់នៅលើផែនដីនេះ។

ទំនាក់ទំនងយ៉ាងស្និទ្ធស្នាលរវាងគ្រីស្តបរិស័ទធម្មតា និងអស់លោកជាគង្វាល មុខជានឹងផ្តល់ផលគ្រប់យ៉ាងសម្រាប់ព្រះសហគមន៍ គឺគ្រីស្តបរិស័ទធម្មតានឹងពង្រឹងគំនិតទទួលការខុសត្រូវរបស់ខ្លួនផ្ទាល់ ពង្រឹងចិត្តឧស្សាហ៍របស់គេ ពង្រឹងកម្លាំងឲ្យគេចូលរួមសហការក្នុងកិច្ចការរបស់អស់លោកគង្វាលយ៉ាងស្រួល។ រីឯអស់លោកគង្វាលវិញ ដោយមានបទពិសោធន៍របស់គ្រីស្តបរិស័ទធម្មតាជួយ អស់លោកអាចវិនិច្ឆ័យបានច្បាស់ និងត្រឹមត្រូវ មិនត្រឹមតែក្នុងរឿងសាសនាប៉ុណ្ណោះទេ តែក្នុងរឿងលោកីយ៍ថែមទៀតផង។ ដូច្នេះ ដោយមានសមាជិកទាំងអស់ជួយពង្រឹងផង ព្រះសហគមន៍ទាំងមូលអាចបំពេញបេសកកម្មរបស់ខ្លួនដោយប្រសិទ្ធភាពបាន គឺជួយមនុស្សលោកឲ្យបានជីវិត។

### ៣៨- ពាក្យបញ្ចប់

គ្រីស្តបរិស័ទធម្មតាម្នាក់ៗ ត្រូវធ្វើជាសាក្សីនៅចំពោះមុខមនុស្សលោកអំពីព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មថ្មីដ៏រុងរឿងរស់នៅក្នុងលោកនេះ និងទៅជាសញ្ញាសម្គាល់អំពីព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅដែរ។ គ្រីស្តបរិស័ទទាំងអស់គ្នា និងគ្រីស្តបរិស័ទម្នាក់ៗតាមចំណែករៀងៗខ្លួន ត្រូវចិញ្ចឹមមនុស្សលោកដោយផលផ្លែដែលកើតពីព្រះវិញ្ញាណ (កាឡ ៥, ២២)។ គេចាក់បង្ហូរព្រះវិញ្ញាណនេះដែលមានសកម្មភាពក្នុងជនក្រីក្រ ក្នុងជនស្លូតបូត និងក្នុងអ្នកកសាងសន្តិភាព ដែលសុទ្ធតែអាចទទួលសុភមង្គលបាន ដូចព្រះអម្ចាស់មានព្រះបន្ទូលមក (មថ ៥, ៣-៩)។ សរុបសេចក្តីមក «វិញ្ញាណផ្តល់ជីវិតឲ្យរូបកាយយ៉ាងណា គ្រីស្តបរិស័ទផ្តល់ជីវិតឲ្យមនុស្សលោកយ៉ាងនោះដែរ» (លិខិតផ្ញើជូនលោកឌីយ៉ូង៉ែត)។

# ជំពូក ៥

## ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យបានវិសុទ្ធ

### ៣៩- អារម្ភកថា

មហាសន្និបាតដ៏វិសុទ្ធ បង្ហាញគម្រោងដ៏អស្ចារ្យរបស់ព្រះជាម្ចាស់អំពីព្រះសហគមន៍ គឺតាមជំនឿយើងព្រះសហគមន៍ពិតជាវិសុទ្ធ ហើយក៏មិនអាចលែងទៅជាវិសុទ្ធបានដែរ។ ក្នុងធម៌ *"សូមលើកតម្កើងសិរីរុងរឿង"* យើងធ្លាប់ប្រកាសថា ព្រះគ្រីស្តជាព្រះបុត្រា ពិតជា "ព្រះដ៏វិសុទ្ធតែមួយព្រះអង្គ" រួមជាមួយព្រះបិតានិងព្រះវិញ្ញាណ។ ព្រះអង្គបានស្រឡាញ់ព្រះសហគមន៍ទុកជាព្រះមហេសី និងបានបូជាព្រះជន្មសម្រាប់ព្រះសហគមន៍ ដើម្បីប្រោសឲ្យព្រះសហគមន៍បានទៅជាវិសុទ្ធ (អភ ៥,២៥-២៦) ទ្រង់បានប្រោសឲ្យព្រះសហគមន៍ ភ្ជាប់ជាមួយព្រះអង្គទុកជាព្រះកាយព្រះអង្គ និងបានប្រទានព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងបរិបូរណ៍ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ហេតុនេះហើយបានជាព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទទាំងអស់ក្នុងព្រះសហគមន៍ ទាំងក្រុមអ្នកកាន់អំណាចតាមលំដាប់លំដោយ ទាំងគ្រីស្តបរិស័ទដែលត្រូវគេគ្រប់គ្រង ឲ្យបានវិសុទ្ធគ្រប់គ្នា ស្របតាមគ្រីស្តទូតចែងថា «ពិតមែនហើយ! ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបងប្អូនបានវិសុទ្ធមែន» (១ថស ៤, ៣ ; អភ ១, ៤)។ ព្រះសហគមន៍សម្តែងជានិច្ច (និងត្រូវសម្តែង) ថា ខ្លួនបានវិសុទ្ធដោយបង្ហាញផលផ្លែ នៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះវិញ្ញាណនៅក្នុងគ្រីស្តបរិស័ទ។ លក្ខណៈដ៏វិសុទ្ធនេះ លេចមកតាមរបៀបផ្សេងៗក្នុងគ្រីស្តបរិស័ទម្នាក់ៗ ដែលតម្រង់ខ្លួនទៅរកសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈតាមរបៀបរស់នៅរបស់គេផ្ទាល់ ទាំងជួយកសាងអ្នកដទៃឲ្យទៅ ជាបុត្រធីតារបស់ព្រះបិតាផង។ លក្ខណៈដ៏វិសុទ្ធនេះលេចមកយ៉ាងច្បាស់ ដោយមានគ្រីស្តបរិស័ទខ្លះយកចិត្តទុកដាក់ ប្រតិបត្តិតាមដំបូន្មានដែលយើងធ្លាប់ហៅថា *"ដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ"*។

មានគ្រីស្តបរិស័ទមួយចំនួនធំ សុខចិត្តប្រតិបត្តិតាមដំបូន្មានទាំងនោះ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជំរុញ តាមរបៀបជាបុគ្គលម្នាក់ៗ ឬតាមស្ថានភាពរស់នៅ ឬតាមរបៀបរស់នៅជាបព្វជិតបព្វជិតា ដែលព្រះសហគមន៍ទទួលស្គាល់ជាផ្លូវការ។ ការប្រតិបត្តិតាមដំបូន្មានទាំងនោះផ្តល់ (និងត្រូវផ្តល់) សក្ខីភាពដ៏ភ្លឺចិញ្ចែងចិញ្ចាច និងជាឧទាហរណ៍មួយអំពីលក្ខណៈដ៏វិសុទ្ធរបស់ព្រះសហគមន៍។

### ៤០- ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ឲ្យបានវិសុទ្ធ

ព្រះអម្ចាស់យេស៊ូជាព្រះបរមគ្រូ និងជាគំរូអំពីសេចក្តីពេញលក្ខណៈគ្រប់យ៉ាង ព្រះអង្គបានបង្រៀនក្រុមសាវ័កទាំងមូល និងសាវ័កម្នាក់ៗ ទោះជាគេមានឋានៈ វណ្ណៈណាក្តី ឲ្យរស់នៅតាមរបៀបដ៏វិសុទ្ធ ដូចព្រះអង្គបង្កើតរបៀបរស់នៅដែរ។ ព្រះអង្គក៏អាចប្រោសឲ្យរបៀបរស់នៅបែបនោះបានគ្រប់លក្ខណៈ ដូចព្រះអង្គមានព្រះបន្ទូលថា «ព្រះបិតារបស់អ្នករាល់គ្នាដ៏ខ្ពង់ខ្ពស់បំផុតគ្រប់លក្ខណ៍យ៉ាងណា សូមឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍យ៉ាងនោះដែរ» (មថ ៥,

៤៨)។ ព្រះអង្គបានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ មកសណ្ឋិតលើសាវ័កទាំងអស់ ដើម្បីជំរុញគេពីខាងក្នុងឲ្យស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់ពីកម្លាំង (មក ១២, ៣០) ព្រមទាំងឲ្យស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះគ្រីស្តបានស្រឡាញ់គេដូច្នោះដែរ (យហ ១៣, ៣៤; ១៥, ១២)។ ព្រះជាម្ចាស់ត្រាស់ហៅសាវ័ករបស់ព្រះគ្រីស្ត មិនមែនព្រោះគេមានកុសលផលបុណ្យនោះទេ តែព្រោះព្រះអង្គបានគ្រោងទុកជាមុន តាមព្រះហឫទ័យប្រណីសន្តោស។ ព្រះអង្គប្រោសគេឲ្យបានសុចរិត ដោយគេរួមក្នុងអង្គព្រះយេស៊ូជាអម្ចាស់។ គេបានទៅជា បុត្រធីតារបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ ដោយសារអគ្គសញ្ញាជ្រមុជទឹក ដែលបញ្ជាក់ជំនឿរបស់គេ គេក៏ទទួលចំណែកនៃសភាពរបស់ព្រះជាម្ចាស់ផ្ទាល់ ហេតុនេះហើយ បានជាគេជាវិសុទ្ធប្រាកដមែន។ គ្រីស្តបរិស័ទត្រូវរក្សាទុកលក្ខណៈដ៏វិសុទ្ធដែលគេបានទទួលនេះ ឲ្យនៅគង់វង្ស និងធ្វើឲ្យលក្ខណៈដ៏វិសុទ្ធនេះបានពេញលេញ តាមការរស់នៅរបស់គេដោយព្រះជាម្ចាស់ប្រណីសន្តោសផង។ គ្រីស្តទូតប៉ូលទូន្មានគេឲ្យរស់នៅក្នុងឋានៈជាជនដ៏វិសុទ្ធ (អភ ៥, ៣) «ដោយព្រះជាម្ចាស់បានជ្រើសរើសបងប្អូនធ្វើជាជនដ៏វិសុទ្ធ និងជាទីស្រឡាញ់របស់ព្រះអង្គ បងប្អូនត្រូវតែកាន់ចិត្តអាណិតមេត្តាចិត្តល្អ សប្បុរស ចេះបន្ទាបខ្លួន មានចិត្តស្លូតបូត និងចិត្តខន្តីអត់ធ្មត់» (កូឡ ៣, ១២)។ គ្រីស្តទូតប៉ូលក៏ដាស់តឿនគេឲ្យបង្កើតផលផ្លែនៃព្រះវិញ្ញាណ ដើម្បីឲ្យគេបានវិសុទ្ធ (កឡ ៥, ២២; រម ៦, ២២)។ ក៏ប៉ុន្តែ ដោយយើងទាំងអស់គ្នាតែងតែធ្វើខុសព្រះហឫទ័យព្រះជាម្ចាស់ជាច្រើន (យក ៣,២) យើងត្រូវការព្រះអង្គអាណិតមេត្តាជានិច្ច។ នៅពេលអធិដ្ឋានជារៀងរាល់ថ្ងៃ យើងតែងតែទូលអង្វរថា «សូមព្រះអង្គលើកលែងទោសឲ្យយើងខ្ញុំផង» (មថ ៦, ១២)។

គ្រីស្តបរិស័ទទាំងអស់ត្រូវដឹងច្បាស់ថា អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទោះជាគេរស់នៅតាមរបៀបណាក្តី ឬមានឋានៈណាក្តី ក៏ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យរស់យ៉ាងពេញលក្ខណៈជាគ្រីស្តបរិស័ទ និងឲ្យមានសេចក្តីស្រឡាញ់យ៉ាងពេញលក្ខណៈដែរ ។ សូម្បីតែក្នុងសង្គមមនុស្សនៅលើផែនដីនេះ ក៏លក្ខណៈវិសុទ្ធរបស់គ្រីស្តបរិស័ទនេះ ពិតជាជួយឲ្យសភាពការណ៍មនុស្សរស់នៅកាន់តែប្រសើរឡើងៗ។ គ្រីស្តបរិស័ទត្រូវយកកម្លាំង ដែលខ្លួនបានទទួលតាមកម្រិតនៃព្រះអំណោយទានរបស់ព្រះគ្រីស្ត មកប្រើដើម្បីឲ្យបានវិសុទ្ធគ្រប់លក្ខណៈ។ គេត្រូវដើរតាមព្រះអង្គជាគំរូ និងបានដូចព្រះអង្គ ដោយបំពេញព្រះហឫទ័យព្រះបិតាក្នុងគ្រប់ប្រការ ហើយបូជាកម្លាំងចិត្តកម្លាំងកាយលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតា និងបម្រើអ្នកដទៃផង។ ធ្វើដូច្នេះ ទើបលក្ខណៈវិសុទ្ធនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់នឹងបង្កើតផលផ្លែជាច្រើន ដូចរបៀបរស់នៅរបស់សន្តបុគ្គលជាច្រើនអនេកជាសាក្សីស្រាប់ ក្នុងប្រវត្តិសាស្ត្រព្រះសហគមន៍។

## ៤១- គ្រីស្តបរិស័ទបានវិសុទ្ធដោយរស់នៅតាមរបៀបជាច្រើន

អស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ ស្តាប់តាមព្រះសូរសៀងរបស់ព្រះបិតា និងគោរពប្រណិប័តន៍ថ្វាយបង្គំព្រះជាម្ចាស់ជាបិតាដោយវិញ្ញាណនិងតាមសេចក្តីពិត។ អ្នកទាំងនោះ ក៏យកចិត្តទុកដាក់ចង់បានលក្ខណៈវិសុទ្ធតែមួយនេះ តាមរបៀបរស់នៅរបស់គេ និងដោយបំពេញមុខងារផ្សេងៗដែរ។ គេយកតម្រាប់តាមព្រះគ្រីស្តដែលដាក់ខ្លួនជាអ្នកក្រីក្រ មានចិត្តសុភាពរាបសា និងលីឈើឆ្កាង។ ធ្វើដូច្នេះ ទើបគេនឹងអាចទទួលចំណែកនៃសិរីរុងរឿងរបស់ព្រះអង្គបាន។ ម្នាក់ៗត្រូវប្តេជ្ញាចិត្តដើរទៅមុខតាមព្រះអំណោយទាន និងតាមទេពកោសល្យរបស់ខ្លួន ដោយមានជំនឿរស់រវើកដាស់តឿនគេឲ្យមានសេចក្តីសង្ឃឹម និងឲ្យប្រព្រឹត្តកិច្ចការទាំងអស់ដោយសេចក្តីស្រឡាញ់។

អស់លោកអភិបាលដែលទទួលបន្ទុកជាគង្វាលហ្វូងចៀមរបស់ព្រះគ្រីស្ត ត្រូវខ្នះខ្នែងបំពេញមុខងារបម្រើរបស់ខ្លួនតាមបែបវិសុទ្ធ ទាំងមានចិត្តសុភាពរាបសា និងមានកម្លាំងក្លាហានផង។ អស់លោកត្រូវប្រព្រឹត្តដូច្នេះមុនគ្រីស្តបរិស័ទឯទៀតៗទាំងអស់ តាមព្រះគ្រីស្តជាមហាបូជាចារ្យដែលស្ថិតនៅអស់កល្បជានិច្ច ជាគង្វាលដ៏ប្រសើរ និងជាអភិបាលនៃ

ជីវិតខាងព្រះវិញ្ញាណរបស់យើង។ ប្រសិនបើអស់លោកបំពេញមុខងាររបស់ខ្លួនតាមបែបនេះ មុខងារនោះ ត្រឡប់ទៅជាមធ្យោបាយដ៏ប្រសើរដែលអាចនាំឲ្យអស់លោកបានវិសុទ្ធ។ ចំពោះអស់លោក ដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យធ្វើជាអភិបាល គឺទទួលមុខងារជាបូជាចារ្យយ៉ាងពេញលេញ ព្រះអង្គប្រណីសន្តោសប្រទានព្រះអំណោយទាន តាមអគ្គសញ្ញាតែងតាំងនេះ ឲ្យអស់លោកអាចបំពេញយ៉ាងពេញលក្ខណៈ នូវបន្ទុកនៃសេចក្តីស្រឡាញ់ក្នុងឋានៈជាគង្វាល។ អស់លោកអធិដ្ឋាន ថ្វាយសក្ការៈបូជា ធ្វើពិធីអត្ថាធិប្បាយគម្ពីរ យកចិត្តទុកដាក់ថែរក្សា និងបម្រើគ្រប់យ៉ាងក្នុងឋានៈជាអភិបាល សុខចិត្តបូជាជីវិតដោយឥតរួញរា ដើម្បីជាប្រយោជន៍ដល់ហ្វូងចៀមរបស់ខ្លួន និងធ្វើជាគំរូដល់ហ្វូងចៀមទាំងមូល (១សល ៥, ៣)។ អស់លោកក៏ជួយព្រះសហគមន៍ឲ្យកាន់តែវិសុទ្ធជារៀងរាល់ថ្ងៃ ដោយអស់លោកធ្វើជាគំរូដល់គេថែមទៀតផង។

អស់លោកគង្វាល ក៏ដូចក្រុមអភិបាលដែរ គឺអស់លោកប្រៀបដូចជា ភួងជ័យខាងព្រះវិញ្ញាណរបស់ក្រុមអភិបាល។ អស់លោករួមចំណែកក្នុងព្រះអំណោយទានរបស់អស់លោកអភិបាល ដោយសារព្រះគ្រីស្តជាស្ពានមេត្រីតែមួយគត់ ស្ថិតនៅអស់កល្បជានិច្ច។ អស់លោកគង្វាល ត្រូវស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់មនុស្សឯទៀតៗកាន់តែខ្លាំងឡើងៗ ដោយបំពេញកិច្ចការរបស់ខ្លួនប្រចាំថ្ងៃ។ អស់លោកត្រូវរក្សាចំណងនៃការរួបរួមគ្នាជាបូជាចារ្យ ហើយត្រូវមានសម្បត្តិខាងព្រះវិញ្ញាណទាំងអស់ឲ្យបានបរិបូណ៌។ អស់លោកត្រូវរស់នៅតាមរបៀបដែលផ្តល់សក្ខីភាពដ៏រស់រវើកអំពីព្រះជាម្ចាស់ នៅចំពោះមុខមនុស្សទាំងអស់ ដូចបូជាចារ្យទាំងប៉ុន្មានដែលបានបង្ហាញលក្ខណៈវិសុទ្ធដ៏ត្រចះត្រចង់របស់ខ្លួនតាំងពីដើមរៀងមក ហើយដែលបានបម្រើព្រះសហគមន៍តាមរបៀបសុភាពរាបសាដោយគ្មាននរណាចាប់អារម្មណ៍។ ព្រះសហគមន៍របស់ព្រះជាម្ចាស់តែងតែលើកតម្កើងគង្វាលទាំងនោះ។

អស់លោកគង្វាល តាមបន្ទុករបស់ខ្លួន តែងតែថ្វាយពាក្យអង្វរ និងសក្ការបូជាសម្រាប់ប្រជាជនរបស់ខ្លួន និងសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល។ អស់លោកត្រូវដឹងខ្លួនអំពីកិច្ចការដ៏អស្ចារ្យដែលអស់លោកប្រព្រឹត្ត និងខិតខំរស់នៅឲ្យបានស្របតាមកិច្ចការទាំងនោះទៀតផង។ មិនត្រូវឲ្យកង្វល់ក្នុងកិច្ចការជាគ្រីស្តទូត គ្រោះកាចនានា និងទុក្ខលំបាក មករារាំងអស់លោកនោះទេ។ ផ្ទុយទៅវិញ ការណ៍ទាំងនោះអាចជួយអស់លោកឲ្យកាន់តែវិសុទ្ធ ដោយអស់លោកយកកម្លាំង ពីការស្ញឹងស្មាធិ៍ជាច្រើន មកជួយទ្រទ្រង់សកម្មភាពរបស់ខ្លួន។ ធ្វើដូច្នេះ អស់លោកក៏លើកទឹកចិត្តព្រះសហគមន៍របស់ព្រះជាម្ចាស់ទាំងមូលថែមទៀតផង។ សូមឲ្យអស់លោកគង្វាល ជាពិសេសបូជាចារ្យ (អាចារ្យ) ភូមិភាគ នឹកជានិច្ចថា អស់លោកអាចទៅជាវិសុទ្ធកាន់តែប្រសើរឡើងបាន ដោយរួមចិត្តគំនិតយ៉ាងស្មោះជាមួយអភិបាលរបស់ខ្លួន និងដោយសហការយ៉ាងទូលំទូលាយជាមួយលោកផង។

អស់លោកឧបដ្ឋាកជាអ្នកបម្រើកម្រិតក្រោម ក៏រួមចំណែកយ៉ាងពិសេសក្នុងបេសកកម្មនិងក្នុងព្រះអំណោយទានរបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់បំផុត។ ជាបឋម អស់លោកឧបដ្ឋាក ដែលបម្រើគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងរបស់ព្រះសហគមន៍ ត្រូវជៀសវាងកុំប្រព្រឹត្តអំពើអាក្រក់ ត្រូវខិតខំធ្វើឲ្យខ្លួនគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងបង្ហាញឲ្យមនុស្សលោកដឹងថា ព្រះអង្គអាចប្រើអស់លោកឲ្យនាំមនុស្សធ្វើអ្វីៗដ៏ល្អគ្រប់យ៉ាងដែលគេអាចធ្វើបាន (១ធម ៣, ៨-១០ និង១២-១៣)។ អស់អ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅ និងញែកដោយឡែកឲ្យទៅជាចំណែករបស់ព្រះអង្គផ្ទាល់ ត្រៀមខ្លួនបំពេញមុខងារបម្រើព្រះសហគមន៍ ក្រោមការពិនិត្យពិច័យរបស់អស់លោកអភិបាល ជាគង្វាល។ អស់លោកត្រូវយកចិត្តទុកដាក់ឲ្យមានចិត្តគំនិតស្របនឹងមុខងារដ៏ប្រសើររបស់ខ្លួន តាមព្រះជាម្ចាស់ត្រាស់ហៅឲ្យគេបំពេញនោះ គឺត្រូវព្យាយាមអធិដ្ឋាន ត្រូវមានចិត្តស្រឡាញ់យ៉ាងឧស្សាហ៍ ត្រូវនឹកគិតតែអំពីសេចក្តីដែលត្រឹមត្រូវ

សុចរិតគួរគោរព និងប្រព្រឹត្តអ្វីៗទាំងអស់ ដើម្បីលើកតម្កើងសិរីរុងរឿងនិងកិត្តិនាមរបស់ព្រះជាម្ចាស់។

យើងត្រូវនឹកដល់គ្រីស្តបរិស័ទធម្មតាឯទៀតៗ ដែលព្រះជាម្ចាស់បានជ្រើសរើស និងដែលលោកអភិបាលត្រាស់ហៅ ឲ្យបូជាកម្លាំងកាយកម្លាំងចិត្តបំពេញកិច្ចការជាគ្រីស្តទូត។ គេធ្វើការក្នុងស្រែចម្ការរបស់ព្រះអម្ចាស់ និងបង្កើតផលផ្លែជាច្រើន។

ចំពោះគ្រីស្តបរិស័ទជាគូស្វាមីភរិយា និងជាឪពុកម្ដាយ ត្រូវជួយគាំទ្រគ្នាទៅវិញទៅមកតាមមាគ៌ាផ្ទាល់ខ្លួនគឺស្រឡាញ់គ្នាយ៉ាងស្មោះស្ម័គ្រអស់មួយជីវិត ដោយព្រះជាម្ចាស់ជួយប្រណីសន្ដោស។ គេត្រូវអប់រំកូនៗដែលខ្លួនសុខចិត្តទទួលពីព្រះជាម្ចាស់ដោយសេចក្ដីស្រឡាញ់ ឲ្យស្គាល់លទ្ធិនៃគ្រីស្តសាសនា និងឲ្យកាន់តាមព្រហ្មវិហារធម៌ស្របតាមដំណឹងល្អ។ បើគេប្រព្រឹត្តដូច្នេះ គេធ្វើជាគំរូឲ្យមនុស្សអំពីសេចក្ដីស្រឡាញ់ដ៏ទូលំទូលាយ ដោយមិនចេះណាយចិត្តឡើយ។ គេជួយសាងសង់សេចក្ដីស្រឡាញ់ជាបងប្អូន ហើយផ្ដល់សក្ខីភាព និងរួមសហការ ធ្វើឲ្យព្រះសហគមន៍ជាព្រះមាតារបស់យើង អាចបង្កើតផលបាន។ ដូច្នេះ គូស្វាមីភរិយាធ្វើជាសញ្ញាសម្គាល់អំពីសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ត គេក៏រួមចំណែកក្នុងព្រះហឫទ័យស្រឡាញ់នោះដែរ ជាព្រះហឫទ័យស្រឡាញ់ចំពោះព្រះសហគមន៍ជាព្រះមហេសី គឺព្រះអង្គបូជាព្រះជន្ម ដើម្បីជាប្រយោជន៍ដល់ព្រះមហេសីនោះ។

ស្ត្រីៗមេម៉ាយនិងអ្នកនៅលីវ បង្ហាញលក្ខណៈដ៏វិសុទ្ធរបស់ព្រះសហគមន៍តាមរបៀបផ្សេងទៀត និងជួយបំពេញសកម្មភាពជាច្រើនក្នុងព្រះសហគមន៍ដែរ។

ចំពោះអ្នកដែលធ្វើការនឿយហត់ សូមឲ្យកិច្ចការទាំងនោះផ្ដល់ឲ្យខ្លួនបានទៅជាមនុស្សពេញលក្ខណៈ និងជួយប្រជាពលរដ្ឋដូចគ្នា ព្រមទាំងជួយលើកស្ទួយកម្រិតជីវភាពនៃសង្គមទាំងមូល និងថែរក្សាបរិស្ថានផង។ គេត្រូវមានចិត្តស្រឡាញ់អ្នកដទៃយ៉ាងសកម្ម ដោយយកតម្រាប់តាមព្រះគ្រីស្ត ដែលទ្រង់សព្វព្រះហឫទ័យធ្វើការដោយព្រះហស្តព្រះអង្គផ្ទាល់។ ព្រះអង្គក៏រួមជាមួយព្រះបិតា នៅតែធ្វើកិច្ចការដើម្បីសង្គ្រោះមនុស្សទាំងអស់។ សូមឲ្យអ្នកទាំងនេះពោរពេញទៅដោយសេចក្ដីសង្ឃឹម ហើយជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក។ សូមឲ្យគេបានវិសុទ្ធកាន់តែខ្លាំងឡើងៗ តាមរយៈកិច្ចការដែលគេធ្វើជារៀងរាល់ថ្ងៃ គឺជាលក្ខណៈវិសុទ្ធរបស់គ្រីស្តទូត។

សូមឲ្យអ្នកក្រីក្រ ជនពិការ អ្នកជំងឺ អ្នករងទុក្ខគ្រប់យ៉ាង អ្នកដែលត្រូវគេបៀតបៀនព្រោះតែទាមទារយុត្តិធម៌ ដឹងច្បាស់ថា គេក៏ចូលរួមយ៉ាងពិសេសជាមួយព្រះគ្រីស្តដែរ គឺរួមជាមួយព្រះគ្រីស្តដែលរងទុក្ខលំបាក ដើម្បីសង្គ្រោះមនុស្សលោក។ ក្នុងគម្ពីរដំណឹងល្អ ព្រះអម្ចាស់ប្រកាសថា អ្នកទាំងនោះមានសុភមង្គលហើយ! «បន្ទាប់ពីបានរងទុក្ខលំបាកមួយរយៈពេលដ៏ខ្លីនេះរួចហើយ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្ដោសគ្រប់យ៉ាង គឺព្រះអង្គដែលត្រាស់ហៅគេឲ្យទទួលសិរីរុងរឿងស្ថិតស្ថេរអស់កល្បជានិច្ច រួមជាមួយព្រះគ្រីស្ត ព្រះអង្គមុខជានឹងលើកគេឲ្យមានជំហរឡើងវិញ ហើយប្រទានឲ្យគេបានរឹងប៉ឹង និងមានកម្លាំងមាំមួន ឥតរង្គើឡើយ» (១សល ៥, ១០)។

ដូច្នេះហើយ អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តនឹងកាន់តែវិសុទ្ធឡើងៗ ស្របតាមសភាពការណ៍នៃការរស់នៅរបស់គេ តាមការងាររបស់គេ តាមកាលៈទេសៈនៃជីវិតរបស់គេ ហើយគេបានវិសុទ្ធតាមរយៈការណ៍ទាំងនោះថែមទៀតផង។ ប៉ុន្តែ គេត្រូវទទួលអ្វីៗទាំងអស់ ដោយផ្ញើជីវិតលើព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុត ហើយក៏ត្រូវរួមសហការជាមួយព្រះបិតា សូមធ្វើឲ្យព្រះហឫទ័យរបស់ព្រះអង្គកើតជារូបរាង ពោលគឺ ដោយគេបម្រើពិភពលោកនេះ គេសម្ដែងឲ្យមនុស្សទាំងអស់អាចមើលឃើញព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះពិភពលោក។

## ៤២- មាគ៌ានិងមធ្យោបាយនាំឲ្យខ្លួនបានវិសុទ្ធ

«ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ អ្នកណាស្ថិតនៅជាប់នឹងសេចក្ដីស្រឡាញ់ អ្នកនោះស្ថិតនៅជាប់នឹងព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ក៏ស្ថិតនៅជាប់នឹងអ្នកនោះដែរ» (១យហ ៤, ១៦)។ «ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង» (រម ៥, ៥)។ គឺព្រះហឫទ័យស្រឡាញ់នេះហើយ ដែលជំរុញយើងឲ្យស្រឡាញ់ព្រះជាម្ចាស់លើសអ្វីៗទាំងអស់ និងឲ្យស្រឡាញ់អ្នកដទៃ ដោយនឹកដល់ព្រះអង្គ។ ដូច្នេះ ព្រះហឫទ័យស្រឡាញ់នេះ ពិតជាព្រះអំណោយទានដំបូង និងដ៏ចាំបាច់ជាងគេ។ ប៉ុន្តែ ព្រះហឫទ័យស្រឡាញ់នេះអាចដុះឡើង និងបង្កើតផលក្នុងចិត្តមនុស្សបាន ដូចពូជមួយដ៏ល្អ លុះត្រាតែគ្រីស្តបរិស័ទម្នាក់ៗស្ម័គ្រចិត្តទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងប្រតិបត្តិតាមព្រះហឫទ័យព្រះអង្គ ដោយព្រះអង្គជួយប្រណីសន្ដោសទៀតផង។ គេក៏ត្រូវទទួលអគ្គសញ្ញាជាញឹកញាប់ ជាពិសេសរួមក្នុងអគ្គសញ្ញាអរព្រះគុណ និងពិធីគោរពប្រណិប័តន៍នានា ដើម្បីគោរពបម្រើព្រះអង្គ គេត្រូវយកចិត្តទុកដាក់និងព្យាយាមអធិដ្ឋាន សុខចិត្តលះបង់ខ្លួនឯង បម្រើបងប្អូនយ៉ាងសកម្ម ព្រមទាំងប្រព្រឹត្តតាមព្រហ្មវិហារធម៌ទាំងប៉ុន្មានផង។ សេចក្ដីស្រឡាញ់ធ្វើឲ្យមនុស្សបានពេញលក្ខណៈ និងនាំឲ្យប្រតិបត្តិតាមធម្មវិន័យបានគ្រប់លក្ខណៈដែរ (កូឡ ៣, ១៤; រម ១៣, ១០)។ សេចក្ដីស្រឡាញ់តម្រង់គ្រប់មធ្យោបាយ ដែលនាំឲ្យបានវិសុទ្ធ និងផ្ដល់ឲ្យមធ្យោបាយទាំងនេះបានស័ក្ដិសិទ្ធិនិងនាំទៅដល់ទិសដៅ។ ហេតុនេះហើយបានជាសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ ជាលក្ខណៈរបស់សាវ័កដ៏ពិតប្រាកដរបស់ព្រះគ្រីស្ត។

ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ បានសម្ដែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គដោយបូជាព្រះជន្មសម្រាប់យើង។ គ្មាននរណាមានសេចក្ដីស្រឡាញ់ខ្លាំងជាងអ្នកដែលបូជាជីវិតថ្វាយព្រះជាម្ចាស់ និងស៊ូប្ដូរជីវិត ដើម្បីបងប្អូននោះឡើយ។ (១យហ ៣, ១៦; យហ ១៥, ១៣)។ តាំងពីដើមដំបូងនៃព្រះសហគមន៍រៀងមក ព្រះជាម្ចាស់បានត្រាស់ហៅគ្រីស្តបរិស័ទខ្លះ ឲ្យផ្ដល់សក្ខីភាពយ៉ាងខ្ពង់ខ្ពស់អំពីសេចក្ដីស្រឡាញ់បែបនេះ នៅចំពោះមុខមនុស្សទាំងអស់ ហើយជាពិសេស នៅចំពោះមុខអ្នកដែលបៀតបៀនធ្វើបាបគេ។ ព្រះអង្គក៏នឹងត្រាស់ហៅគ្រីស្តបរិស័ទខ្លះតទៅទៀតនៅពេលអនាគតឲ្យបូជាជីវិតបែបនេះពុំខាន។ មរណសាក្សី បានដូចព្រះបរមគ្រូរបស់ខ្លួន គឺសុខចិត្តស្លាប់ដោយគ្មាននរណាបង្ខំ ដើម្បីសង្គ្រោះមនុស្សលោក។ អ្នកនោះបានដូចព្រះអង្គ ដោយសុខចិត្តឲ្យគេបង្ហូរឈាមរបស់ខ្លួន។ ហេតុនេះហើយ បានជាព្រះសហគមន៍យល់ឃើញថា ព្រះជាម្ចាស់ប្រទានព្រះអំណោយទានដ៏ខ្ពង់ខ្ពស់នេះដល់មរណសាក្សី និងទុកមរណសាក្សីជាអ្នកដែលបានផ្ដល់ភ័ស្ដុតាងយ៉ាងជាក់ច្បាស់ជាងគេ អំពីសេចក្ដីស្រឡាញ់។ ព្រះអង្គបានប្រណីសន្ដោសឲ្យមនុស្សមួយចំនួនតូចប៉ុណ្ណោះទៅជាមរណសាក្សី ក៏ប៉ុន្តែ គ្រីស្តបរិស័ទទាំងអស់ត្រូវប្រុងខ្លួននឹងប្រកាសជំនឿលើព្រះគ្រីស្ត នៅចំពោះមុខមនុស្សលោក។ នៅពេលមានគេបៀតបៀនធ្វើបាបព្រះសហគមន៍ គ្រីស្តបរិស័ទត្រូវសុខចិត្តដើរតាមព្រះអង្គរហូតដល់ឈើឆ្កាង ព្រោះព្រះសហគមន៍នៅតែជួបការបៀតបៀនរហូតពុំខានឡើយ។

តាមគម្ពីរដំណឹងល្អ ព្រះអម្ចាស់ប្រទានដំបូន្មានច្រើនឲ្យក្រុមសាវ័កកាន់តាម។ ព្រះសហគមន៍បានវិសុទ្ធយ៉ាងពិសេសដោយគ្រីស្តបរិស័ទកាន់តាមដំបូន្មានទាំងនោះ។ តាមដំបូន្មានទាំងនោះ ព្រះបិតាបានប្រោសប្រទានព្រះអំណោយទានដ៏ថ្លៃថ្លាប្រសើរជាងគេ ឲ្យគ្រីស្តបរិស័ទខ្លះថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់តែមួយព្រះអង្គដោយគ្មានចិត្តងាករេ គឺឲ្យរស់នៅជាព្រហ្មចារីនិងមិនរៀបការ (មថ ១៩, ១១; ១ករ ៧, ៧ និង៣២-៣៤)។ ដូច្នេះ គេអាចបម្រើព្រះអង្គយ៉ាងស្រួលជាងអ្នកមានគ្រួសារ។ តាំងពីដើមរៀងមក ព្រះសហគមន៍តែងតែគោរពយ៉ាងពិសេសចំពោះព្រហ្មចារីធម៌អស់មួយជីវិត ដោយនឹកដល់ព្រះរាជ្យនៃព្រះជាម្ចាស់ ទុកជាសញ្ញាសម្គាល់ដាស់តឿនសេចក្ដីស្រឡាញ់ និងទុកជាប្រភពពិសេស ដែលបង្កើតផលខាងព្រះវិញ្ញាណក្នុងពិភពលោក។

ព្រះសហគមន៍នៅតែនឹករឭកពាក្យប្រៀនប្រដៅរបស់គ្រីស្តទូតប៉ូល ដែលដាស់តឿនគ្រីស្តបរិស័ទឲ្យមានចិត្តស្រឡាញ់ គឺគ្រីស្តទូតសូមឲ្យគេមានបទពិសោធន៍ដូចព្រះគ្រីស្តយេស៊ូ ដែលព្រះអង្គបាន «លះបង់អ្វីៗទាំងអស់ មកយកឋានៈជាទាសករវិញ ធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង» (ភល ២, ៧-៨)។ ព្រះអង្គដែលមានសម្បត្តិស្តុកស្តម្ភជាច្រើន ទ្រង់ដាក់ខ្លួនជាអ្នកក្រព្រោះតែយើង (២ករ ៨,៩)។ តាមពិតសាវ័ករបស់ព្រះគ្រីស្តត្រូវតែយកតម្រាប់តាមព្រះអង្គជានិច្ច ហើយត្រូវផ្តល់សក្ខីភាពអំពីព្រះអង្គដែលមានព្រះហឫទ័យស្រឡាញ់ និងដាក់ខ្លួនទៀតផង។ ហេតុនេះហើយ បានជាព្រះសហគមន៍ជាព្រះមាតារបស់យើង មានអំណរដោយគ្រីស្តបរិស័ទមួយចំនួនធំ ទាំងបុរស ទាំងស្ត្រី ស្ម័គ្រចិត្តតាមព្រះអង្គកាន់តែជិតស្និទ្ធ និងបង្ហាញឲ្យកាន់តែច្បាស់ថា ព្រះសង្គ្រោះបានលះបង់អ្វីៗទាំងអស់។ អ្នកទាំងនោះមានសេរីភាព ជាបុត្រធីតារបស់ព្រះជាម្ចាស់ សុខចិត្តរស់នៅតាមរបៀបជាអ្នកក្រីក្រ និងសុខចិត្តស្តាប់បង្គាប់របស់អ្នកណែនាំ ជាជាងធ្វើតាមបំណងរបស់ខ្លួន។ ក្នុងករណីទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ អ្នកទាំងនោះសុខចិត្តចុះចូលក្រោមអំណាចមនុស្សដូចគ្នា ដោយនឹកដល់ព្រះជាម្ចាស់ គេប្រតិបត្តិលើសពីកម្រិតនៃវិន័យទៅទៀត ដើម្បីឲ្យបានកាន់តែដូចព្រះគ្រីស្តដែលស្តាប់តាមបញ្ជាព្រះបិតា។

អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ត្រូវតែខិតខំឲ្យបានវិសុទ្ធ និងបានទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ តាមរបៀបរស់នៅរបស់ខ្លួនម្នាក់ៗ។ សូមឲ្យគេយកចិត្តទុកដាក់ធ្វើជាម្ចាស់នៃតណ្ហារបស់ខ្លួន កុំឲ្យការប្រើប្រាស់សម្បត្តិលោកកីយ៍ និងចិត្តលោភលន់ ផ្ទុយពីចិត្តគំនិតរបស់អ្នក ដែលដាក់ខ្លួនជាអ្នកក្រីក្រ តាមគម្ពីរដំណឹងល្អ បណ្តាលឲ្យគេបែកចេញលែងស្វែងរកសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ។ គ្រីស្តទូតប៉ូលប្រៀនប្រដៅដូចតទៅ៖ «អស់អ្នកដែលប្រើប្រាស់សម្បត្តិលោកីយ៍ ក៏ត្រូវកាន់ចិត្តដូចជាមិនបានប្រើប្រាស់សម្បត្តិលោកីយ៍នោះដែរ ដ្បិតពិភពលោកនេះនឹងត្រូវប្រែប្រួលជាមិនខាន» (១ករ ៧, ៣១)។

# ជំពូក ៦

## បព្វជិតបព្វជិតា

### ៤៣- ការអនុវត្តន៍តាមដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ

ព្រះបន្ទូលនិងការរស់នៅរបស់ព្រះអម្ចាស់យេស៊ូ ពិតជាគំរូនិងជាគ្រឹះនៃដំបូន្មានដែលមានចែងក្នុងគម្ពីរដំណឹងល្អ គឺឲ្យរស់នៅជាព្រហ្មចារីថ្វាយព្រះជាម្ចាស់ ឲ្យរស់នៅរបៀបអ្នកក្រីក្រ និងឲ្យស្តាប់តាមបង្គាប់អ្នកដឹកនាំ។ ក្រុមគ្រីស្តទូត ទាំងគ្រូបាធ្យាយ ទាំងបណ្ឌិត និងទាំងគង្វាលព្រះសហគមន៍ ក៏តែងតែផ្តាំឲ្យរស់នៅតាមបែបនេះដែរ។ ដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ពិតជាព្រះអំណោយទានដែលព្រះសហគមន៍បានទទួលពីព្រះអម្ចាស់របស់ខ្លួន។ ព្រះសហគមន៍ក៏នៅតែថែរក្សាដំបូន្មានទាំងនោះយ៉ាងស្មោះ ដោយព្រះអង្គប្រណីសន្តោស។ ដោយព្រះវិញ្ញាណដ៏វិសុទ្ធណែនាំ ក្រុមអ្នកមានអំណាចក្នុងព្រះសហគមន៍ចាប់អារម្មណ៍បញ្ជាក់លទ្ធិ និងចាត់ចែងអំពីរបៀបអនុវត្តតាមដំបូន្មានទាំងនោះ ហើយតែងតាំងរបៀបរស់នៅយ៉ាងស្ថិតស្ថេរ ដោយយកដំបូន្មានទាំងនោះជាគ្រឹះ។ មានរបៀបរស់នៅតាមដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ប្លែកៗពីគ្នា កើតឡើងកាន់តែច្រើន ប្រៀបដូចគ្រាប់ពូជដែលព្រះជាម្ចាស់សាបព្រោះ កើតជាដើមឈើមួយបែកមែកសាខាជាច្រើនយ៉ាងអស្ចារ្យក្នុងចម្ការរបស់ព្រះអម្ចាស់ គឺមានអ្នកខ្លះជាឥសីរស់នៅម្នាក់ឯង អ្នកខ្លះនាំគ្នារស់នៅរួមជាមួយគ្នា អ្នកខ្លះបង្កើតក្រុមគ្រួសារផ្សេងៗប្រកបដោយ ធនធានខាងព្រះវិញ្ញាណ យ៉ាងស្តុកស្តម្ភ ដែលមានប្រយោជន៍ដល់សមាជិកក្រុមគ្រួសារទាំងនោះផង និងដល់ព្រះកាយព្រះគ្រីស្តទាំងមូលផងដែរ។ ក្រុមគ្រួសារទាំងនោះជួយសមាជិករបស់ខ្លួនឲ្យមានរបៀបរស់នៅស្ថិតស្ថេរជាងនៅម្នាក់ឯង ឲ្យមានលទ្ធិដែលគេសាកល្បងលមើលរួចហើយ ដើម្បីទៅកាន់សេចក្តីដ៏ពេញលក្ខណៈ ឲ្យរួមរស់ជាបងប្អូនក្នុងកងទ័ពរបស់ព្រះគ្រីស្ត និងឲ្យមានសេរីភាពដ៏ពេញលេញដោយស្តាប់តាមបង្គាប់។ ដូច្នេះ បព្វជិតបព្វជិតាអាចបំពេញពាក្យសច្ចារបស់ខ្លួន ដោយចិត្តនឹងន និងចិត្តស្មោះ ឈានទៅមុខតាមផ្លូវនៃសេចក្តីស្រឡាញ់ទាំងមានអំណរសប្បាយមកពីព្រះវិញ្ញាណផង។

បើគិតអំពីព្រះជាម្ចាស់តែងតាំងព្រះសហគមន៍ឲ្យមានរចនាសម្ពន្ធតាមលំដាប់លំដោយ បព្វជិតបព្វជិតារស់នៅតាមរបៀបម្យ៉ាង គាត់មិនមែនបំពេញមុខងារបម្រើព្រះសហគមន៍ទេ ហើយក៏មិនមានឋានៈលើសពីគ្រីស្តបរិស័ទធម្មតាដែរ។ ព្រះជាម្ចាស់ត្រាស់ហៅអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទាំងអ្នកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ ទាំងគ្រីស្តបរិស័ទធម្មតា ឲ្យទទួលព្រះអំណោយទានពិសេសធ្វើជាបព្វជិតបព្វជិតាក្នុងព្រះសហគមន៍ ព្រមទាំងឲ្យបម្រើបេសកកម្មរបស់ព្រះសហគមន៍ គឺនាំការសង្គ្រោះដល់មនុស្សលោក តាមរបៀបរៀងៗខ្លួន។

### ៤៤- លក្ខណៈនិងសារៈសំខាន់នៃការរស់នៅ ជាបព្វជិតបព្វជិតាក្នុងព្រះសហគមន៍

គ្រីស្តបរិស័ទណាដែលផ្ញើជីវិតលើព្រះគ្រីស្ត ហើយដែលធ្វើពិធីសច្ចាប្រណិធាន ឬដែលធ្វើពាក្យសន្យាឯទៀតៗតាមបែបរៀងៗខ្លួន ដែលប្រហាក់ប្រហែលនឹងពាក្យសច្ចាប្រណិធាន គឺគ្រីស្តបរិស័ទនោះ បង្ខំចិត្តឲ្យប្រតិបត្តិតាមដំបូន្មាន

ទាំងបីដែលមានចែងក្នុងគម្ពីរដំណឹងល្អ ដូចមានរៀបរាប់នៅខាងលើ។ អ្នកនោះថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់ ដែលខ្លួនស្រឡាញ់លើសអ្វីៗទាំងអស់ ដើម្បីតម្រង់ខ្លួនទៅបម្រើព្រះអម្ចាស់ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ក្នុងឋានៈពិសេសថ្មីម៉្យាង។ ដោយទទួលអគ្គសញ្ញាជ្រមុជទឹក អ្នកនោះលែងជំពាក់បាបដូចមនុស្សស្លាប់ គេថ្វាយខ្លួនទៅព្រះជាម្ចាស់រួចហើយ។ ប៉ុន្តែដោយប្រកាសពាក្យសច្ចាប្រណិធានក្នុងព្រះសហគមន៍ឲ្យកាន់តាមដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ គេចង់រួចផុតពីអ្វីៗដែលសង្កត់ខ្លួន និងរារាំងខ្លួនតាមផ្លូវទៅរកសេចក្ដីស្រឡាញ់ដ៏ខ្លាំងក្លា ក្នុងការគោរពបម្រើព្រះជាម្ចាស់យ៉ាងពេញលក្ខណៈ។ គេញែកខ្លួនថ្វាយព្រះជាម្ចាស់ ដើម្បីបម្រើព្រះអង្គយ៉ាងស្និទ្ធស្នាល។ គេសង្ឃឹមថា គេនឹងទទួលផលយ៉ាងបរិបូរណ៍ ដែលហូរមកពីអគ្គសញ្ញាជ្រមុជទឹក តាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ គេញែកខ្លួនថ្វាយព្រះអង្គឲ្យកាន់តែប្រសើរឡើងៗ ដោយជាប់ចំណងជាមួយព្រះគ្រីស្ដកាន់តែរឹងប៉ឹងនិងស្ថិតស្ថេរ និងកាន់តែដូចព្រះគ្រីស្ដ ដែលភ្ជាប់នឹងព្រះសហគមន៍ជាព្រះមហេសី ដោយចំណងដែលមិនអាចផ្ដាច់បានឡើយ។

ដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ណែនាំឲ្យគ្រីស្តបរិស័ទមានចិត្តស្រឡាញ់ និងនាំឲ្យអស់អ្នកដែលកាន់តាមបានរួបរួមយ៉ាងពិសេសជាមួយព្រះសហគមន៍ និងជាមួយគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍។ ហេតុនេះហើយការរស់នៅតាមព្រះវិញ្ញាណរបស់គេ ត្រូវតម្រង់ទៅរកប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។ ដូច្នេះ ម្នាក់ៗមានភារកិច្ចខិតខំចាក់គ្រឹះ និងពង្រឹងព្រះរាជ្យរបស់ព្រះគ្រីស្ដក្នុងចិត្តមនុស្ស ដោយអស់ពីកម្លាំង តាមសមត្ថភាពរៀងៗខ្លួន និងស្របតាមព្រះជាម្ចាស់ត្រាស់ហៅ ដោយអធិដ្ឋាន និងបំពេញសកម្មភាពផ្សេងៗ។ គេក៏មានភារកិច្ចលាតសន្ធឹងព្រះរាជ្យនោះក្នុងពិភពលោកទាំងមូលដែរ។ ហេតុនេះហើយបានជាព្រះសហគមន៍ការពារ និងគាំទ្រលក្ខណៈពិសេសនៃគ្រឹះស្ថានបព្វជិតបព្វជិតានានា។

ដោយហេតុនេះហើយ អ្នកធ្វើពិធីប្រកាសពាក្យសច្ចាប្រណិធានកាន់តាមដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ ដូចជាសញ្ញាសម្គាល់មួយដែលអាច (និងដែលត្រូវ) មានឥទ្ធិពលយ៉ាងស័ក្ដិសិទ្ធិ ទាក់ទាញចិត្តសមាជិកទាំងអស់នៃព្រះសហគមន៍ ឲ្យខិតខំបំពេញភារកិច្ចរបស់ខ្លួនដោយចិត្តក្លាហាន តាមឋានៈជាអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅ ឲ្យទៅជាគ្រីស្តបរិស័ទ។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់គ្មានមាតុភូមិនៅស្ថិតស្ថេរក្នុងលោកនេះទេ តែស្វែងរកមាតុភូមិនៅលោកខាងមុខវិញ។ យ៉ាងណាមិញ របៀបរស់នៅជាបព្វជិតបព្វជិតា ផ្ដល់ឲ្យគេមានសេរីភាពខ្លាំងជាងគ្រីស្តបរិស័ទឯទៀតៗ ចំពោះការងារក្នុងលោកនេះ។ របៀបរស់នៅជាបព្វជិតបព្វជិតា បង្ហាញបញ្ជាក់យ៉ាងច្បាស់ ឲ្យគ្រីស្តបរិស័ទទាំងអស់ ស្គាល់អំពីសម្បត្តិសួគ៌ ដែលស្ថិតនៅក្នុងលោកនេះហើយ។ អ្នកទាំងនោះក៏ធ្វើជាសាក្សីបញ្ជាក់ថា មានជីវិតថ្មីម៉្យាងស្ថិតនៅអស់កល្បជានិច្ច ដែលព្រះគ្រីស្ដបានបង្កើតដោយព្រះអង្គប្ដូរព្រះជន្ម។ គេក៏ជូនដំណឹងអំពីជីវិតថ្មី ដែលមនុស្សនឹងទទួលនៅលោកខាងមុខ និងអំពីសិរីរុងរឿងនៃព្រះរាជ្យរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត។ លើសពីនេះទៅទៀត របៀបរស់នៅជាបព្វជិតបព្វជិតា យកតម្រាប់យ៉ាងជិតដិតតាមរបៀបដែលព្រះបុត្រារបស់ព្រះជាម្ចាស់បានរស់នៅ ហើយក៏ជាសញ្ញាសម្គាល់ដែលមានឥតឈប់ឈរក្នុងព្រះសហ-គមន៍ អំពីរបៀបរស់នៅរបស់ព្រះបុត្រា ដែលយាងមកក្នុងលោកនេះ ដើម្បីធ្វើតាមព្រះហឫទ័យព្រះបិតា។ ព្រះអង្គក៏ទូន្មានឲ្យសាវ័កដែលដើរតាមព្រះអង្គឲ្យរស់នៅតាមរបៀបនេះដែរ។ មិនតែប៉ុណ្ណោះរបៀបរស់នៅជាបព្វជិតបព្វជិតា បង្ហាញយ៉ាងពិសេសថា ព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ពស់លើសអ្វីៗទាំងអស់ដែលនៅក្នុងលោកនេះ និងខ្ពស់លើសសេចក្ដីត្រូវការដ៏ចាំបាច់ជាងគេ របស់មនុស្សលោកថែមទៀតផង។ របៀបរស់នៅបែបនោះបង្ហាញឲ្យមនុស្សទាំងអស់ ឃើញមហិទ្ធិឫទ្ធិដ៏ប្រសើរបំផុតរបស់ព្រះគ្រីស្ដ ជាព្រះមហាក្សត្រ និងឃើញអំពីមហិទ្ធិឫទ្ធិហួសពីការស្មានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលមានសកម្មភាពក្នុងព្រះសហគមន៍យ៉ាងអស្ចារ្យគួរស្ងើចសរសើរ។

ទោះបីរបៀបរស់នៅជាបព្វជិតបព្វជិតា ដែលធ្វើពិធីប្រកាសពាក្យសច្ចាប្រណិធានកាន់តាមដំបូន្មាន ដែលមានចែងក្នុងគម្ពីរដំណឹងល្អ មិនស្ថិតនៅក្នុងរចនាសម្ពន្ធតាមលំដាប់លំដោយរបស់ព្រះសហគមន៍ក្តី ក៏របៀបរស់នៅបែបនេះជាប់នឹងជីវិត ហើយនឹងលក្ខណៈដ៏វិសុទ្ធរបស់ព្រះសហគមន៍ជាច់មិនបានដែរ។

## ៤៥- អំណាចរបស់ព្រះសហគមន៍លើបព្វជិតបព្វជិតា

ក្រុមណែនាំព្រះសហគមន៍តាមលំដាប់លំដោយ មានតួនាទីជាគង្វាលរបស់ប្រជារាស្ត្រព្រះជាម្ចាស់ ដែលដឹកនាំចៀមទៅកាន់កន្លែងសម្បូណ៌ស្មៅខៀវខ្ចី (អគ ៣៤, ១៤)។ ក្រុមណែនាំនោះ មានតួនាទីតែងតាំងច្បាប់ ចាត់ចែងដោយប្រាជ្ញា នូវរបៀបអនុវត្តតាមដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អ។ ដំបូន្មានទាំងនោះ ជាមធ្យោបាយពិសេស ដើម្បីជួយបម្រើសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ចំពោះព្រះជាម្ចាស់និងចំពោះអ្នកដទៃ។ ក្រុមណែនាំ សុខចិត្តធ្វើតាមការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទទួលក្បួនវិន័យដែលគ្រីស្តបរិស័ទបុរស និងស្ត្រីដ៏ប្រសើរបានតែងតាំងរួចហើយ។ ក្រោយពីបានកែឆ្នៃឲ្យកាន់តែល្អឡើង ក្រុមណែនាំយល់ស្របឲ្យអនុវត្តត្រឹមត្រូវតាមច្បាប់។ តាមអំណាចរបស់អស់លោក ក្រុមណែនាំប្រុងប្រយ័ត្នថែទាំ និងការពារគ្រឹះស្ថានដែលកើតនៅច្រើនកន្លែង ដើម្បីសាងសង់ព្រះកាយព្រះគ្រីស្ត។ អស់លោកមានបំណងចង់ឲ្យគ្រឹះស្ថានទាំងនោះ កើតកាន់តែច្រើនឡើងៗ និងចម្រើនឡើងទៀតផង ទាំងកាន់តាមគោលគំនិតអ្នកបង្កើតគ្រឹះស្ថានទាំងនោះដោយចិត្តស្មោះ។

ម៉្យាងទៀត អភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងឋានៈលោកជាប្រធានព្រះសហគមន៍ទាំងមូល និងដោយគិតគូរដល់ប្រយោជន៍របស់ព្រះសហគមន៍ទាំងមូល អាចដកយកគ្រឹះស្ថានបព្វជិតបព្វជិតាដែលស្វែងរកសេចក្តីពេញលក្ខណៈ និងសមាជិកទាំងអស់នៃគ្រឹះស្ថាននោះ ឲ្យរួចចេញផុតពីអំណាចអភិបាលភូមិភាគ មកដាក់ក្រោមអំណាចរបស់លោកផ្ទាល់តែម្តង។ លោកធ្វើដូច្នេះ ដើម្បីឲ្យគ្រឹះស្ថានទាំងនោះមានសមត្ថភាពច្រើនជាង អាចតបឆ្លើយនឹងសេចក្តីត្រូវការនៃហ្វូងចៀមទាំងមូលរបស់ព្រះអម្ចាស់។ យ៉ាងណាមិញ លោកអាចទុក ឬផ្ញើទុកគ្រឹះស្ថានទាំងនោះ ឲ្យស្ថិតនៅក្រោមអំណាចរបស់អភិបាលដ៏ប្រសើរឧត្តមនៅមជ្ឈិមបូព៌ាប្រទេសគ្រប់គ្រងបាន។

សមាជិកនៃគ្រឹះស្ថានទាំងនោះ ពេលគេបំពេញភារកិច្ចរបស់ខ្លួនចំពោះព្រះសហគមន៍ តាមរបៀបរស់នៅរៀងៗខ្លួន ត្រូវគោរព និងស្តាប់បង្គាប់អភិបាល តាមក្បួនច្បាប់ព្រះសហគមន៍ ក្នុងឋានៈអស់លោកអភិបាលមានអំណាចជាគង្វាលណែនាំព្រះសហគមន៍ក្នុងភូមិភាគ និងដោយនឹកគិតដល់ការរួបរួមគ្នាជាធ្លុងតែមួយ ហើយនឹកដល់ការចុះសម្រុងគ្នាក្នុងកិច្ចការជាគ្រីស្តទូត។

ព្រះសហគមន៍មិនគ្រាន់តែទទួលស្គាល់ក្រុមបព្វជិតបព្វជិតា ជាផ្លូវការប៉ុណ្ណោះទេ គឺជាកិច្ចផ្តល់ឲ្យគេមានកិត្តិយសដ៏ថ្លៃថ្នូរ ដោយគេមានរបៀបរស់នៅតាមក្បួនវិន័យមួយ។ លើសពីនេះទៅទៀត ក្នុងពិធីបុណ្យទាំងអស់ ព្រះសហគមន៍តែងតែបង្ហាញបញ្ជាក់ថា ការរស់នៅជាបព្វជិតបព្វជិតា ពិតជារបៀបរស់នៅមួយរបស់គ្រីស្តបរិស័ទ ដែលញែកខ្លួនថ្វាយទាំងស្រុង ទៅព្រះជាម្ចាស់ថែមទៀតផង។ តាមអំណាចដែលព្រះជាម្ចាស់បានផ្ញើទុកមក ព្រះសហគមន៍ផ្ទាល់ក៏ទទួលពាក្យសច្ចាប្រណិធានរបស់អស់អ្នកដែលថ្វាយខ្លួន។ ពេលព្រះសហគមន៍អង្វរព្រះជាម្ចាស់ជាសាធារណៈ ព្រះសហគមន៍ក៏អង្វរព្រះអង្គ សូមជួយប្រណីសន្តោសអ្នកទាំងនោះ ព្រះសហគមន៍ក៏ផ្ញើអ្នកទាំងនោះទៅព្រះអង្គ សូមព្រះអង្គប្រទានពរតាមព្រះវិញ្ញាណ ដោយលើកការថ្វាយខ្លួននេះ ទុកជាតង្វាយរួមជាមួយព្រះគ្រីស្ត ក្នុងសក្ការៈបូជាអរព្រះគុណ។

## ៤៦- តម្លៃដ៏ឧត្ដុង្គឧត្ដមនៃការញែកខ្លួនថ្វាយព្រះអម្ចាស់

បព្វជិតបព្វជិតាត្រូវខិតខំអស់ពីសមត្ថភាព ធ្វើឲ្យព្រះសហគមន៍បង្ហាញព្រះគ្រីស្ដដល់គ្រីស្ដបរិស័ទ និងដល់អ្នកកាន់សាសនាដទៃ ស្គាល់ព្រះអង្គកាន់តែច្បាស់ និងកាន់តែពិតប្រាកដ តាមរបៀបរស់នៅរបស់ខ្លួន។ ពេលព្រះគ្រីស្ដស្ញឹងស្មាធិ៍នៅលើភ្នំ ពេលព្រះអង្គប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ឲ្យបណ្ដាជន ពេលព្រះអង្គប្រោសអ្នកជំងឺ និងជនពិការឲ្យជាសះស្បើយ ពេលព្រះអង្គនាំឲ្យអ្នកបាបប្រែចិត្តគំនិតទៅរកព្រះបិតាឲ្យមានជីវិតដែលបង្កើតផលល្អ ពេលព្រះអង្គប្រទានពរដល់កូនក្មេង និងប្រោសមនុស្សទាំងអស់ នៅពេលព្រះអង្គប្រព្រឹត្តការទាំងនោះ គឺព្រះអង្គធ្វើតាមបង្គាប់ព្រះបិតា ដែលចាត់ព្រះអង្គឲ្យយាងមក។

សូមឲ្យបព្វជិតបព្វជិតាទាំងអស់យល់ឃើញថា ការប្រកាសពាក្យសច្ចាប្រណិធានកាន់តាមដំបូន្មានដែលមានចែងក្នុងគម្ពីរដំណឹងល្អ ទោះបីខ្លួនលះបង់សម្បត្តិទ្រព្យលោកីយ៍ក្ដី ក៏ការលះបង់នេះមិនរារាំងខ្លួនឲ្យចម្រើនឡើងជាមនុស្សពេញលក្ខណៈនោះទេ។ ផ្ទុយទៅវិញ លក្ខណៈនៃការលះបង់នេះ ជួយគេឲ្យទទួលផលប្រយោជន៍ជាច្រើន។ បើបព្វជិត បព្វជិតាស្ម័គ្រចិត្តដោយស្មោះ កាន់តាមដំបូន្មានទាំងនោះ តាមតែព្រះជាម្ចាស់ត្រាស់ហៅម្នាក់ៗ ការរស់នៅបែបនោះ ជួយគេយ៉ាងខ្លាំងឲ្យជម្រះចិត្តគំនិត និងឲ្យមានសេរីភាពខាងវិញ្ញាណផងដែរ។ ការរស់នៅបែបនេះ ក៏ដាស់តឿនគេជានិច្ច ឲ្យមានចិត្តស្រឡាញ់យ៉ាងកក់ក្ដៅ ជាពិសេសគេអាចនាំគ្រីស្ដបរិស័ទឲ្យរស់នៅដូចព្រះគ្រីស្ដជាអម្ចាស់កាន់តែជិតស្និទ្ធ គឺព្រះអង្គដែលសព្វព្រះហឫទ័យរស់នៅជាព្រហ្មចារី និងជាអ្នកក្រីក្រ។ នាងព្រហ្មចារិនីម៉ារីជាព្រះមាតា ក៏សុខចិត្តរស់នៅដូច្នេះដែរ។ សន្ដបុគ្គលជាច្រើន ដែលបានបង្កើតក្រុមគ្រួសារបព្វជិតបព្វជិតា បង្ហាញសេចក្ដីនេះយ៉ាងច្បាស់។

សូមកុំឲ្យមាននរណាម្នាក់នឹកគិតថា បព្វជិតបព្វជិតាដែលញែកខ្លួនថ្វាយព្រះជាម្ចាស់ ត្រឡប់ទៅជាជនលែងជាប់ពាក់ព័ន្ធនឹងមនុស្សលោក និងគ្មានប្រយោជន៍ក្នុងសង្គមឲ្យសោះ។ ទោះបីគេមិនរស់នៅរួមជាមួយមនុស្ស ក្នុងសង្គមដោយរូបកាយជានិច្ចក្ដី គេក៏រស់នៅជាមួយមនុស្សលោកយ៉ាងជិតស្និទ្ធ។ ដោយមានព្រះហឫទ័យមេត្តាករុណារបស់ព្រះគ្រីស្ដក្នុងខ្លួន គេរួមសហការជាមួយមនុស្សតាមវិញ្ញាណ សាងសង់បុរីនៅលើផែនដីនេះ ដោយយកព្រះអម្ចាស់ធ្វើជាគ្រឹះ ហើយក៏តម្រង់បុរីនោះទៅរកព្រះអង្គដែរ។ បព្វជិតបព្វជិតារំឭកមនុស្សលោកថា ប្រសិនបើគេមិនយកព្រះអម្ចាស់ធ្វើជាគ្រឹះ និងទិសដៅមកសាងសង់បុរីនៅលើផែនដីនោះទេ អ្នកសាងសង់នឹងនឿយហត់ដោយឥតបានការ។

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធយកគាំទ្រនិងសរសើរតម្កើងអស់បុរស និងស្ត្រីជាបងប្អូនដែលរស់នៅក្នុងអារាម បង្រៀនក្នុងសាលារៀន ធ្វើការក្នុងមន្ទីរពេទ្យ និងនៅព្រះសហគមន៍ក្នុងប្រទេសដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ដ។ បព្វជិតបព្វជិតាទាំងនោះ យកចិត្តស្មោះត្រង់ ចិត្តសុភាពរាបសា ចិត្តភក្ដី តាមពាក្យសច្ចារបស់ខ្លួន ព្រមទាំងបម្រើមនុស្សទាំងអស់ដោយចិត្តទូលំទូលាយ និងតាមរបៀបប្លែកៗពីគ្នា ប្រៀបដូចជា គ្រឿងអលង្ការ ដែលគេយកមកជូនព្រះមហេសីរបស់ព្រះគ្រីស្ដ។

## ៤៧- ពាក្យបញ្ចប់

ចំពោះអស់អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យប្រកាសពាក្យសច្ចប្រណិធាន កាន់តាមដំបូន្មានដែលមានចែងក្នុងគម្ពីរដំណឹងល្អ គឺម្នាក់ៗត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ព្យាយាមរស់នៅឲ្យកាន់តែប្រសើរឡើងៗ តាមបែបដែលព្រះជាម្ចាស់ត្រាស់ហៅ។ អស់លោកអ្នកពិតជានាំឲ្យព្រះសហគមន៍កាន់តែវិសុទ្ធ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះត្រៃឯក ដែលមិនអាចបំបែកបាន ដែលអាចប្រោសឲ្យមនុស្សបានវិសុទ្ធគ្រប់យ៉ាងក្នុងអង្គព្រះគ្រីស្ដ និងដោយសារព្រះគ្រីស្ដ។

# ជំពូក ៧

## ព្រះសហគមន៍មានលក្ខណៈជាប្រផ្នូលអំពីលោកខាងមុខ ព្រះសហគមន៍ធ្វើដំណើរ និងរួមជាមួយព្រះសហគមន៍នៃស្ថានបរមសុខ

### ៤៨- ព្រះជាម្ចាស់ត្រាស់ហៅយើងទាំងអស់គ្នា

ក្នុងអង្គព្រះគ្រីស្តឲ្យចូលព្រះសហគមន៍ យើងក៏បានវិសុទ្ធក្នុងព្រះសហគមន៍ដែរ ដោយព្រះជាម្ចាស់ប្រណីសន្តោស។ ប៉ុន្តែ ព្រះសហគមន៍នេះនឹងបានពេញលក្ខណៈជាស្ថាពរ នៅក្នុងសិរីរុងរឿងនៃលោកខាងមុខ គឺនៅពេលព្រះជាម្ចាស់រៀបចំអ្វីៗជាថ្មីទាំងអស់ (កក ៣, ២១)។ នៅពេលនោះ ពិភពលោកទាំងមូលនិងមនុស្សជាតិ ដែលភ្ជាប់ជាមួយគ្នាយ៉ាងស្អិតរមួតនឹងទៅដល់ទិសដៅរបស់ខ្លួន។ ដោយសារមនុស្សជាតិ ពិភពលោកទាំងមូលក៏នឹងបានពេញលក្ខណៈជាស្ថាពរក្នុងអង្គព្រះគ្រីស្តដែរ(អភ ១, ១០; កូឡ ១, ២០; ២សល ៣, ១០-១៣)។

ព្រះគ្រីស្តដែលត្រូវគេលើកឡើងពីដី ព្រះអង្គបានទាញមនុស្សទាំងអស់ទៅឯព្រះអង្គហើយ (យហ ១២, ៣២) ព្រះអង្គក្រោកឡើងពីចំណោមមនុស្សស្លាប់ (រម ៦, ៩) ទ្រង់ចាក់បង្ហូរព្រះវិញ្ញាណរបស់ព្រះអង្គលើក្រុមគ្រីស្តទូត គឺព្រះវិញ្ញាណដែលផ្តល់ជីវិត។ ដោយព្រះវិញ្ញាណនោះ ព្រះអង្គតែងតាំងព្រះកាយព្រះអង្គ គឺព្រះសហគមន៍ទុកជាអគ្គសញ្ញានៃការសង្គ្រោះរបស់មនុស្សទាំងអស់។ ព្រះគ្រីស្តគង់ខាងស្តាំព្រះបិតា ហើយមានសកម្មភាពក្នុងពិភពលោកជានិច្ច ដើម្បីណែនាំមនុស្សលោកទៅកាន់ព្រះសហគមន៍។ ដោយសារព្រះសហគមន៍ ព្រះគ្រីស្តបង្រួបបង្រួមមនុស្សលោកជាមួយព្រះអង្គយ៉ាងជិតស្និទ្ធ និងចែករំលែកព្រះជន្មដ៏រុងរឿងផ្ទាល់របស់ព្រះអង្គឲ្យគេដោយប្រទានព្រះកាយនិងព្រះលោហិតទុកជាអាហារ។ ព្រះអង្គសន្យាថា នឹងប្រទានលក្ខណៈសម្បត្តិថ្មីឲ្យមនុស្ស តាមសេចក្តីសង្ឃឹមរបស់យើង។ លក្ខណៈសម្បត្តិថ្មីនោះ ចាប់ផ្តើមស្ថិតនៅក្នុងព្រះគ្រីស្តហើយ។ ព្រះវិញ្ញាណដែលព្រះគ្រីស្តចាត់ឲ្យមកនោះ ធ្វើឲ្យលក្ខណៈសម្បត្តិថ្មីនោះ មានកម្លាំងស្ទុះឡើង ហើយនៅតែមានបន្តក្នុងព្រះសហគមន៍ដែរ ដោយសារព្រះវិញ្ញាណ។ ជំនឿបង្រៀនយើងអំពីអត្ថន័យនៃការរស់នៅលើផែនដីនេះ លុះត្រាតែយើងបំពេញការងារ ដែលព្រះបិតាផ្ញើមកឲ្យយើងប្រព្រឹត្តក្នុងលោកនេះ ទាំងមានសង្ឃឹមថា នឹងបានសម្បត្តិនៃលោកខាងមុខ។ ដោយប្រព្រឹត្តដូច្នេះ យើងអាចឈានទៅកាន់ការសង្គ្រោះបាន (ភល ២, ១២)។

ដូច្នេះ ជំនាន់ចុងក្រោយបំផុតមកដល់យើងហើយ (១ករ ១០, ១១)។ ពិភពលោកប្រែជាថ្មីរួចជាស្រេចដោយសារព្រះគ្រីស្ត។ តាំងពីពេលឥឡូវនេះ ការប្រែជាថ្មីនោះកើតជារូបរាងជាមុនយ៉ាងពិតប្រាកដតាមរបៀបម្យ៉ាងគឺថាទោះបី ព្រះសហគមន៍មិនទាន់វិសុទ្ធពេញលក្ខណៈនៅឡើយក្តី ក៏ព្រះសហគមន៍នៅលើផែនដីនេះ តែងខ្លួនដោយភាពវិសុទ្ធដ៏ពិតប្រាកដដែរ។ ប៉ុន្តែ ព្រះសហគមន៍កំពុងធ្វើបូជនីយេសក៍ ទម្រាំដល់ពេលព្រះជាម្ចាស់នឹងប្រតិស្ឋានមេឃថ្មី និងផែនដីថ្មីប្រកបដោយសេចក្តីសុចរិត (២សល ៣, ១៣)។ ហេតុនេះ ទាំងអគ្គសញ្ញារបស់ព្រះសហគមន៍ក្តី ទាំងរចនាសម្ពន្ធរបស់ខ្លួនក្តី ក៏មានលក្ខណៈមិនទៀងទាត់របស់លោកីយ៍ ដែលចេះតែកន្លងផុតទៅដែរ។ ព្រះសហគមន៍

រស់នៅក្នុងចំណោមសត្វលោកដែលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ ដូចស្ត្រីដែលហៀបនឹងសម្រាលកូន ទាំងទន្ទឹងរង់ចាំសិរីរុងរឿងនៃបុត្រធីតារបស់ព្រះជាម្ចាស់ (រម ៨, ១៩-២២)។

ដូច្នេះ យើងរួមជាមួយព្រះគ្រីស្តក្នុងព្រះសហគមន៍ ព្រះវិញ្ញាណក៏បានដៅចំណាំយើងដែរ គឺព្រះវិញ្ញាណបញ្ចាំចិត្តយើងឲ្យជឿថា យើងមុខជានឹងទទួលមរតក (អភ១, ១៤)។ ព្រះបិតាហៅយើងថាជាបុត្រធីតារបស់ព្រះអង្គ យើងក៏ពិតជាបុត្រធីតារបស់ព្រះអង្គមែន (១យហ ៣, ១)។ ប៉ុន្តែ មិនទាន់ដល់ពេលយើងនឹងលេចមករួមជាមួយព្រះគ្រីស្តប្រកបដោយសិរីរុងរឿងនៅឡើយទេ (កូឡ ៣, ៤) គឺនៅពេលនោះ យើងនឹងបានដូចព្រះជាម្ចាស់ ដ្បិតព្រះអង្គមានភាពយ៉ាងណា យើងក៏នឹងឃើញព្រះអង្គយ៉ាងនោះដែរ (១យហ ៣, ២)។ ហេតុនេះហើយ បានជា «ដរាបណាយើងស្ថិតនៅក្នុងរូបកាយនេះ យើងឃ្លាតឆ្ងាយពីព្រះអម្ចាស់» (២ករ ៥, ៦)។ សូម្បីតែយើង ដែលបានទទួលព្រះអំណោយទានដំបូងរបស់ព្រះវិញ្ញាណក្តី ក៏យើងនៅតែថ្ងូរក្នុងចិត្តដែរ (រម ៨, ២៣) ព្រោះយើងប៉ងប្រាថ្នាចង់ទៅនៅជាមួយព្រះគ្រីស្ត (ភល ១, ២៣)។ ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជំរុញយើង ឲ្យប៉ងប្រាថ្នាចង់រស់នៅសម្រាប់ព្រះអង្គកាន់តែជិតស្និទ្ធឡើងៗ គឺថ្វាយខ្លួនចំពោះព្រះគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងសម្រាប់យើង (២ករ ៥, ១៥)។ ហេតុនេះ យើងខិតខំឲ្យបានគាប់ព្រះហឫទ័យព្រះអង្គ ក្នុងគ្រប់កិច្ចការទាំងអស់ (២ករ ៥, ៩)។ យើងប្រដាប់ខ្លួនដោយគ្រឿងសាស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដើម្បីអាចតតាំងនឹងកលល្បិចរបស់មារ និងអាចតទល់នឹងមារ នៅថ្ងៃអពមង្គលបាន (អភ ៦, ១១-១៣)។ យើងមិនដឹងថ្ងៃ និងពេលកំណត់ទេ ហេតុនេះ យើងត្រូវប្រុងស្មារតីជានិច្ចតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ដើម្បីឲ្យយើងអាចចូលរួមក្នុងពិធីមង្គលការ រួមជាមួយព្រះអង្គ និងត្រូវរាប់បញ្ចូលក្នុងចំណោមអស់អ្នកដែលទទួលព្រះពរ (មថ ២៥, ៣១-៤៦) នៅពេលដំណើរជីវិតតែមួយរបស់យើងនឹងចប់ទៅ (ហប ៩, ២៧)។ ពេលនោះ យើងមិនត្រូវថយចេញ ដូចអ្នកបម្រើខ្ជិលច្រអូស តាមព្រះបញ្ជារបស់ព្រះជាម្ចាស់ (មថ ២៥, ២៦) ហើយត្រូវធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច (មថ ២៥,៤១) គឺត្រូវគេចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះទេ (មថ ២២, ១៣ និង ២៥, ៣០)។

មុនពេលយើងនឹងគ្រងរាជ្យជាមួយព្រះគ្រីស្តប្រកបដោយសិរីរុងរឿង យើងត្រូវទៅ «ឈរនៅមុខទីកាត់ក្តីរបស់ព្រះអង្គ ដើម្បីឲ្យម្នាក់ៗទទួលផល តាមអំពើដែលខ្លួនបានប្រព្រឹត្ត ទោះបីជាអំពើនោះល្អ ឬអាក្រក់ក្តី កាលពីនៅរស់ក្នុងរូបកាយនេះនៅឡើយ» (២ករ ៥, ១០)។ នៅអវសាននៃពិភពលោក «មនុស្សនឹងចេញពីផ្នូរមក។ អ្នកដែលបានប្រព្រឹត្តអំពើល្អ នឹងរស់ជាថ្មីដើម្បីទទួលជីវិត រីឯអ្នកដែលបានប្រព្រឹត្តអំពើអាក្រក់វិញ នឹងរស់ជាថ្មីដើម្បីទទួលទោស» (យហ ៥, ២៩; មថ ២៥, ៤៦)។ ហេតុនេះហើយ បានជាយើងយល់ឃើញថា «ទុក្ខលំបាកនាបច្ចុប្បន្នកាល ពុំអាចប្រៀបផ្ទឹមនឹងសិរីរុងរឿង ដែលព្រះជាម្ចាស់ សម្តែងក្នុងយើងនៅអនាគតកាលនោះបានឡើយ» (រម ៨, ១៨; ២ធម ២, ១១-១២)។ យើងមានជំនឿរឹងប៉ឹងមាំមួន ហើយ «ទន្ទឹងរង់ចាំសុភមង្គលតាមសេចក្តីសង្ឃឹមរបស់យើង។ យើងក៏រង់ចាំព្រះយេស៊ូគ្រីស្ត ជាព្រះជាម្ចាស់ដ៏ឧត្តមបំផុតនិងជាព្រះសង្គ្រោះនៃយើង យាងមកប្រកបដោយសិរីរុងរឿង» (ទត ២,១៣)។ «ព្រះអង្គនឹងផ្លាស់ប្រែរូបកាយដ៏ថោកទាបរបស់យើង ឲ្យបានដូចព្រះកាយប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ» (ភល ៣, ២១) គឺព្រះអង្គនឹងយាងមក ហើយ «ទទួលសិរីរុងរឿងព្រោះតែជនដ៏វិសុទ្ធរបស់ព្រះអង្គ។ គេក៏នឹងស្ងើចសរសើរព្រះអង្គ ព្រោះតែអស់អ្នកដែលបានផ្ញើជីវិតលើព្រះអង្គដែរ» (២ថស ១, ១០)។

## ៤៩- ព្រះសហគមន៍នៅលោកខាងមុខរួបរួមជាមួយព្រះសហគមន៍នៅលើផែនដី

ដូច្នេះ ទម្រាំព្រះអម្ចាស់យាងមកប្រកបដោយសិរីរុងរឿង រួមជាមួយពួកទេវទូតរបស់ព្រះអង្គ (មថ ២៥, ៣១)

និងទម្រាំសេចក្ដីស្លាប់ត្រូវរំលាយចោល ព្រមទាំងព្រះអង្គបង្ក្រាបអ្វីៗទាំងអស់ (១ករ ១៥, ២៦-២៧) សាវ័ករបស់ព្រះគ្រីស្ដមួយចំនួន នៅតែបន្ដបូជនីយេសក៍នៅលើផែនដីនេះតទៅទៀត។ មានសាវ័កមួយចំនួនដែលផុតជីវិត នៅតែជម្រះខ្លួនមុននឹងជួបព្រះជាម្ចាស់។ មួយចំនួនទៀត ស្ថិតនៅក្នុងសិរីរុងរឿងរបស់ព្រះជាម្ចាស់ «នៅក្នុងពន្លឺដ៏ត្រចះត្រចង់យ៉ាងពេញលេញ ឃើញព្រះជាម្ចាស់តែមួយព្រះអង្គជាព្រះត្រៃឯក»។ ប៉ុន្ដែ ទោះជាយ៉ាងណាក៏ដោយ ក៏យើងទាំងអស់រួបរួមគ្នាក្នុងសេចក្ដីស្រឡាញ់តែមួយចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ តាមកម្រិត និងតាមរបៀបផ្សេងៗ នាំគ្នាច្រៀង លើកតម្កើងសិរីរុងរឿងថ្វាយព្រះជាម្ចាស់។ អស់អ្នកដែលរួបរួមជាមួយព្រះគ្រីស្ដ និងដែលបានទទួលព្រះវិញ្ញាណរបស់ព្រះអង្គ ហើយក៏រួមគ្នាជាព្រះសហគមន៍តែមួយ និងភ្ជាប់គ្នាទៅវិញទៅមកជាអង្គភាពតែមួយ ក្នុងអង្គព្រះគ្រីស្ដដែរ (អភ ៤, ១៦)។ ដូច្នេះ អស់អ្នកដែលកំពុងធ្វើដំណើរក្នុងលោកនេះនៅឡើយ និងបងប្អូនដែលចែកឋាន សម្រាន្ដលក់ក្នុងសេចក្ដីសុខសាន្ដរបស់ព្រះគ្រីស្ដទៅហើយ ក៏រួមគ្នាមិនដាច់ពីគ្នាទេ។ ផ្ទុយទៅវិញ តាមជំនឿរបស់ព្រះសហគមន៍តាំងពីដើមរៀងមក ក្រុមទាំងពីររឹតតែរួមគ្នា ដោយចែករំលែកសម្បត្តិខាងព្រះវិញ្ញាណទៅវិញទៅមក។ អ្នកដែលនៅលោកខាងមុខ ភ្ជាប់ជាមួយព្រះគ្រីស្ដយ៉ាងជិតស្និទ្ធច្រើនជាង និងជួយព្រះសហគមន៍ទាំងមូលឲ្យកាន់តែវិសុទ្ធ ព្រមទាំងរួមជាមួយព្រះសហគមន៍ ដែលធ្វើពិធីគោរពបម្រើព្រះជាម្ចាស់នៅលើផែនដី ឲ្យកាន់តែឧត្ដុង្គឧត្ដមឡើង ហើយក៏ជួយព្រះសហគមន៍តាមរបៀបជាច្រើនឲ្យកសាងខ្លួនកាន់តែធំឡើងៗដែរ (១ករ ១២, ១២-២៧)។ ព្រះអម្ចាស់ បានទទួលបងប្អូនទាំងនោះ ក្នុងមាតុភូមិនៅក្បែរព្រះអង្គ (២ករ ៥, ៨)។ ដោយសារព្រះគ្រីស្ដ រួមជាមួយព្រះគ្រីស្ដ និងក្នុងអង្គព្រះគ្រីស្ដ បងប្អូនទាំងនោះនៅតែជួយអង្វរព្រះបិតាឲ្យយើង ហើយថ្វាយអំពើល្អដែលគេបានធ្វើនៅលើផែនដី តាមរយៈព្រះគ្រីស្ដយេស៊ូជាស្ពានមេត្រីតែមួយគត់ រវាងព្រះជាម្ចាស់និងមនុស្សលោក (១ធម ២, ៥)។ បងប្អូនទាំងនោះ បានបម្រើព្រះអម្ចាស់ក្នុងគ្រប់កិច្ចការទាំងអស់ និងបានជួយបំពេញទុក្ខលំបាករបស់ព្រះគ្រីស្ដ សម្រាប់ព្រះកាយរបស់ព្រះអង្គជាព្រះសហគមន៍ (កូឡ ១, ២៤)។ ដោយបងប្អូនទាំងនោះយកចិត្តទុកដាក់ស្រឡាញ់យើងដូចបងប្អូន ពួកគាត់ជួយយើងជាមនុស្សទន់ខ្សោយយ៉ាងខ្លាំង។

## ៥០- ព្រះសហគមន៍នៅលោកខាងមុខមានទំនាក់ទំនងជាមួយព្រះសហគមន៍នៅលើផែនដី

ព្រះសហគមន៍ទទួលស្គាល់ថា សមាជិកនៃព្រះកាយដ៏អាថ៌កំបាំងទាំងមូល របស់ព្រះយេស៊ូគ្រីស្ដរួបរួមគ្នារួចហើយ។ តាំងពីដើមដំបូងនៃគ្រីស្ដសាសនា សមាជិកនៃព្រះសហគមន៍ដែលកំពុងធ្វើដំណើរនៅនាលោកនេះ តែងតែនឹករឭកដល់អស់អ្នកដែលចែកឋានទៅហើយ ដោយគោរពប្រណិប័តន៍យ៉ាងខ្លាំង។ គេធ្លាប់អង្វរព្រះជាម្ចាស់ឲ្យអស់អ្នកដែលចែកឋាន ដ្បិត «គំនិតអង្វរព្រះជាម្ចាស់សូមព្រះអង្គលើកលែងទោសឲ្យមនុស្សស្លាប់បានរួចពីបាប ពិតជាគំនិតដ៏វិសុទ្ធរបស់អស់អ្នកគោរពប្រណិប័តន៍ព្រះអង្គមែន» (២មរ ១២, ៤៥)។ ចំពោះគ្រីស្ដទូត និងមរណសាក្សីរបស់ព្រះគ្រីស្ដ ដែលបានផ្ដល់សក្ខីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីជំនឿ និងអំពីសេចក្ដីស្រឡាញ់ រហូតដល់បូជាជីវិតថ្វាយព្រះអង្គនោះ ព្រះសហគមន៍តែងតែជឿជានិច្ចថា ពួកគាត់នៅជាប់កាន់តែជិតស្និទ្ធជាមួយយើងក្នុងអង្គព្រះគ្រីស្ដ។ ព្រះសហគមន៍ក៏ធ្លាប់គោរពគ្រីស្ដទូតនិងមរណសាក្សី ដោយសេចក្ដីស្រឡាញ់ ជាពិសេសរួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី និងសន្ដទេវទូត ហើយសូមពួកគាត់ជួយអង្វរព្រះជាម្ចាស់ផងដែរ។ ក្រោយមក ព្រះសហគមន៍ក៏បន្ថែមអ្នកខ្លះទៀត ដែលសុខចិត្តយកតម្រាប់តាមព្រះគ្រីស្ដយ៉ាងជិតស្និទ្ធ ដោយរស់នៅក្នុងឋានៈជាព្រហ្មចារី និងជាអ្នកក្រីក្រ។ មានអ្នកខ្លះទៀតកាន់តាមព្រហ្មវិហារធម៌នៃគ្រីស្ដសាសនាយ៉ាងអស្ចារ្យ និងបានទទួលព្រះអំណោយទានដ៏ប្រសើររបស់ព្រះជាម្ចាស់ នាំឲ្យព្រះសហគមន៍ទូន្មានឲ្យគ្រីស្ដបរិស័ទគោរពប្រណិប័តន៍ និងយកតម្រាប់តាម។

ប្រសិនបើយើងសញ្ជឹងគិតដល់ការរស់នៅរបស់សន្តបុគ្គលទាំងប៉ុន្មាន ដែលបានយកតម្រាប់តាមព្រះគ្រីស្ត ដោយចិត្តស្មោះនោះ ពិតជាពួកគាត់ដាស់តឿនយើងឲ្យស្វែងរកបុរីនៃលោកខាងមុខ (ហប ១៣, ១៤ និង ១១, ១០)។ នៅពេលជាមួយគ្នានេះ យើងបង្រៀនខ្លួនឯងឲ្យស្គាល់ផ្លូវដ៏ត្រឹមត្រូវ នៅពេលយើងកំពុងឆ្លងកាត់លោកដ៏មិនទៀងទាត់នេះ តាមរបៀបរស់នៅ និងតាមសភាពការណ៍រៀងៗខ្លួន ដើម្បីឲ្យយើងអាចឈានទៅរួបរួមយ៉ាងពេញលក្ខណៈជាមួយព្រះគ្រីស្ត ពោលគឺឲ្យបានវិសុទ្ធ។ ព្រះជាម្ចាស់សម្ដែងវត្តមាន និងព្រះភ័ក្ត្ររបស់ព្រះអង្គយ៉ាងជាក់ច្បាស់ ឲ្យមនុស្សលោកតាមរយៈការរស់នៅរបស់សន្តបុគ្គលជាមនុស្សដូចយើង ដែលផ្លាស់ប្រែឲ្យបានដូចព្រះគ្រីស្តយ៉ាងពេញលក្ខណៈ (២ករ ៣, ១៨)។ ព្រះជាម្ចាស់មានព្រះបន្ទូលមកយើងតាមរយៈសន្តបុគ្គល គឺព្រះអង្គប្រទានសញ្ញាសម្គាល់អំពីព្រះរាជ្យរបស់ព្រះអង្គ ហើយក៏ទាក់ទាញចិត្តយើងយ៉ាងខ្លាំងដែរ ដោយមានមនុស្សជាច្រើនឥតគណនា ធ្វើជាសាក្សីនៅជុំវិញយើង (ហប ១២, ១) និងដោយពួកគាត់បានបញ្ជាក់អំពីសេចក្ដីពិតនៃដំណឹងល្អផង។

ក៏ប៉ុន្តែ យើងនឹករឭកដល់សន្តបុគ្គលដោយគោរព មិនគ្រាន់តែព្រោះពួកគាត់ដាក់គំរូល្អឲ្យយើងធ្វើតាមប៉ុណ្ណោះទេ តែយើងក៏ចង់ពង្រឹងការរួបរួមរបស់ព្រះសហគមន៍ទាំងមូលក្នុងព្រះវិញ្ញាណថែមទៀត ដោយប្រតិបត្តិតាមសេចក្ដីស្រឡាញ់គ្នាទុកជាបងប្អូន (អភ ៤, ១-៦)។ បើយើងជាគ្រីស្តបរិស័ទដែលកំពុងធ្វើដំណើរនៅលើផែនដីនេះ រួបរួមគ្នាឈានទៅកាន់ព្រះគ្រីស្តកាន់តែជិតស្និទ្ធឡើងៗយ៉ាងណា ការរួមសហភាពជាមួយសន្តបុគ្គល ក៏បង្រួបបង្រួមយើងជាមួយព្រះគ្រីស្តកាន់តែខ្លាំងឡើងយ៉ាងនោះដែរ ព្រោះព្រះហឫទ័យប្រណីសន្ដោសគ្រប់យ៉ាងរបស់ព្រះជាម្ចាស់ និងជីវិតរបស់ប្រជារាស្ត្រព្រះអង្គ ហូរពីព្រះគ្រីស្តមក ដូចជាហូរពីប្រភពនិងពីព្រះសិរសារបស់ប្រជារាស្ត្រនោះ។ ហេតុនេះ យើងគួរតែស្រឡាញ់មិត្តភ័ក្តិទាំងនោះ ជាអ្នកដែលទទួលមត៌ករួមជាមួយព្រះយេស៊ូគ្រីស្ត ជាបងប្អូនយើង ជាអ្នកដ៏ប្រសើរដែលជួយយើងបាន។ យើងគួរតែអរព្រះគុណព្រះជាម្ចាស់ព្រោះព្រះអង្គប្រណីសន្ដោសបងប្អូនទាំងនោះ។ «យើងគួរតែទទូចអង្វរសន្តបុគ្គលយ៉ាងក្លៀវក្លា សូមឲ្យពួកគាត់ជួយអង្វរព្រះជាម្ចាស់ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់នៃយើង ជាព្រះសង្គ្រោះតែមួយព្រះអង្គដែលរំដោះយើង។ សូមជ្រកកោនក្រោមម្លប់របស់សន្តបុគ្គល សូមពួកគាត់អង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រទានអ្វីៗដែលយើងត្រូវការ។» ប្រសិនបើយើង បង្ហាញសេចក្ដីស្រឡាញ់យ៉ាងពិតប្រាកដ ចំពោះសន្តបុគ្គល យើងក៏នឹងបង្ហាញសេចក្ដីស្រឡាញ់ចំពោះព្រះគ្រីស្ត ជាទិសដៅនៃសេចក្ដីស្រឡាញ់នោះដែរ ព្រោះព្រះអង្គជា «ភួងជ័យនៃសន្តបុគ្គលទាំងឡាយ»។ ដោយសារព្រះគ្រីស្ត យើងក៏សម្ដែងសេចក្ដីស្រឡាញ់ ចំពោះព្រះជាម្ចាស់ ដែលគួរឲ្យស្ងើចសរសើរក្នុងសន្តបុគ្គលទាំងឡាយ និងដែលសម្ដែងសិរីរុងរឿងក្នុងសន្តបុគ្គលទាំងនោះ។

ពិធីគោរពប្រណិប័តន៍នានាដ៏សក្ការៈ ធ្វើឲ្យយើងរួបរួមយ៉ាងខ្ពង់ខ្ពស់បំផុត ជាមួយព្រះសហគមន៍នៅលោកខាងមុខ គឺក្នុងពិធីគោរពប្រណិប័តន៍ទាំងនោះ អានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធប្រោសយើង ដោយអគ្គសញ្ញានានា។ ក្នុងពិធីនានា យើងរួមសប្បាយរីករាយលើកតម្កើងសិរីរុងរឿងរបស់ព្រះដ៏ឧត្តុង្គឧត្តមបំផុត។ យើងទាំងអស់គ្នាមកពីគ្រប់ពូជអម្បូរ គ្រប់ភាសា គ្រប់ប្រជាជន និងគ្រប់ជាតិសាសន៍ (វវ ៥, ៩) ដែលព្រះគ្រីស្តបានរំដោះដោយបូជាព្រះជន្ម ជួបជុំគ្នាក្នុងព្រះសហគមន៍តែមួយគត់ សូមច្រៀងលើកតម្កើងព្រះជាម្ចាស់តែមួយព្រះអង្គ ជាព្រះត្រៃឯក ដោយសូរស័ព្ទតែមួយដែរ។ ពេលយើងថ្វាយសក្ការបូជាអរព្រះគុណ យើងរួមយ៉ាងប្រសើរជាងគេបំផុត ជាមួយព្រះសហគមន៍នៃស្ថានបរមសុខដែលគោរពបម្រើព្រះជាម្ចាស់។ នៅពេលនោះយើងក៏រួបរួមជាមួយគ្នា ជាបឋមគោរពព្រះនាងម៉ារីប្រកបដោយសិរីរុងរឿងជាព្រហ្មចារិនីជាដរាប គោរពសន្តៈយ៉ូសែប គោរពសន្តគ្រីស្តទូត និងមរណសាក្សី ព្រមទាំងសន្តបុគ្គលទាំងឡាយដែរ។

## ៥១- ពាក្យណែនាំ

មហាសន្និបាតដ៏វិសុទ្ធសូមគោរពប្រណិប័តន៍យ៉ាងខ្លាំងនូវជំនឿរបស់គ្រូបាធ្យាយ គឺជឿថា យើងរួបរួមជាមួយបងប្អូន ដោយមានជីវិតតែមួយ រួមជាមួយបងប្អូនដែលទទួលសិរីរុងរឿងនៃស្ថានបរមសុខរួចហើយ និងរួមជាមួយបងប្អូនដែលចែកស្ថានទៅហើយនោះហើយកំពុងជម្រះខ្លួន។ មហាសន្និបាតសូមប្រកាសសាជាថ្មីទាំងគោរពប្រណិប័តន៍នូវក្រឹត្យនៃមហាសន្និបាតដ៏វិសុទ្ធពីជំនាន់មុនៗ គឺមហាសន្និបាតទីពីរនៅក្រុងនីសេ មហាសន្និបាតក្រុងហ្លូរង្ស និងមហាសន្និបាតក្រុងត្រែនតូ។ នៅពេលជាមួយគ្នានេះ ប្រសិនបើមានគេប្រព្រឹត្តបំពាន ឬប្រព្រឹត្តហួស ឬប្រសិនមានការខ្វះត្រង់កន្លែងណាមួយ មហាសន្និបាតសូមដាស់តឿនអស់អ្នកទទួលខុសត្រូវក្នុងព្រះសហគមន៍ ឲ្យឧស្សាហ៍កែសម្រួល ទាំងដក ឬកែសម្រួលសេចក្តីអាក្រក់ផង។ សូមតែងតាំងអ្វីៗជាថ្មី ដើម្បីលើកតម្កើងព្រះគ្រីស្តនិងព្រះជាម្ចាស់ឲ្យកាន់តែល្អប្រសើរឡើង។ សូមបង្រៀនគ្រីស្តបរិស័ទឲ្យដឹងថា អ្នកដែលចង់គោរពសន្តបុគ្គលយ៉ាងពិតប្រាកដ មិនបាច់ធ្វើពិធី ឬកិច្ចការជាច្រើនខាងក្រៅខ្លួនទេ តែត្រូវប្រតិបត្តិតាមសេចក្តីស្រឡាញ់យ៉ាងខ្លាំង និងសកម្មទៀតផង។ ត្រូវព្យាយាមស្គាល់ការរស់នៅរបស់សន្តបុគ្គល ដើម្បីជាប្រយោជន៍យ៉ាងខ្លាំងបំផុតសម្រាប់យើងនិងសម្រាប់ព្រះសហគមន៍ «ត្រូវយកតម្រាប់តាម និងរួមជាមួយពួកគាត់ ដើម្បីរួមចំណែកក្នុងសុភមង្គលនៅស្ថានបរមសុខ ព្រមទាំងសូមជួយអង្វរព្រះជាម្ចាស់ឲ្យយើងផង»។ ម្យ៉ាងទៀត សូមបង្រៀនគ្រីស្តបរិស័ទឲ្យដឹងច្បាស់ថា ប្រសិនបើគេយល់អំពីទំនាក់ទំនងជាមួយសន្តបុគ្គលតាមពន្លឺដ៏ត្រចះត្រចង់នៃជំនឿដ៏ពិតប្រាកដ ទំនាក់ទំនងនេះមិននាំឲ្យការគោរពនមស្ការថ្វាយបង្គំព្រះជាម្ចាស់ជាព្រះបិតាដោយសារព្រះគ្រីស្ត ក្នុងព្រះវិញ្ញាណអន់ថយនោះទេ ផ្ទុយទៅវិញធ្វើឲ្យការគោរពថ្វាយបង្គំនេះកាន់តែទូលំទូលាយឡើងទៀតផង។

យើងនិងសន្តបុគ្គលទាំងអស់ សុទ្ធតែជាបុត្រធីតារបស់ព្រះជាម្ចាស់ រួមជាក្រុមគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត (ហប ៣, ៦)។ ពេលណាយើង និងសន្តបុគ្គលស្រឡាញ់គ្នាទៅវិញទៅមក ហើយរួបរួមគ្នាលើកតម្កើងព្រះត្រៃឯកដ៏វិសុទ្ធបំផុត ពេលនោះយើងមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ស្របតាមលក្ខណៈពិសេសបំផុតនៃព្រះសហគមន៍។ យើងជាគ្រីស្តបរិស័ទក្នុងលោកនេះ ក្រេបជញ្ជក់នឹងពិធីគោរពសិរីរុងរឿងដ៏ពេញលក្ខណៈនៃស្ថានបរមសុខទុកជាមុន។ នៅពេលដែលព្រះគ្រីស្តសម្តែងព្រះអង្គមក គឺនៅពេលមនុស្សស្លាប់ទទួលជីវិតថ្មីដ៏រុងរឿង ពន្លឺរបស់ព្រះជាម្ចាស់នឹងបំភ្លឺបុរីនៃលោកខាងមុខ ហើយកូនចៀមនឹងទៅជាចង្កៀងនៃបុរីនោះ (វវ ២៤, ២១)។ នៅពេលនោះ ព្រះសហគមន៍នៃជនដ៏វិសុទ្ធទាំងអស់ប្រកបដោយអំណរសប្បាយដ៏លើសលប់ ជាអំណរមកពីសេចក្តីស្រឡាញ់ ក្រាបថ្វាយបង្គំព្រះជាម្ចាស់ និង "កូនចៀមដែលត្រូវគេសម្លាប់ធ្វើយញ្ញ *"ទាំងប្រកាសដោយសូរស័ព្ទតែមួយថា "សូមព្រះអង្គដែលគង់លើបល្ល័ង្ក និងកូនចៀម ទទួលពាក្យសរសើរតម្កើង ព្រះកិត្តិនាម សិរីរុងរឿង និងព្រះចេស្តា អស់កល្បជាអង្វែងតរៀងទៅ"*។ (វវ ៥, ១៣-១៤)។

# ជំពូក ៨

## ព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមាតារបស់ព្រះអម្ចាស់ តាមគម្រោងការដ៏អស្ចារ្យ អំពីព្រះគ្រីស្តនិងព្រះសហគមន៍

### ក- អារម្ភកថា

### ៥២- ព្រះនាងព្រហ្មចារិ នី តាមគម្រោងការដ៏អស្ចារ្យអំពីព្រះគ្រីស្ត

ព្រះជាម្ចាស់សម្រេចសង្គ្រោះមនុស្សលោក តាមព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ និងតាមព្រះប្រាជ្ញាញាណរបស់ព្រះអង្គ។ «លុះដល់ពេលកំណត់ហើយ ព្រះអង្គក៏ចាត់ព្រះបុត្រាឲ្យមកប្រសូតពីស្ត្រីម្នាក់ដើម្បីឲ្យយើងទទួលឋានៈជាបុត្រធីតារបស់ព្រះអង្គ» (កាឡ ៤, ៤-៥)។ ដូច្នេះ «ព្រះបុត្រាព្រះអង្គយាងចុះពីស្ថានបរមសុខ ព្រោះតែយើង និងដើម្បីសង្គ្រោះយើង ព្រះអង្គប្រសូតជាមនុស្សពីនាងព្រហ្មចារិនីម៉ារី ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ»។ ព្រះជាម្ចាស់បានសម្តែងគម្រោងការដ៏អស្ចារ្យ នៃការសង្គ្រោះនេះឲ្យយើងស្គាល់។ គម្រោងការនេះក៏នៅតែមានបន្តក្នុងព្រះសហគមន៍ ដែលព្រះអម្ចាស់បានតែងតាំងទុកជាព្រះកាយរបស់ព្រះអង្គ។ ក្នុងព្រះសហគមន៍នេះ អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ភ្ជាប់ជាមួយព្រះអង្គជាព្រះសិរសា ហើយរួបរួមជាមួយសន្តបុគ្គលទាំងឡាយ។ *"ជាបឋម ត្រូវតែគោរពព្រះនាងម៉ារីប្រកបដោយសិរីរុងរឿង ជាព្រហ្មចារិនីជាដរាបជាព្រះមាតារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់នៃយើង"*។

### ៥៣- ព្រះនាងម៉ារីនិងព្រះសហគមន៍

ពេលទេវទូតនាំដំណឹងមក នាងព្រហ្មចារិនីម៉ារីទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងក្នុងចិត្តផង ទាំងក្នុងរូបកាយផង ហើយនាងបង្ហាញជីវិតដល់មនុស្សលោក។ គេទទួលស្គាល់ និងគោរពនាងទុកជាព្រះមាតាដ៏ពិតប្រាកដ របស់ព្រះអម្ចាស់ ជាព្រះសង្គ្រោះផង។ ព្រះជាម្ចាស់បានរំដោះនាងយ៉ាងអស្ចារ្យបំផុត ដោយឈ្វេងយល់ដល់ កុសលផលបុណ្យរបស់ព្រះបុត្រាព្រះអង្គ។ នាងក៏ភ្ជាប់នឹងព្រះបុត្រាយ៉ាងជិតស្និទ្ធបំផុត មិនអាចផ្តាច់ពីព្រះអង្គបានឡើយ។ នាងទទួលបន្ទុកដ៏ធំមហិមា និងទទួលកិត្តិយសដ៏ថ្លៃថ្នូរ គឺធ្វើជាព្រះមាតានៃព្រះបុត្រារបស់ព្រះជាម្ចាស់។ ហេតុនេះហើយ បានជានាងជាបុត្រីដ៏ជាទីគាប់ព្រះហឫទ័យរបស់ព្រះបិតា ជាព្រះវិហារដ៏សក្ការៈនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ សេចក្តីនេះ ជាព្រះអំណោយទានយ៉ាងពិសេសនៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដែលតម្កល់នាងយ៉ាងខ្ពស់លើសត្វលោកទាំងឡាយ ទាំងនៅលើស្ថានបរមសុខ ទាំងនៅលើផែនដីដែរ។ ក៏ប៉ុន្តែ ក្នុងឋានៈនាងជាពូជពង្សរបស់លោក អាដាំ នាងក៏រួបរួមជាមួយមនុស្សជាតិទាំងមូល ដែលត្រូវការព្រះសង្គ្រោះដែរ។ លើសពីនេះទៅទៀត នាងពិតជា "មាតានៃសរីរាង្គរបស់ព្រះគ្រីស្ត ព្រោះនាងរួមសហការ ដោយចិត្តស្រឡាញ់ បង្កើតព្រះសហគមន៍របស់គ្រីស្តបរិស័ទ ដែលជាសរីរាង្គនៃព្រះអម្ចាស់ ជាមេដឹកនាំនោះ"។ ហេតុនេះហើយ បានជាព្រះសហគមន៍ធ្លាប់សរសើរនាងទុកជាសមាជិក

ដ៏ប្រសើរជាងគេបំផុតតែមួយគត់របស់ព្រះសហគមន៍ ជាគំរូគួរឲ្យព្រះសហគមន៍សរសើរ និងប្រព្រឹត្តតាម គឺឲ្យផ្ញើជីវិតលើព្រះជាម្ចាស់ និងមានចិត្តស្រឡាញ់ដូចនាង។ ព្រះសហគមន៍កាតូលិកដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យដឹង តែងតែគោរពប្រណិប័តន៍នាង ដោយមានចិត្តស្រឡាញ់ ដូចជាកូនៗដែលត្រូវគោរពប្រណិប័តន៍ម្ដាយ ដែលស្រឡាញ់គេយ៉ាងខ្លាំងដែរ។

## ៥៤- គោលបំណងរបស់មហាសន្និបាត

មហាសន្និបាតដ៏វិសុទ្ធបានរៀបរាប់អំពីលទ្ធិនៃជំនឿរបស់ព្រះសហគមន៍ ស្ដីអំពីរបៀបព្រះគ្រីស្ដសង្គ្រោះយើង។ ឥឡូវនេះ មហាសន្និបាតសូមពន្យល់យ៉ាងពិស្ដារ អំពីតួនាទីរបស់ព្រះនាងព្រហ្មចារិនីម៉ារី ក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះបន្ទូលប្រសូតជាមនុស្សផង និងក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះកាយ ដ៏លាក់កំបាំងរបស់ព្រះគ្រីស្ដផង។ មហាសន្និបាតក៏សូមបង្ហាញអំពីរបៀបមនុស្សដែលព្រះគ្រីស្ដបានសង្គ្រោះ ត្រូវគោរពព្រះមាតារបស់ព្រះអម្ចាស់ ជាព្រះមាតារបស់ព្រះគ្រីស្ដ និងជាមាតារបស់មនុស្សលោក គឺជាមាតាអ្នកជឿជាដើម។ ក៏ប៉ុន្តែ មហាសន្និបាតគ្មានបំណងចង់រៀបរាប់លទ្ធិទាំងស្រុងនៃជំនឿអំពីនាងម៉ារី ហើយក៏គ្មានបំណងអារកាត់សេចក្ដីដែលអស់លោកទេវវិទូកំពុងរិះគិត តែមិនទាន់បញ្ជាក់យ៉ាងច្បាស់នៅឡើយទេ។ ហេតុនេះហើយ បានជាគ្រីស្ដបរិស័ទមានសិទ្ធិសេរីភាពបញ្ចេញយោបល់ប្លែកៗពីគ្នាអំពីសេចក្ដីទាំងប៉ុន្មាន ដែលព្រះសហគមន៍មិនទាន់បញ្ជាក់យ៉ាងច្បាស់នៅឡើយអំពីនាងម៉ារី។ ទោះបីនាងជាមនុស្សដូចយើង ហើយនៅក្បែរយើងក្ដី ក៏ព្រះសហគមន៍កាតូលិកដ៏វិសុទ្ធតែងតែគោរពនាងយ៉ាងខ្ពង់ខ្ពស់បន្ទាប់ពីព្រះគ្រីស្ដ។

# ខ- តួនាទីរបស់ព្រះនាងម៉ារីក្នុងការចាត់ចែងការសង្គ្រោះ

## ៥៥- ព្រះមាតារបស់ព្រះគ្រីស្ដតាមគម្ពីរសម្ពន្ធមេត្រីចាស់

គម្ពីរសម្ពន្ធមេត្រីចាស់និងគម្ពីរសម្ពន្ធមេត្រីថ្មី ព្រមទាំងការបញ្ជូនបន្តដ៏គួរឲ្យគោរពរបស់ព្រះសហគមន៍ តាំងពីដើមរៀងមក ពន្យល់កាន់តែច្បាស់ឡើងៗ អំពីតួនាទីដ៏ប្រសើរនៃព្រះមាតារបស់ព្រះសង្គ្រោះ ក្នុងការចាត់ចែងការសង្គ្រោះ ហើយសូមជូនសេចក្ដីនេះឲ្យយើងសញ្ជឹងគិត។ កំណែទាំងប៉ុន្មាននៃគម្ពីរសម្ពន្ធមេត្រីចាស់ ពណ៌នាអំពីប្រវត្តិសាស្ដ្រនៃការសង្គ្រោះ និងអំពីការរៀបចំផ្លូវថ្វាយព្រះគ្រីស្ដយាងមកក្នុងលោកយើងនេះដែរ។ ព្រះសហគមន៍តែងអានឯកសារដើមដំបូងទាំងនោះ និងយល់អត្ថន័យតាមពន្លឺនៃសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងយ៉ាងពេញលេញនៅពេលក្រោយ។ ឯកសារទាំងនោះបង្ហាញកាន់តែច្បាស់ឡើងៗ អំពីស្ដ្រីជាព្រះមាតារបស់ព្រះគ្រីស្ដ។ តាមពន្លឺនេះ យើងត្រូវយល់អត្ថន័យនៃព្រះបន្ទូលសន្យាមកលោកអាដាំ និងនាងអេវ៉ាដែលបានប្រព្រឹត្តអំពើបាបថា នឹងបានជ័យជម្នះលើសត្វពស់ ដូចជាសេចក្ដីព្រាងទុកតាមរបៀបព្យាការី (កណ ៣, ១៥)។ តាមរបៀបដដែលនេះ នាងម៉ារីជាយុវនារីដែលមានផ្ទៃពោះ ហើយនឹងប្រសូតបុត្រមួយដែលគេថ្វាយព្រះនាមថា "ព្រះអេម៉ាន្វូអែល" (អស ៧, ១៤; មីកា ៥, ២-៣; មថ ១, ២២-២៣)។ នាងម៉ារីជាជនប្រសើរជាងគេ ក្នុងចំណោមអ្នកតូចតាច និងអ្នកសុភាពរាបសាររបស់ព្រះអម្ចាស់ ដែលមានចិត្តសង្ឃឹមថា នឹងទទួលការសង្គ្រោះដោយផ្ញើជីវិតលើព្រះអង្គ។ លើសពីនេះទៅទៀត នាងជាបុត្រីក្រុងស៊ីយ៉ូនដ៏ប្រសើរជាងគេ។ ក្រោយពីប្រជារាស្ដ្រទន្ទឹងរង់ចាំយ៉ាងយូរអង្វែង ព្រះបន្ទូលសន្យាបានកើតជារូបរាងនៅពេលកំណត់ គឺព្រះជាម្ចាស់ចាត់ចែងការសង្គ្រោះតាមរបៀបថ្មី នៅពេលព្រះបុត្រារបស់ព្រះជាម្ចាស់យកសភាពជាមនុស្សដោយសារនាង ដើម្បីរំដោះមនុស្សលោកឲ្យបានរួចពីបាប ដោយព្រះអង្គប្រព្រឹត្តកិច្ចការទាំងប៉ុន្មានក្នុងឋានៈជាមនុស្ស។

## ៥៦- នាងម៉ារីទទួលដំណឹងពីទេវទូត

ព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណាយ៉ាងក្រៃលែង ទ្រង់សព្វព្រះហឫទ័យឲ្យមាតា ដែលព្រះអង្គតម្រូវជាមុន សុខចិត្តធ្វើតាមព្រះបន្ទូលព្រះអង្គ មុនព្រះបុត្រាប្រសូតជាមនុស្ស។ ស្ត្រីម្នាក់រួមសហការក្នុងកិច្ចបណ្តាលឲ្យមនុស្សលោកស្លាប់យ៉ាងណា ស្ត្រីម្នាក់ទៀត ក៏រួមសហការធ្វើឲ្យមនុស្សលោកមានជីវិតយ៉ាងនោះដែរ។ សេចក្តីនេះពិតតាមរបៀបដ៏អស្ចារ្យស្តីអំពីព្រះមាតា ដែលប្រទានព្រះយេស៊ូជាជីវិត គឺព្រះអង្គដែលប្រែអ្វីៗទាំងអស់ឲ្យបានជាថ្មី។ ព្រះជាម្ចាស់បានផ្តត់ផ្តង់នាងដោយព្រះអំណោយទាន ត្រូវតាមករណីកិច្ចដ៏ប្រសើរដែលនាងត្រូវបំពេញនោះ។ ហេតុនេះមិនគួរឲ្យឆ្ងល់ ដោយគ្រូបាធ្យាយដ៏វិសុទ្ធនៃព្រះសហគមន៍តែងតែហៅព្រះមាតារបស់ព្រះអម្ចាស់ថា ជាស្ត្រីដ៏វិសុទ្ធបំផុត ជាស្ត្រីនិមល មិនដែលជាប់ជំពាក់បាប ជាស្ត្រីដែលសូនដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងជាស្ត្រីដែលព្រះអង្គប្រតិស្ឋានជាថ្មី។ តាំងពីនាងទើបតែនៅក្នុងផ្ទៃម្តាយ ព្រះជាម្ចាស់បានប្រោសឲ្យនាងបានវិសុទ្ធយ៉ាងភ្លឺស្វាងអស្ចារ្យ តែម្នាក់គត់។ ដូច្នេះពេលទេវទូតជម្រាបសួរនាងព្រហ្មចារីនៅភូមិណាសារ៉ែត លោកមានប្រសាសន៍តាមព្រះបញ្ជារបស់ព្រះជាម្ចាស់ថា «ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាង» (លក ១, ២៨)។ នាងក៏តបឆ្លើយទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!» (លក ១, ៣៨)។ ដូច្នេះ នាងដែលជាពូជពង្សរបស់លោកអាដាំ យល់ស្របនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយត្រឡប់ទៅជាព្រះមាតារបស់ព្រះយេស៊ូ។ នាងក៏សុខចិត្តយ៉ាងស្មោះបំផុតធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលចង់សង្គ្រោះមនុស្សលោក ដោយគ្មានអំពើបាបណាមករារាំងនាងឡើយ។ នាងក៏ប្រគល់ខ្លួន ក្នុងឋានៈជាអ្នកបម្រើរបស់ព្រះអម្ចាស់ សុខចិត្តថ្វាយខ្លួនទាំងស្រុងចំពោះព្រះរាជកិច្ចនៃព្រះបុត្រារបស់នាង ដើម្បីបម្រើគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ រួមជាមួយព្រះបុត្រានិងក្រោមអំណាចរបស់ព្រះបុត្រា ដោយព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការប្រណីសន្តោសផងដែរ។ ហេតុនេះហើយ បានជាអស់គ្រូបាធ្យាយដ៏វិសុទ្ធ យល់ឃើញយ៉ាងត្រឹមត្រូវថា នាងម៉ារីមិនគ្រាន់តែមានរូបកាយ ដែលព្រះជាម្ចាស់ផ្ទុកផ្តាក់ប៉ុណ្ណោះនោះទេ តែនាងម៉ារី រួមសហការក្នុងការនាំការសង្គ្រោះដល់មនុស្សលោក ដោយសារនាងមានសេរីភាព គឺផ្ញើជីវិតលើព្រះជាម្ចាស់ និងសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះអង្គ។ សន្តៈអ៊ីរេណេ មានប្រសាសន៍ថា «ដោយនាងម៉ារីសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះជាម្ចាស់ នាងត្រឡប់ទៅជាអ្នកនាំការសង្គ្រោះមកដល់នាងផ្ទាល់ និងមកដល់មនុស្សលោកទាំងមូលផងដែរ»។ ហេតុនេះហើយបានជាគ្រូបាធ្យាយជាច្រើនពីបុរាណ នៅពេលបកស្រាយគម្ពីរចូលចិត្តនិយាយថា "ដោយនាងម៉ារីសុខចិត្តធ្វើតាមព្រះបញ្ជារបស់ព្រះជាម្ចាស់ នាងស្រាយចំណងដែលនាងអេវ៉ា ចងដោយមិនព្រមធ្វើតាមព្រះបញ្ជារបស់ព្រះអង្គកាលពីមុននោះ"។ អស់លោកក៏តែងប្រៀបប្រដូចនាងម៉ារីនឹងនាងអេវ៉ា ហើយធ្លាប់ហៅនាងម៉ារីថា *"មាតារបស់មនុស្សដែលមានជីវិត"* និងប្រកាសជាញឹកញាប់ថា "ដោយសារនាងអេវ៉ា សេចក្តីស្លាប់ចូលមកក្នុងពិភពលោក ដោយសារនាងម៉ារី ជីវិតចូលមកក្នុងពិភពលោកវិញ"។

## ៥៧- នាងម៉ារីនៅពេលព្រះយេស៊ូមានវ័យជាកុមារ

ព្រះមាតានិងព្រះបុត្រារួមគ្នាក្នុងកិច្ចសង្គ្រោះយ៉ាងជាក់ស្តែង តាំងពីពេលព្រះគ្រីស្តចាប់ផ្ទៃក្នុងនាងព្រហ្មចារិនី មករហូតដល់ពេលព្រះអង្គសោយទិវង្គត។ មុនដំបូង នាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅសួរសុខទុក្ខនាងអេលីសាបិត។ ពេលទារកនៅក្នុងផ្ទៃនាងអេលីសាបិតបម្រះឡើង នាងជម្រាបសួរនាងម៉ារីថា ជាអ្នកមានសុភមង្គល ព្រោះនាងបានជឿថា ព្រះជាម្ចាស់នឹងសង្គ្រោះមនុស្សលោកតាមព្រះបន្ទូលសន្យា (លក ១, ៤១-៤៥)។ បន្ទាប់មក ពេលព្រះយេស៊ូប្រសូតព្រះមាតារបស់ព្រះអម្ចាស់មានអំណរ ដោយបង្ហាញកូនច្បងរបស់នាងឲ្យពួកគង្វាលសត្វ និងពួកហោរាចារ្យឃើញ។

កំណើតបុត្រនោះ មិនបណ្ដាលឲ្យនាងលែងជាព្រហ្មចារិនីទេ តែផ្ទុយទៅវិញបញ្ជាក់ថា នាងនៅព្រហ្មចារិនីជាដរាប។ ពេលនាងយកបុត្រមកថ្វាយក្នុងព្រះវិហារ ក្រោយពីបានថ្វាយតង្វាយរបស់អ្នកក្រីក្ររួចហើយ នាងបានឮលោកស៊ីម៉ូន មានប្រសាសន៍ក្នុងឋានៈលោកជាព្យាការីថា បុត្រនេះនឹងទៅជាទីសម្គាល់មួយ នាំឲ្យមនុស្សជំទាស់ប្រឆាំងគ្នា ហើយនាងឈឺចុកចាប់យ៉ាងខ្លាំង ដូចមានដាវមួយមកចាក់ទម្លុះដួងចិត្តរបស់នាង។ ដូច្នេះ គំនិតលាក់កំបាំងរបស់មនុស្សជាច្រើននឹងលេចធ្លោឲ្យបានច្បាស់ឡើង (លក ២, ៣៤-៣៥)។ ពេលនាងម៉ារីនិងលោកយ៉ូសែបបាត់ព្រះកុមារយេស៊ូ គាត់នាំគ្នាដើររកទាំងព្រួយបារម្ភ។ មាតាបិតារកឃើញព្រះយេស៊ូក្នុងព្រះវិហារ កំពុងតែជាប់នឹងព្រះរាជកិច្ចនៃព្រះបិតារបស់ព្រះអង្គ។ មាតាបិតាពុំបានយល់អត្ថន័យនៃព្រះបន្ទូលរបស់បុត្រឡើយ។ ប៉ុន្តែ មាតារបស់ព្រះកុមារចងចាំហេតុការណ៍ទាំងអស់នោះទុកក្នុងចិត្ត ទាំងនឹកសញ្ជឹងគិតទៀតផង (លក ២, ៤១-៥១)។

## ៥៨- នាងម៉ារី នៅពេលព្រះយេស៊ូបំពេញព្រះរាជកិច្ច

យើងឃើញព្រះមាតាព្រះយេស៊ូយ៉ាងច្បាស់ ពេលព្រះអង្គចាប់ផ្ដើមបំពេញព្រះរាជកិច្ចជាសាធារណៈ គឺក្នុងពិធីមង្គលការនៅភូមិកាណានៅស្រុកកាលីឡេ។ នាងម៉ារីអាណិតគេហើយអង្វរព្រះយេស៊ូ សូមព្រះគ្រីស្ដចាប់ផ្ដើមសម្ដែងការអស្ចារ្យ (យហ ២, ១-១១)។ ពេលព្រះយេស៊ូសម្ដែងធម្មទេសនា នាងសុខចិត្តទទួលព្រះបន្ទូលប្រកាសថា អស់អ្នកដែលស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអនុវត្តតាម ពិតជាមានសុភមង្គលមែន (មក ៣, ៣៥; លក ១, ២៧-២៨) គឺព្រះបុត្រារបស់ព្រះបិតាមិនយល់ដល់សាច់ឈាមទេ តែព្រះអង្គតម្កល់ព្រះរាជ្យនោះលើសអ្វីៗទាំងអស់ ដូចនាងធ្លាប់ធ្វើដោយចិត្តស្មោះរួចមកហើយដែរ (លក ២, ១៩ និង ៥១)។ ដូច្នេះ ពេលព្រះនាងព្រហ្មចារិនីធ្វើបូជនីយេសក៍តាមជំនឿតទៅមុខទៀត នាងរួបរួមជាមួយព្រះបុត្រាដោយចិត្តស្មោះ រហូតដល់ឈើឆ្កាង គឺនាងឈរនៅក្បែរឈើឆ្កាង។ ការណ៍នេះ ពិតជាកើតឡើងតាមព្រះជាម្ចាស់គ្រោងទុកជាមុន (យហ ១៩, ២៥)។ នាងឈឺចុកចាប់យ៉ាងសែនខ្លោចផ្សារួមជាមួយព្រះបុត្រាតែមួយរបស់នាង។ នាងក៏សុខចិត្តរួមក្នុងសក្ការបូជារបស់ព្រះអង្គ តាមចិត្តគំនិតជាម្ដាយ។ ដោយសេចក្ដីស្រឡាញ់ នាងសុខចិត្តឲ្យគេយកបុត្រ ដែលកើតពីសាច់ឈាមរបស់នាង ធ្វើជាយញ្ញ។ ព្រះគ្រីស្ដយេស៊ូកំពុងសោយទិវង្គតនៅលើឈើឆ្កាង ព្រះអង្គប្រគល់នាងឲ្យសាវ័កម្នាក់ទុកជាម្ដាយ ដោយមានព្រះបន្ទូលថា «អ្នកអើយ! នេះហើយ កូនរបស់អ្នក» (យហ ១៩, ២៦-២៧)។

## ៥៩- នាងម៉ារី ក្រោយពេលព្រះជាម្ចាស់លើកព្រះយេស៊ូឡើង

ព្រះជាម្ចាស់សព្វព្រះហឫទ័យសម្ដែងគម្រោងការ នៃការសង្គ្រោះមនុស្សលោកយ៉ាងជាក់ច្បាស់ នៅពេលព្រះអង្គចាក់បង្ហូរព្រះវិញ្ញាណ តាមព្រះបន្ទូលសន្យារបស់ព្រះគ្រីស្ដ។ មុនបុណ្យថ្ងៃទីហាសិប យើងឃើញក្រុមគ្រីស្ដទូត «រួមចិត្តគំនិតគ្នា ព្យាយាមអធិដ្ឋានដោយមានស្ត្រីខ្លះ មាននាងម៉ារីជាមាតារបស់ព្រះយេស៊ូ និងមានបងប្អូនរបស់ព្រះអង្គ មកចូលរួមជាមួយផងដែរ» (កក ១, ១៤)។ យើងក៏ឃើញនាងម៉ារីអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះវិញ្ញាណ ដល់ក្រុមគាត់ ជាព្រះវិញ្ញាណដែលមកសណ្ឋិតលើនាង នៅពេលទេវទូតនាំដំណឹងមកនាងរួចហើយ។ នាងដ៏និមល ដែលព្រះជាម្ចាស់បានការពារមិនឲ្យជំពាក់បាបខាងដើម ក្រោយពីបានបញ្ចប់ជីវិតនៅក្នុងលោកនេះ ព្រះជាម្ចាស់បានលើកឡើងនាងទាំងរូបកាយ ទាំងវិញ្ញាណ ឲ្យចូលក្នុងសិរីរុងរឿងនៃលោកខាងមុខ។ ព្រះអម្ចាស់បានលើកតម្កើងនាង ទៅជាព្រះមហាក្សត្រីយានីនៃពិភពលោក ដើម្បីឲ្យនាងបានដូចព្រះបុត្រាយ៉ាងពេញលេញ គឺដូចព្រះបុត្រាដែលជា «ព្រះអម្ចាស់លើអម្ចាស់នានា» (វវ ១៩, ១ ទុក ៦) ដែលមានជ័យជម្នះលើបាប និងលើសេចក្ដីស្លាប់។

## គ- ព្រះនាងព្រហ្មចារិនីម៉ារី និងព្រះសហាគមន៍

### ៦០- នាងម៉ារីជាអ្នកបម្រើរបស់ព្រះអម្ចាស់

យើងមានស្ពានមេត្រីតែមួយគត់ តាមពាក្យរបស់គ្រីស្តទូតប៉ូលថា «មានព្រះជាម្ចាស់តែមួយព្រះអង្គ មានស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក គឺព្រះគ្រីស្តយេស៊ូជាមនុស្សម្នាក់ដែលបានបូជាព្រះជន្ម ដើម្បីរំដោះមនុស្សទាំងអស់» (១ធម ២,៥-៦)។ ប៉ុន្តែ តួនាទីរបស់នាងម៉ារីដែលជាមាតារបស់មនុស្សទាំងអស់ មិនជំទាស់ និងមិនបណ្តាលឲ្យតួនាទីរបស់ព្រះគ្រីស្ត ដែលជាស្ពានមេត្រីតែមួយគត់នោះអន់ខ្សោយទេ។ ផ្ទុយទៅវិញ តួនាទីនាងម៉ារី បង្ហាញអំពីឫទ្ធិនៃតួនាទីរបស់ព្រះគ្រីស្តនោះវិញ។

ឥទ្ធិពលរបស់ព្រះនាងព្រហ្មចារិនីម៉ារី សម្រាប់សង្គ្រោះមនុស្សលោក ហូរចេញមកពីព្រះជាម្ចាស់សព្វព្រះហឫទ័យចាត់ចែងដូច្នេះ គឺមិនហូរមកពីសេចក្តីត្រូវការណាមួយក្នុងការចាត់ចែងនោះទេ តែហូរមកពីព្រះគ្រីស្ត មានអំពើល្អជាច្រើនលើសលប់រាប់មិនអស់។ ឥទ្ធិពលរបស់ព្រះនាងសំអាងលើព្រះគ្រីស្តដែលជាស្ពានមេត្រី គឺនាងទទួលអ្វីៗទាំងអស់ពីព្រះគ្រីស្ត និងទទួលអានុភាពទាំងអស់ពីព្រះអង្គ។ ឥទ្ធិពលរបស់ព្រះនាងមិនរារាំងគ្រីស្តបរិស័ទមិនឲ្យរួបរួមដោយផ្ទាល់ជាមួយព្រះគ្រីស្តត្រង់ណាសោះឡើយ ផ្ទុយទៅវិញ នាងម៉ារី ជួយគ្រីស្តបរិស័ទឲ្យរួបរួម ដោយផ្ទាល់ជាមួយព្រះគ្រីស្តទៀតផង។

### ៦១- ព្រះជាម្ចាស់បានតម្រូវព្រះនាងព្រហ្មចារិនីម៉ារីមុនកាលសម័យទាំងអស់

តាមគម្រោងការរបស់ព្រះអង្គ ដែលចាត់ព្រះបន្ទូលឲ្យប្រសូតជាមនុស្ស ដើម្បីឲ្យនាងទៅជាព្រះមាតារបស់ព្រះអម្ចាស់។ តាមព្រះជាម្ចាស់ដែលថែរក្សាអ្វីៗទាំងអស់ បានគ្រោងទុកជាមុន ព្រះអង្គចាត់ចែងឲ្យនាងម៉ារីទៅជាព្រះមាតាគួរឲ្យគោរពរបស់ព្រះសង្គ្រោះនៅលើផែនដីនេះ។ គ្មាននណាអាចប្រៀបផ្ទឹមនឹងនាងបានទេ គឺនាងរួមសហការយ៉ាងពិសេស ក្នុងព្រះរាជកិច្ចរបស់ព្រះបុត្រា ដោយចិត្តទូលំទូលាយ ក្នុងឋានៈជាអ្នកបម្រើដ៏សុភាពរាបសាររបស់ ព្រះអម្ចាស់។ ដោយនាងមានផ្ទៃ ដោយនាងសម្រាលព្រះគ្រីស្ត ដោយនាងចិញ្ចឹមព្រះអង្គ ដោយនាងនាំព្រះអង្គទៅថ្វាយព្រះបិតារបស់ព្រះអង្គក្នុងព្រះវិហារ ដោយនាងរងទុក្ខ រួមជាមួយព្រះបុត្រាកំពុងសោយទិវង្គតនៅលើឈើឆ្កាង នាងសហការក្នុងព្រះរាជកិច្ចនៃព្រះសង្គ្រោះយ៉ាងពិសេស ដែលគ្មាននរណាអាចប្រៀបផ្ទឹមនិងនាងបាន។ ដោយនាងស្តាប់បង្គាប់ ដោយនាងផ្ញើជីវិតលើព្រះជាម្ចាស់ ដោយនាងមានសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់យ៉ាងខ្លាំង នាងសហការឲ្យមនុស្សលោកទទួលព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់វិញ។ ហេតុនេះហើយបានជា ប្រសិនបើគិតដល់ព្រះជាម្ចាស់ប្រណីសន្តោសមនុស្សលោក នាងម៉ារីពិតជាមាតារបស់យើងមែន។

### ៦២- តាំងពីពេលនាងយល់ព្រមធ្វើតាមដំណឹងដែលទេវទូតជម្រាបមក

ទាំងផ្ញើជីវិតលើព្រះជាម្ចាស់ នាងក៏នៅតែយល់ស្របតទៅទៀត ដោយចិត្តរឹងប៉ឹងនៅពេលនាងឈរនៅក្បែរឈើឆ្កាង គឺនាងម៉ារីមានតួនាទីជាមាតាក្នុងការចាត់ចែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ហើយនៅតែបន្តតួនាទីនេះតទៅទៀតដោយគ្មានឈប់ឈរ រហូតដល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើសទទួលការសង្គ្រោះជាស្ថាពរ។ ក្រោយពីព្រះអង្គលើកនាងទៅស្ថានបរមសុខរួចហើយ តួនាទីរបស់នាងក្នុងការសង្គ្រោះមិនអាក់ខានឡើយ គឺនាងនៅតែ

ជួយអង្វរព្រះជាម្ចាស់ជារឿយៗ ធ្វើឲ្យយើងទទួលព្រះអំណោយទានពីព្រះអង្គតទៅទៀត ជាព្រះអំណោយទាន ដែលយើងត្រូវការសម្រាប់ទទួលការសង្គ្រោះអស់កល្បជានិច្ច។ ដោយនាងមានចិត្តស្រឡាញ់ទុកជាម្ដាយ នាងចាប់អារម្មណ៍នឹងបងប្អូននៃព្រះបុត្រារបស់នាង ដែលមិនទាន់បង្ហើយបូជនីយេសក៍នៅលើផែនដីនេះនៅឡើយ ហើយដែលប្រឈមមុខនឹងគ្រោះកាចនិងទុក្ខលំបាកផ្សេងៗជាច្រើន ទម្រាំទៅដល់មាតុភូមិដ៏សែនសុខសាន្ត។ ហេតុនេះហើយ បានជាព្រះសហគមន៍តែងតែអង្វរនាងព្រហ្មចារិនី ដោយយកនាមផ្សេងៗមកហៅដូចតទៅ *"មេធាវី"* *"អ្នកជួយអង្វរ"* *"អ្នកប្រោសប្រណី"* *"ស្ពានមេត្រី"*។ ប៉ុន្តែ មានព្រះគ្រីស្តតែមួយព្រះអង្គគត់ ជាស្ពានមេត្រីដ៏ថ្លៃថ្នូរនិងដ៏មានប្រសិទ្ធភាព។ សូមប្រយ័ត្នមិនត្រូវឲ្យពាក្យទាំងនោះ ស្ដីអំពីនាង បន្ថែម ឬដកអ្វីពីមុខងាររបស់ព្រះគ្រីស្តឡើយ។

យើងមិនអាចលើកតម្កើងសត្វលោកណាមួយ ដែលព្រះជាម្ចាស់ប្រតិស្ឋានមក ឲ្យបានស្មើនឹងព្រះបន្ទូល ដែលបានប្រសូតជាមនុស្ស និងជាព្រះសង្គ្រោះសោះឡើយ។ ក៏ប៉ុន្តែ ប្រជាជនគ្រីស្តបរិស័ទទាំងមូលទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាមហាបូជាចារ្យតែមួយ គឺមានអ្នកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ និងគ្រីស្តបរិស័ទឯទៀតៗទទួលចំណែកតាមរបៀបផ្សេងៗ។ គេទទួលចំណែកក្នុងមុខងារទាំងអស់គ្នាយ៉ាងណា ក៏តួនាទីជាស្ពានមេត្រីរបស់ព្រះគ្រីស្តមិនរារាំងឲ្យសត្វលោក ឲ្យរួមសហការជាមួយព្រះអង្គ ក្នុងការសង្គ្រោះយ៉ាងនោះដែរ។ ព្រះជាម្ចាស់ផ្សព្វផ្សាយព្រះហឫទ័យមេត្តាករុណាតែមួយដល់សត្វលោកទាំងអស់យ៉ាងពិតប្រាកដ តាមរបៀបផ្សេងៗយ៉ាងណា ក៏ព្រះអង្គចែកចំណែកក្នុងតួនាទីជាស្ពានមេត្រីតែមួយ ឲ្យសត្វលោកយ៉ាងនោះដែរ។ ការរួមចំណែកនេះ ដាស់តឿនសត្វលោកដែលព្រះជាម្ចាស់ប្រតិស្ឋានមក ឲ្យរួមសហការតាមរបៀបផ្សេងៗក្នុងការសង្គ្រោះ ដែលមកពីព្រះគ្រីស្តតែមួយព្រះអង្គគត់។

ព្រះសហគមន៍ប្រកាសតួនាទីជាបន្ទាប់បន្សំរបស់នាងម៉ារីដោយឥតរួញរាទាល់តែសោះ។ ព្រះសហគមន៍ នៅតែមានបទពិសោធន៍អំពីតួនាទីនោះស្រាប់។ ព្រះសហគមន៍ក៏ទូន្មានឲ្យគ្រីស្តបរិស័ទពឹងផ្អែកលើនាងម៉ារី សូមនាងម៉ារីជួយគេដូចម្ដាយតែងជួយកូន គឺសូមជួយឲ្យគេភ្ជាប់ចិត្តជាមួយព្រះគ្រីស្តជាស្ពានមេត្រី និងជាព្រះសង្គ្រោះ ឲ្យកាន់តែជិតស្និទ្ធឡើងៗ។

## ៦៣- នាងម៉ារីជាគំរូសម្រាប់ព្រះសហគមន៍

ដោយព្រះជាម្ចាស់ប្រទានអំណោយទាន និងបន្ទុកឲ្យព្រះនាងម៉ារី ប្រសូតព្រះបុត្រា នាងភ្ជាប់ជាមួយបុត្រជាព្រះសង្គ្រោះយ៉ាងអស្ចារ្យ។ ដោយព្រះជាម្ចាស់ប្រណីសន្ដោសនាង និងផ្ញើបន្ទុកពិសេសទាំងនោះមកនាង នាងក៏ភ្ជាប់យ៉ាងជិតស្និទ្ធជាមួយព្រះសហគមន៍ដែរ។ សន្ដ: អំប្រ័ស តែងបង្រៀនថា ព្រះមាតារបស់ព្រះអម្ចាស់ពិតជាគំរូរបស់ព្រះសហគមន៍ ត្រង់ជំនឿ ត្រង់សេចក្ដីស្រឡាញ់ និងត្រង់ការរួបរួមយ៉ាងពេញលក្ខណៈជាមួយព្រះគ្រីស្ត។ ព្រះសហគមន៍ក៏ទទួលឈ្មោះយ៉ាងត្រឹមត្រូវថា ជាមាតា និងជាព្រហ្មចារិនីដែរ។ តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ អំពីព្រះសហគមន៍ នាងម៉ារីជាគ្រីស្តបរិស័ទពិសេសដ៏ប្រសើរជាងគេបំផុត គឺនាងជាស្រីព្រហ្មចារិនីនិងជាម្ដាយគំរូ។ នាងបានបង្កើតព្រះបុត្រារបស់ព្រះបិតានៅលើផែនដី ដោយនាងផ្ញើជីវិតលើព្រះជាម្ចាស់ និងដោយនាងស្ដាប់តាមបង្គាប់ព្រះអង្គ គឺនាងមិនបានប្រសូតដោយរួមបវេណីជាមួយបុរសណាម្នាក់ឡើយ តែដោយព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើនាងវិញ។ ក្នុងឋានៈនាងម៉ារីជានាងអេវ៉ាថ្មី នាងជឿទេវទូតរបស់ព្រះជាម្ចាស់ មិនជឿសត្វពស់ពីបុរាណទេ គឺនាងមានជំនឿ ដោយគ្មានមន្ទិលសង្ស័យអ្វីឡើយ។ នាងប្រសូតបុត្រហើយ ព្រះជាម្ចាស់តែងតាំងបុត្រនោះឲ្យទៅជារៀមច្បង ក្នុង

បណ្ដាបងប្អូនជាច្រើន (រម ៨, ២៩) ពោលគឺ ក្នុងចំណោមគ្រីស្តបរិស័ទទាំងប៉ុន្មាន។ ដូច្នេះនាងរួមសហការធ្វើឲ្យគ្រីស្តបរិស័ទទាំងនោះកើតឡើង និងជួយអប់រំគេ ដោយស្រឡាញ់គេក្នុងឋានៈជាម្ដាយ។

## ៦៤- ពេលព្រះសហគមន៍នឹកសញ្ជឹងស្ញប់ស្ញែង

អំពីព្រះនាងព្រហ្មចារិនីម៉ារីដ៏វិសុទ្ធយ៉ាងអស្ចារ្យ ពេលព្រះសហគមន៍យកតម្រាប់តាមសេចក្ដីស្រឡាញ់របស់នាង ព្រមទាំងយកចិត្តទុកដាក់ ធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាដោយចិត្តស្មោះ ពេលនោះ ព្រះសហគមន៍ក៏ត្រឡប់ទៅជាមាតាដែរ ព្រោះព្រះសហគមន៍បានទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទាំងផ្ញើជីវិតលើព្រះអង្គ។ ពេលព្រះសហគមន៍ប្រកាសដំណឹងល្អ និងធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ ព្រះសហគមន៍ក៏បង្កើតកូនដែលចាប់ផ្ទៃដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយដែលកើតពីព្រះជាម្ចាស់ ដើម្បីឲ្យមានជីវិតថ្មីជាជីវិតអមតៈ។ ដូច្នេះ ព្រះសហគមន៍ក៏ជាព្រហ្មចារិនីដែរ ដោយព្រះសហគមន៍ផ្ញើជីវិតលើព្រះគ្រីស្តជាព្រះស្វាមី ហើយក៏កាន់ជំនឿនេះ ដោយចិត្តស្មោះត្រង់បរិសុទ្ធដែរ។ ព្រះសហគមន៍យកតម្រាប់ធ្វើតាមព្រះមាតាព្រះអម្ចាស់របស់ខ្លួន ហើយរក្សាទុកជំនឿពិតប្រាកដ រក្សាទុកសេចក្ដីសង្ឃឹមយ៉ាងមាំមួន និងសេចក្ដីស្រឡាញ់យ៉ាងស្មោះ តាមរបៀបបរិសុទ្ធដូចស្ត្រីព្រហ្មចារិនីម្នាក់ ដោយអានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង។

## ៦៥- ព្រហ្មវិហារធម៌របស់នាងម៉ារីជាគំរូឲ្យព្រះសហគមន៍ប្រតិបត្តិតាម

ព្រះសហគមន៍បានពេញលក្ខណៈរួចហើយ គឺឥតស្លាកស្នាម ឥតជ្រីវជ្រួញឡើយ (អភ ៥, ២៧) ក្នុងរូបព្រះនាងព្រហ្មចារិនីម៉ារីជាតំណាងបានពេញលក្ខណៈ ក៏ប៉ុន្តែ គ្រីស្តបរិស័ទនៅតែខិតខំប្រឹងប្រែងឲ្យកាន់តែវិសុទ្ធឡើងៗ ដោយឈ្នះអំពើបាប។ ហេតុនេះ ហើយបានជា គ្រីស្តបរិស័ទតែងសម្លឹងមើលនាងម៉ារីជាគំរូ ព្រោះនាងកាន់ព្រហ្មវិហារធម៌ដែលចាំងលើសហគមន៍របស់អស់អ្នក ដែលព្រះជាម្ចាស់បានជ្រើសរើស។ ព្រះសហគមន៍នឹកគោរពនាងម៉ារី ទាំងស្ញប់ស្ញែងអំពីព្រះបន្ទូលដែលប្រសូតជាមនុស្ស ទើបព្រះសហគមន៍យល់កាន់តែច្បាស់ឡើងៗនូវគម្រោងការដ៏អស្ចារ្យបំផុតរបស់ព្រះជាម្ចាស់ដែលប្រសូតជាមនុស្ស។ ព្រះសហគមន៍ក៏កាន់តែដូចព្រះស្វាមីដែរ។ ដោយនាងម៉ារីនៅជាប់យ៉ាងជិតជិតនឹងប្រវត្តិសាស្ត្រនៃការសង្គ្រោះ នាងប្រមូលនិងចាំងក្នុងរូបនាង នូវកិច្ចការដ៏ប្រសើរបំផុត ដែលមនុស្សត្រូវប្រព្រឹត្តដោយអនុវត្តតាមជំនឿ។ ពេលព្រះសហគមន៍ពន្យល់អំពីព្រះនាងម៉ារី និងគោរពនាង នាងអញ្ជើញគ្រីស្តបរិស័ទឲ្យមានចិត្តស្មោះ នឹងព្រះបុត្រាដែលបូជាព្រះជន្ម ព្រមទាំងឲ្យមានចិត្តស្រឡាញ់ព្រះបិតាដែរ។ រីឯព្រះសហគមន៍វិញ ព្រះសហគមន៍ស្វែងរកសិរីរុងរឿងរបស់ព្រះគ្រីស្ត និងខិតខំប្រតិបត្តិតាមព្រះហឫទ័យព្រះជាម្ចាស់ក្នុងគ្រប់កិច្ចការទាំងអស់ ក៏កាន់តែដូចព្រះយេស៊ូជាគំរូដ៏ប្រសើររបស់ខ្លួន គឺមានជំនឿ មានសេចក្ដីសង្ឃឹម និងមានសេចក្ដីស្រឡាញ់កាន់តែរឹងប៉ឹងឡើងដែរ។ ហេតុនេះហើយ បានជានៅពេលព្រះសហគមន៍បំពេញកិច្ចការជាគ្រីស្តទូត ព្រះសហគមន៍សម្លឹងមើលយ៉ាងត្រឹមត្រូវទៅកាន់នាងម៉ារីដែលបានប្រសូតព្រះគ្រីស្ត គឺព្រះអង្គដែលចាប់ផ្ទៃក្នុងព្រះនាងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ និងដែលបានប្រសូតពីនាងព្រហ្មចារិនី។ ព្រះអង្គក៏ប្រសូតនិងចម្រើនឡើងក្នុងចិត្តគ្រីស្តបរិស័ទ ដោយសារព្រះសហគមន៍ដែរ។ អស់អ្នកដែលរួមសហការក្នុងបេសកកម្មជាគ្រីស្តទូតរបស់ព្រះសហគមន៍ខិតខំធ្វើឲ្យមនុស្សលោកកើតជាថ្មី។ ពេលព្រះនាងព្រហ្មចារិនីម៉ារីរស់នៅ នាងធ្វើជាគំរូអំពីសេចក្ដីស្រឡាញ់ចំពោះកូនយ៉ាងណា អ្នកទាំងនោះក៏ត្រូវយកនាងធ្វើជាគំរូ គឺត្រូវមានចិត្តស្រឡាញ់ដូចម្ដាយចំពោះកូនយ៉ាងនោះដែរ។

## ឃ- ការគោរពប្រណិប័តន៍ព្រះនាងព្រហ្មចារិនីម៉ារីក្នុងព្រះសហគមន៍

### ៦៦- លក្ខណៈនិងគ្រឹះនៃការគោរពប្រណិប័តន៍ព្រះនាងព្រហ្មចារិនីម៉ារី

ព្រះជាម្ចាស់ប្រណីសន្ដោសលើកនាងម៉ារី ឲ្យទាបជាងព្រះបុត្រាព្រះអង្គ តែឲ្យបានខ្ពស់ជាងអស់ទេវទូត និងមនុស្សទាំងឡាយ ព្រោះនាងជាព្រះមាតាដ៏វិសុទ្ធបំផុតនៃព្រះអម្ចាស់ និងស្ថិតនៅជាមួយព្រះគ្រីស្ដនៅពេលព្រះអង្គប្រព្រឹត្តព្រះរាជកិច្ចដ៏អស្ចារ្យ។ ដូច្នេះ ព្រះសហគមន៍គោរពប្រណិប័តន៍ព្រះនាងម៉ារីយ៉ាងពិសេសពិតជាត្រឹមត្រូវហើយ។ ហេតុនេះហើយ បានជាតាំងពីយូរសតវត្សមក គ្រីស្ដបរិស័ទតែងតែគោរពព្រះនាងព្រហ្មចារិនីម៉ារីដោយថ្វាយព្រះនាមថា *"ព្រះមាតារបស់ព្រះអម្ចាស់"*។ គ្រីស្ដបរិស័ទក៏តែងជ្រកកោនក្រោមម្លប់ព្រះនាង សូមនាងជួយការពារ អង្វរនាងក្នុងគ្រោះកាចនានា និងតាមសេចក្ដីត្រូវការរបស់គេ ជាពិសេសតាំងពីមហាសន្និបាតអេភេសូ មក ប្រជារាស្ដ្ររបស់ព្រះជាម្ចាស់នាំគ្នាគោរពបម្រើនាងម៉ារីយ៉ាងអស្ចារ្យកាន់តែខ្លាំងឡើងៗ ទាំងគោរព ទាំងស្រឡាញ់ ដោយអង្វរនិងយកតម្រាប់ ធ្វើតាមនាង។ គ្រីស្ដបរិស័ទធ្វើឲ្យប្រសាសន៍របស់នាងដែលបានថ្លែងជាមុន កើតជារូបរាងហើយ គឺថា «មនុស្សគ្រប់ជំនាន់នឹងពោលថា ខ្ញុំជាអ្នកមានសុភមង្គលមែន ដ្បិតព្រះដ៏មានឫទ្ធានុភាពបានសម្ដែងការប្រសើរអស្ចារ្យចំពោះខ្ញុំ» (លក ១, ៤៨)។ ព្រះសហគមន៍តែងគោរពបម្រើនាងម៉ារីតាំងពីដើមរៀងមក តែការគោរពបម្រើនេះមានលក្ខណៈពិសេសអស្ចារ្យម៉្យាង គឺមានលក្ខណៈប្លែកទាំងស្រុងពីការនមស្ការក្រាបប្រណិប័តន៍ព្រះបន្ទូលដែលប្រសូតជាមនុស្ស និងពីការនមស្ការថ្វាយបង្គំក្រាបប្រណិប័តន៍ព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធផង។ ការគោរពនាងម៉ារីជួយគាំទ្រការនមស្ការថ្វាយបង្គំព្រះបិតា ព្រះបុត្រា ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងខ្លាំងបំផុត។ ព្រះសហគមន៍យល់ស្របទទួលស្គាល់ពិធី និងរបៀបគោរពប្រណីប័តន៍ផ្សេងៗ ចំពោះព្រះមាតារបស់ព្រះអម្ចាស់ ស្របតាមកន្លែងនិងតាមសម័យ ស្របតាមលក្ខណៈសម្បត្តិ និងទេពកោសល្យរបស់ក្រុមគ្រីស្ដបរិស័ទផ្សេងៗ។ ប៉ុន្តែ ព្រះសហគមន៍យល់ស្របឲ្យគេគោរពព្រះមាតានេះ តាមកម្រិតមិនឲ្យខុសពីលទ្ធិនៃជំនឿដ៏ពិតប្រាកដ ដោយយល់ឃើញថា ការគោរពព្រះមាតានាំឲ្យគ្រីស្ដបរិស័ទស្គាល់ព្រះបុត្រាដូចគេត្រូវស្គាល់ ស្រឡាញ់ព្រះបុត្រា និងលើកតម្កើងសិរីរុងរឿងរបស់ព្រះបុត្រា ហើយក៏ស្ដាប់តាមព្រះបញ្ញារបស់ព្រះអង្គផង។ ព្រះបិតាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច បានប្រតិស្ឋានអ្វីៗសព្វសារពើសម្រាប់ព្រះបុត្រា (កូឡ ១, ១៥-១៦) ហើយទ្រង់សព្វព្រះហឫទ័យឲ្យគ្រប់លក្ខណៈសម្បត្តិរបស់ព្រះអង្គ ស្ថិតនៅក្នុងព្រះបុត្រានោះដែរ (កូឡ ១, ១៩)។

### ៦៧- ដំបូន្មានសម្រាប់ពិធីអន្ដាធិប្បាយព្រះគម្ពីរ និងអំពីការគោរពបម្រើព្រះនាងព្រហ្មចារិនីម៉ារី

មហាសន្និបាតដ៏វិសុទ្ធបង្រៀនលទ្ធិកាតូលិកនេះឲ្យគ្រីស្ដបរិស័ទជឿជាក់ច្បាស់។ នៅពេលជាមួយគ្នានេះ មហាសន្និបាតក៏ដាស់តឿនគ្រីស្ដបរិស័ទទាំងអស់ ឲ្យចូលរួមក្នុងការគោរពព្រះនាងម៉ារីដោយចិត្តទូលាយ ជាពិសេសឲ្យចូលរួមក្នុងពិធីនានា ឲ្យយកចិត្តទុកដាក់ជាខ្លាំងនឹងពិធីជាប្រជាប្រិយ និងរបៀបគោរពព្រះនាង តាមការបង្រៀនព្រះសហគមន៍បានគាំទ្រឲ្យធ្វើជាយូរអង្វែងមក។ មហាសន្និបាតក៏ទូន្មានផ្ដាំគ្រីស្ដបរិស័ទឲ្យកាន់វិន័យទាំងប៉ុន្មាន ដែលព្រះសហគមន៍បានបញ្ញត្តកាលពីសម័យមុនៗ ស្ដីអំពីការគោរពរូបព្រះគ្រីស្ដ រូបនាងម៉ារី និងរូបសន្ដបុគ្គល។ មហាសន្និបាតដាស់តឿនទេវវិទូ និងអស់អ្នកប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងខ្លាំងថា នៅពេលនិយាយអំពីកិត្តិយសដ៏ថ្លៃថ្នូរតែមួយគត់ និងប្លែកពីគេនៃព្រះមាតារបស់ព្រះអម្ចាស់ សូមប្រុងប្រយ័ត្នឲ្យមែនទែនគឺ សូមជៀសវាងម៉្យាង កុំឲ្យនិយាយបំផ្លើស និងម៉្យាងទៀត កុំឲ្យមានគំនិតចង្អៀតចង្អល់ហួសពេក។ សូមសិក្សាព្រះគម្ពីរ សិក្សាសេចក្ដីបង្រៀនរបស់គ្រូបាធ្យាយដ៏វិសុទ្ធ និងបណ្ឌិតនៃព្រះសហគមន៍ ព្រមទាំងសិក្សាក្បួនពិធីនានា ក្រោមការណែនាំនៃក្រុមបង្រៀនរបស់ព្រះសហគមន៍។

ការសិក្សានេះ មុខជានឹងបង្ហាញឲ្យយល់យ៉ាងត្រឹមត្រូវនិងយ៉ាងច្បាស់ នូវតួនាទីនិងឯកសិទ្ធិរបស់ព្រះនាងព្រហ្មចារិនីម៉ារី គឺតួនាទីនិងឯកសិទ្ធិទាំងនោះតម្រង់អ្នកជឿទៅកាន់ព្រះគ្រីស្តជានិច្ច គឺព្រះអង្គជាប្រភពនៃសេចក្តីពិតដ៏ពេញលេញ ហើយក៏ជាប្រភពផ្តល់ឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ និងចេះនមស្ការថ្វាយបង្គំក្រាបប្រណិប័តន៍ព្រះបិតា។ សូមអស់លោកប្រុងប្រយ័ត្នជាខ្លាំង កុំមានប្រសាសន៍ ឬធ្វើកាយវិការណាមួយដែលអាចនាំឲ្យបងប្អូន ដែលបែកចេញពីព្រះសហគមន៍កាតូលិកយើង ឬនរណាក៏ដោយយល់ច្រឡំ និងវង្វេងអំពីលទ្ធិនៃជំនឿដ៏ពិតប្រាកដរបស់ព្រះសហគមន៍។ សូមគ្រីស្តបរិស័ទនឹកចងចាំថា ការគោរពប្រណិប័តន៍នាងម៉ារីយ៉ាងពិតប្រាកដ មិនអាស្រ័យលើការរំភើបចិត្តដ៏ឥតបានផល និងមិនទៀងទាត់នោះទេ ហើយក៏មិនអាស្រ័យលើការឆាប់ជឿគេផ្តេសផ្តាសដែរ។ ការគោរពប្រណិប័តន៍នាងម៉ារីយ៉ាងពិតប្រាកដ គឺហូរមកពីជំនឿដ៏ពិតប្រាកដ និងនាំឲ្យស្គាល់កិត្តិយសដ៏ថ្លៃថ្នូរអស្ចារ្យនៃព្រះមាតារបស់ព្រះអម្ចាស់។ ការគោរពប្រណិប័តន៍យ៉ាងពិតប្រាកដ ក៏ជំរុញឲ្យស្រឡាញ់ព្រះមាតានេះ ដូចកូនចៅស្រឡាញ់ម្តាយ និងឲ្យយកតម្រាប់តាមព្រហ្មវិហារធម៌របស់ព្រះនាងទៅទៀតផង។

## ង- នាងម៉ារីជាសញ្ញាសម្គាល់អំពីសេចក្តីសង្ឃឹមយ៉ាងនឹងន និងជាសញ្ញាលួងលោមប្រជារាស្រ្តរបស់ព្រះជាម្ចាស់

### ៦៨- ព្រះមាតារបស់ព្រះយេស៊ូ

ទទួលសិរីរុងរឿងទាំងរូបកាយ ទាំងវិញ្ញាណនៅស្ថានបរមសុខរួចហើយយ៉ាងណា ព្រះនាងក៏ជាតំណាងរបស់ព្រះសហគមន៍នៅលើផែដីនេះ និងធ្វើឲ្យព្រះសហគមន៍នៃលោកខាងមុខចាប់ផ្តើមកើតជារូបរាងហើយយ៉ាងនោះដែរ។ ទម្រាំដល់ថ្ងៃព្រះអម្ចាស់យាងមក (២សល ៣, ១០) ទុកនាងបញ្ចាំងសញ្ញាសម្គាល់ អំពីសេចក្តីសង្ឃឹមយ៉ាងនឹងនរ និងជាសញ្ញាលួងលោមនៅមុខប្រជារាស្រ្តរបស់ព្រះជាម្ចាស់កំពុងធ្វើបូជនីយេសក៍នៅលើផែនដី។

### ៦៩- មហាសន្និបាតដ៏វិសុទ្ធមានអំណរសប្បាយជាខ្លាំងនិងធូរចិត្ត

ដោយយល់ឃើញថា សូម្បីក្នុងចំណោមបងប្អូនគ្រីស្តបរិស័ទ ដែលបែកចេញពីព្រះសហគមន៍កាតូលិកយើងក្តី ក៏មានបងប្អូនមួយចំនួនតែងតែគោរពព្រះមាតានៃព្រះអម្ចាស់ជាព្រះសង្គ្រោះ ជាពិសេសបងប្អូនខាងបូព៌ាប្រទេស ស៊ុះឡើង ដោយចិត្តស្រឡាញ់ និងដោយចិត្តស្មោះរួមគ្នាទៅគោរពបម្រើព្រះមាតានៃព្រះអម្ចាស់ ជាព្រហ្មចារិនីជាដរាប។ សូមគ្រីស្តបរិស័ទទាំងអស់ទទូចអង្វរព្រះមាតារបស់ព្រះអម្ចាស់ និងមាតារបស់មនុស្សលោក។ ដូចកាលពីដើមព្រះនាងរួមជាមួយព្រះសហគមន៍ដែលទើបកើតមក និងជួយអង្វរព្រះជាម្ចាស់យ៉ាងណា ឥឡូវនេះ ដោយព្រះជាម្ចាស់បានលើកតម្កើងព្រះនាង លើសសន្តបុគ្គលនិងលើសទេវទូតទាំងឡាយហើយ ព្រះនាងក៏នៅតែជួយអង្វរព្រះបុត្រាតទៅទៀត ទាំងរួបរួមនឹងសន្តបុគ្គលទាំងឡាយយ៉ាងនោះដែរ។ ព្រះនាងជួយអង្វររហូតដល់ពេលគ្រួសារនៃប្រជាជាតិនានា ទោះបីគេមានឈ្មោះដ៏ល្អប្រសើរជាគ្រីស្តបរិស័ទក្តី ឬមិនទាន់ស្គាល់ព្រះសង្គ្រោះរបស់គេក្តី បានរួបរួមគ្នាយ៉ាងសប្បាយរីករាយ ដោយសន្តិភាព និងដោយសេចក្តីសុខសាន្តជាស្ថាពរ ក្នុងប្រជារាស្រ្តតែមួយរបស់ព្រះជាម្ចាស់ ដើម្បីលើកតម្កើងសិរីរុងរឿងនៃព្រះត្រៃឯកដ៏វិសុទ្ធបំផុត ដែលមិនអាចបំបែកបានឡើយ។

អស់លោកអភិបាលដែលចូលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងធម្មនុញ្ញគោលលទ្ធិទាំងមូលខាងលើនេះ ព្រមទាំងគោលការណ៍នីមួយៗនៃធម្មនុញ្ញគោលលទ្ធិនេះផងដែរ។ រីឯយើងវិញ គឺស្របតាមអំណាចជាគ្រីស្តទូត ដែល

ព្រះគ្រីស្តបានប្រគល់ឲ្យរួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណចូលរួមជាមួយផងនោះ យើងក៏យល់ព្រមសម្រេចថានឹងចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តី ដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈសិលា ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៦៤

ខ្ញុំប៉ូលអភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ព្រះបន្ទូលព្រះជាម្ចាស់

## DEI VERBUM

## ខ្ញុំប៉ូលជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាល ក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសធម្មនុញ្ញនេះ ដើម្បីឲ្យគេនឹក ចងចាំ រហូតតរៀងទៅ។

## ធម្មនុញ្ញគោលលទ្ធិ អំពីព្រះជាម្ចាស់សម្ដែង ព្រះអង្គឲ្យមនុស្សលោកស្គាល់

### ១- បុព្វកថា

ពេលមហាសន្និបាតដ៏វិសុទ្ធ ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយគោរព និងប្រកាសព្រះបន្ទូលនេះ ដោយអង់អាច អស់លោកអភិបាលរួមចិត្តគំនិតជាមួយសន្ដ:យ៉ូហានដែលមានប្រសាសន៍ថា៖ "យើងសូមជូនដំណឹងមកបងប្អូន អំពីជីវិតអស់កល្បជានិច្ចដែលបែរទៅរកព្រះបិតា បានលេចមកឲ្យយើងឃើញហើយ។ យើងសូមជូនដំណឹងអំពីព្រះបន្ទូលដែលយើងបានឃើញ និងបានឮនោះមកបងប្អូន ដើម្បីឲ្យបងប្អូនបានចូលរួមរស់ជាមួយយើង។ រីឯយើងវិញ យើងក៏រួមរស់ជាមួយព្រះបិតា និងជាមួយព្រះយេស៊ូគ្រីស្ដជាព្រះបុត្រារបស់ព្រះអង្គដែរ" (១យហ ១, ២-៣)។ ហេតុនេះហើយ បានជាយើងសូមអនុវត្តតាមមហាសន្និបាតត្រែនតូ និងមហាសន្និបាតវ៉ាទីកង់ទី១ ដែលមានបំណងពន្យល់ពីលទ្ធិដ៏ពិតប្រាកដ អំពីព្រះជាម្ចាស់សម្ដែងព្រះអង្គ និងអំពីព្រះសហគមន៍បញ្ជូនបន្តសេចក្ដីដែលព្រះអង្គបាន សម្ដែងឲ្យមនុស្សលោកស្គាល់នោះ។ ដូច្នេះពិភពលោកទាំងមូល ឮពាក្យប្រកាសដំណឹងស្ដីពីការសង្គ្រោះ និងជឿដំណឹងនេះ។ ដោយគេមានជំនឿ គេក៏បានសេចក្ដីសង្ឃឹម ដោយគេមានសេចក្ដី សង្ឃឹមគេក៏មានចិត្តស្រឡាញ់ផងដែរ។

# ជំពូក ១

## ព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់

### ២- អំពីលក្ខណៈព្រះជាម្ចាស់សម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់

ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យសប្បុរស និងដោយព្រះប្រាជ្ញាញាណ ទ្រង់សព្វព្រះហឫទ័យសម្ដែងព្រះអង្គផ្ទាល់ និងសម្ដែងគម្រោងការដ៏អស្ចារ្យ នៃព្រះហឫទ័យរបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់ (អភ ១, ៩)។ តាមគម្រោងនេះ មនុស្សលោកអាចចូលទៅកាន់ព្រះបិតាបាន ដោយសារព្រះគ្រីស្ត ជាព្រះបន្ទូលប្រសូតជាមនុស្ស និងដោយរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង មនុស្សក៏រួមចំណែកក្នុងសភាពរបស់ព្រះជាម្ចាស់ផ្ទាល់ដែរ (អភ ២, ១៨; ២សល ១, ៤)។ ព្រះជាម្ចាស់ដែលមនុស្សមើលមិនឃើញ (កូឡ ១, ១៥; ១ធម ១, ១៧) សម្ដែងព្រះអង្គឲ្យមនុស្សលោកស្គាល់ គឺព្រះអង្គប្រកបដោយព្រះហឫ ទ័យ ស្រឡាញ់ដ៏ទូលំទូលាយ ទ្រង់មានព្រះបន្ទូលមករកមនុស្ស ដូចជាមករកមិត្តសម្លាញ់ (ដណ ៣៣, ១១; យហ ១៥, ១៤-១៥) ព្រះអង្គសន្ទនាជាមួយពួកគេ (បារ ៣, ៣៨) អញ្ជើញគេឲ្យរួមរស់ជាមួយ និងប្រោសរំលែកព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យគេ។ ព្រះអង្គសម្ដែងព្រះអង្គ ដោយសារព្រឹត្តិការណ៍ និងព្រះបន្ទូលដែលភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធ។ ហេតុនេះ ស្នាព្រះហស្តដែលព្រះជាម្ចាស់បានប្រព្រឹត្តតាមប្រវត្តិនៃការសង្គ្រោះ បានបញ្ជាក់ និងពង្រឹងទាំងលទ្ធិ ទាំងអត្ថន័យដែលព្រះបន្ទូលថ្លែង។ រីឯព្រះបន្ទូលវិញ ក៏ប្រកាសអំពីស្នាព្រះហស្តទាំងនោះ និងបកស្រាយគម្រោងការដ៏អស្ចារ្យ ដែលកប់ទុកក្នុងស្នាព្រះហស្តទាំងនោះដែរ។ របៀបព្រះជាម្ចាស់សម្ដែងព្រះអង្គនេះ គឺបង្ហាញសេចក្ដីពិតដ៏ជ្រាលជ្រៅអំពីព្រះជាម្ចាស់ និងអំពីការសង្គ្រោះរបស់មនុស្ស។ សេចក្ដីពិតចាំងពន្លឺក្នុងអង្គព្រះគ្រីស្តសម្រាប់យើង គឺព្រះគ្រីស្តជាស្ពានមេត្រីផង និងបំពេញសេចក្ដីទាំងអស់ដែលព្រះជាម្ចាស់សម្ដែងឲ្យបានពេញលក្ខណៈ។

### ៣-ការរៀបចំមាគ៌ាជូនដំណឹងល្អ

ព្រះជាម្ចាស់ប្រតិស្ឋាន (យហ ១, ៣) និងថែរក្សាអ្វីៗទាំងអស់ឲ្យបានគង់វង្សដោយសារព្រះបន្ទូល។ ព្រះអង្គមិនឈប់ឈរប្រទានសក្ខីភាពអំពីព្រះអង្គ តាមរយៈសត្វលោកទាំងអស់ដែលព្រះអង្គបានប្រតិស្ឋានមកនោះ (រម ១, ១៩-២០)។ ព្រះអង្គក៏សព្វព្រះហឫទ័យ បើកមាគ៌ានៃការសង្គ្រោះដ៏ប្រសើរជាង ទើបទ្រង់បានសម្ដែងព្រះអង្គផ្ទាល់តាំងពីដើមដំបូងបង្អស់ឲ្យឪពុកម្ដាយដើមស្គាល់។ បន្ទាប់ពីឪពុកម្ដាយដើមបានប្រព្រឹត្តអំពើបាប ព្រះអង្គប្រោសឲ្យគេងើបឡើងវិញ ដោយមានព្រះបន្ទូលសន្យាថានឹងរំដោះគេ ដើម្បីឲ្យគេមានសេចក្ដីសង្ឃឹមថានឹងទទួលការសង្គ្រោះ (កណ ៣, ១៥)។ ព្រះអង្គនៅតែថែទាំមនុស្សជាតិដោយឥតឈប់ឈរ ដើម្បីប្រោសប្រទានជីវិតអស់កល្បជានិច្ច ដល់អស់អ្នកដែលស្វែងរកការសង្គ្រោះនេះ ដោយព្យាយាមប្រព្រឹត្តអំពើល្អ (រម ២, ៦-៧)។ ព្រះអង្គត្រាស់ហៅលោកអាប្រាហាំ តាមពេលកំណត់ ដើម្បីបង្កើតប្រជាជនមួយដ៏ធំដោយសារលោក (កណ ១២, ២)។ បន្ទាប់ពីអស់បុព្វបុរស ព្រះអង្គអប់រំប្រជាជននេះ ដោយសារលោកម៉ូសេ និងអស់លោកព្យាការីទាំងឡាយ ដើម្បីឲ្យប្រជាជនទទួលស្គាល់ថា ព្រះអង្គពិតជាព្រះជាម្ចាស់តែមួយព្រះអង្គគត់ដែលមានព្រះជន្មគង់នៅ និងជាព្រះដ៏ពិតប្រាកដជាព្រះបិតាដែលផ្គត់ផ្គង់មនុស្សលោក ហើយជា

ចៅក្រមដ៏សុចរិត។ ព្រះអង្គក៏អប់រំប្រជាជននោះ ឲ្យទន្ទឹងរង់ចាំព្រះសង្គ្រោះ តាមព្រះបន្ទូលសន្យា ទាំងរៀបចំមាគ៌ាតាមរបៀបនេះ ជូនដំណឹងល្អតាមដំណើរសតវត្សនានា។

## ៤-ព្រះគ្រីស្ដបំពេញការសម្ដែងព្រះជាម្ចាស់

"នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូល មកកាន់បុព្វបុរសយើងជាច្រើនលើកច្រើនសា ដោយប្រើរបៀបផ្សេងៗជាច្រើន តាមរយៈអស់លោកព្យាការី។ នៅគ្រានេះ ជាគ្រាចុងក្រោយបំផុត ព្រះអង្គមានព្រះបន្ទូលមកយើង តាមរយៈព្រះបុត្រា" (ហប ១, ១-២)។ ព្រះអង្គចាត់ព្រះបុត្រាជាព្រះបន្ទូល ដែលមានព្រះជន្មអស់កល្បជានិច្ច ហើយដែលបំភ្លឺមនុស្សគ្រប់ៗគ្នា ដើម្បីឲ្យព្រះបុត្រាគង់នៅជាមួយមនុស្សលោក និងសម្ដែងការអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ឲ្យគេស្គាល់ (យហ ១, ១-១៨)។ ហេតុនេះ ព្រះយេស៊ូគ្រីស្ដជា *"ព្រះបន្ទូលប្រសូតជាមនុស្ស" "ជាមនុស្សដែលព្រះបិតាចាត់ឲ្យមករកមនុស្សលោក" "ថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់"* (យហ ៣, ៣៤) ទ្រង់បង្ហើយកិច្ច សង្គ្រោះ ដែលព្រះបិតាបានផ្ញើឲ្យព្រះអង្គប្រព្រឹត្ត (យហ ៥,៣៦; ១៧,៤)។ ហេតុនេះ អ្នកដែលឃើញព្រះគ្រីស្ដ ក៏ឃើញព្រះបិតាដែរ (យហ ១៤, ៩)។ ពេលព្រះយេស៊ូរស់នៅជាមួយមនុស្សលោក ទ្រង់បង្ហាញព្រះអង្គផ្ទាល់តាម ព្រះបន្ទូលនិងតាមកិច្ចការតាមទីសម្គាល់និងតាមការអស្ចារ្យ ហើយជាពិសេសដោយទ្រង់សោយទិវង្គត ហើយក្រោកឡើងពី ចំណោមមនុស្សស្លាប់ និងមានព្រះជន្មថ្មីដ៏រុងរឿង។ នៅទីបញ្ចប់ ទ្រង់ចាត់ព្រះវិញ្ញាណនៃសេចក្ដីពិត។ ដោយព្រះគ្រីស្ដប្រព្រឹត្តការទាំងនោះ ព្រះអង្គបង្ហើយ និងបង្គ្រប់សេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងអំពីព្រះអង្គផ្ទាល់ ព្រះគ្រីស្ដ ក៏បញ្ជាក់ពីការសម្ដែងព្រះជាម្ចាស់នេះដែរ។ ព្រះគ្រីស្ដក្នុងឋានៈជាព្រះជាម្ចាស់បញ្ជាក់ទៀតថា ព្រះជាម្ចាស់ផ្ទាល់គង់នៅជាមួយយើង ដើម្បីដកយើងឲ្យរួចផុតពីភាពងងឹតនៃអំពើបាប និងនៃសេចក្ដីស្លាប់ ព្រមទាំងទ្រង់ប្រោសឲ្យយើងក្រោកឡើង និងទទួលព្រះជន្មដែលស្ថិតនៅអស់កល្បជានិច្ច។

ការចាត់ចែងការសង្គ្រោះ ដោយសារព្រះគ្រីស្ដបែបនេះ ពិតជាសម្ពន្ធមេត្រីថ្មីចុងក្រោយបំផុត ដែលមិនត្រូវកន្លងផុតទៅទេ។ មនុស្សយើងក៏មិនត្រូវរង់ចាំព្រះជាម្ចាស់ សម្ដែងព្រះអង្គសារជាថ្មី ជាសាធារណៈទៀតដែរ រហូតដល់ពេលព្រះយេស៊ូគ្រីស្ដជាអម្ចាស់នៃយើង នឹងសម្ដែងព្រះអង្គយ៉ាងរុងរឿង (១ធម ៦, ១៤ និង ទត ២, ១៣)។

## ៥-ត្រូវទទួលសេចក្ដីដែលព្រះជាម្ចាស់សម្ដែងនេះ ដោយផ្ញើជីវិតលើព្រះអង្គ

មនុស្សយើងត្រូវតែ *"គោរពប្រណិប័តន៍ព្រះជាម្ចាស់ដោយផ្ញើជីវិតលើព្រះអង្គ"* ដែលសម្ដែងព្រះអង្គ (រម ១៦, ២៦ ; រម ១, ៥; ២ករ ១០, ៥-៦)។ ដោយសារជំនឿ មនុស្សផ្ញើជីវិតទាំងស្រុង និងដោយសេរីទៅលើព្រះជាម្ចាស់ គឺគេ "យកប្រាជ្ញានិងបំណងទាំងស្រុងរបស់ខ្លួន មកគោរពប្រណិប័តន៍ព្រះជាម្ចាស់ដែលសម្ដែងព្រះអង្គ"។ អ្នកជឿក៏សម្រេចចិត្តទទួលសេចក្ដីដែលព្រះអង្គសម្ដែងនោះថែមទៀតផង។ ព្រះជាម្ចាស់ត្រូវតែប្រណីសន្ដោសគេ ជួយបំភ្លឺចិត្តមនុស្សជាមុនសិន ទើបគេអាចផ្ញើជីវិតលើព្រះអង្គបាន ព្រមទាំងដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធជួយគេពីខាងក្នុង គឺព្រះវិញ្ញាណប្រោសឲ្យគេរំភើបចិត្ត និងប្រែចិត្តគេទៅរកព្រះជាម្ចាស់ ព្រះវិញ្ញាណក៏បើកភ្នែកនៃវិញ្ញាណរបស់គេ និងប្រទានឲ្យ *"អស់អ្នកជឿមានចិត្តកក់ក្ដៅ ដោយយល់ស្របនិងសុខចិត្តជឿសេចក្ដីពិត"*។ ព្រះវិញ្ញាណដ៏វិសុទ្ធ នៅតែប្រោសឲ្យជំនឿនេះបានកាន់តែប្រសើរឡើងៗ ដោយព្រះអង្គប្រទានព្រះអំណោយទានផ្សេងៗ ដើម្បីឲ្យគេយល់កាន់តែជ្រៅនូវសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងមកនោះ។

## ៦-ប្រាជ្ញាមនុស្សអាចស្គាល់សេចក្តីខ្លះអំពីព្រះជាម្ចាស់បាន

ព្រះជាម្ចាស់សព្វព្រះហឫទ័យសម្តែងព្រះអង្គ និងចែករំលែកព្រះជន្មព្រះអង្គ ព្រមទាំងបង្ហាញនិងប្រកាសក្រឹត្យវិន័យ ដែលស្ថិតនៅអស់កល្បជានិច្ច ស្តីអំពីព្រះហឫទ័យរបស់ព្រះអង្គដែលចង់សង្គ្រោះមនុស្សលោក គឺ *"ព្រះអង្គសព្វព្រះហឫទ័យចែក រំលែកសម្បត្តិរបស់ព្រះអង្គឲ្យមនុស្សលោក ជាសម្បត្តិហួសពីសមត្ថភាពនៃប្រាជ្ញារបស់មនុស្ស អាចគិតយល់បាន"*។

មហាសន្និបាតដ៏វិសុទ្ធប្រកាសថា *"ដោយសារប្រាជ្ញារបស់ខ្លួន មនុស្សមានសមត្ថភាពអាចស្គាល់ព្រះជាម្ចាស់យ៉ាងជាក់ច្បាស់ តាមរយៈសត្វលោកដែលព្រះអង្គបានប្រតិស្ឋានមក ព្រោះព្រះអង្គជាដើមកំណើតនិងជាចុងបំផុតនៃអ្វីៗទាំងអស់"* (រម ១, ២០)។ ប៉ុន្តែ មហាសន្និបាតបង្រៀនទៀតថា ទោះបីជាមនុស្សមានសមត្ថភាពអាចស្គាល់ សេចក្តីខ្លះអំពីព្រះជាម្ចាស់ តាមប្រាជ្ញារបស់ខ្លួនបានក្តី ក៏ប៉ុន្តែ ក្នុងសភាពការណ៍បច្ចុប្បន្ននៃមនុស្សជាតិ ព្រះអង្គបានសម្តែងសេចក្តីទាំងនោះ *"ដើម្បីឲ្យមនុស្សលោកស្គាល់យ៉ាងស្រួល យ៉ាងជាក់ច្បាស់ ដោយមិនវង្វេងត្រង់ណាឡើយ"*។

# ជំពូក ២

## ការបញ្ជូនបន្ត
## សេចក្តីដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់

### ៧- ក្រុមគ្រីស្តទូត និងអ្នកបន្តមុខងាររបស់អស់លោក ជាអ្នកប្រកាសដំណឹងល្អ

ព្រះជាម្ចាស់បានសម្តែងព្រះអង្គ ដើម្បីសង្គ្រោះមនុស្សគ្រប់ជាតិសាសន៍។ ដោយព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរសយ៉ាងខ្លាំង ព្រះអង្គក៏ចាត់ចែងឲ្យសេចក្តីដែលព្រះអង្គបានសម្តែងនោះ ស្ថិតនៅគង់វង្សឥតប្រែប្រួល និងត្រូវឲ្យគេបញ្ជូនបន្តទៅមនុស្សនៅគ្រប់ជំនាន់ ក្រោយតទៅទៀត។ ហេតុនេះហើយ បានជាព្រះគ្រីស្តជាអម្ចាស់ ដែលបង្គ្រប់សេចក្តីគ្រប់បែបយ៉ាង ដែលព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតសម្តែងនោះ (២ករ ១, ៣០; ៣, ១៦-៤, ៦) ទ្រង់ក៏បានប្រកាសដំណឹងល្អដោយផ្ទាល់ព្រះឱស្ឋ និងធ្វើឲ្យដំណឹងល្អនេះកើតជារូបរាង ដោយព្រះអង្គផ្ទាល់ ជាដំណឹងល្អដែលអស់លោកព្យាការីបានសន្យាទុកកាលពីមុនមកនោះ។ បន្ទាប់មក ព្រះគ្រីស្តបញ្ជាឲ្យក្រុមគ្រីស្តទូតប្រកាសដំណឹងល្អនេះឲ្យមនុស្សទាំងអស់ ទុកជាប្រភពនៃសេចក្តីពិតគ្រប់យ៉ាង ដែលអាចសង្គ្រោះគេបាន និងទុកជាក្បួននៃសីលធម៌គ្រប់យ៉ាងដែរ ដោយប្រទានព្រះអំណោយទានផ្សេងៗទៀតផង។ អស់លោកប្រព្រឹត្តតាមព្រះបញ្ជានេះយ៉ាងស្មោះ គឺម្យ៉ាងក្រុមគ្រីស្តទូតបញ្ជូនបន្តសេចក្តី ដែលគេបានរៀនដោយស្តាប់ព្រះបន្ទូលព្រះគ្រីស្តផ្ទាល់ ដោយរស់នៅជាមួយព្រះអង្គ និងដោយឃើញកិច្ចការដែលព្រះអង្គប្រព្រឹត្ត ព្រមទាំងបញ្ជូនបន្តសេចក្តី ដែលព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺអស់លោកឲ្យដឹងទៀតផង។ អស់លោកបញ្ជូនបន្តសេចក្តីទាំងនោះ ដោយប្រកាសដំណឹងល្អ ដោយធ្វើជាគំរូល្អដល់គេឬដោយចាត់ចែងស្ថាប័នផ្សេងៗទៀតផង។ ម្យ៉ាងវិញទៀត ក្រុមគ្រីស្តទូតឬអ្នកដែល រស់នៅជាមួយក្រុមគ្រីស្តទូត បានកត់ត្រាទុកជាលាយ លក្ខណ៍អក្សរនូវសារស្តីអំពីការសង្គ្រោះ ដោយមានព្រះវិញ្ញាណដ៏ វិសុទ្ធដដែលនេះ បំភ្លឺចិត្តគំនិតគេឲ្យសរសេរផង។

ប៉ុន្តែ ក្រុមគ្រីស្តទូតបានតែងតាំងអភិបាលឲ្យបន្តមុខងារពីអស់លោក ដើម្បីរក្សាទុកដំណឹងល្អនេះឲ្យនៅគង់វង្សជានិច្ចមិនប្រែប្រួលឡើយ និងឲ្យមានជីវិតរស់រវើកក្នុងព្រះសហគមន៍។ ក្រុមគ្រីស្តទូតបាន *"ផ្ញើមុខងារបង្រៀនរបស់ខ្លួនឲ្យអភិបាលទាំងនោះ"*។ ហេតុនេះការបញ្ជូនបន្តដ៏វិសុទ្ធនេះ និងព្រះគម្ពីរនៃសម្ពន្ធមេត្រីទាំងពីរ ប្រៀបដូចជាកញ្ចក់មួយសម្រាប់ឲ្យព្រះសហគមន៍ឆ្លុះមើលព្រះជាម្ចាស់ទាំងស្មឹងស្មាធិ៍ នៅពេលធ្វើដំណើរទៅ នាលោកនេះ គឺព្រះសហគមន៍ទទួលអ្វីៗទាំងអស់ពីព្រះអង្គ ទម្រាំព្រះអង្គប្រោសឲ្យឃើញព្រះភ័ក្ត្រផ្ទាល់របស់ព្រះអង្គ ព្រះអង្គមានភាពយ៉ាងណា ព្រះសហគមន៍នឹងឃើញ យ៉ាងនោះដែរ (១យហ ៣, ២)។

### ៨- ការបញ្ជូនបន្តដ៏វិសុទ្ធ

ហេតុនេះហើយ បានជាសេចក្តីដែលក្រុមគ្រីស្តទូតបានប្រកាស មានកត់ត្រាទុកយ៉ាងពិសេសក្នុងព្រះគម្ពីរ ដោយព្រះវិញ្ញាណបំភ្លឺអ្នកនិពន្ធ ហើយត្រូវរក្សាទុកតៗគ្នាកុំឲ្យដាច់ នៅគង់រហូតដល់អវសានកាលនៃពិភពលោក។ ក្រុមគ្រីស្ត

ទូតបានបញ្ជូនបន្តនូវសេចក្តី ដែលអស់លោកបានទទួលដោយផ្ទាល់ ហើយដាស់តឿនគ្រីស្តបរិស័ទឲ្យរក្សាទុកសេចក្តីដែលគេទទួលយក ដោយស្តាប់ ឬដោយទទួលជាលាយលក្ខណ៍អក្សរ (២ថស ២, ១៥)។ អស់លោកដាស់តឿនគ្រីស្តបរិស័ទ ឲ្យតយុទ្ធដើម្បីជំនឿ ដែលគេបានទទួលម្តងជាស្រេច (យដ ៣)។ រីឯសេចក្តី ដែលគ្រីស្តបរិស័ទទទួលពីក្រុមគ្រីស្តទូតបញ្ជូនបន្តមក មានអ្វីៗទាំងប៉ុន្មានដែលអាចជួយណែនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ឲ្យរស់នៅយ៉ាងវិសុទ្ធ និងដែលអាចជួយពង្រីកជំនឿរបស់គេ។ ដូច្នេះ ដោយព្រះសហគមន៍ បង្រៀនលទ្ធិដោយរស់នៅតាមជំនឿ និងដោយធ្វើពិធីគោរពបម្រើព្រះជាម្ចាស់ ព្រះសហគមន៍បញ្ជូនបន្តលក្ខណៈសម្បត្តិរបស់ខ្លួន និងអ្វីៗដែលខ្លួនជឿឲ្យមនុស្សគ្រប់ជំនាន់តទៅទៀតផង។

ការបញ្ជូនបន្តមកពីក្រុមគ្រីស្តទូតនោះ ក៏នៅតែមានបន្តក្នុងព្រះសហគមន៍សព្វថ្ងៃ ក្រោមការឧបត្ថម្ភនៃព្រះវិញ្ញាណដ៏វិសុទ្ធដែរ គឺគ្រីស្តបរិស័ទយល់អ្វីទាំងអស់ និងយល់ព្រះបន្ទូលកាន់តែច្បាស់ឡើងៗ ដោយអ្នកជឿយកព្រះបន្ទូលនេះមកស្មឹងស្មាធិ៍ សិក្សា នឹកសញ្ជឹងក្នុងចិត្តទៀតផង (លក ២, ១៩.៥១)។ ម្យ៉ាងគេយល់អំពីសម្បត្តិសួគ៌កាន់តែច្បាស់ក្នុងជម្រៅចិត្តគេ។ ម្យ៉ាងទៀត គេស្តាប់សេចក្តីអស់លោកអភិបាល ដែលបន្តមុខងារពីក្រុមគ្រីស្តទូតមកតែងតែប្រកាស ព្រោះអស់លោកពិតជាបានទទួលព្រះអំណោយទាននៃសេចក្តីពិត។ ដូច្នេះ ទោះបីសតវត្សចេះតែកន្លងផុតទៅក្តី ក៏ព្រះសហគមន៍ខិតខំស្វែងរកសេចក្តី ពិតដ៏ពេញលេញរបស់ព្រះជាម្ចាស់ជានិច្ច រហូតដល់ពេលព្រះបន្ទូលរបស់ព្រះអង្គកើតជារូបរាងក្នុង ព្រះសហគមន៍ជាស្ថាពរ។

ការប្រៀនប្រដៅរបស់គ្រូបាធ្យាយដ៏វិសុទ្ធ ផ្តល់សក្ខីភាពបញ្ជាក់ថា ការបញ្ជូនបន្តនេះធ្វើឲ្យព្រះសហគមន៍មានជីវិតរស់រវើក។ ការបញ្ជូនបន្តនេះ មានតម្លៃដ៏ថ្លៃថ្នូរ គឺមានឥទ្ធិពលក្នុងការប្រតិបត្តិ និងក្នុងការរស់នៅរបស់ព្រះសហគមន៍ដែលជឿ និងអធិដ្ឋាន។ ការបញ្ជូនបន្តដដែលនេះ នាំឲ្យព្រះសហគមន៍ស្គាល់បញ្ជីកំណត់នៃព្រះគម្ពីរទាំងអស់។ ការបញ្ជូនបន្តដដែលនេះ ធ្វើឲ្យគ្រីស្តបរិស័ទក្នុងព្រះសហគមន៍យល់អំពីអត្ថន័យនៃព្រះគម្ពីរ និងធ្វើឲ្យគម្ពីរនេះបង្កើតផលតទៅជានិច្ច។ ដូច្នេះ ព្រះជាម្ចាស់ដែលមានព្រះបន្ទូលកាលពីដើមមក នៅតែសន្ទនាជាមួយមហេសីនៃព្រះបុត្រាដ៏ជាទីស្រឡាញ់ជានិច្ចនិរន្តរ៍។ ព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើឲ្យសូរសៀងនៃដំណឹងល្អមានជីវិតលាន់ឮក្នុងព្រះសហគមន៍ ហើយក៏លាន់ឮនៅក្នុងពិភពលោកទាំងមូលដោយសារព្រះសហគមន៍ដែរ។ ព្រះវិញ្ញាណក៏ណែនាំអ្នកជឿទាំងប៉ុន្មាន ឲ្យស្គាល់សេចក្តីពិតគ្រប់ជំពូក និងប្រោសឲ្យតម្លៃដ៏ថ្លៃថ្នូរនៃព្រះបន្ទូលរបស់ព្រះគ្រីស្ត ស្ថិតនៅក្នុងគេយ៉ាងបរិបូណ៌ (កូឡ ៣, ១៦)។

## ៩- ការបញ្ជូនបន្ត និងព្រះគម្ពីរពាក់ព័ន្ធគ្នាទៅវិញទៅមក

ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរជាប់ពាក់ព័ន្ធគ្នា និងមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាលជាមួយគ្នា។ ការបញ្ជូនបន្ត និងព្រះគម្ពីរ ផុសចេញមកពីប្រភពតែមួយ ពោលគឺពីព្រះជាម្ចាស់។ គម្ពីរនិងការបញ្ជូនបន្ត ក៏ហាក់ដូចជារួមជាធ្លុងតែមួយ និងមានទិសដៅតែមួយដែរ។ ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលកត់ត្រាទុកជាលាយលក្ខណ៍អក្សរដោយព្រះវិញ្ញាណបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ រីឯការបញ្ជូនបន្តដ៏វិសុទ្ធវិញ ក៏នាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្តជាអម្ចាស់ និងព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ញើទុកឲ្យក្រុមគ្រីស្តទូត រួចបញ្ជូនបន្តគ្រប់សេចក្តីទាំងអស់ដល់អ្នកបន្តមុខងារពីអស់លោក។ ពេលអស់លោក ដែលបន្តមុខងាររបស់គ្រីស្តទូតទាំងឡាយ នោះប្រកាសព្រះបន្ទូលអស់លោករក្សាទុកបកស្រាយ និងផ្សព្វផ្សាយព្រះបន្ទូលនោះយ៉ាងស្មោះ ដោយព្រះវិញ្ញាណនៃសេចក្តីពិតបំភ្លឺចិត្តគំនិតគេ។ ហេតុនេះហើយបានជាព្រះសហគមន៍ មានជំនឿយ៉ាងជាក់ច្បាស់ទៅលើសេចក្តីទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានសម្តែងមកនោះ ពុំមែន

ដោយសំអាងតែលើព្រះគម្ពីរប៉ុណ្ណោះទេ។ ហេតុនេះ ត្រូវទទួលស្គាល់ និងលើកតម្កើង ការបញ្ជូនបន្ត និងព្រះគម្ពីរ ដោយចិត្តស្រឡាញ់និងគោរពស្មើគ្នា។

## ១០-ការបញ្ជូនបន្តព្រះគម្ពីរ និងការណែនាំព្រះសហគមន៍

ការបញ្ជូនបន្តដ៏វិសុទ្ធនិងព្រះគម្ពីរ ជាបញ្ញើដ៏សក្ការៈតែមួយនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលផ្ញើទុកឲ្យព្រះសហគមន៍។ បើប្រជាជនដ៏វិសុទ្ធទាំងមូល រួបរួមជាមួយអស់គង្វាលរបស់ខ្លួន ភ្ជាប់ចិត្តទៅនឹងបញ្ញើនេះ គេមុខជា នឹងនៅតែព្យាយាមជានិច្ចស្ដាប់ការប្រៀនប្រដៅរបស់ក្រុមគ្រីស្ដទូត រួបរួមគ្នាទុកជាបងប្អូន ធ្វើពិធីកាច់នំប៉័ងនិងអធិដ្ឋាន (កក ២, ៤២)។ ហេតុនេះហើយ បានជាអស់គង្វាលនិងអស់អ្នកជឿ រួមគ្នាជាចិត្តគំនិតតែមួយយ៉ាងស្អិតរមួតក្នុងកិច្ចរក្សាជំនឿដែលគេបានទទួល ក្នុងកិច្ចប្រតិបត្តិតាមជំនឿ និងក្នុងការប្រកាសជំនឿដែលគេទទួលតមក។

ព្រះជាម្ចាស់ បានផ្ញើបន្ទុកបកស្រាយព្រះបន្ទូលរបស់ព្រះអង្គយ៉ាងពិតប្រាកដ ទោះបីជាព្រះបន្ទូលកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្ដី ឬបញ្ជូនបន្តមកក្ដី ឲ្យការណែនាំដែលមានជីវិតក្នុងព្រះសហគមន៍ អាចបកស្រាយបាន។ មានតែការណែនាំនោះប៉ុណ្ណោះ ដែលមានអំណាចបកស្រាយក្នុងព្រះនាមព្រះយេស៊ូគ្រីស្ដ។ ប៉ុន្តែការណែនាំនេះ គ្មានអំណាចលើសពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ទេ តែបម្រើព្រះបន្ទូលទៅវិញ។ ការណែនាំក៏បង្រៀនតែសេចក្ដី ដែលគេបានទទួលតមក ហើយស្ដាប់ព្រះបន្ទូលនេះដោយចិត្តស្រឡាញ់ តាមបញ្ជារបស់ព្រះជាម្ចាស់ និង ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង។ ការណែនាំថែរក្សាព្រះបន្ទូលយ៉ាងល្អបំផុត និងពន្យល់ព្រះបន្ទូលយ៉ាងត្រឹមត្រូវ ហើយស្រង់យកពីបញ្ញើនៃជំនឿតែមួយនេះ នូវអ្វីៗទាំងប៉ុន្មាន ដែលក្រុមណែនាំជូនឲ្យគ្រីស្ដបរិស័ទជឿ ទុកជាសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់។

ដូច្នេះ យើងឃើញជាក់ច្បាស់ថា ការបញ្ជូនបន្តដ៏វិសុទ្ធ និងព្រះគម្ពីរ ហើយនិងការណែនាំព្រះសហគមន៍ជាប់ពាក់ព័ន្ធគ្នា និងរួមគ្នាតាមព្រះជាម្ចាស់ចាត់ចែងយ៉ាងឈ្លាសវៃ។ ក្នុងកត្តាទាំងបីនេះ គ្មានអ្វីណាមួយដែលអាចស្ថិតស្ថេរដោយឯកឯងបានទេ គឺអ្វីទាំងបីនោះរួមគ្នាយ៉ាងសកម្ម ដើម្បីសង្គ្រោះមនុស្សលោក តាមរបៀបរៀងៗខ្លួន ក្រោមការឧបត្ថម្ភនៃព្រះវិញ្ញាណដ៏វិសុទ្ធតែមួយព្រះអង្គ។

# ជំពូក ៣

## ព្រះជាម្ចាស់បំភ្លឺអ្នកនិពន្ធព្រះគម្ពីរ និងការបកស្រាយព្រះគម្ពីរ

### ១១- ព្រះគម្ពីរមកពីព្រះវិញ្ញាណបំភ្លឺចិត្តគំនិតអ្នកនិពន្ធ

ព្រះវិញ្ញាណដ៏វិសុទ្ធ បានបំភ្លឺចិត្តគំនិតអ្នកនិពន្ធ ឲ្យកត់ត្រាទុកជាលាយលក្ខណ៍អក្សរ នូវសេចក្តីពិត ដែលព្រះជាម្ចាស់បានសម្តែងមក ហើយដែលមានរៀបរាប់ក្នុងកណ្ឌទាំងប៉ុន្មាននៃព្រះគម្ពីរ។ ព្រះសហគមន៍កាតូលិកជាមាតារបស់យើង សំអាងទៅលើជំនឿរបស់ក្រុមគ្រីស្តទូតជាគ្រឹះ ហើយចាត់គ្រប់ផ្នែកនៃកណ្ឌទាំងប៉ុន្មាន ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ក្តី សម្ពន្ធមេត្រីថ្មីក្តី ទុកជាសក្ការៈនិងទុកជាសាសនបញ្ញត្តិរបស់ខ្លួន ព្រោះព្រះវិញ្ញាណបំភ្លឺចិត្តគំនិតអ្នកនិពន្ធឲ្យសរសេរ (យហ ២០,៣១; ២ ធម ៣, ១៦; ២សល ១,១៩-២១) គឺព្រះជាម្ចាស់បាននិពន្ធកណ្ឌទាំងនោះ ហើយព្រះសហគមន៍ក៏បានទទួលកណ្ឌគម្ពីរទាំងនោះដោយយល់ដូច្នោះដែរ។ ព្រះជាម្ចាស់បានជ្រើសរើសមនុស្សខ្លះ ដើម្បីនិពន្ធកណ្ឌ ព្រះគម្ពីរទាំងនោះ គឺព្រះអង្គឲ្យអ្នកទាំងនោះ ប្រើចំណេះប្រាជ្ញា ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនយ៉ាងពិតប្រាកដ ហើយទ្រង់មានសកម្មភាពក្នុងអ្នកទាំងនោះ និងដោយសារអ្នកទាំងនោះ ព្រះអង្គឲ្យគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរ នូវសេចក្តីទាំងប៉ុន្មាន ដែលព្រះអង្គសព្វព្រះហឫទ័យឲ្យគេសរសេរ គឺសរសេរតែសេចក្តីណាដែលព្រះអង្គសព្វព្រះហឫទ័យប៉ុណ្ណោះ។ ដូច្នេះ គេជាអ្នកនិពន្ធយ៉ាងពិតប្រាកដ។ (ហប ១, ១ និង ៤, ៧; ២សម ២៣, ២; មថ ១, ២២)។

ហេតុនេះហើយ បានជាត្រូវរាប់សេចក្តីទាំងអស់ដែលអ្នកនិពន្ធ និងអ្នកតំណាលរឿងនិទានបានកត់ត្រានោះ ទុកជាសេចក្តីដែលព្រះវិញ្ញាណបានបញ្ជាក់ ព្រោះព្រះវិញ្ញាណបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធ។ យើងក៏ត្រូវតែប្រកាសថា ក្នុងកណ្ឌគម្ពីរ មានបង្រៀនយ៉ាងប្រាកដប្រជា យ៉ាងត្រឹមត្រូវ ដោយគ្មានកំហុសនូវសេចក្តីពិត ដែលព្រះជាម្ចាស់ សព្វព្រះហឫទ័យឲ្យគេកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្នុងព្រះគម្ពីរ សម្រាប់សង្គ្រោះយើង។ ហេតុនេះ *"គ្រប់អត្ថបទគម្ពីរសុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យនិពន្ធ និងមានប្រយោជន៍សម្រាប់បង្រៀន រកខុសត្រូវកែតម្រង់ និងអប់រំឲ្យរស់នៅតាមសេចក្តីសុចរិត ក្នុងគោលបំណងឲ្យអ្នកបម្រើរបស់ព្រះជាម្ចាស់មានសមត្ថភាព និងប្រុងប្រៀបខ្លួនជាស្រេច ដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក។"* (២ធម ៣, ១៦-១៧)។

### ១២- របៀបបកស្រាយព្រះគម្ពីរ

ក្នុងព្រះគម្ពីរព្រះជាម្ចាស់ ពិតជាមានព្រះបន្ទូលតាមរយៈមនុស្ស និងបានប្រើពាក្យសម្តីរបស់មនុស្ស។ ហេតុនេះ អ្នកបកស្រាយព្រះគម្ពីរ ត្រូវស្វែងរកដោយពិនិត្យពិច័យ នូវសេចក្តីដែលអ្នកនិពន្ធទាំងនោះ មានបំណងនិយាយប្រាប់ និងសេចក្តីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យសម្តែងតាមរយៈពាក្យរបស់គេ។ ធ្វើដូច្នេះ អ្នកបកស្រាយនឹងដឹងច្បាស់ នូវសេចក្តីដែលព្រះជាម្ចាស់ផ្ទាល់ សព្វព្រះហឫទ័យសម្តែងឲ្យយើងស្គាល់នោះ។

ក្នុងគោលបំណងចង់ស្គាល់គំនិតរបស់អ្នកនិពន្ធ អ្នកបកស្រាយត្រូវចាប់អារម្មណ៍នឹងប្រការផ្សេងៗ មាន *"របៀប*

*និពន្ធ"* ឬ *"រចនាបទអក្សរសិល្ប"* ជាដើម។ អស់លោកបង្ហាញសេចក្ដីពិតតាមរបៀបផ្សេងៗពីគ្នា ក្នុងអត្ថបទរៀបរាប់អំពីប្រវត្តិសាស្ត្រក្នុងសេចក្ដីប្រកាសរបស់ព្យាការី ក្នុងពាក្យកាព្យ ឬក្នុងអត្ថបទនិពន្ធតាមរបៀបផ្សេងៗទៀត។ ហេតុនេះហើយ អ្នកបកស្រាយត្រូវស្វះស្វែងរកសេចក្ដី ដែលអ្នកនិពន្ធចង់ប្រាប់ និងបានប្រាប់ហើយ តាមកាលៈទេសៈ តាមសភាពការណ៍នៃសម័យរបស់គាត់រស់នៅ តាមអារ្យធម៌ និងតាមវប្បធម៌របស់គាត់ ព្រមទាំងតាមរបៀបនិពន្ធ ដែលអ្នកស្រុកធ្លាប់ប្រើនៅជំនាន់នោះ។ អ្នកបកស្រាយត្រូវយល់យ៉ាងច្បាស់អំពីរបៀបដែល អ្នកស្រុកតែងគិតគូរជាទូទៅអំពីជីវិត អំពីរបៀបដែលគេធ្លាប់និយាយ ឬការតំណាលនិទានរឿងក្នុងសម័យអ្នកនិពន្ធនោះ ព្រមទាំងអំពីរបៀបដែលមនុស្សរស់នៅតាមកន្លែងផ្សេងៗ នៅសម័យនោះធ្លាប់ប្រើក្នុងការទាក់ទងគ្នាទៅវិញទៅមក។ ធ្វើដូច្នេះ អ្នកបកស្រាយ អាចរកឃើញនូវសេចក្ដី ដែលអ្នកនិពន្ធដ៏សក្ការៈមានបំណងចង់ប្រាប់ ដោយចែងក្ដែជាលាយលក្ខណ៍អក្សរ។

ដោយព្រះវិញ្ញាណបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធ ឲ្យចែងជាលាយលក្ខណ៍អក្សរ ត្រូវអាន និងបកស្រាយព្រះគម្ពីរក្រោមពន្លឺនៃព្រះវិញ្ញាណដែរ។ ត្រូវចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះសេចក្ដីទាំងអស់ដែលមានចែងក្នុងព្រះគម្ពីរទាំងមូល ហើយដែលសម្ដែងសេចក្ដីពិតដដែលដូចគ្នាដែរ។ ត្រូវចាប់អារម្មណ៍អំពីការបញ្ជូនបន្តដ៏រស់រវើក នៃព្រះសហគមន៍ទាំងមូល និងអំពីលក្ខណៈប្រៀបធៀបនៃជំនឿផង។ ធ្វើដូច្នេះ ទើបអ្នកបកស្រាយរកអត្ថន័យដ៏ពិតប្រាកដនៃព្រះគម្ពីរឃើញ។ អ្នកវិភាគគម្ពីរ មានភារកិច្ចខិតខំពិនិត្យពិច័យ និងពន្យល់អត្ថន័យនៃព្រះគម្ពីរឲ្យកាន់តែជ្រៅទៅៗ តាមគោលការណ៍ទាំងនោះ ដើម្បីឲ្យព្រះសហគមន៍មានយោបល់កាន់តែល្អប្រសើរឡើងៗ។ ដោយការសិក្សារបស់ខ្លួន អ្នកវិភាគទាំងនោះដូចជារៀបចំផ្លូវឲ្យព្រះសហគមន៍ អាចកំណត់អត្ថន័យឲ្យកាន់តែច្បាស់ឡើងបាន។ អ្វីៗទាំងអស់ដែលមានទាក់ទិននឹងរបៀបបកស្រាយព្រះគម្ពីរ គឺស្ថិតនៅលើព្រះសហគមន៍ដែលត្រូវរិះគិតពិចារណាដោះស្រាយ ព្រោះព្រះសហគមន៍ទទួលមុខងារបម្រើពីព្រះជាម្ចាស់មក និងក្នុងនាមព្រះអង្គពោលគឺរក្សាទុកនិងបកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់។

## ១៣- ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា

ហេតុនេះ ទោះបីយើងត្រូវតែគោរពសេចក្ដីពិត និងលក្ខណៈដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ជានិច្ចក្ដី ក៏ក្នុងព្រះគម្ពីរព្រះអង្គសម្ដែងព្រះហឫទ័យមេត្តាករុណា យ៉ាងអស្ចារ្យនៃព្រះប្រាជ្ញាញាណ ដែលស្ថិតនៅអស់កល្បជានិច្ច *"ដើម្បីឲ្យយើងស្គាល់ព្រះហឫទ័យសប្បុរសរបស់ព្រះជាម្ចាស់ ដែលរកថ្លែងពុំបាន និងដឹងថាព្រះអង្គមានព្រះបន្ទូល ស្របតាមរបៀបមនុស្សយើងនិយាយ ព្រោះព្រះអង្គណែនាំនិងថែទាំមនុស្សជាតិយើងជាមុន"*។

# ជំពូក ៤

# គម្ពីរសម្ពន្ធមេត្រីចាស់

## ១៤- ប្រវត្តិសាស្ត្រនៃការសង្គ្រោះក្នុងកណ្ឌគម្ពីរនៃសម្ពន្ធមេត្រីចាស់

ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យស្រឡាញ់អាណិតមនុស្សលោកហួសប្រមាណ ព្រះអង្គគ្រោងទុក និងរៀបចំការសង្គ្រោះគេ ទើបព្រះអង្គជ្រើសរើសប្រជាជនមួយ ដើម្បីផ្ញើព្រះបន្ទូលសន្យាតាមការចាត់ចែងយ៉ាងពិសេសរបស់ព្រះអង្គ។ បន្ទាប់ពីព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយលោកអាប្រាហាំ (កណ ១៥, ១៨) និងជាមួយប្រជាជនអ៊ីស្រាអែលដោយសារលោកម៉ូសេមក (ដណ ២៤, ៨) ព្រះអង្គក៏សម្តែងព្រះអង្គដោយមានព្រះបន្ទូល និងដោយប្រព្រឹត្តកិច្ចការផ្សេងៗ ឲ្យប្រជាជនដែលទ្រង់បានជ្រើសរើសនោះដឹងថា ព្រះអង្គជាព្រះជាម្ចាស់តែមួយព្រះអង្គគត់ ដ៏ពិតប្រាកដ និងដែលមានព្រះជន្មគង់នៅ។ ដូច្នេះ ប្រជាជនអ៊ីស្រាអែលមានបទពិសោធន៍អំពី *"មាគ៌ា"* របស់ព្រះជាម្ចាស់ ដែលយាងមករកមនុស្សលោក។ ដោយព្រះជាម្ចាស់ មានព្រះបន្ទូលផ្ទាល់ព្រះអង្គ តាមរយៈអស់លោកព្យាការី ប្រជាជនអ៊ីស្រាអែល ក៏យល់មាគ៌ាទាំងនោះកាន់តែច្បាស់ឡើងៗ និងកាន់តែជ្រៅទៅៗជារៀងរាល់ថ្ងៃ ព្រមទាំងផ្តល់សក្ខីភាពពីព្រះអង្គកាន់តែខ្លាំងឡើងៗក្នុងចំណោមប្រជាជាតិនានា (ទន ២១, ២៨-២៩; ៩៥, ១-៣; អស ២, ១-៤; យរ ៣, ១៧)។ ការចាត់ចែងការសង្គ្រោះ ដែលព្រះអង្គប្រទានដំណឹងជាមុន និងដែលអ្នកនិពន្ធព្រះគម្ពីរបាននិទានតំណាល ហើយពន្យល់នោះ លេចចេញមកក្នុងកណ្ឌទាំងប៉ុន្មាន នៃគម្ពីរសម្ពន្ធមេត្រីចាស់ ទុកជាព្រះបន្ទូលដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ បានជាកណ្ឌគម្ពីរនៃសម្ពន្ធមេត្រីចាស់ ដែលព្រះជាម្ចាស់បំភ្លឺចិត្តគំនិតអ្នកនិពន្ធ ឲ្យចែងនោះ នៅតែមានតម្លៃដ៏ថ្លៃថ្នូរមិនអាចសាបសូន្យបានឡើយ *"ដ្បិតអ្វីៗដែលមានចែងទុកពីមុនមក គឺចែងទុកសម្រាប់អប់រំយើង ដើម្បីឲ្យយើងមានសេចក្តីសង្ឃឹម ដោយគម្ពីរជួយសម្រាលទុក្ខយើង និងឲ្យយើងចេះស៊ូទ្រាំ"* (រម ១៥, ៤)។

## ១៥-គម្ពីរសម្ពន្ធមេត្រីចាស់មានសារៈសំខាន់សម្រាប់គ្រីស្តបរិស័ទ

ព្រះជាម្ចាស់ចាត់ចែងសម្ពន្ធមេត្រីចាស់ ជាពិសេសសម្រាប់រៀបចំផ្លូវថ្វាយព្រះគ្រីស្ត ជាព្រះសង្គ្រោះនៃពិភពលោកយាងមក និងរៀបចំព្រះរាជ្យរបស់ព្រះគ្រីស្ត ព្រះអង្គក៏ប្រទានដំណឹងជាមុនតាមរបៀបព្យាការីអំពីព្រះគ្រីស្តយាងមកនោះ (លក ២៤, ៤៤; យហ ៥, ៣៩; ១សល ១, ១០) ព្រមទាំងផ្តល់និមិត្តសញ្ញាផ្សេងៗ ជាប្រផ្នូលអំពីព្រះគ្រីស្តថែមទៀតផង (១ករ ១០, ១១)។ ព្រះជាម្ចាស់ឈ្វេងយល់ដល់សភាពការណ៍មនុស្សលោក មុនព្រះគ្រីស្តសង្គ្រោះគេ។ ដូច្នេះ កណ្ឌគម្ពីរនៃសម្ពន្ធមេត្រីចាស់ សម្តែងឲ្យមនុស្សទាំងអស់បានស្គាល់ព្រះជាម្ចាស់ និងស្គាល់សភាពរបស់ខ្លួន ជាមនុស្ស ព្រមទាំងស្គាល់របៀបព្រះអង្គប្រព្រឹត្តចំពោះមនុស្សលោក ដោយព្រះហឫទ័យសុចរិត និងមេត្តាករុណា។ ទោះបីក្នុងកណ្ឌគម្ពីរទាំងនោះ មានចែងសេចក្តីមិនពេញលក្ខណៈដែលត្រូវបាត់ទៅក្តី ក៏កណ្ឌទាំងនោះ បង្ហាញគរុកោសល្យដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ ដែលអប់រំមនុស្សលោក។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទត្រូវទទួលកណ្ឌគម្ពីរទាំងនោះ

ដោយគោរពប្រណិប័តន៍ ព្រោះក្នុងគម្ពីរទាំងនោះមានចែងគំនិតយ៉ាងច្បាស់អំពីព្រះអម្ចាស់ មានបង្រៀនលទ្ធិយ៉ាងជ្រាលជ្រៅអំពីព្រះអង្គ មានចែងអំពីប្រាជ្ញាញាណពោរពេញដោយសប្បុរសធម៌ ចំពោះការរស់នៅរបស់មនុស្សយើង មានចែងពាក្យអធិដ្ឋានមួយចំនួនដ៏មានតម្លៃដ៏ប្រសើរបំផុត។ មិនតែប៉ុណ្ណោះសោត ក្នុងកណ្ឌគម្ពីរទាំងនោះ មានបង្កប់ទុកនូវគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់យើងផង។

## ១៦-គម្ពីរនៃសម្ពន្ធមេត្រីទាំងពីររួមគ្នាជាឆ្អឹងតែមួយ

ព្រះជាម្ចាស់បានបំភ្លឺចិត្តគំនិតអស់អ្នកនិពន្ធកណ្ឌទាំងអស់ នៃគម្ពីរសម្ពន្ធមេត្រីទាំងពីរ ព្រះអង្គក៏ជាអ្នកនិពន្ធព្រះគម្ពីរទាំងមូលដែរ។ ព្រះអង្គក៏ចាត់ចែងគម្ពីរទាំងពីរនោះ តាមព្រះប្រាជ្ញាញាណ គឺបង្កប់ទុកគម្ពីរសម្ពន្ធមេត្រីថ្មី ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ ហើយគម្ពីរសម្ពន្ធមេត្រីចាស់ ក៏ទទួលអត្ថន័យយ៉ាងពេញលេញ ដោយសារគម្ពីរសម្ពន្ធមេត្រីថ្មីដែរ។ ទោះបីព្រះគ្រីស្តចងសម្ពន្ធមេត្រីថ្មី ដោយសារព្រះលោហិតរបស់ព្រះអង្គក្តី (លក ២២, ២០; ១ករ ១១, ២៥) ក៏ព្រះអង្គលើកយកសេចក្តីទាំងប៉ុន្មាន ដែលមានបង្កប់ទុកក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីចាស់ បញ្ចូលក្នុងព្រះបន្ទូលប្រកាសដំណឹងល្អ។ កណ្ឌគម្ពីរសម្ពន្ធ មេត្រីចាស់ទទួល និងបង្ហាញអត្ថន័យយ៉ាងពេញលេញ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី (មថ ៥, ១៧; លក ២៤, ២៧; រម ១៦, ២៥-២៦; ករ ៣, ១៤, ១៤-១៦) ហើយក៏ជួយបំភ្លឺ និងពន្យល់កណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មីទៀតផង។

# ជំពូក ៥

## គម្ពីរសម្ពន្ធមេត្រីថ្មី

### ១៧- ព្រះគម្ពីរសម្ពន្ធមេត្រីថ្មីមានតម្លៃដ៏ថ្លៃបំផុត

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិតជាឫទ្ធានុភាពរបស់ព្រះអង្គ សម្រាប់សង្គ្រោះអស់អ្នកផ្ញើជីវិតលើព្រះអង្គ (រម ១, ១៦)។ ព្រះបន្ទូលនេះមានចែងទុកក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី ហើយបង្ហាញឫទ្ធានុភាពយ៉ាងពិសេសក្នុងគម្ពីរនេះ។ ដល់ពេលកំណត់ គឺនៅគ្រាចុងក្រោយបង្អស់ (កឡ ៤, ៤) ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ហើយតាំងទីលំនៅក្នុងចំណោមពួកយើង ពោរពេញដោយព្រះហឫទ័យប្រណីសន្ដោសនិងដោយសេចក្ដីពិត (យហ ១, ១៤)។ ព្រះគ្រីស្ដតែងតាំងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដី។ ព្រះអង្គសម្ដែងទាំងព្រះបិតា ទាំងព្រះអង្គផ្ទាល់ ដោយប្រព្រឹត្តព្រះរាជកិច្ចនានា និងដោយមានព្រះបន្ទូល។ ដោយព្រះអង្គសោយទិវង្គត មានព្រះជន្មថ្មី យាងឡើងស្ថានបរមសុខយ៉ាងរុងរឿង ព្រមទាំងចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក គឺព្រះអង្គបង្ហើយព្រះរាជកិច្ចរបស់ព្រះអង្គ។ ដោយគេលើកព្រះគ្រីស្ដពីដីឡើង (យហ ១២, ៣២) ព្រះអង្គទាញមនុស្សទាំងអស់ទៅឯព្រះអង្គ។ មានតែព្រះអង្គទេ ដែលមានព្រះបន្ទូលផ្ដល់ជីវិតអស់កល្បជានិច្ច (យហ ៦, ៦៨)។ ប៉ុន្ដែ ព្រះជាម្ចាស់ពុំបានសម្ដែងគម្រោងការដ៏អស្ចារ្យនេះមកមនុស្សជំនាន់មុនៗ ដូចព្រះអង្គបានសម្ដែងនៅពេលនេះ ឲ្យក្រុមគ្រីស្ដទូតនិងព្យាការីរបស់ព្រះអង្គស្គាល់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ (អភ ៣, ៤-៦) ហេតុនេះ អស់លោកត្រូវប្រកាសដំណឹងល្អ ដាស់តឿនមនុស្សឲ្យផ្ញើជីវិតលើព្រះយេស៊ូជាព្រះគ្រីស្ដនិងជាព្រះអម្ចាស់ ព្រមទាំងអស់លោកត្រូវប្រមែប្រមូលព្រះសហគមន៍ព្រះអង្គផង។ កណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី ផ្ដល់សក្ខីភាពអំពីព្រឹត្ដការណ៍ទាំងនេះ ជាសក្ខីភាពអចិន្ត្រៃយ៍មកពីព្រះជាម្ចាស់។

### ១៨- កណ្ឌគម្ពីរដំណឹងល្អ ហូរចេញមកពីក្រុមគ្រីស្ដទូត

មនុស្សណាក៏ទទួលស្គាល់ថា ក្នុងចំណោមកណ្ឌគម្ពីរទាំងអស់ សូម្បីតែក្នុងចំណោមកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី គឺកណ្ឌគម្ពីរដំណឹងល្អជាកណ្ឌដ៏ប្រសើរជាងគេបំផុត ព្រោះកណ្ឌគម្ពីរដំណឹងល្អជាសក្ខីភាពពិសេសអំពីជីវប្រវត្តិ និងអំពីសេចក្ដីប្រៀនប្រដៅរបស់ព្រះបន្ទូលដែលប្រសូតជាមនុស្ស និងជាព្រះសង្គ្រោះនៃយើង។

ជានិច្ចកាល និងនៅគ្រប់ទីកន្លែង ព្រះសហគមន៍បានចាត់ទុក ហើយនៅតែចាត់ទុកថា កណ្ឌគម្ពីរដំណឹងល្អទាំងបួននេះ ហូរចេញពីក្រុមគ្រីស្ដទូតមក។ សេចក្ដីដែលក្រុមគ្រីស្ដទូតបានប្រកាសតាមព្រះបញ្ជារបស់ព្រះគ្រីស្ដ អស់លោកផ្ទាល់ និងអ្នករស់នៅជាមួយ បានកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្នុងសំណេរ ដែលជាគ្រឹះនៃជំនឿ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតអស់លោក ហើយបញ្ជូនបន្ដមកយើង គឺគម្ពីរដំណឹងល្អទាំងបួន ពោលគឺ គម្ពីរដំណឹងល្អតាមលោកម៉ាថាយ តាមលោកម៉ាកូស តាមលោកលូកា និងតាមលោកយ៉ូហាន។

## ១៩- គម្ពីរដំណឹងល្អ មានលក្ខណៈជាប្រវត្តិសាស្ត្រ

ព្រះសហគមន៍ដ៏វិសុទ្ធជាមាតារបស់យើង បានចាត់ទុក ហើយនៅតែចាត់ទុកយ៉ាងរឹងមាំមិនដែលងាករេថា គម្ពីរដំណឹងល្អទាំងបួននោះ បញ្ជូនបន្តយ៉ាងពិតប្រាកដនូវកិច្ចការទាំងប៉ុន្មាន ដែលព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់បានប្រព្រឹត្ត និងសេចក្តីទាំងប៉ុន្មាន ដែលព្រះអង្គបានបង្រៀននៅពេលព្រះអង្គ រស់នៅក្នុងចំណោមមនុស្សលោក ដើម្បីសង្គ្រោះមនុស្សលោកអស់កល្បជានិច្ច រហូតដល់ថ្ងៃដែលព្រះជាម្ចាស់ បានលើកព្រះអង្គឡើងស្ថានបរមសុខ (កក ១, ១-២)។ ព្រះសហគមន៍ប្រកាសបញ្ជាក់ដោយមិនងាករេថា កិច្ចការក្នុងកណ្ឌគម្ពីរទាំងបួននោះ ពិតជាកើតតាមប្រវត្តិសាស្ត្រមែន។ ក្រោយពេលព្រះជាម្ចាស់បានលើកព្រះអម្ចាស់យេស៊ូឡើងស្ថានបរមសុខ ក្រុមគ្រីស្តទូតក៏បានបញ្ជូនបន្តសេចក្តី ដែលព្រះអង្គមានព្រះបន្ទូលនោះ និងអំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះអង្គបានប្រព្រឹត្តឲ្យអ្នកដទៃស្តាប់។ អស់លោកយល់អត្ថន័យបានជ្រៅជាងពីមុន ព្រោះព្រឹត្តិការណ៍ដ៏រុងរឿងរបស់ព្រះគ្រីស្ត បានសម្តែងឲ្យអស់លោក យល់អត្ថន័យនេះ ដោយមានពន្លឺនៃព្រះវិញ្ញាណនៃសេចក្តីពិតបំភ្លឺចិត្តគំនិតអស់លោកដែរ (យហ ១៤, ២៦; ១៦,១៣)។ ហេតុនេះ អ្នកនិពន្ធដ៏សក្ការៈ កត់ត្រាទុកកណ្ឌគម្ពីរទាំងបួននោះ ដោយជ្រើសរើសឯកសារខ្លះ ក្នុងចំណោមឯកសារជាច្រើន ដែលអស់លោកបានទទួលតៗពីគេ ដោយស្តាប់ពូគេរៀបរាប់ក្តី ឬជាឯកសារចែងជាលាយលក្ខណ៍អក្សរ រួចជាស្រេចមកហើយក្តី។ គេក៏សង្ខេបឯកសារខ្លះៗទៀត ឬពន្យល់ឯកសារខ្លះ ស្របតាមសភាពការណ៍នៃព្រះសហគមន៍នានា។ គេចែងគម្ពីរដូចជាធម្មទេសនាម៉្យាង ដើម្បីចែកចាយជានិច្ចនូវសេចក្តីដ៏ពិតប្រាកដ និងត្រឹមត្រូវអំពីព្រះយេស៊ូ។ ទោះបីអ្នកនិពន្ធបានចែងកណ្ឌទាំងបួននោះ តាមសេចក្តីដែលគេចងចាំដោយផ្ទាល់ក្តី តាមអនុស្សាវរីយ៍របស់គេក្តី ឬតាមសក្ខីភាពរបស់ *"អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែកតាំងពីដំបូងមក និងដែលទៅជាអ្នកបម្រើព្រះបន្ទូលក្តី ក៏អស់លោកនិពន្ធកណ្ឌទាំងបួននោះ ដោយមានបំណងឲ្យយើងដឹងថា ការប្រៀនប្រដៅដែលយើងបានទទួលនោះ ជាសេចក្តីត្រឹមត្រូវពិតមែន"* (លក ១, ២-៤)។

## ២០-កណ្ឌឯទៀតៗនៃគម្ពីរសម្ពន្ធមេត្រីថ្មី

ក្នុងក្បួនបញ្ជីនៃកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី ក្រៅពីគម្ពីរដំណឹងល្អទាំងបួន ក៏មានលិខិតរបស់គ្រីស្តទូតប៉ូល និងសំណេរឯទៀតៗ ដែលក្រុមគ្រីស្តទូតបាននិពន្ធ ដោយព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតអស់លោកឲ្យនិពន្ធដែរ។ តាមព្រះជាម្ចាស់គ្រោងទុកដោយព្រះប្រាជ្ញាញាណ កណ្ឌទាំងនេះបញ្ជាក់សេចក្តីដែលទាក់ទិននឹងព្រះគ្រីស្តជាអម្ចាស់នៃយើង គឺលាតត្រដាងលទ្ធិដ៏ពិតប្រាកដរបស់ព្រះអង្គកាន់តែច្បាស់ នាំឲ្យមនុស្សលោកស្គាល់ព្រះរាជកិច្ចរបស់ព្រះគ្រីស្ត ដែលមានឫទ្ធានុភាពអាចសង្គ្រោះគេបាន។ កណ្ឌទាំងនោះ រៀបរាប់អំពីដើមកំណើតនិងការពង្រីកយ៉ាងអស្ចារ្យ នៃព្រះសហគមន៍ ហើយជូនដំណឹងជាមុន អំពីព្រះសហគមន៍ដ៏ពេញលក្ខណៈ យ៉ាងរុងរឿងនៅពេលចុងក្រោយបំផុត។

ព្រះអម្ចាស់យេស៊ូជួយគាំទ្រក្រុមគ្រីស្តទូតរបស់ព្រះអង្គ (មថ ២៨, ២០) តាមព្រះបន្ទូលសន្យា ហើយចាត់ព្រះវិញ្ញាណ ដែលជួយការពារយាងមកណែនាំឲ្យគេ ស្គាល់សេចក្តីពិតគ្រប់ជំពូក (យហ ១៦, ១៣)។

# ជំពូក ៦

## ព្រះគម្ពីរក្នុងជីវិតរបស់ព្រះសហគមន៍

### ២១-ព្រះគម្ពីរមានសារៈសំខាន់សម្រាប់ព្រះសហគមន៍

តាំងពីដើមរៀងមក ព្រះសហគមន៍តែងតែគោរពប្រណិប័តន៍ព្រះគម្ពីរជានិច្ច ដូចព្រះសហគមន៍ធ្លាប់គោរពប្រណិប័តន៍ព្រះកាយផ្ទាល់របស់ព្រះអម្ចាស់ដែរ។ ជាពិសេសក្នុងពិធីគោរពប្រណិប័តន៍ ព្រះសហគមន៍នៅតែយកអាហារដែលផ្ដល់ជីវិត ពីតុនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាតុនៃព្រះកាយព្រះគ្រីស្តផងដែរ ទៅជូនគ្រីស្តបរិស័ទជានិច្ច។ តាំងពីដើមរៀងមក ព្រះសហគមន៍បានចាត់ទុក ហើយនៅតែចាត់ទុកព្រះគម្ពីរជាក្បួនដ៏ខ្ពង់ខ្ពស់តែមួយនៃជំនឿរបស់ខ្លួន រួមជាមួយការបញ្ជូនបន្តដ៏វិសុទ្ធផងដែរ។ ព្រះជាម្ចាស់បានបំភ្លឺចិត្តគំនិតអ្នកនិពន្ធគម្ពីរ ដែលបានកត់ត្រាទុកសេចក្តី ជាលាយលក្ខណ៍អក្សរម្ដងជាស្រេច។ ហេតុនេះហើយ បានជាព្រះគម្ពីរថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ផ្ទាល់ដោយមិនប្រែប្រួល ហើយធ្វើឲ្យព្រះសូរសៀងរបស់ព្រះវិញ្ញាណលាន់ឮឡើង ដោយសារពាក្យសម្ដីរបស់អស់លោកព្យាការី និងរបស់ក្រុមគ្រីស្តទូត។ ហេតុនេះ ធម្មទេសនានៃព្រះសហគមន៍ និងគ្រីស្តសាសនាផ្ទាល់ ត្រូវយកព្រះគម្ពីរធ្វើជាអាហារ និងជាក្បួនមាត្រា។ ក្នុងព្រះគម្ពីរព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុតយាងមកជួបបុត្រធីតា ដោយព្រះហឫទ័យមេត្តាករុណា និងយាងមកសន្ទនាជាមួយគេ។ ឫទ្ធានុភាព និងព្រះចេស្ដាបង្កប់ទុកក្នុងព្រះគម្ពីរយ៉ាងជ្រាលជ្រៅបំផុត រហូតដល់ព្រះសហគមន៍អាចយកព្រះគម្ពីរធ្វើជាទីពំនឹងដ៏រឹងមាំ និងធ្វើជាកម្លាំងរបស់ខ្លួនធ្វើជាកម្លាំង នៃជំនឿរបស់បុត្រធីតា នៃព្រះសហគមន៍ជាអាហារខាងវិញ្ញាណរបស់គេ និងធ្វើជាប្រភពដ៏ថ្លៃថ្លា ដែលមិនចេះរីងស្ងួត នៃជីវិតតាមវិញ្ញាណរបស់គេទៀតដែរ។ ហេតុនេះហើយ បានជាពាក្យដែលថ្លែងថា *"ព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានជីវិត និងមានមហិទ្ធិឫទ្ធិ"* (ហប ៤, ១២) *"ព្រះបន្ទូលអាចកសាងព្រះសហគមន៍ និងផ្ដល់ចំណែកមត៌ក រួមជាមួយអស់អ្នកដែលព្រះជាម្ចាស់ បានប្រោសឲ្យបានវិសុទ្ធ"* (កក ២០, ៣២; ១ ថស ២, ១៣) ពិតជាសំដៅទៅលើព្រះគម្ពីរប្រាកដមែន។

### ២២- ត្រូវតែបកប្រែគម្ពីរតាមរបៀបផ្សេងៗជាចាំបាច់

ត្រូវឲ្យគ្រីស្តបរិស័ទ អាចឈានទៅកាន់ព្រះគម្ពីរយ៉ាងស្រួលបំផុត។ ហេតុនេះហើយ បានជាតាំងពីដើមរៀងមកព្រះសហគមន៍បានទទួលគម្ពីរសម្ពន្ធមេត្រីចាស់ ដែលប្រែជាភាសាក្រិកពីបុរាណហៅថា *"គម្ពីរចិតសិប"* (LXX) ទុកជាគម្ពីររបស់ខ្លួន។ ព្រះសហគមន៍នៅតែគោរពគម្ពីរ ដែលប្រែតាមរបៀបផ្សេងៗទៀត ជាភាសាបូព៌ា ឬជាភាសាឡាតាំង ជាពិសេសគម្ពីរ ប្រែជាភាសាឡាតាំងហៅថា *"របស់ប្រជាជនសាមញ្ញទូទៅ"* (Vulgate)។ ប៉ុន្តែ ត្រូវធ្វើយ៉ាងណាឲ្យមនុស្សនៅគ្រប់សម័យ មានសមត្ថភាពអានព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។ ហេតុនេះ ព្រះសហគមន៍ជាមាតា ដែលតែងតែថែរក្សាកូន យកចិត្តទុកដាក់ឲ្យមានគេបកប្រែគម្ពីរជាភាសាផ្សេងៗយ៉ាងសមរម្យ និងត្រឹមត្រូវ ដោយយកឯកសារដើមមកបកប្រែផង។ ប្រសិនបើមានតម្រូវការ បងប្អូនគ្រីស្តបរិស័ទ និកាយផ្សេងៗ សហការបកប្រែគម្ពីរអន្តរនិកាយ ឲ្យគ្រីស្តបរិស័ទទាំងអស់អាចប្រើបាន លុះត្រាតែអស់លោកជាអ្នកមានសមត្ថកិច្ចក្នុងព្រះសហគមន៍អនុញ្ញាត។

## ២៣-ទេវវិទូកាតូលិកមានភារកិច្ចជាគ្រីស្តទូត

ព្រះសហគមន៍ ជាព្រះមហេសីនៃព្រះបន្ទូលប្រសូតជាមនុស្ស។ ព្រះវិញ្ញាណដ៏វិសុទ្ធអប់រំព្រះសហគមន៍ ឲ្យខិតខំស្វះស្វែងរក ឲ្យយល់ព្រះគម្ពីរ កាន់តែជ្រៅទៅៗជារៀងរាល់ថ្ងៃ ដើម្បីជូនព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអាហារដល់បុត្រធីតារបស់ខ្លួនជានិច្ចនិរន្តរ៍។ ហេតុនេះហើយ បានជាព្រះសហគមន៍ ក៏គាំទ្រការសិក្សាអំពីសេចក្តីប្រៀនប្រដៅរបស់គ្រូបាធ្យាយដ៏វិសុទ្ធដែរ ទាំងគ្រូបាធ្យាយនៅបូព៌ាប្រទេស ទាំងគ្រូបាធ្យាយនៅបស្ចិមប្រទេស ព្រមទាំងគាំទ្រការសិក្សាក្បួននៃពិធីគោរពប្រណិប័តន៍ទាំងឡាយ។ ត្រូវឲ្យអ្នកវិភាគគម្ពីរ និងអស់ទេវវិទូកាតូលិក រួមកម្លាំងគ្នា ខិតខំពិនិត្យពិច័យយ៉ាងល្អិតល្អន់ ដោយប្រើគ្រប់វិធីស្របតាមសេចក្តីត្រូវការ និងក្រោមការណែនាំរបស់អស់លោក មានបន្ទុកបង្រៀនព្រះសហគមន៍ផង។ គេក៏ត្រូវយកចិត្តទុកដាក់បកស្រាយព្រះគម្ពីរ ដើម្បីឲ្យអ្នកបម្រើព្រះបន្ទូល ភាគច្រើនអាចយកព្រះបន្ទូលធ្វើជាអាហារមកជូនជាប្រយោជន៍ដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ គឺព្រះបន្ទូលដែលបំភ្លឺចិត្តគំនិតមនុស្សពង្រឹងបំណងប្រាថ្នា និងធ្វើឲ្យមនុស្សស្រឡាញ់ព្រះជាម្ចាស់ដោយចិត្តស្មោះ។ មហាសន្និបាតដ៏វិសុទ្ធ សូមលើកទឹកចិត្តយ៉ាងខ្លាំងដល់អស់បុត្រធីតានៃព្រះសហគមន៍ ដែលយកចិត្តទុកដាក់សិក្សា និងពិនិត្យពិច័យព្រះគម្ពីរ សូមបន្តកិច្ចការដែលខ្លួនចាប់ផ្តើមនោះ រហូតដល់ទីបញ្ចប់ ដោយមានចិត្តអង់អាចថ្មីជារៀងរាល់ថ្ងៃ និងចិត្តក្លៀវក្លាយ៉ាងខ្លាំង ស្របតាមគោលគំនិតនៃព្រះសហគមន៍។

## ២៤- ព្រះគម្ពីរ និងទេវវិទ្យា

ទេវវិទ្យាដ៏វិសុទ្ធ សម្អាងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចែងជាលាយលក្ខណ៍អក្សរ ដែលមិនអាចបំបែកពីការបញ្ជូនបន្តដ៏វិសុទ្ធ បានទុកជាសម្អាងលើគ្រឹះដែលនៅស្ថិតស្ថេររហូតមក។ ទេវវិទ្យាពង្រឹងខ្លួនឯងកាន់តែថ្មីឡើងៗ ក៏ដោយសារព្រះគម្ពីរដែរ គឺនៅពេលទេវវិទូពិនិត្យពិច័យនូវសេចក្តីពិតទាំងមូល ដែលលាក់ទុកក្នុងគម្រោងដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដោយយកជំនឿធ្វើជាពន្លឺ។ ក្នុងព្រះគម្ពីរមានកត់ត្រាទុកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយព្រះអង្គបានបំភ្លឺចិត្តគំនិតអ្នកនិពន្ធព្រះគម្ពីរ ពិតជាព្រះបន្ទូលរបស់ព្រះអង្គមែន។ សូមចាត់ទុកការសិក្សាព្រះគម្ពីរ ជាដួងព្រលឹងនៃទេវវិទ្យា។ សូមឲ្យអស់អ្នកបម្រើព្រះបន្ទូល គឺអ្នកធ្វើពិធីអត្ថាធិប្បាយក្នុងឋានៈជាគង្វាល អ្នកអប់រំជំនឿ អ្នកបង្រៀនគ្រីស្តបរិស័ទគ្រប់យ៉ាង ជាពិសេសអ្នកធ្វើពិធីអត្ថាធិប្បាយក្នុងពីធីគោរពប្រណិប័តន៍នានា ជាកិច្ចដែលប្រសើរជាងគេ យកព្រះបន្ទូល ដែលកត់ត្រាទុកក្នុងព្រះគម្ពីរ ធ្វើជាអាហារដ៏ឆ្ងាញ់ពិសា និងមានកម្លាំងដ៏វិសុទ្ធផង។

## ២៥-ការផ្តាំឲ្យអានព្រះគម្ពីរ

ហេតុនេះហើយ បានជាអស់អ្នកដែលបំពេញមុខងារមួយក្នុងព្រះសហគមន៍ មានអស់បូជាចារ្យរបស់ព្រះគ្រីស្តជាដើម ព្រមទាំងអស់លោកឧបដ្ឋាក និងអ្នកអប់រំជំនឿដែលធ្លាប់បម្រើព្រះបន្ទូលយ៉ាងត្រឹមត្រូវ ត្រូវភ្ជាប់ចិត្តនឹងព្រះគម្ពីរព្យាយាមអាន និងសិក្សាព្រះគម្ពីរយ៉ាងជ្រាលជ្រៅ ស្វែងរកអត្ថន័យតាមព្រះវិញ្ញាណ ក្រែងលោនរណាម្នាក់ក្លាយទៅជា "អ្នកប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែបបូរមាត់ខាងក្រៅប៉ុណ្ណោះ តែមិនស្តាប់ព្រះបន្ទូលនេះខាងក្នុងចិត្តគេទេ"។ ផ្ទុយទៅវិញ អស់លោកមានភារកិច្ចចែករំលែកព្រះបន្ទូល ជាទ្រព្យសម្បត្តិដ៏មានតម្លៃហួសកម្រិត ជាពិសេសនៅពេលធ្វើពិធីគោរពប្រណិប័តន៍នានា។ មហាសន្និបាតដ៏វិសុទ្ធ ក្រើនរំឭកដាស់តឿនគ្រីស្តបរិស័ទទាំងអស់យ៉ាងខ្លាំងជាទីបំផុត ជាពិសេស បព្វជិតបព្វជិតាឲ្យរៀន *"ចំណេះដ៏វិសេសវិសាលដែលនៅក្នុងព្រះគ្រីស្ត"* (ភល ៣, ៨) ដោយអានព្រះគម្ពីរជាញឹក ដ្បិត *"អ្នកដែលមិនស្គាល់ព្រះគម្ពីរ ក៏មិនស្គាល់ព្រះគ្រីស្តដែរ"*។ ទោះនៅពេលធ្វើពិធីបុណ្យនានា ដែលជ្រួតជ្រាប

ដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្ដី ទោះបីអានគម្ពីរម្នាក់ឯង ដោយគោរពប្រពៃណិប័តន៍ក្ដី ទោះគេរៀនតាមសាលា ឬតាមរបៀបផ្សេងក្ដី ដូចមានចាត់ចែងនៅគ្រប់កន្លែងសព្វថ្ងៃ សូមឲ្យពួកគេចូលចិត្តអានគម្ពីរដោយផ្ទាល់ដែរ។ សូមចាត់ចែងការសិក្សាគួរឲ្យសរសើរនេះ ដូចមានផ្សព្វផ្សាយសព្វថ្ងៃនៅគ្រប់កន្លែង តាមសេចក្ដីអនុញ្ញាតនិងតាមការគាំទ្ររបស់អស់លោកអភិបាលជាគង្វាលព្រះសហគមន៍។ សូមឲ្យអ្នកសិក្សាទាំងនោះនឹកចងចាំជានិច្ចថា ត្រូវអានព្រះគម្ពីរ ទាំងអធិដ្ឋានផង ទើបមនុស្សនិងព្រះជាម្ចាស់អាចសន្ទនាជាមួយគ្នាបាន ដ្បិត *"ពេលណាយើងអធិដ្ឋាន ពេលនោះ យើងនិយាយទូលព្រះអង្គ ហើយពេលយើងអានព្រះបន្ទូល យើងស្ដាប់ព្រះអង្គវិញ"*។

អស់លោកអភិបាល *"ដែលទទួលបញ្ញើនៃលទ្ធិមកពីក្រុមគ្រីស្ដទូត"* មានភារកិច្ចបង្រៀនគ្រីស្ដបរិស័ទក្នុងភូមិភាគរបស់ខ្លួនយ៉ាងសមគួរ ឲ្យគេចេះប្រើកណ្ដព្រះគម្ពីរយ៉ាងត្រឹមត្រូវ ជាពិសេសគម្ពីរសម្ពន្ធមេត្រីថ្មី មានគម្ពីរដំណឹងល្អជាដើម។ សូមចាត់ឲ្យមានគេបកប្រែគម្ពីរទាំងនោះ។ សូមដាក់កំណត់អត្ថាធិប្បាយតាមសេចក្ដីត្រូវការ ឲ្យបានគ្រប់គ្រាន់ពិតប្រាកដមែន ដើម្បីឲ្យបុត្រធីតានៃព្រះសហគមន៍ មានលទ្ធភាពអានព្រះគម្ពីរដោយមិនខ្លាចវង្វេង និងទទួលផលប្រយោជន៍បាន ព្រមទាំងឲ្យព្រះបន្ទូលជ្រួតជ្រាបក្នុងចិត្តគំនិតរបស់គេផង។

មិនតែប៉ុណ្ណោះសោត សូមបោះពុម្ពគម្ពីរសម្រាប់អ្នកដែលមិនកាន់គ្រីស្ដសាសនាយើងទៀតផង ដោយដាក់កំណត់អត្ថាធិប្បាយតាមសេចក្ដីត្រូវការ ស្របតាមសភាពការណ៍របស់អ្នកអាន។ ទោះយ៉ាងណាក៏ដោយ សូមអស់គង្វាល ដែលមានភារកិច្ចណែនាំ និងគ្រីស្ដបរិស័ទទាំងឡាយ ទោះជាបព្វជិតបព្វជិតា ឬគ្រីស្ដបរិស័ទធម្មតាក៏ដោយ ត្រូវយកចិត្តទុកដាក់ ផ្សព្វផ្សាយគម្ពីរដោយរិះគិតពិចារណាផង។

### ២៦-សេចក្ដីបញ្ចប់

ហេតុនេះ *"សូមឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ បង្ហើយកិច្ចការរបស់ខ្លួន និងបានរុងរឿង"* (២ថស ៣, ១) ដោយគេអាន និងសិក្សាព្រះគម្ពីរ។ សូមឲ្យកំណប់ដ៏ថ្លៃថ្លានៃសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងមក និងផ្ញើឲ្យព្រះសហគមន៍នោះ បំពេញបំណងចិត្តរបស់មនុស្សឲ្យកាន់តែច្រើនឡើងៗ។ ព្រះសហគមន៍ទទួលជីវិតកាន់តែច្រើនឡើងៗ ដោយព្យាយាមថ្វាយអភិបូជាយ៉ាងណា យើងសង្ឃឹមថាគ្រីស្ដបរិស័ទក៏នឹងមានជីវិតតាមវិញ្ញាណចម្រើនឡើងជាថ្មី ដោយព្យាយាមគោរពព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងនោះដែរ ព្រោះព្រះបន្ទូលរបស់ព្រះអង្គ *"ស្ថិតនៅអស់កល្បជានិច្ច"* (តាម អស ៤០, ៨; ១សល ១, ២៣-២៥)។

អស់លោកអភិបាល ដែលចូលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងធម្មនុញ្ញគោលលទ្ធិទាំងមូលខាងលើនេះ ព្រមទាំងគោលការណ៍នីមួយៗនៃធម្មនុញ្ញនេះផងដែរ។ រីឯយើងវិញ គឺស្របតាមអំណាចជាគ្រីស្ដទូតដែលព្រះគ្រីស្ដបានប្រគល់ឲ្យ រួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណចូលរួមជាមួយផង យើងក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្ដី ដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម ព្រះវិហារសន្តៈ សិលា ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៥

ខ្ញុំប៉ូលអភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខា របស់លោកអភិបាល)

# មហាសន្និបាតដ៏វិសុទ្ធ

(អំពីពិធីគោរពប្រណិប័តន៍)

## Sacrosanctum Concilium

## ខ្ញុំ ប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាល ដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធ សូមប្រកាសសេចក្តីនេះ ដើម្បីគេនឹកចងចាំរហូតតរៀងទៅ។ ធម្មនុញ្ញអំពីពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់

### បុព្វកថា

**១-មហាសន្និបាតដ៏វិសុទ្ធបំផុត មានគោលដៅដូចតទៅ៖**

* ជួយឲ្យជីវិតតាមព្រះវិញ្ញាណរបស់គ្រីស្តបរិស័ទ រីកចម្រើនឡើង ៗជាលំដាប់ជារៀងរាល់ថ្ងៃ។
* ជួយកែសម្រួលអ្វីៗ ដែលព្រះសហគមន៍បានចាត់ចែងជាយូរមកហើយ ដែលអាចប្រែប្រួលបាន សមស្រប តាមតម្រូវការនាសម័យយើងនេះ។
* គាំទ្រអ្វី ៗទាំងប៉ុន្មាន ដែលអាចជួយឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត រួបរួមគ្នាជាធ្លុងតែមួយ។
* ពង្រឹងអ្វី ៗទាំងប៉ុន្មាន ដែលអាចណែនាំមនុស្សលោកទាំងអស់ ឲ្យមកជ្រកកោនក្រោមម្លប់នៃព្រះសហគមន៍។

ដោយមានគោលដៅទាំងនោះ មហាសន្និបាតយល់ឃើញថា មានភារកិច្ចពិសេស គឺយកចិត្តទុកដាក់កែសម្រួល និងជួយពង្រីកពង្រឹង ពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់។

**២-ពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត**

ដោយសារពិធីគោរពប្រណិប័តន៍ ជាពិសេសដោយសារសក្ការបូជាអរព្រះគុណ *"ព្រះជាម្ចាស់រំដោះយើង"*។ ពិធីទាំងនោះ ក៏ជួយយ៉ាងខ្ពង់ខ្ពស់បំផុត ឲ្យគ្រីស្តបរិស័ទប្រកាសជំនឿត ាមការរស់នៅរបស់ខ្លួន និងសម្តែងឲ្យអ្នកដទៃស្គាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ព្រមទាំងស្គាល់លក្ខណៈដ៏ពិតប្រាកដរបស់ព្រះសហគមន៍ទៀតផង។ មានតែព្រះសហគមន៍ទេ ដែលមានលក្ខណៈលោកីយ៍ផង ហើយនៅពេលតែមួយនោះ មានលក្ខណៈរបស់ព្រះជាម្ចាស់ផង។

មនុស្សអាចមើលឃើញព្រះសហគមន៍បានផង ហើយមានអ្វីៗដ៏ប្រសើរជាង ដែលមនុស្សមើលមិនឃើញផងដែរ។ ព្រះសហគមន៍ ខ្នះខ្នែងប្រព្រឹត្តសកម្មភាពផង ហើយនៅស្ងៀមស្ងឹងស្មាធិ៍ផង ព្រះសហគមន៍រស់នៅក្នុងលោកនេះ តែក៏នៅដូចជាជនបរទេសនៅក្នុងលោកនេះដែរ។ ប៉ុន្តែ ព្រះសហគមន៍រស់នៅតាមបែបធ្វើឲ្យអ្វីៗក្នុងខ្លួន ដែលមានលក្ខណៈលោកីយ៍ តម្រង់ទៅរកអ្វីៗដែលមានលក្ខណៈជាព្រះជាម្ចាស់ ហើយចុះចូលនឹងលក្ខណៈនោះដែរ ឲ្យអ្វីៗដែលមើលឃើញ បានតម្រង់ហើយចុះចូលនឹងអ្វីៗ ដែលមើលមិនឃើញ ឲ្យអ្វីៗដែលពាក់ព័ន្ធនឹងសកម្មភាព តម្រង់ ហើយចុះចូលនឹងការស្ងឹងស្មាធិ៍ ឲ្យអ្វីៗក្នុងលោកនេះ តម្រង់ហើយចុះចូលនឹងអ្វីៗ ដែលជាប់នឹងលោកខាងមុខដែលយើងស្វែងរកនោះ (ហប ១៣, ១៤)។ ហេតុនេះហើយ បានជាពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ សាងអស់អ្នកនៅខាងក្នុងព្រះសហគមន៍ជារៀងរាល់ថ្ងៃ ឲ្យទៅជាព្រះវិហារដ៏វិសុទ្ធ ដោយរួមក្នុងអង្គព្រះអម្ចាស់ ទៅជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណ (អភ ២, ២១-២២) រហូតដល់មានទំហំសមរម្យនឹងព្រះគ្រីស្ត ដែលបំពេញអ្វីៗទាំងអស់ (អភ ៤, ១៤)។ ពិធីគោរពប្រណិប័តន៍ពង្រឹងកម្លាំងចិត្តរបស់គេយ៉ាងអស្ចារ្យ ដើម្បីឲ្យគេអាចប្រកាសព្រះគ្រីស្តបាន។ ពិធីគោរពប្រណិប័តន៍ ក៏បង្ហាញព្រះសហគមន៍ឲ្យអ្នកនៅខាងក្រៅឃើញដូចជាទង់មួយ ជាសញ្ញាដែលព្រះជាម្ចាស់លើកឡើង នៅចំពោះមុខប្រជាជាតិទាំងឡាយ (អស ១១, ១២)។ បុត្រធីតារបស់ព្រះជាម្ចាស់ ដែលខ្ចាត់ខ្ចាយក៏មកប្រមូលផ្តុំគ្នាជាអង្គតែមួយ (យហ ១១, ៥២) ក្រោមទង់សញ្ញានោះ ទម្រាំដល់ពេលមានហ្វូងចៀមតែមួយ និងមានគង្វាលតែមួយផងដែរ (យហ ១០, ១៦)។

## ៣- ធម្មានុញ្ញ និងរបៀបរបបពិធី

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធយល់ឃើញថា ត្រូវរំឭកអំពីគោលការណ៍ខាងក្រោមនេះ និងត្រូវតែងតាំងសេចក្តីណែនាំឲ្យអនុវត្តតាម ដើម្បីជួយលើកស្ទួយ និងកែសម្រួលពិធីគោរពប្រណិប័តន៍។

ក្នុងចំណោមគោលការណ៍ និងសេចក្តីណែនាំទាំងនោះ មានគោលការណ៍និងសេចក្តីណែនាំខ្លះៗ ដែលព្រះសហគមន៍កាន់តាមរបៀបរបបពិធីនៃព្រះសហគមនក្រុងរ៉ូម និងព្រះសហគមន៍កាន់តាមរបៀបរបបពិធីផ្សេងៗ អាច (នឹងត្រូវ) អនុវត្តតាមទាំងអស់គ្នា។ ក៏ប៉ុន្តែត្រូវយល់ថា មានតែព្រះសហគមន៍កាន់តាមរបៀបរបបពិធីនៃព្រះសហគមន៍ក្រុងរ៉ូមប៉ុណ្ណោះទេ ដែលត្រូវអនុវត្តតាមសេចក្តីណែនាំចែងយ៉ាងជាក់ច្បាស់ខាងក្រោមនេះ លើកលែងតែចំពោះសេចក្តីណែនាំណា ដែលមានលក្ខណៈជាប់នឹងរបៀបរបបពិធីផ្សេងឯទៀត។

## ៤- មិនតែប៉ុណ្ណោះសោតមហាសន្និបាតដ៏វិសុទ្ធសូមប្រកាសថា

របៀបរបបពិធីផ្សេងៗដែលព្រះសហគមន៍ជាព្រះមាតាដ៏វិសុទ្ធរបស់យើង តែងតែទទួលស្គាល់យ៉ាងត្រឹមត្រូវ តាមច្បាប់រួចហើយ សុទ្ធតែមានសិទ្ធិ និងមានតម្លៃដ៏ថ្លៃថ្នូរស្មើគ្នា។ នៅពេលអនាគត ព្រះសហគមន៍ក៏មានបំណងចង់រក្សាទុក និងជួយលើកស្ទួយរបៀបរបបពិធីទាំងនោះឲ្យចម្រើនឡើងគ្រប់បែបយ៉ាងទៀតផង។ មហាសន្និបាតបញ្ជាក់ ដូច្នេះពិតជាត្រឹមត្រូវតាមការបញ្ជូនបន្តរបស់ព្រះសហគមន៍មែន។ មហាសន្និបាតក៏មានបំណងប្រាថ្នាថា នៅត្រង់កន្លែងណា ដែលត្រូវការកែសម្រួលរបៀបរបបពិធីបុណ្យនោះ ត្រូវកែសម្រួលទាំងស្រុង ដោយប្រុងប្រយ័ត្ន និងដោយគិតគូរដល់ការបញ្ជូនបន្តដ៏ត្រឹមត្រូវរបស់ព្រះសហគមន៍។ សូមជួយឲ្យរបៀបរបបពិធីទាំងនោះមានកម្លាំងថ្មី សមស្របតាមកាលៈទេសៈ និងតាមតម្រូវការនាបច្ចុប្បន្នកាល។

# ឧបសម្ព័ន្ធ ១

## គោលការណ៍ទូទៅសម្រាប់កែសម្រួលពិធីគោរពប្រណិប័តន៍

### ១-លក្ខណៈនៃពិធីគោរពប្រណិប័តន៍ និងសារៈសំខាន់នៃពិធីទាំងនោះ ក្នុងការរស់នៅរបស់ព្រះសហគមន៍

### ៥-ព្រះគ្រីស្តសង្គ្រោះមនុស្សលោក

ព្រះជាម្ចាស់ *"សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ និងបានស្គាល់សេចក្តីពិតយ៉ាងច្បាស់"* (១ ធម ២, ៤)។ *"នៅជំនាន់ដើមព្រះអង្គ មានព្រះបន្ទូលមកកាន់បុព្វបុរសយើងជាច្រើនលើកច្រើនសា ដោយប្រើរបៀបផ្សេងៗជាច្រើន តាមរយៈពួកព្យាការី"* (ហប ១, ១)។ លុះដល់ពេលកំណត់ហើយ ព្រះអង្គចាត់ព្រះបុត្រា ឲ្យយាងមក។ ព្រះបុត្រានេះ ជាព្រះបន្ទូលដែលប្រសូតជាមនុស្ស។ ព្រះវិញ្ញាណដ៏វិសុទ្ធចាក់ប្រេងអភិសេកព្រះបន្ទូល ដែលប្រសូតជាមនុស្សនោះ ដើម្បីនាំដំណឹងល្អមកប្រាប់ជនក្រីក្រ ហើយថែទាំអ្នកដែលបាក់ទឹកចិត្ត (អស ៦១, ១; លក ៤, ១៨)។ *"ព្រះគ្រីស្តហាក់ដូចជា គ្រូពេទ្យទាំងខាងរូបកាយផង ទាំងខាងវិញ្ញាណផង"* ព្រះអង្គក៏ជាស្ពានមេត្រី រវាងព្រះជាម្ចាស់ និងមនុស្សលោកដែរ (១ធម ២, ៥)។ ដោយព្រះគ្រីស្តជាព្រះបន្ទូល ដែលប្រសូតជាមនុស្ស មានសភាពជាព្រះជាម្ចាស់ និងមានសភាពជាមនុស្សភ្ជាប់គ្នាក្នុងបុគ្គលតែមួយ ព្រះអង្គអាចសង្គ្រោះមនុស្សយើងបាន។ ហេតុនេះហើយបានជាក្នុងអង្គព្រះគ្រីស្ត *"តម្លៃលោះដ៏ពេញលក្ខណៈដែលនាំឲ្យយើងបានស្រុះស្រួលជានាជាមួយព្រះបិតា និងការបម្រើរបស់ព្រះជាម្ចាស់យ៉ាងពេញលេញ ក៏ចូលមកដល់យើងហើយ"*។

ព្រះគ្រីស្តជាអម្ចាស់បានរំដោះមនុស្សលោកជាស្រេច និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់យ៉ាងពេញលក្ខណៈ ដោយព្រះអង្គរងទុក្ខលំបាក ក្រោកឈរឡើងពីចំណោមមនុស្សស្លាប់ និងយាងឡើងស្ថានលើយ៉ាងរុងរឿង។ នេះជាព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងក្នុងបុណ្យចម្លង។ ដោយសារព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ព្រះអង្គ *"បានកម្ទេចបំផ្លាញអំណាចនៃសេចក្តីស្លាប់របស់មនុស្សយើង ដោយទ្រង់សោយទិវង្គត ហើយទ្រង់ក៏កែតម្រង់ជីវិតឲ្យបានជាថ្មីឡើងវិញ ដោយទ្រង់មានព្រះជន្មថ្មីដ៏រុងរឿង"*។ *"ព្រះសហគមន៍ទាំងមូល ដែលជាអគ្គសញ្ញាដ៏ប្រសើរអស្ចារ្យយ៉ាងក្រៃលែង"* ក៏កើតចេញមកពីមុខរបួសត្រង់ចន្លោះឆ្អឹងជំនីររបស់ព្រះអង្គ ដែលផ្ទុំលក់ពួដ៏ឈើឆ្កាង។ ស្នាព្រះហស្តដ៏អស្ចារ្យ ដែលព្រះជាម្ចាស់បានប្រព្រឹត្តក្នុងចំណោមប្រជារាស្ត្រនៃសម្ពន្ធមេត្រីចាស់ ក៏សុទ្ធសឹងតែ ជាប្រផ្នូលអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនេះដែរ។

### ៦-ព្រះសហគមន៍បន្តកិច្ចសង្គ្រោះរបស់ព្រះគ្រីស្តដោយធ្វើពិធីពិធីគោរពប្រណិប័តន៍តិ

ព្រះបិតាចាត់ព្រះគ្រីស្តឲ្យយាងមកយ៉ាងណា ព្រះគ្រីស្តក៏ចាត់ក្រុមគ្រីស្តទូតរបស់ព្រះអង្គឲ្យទៅយ៉ាងនោះដែរ។ គ្រីស្តទូតទាំងនោះ ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យប្រកាសដំណឹងល្អដល់សត្វលោកទាំងអស់ (មក ១៦,

១៥) គឺជូនដំណឹងថា ដោយព្រះបុត្រារបស់ព្រះជាម្ចាស់សោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គបានរំដោះយើងឲ្យរួចពីអំណាចរបស់មារសាតាំង (កក ២៦, ១៨) និងបានរំដោះយើងឲ្យរួចពីសេចក្ដីស្លាប់ ព្រមទាំងចម្លងយើង ចូលក្នុងព្រះរាជ្យនៃព្រះបិតារបស់ព្រះអង្គ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះគ្រីស្ដចាត់ក្រុមគ្រីស្ដទូត ឲ្យប្រព្រឹត្តតាមកិច្ចសង្គ្រោះដែលអស់លោកប្រកាសនោះទៀតផង ដោយអស់លោកថ្វាយសក្ការបូជាអរព្រះគុណ និងធ្វើអគ្គសញ្ញានានា ដែលជាស្នូលនៃពិធីគោរពប្រណិប័តន៍ទាំងអស់។ ឧបមាថា ដោយអគ្គសញ្ញាជ្រមុជទឹក មនុស្សផ្សាភ្ជាប់នឹងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ដ ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងក្នុងបុណ្យចម្លង គឺគេស្លាប់រួមជាមួយព្រះអង្គ គេចូលក្នុងផ្នូររួមជាមួយព្រះអង្គ ហើយគេក៏មានជីវិតថ្មីដ៏រុងរឿងរួមជាមួយព្រះអង្គដែរ។ គេទទួលព្រះវិញ្ញាណនៃបុត្រធីតា ដែលធ្វើឲ្យយើងបន្លឺសំឡេងឡើងថា *"អប្បាព៉ាឪ"* (រម ៨, ១៥; អភ ២, ៦; កូឡ ៣, ១; ២ធម ២, ១១)។ គេក៏ក្លាយទៅជាអ្នកថ្វាយបង្គំដ៏ពិតប្រាកដ ដែលព្រះបិតាសព្វព្រះហឫទ័យចង់បាន (យហ ៤, ២៣)។ យ៉ាងណាមិញ រៀងរាល់ពេលគេជួបជុំគ្នាបរិភោគក្នុងពិធីជប់លៀងរបស់ព្រះអម្ចាស់ គេប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត គឺប្រកាសរហូតដល់ព្រះអង្គយាងមក (១ករ ១១, ២៦)។ ហេតុនេះហើយ បានជានៅបុណ្យថ្ងៃទីហាសិប ជាថ្ងៃព្រះសហគមន៍លេចចេញមកឲ្យពិភពលោកឃើញ *"អស់អ្នកដែលទទួលសេចក្ដីដែលលោកសិលាប្រកាស ក៏បានទទួលពិធីជ្រមុជទឹក"*។ *"សាវ័កទាំងប៉ុន្មាន ព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមគ្រីស្ដទូត រួមរស់ជាមួយគ្នាទុកជាបងប្អូន ធ្វើពិធីកាច់នំបុ័ង និងព្យាយាមអធិដ្ឋាន...។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូល គោរពរាប់អានពួកគេទាំងអស់គ្នា"* (កក ២, ៤១-៤៧)។ តាំងពីពេលនោះមក ព្រះសហគមន៍តែងតែជួបជុំរួបរួមគ្នា លើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ដ ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងនៅថ្ងៃបុណ្យចម្លង មិនដែលអាក់ខានឡើយ។ ព្រះសហគមន៍ក៏តែងអានសេចក្ដី *"ដែលមានចែងទុកអំពីព្រះអង្គ នៅក្នុងគម្ពីរទាំងមូល"* (លក ២៤, ២៧)។ ព្រះសហគមន៍តែងតែថ្វាយសក្ការបូជាអរព្រះគុណ *"ដែលធ្វើឲ្យជ័យជម្នះដ៏ត្រចះត្រចង់របស់ព្រះគ្រីស្ដលើសេចក្ដីស្លាប់ មានវត្តមានក្នុងចំណោមពួកយើង"*។ នៅពេលជាមួយគ្នានោះ ព្រះសហគមន៍ក៏អរព្រះគុណ *"ព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏ប្រសើរបំផុតរបស់ព្រះអង្គដែលរកថ្លែងពុំបាន"* (២ករ ៩, ១៥) ក្នុងអង្គព្រះគ្រីស្ដយេស៊ូ *"ដើម្បីឲ្យយើងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ"* (អភ ១, ១២) តាមឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ។

## ៧-វត្តមានរបស់ព្រះគ្រីស្ដក្នុងពិធីគោរពប្រណិប័តន៍

ព្រះគ្រីស្ដនៅតែមានវត្តមានក្នុងព្រះសហគមន៍ជានិច្ច ជាពិសេសនៅពេលព្រះសហគមន៍ធ្វើពិធីគោរពប្រណិប័តន៍ផ្សេងៗ គឺព្រះអង្គបង្ហើយព្រះរាជកិច្ចដ៏ប្រសើរបំផុតនោះឲ្យបានជាស្ថាពរ។ ព្រះអង្គគង់នៅក្នុងសក្ការបូជានៃអភិបូជា គឺក្នុងរូបបូជាចារ្យជាអ្នកបំពេញមុខងារបម្រើ។ *"ព្រះអង្គដែលថ្វាយខ្លួននៅពេលនេះ ដោយសារមុខងារបម្រើរបស់បូជាចារ្យក៏ជាព្រះអង្គដែលបានបូជាព្រះជន្មនៅឈើឆ្កាងដែរ"*។ ព្រះអង្គគង់នៅតាមកម្រិតដ៏ខ្ពង់ខ្ពស់បំផុត ក្នុងរូបសញ្ញានំ និងស្រា ដែលថ្វាយក្នុងអគ្គសញ្ញាអរព្រះគុណ។ ព្រះអង្គក៏គង់នៅតាមអគ្គសញ្ញានានា ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ។ ដូច្នេះ នៅពេលនរណាម្នាក់ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ គឺព្រះគ្រីស្ដផ្ទាល់ជ្រមុជទឹកជូនគេ។ ព្រះអង្គគង់នៅតាមព្រះបន្ទូលព្រះអង្គ ដ្បិតពេលណាគេអានព្រះគម្ពីរនៅក្នុងព្រះសហគមន៍ ពេលនោះ គឺព្រះអង្គផ្ទាល់មានព្រះបន្ទូល។ ពេលព្រះសហគមន៍ទូលអង្វរ និងស្មូតទំនុកតម្កើង ព្រះអង្គក៏គង់នៅទីនោះដែរ ព្រោះព្រះអង្គមានព្រះបន្ទូលសន្យាថា៖ *"នៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះជាមួយគេដែរ"* (មថ ១៨, ២០)។ ពិតមែនហើយ ព្រះគ្រីស្ដរួបរួមជាមួយព្រះសហគមន៍គ្រប់ពេលវេលា ដើម្បីបំពេញព្រះរាជកិច្ចដ៏ប្រសើរបំផុតនេះ គឺនាំឲ្យមនុស្សលើកតម្កើង

សិរីរុងរឿងរបស់ព្រះជាម្ចាស់យ៉ាងពេញលេញ ព្រមទាំងប្រោសឲ្យមនុស្សបានវិសុទ្ធផង។ ព្រះគ្រីស្តរួមជាមួយនឹងព្រះសហគមន៍ ជាព្រះមហេសីដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ព្រះសហគមន៍អង្វរព្រះអម្ចាស់របស់ខ្លួន ហើយគោរពបម្រើថ្វាយបង្គំព្រះបិតាដែលមានព្រះជន្មគង់នៅជានិច្ចនិរន្តរ៍ ដោយសារព្រះអង្គ។

ហេតុនេះហើយ បានជាត្រូវចាត់ទុកយ៉ាងត្រឹមត្រូវថា ព្រះយេស៊ូគ្រីស្តពិតជាបំពេញមុខងារជាបូជាចារ្យ ដោយសារពិធីគោរពប្រណិប័តន៍។ ដោយព្រះយេស៊ូគ្រីស្តបំពេញមុខងារជាបូជាចារ្យនោះ ព្រះអង្គក៏សម្តែងថា ព្រះអង្គប្រោសឲ្យមនុស្សបានវិសុទ្ធ តាមសញ្ញាសម្គាល់ដែលអាចមើលឃើញ ហើយព្រះអង្គប្រោសឲ្យគេបានវិសុទ្ធ តាមរបៀបប្លែកៗពីគ្នាស្របតាមសញ្ញានីមួយៗទាំងនោះផង។ ដោយព្រះយេស៊ូគ្រីស្តបំពេញមុខងារជាបូជាចារ្យនោះ ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះយេស៊ូគ្រីស្ត គឺទាំងព្រះសិរសា ទាំងសរីរាង្គ នាំគ្នាគោរពបម្រើព្រះជាម្ចាស់យ៉ាងសាធារណៈ និងយ៉ាងពេញលេញ។

ហេតុនេះហើយ បានជាគ្រប់ពិធីគោរពប្រណិប័តន៍ជាព្រះរាជកិច្ចរបស់ព្រះគ្រីស្តជាបូជាចារ្យផង និងជាកិច្ចរបស់ព្រះសហគមន៍ជាព្រះកាយព្រះអង្គផង គឺជាកិច្ចសក្ការៈដ៏ប្រសើរឧត្តុងឧត្តមបំផុត គ្មានកិច្ចដ៏សក្ការៈណាមួយផ្សេងទៀតស័ក្តិសិទ្ធិដូច ឬមានកម្រិតដូចបានឡើយ។

## ៨-ពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់នៅលោកនេះ និងពិធីគោរពប្រណិប័តន៍នៅលោកខាងមុខ

ពេលយើងចូលរួមធ្វើពិធីគោរពប្រណិប័តន៍ក្នុងលោកនេះ យើងក្រេបជញ្ជក់ជាមុន នូវរសជាតិនៃពិធីគោរពប្រណិប័តន៍ នៅបុរីយេរូសាឡឹមដ៏វិសុទ្ធនៃលោកខាងមុខដែរ។ យើងកំពុងតែជាបូជនីយសក័ក្នុងលោកនេះ តម្រង់ទៅបុរីនោះ ជាបុរីព្រះគ្រីស្តគង់ខាងស្តាំព្រះបិតា ក្នុងឋានៈជាអ្នកបម្រើវិហារដ៏សក្ការៈ និងជាព្រះពន្លាដ៏ពិតប្រាកដ (*វវ* ២១, ២; កូឡ ៣, ១; ហប ៨,២)។ យើងក៏ច្រៀងបទលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ រួមជាមួយកងកម្លាំងនៃស្ថានបរមសុខដែរ។ ដោយនឹកគោរពសន្តបុគ្គលទាំងឡាយ យើងសង្ឃឹមថានឹងបានចូលរួមជាមួយដែរ។ យើងក៏ទន្ទឹងរង់ចាំព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង និងជាព្រះសង្គ្រោះ រហូតដល់ពេលព្រះអង្គដែលជាជីវិតរបស់យើង សម្តែងព្រះអង្គមក។ នៅពេលនោះ យើងក៏នឹងលេចឡើងមករួមជាមួយព្រះអង្គប្រកបដោយសិរីរុងរឿងដែរ (ភល ៣, ២០; កូឡ ៣,៤)។

## ៩-ព្រះសហគមន៍មានសកម្មភាពឯទៀតៗជាច្រើន ក្រៅពីពិធីគោរពប្រណិប័តន៍

ពិធីគោរពប្រណិប័តន៍ ពុំមែនជាសកម្មភាពទាំងមូលរបស់ព្រះសហគមន៍ទេ ដ្បិតមុនមនុស្សអាចចូលរួមក្នុងពិធីទាំងនោះបាន លុះត្រាតែព្រះជាម្ចាស់ត្រាស់ហៅគេឲ្យមានជំនឿ និងឲ្យគេប្រែចិត្តគំនិត។ *"គេអង្វរព្រះជាម្ចាស់ដូចម្តេចកើត បើគេមិនជឿ? ឲ្យគេជឿលើព្រះអង្គដូចម្តេចកើត បើគេមិនដែលឮព្រះអង្គមានព្រះបន្ទូល? ឲ្យគេឮដូចម្តេច កើត បើគ្មាននរណាប្រកាស? ឲ្យមានអ្នកប្រកាសដូចម្តេចកើត បើគ្មាននរណាចាត់ឲ្យទៅប្រកាសផងនោះ?"* (រម ១០, ១៤-១៥)។

ហេតុនេះហើយ បានជាព្រះសហគមន៍ប្រកាសដំណឹងល្អ ស្តីអំពីការសង្គ្រោះដល់អស់អ្នកដែលគ្មានជំនឿលើព្រះគ្រីស្ត ដើម្បីឲ្យមនុស្សទាំងអស់ស្គាល់ព្រះជាម្ចាស់ ជាព្រះដ៏ពិតប្រាកដតែមួយអង្គគត់និងស្គាល់ព្រះយេស៊ូគ្រីស្ត ដែលព្រះជាម្ចាស់ចាត់ឲ្យយាងមកដែរ។ ដូច្នេះគេប្រែចិត្តគំនិត ទាំងនឹកស្តាយដោយបានប្រព្រឹត្តអំពើបាបទៀតផង។ ចំពោះគ្រីស្តបរិស័ទដែលមានជំនឿវិញ ព្រះសហគមន៍ត្រូវតែប្រកាសជំនឿដល់គេជានិច្ច និងនាំឲ្យគេនឹកស្តាយ ដោយបាន

ប្រព្រឹត្តអំពើបាបដែរ (យហ ១៧, ៣; លក ២៤, ២៧; កក ២, ៣៨)។ ព្រះសហគមន៍ក៏ត្រូវអប់រំគេ ឲ្យទទួលអគ្គសញ្ញា ត្រូវបង្ហាត់បង្រៀនគេ ឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មានដែលព្រះគ្រីស្ដបានបង្គាប់ (មថ ២៨, ២០) និងដាស់តឿនគេ ឲ្យប្រព្រឹត្តកិច្ចការដ៏សប្បុរសគ្រប់យ៉ាង ឲ្យគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងធ្វើកិច្ចការជាគ្រីស្ដទូតទៀតផង។ គ្រីស្ដបរិស័ទធ្វើកិច្ចការទាំងនោះ ដើម្បីបង្ហាញបញ្ជាក់ថា ទោះគេមិនកើតមកពីលោកីយ៍នេះក្ដី គេក៏នៅតែជាពន្លឺបំភ្លឺមនុស្សលោក ហើយគេលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតា នៅចំពោះមុខមនុស្សលោកផងដែរ។

## ១០ ពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ ជាកំពូល និងជាប្រភពនៃជីវិតរបស់ព្រះសហគមន៍

ប៉ុន្តែ សកម្មភាពគ្រប់យ៉ាងរបស់ព្រះសហគមន៍ ពិតជាតម្រង់ឆ្ពោះទៅកាន់ពិធីគោរពប្រណិប័តន៍ទុកជាកំពូល។ ពិធីគោរពប្រណិប័តន៍ ក៏ជាប្រភពនៃឫទ្ធានុភាពទាំងស្រុងរបស់ព្រះសហគមន៍ដែរ។ អស់អ្នកដែលខិតខំបំពេញកិច្ចការជាគ្រីស្ដទូត មានគោលដៅណែនាំឲ្យមនុស្សទាំងអស់ ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយផ្ញើជីវិតលើព្រះគ្រីស្ដ និងដោយទទួលអគ្គសញ្ញាជ្រមុជទឹកទៀតផង។ បន្ទាប់មក ឲ្យគេជួបជុំគ្នា និងលើកតម្កើងព្រះជាម្ចាស់ក្នុងព្រះសហគមន៍ និងឲ្យចូលរួមក្នុងសក្ការបូជានៃអភិបូជា ព្រមទាំងឲ្យបរិភោគរួមក្នុងពិធីជប់លៀងរបស់ព្រះអម្ចាស់។ ម្យ៉ាងទៀត ពិធីគោរពប្រណិប័តន៍ ក៏ជំរុញគ្រីស្ដបរិស័ទដែលទទួលទាននៃ *"អគ្គសញ្ញានៃបុណ្យចម្លង"* យ៉ាងឆ្អែតស្កប់ស្កល់ ឲ្យរួបរួមគ្នាជា *"ធ្លុងតែមួយ"*។ ក្នុងពិធីគោរពប្រណិប័តន៍ ព្រះសហគមន៍អង្វរព្រះអង្គ *"សូមឲ្យគ្រីស្ដបរិស័ទកាន់តាមអ្វីៗ ដែលគេបានយល់ឃើញដោយសារជំនឿ"* តាមការរស់នៅរបស់ខ្លួន។ ក្នុងអភិបូជា ព្រះសហគមន៍ចងសម្ពន្ធមេត្រីរបស់ព្រះអម្ចាស់ជាមួយមនុស្សលោកសាជាថ្មី។ សម្ពន្ធមេត្រីថ្មីនេះ ក៏ទាក់ទាញចិត្តគ្រីស្ដបរិស័ទហើយព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ដ ក៏ជំរុញចិត្តគេទៀតផងដែរ។ ហេតុនេះហើយ បានជាព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ហូរចេញមកពីពិធីគោរពប្រណិប័តន៍ ជាពិសេសពីអគ្គសញ្ញាអរព្រះគុណ ដែលហាក់បីដូចជា ហូរចេញពីប្រភពតែមួយ មកក្នុងយើង។ យើងក៏អាចទទួលព្រះហឫទ័យប្រណីសន្ដោសនេះយ៉ាងស័ក្ដិសិទ្ធបំផុត ដែលប្រោសឲ្យមនុស្សយើងបានវិសុទ្ធក្នុងអង្គព្រះគ្រីស្ដដែរ។ សកម្មភាពឯទៀតៗទាំងប៉ុន្មានរបស់ព្រះសហគមន៍ មានគោលដៅតែមួយ គឺលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

## ១១-ចិត្តគំនិតអ្នកចូលរួមក្នុងពិធីគោរពប្រណិប័តន៍

បើគ្រីស្ដបរិស័ទចង់ទទួលព្រះហឫទ័យប្រណីសន្ដោសនេះ តាមរបៀបដែលមានប្រសិទ្ធភាព និងយ៉ាងពេញលេញ គេត្រូវចូលរួមក្នុងពិធីគោរពប្រណិប័តន៍ដោយមានអារម្មណ៍ល្អ គឺមានចិត្តទៀងត្រង់ មានចិត្តគំនិតស្របតាមពាក្យ ដែលគេពោល។ គេត្រូវរួមសហការជាមួយព្រះជាម្ចាស់ ប្រកបដោយព្រះហឫទ័យប្រណីសន្ដោស។ បើមិនដូច្នេះទេ ព្រះហឫទ័យប្រណីសន្ដោសដែលគេទទួលនោះ គឺអសារឥតការឡើយ (២ករ ៦, ១)។ ហេតុនេះហើយ បានជាអស់អ្នកណែនាំព្រះសហគមន៍ត្រូវយកចិត្តទុកដាក់ ធ្វើឲ្យគ្រីស្ដបរិស័ទចូលរួមក្នុងពិធីបុណ្យ ដោយយល់អត្ថន័យ គឺយល់អត្ថន័យនៃពិធីចូលរួមយ៉ាងសកម្ម និងតាមរបៀបដែលអាចបង្កើតផលបានទៀតផង មិនត្រូវគិតគូរឲ្យគ្រាន់តែគោរពតាមច្បាប់ ឬគ្រាន់តែធ្វើពិធីយ៉ាងត្រឹមត្រូវតាមវិន័យប៉ុណ្ណោះទេ។

## ១២-ពិធីគោរពប្រណិប័តន៍ និងពិធីគោរពតាមប្រពៃណី

ការរស់នៅតាមព្រះវិញ្ញាណ មិនអាស្រ័យតែលើការចូលរួមក្នុងពិធីគោរពប្រណិប័តន៍ប៉ុណ្ណោះទេ។ ទោះជាព្រះ

ជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទ ឲ្យអធិដ្ឋានរួមជាមួយអ្នកឯទៀតៗក្ដី ក៏គេត្រូវចូលទៅក្នុងបន្ទប់របស់ខ្លួន ហើយទូលទៅព្រះបិតានៅទីស្ងាត់កំបាំង (មថ ៦, ៦)។ លើសពីនេះទៅទៀត គេត្រូវអធិដ្ឋានឥតឈប់ឈរ តាមគ្រីស្តទូតប៉ូលប្រៀនប្រដៅ (១ថស ៥, ១៧)។ គ្រីស្តទូតប៉ូលដដែល បង្រៀនយើងថា យើងត្រូវផ្ទុកសេចក្ដីស្លាប់របស់ព្រះយេស៊ូក្នុងរូបកាយយើង ដែលរមែងតែងតែស្លាប់ ដើម្បីឲ្យព្រះជន្មរបស់ព្រះយេស៊ូ លេចចេញមកឲ្យគេឃើញនៅក្នុងរូបកាយយើងដែរ (២ករ ៤, ១០-១១)។ ហេតុនេះហើយ បានជាក្នុងសក្ការបូជានៃអភិបូជា យើងតែងអង្វរព្រះអម្ចាស់ថា ដោយព្រះអង្គសព្វព្រះហឫទ័យទទួលយញ្ញបូជាខាងវិញ្ញាណនោះទុកជាតង្វាយ សូមព្រះអង្គលើកយើង *"ទុកជាតង្វាយ ដែលស្ថិតនៅអស់កល្បជានិច្ច ថ្វាយព្រះអង្គ"*។

### ១៣-គួរទន្ទានយ៉ាងខ្លាំងឲ្យគ្រីស្តបរិស័ទធ្វើពិធីតាមប្រពៃណី

លុះត្រាតែពិធីទាំងនោះ ស្របតាមច្បាប់ និងតាមសេចក្ដីណែនាំរបស់ព្រះសហគមន៍ ជាពិសេសប្រសិនបើគេនាំគ្នាធ្វើពិធីទាំងនោះ ស្របតាមបទបញ្ជារបស់សន្តអាសនៈ។

ត្រូវចាត់ទុកថា ពិធីតាមប្រពៃណីរបស់ព្រះសហគមន៍ភូមិភាគនីមួយៗ មានតម្លៃថ្លៃថ្នូរពិសេស នៅពេលណាប្រជាជននាំគ្នាធ្វើតាមបបញ្ជារបស់លោកអភិបាល ឬតាមទំនៀមទម្លាប់ ឬតាមក្បួនពិធី ដែលបានទទួលការអនុម័តត្រឹមត្រូវតាមច្បាប់។

ប៉ុន្តែ ត្រូវចាត់ចែងពិធីតាមប្រពៃណីទាំងនោះ ដោយគិតគូរដល់ពិធីគោរពប្រណិប័តន៍តាមរដូវប្រចាំឆ្នាំ ដើម្បីឲ្យពិធីតាមប្រពៃណីទាំងនោះ សមស្របតាមពិធីគោរពប្រណិប័តន៍តាមរដូវប្រចាំឆ្នាំ ដែលហាក់ដូចជាពិធីតាមប្រពៃណីទាំងនោះ ហូរចេញមកពីពិធីតាមរដូវប្រចាំឆ្នាំ ព្រមទាំងណែនាំប្រជាជនឲ្យចូលរួមក្នុងពិធីប្រចាំឆ្នាំទៀតផង ពីព្រោះតាមលក្ខណៈនៃពិធី គឺពិធីគោរពប្រណិប័តន៍តាមរដូវប្រចាំឆ្នាំ ប្រសើរជាងពិធីគោរពតាមប្រពៃណីទាំងនោះ។

## ២-ត្រូវអប់រំគ្រីស្តបរិស័ទខាងពិធីគោរពប្រណិប័តន៍ និងឲ្យចូលរួមយ៉ាងសកម្ម

### ១៤-ព្រះសហគមន៍ជាមាតា

មានបំណងប្រាថ្នាចង់ណែនាំគ្រីស្តបរិស័ទទាំងអស់ ឲ្យចូលរួមក្នុងពិធីគោរពប្រណិប័តន៍យ៉ាងពេញលេញ ដោយយល់អត្ថន័យ និងចូលរួមយ៉ាងសកម្មទៀតផង។ របៀបចូលរួមក្នុងពិធីបែបនេះ ពិតជាស្របតាមលក្ខណៈផ្ទាល់នៃពិធីគោរពប្រណិប័តន៍ ហើយគ្រីស្តបរិស័ទទាំងអស់ក៏មានសិទ្ធិ និងមានភារកិច្ចចូលរួមក្នុងពិធីតាមបែបនេះដែរ ព្រោះគ្រីស្តបរិស័ទ ដែលទទួលអគ្គសញ្ញាជ្រមុជទឹកជា *"ពូជសាសន៍មួយដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាជាតិសាសន៍ដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះជាម្ចាស់ បានយកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ"* (១សល ២, ៩; ២, ៤-៥)។

ពេលកែសម្រួល និងលើកស្ទួយពិធីគោរពប្រណិប័តន៍ ត្រូវខិតខំឲ្យអស់ពីសមត្ថភាព តាមគោលដៅតែមួយ គឺណែនាំឲ្យប្រជាជនទាំងមូលចូលរួមយ៉ាងពេញលេញ និងយ៉ាងសកម្មក្នុងពិធីគោរពប្រណិប័តន៍ទាំងនោះ។ ពិធីគោរពប្រណិប័តន៍ពិតជាប្រភពទីមួយ និងដ៏ចាំបាច់ដែលខានមិនបាន ដើម្បីឲ្យគ្រីស្តបរិស័ទ មានចិត្តគំនិតជាគ្រីស្តបរិស័ទសុទ្ធសាធ។ ហេតុនេះហើយ បានជាអស់លោកគង្វាលព្រះសហគមន៍ ត្រូវខិតខំខ្នះខ្នែងក្នុងគ្រប់កិច្ចការណែនាំរបស់ខ្លួន

អប់រំប្រជាជនគ្រីស្តបរិស័ទឲ្យចូលរួមក្នុងពិធីបុណ្យបែបនេះ ដោយប្រើវិធីគរុកោសល្យតាមសេចក្តីត្រូវការ។

ប៉ុន្តែ ប្រសិនបើគោលគំនិត និងកម្លាំងនៃពិធីគោរពប្រណិប័តន៍មិនជ្រួតជ្រាបចិត្តអស់លោកគង្វាលយ៉ាងជ្រៅទេ ហើយប្រសិនបើអស់លោក មិនបានទទួលសមត្ថភាពអាចបង្រៀនអ្នកដទៃជាមុនសិននោះ មហាសន្និបាត គ្មានសង្ឃឹមថា នឹងទៅដល់គោលដៅរបស់ខ្លួនបានឡើយ។ ហេតុនេះហើយ ត្រូវគិតគូរអំពីការអប់រំក្រុមគង្វាល អំពីពិធីគោរពប្រណិប័តន៍ជាមុនសិន។ ការនេះពិតជាចំបាច់បំផុត។ អាស្រ័យហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធបានសម្រេចសេចក្តីដូចតទៅ៖

## ១៥-ត្រូវអប់រំសាស្ត្រាចារ្យខាងពិធីគោរពគោរពប្រណិប័តន៍

សាស្ត្រាចារ្យដែលបង្រៀនអំពីពិធីគោរពប្រណិប័តន៍នៅក្នុងទេវវិទ្យាល័យ នៅក្នុងគេហដ្ឋានអប់រំ បព្វជិត បព្វជិតា និងនៅក្នុងមហាវិទ្យាល័យខាងទេវវិទ្យា ត្រូវទទួលការហ្វឹកហ្វឺនអប់រំនៅគ្រឹះស្ថាន ដែលមានគោលដៅបង្រៀនអំពីពិធីគោរពប្រណិប័តន៍។

## ១៦-ការអប់រំក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង

ត្រូវរាប់បញ្ចូលការបង្រៀនអំពីពិធីគោរពប្រណិប័តន៍ ក្នុងចំណោមមុខវិជ្ជាដ៏សំខាន់ៗ និងដែលត្រូវការជាចាំបាច់ ដែលត្រូវតែរៀននៅក្នុងទេវវិទ្យាល័យ និងនៅក្នុងគេហដ្ឋានអប់រំបព្វជិតបព្វជិតា។ នៅមហាវិទ្យាល័យខាងទេវវិទ្យាវិញ ត្រូវរាប់បញ្ចូលការបង្រៀនអំពីពិធីគោរពប្រណិប័តន៍ ក្នុងចំណោមមុខវិជ្ជាដ៏សំខាន់ជាងគេ។ ត្រូវបង្រៀនអំពីពិធីគោរពប្រណិប័តន៍ ដោយនឹកគិតដល់ទេវវិទ្យា និងដល់ប្រវត្តិវិទ្យា ព្រមទាំងដល់វិជ្ជានៃជីវិតតាមព្រះវិញ្ញាណ ដល់វិជ្ជាណែនាំគ្រីស្តបរិស័ទ និងដល់ច្បាប់វិន័យទៀតផង។ ម្យ៉ាងទៀត សាស្ត្រាចារ្យដែលបង្រៀនមុខវិជ្ជាផ្សេងៗជាពិសេសសាស្ត្រាចារ្យបង្រៀនទេវវិទ្យាលទ្ធិមូលដ្ឋាន បង្រៀនព្រះគម្ពីរ បង្រៀនវិជ្ជានៃជីវិតតាមព្រះវិញ្ញាណវិជ្ជាណែនាំគ្រីស្តបរិស័ទ ក៏ត្រូវយកចិត្តទុកដាក់ គូសសង្កត់លើគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងលើប្រវត្តិសាស្ត្រនៃការសង្គ្រោះ តាមតែមុខវិជ្ជារបស់ខ្លួនអនុញ្ញាតឲ្យ ទើបនិស្សិតអាចយល់ឃើញយ៉ាងច្បាស់ថា មុខវិជ្ជាទាំងនោះ ពាក់ពន្ធ័ជាមួយពិធីគោរពប្រណិប័តន៍ ព្រមទាំងយល់ឃើញថា ការអប់រំរបស់បូជាចារ្យស៊ីគ្នាពីខាងក្នុងទៀតផង។

## ១៧-ចំពោះអស់អ្នកដែលនឹងទទួលអគ្គសញ្ញាតែងតាំង

នៅពេលខាងមុខហើយកំពុងតែរៀននៅទេវវិទ្យាល័យ និងនៅក្នុងគេហដ្ឋានអប់រំបព្វជិតបព្វជិតា ត្រូវយកពិធីគោរពប្រណិប័តន៍ មកអប់រំខ្លួនឲ្យមានជីវិតខាងព្រះវិញ្ញាណ គឺត្រូវណែនាំគេយ៉ាងប្រសើរឲ្យយល់អត្ថន័យពិធីដ៏សក្ការៈ និងឲ្យផ្ចង់ចិត្តយ៉ាងខ្លាំងនឹងពិធីទាំងនោះ។ ត្រូវធ្វើពិធីលើកតម្កើងព្រឹត្តិការណ៍ដ៏វិសុទ្ធ ពោលគឺថ្វាយអភិបូជា និងប្រព្រឹត្តកិច្ចគោរពប្រណិប័តន៍ផ្សេងទៀតផង ដោយមានពិធីគោរពប្រណិប័តន៍ជ្រួតជ្រាបចិត្តគេផងដែរ។ គេក៏ត្រូវរៀនឲ្យចេះគោរពក្បួនវិន័យនៃពិធីគោរពប្រណិប័តន៍ដែរ។ ធ្វើដូច្នេះទើបការរស់នៅក្នុងទេវវិទ្យាល័យ និងនៅក្នុងគេហដ្ឋានអប់រំបព្វជិត បព្វជិតា នឹងជ្រួតជ្រាបដោយគោលគំនិតនៃពិធីគោរពប្រណិប័តន៍ជាពុំខាន។

## ១៨-ត្រូវជួយលោកគង្វាល

ទាំងភូមិភាគ ទាំងបព្វជិត ដែលកំពុងបម្រើព្រះសហគមន៍ ដោយប្រើជំនួយទាំងប៉ុន្មាន ដែលអស់លោកត្រូវការដើម្បីយល់អត្ថន័យពីពិធីដែលអស់លោកធ្វើ ឲ្យកាន់តែច្បាស់ នៅពេលអស់លោកបំពេញមុខងារដ៏សក្ការៈផ្សេងៗ។ ត្រូវ

ជួយអស់លោកឲ្យរស់នៅតាមពិធីគោរពប្រណិប័តន៍ និងឲ្យអស់លោកអាចចែករំលែកបទពិសោធន៍នោះ ជាមួយនឹងគ្រីស្តបរិស័ទ ដែលព្រះសហគមន៍ផ្ញើទុកមកឲ្យអស់លោក។

### ១៩-ការអប់រំគ្រីស្តបរិស័ទអំពីពិធីគោរពប្រណិប័តន៍

អស់លោកគង្វាលព្រះសហគមន៍ ត្រូវខិតខំខ្នះខ្នែងដោយចិត្តអត់ធ្មត់ បន្តការអប់រំគ្រីស្តបរិស័ទអំពីពិធីគោរពប្រណិប័តន៍ និងណែនាំឲ្យគេចូលរួមក្នុងពិធីទាំងអស់យ៉ាងសកម្ម ទាំងខាងរូបកាយ ទាំងខាងវិញ្ញាណផង។ ត្រូវអប់រំគេស្របតាមអាយុ តាមសភាពការណ៍ជីវភាព និងតាមកម្រិតវប្បធម៌សាសនារបស់គេទៀតដែរ។ ធ្វើដូច្នេះ ទើបអស់លោកដែលណែនាំព្រះសហគមន៍ មុខជានឹងសម្រេចភារកិច្ចមួយដ៏សំខាន់របស់ខ្លួន ជាអ្នកចាត់ចែងអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់យ៉ាងស្មោះត្រង់។ ក្នុងករណីនេះ អស់លោកមិនត្រូវណែនាំហ្វូងចៀមរបស់ខ្លួន ដោយគ្រាន់តែប្រើពាក្យសម្ដីប៉ុណ្ណោះទេ តែខ្លួនផ្ទាល់ត្រូវធ្វើជាគំរូដល់គេថែមទៀតផង។

### ២០-មធ្យោបាយផ្សព្វផ្សាយពិធីគោរពប្រណិប័តន៍

ត្រូវផ្សព្វផ្សាយពិធីគោរពប្រណិប័តន៍ដ៏សក្ការៈ ជាពិសេសអភិបូជា តាមវិទ្យុនិងតាមទូរទស្សន៍ តាមរបៀបដ៏ថ្លៃថ្នូរមិនអធិកអធមពេក ស្ថិតក្រោមការណែនាំនិងធានារ៉ាប់រងរបស់អ្នកស្ទាត់ជំនាញម្នាក់ ដែលលោកអភិបាលចាត់ចែងឲ្យបំពេញមុខងារនេះ។

## ៣-ការកែសម្រួលពិធីគោរពប្រណិប័តន៍ដ៏សក្ការៈ

### ២១-ព្រះសហគមន៍ជាព្រះមាតា

គួរឲ្យគោរព មានបំណងយកចិត្តទុកដាក់យ៉ាងខ្លាំង នឹងកែសម្រួលពិធីគោរពប្រណិប័តន៍ទូទៅឲ្យប្រែជាថ្មី ដើម្បីឲ្យប្រជារាស្ត្រគ្រីស្តបរិស័ទ អាចទទួលព្រះអំណោយទានយ៉ាងច្រើន ពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ដោយសារពិធីគោរពប្រណិប័តន៍ដ៏សក្ការៈទាំងនោះ។ ក្នុងពិធីគោរពប្រណិប័តន៍ មានផ្នែកមួយដែលកែសម្រួលមិនបាន គឺអ្វីៗដែលព្រះជាម្ចាស់បានតែងតាំង។ មានផ្នែកផ្សេងៗទៀត ដែលអាចប្រែប្រួលតាមដំណើរនៃប្រវត្តិសាស្ត្របាន។ ប្រសិនបើមានសេចក្ដីខ្លះ ចូលលាយឡំក្នុងពិធីបុណ្យដោយចៃដន្យ ជាសេចក្ដីដែលមិនសូវស៊ីនឹងលក្ខណៈនៃពិធីបុណ្យ ឬមិនសូវសមស្របនឹងសម័យបច្ចុប្បន្ន ក៏សេចក្ដីទាំងនោះអាចកែសម្រួលបាន ហើយក៏ត្រូវតែកែសម្រួលទៀតផង។

ត្រូវកែសម្រួលពិធីគោរពប្រណិប័តន៍ឲ្យបានជាថ្មី ដោយចាត់ចែងអត្ថបទនិងពិធីនានា តាមរបៀបដែលបង្ហាញអត្ថន័យយ៉ាងច្បាស់ថា ពិធីទាំងនោះជាសញ្ញាសម្គាល់អំពីព្រះហឫទ័យប្រណីសន្ដោសដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ ដោយកែសម្រួលពិធីគោរពប្រណិប័តន៍ឲ្យបានជាថ្មីដូច្នេះ ទើបប្រជាជនគ្រីស្តបរិស័ទ ងាយស្រួលយល់អត្ថន័យឲ្យកាន់តែច្បាស់។ ប្រសិនបើអាចធ្វើបាន ប្រជាជនក៏អាចចូលរួមក្នុងពិធីទាំងនោះយ៉ាងពេញលេញ និងយ៉ាងសកម្ម ព្រមទាំងរួមគ្នាជាសហគមន៍ទៀតផង។ ហេតុនេះហើយបានជាមហាសន្និបាតដ៏វិសុទ្ធបានតែងតាំងសេចក្ដីណែនាំទូទៅដូចតទៅ៖

#### ក-សេចក្ដីណែនាំទូទៅ

### ២២-អំពីអ្នកទទួលខុសត្រូវពិធីគោរពប្រណិប័តន៍

១- ការសម្រេចសេចក្ដីអំពីពិធីគោរពប្រណិប័តន៍ដ៏សក្ការៈ អាស្រ័យតែលើអំណាចនៃព្រះសហគមន៍ប៉ុណ្ណោះ

គឺថា មានតែសន្ត អាសនៈប៉ុណ្ណោះ អាចសម្រេចបាន ហើយក៏អាស្រ័យលើលោកអភិបាលសម្រេច តាមក្បួនច្បាប់បានកំណត់ទុក។

២-ក្រុមអភិបាលតែងតាំងយ៉ាងត្រឹមត្រូវតាមច្បាប់ ដែលមានសមត្ថកិច្ចក្នុងតំបន់មួយ ក៏មានអំណាចអាចសម្រេចសេចក្តី អំពីពិធីគោរពប្រណិប័តន៍បាន តាមកម្រិតអំណាចក្រុមអភិបាលទាំងនោះ កំណត់តាមច្បាប់រួចហើយ។

៣-ហេតុនេះហើយ បានជាគ្មាននរណាផ្សេងទៀត សូម្បីតែបូជាចារ្យ (អាចារ្យ)ក្តី មានសិទ្ធិបន្ថែមបន្ថយអ្វី ឬផ្លាស់ប្តូរអ្វី ក្នុងពិធីគោរពប្រណិប័តន៍ដោយខ្លួនឯងបានសោះ។

## ២៣-ការបញ្ជូនបន្ត និងការអភិវឌ្ឍន៍ពិធីគោរពប្រណិប័តន៍

មុននឹងកែសម្រួលផ្នែកនីមួយៗ ដែលត្រូវការកែសម្រួលនោះ ត្រូវស្រាវជ្រាវយ៉ាងហ្មត់ចត់តាមទេវវិទ្យា តាមប្រវត្តិសាស្ត្រ និងតាមកិច្ចការណែនាំគ្រីស្តបរិស័ទជាមុនសិនដើម្បីរក្សាទុកការបញ្ជូនបន្តដ៏ត្រឹមត្រូវនៃព្រះសហគមន៍ផង និងដើម្បីឲ្យពិធីគោរពប្រណិប័តន៍អាចអភិវឌ្ឍន៍ឲ្យចម្រើនឡើងផងដែរ។ លើសពីនេះទៅទៀត ក៏ត្រូវគិតគូរដល់ក្បួនវិន័យទូទៅអំពីរចនាសម្ពន្ធ និងអំពីគោលដៅនៃពិធីគោរពប្រណិប័តន៍ ព្រមទាំងគិតគូរដល់បទពិសោធន៍អំពីការកែសម្រួលពិធីគោរពប្រណិប័តន៍តាំងពីប៉ុន្មានឆ្នាំកន្លងមក ហើយក៏ត្រូវនឹកដល់សេចក្តីអនុញ្ញាតតាមតំបន់ផ្សេងៗទៀតផង។ មិនតែប៉ុណ្ណោះ ត្រូវកែសម្រួលពិធីឲ្យបានជាថ្មី លុះត្រាតែមានប្រយោជន៍ដល់ព្រះសហគមន៍យ៉ាងពិតប្រាកដ និងយ៉ាងជាក់ច្បាស់ ហើយក៏ត្រូវធានាអះអាងយ៉ាងច្បាស់ថា របៀបធ្វើពិធីបែបថ្មីៗនោះ ហូរចេញមកពីរបៀបពិធីដែលធ្លាប់ធ្វើពីមុនមក ហាក់ដូចជាកើតចេញពីពិធីចាស់នោះវិញ។ ប្រសិនបើអាចធ្វើបាន ត្រូវជៀសវាងកុំឲ្យមានពិធីប្លែកៗពីគ្នាខ្លាំងពេកក្នុងតំបន់ដែលនៅក្បែរគ្នា។

## ២៤-ព្រះគម្ពីរ និងពិធីគោរពប្រណិប័តន៍

ព្រះគម្ពីរមានសារៈសំខាន់យ៉ាងខ្លាំងជាទីបំផុតក្នុងពិធីគោរពប្រណិប័តន៍ ព្រោះអត្ថបទដែលបានប្រកាសក្នុងពិធីទាំងនោះ និងដែលគេពន្យល់តាមពិធីអត្ថាធិប្បាយ ព្រមទាំងទំនុកតម្កើងដែលគេសូត្រ សុទ្ធតែដកស្រង់ចេញពីព្រះគម្ពីរមក។ ពាក្យអធិដ្ឋានផ្សេងៗ ពាក្យអង្វរនានា និងបទចម្រៀងក្នុងពិធីគោរពប្រណិប័តន៍ ក៏សុទ្ធសឹងតែយោងគំនិត និងកម្លាំងពីព្រះគម្ពីរដែរ។ កាយវិការនិងនិមិត្តរូបផ្សេងៗ ក៏ទទួលអត្ថន័យពីព្រះគម្ពីរថែមទៀតផង។ ហេតុនេះហើយ បានជាត្រូវតែលើក ស្ទួយឲ្យគ្រីស្តបរិស័ទក្រេបជញ្ជក់ឱជារសដ៏ឆ្ងាញ់នៃព្រះគម្ពីរដែលមានជីវិតរស់រវើក តាមការបញ្ជូនបន្តគួរឲ្យគោរពនៃរបៀបរបបពិធីនៅបូព៌ាប្រទេស និងនៅបស្ចិមប្រទេសផ្តល់សក្ខីភាពស្រាប់។ បើធ្វើដូច្នេះ ទើបការកែសម្រួលពិធីគោរពប្រណិប័តន៍ដ៏សក្ការៈបានជាថ្មី នឹងចម្រើនឡើង ហើយសមស្របតាមសម័យ ព្រមទាំងទទួលជ័យជម្នះពុំខាន។

## ២៥-ត្រូវកែសម្រួលក្បួនពិធីគោរពប្រណិប័តន៍

ត្រូវកែសម្រួលសៀវភៅ ក្បួនពិធីគោរពប្រណិប័តន៍យ៉ាងប្រញាប់បំផុត ដោយសូមអ្នកជំនាញការជួយផង និងដោយសួរយោបល់របស់អស់លោកអភិបាលតាមតំបន់ផ្សេងៗ ក្នុងពិភពលោកទាំងមូល។

## ខ-សេចក្តីណែនាំមកពីលក្ខណៈពិធីជាកិច្ចការរួមរបស់ប្រជាជន

### ២៦-ពិធីគោរពប្រណិប័តន៍

មិនមែនជាកិច្ចឯកជនរបស់គ្រីស្តបរិស័ទម្នាក់ៗទេ តែពិតជាកិច្ចលើកតម្កើងរួមរបស់ព្រះសហគមន៍ ដែលជា *"អគ្គសញ្ញាសម្តែងអំពីការរួបរួមគ្នាជាធ្លុងតែមួយ"* ពោលគឺ ជាប្រជារាស្ត្រដ៏វិសុទ្ធដែលជួបជុំគ្នា និងដែលមានរបៀបរៀបរយតាមលំដាប់លំដោយ ក្រោមការណែនាំរបស់ក្រុមអភិបាល។

ហេតុនេះហើយ បានជាពិធីគោរពប្រណិប័តន៍ ទាក់ទិននឹងព្រះកាយនៃព្រះសហគមន៍ទាំងមូល និងសម្តែងព្រះកាយនេះឲ្យគេឃើញ ហើយក៏មានឥទ្ធិពលលើព្រះកាយនោះទៀតផងដែរ។ ប៉ុន្តែ ពិធីគោរពប្រណិប័តន៍ទាំងនោះមានទំនាក់ទំនងនឹងសមាជិកនីមួយៗ តាមរបៀបផ្សេងៗពីគ្នា គឺតាមការតែងតាំងផ្សេងៗ តាមមុខងារផ្សេងៗ និងតាមរបៀបគេចូលរួម ក្នុងពិធីទាំងនោះទៀតផង។

### ២៧-ពិធីរួម

តាមលក្ខណៈពិសេសនៃពិធីនីមួយៗ ពេលណាពិធីនានាអាចប្រព្រឹត្តទៅដោយរួមគ្នាបាន ដោយមានគ្រីស្តបរិស័ទចូលរួមជារឿយៗនិងយ៉ាងសកម្មផង ប្រសិនបើអាចធ្វើបាន ត្រូវគូសបញ្ជាក់ថា ការធ្វើពិធីរួមប្រសើរជាងធ្វើពិធីម្នាក់ឯងដែលហាក់ដូចជាពិធីផ្ទាល់ខ្លួនតែម្តង។ សេចក្តីណែនាំនេះបានការ ជាពិសេសសំដៅទៅលើអភិបូជា និងលើអគ្គសញ្ញាផ្សេងៗជូនគ្រីស្តបរិស័ទ។ តាមពិត អភិបូជានៅតែមានលក្ខណៈជាពិធីសាធារណៈ និងមានលក្ខណៈជាពិធីរួម របស់សង្គមជានិច្ច។

### ២៨-តម្លៃដ៏ថ្លៃថ្នូរនៃពិធីលើកតម្កើង

ពេលធ្វើពិធីលើកតម្កើងផ្សេងៗ ទាំងលោកដែលមានមុខងារបម្រើ ទាំងគ្រីស្តបរិស័ទក៏ម្នាក់ៗត្រូវតែប្រព្រឹត្តតាមតួនាទីរៀងៗខ្លួន គឺត្រូវបំពេញតួនាទីនេះទាំងមូល ហើយបំពេញតែតួនាទីរបស់ខ្លួនប៉ុណ្ណោះ ស្របតាមលក្ខណៈ ពិធីនោះ និងស្របតាមសេចក្តីណែនាំពិធីគោរពប្រណិប័តន៍ទៀតផងដែរ។

### ២៩-អ្នកបម្រើអាសនៈ

អ្នកប្រកាសអត្ថបទគម្ពីរ អ្នកណែនាំកម្មវិធី និងអស់សមាជិកក្រុមអ្នកចម្រៀង គឺសុទ្ធតែបំពេញ មុខងារបម្រើពិធីគោរពប្រណិប័តន៍យ៉ាងពិតប្រាកដមែន។ ហេតុនេះហើយ បានជាគេត្រូវបំពេញបន្ទុកនោះ ដោយចិត្តស្រឡាញ់យ៉ាងស្មោះ និងតាមរបៀបរៀបរយ សមស្របតាមមុខងារដ៏ប្រសើរឧត្តមនេះ និងសមស្របតាមប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាមទារយ៉ាងត្រឹមត្រូវឲ្យគេបម្រើនោះ។

ហេតុនេះហើយ ត្រូវអប់រំអ្នកទាំងនោះឲ្យជ្រួតជ្រាបនូវគោលគំនិតនៃពិធីគោរពប្រណិប័តន៍ តាមតែម្នាក់ៗអាចទទួលបាន ហើយត្រូវហ្វឹកហ្វឺនគេឲ្យបំពេញតួនាទីរបស់ខ្លួនយ៉ាងត្រឹមត្រូវ និងតាមរបៀបរៀបរយទៀតផង។

### ៣០-គ្រីស្តបរិស័ទត្រូវចូលរួមពិធីគោរពប្រណិប័តន៍យ៉ាងសកម្ម

ត្រូវលើកស្ទួយឲ្យប្រជាជន បន្លឺសំឡេងអបអរសាទរ តបឆ្លើយនឹងបូជាចារ្យ ស្មូតទំនុកតម្កើង អានពាក្យបន្ទរ

នៃទំនុកតម្កើង និងច្រៀងបទផ្សេងៗ ព្រមទាំងធ្វើកាយវិការ និងមានឥរិយាបថខ្លះ ដើម្បីឲ្យគេចូលរួមក្នុងពិធីគោរពប្រណិប័តន៍យ៉ាងសកម្ម។ ក្នុងពេលធ្វើពិធី ត្រូវទុកឲ្យមានពេលស្ងៀមស្ងាត់ខ្លះសម្រាប់អធិដ្ឋាន។

### ៣១- នៅពេលកែសម្រួលសៀវភៅ

ជាក្បួនពិធីគោរពប្រណិប័តន៍ ត្រូវយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្ន ឲ្យចែងជាពណ៌ក្រហម អំពីអ្វីៗដែលគ្រីស្តបរិស័ទត្រូវធ្វើ។

### ៣២- ពិធីគោរពប្រណិប័តន៍ និងឋានៈវណ្ណៈក្នុងសង្គម

ក្នុងពិធីគោរពប្រណិប័តន៍ មិនត្រូវរើសអើងនរណាឲ្យសោះ។ ក្រៅពីបន្ទុកផ្សេងៗក្នុងពិធីគោរពប្រណិប័តន៍ និងពីមុខងារជាបូជាចារ្យ ហើយក្រៅពីរដ្ឋអំណាចដែលត្រូវគោរពស្របតាមច្បាប់នៃពិធីគោរពប្រណិប័តន៍ មិនត្រូវរើសមុខនរណាឡើយ។ ទោះជាបុគ្គលម្នាក់ៗក្តី ជាអ្នកមានឋានៈវណ្ណៈខ្ពស់យ៉ាងណាក្តី នៅក្នុងពិធីនានាក្តីឬនៅក្នុងពិធីលើកកិត្តិយសខាងក្រៅពីពិធីបុណ្យក្តី ក៏មិនត្រូវរើសអើងនរណាឡើយ។

## គ. សេចក្តីណែនាំមកពីលក្ខណៈគរុកោសល្យ និងលក្ខណៈណែនាំនៃពិធីគោរពប្រណិប័តន៍

### ៣៣-គោលបំណងពិធីគោរពប្រណិប័តន៍

មានគោលដៅលើកតម្កើងសិរីរុងរឿងរបស់ព្រះដ៏ឧត្តុងឧត្តមបំផុត ជាគោលដៅដ៏សំខាន់ជាងគេក្តី ក៏ពិធីគោរពប្រណិប័តន៍មានប្រយោជន៍ជាខ្លាំង សម្រាប់បង្រៀនប្រជាជនគ្រីស្តបរិស័ទតាមគរុកោសល្យដែរ។ ក្នុងពិធីគោរពប្រណិប័តន៍នោះ ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ប្រជារាស្ត្រព្រះអង្គ ព្រះគ្រីស្តក៏នៅតែប្រកាសដំណឹងល្អដែរ។ រីឯប្រជាជនក៏ឆ្លើយតបដោយបទចម្រៀង និងដោយពោលពាក្យអង្វរទៀតផង។

លើសពីនេះទៅទៀត លោកបូជាចារ្យដែលជាប្រធានអង្គប្រជុំក្នុងឋានៈជាតំណាងព្រះគ្រីស្ត ពោលពាក្យថ្វាយព្រះបិតា ក្នុងនាមប្រជាជនដ៏វិសុទ្ធទាំងមូលនិងក្នុងនាមអស់អ្នកដែលចូលរួមផង។ ក្នុងពិធីនានា ព្រះគ្រីស្ត ឬព្រះសហគមន៍ បានជ្រើសរើសវត្ថុនិងកាយវិការដែលមើលឃើញ ធ្វើជាសញ្ញាសម្គាល់អំពីអ្វីៗដ៏ពិតបាក្រដពាក់ពន្ធនឹងព្រះជាម្ចាស់ដែលមើលមិនឃើញ។ ហេតុនេះហើយ បានជាពេលមានអាន *"អ្វីៗដែលមានចែងទុកពីមុនមក គឺចែងទុកសម្រាប់អប់រំយើង"* (រម ១៥, ៤) ហើយពេលព្រះសហគមន៍អធិដ្ឋាន ឬច្រៀង ឬធ្វើកិច្ចការផ្សេងៗ សុទ្ធតែជាកិច្ចចិញ្ចឹមជំនឿអ្នកចូលរួម និងលើកចិត្តគេថ្វាយព្រះជាម្ចាស់ដែរ។ គេគោរពថ្វាយបង្គំព្រះអង្គតាមព្រះវិញ្ញាណ ហើយទទួលព្រះអំណោយទានតាមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គឲ្យបរិបូរណ៍ទៀតផង។ ហេតុនេះហើយ បានជានៅពេលកែសម្រួលពិធីគោរពប្រណិប័តន៍ ត្រូវតែអនុម័តតាមសេចក្តីណែនាំដូចតទៅ៖

### ៣៤-ពិធីនីមួយៗត្រូវភ្ជាប់នឹងពិធីឯទៀតៗយ៉ាងសមរម្យ

ត្រូវឲ្យពិធីនីមួយៗបានថ្លៃថ្នូរ តែងាយស្រួលយល់ ដោយពិធីនោះខ្លី និងសម្តែងអត្ថន័យយ៉ាងច្បាស់។ ត្រូវជៀសវាង កុំឲ្យច្រំដែលៗឥតបានការ។ ពិធីទាំងនោះ ត្រូវស្របតាមសមត្ថភាពគ្រីស្តបរិស័ទអាចស្តាប់បាន។ ជាទូទៅ មិនត្រូវការ ឲ្យនរណាពន្យល់ពិធីយ៉ាងច្រើន ដើម្បីឲ្យគេអាចយល់អត្ថន័យ គឺត្រូវឲ្យគេអាចយល់ដោយខ្លួនឯងតែម្តង។

## ៣៥-ព្រះគម្ពីរ ពិធីអត្ថាធិប្បាយព្រះគម្ពីរ និងការអប់រំជំនឿតាមពិធីគោរពប្រណិប័តន៍

ក្នុងគោលបំណងឲ្យឃើញច្បាស់ថា ព្រះគម្ពីរនិងពិធីភ្ជាប់ជាមួយគ្នាយ៉ាងស្អិតរមួតក្នុងពិធីគោរពប្រណិប័តន៍ត្រូវៈ

១- ក្នុងពិធីលើកតម្កើងដ៏សក្ការៈផ្សេងៗ ត្រូវកែសម្រួលឲ្យប្រកាសអត្ថបទព្រះគម្ពីរច្រើនជាងពីមុន គឺអត្ថបទខុសប្លែកៗ ពីគ្នាជាងពីមុន ហើយសមស្របនឹងពិធីគោរពប្រណិប័តន៍ដែលកំពុងតែធ្វើនោះ។

២- ពិធីអត្ថាធិប្បាយព្រះគម្ពីរ ពិតជាផ្នែកមួយនៃពិធីគោរពប្រណិប័តន៍។ ហេតុនេះ ប្រសិនបើពិធីគោរពប្រណិប័តន៍អនុញ្ញាតឲ្យមាន ពិធីអត្ថាធិប្បាយព្រះគម្ពីរ ត្រូវកំណត់ពេលឲ្យបានសមនឹងធ្វើពិធីអត្ថាធិប្បាយនោះ កត់ទុកក្នុងក្បួនពិធី។ ត្រូវបំពេញមុខងារអត្ថាធិប្បាយព្រះគម្ពីរនេះ ដោយចិត្តស្មោះយ៉ាងខ្លាំងជាទីបំផុត និងយ៉ាងត្រឹមត្រូវ។ អ្នកធ្វើពិធីអត្ថាធិប្បាយព្រះគម្ពីរ ត្រូវយោងសេចក្តីពីព្រះគម្ពីរ និងពីពិធីគោរពប្រណិប័តន៍ទុកជាប្រភព ព្រោះក្នុងពិធីគោរពប្រណិប័តន៍ មានប្រកាសអំពីស្នាព្រះហស្តដ៏អស្ចារ្យទាំងប៉ុន្មាន ដែលព្រះជាម្ចាស់បានប្រព្រឹត្តតាមប្រវត្តិសាស្ត្រនៃការសង្គ្រោះ គឺជាគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តតែម្តង។ គម្រោងការនេះស្ថិតនៅជានិច្ច ហើយក៏នៅតែមានសកម្មភាពក្នុងកណ្តាលចំណោមយើងដែរ ជាពិសេសនៅពេលយើងធ្វើពិធីគោរពប្រណិប័តន៍នានា។

៣- លើសពីនេះទៅទៀត ត្រូវប្រើរបៀបគ្រប់យ៉ាង ដើម្បីអប់រំជំនឿតាមពិធីគោរពប្រណិប័តន៍។ ប្រសិនបើត្រូវការ ត្រូវរៀបចំពាក្យលំនាំខ្លីៗឲ្យអានក្នុងពិធី។ បូជាចារ្យ ឬអ្នកមានសមត្ថកិច្ចផ្សេងទៀត ត្រូវអានពាក្យលំនាំនោះ នៅពេលដ៏សមរម្យ តាមសេចក្តីដែលគេរៀបចំទុកជាមុន ឬដោយពោលពាក្យស្រដៀងនឹងសេចក្តីនោះ។

៤- ត្រូវយកចិត្តទុកដាក់ធ្វើពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ នៅយប់មុនបុណ្យដ៏ឱឡារិកនានា នៅថ្ងៃខ្លះក្នុងរដូវ អបអរសាទរព្រះគ្រីស្តយាងមក និងក្នុងរដូវអប់រំពិសេស ព្រមទាំងនៅថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យ។ ជាពិសេសនៅភូមិគ្មានបូជាចារ្យ ក៏ត្រូវយកចិត្តទុកដាក់ធ្វើពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ដែរ។ ក្នុងករណីនេះ ឧបដ្ឋាកម្នាក់ ឬគ្រីស្តបរិស័ទម្នាក់ផ្សេងទៀត ជាតំណាងរបស់លោកអភិបាល អាចណែនាំពិធីលើកតម្កើងព្រះបន្ទូលនោះបាន។

## ៣៦-ភាសាក្នុងពិធីគោរពប្រណិប័តន៍

១- ត្រូវតែប្រើភាសាឡាតាំង ក្នុងព្រះសហគមន៍ទាំងប៉ុន្មាន ដែលកាន់តាមរបៀបរបបពិធីឡាតាំងលើកលែងតែមានច្បាប់ពិសេសដោយឡែក។

២- ក៏ប៉ុន្តែ ភាសារបស់ប្រជាជនរស់នៅក្នុងតំបន់ ពិតជាមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់ប្រជាជននោះជាពិសេស នៅពេលថ្វាយអភិបូជា ឬនៅពេលធ្វើអគ្គសញ្ញានានាជូនគេ ឬនៅក្នុងផ្នែកផ្សេងៗទៀត នៃពិធីគោរពប្រណិប័តន៍។ ហេតុនេះ គួរអនុញ្ញាតឲ្យប្រើភាសាប្រជាជនតាមតំបន់ ជាពិសេសសម្រាប់ប្រកាសអត្ថបទព្រះគម្ពីរនិងពោលពាក្យណែនាំ នៅពេលពោលពាក្យអង្វរមួយចំនួន និងនៅបទចម្រៀងផ្សេងៗ តាមសេចក្តីណែនាំទាំងប៉ុន្មាន ដែលមានចែងទុកក្នុងជំពូកខាងក្រោយ សម្រាប់ករណីនីមួយៗ។

៣- ប្រសិនបើបានអនុវត្តតាមសេចក្តីណែនាំទាំងនោះរួចហើយ ក្រុមអភិបាលដែលមានសមត្ថកិច្ចក្នុងតំបន់

មួយ តាមសេចក្តីចែងក្នុងមាត្រា ២២, ២ ខាងលើនេះ (ក្រោយពីបានរិះគិតពិចារណាជាមួយក្រុមអភិបាលនៃតំបន់ជិតខាងដែល និយាយភាសាតែមួយដូចគ្នា) ក៏អាចសម្រេចអំពីការប្រើភាសា និងអំពីរបៀបប្រើភាសានោះ។ ក្រុមអភិបាលត្រូវសូម ឲ្យអាសនៈរបស់គ្រីស្តទូតសិលាទទួលស្គាល់ គឺអនុញ្ញាតឲ្យប្រើ។

៤- ពេលបកប្រែពីភាសាឡាតាំង មកជាភាសាប្រចាំតំបន់រួចហើយ មុននឹងត្រូវប្រើប្រាស់ក្នុងពិធីគោរពប្រណិប័តន៍ ក្រុមអភិបាលដែលមានសមត្ថកិច្ចក្នុងតំបន់ ត្រូវអនុម័តឲ្យប្រើ តាមសេចក្តីដែលមានបញ្ជាក់នៅខាងលើនេះ។

## ឃ. សេចក្តីណែនាំដើម្បីកែសម្រួលពិធីគោរពប្រណិប័តន៍ឲ្យបានស្រុបតាមបុគ្គលិកលក្ខណៈ និងតាមសភាពការណ៍ប្រជាជាតិនានា

### ៣៧-ព្រះសហគមន៍

គ្មានបំណងចង់បង្ខំយ៉ាងតឹងរ៉ឹងឲ្យមានរបៀបតែមួយដដែលទេ ក្នុងវិស័យណាដែលគ្មានពាក់ព័ន្ធ និងជំនឿ ឬមិនពាក់ព័ន្ធនឹងប្រយោជន៍រួមនៃព្រះសហគមន៍ទាំងមូល ទោះបីក្នុងវិស័យនៃពិធីគោរពប្រណិប័តន៍ក្តី ក៏ព្រះសហគមន៍ មិនចង់បង្ខំដែរ។ ផ្ទុយទៅវិញ ព្រះសហគមន៍គោរពនិងលើកស្ទួយព្រះអំណោយទាន និងទេពកោសល្យនៃប្រជាជាតិនានា ព្រមទាំងមានបំណងចង់ឲ្យព្រះអំណោយទាន និងទេពកោសល្យទាំងនេះចម្រើនឡើងទៀតផង។ ព្រះសហគមន៍ពេញចិត្តនឹងអ្វីៗទាំងអស់ ក្នុងរបៀបរស់នៅរបស់ប្រជាជាតិទាំងឡាយ លើកលែងតែអ្វីៗ ដែលភ្ជាប់នឹងជំនឿអកុសល ឬអ្វីៗដែលវង្វេងឆ្ងាយពីសេចក្តីពិត។ ប្រសិនជាអាចធ្វើបាន ព្រះសហគមន៍ក៏ជួយរក្សាទុកអ្វីៗទាំងនោះ ឲ្យស្ថិតនៅគង់វង្សឥតខ្ចោះ។ លើសពីនេះទៅទៀត ជួនកាលព្រះសហគមន៍ទទួលអ្វីៗទាំងនោះ ឲ្យចូលក្នុងពិធីគោរពប្រណិប័តន៍ដែរ លុះត្រាតែអ្វីទាំងនោះ ស្របតាមគោលការណ៍នៃគំនិតពិធីគោរពប្រណិប័តន៍នោះ។

### ៣៨-ត្រូវសុខចិត្តឲ្យមានសេចក្តីប្លែកៗពីគ្នាយ៉ាងត្រឹមត្រូវ

ក្នុងពិធីគោរពប្រណិប័តន៍នានា និងត្រូវសុខចិត្តកែសម្រួលពិធីនានាស្របតាមអង្គប្រជុំប្លែកៗពីគ្នា និងតាមតំបន់នីមួយៗ ហើយតាមប្រជាជាតិ ជាពិសេសនៅដែនដីដែលមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។ សូម្បីតែនៅពេលកែសម្រួលសៀវភៅក្បួនពិធីគោរពប្រណិប័តន៍ក្តី ក៏ត្រូវសុខចិត្តទទួលសេចក្តីប្លែកៗពីគ្នាដូច្នេះដែរ។ ប៉ុន្តែ ត្រូវរក្សាទុកខ្លឹមសារ នៃរបៀបរបបពិធីរបស់ព្រះសហគមន៍ក្រុងរ៉ូម ឲ្យនៅស្ថិតស្ថេរគង់វង្ស។ ត្រូវនឹកចងចាំគោលការណ៍នេះជានិច្ចនៅពេលកែសម្រួលរចនាសម្ពន្ធនៃពិធីគោរពប្រណិប័តន៍ និងនៅពេលចែងសេចក្តីណែនាំក្នុងក្បួនពិធីផង។

### ៣៩-តាមព្រំដែនដែលមានបញ្ជាក់ក្នុងសៀវភៅជាក្បួនបោះពុម្ពទុកជាគំរូ

ក្រុមអភិបាលដែលមានសមត្ថកិច្ចក្នុងតំបន់ មួយ តាមសេចក្តីចែងនៅមាត្រា ២២, ២ មានសិទ្ធិនិងភារកិច្ចបញ្ជាក់ការកែសម្រួលជាពិសេស អំពីការធ្វើអគ្គសញ្ញាជូនគ្រីស្តបរិស័ទ អំពីការធ្វើអនុសញ្ញា អំពីការធ្វើក្បួនហែយ៉ាងឱឡារិក អំពីការប្រើភាសាក្នុងពិធីគោរពប្រណិប័តន៍ អំពីភ្លេងដ៏សក្ការៈ និងអំពីសិល្បៈ។ ប៉ុន្តែ អស់លោកត្រូវគោរពស្របតាមសេចក្តីណែនាំជាគ្រឹះ ដែលមានចែងទុកក្នុងធម្មនុញ្ញនេះ។

### ៤០-ក៏ប៉ុន្តែ នៅកន្លែងផ្សេងៗ

នៅកន្លែងផ្សេងៗ និងតាមសភាពការណ៍ផ្សេងៗជាច្រើន ត្រូវកែសម្រួលពិធីគោរពប្រណិប័តន៍យ៉ាងខ្លាំងជាង និងជាបន្ទាន់ ជាមូលហេតុ ដែលបង្កើតឧបសគ្គរឹតតែពិបាកដោះស្រាយទៅទៀត មានដូចតទៅ៖

១- ក្រុមអភិបាលដែលមានសមត្ថកិច្ចក្នុងតំបន់មួយ តាមសេចក្ដីចែងក្នុងមាត្រា ២២, ២ ក្នុងករណីនេះ ត្រូវយកចិត្តទុកដាក់ រិះគិតពិចារណាដោយប្រយ័ត្នប្រយែង អំពីអ្វីក្នុងប្រពៃណី និងក្នុងបុគ្គលិកលក្ខណៈរបស់ជាតិនីមួយៗ ដែលអស់លោកអាចទទួលឲ្យចូលក្នុងពិធីគោរពបម្រើព្រះជាម្ចាស់ បានតាមតម្រូវការ។ ត្រូវផ្ញើសេចក្ដីកែសម្រួល ដែលអស់លោកយល់ឃើញថា មានប្រយោជន៍ហើយនោះ ទៅសួរយោបល់របស់អាសនៈគ្រីស្តទូតសិលា។ ក្រោយពីសន្តអាសនៈនេះបានយល់ព្រម សូមបញ្ចូលក្នុងពិធីគោរពប្រណិប័តន៍។

២- ប៉ុន្តែ អាសនៈគ្រីស្តទូតសិលា ត្រូវផ្ដល់លទ្ធភាពឲ្យក្រុមអភិបាលដែលមានសមត្ថកិច្ចក្នុងតំបន់អនុញ្ញាតឲ្យគេល្បងលមើលជាមុនសិន ក្នុងអង្គប្រជុំខ្លះដែលអាចល្បងលមើលយ៉ាងសមរម្យបាន ក្នុងរយៈពេលកំណត់មួយប្រសិនបើត្រូវការ។ ធ្វើដូច្នេះ ទើបអស់លោកកែសម្រួលពិធីគោរពប្រណិប័តន៍បាន ដោយថ្លឹងថ្លែងតាមតម្រូវការ។

៣- តាមធម្មតាច្បាប់វិន័យខាងពិធីគោរពប្រណិប័តន៍ បង្កើតឧបសគ្គជាច្រើន ក្នុងករណីកែសម្រួលឲ្យបានស្របតាមជាតិនានា ជាពិសេសនៅដែនដីដែលមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។ ហេតុនេះ ត្រូវមានអ្នកជំនាញការអំពីការកែសម្រួលនោះ មកជួយចែងច្បាប់ទាំងនោះផង។

## ៤- ការពង្រីក និងពង្រឹងការរស់នៅតាមពិធីគោរពប្រណិប័តន៍ ក្នុងភូមិភាគ និងក្នុងព្រះសហគមន៍តាមភូមិនីមួយៗ

### ៤១-ការរស់នៅក្នុងភូមិភាគតាមពិធីគោរពប្រណិប័តន៍

ត្រូវចាត់លោកអភិបាលទុកជាមហាបូជាចារ្យនៃហ្វូងចៀមរបស់លោក។ ក្នុងភូមិភាគ គ្រីស្តបរិស័ទក៏រួមរស់ក្នុងអង្គព្រះគ្រីស្ត អាស្រ័យលើលោកតាមផ្នែកខ្លះៗផងដែរ។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទទាំងអស់ ត្រូវចាត់ទុកការរស់នៅ តាមពិធីគោរពប្រណិប័តន៍ក្នុងភូមិភាគរួមជាមួយលោកអភិបាល ជាការដ៏ប្រសើរបំផុត ជាពិសេសនៅវិសាលវិហារ។ គ្រីស្តបរិស័ទត្រូវជឿជាក់ថាព្រះសហគមន៍សម្ដែងខ្លួនយ៉ាងច្បាស់ នៅពេលប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ចូលរួមយ៉ាងពេញលេញ និងយ៉ាងសកម្មក្នុងពិធីគោរពប្រណិប័តន៍នានា ជាពិសេសក្នុងអភិបូជាតែមួយដូចគ្នា ក្នុងការអធិដ្ឋានតែមួយដូចគ្នា នៅក្បែរតុសក្ការៈតែមួយគត់ ដោយមានលោកអភិបាលធ្វើជាអធិបតី ហើយមានក្រុមបូជាចារ្យ និងអ្នកបំពេញមុខងារបម្រើទាំងអស់រួមគ្នា នៅជុំវិញផងដែរ។

### ៤២-ការរស់នៅតាមពិធីគោរពប្រណិប័តន៍ក្នុងព្រះសហគមន៍តាមភូមិនីមួយៗ

លោកអភិបាល មិនអាចធ្វើជាអធិបតីលើព្រះសហគមន៍របស់លោកគ្រប់ពេលវេលា និងនៅគ្រប់កន្លែង ដោយ

ផ្ទាល់ខ្លួនបានទេ ហេតុនេះ លោកត្រូវតែងតាំងក្រុមគ្រីស្តបរិស័ទ។ ក្នុងចំណោមក្រុមទាំងនោះ ព្រះសហគមន៍តាមភូមិជាក្រុមសំខាន់ជាងគេ ចាត់ចែងក្រោមការណែនាំរបស់លោកគង្វាលម្នាក់ ជាតំណាងលោកអភិបាល។ ព្រះសហគមន៍តាមភូមិទាំងនោះ ក៏ជារូបតំណាងម៉្យាង អំពីព្រះសហគមន៍តែងតាំងក្នុងពិភពលោកទាំងមូល ដែលមនុស្សអាចមើលឃើញបាន។

ហេតុនេះហើយ បានជាត្រូវជួយលើកស្ទួយចិត្តគំនិតគ្រីស្តបរិស័ទ និងអស់លោកដែលទទួលអគ្គសញ្ញាតែងតាំងឲ្យប្រតិបត្តិនិងឲ្យរស់នៅ តាមពិធីគោរពប្រណិប័តន៍ក្នុងព្រះសហគមន៍តាមភូមិ ព្រមទាំងឲ្យគេមានទំនាក់ទំនងជាមួយលោកអភិបាលផង។ ត្រូវខិតខំឲ្យព្រះសហគមន៍ក្នុងភូមិនីមួយៗនឹកគិតថា គេពិតជាសហគមន៍មួយដែលរួបរួមគ្នាជាធ្លុងតែមួយ ជាពិសេសនៅពេលគេថ្វាយអភិបូជារួមគ្នានៅថ្ងៃអាទិត្យ។

## ៥-ត្រូវពង្រីកនិងពង្រឹងការណែនាំគ្រីស្តបរិស័ទខាងពិធីគោរពប្រណិប័តន៍

### ៤៣-ព្រះវិញ្ញាណជំរុញព្រះសហគមន៍ឲ្យកែសម្រួលពិធីគោរពប្រណិប័តន៍

ត្រូវរាប់យ៉ាងត្រឹមត្រូវថា ព្រះជាម្ចាស់ដែលថែរក្សាមនុស្សលោក ព្រះអង្គចាត់ចែងឲ្យព្រះសហគមន៍ខំខ្នះខ្នែងលើកស្ទួយ និងកែសម្រួលពិធីគោរពប្រណិប័តន៍ឲ្យបានជាថ្មីនោះ ទុកជាសញ្ញាសម្គាល់បញ្ជាក់អំពីសកម្មភាពរបស់ព្រះអង្គនាបច្ចុប្បន្នកាលមែន គឺហាក់ដូចជាព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកកាត់ឆ្លងព្រះសហគមន៍របស់ព្រះអង្គ។ ព្រះវិញ្ញាណប្រទានឲ្យព្រះសហគមន៍មានជីវិតរស់រវើក។ លើសពីនេះទៅទៀត ព្រះអង្គប្រោសឲ្យមនុស្សទូទៅសព្វថ្ងៃ យល់ឃើញអំពីសាសនាផ្សេងៗ និងគោរពសាសនាតាមរបៀតាមបប្លែកពីមុន។

ហេតុនេះ ដើម្បីលើកស្ទួយពង្រីក និងពង្រឹងការណែនាំខាងពិធីគោរពប្រណិប័តន៍ ឲ្យកាន់តែប្រសើរឡើង មហាសន្និបាតដ៏វិសុទ្ធសម្រេចសេចក្តីដូចតទៅ៖

### ៤៤-គណៈកម្មាធិការជាតិអំពីពិធីគោរពប្រណិប័តន៍

ក្រុមលោកអភិបាល មានសមត្ថកិច្ចក្នុងតំបន់មួយ តាមសេចក្តីចែងក្នុងមាត្រា ២២, ២ ត្រូវតែងតាំងគណៈកម្មាធិការពិធីគោរពប្រណិប័តន៍មួយ ដែលមានអ្នកជំនាញការ ខាងវិជ្ជាពិធីគោរពប្រណិប័តន៍ ខាងភ្លេងដ៏សក្ការៈ ខាងសិល្បៈដ៏សក្ការៈនិងខាងការណែនាំ។ ប្រសិនបើអាចធ្វើបាន ត្រូវមានគ្រឹះស្ថានអប់រំខាងពិធីគោរពប្រណិប័តន៍ជួយគណៈកម្មាធិការនោះ។ ក្នុងចំណោមសមាជិកគ្រឹះស្ថានអប់រំខាងពិធីគោរពប្រណិប័តន៍ ប្រសិនបើ អស់លោកយល់ឃើញថាមានប្រយោជន៍ អស់លោកអាចទទួលគ្រីស្តបរិស័ទធម្មតា ដែលមានចំណេះចេះដឹងយ៉ាងប្រសើរ អំពីពិធីគោរពប្រណិប័តន៍។ គណៈកម្មាធិការនោះ ទទួលខុសត្រូវលើការណែនាំពិធីគោរពប្រណិប័តន៍ តាមតំបន់របស់ខ្លួន ក្រោមការណែនាំរបស់ក្រុមលោកអភិបាលមានសមត្ថកិច្ចក្នុងតំបន់ ដូចមានចែងខាងលើ។ គ្រប់ពេលដែលក្រុមអភិបាលត្រូវស្នើសួរយោបល់អាសនៈរបស់គ្រីស្តទូតសិលា អំពីការកែសម្រួលពិធីមួយ គណៈកម្មាធិការនោះក៏ជួយលើកស្ទួយឲ្យគេស្រាវជ្រាវ និងឲ្យគេសាកល្បងលមើលពិធីតាមតម្រូវការ។

### ៤៥-គណៈកម្មាធិការពិធីគោរពប្រណិប័តន៍ភូមិភាគ

តាមរបៀបដដែល ភូមិភាគនីមួយៗត្រូវមានគណៈកម្មាធិការពិធីគោរពប្រណិប័តន៍ក្រោមការណែនាំរបស់លោក

អភិបាល ដើម្បីលើកស្ទួយពង្រីកនិងពង្រឹងសកម្មភាពខាងពិធីគោរពប្រណិប័តន៍។ ជួនកាល គួរឲ្យភូមិភាគច្រើនតែងតាំងគណៈកម្មាធិការតែមួយ ដែលសហការជាមួយគ្នា ហើយលើកស្ទួយពិធីគោរពប្រណិប័តន៍ផង។

## ៤៦-គណៈកម្មាធិការផ្សេងៗ

ក្រៅពីគណៈកម្មាធិការពិធីគោរពប្រណិប័តន៍ ប្រសិនបើអាចធ្វើបាន ភូមិភាគនីមួយៗ ក៏ត្រូវតែងតាំងគណៈកម្មាធិការ ភ្លេងដ៏សក្ការៈ និងគណៈកម្មាធិការសិល្បៈដ៏សក្ការៈដែរ។

គណៈកម្មាធិការទាំងបីនោះត្រូវធ្វើការដោយរួមកម្លាំងគ្នាជាចាំបាច់។ ជួនកាល ត្រូវឲ្យគណៈកម្មាធិការទាំង បីនោះចូលរួមគ្នាជាគណៈកម្មាធិការតែមួយគត់។

# ជំពូក ២

# ព្រឹត្តិការណ៍ដ៏អស្ចារ្យ នៃអគ្គសញ្ញាអរព្រះគុណ

## ៤៧-អភិបូជា និងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង

នៅពិធីជប់លៀងចុងក្រោយ គឺនៅពេលយប់ដែលគេបញ្ជូលព្រះយេស៊ូជាព្រះសង្គ្រោះរបស់យើង ព្រះអង្គតែងតាំងសក្ការបូជាអរព្រះគុណ គឺសក្ការបូជានៃព្រះកាយនិងព្រះលោហិតព្រះអង្គ ដើម្បីបន្តសក្ការបូជារបស់ព្រះអង្គឲ្យដ៏ឈើឆ្កាងតរៀងទៅ រហូតដល់ព្រះអង្គយាងមក។ ព្រះអង្គផ្ញើទុកឲ្យព្រះសហគមន៍ជាព្រះមហេសីដ៏ជាទីស្រឡាញ់ នឹករឭកអំពីព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង គឺព្រះអង្គផ្ញើទុកនូវអគ្គសញ្ញា នៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គជាសញ្ញាសម្គាល់ អំពីព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយ ជាចំណងនៃសេចក្ដីស្រឡាញ់ និងជាពិធីជប់លៀងនៃបុណ្យចម្លង។ ក្នុងពិធីជប់លៀងនៃបុណ្យចម្លងនោះ គ្រីស្តបរិស័ទយើងបរិភោគព្រះគ្រីស្តទុកជាអាហារយើងទទួលព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់យ៉ាងពេញបរិបូរណ៍ ហើយក៏ទទួលព្រះអំណោយទានដើម ដំបូងដែលបញ្ចាំចិត្តយើងឲ្យដឹងថា យើងមុខជានឹងទទួលសិរីរុងរឿងនៅពេលអនាគតជាពុំខាន។

## ៤៨-គ្រីស្តបរិស័ទត្រូវចូលរួមក្នុងអភិបូជាយ៉ាងសកម្ម

ហេតុនេះហើយ បានជាព្រះសហគមន៍យកចិត្តទុកដាក់ ណែនាំគ្រីស្តបរិស័ទឲ្យចូលរួមលើកតម្កើងគម្រោងការដ៏អស្ចារ្យនៃជំនឿនេះ ពោលគឺថ្វាយអភិបូជា ឲ្យយល់យ៉ាងច្បាស់ទាំងពិធី ទាំងពាក្យអធិដ្ឋានផ្សេងៗ ដើម្បីរួមយ៉ាងសកម្មក្នុងកិច្ចដ៏សក្ការៈនេះដោយដឹងខ្លួន និងដោយចិត្តស្រឡាញ់។ គ្រីស្តបរិស័ទ មិនត្រូវចូលអភិបូជា ទុកជាទស្សនិកជនដែលនៅខាងក្រៅ ហើយដែលស្ងៀមស្ងាត់ប៉ុណ្ណោះទេ។ ព្រះសហគមន៍ ត្រូវយកចិត្តទុកដាក់អប់រំគ្រីស្តបរិស័ទ អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងឲ្យគេទទួលទានអាហារពីតុ នៃព្រះកាយព្រះអម្ចាស់ ហើយនាំគ្នាអរព្រះគុណព្រះជាម្ចាស់ទៀតផង។ មិនគ្រាន់តែលោកបូជាចារ្យថ្វាយយញ្ញដ៏និមលនេះប៉ុណ្ណោះទេ តែគ្រីស្តបរិស័ទទាំងអស់ រួមជាមួយលោក ថ្វាយយញ្ញនោះដែរ។ ដូច្នេះ គេក៏រៀនថ្វាយខ្លួនពីមួយថ្ងៃទៅមួយថ្ងៃទៀត រហូតដល់គេរួបរួមជាមួយព្រះជាម្ចាស់ និងរួបរួមជាមួយគ្នាដោយសារព្រះគ្រីស្តជាស្ពានមេត្រី ដើម្បីឲ្យព្រះជាម្ចាស់បំពេញអ្វីៗទាំងអស់ ក្នុងមនុស្សទាំងអស់ជាស្ថាពរ នៅពេលចុងក្រោយបំផុត។

## ៤៩-ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធ

មានបំណងឲ្យសក្ការបូជា នៃអភិបូជាបានស័ក្តិសិទ្ធយ៉ាងពេញលេញ ជាពិសេសនៅពេលប្រជាជនគ្រីស្តបរិស័ទចូលរួមថ្វាយអភិបូជានៅថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យដែលគេត្រូវចូលជាកំហិត ទើបមហាសន្និបាតបានសម្រេចសេចក្ដីដូចតទៅ៖

## ៥០-ត្រូវកែសម្រួលក្បួនធម្មតានៃពិធីអភិបូជា

ត្រូវកែសម្រួលក្បួនពិធីអភិបូជា ដើម្បីឲ្យគ្រីស្តបរិស័ទយល់ឃើញកាន់តែច្បាស់ថា ផ្នែកនីមួយៗក្នុងអភិបូជា មាន

តួនាទីពិសេសផ្ទាល់ និងភ្ជាប់គ្នាទៅវិញទៅមកផង។ ធ្វើដូច្នេះ ទើបគ្រីស្តបរិស័ទងាយស្រួលចូលរួមបានដោយគោរព និងយ៉ាងសកម្ម។

ទោះបីត្រូវរក្សាទុកខ្លឹមសារនៃពិធីនីមួយៗយ៉ាងជាក់លាក់ក្តី ក៏ត្រូវកែសម្រួលពិធីទាំងនោះ ឲ្យងាយយល់ កុំឲ្យស្មុគស្មាញឡើយ។ ត្រូវលុបចោលអ្វីៗដែលមានចែងពីរដង ឬដែលបន្ថែមតាមដំណើរនៃប្រវត្តិសាស្ត្រ ហើយដែលមិនសូវមានប្រយោជន៍ប៉ុន្មានទេ។ ត្រូវយកសេចក្តីខ្លះដែលបាត់បង់តាមប្រវត្តិសាស្ត្រឲ្យមានឡើងវិញ តាមសេចក្តីណែនាំបុរាណរបស់គ្រូបាធ្យាយដ៏វិសុទ្ធ លុះត្រាតែសេចក្តីនោះ មានប្រយោជន៍ និងសមរម្យផង។

## ៥១-ត្រូវអានអត្ថបទព្រះគម្ពីរច្រើនជាងពីមុន

ត្រូវយកព្រះគម្ពីរជាទ្រព្យដ៏ថ្លៃថ្នូរ មកជូនគ្រីស្តបរិស័ទទទួលទានពីតុនៃព្រះបន្ទូលឲ្យបានច្រើនជាងពីមុន។ សូមប្រកាសផ្នែកដ៏សំខាន់ៗក្នុងព្រះគម្ពីរ ឲ្យគ្រីស្តបរិស័ទស្តាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំដែលត្រូវកំណត់ទុកមក។

## ៥២ ពិធីអត្ថាធិប្បាយព្រះគម្ពីរ

មហាសន្និបាតដាស់តឿនយ៉ាងខ្លាំង ឲ្យមានពិធីអត្ថាធិប្បាយព្រះគម្ពីរ ដែលជាផ្នែកមួយដ៏ពិតប្រាកដក្នុងអភិបូជា។ អ្នកអធិប្បាយ ត្រូវពន្យល់អំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនៃជំនឿ និងបង្ហាញសេចក្តីណែនាំសម្រាប់ការរស់នៅ ក្នុងឋានៈជាគ្រីស្តបរិស័ទ។ ត្រូវយោងសេចក្តីពីព្រះគម្ពីរ តាមរដូវនានានៃពិធីគោរពប្រណិប័តន៍ក្នុងមួយឆ្នាំ។ លើសពីនេះទៅទៀត ប្រសិនបើមានប្រជាជនចូលរួមថ្វាយអភិបូជានៅថ្ងៃអាទិត្យ ឬនៅថ្ងៃបុណ្យដែលគេត្រូវចូលជាកំហិត មិនត្រូវចោលពិធីអត្ថាធិប្បាយព្រះគម្ពីរជាដាច់ខាត លើកលែងតែមានមូលហេតុមួយដ៏ធ្ងន់ធ្ងរ។

## ៥៣-ពាក្យអង្វរសកល

ត្រូវឲ្យមាន *"ពាក្យអង្វរសកល"* ឬ *"ពាក្យអង្វររបស់គ្រីស្តបរិស័ទ"* ឡើងវិញ ដូចកាលពីដើម ក្រោយពីពិធីប្រកាសដំណឹងល្អ និងពិធីអត្ថាធិប្បាយព្រះគម្ពីរ ជាពិសេសនៅថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យដែលខានមិនបាន។ សូមឲ្យប្រជាជនចូលរួមអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍ដ៏វិសុទ្ធ សម្រាប់អស់លោកអ្នកដែលកាន់រដ្ឋអំណាច សម្រាប់អស់អ្នកដែលគ្រោះកាចគ្របសង្កត់សង្កិន សម្រាប់មនុស្សទាំងអស់ និងសូមឲ្យមនុស្សលោកទាំងមូលទទួលការសង្គ្រោះ (១ធម ២, ១-២)។

## ៥៤-ភាសាឡាតាំង និងភាសាប្រជាជន

ពេលថ្វាយអភិបូជាដោយមានប្រជាជនចូលរួម ត្រូវប្រើភាសាប្រជាជនដែលរស់នៅតាមតំបន់នោះ ជាពិសេសសមនឹងប្រើភាសាប្រជាជនសម្រាប់ប្រកាសអត្ថបទព្រះគម្ពីរ និងសម្រាប់ "ពាក្យអង្វរសកល"ព្រមទាំងនៅក្នុងផ្នែក ដែលទាក់ទិននឹងប្រជាជន ស្របតាមសភាពការណ៍នៃកន្លែងនីមួយៗ ហើយក៏ស្របតាមមាត្រា ៣៦ នៃធម្មនុញ្ញនេះដែរ។ ក៏ប៉ុន្តែ ត្រូវយកចិត្តទុកដាក់ឲ្យគ្រីស្តបរិស័ទអាចរួមគ្នាឆ្លើយតបបូជាចារ្យ និងច្រៀងផ្នែកទាំងប៉ុន្មានដែលទាក់ទិននឹងគេជាភាសាឡាតាំងបានផង។ នៅកន្លែងណាក្រុមអភិបាលយល់ឃើញថា គួរប្រើភាសាប្រជាជនរស់នៅក្នុងតំបន់ឲ្យបានច្រើនជាងនេះ ត្រូវធ្វើតាមបទបញ្ញត្តនៅមាត្រា ៤០ នៃធម្មនុញ្ញនេះ។

## ៥៥-ពិធីរួបរួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម តាមរូបសញ្ញាទាំងពីរ

មហាសន្និបាតផ្តែផ្តាំដាស់តឿនយ៉ាងខ្លាំង ឲ្យគ្រីស្តបរិស័ទចូលរួមអភិបូជា តាមរបៀបដ៏ល្អប្រសើរជាងគេ គឺឲ្យទទួលព្រះកាយ និងព្រះលោហិតព្រះអម្ចាស់ ដោយទទួលនំប៉័ងប្រសិទ្ធិក្នុងអភិបូជានោះ ក្រោយពីបូជាចារ្យបានទទួល។

តាមការយល់ឃើញរបស់ក្រុមអភិបាល ត្រូវអនុញ្ញាតឲ្យអ្នកទទួលអគ្គសញ្ញាតែងតាំង និងបព្វជិត បព្វជិតា ព្រមទាំងគ្រីស្តបរិស័ទធម្មតា អាចរួបរួមជាមួយព្រះយេស៊ូដែលបូជាព្រះជន្ម តាមរូបសញ្ញាទាំងពីរ គឺទទួលព្រះកាយ និងព្រះលោហិត។ (តែត្រូវរក្សាទុកគោលលទ្ធិ ដែលមហាសន្និបាតត្រែនតូ តែងតាំងរួចហើយ)។ អាសនៈគ្រីស្តទូតសិលានឹងបញ្ជាក់តាមក្រោយ នូវពេលគេអាចទទួលព្រះកាយតាមរូបសញ្ញាទាំងពីរដូច្នេះបាន។ ឧបមាថា អស់លោកគង្វាលថ្មីក្នុងអភិបូជាតែងតាំងខ្លួនជាបូជាចារ្យ បព្វជិតបព្វជិតាក្នុងអភិបូជាថ្វាយនៅថ្ងៃធ្វើពិធីសច្ចាប្រណិធាន ព្រមទាំងពន្លកថ្មីក្នុងអភិបូជា តពីពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក។ល។ អាចទទួលព្រះកាយតាមរូបសញ្ញាទាំងពីរដូច្នេះបាន។

## ៥៦-ផ្នែកអភិបូជាទាំងពីរស៊ីចង្វាក់គ្នា

ពិធីលើកតម្កើងព្រះបន្ទូល និងពិធីអរព្រះគុណ រួមគ្នាជាអភិបូជា។ ផ្នែកទាំងពីរភ្ជាប់ជាមួយគ្នាយ៉ាងស្អិតល្មួត រហូតទៅជាកិច្ចគោរពបម្រើតែមួយគត់។ ហេតុនេះហើយ មហាសន្និបាតដ៏វិសុទ្ធក្រើនដាស់តឿនយ៉ាងខ្លាំង ឲ្យអស់គង្វាលបង្រៀនគ្រីស្តបរិស័ទនៅពេលអប់រំជំនឿ ឲ្យចូលរួមក្នុងពិធីអភិបូជាទាំងមូល ជាពិសេសនៅថ្ងៃអាទិត្យ និងថ្ងៃបុណ្យដែលត្រូវចូលជាកំហិត។

## ៥៧-លោកបូជាចារ្យថ្វាយអភិបូជារួម

១- ពេលក្រុមលោកបូជាចារ្យរួមគ្នាថ្វាយអភិបូជា អស់លោកបង្ហាញយ៉ាងប្រសើរថា អស់លោករួមគ្នាក្នុងមុខងារជាបូជាចារ្យតែមួយរបស់ព្រះគ្រីស្តជាមហាបូជាចារ្យ។ ក្នុងព្រះសហគមន៍ទាំងនៅបស្ចិមប្រទេស ទាំងនៅបូព៌ាប្រទេស ក្រុមបូជាចារ្យនៅតែរួមគ្នាថ្វាយអភិបូជារហូតមកដល់សព្វថ្ងៃ។ ហេតុនេះហើយ បានជាមហាសន្និបាតយល់ព្រមពង្រីកសេចក្តីអនុញ្ញាតឲ្យក្រុមលោកគង្វាល រួមថ្វាយអភិបូជាក្នុងករណីដូចតទៅ៖

ក- ១- នៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ទាំងនៅពេលថ្វាយអភិបូជាប្រសិទ្ធពរលើប្រេង ទាំងនៅអភិបូជាពេលល្ងាច។

២- ពេលមហាសន្និបាត ឬប្រជុំក្រុមអភិបាល ឬសន្និបាតរួមគ្នាថ្វាយអភិបូជា។

៣- ពេលថ្វាយអភិបូជាប្រសិទ្ធិពរដល់លោកជាមេក្រុមគ្រួសារបព្វជិត។

ខ- លើសពីនេះទៅទៀត តាមសេចក្តីអនុញ្ញាតរបស់លោកអភិបាល ដែលមានភារកិច្ចថ្លឹងថ្លែង អំពីប្រយោជន៍ថ្វាយអភិបូជារួមគឺ៖

១- ពេលថ្វាយអភិបូជាក្នុងអារាមបព្វជិតបព្វជិតា។ ប្រសិនមានបូជាចារ្យច្រើនក្នុងភូមិមួយ ហើយប្រសិនបើ គ្រីស្តបរិស័ទមិនត្រូវការឲ្យបូជាចារ្យម្នាក់ ថ្វាយអភិបូជាដោយឡែក បូជាចារ្យទាំងអស់ត្រូវថ្វាយអភិបូជារួមក្នុងព្រះវិហារ។

២- ពេលប្រជុំគ្រប់យ៉ាងរបស់លោកបូជាចារ្យ ទោះជាបូជាចារ្យភូមិភាគក្តី ឬបូជាចារ្យបព្វជិតក្តី។

២-ក- លោកអភិបាល មានភារកិច្ចផ្តល់សេចក្តីណែនាំសម្រាប់ថ្វាយអភិបូជា រួមក្នុងភូមិភាគរបស់លោក។

ខ- ត្រូវរក្សាទុកឲ្យបូជាចារ្យម្នាក់ៗមានសិទ្ធិថ្វាយអភិបូជានៅម្នាក់ឯងជានិច្ចប៉ុន្តែ បូជាចារ្យ មិនត្រូវថ្វាយអភិបូជាម្នាក់ឯងដូច្នេះ នៅពេលក្រុមលោកគង្វាលកំពុងរួមគ្នាថ្វាយអភិបូជានៅព្រះវិហារដដែល ឬនៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ជាថ្ងៃរឭកអំពីព្រះអម្ចាស់ជប់លៀងក្រុមសាវ័ក។

## ៥៨-ត្រូវតែងតាំងក្បួនពិធីមួយថ្មី

សម្រាប់ថ្វាយអភិបូជារួម ហើយត្រូវបញ្ចូលក្បួនពិធីនោះ ក្នុងក្បួនពិធីរបស់អភិបាល និងរបស់ព្រះសហគមន៍ក្រុងរ៉ូមទៀតផង។

# ជំពូក ៣

# អគ្គសញ្ញាឯទៀតៗ និងអនុសញ្ញា

## ៥៩-លក្ខណៈអគ្គសញ្ញានានា

អគ្គសញ្ញាមានគោលដៅនាំឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ និងកសាងព្រះកាយព្រះគ្រីស្ត ព្រមទាំងគោរពបម្រើព្រះជាម្ចាស់។ ប៉ុន្តែ ដោយអគ្គសញ្ញាមានលក្ខណៈជាសញ្ញាសម្គាល់ អគ្គសញ្ញានានាក៏ជួយអប់រំជំនឿដែរ។ មានតែអ្នកផ្ញើជីវិតលើព្រះគ្រីស្តទេ ដែលអាចទទួលអគ្គសញ្ញាបាន។ ពេលធ្វើអគ្គសញ្ញាដោយមាននិយាយពាក្យនិងប្រើវត្ថុផ្សេងៗ អគ្គសញ្ញាក៏បំប៉ននិងពង្រឹងជំនឿ ព្រមទាំងបង្ហាញបញ្ជាក់ជំនឿរបស់អ្នកទទួលថែមទៀត។ ហេតុនេះហើយ បានជាយើងធ្លាប់ហៅអគ្គសញ្ញាថា *"អគ្គញ្ញានៃជំនឿ"*។ ព្រះជាម្ចាស់ប្រណីសន្ដោសអ្នកជឿ ដោយសារអគ្គសញ្ញាមែន ប៉ុន្តែ ពិធីធ្វើអគ្គសញ្ញាជូនគ្រីស្តបរិស័ទ ក៏អាចជួយឲ្យគេរៀបចំខ្លួនទទួលព្រះអំណោយទាន តាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ តាមរបៀបដែលអាចបង្កើតផល។ អគ្គសញ្ញា នាំឲ្យគេគោរពបម្រើព្រះជាម្ចាស់ ព្រមទាំងឲ្យប្រតិបត្តិតាមសេចក្ដីស្រឡាញ់។

ដូច្នេះ ត្រូវឲ្យគ្រីស្តបរិស័ទយល់អត្ថន័យនៃសញ្ញាសម្គាល់ ដែលមានប្រើក្នុងអគ្គសញ្ញានានាដោយងាយ។ ការយល់អត្ថន័យ ដូច្នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ គេក៏ត្រូវព្យាយាមទទួលអគ្គសញ្ញាទាំងនោះដែរ ព្រោះអគ្គសញ្ញាបំប៉នគេឲ្យរស់នៅតាមរបៀបជាគ្រីស្តបរិស័ទ។

## ៦០-អនុសញ្ញា

ព្រះសហគមន៍ជាមាតាដ៏វិសុទ្ធ តែងតាំងអនុសញ្ញាផ្សេងៗ។ អនុសញ្ញាជាសញ្ញាសម្គាល់ដ៏សក្ការៈ ស្រដៀងនឹងអគ្គសញ្ញា សម្ដែងអំពីផលខ្លះ ជាពិសេសផលខាងព្រះវិញ្ញាណ ដែលគ្រីស្តបរិស័ទទទួលដោយពាក្យអង្វររបស់ព្រះសហគមន៍។ ដោយអនុសញ្ញាទាំងនោះ មនុស្សមានចិត្តចង់ទទួលផលដ៏ប្រសើរនៃអគ្គសញ្ញា ហើយក៏បានវិសុទ្ធតាមសភាពការណ៍ផ្សេងៗ ប្រចាំការរស់នៅរបស់គេ។

## ៦១-តម្លៃដ៏ថ្លៃថ្នូរ នៃពិធីគោរពប្រណិប័តន៍ និងទំនាក់ទំនងនឹងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង

អគ្គសញ្ញា និងអនុសញ្ញានានា នាំឲ្យស្ទើរតែគ្រប់ព្រឹត្តិការណ៍ប្រចាំការរស់នៅរបស់គ្រីស្តបរិស័ទ ដែលស្វែងរកព្រះជាម្ចាស់ដោយចិត្តទៀងត្រង់ បានវិសុទ្ធដោយព្រះហឫទ័យប្រណីសន្ដោស ដែលហូរចេញមកពីព្រះគ្រីស្តដែលរងទុក្ខលំបាក សោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង។ គឺព្រះគ្រីស្តនេះហើយ ដែលប្រោសឲ្យអគ្គសញ្ញា និងអនុសញ្ញាទាំងប៉ុន្មានមានអនុភាព។ វត្ថុស្ទើរតែទាំងអស់ ដែលមនុស្សប្រើប្រាស់យ៉ាងត្រឹមត្រូវ (ក្នុងអគ្គសញ្ញា និងអនុសញ្ញា) ក៏អាចតម្រង់ទៅរកគោលដៅតែមួយ គឺធ្វើឲ្យមនុស្សបានវិសុទ្ធ និងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

## ៦២-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញានានា

តាមដំណើរនៃប្រវត្តិសាស្ត្រតរៀងមក មានកត្តាខ្លះក្នុងពិធីធ្វើអគ្គសញ្ញា និងអនុសញ្ញាបណ្តាលឲ្យគ្រីស្តបរិស័ទ នៅសម័យឥឡូវ មិនសូវយល់លក្ខណៈ និងគោលដៅនៃអគ្គសញ្ញាឬអនុសញ្ញាទាំងនោះទេ។ ហេតុនេះហើយ បានជាត្រូវកែសម្រួលសេចក្តីខ្លះៗ ដើម្បីឲ្យបានសមស្របតាមតម្រូវការនៃសម័យឥឡូវ។ ដើម្បីកែសម្រួលពិធីទាំងនោះ មហាសន្និបាតដ៏វិសុទ្ធ សម្រេចសេចក្តីដូចតទៅៈ

## ៦៣-ភាសា

ពេលធ្វើអគ្គសញ្ញា និងអនុសញ្ញាជូនគេ ភាសារបស់ប្រជាជនតាមតំបន់ អាចជួយគេយ៉ាងខ្លាំង ហេតុនេះហើយ បានជាត្រូវប្រើភាសាប្រជាជនឲ្យបានច្រើន តាមសេចក្តីណែនាំដូចតទៅៈ

ក- ពេលធ្វើអគ្គសញ្ញា និងអនុសញ្ញាជូនគេ គេអាចប្រើភាសាប្រជាជនក្នុងតំបន់បាន ស្របតាមសេចក្តីណែនាំចែងនៅមាត្រា ៣៦។

ខ- ក្រុមអភិបាល ជាអំណាចដែលមានសមត្ថកិច្ចក្នុងតំបន់មួយ តាមសេចក្តីចែងនៅមាត្រា ២២, ២ នៃធម្មនុញ្ញនេះ ត្រូវបង្កើតក្បួនពិធីដោយឡែកយ៉ាងឆាប់ៗ ស្របតាមតម្រូវការនៃតំបន់នីមួយៗ ហើយក៏ត្រូវចាត់ចែងអំពីភាសាដែរ។ ពេលបង្កើតក្បួនពិធីទាំងនោះ ត្រូវស្របតាមសៀវភៅក្បួនពិធីក្រុងរ៉ូម បោះពុម្ពជាថ្មី។ ក្រោយពីអាសនៈគ្រីស្តទូតសិលា កែសម្រួលក្បួនពិធីទាំងនោះរួចហើយ ទើបអាចប្រើក្នុងតំបន់រៀងៗខ្លួន។ ពេលនិពន្ធក្បួនពិធីទាំងនោះ ឬក្បួនផ្សេងៗទៀតដោយឡែក ត្រូវចម្លងសេចក្តីណែនាំ ដែលមានកត់ត្រាទុកនៅក្នុងសៀវភៅក្បួនពិធីក្រុងរ៉ូម ដាក់នៅខាងមុខពិធីនីមួយៗ ជាសេចក្តីណែនាំទាក់ទងនឹងការណែនាំគ្រីស្តបរិស័ទ និងទាក់ទងនឹងរបៀបធ្វើពិធីនីមួយៗ ហើយដែលមានសារៈសំខាន់ពិសេសដោយនឹកគិតដល់សង្គមដែរ។

## ៦៤-ការអប់រំមនុស្សពេញវ័យ ដែលស្តាប់ព្រះបន្ទូលលាន់ឮឡើង

ត្រូវចាត់ចែងការអប់រំជំនឿមនុស្សពេញវ័យ ដែលស្តាប់ព្រះបន្ទូលលាន់ឮឡើង ឲ្យមានដំណាក់កាលជាច្រើនប្លែកៗពីគ្នា ទើបពេលអ្នកទទួលការអប់រំយ៉ាងសមរម្យបានវិសុទ្ធ គឺដោយសារពិធីដែលគេប្រព្រឹត្តតាមដំណាក់កាលទាំងនោះ។ ត្រូវប្រព្រឹត្តតាមរបៀបនេះ តាមការយល់ឃើញរបស់លោកអភិបាលភូមិភាគ។

## ៦៥-ក្នុងប្រទេសដែលមនុស្សជាច្រើនមិនស្គាល់ព្រះគ្រីស្ត

ប្រជាជនតែងតែធ្វើពិធីបញ្ចូលក្នុងសាសនារបស់គេ តាមប្រពៃណីផ្ទាល់ខ្លួន។ មហាសន្និបាតអនុញ្ញាតឲ្យយកសេចក្តីខ្លះៗ ដកស្រង់ពីពិធីតាមប្រពៃណីរបស់គេ មកដាក់ចូលក្នុងក្បួនពិធីបញ្ចូលក្នុងគ្រីស្តសាសនា តាមប្រពៃណីព្រះសហគមន៍យើង។ យើងត្រូវសម្រួលសេចក្តីទាំងនោះ ឲ្យបានស្របតាមពិធីគ្រីស្តសាសនា ត្រូវតាមសេចក្តីចែងក្នុងមាត្រាលេខ ៣៧-៤០ នៃធម្មនុញ្ញយើងនេះ។

## ៦៦-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាជ្រមុជទឹក

ត្រូវកែសម្រួលក្បួនពិធីទាំងពីរនៃអគ្គសញ្ញាជ្រមុជទឹកជូនមនុស្សពេញវ័យ គឺមួយជាក្បួនពិធីធម្មតា និងមួយទៀត

ជាក្បួនពិធីយ៉ាងឱឡារិក ជាក្បួនដែលគិតគូរដល់ការអប់រំជំនឿរបស់មនុស្សពេញវ័យ ដែលកែសម្រួលជាថ្មីឡើងវិញរួចហើយ។ ត្រូវបញ្ចូលក្នុងសៀវភៅក្បួនពិធី នៃព្រះសហគមន៍ក្រុងរ៉ូម នូវអភិបូជាដែលហៅថា *"អភិបូជាក្នុងពេលធ្វើអគ្គសញ្ញាជ្រមុជទឹក"*។

## ៦៧-ត្រូវកែសម្រួលពិធីអគ្គសញ្ញាជ្រមុជទឹកជូនទារក

ឲ្យបានសមស្របតាមសភាពការណ៍ដ៏ពិតប្រាកដរបស់ទារក។ ម៉្យាងទៀត ក្នុងពិធីនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីតួនាទីឪពុកម្ដាយបង្កើត និងតួនាទីរបស់ឪពុកម្ដាយធម៌។

## ៦៨-ត្រូវកែសម្រួលពិធីអគ្គសញ្ញាជ្រមុជទឹក

ក្នុងករណីមានមនុស្សជាច្រើនទទួលអគ្គសញ្ញានោះស្របតាមការយល់ ឃើញរបស់លោកអភិបាលនៃភូមិភាគ។ ម៉្យាងទៀត ត្រូវបង្កើតក្បួនពិធីមួយទៀតយ៉ាងខ្លី ដែលគេអាចប្រើបានគ្រប់គ្នា ជាពិសេសអ្នកអប់រំជំនឿនៅដែនដី មនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត និងជាទូទៅនៅករណីខ្លាចអ្នកនោះស្លាប់ ហើយគ្មានបូជាចារ្យ ឬឧបដ្ឋាកនៅពេលនោះ។

## ៦៩-ត្រូវចែងក្បួនពិធីមួយថ្មី ជំនួសពិធីហៅថា

ការបំពេញពិធីអគ្គសញ្ញាជ្រមុជទឹកយ៉ាងខ្លីបំផុតជូនទារក ដោយបញ្ជាក់យ៉ាងច្បាស់ និងសមរម្យថា ទោះបីទារកនោះទទួលអគ្គសញ្ញាជ្រមុជទឹកតាមពិធីដ៏ខ្លីក្ដី ក៏ព្រះសហគមន៍បានទទួលទារកនេះ ទុកជាសមាជិករួចហើយ។

ត្រូវចែងក្បួនពិធីមួយថ្មីទៀត សម្រាប់អស់អ្នកដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក ដែលយកជាការបានតាមនិកាយផ្សេងៗ ហើយដែលប្រែចិត្តគំនិតមករកសាសនាកាតូលិកយើង ដើម្បីបង្ហាញបញ្ជាក់ថា ព្រះសហគមន៍ទទួលគេឲ្យរួបរួមជាមួយដែរ។

## ៧០-ក្រៅពីរដូវបុណ្យចម្លង

គេអាចប្រសិទ្ធពរលើទឹក នៅពេលធ្វើពិធីអគ្គសញ្ញាជ្រមុជទឹកជូនគេនោះ តាមរូបមន្តមួយយ៉ាងខ្លី ដែលត្រូវទទួលសេចក្ដីអនុញ្ញាតជាមុនសិន។

## ៧១-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាលាបថ្វាស

ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាលាបថ្វាស ក្នុងគោលបំណងបង្ហាញបញ្ជាក់យ៉ាងច្បាស់ថា អគ្គសញ្ញាលាបថ្វាសភ្ជាប់យ៉ាងស្អិតល្មួត ជាមួយនឹងការបញ្ចូលមនុស្សពេញវ័យក្នុងគ្រីស្តសាសនាទាំងស្រុង។ គួរឲ្យកែសម្រួលពាក្យសន្យាមុនទទួលអគ្គសញ្ញាជ្រមុជទឹក។

ប្រសិនបើគួរឲ្យធ្វើ លោកអភិបាលអាចធ្វើអគ្គសញ្ញាលាបថ្វាសជូន នៅពេលថ្វាយអភិបូជា។ ប្រសិនបើមានធ្វើអគ្គសញ្ញាលាបថ្វាសជូនគេ ក្រៅពីពេលថ្វាយអភិបូជា ត្រូវចែងពាក្យពន្យល់មុនពេលចាប់ផ្ដើមធ្វើពិធី និងចាត់ពាក្យនេះទុកជាអារម្ភកថា។

## ៧២-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាលើកលែងទោស

ត្រូវកែសម្រួលពិធី និងរូបមន្តនៃអគ្គសញ្ញាលើកលែងទោស ដើម្បីបញ្ជាក់យ៉ាងច្បាស់អំពីលក្ខណៈ និងអំពី

លទ្ធផល នៃអគ្គសញ្ញាលើកលែងទោសនោះ។

## ៧៣-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាលាបប្រេងអ្នកជំងឺ

គួរហៅ *"អគ្គសញ្ញាលាបប្រេងព្រះបង្ហើយ"* ថា *"អគ្គសញ្ញាលាបប្រេងអ្នកជំងឺ"* វិញ ទើបប្រសើរជាង ព្រោះអគ្គសញ្ញានោះ មិនមែនជាអគ្គសញ្ញាជូនតែអ្នកដែលហៀបនឹងបាត់បង់ជីវិតប៉ុណ្ណោះទេ។ ពេលគ្រីស្តបរិស័ទម្នាក់ មានវ័យចំណាស់ ឬចាប់ផ្តើមមានជំងឺជាទម្ងន់ គឺពេលនោះហើយ ជាពេលសមរម្យទទួលអគ្គសញ្ញាលាបប្រេងអ្នកជំងឺ។

## ៧៤-ក្រៅពីក្បួនពិធីអគ្គសញ្ញាលាបប្រេងអ្នកជំងឺ

ក្រៅពីក្បួនពិធីអគ្គសញ្ញាលាបប្រេងអ្នកជំងឺ និងពិធីទទួលព្រះកាយពេលហៀបលាចាកលោកនេះ ដែលជាពិធីដោយឡែកពីគ្នា ត្រូវចែងក្បួនពិធីមួយទៀត ដែលមានពិធីត។គ្នា គឺអគ្គសញ្ញាលាបប្រេង ក្រោយពីបានទទួលអគ្គសញ្ញាលើកលែងទោស ហើយមុននឹងទទួលព្រះកាយនៅពេលហៀបនឹងលាចាកលោកនេះ។

## ៧៥-ត្រូវកំណត់ចំនួនកន្លែងលាបប្រេងលើរូបកាយអ្នកជំងឺ

ស្របតាមសភាពការណ៍អ្នកជំងឺ។ ត្រូវកែសម្រួលពាក្យអង្វរ ក្នុងអគ្គសញ្ញាលាបប្រេងអ្នកជំងឺ ឲ្យស្របតាមសភាពកាណ៍របស់អ្នកជំងឺនោះដែរ។

## ៧៦-ត្រូវកែសម្រួលពិធីនៃអគ្គសញ្ញាតែងតាំង

ក្នុងអគ្គសញ្ញាតែងតាំង ត្រូវកែសម្រួលទាំងពិធី ទាំងសេចក្តីដែលលោកអភិបាលសូត្រ។ ពេលលោកថ្លែងពាក្យណែនាំខាងដើមអគ្គសញ្ញាតែងតាំងនីមួយៗ ឬខាងដើមពិធីប្រសិទ្ធិឲ្យទៅជាបូជាចារ្យ លោកអភិបាលអាចនិយាយភាសាតំបន់បាន។

ក្នុងពិធីប្រសិទ្ធិឲ្យទៅជាអភិបាល អស់អភិបាលដែលចូលរួមក្នុងពិធីនោះ មានសិទ្ធិដាក់ដៃតែងតាំងអភិបាលថ្មីនោះ។

## ៧៧-ត្រូវកែសម្រួលពិធីអគ្គសញ្ញាអាពាហ៍ពិពាហ៍

ត្រូវកែសម្រួលពិធីអគ្គសញ្ញាអាពាហ៍ពិពាហ៍ ដែលមានកត់ត្រាទុកក្នុងក្បួនពិធីព្រះសហគមន៍ក្រុងរ៉ូម និងត្រូវបន្ថែមសេចក្តីខ្លះ ដើម្បីបង្ហាញបញ្ជាក់អំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ តាមអគ្គសញ្ញានេះ និងត្រូវសង្កត់លើភារកិច្ចរបស់គូស្វាមីភរិយា។

*"ប្រសិនបើនៅតំបន់ខ្លះ ព្រះសហគមន៍យកទំនៀមទម្លាប់និងពិធីផ្សេងៗដែលគួរឲ្យសរសើរ មកប្រើក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍ មហាសន្និបាតដ៏វិសុទ្ធ ប្រាថ្នាចង់យ៉ាងខ្លាំងឲ្យរក្សាទុកទំនៀមទម្លាប់ និងពិធីនោះទាំងស្រុង"* (មហាសន្និបាតត្រែនតូ)។

ម្យ៉ាងទៀត ក្រុមអភិបាលជាអំណាច មានសមត្ថកិច្ចក្នុងតំបន់មួយ តាមសេចក្តីចែងក្នុងមាត្រា ២២,២ នៃធម្មនុញ្ញនេះ មានសិទ្ធិបង្កើតពិធី ដែលសមស្របតាមប្រពៃណីស្រុក និងប្រជាជនដូចមានចែងក្នុងមាត្រា ៦៣។ ក៏ប៉ុន្តែ ត្រូវឲ្យបូជាចារ្យ ដែលធ្វើអធិបតីក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍សុំ ហើយត្រូវទទួលពាក្យយល់ព្រមរបស់សាមីខ្លួនទាំងពីរនាក់យកគ្នាជាគូស្វាមីភរិយាជាកំហិត។

### ៧៨-តាមធម្មតា

ត្រូវធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍ ក្នុងពេលថ្វាយអភិបូជាក្រោយពីបានប្រកាសគម្ពីរដំណឹងល្អ ហើយមុនពាក្យអង្វរសកល។ ត្រូវកែសម្រួលពាក្យអង្វរសូមព្រះអង្គប្រទានពរដល់ភរិយាថ្មោងថ្មី ដើម្បីគូសសង្កត់ថា គូស្វាមីភរិយាមានភារកិច្ចស្មើគ្នា នឹងត្រូវស្មោះត្រង់ភក្ដីទៅវិញទៅមក។ ពាក្យអង្វរនេះ អាចសូត្រជាភាសាស្រុកនោះបាន។

ប៉ុន្តែ ប្រសិនបើមានធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍ក្រៅពីអភិបូជា ត្រូវប្រកាសអត្ថបទដកស្រង់ពីលិខិត និងពីគម្ពីរដំណឹងល្អ នៅខាងដើមពិធី ហើយត្រូវប្រទានពរលើគូស្វាមីភរិយាជានិច្ចកុំអាក់ខានឡើយ។

### ៧៩-ត្រូវកែសម្រួលអនុសញ្ញា

- ត្រូវកែសម្រួលអនុសញ្ញា ដោយកាន់តាមគោលការណ៍ដ៏សំខាន់ដូចតទៅ គឺត្រូវមានបំណងចង់ជួយគ្រីស្តបរិស័ទ ឲ្យយល់អត្ថន័យ និងចូលរួមយ៉ាងសកម្មដោយងាយស្រួល ទាំងយកចិត្តទុកដាក់នឹងតម្រូវការនាបច្ចុប្បន្ន។ ពេលកែសម្រួលអនុសញ្ញា គេក៏អាចបន្ថែមអនុសញ្ញាថ្មីទៀតតាមតម្រូវការ ស្របតាមសេចក្តីណែនាំដែលមានចែងក្នុងមាត្រា ៦៣ ដែរ។
- ត្រូវទុកពរ ដែលមានតែអភិបាលអាចប្រទានបាន តែមួយចំនួនតូច។
- ត្រូវព្រាងទុកឲ្យគ្រីស្តបរិស័ទធម្មតាដែលមានលក្ខណៈសមរម្យ អាចធ្វើអនុសញ្ញាខ្លះបាន ក្នុងកាលៈទេសៈដែលលោកអភិបាលយល់ឃើញថា គួរឲ្យធ្វើនោះ។

### ៨០-ពិធីសច្ចាប្រណិធាន

ត្រូវកែសម្រួលពិធីញែកស្ត្រីព្រហ្មចារីថ្វាយព្រះជាម្ចាស់ ដែលមានកត់ត្រាទុកក្នុងក្បួនពិធីអភិបាលព្រះសហគមន៍ក្រុងរ៉ូម។

ម្យ៉ាងទៀត ត្រូវបង្កើតពិធីមួយ គឺបព្វជិតាប្រកាសពាក្យសច្ចាប្រណិធាន និងប្រកាសពាក្យសន្យាសាជាថ្មី ដើម្បីឲ្យពិធីទាំងនោះស៊ីសង្វាក់គ្នា មិនស្មុគស្មាញ ហើយថ្លៃថ្នូរទៀតផង។ អស់អ្នកដែលធ្វើពិធីសច្ចាប្រណិធានឬធ្វើពិធីប្រកាសពាក្យសន្យាសាជាថ្មី ក្នុងពេលថ្វាយអភិបូជា ត្រូវអនុវត្តតាមពិធីថ្មីនោះ លើកលែងតែមានច្បាប់វិន័យផ្សេងដោយឡែក។ បើបព្វជិតាធ្វើពិធីសច្ចាប្រណិធានក្នុងពេលថ្វាយអភិបូជា ទើបប្រសើរជាង។

### ៨១-ត្រូវកែសម្រួលពិធីបញ្ចុះសព

ត្រូវឲ្យពិធីបញ្ចុះសពបញ្ជាក់យ៉ាងច្បាស់ថា គ្រីស្តបរិស័ទដែលចែកស្ថានរួចហើយ បានចូលរួមជាមួយព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង។ ពិធីទាំងនោះ សូម្បីតែពណ៌អាវអ្នកធ្វើពិធីគោរពប្រណិប័តន៍ ក៏ត្រូវសមស្របតាមសភាពការណ៍ និងតាមប្រពៃណីប្រជាជនរស់នៅតាមតំបន់ផ្សេង ៗដែរ។

### ៨២-ត្រូវកែសម្រួល

ពិធីបញ្ចុះសពទារក ហើយត្រូវបង្កើតឲ្យមានអភិបូជាពិសេស សម្រាប់ឱកាសនេះដែរ។

# ជំពូក ៤

## ពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់

### ៨៣-ពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់ ជាកិច្ចរបស់ព្រះគ្រីស្ត និងជាកិច្ចរបស់ព្រះសហគមន៍

ព្រះគ្រីស្តយេស៊ូជាមហាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី ដែលស្ថិតនៅគង់វង្សអស់កល្បជានិច្ច។ ពេលព្រះអង្គប្រសូតជាមនុស្ស ព្រះអង្គក៏យកបទដែលមានច្រៀងអស់កល្បជានិច្ចនៅលោកខាងមុខ មកឲ្យយើងច្រៀងនៅពេលយើង នៅនិរទេសក្នុងលោកនេះ។ ព្រះគ្រីស្តប្រោសឲ្យសហគមន៍របស់មនុស្សលោកទាំងអស់រួមជាមួយព្រះអង្គ ច្រៀងបទលើកតម្កើងនេះថ្វាយព្រះជាម្ចាស់។

ព្រះគ្រីស្តយេស៊ូនៅតែបន្តបំពេញមុខងារ ជាមហាបូជាចារ្យនេះ ដោយសារព្រះសហគមន៍ គឺមិនគ្រាន់តែដោយព្រះសហគមន៍ថ្វាយអភិបូជាប៉ុណ្ណោះទេ តែដោយរបៀបផ្សេងៗទៀត ជាពិសេសដោយព្រះសហគមន៍ធ្វើពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់។ ព្រះសហគមន៍លើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ឥតឈប់ឈរ ហើយអង្វរព្រះអង្គ សូមសង្គ្រោះមនុស្សលោកទាំងមូលទៀតផង។

### ៨៤-តាមការបញ្ជូនបន្តរបស់គ្រីស្តបរិស័ទតាំងពីបរមបុរាណមក

មានតែងតាំងពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់ ដើម្បីឲ្យមនុស្សលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គទាំងយប់ទាំងថ្ងៃ និងញែកគ្រប់ពេលវេលាឲ្យបានវិសុទ្ធថ្វាយព្រះអង្គផង។ ពេលអស់លោកបូជាចារ្យឬអ្នកផ្សេងៗទៀតដែលព្រះសហគមន៍ចាត់ចែងទុកជាតំណាង ឲ្យបំពេញកិច្ចការនេះ នាំគ្នាលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ តាមបទដ៏ប្រសើរនេះ ស្របតាមវិន័យដ៏ត្រឹមត្រូវឬនៅពេលគ្រីស្តបរិស័ទ រួមអធិដ្ឋានជាមួយបូជាចារ្យ តាមរបៀបព្រះសហគមន៍យល់ស្របនោះ គឺនៅពេលនោះ ពិតជាព្រះសហគមន៍ជាព្រះមហេសី បន្លឺសូរសំឡេងឡើងនិយាយសន្ទនាជាមួយព្រះគ្រីស្តជាព្រះស្វាមីមែន ឬបើពោលឲ្យបានល្អជាងនេះទៅទៀត គឺព្រះគ្រីស្តរួមជាមួយព្រះកាយព្រះអង្គ មានព្រះបន្ទូលទៅកាន់ព្រះបិតា។

### ៨៥-ហេតុនេះហើយបានជាអស់អ្នកដែលបំពេញកិច្ចនេះ

ក៏បំពេញការងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះសហគមន៍ហើយ នៅពេលជាមួយគ្នានោះ ក៏ទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត រួមជាមួយព្រះមហេសីរបស់ព្រះគ្រីស្ត។ ពេលគេបំពេញកិច្ចលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ គេឈរនៅខាងមុខបល្ល័ង្ករបស់ព្រះអង្គ ក្នុងនាមព្រះសហគមន៍ជាព្រះមាតា។

## ៨៦-ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ មានប្រយោជន៍ខាងការណែនាំគ្រីស្តបរិស័ទ

បូជាចារ្យទាំងប៉ុន្មានដែលកំពុងបំពេញមុខងារបម្រើជាគង្វាល ត្រូវតែយកចិត្តទុកដាក់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមពេលកំណត់នោះ ដោយយល់កាន់តែច្បាស់ថា ខ្លួនត្រូវអនុវត្តតាមដំបូន្មានរបស់ គ្រីស្តទូតប៉ូល ដែលមានប្រសាសន៍ថា *"ចូរអធិដ្ឋានឥតឈប់ឈរ"* (១ថស ៥, ១៧)។ មានតែព្រះអម្ចាស់យេស៊ូមួយព្រះអង្គទេ ដែលអាចប្រោសឲ្យកិច្ចអស់លោកប្រព្រឹត្តជារៀងរាល់ថ្ងៃបានស័ក្តិសិទ្ធ និងអាចចម្រើនឡើងបាន គឺព្រះអង្គមានព្រះបន្ទូលថា *"បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតបានឡើយ "*(យហ ១៥, ៥)។ ហេតុនេះហើយ បានជានៅពេលក្រុមគ្រីស្តទូតតែងតាំងឧបដ្ឋាក អស់លោកមានប្រសាសន៍ថា *"រីឯយើងវិញ យើងនឹងគិតតែពីអធិដ្ឋាន ហើយបម្រើព្រះបន្ទូល"* (កក ៦, ៤)។

## ៨៧-មហាសន្និបាតដ៏វិសុទ្ធ

នៅតែបន្តការកែសម្រួលដែលអាសនៈគ្រីស្តទូតសិលាចាប់ផ្តើម ដោយជោគជ័យ។ មហាសន្និបាតមានបំណងចង់ឲ្យអស់លោកបូជាចារ្យក្តី សមាជិកផ្សេងៗទៀតរបស់ព្រះសហគមន៍ក្តី លើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ឲ្យកាន់តែប្រសើរ និងកាន់តែពេញលក្ខណៈឡើងក្នុងសភាពការណ៍នាសម័យឥឡូវ។ ហេតុនេះហើយ បានជាមហាសន្និបាតសម្រេចក្រឹត្យ ស្តីអំពីពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ស្របតាមក្បួនពិធីគោរពប្រណិប័តន៍ព្រះសហគមន៍ក្រុងរ៉ូម ដូចខាងក្រោមនេះ៖

## ៨៨-ត្រូវកែសម្រួលលំដាប់លំដោយនៃពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់

ពិធីលើកតម្កើងសិរីរុងរឿង ព្រះជាម្ចាស់តាមពេលកំណត់ មានគោលដៅលើកពេលវេលាពេញមួយថ្ងៃ ថ្វាយព្រះជាម្ចាស់ឲ្យបានវិសុទ្ធ។ ហេតុនេះប្រសិនបើអាចធ្វើបាន ត្រូវកែសម្រួលដំណើរនៃពិធីលើកតម្កើងសិរីរុងរឿង ព្រះជាម្ចាស់នេះ ដើម្បីឲ្យពេលកំណត់នេះបានត្រូវចំនឹងពេលវេលាដ៏ពិតប្រាកដប្រចាំថ្ងៃ។ ម្យ៉ាងទៀត ត្រូវយកចិត្តទុកដាក់អំពីសភាពការណ៍នៃជីវភាពរបស់មនុស្សនាបច្ចុប្បន្នកាល ជាពិសេសអំពីសភាពការណ៍របស់អស់អ្នក ដែលបំពេញកិច្ចការជាគ្រីស្តទូត។

## ៨៩-ហេតុដូច្នេះហើយ បានជាត្រូវកែសម្រួលពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមសេចក្តីណែនាំដូចតទៅ៖

ក- តាមប្រពៃណីដ៏ជាទីគោរពនៃព្រះសហគមន៍សកល ពិធីលើកតម្កើងនៅពេលព្រឹក និងពិធីលើកតម្កើងនៅពេលល្ងាច ជាស្នូលដ៏សំខាន់ជាងគេនៃពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់រៀងរាល់ថ្ងៃ។ ហេតុនេះ ត្រូវចាត់ពិធីទាំងពីរនោះ ទុកជាពេលកំណត់ដ៏ប្រសើរជាងគេ ហើយត្រូវធ្វើពិធីទាំងពីរ ស្របតាមគោលការណ៍នេះទៀតផង។

ខ- ត្រូវចាត់ចែងពិធីលើកតម្កើងនៅពេលយប់ ដើម្បីឲ្យបានសមនឹងពេលចុងក្រោយប្រចាំថ្ងៃ។

គ- ចំពោះពិធីលើកតម្កើងដែលហៅថា *"ពិធីលើកតម្កើងនៅកណ្តាលយប់"* ទោះបីនៅក្នុងអារាម ពិធីនេះ ត្រូវរក្សាទុកលក្ខណៈជាពិធីលើកតម្កើងរួមនៅពេលយប់ ក៏ត្រូវកែសម្រួលពិធីនោះ ដើម្បីឲ្យគេអាចសូត្រនៅ

ពេលណាក៏បាន។ ត្រូវសូត្រទំនុកតម្កើងចំនួនតិចជាងពីមុន តែត្រូវអានអត្ថបទផ្សេងៗ ឲ្យបានវែងជាងពីមុនវិញ។

ឃ- ត្រូវលុបបំបាត់ *"ពិធីលើកតម្កើងដើមដំបូងនៅព្រឹកព្រលឹម"* ចោល។

ង- ប្រសិនបើមានធ្វើពិធីលើកតម្កើងរួមគ្នាក្នុងអារាម ទោះបី *"ពិធីលើកតម្កើងនៅ ម៉ោងប្រាំបួនព្រឹក"* *"ពិធីលើកតម្កើងនៅថ្ងៃត្រង់"* *"ពិធីលើកតម្កើងនៅម៉ោងបីរសៀល"* មិនសូវសំខាន់ក្ដី ក៏ត្រូវតែធ្វើក្នុងអារាមដែរ។ តែប្រសិនបើមានធ្វើ ពិធីទាំងបីនោះក្រៅពីអារាមវិញ មានសិទ្ធិជ្រើសរើសពិធីលើកតម្កើងតែមួយបាន គឺពិធីណាស្របតាមពេលវេលាប្រចាំថ្ងៃដែលអាចធ្វើបាន។

៩០-ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ពិតជាប្រភពនៃការគោរពថ្វាយបង្គំព្រះជាម្ចាស់ ដោយពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ជាពិធីលើកតម្កើងជាសាធារណៈរបស់ព្រះសហគមន៍ ពិធីនោះ ក៏ពិតជាប្រភពនៃការគោរពថ្វាយបង្គំព្រះជាម្ចាស់ និងពិតជាអាហារចិញ្ចឹមពាក្យអធិដ្ឋានផ្ទាល់ខ្លួន។ ហេតុនេះហើយ សូមក្រើនដាស់តឿនក្នុងព្រះនាមព្រះអម្ចាស់ អស់លោកបូជាចារ្យ និងអស់អ្នកដែលចូលរួមក្នុងពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ថា នៅពេលធ្វើពិធីនោះ សូមមានចិត្តគំនិតស្របតាមសំឡេងអស់លោកអ្នកវិញ។ សូមអស់លោកអ្នកខិតខំរៀនឲ្យមានចំណេះកាន់តែជ្រៅ អំពីពិធីគោរពប្រណិប័តន៍ និងអំពីព្រះគម្ពីរ ជាពិសេសស្គាល់អត្ថន័យទំនុកតម្កើង ទើបអស់លោកអ្នកអាចមានចិត្តគំនិតស្របតាមសំឡេងអស់លោកអ្នកបាន។

ពេលកែសម្រួលពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ តាមពេលកំណត់ឲ្យបានជាថ្មីនោះ ត្រូវសម្រួលទ្រព្យដ៏មានតម្លៃគួរឲ្យគោរព នៃក្បួនពិធី នៃព្រះសហគមន៍ក្រុងរ៉ូមតាំងពីយូរយារមក ដើម្បីឲ្យអស់លោកអ្នកដែលទទួលទ្រព្យដ៏មានតម្លៃយ៉ាងខ្ពង់ខ្ពស់នេះ ទុកជាបញ្ញើ ងាយស្រួលស្ដាប់ ហើយយោងប្រយោជន៍កាន់តែច្រើនឡើងៗ។

## ៩១-អំពីទំនុកតម្កើង

មិនត្រូវចែកទំនុកតម្កើងទាំងអស់ ឲ្យសូត្រក្នុងរយៈពេលតែមួយអាទិត្យប៉ុណ្ណោះទេ តែត្រូវចែកទំនុកតម្កើងទាំងអស់ ឲ្យសូត្រក្នុងរយៈពេលវែងជាងនោះទៅទៀត។ ធ្វើដូច្នេះ ទើបអស់លោកអ្នកអាចសូត្រតាមពេលកំណត់ តាមសេចក្ដីចែងក្នុងមាត្រា ៨៩ យ៉ាងពិតប្រាកដបាន។

ត្រូវបង្ហើយការកែសម្រួលក័ណ្ឌគម្ពីរទំនុកតម្កើងដែលចាប់ផ្ដើម ឲ្យបានរួចឆាប់ៗ ដោយគោរពទាំងអក្សរសាស្ត្រភាសាឡាតាំងនៃគ្រីស្តសាសនា ទាំងរបៀបប្រើទំនុកតម្កើង ក្នុងពិធីគោរពប្រណិប័តន៍ ព្រមទាំងតាមការបញ្ជូនបន្តទាំងមូលនៃព្រះសហគមន៍ដែលកាន់តាមប្រពៃណីឡាតាំង។

## ៩២-ការចាត់ចែងអត្ថបទដែលត្រូវអាន

ចំពោះអត្ថបទដែលត្រូវអាន ត្រូវអនុវត្តតាមសេចក្ដីណែនាំដូចតទៅ៖

ក- ត្រូវចាត់ចែងអានអត្ថបទព្រះគម្ពីរ ដើម្បីឲ្យគេអាចចូលយ៉ាងងាយ ទៅកាន់ទ្រព្យដ៏ថ្លៃថ្នូរនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានបរិបូរណ៍ជាងពីមុន។

ខ- ត្រូវជ្រើសរើសយកអត្ថបទដកស្រង់ចេញពីក្រុមគ្រូបាធ្យាយនៃព្រះសហគមន៍ និងពីក្រុមអស់លោកអ្នក

បណ្ឌិត ព្រមទាំងពីអ្នកនិពន្ធផ្សេង ៗរបស់ព្រះសហគមន៍ តាមរបៀបល្អជាងពីមុន។

គ- ត្រូវកែសម្រួលអត្ថបទ ស្តីអំពីរឿងមរណសាក្សី និងជីវប្រវត្តិនៃសន្តបុគ្គល ឲ្យបានស្របតាមប្រវត្តិសាស្ត្រដ៏ពិតប្រាកដ។

## ៩៣-ត្រូវកែសម្រួលបទលើកតម្កើង

ប្រសិនបើយល់ឃើញថា គួរឲ្យកែសម្រួលបទលើកតម្កើង ឲ្យបានស្របតាមរបៀបដើមវិញ ដោយចោល ឬប្រែសម្រួលសេចក្តីទាំងប៉ុន្មាន ដែលមានលក្ខណៈជារឿងព្រេង ឬដែលមិនសូវស៊ីសង្វាក់នឹងការគោរពថ្វាយបង្គំតាមគ្រីស្តសាសនា។ ត្រូវទទួលយកបទលើកតម្កើងផ្សេង ៗទៀត ដកស្រង់ពីទ្រព្យដ៏ថ្លៃថ្នូរនៃបទលើកតម្កើងនានា តាមតម្រូវការ។

## ៩៤-ពេលវេលាធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់

ត្រូវធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ចំពេលវេលាដែលមានចែងក្នុងក្បួនពិធី ឬជិតពេលកំណត់នោះ។ ធ្វើដូច្នេះ ទើបពេលវេលាប្រចាំថ្ងៃបានវិសុទ្ធយ៉ាងពិតប្រាកដ ហើយអ្នកធ្វើពិធី ក៏បានផលខាងព្រះវិញ្ញាណដែរ។

## ៩៥-អំពីភារកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់

ក្រុមបព្វជិតបព្វជិតា ដែលមានកាតព្វកិច្ចរួមគ្នាធ្វើពិធីផ្សេង ៗក្នុងអារាម ក្រៅពីថ្វាយអភិបូជារួមក្នុងអារាម ក៏មានកាតព្វកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ តាមពេលកំណត់ជារៀងរាល់ថ្ងៃនៅអារាមគឺ៖

ក- ក្រុមលោកដែលមានឋានៈកិត្តិយសក្នុងវិហារមួយ ក្រុមលោកសង្ឃនិងដូនជីកាតូលិក បព្វជិតបព្វជិតាដែលមានកាតព្វកិច្ចរួមគ្នាធ្វើពិធីផ្សេង ៗក្នុងអារាម តាមក្បួនច្បាប់ទូទៅរបស់ព្រះសហគមន៍ ឬតាមធម្មនុញ្ញរបស់ក្រុមគ្រួសាររបស់គេ ត្រូវធ្វើគ្រប់ផ្នែកទាំងអស់នៃពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ តាមពេលកំណត់ជាកំហិត។

ខ- ក្រុមប្រឹក្សានៃវិសាលវិហារ ឬក្រុមបូជាចារ្យក្នុងវិហារខ្លះ ត្រូវធ្វើតែផ្នែកខ្លះនៃពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ គឺផ្នែកណាដែលត្រូវធ្វើស្របតាមក្បួនច្បាប់ទូទៅ ឬស្របតាមក្បួនច្បាប់របស់ក្រុមអស់លោកដោយឡែក។

គ- អស់លោកអ្នកជាសមាជិកក្រុមគ្រួសារខាងលើនេះ ទោះបីគេទទួលអគ្គសញ្ញាតែងតាំងក្តី ឬបានធ្វើពិធីសច្ចាប្រណិធានយ៉ាងឱឡារិកក្តី លើកលែងតែបងប្អូនជាអ្នកបម្រើក្នុងអារាម ប្រសិនបើគេមិនធ្វើពិធីលើកតម្កើងសិរីរុងរឿង ព្រះជាម្ចាស់តាមពេលកំណត់រួមគ្នាក្នុងអារាមទេ ក៏ត្រូវសូត្រម្នាក់ឯង តាមម៉ោងពិធីទាំងនោះដែរ។

## ៩៦-អស់លោកដែលបានទទួលអគ្គសញ្ញាតែងតាំងរួចហើយ

តែគ្មានកាតព្វកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជា ម្ចាស់តាមពេលកំណត់រួមក្នុងអារាមទេ ក៏មានកាតព្វកិច្ចធ្វើពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់ទាំងមូល ជារៀងរាល់ថ្ងៃជាកំហិត ដោយរួមគ្នា ឬនៅម្នាក់ឯង ត្រូវស្របតាម

សេចក្ដីណែនាំចែងក្នុងមាត្រា ៨៩។

### ៩៧-ប្រសិនគេអាក់ខានធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់

ត្រូវបញ្ជាក់កិច្ចការដែលគេត្រូវធ្វើជំនួសហើយត្រូវកត់ត្រាទុកជាសេចក្ដីណែនាំក្នុងក្បួនពិធី។ ក្នុងករណីពិសេស ហើយប្រសិនបើមានមូលហេតុត្រឹមត្រូវ អស់លោកអភិបាលអាចអនុញ្ញាតឲ្យអស់អ្នក ដែលនៅក្រោមអំណាចរបស់លោក រួចពីកាតព្វកិច្ចរបស់គេ គឺអនុញ្ញាតឲ្យធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តែមួយផ្នែក ឬអនុញ្ញាតមិនឲ្យធ្វើគ្រប់ផ្នែកក៏បានដែរ។ លោកក៏អាចបញ្ជាក់កិច្ចកាដែលគេត្រូវធ្វើជំនួស។

### ៩៨-ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់នៅគ្រឹះស្ថានបព្វជិតបព្វជិតា

សមាជិកគ្រឹះស្ថានបព្វជិតបព្វជិតាណាក៏ដោយ ដែលមានគោលដៅរស់នៅតាមរបៀបដ៏ពេញលក្ខណៈល្អ ឥតខ្ចោះ ហើយដែលមានកាតព្វកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ផ្នែកខ្លះៗ ស្របតាមធម្មនុញ្ញរបស់គ្រឹះស្ថានទាំងនោះ ពិតជាបំពេញពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជាសាធារណៈរបស់ព្រះសហគមន៍ហើយ។

ប្រសិនបើគេធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់យ៉ាងខ្លីតាមធម្មនុញ្ញរបស់គេ គេក៏បំពេញពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជាសាធារណៈរបស់ព្រះសហគមន៍ពិតមែនដែរ លុះត្រាតែពិធីដ៏ខ្លីនោះមានចាត់ចែងតាមរបៀបពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ តាមពេលកំណត់ និងបានទទួលសេចក្ដីអនុញ្ញាតយ៉ាងត្រឹមត្រូវ។

### ៩៩-ពិធីសូត្ររួម

ពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ជាសូរសំឡេងរបស់ព្រះសហគមន៍គឺជាសូរសំឡេង របស់ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ដទាំងមូលដែលលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជាសាធារណៈ។ ហេតុនេះហើយបានជាមហាសន្និបាតផ្ដែផ្ដាំដាស់តឿនអស់លោក ដែលបានទទួលអគ្គសញ្ញាតែងតាំង ហើយដែលគ្មានកាតព្វកិច្ចធ្វើពិធីរួមក្នុងអារាមទេ ជាពិសេសផ្ដែផ្ដាំឲ្យលោកគង្វាលដែលរួមរស់ជាមួយគ្នា ឬដែលជួបជុំគ្នាម្ដងម្កាលថា ត្រូវធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ យ៉ាងហោចណាស់មួយផ្នែកដែរ។

អស់អ្នក ដែលធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ទោះបីរួមគ្នានៅអារាមក្ដី សូត្ររួមគ្នាកន្លែងផ្សេងក្ដី ក៏ត្រូវបំពេញភារកិច្ចដែលព្រះសហគមន៍ផ្ញើទុកឲ្យអស់លោក ឲ្យបានល្អប្រសើរឥតខ្ចោះតាមតែគេអាចធ្វើបានដោយគោរពថ្វាយបង្គំនៅខាងក្នុងចិត្តផង និងដោយធ្វើពិធីយ៉ាងល្អប្រសើរនៅខាងក្រៅផងដែរ។

ម៉្យាងទៀត ត្រូវសូត្រទំនុកតម្កើងក្នុងពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ នៅក្នុងអារាម ឬរួមគ្នានៅកន្លែងផ្សេងតាមតែអាចធ្វើទៅបាន។

### ១០០-គ្រីស្ដបរិស័ទត្រូវចូលរួមធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់

អស់លោកគង្វាល ត្រូវយកចិត្តទុកដាក់ចាត់ចែងពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់រួមគ្នាក្នុងព្រះវិហារ គឺពិធីនៅម៉ោងសំខាន់ៗ ជាពិសេសពិធីលើកតម្កើងពេលល្ងាច នៅថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យឱឡារិក។ មហាសន្និបាត ផ្ដែផ្ដាំឲ្យគ្រីស្ដបរិស័ទធម្មតា ធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់រួមជាមួយលោកគង្វាលក៏បាន ឬរួមជាមួយគ្នាក៏បាន ឬ

ម្នាក់ឯងក៏បានដែរ។

**១០១-ភាសា**

ក- អស់លោកដែលបានទទួលអគ្គសញ្ញាតែងតាំងពេលធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ត្រូវតែប្រើភាសាឡាតាំង ស្របតាមប្រពៃណីក្បួនពិធីជាភាសាឡាតាំងដ៏បរមបុរាណមក។ ក៏ប៉ុន្តែលោកអភិបាលភូមិភាគមានសិទ្ធិអាចអនុញ្ញាតឲ្យសូត្រតាមក្បួនបកប្រែជាភាសាតំបន់ ស្របតាមសេចក្ដីចែងក្នុងមាត្រា ៣៦។ លោកអភិបាលអនុញ្ញាតដូច្នេះ ដើម្បីកុំឲ្យលោកម្នាក់ៗ ដែលមិនចេះភាសាឡាតាំងជួបឧបសគ្គរារាំងយ៉ាងធ្ងន់ធ្ងរ មិនអាចបំពេញភារកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់យ៉ាងល្អបាន។

ខ- ចំពោះបព្វជិតា និងសមាជិកគ្រឹះស្ថានដែលមានគោលដៅរស់នៅយ៉ាងល្អឥតខ្ចោះពេញលក្ខណៈ ទាំងបុរស ទាំងស្ត្រី មេដឹកដែលមានសមត្ថកិច្ចណែនាំគ្រឹះស្ថានទាំងនោះ មានសិទ្ធិអាចអនុញ្ញាតឲ្យសមាជិកក្រុមទាំងនោះសូត្រជា ភាសាក្នុងតំបន់បាន នៅពេលធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ សូម្បីតែនៅពេលធ្វើពិធីរួមគ្នាក្នុងអារាម ក៏បានដែរ លុះត្រាតែក្បួនពិធីបកប្រែដែលគេសូត្រនោះបានទទួលការអនុម័ត។

គ- លោកណាដែលបានទទួលអគ្គសញ្ញាតែងតាំង ហើយដែលមានកាតព្វកិច្ចធ្វើពិធីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់តាមពេលកំណត់ ប្រសិនបើលោកធ្វើពិធីនោះ ជាភាសាក្នុងតំបន់នោះ រួមជាមួយក្រុមគ្រីស្តបរិស័ទ ឬជាមួយក្រុមផ្សេងៗដែលមានចែងនៅក្នុងលេខ២ ខាងលើនេះ ក៏បំពេញកាតព្វកិច្ចរបស់ខ្លួន ពិតមែនហើយ លុះត្រាតែក្បួនពិធីបកប្រែដែលគេសូត្រនោះបានទទួលការអនុម័ត។

# ជំពូក ៥

# ពិធីគោរពប្រណិប័តន៍ក្នុងអំឡុងពេលពេញមួយឆ្នាំ

## ១០២-អត្ថន័យពិធីគោរពប្រណិប័តន៍ក្នុងអំឡុងពេលពេញមួយឆ្នាំ

ព្រះសហគមន៍ ជាមាតាដ៏វិសុទ្ធរបស់យើងយល់ឃើញថា មានភារកិច្ចលើកតម្កើងកិច្ចសង្គ្រោះដែលព្រះគ្រីស្តជាព្រះស្វាមីបានសម្រេច ដោយចាត់ចែងពិធីនឹករឭកដ៏សក្ការៈ តាមថ្ងៃកំណត់តៗមក ក្នុងអំឡុងពេលពេញមួយឆ្នាំ។ រៀងរាល់ថ្ងៃអាទិត្យ នៅថ្ងៃដែលព្រះសហគមន៍ហៅថា *"ថ្ងៃរបស់ព្រះអម្ចាស់"* ព្រះសហគមន៍នឹករឭកដល់ព្រះអម្ចាស់ មានព្រះជន្មថ្មីដ៏រុងរឿង ដូចព្រះសហគមន៍ធ្លាប់លើកតម្កើងមួយឆ្នាំម្តងៗ ទាំងនឹករឭកដល់ព្រះអង្គរងទុក្ខលំបាក នៅពេលជាមួយគ្នាផង ក្នុងឱកាសបុណ្យចម្លង ជាពិធីយ៉ាងឱឡារិកជាងគេបំផុត។

ក្នុងអំឡុងពេលពេញមួយឆ្នាំ ព្រះសហគមន៍លាតព្រឹត្តិការណ៍ដ៏អស្ចារ្យ ដែលព្រះគ្រីស្តបានសម្រេច គឺតាំងពីព្រះយេស៊ូប្រសូតជាមនុស្ស រហូតដល់ព្រះបិតាលើកព្រះអង្គឡើង និងរហូតដល់បុណ្យថ្ងៃទីហាសិប ហើយរហូតដល់ថ្ងៃព្រះអម្ចាស់យាងមកយ៉ាងរុងរឿង តាមសេចក្តីរង់ចាំដ៏សែនសុខសាន្តរបស់យើង។

ដោយលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែលរំដោះយើងបែបនេះ ព្រះសហគមន៍ក៏បើកទ្រព្យដ៏មានតម្លៃនៃអនុភាព និងនៃគុណបុណ្យព្រះអម្ចាស់របស់ខ្លួនឲ្យគ្រីស្តបរិស័ទ។ ធ្វើដូច្នេះ ព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះហាក់ដូចជាមានវត្តមានតាមពេលវេលាជាបន្តបន្ទាប់ហើយគ្រីស្ត បរិស័ទអាចភ្ជាប់នឹងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះ និងបានពោរពេញដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលសង្គ្រោះគេ។

## ១០៣-ដោយព្រះសហគមន៍លើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងប៉ុន្មានរបស់ព្រះគ្រីស្ត

ក្នុងអំឡុងពេលពេញមួយឆ្នាំ ព្រះសហគមន៍ក៏គោរពព្រះនាងម៉ារីជាព្រះមាតារបស់ព្រះអម្ចាស់ ដោយមានសេចក្តីស្រឡាញ់យ៉ាងពិសេសចំពោះព្រះនាង ព្រោះព្រះនាងភ្ជាប់ជាមួយបុត្ររបស់នាងក្នុងកិច្ចសង្គ្រោះរបស់បុត្រនោះ ដោយចំណងដែលមិនអាចស្រាយបាន។ ពេលព្រះសហគមន៍សម្លឹងមើលព្រះនាងម៉ារី ព្រះសហគមន៍សរសើរ និងលើកតម្កើងផលដ៏ប្រសើរជាងគេបំផុតរបស់ព្រះគ្រីស្តដែលរំដោះមនុស្សលោក។ ម្យ៉ាងទៀត ពេលព្រះសហគមន៍សម្លឹងមើលព្រះនាងព្រះសហគមន៍ក៏នឹករំពឹងគិតដោយអំណរ ហាក់ដូចជាសម្លឹងមើលក្នុងរូបដ៏និមលបំផុតនោះ នូវអ្វីៗដែលខ្លួនប្រាថ្នាចង់បាន ហើយសង្ឃឹមថានឹងបានទាំងស្រុងដូចព្រះនាងដែរ។

## ១០៤-ព្រះសហគមន៍បញ្ចូលថ្ងៃនឹករឭកមរណសាក្សី និងសន្តបុគ្គលផ្សេងៗទៀត

ក្នុងចំណោមពិធីគោរពប្រណិប័តន៍ប្រចាំឆ្នាំ។ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្តោសជាច្រើនយ៉ាងព្រះអង្គបានលើកសន្តបុគ្គលទាំងនោះ ឲ្យបានពេញលក្ខណៈ និងឲ្យបានទទួលការសង្គ្រោះអស់កល្បជានិច្ចរួចហើយ។

សន្តបុគ្គលទាំងនោះនាំគ្នាច្រៀងបទលើកតម្កើងដ៏ពេញលក្ខណៈថ្វាយព្រះជាម្ចាស់នៅស្ថានបរមសុខ ព្រមទាំងជួយអង្វរព្រះអង្គឲ្យយើង។ ពេលព្រះសហគមន៍ធ្វើពិធីនឹកថ្ងៃខួបនៃកំណើតរបស់សន្តបុគ្គល នៅស្ថានបរមសុខនោះ ព្រះសហគមន៍ក៏ប្រកាសព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង គឺសន្តបុគ្គលទាំងនោះ រងទុក្ខលំបាករួមជាមួយព្រះគ្រីស្ត ហើយក៏បានទទួលសិរីរុងរឿងរួមជាមួយព្រះគ្រីស្តដែរ។ ព្រះសហគមន៍ក៏បង្ហាញសន្តបុគ្គល ទុកជាគំរូឲ្យគ្រីស្តបរិស័ទយកតម្រាប់តាម គឺគំរូដែលទាក់ទាញគ្រីស្តបរិស័ទទាំងអស់ទៅរកព្រះបិតា ដោយសារព្រះគ្រីស្ត។ អំពើល្អរបស់សន្តបុគ្គលទាំងនោះនៅពេលគាត់រស់នៅ ក៏ធ្វើឲ្យព្រះជាម្ចាស់នឹងប្រទានពរដល់ព្រះសហគមន៍ដែរ។

### ១០៥-ព្រះសហគមន៍អប់រំគ្រីស្តបរិស័ទ

តាមរដូវផ្សេងៗក្នុងអំឡុងពេលពេញមួយឆ្នាំ ដោយនាំឲ្យគេប្រព្រឹត្តតាមវិន័យ បញ្ញូនបន្តពីដើមមក គឺឲ្យគេធ្វើសកម្មភាពផ្សេងៗទាំងខាងវិញ្ញាណផង ទាំងខាងរូបកាយផង។ ព្រះសហគមន៍បង្រៀនគេ នាំឲ្យគេអធិដ្ឋាន និងឲ្យគេប្រែចិត្តគំនិត ហើយប្រព្រឹត្តកិច្ចការតាមមេត្តាករុណាទៀតផង។

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធសម្រេចសេចក្តីដូចខាងក្រោមនេះ៖

### ១០៦-ត្រូវលើកតម្លៃនៃថ្ងៃអាទិត្យ

ព្រះសហគមន៍លើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង រៀងរាល់ថ្ងៃទី៨ដែលយើងតែងហៅយ៉ាង ត្រឹមត្រូវថា *"ថ្ងៃរបស់ព្រះអម្ចាស់"* ព្រោះជាថ្ងៃព្រះគ្រីស្តមានព្រះជន្មថ្មីដ៏រុងរឿង តាមក្រុមគ្រីស្តទូតបានបញ្ជូនបន្តមក។ នៅថ្ងៃអាទិត្យនោះ គ្រីស្តបរិស័ទត្រូវតែជួបជុំគ្នា។ ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចូលរួមថ្វាយពិធីអរព្រះគុណ គ្រីស្តបរិស័ទនាំគ្នា នឹករឭកដល់ព្រះអម្ចាស់យេស៊ូរងទុក្ខលំបាក និងមានព្រះជន្មថ្មីដ៏រុងរឿង។ គ្រីស្តបរិស័ទ ក៏អរព្រះគុណព្រះបិតាដែល *"បានប្រោសគេឲ្យកើតជាថ្មី ដោយប្រោសឲ្យព្រះយេស៊ូគ្រីស្តមានព្រះជន្មថ្មីដ៏រុងរឿង។ ដូច្នេះ យើងមានសេចក្តីសង្ឃឹម ដែលមិនចេះសាបសូន្យឡើយ"* (១សល ១, ៣)។ ហេតុនេះហើយបានជាថ្ងៃរបស់ ព្រះអម្ចាស់ ជាថ្ងៃធ្វើពិធីគោរពថ្វាយបង្គំដ៏សំខាន់ជាងគេ។ ត្រូវដាស់តឿនឲ្យគ្រីស្តបរិស័ទគោរពថ្ងៃរបស់ព្រះអម្ចាស់ ដើម្បីឲ្យទៅជាថ្ងៃប្រកបដោយអំណរសប្បាយ និងសម្រាកពីការងារ ។ បុណ្យឯទៀតៗទាំងអស់គ្មានអាទិភាពលើថ្ងៃអាទិត្យទេ លើកលែងតែបុណ្យយ៉ាងឱឡារិកបំផុត ពីព្រោះថ្ងៃអាទិត្យពិតជាគ្រឹះ និងជាស្នូលនៃពិធីគោរពប្រណិប័តន៍ប្រចាំឆ្នាំទាំងមូល។

### ១០៧-ត្រូវកែសម្រួលពិធីគោរពប្រណិប័តន៍ក្នុងអំឡុងពេលពេញមួយឆ្នាំ

ត្រូវកែសម្រួលពិធីគោរពប្រណិប័តន៍ ក្នុងអំឡុងពេលពេញមួយឆ្នាំ ដើម្បីរក្សាទុកលក្ខណៈដើម និងចិញ្ចឹមជំនឿរបស់គ្រីស្តបរិស័ទ ហើយណែនាំគេឲ្យគោរពថ្វាយបង្គំព្រះជាម្ចាស់ ដោយធ្វើពិធីលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យ របស់ព្រះគ្រីស្តដែលរំដោះមនុស្សលោកជាពិសេសដោយលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង។ ត្រូវរក្សាទុក ឬកែសម្រួលទំនៀមទម្លាប់ និងវិន័យតាមការបញ្ជូនបន្តមក ដែលភ្ជាប់នឹងរដូវដ៏សក្ការៈ ទាំងសម្របទៅតាមសភាពការណ៍នាសម័យបច្ចុប្បន្ន។ ប្រសិនបើត្រូវកែសម្រួលពិធីគោរពប្រណិប័តន៍ក្នុងអំឡុងពេលពេញមួយឆ្នាំ ត្រូវកែសម្រួលស្របតាមសភាពការណ៍តំបន់នីមួយៗ តាមសេចក្តីចែងក្នុងមាត្រា ៣៩ និង ៤០។

### ១០៨-ត្រូវតម្រង់ចិត្តគំនិតរបស់គ្រីស្តបរិស័ទ

ឲ្យចាប់អារម្មណ៍យ៉ាងពិសេសនឹងថ្ងៃបុណ្យ ដែលលើកតម្កើងព្រះអម្ចាស់ ព្រោះតាមរយៈថ្ងៃបុណ្យទាំងនោះ ព្រះ

សហគមន៍លើកតម្កើងគម្រោងការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះរបស់យើង ក្នុងអំឡុងពេលមួយឆ្នាំម្តង។ បន្ទាប់មក ត្រូវនាំគ្រីស្តបរិស័ទឲ្យចាប់អារម្មណ៍នឹងបណ្យតាមរដូវធម្មតាប្រចាំឆ្នាំ ដែលមានអាទិភាពលើពិធីនឹករឭកដល់សន្តបុគ្គល។ ធ្វើដូច្នេះ ទើបគ្រីស្តបរិស័ទលើកតម្កើងគម្រោងការដ៏អស្ចារ្យ នៃការសង្គ្រោះបានសព្វគ្រប់យ៉ាង សមរម្យក្នុងអំឡុងពេលពេញមួយឆ្នាំ។

## ១០៩-រដូវអប់រំពិសេស ឬរដូវសៃសិបថ្ងៃ

រដូវអប់រំពិសេសមានលក្ខណៈពីរយ៉ាង ទីមួយគឺ ព្រះសហគមន៍អញ្ជើញគ្រីស្តបរិស័ទកាន់តែខ្លាំងឡើងៗឲ្យស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់និងឲ្យព្យាយាមអធិដ្ឋាន ដោយគេនាំគ្នានឹករឭកពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក ឬអប់រំចំណូលថ្មីឲ្យត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក។ លក្ខណៈទីពីរ គឺព្រះសហគមន៍រៀបចំចិត្តគំនិតគ្រីស្តបរិស័ទឲ្យលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង។ ត្រូវយកចិត្តទុកដាក់បង្ហាញលក្ខណៈទាំងពីរនោះ ឲ្យបានច្បាស់ទាំងនៅពេលធ្វើពិធីគោរពប្រណិប័តន៍ក្តី ទាំងនៅពេលអប់រំជំនឿតាមពិធីគោរពប្រណិប័តន៍ក្តី។ ហេតុនេះហើយ៖

ក- ក្នុងពិធីនានានៃរដូវអប់រំពិសេសនោះ ត្រូវយកកត្តាទាក់ទងនឹងអគ្គសញ្ញាជ្រមុជទឹកមកប្រើឲ្យបានច្រើន។ ប្រសិនបើមានប្រយោជន៍ គួរយកកត្តាខ្លះនៃពិធីអគ្គសញ្ញាជ្រមុជទឹក បញ្ជូនបន្តពីបុរាណមកឲ្យមានឡើងវិញ។

ខ- អំពីការប្រែចិត្តគំនិត ក៏ត្រូវគិតតាមរបៀបដដែល។ ចំពោះការអប់រំជំនឿ ត្រូវណែនាំគ្រីស្តបរិស័ទឲ្យនឹកគិតថា អំពើបាបបណ្តាលឲ្យមានផលអាក្រក់ដល់សង្គម។ នៅពេលជាមួយគ្នានេះត្រូវនាំឲ្យគេនឹកគិតអំពីលក្ខណៈផ្ទាល់នៃ ការប្រែចិត្តគំនិត គឺត្រូវស្អប់អំពើបាប ព្រោះជាអំពើខុសនឹងព្រះហឫទ័យព្រះជាម្ចាស់។ សូមកុំបំភ្លេចមុខនាទីរបស់ព្រះសហគមន៍ ក្នុងការប្រែចិត្តគំនិត។ ត្រូវគូសសង្កត់លើពាក្យអង្វរព្រះជាម្ចាស់ឲ្យអស់អ្នកបាបផងដែរ។

## ១១០-គ្រីស្តបរិស័ទប្រែចិត្តគំនិតក្នុងរដូវអប់រំពិសេសមានន័យថា

គេមិនគ្រាន់តែប្រែនៅខាងក្នុងចិត្តឬដោយម្នាក់ឯងប៉ុណ្ណោះទេ តែគេក៏ត្រូវប្រែចិត្តគំនិតនៅខាងក្រៅដែរ ហើយនៅខាងរបៀបរស់នៅក្នុងសង្គមទៀត។ អភិបាលដែលកាន់អំណាចក្នុងតំបន់នីមួយៗ តាមសេចក្តីចែងនៅមាត្រា ២២ ត្រូវជួយលើកស្ទួយ និងផ្តែផ្តាំឲ្យគ្រីស្តបរិស័ទប្រែចិត្តគំនិតយ៉ាងប្រាកដ តាមសមត្ថភាពនៃសម័យយើង និងតាមសមត្ថភាពនៅក្នុងតំបន់នីមួយៗ ព្រមទាំងតាមជីវភាពគ្រីស្តបរិស័ទ។ ទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវតមអាហាក្នុងឱកាសបុណ្យចម្លង ចាត់ទុកជាកិច្ចដ៏សក្ការៈ គឺត្រូវតមអាហារនៅថ្ងៃសុក្រដែលព្រះអម្ចាស់រងទុក្ខលំបាក និងសោយទិវង្គត។ ត្រូវតមអាហារនៅគ្រប់ទីកន្លែងជាកំហិត ហើយប្រសិនគួរឲ្យធ្វើបាន ក៏ត្រូវតមអាហារថ្ងៃសៅរ៍ពិសិដ្ឋដែរ ដើម្បីឲ្យគ្រីស្តបរិស័ទមានចិត្តខ្ពង់ខ្ពស់និងមានសេរីភាពក្នុងចិត្ត និងទៅដល់ថ្ងៃដែលព្រះអម្ចាស់មានព្រះជន្មថ្មីដ៏រុងរឿងយ៉ាងសែនរីករាយ។

## ១១១-ថ្ងៃគោរពសន្តបុគ្គល

ព្រះសហគមន៍តែងតែគោរពសន្តបុគ្គល ហើយក៏គោរពធាតុដ៏ពិតប្រាកដ និងរូបរបស់គេថែមទៀតដែរ តាមការបញ្ជូនបន្តពីបុរាណមក។ ថ្ងៃនឹករឭកគោរពសន្តបុគ្គលជាឱកាសប្រកាសអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែល

ព្រះអង្គបានប្រព្រឹត្ត ក្នុងអ្នកបម្រើរបស់ព្រះអង្គហើយក៏ជាឱកាស បង្ហាញគំរូឲ្យគ្រីស្តបរិស័ទយកតម្រាប់ធ្វើតាម។

ព្រះសហគមន៍ភូមិភាគនីមួយៗ ឬព្រះសហគមន៍ក្នុងប្រទេសមួយ ឬក្រុមគ្រួសារបព្វជិតបព្វជិតាដោយឡែក ត្រូវចាត់ចែងថ្ងៃគោរពមួយចំនួនដោយខ្លួនឯង ដើម្បីកុំឲ្យថ្ងៃគោរពសន្តបុគ្គល មានអាទិភាពលើថ្ងៃគោរពលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងប៉ុន្មាននៃការសង្គ្រោះ។ ព្រះសហគមន៍សកលត្រូវនឹករឭកគោរពតែសន្តបុគ្គលណា ដែលមានសារៈសំខាន់សម្រាប់ព្រះសហគមន៍សកលប៉ុណ្ណោះ។

# ជំពូក ៦

## ភ្លេងដ៏សក្ការៈ

### ១១២-ភ្លេងដ៏សក្ការៈមានតម្លៃថ្លៃថ្នូរ

ព្រះសហគមន៍សកលមានប្រពៃណីដ៏យូរលង់ អំពីភ្លេងដ៏សក្ការៈ ហើយបានប្រមូលបទភ្លេងជាច្រើនទុកជាទ្រព្យដ៏មានតម្លៃខ្ពង់ខ្ពស់បំផុត រកអ្វីមកប្រៀបផ្ទឹមពុំបាន ជាទ្រព្យប្រសើរជាងសិល្បៈឯទៀតៗទាំងអស់។ ការណ៍នេះ មកពីភ្លេងដ៏សក្ការៈភ្ជាប់នឹងពាក្យសម្ដី គឺជាផ្នែកដែលត្រូវការជាចាំបាច់ ក្នុងពិធីគោរពប្រណិប័តន៍នានាដ៏ឱឡារិក ហើយក៏ពិតជាផ្នែកមួយក្នុងពិធីគោរពប្រណិប័តន៍ទាំងនោះ។ ពិតមែនហើយ ក្នុងព្រះគម្ពីរមានលើកតម្កើងបទចម្រៀងដ៏សក្ការៈ (អភ ៥, ១៩; កូឡ ៣, ១៦) គ្រូបាធ្យាយនៃព្រះសហគមន៍ និងអភិបាលព្រះសហគមន៍ក្រុងរ៉ូមជាច្រើននាក់ ក៏បានលើកតម្កើងបទចម្រៀងដ៏សក្ការៈដែរ។ នៅសម័យថ្មីៗ អភិបាលព្រះសហគមន៍ក្រុងរ៉ូមបន្តពីសន្តៈពីយ៉ូស ទី១០ ក៏បានពន្យល់បញ្ជាក់យ៉ាងច្បាស់ អំពីតួនាទីរបស់ភ្លេងដ៏សក្ការៈក្នុងពីធីគោរពបម្រើព្រះជាម្ចាស់ដែរ។

ហេតុនេះហើយ បានជាភ្លេងដ៏សក្ការៈកាន់តែរួមភ្ជាប់នឹងកិច្ចនៃពិធីគោរពប្រណិប័តន៍យ៉ាងណា ភ្លេងក៏កាន់តែវិសុទ្ធយ៉ាងនោះដែរ គឺភ្លេងនាំឲ្យរំភើបចិត្តក្នុងពេលអធិដ្ឋាន បណ្ដោយឲ្យអ្នកចូលពិធីរួមគ្នាប្រមូលអារម្មណ៍ ឬផ្ដល់ឲ្យពិធីដ៏សក្ការៈបានឧត្ដុង្គឧត្ដម។ ប៉ុន្តែ ព្រះសហគមន៍ទទួលស្គាល់សិល្បៈដ៏ពិតប្រាកដគ្រប់យ៉ាងឯទៀតៗ លុះត្រាតែសិល្បៈទាំងនោះមានគុណសម្បត្តិយ៉ាងសមរម្យ។ បើមានគុណសម្បត្តិដូច្នេះមែន ព្រះសហគមន៍ក៏បញ្ចូលសិល្បៈទាំងនោះក្នុងពិធីបុណ្យដែរ។

ហេតុនេះហើយ ដោយគោរពតាមបទបញ្ជា និងតាមសេចក្ដីណែនាំនៃការបញ្ជូនបន្តមក ព្រមទាំងដោយគោរពវិន័យព្រះសហគមន៍ ហើយដោយយល់ឃើញថា ភ្លេងដ៏សក្ការៈមានគោលដៅលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងជួយឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ មហាសន្និបាតដ៏វិសុទ្ធ សម្រេចសេចក្ដីដូចតទៅ៖

### ១១៣- ពិធីគោរពប្រណិប័តន៍យ៉ាងឱឡារិក

ពិធីគោរពប្រណិប័តន៍បានឱឡារិកឧត្ដុង្គឧត្ដម លុះត្រាតែមានបទចម្រៀង មានអភិបាល និងលោកគង្វាលធ្វើជាអធិបតី និងមានគ្រីស្តបរិស័ទចូលរួមយ៉ាងសកម្មផង។ ចំពោះភាសាដែលត្រូវប្រើនោះ ត្រូវអនុវត្តតាមបទបញ្ជាក់ចែងនៅមាត្រា ៣៦។ ចំពោះអភិបូជា ត្រូវអនុវត្តតាមបទបញ្ជាចែងនៅមាត្រា៥៤។ ចំពោះអគ្គសញ្ញានានា ត្រូវអនុវត្តតាមបទបញ្ជា នៅមាត្រា ៦៣។ ចំពោះពិធីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមពេលកំណត់ ត្រូវអនុវត្តតាមបទបញ្ជាក់ចែងនៅមាត្រា ១០១ វិញ។

### ១១៤- ត្រូវរក្សាទុកទ្រព្យដ៏មានតម្លៃរបស់ភ្លេងដ៏សក្ការៈ

ទាំងយកចិត្តទុកដាក់យ៉ាងខ្លាំងថែទាំភ្លេងនោះឲ្យចម្រើនឡើង។ ត្រូវព្យាយាមយកចិត្តទុកដាក់ ពង្រីកចំនួនក្រុម

អ្នកច្រៀង ជាពិសេសនៅវិសាលវិហារ។ ប៉ុន្តែ លោកអភិបាល និងលោកគង្វាលឯទៀតៗ ត្រូវខ្នះខ្នែងនិងប្រយ័ត្នថា ក្នុងគ្រប់ពិធីគោរពប្រណិប័តន៍ដែលមានបទចម្រៀង ត្រូវឲ្យអង្គប្រជុំរបស់គ្រីស្តបរិស័ទទាំងមូល អាចចូលរួមយ៉ាងសកម្ម តាមផ្នែករបស់ខ្លួនផ្ទាល់ ស្របតាមសេចក្តីណែនាំចែងនៅមាត្រា ២៨ និង ៣០។

## ១១៥-ការអប់រំខាងភ្លេង

ក្នុងទេវវិទ្យាល័យ នៅគេហដ្ឋានអប់រំបព្វជិតបព្វជិតា ក្នុងគេហដ្ឋានសិក្សារបស់គេនិងក្នុងវិទ្យាស្ថានឯទៀតៗ ហើយនៅក្នុងសាលារៀនកាតូលិក ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងនឹងបង្ហាត់បង្រៀនភ្លេង ហើយបង្ហាត់ឲ្យចេះប្រើប្រាស់ភ្លេងថែមទៀត។ លោកគ្រូអ្នកគ្រូដែលទទួលបន្ទុកបង្រៀនភ្លេងដ៏សក្ការៈនោះ ត្រូវទទួលការហ្វឹកហ្វឺន ដោយយកចិត្តទុកដាក់ជាមុនសិន។

មហាសន្និបាត ផ្តែផ្តាំឲ្យបង្កើតវិទ្យាស្ថានដ៏ខ្ពង់ខ្ពស់ បង្រៀនភ្លេងដ៏សក្ការៈនៅកន្លែងណា ដែលគួរបង្កើតនោះ។ ត្រូវអប់រំអ្នកនិពន្ធបទភ្លេង និងអ្នកច្រៀងជាពិសេសក្មេងៗ ឲ្យគេស្គាល់ពិធីគោរពប្រណិប័តន៍យ៉ាងត្រឹមត្រូវពិតប្រាកដ។

## ១១៦-បទភ្លេងតាមសន្តៈគ្រេហ្គ័រ និងពហុស្វរស័ព្ទ

ព្រះសហគមន៍ទទួលស្គាល់ថា បទភ្លេងតាមសន្តៈគ្រេហ្គ័រ ពិតជាភ្លេងពិសេសផ្ទាល់នៃពិធីគោរពប្រណិប័តន៍តាមក្បួនពិធីព្រះសហគមន៍ក្រុងរ៉ូម។ ហេតុនេះហើយ បានជាក្នុងពិធីគោរពប្រណិប័តន៍នានា បទភ្លេងតាមសន្តៈគ្រេហ្គ័រ មានអាទិភាពលើបទឯទៀតៗទាំងអស់ ទោះបីបទឯទៀតៗ មានតម្លៃស្មើគ្នាក្តី។

ប៉ុន្តែ ត្រូវសុខចិត្តទទួលយកបទភ្លេងដ៏សក្ការៈបែបផ្សេងៗទៀត ជាពិសេសបទពហុស្វរស័ព្ទឲ្យ ប្រើក្នុងពិធីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ លុះត្រាតែបទភ្លេងនិងបទពហុស្វរស័ព្ទទាំងនោះស៊ីចង្វាក់នឹងខ្លឹមសារនៃពិធីគោរពប្រណិប័តន៍ ស្របតាមមាត្រា ៣០។

## ១១៧-ការបោះពុម្ពសៀវភៅនៃបទភ្លេងតាមសន្តៈគ្រេហ្គ័រ

ត្រូវបង្ហើយការបោះពុម្ពសៀវភៅគំរូនៃបទភ្លេងតាមសន្តៈគ្រេហ្គ័រឲ្យបានរួចរាល់។ លើសពីនេះទៅទៀត ត្រូវកែសម្រួលសៀវភៅទាំងប៉ុន្មាន បោះពុម្ពក្រោយពីសន្តៈពីយ៉ូស ទី១០ កែទម្រង់ក្បួនពិធីគោរពប្រណិប័តន៍ រួចសូមបោះពុម្ពសាជាថ្មី។ គួរបោះពុម្ពសៀវភៅមួយផ្សេងទៀត មានបទភ្លេងដែលមានភាពងាយស្រួលជាង ឲ្យគេអាចប្រើនៅព្រះវិហារតូចៗបាន។

## ១១៨-បទភ្លេងសាសនាជាប្រជាប្រិយ

គួរលើកស្ទួយបទភ្លេងសាសនាជាប្រជាប្រិយ ក្នុងពិធីគោរពប្រណិបតិន៍តាមប្រជាប្រពៃណី និងក្នុងពិធីដ៏សក្ការៈ ហើយក្នុងពិធីគោរពប្រណិប័តន៍ថែមទៀត ស្របតាមសេចក្តីណែនាំ និងបទបញ្ញាក់។ ធ្វើដូច្នេះទើបគ្រីស្តបរិស័ទអាចបន្លឺសំឡេងឡើងបាន។

## ១១៩-ភ្លេងដ៏សក្ការៈក្នុងដែនដីដែលមនុស្សជាច្រើនមិនស្គាល់ព្រះគ្រីស្ត

តាមតំបន់ខ្លះ ជាពិសេសនៅដែនដីដែលមនុស្សជាច្រើនមិនស្គាល់ព្រះគ្រីស្ត ជួនកាលប្រជាជនធ្លាប់មានបទ តាម

ប្រពៃណីភ្លេងផ្ទាល់របស់គេ។ ភ្លេងទាំងនោះក៏មានសារៈសំខាន់ក្នុងសាសនា និងក្នុងសង្គមរបស់គេថែមទៀត។ ហេតុនេះហើយ ត្រូវយកចិត្តទុកដាក់គោរពភ្លេងរបស់គេ ទុកជាមានតម្លៃ និងយកមកប្រើនៅពេលអប់រំចិត្តគំនិតគេខាងសាសនាផង និងនៅពេលកែសម្រួលពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ផង ឲ្យបានសម្របទៅតាមទេពកោសល្យជាតិរបស់គេ ស្របតាមគោលគំនិតនៃមាត្រា ៣៩ និង ៤០។

ហេតុនេះ ពេលហ្វឹកហ្វឺនសាសនទូតអំពីភ្លេង ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងឲ្យគេមានលទ្ធភាពអាចគាំទ្រភ្លេងប្រជាប្រិយ តាមប្រពៃណីប្រជាជនទាំងនោះទាំងនៅសាលារៀន ទាំងនៅក្នុងពិធីគោរពប្រណិប័តន៍ ប្រសិនបើអាចធ្វើបាន។

## ១២០-អ័គ្គ និងគ្រឿងតូរ្យតន្ត្រី

ព្រះសហគមន៍ដែលគោរពបម្រើព្រះជាម្ចាស់ តាមរបៀបរបបឡាតាំងត្រូវគោរពយ៉ាងខ្លាំងនូវអ័គ្គដែលមានបំពង់ទុកជាគ្រឿងតូរ្យតន្ត្រីមួយដ៏ប្រសើរជាងគេតាមប្រពៃណីព្រះសហគមន៍នោះ។ សូរសំឡេងអ័គ្គនោះ អាចជួយឲ្យពិធីនានាបានរុងរឿងគួរឲ្យសរសើរ ហើយក៏អាចជួយតម្រង់ចិត្តគំនិតគ្រីស្តបរិស័ទយ៉ាងខ្លាំង ទៅកាន់ព្រះជាម្ចាស់ និងទៅកាន់ស្ថានបរមសុខ។ មានសិទ្ធិអនុញ្ញាតឲ្យប្រើគ្រឿងតូរ្យតន្ត្រីឯទៀតៗក្នុងកិច្ចគោរពបម្រើព្រះជាម្ចាស់បាន តាមតែគ្រឿងតូរ្យតន្ត្រីទាំងនោះសមរម្យនឹងពិធី ហើយសមនឹងសេចក្តីថ្លៃថ្នូរនៃព្រះវិហារ។ នៅពេលក្រោយ គ្រឿងតូរ្យតន្ត្រីទាំងនោះមុខជានឹងទៅជាគ្រឿងដ៏សក្ការៈ និងអាចជួយកសាងចិត្តគំនិតគ្រីស្តបរិស័ទបានទៀត។ គ្រឿងតូរ្យតន្ត្រី អាចប្រើបានតាមការយល់ឃើញ និងការអនុញ្ញាតរបស់លោកអភិបាល ដែលមានអំណាចក្នុងតំបន់ ស្របតាមមាត្រា ២២ ហើយ ៣៧ និង ៤០។

## ១២១-បេសកកម្មរបស់អ្នកនិពន្ធបទភ្លេង

អ្នកនិពន្ធបទភ្លេងប្រកបដោយគោលគំនិតជាគ្រីស្តបរិស័ទសុទ្ធសាធ ត្រូវយល់ឃើញថា ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យរក្សាភ្លេងដ៏សក្ការៈ និងធ្វើឲ្យទ្រព្យដ៏មានតម្លៃនៃភ្លេងដ៏សក្ការៈនោះចម្រើនឡើង។ អ្នកនិពន្ធទាំងនោះត្រូវតែងសាច់ភ្លេង ដែលមានលក្ខណៈជាភ្លេងដ៏សក្ការៈយ៉ាងពិតប្រាកដ។ ត្រូវតែងសាច់ភ្លេងក្នុងគោលបំណង មិនគ្រាន់តែឲ្យក្រុមធំៗអាចច្រៀងបានប៉ុណ្ណោះទេ តែឲ្យក្រុមតូចៗក៏អាចច្រៀងបានដែរ និងជួយអង្គប្រជុំគ្រីស្តបរិស័ទទាំងមូលឲ្យចូលរួមច្រៀងយ៉ាងសកម្ម។

អត្ថន័យបទចម្រៀង ត្រូវស្របតាមលទ្ធិកាតូលិក ហើយត្រូវចូលចិត្តជ្រើសរើសយកសេចក្តីចេញពីព្រះគម្ពីរ ឬពីប្រភពនៃពិធីគោរពប្រណិប័តន៍ឯទៀតៗផង។

# ជំពូក ៧

## សិល្បៈដ៏សក្ការៈ និងសម្ភារៈប្រើប្រាស់ក្នុងកិច្ចគោរពបម្រើព្រះជាម្ចាស់

### ១២២-កិត្តិយសដ៏ថ្លៃថ្នូរនៃសិល្បៈសក្ការៈ

ក្នុងចំណោមសកម្មភាពដ៏ល្អប្រសើរជាងគេ នៃប្រាជ្ញារបស់មនុស្សលោក ត្រូវរាប់បញ្ចូលយ៉ាងត្រឹមត្រូវ នូវវិចិត្រសិល្បៈនានា ជាពិសេសសិល្បៈខាងសាសនា។ សិល្បៈដ៏សក្ការៈក៏ជាកំពូលនៃសិល្បៈខាងសាសនាទាំងនោះ។ លក្ខណៈពិសេសនៃសិល្បៈដ៏សក្ការៈនេះ មានគោលដៅសម្ដែងនូវសោភ័ណភាពដ៏អស្ចារ្យបំផុតរបស់ព្រះជាម្ចាស់ តាមស្នាដៃរបស់សិល្បៈករសិល្បការិនី។ សិល្បៈករសិល្បការិនីដ៏សក្ការៈទាំងនោះ ប្ដូជាកម្លាំងកាយកម្លាំងចិត្ត លើកតម្កើងកោតសរសើរសិរីរុងរឿងរបស់ព្រះអង្គ ដោយគេមានគោលបំណងតែមួយ គឺជួយតម្រង់ចិត្តគំនិតរបស់មនុស្ស ទៅរកព្រះជាម្ចាស់ តាមតែគេអាចធ្វើបាន។

ហេតុនេះហើយ បានជាព្រះសហគមន៍ជាព្រះមាតាដ៏ជាទីគោរព បានរាប់អានវិចិត្រសិល្បៈជានិច្ចនិងសូមឲ្យវិចិត្រសិល្បៈករសិល្បការិនីជួយបម្រើជានិច្ច ជាពិសេសសូមឲ្យគេឆ្នៃសម្ភារៈទាំងប៉ុន្មាន ដែលប្រើប្រាស់នៅពេលគោរពបម្រើព្រះជាម្ចាស់ ឲ្យបានសមរម្យ ថ្លៃថ្នូរ និងល្អស្អាត ដើម្បីជាសញ្ញានិងជានិមិត្តរូបបង្ហាញអំពីអ្វីៗនៃលោកខាងមុខ។ ព្រះសហគមន៍ ក៏មិនដែលឈប់អប់រំហ្វឹកហ្វឺនសិល្បករសិល្បការិនី តាមបច្ចេកទេសរបស់គេ។ លើសពីនេះទៅទៀត ព្រះសហគមន៍ ក៏ចាត់ខ្លួនទុកជាអ្នកមានសិទ្ធិវិនិច្ឆ័យស្នាដៃវិចិត្រសិល្បៈ ដោយបញ្ជាក់យ៉ាងច្បាស់ថា ក្នុងចំណោមស្នាដៃនៃវិចិត្រសិល្បៈទាំងនោះ ស្នាដៃណាសមស្របតាមជំនឿ និងសមស្របតាមការគោរពប្រណិបតិន៍ព្រះជាម្ចាស់ ហើយសមស្របតាមច្បាប់វិន័យប្រពៃណីនៃសាសនា ដែលអាចប្រើក្នុងពិធីគោរពបម្រើព្រះជាម្ចាស់បាន។

ព្រះសហគមន៍ បានយកចិត្តទុកដាក់យ៉ាងពិសេស ឲ្យសម្ភារៈដ៏សក្ការៈបានសមរម្យ និងមានសោភ័ណភាព ដើម្បីជួយលើកពិធីគោរពបម្រើព្រះជាម្ចាស់បានរុងរឿងឧត្តុង្គឧត្ដម។ ប៉ុន្តែ ព្រះសហគមន៍ក៏ទទួលស្គាល់ថា ទាំងគ្រឿងប្រឌិតសម្ភារៈ ទាំងសម្ភារៈ ទាំងរបៀបសម្អាតតុបតែងផ្ទះ ចេះតែផ្លាស់ប្ដូរជានិច្ចតាមការអភិវឌ្ឍន៍នៃបច្ចេកទេស តាមសម័យនីមួយៗ។

ហេតុនេះហើយ បានជាអស់លោកអភិបាលដែលប្រជុំគ្នាក្នុងមហាសន្និបាត បានសម្រេចសេចក្ដីអំពីរឿងទាំងនោះដូចតទៅ៖

### ១២៣-អំពីរចនាបទសិល្បៈ

ព្រះសហគមន៍ មិនដែលចាត់ទុករចនាបទសិល្បៈតែមួយ ជាសិល្បៈរបស់ព្រះសហគមន៍ផ្ទាល់ទេ ផ្ទុយទៅវិញព្រះសហគមន៍ ទទួលស្គាល់របៀបផ្សេងៗនៃសិល្បៈ តាមសម័យនីមួយៗ ត្រូវតាមទេពកោសល្យ និងតាមសភាពការណ៍ប្រជាជននីមួយៗ ព្រមទាំងតាមតម្រូវការនៃរបៀបរបបពិធីគោរពប្រណិប័តន៍ផ្សេងៗទៀត។ ព្រះសហគមន៍រាប់ថា

សិល្បករ សិល្បការិនីបានបង្កើតកំណប់សិល្បៈដ៏ថ្លៃថ្នូរតាមដំណើរនៃប្រវត្តិសាស្ត្រតរៀងមកជាទ្រព្យដ៏មានតម្លៃដែលមនុស្សត្រូវរក្សាទុក ដោយយកចិត្តទុកដាក់យ៉ាងខ្លាំងជាទីបំផុត។ សូមឲ្យវិចិត្រសិល្បករសិល្បការិនីនាសម័យយើងនេះ ហើយវិចិត្រសិល្បករសិល្បការិនីប្រជាជាតិ និងប្រជាជនទាំងឡាយ មានសិទ្ធិសេរីភាពអាចប្រើសិល្បៈរបស់ខ្លួន បានក្នុងព្រះសហគមន៍ដែរ។ ក៏ប៉ុន្តែ ត្រូវជួយតុបតែងព្រះវិហារ និងជួយពិធីដ៏សក្ការៈទាំងឡាយ ដោយសេចក្តីគោរព និងមានកិត្តិយស។ ធ្វើដូច្នេះ វិចិត្រសិល្បៈប្រជាជាតិ និងប្រជាជនទាំងឡាយ នៅសម័យឥឡូវ ក៏មុខជាមានលទ្ធភាពអាចចូលរួមសំឡេងក្នុងក្រុមដ៏ប្រសើរឧត្តុង្គឧត្តម ដែលលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ រួមជាមួយសិល្បករ សិល្បការរីនីដែលបានលើកតម្កើងជំនឿកាតូលិក តាមសតវត្សនានាកន្លងមក។

### ១២៤-អស់លោកអភិបាលភូមិភាគ

ត្រូវយកចិត្តទុកដាក់គាំទ្រ និងលើកស្ទួយសិល្បៈឲ្យទៅជាសក្ការៈយ៉ាងប្រាកដប្រជា។ សូមអស់លោកយល់ដល់សោភ័ណភាពដ៏ថ្លៃថ្នូរ ជាជាងនឹកដល់សេចក្តីអធិកអធមតាមអំនួតលោកីយ៍។ ចំពោះសម្លៀកបំពាក់សម្រាប់ពិធីគោរពបម្រើព្រះជាម្ចាស់ ក៏ត្រូវគិតដូច្នេះដែរ។

អស់លោកអភិបាល ត្រូវយកចិត្តទុកដាក់យកស្នាដៃសិល្បៈខ្លះចេញពីព្រះវិហារ និងពីកន្លែងដ៏សក្ការៈឯទៀតៗ គឺស្នាដៃសិល្បៈដែលផ្ទុយនឹងជំនឿ ផ្ទុយនឹងសីលធម៌ ផ្ទុយនឹងការគោរពថ្វាយបង្គំព្រះជាម្ចាស់ស្នាដៃ សិល្បៈដែលពិតជាប្រឆាំងនឹងចិត្តគំនិតនៃសាសនា ដោយមានរូបអបាយមុខដ៏ថោកទាបដោយខ្វះទេពកោសល្យ ឬជាស្នាដៃសិល្បៈក្លែងក្លាយ ឬភូតភរកុហក។

ពេលសាងសង់ព្រះវិហារ ត្រូវយកចិត្តទុកដាក់យ៉ាងប្រាកដប្រជា ឲ្យអគារទាំងនោះស្រួលនឹងធ្វើពិធីគោរពប្រណិប័តន៍នានា និងជួយឲ្យគ្រីស្តបរិស័ទងាយស្រួលចូលរួមយ៉ាងសកម្មក្នុងពិធីទាំងនោះផង។

### ១២៥- រូបភាពដ៏សក្ការៈ

ត្រូវរក្សាទុកទំនៀមទម្លាប់ដាក់រូបភាព និងរូបដិមាក្នុងព្រះវិហារ ជូនឲ្យគ្រីស្តបរិស័ទអាចគោរពបាន។ ប៉ុន្តែ ត្រូវតាំងរូបភាពតែចំនួនតិចទេ និងត្រូវចាត់ចែងយ៉ាងសមរម្យ កុំឲ្យប្រជាជនគ្រីស្តបរិស័ទនឹកឆ្ងល់និងបណ្តាលឲ្យគេ ភ័ន្តច្រឡំគោរពរូបបដិមាតាមរបៀបមិនត្រឹមត្រូវ។

### ១២៦-អស់លោកអភិបាល

ត្រូវស្តាប់យោបល់គណៈកម្មាធិការសិល្បៈប្រចាំភូមិភាគដើម្បីជួយវិនិច្ឆ័យស្នាដៃសិល្បៈ។ ប្រសិនបើត្រូវការអស់លោកក៏ត្រូវសួរយោបល់អ្នកជំនាញការពិសេស និងសួរយោបល់គណៈកម្មាធិការផ្សេងៗដែល មានចែងទុកនៅមាត្រា ៤៤, ៤៥ និង ៤៦។ លោកអភិបាល ត្រូវយកចិត្តទុកដាក់កុំឲ្យគេលួចប្លន់ ឬបង្ខូចគ្រឿងដ៏សក្ការៈទាំងប៉ុន្មាន និងស្នាដៃសិល្បៈដែលមានតម្លៃ ពីព្រោះជាគ្រឿងតុបតែងសម្អាតព្រះដំណាក់របស់ព្រះជាម្ចាស់។

### ១២៧-ការអប់រំហ្វឹកហ្វឺនសិល្បករសិល្បការិនី

លោកអភិបាល ត្រូវយកចិត្តទុកដាក់ធ្វើឲ្យខ្លឹមសារនៃសិល្បៈដ៏សក្ការៈនិងខ្លឹមសារនៃពិធីគោរពប្រណិប័តន៍ ជ្រួតជ្រាបចិត្តគំនិតរបស់សិល្បករសិល្បការិនី។ អស់លោកអភិបាល អាចធ្វើការនេះដោយខ្លួនលោកផ្ទាល់ ឬតាមរយៈ

បូជាចារ្យ (អាចារ្យ) ដែលមានទេពកោសល្យ មានសមត្ថភាព និងស្រឡាញ់សិល្បៈ។

លើសពីនេះទៅទៀត មហាសន្និបាតផ្ដែផ្ដាំឲ្យបង្កើតសាលារៀន និងវិទ្យាស្ថានសម្រាប់ហ្វឹកហ្វឺនសិល្បករ សិល្បការិនី អំពីសិល្បៈដ៏សក្ការៈ នៅកន្លែងដែលអស់លោកយល់ឃើញថា គួរឲ្យមាន។

សិល្បករសិល្បការិនីទាំងប៉ុន្មាន ដែលមានទេពកោសល្យ ហើយដែលមានបំណងប្រាថ្នាបម្រើសិរីរុងរឿង របស់ព្រះជាម្ចាស់ក្នុងព្រះសហគមន៍ដ៏វិសុទ្ធ ត្រូវនឹកចងចាំជានិច្ចថា គេត្រូវតែយកតម្រាប់តាមព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ ដែលប្រតិស្ឋានពិភពលោក គឺគេបង្កើតស្នាដៃសម្រាប់គោរពបម្រើព្រះជាម្ចាស់តាមព្រះសហគមន៍កាតូលិក។ ស្នាដៃទាំងនោះ មានគោលដៅជួយកសាងគ្រីស្តបរិស័ទឲ្យចេះគោរពប្រណិបតិន៍ព្រះជាម្ចាស់ និងអប់រំជំនឿគេ។

## ១២៨-ត្រូវកែសម្រួលច្បាប់ស្ដីអំពីសិល្បៈដ៏សក្ការៈ

ត្រូវកែសម្រួលមាត្រា និងលក្ខន្តិកៈនៃក្បួនច្បាប់ទូទៅរបស់ព្រះសហគមន៍ នៅពេលឆាប់ៗខាងមុខនេះគឺនៅ ពេលកែសម្រួលសៀវភៅក្បួនពិធីគោរពប្រណិប័តន៍ ស្របតាមមាត្រា ២៥ គឺត្រូវកែសម្រួលច្បាប់វិន័យអំពីអ្វីៗ ដែលទាក់ទិននឹងការគោរពបម្រើព្រះជាម្ចាស់ ជាពិសេស មានវិន័យច្បាប់អំពី៖

- របៀបសាងសង់ព្រះវិហារយ៉ាងសមរម្យនិងងាយស្រួលធ្វើពិធី
- រូបភាព និងការកសាងតុសក្ការៈ
- រូបភាពនៃព្រះពន្លាដាក់នំប្រសិទ្ធិក្នុងពិធីអរព្រះគុណឲ្យបានថ្កុំថ្កើងនិងមានសុវត្ថិភាព
- កន្លែងរាងទឹកធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យងាយស្រួលនិងថ្លៃថ្នូរ
- កន្លែងដាក់រូបភាពនិងរូបបដិមាឲ្យបានសមរម្យ
- ការរចនានិងតុបតែងព្រះវិហារ។

ត្រូវកែច្បាប់វិន័យណាដែលមិនសូវសមនឹងធម្មនុញ្ញ ស្ដីអំពីការកែសម្រួលពិធីគោរពបម្រើព្រះជាម្ចាស់ជាទូទៅ ឬត្រូវលុបចោលតែម្ដង។ រីឯច្បាប់វិន័យដែលជួយកែសម្រួលនេះ ត្រូវរក្សាទុក ឬត្រូវបង្កើតច្បាប់វិន័យថ្មីបន្ថែម។

ក្នុងករណីនេះ ជាពិសេសក្នុងរឿងច្បាប់វិន័យស្ដីអំពីរូបភាព និងវត្ថុធាតុដើម ធ្វើគ្រឿងសង្ឃារិម និងធ្វើសម្លៀកបំពាក់ដ៏សក្ការៈ ក្រុមអភិបាលតាមតំបន់នីមួយៗ មានសិទ្ធិសេរីភាពកែសម្រួលស្របតាមតម្រូវការ និងតាមទំនៀមទម្លាប់តំបន់តាមសេចក្ដីណែនាំក្នុងមាត្រា ២២។

## ១២៩-ការអប់រំអស់លោកដែលទទួលអគ្គសញ្ញាតែងតាំង

ពេលអស់លោកដែលនឹងទទួលអគ្គសញ្ញាតែងតាំងនៅពេលខាងមុខ ហើយកំពុងរៀនទស្សនវិជ្ជានិងទេវវិជ្ជាក៏ត្រូវរៀនអំពីប្រវត្តិនិងអំពីការអភិវឌ្ឍន៍នៃសិល្បៈសក្ការៈដែរ។ គេក៏ត្រូវរៀនអំពីគោលការណ៍ណែនាំដ៏ត្រឹមត្រូវសម្រាប់បង្កើតស្នាដៃសិល្បៈនោះទៀតផង។ គេត្រូវចេះវាយតម្លៃនៃវិមានគួរឲ្យគោរពរបស់ព្រះសហគមន៍ និងរក្សាទុក ព្រមទាំងឲ្យមានសមត្ថភាពអាចផ្ដល់ពាក្យទូន្មានដល់សិល្បករសិល្បការិនី ដែលកំពុងបង្កើតស្នាដៃរបស់ខ្លួន។

## ១៣០-គ្រឿងឥស្សរយសរបស់អភិបាល

មានតែអស់លោក ដែលបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាល ឬអ្នកទទួលការគ្រប់គ្រងដោយឡែក ក្នុងព្រះសហគមន៍ប៉ុណ្ណោះ ដែលមានសិទ្ធិពាក់គ្រឿងឥស្សរយសជាអភិបាល។

អស់លោកអភិបាល ដែលចូលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងធម្មនុញ្ញទាំងមូលខាងលើនេះ ព្រមទាំងគោលការណ៍នីមួយៗនៃធម្មនុញ្ញគោលលទ្ធិនេះផងដែរ។ រីឯយើងវិញ គឺស្របតាមអំណាចជាគ្រីស្តទូត ដែលព្រះគ្រីស្តបានប្រគល់ឲ្យរួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណចូលរួមជាមួយផងនោះ យើងក៏យល់ព្រមសម្រេចនឹងចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈសិលា ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ១៩៦៣
ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក
(ហត្ថលេខារបស់លោកអភិបាល)

# អំណរ និង សេចក្ដីសង្ឃឹម

(អំពីមុខងារព្រះសហគមន៍ក្នុងពិភពលោក)

**GAUDIUM et SPES**

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលនៃមហាសន្និបាតដ៏វិសុទ្ធ សូមប្រកាសធម្មនុញ្ញណែនាំនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

## ធម្មនុញ្ញណែនាំអំពីព្រះសហគមន៍ក្នុងពិភពលោកនាបច្ចុប្បន្នកាល អំណរ និង សេចក្ដីសង្ឃឹម

## បុព្វកថា

### ១- ព្រះសហគមន៍រួមយ៉ាងជិតស្និទ្ធជាមួយមហាគ្រួសាររបស់មនុស្សជាតិ

អំណរសប្បាយ និងសេចក្ដីសង្ឃឹម ទុក្ខព្រួយ និងកង្វល់របស់មនុស្សលោកនាសម័យឥឡូវ ជាពិសេសរបស់ជនក្រីក្រ និងអ្នករងទុក្ខវេទនាជាដើម ក៏ជាអំណរសប្បាយជាសេចក្ដីសង្ឃឹម ជាទុក្ខព្រួយ និងជាកង្វល់របស់សាវ័កព្រះគ្រីស្ដដែរ។ អ្វីៗដែលពាក់ព័ន្ធនឹងលក្ខណៈដ៏ពិតប្រាកដរបស់មនុស្ស ក៏ពាក់ព័ន្ធនឹងសាវ័ករបស់ព្រះអង្គដែរ។

សហគមន៍របស់គ្រីស្ដបរិស័ទសាងសង់ឡើង ដោយសារមនុស្សរួមគ្នាក្នុងអង្គព្រះគ្រីស្ដ ហើយមានព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំពេលធ្វើដំណើរឆ្ពោះទៅកាន់ព្រះរាជ្យរបស់ព្រះបិតា។ គ្រីស្ដបរិស័ទទទួលសារមួយស្ដីអំពី *"ការសង្គ្រោះ"* ដែលត្រូវជម្រាបជូនដល់មនុស្សទាំងអស់។ សហគមន៍របស់គ្រីស្ដបរិស័ទទទួលស្គាល់ថា ខ្លួនរួមសាមគ្គីយ៉ាងជិតស្និទ្ធ និងយ៉ាងពិតប្រាកដ ជាមួយមនុស្សជាតិទាំងមូល និងតាមប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។

### ២- មហាសន្និបាតជម្រាបមកដល់មនុស្សទាំងអស់

ក. ក្រោយពីបានខិតខំរិះគិតអំពីគម្រោងការដ៏អស្ចារ្យ របស់ព្រះសហគមន៍យ៉ាងពិស្ដាររួចមក មហាសន្និបាតវ៉ាទីកង់ ទី២ មិនគ្រាន់តែជម្រាបមកបុត្រធីតារបស់ព្រះសហគមន៍ និងអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ដប៉ុណ្ណោះទេ តែមហាសន្និបាត ក៏មិនស្ទាក់ស្ទើរក្នុងការជម្រាបមកមនុស្សទាំងអស់ដែរ។ មហាសន្និបាតមានបំណងរៀបរាប់ យោបល់របស់ខ្លួនអំពីវត្តមាន និងសកម្មភាពរបស់ព្រះសហគមន៍ ក្នុងពិភពលោកនាបច្ចុប្បន្នកាល។

ខ. មហាសន្និបាតនឹកគិតដល់មនុស្សទាំងអស់ ពោលគឺដល់មហាគ្រួសាររបស់មនុស្សជាតិទាំងមូល និងដល់ពិភពលោកជាទីលំនៅរបស់គេ។ ពិភពលោកនេះ ប្រៀបដូចជារោងល្ខោនមួយ ដែលមនុស្សជាតិទាំងមូលសម្ដែងប្រវត្តិសាស្ត្រ និងជាកន្លែងដែលមានស្លាកស្នាមរបស់មនុស្ស គឺស្នាមនៃការខិតខំឆ្នៃប្រឌិត មានទាំងបរាជ័យ និងជ័យជម្នះ។ គ្រីស្តបរិស័ទជឿថា ព្រះអាទិករបានប្រតិស្ឋាន និងនៅតែថែរក្សាពិភពលោកនេះដោយព្រះហឫទ័យអាណិតមេត្តា។ គេក៏ជឿថា ពិភពលោកក៏ធ្លាក់ក្រោមអំណាចនៃអំពើបាបដែរ ក៏ប៉ុន្តែព្រះគ្រីស្តបានកម្ទេចអំណាចរបស់មារកំណាចរួចហើយ ដោយព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាង និងមានព្រះជន្មថ្មីដ៏រុងរឿង។ ព្រះអង្គក៏បានរំដោះពិភពលោក ដើម្បីឲ្យប្រែទ្រង់ទ្រាយតាមព្រះជាម្ចាស់គ្រោងទុក និងដើម្បីឲ្យបានពេញលក្ខណៈផង។

## ៣- ព្រះសហគមន៍បម្រើមនុស្ស

ក. សព្វថ្ងៃ មនុស្សជាតិរំភើបចិត្តស្ងើចសរសើរអំពីអ្វីៗ ដែលខ្លួនបានរកឃើញនិងបង្កើតឡើង ព្រមទាំងស្ងើចសរសើរអំពីអំណាចរបស់ខ្លួនទៀតផង។ ក៏ប៉ុន្តែ មនុស្សលោកចេះ តែតប់ប្រមល់នឹងការវិវឌ្ឍន៍នៃពិភពលោកនាសម័យឥឡូវ ហើយចេះតែចោទសួរខ្លួនឯងជាញឹកញាប់ អំពីឋានៈនិងតួនាទីរបស់មនុស្សក្នុងពិភពលោក អំពីអត្ថន័យនៃការខិតខំប្រឹងប្រែងរបស់មនុស្សម្នាក់ៗ និងការប្រឹងប្រែងរួម។ លើសពីនេះទៅទៀត គេតែងតែចោទសួរខ្លួនឯង អំពីទីដៅចុងក្រោយបំផុតនៃអ្វីទាំងអស់ក្នុងលោកនេះ និងទីដៅចុងក្រោយបំផុតនៃមនុស្សជាតិផងដែរ។

ហេតុនេះហើយ បានជាមហាសន្និបាត ក្នុងឋានៈជាសាក្សីអំពីជំនឿនៃគ្រីស្តសាសនា និងជាអ្នកណែនាំជំនឿនៃប្រជារាស្ត្រទាំងមូលរបស់ព្រះជាម្ចាស់ ដែលព្រះគ្រីស្តបានប្រមែប្រមូលហើយនោះ សូមនិយាយសន្ទនាអំពីបញ្ហាទាំងនេះជាមួយមហាគ្រួសាររបស់មនុស្សជាតិទាំងមូល។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាផ្នែកមួយក្នុងមហាគ្រួសារនោះ។ ដោយព្រះវិញ្ញាណដ៏វិសុទ្ធណែនាំ មហាសន្និបាតសូមជួយផ្ដល់យោបល់តាមពន្លឺនៃដំណឹងល្អ និងសូមចែកឫទ្ធានុភាព ដែលអាចសង្គ្រោះមនុស្សលោកបាន ហើយដែលព្រះសហគមន៍បានទទួលពីព្រះគ្រីស្តមក។ ព្រះគ្រីស្តបានបង្កើតព្រះសហគមន៍នោះ។ ធ្វើដូច្នេះ មហាសន្និបាតផ្ដល់ភស្តុតាងយ៉ាងជាក់ច្បាស់ថា ខ្លួនរួមសាមគ្គីជាមួយមហាគ្រួសាររបស់មនុស្សជាតិទាំងមូល ដោយគោរព និងដោយសេចក្ដីស្រឡាញ់។ យើងទាំងអស់គ្នាត្រូវតែសង្គ្រោះមនុស្សនិងប្រែសង្គមមនុស្សឲ្យបានជាថ្មីផង គឺត្រូវសង្គ្រោះមនុស្សទាំងស្រុង ទាំងរូបកាយ ទាំងវិញ្ញាណ ទាំងចិត្តគំនិត ទាំងមនសិការ ទាំងការរិះគិត និងការសម្រេចចិត្ត។ គោលគំនិតនេះហើយ ដែលនឹងទៅជាគោលចម្បងនៃការរៀបរាប់ខាងក្រោមនេះ។

ខ. ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធសូមប្រកាសថា ព្រះជាម្ចាស់ត្រាស់ហៅមនុស្សឲ្យមានជីវិតដ៏ថ្លៃថ្នូរបំផុតនិងបញ្ជាក់ថា ព្រះអង្គដាក់ព្រះជន្មរបស់ព្រះអង្គផ្ទាល់ ដូចជាគ្រាប់ពូជនៅក្នុងខ្លួនមនុស្ស។ មហាសន្និបាតសូមឲ្យព្រះសហគមន៍រួមសហការយ៉ាងស្មោះជាមួយមនុស្សលោក ដើម្បីនាំមនុស្សទាំងអស់ឲ្យរួបរួមគ្នាជាបងប្អូន ស្របតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់។ ព្រះសហគមន៍គ្មានបំណងលោភលន់តាមលោកីយ៍ទេ តែមានទិសដៅតែមួយ គឺបន្តព្រះរាជកិច្ចរបស់ព្រះគ្រីស្ត ដោយមានព្រះវិញ្ញាណ ដែលជួយការពារ និងជំរុញផង។ ព្រះគ្រីស្តយាងមកក្នុងលោកដើម្បីផ្ដល់សក្ខីភាពអំពីសេចក្ដីពិត និងដើម្បីសង្គ្រោះមនុស្សលោក មិនមែនយាងមកដាក់ទោសទេ។ ព្រះអង្គយាងមកបម្រើគេ មិនមែនដើម្បីឲ្យគេបម្រើព្រះអង្គឡើយ (យហ ៣, ១៧; ១៨, ៣៧; មថ ២០, ២៨; មក ១០, ៤៥)។

# សភាពការណ៍មនុស្ស ក្នុងពិភពលោកនាបច្ចុប្បន្នកាល

## ៤. សេចក្តីសង្ឃឹមនិងការតប់ប្រមល់របស់មនុស្ស

ក. ព្រះសហគមន៍មានភារកិច្ចពិនិត្យមើល សញ្ញាសម្គាល់នៃពេលវេលាជានិច្ច និងបកស្រាយអត្ថន័យនៃសញ្ញាសម្គាល់ទាំងនោះ តាមពន្លឺនៃដំណឹងល្អរបស់ព្រះគ្រីស្ត ដើម្បីអាចបំពេញមុខងារនេះបាន។ ធ្វើដូច្នេះ ព្រះសហគមន៍អាចតបឆ្លើយនឹងសំណួរដែល មនុស្សចេះតែចោទជានិច្ចជាកាល ឲ្យបានស្របនឹងជំនាន់នីមួយៗ គឺថា តើជីវិតមនុស្សនាបច្ចុប្បន្នកាលនិងជីវិតនៅលោកខាងមុខមានអត្ថន័យយ៉ាងណា? តើជីវិតទាំងពីរបែបនេះ មានទំនាក់ទំនងយ៉ាងដូចម្តេច? ព្រះសហគមន៍ត្រូវតែស្គាល់ និងយល់ពិភពលោកនេះជាពិភពដែលយើងរស់នៅ ត្រូវស្គាល់និងយល់អំពីសេចក្តីដែលមនុស្សលោកកំពុងរង់ចាំ សេចក្តីប៉ងប្រាថ្នារបស់គេ និងសភាពការណ៍នាបច្ចុប្បន្ន ដែលអាចនាំឲ្យពិភពលោកវិនាសអន្តរាយបាន។ នេះជាលក្ខណៈដ៏សំខាន់ៗខ្លះនៃពិភពលោកនាបច្ចុប្បន្នកាល តាមយើងអាចយល់ឃើញបាន។

ខ. សព្វថ្ងៃ មានយុគសម័យថ្មីកើតឡើងក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ គឺមានការផ្លាស់ប្តូរយ៉ាងជ្រៅ និងយ៉ាងលឿនបំផុតសាយបន្តិចម្តងៗក្នុងពិភពទាំងមូល។ ការផ្លាស់ប្តូរទាំងនេះ កើតមកពីប្រាជ្ញា និងពីសកម្មភាពរបស់មនុស្ស ដែលចេះតែបង្កើតអ្វីៗផ្សេងៗ។ ការផ្លាស់ប្តូរទាំងនោះ ក៏មានឥទ្ធិពលលើមនុស្សផ្ទាល់ លើការរិះគិតពិចារណា លើសេចក្តីប៉ងប្រាថ្នា របស់គេទាំងលើបុគ្គលម្នាក់ៗ ទាំងលើសង្គមទាំងមូល។ ការផ្លាស់ប្តូរទាំងនោះ មានឥទ្ធិពលលើរបៀបរិះគិតនិងលើរបៀបប្រព្រឹត្តចំពោះអ្វីៗទាំងអស់ និងចំពោះមនុស្សដូចគ្នា។ យើងពិតជាអាចនិយាយថា សង្គមនិងវប្បធម៌កំពុងតែប្រែប្រួលប្រាកដមែន។ ការប្រែប្រួលនេះមានឥទ្ធិពលរហូតដល់របៀបអនុវត្តតាមសាសនាទៀតផង។

គ. ការផ្លាស់ប្រែនៃពិភពលោកបែបនេះ ប្រៀបដូចជាវិបត្តិនានានៅពេលខ្លួនចម្រើនធំធាត់ដែរ គឺបណ្តាលឲ្យកើតការពិបាកដ៏ធ្ងន់ធ្ងរជាច្រើន។ មនុស្សចេះតែលាតសន្ធឹងអំណាចរបស់ខ្លួនឲ្យកាន់តែឆ្ងាយទៅៗ ក៏ប៉ុន្តែខ្លួនមិនទាន់មានសមត្ថភាព ធ្វើជាម្ចាស់នៃអំណាចនេះគ្រប់ពេលវេលានៅឡើយទេ។ ទោះបីមនុស្សចេះស្ទង់ថាមពលកប់យ៉ាងជ្រៅបំផុតក្នុងចិត្តគេក្តី ក៏មនុស្សជាច្រើននៅតែមានចិត្តសង្ស័យលើខ្លួនឯង។ បន្តិចម្តងៗ មនុស្សទទួលស្គាល់បទដ្ឋាននៃការរស់នៅក្នុងសង្គមឲ្យកាន់តែច្បាស់ឡើងៗ ក៏ប៉ុន្តែ គេនៅតែស្ទាក់ស្ទើរអំពីទិសដៅ ដែលត្រូវកំណត់ដាក់ឲ្យសង្គមនោះ។

ឃ.មនុស្សលោកនាបច្ចុប្បន្នមានធនធានហូរហៀរ មានសមត្ថភាព និងមានកម្លាំងសេដ្ឋកិច្ច ដែលតាមប្រវត្តិសាស្ត្រកាលពីដើមរៀងមកមិនដែលមានទេ ក៏ប៉ុន្តែ មានមនុស្សមួយចំនួនធំនៅតែខ្វះស្បៀងអាហាររស់នៅជាជនកម្សត់ទុរគត និងមានមនុស្សជាច្រើនរាប់មិនអស់មិនចេះអក្សរ។ មនុស្សនាបច្ចុប្បន្នកាលមានបំណងប្រាថ្នាចង់បានសេរីភាព ដែលមិនដែលមានដូចកាលពីពេលមុន ក៏ប៉ុន្តែ នៅពេលជាមួយគ្នានេះក៏កើតមានរបៀបរស់នៅបែបថ្មី គឺបណ្តាលឲ្យមនុស្សទៅជាទាសករខាងសង្គមនិងខាងចិត្តគំនិតទៅវិញ។ មនុស្សលោកភ្ញាក់ស្មារតីយ៉ាងខ្លាំងថា គេត្រូវរួមគ្នាជាផ្លូងតែមួយត្រូវការពឹងពាក់គ្នាទៅវិញទៅមក និងត្រូវ

ការសាមគ្គីជាចាំបាច់។ ប៉ុន្តែនៅពេលដដែលនេះ មនុស្សលោកនៅតែមានការប្រទាញប្រទង់គ្នា ប្រឆាំងជំទាស់ដណ្ដើមអំណាច ដោយមានថាមពលផ្សេងៗ ហើយគេក៏នៅតែមានការបាក់បែកយ៉ាងខ្លាំងខាងនយោបាយ ខាងសង្គម ខាងសេដ្ឋកិច្ច ខាងជាតិសាសន៍ និងខាងមនោគមវិជ្ជានៅឡើយ។ គេខ្លាចកើតសង្គ្រាម ដែលអាចបំផ្លាញពិភពលោកទាំងមូលឲ្យវិនាសថែមទៀតផង។ មនុស្សផ្លាស់ប្ដូរយោបល់គ្នាទៅវិញទៅមកកាន់តែច្រើនឡើងៗ ក៏ប៉ុន្តែ ពាក្យសម្រាប់បញ្ចេញគំនិតយោបល់ដ៏សំខាន់ៗ មានអត្ថន័យប្លែកៗពីគ្នាតាមមនោគមវិជ្ជាប្លែកពីគ្នាដែរ។ មិនតែប៉ុណ្ណោះ មនុស្សយកចិត្តទុកដាក់ខិតខំចាត់ចែងរចនាសម្ពន្ធឲ្យកាន់តែប្រសើរឡើងៗ ក៏ប៉ុន្តែ ការខិតខំចាត់ចែងរចនាសម្ពន្ធនេះ គ្មានការចម្រើនខាងផ្លូវវិញ្ញាណទេ។

ង. ដូច្នេះ មនុស្សជាច្រើននៅសម័យឥឡូវ ភ្ញាក់ផ្អើលដោយសារសភាពការណ៍ដ៏ស្មុគស្មាញនេះ គេពិបាកពិចារណាថា អ្វីៗជាតម្លៃថ្លៃថ្នូរដ៏អចិន្ត្រៃយ៍ អាចទៅជាគោលណែនាំជីវិតមនុស្សលោក។ ទន្ទឹមនឹងនេះ គេមិនដឹងធ្វើយ៉ាងណា ដើម្បីឲ្យតម្លៃដ៏ថ្លៃថ្នូរទាំងនេះបានសមស្របនឹងអ្វីៗ ដែលគេនិងបង្កើតថ្មីៗទេ។ គេព្រួយបារម្ភទាំងមានចិត្តសង្ឃឹម ទាំងតប់ប្រមល់មិនដឹងថា ត្រូវយល់យ៉ាងណាអំពីការវិវឌ្ឍន៍នៃពិភពលោកសព្វថ្ងៃ។ ការវិវឌ្ឍន៍នៃពិភពលោកសព្វថ្ងៃ ដូចជាប្រកួតប្រជែងជាមួយតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស ឬបើនិយាយតាមរបៀបផ្សេងទៀត ការវិវឌ្ឍន៍នោះ គឺបង្ខំមនុស្សឲ្យរកចម្លើយដោះស្រាយបញ្ហានៃការវិវឌ្ឍន៍វិញ។

## ៥- ការផ្លាស់ប្ដូរយ៉ាងខ្លាំង

ក. សព្វថ្ងៃ មនុស្សមានចិត្តគំនិតរំជើបរំជួលនឹងសភាពការណ៍ជីវភាព ភ្ជាប់នឹងការផ្លាស់ប្ដូរជាទូទៅក្នុងសង្គមដែរ។ តាមការផ្លាស់ប្ដូររួមនេះ វិទ្យាសាស្ត្រ គណិតវិទ្យា ជីវវិទ្យា និងមនុស្សសាស្ត្រ មានប្រៀបលើវិជ្ជាឯទៀតៗទាំងអស់ ក្នុងការអប់រំចិត្តគំនិតយុវជន។ បច្ចេកទេសដែលកើតចេញពីវិជ្ជាទាំងប៉ុន្មាននោះ ក៏មានប្រៀបលើការរស់នៅដែរ។ ចិត្តគំនិតអប់រំតាមវិទ្យាសាស្ត្របែបនេះ បានធ្វើឲ្យវប្បធម៌និងរបៀបរិះគិតប្លែកពីវប្បធម៌ និងរបៀបរិះគិតកាលពីមុន។ ការអភិវឌ្ឍន៍នៃបច្ចេកទេសបានប្រែទ្រង់ទ្រាយនៃផែនដីរួចទៅហើយ រហូតដល់មនុស្សចង់ទៅដណ្ដើមយកអាកាសវេហាស៍ទៀតផង ហើយគេក៏ទៅដល់ស្ថានព្រះច័ន្ទរួចហើយដែរ។

ខ. មនុស្សហាក់ដូចជា លាតអំណាចនៃប្រាជ្ញារបស់ខ្លួន រហូតដល់ធ្វើជាម្ចាស់លើពេលវេលាគឺមនុស្សបច្ចុប្បន្នមានចំណេះស្គាល់ព្រឹត្តការណ៍ ដែលកើតពីអតីតកាលដោយសារប្រវត្តិសាស្ត្រគេក៏មានគម្រោងការ និងសេចក្ដីព្រាងសម្រាប់ពេលអនាគតដែរ។ ការអភិវឌ្ឍន៍ជីវវិទ្យា ចិត្តវិទ្យា និងសង្គមវិទ្យា មិនគ្រាន់តែផ្ដល់ឱកាសឲ្យមនុស្សស្គាល់ខ្លួន កាន់តែច្បាស់ឡើងៗប៉ុណ្ណោះទេ តែផ្ដល់មធ្យោបាយឲ្យមនុស្សអាចមានឥទ្ធិពលទៅលើជីវិតរបស់មនុស្សក្នុងសង្គមនានាថែមទៀត ដោយយកបច្ចេកទេស ស្របតាមសង្គមនោះមកប្រើ។ នៅពេលជាមួយគ្នានេះ មនុស្សជាតិខិតខំគ្រោងទុកអំពីចំនួនមនុស្សក្នុងប្រទេសនីមួយៗ ព្រមទាំងត្រួតត្រាចំនួនទាំងនោះផងដែរ។

គ. ចលនានៃប្រវត្តិសាស្ត្រកាន់តែលឿនទៅៗ បណ្ដាលឲ្យម្នាក់ៗពិបាកនឹងតាមទាន់។ វាសនាសហគមន៍មនុស្សទាំងមូលត្រឡប់ទៅជាវាសនារួមតែមួយ មិនបែកពីគ្នាដូចសម័យមុនៗ ពោលគឺ មិនដូចកាលដែលប្រទេសនីមួយៗមានប្រវត្តិសាស្ត្រដាច់ៗពីគ្នា។ សរុបសេចក្ដីមក ពិភពលោកឆ្លងពីសភាពការណ៍នឹងន ទៅជាសភាពការណ៍ដែលមានចលនានិងវិវឌ្ឍន៍ឡើង។ ហេតុនេះហើយ បានជាកើតរបៀបរិះគិតថ្មី

អំពីបញ្ហាដ៏ធំទូលំទូលាយបណ្ដោយឲ្យអ្នកប្រាជ្ញត្រូវធ្វើវិភាគនិងសំយោគថ្មី។

## ៦- ការប្រែប្រួលខាងសង្គម

ក. ដោយសភាពការណ៍មនុស្សលោកប្រែប្រួលដូច្នេះ សហគមន៍នានាដែលកាន់តាមប្រពៃណីពីបុរាណ គឺបក្ខសម្ពន្ធ កុលសម្ពន្ធដែលមានចាស់ព្រឹទ្ធាចារ្យត្រួតត្រា សហគមន៍ភូមិ និងក្រុមឯទៀតៗ ព្រមទាំងទំនាក់ទំនងក្នុងសង្គម ក៏ប្រែប្រួលកាន់តែខ្លាំង ពីមួយថ្ងៃទៅមួយថ្ងៃដែរ។

ខ. សង្គមបែបឧស្សាហកម្ម ក៏លាតសន្ធឹងក្នុងពិភពលោកបន្តិចម្ដងៗ បណ្ដាលឲ្យប្រទេសខ្លះមានសេដ្ឋកិច្ចជឿនលឿនមានធនធានច្រើនហូរហៀរ ប្រែទស្សនៈនិងរបៀបរស់នៅក្នុងសង្គមទាំងស្រុង ឲ្យបានប្លែកពីទស្សនៈ និងរបៀបរស់នៅដែលគេមានតាំងពីយូរសតវត្សមក។ តាមរបៀបដដែលនេះ វប្បធម៌នៃការរស់នៅក្នុងទីក្រុង កាន់តែមានឥទ្ធិពលទាក់ទាញចិត្តអ្នកស្រែចម្ការ គឺបណ្ដាលឲ្យកើតមានទីក្រុងថ្មីៗជាច្រើនដែលមានមនុស្សកាន់តែច្រើនរស់នៅ ព្រមទាំងបណ្ដាលឲ្យរបៀបរស់នៅបែបអ្នកក្រុង ភាយចូលទៅក្នុងស្រុកស្រែចម្ការទៀតផង។

គ. មានមធ្យោបាយទូរគមនាគមន៍ថ្មីៗក្នុងសង្គមកាន់តែល្អប្រសើរឡើង ជួយឲ្យប្រជាជននៅគ្រប់កន្លែងដឹងយ៉ាងឆាប់រហ័សបំផុត នូវព្រឹត្តិការណ៍ដែលកើតឡើងក្នុងពិភពលោកទាំងមូល។ មធ្យោបាយទាំងនោះ ក៏ជួយផ្សព្វផ្សាយគំនិត និងមនោសញ្ចេតនាផ្សេងៗ បណ្ដាលឲ្យកើតប្រតិកម្មតៗគ្នាជាច្រើន។

ឃ.ត្រូវចាប់អារម្មណ៍ទៀតថា ដោយមូលហេតុផ្សេងៗ មានមនុស្សជាច្រើនត្រូវចាកចេញពីភូមិស្រុករបស់ខ្លួនទៅរស់នៅ ជាអន្តោប្រវេសន៍ក្នុងប្រទេសផ្សេងទៀត ហើយក៏ផ្លាស់ប្ដូររបៀបរស់នៅដែរ។

ង. និយាយរួមទៅ មនុស្សមានទំនាក់ទំនងជាមួយនឹងមនុស្សដូចគ្នា កាន់តែច្រើនឡើងៗ រីឯចលនានាំឲ្យមនុស្សរស់នៅជាមួយគ្នាកាន់តែច្រើនឡើង (ហៅថា *"សង្គមនីយកម្ម"*) បង្កើតចំណងទំនាក់ទំនងថ្មីៗជាច្រើន ប៉ុន្តែ ជួនកាលមិនជួយអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ ឲ្យបានពេញលេញឡើយ គឺមិនជួយបង្កើតទំនាក់ទំនង ដែលពិតជាទំនាក់ទំនងរវាងនុស្សនិងមនុស្ស ពោលគឺឲ្យមាន *"បុគ្គលិកូបនីយកម្ម"* (កិច្ចនាំឲ្យមនុស្សម្នាក់ៗ ទៅជាបុគ្គលដ៏ពេញលក្ខណៈដោយមានទំនាក់ទំនងជាមួយអ្នកដទៃ)។

ច. តាមពិត ការវិវឌ្ឍន៍សង្គមបែបនេះ កើតឡើងជាពិសេសក្នុងប្រជាជាតិដែលបានទទួលផលពីការជឿនលឿនខាងសេដ្ឋកិច្ចនិងខាងបច្ចេកទេសរួចហើយ។ ប៉ុន្តែ ការការវិវឌ្ឍន៍សង្គមបែបនេះក៏ចាប់ផ្ដើមកើតឡើងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែរ គឺប្រជាជនប្រទេសទាំងនោះចង់ទទួលចំណែកផល នៃឧស្សាហូបនីយកម្ម (ការផ្លាស់កសិកម្មទៅជា ឧស្សាហកម្ម) និងនៃនគរូបនីយកម្ម (អ្នកជនបទផ្លាស់ទីមករស់នៅទីក្រុង)។ ប៉ុន្តែ ប្រជាជនទាំងនោះ ជាពិសេសទោះជាប្រជាជន ដែលផ្ចង់ចិត្តនឹងប្រពៃណីបូរាណជាងគេ ក៏មានបំណងចង់ប្រើសេរីភាពរបស់គេ តាមបែបមនុស្សពេញវ័យ និងតាមរបៀបជាបុគ្គលផ្ទាល់ខ្លួន។

## ៧- ការផ្លាស់ប្ដូរខាងចិត្តសាស្ត្រ ខាងសីលធម៌ និងខាងសាសនា

ក. ការផ្លាស់ប្ដូរចិត្តគំនិតនិងការផ្លាស់ប្ដូររចនាសម្ព័ន្ធក្នុងសង្គម បណ្ដាលឲ្យមនុស្ស ជាពិសេសយុវជន រិះគន់ និងមានចិត្តសង្ស័យអំពីតម្លៃនៃប្រពៃណី ដែលគេបានទទួលពីដូនតាមក ហើយមិនសុខចិត្តរស់នៅតាម

សភាពការណ៍ពីមុនទៀតឡើយ។ លើសពីនេះទៅទៀត ដោយគេព្រួយបារម្ភ គេនាំគ្នាបះបោរប្រឆាំងនឹងសង្គម។ នៅពេលជាមួយគ្នានេះ គេយល់ច្បាស់អំពីសារៈសំខាន់របស់ខ្លួនក្នុងសង្គម ហើយចង់ធ្វើម្ចាស់ការលើសង្គមនោះ ដោយមិនបង្អង់ឡើយ។ ហេតុនេះហើយបានជាទាំងឪពុកម្ដាយ ទាំងអ្នកអប់រំ តែងតែជួបប្រទះការពិបាកកាន់តែខ្លាំងឡើងៗ ក្នុងការបំពេញមុខងារអប់រំគេ។

ខ. ជួនកាល ក្របខ័ណ្ឌនៃការរស់នៅច្បាប់ របៀបរិះគិតពិចារណា និងរបៀបយល់ឃើញ ដែលហូរមកពីអតីតកាល ដូចជាមិនសូវស្រុបនឹងសភាពការណ៍នាបច្ចុប្បន្នកាល។ ហេតុនេះមនុស្សជ្រួលច្របល់ក្នុងចិត្ត មិនដឹងថា ខ្លួនត្រូវមានកិរិយាមារយាទយ៉ាងណានោះទេ សូម្បីតែអំពីសីលធម៌និងវិន័យណែនាំ។

គ. របៀបរស់នៅបែបថ្មីៗទាំងនោះ ក៏មានឥទ្ធិពលលើរបៀបអនុវត្តតាមសាសនាដែរ។ ម្យ៉ាង ដោយមនុស្សជាប់ក្នុងការរិះគិតពិចារណាកាន់តែជ្រៅទៅៗ គេលែងគិតគូរអំពីពិភពលោកតាមរបៀបមន្តអាគម និងតាមអប្បិយជំនឿទៀតដែរ តែគេត្រូវភ្ជាប់ចិត្តនឹងលទ្ធិនៃជំនឿដោយខ្លួនឯងផ្ទាល់យ៉ាងសកម្ម។ ដូច្នេះ មានមនុស្សកាន់តែច្រើន មានទំនាក់ទំនងផ្ទាល់ជាមួយព្រះជាម្ចាស់ ទុកជាព្រះដែលមានព្រះជន្មគង់នៅ។ ម្យ៉ាងទៀត មានមនុស្សកាន់តែច្រើនឡើងៗលែងចូលរួមពិធីគោរពណប្រតិបត្តិ៍តាមសាសនា។ កាលពីមុនមានតែមនុស្សមួយចំនួនតូច ដែលបដិសេធមិនព្រមទទួលព្រះជាម្ចាស់បោះបង់ចោលសាសនា ឬមិនរវីរវល់នឹងសាសនា។ ប៉ុន្តែអ្នកទាំងនោះត្រូវចោទថា ប្លែកពីគេ។ ផ្ទុយទៅវិញសព្វថ្ងៃ មនុស្សទូទៅចូលចិត្តនិយាយថា អ្នកប្រព្រឹត្តដូច្នេះ ពិតជាប្រព្រឹត្តស្របតាមការអភិវឌ្ឍន៍នៃវិទ្យាសាស្ត្រ ឬតាមលទ្ធិមនុស្សនិយមរបៀបថ្មី។ កាលពីមុនមានតែទស្សនវិទូប៉ុណ្ណោះទេ ដែលមិនរវីរវល់នឹងសាសនា។ តែសព្វថ្ងៃ ក្នុងតំបន់ជាច្រើន អ្នកនិពន្ធអក្សរសាស្ត្រ អ្នកសិល្បៈ អ្នកបកស្រាយតាមមនុស្សសាស្ត្រ និងអ្នកបកស្រាយប្រវត្តិសាស្ត្រ សូម្បីតែអ្នកកាន់ច្បាប់រដ្ឋ ក៏មិនអើពើហើយបដិសេធព្រះជាម្ចាស់ដែរ។ ហេតុនេះហើយបានជាមនុស្សជាច្រើនវិលវល់ក្នុងចិត្តនិងជ្រួលច្របល់ជាខ្លាំង។

## ៨-ការបង្ខូចតុល្យភាព និងសតិមនុស្សក្នុងពិភពលោកទំនើប

ក. ការវិវឌ្ឍន៍យ៉ាងលឿនបែបនេះ ជួនកាលកើតឡើងដោយគ្មានរបៀបរៀបរយ ជាពិសេសការភ្ញាក់ស្មារតីកាន់តែច្បាស់ថា មនុស្សលោកបែកខ្ញែកគ្នា បណ្ដាលឲ្យកើតទំនាស់ និងបង្ខូចតុល្យភាពក្នុងសង្គមព្រមទាំងបង្ខូចសតិមនុស្ស កាន់តែធ្ងន់ទៅៗ។

ខ. ចំពោះបុគ្គលម្នាក់ៗ ជួនកាល ខូចសតិដោយសារប្រាជ្ញាខាងបច្ចេកទេសទំនើបរបស់ខ្លួន មិនស៊ីចង្វាក់ និងទស្សនៈអរូបីអំពីជំនឿ ដែលគេបានទទួលពីមុនមក ហើយគេគ្មានសមត្ថភាពធ្វើសំយោគនូវចំណេះដឹងទាំងប៉ុន្មានរបស់ខ្លួនឲ្យបានសមរម្យ។ គេក៏ខូចសតិ ដោយមតិទំនើបៗដែលខ្វល់ខ្វាយចង់តែធ្វើការឲ្យសម្រេចបានជាលទ្ធផល តែមិនរវីរវល់នឹងមនសិការ ដែលបញ្ជាឲ្យប្រព្រឹត្តតាមសីលធម៌។ សភាពការណ៍ក្នុងការរស់នៅរួម មិនស៊ីចង្វាក់នឹងការរិះគិតដោយម្នាក់ឯង នេះក៏បណ្ដាលឲ្យខូចសតិដែរ។ មនុស្សធ្វើការតែមួយមុខតាមឯកទេសរបស់ខ្លួន តែគ្មានទស្សនៈរួមទូទៅ នេះក៏បណ្ដាលឲ្យខូចសតិដែរ។

គ. ក្នុងរង្វង់គ្រួសារមានទាស់ទែងគ្នា មិនចុះសម្រុងគ្នា បណ្ដាលមកពីមានមនុស្សច្រើនពេក ពីសភាពការណ៍សេដ្ឋកិច្ច ពីសភាពការណ៍ក្នុងសង្គម ពីទំនាស់តណៈនិងតណៈ ឬមកពីទំនាក់ទំនងថ្មីក្នុងសង្គមរវាងបុរស

និងស្ត្រី។

ឃ.ដោយជាតិសាសន៍បែកខ្ញែកទាស់ទែងគ្នា វណ្ណៈឋានៈ ប្រទេសមានធនធានស្តុកស្តម្ភនិងប្រទេសមានធនធានតិចជាង ទាស់ទែងគ្នា បណ្តាលឲ្យខូចដល់តុល្យភាពក្នុងសង្គមនិងក្នុងពិភពលោក។ ស្ថាប័នអន្តរជាតិកើតឡើងដោយប្រជាជាតិនានា ក្នុងគោលបំណងចង់ស្វែងរកសន្តិភាព ប៉ុន្តែដោយមានការឃោសនាមនោគមវិជ្ជាផ្សេងៗ មានប្រជាជាតិនិងក្រុមឯទៀតៗ ដែលគិតតែពីប្រយោជន៍របស់ខ្លួន គឺបណ្តាលឲ្យទាស់ទែងគ្នា។

ង. ដោយមនុស្សមិនទុកចិត្តគ្នានិងស្អប់គ្នាទៅវិញទៅមក បណ្តាលឲ្យកើតជម្លោះ និងមហន្តរាយ គឺមនុស្សផ្ទាល់ជាមូល ហេតុនៃការបង្កើតជម្លោះ និងមហន្តរាយទាំងនោះ ហើយក៏ជាអ្នករងគ្រោះដែរ។

## ៩- មនុស្សជាតិមានសេចក្តីប៉ងប្រាថ្នាកាន់តែសកល

ក. ក្នុងពេលជាមួយគ្នានេះ មានមនុស្សកាន់តែច្រើនយល់ឃើញថា មនុស្សជាតិអាច (និងត្រូវ) ពង្រឹងម្ចាស់ការលើបរិស្ថាននិងលើសត្វលោកទាំងឡាយ។ មនុស្សក៏អាច (ហើយត្រូវ) ចាត់ចែងរបៀបរៀបរយក្នុងកិច្ចការនយោបាយក្នុងសង្គម និងក្នុងសេដ្ឋកិច្ច ឲ្យមានសណ្តាប់ធ្នាប់ដែរ ក្នុងបុព្វហេតុបម្រើមនុស្សកាន់តែខ្លាំងឡើងៗ និងផ្តល់ឲ្យមនុស្សម្នាក់ៗ និងឲ្យក្រុមនីមួយៗ អាចប្រកាសបញ្ជាក់និងពង្រឹងតម្លៃដ៏ថ្លៃថ្នូររបស់ខ្លួន។

ខ. ដោយមូលហេតុនេះ មនុស្សជាច្រើនភ្ញាក់ស្មារតីកាន់តែច្បាស់ថា មានអយុត្តិធម៌ក្នុងពិភពលោក គ្មានចែកធនធានរួមឲ្យបានស្មើ ហើយយល់ឃើញថាគេរងអយុត្តិធម៌ នាំគ្នាតវ៉ាទាមទារតម្លៃដ៏ថ្លៃថ្នូររបស់ខ្លួនយ៉ាងឃោរឃៅ។ ប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មានប្រទេសដែលទើបបានទទួលឯករាជ្យជាដើម ចង់ទទួលចំណែកផលនៃអរិយធម៌ទំនើបក្នុងវិស័យសេដ្ឋកិច្ច និងនយោបាយ ព្រមទាំងចង់មានតួនាទីក្នុងឆាកអន្តរជាតិផង។ ក៏ប៉ុន្តែ ប្រជាជាតិទាំងនោះ និងប្រជាជាតិដែលមានធនធានស្តុកស្តម្ភ ហើយអភិវឌ្ឍន៍លឿនជាង កាន់តែមានគម្លាតឆ្ងាយពីគ្នា។ នៅពេលជាមួយគ្នានេះ ជាញឹកញយណាស់ ប្រជាជាតិទាំងនោះស្ថិតនៅក្រោមចំណុះប្រជាជាតិដែលស្តុកស្តម្ភកាន់តែខ្លាំងឡើង សូម្បីតែក្នុងវិស័យសេដ្ឋកិច្ច។ ប្រជាជនដែលស្រេកឃ្លាន តែងចោទប្រកាន់ប្រជាជាតិដែលមានសម្បូណ៌ហូរហៀរ។ នៅប្រទេសណាដែលស្ត្រីមិនទាន់មានសិទ្ធិស្មើនឹងបុរស ស្ត្រីក៏នាំគ្នាទាមទារសិទ្ធិនោះ និងសូមឲ្យរដ្ឋអនុវត្តតាមទៀតផង។ ប្រជាពលករ គឺកម្មករនិងកសិករ មិនគ្រាន់តែចង់បានប្រាក់បៀវត្សសម្រាប់ចិញ្ចឹមជីវិតប៉ុណ្ណោះទេ តែមានបំណងចង់ពង្រឹងកិត្តិយសនៃបុគ្គលិកលក្ខណៈរបស់ខ្លួន ដោយសារកិច្ចការរបស់គេ។ ប្រសើរជាងនេះទៅទៀត គេក៏ចង់ចូលរួមក្នុងការចាត់ចែងជីវិតសេដ្ឋកិច្ច ជីវិតក្នុងសង្គម ជីវិតនយោបាយ និងវប្បធម៌ផងដែរ។ នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ ដែលមនុស្សជាតិទាំងមូលហ៊ានគិតថា ប្រជាជាតិទាំងអស់អាច (នឹងត្រូវ) ទទួលផលផ្លែពីអរិយធម៌យ៉ាងពិតប្រាកដ។

គ. ប៉ុន្តែ មនុស្សមានសេចក្តីប៉ងប្រាថ្នាជ្រៅជាង និងសកលជាងសេចក្តីប៉ងប្រាថ្នាទាំងនោះទៅទៀត គឺមនុស្សនិងក្រុមនានាស្រេកឃ្លានចង់បានជីវិតយ៉ាងពេញលេញប្រកបដោយសេរីភាព ចង់រស់នៅយ៉ាងថ្លៃថ្នូរសមនឹងឋានៈខ្លួនជាមនុស្ស អាចប្រើប្រាស់លទ្ធភាពដ៏ទូលំទូលាយទាំងប៉ុន្មាន នៃពិភពលោកនាបច្ចុប្បន្នមក

បម្រើខ្លួនដែរ។ ចំពោះប្រជាជាតិនានា គេនៅតែខិតខំដោយក្លាហាន ដើម្បីឲ្យប្រួបរួមគ្នាជាសហគមន៍សកលម្យ៉ាង។

ឃ.ដូច្នេះ យើងអាចសង្កេតឃើញថា ពិភពលោកទំនើបមានអំណាចខ្លាំងផង និងទន់ខ្សោយផង អាចប្រព្រឹត្តអ្វីដ៏ល្អប្រសើរជាងគេបំផុតផង និងអ្វីដ៏អាក្រក់ជាងគេបំផុតផង ហាក់ដូចជាមានផ្លូវពីរនៅពីមុខ គឺផ្លូវទៅកាន់សេរីភាពផង និងផ្លូវទៅកាន់ភាពជាទាសករផង អាចអភិវឌ្ឍន៍បាន ឬថយក្រោយវិញបានដែរ ទៅកាន់ភាតរភាព ឬទៅកាន់ការស្អប់គ្នា។ ម្យ៉ាងទៀត មនុស្សបានធ្វើឲ្យថាមពលចាប់ផ្ដើមមានចលនាផ្សេងៗ។ តែមនុស្សភ្ញាក់ស្មារតីថា ឥឡូវខ្លួនអាចតម្រង់ថាមពលទាំងនោះទៅទិសល្អ ស្រេចតែចិត្ត គឺបណ្ដោយឲ្យថាមពលទាំងនោះកម្ទេចខ្លួន ឬបម្រើខ្លួនក៏បានដែរ។ ហេតុនេះហើយបានជាមនុស្សចោទសួរខ្លួនឯង។

## ១០- មនុស្សជាតិចោទសួរយ៉ាងជ្រៅ

ក. តាមពិត ការបង្ខូចតុល្យភាពក្នុងពិភពលោកសព្វថ្ងៃ ជាប់នឹងការបង្ខូចតុល្យភាពជាគ្រឹះដែលមានឫសក្នុងចិត្តមនុស្សតែម្ដង។ ក្នុងចិត្តមនុស្ស មានកត្តាជាច្រើនប្រទាញប្រទង់គ្នា។ ណាមួយ ក្នុងឋានៈខ្លួនជាសត្វលោក មនុស្សមានព្រំដែនជាច្រើន។ ណាមួយទៀត ខ្លួនប៉ងប្រាថ្នាចង់បានជីវិតដ៏ប្រសើរបំផុត ដែលពិតជាទិសដៅរបស់ខ្លួន។ មានបំណងជាច្រើនទាក់ទាញចិត្ត ហើយខ្លួនត្រូវជ្រើសរើសជានិច្ចថា ធ្វើតាមបំណងទាំងនេះក៏បាន ឬលះបង់ក៏បានដែរ។ អាក្រក់ជាងនេះទៅទៀត ដោយខ្លួនទន់ខ្សោយនិងជាអ្នកបាប ជាញឹកញាប់មនុស្សចេះតែប្រព្រឹត្តអំពើអាក្រក់ដែលខ្លួនមិនចង់ធ្វើ តែមិនប្រព្រឹត្តអំពើល្អដែលខ្លួន ចង់ធ្វើនោះទេ (រម ៧, ១៤.២១)។ សរុបសេចក្ដីមក មនុស្សបាក់បែកគ្នាឯងពីខាងក្នុងចិត្ត ជាមូលហេតុបង្កបង្កើតទំនាស់ទាស់ទែងគ្នាជាច្រើននិងយ៉ាងធ្ងន់ធ្ងរ។ តាមពិត មានមនុស្សជាច្រើនបែរចិត្តឆ្ងាយ មិនយល់ឃើញសភាពការណ៍ដ៏សែនពិបាកនេះយ៉ាងជាក់ច្បាស់ទេ ព្រោះគេរស់នៅតាមលទ្ធិសម្ភារៈនិយម ដែលជ្រួតជ្រាបក្នុងការរស់នៅរបស់គេស្រាប់។ មានមនុស្សមួយចំនួនទៀត រងគ្រោះដោយភាពក្រីក្រតោកយ៉ាក មិនអាចចាប់អារម្មណ៍នឹងសេចក្ដីនេះបាន។ មានចំនួនមនុស្សរឹតតែច្រើនទៅទៀតស្មានថា បានសេចក្ដីសុខសាន្តដោយទទួលសេចក្ដីអត្ថាធិប្បាយផ្សេងៗអំពីពិភពលោក តាមតែសង្គមផ្ដល់ឲ្យ។ មានក្រុមខ្លះសង្ឃឹមថា មនុស្សជាតិអាចមានសេរីភាពដ៏ពិតប្រាកដ និងយ៉ាងពេញលេញ ដោយសារតែខ្លួនខិតខំប្រឹងប្រែងប៉ុណ្ណោះ។ គេបញ្ចុះបញ្ចូលខ្លួនឯងថា រាជ្យរបស់មនុស្សនៅលើផែនដី នឹងអាចបំពេញសេចក្ដីប៉ងប្រាថ្នាទាំងប៉ុន្មាន ដែលខ្លួនចង់បាននោះ។ មានក្រុមអ្នកខ្លះទៀតអស់សង្ឃឹម ដោយយល់ឃើញថា ជីវិតគ្មានន័យសោះ។ គេនាំគ្នាលើកតម្កើងអ្នកក្លាហានមោះមុត ដែលផ្ដល់អត្ថន័យទាំងស្រុងដល់ជីវិត តាមខ្លួនយល់ឃើញវិញ។ទោះជាយ៉ាងណាក៏ដោយ ក៏មានមនុស្សកាន់តែច្រើនឡើងៗ នៅពេលឃើញការវិវឌ្ឍន៍នៃពិភពលោកសព្វថ្ងៃ នាំគ្នាចោទសួរសំណួរជាគ្រឹះ ឬនឹកគិតអំពីសំណួរទាំងនោះតាមរបៀបមោះមុតជាថ្មីថា តើអ្វីទៅមនុស្ស? តើទុក្ខវេទនា សេចក្ដីអាក្រក់ មរណភាព មានអត្ថន័យយ៉ាងណា? ទោះបីមានការអភិវឌ្ឍន៍ច្រើនយ៉ាងណាក្ដី ក៏ទុក្ខវេទនា សេចក្ដីអាក្រក់ មរណភាព ស្ថិតនៅរហូតដែរ។ តើជ័យជម្នះទាំងប៉ុន្មានក្នុងវិស័យជាច្រើនបានប្រយោជន៍អ្វី បើត្រូវបង់ខាតថ្លៃច្រើនយ៉ាងនេះ? តើមនុស្សអាចយកអ្វីមកជួយសង្គមបាន? តើមនុស្សអាចរង់ចាំទទួលអ្វីពីសង្គម? ផុតពីជីវិតនេះ តើនឹងទៅជាយ៉ាងណាដែរ?

ខ. ចំពោះព្រះសហគមន៍វិញ ព្រះសហគមន៍ជឿថា ព្រះគ្រីស្តដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ (២ករ ៥, ១៥) ព្រះអង្គប្រទានពន្លឺ និងកម្លាំងឲ្យមនុស្ស ដោយសារព្រះវិញ្ញាណព្រះអង្គ ដើម្បីឲ្យមនុស្សអាចតបឆ្លើយស្របតាមទិសដៅដ៏ខ្ពង់ខ្ពស់របស់ខ្លួន គឺតាម ព្រះជាម្ចាស់ត្រាស់ហៅ។ ព្រះសហគមន៍ជឿថា នៅក្រោមមេឃនេះក្រៅពីព្រះគ្រីស្តយេស៊ូ ព្រះជាម្ចាស់ ពុំបានប្រទាននាមណាមួយផ្សេងទៀតមកមនុស្ស ដើម្បីសង្គ្រោះយើងនោះឡើយ (កក ៤, ១២)។ ព្រះសហគមន៍ក៏ជឿថា អត្ថន័យដ៏សំខាន់ និងទិសដៅនៃប្រវត្តិសាស្ត្រទាំងមូលរបស់មនុស្ស ស្ថិតនៅក្នុងអង្គព្រះអម្ចាស់ និងព្រះបរមគ្រូរបស់ខ្លួន។ ព្រះសហគមន៍បញ្ជាក់ទៀតថា ទោះបីមានការផ្លាស់ប្តូរជាច្រើនយ៉ាងណាក្តី ក៏មានសេចក្តីខ្លះនៅស្ថិតស្ថេរនៅឡើយ គឺអ្វីៗដែលមានគ្រឹះនៅក្នុងអង្គព្រះគ្រីស្ត គឺព្រះអង្គមិនប្រែប្រួលឡើយពីដើម នៅពេលសព្វថ្ងៃ និងនៅរហូតដល់អស់កល្បជានិច្ចព្រះអង្គនៅតែដដែល (ហប ១៣, ៨)។ ហេតុនេះហើយ បានជាមហាសន្និបាត ក្រោមពន្លឺរបស់ព្រះគ្រីស្តជារូបតំណាងរបស់ព្រះជាម្ចាស់ ដែលយើងមើលពុំឃើញជារៀមច្បងនៃសត្វលោកទាំងអស់ ដែលព្រះជាម្ចាស់បានប្រតិស្ឋានមក (កូឡ ១, ១៥) មានបំណងនិយាយសន្ទនាជាមួយ មនុស្សទាំងអស់ ដើម្បីបំភ្លឺការអាថ៌កំបាំងរបស់មនុស្ស និងជួយមនុស្សជាតិឲ្យរកដំណោះស្រាយចំពោះបញ្ហាដ៏សំខាន់ៗនាបច្ចុប្បន្ននេះ។

**ភាគទីមួយ**

# ព្រះសហគមន៍ និងគោលដៅនៃជីវិតរបស់មនុស្សតាមព្រះជាម្ចាស់កំណត់ទុក

## ១១- ព្រះសហគមន៍ត្រូវតបឆ្លើយនឹងព្រះវិញ្ញាណដែលត្រាស់ហៅ

ក. ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ខិតខំពិនិត្យមើលព្រឹត្តិការណ៍ ដើម្បីរកឃើញនូវអ្វីៗដែលមនុស្សសម័យឥឡូវទាមទារ និងចង់បានជាចំបាច់ ព្រមទាំងរកឃើញអ្វីៗ ដែលជាសញ្ញាសម្គាល់ដ៏ពិតប្រាកដអំពីវត្តមានរបស់ព្រះជាម្ចាស់ និងអំពីគម្រោងការព្រះអង្គផង។ ព្រះសហគមន៍រួមរស់ជាមួយមនុស្សឯទៀតៗនៅសម័យឥឡូវ ដោយធ្វើជីវិតលើព្រះគ្រីស្ត ទាំងដឹងថា ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ដែលគង់នៅពាសពេញផែនដីទាំងមូលណែនាំផង។ ជំនឿពិតជាផ្តល់ឲ្យមនុស្សយល់អំពីអ្វីៗទាំងអស់តាមអត្ថន័យថ្មី និងសម្តែងឲ្យយើងស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ អំពីគោលដៅនៃជីវិតទាំងស្រុងរបស់មនុស្ស តាមព្រះអង្គត្រាស់ហៅ។ ជំនឿក៏តម្រង់វិញ្ញាណមនុស្សឲ្យរកដំណោះស្រាយបញ្ហារបស់មនុស្ស ឲ្យបានស្របនឹងលក្ខណៈជាមនុស្ស។

ខ. មុនដំបូង មហាសន្និបាតមានបំណងចង់យកជំនឿនេះ មករិះគិតពិចារណាអំពីអ្វីៗ ដែលមនុស្សសម័យឥឡូវយល់ឃើញថា មានតម្លៃថ្លៃជាងគេ និងភ្ជាប់អ្វីៗដែលមានតម្លៃជាងគេទាំងនោះ ទៅនឹងព្រះជាម្ចាស់ជាប្រភព។ ដោយអ្វីៗដែលមនុស្សសម័យឥឡូវយល់ឃើញថាមានតម្លៃ ហូរចេញពីប្រាជ្ញាញាណរបស់មនុស្ស គឺអ្វីៗទាំងនោះពិតជាល្អណាស់ ព្រោះជាព្រះអំណោយទានរបស់ព្រះជាម្ចាស់។ ក៏ប៉ុន្តែ ដោយសារកិលេសតណ្ហា មនុស្សបង្វែរអ្វីៗដ៏ល្អដែលមានតម្លៃទាំងនោះ ឆ្ងាយពីរបៀបរៀបរយដែលព្រះជាម្ចាស់រៀបចំទុក។ ហេតុនេះហើយ ត្រូវជម្រះអ្វីៗទាំងនោះជាចាំបាច់។

គ. តើព្រះសហគមន៍ មានទស្សនៈយ៉ាងណាអំពីមនុស្ស? តើព្រះសហគមន៍ត្រូវជូនគោលការណ៍ណាខ្លះដើម្បីជួយសាងសង់សង្គមសម័យឥឡូវ? តើសកម្មភាពរបស់មនុស្សក្នុងពិភពលោក មានអត្ថន័យយ៉ាងណានៅទីបំផុត? មហាសន្និបាតត្រូវតែតបឆ្លើយនឹងសំណួរទាំងនោះដោយខានពុំបាន។ មនុស្សជាតិ និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលជាចំណែកមួយចូលរួមក្នុងចំណោមមនុស្សជាតិ ត្រូវតែជួយបម្រើគ្នាទៅវិញទៅមកឲ្យកាន់តែច្បាស់ឡើងៗ។ ដោយធ្វើដូច្នេះ ព្រះសហគមន៍មុខជានឹងសម្តែងលក្ខណៈតាមបេសកកម្មរបស់ខ្លួន គឺសម្តែងលក្ខណៈជាសាសនាផង ហើយលក្ខណៈជាមនុស្សសុទ្ធសាធផង។

# ជំពូក ១

## មនុស្សជាបុគ្គលមានតម្លៃដ៏ថ្លៃថ្នូរ

### ១២- មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់

ក. អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ និងអ្នកដែលមិនផ្ញើជីវិតលើព្រះអង្គជាច្រើន មានយោបល់ស្របគ្នាអំពីចំណុចនេះថា អ្វីៗទាំងអស់នៅលើផែនដីទាំងមូល មានទិសដៅនិងអត្ថន័យដោយសារមនុស្ស ដែលជាស្នូល និងជាកំពូលនៃពិភពលោក។

ខ. ក៏ប៉ុន្តែ អ្វីទៅមនុស្ស? មនុស្សយើងបានផ្តល់យោបល់ផ្សេងៗជាច្រើនអំពីខ្លួនផ្ទាល់ ជួនកាលជាចម្លើយផ្ទុយគ្នា គឺថា ជួនកាលមនុស្សលើកតម្កើងខ្លួនឯង ទុកជាក្បួនវិន័យដាច់ខាតលើអ្វីៗទាំងអស់ ជួនកាលមនុស្សបន្ទាបខ្លួនរហូតដល់អស់សង្ឃឹម។ ហេតុនេះហើយបានជាមនុស្សនៅតែមានចិត្តសង្ស័យ និងតប់ប្រមល់។ ព្រះសហគមន៍ក៏ចាប់អារម្មណ៍យ៉ាង ខ្លាំងនឹងការពិបាកទាំងនោះ។ ព្រះសហគមន៍មានសមត្ថភាពអាចតបចម្លើយបានទៅសំណួរទាំងនោះ ព្រោះព្រះជាម្ចាស់បានបង្រៀនព្រះសហគមន៍ ដោយសម្តែងសេចក្តីពិតអំពីព្រះអង្គឲ្យស្គាល់តាមព្រះគម្ពីរ។ តាមព្រះគម្ពីរ មានចែងអំពីលក្ខណៈដ៏ពិតប្រាកដរបស់មនុស្ស គឺមានបញ្ជាក់យ៉ាងច្បាស់ថា មនុស្សទន់ខ្សោយមែនហើយ តែនៅពេលជាមួយគ្នានេះ ត្រូវទទួលស្គាល់យ៉ាងត្រឹមត្រូវ នូវតម្លៃដ៏ថ្លៃថ្នូរ និងគោលដៅនៃជីវិតរបស់គេ តាមព្រះជាម្ចាស់កំណត់ទុក។

គ. ក្នុងព្រះគម្ពីរមានចែងថា ព្រះជាម្ចាស់ប្រតិស្ឋានមនុស្ស *"ឲ្យមានលក្ខណៈដូចព្រះអង្គ"* អាចស្គាល់ និងស្រឡាញ់ព្រះអាទិកររបស់ខ្លួន ព្រះអង្គតែងតាំងមនុស្សទុកជាម្ចាស់នៃសត្វលោកទាំងអស់នៅលើផែនដី (កណ ១, ២៦ ប្រាញ ២, ២៣) ដើម្បីឲ្យមានអំណាចលើសត្វលោកទាំងនោះ និងប្រើប្រាស់សត្វលោកទាំងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ (បស ១៧, ៣.១០)។ *"តើមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកគិតដល់គេដូច្នេះ? តើបុត្រមនុស្សជាអ្វីបានជា ព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ? ព្រះអង្គបានប្រោសឲ្យគេមានឋានៈទាបជាងទេវតាតែបន្តិចប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យព្រះអង្គ ប្រទានឲ្យគេគ្រប់គ្រងលើអ្វីៗទាំងអស់ ដែលព្រះអង្គបានប្រតិស្ឋានមក ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឲ្យនៅក្រោមជើងរបស់គេ"* (ទន ៨, ៥.៧)។

ឃ. ប៉ុន្តែ ព្រះជាម្ចាស់មិនបានប្រតិស្ឋានមនុស្សឲ្យនៅតែម្នាក់ឯងទេ តែតាំងពីដើមរៀងមក *"ព្រះអង្គប្រតិស្ឋានមនុស្សជាបុរសជាស្ត្រី"* (កណ ១, ២៧)។ សង្គមដែលមានបុរសនិងស្ត្រីនេះ ជារបៀបដើមដំបូង ដើម្បីបញ្ជាក់ថា បុគ្គលទាំងអស់ត្រូវតែរួបរួមគ្នា។ តាមលក្ខណៈដ៏ជ្រៅបំផុតរបស់ខ្លួន មនុស្សជាបុគ្គលមួយដែលរស់នៅក្នុងសង្គម។ ប្រសិនបើមនុស្សគ្មានទំនាក់ទំនងជាមួយអ្នកដទៃ គេមិនអាចរស់នៅបានទេ ហើយគេក៏មិនអាចធ្វើឲ្យទេពកោសល្យរបស់ខ្លួនចម្រើនឡើងបានដែរ។

ង. ហេតុនេះហើយ ក្នុងព្រះគម្ពីរមានចែងទៀតថា *"ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ ដែលព្រះអង្គប្រតិស្ឋានមកនោះ ទ្រង់ឈ្វេងយល់ថាល្អប្រសើរបំផុតហើយ"*។ (កណ ១, ៣១)។

## ១៣- អំពើបាប

ក. ព្រះជាម្ចាស់តែងតាំងមនុស្សមានសភាពសុចរិត។ ប៉ុន្តែ មារដ៏មានកលល្បិចជាងគេ បញ្ឆោតមនុស្ស បណ្ដាលឲ្យគាត់ ប្រើសេរីភាពរបស់ខ្លួនហួសហេតុ លើកខ្លួនប្រឆាំងទាស់នឹងព្រះជាម្ចាស់ និងមានបំណងចង់បានសេចក្ដីសុខដោយមិនត្រូវការព្រះអង្គសោះ។ ទោះបីមនុស្សលោកស្គាល់ព្រះជាម្ចាស់ក្ដី ក៏ *"គេពុំបានលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ឲ្យសមនឹងឋានៈរបស់ព្រះជាម្ចាស់ទេ(...) ផ្ទុយទៅវិញចិត្តល្ងីល្ងើរបស់គេក៏បែរទៅជាងងឹតសូន្យសុងដែរ។ គេនាំគ្នាថ្វាយបង្គំ និងគោរពបម្រើអ្វីៗដែលព្រះជាម្ចាស់ប្រតិស្ឋានមក ជំនួសការគោរពបម្រើព្រះ ដែលបានប្រតិស្ឋានសត្វលោកទាំងនោះវិញ"* (រម ១, ២១.២៥)។ ព្រះជាម្ចាស់សម្ដែងឲ្យយើងដឹងសេចក្ដីនេះ យើងក៏មានបទពិសោធន៍ដូច្នេះដែរ។ ប្រសិនបើមនុស្សយើងពិនិត្យមើលចិត្តគំនិតរបស់ខ្លួន យើងមុខជានឹងយល់ឃើញថា ខ្លួនមានលម្អៀងទៅប្រព្រឹត្តអំពើបាប មានតណ្ហាជាច្រើនចង់ពន្លិចស្មារតីរបស់យើង។ តណ្ហាទាំងប៉ុន្មាននេះ មិនមែនបណ្ដាលមកពីព្រះអាទិកររបស់យើង ដែលមានព្រះហឫទ័យសប្បុរសទេ។ មនុស្សលោកមិនព្រមទទួលស្គាល់ព្រះជាម្ចាស់ ទុកជាដើមកំណើតរបស់ខ្លួនឡើយ។ ធ្វើដូច្នេះ គេបាក់បែកសណ្ដាប់ធ្នាប់ ដែលតម្រង់ខ្លួនទៅរកទីដៅចុងក្រោយបំផុតនៃជីវិតរបស់គេ។ នៅពេលជាមួយគ្នានេះ មនុស្សកើតតណ្ហាប្រទាញប្រទង់នឹងខ្លួនឯង ដែលបណ្ដាលឲ្យបំបែកទំនាក់ទំនងជាមួយមនុស្សឯទៀតៗ និងជាមួយសត្វលោកទាំងឡាយយ៉ាងស្រួល។

ខ. ហេតុនេះ យើងយល់ឃើញថា មនុស្សបាក់បែកពីប្រភពខាងក្នុង។ ការរស់នៅរបស់មនុស្សយើង ទោះជាការរស់នៅរបស់បុគ្គលម្នាក់ៗក្ដី ឬជាការរស់នៅរួមក្ដី ច្បាស់ជាការតយុទ្ធដ៏ឃោរឃៅ គឺសេចក្ដីល្អតយុទ្ធនិងសេចក្ដីអាក្រក់ ពន្លឺតយុទ្ធនិងភាពងងឹត។ លើសពីនេះទៅទៀត មនុស្សយើងឃើញថា គឺយើងម្នាក់ៗដឹងខ្លួនថា ដូចជាជាប់ច្រវាក់ដ៏ធ្ងន់។ ប៉ុន្តែ ព្រះអម្ចាស់ផ្ទាល់យាងមកប្រោសឲ្យមនុស្សយើងមានសេរីភាព និងមានកម្លាំងឡើងវិញ ព្រះអង្គប្រែយើងពីខាងក្នុងឲ្យបានថ្មី ដោយបណ្ដេញចៅហ្វាយរបស់មនុស្សលោកចេញទៅខាងក្រៅ (យហ ១២, ៣១) គឺចៅហ្វាយ ដែលបណ្ដាលឲ្យមនុស្សធ្វើជាខ្ញុំបម្រើរបស់បាប (យហ ៨, ៣៤)។ បាបក៏បណ្ដាលឲ្យមនុស្សអន់ថយ ហើយឃាត់មិនឲ្យទៅជាមនុស្សពេញលក្ខណៈ។

គ. យើងទាំងអស់គ្នា មានបទពិសោធន៍អំពីតម្លៃដ៏ខ្ពង់ខ្ពស់បំផុត នៃជីវិតរបស់មនុស្ស តាមព្រះហឫទ័យព្រះជាម្ចាស់កំណត់ទុក ហើយក៏មានបទពិសោធន៍អំពីទុក្ខដ៏ធ្ងន់ធ្ងររបស់មនុស្សផងដែរ។ ព្រះគម្ពីរសម្ដែងអត្ថន័យដ៏ជ្រៅចុងក្រោយបំផុត នៃតម្លៃដ៏ខ្ពង់ខ្ពស់និងនៃទុក្ខទាំងនោះ។

## ១៤- សភាពរបស់មនុស្ស

ក. ទោះបីមនុស្សមានរូបកាយនិងវិញ្ញាណ តែក៏ជាអង្គតែមួយដែរ។ ក្នុងឋានៈខ្លួនមានរូបកាយ មនុស្សយើងសរុបធាតុ និងអ្វីៗទាំងអស់ដែលមានក្នុងពិភពលោក ដូច្នេះអ្វីៗទាំងនោះអាចលើកតម្កើងសិរីរុងរឿងព្រះអាទិកររបស់ខ្លួនដោយសេរី តាមរយៈមនុស្ស ជាកំពូលនៃពិភពលោក (ដន ៣, ៥៧.៩០)។ ហេតុនេះត្រូវហាមផ្ដាច់មនុស្សយើង កុំឲ្យមាក់ងាយជីវិតរូបកាយជាដាច់ខាត ផ្ទុយទៅវិញ មនុស្សយើងត្រូវតែលើក

តម្លៃនៃរូបកាយ និងគោរពរូបកាយដែលព្រះជាម្ចាស់ប្រតិស្ឋានមក ហើយដែលត្រូវទទួលជីវិតថ្មីដ៏រុងរឿងនៅពេលចុងក្រោយបំផុត។ ប៉ុន្តែ ដោយមនុស្សយើងត្រូវរបួសដោយសារអំពើបាប យើងដឹងខ្លួនថារូបកាយបះបោរប្រឆាំងនឹងវិញ្ញាណ។ ហេតុនេះកិត្តិយសរបស់មនុស្សយើង ទាមទារឲ្យយើងប្រើរូបកាយមកលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (១ករ ៦, ១៣.២០) មិនបណ្តោយឲ្យរូបកាយធ្លាក់ទៅធ្វើជាទាសករនៃតណ្ហា ជាលម្អៀងទៅរកសេចក្តីអាក្រក់ដែលកប់ទុកក្នុងចិត្ត។

ខ. តាមពិត យើងមិនយល់ច្រឡំ ដោយទទួលស្គាល់ថា មនុស្សយើងប្រសើរជាងជាតិទាំងឡាយដែលស្ថិតក្នុងខ្លួន និងរាប់ទៀតថា មនុស្សយើងមិនគ្រាន់តែជាចំណែកដ៏តូចនៃធម្មជាតិ ឬជាគ្រឿងអនាមិកនៃសង្គមប៉ុណ្ណោះទេ គឺមនុស្សយើងមានអ្វីលើសកត្តាទាំងនោះ មនុស្សយើងហួសពីវត្ថុទាំងឡាយ ព្រោះខ្លួនមានវិចារណញ្ញាណនៅខាងក្នុង។ នៅពេលយើងនឹកស្មឹងស្មាធិ៍រិះគិតអំពីខ្លួនឯង យើងទៅដល់ទីជម្រៅនៃវិចារណញ្ញាណដែលនៅខាងក្នុងនោះ ជាកន្លែងព្រះជាម្ចាស់រង់ចាំជួបយើង គឺព្រះជាម្ចាស់ដែលស្ទង់ចិត្តគំនិត (១ពង្ស ១៦, ៧; យរ ១៧, ១០)។ មនុស្សយើង ក៏សម្រេចអំពីវាសនារបស់ខ្លួនដោយផ្ទាល់ខ្លួននៅទីជម្រៅនៃចិត្តគំនិតនោះ ដោយព្រះជាម្ចាស់ប្រោសប្រណីផង។ ដូច្នេះ ពេលណាយើងទទួលស្គាល់ថាខ្លួនមានវិញ្ញាណដ៏អមតៈ ពេលនោះយើងយល់ដល់ទីជម្រៅនៃសេចក្តីដ៏ពិតប្រាកដអំពីខ្លួន គឺយើងលែងគិតថា យើងជាគ្រឿង ដែលកើតមកតែពីធម្មជាតិ ឬដោយសង្គម ដូចគេស្រមៃឃើញទៀតហើយ។

## ១៥- ប្រាជ្ញាមានតម្លៃដ៏ថ្លៃថ្នូរ

ក. មនុស្សយើងទទួលប្រាជ្ញា ជាចំណែកនៃពន្លឺរបស់ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ ហេតុនេះហើយបានជាយើងយល់ដឹងយ៉ាងត្រឹមត្រូវថា ខ្លួនប្រសើរជាងអ្វីៗទាំងអស់ក្នុងពិភពលោក ព្រោះយើងមានប្រាជ្ញា។ ពីសតវត្សមួយទៅសតវត្សមួយ មនុស្សព្យាយាមខិតខំប្រើប្រាជ្ញារបស់ខ្លួនធ្វើឲ្យវិទ្យាសាស្ត្រនៃបទពិសោធន៍ បច្ចេកទេស និងវិចិត្រសិល្បៈ ចម្រើនឡើងជាលំដាប់។ នៅសម័យឥឡូវ មនុស្សយើងបានជ័យជម្នះយ៉ាងអស្ចារ្យ ដោយបានរកឃើញអ្វីៗខាងសម្ភារៈ និងបានបង្ក្រាបពិភពសម្ភារៈនោះ យកមកប្រើប្រាស់។ ប៉ុន្តែ ជានិច្ចជាកាល មនុស្សបានស្វះស្វែងរកសេចក្តីពិតដ៏ជ្រៅជាង ហើយបានរកឃើញផងដ្បិតប្រាជ្ញាមនុស្សមិនគ្រាន់តែចេះពិនិត្យមើលអ្វីៗដែលអាចមើលឃើញបានប៉ុណ្ណោះទេ តែអាចរិះគិត និងយល់យ៉ាងជាក់ច្បាស់នូវអ្វីដ៏ពិតប្រាកដដែលមានកប់នៅខាងក្នុងអ្វីទាំងនោះ តាមតែអាចយល់បាន ទោះបីអំពើបាបបានបន្សល់ទុកភាពងងឹត និងភាពទន់ខ្សោយក្នុងប្រាជ្ញាមនុស្សយើងក៏ដោយ។

ខ. ក្នុងឋានៈខ្លួនមានប្រាជ្ញា បុគ្គលម្នាក់ៗស្វែងរក (ហើយត្រូវតែស្វែងរក) ធ្វើឲ្យខ្លួនបានពេញលក្ខណៈដោយសារគតិបណ្ឌិត។ គតិបណ្ឌិតតែងតែទាក់ទាញវិញ្ញាណរបស់មនុស្សយ៉ាងខ្លាំង និងយ៉ាងថ្នាក់ថ្នម ឲ្យស្វះស្វែងរក និងស្រឡាញ់សេចក្តីពិតនិងអ្វីដ៏ល្អប្រសើរ។ មនុស្សណាដែលមានគតិបណ្ឌិតជ្រួតជ្រាបពិតជា ឆ្លងពីពិភព ដែលមើលឃើញទៅពិភពដែលមើលមិនឃើញពុំខាន។

គ. មនុស្សសម័យឥឡូវត្រូវការគតិបណ្ឌិតនេះជាចាំបាច់ ច្រើនជាងមនុស្សសម័យឯទៀតៗទាំងអស់ ដើម្បីធ្វើឲ្យអ្វីៗ ដែលមនុស្សបានរកឃើញនិងបង្កើត ពិតជាមានលក្ខណៈជាមនុស្សអាចបម្រើមនុស្សបាន។ ប្រសិនបើ គ្មានមនុស្សប្រកបដោយគតិបណ្ឌិតទេ ពិភពលោកពិតជាគ្មានអនាគត។ គួរឲ្យបន្ថែមសេចក្តី

កំណត់នេះថា គឺមានប្រទេសជាច្រើនក្រីក្រខាងធនធានសម្ភារៈ តែបែរទៅជាមានខាងគតិបណ្ឌិត គេអាច ជួយប្រទេសឯទៀតៗយ៉ាងខ្លាំងឲ្យបានគតិបណ្ឌិតនោះ។

ឃ.ដោយព្រះអំណោយទាននៃព្រះវិញ្ញាណជួយបំភ្លឺចិត្តគំនិត មនុស្សអាចយល់ស៊ីងស្មាធិ៍និងក្រេបជញ្ជក់ ឱជារសនៃគម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យព្រះជាម្ចាស់ ដោយសារជំនឿ (បស ១៧, ៧.៨)។

## ១៦- មនសិការខាងសីលធម៌មានតម្លៃដ៏ថ្លៃថ្នូរ

នៅពេលមនុស្សយើងរិះគិត យើងមុខជានឹងរកឃើញក្បួនវិន័យ ដែលខ្លួនមិនបានកំណត់ខ្លួនឯងកប់នៅខាងជម្រៅនៃមនសិការរបស់ខ្លួន គឺក្បួនវិន័យដែលយើងត្រូវតែអនុវត្តតាម។ សម្លេងនេះនៅតែជំរុញយើង ឲ្យមានចិត្តស្រឡាញ់ ឲ្យប្រព្រឹត្តអំពើល្អ និងជៀសវាងមិនឲ្យប្រព្រឹត្តអំពើអាក្រក់ ដែលលាន់ឮក្នុងជម្រៅចិត្តតាមកាលៈទេសៈថា *"ចូរប្រព្រឹត្តអំពើនេះ កុំប្រព្រឹត្តអំពើនោះ"*។ ព្រះជាម្ចាស់ចារក្បួនវិន័យនោះក្នុងចិត្តមនុស្ស។ មនុស្សមានកិត្តិយស ដោយអនុវត្តតាម ហើយក្បួនវិន័យនោះ ក៏នឹងវិនិច្ឆ័យមនុស្សដែរ (រម ២, ១៤.១៦)។ ក្នុងមនុស្ស មនសិកាជាមណ្ឌលដ៏ស្ងាត់កំបាំងជាងគេ ជាទីកន្លែងដ៏សក្ការៈដែលមនុស្សនៅតែម្នាក់ឯងជាមួយព្រះជាម្ចាស់ ជាកន្លែងព្រះសូរសៀងរបស់ព្រះអង្គលាន់ឮឡើង (មថ ២២, ៣៧-៤០; កាឡ ៥, ១៤)។ មនសិការ រកឃើញយ៉ាងអស្ចារ្យនូវវិន័យស្តីអំពីសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងចំពោះបងប្អូន ដែលជាវិន័យកំពូល (មថ ២២, ៣៧-៤០; កាឡ ៥, ១៤)។

ដោយគ្រីស្តបរិស័ទស្មោះត្រង់នឹងមនសិការ រួមជាមួយមនុស្សឯទៀតៗទាំងអស់ គេត្រូវរួមគ្នាស្វែងរកសេចក្តីពិត និងដោះស្រាយយ៉ាងត្រឹមត្រូវនូវបញ្ហាខាងសីលធម៌ ដែលការរស់នៅរបស់បុគ្គលម្នាក់ៗ និងការរស់នៅក្នុងសង្គមចេះតែចោទឡើង។ មនសិការទៀងត្រង់កាន់តែខ្លាំងយ៉ាងណា បុគ្គល ឬក្រុមមនុស្សអាចសម្រេចសេចក្តីឲ្យកាន់តែច្បាស់ និងឲ្យបានស្របនឹងច្បាប់សីលធម៌ ដែលមិនអាចប្រែកែបានយ៉ាងនោះដែរ។ ក៏ប៉ុន្តែ ទោះបីមនសិការវង្វេង ជាញឹកញាប់ ដោយមនុស្សមិនអាចឈ្នះអវិជ្ជាក្តី ក៏មនសិការនៅតែរក្សាទុកតម្លៃដ៏ថ្លៃថ្នូរដដែល។ ផ្ទុយទៅវិញ បើមនុស្សមិនរវីរវល់ស្វែងរកសេចក្តីពិត និងអ្វីដ៏ល្អប្រសើរ ហើយមានទម្លាប់ប្រព្រឹត្តអំពើបាប យូរៗទៅមនសិការរបស់គេហាក់ដូចជាខ្វាក់។

## ១៧- សេរីភាពមានតម្លៃដ៏ឧត្តុង្គឧត្តម

មនុស្សបែរទៅរកអ្វីដ៏ល្អ ដោយប្រើសេរីភាពរបស់ខ្លួនជានិច្ច។ មនុស្សសម័យឥឡូវចូលចិត្តនឹងសេរីភាពនេះយ៉ាងខ្លាំង ហើយក៏ខិតខំចង់បានយ៉ាងក្តៀវក្លាផង។ គេស្វែងរកដូច្នេះត្រឹមត្រូវហើយ។ ក៏ប៉ុន្តែជាញឹកញាប់ គេស្រឡាញ់សេរីភាពតាមរបៀបមិនទៀងត្រង់ទេ ហាក់ដូចជាគេយល់ថាមានសិទ្ធិធ្វើអ្វីក៏បាន សូម្បីតែអំពើអាក្រក់ក៏ធ្វើបានដែរ ឲ្យតែខ្លួនចូលចិត្ត និងសប្បាយប៉ុណ្ណោះ។ រីឯសេរីភាពដ៏ពិតប្រាកដវិញ ជាសញ្ញាសម្គាល់ពិសេសបញ្ជាក់ថាមនុស្សមានលក្ខណៈដូចព្រះជាម្ចាស់។ ព្រះជាម្ចាស់សព្វព្រះហឫទ័យទុកឲ្យមនុស្សអាចស្វែងរកព្រះអាទិកររបស់ខ្លួន ដោយសម្រេចខ្លួនឯងបាន (បស ១៥, ១៤) ហើយប្រសិនបើគេផ្ញើជីវិតលើព្រះអង្គដោយប្រើសេរីភាពនោះ គេក៏អាចបានពេញលក្ខណៈយ៉ាងសែនសុខសាន្តបានដែរ។ ហេតុនេះ កិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សទាមទារឲ្យមនុស្សប្រព្រឹត្តកិច្ចការអ្វីៗ ដែលខ្លួនបានជ្រើសរើសដោយដឹងខ្លួន ដោយសេរីភាព គឺសម្រេចដោយជឿជាក់ដោយខ្លួនឯងផ្ទាល់យ៉ាងជ្រៅក្នុងចិត្ត មិនមែនដោយមានតណ្ហាពុះកញ្ជ្រោល ឬដោយគេបង្ខំឡើយ។ ប្រសិនបើ មនុស្សរំដោះខ្លួនឲ្យរួចផុតពីធ្វើជាទាសករនៃតណ្ហាទាំងអស់ គេមុខជាបានកិត្តិយសនេះ ដោយខ្លួនជ្រើសរើសដោយសេរីនឹងប្រព្រឹត្តអំពើល្អ។ ពេលនោះ គេចាប់ផ្តើមធ្វើដំណើរទៅកាន់ទីដៅនៃជីវិតរបស់ខ្លួន និងប្រើប្រាជ្ញាដ៏វាងវៃ ដើម្បីខិតខំយ៉ាងពិតប្រាកដនឹងរកមធ្យោបាយទៅកាន់ទីដៅ

នោះ។ ក៏ប៉ុន្តែ សេរីភាពរបស់មនុស្ស អាចតម្រង់ខ្លួនទាំងស្រុងនិងយ៉ាងសកម្មទៅកាន់ព្រះជាម្ចាស់ បានយ៉ាងពិតប្រាកដ ដោយសារតែព្រះអង្គជួយប្រោសប្រណី ព្រោះអំពើបាបបានធ្វើឲ្យសេរីភាពនោះត្រូវរបួស។ យើងម្នាក់ៗនឹងត្រូវទៅឈរនៅមុខទីកាត់ក្ដីរបស់ព្រះជាម្ចាស់ដើម្បីឲ្យម្នាក់ៗ ទទួលផលតាមអំពើដែលខ្លួនបានប្រព្រឹត្តកាលពីនៅរស់ក្នុងរូបកាយ ទោះបី ជាអំពើនោះល្អ ឬអាក្រក់ក្ដី (២ករ ៥, ១០)។

## ១៨- ការអាថ៌កំបាំងនៃមរណភាព

ក. លក្ខណៈដ៏អាថ៌កំបាំងនៃជីវិតមនុស្ស ទៅដល់កំពូលនៅពេលមនុស្សប្រឈមមុខនឹងមរណភាព។ មនុស្សមិនគ្រាន់តែជ្រួលច្របល់ដោយខ្លួនខ្លាចរងទុក្ខឈឺចុកចាប់ និងដោយរូបកាយត្រូវអន់ថយទៅៗប៉ុណ្ណោះទេ តែលើសពីនេះទៅទៀត មនុស្សរឹតតែភ័យ ខ្លាចនឹងការវិនាសអន្តរាយរហូតជាស្ថាពរ។ បំណងប្រាថ្នាដ៏ជ្រៅបំផុតនៃចិត្តគំនិតបំភ្លឺយើងយ៉ាងត្រឹមត្រូវថា យើងមិនព្រមអន្តរាយទាំងស្រុងដូច្នេះជាដាច់ខាត ហើយក្នុងឋានៈជាបុគ្គលម្នាក់ យើងក៏មិនសុខចិត្តទទួលបរាជ័យដ៏ធ្ងន់ធ្ងរនេះឡើយ។ មនុស្សយើងមានពូជនៃជីវិតអស់កល្បជានិច្ចកប់ក្នុងខ្លួន ពូជនៃជីវិតនេះមិនមែនកើតតាមធម្មជាតិទេ។ ដោយយើងមានពូជនៃជីវិតនេះ យើងតែងតែជំទាស់យ៉ាងខ្លាំងនឹងមរណភាព។ មនុស្សយើងខិតខំតាមបច្ចេកទេសទាំងប៉ុន្មានយ៉ាងណា ទោះបីបច្ចេកទេសទាំងនោះ មានប្រយោជន៍យ៉ាងណាក៏ដោយ ក៏មិនអាចបន្ធូរការតប់ប្រមល់របស់ខ្លួនឲ្យបានធូរស្រាលឡើយ។ ជីវវិទ្យាអាចបន្តអាយុជីវិតមនុស្សបាន តែមិនអាចបំពេញបំណងរបស់មនុស្សដែលចង់បានជីវិតរហូត ដែលនៅតែជាប់ក្នុងជម្រៅចិត្តគេជានិច្ច។

ខ. ប៉ុន្តែ ទោះបីមនុស្សយើងស្រមៃឃើញអំពីមរណភាពយ៉ាងណាក្ដី ក៏មិនអាចដោះស្រាយបញ្ហានេះបានដែរ។ ព្រះសហគមន៍ដែលទទួលសេចក្ដីបង្រៀនពីព្រះជាម្ចាស់បានសម្ដែងឲ្យដឹង ក៏ប្រកាសបញ្ជាក់ថាព្រះអង្គប្រតិស្ឋានមនុស្សដើម្បី ឲ្យមានទីដៅដ៏សុខក្សេមក្សាន្តរួចផុតពីទុក្ខវេទនានៃលោកនេះ។ តាមជំនឿរបស់គ្រីស្តបរិស័ទ មនុស្សរមែងតែងតែស្លាប់ព្រោះតែអំពើបាប ប៉ុន្តែ គង់តែថ្ងៃណាមួយ មរណភាពខាងរូបកាយ មនុស្សត្រូវចាញ់ជាពុំខាន គឺនៅពេលព្រះសង្គ្រោះដ៏មានឫទ្ធានុភាពសព្វប្រការ និងប្រកបដោយព្រះហឫទ័យមេត្តាករុណានឹងសង្គ្រោះមនុស្សលោក។ មនុស្សបាត់បង់ការសង្គ្រោះនេះ ព្រោះតែអំពើបាបរបស់ខ្លួន។ ព្រះជាម្ចាស់បានត្រាស់ហៅមនុស្ស ហើយនៅតែត្រាស់ហៅគេឲ្យផ្ញើជីវិតទាំងស្រុង លើព្រះអង្គដើម្បីឲ្យរួបរួមជាមួយព្រះអង្គក្នុងជីវិតអស់កល្បជានិច្ច ដែលមិនចេះប្រែប្រួលឡើយ។ ព្រះគ្រីស្ត បានជ័យជម្នះនេះ ដោយមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គក៏រំដោះមនុស្សឲ្យបានរួចពីស្លាប់ ដោយទ្រង់សោយទិវង្គត។ ព្រះសហគមន៍ផ្ដល់ឲ្យមនុស្សគ្រប់ៗគ្នាអាចពិនិត្យពិច័យជំនឿដ៏រឹងប៉ឹងរបស់ខ្លួន គឺជំនឿនេះអាចតបឆ្លើយនឹងសំណួរ ដែលមនុស្សចោទសួរអំពីអនាគតរបស់ខ្លួន ទាំងតប់ប្រមល់។ នៅពេលជាមួយគ្នានេះជំនឿក៏ផ្ដល់ឲ្យមនុស្ស ភាពមានលទ្ធអាចរួបរួមជាមួយបងប្អូនដ៏ជាទីស្រឡាញ់ ដែលចែកឋានទៅហើយក្នុងអង្គព្រះគ្រីស្ត។ ជំនឿក៏ផ្ដល់ឲ្យយើងមានសេចក្ដីសង្ឃឹមថា បងប្អូនទាំងនោះ បានទទួលជីវិតដ៏ពេញលេញនៅក្បែរព្រះអង្គដែរ។

## ១៩- មូលហេតុបណ្ដាលឲ្យមនុស្សមិនព្រមជឿថាមានព្រះជាម្ចាស់

ក. មនុស្សយើងមានកិត្តិយសដ៏ថ្លៃថ្នូរបំផុត មកពីព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យរួបរួមជាមួយព្រះអង្គ។ តាំង

ពីពេលមានមនុស្សនៅលើផែនដី ព្រះអង្គអញ្ជើញមនុស្សយើងឲ្យនិយាយសន្ទនាជាមួយព្រះអង្គ។ មនុស្សយើងកើតមកនៅលើផែនដី មកពីព្រះជាម្ចាស់ប្រតិស្ឋានដោយព្រះហឫទ័យស្រឡាញ់ ហើយព្រះអង្គក៏នៅតែប្រទានឲ្យមនុស្សយើងមានជីវិតតទៅទៀត។ មនុស្សរស់យ៉ាងពេញលក្ខណៈតាមសេចក្ដីពិត លុះត្រាតែខ្លួនទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គដោយសេរីភាព និងផ្ញើជីវិតទាំងស្រុងទៅលើព្រះអាទិកររបស់ខ្លួន។ ក៏ប៉ុន្តែ មនុស្សសម័យឥឡូវ មិនយល់អំពីចំណងដ៏ស្និទ្ធស្នាលយ៉ាងជ្រៅជាមួយព្រះជាម្ចាស់ ជាចំណងផ្ដល់ជីវិតឲ្យគេនេះទេ។ មានមនុស្សខ្លះ លះបង់ចំណងនេះយ៉ាងជាក់ស្ដែងថែមទៀតផង បានជាការបដិសេធថា គ្មានព្រះជាម្ចាស់ទាល់តែសោះ ជាបញ្ហានៅក្នុងចំណោមបញ្ហាដ៏ធ្ងន់ធ្ងរជាងគេ នៅសម័យឥឡូវនេះ។ យើងត្រូវយកចិត្តទុកដាក់ពិនិត្យពិច័យបញ្ហានេះយ៉ាងល្អិតល្អន់។

ខ. ទ្រឹស្ដីហៅថា *"លទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់"* មានប្រភេទផ្សេងពីគ្នាជាច្រើន។ មានអ្នកខ្លះប្រកាសយ៉ាងច្បាស់ថា គ្មានព្រះជាម្ចាស់។ មានអ្នកខ្លះទៀតយល់ឃើញថា មនុស្សមិនអាចនិយាយអ្វីអំពីព្រះអង្គទាល់តែសោះ មានអ្នកខ្លះទៀត រិះគិតអំពីព្រះជាម្ចាស់ ហាក់ដូចជាបញ្ហាដែលគ្មានអត្ថន័យ។ មានមនុស្សជាច្រើន រិះគិតដោយប្រើវិទ្យាសាស្ត្រខាងសម្ភារៈហួសព្រំដែន មិនត្រឹមត្រូវទេ ឬអះអាងថា ប្រាជ្ញាមនុស្សអាចពន្យល់អ្វីៗទាំងអស់ តាមវិទ្យាសាស្ត្របាន ឬផ្ទុយទៅវិញ មិនព្រមទទួលសេចក្ដីពិតណា ទុកជាសេចក្ដីពិតទាល់តែសោះ។ មានអ្នកខ្លះលើកតម្កើងមនុស្សហួសហេតុ ជាហេតុនាំឲ្យជំនឿទៅលើព្រះជាម្ចាស់មិនសូវមានអត្ថន័យ គេមិនបដិសេធថាគ្មានព្រះជាម្ចាស់ចំៗទេ តែគេរវីរវល់ប្រកាសពីកិត្តិយសរបស់មនុស្សប៉ុណ្ណោះ។ មានអ្នកខ្លះ ស្រមៃឃើញព្រះជាម្ចាស់ តាមរបៀបដែលគួរឲ្យបដិសេធ ព្រោះព្រះនោះជាព្រះក្លែងក្លាយមែន មិនមែនជាព្រះជាព្រះជាម្ចាស់ ដែលមានចែងក្នុងគម្ពីរដំណឹងល្អទេ។ មានអ្នកខ្លះមិនដែលរិះគិតអំពីព្រះជាម្ចាស់ទេ គេដូចជាគ្មានរវីរវល់អំពីសាសនាសោះ ហើយគិតថា មិនបាច់រវីរវល់នឹងសាសនាណាឡើយ។ ជាញឹកញាប់ លទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់កើតមក ដោយមនុស្សបះបោរទាស់នឹងសេចក្ដីអាក្រក់ដែលស្ថិតនៅក្នុងពិភពលោក ឬដោយក្រុមមនុស្សខ្លះ លើកយកឧត្តមគតិខ្លះអំពីមនុស្សទុកជាឧត្តមគតិខ្ពង់ខ្ពស់បំផុត ដូចជាព្រះមួយអង្គ។ វប្បធម៌ទំនើបយកចិត្តទុកដាក់នឹងអ្វីៗនៅលើផែន ដីនេះខ្លាំងពេក បណ្ដាលឲ្យពិបាកនឹកគិតអំពីព្រះជាម្ចាស់។ តែការណ៍នេះ មិនមែនមកពីសភាពនៃវប្បធម៌ទំនើបផ្ទាល់ទេ។

គ. អស់អ្នកដែលខិតខំបំបាត់ព្រះជាម្ចាស់ចេញពីចិត្តគំនិតរបស់គេ គឺចោលបញ្ហាសាសនាឲ្យដាច់ពីខ្លួន មិនប្រព្រឹត្តតាមបញ្ជានៃមនសិការរបស់ខ្លួនទេ គេពិតជាមានកំហុស។ អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ក៏មានកំហុសខ្លះក្នុងការបដិសេធនោះដែរ។ ប្រសិនបើយើងគិតអំពីលទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់ទុកជាបញ្ហារួម គ្មានដើមកំណើតពីខ្លួនឯងទេ គឺមានមូលហេតុផ្សេងៗ។ ជួនកាល អ្នកកាន់លទ្ធិបដិសេធនោះមានប្រតិកម្មរិះគន់ទាស់នឹងសាសានានានា នៅតំបន់ខ្លះមានប្រតិកម្មទាស់នឹងគ្រីស្ដសាសនាក៏មានដែរ។ ហេតុនេះហើយ អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ត្រូវទទួលកំហុសក្នុងកំណើតលទ្ធិទាំងនោះ។ ជួនកាល អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ ធ្វេសប្រហែសនឹងការអប់រំជំនឿរបស់ខ្លួន ឬគេពន្យល់ជំនឿរបស់ខ្លួនតាមរបៀបមិនត្រឹមត្រូវ នាំឲ្យវង្វេង ឬគេកាន់សាសនាមិនត្រឹមត្រូវ កាន់តាមសីលធម៌មិនបានល្អ ឬខុសសីលធម៌ក្នុងសង្គម។ យើងអាចនិយាយថា គេលាក់ព្រះភ័ក្ត្រដ៏ពិតប្រាកដរបស់ព្រះជាម្ចាស់ និងលាក់អត្ថន័យសាសនាជាជាងគេធ្វើឲ្យមនុស្សលោកស្គាល់។

## ២០- ទ្រឹស្តីបដិសេធថាគ្មានព្រះជាម្ចាស់

ក. ជាញឹកញយទ្រឹស្តីទំនើប ដែលបដិសេធថាគ្មានព្រះជាម្ចាស់ ជំរុញមនុស្សឲ្យពឹងលើខ្លួនឯង រហូតដល់បំណងនេះ ទៅជាឧបសគ្គរាំងមនុស្ស មិនឲ្យមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។ មានមូលហេតុផ្សេងៗទៀត ដែលយើងមិនយកមកមករិះគិតទេ។ អស់អ្នកដែលប្រកាន់ទ្រឹស្តីបែបនេះ តែងអះអាងថា មនុស្សមានសេរីភាពបានសេចក្តីថា មនុស្សជាទិសដៅរបស់ខ្លួនផ្ទាល់ មានតែមនុស្សប៉ុណ្ណោះទេ ដែលបង្កើត និងណែនាំប្រវត្តិសាស្ត្ររបស់ខ្លួន។ គេអួតអះអាងថា ទស្សនៈអំពីមនុស្សបែបនេះមិនអាចទទួលស្គាល់ថា មានព្រះអម្ចាស់មួយព្រះអង្គជាដើមកំណើត និងជាចុងបំផុតនៃអ្វីៗទាំងអស់បានទេ ឬយ៉ាងហោចណាស់ ជំនឿបែបនេះដូចជាឥតបានការ។ ការអភិវឌ្ឍន៍ខាងបច្ចេកទេស នាបច្ចុប្បន្នកាលនេះ នាំឲ្យមនុស្សយល់ឃើញថា ខ្លួនមានអំណាចខ្លាំងក្លាលើអ្វីទាំងអស់។ ទស្សនៈនេះក៏ដូចជាជួយពង្រឹងទ្រឹស្តីបដិសេធថា គ្មានព្រះជាម្ចាស់នោះដែរ។

ខ. លទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់នាបច្ចុប្បន្នកាលមានច្រើនបែប។ យើងមិនត្រូវបំភ្លេចលទ្ធិ ដែលរង់ចាំការរំដោះរបស់មនុស្សជាពិសេសរំដោះខ្លួនក្នុងវិស័យសេដ្ឋកិច្ចនិងសង្គម។ តាមអ្នកប្រកាន់លទ្ធិបែបនោះ សាសនាជំទាស់នឹងការរំដោះមនុស្ស ដោយលក្ខណៈសាសនាផ្ទាល់ ព្រោះសាសនាអះអាងលើសេចក្តីសង្ឃឹម ដែលបញ្ឆោតមនុស្សថា គេនឹងបានជីវិតនៅលោកខាងមុខ បណ្តាលឲ្យមនុស្សមិនរវីរវល់នឹងសាងសង់ពិភពលោកនៅលើផែនដីនេះ។ ហេតុនេះហើយ បានជានៅពេលអ្នកប្រកាន់លទ្ធិបែបនេះ កាន់អំណាចត្រួតត្រាប្រទេស គេវាយប្រហារសាសនាយ៉ាងឃោរឃៅ។ ពួកគេប្រើគ្រប់មធ្យោបាយនៃរដ្ឋអំណាច ដើម្បីផ្សព្វផ្សាយលទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់នោះ ជាពិសេសក្នុងការអប់រំយុវជន។

## ២១- ឥរិយាបថរបស់ព្រះសហគមន៍ចំពោះលទ្ធិបដិសេធថាគ្មានព្រះជាម្ចាស់

ក. ព្រះសហគមន៍ស្មោះត្រង់ចំពោះព្រះជាម្ចាស់ផង និងស្មោះត្រង់ចំពោះមនុស្សផង តែក៏នៅតែដាក់ទោសលទ្ធិ និងរបៀបប្រព្រឹត្តទាំងនោះយ៉ាងម៉ឺងម៉ាត់ជាខ្លាំង ទាំងព្រួយផង ដូចព្រះសហគមន៍បានដាក់ទោសនៅសម័យមុនៗដែរ ព្រោះលទ្ធិនិងរបៀបប្រព្រឹត្តដ៏អាក្រក់ទាំងនោះ ផ្ទុយនឹងប្រាជ្ញានិងបទពិសោធន៍របស់មនុស្សទូទៅ ហើយបណ្តាលឲ្យមនុស្សធ្លាក់ពីឋានៈដ៏ថ្លៃថ្នូរ ដែលខ្លួនមានតាំងពីកំណើតមក។

ខ. ក៏ប៉ុន្តែ ព្រះសហគមន៍ខិតខំយល់អំពីមូលហេតុដ៏លាក់កំបាំង ក្នុងចិត្តគំនិតអ្នកបដិសេធថាគ្មានព្រះជាម្ចាស់។ ទោះបីព្រះសហគមន៍ដឹងច្បាស់ថា លទ្ធិនោះបណ្តាលឲ្យកើតបញ្ហាធ្ងន់ធ្ងរក្តី ក៏ព្រះសហគមន៍យល់ឃើញថា ត្រូវរិះគិតយ៉ាងពិស្តារ និងយ៉ាងជ្រៅអំពីមូលហេតុទាំងនោះ ដោយមានសេចក្តីស្រឡាញ់ចំពោះមនុស្សគ្រប់ៗគ្នា។

គ. ព្រះសហគមន៍ប្រកាន់ជំនឿថា ការទទួលស្គាល់ព្រះជាម្ចាស់ មិនជំទាស់នឹងតម្លៃដ៏ថ្លៃថ្នូររបស់មនុស្សត្រង់ណាសោះឡើយ ព្រោះតម្លៃដ៏ថ្លៃថ្នូរនេះមកពីព្រះជាម្ចាស់ផ្ទាល់ គឺព្រះអង្គហើយជាគ្រឹះនៃតម្លៃដ៏ថ្លៃថ្នូរនេះ និងធ្វើឲ្យតម្លៃដ៏ថ្លៃថ្នូរនេះបានពេញលក្ខណៈ។ ព្រះជាម្ចាស់ជាព្រះអាទិកររបស់មនុស្ស បានតែងតាំងមនុស្សឲ្យមានប្រាជ្ញា និងមានសេរីភាព ហើយឲ្យរស់នៅក្នុងសង្គម។ ជាពិសេសព្រះអង្គត្រាស់ហៅមនុស្សឲ្យរួបរួមយ៉ាងស្និទ្ធស្នាលជាមួយព្រះអង្គក្នុងឋានៈ ជាបុត្រធីតា និងចែករំលែកសុភមង្គលផ្ទាល់របស់ព្រះអង្គ

ឲ្យមនុស្សផងដែរ។ ព្រះសហគមន៍បង្រៀនទៀតថា សេចក្ដីសង្ឃឹមនឹងបានសេចក្ដីសុខសាន្ដនៅលោកខាងមុខ មិនបណ្ដាលឲ្យកិច្ចការនៅក្នុងលោកនេះលែងមានសារៈសំខាន់ទេ ផ្ទុយទៅវិញ សេចក្ដីសង្ឃឹមនេះផ្ដល់ឲ្យមនុស្សបំពេញកិច្ចការក្នុងលោកនេះ ឲ្យបានសម្រេចដោយមានមូលហេតុថ្មីៗថែមទៀត។ ពេលមនុស្សមិនត្រូវការព្រះជាម្ចាស់គាំទ្រ ហើយពេលមនុស្សគ្មានសេចក្ដីសង្ឃឹម នឹងបានជីវិតអស់កល្បជានិច្ច តម្លៃដ៏ថ្លៃថ្នូររបស់មនុស្សដូចជា ត្រូវរបួសយ៉ាងធ្ងន់ ដូចយើងអាចសង្កេតឃើញក្នុងលោកបច្ចុប្បន្ននេះស្រាប់ហើយ គ្មានអ្វីអាចដោះស្រាយការអាថ៌កំបាំងនៃជីវិតនិងសេចក្ដីស្លាប់ ការអាថ៌កំបាំងនៃអំពើបាប និងទុក្ខវេទនាបានសោះ។ ដូច្នេះជាញឹកញាប់មនុស្សធ្លាក់ទឹកចិត្ត អស់សង្ឃឹម។

ឃ.នៅពេលជាមួយគ្នានេះ មនុស្សម្នាក់ៗនៅតែមិនសួរអំពីអត្ថន័យជីវិត របស់ខ្លួនជាសំណួរ ដែលគេយល់ឃើញយ៉ាងស្រពិចស្រពិល។ នៅពេលខ្លះ ជាពិសេសក្នុងព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការរស់នៅ គ្មាននរណាអាចជៀសផុតពីសំណួរបែបនេះទេ។ មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ដែលអាចតបឆ្លើយនឹងសំណួរនេះបានយ៉ាងពេញលេញហើយប្រកែកមិនបាន គឺព្រះអង្គអញ្ជើញមនុស្សយើងឲ្យរិះគិតយ៉ាងជ្រៅជាង និងឲ្យស្វះស្វែងរកដោយចិត្តសុភាពរាបសាជាងដែរ។

ង. យើងត្រូវព្យាបាលលទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់ ដោយរៀបរាប់ពន្យល់លទ្ធិនៃគ្រីស្ដសាសនាតាមសេចក្ដីត្រូវការរបស់គេ ហើយដោយព្រះសហគមន៍ និងសមាជិកនៃព្រះសហគមន៍រស់នៅបែបបរិសុទ្ធ។ ព្រះសហគមន៍ទទួលភារកិច្ចធ្វើឲ្យមនុស្សលោកមើលឃើញវត្តមានរបស់ព្រះបិតាជាអម្ចាស់ និងព្រះបុត្រាប្រសូតជាមនុស្សគង់នៅក្នុងលោកនេះ ដោយព្រះសហគមន៍ប្រែជាថ្មី និងជម្រះខ្លួនជានិច្ច ក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ (ពន្លឺ ៨)។ ជាពិសេស គ្រីស្ដបរិស័ទត្រូវផ្ដល់សក្ខីភាពអំពីជំនឿរស់រវើក ក្នុងឋានៈជាមនុស្សពេញវ័យ គឺជាជំនឿដែលទទួលការអប់រំ ឲ្យសុខចិត្តទទួលស្គាល់ឧបសគ្គនានាយ៉ាងជាក់ច្បាស់ និងអាចពុះពារឈ្នះឧបសគ្គទាំងនោះបានផង។ មរណសាក្សីជាច្រើនឥតគណនា បានផ្ដល់សក្ខីភាពអំពីជំនឿនេះ ហើយនៅតែមានមរណសាក្សី បន្ដផ្ដល់សក្ខីភាពយ៉ាងត្រចះត្រចង់សព្វថ្ងៃនៅឡើយ។ ព្រះសហគមន៍បង្ហាញផលផ្លែរបស់ខ្លួន ដោយចូលជ្រួតជ្រាបក្នុងការរស់នៅទាំងមូល របស់អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ សូម្បីតែក្នុងការរស់នៅជាធម្មតារបស់មនុស្សលោក។ ព្រះសហគមន៍នាំគេឲ្យរកយុត្តិធម៌ និងសេចក្ដីស្រឡាញ់ ជាពិសេសចំពោះអ្នកខ្វះខាតជាងគេ។ នៅទីបញ្ចប់ បើគ្រីស្ដបរិស័ទ ដែលធ្វើការដោយមានចិត្តថ្លើមតែមួយ ព្រោះតែជំនឿតាមដំណឹងល្អ និងស្រឡាញ់គ្នាទុកជាបងប្អូននិងបង្ហាញខ្លួនទុកជាសញ្ញានៃការរួបរួមគ្នា ជាធ្លុងតែមួយ ពិតជាជួយសម្ដែងអំពីវត្តមានរបស់ព្រះជាម្ចាស់ ដែលគង់នៅក្នុងលោកនេះ។

ច. ទោះបីព្រះសហគមន៍ជំទាស់មិនព្រមទទួលលទ្ធិបដិសេធថា គ្មានព្រះជាម្ចាស់ជាដាច់ខាតក្ដី ក៏ព្រះសហគមន៍នៅតែប្រកាសដោយគ្មានគំនិតលាក់លៀមថា មនុស្សទាំងអស់ ទោះជាអ្នកជឿលើព្រះជាម្ចាស់ក្ដី អ្នកមិនជឿលើព្រះអង្គក្ដី ត្រូវតែយកចិត្តទុកដាក់នឹងសាងសង់ពិភពលោកយ៉ាងត្រឹមត្រូវតាមយុត្តិធម៌ ជាកន្លែងគេរស់នៅរួមជាមួយគ្នា។ គេអាចសាងសង់ពិភពលោកបាន លុះត្រាតែគេនិយាយសន្ទនាទៅវិញទៅមកដោយចិត្តស្មោះ និងដោយប្រុងប្រយ័ត្ន។ ហេតុនេះ ព្រះសហគមន៍នឹកស្ដាយ ដោយមានរដ្ឋអំណាចខ្លះប្រព្រឹត្តចំពោះអ្នកជឿលើព្រះជាម្ចាស់ តាមរបៀបផ្សេងពីរបៀបប្រព្រឹត្តចំពោះអ្នកមិនជឿលើព្រះអង្គ ទាំងរំលោភសិទ្ធិមនុស្ស។ ព្រះសហគមន៍ទាមទារឲ្យអ្នកជឿ មានសេរីភាពកាន់សាសនារបស់ខ្លួនយ៉ាងពិតប្រាកដ និងមានសិទ្ធិសេរីភាពយកពិភពលោកនេះ ធ្វើជាព្រះវិហារថ្វាយព្រះជាម្ចាស់ផង។ ចំពោះអ្នកដែលបដិសេធថា

គ្មានព្រះជាម្ចាស់វិញ ព្រះសហគមន៍អញ្ជើញគេដោយមនុស្សធម៌ ឲ្យពិនិត្យមើលដំណឹងល្អរបស់ព្រះគ្រីស្ដ កុំឲ្យគេមានគំនិតប្រកាន់។

ឆ. ពេលព្រះសហគមន៍ទាមទារ និងការពារតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស ព្រះសហគមន៍ដឹងច្បាស់ថា សាររបស់ខ្លួនត្រូវនឹងជម្រៅចិត្តដ៏អាថ៌កំបាំងរបស់មនុស្ស។ ធ្វើដូច្នេះ ព្រះសហគមន៍ផ្ដល់សេចក្ដីសង្ឃឹមវិញ ដល់អស់អ្នកដែលមិនហ៊ានជឿថា គេមានវាសនាដ៏ប្រសើរឧត្ដម។ សាររបស់ព្រះសហគមន៍នេះ មិនបណ្ដាលឲ្យកិត្តិយសរបស់មនុស្សអន់ថយទេ តែជួយឲ្យមនុស្សចម្រើនឡើងទៅវិញ ដោយផ្សព្វផ្សាយពន្លឺជីវិត និងសេរីភាព។ ក្រៅពីព្រះជាម្ចាស់ គ្មានអ្វីអាចធ្វើឲ្យមនុស្សស្កប់ស្កល់ចិត្តបានទេ *"បពិត្រព្រះអម្ចាស់ ព្រះអង្គបានបង្កើតយើងសម្រាប់ព្រះអង្គ។ ចិត្តយើងស្កប់ស្កល់ លុះត្រាតែបានសម្រាកនៅក្នុងព្រះអង្គ"* (សន្ដៈអូហ្គូស្ដាំង)។

## ២២- ព្រះគ្រីស្ដជាមនុស្សថ្មី

ក. តាមពិត ប្រសិនបើយើងចង់យល់ខ្លះៗ អំពីការអាថ៌កំបាំងរបស់មនុស្ស យើងត្រូវតែរិះគិតក្នុងពន្លឺនៃគម្រោងការដ៏អស្ចារ្យរបស់ព្រះបន្ទូលដែលប្រសូតជាមនុស្ស គ្មានផ្លូវផ្សេងទៀតទេ។ លោកអាដាំជាមនុស្សមុនគេជាប្រផ្នូលរបស់មនុស្សម្នាក់ដែលត្រូវមកខាងក្រោយ ពោលគឺ ជាប្រផ្នូលរបស់ព្រះគ្រីស្ដជាព្រះអម្ចាស់ (រម ៥, ១៤) ព្រះអង្គពិតជាលោកអាដាំថ្មី។ ពេលព្រះគ្រីស្ដសម្ដែងការអាថ៌កំបាំងដ៏អស្ចារ្យរបស់ព្រះបិតា និងការអាថ៌កំបាំងនៃព្រះហឫទ័យស្រឡាញ់របស់ ព្រះអង្គទ្រង់ក៏សម្ដែងឋានៈរបស់មនុស្សយ៉ាងពេញលេញ និងនាំឲ្យគេស្គាល់តម្លៃដ៏ថ្លៃថ្នូររបស់ខ្លួន តាមព្រះជាម្ចាស់បានកំណត់ទុក។ យើងមិនត្រូវឆ្ងល់ដោយសេចក្ដីពិតទាំងប៉ុន្មាននៅខាងលើ មានប្រភពចេញពីព្រះគ្រីស្ដ និងទៅដល់កំពូល ដោយសារព្រះគ្រីស្ដផងដែរ។

ខ. "ព្រះគ្រីស្ដជាតំណាងរបស់ព្រះជាម្ចាស់ដែលយើងមើលពុំឃើញ (កូឡ ១, ១៥; ២ករ ៤៤)។ កាលពីដើមដោយលោកអាដាំប្រព្រឹត្តអំពើបាប លោកបង្ខូចមនុស្ស ឲ្យលែងបានដូចព្រះជាម្ចាស់។ តែព្រះគ្រីស្ដ ដែលជាមនុស្សដ៏ពេញលក្ខណៈ បានប្រោសឲ្យពូជពង្សរបស់លោកអាដាំ បានដូចព្រះជាម្ចាស់វិញ។ ព្រះគ្រីស្ដយកសភាពជាមនុស្សយ៉ាងពិតប្រាកដ មិនមែនជាព្រះជាម្ចាស់ប្រែក្រឡាជាមនុស្សទេ គឺព្រះអង្គលើកសភាពមនុស្សយើង ដើម្បីឲ្យសភាពមនុស្សយើងទទួលតម្លៃដ៏ថ្លៃថ្នូរយកអ្វីមកប្រៀបផ្ទឹមពុំបាន។ ដោយព្រះបុត្រារបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ទ្រង់ដូចជាភ្ជាប់ព្រះអង្គជាមួយមនុស្សគ្រប់ៗរូប។ ព្រះអង្គបានធ្វើការចិញ្ចឹមជីវិតដោយផ្ទាល់ដៃជាមនុស្ស ព្រះអង្គបានរិះគិតដោយមានប្រាជ្ញាជាមនុស្ស ព្រះអង្គបានប្រព្រឹត្តកិច្ចការទាំងអស់ ដោយសម្រេចសេចក្ដីតាមរបៀបមនុស្ស ព្រះអង្គបានស្រឡាញ់ដោយមានចិត្តជាមនុស្ស។ ព្រះអង្គប្រសូតដោយសារព្រះនាងព្រហ្មចារីនីម៉ារី ហើយបានទៅជាមនុស្សដូចយើងបិះបិទក្នុងគ្រប់ប្រការទាំងអស់ តែព្រះអង្គមិនបានប្រព្រឹត្តអំពើបាបសោះឡើយ (ហប ៤, ១៥)។

គ. ព្រះគ្រីស្ដជាកូនចៀមដែលគ្មានទោស តែបានជីវិតជូនមកយើង ដោយព្រះអង្គសព្វព្រះហឫទ័យបូជាព្រះជន្មដោយគ្មាននរណាបង្ខំឡើយ។ ព្រះជាម្ចាស់បានសម្រុះសម្រួលយើងក្នុងអង្គព្រះគ្រីស្ដ ឲ្យជានានឹងព្រះអង្គព្រមទាំងឲ្យជានាគ្នានឹងគ្នាផង (២ករ ៥, ១៨.១៩; កូឡ ១, ២០, ២២)។ ព្រះគ្រីស្ដបានដកយើង

ឲ្យរួចពីធ្វើទាសកររបស់មារនិងរបស់បាប។ ដូច្នេះ យើងម្នាក់ៗអាចនិយាយរួមជាមួយគ្រីស្ទទូតប៉ូលថា៖ *"ព្រះបុត្រារបស់ព្រះជាម្ចាស់បានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសម្រាប់ខ្ញុំ"* (កាឡ ២, ២០)។ ដោយព្រះអង្គរងទុក្ខសម្រាប់យើង ព្រះអង្គមិនគ្រាន់តែធ្វើជាគំរូ ឲ្យយើងដើរតាមលំអានព្រះអង្គប៉ុណ្ណោះទេ (១សល ២, ២១; មថ ១៦, ២៤; លក ១៤, ២៧) តែព្រះអង្គបានបើកមាគ៌ាមួយ។ ប្រសិនបើយើងដើរតាមមាគ៌ានោះ ជីវិត និងសេចក្តីស្លាប់របស់មនុស្សយើងបានវិសុទ្ធ និងទទួលអត្ថន័យថ្មីផង។

ឃ. គ្រីស្តបរិស័ទយើង បានត្រឡប់ឲ្យទៅដូចជាព្រះបុត្រា ជារៀមច្បងក្នុងបណ្តាបងប្អូនជាច្រើន។ (រម ៨, ២៩; កូឡ ១, ១៨) និង *"បានទទួលព្រះអំណោយទានដំបូង របស់ព្រះវិញ្ញាណ"* (រម ៨, ២៣) ដែលប្រោសឲ្យយើង មានសមត្ថភាពអាចប្រព្រឹត្តតាមធម្មវិន័យថ្មី គឺតាមសេចក្តីស្រឡាញ់ (រម ៨, ១.១១; ២ករ ៤, ១៤)។ មនុស្សប្រែជាថ្មីទាំងស្រុងពីខាងក្នុង ដោយសារព្រះវិញ្ញាណនេះដែល *"បញ្ចាំចិត្តយើង"* (អភ ១, ១៤) ទាំងរង់ចាំព្រះជាម្ចាស់លោះរូបកាយយើង (រម ៨, ២៣) គឺថា *"ប្រសិនបើព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលបានប្រោសព្រះយេស៊ូឲ្យមានព្រះជន្មថ្មីដ៏រុងរឿង ទ្រង់សណ្ឋិតនៅក្នុងបងប្អូនមែននោះ ព្រះអង្គដែលបានប្រោសព្រះគ្រីស្តឲ្យមានព្រះជន្មថ្មីដ៏រុងរឿង ទ្រង់ក៏នឹងប្រោសឲ្យរូបកាយរបស់បងប្អូន ដែលរមែងតែងតែស្លាប់នោះ មានជីវិតដោយសារព្រះវិញ្ញាណ ដែលសណ្ឋិតនៅក្នុងបងប្អូននោះដែរ"* (រម ៨, ១១) ក៏ប៉ុន្តែ គ្រីស្តបរិស័ទ មានកាតព្វកិច្ចត្រូវប្រឆាំងនឹងសេចក្តីអាក្រក់ជាចាំបាច់មែន ទោះបីខ្លួនត្រូវប្រឈមមុខនឹងទុក្ខជាច្រើន និងសេចក្តីស្លាប់ក៏ដោយ។ ដោយយើងរួមជាមួយព្រះយេស៊ូ ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង នៅពេលយើងស្លាប់ យើងនឹងបានដូចព្រះគ្រីស្ត ហើយមានសេចក្តីសង្ឃឹមពង្រឹងចិត្តយើង។ ដូច្នេះ យើងក៏ធ្វើដំណើរទៅទទួលជីវិតថ្មីដ៏រុងរឿងដែរ (ភល ៣, ១០; រម ៨, ១៧)។

ង. សេចក្តីនេះ មិនគ្រាន់តែសំដៅទៅដល់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តប៉ុណ្ណោះទេ តែសំដៅទៅដល់មនុស្សទាំងអស់ដែលមានឆន្ទៈល្អ ដោយមានព្រះហឫទ័យ ប្រោសប្រណីរបស់ព្រះជាម្ចាស់បំពេញសកម្មភាពក្នុងគេ ដោយមើលមិនឃើញ (ពន្លឺ ១៦)។ ដោយព្រះគ្រីស្តសោយទិវង្គត ដើម្បីមនុស្សទាំងអស់ (រម ៨, ៣២) និងដោយព្រះជាម្ចាស់កំណត់ទីដៅតែមួយ ឲ្យជីវិតមនុស្សយ៉ាងពិតមែននោះ ពោលគឺឲ្យរួមរស់ជាមួយព្រះអង្គ យើងត្រូវតែយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យមនុស្សទាំងអស់អាចរួមជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង តាមរបៀបដែលព្រះជាម្ចាស់ស្គាល់។

ច. ការអាថ៌កំបាំងនៃជីវិតមនុស្ស ពិតជាមានតម្លៃដ៏អស្ចារ្យយ៉ាងនេះមែន។ ព្រះគ្រីស្តសម្តែងតម្លៃដ៏អស្ចារ្យនៃការអាថ៌កំបាំងរបស់ជីវិតមនុស្សបែបនេះ ឲ្យអ្នកផ្ញើជីវិតលើព្រះអង្គស្គាល់។ ហេតុនេះហើយ បានជាដោយសារព្រះគ្រីស្ត និងដោយរួមក្នុងអង្គព្រះគ្រីស្ត យើងអាចយល់អំពីបញ្ហាដ៏អាថ៌កំបាំងនៃទុក្ខនិងនៃសេចក្តីស្លាប់ ដែលសង្កត់ពីលើមនុស្សយើង។ ក្រៅពីដំណឹងល្អរបស់ព្រះគ្រីស្ត គ្មាននរណាអាចយល់អំពីអាថ៌កំបាំងទាំងនោះបានឡើយ។ ព្រះគ្រីស្តមានព្រះជន្មថ្មីដ៏រុងរឿង។ ដោយព្រះអង្គសោយទិវង្គត ព្រះអង្គបានឈ្នះសេចក្តីស្លាប់ និងប្រទានជីវិតឲ្យយើងយ៉ាងបរិបូណ៌ ដើម្បីឲ្យយើងទៅជាបុត្រធីតារួមក្នុងអង្គព្រះបុត្រា និងបន្លឺសម្លេងដោយរួមក្នុងអង្គព្រះវិញ្ញាណថា "អប្បា! ឱ! ព្រះបិតា!" (រម ៨, ១៥; កឡ ៤៦; យហ ១, ១២; ១យហ ៣, ២១)។

# ជំពូក ២

## សហគមន៍របស់មនុស្ស

### ២៣- គោលបំណងនៃមហាសន្និបាត

ក. ក្នុងចំណោមលក្ខណៈដ៏សំខាន់ៗនៃពិភពលោកនាបច្ចុប្បន្ននេះ យើងត្រូវចាប់អារម្មណ៍នឹងទំនាក់ទំនងកាន់តែច្រើនឡើងៗ រវាងមនុស្សនឹងមនុស្ស។ ការអភិវឌ្ឍន៍បច្ចេកទេសសព្វថ្ងៃ ក៏ជួយពង្រីកទំនាក់ទំនងទាំងនោះយ៉ាងខ្លាំងដែរ។ ប៉ុន្តែ ការសន្ទនាគ្នាទៅវិញទៅមកទុកជាបងប្អូន មិនបានពេញលក្ខណៈ តាមទំនាក់ទំនងបែបនេះទេ តែការសន្ទនានេះ បានជ្រៅជាងដោយមនុស្សរួមជាសហគមន៍របស់បុគ្គល ដែលមានទំនាក់ទំនងជាមួយគ្នា។ បើមនុស្សចង់រួមជាសហគមន៍ គេត្រូវគោរពគ្នាទៅវិញទៅមក គឺគោរពតម្លៃដ៏ថ្លៃថ្នូរយ៉ាងពេញលេញរបស់ខ្លួនខាងវិញ្ញាណ។ សេចក្ដីដែលព្រះគ្រីស្ដបានសម្ដែងមក ជួយយ៉ាងខ្លាំងឲ្យបុគ្គលទាំងប៉ុន្មានរួបរួមគ្នាបែបនោះ ព្រមទាំងណែនាំឲ្យយើងយល់យ៉ាងជ្រៅ អំពីបទដ្ឋានសង្គម គឺព្រះអាទិករបានចាររបៀបរស់នៅក្នុងសង្គមបែបនោះ កប់ទុកក្នុងសភាពមនុស្សខាងវិញ្ញាណ និងខាងសីលធម៌។

ខ. ប៉ុន្តែ ឯកសារថ្មីៗនៃការណែនាំព្រះសហគមន៍ បានពន្យល់លទ្ធិនៃគ្រីស្ដសាសនាយ៉ាងក្បោះក្បាយ អំពីសង្គមមនុស្ស។ មហាន្និបាតគ្រាន់តែរំឭកសេចក្ដីដ៏ពិតសំខាន់ខ្លះ និងរៀបរាប់គ្រឹះនៃលទ្ធិនោះ ដោយបានរិះគិតក្រោមពន្លឺនៃសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងមក។ បន្ទាប់មក មហាន្និបាត នឹងរៀបរាប់អំពីលទ្ធផល ដែលមានសារៈសំខាន់ពិសេសនាបច្ចុប្បន្នកាលនេះ។

### ២៤- ព្រះជាម្ចាស់បានត្រាស់ហៅមនុស្សឲ្យមានលក្ខណៈជាសង្គម

ក. ព្រះជាម្ចាស់ជាព្រះបិតា ថែរក្សាការពារមនុស្សទាំងអស់ជាបុត្រធីតារបស់ព្រះអង្គ។ ព្រះអង្គសព្វព្រះហឫទ័យ ឲ្យមនុស្សទាំងអស់ចូលរួមជាមហាគ្រួសារតែមួយ និងរាប់គ្នាទុកជាបងប្អូនទៅវិញទៅមក។ ព្រះអង្គបានប្រតិស្ឋានមនុស្សទាំងអស់ឲ្យមានលក្ខណៈដូចព្រះអង្គ *"ព្រះអង្គប្រទានឲ្យប្រជាជាតិនានា កើតចេញមកពីមនុស្សតែម្នាក់ ហើយឲ្យគេរស់នៅពាសពេញលើផែនដីទាំងមូល"* (កក ១៧, ២៦)។ ព្រះជាម្ចាស់ត្រាស់ហៅ ឲ្យមនុស្សទាំងអស់មានទិសដៅតែមួយគត់ គឺព្រះអង្គតែម្ដង។

ខ. ហេតុនេះហើយ បានជាសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ និងចំពោះអ្នកដទៃ ជាវិន័យទីមួយដ៏សំខាន់ជាងគេ។ ក្នុងព្រះគម្ពីរមានចែងថាការស្រឡាញ់ព្រះជាម្ចាស់ មិនអាចបែកចេញពីការស្រឡាញ់អ្នកដទៃទេ។ វិន័យឯទៀតៗសង្ខេបមកជាវិន័យតែមួយនេះថា *"ចូរស្រឡាញ់អ្នកឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ..."*។ *"សេចក្ដីស្រឡាញ់ នាំឲ្យប្រតិបត្តិតាមវិន័យបានពេញលក្ខណៈ"* (រម ១៣, ១០; ១យហ ៤, ២០)។ សេចក្ដីនេះ មានសារៈសំខាន់ជាទីបំផុត និងជាក់ស្ដែងសម្រាប់មនុស្សលោក ដែលកាន់តែពឹង

ផ្អែកគ្នាទៅវិញទៅមក ក្នុងពិភពលោក ដែលកាន់តែរួមគ្នាជាធ្លុងតែមួយ។

គ. សូមរិះគិតឲ្យបានជ្រៅជាងទៅទៀត។ ពេលព្រះអម្ចាស់យេស៊ូអង្វរព្រះបិតា ព្រះអង្គ *"សូមឲ្យមនុស្សទាំងអស់រួមជាអង្គតែមួយ ដូចយើងជាអង្គតែមួយដែរ"* (យហ ១៧, ២១.២២)។ ព្រះយេស៊ូប្រទានទស្សនៈមួយ ដែលប្រាជ្ញាមនុស្សលោកគិតមិនដល់ គឺព្រះអង្គដូចជាផ្តល់គំនិតថា ពេលបុត្រធីតារបស់ព្រះជាម្ចាស់រួបរួមគ្នាក្នុងសេចក្តីពិត និងក្នុងសេចក្តីស្រឡាញ់គឺគេរួបរួមគ្នា ម្យ៉ាងដូចព្រះបិតាព្រះបុត្រា និងព្រះវិញ្ញាណរួបរួមគ្នាដែរ។ ដោយមនុស្សបានដូចព្រះត្រៃឯក ដូច្នេះ មនុស្សមានសមត្ថភាពនឹងស្គាល់លក្ខណៈរបស់ខ្លួនបានយ៉ាងពេញលេញ ហើយលុះត្រាតែគេប្រគល់ខ្លួនឲ្យអ្នកដទៃ ដោយមិនរកប្រយោជន៍ផ្ទាល់ខ្លួនសោះ (លក ១៧, ៣៣) ព្រោះព្រះជាម្ចាស់សព្វព្រះហឫទ័យប្រតិស្ឋានមនុស្ស ដើម្បីជាប្រយោជន៍សម្រាប់តែខ្លួនឯងប៉ុណ្ណោះ ខុសប្លែកពីសត្វលោកឯទៀតៗទាំងអស់។

## ២៥- បុគ្គលម្នាក់ៗនិងសង្គមមនុស្សជំពាក់ជំពិនជាមួយគ្នា

ក. មនុស្សមានលក្ខណៈជាសង្គម។ លក្ខណៈនោះបង្ហាញយ៉ាងជាក់ច្បាស់ថា ការអភិវឌ្ឍន៍បុគ្គលម្នាក់ៗ និងការអភិវឌ្ឍន៍សង្គមជំពាក់ជំពិនគ្នាទៅវិញទៅមក។ បុគ្គលម្នាក់ៗ តាមសភាពរបស់ខ្លួនជាមនុស្ស ត្រូវរស់នៅក្នុងសង្គម ជាតម្រូវការដ៏ចាំបាច់។ ប៉ុន្តែ មនុស្សជា (និងត្រូវជា) ដើមកំណើត ជាប្រធាន និងជាទិសដៅរបស់ស្ថាប័នទាំងអស់។ ការរស់នៅក្នុងសង្គម មិនមែនបន្ថែមអ្វីលើលក្ខណៈមនុស្សទេ។ មនុស្សចម្រើនឡើងគ្រប់វិស័យ នឹងអាចទៅដល់ទិសដៅកំណត់របស់ខ្លួនបាន លុះត្រាតែខ្លួនមានទំនាក់ទំនងជាមួយអ្នកដទៃ ជួយបម្រើគ្នាទៅវិញទៅមក និងនិយាយសន្ទនាជាមួយមនុស្សជាបងប្អូន។

ខ. មនុស្សត្រូវការចំណងខាងសង្គមជាចាំបាច់ ដើម្បីបុគ្គលិកលក្ខណៈរបស់ខ្លួនចម្រើនឡើង។ ក្នុងចំណោមចំណងទាំងនោះ ក្រុមគ្រួសារនិងសហគមន៍រស់នៅក្នុងភូមិស្រុក ទាក់ទិនចំៗនឹងលក្ខណៈដ៏ជ្រៅរបស់មនុស្ស។ មានចំណងខ្លះមកពីសេរីភាពនៃសេចក្តីប៉ងប្រាថ្នារបស់ខ្លួន។ សព្វថ្ងៃមានកត្តាផ្សេងៗបណ្តោយឲ្យទំនាក់ទំនងរវាងមនុស្ស និងមនុស្ស និងការជំពាក់ជំពិនទៅវិញទៅមក មានកាន់តែច្រើនឡើងឥតឈប់ឈរ។ ហេតុនេះហើយ បានជាកើតសមាគម និងស្ថាប័នផ្សេងៗតាមសិទ្ធិឯកជនឬសិទ្ធិសាធារណៈ។ យើងតែងតែហៅការនេះថា *"សង្គមនិយកម្ម"*។ គង់តែ *"សង្គមនិយកម្ម"* នេះ បណ្តាលឲ្យកើតវិបត្តិខ្លះក៏ប៉ុន្តែ នាំប្រយោជន៍ជាច្រើន ដែលផ្តល់លទ្ធភាពឲ្យមនុស្សពង្រឹងបុគ្គលិកលក្ខណៈរបស់ខ្លួន និងបណ្តាលឲ្យគុណសម្បត្តិរបស់គេចម្រើនឡើង ហើយធានាសិទ្ធិថែមទៀត។

គ. បុគ្គលម្នាក់ៗទទួលផលប្រយោជន៍ជាច្រើន ពីការរស់នៅក្នុងសង្គម ដើម្បីឲ្យខ្លួនសម្រេចតាមគោលដៅនៃជីវិតដែលព្រះជាម្ចាស់បានកំណត់ទុក សូម្បីតែគោលដៅខាងសាសនាក្តី ក៏ការរស់នៅក្នុងសង្គមជួយដែរ។ ក៏ប៉ុន្តែយើងត្រូវទទួលស្គាល់ថា មនុស្សជាច្រើនបែរចេញពីការប្រព្រឹត្តអំពើល្អ ទៅប្រព្រឹត្តអំពើអាក្រក់វិញ ដោយសារការទាក់ទាញពីបរិស្ថានក្នុងសង្គម ជាកន្លែងគេធ្លាប់រស់នៅតាំងពីកើតមក។ យើងឃើញជាញឹកញាប់ថា គេប្រព្រឹត្តខុសគន្លងក្នុងការរស់នៅក្នុងសង្គម មកពីមានការតឹងតែងក្នុងរចនាសម្ពន្ធសេដ្ឋកិច្ចនយោបាយនិងសង្គម។ ប៉ុន្តែ បើយើងរកមូលហេតុយ៉ាងជ្រៅជាង គឺគេប្រព្រឹត្តខុសគន្លងមកពីមនុស្សមានអំណួត និងគេគិតតែពីខ្លួនឯង បណ្តាលឲ្យខូចដល់បរិយាកាសក្នុងសង្គម។ តាំងពីកើតមក មនុស្ស

មានទំនោរ ដែលនាំឲ្យប្រព្រឹត្តអំពើបាបរួចហើយ ប៉ុន្តែ បើអំពើបាបបានបង្ខូចរបៀបរៀបរយរបស់ពិភពលោកថែមទៀត គេមានមូលហេតុថ្មីៗ ទាក់ទាញឲ្យគេប្រព្រឹត្តអំពើបាប។ ប្រសិនបើគេមិនខិតខំយ៉ាងខ្លាំង ហើយបើគ្មានព្រះជាម្ចាស់ជួយប្រោសប្រណី គេមិនអាចឈ្នះទំនោរអាក្រក់ទាំងនោះបានឡើយ។

## ២៦- ត្រូវគិតគូររកប្រយោជន៍រួម

ក. ចំណងមនុស្សនឹងមនុស្សរឹតតែខ្លាំងឡើងបន្តិចម្តងៗ ហើយលាតសន្ធឹងទៅលើពិភពលោកទាំងមូល។ ហេតុនេះហើយ បានជាប្រយោជន៍រួមក៏លាតត្រដាងទៅលើពិភពលោកទាំងមូលកាន់តែសកល ហើយពាក់ព័ន្ធនឹងសិទ្ធនិង ភារកិច្ចរបស់មនុស្សជាតិទាំងមូល។ ពាក្យ "*ប្រយោជន៍រួម*" មានន័យថា លក្ខណៈទាំងប៉ុន្មាន ក្នុងសង្គមដែលហុចឲ្យទាំងក្រុមផ្សេងៗ ទាំងសមាជិកនីមួយៗនៃក្រុមទាំងនោះ អាចបានពេញលក្ខណៈកាន់តែពេញលេញ និងកាន់តែស្រួលឡើង។ ក្រុមនីមួយៗត្រូវយល់ដល់សេចក្តីត្រូវការ និងដល់សេចក្តីប៉ងប្រាថ្នាដ៏ត្រឹមត្រូវនៃក្រុមឯទៀតៗ ហើយក៏ត្រូវយល់ដល់ប្រយោជន៍រួមនៃក្រុមគ្រួសារមនុស្សទាំងអស់។

ខ. នៅពេលជាមួយគ្នានេះ មនុស្សយល់កាន់តែច្បាស់ អំពីកិត្តិយសដ៏ថ្លៃថ្នូរបំផុតរបស់បុគ្គលម្នាក់ៗ ដែលមានតម្លៃលើសអ្វីៗទាំងអស់ ហើយដែលមានសិទ្ធិនិងភារកិច្ចនៅគ្រប់កន្លែងក្នុងពិភពលោក គ្មាននរណាមានសិទ្ធិរំលោភបាន។ ហេតុនេះហើយ ត្រូវរកមធ្យោបាយធ្វើយ៉ាងណា ឲ្យមនុស្សអាចឈានទៅដល់អ្វីៗដែលខ្លួនត្រូវការ ដើម្បីរស់នៅតាមរបៀបសមនឹងឋានៈខ្លួនជាមនុស្សដ៏ពិតប្រាកដ។ ឧបមាថា ឲ្យគេមានចំណីអាហារ សម្លៀកបំពាក់ ផ្ទះនៅសិទ្ធិជ្រើសរើសរបៀបរស់នៅដោយសេរី បង្កើតក្រុមគ្រួសារ សិទ្ធិរៀនសូត្រ មានការងារធ្វើ មានកេរ្តិ៍ឈ្មោះ សិទ្ធិឲ្យគេគោរព ឲ្យមានពត៌មានដ៏សមរម្យ ឲ្យមានសិទ្ធិប្រព្រឹត្តតាមមនសិការដ៏ត្រឹមត្រូវរបស់ខ្លួន ឲ្យមានសិទ្ធការពារការរស់នៅផ្ទាល់ខ្លួន និងឲ្យមានសេរីភាពត្រឹមត្រូវ មានសេរីភាពខាងសាសនាជាដើម។

គ. ហេតុនេះ របៀបរៀបរយក្នុងសង្គម និងការអភិវឌ្ឍន៍សង្គម ត្រូវបែរទៅរកប្រយោជន៍របស់បុគ្គលជានិច្ច ព្រោះវត្ថុត្រូវស្ថិតនៅក្រោមចំណុះរបស់បុគ្គល បុគ្គលមិនត្រូវស្ថិតនៅក្រោមចំណុះរបស់វត្ថុទេ។ ព្រះអម្ចាស់ប្រទានយោបល់ដោយមានព្រះបន្ទូលថា *"ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្ប័ទ ដើម្បីជាប្រយោជន៍ដល់មនុស្សព្រះអង្គមិនបានបង្កើតមនុស្ស ដើម្បីឲ្យបម្រើថ្ងៃសប្ប័ទឡើយ"* (មក ២,២៧)។ ត្រូវយកព្រះបញ្ញានេះ មកអនុវត្តក្នុងវិស័យផ្សេងៗ គឺត្រូវយកសេចក្តីពិតធ្វើជាគ្រឹះក្នុងការកសាងសង្គមតាមយុត្តិធម៌។ ព្រះបញ្ញានេះ ត្រូវមានជីវិតរស់រវើកដោយសេចក្តីស្រឡាញ់ ហើយឲ្យកាន់តែស្របតាមលក្ខណៈជាមនុស្សដែលប្រកបដោយសេរីភាព។ យើងត្រូវខិតខំប្រែចិត្តគំនិតមនុស្ស ហើយផ្លាស់ប្តូរសង្គមស្ទើរតែទាំងស្រុង។

ឃ. ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំពេលវេលា និងប្រែទ្រង់ទ្រាយនៃផែនដី តាមព្រះហឫទ័យមេត្តាករុណាថែរក្សាពិភពលោកជានិច្ច។ ព្រះវិញ្ញាណស្ថិតនៅការវិវឌ្ឍន៍នោះ។ ដំណឹងល្អដែលប្រៀបដូចជាមេក្នុងម្សៅ គឺបានបង្កើត និងនៅតែបង្កើត ឲ្យមនុស្សមានបំណងទាមទារកិត្តិយសដ៏ថ្លៃថ្នូរឃាត់មិនបាន។

## ២៧- ការគោរពជាបុគ្គលម្នាក់ៗ

ក. មហាសន្និបាតនឹកដល់ផលនៃគំនិតទាំងនោះ ជាគោលដែលត្រូវអនុវត្តតាម និងដែលមានលក្ខណៈបន្ទាន់

យ៉ាងពិសេស គឺមហាសន្និបាតគូសសង្កត់លើការគោរពបុគ្គលម្នាក់ៗ។ សូមឲ្យម្នាក់ៗរាប់អ្នកដទៃ ទុកជា *"រូបខ្លួនឯង"* ដោយគ្មានរើសអើងនរណាមួយឡើយ គឺសូមនឹកគិតដល់ការរស់នៅរបស់គេ នឹកគិតដល់អ្វីៗដែលគេត្រូវការ ដើម្បីមានជីវភាពយ៉ាងថ្លៃថ្នូរ (យក ២, ១៥.១៦)។ កុំយកតម្រាប់តាមអ្នកមានក្នុងគម្ពីរ ដែលមិនរវីរវល់នឹងអ្នកក្រីក្រ ឈ្មោះឡាសារ នោះ (លក ១៦, ១៩.៣១)។

ខ. ជាពិសេស សព្វថ្ងៃយើងមានភារកិច្ចដ៏សំខាន់បំផុត គឺក្លាយខ្លួនទៅជាបងប្អូនរបស់អ្នកដទៃទោះជានរណាក៏ដោយ។ ប្រសិនបើគេមកជួបយើង យើងក៏ត្រូវបម្រើគេយ៉ាងសកម្ម។ ប្រហែលអ្នកដទៃនោះ ជាមនុស្សចាស់ជរា ដែលគ្មាននរណាថែរក្សា ឬក៏ជាកម្មករបរទេស ដែលត្រូវគេមើលងាយដោយគ្មានមូលហេតុ ឬក៏ជាអ្នកដែលត្រូវគេនិរទេស ឬក៏ជាកូនឥតខាន់ស្លា ដែលទទួលផលអាក្រក់ពីកំហុស ដែលខ្លួនមិនបានប្រព្រឹត្ត ឬក៏ជាអ្នកស្រេកឃ្លាន ដែលដាស់តឿនមនសិការយើង ដោយរំឭកព្រះបន្ទូលរបស់ព្រះអម្ចាស់ថា *"គ្រប់ពេលដែលអ្នករាល់គ្នាបានប្រព្រឹត្តអំពើអ្វី ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនោះ ក៏ដូចជាអ្នករាល់គ្នាបានប្រព្រឹត្តចំពោះយើងដែរ"* (មថ ២៥, ៤០)។

គ. លើសពីនេះទៅទៀត ត្រូវរាប់អ្វីៗទាំងអស់ដែលប្រឆាំងនឹងជីវិតមនុស្ស ទុកជាការអាក្រក់បំផុត ដូចជាអំពើឃាតកម្មគ្រប់យ៉ាង មានការប្រល័យពូជសាសន៍ ការពន្លូតកូន ការជួយមនុស្សឲ្យចែកឋានយ៉ាងស្រួល និងការធ្វើអត្តឃាតខ្លួនឯង។ មានអ្វីៗទាំងអស់ដែលប៉ះពាល់នឹងរូបបុគ្គលម្នាក់ៗ គឺមានការកាត់អវៈយវៈខ្លះ ការធ្វើទារុណកម្មទាំងលើរូបកាយ ទាំងខាងវិញ្ញាណ មានការបង្ខិតបង្ខំខាងចិត្តគំនិតជាដើម។ មានអ្វីៗដែលបណ្ដាលឲ្យកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សត្រូវរបួស គឺមានជីវភាពរស់នៅមិនសមនឹងឋានៈជាមនុស្ស មានការដាក់ពន្ធនាគារដោយគ្មានមូលហេតុ មានការជម្លៀសប្រជាជន ការចាប់ជំរិតធ្វើជាទាសករ ការធ្វើពេស្យាចារ ជំនួញមនុស្សស្រី និងកុមារ។ មានអំពើរំលោភបំពានលើកម្លាំងពលកម្ម បណ្ដាលឲ្យមនុស្សធ្លាក់ជាគ្រឿងឧបករណ៍សម្រាប់ពួកមូលធនតែប៉ុណ្ណោះ ដោយមិនគិតដល់បុគ្គលិកលក្ខណៈរបស់គេ ជាមនុស្សប្រកបដោយសេរីភាព និងអាចទទួលការខុសត្រូវបាន។ អំពើទាំងនេះ និងអំពើប្រហែលនឹងការទាំងនេះ សុទ្ធតែជាការអាក្រក់ គួរឲ្យខ្ពើមរអើម។ អំពើទាំងនោះបង្ខូចអរិយធម៌ផង និងបង្អាប់បង្អោនកិត្តិយសដ៏ថ្លៃថ្នូររបស់អ្នកប្រព្រឹត្តផង ខ្លាំងជាងបង្អាប់បង្អោនកិត្តិយសអ្នកដែលរងគ្រោះ។ អ្នកប្រព្រឹត្តអំពើទាំងនោះ ក៏ប្រមាថមើលងាយសេរីរុងរឿងរបស់ព្រះអាទិករដែរ។

## ២៨- ការគោរពនិងការស្រឡាញ់ខ្មាំងសត្រូវ

ក. យើងត្រូវគោរពនិងស្រឡាញ់ អស់អ្នកដែលគិតនិងប្រព្រឹត្តតាមរបៀបប្លែកពីយើង ក្នុងសង្គម ក្នុងវិស័យនយោបាយ ឬខាងសាសនាជាដើម។ ប្រសិនបើយើងខិតខំយល់ចិត្តគំនិតរបស់គេ គឺខិតខំយល់ទស្សនៈរបស់គេពីខាងក្នុងកាន់តែជ្រៅទៅៗ ដោយចិត្តមេត្តានិងដោយសេចក្ដីស្រឡាញ់ យើងមុខជានឹងសន្ទនាជាមួយគេ កាន់តែស្រួលដែរ។

ខ. តាមពិត មិនត្រូវឲ្យសេចក្ដីស្រឡាញ់និងចិត្តមេត្តាចំពោះគេ ជំរុញឲ្យយើងមិនរវីរវល់នឹងប្រកាសសេចក្ដីពិត និងទូន្មានឲ្យគេធ្វើអំពើល្អនោះទេ។ ផ្ទុយទៅវិញ សេចក្ដីស្រឡាញ់នេះ ជំរុញសាវ័ករបស់ព្រះគ្រីស្តឲ្យប្រកាសសេចក្ដីពិត ដែលសង្គ្រោះមនុស្សទាំងអស់។ យើងត្រូវលះបង់ចោលកំហុសជានិច្ច ក៏ប៉ុន្តែ ត្រូវរែក

ញែកឲ្យដាច់រវាងកំហុស និងបុគ្គល។ ទោះបីគេភាន់ច្រឡំក្តី សូម្បីតែគេយល់ខុស ឬយល់មិនគ្រប់គ្រាន់អំពីសាសនាក្តី ក៏គេនៅតែមានកិត្តិយសដ៏ថ្លៃថ្នូររបស់ខ្លួន ជាបុគ្គលម្នាក់ជានិច្ច។ មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ដែលវិនិច្ឆ័យ និងស្ទង់ចិត្តគំនិតមនុស្ស។ ហេតុនេះ ព្រះអង្គហាមយើងមិនឲ្យវិនិច្ឆ័យ ដាក់ទោសលើចិត្តគំនិតរបស់នរណាម្នាក់ឡើយ (លក ៦, ៣៧-៣៨; មថ ៧, ១-១២; រម២, ១-១១ និង ១៤, ១០-១២)។

គ. ព្រះគ្រីស្តប្រៀនប្រដៅ រហូតដល់សូមឲ្យយើងអង្វរព្រះជាម្ចាស់លើកលែងទោសឲ្យអ្នកដែលធ្វើបាបយើង (មថ ៥, ៤៣-៤៧) និងលាតត្រដាងវិន័យអំពីសេចក្តីស្រឡាញ់ ជាវិន័យនៃសម្ពន្ធមេត្រីថ្មី រហូតដល់ស្រឡាញ់ខ្មាំងសត្រូវទាំងអស់ទៅទៀត គឺថា *"អ្នករាល់គ្នាធ្លាប់ឮសេចក្តីថ្លែងទុកមកថា៖ ចូរស្រឡាញ់បងប្អូនឯទៀតៗ ហើយស្អប់ខ្មាំងសត្រូវរបស់អ្នក។ រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យអស់អ្នក ដែលបៀតបៀនអ្នករាល់គ្នាផង"* (មថ ៥, ៤៣-៤៤)។

## ២៩- មនុស្សស្មើគ្នាទាំងអស់

ក. មនុស្សទាំងអស់ សុទ្ធតែមានវិចារណញ្ញាណ។ ព្រះជាម្ចាស់ប្រតិស្ឋានមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គ។ គេមានសភាពតែមួយ និងដើមកំណើតតែមួយដែរ។ ព្រះគ្រីស្តបានរំដោះគេទាំងអស់គ្នា។ ព្រះជាម្ចាស់ក៏កំណត់ឲ្យជីវិតមនុស្សមានទិសដៅតែមួយ និងមានវាសនាតែមួយដែរ។ ហេតុនេះហើយ បានជាយើងត្រូវទទួលស្គាល់ ហើយក៏ត្រូវទទួលស្គាល់ ឲ្យកាន់តែច្បាស់ឡើងថា មនុស្សស្មើគ្នាទាំងអស់។

ខ. តាមពិត ប្រសិនបើយើងមើលសមត្ថភាពខាងរូបកាយដែលប្លែកពីគ្នា កម្លាំងប្រាជ្ញានិងកម្លាំងសីលធម៌ដែលប្លែកពីគ្នា យើងមុខជាដឹងថា មនុស្សទាំងអស់មិនស្មើគ្នាទេ។ ក៏ប៉ុន្តែ ចំពោះសិទ្ធិមនុស្សដ៏សំខាន់ៗមិនត្រូវប្រកាន់គ្នា គឺមិនត្រូវប្រកាន់វណ្ណៈឋានៈ កម្រិតវប្បធម៌ ភេទ ជាតិសាសន៍ ពណ៌សម្បុរជីវភាព ភាសា ឬសាសនាសោះឡើយ។ ត្រូវពុះពារនិងបំបាត់ការប្រកាន់ទាំងនោះ ដែលផ្ទុយនឹងគម្រោងការរបស់ព្រះជាម្ចាស់។ គួរឲ្យស្តាយណាស់ដោយឃើញថា សិទ្ធិមនុស្សមិនទាន់មានការធានានៅគ្រប់កន្លែងនៅឡើយ។ ឧបមាថា បើស្ត្រីគ្មានសិទ្ធិជ្រើសរើសគូស្រករបស់ខ្លួនដោយសេរី គ្មានសិទ្ធិជ្រើសរើសរបៀបរស់នៅ ទទួលការសិក្សា និងមានវប្បធម៌ស្មើនឹងបុរស ពេលនោះការរំលោភសិទ្ធិលេចចេញមកហើយ។

គ. លើសពីនេះទៅទៀត ទោះបីមនុស្សប្លែកពីគ្នាយ៉ាងណាក្តី ក៏មនុស្សមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នា ហេតុនេះត្រូវទាមទារឲ្យមនុស្សមានជីវភាពត្រឹមត្រូវតាមយុត្តិធម៌ និងតាមលក្ខណៈរបស់ខ្លួនជាមនុស្សកាន់តែខ្លាំងឡើងៗ។ សភាពការណ៍សេដ្ឋកិច្ច ឬសភាពការណ៍ក្នុងសង្គមមានគម្លាតគ្នា ហួសហេតុពេកក្នុងចំណោមសមាជិកនៃប្រជាជាតិមួយ ឬក្នុងចំណោមប្រជាជាតិនានា ដែលចូលរួមក្នុងមហាគ្រួសារតែមួយរបស់មនុស្សជាតិ ពិតជាបណ្តាលឲ្យទាស់ចិត្តគំនិត និងរារាំងយុត្តិធម៌ក្នុងសង្គម រារាំងសមធម៌ ប្រឆាំងនឹងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ប្រឆាំងនឹងសន្តិភាពក្នុងសង្គមជាតិនិងអន្តជាតិ។

ឃ. សូមឲ្យស្ថាប័ន ទាំងឯកជន ទាំងសាធារណៈ ខិតខំបម្រើកិត្តិយសដ៏ថ្លៃថ្នូរ និងបម្រើទិសដៅនៃជីវិតមនុស្សដែលព្រះជាម្ចាស់បានកំណត់ទុកមក។ នៅពេលជាមួយគ្នានេះ សូមឲ្យស្ថាប័នទាំងអស់ប្រយុទ្ធយ៉ាងសកម្ម

ប្រឆាំងនឹងភាពជាទាសករគ្រប់យ៉ាង ទាំងក្នុងសង្គម ទាំងខាងនយោបាយ។ សូមធានារ៉ាប់រងសិទ្ធិមនុស្ស នៅគ្រប់របបនយោបាយ។ ទោះបីត្រូវចំណាយពេលវេលាយ៉ាងយូរក្តី ដើម្បីឈានទៅដល់ទីដៅ ដែលយើងចង់បាននោះ ស្ថាប័នទាំងប៉ុន្មានរបស់មនុស្សត្រូវតែតបឆ្លើយបន្តិចម្តងៗ នឹងសេចក្តីខាងវិញ្ញាណដែលប្រសើរជាងគេទាំងអស់។

## ៣០- ត្រូវកាន់សីលធម៌រួម

ក. ពិភពលោកផ្លាស់ប្រែយ៉ាងខ្លាំងនិងយ៉ាងលឿន។ ការផ្លាស់ប្តូរនេះទាមទារយ៉ាងខ្លាំងសូមកុំឲ្យនរណាម្នាក់ស្កប់ចិត្តនឹងសីលធម៌សម្រាប់តែបុគ្គលម្នាក់ៗឡើយ តែសូមម្នាក់ៗឲ្យយកចិត្តទុកដាក់នឹងការប្រែប្រួលក្នុងពិភពលោកវិញ។ មនុស្សម្នាក់ៗជួយដល់ប្រយោជន៍រួមតាមសមត្ថភាពរៀងៗខ្លួន ដោយគិតគូរដល់សេចក្តីត្រូវការរបស់អ្នកដទៃ។ បើគេយកចិត្តទុកដាក់យ៉ាងពិតប្រាកដ ឲ្យស្ថាប័នសាធារណៈ ឬស្ថាប័នឯកជនចម្រើនឡើង ជាពិសេសស្ថាប័នដែលមានគោលដៅ ធ្វើឲ្យជីវភាពមនុស្សកាន់តែប្រសើរឡើង ពេលនោះ គេពិតជាបំពេញភារកិច្ចរបស់ខ្លួនក្នុងការរកយុត្តិធម៌ និងសម្តែងសេចក្តីស្រឡាញ់មែន។ ផ្ទុយទៅវិញមានមនុស្សមួយចំនួនប្រកាសថា ខ្លួនមានគំនិតទូលំទូលាយ និងសប្បុរសតែគេបែរជាមិនរវីរវល់នឹងសាមគ្គីភាពក្នុងសង្គមសោះ។ លើសពីនេះទៅទៀត ក្នុងប្រទេសខ្លះ មនុស្សជាច្រើនមិនរវីរវល់អនុវត្តតាមច្បាប់ និងបញ្ញត្តិជារបស់សង្គមទេ។ មនុស្សជាច្រើនមិនញញើតក្នុងការបន្លំ ឬរកឧបាយកលផ្សេងៗ ដើម្បីឲ្យរួចផុតពីការបង់ពន្ធដារ ឬឲ្យបានរួចពីបំណុលរួមរបស់រដ្ឋ។ មានអ្នកខ្លះទៀតធ្វេសប្រហែស មិនព្រមគោរពតាមច្បាប់ណែនាំ ការរស់នៅក្នុងសង្គម មានច្បាប់អំពីការរក្សាសុខុមាលភាព នៃរចនាសម្ព័ន្ធសុខាភិបាល ច្បាប់ចរាចរ។ល។ ដោយធ្វេសប្រហែលមិនគិតគូរដូច្នេះ គេបណ្តាលឲ្យទាំងជីវិតគេទាំងជីវិតអ្នកដទៃ អាចជួបប្រទះនឹងគ្រោះថ្នាក់បាន។

ខ. សូមឲ្យមនុស្សគ្រប់ៗគ្នា យកចិត្តទុកដាក់ជាខ្លាំងនឹងរាប់ការសាមគ្គីផ្សេងៗក្នុងសង្គម ទុកជាភារកិច្ចចម្បងដ៏សំខាន់របស់ខ្លួននាបច្ចុប្បន្នកាល ព្រមទាំងគោរពតាមការសាមគ្គីទាំងនោះផង។ ពិភពលោកកាន់តែរួមគ្នាឡើងៗយ៉ាងណា ភារកិច្ចរបស់មនុស្សជាក់ច្បាស់លាតត្រដាងហួសពីក្រុមតូចៗ គឺត្រូវលាតសន្ធឹងបន្តិចម្តងៗ ទៅពិភពលោកទាំងមូលយ៉ាងនោះដែរ។ ពិភពលោកអាចរួមជាធ្លុងតែមួយបាន លុះត្រាតែបុគ្គល និងក្រុមនីមួយៗគិតគូរដល់សីលធម៌និងដល់សង្គម ព្រមទាំងផ្សព្វផ្សាយគំនិតទាំងនោះនៅជុំវិញខ្លួន។ នៅពេលនោះ ដោយមានព្រះជាម្ចាស់ប្រោសប្រណីជួយឧបត្ថម្ភផង មានមនុស្សថ្មីយ៉ាងពិតប្រាកដមុខជានឹងកើតឡើង គឺជាអ្នកកសាងមនុស្សលោកថ្មី។

## ៣១- ការទទួលខុសត្រូវ

ក. ត្រូវយកចិត្តទុកដាក់អភិវឌ្ឍន៍វប្បធម៌ ដោយប្រើមធ្យោបាយដ៏ធំៗជាច្រើន ដែលមនុស្សលោកមានសព្វថ្ងៃ ដើម្បីឲ្យម្នាក់ៗ អាចទទួលខុសត្រូវចំពោះខ្លួនឯង និងចំពោះក្រុមផ្សេងៗដែលខ្លួនជាសមាជិកនោះ។ ជាបឋមត្រូវចាត់ចែងការអប់រំយុវជន ទោះជាមានឋានៈ វណ្ណៈណាក្តីក្នុងសង្គម ដើម្បីឲ្យអាចបង្កើតធនធានមនុស្សទាំងបុរសទាំងស្ត្រី មិនគ្រាន់តែឲ្យគេមានចំណេះច្រើនប៉ុណ្ណោះទេ តែឲ្យគេមានបុគ្គលិកលក្ខណៈរឹងប៉ឹង ដ្បិតសម័យឥឡូវត្រូវការមនុស្សបែបនេះយ៉ាងខ្លាំងជាងគេ។

ខ. ប៉ុន្តែ មនុស្សពិបាកនឹងមានគំនិតទទួលខុសត្រូវខ្ពស់បែបនេះណាស់។ គេត្រូវមានជីវភាពល្មម ដែលសម នឹងឲ្យគេដឹងអំពីតម្លៃដ៏ថ្លៃថ្នូររបស់ខ្លួន និងឲ្យគេអាចតបឆ្លើយនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយ បម្រើព្រះអង្គ និងបម្រើមនុស្សដូចគ្នា អស់ពីសមត្ថភាព។ ជាញឹកញាប់ ពេលណាមនុស្សធ្លាក់ខ្លួនជាអ្នក ក្រីក្រទុរគតខ្លាំងពេក សេរីភាពរបស់គេក៏ចុះអន់ថយ។ ពេលមនុស្សបណ្តោយខ្លួន ទៅតាមសម្រួលពេក សេរីភាពរបស់គេក៏ចុះអន់ថយដែរ គឺគេគិតតែពីខ្លួនឯងមិនរវីរវល់នឹងអ្នកដទៃសោះ។ ផ្ទុយទៅវិញ ពេល មនុស្សរស់នៅដោយសុខចិត្តទទួលការបង្ខិតបង្ខំពីសង្គម ព្រោះជៀសវាងមិនបាន និងសុខចិត្តទទួល កាតព្វកិច្ចជាច្រើន ដោយរួមសាមគ្គីជាមួយមនុស្សឯទៀត ហើយប្តេជ្ញាបម្រើសហគមន៍មនុស្ស នៅពេល នោះ សេរីភាពរបស់គេក៏កាន់តែរឹងប៉ឹងឡើង ៗទៅវិញ។

គ. ហេតុនេះ ត្រូវដាស់តឿនមនុស្សទាំងអស់ ឲ្យមានបំណងចង់រួមចំណែកក្នុងកិច្ចការរួម។ ត្រូវសរសើរ ប្រជាជាតិខ្លះ ដែលនាំប្រជាពលរដ្ឋជាច្រើនឲ្យរួមចំណែកក្នុងកិច្ចការរដ្ឋ ដោយមានសេរីភាពយ៉ាងពិត ប្រាកដ។ ក៏ប៉ុន្តែ ត្រូវនឹកដល់សភាព ការណ៍ប្រជាជននីមួយ ៗ និងនឹកគិតថា រដ្ឋអំណាចក៏ត្រូវកាន់អំណាច យ៉ាងរឹងមាំដែរ។ ត្រូវឲ្យប្រជាពលរដ្ឋទាំងអស់យល់ថា ក្រុមទាំងប៉ុន្មានក្នុងសង្គមកាន់ តាមឧត្តមគតិ ដែល ទាក់ទាញចិត្តគេ គឺឲ្យបម្រើប្រជាពលរដ្ឋដូចគ្នា ទើបប្រជាពលរដ្ឋទាំងអស់ មានបំណងចង់រួមចំណែកក្នុង ការរស់នៅរបស់ក្រុមទាំងនោះ។ គួរឲ្យនឹកយ៉ាងត្រឹមត្រូវថា អនាគតអាស្រ័យលើអស់អ្នក ដែលផ្តល់ឲ្យ មនុស្សតំណក្រោយ ៗ ឲ្យគេមានមូលហេតុចង់រស់តទៅទៀត និងមានសេចក្តីសង្ឃឹម។

## ៣២- ព្រះបន្ទូលប្រសូតជាមនុស្ស និងសាមគ្គីជាមួយមនុស្ស

ក. ព្រះជាម្ចាស់ប្រតិស្ឋានមនុស្ស ឲ្យរស់នៅរួមគ្នាក្នុងសង្គម មិនឲ្យរស់នៅម្នាក់ឯងទេ។ យ៉ាងណាមិញ *"ព្រះអង្គក៏មិនសព្វព្រះហឫទ័យឲ្យមនុស្សបានវិសុទ្ធនិងសង្គ្រោះគេម្នាក់ៗ ដោយគ្មានចំណងទាក់ទង ជាមួយអ្នកដទៃទៅវិញទៅមកនោះទេ តែព្រះអង្គសព្វព្រះហឫទ័យតែងតាំងឲ្យមនុស្សទៅជាប្រជាជនមួយ ដែលនឹងស្គាល់ព្រះអង្គតាមសេចក្តីពិត និងបម្រើព្រះអង្គយ៉ាងវិសុទ្ធ"* (ពន្លឺ ៩)។ ហេតុនេះ តាំងពីដើម ប្រវត្តិសាស្ត្រនៃការសង្គ្រោះ ព្រះអង្គបានជ្រើសរើសមនុស្ស មិនមែនជាបុគ្គលដោយឡែកពីគេទេ តែទុកជា សមាជិកនៃសហគមន៍មួយ។ ព្រះជាម្ចាស់ក៏បានសម្តែងគម្រោងការរបស់ព្រះអង្គ ឲ្យក្រុមអ្នកដែលទ្រង់ ជ្រើសរើសបានស្គាល់ និងហៅគេថា *"ប្រជារាស្ត្ររបស់ព្រះអង្គ"* (ដណ ៣, ៧.១២)។ ព្រះអង្គក៏ចងសម្ពន្ធ មេត្រី ជាមួយប្រជាជននោះ នៅលើភ្នំស៊ីណៃទៀតផង (ដណ ២៤,១,៨)។

ខ. ព្រះយេស៊ូគ្រីស្តប្រព្រឹត្តស្នាព្រះហស្ត ដែលបង្រៀនលក្ខណៈរបស់មនុស្ស ជាសង្គមយ៉ាងពេញលេញ។ ព្រះ បន្ទូលប្រសូតជាមនុស្សផ្ទាល់ ទ្រង់សព្វព្រះហឫទ័យចូលរួមសាមគ្គីក្នុងសង្គមនោះ។ ព្រះអង្គចូលរួមក្នុង ពិធីមង្គលការនៅភូមិកាណា ព្រះអង្គសូមទៅទទួលទាននៅផ្ទះលោកសាខេ ទ្រង់រួមតុជាមួយក្រុមអ្នក ទារពន្ធ និងអ្នកបាប។ ព្រះអង្គបានសម្តែងព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា និងភាពដ៏ប្រសើរបំផុត នៃជីវិតរបស់មនុស្ស តាមព្រះជាម្ចាស់បានកំណត់ទុក ដោយលើកយកកិច្ចការសាមញ្ញធម្មតានៃការរស់ នៅក្នុងសង្គម ព្រមទាំងលើកយកនិមិត្តរូប ពីការរស់នៅប្រចាំថ្ងៃរបស់គេមកនិយាយ។ ព្រះអង្គបានប្រោស ឲ្យចំណងនានារបស់មនុស្សបានវិសុទ្ធ ជាពិសេសចំណងនានា ក្នុងក្រុមគ្រួសារជាប្រភពនៃការរស់នៅក្នុង សង្គម។ ព្រះអង្គក៏សព្វព្រះហឫទ័យអនុវត្តតាមច្បាប់មាតុភូមិរបស់ព្រះអង្គ។ ព្រះអង្គ ក៏សព្វព្រះហឫទ័យ

ប្រកបអាជីវកម្មជាជាង តាមរបៀបមនុស្សនៅសម័យ និងនៅតំបន់ព្រះអង្គរស់នៅ។

គ. ពេលព្រះយេស៊ូសម្តែងធម្មទេសនា ព្រះអង្គបានប្រកាសយ៉ាងច្បាស់ថា បុត្រធីតារបស់ព្រះជាម្ចាស់ត្រូវតែរស់នៅជាមួយគ្នាដូចបងប្អូនបង្កើត។ ពេលព្រះអង្គអធិដ្ឋាន ទ្រង់សូមឲ្យសាវ័កទាំងអស់រួបរួមគ្នា ជាអង្គតែមួយ។ លើសពីនេះទៅទៀត ព្រះអង្គបានបូជាព្រះជន្ម ដើម្បីរំដោះមនុស្សទាំងអស់។ ព្រះអង្គមានព្រះបន្ទូលថា *"គ្មាននរណាមានសេចក្តីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូប្តូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ"* (យហ ១៥, ១៣)។ ព្រះអង្គក៏បញ្ជាឲ្យក្រុមគ្រីស្តទូត ទៅប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ ដើម្បីឲ្យមនុស្សជាតិទាំងមូល ត្រឡប់ទៅជាមហាគ្រួសាររបស់ព្រះជាម្ចាស់។ ក្នុងមហាគ្រួសារនោះ សេចក្តីស្រឡាញ់នឹងទៅជាធម្មវិន័យយ៉ាងពេញលក្ខណៈ។

ឃ. ព្រះយេស៊ូជារៀមច្បងក្នុងបណ្តាបងប្អូនជាច្រើន។ ក្រោយពីព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គបានប្រទានព្រះវិញ្ញាណរបស់ព្រះអង្គ។ នៅពេលនោះ ព្រះអង្គតែងតាំងឲ្យអស់អ្នក ដែលទទួលព្រះអង្គដោយផ្ញើជីវិតលើព្រះអង្គ និងដោយមានចិត្តស្រឡាញ់ រួបរួមគ្នាទុកជាបងប្អូនតាមរបៀបថ្មី គឺរួបរួមគ្នាជាព្រះកាយផ្ទាល់របស់ព្រះអង្គជាព្រះសហគមន៍។ ក្នុងព្រះកាយនោះ យើងទាំងអស់គ្នាជាសរីរាង្គរបស់គ្នាទៅវិញទៅមក យើងក៏ត្រូវជួយគ្នា ទៅវិញទៅមកតាមព្រះអំណោយទានផ្សេងៗ ដែលយើងបានទទួលដែរ។

ង. សាមគ្គីភាពនេះត្រូវតែចម្រើនឡើងជាលំដាប់ជានិច្ច រហូតដល់បានពេញលេញ នៅថ្ងៃដែលព្រះជាម្ចាស់ប្រណីសន្តោសសង្គ្រោះមនុស្សទាំងអស់ ហើយពេលនោះមនុស្សទាំងអស់ ទៅជាមហាគ្រួសារដ៏ជាទីស្រឡាញ់របស់ព្រះអង្គ និងរបស់ព្រះគ្រីស្តជារៀមច្បង ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតាយ៉ាងពេញលក្ខណៈ។

# ជំពូក ៣

## សកម្មភាពរបស់មនុស្សក្នុងពិភពលោក

### ៣៣- អារម្ភកថា

ក. តាំងពីដើមរៀងមក មនុស្សចេះតែខិតខំធ្វើការនិងប្រើប្រាជ្ញារបស់ខ្លួន ដើម្បីឲ្យជីវិតកាន់តែចម្រើនឡើង។ ប៉ុន្តែសព្វថ្ងៃ ដោយវិទ្យាសាស្ត្រនិងបច្ចេកទេសជួយផង មនុស្សលោកក្លាយទៅជាម្ចាស់លើធម្មជាតិស្ទើរតែទាំងស្រុង ហើយនៅតែបន្តពង្រីកអំណាចរបស់ខ្លួនជានិច្ច។ ដោយប្រជាជាតិទាំងឡាយនៅលើពិភពលោក មានមធ្យោបាយកាន់តែច្រើនឡើង ចែករំលែកអ្វីៗគ្រប់យ៉ាងឲ្យគ្នាទៅវិញទៅមក មហាគ្រួសាររបស់មនុស្ស ទទួលស្គាល់ថា ខ្លួនជាសហគមន៍តែមួយ ដែលតែងតាំងឡើងក្នុងលោកនេះ។ ហេតុនេះ សព្វថ្ងៃមនុស្ស ចេះតែបង្កើតទ្រព្យសម្បត្តិជាច្រើន ជាសម្បត្តិដែលកាលពីមុន មនុស្សរង់ចាំដោយបន់ស្រន់ សូមពីថាមពលនៃទេវលោក។

ខ. ក្នុងចំណោមមនុស្សជាតិ ដោយឃើញកិច្ចការដ៏អស្ចារ្យនោះ លាតន្ទឹងក្នុងពិភពលោកទាំងមូលរួចហើយមាន មនុស្សជាច្រើននាំគ្នាសួរសំណួរផ្សេងៗ ឧបមាថា តើសកម្មភាពដ៏ឧឡារិកបែបនេះមានអត្ថន័យ និងតម្លៃអ្វី? តើត្រូវយកទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកទាំងនេះធ្វើអ្វី? តើមនុស្សម្នាក់ៗឬមនុស្សរួមគ្នា ខិតខំប្រឹងប្រែង ដើម្បីធ្វើអ្វី? ព្រះសហគមន៍បានទទួលបញ្ញើនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយយោងគោលការណ៍ខាង សាសនា និងខាងសីលធម៌ពីព្រះបន្ទូលនេះ មកស្វែងរកចម្លើយនៃសំណួរទាំងនោះ។ តែព្រះសហគមន៍គ្មាន ចម្លើយតបឆ្លើយភ្លាមៗនឹងសំណួរនីមួយៗនោះទេ ក៏ប៉ុន្តែ ព្រះសហគមន៍មានបំណងចង់នាំពន្លឺនៃសេចក្តី ដែលព្រះជាម្ចាស់បានសម្តែងមក ឲ្យចូលរួមជាមួយបទពិសោធន៍របស់មនុស្សលោកទាំងមូល ដើម្បីបំភ្លឺ មនុស្សជាតិដែលទើបចាប់ផ្តើមឈាងចូលតាមផ្លូវនេះ។

### ៣៤- តម្លៃដ៏ថ្លៃថ្នូរនៃសកម្មភាពរបស់មនុស្ស

ក. គ្រីស្តបរិស័ទដឹងជាក់ច្បាស់ថា សកម្មភាពរបស់មនុស្សលោក ទាំងសកម្មភាពបុគ្គលក្តី ទាំងសកម្មភាពរួមក្តី គឺ ការខិតខំប្រឹងប្រែងដ៏សម្បើមអស្ចារ្យ តាំងពីយូរសតវត្សតៗមក បណ្តោយឲ្យជីវភាពមនុស្សកាន់តែ ប្រសើរឡើងៗ។ ការណ៍នេះ ពិតជាស្របតាមគម្រោងការរបស់ព្រះជាម្ចាស់មែន។ ព្រះជាម្ចាស់បាន ប្រតិស្ឋានមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គ។ ព្រះអង្គក៏ប្រទានបេសកកម្មឲ្យមនុស្សគ្រប់គ្រងផែនដី និង អ្វីៗ ដែលនៅលើផែនដី ព្រមទាំងឲ្យ *"ត្រួតត្រាពិភពលោកដោយភាពវិសុទ្ធ និងសុចរិតតាមយុត្តិធម៌"* (កណ ១, ២៦-២៧; ៩, ២-៣; ប្រា ៩, ២-៣)។ ដោយទទួលស្គាល់ព្រះជាម្ចាស់ទុកជាព្រះអាទិករនៃ អ្វីៗទាំងអស់ មនុស្សអាចចាត់ទុកព្រះអង្គជាប្រភពនៃជីវិតរបស់ខ្លួន និងជាដើមកំណើតនៃពិភពលោក

ទាំងមូល។ ធ្វើដូច្នេះ ដោយអ្វីៗទាំងអស់ចុះចូលក្រោមអំណាចរបស់មនុស្ស *"ព្រះនាមព្រះអង្គថ្កុំថ្កើងរុងរឿង ពាសពេញលើផែនដីទាំងមូល"* (ទន ៨, ៧ និង ១០)។

ខ. សេចក្តីប្រៀនប្រដៅនេះ ក៏មានសារៈសំខាន់ចំពោះសកម្មភាពផ្សេងរបស់មនុស្សជារៀងរាល់ថ្ងៃដែរ។ ពេលបុរស និងស្ត្រីធ្វើការចិញ្ចឹមជីវិតរបស់ខ្លួន និងក្រុមគ្រួសារ ទាំងបំពេញកិច្ចការតាមរបៀបបម្រើសង្គម អ្នកទាំងនោះ អាចយល់ឃើញថា ការងាររបស់គេបន្តស្នាព្រះហស្តរបស់ព្រះអាទិករ គេបម្រើបងប្អូន និងខ្លួនគេផ្ទាល់ជួយឲ្យគម្រោង ការរបស់ព្រះជាម្ចាស់បានសម្រេច គឺគម្រោងការរបស់ព្រះអង្គ ដែលថែរក្សាការពារមនុស្សលោកតាមប្រវត្តិសាស្ត្រ។

គ. គ្រីស្តបរិស័ទយល់ឃើញថា មនុស្សប្រកបដោយប្រាជ្ញានិងដោយសេចក្តីក្លាហានមានជ័យជម្នះលើធម្មជាតិ មិនជំទាស់នឹងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ទេ គេក៏មិនចាត់ទុកថា មនុស្សជាសត្វលោក ប្រកបដោយប្រាជ្ញា ហាក់ដូចជាប្រកួតប្រជែងនឹងព្រះអាទិករដែរ។ ផ្ទុយទៅវិញគ្រីស្តបរិស័ទជឿជាក់ថា ជ័យជម្នះរបស់មនុស្សជាតិ ពិតជាសញ្ញាសម្គាល់បង្ហាញអំពីព្រះដ៏ឧត្តុង្គឧត្តម និងជាលទ្ធផលតាមគម្រោងការរបស់ព្រះអង្គ ដែលរកថ្លែងពុំបាន។ ប៉ុន្តែ អំណាចរបស់មនុស្សចម្រើនខ្លាំងឡើងយ៉ាងណា បុគ្គល ឬក្រុមក៏ទទួលការខុសត្រូវកាន់តែទូលំទូលាយយ៉ាងនោះដែរ។ សេចក្តីនេះ សរឲ្យយល់ឃើញថា ដំណឹងល្អដែលគ្រីស្តបរិស័ទប្រកាសនោះ មិនមែនបង្វែរគេមិនឲ្យកសាងពិភពលោកទេ ហើយក៏មិនមែនមិនឲ្យអើពើនឹងវាសនារបស់មនុស្សដូចគ្នាដែរ តែផ្ទុយទៅវិញដំណឹងល្អនោះ ជំរុញគ្រីស្តបរិស័ទឲ្យកសាងពិភពលោក និងចាប់អារម្មណ៍នឹងវាសនាមនុស្សដូចគ្នា ទុកជាកាតព្វកិច្ចជាបន្ទាន់ជាងគេ។

## ៣៥- សេចក្តីណែនាំសម្រាប់សកម្មភាពរបស់មនុស្ស

ក. សកម្មភាពរបស់មនុស្សហូរចេញមកពីមនុស្សយ៉ាងណា ក៏សកម្មភាពនោះ ស្ថិតនៅក្រោមអំណាចរបស់មនុស្សយ៉ាងនោះដែរ។ ពេលមនុស្សបំពេញសកម្មភាព គេមិនគ្រាន់តែប្រែវត្ថុនិងសង្គមប៉ុណ្ណោះទេ តែគេក៏ធ្វើឲ្យខ្លួនកាន់តែពេញលក្ខណៈដែរ។ គេរៀនសេចក្តីជាច្រើន គេពង្រឹងទេពកោសល្យរបស់ខ្លួន មិនគិតតែពីខ្លួនឯង ហើយបែរទៅគិតដល់សេចក្តី ដែលហួសពីខ្លួនថែមទៀតផង។ បើគេចេះណែនាំសម្ទុះនេះយ៉ាងត្រឹមត្រូវល្អ សម្ទុះនេះមានតម្លៃប្រសើរជាងទ្រព្យសម្បត្តិទាំងប៉ុន្មាននៅក្រៅខ្លួន ដែលគេសន្សំបាន។ តម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស អាស្រ័យលើបុគ្គលិកលក្ខណៈរបស់ខ្លួនជាជាងអាស្រ័យលើទ្រព្យសម្បត្តិ ដែលខ្លួនមាននោះ។ យ៉ាងណាមិញ អ្វីៗដែលមនុស្សប្រព្រឹត្ត ដើម្បីឲ្យមានយុត្តិធម៌កាន់តែច្រើនឡើងៗ ឲ្យមនុស្សរួបរួមគ្នា ជាបងប្អូនកាន់តែខ្លាំងឡើងៗ និងឲ្យបង្កើតទំនាក់ទំនងកាន់តែប្រកបដោយលក្ខណៈជាមនុស្សក្នុងសង្គមកាន់តែល្អឡើងៗ គឺការទាំងនោះ សុទ្ធតែមានតម្លៃដ៏ថ្លៃថ្នូរលើសពីការរីកចម្រើនខាងបច្ចេកទេសទៅទៀត។ ការចម្រើនខាងបច្ចេកទេសទាំងប៉ុន្មាន អាចជួយឲ្យមនុស្សមានមូលដ្ឋានជាសម្ភារៈសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស ប៉ុន្តែ បើមានតែការចម្រើនខាងបច្ចេកទេសប៉ុណ្ណោះ នោះធនធានមនុស្សមិនអាចចម្រើនបានឡើយ។

ខ. ហេតុនេះ សេចក្តីណែនាំសកម្មភាពរបស់មនុស្ស មានដូចតទៅ គឺ សកម្មភាពនោះ ត្រូវរកផលប្រយោជន៍ដ៏ពិតប្រាកដជូនមនុស្សជាតិ ស្របតាមគម្រោងការនិងតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សកម្មភាព

នោះ ត្រូវបណ្តោយឲ្យមនុស្ស ទោះក្នុងឋានៈជាបុគ្គលផ្ទាល់ ឬក្នុងឋានៈជាសមាជិកនៃសង្គមក្តី រីកចម្រើនឡើងយ៉ាងពេញលក្ខណៈតាមព្រះជាម្ចាស់ត្រាស់ហៅគេម្នាក់ៗ។

## ៣៦- អ្វីៗនៅលើផែនដីស្វយ័តយ៉ាងត្រឹមត្រូវ

ក. សព្វថ្ងៃមានមនុស្សជាច្រើននាំគ្នានឹកខ្លាចថា មិនត្រូវឲ្យសកម្មភាពរបស់មនុស្សនឹងសាសនា មានចំណងពេក ក្រែងចំណងដ៏ស្អិតល្មួតនេះ បណ្តាលឲ្យទាំងមនុស្ស ទាំងសង្គម ទាំងវិទ្យាសាស្ត្របាត់បង់ស្វ័យភាពរបស់ខ្លួន។

ខ. ប្រសិនបើគេយល់ថា អ្វីៗនៅលើផែនដីនេះ ប្រកបដោយស្វ័យភាព មានន័យថា សត្វលោកទាំងប៉ុន្មានដែលព្រះជាម្ចាស់ប្រតិស្ឋានមក ថែមទាំងសង្គមនានាផងដែរ មានក្បួនច្បាប់ផ្ទាល់ មានតម្លៃដ៏ថ្លៃថ្នូរផ្ទាល់ ហើយមនុស្សត្រូវតែរៀនឲ្យស្គាល់បន្តិចម្តងៗ នូវក្បួនច្បាប់ និងតម្លៃដ៏ថ្លៃថ្នូរទាំងនោះ ហើយក៏ត្រូវរៀនឲ្យចេះប្រើប្រាស់ និងឲ្យចេះចាត់ចែងទៀតផង។ ដូច្នេះ អ្នកស្វះស្វែងចង់បានស្វ័យភាពបែបនោះ ពិតជាត្រឹមត្រូវហើយ។ មិនគ្រាន់តែមនុស្សសម័យឥឡូវ ទាមទារស្វ័យភាពនោះប៉ុណ្ណោះទេ តែស្វ័យភាពនោះ ស្របតាមព្រះហឫទ័យរបស់ព្រះអាទិករថែមទៀតផង។ ដោយព្រះជាម្ចាស់ប្រតិស្ឋានអ្វីៗទាំងអស់ ព្រះអង្គក៏តែងតាំងអ្វីៗ ឲ្យនៅជាប់ស្ថិតស្ថេរតាមសេចក្តីពិត និងតាមតម្លៃដ៏ថ្លៃថ្នូររបស់អ្វីៗទាំងនោះផ្ទាល់។ អ្វីៗទាំងអស់ក៏ត្រូវបានចាត់ចែងឲ្យមានរបៀបរៀបរយ និងតាមក្បួនច្បាប់ពិសេសរបស់អ្វីៗទាំងនោះ។ មនុស្សត្រូវតែគោរពអ្វីៗទាំងនោះ ព្រមទាំងទទួលស្គាល់វិធីផ្ទាល់របស់វិទ្យាសាស្ត្រនីមួយៗ និងបច្ចេកទេសនីមួយៗដែរ។ ហេតុនេះហើយបានជា ការស្វែងរកតាមក្បួនវិធីក្នុងគ្រប់វិស័យនៃចំណេះដឹង មិនដែលជំទាស់នឹងជំនឿទេ លុះត្រាតែគេស្វែងរកតាមរបៀបជាវិទ្យាសាស្ត្រយ៉ាងពិតប្រាកដ និងត្រូវតាមវិន័យនៃសីលធ៌។ អ្វីៗដែលស្ថិតនៅក្នុងលោកនេះ និងជំនឿហូរចេញមកពីព្រះជាម្ចាស់តែមួយព្រះអង្គ ជាប្រភពតែមួយ។ លើសពីនេះទៅទៀត អ្នកខិតខំស្វែងរកការអាថ៌កំបាំងនៃវត្ថុទាំងអស់ដោយចិត្តព្យាយាមខន្តី និងដោយចិត្តសុភាពរាបសា ទោះបីអ្នកនោះមិនដឹងខ្លួនក្តី ក៏ព្រះជាម្ចាស់ណែនាំគេដែរ គឺព្រះអង្គដែលទ្រទ្រង់សត្វលោកទាំងអស់ និងប្រោសឲ្យសត្វលោកទាំងអស់ មានលក្ខណៈផ្ទាល់របស់ខ្លួន។ អំពីរឿងនេះ យើងនឹកស្តាយថា ជួនកាលមានគ្រីស្តបរិស័ទខ្លះកាលពីមុន មិនយល់អំពីស្វ័យភាពដ៏ត្រឹមត្រូវនៃវិទ្យាសាស្ត្រនោះ។ ឥរិយាបថគ្រីស្តបរិស័ទទាំងនោះ បណ្តាលឲ្យមនុស្សជជែកឈ្លោះប្រកែកគ្នា រហូតដល់នាំឲ្យអ្នកខ្លះយល់ឃើញថា វិទ្យាសាស្ត្រនិងជំនឿទាស់ទែងគ្នាទៀតផង។

គ. ក៏ប៉ុន្តែ ប្រសិនបើគេយល់ថា អ្វីៗនៅលើផែនដីនេះប្រកបដោយស្វ័យភាព មានន័យថាសត្វលោកទាំងប៉ុន្មាន មិននៅជាចំណុះរបស់ព្រះជាម្ចាស់ទេ ហើយស្មានថា មនុស្សអាចប្រើប្រាស់សត្វលោកទាំងនោះតាមតែអំពើចិត្ត ដោយមិនគិតដល់ព្រះអាទិកររបស់វា ប៉ុន្តែអស់អ្នកដែលទទួលស្គាល់ព្រះជាម្ចាស់មុខជានឹងដឹងភ្លាមថា ពាក្យទាំងនេះមិនត្រឹមត្រូវសោះ។ ប្រសិនបើគ្មានព្រះអាទិករប្រតិស្ឋានមក ក៏គ្មានសត្វលោកទៀតដែរ។ ម្យ៉ាងទៀត អស់អ្នកកាន់សាសនា ទោះបីសាសនាណាក៏ដោយ ក៏តែងតែឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ ដែលសម្តែងព្រះអង្គតាមរយៈសត្វលោកទាំងឡាយ។ អ្នកបំភ្លេចព្រះជាម្ចាស់ ក៏ពិបាកយល់អំពីតម្លៃសត្វលោកឲ្យបានច្បាស់ដែរ។

## ៣៧- អំពើបាបបានបន្ទូចសកម្មភាពរបស់មនុស្ស

ក. ស្របតាមបទពិសោធន៍របស់មនុស្សជាច្រើន សតវត្សកន្លងមកព្រះគម្ពីរប្រៀនប្រដៅមហាគ្រួសារ របស់មនុស្សថា ការអភិវឌ្ឍន៍បាននាំអ្វីៗដ៏ល្អយ៉ាងខ្លាំងសម្រាប់មនុស្ស ប៉ុន្តែ ក៏បាននាំការល្បួងយ៉ាងធ្ងន់ជាប់ជាមួយដែរ។ ពេលមនុស្សមិនយល់ច្បាស់ថា អ្វីជាបុណ្យអ្វីជាបាប អ្វីថ្លៃថ្នូរជាងគេ ហើយអ្វីថោកទាបជាងគេ នៅពេលបុណ្យ និងបាបលាយចូលគ្នា ពេលនោះទាំងបុគ្គល ទាំងក្រុមមនុស្សតែងតែគិតពីប្រយោជន៍ផ្ទាល់ខ្លួន មិនគិតដល់ប្រយោជន៍អ្នកដទៃទៀតទេ។ ហេតុនេះ ពិភពលោកលែងជាកន្លែងមនុស្សអាចរស់នៅដូចបងប្អូនយ៉ាងពិតប្រាកដទៀតហើយ។ នៅពេលជាមួយគ្នានោះ មនុស្សមាននអំណាចកាន់តែខ្លាំងឡើងៗ ដែលអាចបំផ្លាញមនុស្សលោកគ្នាឯងទៀតផង។

ខ. ប្រវត្តិសាស្ត្រមនុស្សលោកតាំងពីដើមរៀងមក សុទ្ធតែជាការប្រយុទ្ធដ៏សាហាវ ប្រឆាំងនឹងអំណាចនានានៃសេចក្ដីងងឹត។ ព្រះអម្ចាស់មានព្រះបន្ទូលមកយើងរួចហើយថា ការប្រយុទ្ធនេះ ចាប់ផ្ដើមតាំងពីដើមកំណើតពិភពលោករៀងមក នឹងនៅតែបន្តរហូត ដល់ថ្ងៃចុងក្រោយបំផុត (មថ ២៤, ១៣; ១៣, ២៤-៣០ និង ៣៦-៤៣)។ មនុស្សចូលក្នុងចម្បាំងនេះ ត្រូវតែប្រយុទ្ធ ដើម្បីភ្ជាប់ចិត្តនឹងសេចក្ដីល្អ។ មនុស្សអាចស្ងប់ក្នុងចិត្តបាន ក្រោយពីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង និងដោយព្រះជាម្ចាស់ប្រោសប្រណីទៀតផង។

គ. ហេតុនេះហើយ បានជាព្រះសហគមន៍របស់ព្រះគ្រីស្តទទួលស្គាល់ថា ការអភិវឌ្ឍន៍ធនធានមនុស្ស អាចបម្រើសុភមង្គលដ៏ពិតប្រាកដរបស់មនុស្សមែន ព្រះសហគមន៍ក៏ទុកចិត្តលើគម្រោងការរបស់ព្រះអាទិករដែរ។ ក៏ប៉ុន្តែ ព្រះសហគមន៍មិន អាចបំភ្លេចពាក្យប្រៀនប្រដៅរបស់គ្រីស្តទូតប៉ូលថា *"មិនត្រូវយកតម្រាប់តាមលោកីយ៍នេះឡើយ"* (រម ១២, ២) គឺថាកុំ យកតម្រាប់តាមអំណួតដ៏ឥតបានការ និងសេចក្ដីអាក្រក់ដែលប្រែសកម្មភាពរបស់មនុស្ស។ សកម្មភាពនោះ តម្រង់ទៅបម្រើព្រះជាម្ចាស់ និងបម្រើមនុស្ស តែសេចក្ដីអាក្រក់ ប្រែសកម្មភាពនោះ នាំឲ្យប្រព្រឹត្តអំពើបាបវិញ។

ឃ. មានគេសួរថា តើនរណាអាចឈ្នះទុក្ខបែបនេះបាន? គ្រីស្តបរិស័ទឆ្លើយថា អំណួតនិងសេចក្ដីស្រឡាញ់ហួសហេតុរបស់មនុស្សចំពោះខ្លួនឯង រៀងរាល់ថ្ងៃបណ្ដាលឲ្យសកម្មភាពទាំងនោះមិនដល់ទិសដៅមែន ប៉ុន្តែ ត្រូវការព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ជម្រះ និងនាំឲ្យសកម្មភាពទាំងនោះបានពេញលក្ខណៈ។ មនុស្សអាច (និង ត្រូវ) ស្រឡាញ់អ្វីៗទាំងនោះ ដែលព្រះជាម្ចាស់ប្រតិស្ឋានមក ព្រោះព្រះគ្រីស្តបានរំដោះគេ ហើយគេបានទៅជាសត្វលោកថ្មី ដោយរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ មនុស្សទទួលអ្វីៗទាំងនោះ ពីព្រះជាម្ចាស់ ហើយយល់ឃើញអ្វីៗទាំងនោះ ដូចជាផុះចេញពីព្រះហស្តរបស់ព្រះអង្គ និងគោរពអ្វីទាំងនោះទៀតផង។ គាត់អរព្រះគុណព្រះជាម្ចាស់ដែលប្រតិស្ឋានអ្វីៗទាំងអស់ ដោយព្រះហឫទ័យសប្បុរស គាត់ប្រើប្រាស់ និងបានអំណរដោយសារអ្វីទាំងនោះ ទាំងមានចិត្តគំនិតជាអ្នកក្រ និងដោយសេរីភាព។ នៅពេលនោះ គាត់ចូលទៅកាន់កាប់ពិភពលោកដ៏ពិតប្រាកដ ក្នុងឋានៈជាអ្នក ដែលគ្មានអ្វីសោះ តែតាមពិតបានអ្វីទាំងអស់ទុកជាកម្មសិទ្ធិរបស់ខ្លួន (២ករ ៦, ១០) *"អ្វីៗទាំងអស់សុទ្ធតែសម្រាប់បម្រើបងប្អូន។ រីឯបងប្អូនវិញ បងប្អូនបម្រើព្រះគ្រីស្តហើយព្រះគ្រីស្តក៏បម្រើព្រះជាម្ចាស់"* (១ករ ៣, ២២-២៣)។

## ៣៨- ព្រះគ្រីស្តដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង ធ្វើឲ្យសកម្មភាពរបស់មនុស្សបានពេញលក្ខណៈ

ក. ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើ។ ព្រះបន្ទូលបានប្រសូតជាមនុស្ស និងយាងមករស់នៅលើផែនដីរបស់មនុស្ស (យហ ១, ៣.១៤)។ ព្រះអង្គជាមនុស្សដ៏ពេញលក្ខណៈ យាងចូលក្នុងប្រវត្តិសាស្ត្រមនុស្សលោក ហើយលើកប្រវត្តិសាស្ត្រនេះ និងប្រមូលអ្វីៗទាំងអស់ឲ្យរួបរួមក្នុងអង្គព្រះគ្រីស្តជាសិរីសា (អភ ១, ១០)។ ព្រះអង្គសម្តែងឲ្យយើងដឹងថា *"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"* (១យហ ៤, ៨) ហើយនៅពេលជាមួយគ្នានោះ ព្រះអង្គបង្រៀនយើងថា វិន័យថ្មីអំពីសេចក្តីស្រឡាញ់ ពិតជាគ្រឹះនាំឲ្យមនុស្សបានពេញលក្ខណៈ និងនាំឲ្យផ្លាស់ប្រែពិភពលោកទៀតផង។ ដូច្នេះ ព្រះអង្គនាំឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះជាម្ចាស់ដែលស្រឡាញ់មនុស្សលោកជឿជាក់ថា មនុស្សទាំងអស់អាចដើរតាមមាគ៌ានៃសេចក្តីស្រឡាញ់នោះបាន ហើយការខិតខំប្រឹងប្រែងធ្វើឲ្យមនុស្សទូទាំងសកលលោក ទៅជាបងប្អូនគ្នា មិនមែនឥតបានការឡើយ។ ព្រះអង្គប្រៀនប្រដៅយើងទៀតថា សេចក្តីស្រឡាញ់នេះ មិនអាស្រ័យតែលើការអស្ចារ្យប៉ុណ្ណោះទេ តែសម្តែងចេញក្នុងកិច្ចការធម្មតា ក្នុងការរស់នៅប្រចាំថ្ងៃ។ ដោយព្រះអង្គសព្វព្រះហឫទ័យសោយទិវង្គតសម្រាប់យើងទាំងអស់គ្នា ជាអ្នកបាប (យហ ៣, ១៦; រម ៥, ៨-១០) ព្រះអង្គធ្វើជាគំរូ បង្រៀនឲ្យយើងដឹងថា អស់អ្នកដែលខិតខំរកយុត្តិធម៌និងសន្តិភាព ត្រូវផ្ទុកទុក្ខលំបាក មកពីភាពទន់ខ្សោយរបស់ខ្លួន និងមកពីពិភពលោកដូចជាយកឈើឆ្កាងមកដាក់លើស្មារដូច្នេះដែរ។ ព្រះបិតាបានតែងតាំងព្រះគ្រីស្ត ធ្វើជាព្រះអម្ចាស់ ដោយប្រោសព្រះអង្គឲ្យមានព្រះជន្មថ្មីដ៏រុងរឿង ព្រះបិតាក៏បានប្រទានឲ្យព្រះគ្រីស្ត មានគ្រប់អំណាចនៅលើផែនដី និងនៅស្ថានបរមសុខ (កក ២, ៣៦; មធ ២៨, ១៨)។ ឥឡូវនេះ ព្រះគ្រីស្តជាអម្ចាស់មានសកម្មភាពក្នុងចិត្តគំនិតមនុស្សលោក ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណព្រះអង្គ។ ព្រះអង្គមិនគ្រាន់តែដាស់តឿនមនុស្ស ឲ្យមានបំណងចង់ចូលនៅលោកខាងមុខប៉ុណ្ណោះទេ តែព្រះអង្គក៏ប្រោសឲ្យគេមានបំណងប្រាថ្នាដ៏សប្បុរស ដែលជំរុញមហាគ្រួសាររបស់មនុស្សលោក ឲ្យខិតខំធ្វើឲ្យជីវភាពរបស់គេកាន់តែសមនឹងលក្ខណៈជាមនុស្ស និងឲ្យគេត្រួតត្រាផែនដីទាំងមូលក្នុងគោលដៅនេះផង។ ព្រះវិញ្ញាណក៏ជម្រះហើយពង្រឹងបំណងដ៏សប្បុរសទាំងនោះថែមទៀត។ តាមពិតព្រះវិញ្ញាណប្រទានព្រះអំណោយទានផ្សេងៗពីគ្នា គឺព្រះអង្គត្រាស់ហៅមនុស្សខ្លះ ឲ្យប្រកាសយ៉ាងច្បាស់អំពីបំណងរបស់ខ្លួន ចង់ចូលដំណាក់នៃស្ថានបរមសុខ និងឲ្យគេផ្តល់សក្ខីភាពនេះយ៉ាងរស់រវើក ក្នុងមហាគ្រួសារមនុស្សលោក។ ព្រះអង្គក៏ត្រាស់ហៅមនុស្សឯទៀតៗ ឲ្យប្តេជ្ញាចិត្តបម្រើមនុស្សលោក នៅលើផែនដីនេះ គឺរៀបចំរបៀបរស់នៅក្រោមអំណាចរបស់ព្រះជាម្ចាស់ដែលគ្រងរាជ្យ ដោយសារមុខងារបម្រើនេះ។ ប៉ុន្តែ ព្រះអង្គប្រោសឲ្យមនុស្សទាំងអស់ ទៅជាមនុស្សប្រកបដោយសេរីភាព សុខចិត្តលះបង់អស្មិមានះចោល ប្រមូលថាមពលទាំងប៉ុន្មាននៅលើផែនដី មកបម្រើជីវិតមនុស្ស។ គេស្ទុះទៅរកអនាគតគឺទៅកាន់ពេលដែលមនុស្សជាតិនឹងក្លាយទៅជាតង្វាយដ៏គាប់ព្រះហឫទ័យព្រះជាម្ចាស់ (រម ១៥, ១៦)។

ខ. ព្រះអម្ចាស់ទុកព្រះអំណោយទានដំបូងនៃសេចក្តីសង្ឃឹមនេះ និងផ្តល់អាហារសម្រាប់ធ្វើដំណើរ គឺអគ្គសញ្ញាអរព្រះគុណ ជាអគ្គសញ្ញាបញ្ជាក់ជំនឿ។ ក្នុងអគ្គសញ្ញានោះ ធាតុនៃធម្មជាតិដែលមនុស្សបានដាំនិងថែទាំ ក្លាយទៅជាព្រះកាយនិងព្រះលោហិត ប្រកបដោយសិរីរុងរឿង។ ពិធីជប់លៀងរបស់បងប្អូនដែលរួបរួមគ្នា ជាប្រផ្នូលនៃពិធីជប់លៀងនៅស្ថានបរមសុខ។

## ៣៩- ផែនដីថ្មី និងផ្ទៃមេឃថ្មី

ក. យើងមិនដឹងអំពីផែនដី និងមនុស្សជាតិបានពេញលក្ខណៈចប់សព្វគ្រប់ទាំងអស់នៅពេលណាទេ (កក ១, ៧) យើងក៏មិនស្គាល់របៀបពិភពលោកត្រូវផ្លាស់ប្រែដែរ។ សភាពការណ៍ពិភពលោកនេះ ដែលត្រូវបានបង្ខូចដោយសារអំពើបាប នៅតែប្រែប្រួល (១ករ ៧, ៣១)។ ក៏ប៉ុន្តែ យើងបានរៀនថា ព្រះជាម្ចាស់រៀបចំដំណាក់ថ្មី និងផែនដីថ្មីសម្រាប់យើង ជាផែនដីដែលមានយុត្តិធម៌គ្រងរាជ្យ (២ករ ៥, ២; ២សល ៣, ១៣)។ បរមសុខនៅលើផែនដីថ្មីនោះ និងបំពេញយ៉ាងហួសប្រមាណនូវបំណងទាំងប៉ុន្មានរបស់មនុស្សដែលចង់បានសេចក្តីសុខសាន្ត (១ករ ២, ៩; វវ ២១, ៤-៥)។ នៅពេលនោះ សេចក្តីស្លាប់ចាញ់រួចហើយ បុត្រធីតារបស់ព្រះជាម្ចាស់ នឹងមានជីវិតថ្មីដ៏រុងរឿង រួមក្នុងអង្គព្រះគ្រីស្ត អ្វីៗដ៏ទន់ខ្សោយដែលរមែងតែងតែរលួយ ដែលព្រះជាម្ចាស់បានសាបព្រោះនោះ នឹងទទួលជីវិតថ្មីដែលមិនចេះរលួយ (១ករ ១៥, ៤២.៥៣)។ សេចក្តីស្រឡាញ់ និងកិច្ចការដែលមនុស្សបានប្រព្រឹត្តដោយសេចក្តីស្រឡាញ់ នឹងស្ថិតនៅ (១ករ ១៣, ៨-៣; ១៤) ហើយអ្វីៗទាំងអស់ ដែលព្រះអង្គប្រតិស្ឋានមក ដើម្បីជាប្រយោជន៍ដល់មនុស្ស នឹងត្រូវព្រះអង្គរំដោះឲ្យរួចផុតពីសេចក្តីវិនាសអន្តរាយ (រម ៨, ១៩.២១)។

ខ. យើងដឹងច្បាស់ថា បើមនុស្សម្នាក់បានពិភពលោកទាំងមូលមកធ្វើជាសម្បត្តិរបស់ខ្លួនតែត្រូវស្លាប់បាត់បង់ជីវិតនោះ តើមានប្រយោជន៍អ្វី (លក ៩, ២៥)។ ប៉ុន្តែ ការរង់ចាំផែនដីថ្មី មិនបណ្តាលឲ្យយើងមិនយកចិត្តទុកដាក់នឹងថែទាំផែនដីនេះទេ ផ្ទុយទៅវិញដាស់យើងឲ្យភ្ញាក់ឡើង ព្រោះព្រះកាយនៃគ្រួសារថ្មីរបស់មនុស្សនោះ ចម្រើនធំឡើងនៅលើផែនដីនេះ ហើយបង្ហាញការព្រាងអំពីលោកខាងមុខទៀតផង។ ហេតុនេះហើយ ត្រូវញែកឲ្យបានច្បាស់រវាងការអភិវឌ្ឍន៍ខាងផែនដី និងការចម្រើនខាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ក៏ប៉ុន្តែ ការអភិវឌ្ឍន៍ខាងផែនដី មានសារៈសំខាន់ជាខ្លាំងសម្រាប់ព្រះរាជ្យរបស់ជាម្ចាស់ គឺការអភិវឌ្ឍន៍នោះ អាចជួយចាត់ចែងរចនាសម្ពន្ធសង្គម ឲ្យមានលក្ខណៈជាមនុស្សកាន់តែប្រសើរឡើងៗ។

គ. តម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស ការរួបរួមគ្នាជាបងប្អូន និងសេរីភាព ដែលសុទ្ធតែជាផលដ៏ល្អបំផុតមកពីសភាពមនុស្សយើង និងមកការខិតខំរបស់យើង។ យើងបានផ្សព្វផ្សាយសេចក្តីទាំងនេះនៅលើផែនដី តាមព្រះបញ្ញារបស់ព្រះអម្ចាស់ និងដោយរួមក្នុងព្រះវិញ្ញាណព្រះអង្គ។ យើងនឹងបានសេចក្តីទាំងនេះវិញ នៅពេលខាងមុខ ក្រោយពីព្រះគ្រីស្តបានប្រោសឲ្យសេចក្តីទាំងនេះ បានបរិសុទ្ធផុតពីសៅហ្មងនានា ទាំងភ្លីត្រចះត្រចង់ និងផ្លាស់ទ្រង់ទ្រាយ គឺនៅពេលព្រះគ្រីស្តនិងប្រគល់ *"ព្រះរាជ្យដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច និងសកល ថ្វាយព្រះបិតារបស់ព្រះអង្គ គឺជាព្រះរាជ្យដែលមានសេចក្តីពិត និងជីវិត ភាពដ៏វិសុទ្ធ និងព្រះហឫទ័យប្រោសប្រណី យុត្តិធម៌ សេចក្តីស្រឡាញ់ និងសន្តិភាពគ្រងរាជ្យ"*។ ឥឡូវនេះ ព្រះជាម្ចាស់ គ្រងរាជ្យនៅលើផែនដីនេះយ៉ាងអាថ៌កំបាំងរួចហើយ។ នៅពេលព្រះអម្ចាស់នឹងយាងមកវិញ ព្រះជាម្ចាស់នឹងគ្រងរាជ្យយ៉ាងពេញលក្ខណៈ។

# ជំពូក ៤

## តួនាទីរបស់ព្រះសហគមន៍ក្នុងចំណោមមនុស្សលោកនាបច្ចុប្បន្នកាល

### ៤០- ព្រះសហគមន៍និងមនុស្សលោកមានទំនាក់ទំនងទៅវិញទៅមក

ក. យើងបានថែងអំពីតម្លៃដ៏ថ្លៃថ្នូរនៃបុគ្គលម្នាក់ៗ អំពីសហគមន៍របស់មនុស្សលោក អំពីអត្ថន័យដ៏ជ្រៅនៃសកម្មភាពរបស់មនុស្សរួចហើយ។ សេចក្ដីទាំងនោះ ជាគ្រឹះនៃទំនាក់ទំនងរបស់ព្រះសហគមន៍ និងមនុស្សលោក ហើយក៏ជាមូលដ្ឋានណែនាំឲ្យមនុស្សលោក និងព្រះសហគមន៍អាចនិយាយសន្ទនាទៅវិញទៅមក។ យើងសន្មតថា មិត្តអ្នកអានចងចាំសេចក្ដីប្រៀនប្រដៅបញ្ជាក់នៃមហាសន្និបាត អំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍។ ក្នុងជំពូកនេះ យើងមានបំណងចង់បរិយាយអំពីព្រះសហគមន៍ដដែលនោះ គឺព្រះសហគមន៍ ដែលស្ថិតនៅក្នុងចំណោមមនុស្សលោក រស់នៅក្នុងមនុស្សលោក និងមានសកម្មភាពរួមជាមួយមនុស្សលោក។

ខ. ព្រះបិតាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច បានបង្កើតព្រះសហគមន៍ដោយព្រះហឫទ័យស្រឡាញ់ (ទត ៣, ៤) ព្រះគ្រីស្តជាព្រះសង្គ្រោះ តែងតាំងព្រះសហគមន៍តាមប្រវត្តិសាស្ត្រ។ ព្រះវិញ្ញាណប្រមែប្រមូលព្រះសហគមន៍ (អភ ១, ៣. ៥-៦. ១៣-១៤.២៣)។ ព្រះសហគមន៍នៅតែបន្តគោលដៅរបស់ខ្លួន គឺសង្គ្រោះមនុស្សលោក។ ប៉ុន្តែ ការសង្គ្រោះនេះ នឹងបានសព្វគ្រប់ជាស្ថាពរនៅពេលចុងក្រោយបំផុតពោលគឺ នៅលោកខាងមុខ។ សព្វថ្ងៃ ព្រះសហគមន៍ស្ថិតនៅលើផែនដីនេះ ហើយមានសមាជិករស់នៅលើផែនដីនេះចូលរួម។ ព្រះជាម្ចាស់ត្រាស់ហៅ គេឲ្យបង្កើតមហាគ្រួសារនៃបុត្រធីតារបស់ព្រះអង្គ តាមប្រវត្តិសាស្ត្រមនុស្សលោក។ មហាគ្រួសារនេះ ត្រូវតែរីកចម្រើនឡើងជាលំដាប់ រហូតដល់ពេលព្រះអម្ចាស់យាងមក។ មហាគ្រួសារនេះ រួមគ្នាដើម្បីបានសម្បត្តិសួគ៌ តែមានសម្បត្តិទាំងនេះរួចហើយ។ ព្រះគ្រីស្ត *"តែងតាំងមហាគ្រួសារនេះ ទុកជាសង្គមម៉្យាង ក្នុងលោកនេះ និងចាត់ចែងដោយមានរបៀបរៀបរយ"*។ ព្រះអង្គក៏ *"បានប្រទានមធ្យោបាយគ្រប់គ្រាន់ ឲ្យព្រះសហគមន៍អាចរួបរួមគ្នាជាសង្គម ដែលមើលឃើញបាន"* (ពន្លឺ ៩)។ ព្រះសហគមន៍ជា *"ក្រុមដែលគេអាចមើលឃើញបានផង និងជាសហគមន៍ខាងវិញ្ញាណដែលគេមើលមិនឃើញផង"* (ពន្លឺ ៨)។ ដូច្នេះ ព្រះសហគមន៍រួមដំណើរជាមួយមនុស្សជាតិទាំងមូល និងចែករំលែកជោគវាសនារបស់មនុស្សលោកនៅលើផែនដី។ ព្រះសហគមន៍ក៏ដូចជាមេក្នុងម្សៅ និងដូចជាវិញ្ញាណនៃសង្គមមនុស្ស ដែលព្រះជាម្ចាស់ត្រាស់ហៅ ឲ្យប្រែថ្មីជានិច្ចក្នុងអង្គព្រះគ្រីស្ត និងឲ្យក្លាយទៅជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។

គ. តាមពិត ព្រះសហគន៍ជាបុរីនៃលោកខាងមុខ និងសង្គមមនុស្សជាបុរីនៃផែនដីនេះជាប់ជំពាក់គ្នាទៅវិញទៅមក។ មានតែអ្នកផ្ញើជីវិតលើព្រះជាម្ចាស់ទេ ដែលអាចចាប់អារម្មណ៍នឹងសេចក្ដីនេះបាន។ លើសពីនេះ

ទៅទៀត ព្រះសហគមន៍នៅតែជាគម្រោងការដ៏អស្ចារ្យ នៃប្រវត្តិសាស្ត្រមនុស្សលោក ដែលត្រូវរីកវរដោយសារអំពើបាប រហូតដល់សិរីរុងរឿងនៃបុត្រធីតារបស់ព្រះជាម្ចាស់ នឹងលេចចេញមកយ៉ាងពេញលេញ។ ប៉ុន្តែ ព្រះសហគមន៍នៅតែបន្តគោលដៅរបស់ខ្លួនផ្ទាល់ គឺសង្គ្រោះមនុស្សលោក មានន័យថា ព្រះសហគមន៍មិនគ្រាន់តែ ចែករំលែកព្រះជន្មរបស់ព្រះជាម្ចាស់ឲ្យមនុស្សប៉ុណ្ណោះទេ ថែមទាំងផ្សព្វផ្សាយពន្លឺ ដែលសាយភាយចេញពីព្រះជន្មរបស់ព្រះជាម្ចាស់ មកលើពិភពលោកទាំងមូល។ ព្រះសហគមន៍ចាំងពន្លឺនោះ ជាពិសេសដោយព្យាបាល និងលើកតម្កើងកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្ស ដោយពង្រឹងសង្គមឲ្យជាប់ស្ថិតស្ថេររួមគ្នា ដោយផ្តល់ឲ្យសកម្មភាពប្រចាំថ្ងៃរបស់មនុស្សទទួលអត្ថន័យថ្មីដ៏ខ្ពង់ខ្ពស់។ ដូច្នេះ ព្រះសហគមន៍ជឿជាក់ថា ដោយសារសមាជិកនីមួយៗរបស់ខ្លួន និងដោយសារខ្លួនជាសហគមន៍ទាំងមូល ព្រះសហគមន៍អាចជួយយ៉ាងទូលំទូលាយឲ្យគ្រួសារមនុស្ស និងប្រវត្តិសាស្ត្ររបស់គេ មានលក្ខណៈជាមនុស្សកាន់តែខ្លាំងឡើងៗ។

ឃ. ព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះជំនួយរបស់ព្រះសហគមន៍ និងក្រុមជំនុំគ្រីស្តបរិស័ទឯទៀតៗ ដែលបានផ្តល់ (និងនៅតែផ្តល់) ដើម្បីឲ្យសម្រេចគោលដៅតែមួយនេះបាន។ ព្រះសហគមន៍មានអំណរសប្បាយនឹងជំនួយទាំងនោះ។ នៅពេលជាមួយគ្នានេះ ព្រះសហគមន៍ជឿជាក់ថា មនុស្សលោកអាចជួយព្រះសហគមន៍យ៉ាងសកម្មតាមរបៀបផ្សេងៗ ដោយទេពកោសល្យ និងដោយសកម្មភាពរបស់បុគ្គល និងរបស់សមាគមផ្សេងៗនៃមនុស្សលោកឲ្យរៀបចំផ្លូវជូនដំណឹងល្អ។

សូមជូនគោលការណ៍ខ្លះៗជាទូទៅ អំពីការចម្រើននៃទំនាក់ទំនងនិងការផ្លាស់ប្តូររបស់ព្រះសហគមន៍ និងមនុស្សលោក អំពីជំនួយទៅវិញទៅមក ក្នុងវិស័យរួមគ្នា។

## ៤១- ជំនួយព្រះសហគមន៍ចង់ផ្តល់ដល់មនុស្សគ្រប់ៗរូប

ក. មនុស្សសម័យទំនើប កំពុងធ្វើដំណើរឆ្ពោះទៅរកការអភិវឌ្ឍន៍នៃបុគ្គលិកលក្ខណៈរបស់ខ្លួនទាំងស្រុង។ គេស្វះស្វែងរកចង់ដឹងអំពីសិទ្ធិរបស់ខ្លួន និងទាមទារសិទ្ធិទាំងនោះកាន់តែខ្លាំងឡើងៗផង។ ចំណែកឯព្រះសហគមន៍ ទទួលបេសកកម្មបង្ហាញគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ គឺព្រះជាម្ចាស់ ដែលជាទិសដៅចុងក្រោយបំផុតរបស់មនុស្ស។ ព្រះសហគមន៍ក៏សម្តែងឲ្យមនុស្សស្គាល់អត្ថន័យនៃការរស់នៅរបស់ខ្លួន គឺសេចក្តីពិតដ៏សំខាន់ជាងគេប្រចាំជីវិត។ ព្រះសហគមន៍ដែលបម្រើព្រះជាម្ចាស់ដឹងជាក់ច្បាស់ថា មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ដែលអាចតបបំពេញបំណងដ៏ជ្រៅបំផុតដែលកប់ទុកក្នុងចិត្តមនុស្ស ព្រោះអ្វីៗក្នុងលោកនេះ ពុំបានធ្វើឲ្យមនុស្សអាចឆ្អែតស្កប់ស្កល់បានឡើយ។ ព្រះសហគមន៍ក៏ដឹងថា មនុស្សគង់តែចាប់អារម្មណ៍នឹងសាសនា យ៉ាងហោចណាស់ក៏មានបន្តិចដែរ ព្រោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទាក់ទាញចិត្តគេជានិច្ច ដូចមានបទពិសោធន៍តាមសតវត្សមុនៗ និងមានសក្ខីភាពជាច្រើននាសម័យឥឡូវជាភស្តុតាងស្រាប់។ មនុស្សនៅតែចង់ស្គាល់នូវអត្ថន័យជីវិតរបស់ខ្លួន អត្ថន័យកិច្ចការរបស់ខ្លួន និងអត្ថន័យនៃសេចក្តីស្លាប់ ទោះបីជាយ៉ាងស្រពិចស្រពិលក៏ដោយ។ វត្តមានរបស់ព្រះសហគមន៍រំឭកបញ្ហាទាំងនេះឲ្យគេ។ មានតែព្រះជាម្ចាស់មួយព្រះអង្គគត់ ដែលអាចតបឆ្លើយនឹងសំណួរទាំងនោះយ៉ាងពេញលេញបាន ព្រោះព្រះអង្គប្រតិស្ឋានមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គ ព្រះអង្គក៏បានរំដោះគេឲ្យបានរួចពីបាបផង។ ព្រះអង្គតបឆ្លើយដោយសម្តែងសេចក្តីពិត តាមរយៈព្រះបុត្រា ដែលប្រសូតជា

មនុស្ស។ អស់អ្នកដើរតាមព្រះគ្រីស្ត ជាមនុស្សដ៏ពេញលក្ខណៈក៏ត្រឡប់ ទៅជាមានលក្ខណៈជាមនុស្សកាន់តែប្រសើរឡើងៗ។

ខ. ដោយព្រះសហគមន៍មានជំនឿនេះ ព្រះសហគមន៍អាចជួយមនុស្សលោកមិនឲ្យគិតអំពីតម្លៃដ៏ថ្លៃថ្នូររបស់សភាពនៃមនុស្សជាតិប្រែប្រួលតាមមតិផ្សេងៗដែលចេះតែផ្លាស់ប្តូរជានិច្ច ឧបមាថា មតិខ្លះបន្ទាបរូបកាយមនុស្សហួសហេតុ ផ្ទុយទៅវិញមានមតិខ្លះលើកតម្កើងរូបកាយហួសកម្រិត។ គ្មានច្បាប់ណារបស់មនុស្សលោកអាចធានាតម្លៃដ៏ថ្លៃថ្នូរនិងសេរីភាពរបស់មនុស្សដូចដំណឹងល្អរបស់ព្រះគ្រីស្តទេ គឺដំណឹងល្អ ដែលព្រះអង្គផ្ញើទុកមកព្រះសហគមន៍។ ដំណឹងល្អនេះ ជូនដំណឹងនិងប្រកាសអំពីសេរីភាពនៃបុត្រធីតារបស់ព្រះជាម្ចាស់ និងបោះបង់ភាពជាទាសករគ្រប់យ៉ាង ដែលមកពីអំពើបាប (រម ៨, ១៤-១៧)។ ដំណឹងល្អនេះគោរពតម្លៃដ៏ថ្លៃថ្នូរនៃមនសិការរបស់មនុស្ស ដោយឥតល្អៀងគឺមនសិការដែលអាចជ្រើសរើសអ្វីៗដោយសេរី។ ដំណឹងល្អនេះបង្រៀនឥតឈប់ឈរឲ្យប្រើទេពកោសល្យទាំងប៉ុន្មានរបស់មនុស្សឲ្យបង្កើតផលសម្រាប់បម្រើព្រះជាម្ចាស់ និងដើម្បីជាប្រយោជន៍ដល់មនុស្សលោក។ មិនតែប៉ុណ្ណោះសោត ដំណឹងល្អផ្ញើមនុស្សម្នាក់ៗ ឲ្យគេស្រឡាញ់គ្រប់ៗគ្នា (មថ ២២, ៣៩)។ សេចក្តីទាំងនេះ ស្របតាមបទដ្ឋានដែលជាគ្រឹះនៃការចាត់ចែងការសង្គ្រោះរបស់ព្រះគ្រីស្ត។ ប្រសិនបើ ព្រះជាម្ចាស់តែមួយព្រះអង្គ ពិតជាព្រះអាទិករ និងជាព្រះសង្គ្រោះ ហើយជាព្រះអម្ចាស់នៃប្រវត្តិសាស្ត្រមនុស្សលោក និងនៃប្រវត្តិសាស្ត្រនៃការសង្គ្រោះមែននោះ ការចាត់ចែងរបស់ព្រះជាម្ចាស់នេះ មិនបំបាត់ស្វ័យភាពដ៏ត្រឹមត្រូវរបស់សត្វលោកទេ ជាពិសេសស្វ័យភាពរបស់មនុស្ស។ ផ្ទុយទៅវិញការ ចាត់ចែងរបស់ព្រះជាម្ចាស់នេះ តែងតាំងស្វ័យភាពនេះឡើងវិញ និងបញ្ជាក់ឲ្យមានកិត្តិយសយ៉ាងថ្លៃថ្នូរ។

គ. ហេតុនេះហើយបានជាតាមដំណឹងល្អដែលព្រះគ្រីស្តបានផ្ញើទុកនោះ ព្រះសហគមន៍ប្រកាសសិទ្ធិមនុស្សទទួលស្គាល់ និងរាប់រកយ៉ាងខ្លាំង នូវសកម្មភាពដ៏ស្វាហាប់របស់មនុស្សលោក នៅសម័យឥឡូវ ជាសកម្មភាពបណ្តោយឲ្យសិទ្ធិមនុស្សនេះ ស្ទុះឡើងជាថ្មីនៅគ្រប់ទីកន្លែង។ក៏ប៉ុន្តែ ត្រូវយកគំនិតនៃដំណឹងល្អមកបញ្ជ្រាបក្នុងចលនានេះ ហើយត្រូវជៀសវាងកុំគិតយកស្វ័យភាពនេះ ធ្វើជាលេសសង្កេតផ្លាស់គ្រប់យ៉ាង។ យើងទាំងអស់គ្នាតែងតែជួបការល្បួងដោយស្មានថា ពេលណាយើងរួចផុតពីវិន័យនៃធម៌របស់ព្រះជាម្ចាស់ ពេលនោះយើងរក្សាសិទ្ធិរបស់ខ្លួនផ្ទាល់យ៉ាងពេញលេញ។ ប្រសិនបើ មនុស្សឈានចូលតាមផ្លូវនោះ តម្លៃដ៏ថ្លៃថ្នូររបស់គេមុខជាជួបនឹងវិនាសសូន្យជាពុំខាន មិនអាចរួចខ្លួនបានទេ។

## ៤២- ព្រះសហគមន៍អាចជួយសង្គមមនុស្សបាន

ក. មហាគ្រួសាររបស់មនុស្សលោក ទទួលកម្លាំងយ៉ាងខ្លាំងនិងបានពេញលក្ខណៈជាស្ថាពរ ដោយក្រុមគ្រួសារនៃបុត្រធីតា របស់ព្រះជាម្ចាស់រួបរួមគ្នាជាធ្លុងតែមួយ (ពន្លឺ ៩) យកព្រះគ្រីស្តធ្វើជាគ្រឹះ។

ខ. ព្រះគ្រីស្តបានផ្ញើបេសកកម្មមកព្រះសហគមន៍ ពុំមែនជាបេសកកម្មខាងនយោបាយ ឬខាងសេដ្ឋកិច្ច ឬខាងសង្គមទេ តែព្រះអង្គប្រទានបេសកកម្ម ដែលមានគោលដៅខាងសាសនា។ ដោយព្រះសហគមន៍ទទួលបេសកកម្មខាងសាសនានោះ ព្រះសហគមន៍ទទួលមុខងារមួយ និងទទួលពន្លឺ ហើយក៏ទទួលកម្លាំងដែលអាចជួយតែងតាំងនិងពង្រឹង សហគមន៍របស់មនុស្សតាមធម្មវិន័យរបស់ព្រះជាម្ចាស់។ យ៉ាងណា

មិញ ព្រះសហគមន៍ក៏អាច (និងត្រូវ) ដាស់តឿនឲ្យមនុស្សលោកធ្វើកិច្ចការផ្សេងៗ ដើម្បីបម្រើមនុស្សទាំងអស់ ជាពិសេសអ្នកខ្វះខាត។ ព្រះសហគមន៍ត្រូវមានកិច្ចការតាមបែបមនុស្សធម៌ និងកិច្ចការផ្សេងៗដូចគ្នា តាមសេចក្ដីត្រូវការ និងតាមកាលៈទេសៈតាមពេលវេលានិងតាមកន្លែង។

គ. ព្រះសហគមន៍ក៏ទទួលស្គាល់អ្វីៗដ៏ល្អ ក្នុងសកម្មភាពដ៏ស្វាហាប់នៃសង្គមសព្វថ្ងៃ ជាពិសេសចលនាស្វែងរកឯកភាពសង្គមរូបនិយកម្មដ៏ត្រឹមត្រូវ និងសាមគ្គីរបស់ប្រជាពលរដ្ឋ និងខាងសេដ្ឋកិច្ច។ បេសកកម្មដ៏ជ្រៅនៃព្រះសហគមន៍ក៏រួមយ៉ាងសមគួរនឹងការខិតខំពង្រឹងឯកភាពដែរ ព្រោះ *"ព្រះសហគមន៍រួមក្នុងអង្គព្រះគ្រីស្ត ហាក់ដូចជាអគ្គសញ្ញាម៉្យាង គឺជាសញ្ញាសម្គាល់បង្ហាញព្រះជាម្ចាស់ផង និងជាមធ្យោបាយនាំឲ្យមនុស្សអាចរួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះអង្គបានផង ហើយក៏ជាសញ្ញាសម្គាល់ និងជាមធ្យោបាយនាំឲ្យមនុស្សជាតិទាំងមូលរួមគ្នាជាធ្លុងតែមួយដែរ"* (ពន្លឺ ១)។ ព្រះសហគមន៍បង្ហាញឲ្យមនុស្សលោកដឹងថា ការរួបរួមយ៉ាងពិតប្រាកដជាសង្គម ដែលអាចមើលឃើញបាន ហូរមកពីចិត្តគំនិតរួបរួមគ្នា គឺមកពីជំនឿ និងសេចក្ដីស្រឡាញ់នោះ ដែលជាគ្រឹះនៃឯកភាពរបស់ខ្លួនសាងសង់ក្នុងអង្គព្រះវិញ្ញាណរលាយមិនបាន។ ព្រះសហគមន៍អាចបញ្ចូលថាមពលក្នុងសង្គមទំនើបបាន មកពីគ្រីស្តបរិស័ទរស់នៅយ៉ាងពិតប្រាកដតាមជំនឿ និងសេចក្ដីស្រឡាញ់នោះ មិនមែនមកពីព្រះសហគមន៍ចង់គ្រងរាជ្យលើ មនុស្សលោកពីខាងក្រៅ ដោយប្រើតែមធ្យោបាយជាមនុស្សសុទ្ធសាធទេ។

ឃ. ម៉្យាងទៀត តាមបេសកកម្ម និងតាមលក្ខណៈរបស់ខ្លួន ព្រះសហគមន៍មិនជាប់នឹងវប្បធម៌ពិសេសណាមួយ ក៏មិនជាប់នឹងរបបនយោបាយ ឬរបបសេដ្ឋកិច្ច ឬរបបសង្គមណាមួយទេ។ ហេតុនេះហើយ ដោយមានលក្ខណៈសកលបែបនេះ ព្រះសហគមន៍អាចទៅជាចំណងយ៉ាងជិតស្និទ្ធជាខ្លាំងរវាងសហគមន៍មនុស្សនានា និងប្រជាជាតិនានា ប៉ុន្តែលុះត្រាតែប្រជាជាតិទាំងនោះ ទុកចិត្តលើព្រះសហគមន៍ និងទទួលស្គាល់ថា ព្រះសហគមន៍មានសេរីភាពយ៉ាងពិត ប្រាកដក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ ហេតុនេះហើយ បានជាព្រះសហគមន៍ទូន្មានកូនចៅរបស់ខ្លួន និងមនុស្សទាំងអស់ថា ត្រូវបំបាត់ការបាក់បែកគ្នាគ្រប់យ៉ាង គឺប្រជាជាតិកុំបាក់បែកនិងប្រជាជាតិឯទៀត ជាតិសាសន៍ក៏កុំបាក់បែកនឹងជាតិសាសន៍ឯទៀត ហើយត្រូវពង្រឹងសហគមន៍មនុស្សដ៏ត្រឹមត្រូវពីខាងក្នុង គឺឲ្យមានចិត្តគំនិតជាក្រុមគ្រួសារនៃបុត្រធីតារបស់ព្រះជាម្ចាស់។

ង. មនុស្សលោកតែងបានបង្កើត (ហើយនៅតែបង្កើត) ស្ថានប័នផ្សេងៗជាច្រើន។ មហាសន្និបាតរាប់រកដោយសេចក្ដីគោរពជាខ្លាំងនូវអ្វីៗដ៏ពិតប្រាកដ ដ៏ល្អប្រសើរដ៏សុចរិតយុត្តិធម៌ ក្នុងស្ថាប័នទាំងនោះ។ មហាសន្និបាតក៏ប្រកាសថា ព្រះសហគមន៍មានបំណងចង់ជួយស្ថាប័នទាំងនោះ ដោយជួយឲ្យកើត និងចម្រើនទៀតផង ស្រេចតែព្រះសហគមន៍អាចធ្វើបាន និងស្របតាមបេសកកម្មរបស់ខ្លួន។ ព្រះសហគមន៍មានបំណងចង់ខ្លាំងជាងគេ គឺមានសមត្ថភាពអាចចម្រើនឡើងបានដោយសេរី ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់រស់នៅក្នុងគ្រប់របបនយោបាយ ដែលទទួលស្គាល់សិទ្ធិមនុស្សជាគ្រឹះនៃបុគ្គលម្នាក់ នៃក្រុមគ្រួសារ និងទទួលស្គាល់សេចក្ដីត្រូវការរួមដ៏ចាំបាច់របស់គេ។

## ៤៣- ព្រះសហគមន៍មានបំណងចង់ជួយសកម្មភាពរបស់មនុស្ស ដោយសារគ្រីស្តបរិស័ទ

ក. មហាសន្និបាត សូមក្រើនរំឭកគ្រីស្តបរិស័ទជាប្រជាពលរដ្ឋនៃបុរីមួយនៅក្នុងលោកនេះផង និងនៃបុរីមួយ

ទៀត នៅលោកខាងមុខផង ឲ្យបំពេញកិច្ចការទាំងប៉ុន្មានរបស់ខ្លួននៅលើផែនដីនេះ ដោយចិត្តឧហ្សាហ៍ និងដោយចិត្តស្មោះស្ម័គ្រ ទាំងបណ្តោយខ្លួនតាមគំនិតនៃដំណឹងល្អណែនាំផង។ មានអ្នកខ្លះស្មានថា ខ្លួនមិនត្រូវយកចិត្តទុកដាក់នឹងកិច្ចការរបស់មនុស្សក្នុងលោកនេះទេ ព្រោះគេដឹងថា *"ក្នុងលោកនេះ យើងគ្មានបុរីដែលនៅស្ថិតស្ថេរគង់វង្សរហូតឡើយ គឺយើងកំពុងតែធ្វើដំណើរឆ្ពោះទៅកាន់បុរីលោកខាងមុខ"* (ហប ១៣, ១៤)។ អ្នកទាំងនោះ ឃ្លាតចាកពីសេចក្តីពិត ព្រោះគេមិនដឹងខ្លួនថា ជំនឿផ្ទាល់ជំរុញគេឲ្យបំពេញកិច្ចការទាំងនោះកាន់តែចាំបាច់ តាមតែព្រះជាម្ចាស់ត្រាស់ហៅគេម្នាក់ៗឲ្យបំពេញនោះ (២ថស ៣, ៦-១៣; អភ ៤, ២៨)។ ផ្ទុយទៅវិញ មានអ្នកខ្លះស្មានថា ខ្លួនត្រូវតែបូជាជីវិតប្រើកម្លាំងទាំងអស់របស់ខ្លួនធ្វើសកម្មភាពផ្សេងៗនៅលើផែនដីនេះ ហាក់ដូចជា កិច្ចការទាំងនោះគ្មានជំពាក់ជំពិននឹងការរស់នៅតាមសាសនារបស់ខ្លួនទាល់តែសោះ។ អ្នកទាំងនោះ ក៏យល់ច្រឡំដែរ។ គេយល់ឃើញថា អ្នកកាន់សាសនាគ្រាន់តែត្រូវធ្វើពិធីគោរពប្រណិប័តន៍ផ្សេងៗ និងប្រតិបត្តិតាមវិន័យខ្លះ បញ្ជាក់យ៉ាងជាក់ច្បាស់ប៉ុណ្ណោះ។ មនុស្សជាច្រើនញែកជំនឿរបស់ខ្លួន ឲ្យដាច់ពីកិរិយាមាយាទក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ។ ការញែកបែបនេះ ពិតជាបណ្តាលឲ្យមនុស្សសម័យឥឡូវភាន់ច្រឡំ និងវង្វេងយ៉ាងខ្លាំង។ កាលពីដើម តាមគម្ពីរសម្ពន្ធមេត្រីចាស់ អស់លោកព្យាការីតែងតែស្តីបន្ទោសយ៉ាងខ្លាំង អស់អ្នកដែលប្រព្រឹត្តតាមរបៀបនេះ (អស ៥៨, ១-១២)។ ក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី ព្រះយេស៊ូគ្រីស្តផ្ទាល់ព្រះអង្គ មានព្រះបន្ទូលស្តីបន្ទោសអ្នកប្រព្រឹត្តដូច្នេះ រឹតតែខ្លាំងទៅទៀត ទាំងគំរាមកំហែងថា គេមុខជានឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរពុំខាន (មថ ២៣, ៣-៣៣; មក ៧, ១០-១៣)។ សូមកុំបង្កើតទំនាស់ ដោយគ្មានមូលហេតុ ដោយញែកសកម្មភាពរបស់ខ្លួនខាងវិជ្ជាជីវៈក្តី ឬខាងសង្គមក្តី ឲ្យទាស់នឹងការរស់នៅខាងសាសនាជាដាច់ខាត។ គ្រីស្តបរិស័ទដែលមិនបំពេញកាតព្វកិច្ចរបស់ខ្លួននៅនាផែនដីនេះ ក៏មិនបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះអ្នកដទៃ ហើយជាពិសេសចំពោះព្រះជាម្ចាស់ថែមទៀតផង។ គេក៏មិនងាយទទួលការសង្គ្រោះដែរ។ សូមគ្រីស្តបរិស័ទទាំងឡាយ យកតម្រាប់តាមព្រះគ្រីស្តដែលបានប្រកបអាជីវកម្មជាជាង។ សូមឲ្យគេរីករាយវិញ ដោយខ្លួនអាចបំពេញកិច្ចការទាំងអស់នៅលើផែនដីនេះ ឲ្យប្រួបរួមជាសំយោគដែលមានជីវិតរស់រវើក គឺលើកយកការខិតខំទាំងប៉ុន្មានរបស់មនុស្សលោកក្នុងក្រុមគ្រួសារក្តី ទាំងខាងវិជ្ជាជីវៈ ទាំងខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេស ឲ្យរួមនឹងសេចក្តីប្រៀនប្រដៅដ៏មានតម្លៃថ្លៃថ្នូរនៃសាសនា ក្រោមការចាត់ចែងរបស់ព្រះជាម្ចាស់ដ៏ឧត្តុងឧត្តមបំផុត គឺអ្វីទាំងអស់រួមសហការលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

ខ. គ្រីស្តបរិស័ទធម្មតា មានភារកិច្ចផ្ទាល់ បំពេញការងារផ្សេងៗក្នុងលោកនេះ តាមវិជ្ជាជីវៈរបស់ខ្លួន។ ប៉ុន្តែជួនកាល មានបព្វជិតបព្វជិតា ខ្លះក៏ប្រកបវិជ្ជាជីវៈ និងការងារទាំងនោះដែរ។ ពេលគ្រីស្តបរិស័ទធម្មតាប្រព្រឹត្តការទាំងនេះ ក្នុងឋានៈជាប្រជាពលរដ្ឋនៃពិភពលោកនេះម្នាក់ៗក្តី ឬរួមជាមួយអ្នកឯទៀតៗក្តី គេត្រូវយកចិត្តទុកដាក់ នឹងមានសមត្ថភាពដ៏ពិតប្រាកដតាមវិជ្ជាជីវៈរៀងៗខ្លួន មិនគ្រាន់តែខិតខំឲ្យគោរពតាមវិន័យផ្ទាល់នៃវិជ្ជាជីវៈនីមួយៗប៉ុណ្ណោះទេ។ គេត្រូវចូល ចិត្តរួមសហការជាមួយអស់អ្នកដែលមានគោលដៅស្រដៀងនឹងខ្លួនទៀតផង។ ដោយដឹងខ្លួនអំពីសេចក្តីដែលជំនឿបញ្ជាឲ្យប្រព្រឹត្ត និងដោយទទួលកម្លាំងពីជំនឿនេះទៀតផង សូមកុំខ្លាចនឹងបញ្ចេញគំនិតថ្មីនិងចាប់ផ្តើមប្រព្រឹត្តតាមរហូតដល់បានសម្រេចតាមតែឱកាសហុចឲ្យ។ គ្រីស្តបរិស័ទដែលទទួលការអប់រំជាមុន មានមនសិការដឹងខ្លួនថាគេមានភារកិច្ចនឹងចារិកធម្មវិន័យរបស់ព្រះជាម្ចាស់ ក្នុងបុរីនៅនាផែនដីនេះ។ សូមទទួលពន្លឺ និងកម្លាំងខាង

ព្រះវិញ្ញាណពីអស់លោកបូជាចារ្យ។ ប៉ុន្តែ សូមកុំនឹកគិតថា អស់លោកគង្វាលមានសមត្ថភាព អាចដោះស្រាយយ៉ាងជាក់ច្បាស់ឲ្យបានភ្លាមៗ នូវបញ្ហាទាំងអស់ទាំងធំ ទាំងតូច ដែលខ្លួនជួបប្រទះនោះ។ កុំស្មានថា អស់លោកមានមុខងារនេះឲ្យសោះ។ សូមគ្រីស្តបរិស័ទធម្មតា ដោះស្រាយបញ្ហាទាំងនោះ ដោយទទួលការខុសត្រូវខ្លួនឯងផ្ទាល់ ដោយព្រះប្រាជ្ញាញាណនៃព្រះគ្រីស្តបំភ្លឺចិត្តគំនិត និងដោយយកចិត្តទុកដាក់ស្តាប់ក្រុមណែនាំព្រះសហគមន៍យ៉ាងស្មោះ។

គ. តាមធម្មតា និងជាញឹកញាប់ ទស្សនៈតាមជំនឿរបស់គ្រីស្តបរិស័ទអំពីពិភពលោក នាំឲ្យគេដោះស្រាយបញ្ហាទាំងនោះតាមរបៀបនេះ ឬតាមរបៀបនោះ ស្របតាមកាលៈទេសៈ។ ប្រហែលគ្រីស្តបរិស័ទឯទៀតៗ នឹងដោះស្រាយបញ្ហាដដែលតាមរបៀបផ្សេងទៀតដោយមានចិត្តស្មោះនឹងគ្រីស្តសាសនាដូចគ្នា។ ការនេះកើតជាញឹកញាប់ ហើយត្រឹមត្រូវថែមទៀតផង។ ជួនកាលគ្រីស្តបរិស័ទជាច្រើនយល់ឃើញយ៉ាងស្រួលថា ការដំណោះស្រាយតាមគំនិតរបស់ក្រុមនេះ ឬរបស់ក្រុមនោះ ស្របតាមដំណឹងល្អ (ទោះបីគេយល់ជំទាស់នឹងបំណងរបស់អ្នកដែលបានដោះស្រាយបញ្ហាទាំងនោះក្តី)។ ក្នុងករណីនេះ ត្រូវនឹកគិតជានិច្ចថា គ្មាននរណាម្នាក់មានសិទ្ធិអះអាងថា អំណាចរបស់ព្រះសហគមន៍គាំទ្រតែយោបល់របស់គេប៉ុណ្ណោះទេ។ សូមឲ្យគ្រីស្តបរិស័ទនិយាយពិគ្រោះគ្នាដោយចិត្តស្មោះត្រង់ និងមានបំណងចង់បំភ្លឺគ្នាទៅវិញទៅមកជានិច្ច។ សូមថែរក្សាទុកសេចក្តីស្រឡាញ់គ្នា ហើយជាពិសេសសូមនឹកពីការស្វែងរកប្រយោជន៍រួមទៀតផង។

ឃ. គ្រីស្តបរិស័ទធម្មតា ត្រូវទទួលចំណែកយ៉ាងសកម្មក្នុងការរស់នៅជាទូទៅរបស់ព្រះសហគមន៍។ ប៉ុន្តែ ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យធ្វើជាសាក្សី អំពីព្រះគ្រីស្តនៅកណ្តាលចំណោមសហគមន៍ មនុស្សជាតិក្នុងគ្រប់កាលៈទេសៈទាំងអស់ មិនគ្រាន់តែនាំឥទ្ធិពលរបស់ព្រះគ្រីស្ត ឲ្យជ្រួតជ្រាបក្នុងពិភពលោកប៉ុណ្ណោះទេ។

ង. ចំពោះអស់លោកអភិបាល ដែលទទួលបន្ទុកណែនាំព្រះសហគមន៍របស់ព្រះជាម្ចាស់ សូមអស់លោករួមជាមួយអស់លោកគង្វាលរបស់អស់លោក ប្រកាសសាររបស់ព្រះគ្រីស្ត តាមរបៀបដែលជួយណែនាំឲ្យគ្រីស្តបរិស័ទអាចបំពេញសកម្មភាព ទាំងប៉ុន្មានរបស់គេនៅលើផែនដីនេះ គឺឲ្យបានជ្រួតជ្រាប ដោយពន្លឺនៃដំណឹងល្អ។ សូមអស់គង្វាលនឹកចងចាំថា អស់លោកបង្ហាញមុខព្រះសហគមន៍ ឲ្យមនុស្សលោកឃើញដោយសារកិរិយាមាយាទប្រចាំថ្ងៃរបស់អស់លោក និងដោយអស់លោកយកចិត្តទុកដាក់ចំពោះមនុស្សលោក (ពន្លឺ ២៨)។ មនុស្សនឹងយល់ថា សាររបស់ព្រះគ្រីស្តមានប្រសិទ្ធភាព និងពិតប្រាកដ ដោយបានឃើញមុខនៃព្រះសហគមន៍នោះ។ តាមកិរិយា និងតាមពាក្យសម្តីរបស់អស់លោក រួមជាមួយបព្វជិតបព្វជិតា និងជាមួយគ្រីស្តបរិស័ទរបស់អស់លោក សូមអស់លោកធ្វើជាភស្តុតាងបញ្ជាក់ថា ព្រះសហគមន៍ដែលគ្រាន់តែមានវត្តមានជាមួយគេ ដោយមានព្រះអំណោយទានទាំងប៉ុន្មាន ដែលខ្លួននាំមកពិតជាប្រភពមិនចេះរីងស្ងួតនៃថាមពល ដែលមនុស្សលោកនាបច្ចុប្បន្ននេះ ត្រូវការជាចាំបាច់។ សូមអស់លោកយកចិត្តទុកដាក់ព្យាយាមរៀន ដើម្បីឲ្យមានសមត្ថភាពអាចទទួលខុសត្រូវក្នុងកិច្ចសន្ទនាជាមួយពិភពលោក និងជាមួយមនុស្សលោក ដែលមានមតិប្លែកៗពីគ្នាផង។ ជាពិសេសទៅទៀតសូមឲ្យអស់លោកនឹកចងចាំក្នុងចិត្តជានិច្ច នូវសេចក្តីប្រកាសនៃមហាសន្និបាតថា *"សព្វថ្ងៃមនុស្សជាតិរួមគ្នាជាប្រជាពលរដ្ឋ តាមសេដ្ឋកិច្ច និងតាមសង្គមកាន់តែខ្លាំងឡើងៗ។ ហេតុនេះហើយ បានជាអស់លោកបូជាចារ្យមានភារៈកិច្ចជាបន្ទាន់បំផុត រួមគ្នាខិតខំគិតគូរអស់ពីសមត្ថភាព និងប្រើគ្រប់មធ្យោបាយក្រោមការណែនាំរបស់ក្រុមអភិបាល*

*និងរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ដើម្បីជៀសវាងកុំឲ្យមានមូលហេតុណាមួយ បណ្ដាលឲ្យមនុស្សលោកបែកបាក់គ្នាឡើយ។ អស់លោកក៏មានភារកិច្ចណែនាំមនុស្សជាតិទាំងមូល ឲ្យប្រមូលគ្នាជាធ្លុងតែមួយជាមហាគ្រួសាររបស់ព្រះជាម្ចាស់"* (ពន្លឺ ២៨)។

ច. ទោះបីព្រះសហគមន៍ នៅតែជាព្រះមហេសីដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ ដោយអនុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធក្ដី ទោះបីព្រះសហគមន៍ មិនដែលលែងធ្វើជាសញ្ញាសម្គាល់បង្ហាញការសង្គ្រោះក្នុងចំណោមមនុស្សលោកក្ដី ក៏ព្រះសហគមន៍ជ្រាបច្បាស់ថា តាមប្រវត្តិដ៏យូរអង្វែងរបស់ខ្លួនមានទាំងលោក ដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ ទាំងគ្រីស្ដបរិស័ទមួយចំនួនធំ មិនបានកាន់យ៉ាងស្មោះនឹងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទេ។ នាបច្ចុប្បន្នកាលនេះក៏ដូច្នោះដែរ គឺព្រះសហគមន៍ជ្រាបថា សារដ៏ថ្លៃថ្នូរដែលខ្លួនសម្ដែងនោះ ប្លែកដាច់យ៉ាងឆ្ងាយពីភាពទន់ខ្សោយ ក្នុងឋានៈជាមនុស្សរបស់អស់អ្នកដែលបានទទួលដំណឹងល្អនេះទុកជាបញ្ញើដែរ។ ទោះបីប្រវត្តិសាស្ត្រវិនិច្ឆ័យការភ្លាំងភ្លាត់ដ៏អាក្រក់ទាំងនោះយ៉ាងណាក្ដី ក៏យើងត្រូវដឹងខ្លួន និងប្រឆាំងនឹងអំពើទាំងនេះយ៉ាងដាច់អហង្ការ កុំឲ្យអំពើទាំងនោះរារាំងការផ្សព្វផ្សាយដំណឹងល្អឡើយ។ ព្រះសហគមន៍ជ្រាបច្បាស់ទៀតថា ខ្លួនត្រូវរៀនជានិច្ចពីបទពិសោធន៍តាមសតវត្សមុនៗមក ដើម្បីពង្រីកទំនាក់ទំនងរបស់ខ្លួនជាមួយមនុស្សលោក។ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំព្រះសហគមន៍ជាមាតារបស់យើង *"នៅតែដាស់តឿនកូនចៅឥតឈប់ឈរថា ត្រូវជម្រះខ្លួនឲ្យបានបរិសុទ្ធ និងប្រែឲ្យបានជាថ្មី ដើម្បីឲ្យសញ្ញាសម្គាល់របស់ព្រះគ្រីស្ដ ចាំងនៅលើមុខព្រះសហគមន៍ ឲ្យកាន់តែភ្លឺស្វាងឡើងៗ"* (ពន្លឺ ១៥)។

## ៤៤- ព្រះសហគមន៍ទទួលជំនួយពីមនុស្សលោកនាបច្ចុប្បន្នកាល

ក. មនុស្សលោកត្រូវតែទទួលស្គាល់ព្រះសហគមន៍ ទុកជាដំណើរការដ៏ពិតប្រាកដតាមសង្គម ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន និងទុកជាមេរៀនរបស់ខ្លួនជាចាំបាច់។ យ៉ាងណាមិញ ព្រះសហគមន៍ក៏ជ្រាបនូវអ្វីៗទាំងអស់ដែលខ្លួនបានទទួលពីប្រវត្តិសាស្ត្រ និងពីការអភិវឌ្ឍន៍របស់មនុស្សជាតិផងដែរ។

ខ. បទពិសោធន៍តាំងពីប៉ុន្មានសតវត្សកន្លងមក ការអភិវឌ្ឍន៍នៃវិទ្យាសាស្ត្រទាំងប៉ុន្មាន ទ្រព្យសម្បត្តិដ៏ថ្លៃថ្នូរនៃវប្បធម៌ទាំងឡាយ សុទ្ធតែជួយមនុស្សឲ្យស្គាល់ខ្លួនឯងកាន់តែច្បាស់ និងបើកមាគ៌ាថ្មីជូនដល់សេចក្ដីពិត។ ការទាំងនោះ ក៏មានប្រយោជន៍សម្រាប់ព្រះសហគមន៍ដែរ។ តាំងតែពីដើមប្រវត្តិសាស្ត្ររបស់ខ្លួនមក ព្រះសហគមន៍បានបង្ហាត់ខ្លួន ឲ្យថ្លែងសាររបស់ព្រះគ្រីស្ដ ដោយយកគំនិត និងភាសារបស់ប្រជាជននានាមកប្រើ ហើយបានខិតខំបកស្រាយសារនោះយ៉ាងថ្លៃថ្នូរ ដោយយកប្រាជ្ញារបស់ទស្សនវិទូថែមទៀតផង។ ព្រះសហគមន៍ប្រព្រឹត្តដូច្នេះ ក្នុងគោលបំណងសម្របដំណឹងល្អ តាមរបៀបមនុស្សទាំងអស់អាចស្ដាប់បាន និងតាមអ្នកប្រាជ្ញទាមទារផង។ ប៉ុន្តែ ព្រះសហគមន៍បានសម្របដំណឹងល្អនេះ តាមព្រំដែនដែលអាចធ្វើបាន។ តាមពិតរបៀបប្រកាសព្រះបន្ទូល ដែលព្រះជាម្ចាស់បានសម្ដែងមក ស្របតាមប្រជាជនទាំងនោះ ពិតត្រូវជាក្បួនសម្រាប់ការប្រកាសដំណឹងល្អគ្រប់ពេល។ ដោយប្រព្រឹត្តដូច្នេះ ព្រះសហគមន៍អាចផ្ដល់ឲ្យប្រជាជាតិនានា មានសមត្ថភាពអាចថ្លែងសារនៃគ្រីស្តសាសនា តាមរបៀបដែលគេត្រូវការ។ នៅពេលជាមួយគ្នានោះ ការនេះបណ្ដោយឲ្យព្រះសហគមន៍ និងអរិយធម៌នានាអាចជួយសន្ទនាគ្នា

យ៉ាងរស់រវើកទៀតផង (ពន្លឺ ១៣)។ ជាពិសេសនាបច្ចុប្បន្នកាល ជាសម័យនៃអ្វីៗទាំងអស់ដំណើរការយ៉ាងលឿនបំផុត និងមានរបៀបរិះគិតជាច្រើនអនេក ព្រះសហគមន៍ត្រូវការអស់អ្នកដែលរស់នៅក្នុងពិភពលោក ទោះជាគ្រីស្តបរិស័ទក្តី មិនមែនគ្រីស្តបរិស័ទក្តី ដែលស្គាល់ស្ថាប័ននានាមានចំណេះវិជ្ជាផ្សេងៗ និងយល់រចនាសម្ព័ន្ធរិះគិត ដើម្បីឲ្យការផ្លាស់ប្តូររវាងព្រះសហគមន៍ និងអរិយធម៌ទាំងឡាយចម្រើនឡើង។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល ជាពិសេសអស់លោកគង្វាល និងទេវវិទូ ដោយព្រះវិញ្ញាណដ៏វិសុទ្ធជួយឧបត្ថម្ភផង មានភារកិច្ចស្ទង់មើលរិះគិតពិចារណា និងបកស្រាយភាសានានា នៅសម័យឥឡូវ និងវិនិច្ឆ័យតាមពន្លឺនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សលោកអាចទទួលសេចក្តីពិត ដែលព្រះជាម្ចាស់បានសម្តែងមកឲ្យកាន់តែច្បាស់ឡើង ឲ្យគេអាចយល់កាន់តែស្រួលបាន និងជូនឲ្យគេស្របតាមអរិយធម៌របស់គេផង។

គ. ព្រះសហគមន៍មានរចនាសម្ព័ន្ធជាសង្គមដែលអាចមើលឃើញបាន ជាសញ្ញាសម្គាល់បង្ហាញថា ខ្លួនរួបរួមក្នុងអង្គព្រះគ្រីស្ត។ ដូច្នេះព្រះសហគមន៍អាចទទួលផល និងតាមពិតទទួលផលរួចហើយ ពីដំណើរការនៃជីវិតក្នុងសង្គម។ សេចក្តីនេះ មិនមែនហាក់ដូចជា ព្រះសហគមន៍ ខ្វះអ្វីមួយក្នុងការតែងតាំង ដែលព្រះគ្រីស្តប្រទានឲ្យនោះទេ តែសម្រាប់ឲ្យការតែងតាំងនោះកាន់តែជ្រៅទៅៗ និងសម្រាប់ថ្លែងអំពីការតែងតាំងនោះ ឲ្យកាន់តែច្បាស់ និងឲ្យបានស្របយ៉ាងស្រួលសម្រាប់សម័យឥឡូវ។ ព្រះសហគមន៍សម្គាល់ឃើញទាំងអរគុណថា ខ្លួនទទួលជំនួយផ្សេងៗពីមនុស្សគ្រប់ឋានៈ វណ្ណៈ ជាជំនួយជាប្រយោជន៍ដល់សហគមន៍របស់ខ្លួនទាំងមូលផង និងដល់បុត្រធីតាម្នាក់ៗផង។ អស់អ្នកដែលជួយសហការអភិវឌ្ឍន៍សហគមន៍មនុស្សជាតិ តាមវិស័យក្រុមគ្រួសារ វិស័យវប្បធម៌ វិស័យសេដ្ឋកិច្ចនិងសង្គម វិស័យនយោបាយទាំងជាតិ និងអន្តជាតិនោះ ផ្តល់ជំនួយយ៉ាងសំខាន់ដល់ព្រះសហគមន៍ ស្របតាមគម្រោងការរបស់ព្រះជាម្ចាស់ ព្រោះព្រះសហគមន៍អាចចម្រើនឡើង បានដោយសារពិភពលោកខាងក្រៅ។ លើសពីនេះទៅទៀត ព្រះសហគមន៍ទទួលស្គាល់ថា ទោះអ្នកប្រឆាំងនឹងអ្នកបៀតបៀន ក៏បានផ្តល់ផលប្រយោជន៍យ៉ាងខ្លាំង ដល់ព្រះសហគមន៍ ហើយនៅតែបន្តផ្តល់ទៀតផងដែរ។

## ៤៥- ព្រះគ្រីស្តជាដើមដំបូង និងជាចុងក្រោយបំផុត

ក. ទោះបីព្រះសហគមន៍ជួយមនុស្សលោកក្តី ឬទទួលជំនួយពីមនុស្សលោកក្តី ក៏ព្រះសហគមន៍តម្រង់ខ្លួនទៅរកគោលដៅតែមួយដែរ គឺសូមព្រះជាម្ចាស់យាងមកគ្រងរាជ្យ និងឲ្យមនុស្សជាតិទទួលការសង្គ្រោះ។ តាមពិតនៅពេលប្រជារាស្ត្ររបស់ព្រះជាម្ចាស់កំពុងធ្វើដំណើរនៅនាលោកនេះ ប្រជារាស្ត្រនេះ អាចនាំផលល្អទាំងប៉ុន្មានមកដល់មហាគ្រួសារនៃមនុស្សជាតិបាន ក៏ហូរចេញមកពីលក្ខណៈរបស់ព្រះសហគមន៍ដែលពិតជា *"អគ្គសញ្ញានៃការសង្គ្រោះរបស់មនុស្សទាំងអស់"* (ពន្លឺ ៤៨) គឺព្រះសហគមន៍បង្ហាញឲ្យមនុស្សលោកស្គាល់គម្រោងការដ៏អស្ចារ្យ នៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្ស និងធ្វើឲ្យគម្រោងការដ៏អស្ចារ្យកើតជារូបរាង។

ខ. ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលប្រតិស្ឋានអ្វីៗទាំងអស់ បានប្រសូតជាមនុស្ស ដើម្បីឲ្យព្រះអង្គទៅជាមនុស្សដ៏ពេញលក្ខណៈ សង្គ្រោះមនុស្សទាំងអស់ និងប្រមែប្រមូលអ្វីៗទាំងអស់ ដាក់ក្នុងព្រះអង្គផ្ទាល់។

ព្រះអម្ចាស់ពិតជាទីបញ្ចប់នៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ បំណងនៃមនុស្សជាតិតាមប្រវត្តិសាស្ត្រ និងតាមអរិយធម៌ជាតិនានា សុទ្ធតែតម្រង់ទៅរកព្រះគ្រីស្តទុកជាទិសដៅតែមួយ។ ព្រះគ្រីស្តពិតជាកំពូល និងជាស្នូលនៃមនុស្សជាតិទាំងមូល ជាអំណរសប្បាយរបស់មនុស្សទាំងអស់ និងបំពេញសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានរបស់មនុស្សយ៉ាងពេញលេញ។ ព្រះបិតាបានប្រោសព្រះគ្រីស្តឲ្យក្រោកឈរឡើង ពីចំណោមមនុស្សស្លាប់ ព្រះអង្គលើកព្រះគ្រីស្តឡើង និងប្រោសឲ្យគង់ខាងស្តាំព្រះអង្គព្រមទាំងតែងតាំងព្រះគ្រីស្តជាចៅក្រម ដែលនឹងវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់។ យើងបានទទួលជីវិត ហើយប្រមូលផ្តុំគ្នា ក្នុងព្រះវិញ្ញាណរបស់ព្រះអង្គ យើងក៏កំពុងធ្វើដំណើរឆ្ពោះទៅកាន់ទិសដៅនៃប្រវត្តិសាស្ត្រមនុស្សលោក ដែលស្របតាមគម្រោងការនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គគឺប្រមូលអ្វីៗទាំងអស់ ដែលនៅឯមេឃ និងនៅលើផែនដី ឲ្យរួមគ្នានៅក្នុងអង្គព្រះគ្រីស្តជាម្ចាស់តែមួយ (អភ ១, ១០)។

គ. ព្រះអម្ចាស់ផ្ទាល់មានព្រះបន្ទូលថា "យើងនឹងមកដល់ក្នុងពេលឆាប់ៗ ទាំងយករង្វាន់មកចែកឲ្យម្នាក់ៗតាមអំពើដែលខ្លួនបានប្រព្រឹត្ត។ យើងជាអាល់ផានិងជាអូមេកានៅមុនគេ និងនៅក្រោយគេបំផុតជាដើមដំបូង និងជាចុងបង្អស់ (វវ ២២, ១២-១៣)។

# ភាគទី ២

## អំពីបញ្ហាខ្លះបន្ទាន់ជាងគេ

**៤៦- អារម្ភកថា**

ក. មហាសន្និបាតបានបរិយាយអំពីតម្លៃដ៏ថ្លៃថ្នូរនៃជីវិតមនុស្ស និងអំពីតួនាទីរបស់ខ្លួនក្នុងពិភពលោកក្នុងឋានៈជាបុគ្គលម្នាក់ និងក្នុងឋានៈខ្លួនរួមក្នុងសង្គមតាមព្រះជាម្ចាស់កំណត់ទុកមក។ ឥឡូវនេះ មហាសន្និបាត មានបំណងណែនាំមនុស្សទាំងអស់ ឲ្យចាប់អារម្មណ៍នឹងបញ្ហាខ្លះ ជាបញ្ហាបន្ទាន់យ៉ាងពិសេសនាសម័យបច្ចុប្បន្ន ជាបញ្ហាទាក់ទិននឹងមនុស្សជាតិយ៉ាងខ្លាំងបំផុត។ មហាសន្និបាត នឹងបរិយាយតាមពន្លឺនៃដំណឹងល្អរបស់ព្រះគ្រីស្តផង និងតាមបទពិសោធន៍របស់មនុស្សលោកផង។

ខ. មនុស្សទូទៅសម័យឥឡូវចាប់អារម្មណ៍នឹងប្រធានបទជាច្រើន។ ក្នុងចំណោមប្រធានបទទាំងនោះ ត្រូវកំណត់ប្រធានបទដូចតទៅ គឺអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ វប្បធម៌ ជីវភាពសេដ្ឋកិច្ចក្នុងសង្គម នយោបាយ សាមគ្គីភាពរបស់ប្រជាជាតិនានា និងសន្តិភាព។ គួរឲ្យយើងចាំងពន្លឺនៃគោលការណ៍មកពីព្រះគ្រីស្តទៅលើបញ្ហានីមួយៗនោះ។ ដូច្នេះ យើងនឹងណែនាំគ្រីស្តបរិស័ទ ហើយក៏បំភ្លឺមនុស្សទាំងអស់ក្នុងការស្វែងរកដំណោះស្រាយ បញ្ហាដ៏ច្រើនអនេក និងស្មុគស្មាញទៀតផង។

# ជំពូក ១

## អាពាហ៍ពិពាហ៍និងការរស់នៅជាក្រុមគ្រួសារមានតម្លៃថ្លៃប្រសើរ

### ៤៧- អាពាហ៍ពិពាហ៍និងក្រុមគ្រួសារក្នុងពិភពលោកសព្វថ្ងៃ

ក. សន្តិភាពរបស់បុគ្គលម្នាក់ៗ និងសន្តិភាពរបស់សង្គម ទាំងសង្គមមនុស្ស ទាំងសង្គមគ្រីស្តបរិស័ទ ភ្ជាប់យ៉ាងជិតស្និទ្ធ នឹងការចម្រើននៃសហគមន៍គូស្វាមីភរិយា និងការចម្រើននៃសហគមន៍ក្រុមគ្រួសារ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទរួមជាមួយអស់អ្នកដែលរាប់រកសហគមន៍ស្វាមីភរិយា និងសហគមន៍ក្រុមគ្រួសារយ៉ាងខ្លាំង មានអំណរសប្បាយយ៉ាងស្មោះ ចំពោះអស់អ្នកដែលគាំទ្រគូស្វាមីភរិយា និងក្រុមគ្រួសារតាមរបៀបផ្សេងៗ។ អ្នកទាំងនេះ ជួយណែនាំមនុស្សលោកនាបច្ចុប្បន្នកាល ឲ្យចូលចិត្ត រាប់រកកាន់តែខ្លាំងឡើងៗ ចំពោះសហគមន៍នេះ ជាសហគមន៍ប្រកបដោយសេចក្តីស្រឡាញ់ និងជួយណែនាំមនុស្សលោកឲ្យគោរពជីវិតទៀតផង។ គេក៏ជួយគូស្វាមីភរិយា និងឪពុកម្តាយឲ្យបំពេញបេសកកម្មដ៏ប្រសើររបស់ខ្លួនដែរ។ អ្នកទាំងនោះ រង់ចាំទទួលលទ្ធផលកាន់តែល្អឡើង ពីការគោរពគូស្វាមីភរិយា និងជីវិតនោះ ព្រមទាំងយកចិត្តទុកដាក់ឲ្យមនុស្សឯទៀតៗធ្វើតាមទៀតផង។

ខ. មនុស្សនៅគ្រប់ទីកន្លែង មិនចាប់អារម្មណ៍ចំពោះកិត្តិយសដ៏ថ្លៃថ្នូនៃអាពាហ៍ពិពាហ៍ និងនៃក្រុមគ្រួសារដូចគ្នាទេ។ ជួនកាលបុរសមានភរិយាច្រើន ឬស្ត្រីមានស្វាមីច្រើន មានការលែងលះគ្នា ដែលប្រៀបដូចជាជំងឺរាតត្បាតម៉្យាង មានស្នេហាដោយសេរី និងស្នេហាក្លែងក្លាយឯទៀតៗ។ល។ ការទាំងប៉ុន្មាននោះ បង្អាប់បង្អោនកិត្តិយសដ៏ថ្លៃថ្នូរ នៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារ។ ម៉្យាងទៀត អត្តទត្តបុគ្គលនិយម គឺមនុស្សដែលគិតតែពីខ្លួនឯង អ្នកដែលគិតតែពីការភ្លើតភ្លើនសប្បាយតាមផ្លូវភេទ និងអស់អ្នកប្រព្រឹត្តតាមរបៀបផ្សេងៗខុសវិន័យរារាំងមិនឲ្យកើតកូន សុទ្ធតែបង្អាប់បង្អោនសេចក្តីស្រឡាញ់ នៃគូស្វាមីភរិយានេះទៀតផង។ សភាពការណ៍សេដ្ឋកិច្ច សភាពការណ៍ក្នុងសង្គម សភាពការណ៍ចិត្តសាស្ត្រ និងសភាពការណ៍ប្រជាពលរដ្ឋក្នុងប្រទេសនាបច្ចុប្បន្ន ក៏នាំរឹកររយ៉ាងធ្ងន់ធ្ងរចូលក្នុងរង្វង់ក្រុមគ្រួសារដែរ។ មិនតែប៉ុណ្ណោះ យើងក៏ព្រួយបារម្ភដោយសង្កេតឃើញថា នៅតំបន់ខ្លះក្នុងពិភពលោក ការបង្កើនចំនួនប្រជាជនបណ្តាលឲ្យកើតបញ្ហាផ្សេងៗដែរ។ ការទាំងប៉ុន្មាននោះ បណ្តាលឲ្យមនសិការមនុស្សតប់ប្រមល់។ ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ទោះបីការផ្លាស់ប្តូរប្រែប្រួលយ៉ាងជ្រៅ នៃសង្គមសម័យឥឡូវបណ្តាលឲ្យកើតការពិបាកជាច្រើនក្តី ក៏ការផ្លាស់ប្តូរទាំងនោះសម្តែងជាញឹកណាស់ និងតាមរបៀបផ្សេងអំពីលក្ខណៈដ៏ពិតប្រាកដនៃគូស្វាមីភរិយា និងក្រុមគ្រួសារដែរ។ អាពាហ៍ពិពាហ៍និងក្រុមគ្រួសារ នៅតែមាំមួន និងមានកម្លាំងយ៉ាងរឹងប៉ឹងទៀតផង។

គ. ហេតុនេះហើយ បានជាមហាសន្និបាតសូមបរិយាយយ៉ាងច្បាស់ នូវចំណុចខ្លះៗនៃលទ្ធិរបស់ព្រះសហគមន៍

ដោយមានបំណងចង់បំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទ និងលើកទឹកចិត្តគេផង ព្រមទាំងបំភ្លឺចិត្តគំនិត និងលើកទឹកចិត្តអស់អ្នកដែលខិតខំថែរក្សាទុក និងពង្រឹងកិត្តិយសនៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារឲ្យបានដូចកាលពីដើម។ អ្នកទាំងនោះ ក៏នឹងលើកតម្កើងតម្លៃដ៏ថ្លៃថ្នូរពិសេស និងដ៏សក្ការៈនៃការរស់នៅជាគូស្វាមីភរិយាទៀតផង។

## ៤៨- ការរស់នៅជាគូស្វាមីភរិយានិងជាក្រុមគ្រួសារមានលក្ខណៈដ៏វិសុទ្ធ

ក. គូស្វាមីភរិយា ពិតជាសហគមន៍ដ៏ជ្រៅម៉្យាង ដោយអ្នកទាំងពីររួមរស់ជាមួយគ្នា និងស្រឡាញ់គ្នា។ ព្រះអាទិករតែងតាំងសហគមន៍នេះ និងប្រទានឲ្យសហគមន៍នេះមានវិន័យផ្ទាល់។ សហគមន៍នេះ សង់ឡើងលើសម្ពន្ធមេត្រីរវាងគូស្វាមីភរិយា គឺអ្នកទាំងពីរសន្យាថា ម្នាក់ៗយល់ព្រមរស់នៅជាគូស្វាមីភរិយា។ ពាក្យសន្យានេះ ពុំអាចដាច់និងលប់បំបាត់បានឡើយ។ ពេលគូស្វាមីភរិយាប្រគល់ខ្លួនទៅវិញទៅមក និងទទួលគ្នាទៅវិញទៅមក អ្នកទាំងពីរពិតជាប្រព្រឹត្តកិច្ចមួយ ដែលមានលក្ខណៈជាមនុស្សសុទ្ធសាធមែន។ ដូច្នេះ កើតស្ថាប័នម៉្យាង គឺអាពាហ៍ពិពាហ៍ដែលធម្មវិន័យរបស់ព្រះជាម្ចាស់ក៏បញ្ជាក់ ហើយសូម្បីតែសង្គមមនុស្ស ក៏ទទួលស្គាល់ដែរ។ ចំណងដ៏សក្ការៈនៃអាពាហ៍ពិពាហ៍នេះ នៅស្ថិតស្ថេរមិនប្រែប្រួលតាមទំនើងចិត្តមនុស្សទេ ដើម្បីជាប្រយោជន៍ដល់គូស្វាមីភរិយា និងជាប្រយោជន៍ដល់កូនៗ និងជាប្រយោជន៍ដល់សង្គមទៀតផង។ ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គ បានបង្កើតការរស់នៅជាគូស្វាមីភរិយាដែលមានសេចក្តីថ្លៃថ្នូរផ្ទាល់ និងមានទីដៅផ្សេងៗ។ សេចក្តីទាំងនោះមានសារៈសំខាន់ជាទីបំផុត ដើម្បីបន្តពូជមនុស្សជាតិតទៅទៀត ដើម្បីឲ្យសមាជិកម្នាក់ៗ ក្នុងក្រុមគ្រួសារអាចអភិវឌ្ឍចម្រើនឡើង និងអាចទទួលជីវិតអស់កល្បជានិច្ច ហើយដើម្បីឲ្យក្រុមគ្រួសារ និងសហគមន៍មនុស្សទាំងមូលបានសេចក្តីថ្លៃថ្នូរ នៅស្ថិតស្ថេរ រស់នៅដោយសុខសាន្ត និងចម្រើនឡើង។ លក្ខណៈនៃអាពាហ៍ពិពាហ៍ និងលក្ខណៈនៃសេចក្តីស្រឡាញ់របស់គូស្វាមីភរិយា តម្រង់តទៅការបន្តពូជ និងទៅការអប់រំកូន ហាក់ដូចជាកំពូលនៃអាពាហ៍ពិពាហ៍និងនៃសេចក្តីស្រឡាញ់នោះ។ ដោយសម្ពន្ធមេត្រីជាគូស្វាមីភរិយា បុរស និងស្ត្រី *"មិនមែនជាបុគ្គលពីរនាក់ទៀតទេគឺជារូបកាយតែមួយវិញ"* (មថ ១៩, ៦) គេជួយគ្នាគាំទ្រគ្នាទៅវិញទៅមក ដោយរួមបវេណីផង និងដោយមានសកម្មភាពរួមផង។ ដូច្នេះ គេដឹងខ្លួនថា គេរួបរួមគ្នាជាចិត្តថ្លើមតែមួយ និងរួបរួមគ្នាកាន់តែជិតស្និទ្ធឡើងៗផង។ អ្នកទាំងពីរប្រគល់ខ្លួនទៅវិញទៅមក ដោយរួមបវេណី ទាមទារឲ្យគូស្វាមីភរិយា មានចិត្តស្មោះភក្តីទាំងស្រុង និងរួមគ្នាមិនអាចបំបែកបានឡើយ។

ខ. ព្រះគ្រីស្តជាអម្ចាស់បានប្រទានពរយ៉ាងបរិបូណ៌ លើសេចក្តីស្រឡាញ់នោះ តាមទីដៅផ្សេងៗ។ សេចក្តីស្រឡាញ់នោះ ហូរចេញមកពីព្រះជាម្ចាស់ ជាប្រភពនៃសេចក្តីស្រឡាញ់ និងតែងតាំងតាមនិមិត្តសញ្ញាអំពីព្រះគ្រីស្តរួមជាមួយព្រះសហគមន៍។ កាលពីដើម ព្រះជាម្ចាស់ចងសម្ពន្ធមេត្រីប្រកបដោយព្រះហឫទ័យស្រឡាញ់ និងភក្តី ស្មោះជាមួយប្រជារាស្ត្រព្រះអង្គយ៉ាងណា (ហស ២; យេ ៣, ៦-១៣; អគ ១៦ និង ២៣; អស ៥៤) សព្វថ្ងៃ ព្រះសង្គ្រោះរបស់មនុស្សលោក ជាព្រះស្វាមីនៃព្រះសហគមន៍ (មថ ៩, ១៥; មក ២, ១៩-២០; លក ៥, ៣៤-៣៥; យហ ៣, ២៩; ២ករ ១១, ២៥-២៧; វវ ១៩, ៧-៨; ២១, ២ និង ៩) ក៏យាងមកជួបគូស្វាមីភរិយាជាគ្រីស្តបរិស័ទ ដោយសារអគ្គសញ្ញាអាពាហ៍ពិពាហ៍យ៉ាងនោះដែរ។ ព្រះអង្គនៅតែសណ្ឋិតនៅជាមួយគូស្វាមីភរិយា ដែលប្រគល់រូបកាយគ្នាទៅវិញទៅមក ដើម្បីឲ្យគេអាច

ស្រឡាញ់គ្នាដោយចិត្តភក្តីស្មោះស្ម័គ្រជានិច្ចរហូត ដូចព្រះអង្គបានស្រឡាញ់ព្រះសហគមន៍ និងបានបូជាព្រះជន្មសម្រាប់ព្រះសហគមន៍ដែរ (អភ ៥, ២៥)។ ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ បានលើកយកសេចក្តីស្រឡាញ់ដ៏ពិតប្រាកដ របស់គូស្វាមីភរិយាឲ្យចូលរួមជាមួយ។ ឫទ្ធានុភាពរបស់ព្រះគ្រីស្តដែលរំដោះមនុស្សលោក និងព្រះសហគមន៍ ដែលមានសកម្មភាពសង្គ្រោះមនុស្សលោក ក៏ណែនាំសេចក្តីស្រឡាញ់នោះ និងប្រទានឲ្យមានតម្លៃថ្មីទៅទៀត។ ដូច្នេះ សេចក្តីស្រឡាញ់នោះ អាចណែនាំគូស្វាមីភរិយាទៅកាន់ព្រះជាម្ចាស់យ៉ាងស័ក្តិសិទ្ធិ អាចជួយគេ និងអាចជួយពង្រឹងគេក្នុងបេសកកម្មដ៏ប្រសើរបំផុត ជាឪពុក និងជាម្តាយ (ពន្លឺ ១១, ៣៥,៤១)។ ហេតុនេះហើយ បានជាមានអគ្គសញ្ញាមួយដ៏ពិសេសផ្តល់កម្លាំងដល់គូស្វាមីភរិយាជាគ្រីស្តបរិស័ទ ហាក់ដូចជា ប្រសិទ្ធគេ ដើម្បីឲ្យគេអាចបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសមរម្យ។ អនុភាពនៃអគ្គសញ្ញានេះ ជួយគេឲ្យបំពេញបេសកកម្មរបស់ខ្លួន ជាគូស្វាមីភរិយា និងជាអ្នកណែនាំក្រុមគ្រួសារ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ក៏ជ្រួតជ្រាបក្នុងការរស់នៅទាំងអស់របស់គេ ឲ្យគេមានជំនឿ មានសេចក្តីសង្ឃឹមនិងមានសេចក្តីស្រឡាញ់។ ដូច្នេះ គូស្វាមីភរិយាអាចឈានទៅជាបុគ្គលកាន់តែពេញលក្ខណៈឡើងៗ និងអាចជួយគ្នាទៅវិញទៅមក ឲ្យបានវិសុទ្ធទៀតផង។ គេក៏រួមចំណែកលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

គ. ដោយឪពុកម្តាយធ្វើជាគំរូ និងដោយគាត់រួមគ្នាអង្វរព្រះជាម្ចាស់ទុកជាមុនឲ្យកូនៗ ហើយសូម្បីតែអស់អ្នកដែលរស់នៅក្នុងរង្វង់ក្រុមគ្រួសារ ក៏នឹងមានចិត្តប្រកបដោយមនុស្សធម៌យ៉ាងស្រួល ហើយរកផ្លូវទៅកាន់ការសង្គ្រោះ និងឲ្យបានវិសុទ្ធយ៉ាងស្រួលដែរ។ រីឯគូស្វាមីភរិយាវិញ គេចម្រើនឡើងដោយមានកិត្តិយសដ៏ថ្លៃថ្នូរបំពេញតួនាទីរបស់ខ្លួនជាឪពុកនិងជាម្តាយ។ គាត់ក៏ខិតខំបំពេញភារកិច្ចអប់រំរបស់ខ្លួន ដោយយកចិត្តទុកដាក់ គឺជាភារកិច្ចរបស់គាត់ផ្ទាល់ ជាពិសេសអប់រំកូនៗខាងផ្លូវសាសនា។

ឃ. កូនៗជាសមាជិកដ៏រស់រវើកនៃក្រុមគ្រួសារ។ គេជួយឪពុកម្តាយឲ្យបានវិសុទ្ធ តាមរបៀបរបស់គេ។ គេអរគុណឪពុកម្តាយ គេគោរពកោតខ្លាចគាត់ និងទុកចិត្តលើគាត់ទៀតផង។ ធ្វើដូច្នេះ គេពិតជាតបឆ្លើយនឹងគុណបុណ្យឪពុកម្តាយ។ ក្នុងឋានៈជាបុត្រធីតាដ៏ល្អ គេជួយឪពុកម្តាយនៅគ្រាពិបាកប្រចាំជីវិត ជាពិសេសគេជួយថែរក្សានៅពេលគាត់ចាស់ជរានៅឯកោ។ មនុស្សទាំងអស់ត្រូវតែគោរពបុរសពោះមាយ និងស្ត្រីមេម៉ាយ ដែលមានចិត្តក្លាហាន រស់នៅតាមរបៀបព្រះជាម្ចាស់ត្រាស់ហៅ ឲ្យគេជាគូស្វាមីភរិយាកាលពីមុននោះ (១ធម ៥, ៣)។ ក្រុមគ្រួសារត្រូវចែករំលែកធនធានខាងវិញ្ញាណទៅវិញទៅមក ដោយចិត្តទូលាយ។ ក្រុមគ្រួសារគ្រីស្តបរិស័ទកើតដោយសារអាពាហ៍ពិពាហ៍ ជានិមិត្តសញ្ញា និងទទួលចំណែកក្នុងសម្ពន្ធមេត្រីប្រកប ដោយសេចក្តីស្រឡាញ់រវាងព្រះគ្រីស្ត និងព្រះសហគមន៍ (អភ ៥, ៣២) ហេតុនេះក្រុមគ្រួសារគ្រីស្តបរិស័ទ ត្រូវបង្ហាញឲ្យមនុស្សលោកឃើញវត្តមានដ៏រស់រវើករបស់ព្រះសង្គ្រោះ ក្នុងលោកនេះ និងលក្ខណៈដ៏ពិតប្រាកដរបស់ព្រះសហគមន៍។ គេបង្ហាញវត្តមាននេះ ដោយសេចក្តីស្រឡាញ់ជាគូស្វាមីភរិយា ដោយបង្កើតកូនដោយចិត្តទូលាយ ដោយគេមានចិត្តស្មោះភក្តី ចំពោះគ្នានឹងគ្នា និងដោយសមាជិកទាំងអស់ក្នុងក្រុមគ្រួសារនោះចេះសហការគ្នាផង។

## ៤៩- សេចក្តីស្រឡាញ់ជាគូស្វាមីភរិយា

ក. ព្រះបន្ទូលរបស់ព្រះជាម្ចាស់អញ្ជើញអ្នកភ្ជាប់ពាក្យឲ្យកាន់តាមសេចក្តីសន្យារបស់គេ និងស្រឡាញ់គ្នាទៅ

វិញទៅមកយ៉ាងបរិសុទ្ធ។ ព្រះបន្ទូលក៏អញ្ជើញគូស្វាមីភរិយាឲ្យស្រឡាញ់គ្នា ដោយឥតរសាយចិត្តឡើយ (កណ ២, ២២-២៤; សភ ៥, ១៨-២០; ៣១, ១០-៣១; តប ៨, ៤-៨; ចស ១, ១-៣; ២, ១៦; ៧, ៨-១១; ១ករ ៧, ៤-៦; អភ ៥, ២៥-៣៣)។ មនុស្សជាច្រើននៅសម័យឥឡូវ ក៏លើកតម្កើងសេចក្តីស្រឡាញ់ដ៏ពិតប្រាកដរបស់គូស្វាមីភរិយាដែរ ដែលគេសម្តែងតាមរបៀបផ្សេងៗ ស្របតាមប្រពៃណីដ៏ត្រឹមត្រូវរបស់ប្រជាជននានា និងស្របតាមអាយុរបស់គេផង។ សេចក្តីស្រឡាញ់នោះ ពិតជាមានលក្ខណៈជាមនុស្សយ៉ាងវិសេស ព្រោះសេចក្តីស្រឡាញ់នោះ ហូរចេញមកពីបុគ្គលម្នាក់ ទៅកាន់បុគ្គលម្នាក់ទៀត ដោយគេសម្រេចចិត្តថា នឹងមានសញ្ចេតនាស្រឡាញ់នោះ។ សេចក្តីស្រឡាញ់នោះ ផ្តល់សេចក្តីសុខដល់បុគ្គលទាំងស្រុង។ ហេតុនេះ សេចក្តីស្រឡាញ់នោះ អាចផ្តល់តម្លៃពិសេស ដល់កាយវិការទាំងប៉ុន្មាន ដែលគូស្វាមីភរិយាប្រព្រឹត្តតាមរូបកាយ និងដល់ជីវិតនៃចិត្តគំនិត ដែលបង្ហាញសេចក្តីស្រឡាញ់នោះផង។ សេចក្តីស្រឡាញ់នោះ បណ្តាលឲ្យកាយវិការ និងរបៀបបញ្ចេញមនោសញ្ចេតនាទាំងនោះទទួលតម្លៃទុកជាកត្តា និងជាសញ្ញាសម្គាល់នៃការរាប់អានផ្ទាល់ក្នុងលក្ខណៈជាគូស្វាមីភរិយា។ ព្រះអម្ចាស់បានប្រោសព្យាបាលសេចក្តីស្រឡាញ់នោះ និងលើកតម្កើងឲ្យបានពេញលក្ខណៈ ដោយព្រះអង្គប្រោសប្រណីយ៉ាងពិសេស តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។ សេចក្តីស្រឡាញ់នោះបង្រួមបង្រួបលក្ខណៈជាមនុស្សផង និងលក្ខណៈជាព្រះជាម្ចាស់ផង និងណែនាំគូស្វាមីភរិយា ឲ្យប្រគល់ខ្លួនឲ្យគ្នាទៅវិញទៅមកដោយសេរី។ អ្នកទាំងពីរបង្ហាញការប្រគល់ខ្លួននោះ ដោយបញ្ចេញមនោសញ្ចេតនា និងដោយធ្វើកាយវិការថ្នាក់ថ្នមគ្នា។ សេចក្តីស្រឡាញ់នោះ ក៏ជ្រួតជ្រាបដល់ការរស់នៅទាំងស្រុងរបស់គេទៀតផង។ លើសពីនេះទៅទៀត សេចក្តីស្រឡាញ់នោះ កាន់តែពេញលក្ខណៈ និងចម្រើនឡើង ដោយគូស្វាមីភរិយា ស្នេហាគ្នាជាញឹកដោយចិត្តទូលាយដែរ។ ដូច្នេះសេចក្តីស្រឡាញ់នេះ ហួសពីតណ្ហា ដែលលម្អៀងទៅរកការភ្លើតភ្លើនតាមតណ្ហាឆ្ងាយណាស់។ ប្រសិនបើគូស្វាមីភរិយាស្រឡាញ់គ្នា ដោយសំអាងតែលើលម្អៀងនៃតណ្ហាភ្លើតភ្លើនធម្មតានោះ សេចក្តីស្រឡាញ់របស់គេមុខជាសាបសូន្យបាត់ទៅយ៉ាងឆាប់ៗ និងយ៉ាងសែនអណោចអធមជាពុំខានឡើយ។

ខ. សេចក្តីស្រឡាញ់នោះ សម្តែងចេញតាមរបៀបពិសេសរបស់វា និងសម្រេចដោយគូស្វាមីភរិយា ស្នេហាគ្នាជាកិច្ចផ្ទាល់នៃការរស់នៅជាគូស្វាមីភរិយា។ ហេតុនេះហើយ បានជាកាយវិការទាំងប៉ុន្មានដែលគូស្វាមីភរិយាប្រព្រឹត្តនៅពេលស្នេហាដ៏បរិសុទ្ធនោះ ពិតជាកិច្ចដ៏ល្អប្រកបដោយគុណធម៌ និងសមរម្យថ្លៃថ្នូរទៀតផង។ ប្រសិនបើ គូស្វាមីភរិយាស្នេហាគ្នាតាមលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ កាយវិការទាំងនោះទៅជាសញ្ញាសម្គាល់បង្ហាញអំពីការប្រគល់ខ្លួនទៅវិញទៅមក និងជួយសម្រួលការប្រគល់ខ្លួននោះទៀតផង។ ការប្រគល់ខ្លួនទៅវិញទៅមកនោះ ក៏ផ្តល់ផលប្រយោជន៍ដ៏មានតម្លៃដល់គូស្វាមីភរិយា ទាំងមានអំណរសប្បាយ និងអរគុណគ្នាផង។ គូស្វាមីភរិយាធ្វើពិធីទទួលស្គាល់ការប្តេជ្ញាចិត្តរបស់ខ្លួន នឹងស្រឡាញ់គ្នាទៅវិញទៅមក ជាពិសេសព្រះគ្រីស្តប្រោសប្រសិទ្ធិឲ្យសេចក្តីស្រឡាញ់នោះបានវិសុទ្ធថែមទៀតផង ដោយអគ្គសញ្ញាអាពាហ៍ពិពាហ៍។ សេចក្តីស្រឡាញ់នោះ នៅស្មោះភក្តីរលាយមិនបាន គឺភក្តីទាំងរូបកាយទាំងគំនិត ទាំងនៅគ្រាស្រណុក និងនៅគ្រាវេទនា។ ហេតុនេះ សេចក្តីស្រឡាញ់បែបនេះ ទាមទារមិនឲ្យលែងលះគ្នា និងមិនឲ្យក្បត់ចិត្តគ្នាបានឡើយ។ យើងត្រូវទទួលស្គាល់ថា ពេលគូស្វាមីភរិយាស្នេហាគ្នាយ៉ាងពេញលក្ខណៈនោះ បុរស និងស្ត្រី មានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នាក្នុងឋានៈជាបុគ្គលម្នាក់។ ភាពស្មើគ្នា

នោះ បង្ហាញយ៉ាងច្បាស់ថា ត្រូវមានគូស្រករតែមួយគត់ ដូចព្រះអម្ចាស់បានបញ្ជាក់ស្រាប់ហើយ។ គូស្វាមីភរិយាជាគ្រីស្តបរិស័ទ ត្រូវមានព្រហ្មវិហារធម៌យ៉ាងខ្លាំង ទើបអាចកាន់តាមកាតព្វកិច្ចរបស់ខ្លួន ដោយចិត្តព្យាយាម តាមតែព្រះជាម្ចាស់ត្រាស់ហៅគេ។ ហេតុនេះ បានជាព្រះជាម្ចាស់ប្រោសប្រណី ឲ្យគូស្វាមីភរិយាមានសមត្ថភាពអាចរស់នៅបែបវិសុទ្ធនោះបាន។ អ្នកទាំងពីរត្រូវតែថែរក្សាសេចក្ដីស្រឡាញ់ឲ្យ កាន់តែខ្លាំងឡើង ចេះអត់ទោសឲ្យគ្នាដោយចិត្តទូលាយ ប្រុងខ្លួនបូជាជីវិតសម្រាប់គូរបស់ខ្លួនគឺ លះបង់ប្រយោជន៍របស់ខ្លួនជានិច្ច។ អ្នកទាំងពីរត្រូវតែអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសឲ្យគេមានសេចក្ដីស្រឡាញ់បែបនោះផង។

គ. ត្រូវគោរពស្នេហាដ៏ពិតប្រាកដរបស់គូស្វាមីភរិយាយ៉ាងខ្ពង់ខ្ពស់បំផុត។ ប្រសិនបើ គូស្វាមីភរិយាជាគ្រីស្តបរិស័ទផ្តល់សក្ខីភាពយ៉ាងប្រសើរអំពីចិត្តស្មោះភក្ដី អំពីការរស់នៅយ៉ាងសុខដុមរមនា ប្រសិនបើគេស៊ូប្តូរជីវិតអប់រំកូនៗ ប្រសិនបើគេទទួលខុសត្រូវឲ្យរបៀបរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារប្រែជាថ្មីតាមសេចក្ដីត្រូវការក្នុងវិស័យវប្បធម៌ ចិត្តសាស្ត្រ និងសង្គម គេពិតជាជួយបង្កើតមតិសាធារណៈដ៏ត្រឹមត្រូវអំពីសេចក្ដីស្នេហានោះ។ ត្រូវបង្ហាត់យុវជនឲ្យទាន់ពេលវេលា និងតាមសេចក្ដីត្រូវការ អំពីកិត្តិយសដ៏ថ្លៃថ្នូរនៃសេចក្ដីស្នេហាជាគូស្វាមីភរិយា អំពីគោលដៅ និងអំពីរបៀបប្រព្រឹត្តផងដែរ។ បើអប់រំយុវជនក្នុងរង្វង់ក្រុមគ្រួសារ ទើបប្រសើរជាងទទួលការបង្ហាត់នៅកន្លែងផ្សេង។ ដូច្នេះយុវជន ដែលទទួលការអប់រំអំពីព្រហ្មចរិយធម៌ ដល់ពេលកំណត់ គេអាចរៀបអាពាហ៍ពិពាហ៍ រស់នៅជាគូស្វាមីភរិយាក្រោយ ពីបានរស់នៅយ៉ាងថ្លៃថ្នូរ តាំងពីពេលភ្ជាប់ពាក្យមក។

## ៥០-គូស្វាមីភរិយាបន្តពូជ

ក. លក្ខណៈផ្ទាល់នៃអាពាហ៍ពិពាហ៍ និងស្នេហាជាគូស្វាមីភរិយា មានគោលដៅតម្រង់ទៅបន្តពូជ និងអប់រំកូន។ កូនៗ ជាអំណោយទានដ៏ប្រសើរបំផុតនៃការរស់ជាគូស្វាមីភរិយា ហើយក៏ជួយផ្តល់សេចក្ដីសុខដល់ឪពុកម្តាយយ៉ាងខ្លាំងដែរ។ ព្រះជាម្ចាស់មានព្រះបន្ទូលដោយផ្ទាល់ព្រះអង្គថា *"បើមនុស្សនៅតែឯង មិនស្រួលទេ"* (កណ ២, ១៨)។ តាំងពីដើមរៀងមក ព្រះអង្គប្រតិស្ឋានមនុស្ស ជាបុរស និងជាស្ត្រី (មថ ១៩, ៤) ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យមនុស្សទទួលចំណែកពិសេស ក្នុងកិច្ចប្រតិស្ឋានរបស់ព្រះអង្គ ហេតុនេះហើយ បានជាព្រះអង្គប្រទានពរឲ្យបុរសនិងស្ត្រីថា *"ចូរបង្កើត កូនចៅឲ្យបានកើនច្រើនឡើង"* (កណ ១, ២៨)។ ដូច្នេះ ស្នេហាដ៏ពិតប្រាកដ តាមការយល់ឃើញយ៉ាងត្រឹមត្រូវ ដូចរចនាសម្ពន្ធនៃក្រុមគ្រួសារ ដែលហូរមកពីស្នេហានោះ ក៏តម្រង់ទៅជួយឲ្យគូស្វាមីភរិយាមានចិត្តទូលាយសហការ ជាមួយព្រះហឫទ័យស្រឡាញ់របស់ព្រះអាទិករ និងរបស់ព្រះសង្គ្រោះ គឺព្រះអង្គមានបំណងចង់ពង្រីកមហាគ្រួសាររបស់ព្រះអង្គ និងឲ្យមហាគ្រួសារនោះកាន់តែប្រសើរឡើងៗដោយសារគេ។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវភ្លេច គោលដៅឯទៀតៗនៃការរស់នៅជាគូស្វាមីភរិយាដែរ។

ខ. គូស្វាមីភរិយា មានភារកិច្ចផ្ទាល់នឹងបន្តជីវិត ហើយអប់រំកូន។ ត្រូវចាត់ទុកថា ភារកិច្ចនេះជាបេសកកម្មរបស់អ្នកទាំងពីរផ្ទាល់។ គូស្វាមីភរិយាដឹងខ្លួនថា គេជាសហការីនៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ជាព្រះអាទិករ ហាក់ដូចជាបកស្រាយព្រះហឫទ័យស្រឡាញ់នោះ ឲ្យអ្នកដទៃស្គាល់។ ហេតុនេះ

ហើយ បានជាគេត្រូវបំពេញបន្ទុកបន្តពូជទាំងទទួលការខុសត្រូវ ក្នុងឋានៈជាមនុស្សផង និងជាគ្រីស្តបរិស័ទផង។ ពេលសម្រេចចិត្តបន្តពូជអ្នកទាំងពីរត្រូវតែយល់ព្រមនឹងគ្នា រួមគ្នាខិតខំរិះគិត សម្រេចចិត្តយ៉ាងទៀងត្រង់ ទាំងសុខចិត្តស្តាប់តាមព្រះបញ្ញារបស់ព្រះជាម្ចាស់ដោយគោរព។ អ្នកទាំងពីរត្រូវរិះគិតថ្លឹងថ្លែងសេចក្តីសុខរបស់ខ្លួនផ្ទាល់ សេចក្តីសុខរបស់កូនៗដែលកើតរួចហើយ ហើយសេចក្តីសុខកូន ដែលនឹងកើតនៅពេលអនាគត។ គេពិនិត្យពិចារណាអំពីសភាពការណ៍ខាងសម្ភារៈ និងខាងវិញ្ញាណនាសម័យគេរស់នៅ និងអំពីសភាពការណ៍របស់ខ្លួនគេផ្ទាល់។ គេគិតគូរអំពីសេចក្តីសុខក្នុងសហគមន៍ គ្រួសារ អំពីសេចក្តីត្រូវការរបស់សង្គមនៅនាលោកនេះ និងអំពីសេចក្តីត្រូវការរបស់ព្រះសហគមន៍ថែមទៀតផង។ គូស្វាមីភរិយាជាគ្រីស្តបរិស័ទ ត្រូវសម្រេចចិត្តបន្តពូជ ដោយខ្លួនគេផ្ទាល់តែម្តង នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។ សូមឲ្យគូស្វាមីភរិយាជាគ្រីស្តបរិស័ទដឹងច្បាស់ថា គេមិនអាចរស់នៅនិងប្រព្រឹត្តតាមអំពើចិត្តបានទេ តែគេមានកាតព្វកិច្ចប្រព្រឹត្តតាមមនសិការរបស់ខ្លួនជានិច្ច គឺមនសិការ ដែលត្រូវស្របតាមធម្មវិន័យរបស់ព្រះជាម្ចាស់។ សូមឲ្យគូស្វាមីភរិយាយកចិត្តទុកដាក់ស្តាប់ ការណែនាំព្រះសហគមន៍ ដែលមានអំណាចអាចបកស្រាយធម្មវិន័យនោះ តាមពន្លឺនៃដំណឹងល្អ។ ធម្មវិន័យរបស់ព្រះជាម្ចាស់នេះ សម្តែងយ៉ាងច្បាស់អំពីអត្ថន័យស្នេហារបស់គូស្វាមីភរិយាការពារសេចក្តីស្រឡាញ់ និងណែនាំសេចក្តីស្រឡាញ់នោះឲ្យមានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ។ គូស្វាមីភរិយាត្រូវផ្ញើជីវិតលើព្រះជាម្ចាស់ ដែលថែរក្សាពិភពលោក និងត្រូវអប់រំខ្លួនឲ្យមានចិត្តលះបង់បូជាជីវិត (១ករ ៧, ៥)។ ហេតុនេះហើយ បានជាពេលគូស្វាមីភរិយាគ្រីស្តបរិស័ទ ទទួលការខុសត្រូវបំពេញមុខងាររបស់ខ្លួន ជាអ្នកបន្តពូជ គេទទួលការខុសត្រូវដោយចិត្តទូលាយ ក្នុងឋានៈជាមនុស្សផង និងជាគ្រីស្តបរិស័ទផង។ ពេលនោះ គេលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ហើយតម្រង់ខ្លួនទៅជាមនុស្សពេញលក្ខណៈក្នុងអង្គព្រះគ្រីស្ត។ ក្នុងចំណោមអស់អ្នកដែលបំពេញកិច្ចបន្តពូជ ដែលព្រះជាម្ចាស់បានផ្ញើទុកឲ្យបំពេញនោះ ត្រូវចាប់អារម្មណ៍យ៉ាងពិសេសចំពោះអ្នកដែលព្រមពៀងគ្នា ក្រោយពីបានពិគ្រោះជាមួយគ្នា សុខចិត្តបង្កើតកូនឲ្យបានច្រើន និងអប់រំឲ្យបានថ្លៃថ្នូរដោយចិត្តទូលាយ។

គ. ប៉ុន្តែ ព្រះជាម្ចាស់តែងតាំងការរស់នៅជាគូស្វាមីភរិយា មិនគ្រាន់តែសម្រាប់បន្តពូជប៉ុណ្ណោះទេ។ លក្ខណៈផ្ទាល់របស់សម្ពន្ធមេត្រីចងបុរស និងស្ត្រីដែលស្រាយមិនបាន ហើយសេចក្តីសុខរបស់កូនៗ ទាមទារឲ្យសេចក្តីស្រឡាញ់របស់គូស្វាមីភរិយាបានទៀងត្រង់ និងរីកចម្រើនឡើងៗជាលំដាប់។ ហេតុនេះហើយ ត្រូវចាត់ការរស់នៅរបស់គូស្វាមីភរិយាដែលគ្មានកូន ផ្ទុយនឹងបំណងប្រាថ្នាយ៉ាងខ្លាំងរបស់គេ ទុកជាសហគមន៍មួយ និងជាការរួបរួមទាំងស្រុងប្រចាំជីវិត ដែលនៅតែមានតម្លៃយ៉ាងថ្លៃថ្នូរ និងមិនអាចស្រាយបានដែរ។

## ៥១- ស្នេហារបស់គូស្វាមីភរិយានិងការគោរពជីវិត។

ក. មហាសន្និបាតដឹងច្បាស់ថា សព្វថ្ងៃគូស្វាមីភរិយា ដែលមានបំណងចង់ណែនាំការរស់នៅរបស់ខ្លួនយ៉ាងសមរម្យ ត្រូវតែប្រឈមមុខជាញឹកញាប់ នឹងសភាពការណ៍ជីវភាពខ្លះៗមិនស្រួល គ្មានលទ្ធភាពអាចបង្កើនចំនួនកូនរបស់ខ្លួនបានឡើយ យ៉ាងហោចណាស់ក្នុងរយៈពេលមួយប៉ុណ្ណោះ។ ហេតុនេះ គេពិបាកប្រព្រឹត្តតាមសេចក្តីស្នេហាដ៏ស្មោះភក្តីរបស់គេ និងរួមរស់យ៉ាងពេញលេញតាមឋានៈជាគូស្វាមីភរិយាដែរ។

ប្រសិនបើគូស្វាមីភរិយាជាច់រួមបវេណី គេប្រហែលពិបាកស្រឡាញ់គ្នាយ៉ាងស្មោះភក្តី ហើយក៏អាចបណ្តាលឲ្យសេចក្តីសុខរបស់កូនៗពិបាកដែរ។ នៅក្នុងករណីនោះ ការអប់រំកូនៗក៏សែនពិបាក ហើយគូស្វាមីភរិយាប្រហែលនឹងខ្វះ សេចក្តីក្លាហានទទួលកូននៅពេលក្រោយតទៅទៀត។

ខ. មានគូស្វាមីភរិយាខ្លះ ហ៊ានដោះស្រាយបញ្ហាទាំងនេះតាមរបៀបទុច្ចរិត ខុសវិន័យ រហូតដល់ហ៊ានសម្លាប់កូនទៅទៀត។ ព្រះសហគមន៍សូមរំឭកថា វិន័យទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ណែនាំ អំពីការបន្តជីវិត និងវិន័យដែលជួយឲ្យសេចក្តី ស្រឡាញ់ដ៏ពិតប្រាកដរបស់គូស្វាមីភរិយាចម្រើនឡើង មិនទាស់ទែងគ្នាឡើយ។

គ. ព្រះជាម្ចាស់ជាប្រភពនៃជីវិត ព្រះអង្គបានផ្ញើមុខងារបន្តជីវិតឲ្យមនុស្សលោក ជាមុខងារដ៏ប្រសើរថ្លៃថ្នូរ។ មនុស្សត្រូវតែបំពេញមុខងារនេះ តាមរបៀបគាប់ព្រះហឫទ័យព្រះអង្គ។ ហេតុនេះហើយបានជាត្រូវរក្សាទុកជីវិតតាំងតែពីពេលទារកចាប់ផ្ទៃមក ដោយយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុត។ ការពន្លូតកូន ឬការធ្វើឃាតកូន ពិតជាបទឧក្រិដ្ឋដ៏អប្រិយគួរឲ្យស្អប់ខ្ពើមណាស់។ គុណសម្បត្តិរបស់មនុស្ស ដែលមានភេទ និងដែលមានអំណាចអាចបង្កើតកូនប្រសើរអស្ចារ្យ ច្រើនជាងគុណសម្បត្តិសត្វឯទៀតៗ ដែលមានជីវិតកម្រិតទាប។ ហេតុនេះហើយ បានជាគូស្វាមីភរិយាត្រូវគោរពកាយវិការពិសេស ដែលខ្លួនប្រព្រឹត្តសម្រាប់បន្តជីវិតយ៉ាងខ្លាំង ឲ្យបានស្របតាមតម្លៃថ្លៃថ្នូរដ៏ពិតប្រាកដរបស់មនុស្ស។ ពេលគូស្វាមីភរិយាត្រូវសម្រួលស្នេហា នឹងការបន្តជីវិតក្នុងឋានៈជាអ្នកទទួលខុសត្រូវនោះ ត្រូវនឹកគិតថាចរិយាសីលធម៌ក្នុង ការប្រព្រឹត្តមិនអាស្រ័យតែលើចិត្តគំនិតដ៏ស្មោះត្រង់របស់គេ ឬមិនអាស្រ័យដោយគេថ្លឹងថ្លែងមូលហេតុផ្សេងៗប៉ុណ្ណោះទេ តែត្រូវសម្រេចចរិយាសីលធម៌តាមកត្តាខ្លះ ដែលប្រកែកមិនបាន ដែលហូរមកពីលក្ខណៈរបស់បុគ្គល និងសភាពនៃកិច្ចការដែលគេប្រព្រឹត្តនោះវិញ។ លក្ខណៈសម្រាប់ថ្លឹងថ្លែងវិនិច្ឆ័យទាំងនោះ ក៏គោរពអត្ថន័យរបស់គូស្វាមីភរិយា ដែលប្រគល់ខ្លួនឲ្យគ្នាទៅវិញទៅមក និងអត្ថន័យនៃកិច្ចបន្តជីវិត ស្របតាមលក្ខណៈខ្លួនគេជាមនុស្ស ក្នុងបរិយាកាសនៃសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដ។ ប្រសិនបើគូស្វាមីភរិយាមិនប្រព្រឹត្តតាមព្រហ្មចារិយធម៌ដោយចិត្តស្មោះទេ គេមិនអាចសម្រេចដូច្នេះបានឡើយ។ អំពីការពន្យារកំណើតកូន បុត្រធីតានៃព្រះសហគមន៍ ដែលអនុវត្តតាមគោលការណ៍ព្រះសហគមន៍ គ្មានសិទ្ធិប្រព្រឹត្តតាមមាគ៌ា ដែលការណែនាំព្រះសហគមន៍មិនយល់ព្រមនោះទេ ព្រោះការណែនាំនេះ មានតួនាទីបកស្រាយធម្មវិន័យរបស់ព្រះជាម្ចាស់។

ឃ.សូមឲ្យមនុស្សទាំងអស់ជ្រាបយ៉ាងច្បាស់ថា មិនត្រូវនឹកគិតអំពីជីវិតមនុស្ស និងអំពីបន្ទុកបន្តពូជនោះដោយនឹកត្រឹមតែ ពីលោកនេះប៉ុណ្ណោះទេ ហើយក៏គ្មានអត្ថន័យយ៉ាងពេញលេញត្រឹមតែក្នុងលោកនេះដែរ។ ត្រូវរិះគិតអំពីជីវិត មនុស្សនិងបន្ទុកនៃការបន្តពូជ ដោយនឹកជានិច្ចដល់វាសនារបស់មនុស្ស ជាវាសនា ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ។

## ៥២- មនុស្សទាំងអស់ត្រូវយកចិត្តទុកដាក់ពង្រឹងតម្លៃនៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារ

ក. ក្រុមគ្រួសារហាក់ដូចជាសាលាអប់រំមនុស្ស ឲ្យចម្រើនឡើង។ ក៏ប៉ុន្តែ ក្រុមគ្រួសារនេះ ទាមទារឲ្យសមាជិកទាំងអស់ រួបរួមគ្នាដោយចិត្តថ្លើមតែមួយ ឲ្យគូស្វាមីភរិយាចែករំលែកគំនិតយោបល់របស់ខ្លួន ហើយក៏

ទាមទារឲ្យឪពុកម្ដាយយកចិត្តទុកដាក់រួមសហការ ក្នុងកិច្ចអប់រំកូនៗដែរ ទើបក្រុមគ្រួសារនេះ អាចទៅដល់ជីវិតរបស់ខ្លួនយ៉ាងពេញលេញ និងអាចបំពេញបេសកកម្មរបស់ខ្លួនឲ្យបានពេញលក្ខណៈ។ ឪពុកត្រូវមានវត្តមានយ៉ាងសកម្ម ទើបគាត់អាចជួយជាខ្លាំងក្នុងការអប់រំកូនបាន។ ក៏ប៉ុន្តែ កូនៗ ជាពិសេសកូនៗតូចជាងគេ ត្រូវការម្ដាយជាចាំបាច់។ ហេតុនេះហើយ បានជាត្រូវបណ្ដោយឲ្យម្ដាយមានលទ្ធភាពអាចថែទាំក្រុមគ្រួសាររបស់ខ្លួនបាន។ តែមិនត្រូវបំភ្លេចថា សិទ្ធិស្ត្រីកំពុងចម្រើនឡើងក្នុងសង្គមដែរ។ សូមអប់រំកូនៗយ៉ាងណា ដើម្បីឲ្យនៅពេលវាពេញវ័យ វាចេះទទួលខុសត្រូវ អាចតបឆ្លើយនឹងព្រះជាម្ចាស់ត្រាស់ហៅគេ។ ប្រសិនបើ ព្រះអង្គត្រាស់ហៅឲ្យគេកាន់សាសនា គេនឹងអាចជ្រើសរើសរបៀបរស់នៅរបស់ខ្លួន។ ប្រសិនបើគេរៀបអាពាហ៍ពិពាហ៍ ឲ្យគេអាចបង្កើតក្រុមគ្រួសាររបស់ខ្លួនផ្ទាល់បាន ដោយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមសីលធម៌ តាមសង្គម និងតាមសេដ្ឋកិច្ចទៀតផង។ ឪពុកម្ដាយ ឬអាណាព្យាបាលមានភារកិច្ចណែនាំកូនៗដោយទូន្មានគេដោយប្រាជ្ញា ក្នុងការរៀបអាពាហ៍ពិពាហ៍។ ទោះបីយុវជនចូលចិត្តស្ដាប់គាត់ក្ដី ក៏គាត់ត្រូវប្រយ័ត្ន កុំបង្ខំចិត្តគេដោយត្រង់ៗ ឬដោយប្រយោល ជំរុញគេឲ្យរៀបអាពាហ៍ពិពាហ៍ ឬឲ្យជ្រើសរើសគូស្រករ។

ខ. ក្រុមគ្រួសារពិតជាកន្លែងដែលមនុស្សច្រើនតំណអាចជួបគ្នាបាន និងអាចជួយគ្នាទៅវិញទៅមក ឲ្យទទួលប្រាជ្ញាកាន់តែទូលំទូលាយឡើងដែរ។ ក្រុមគ្រួសារក៏ពិតជាកន្លែងសម្រួលសិទ្ធិបុគ្គលម្នាក់ៗ ជាមួយសិទ្ធិបុគ្គលដទៃទៀតក្នុងសង្គមផង។ ហេតុនេះហើយ បានជាក្រុមគ្រួសារពិតជាគ្រឹះនៃសង្គមមែន។ អស់លោកអ្នកដែលមានឥទ្ធិពលលើសហគមន៍នានា និងនៅលើក្រុមផ្សេងៗក្នុងសង្គម ត្រូវយកចិត្តទុកដាក់ពង្រឹងការរស់នៅជាគូស្វាមីភរិយា និងក្រុមគ្រួសារយ៉ាងសកម្ម។ សូមឲ្យរដ្ឋអំណាចទទួលស្គាល់លក្ខណៈដ៏ពិតប្រាកដនៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារថែរក្សាការពារ និងធ្វើឲ្យការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារចម្រើនឡើង ការពារសីលធម៌សាធារណៈ និងជួយជីវភាពក្រុមគ្រួសារទៀតផង។ សូមឲ្យរដ្ឋអំណាចចាត់ទុកថា ការទាំងនោះជាកាតព្វកិច្ចដ៏សក្ការៈរបស់ខ្លួន។ ត្រូវធានាសិទ្ធិឪពុកម្ដាយ ឲ្យបង្កើតកូន និងសិទ្ធិឲ្យអប់រំកូនៗក្នុងរង្វង់ក្រុមគ្រួសារដែរ។ ត្រូវបង្កើតក្បួនច្បាប់ និងឲ្យមានក្រុមផ្សេងៗដើម្បីការពារ និងផ្ដល់ជំនួយតាមសេចក្ដីត្រូវការដល់អស់អ្នកដែលបាត់បង់ក្រុមគ្រួសារ ដែលគួរឲ្យអាណិត។

គ. គ្រីស្តបរិស័ទចេះប្រើប្រាស់ពេលវេលា (អភ ៥, ១៦; កូឡ ៤, ៥) ត្រូវរែកញែកអ្វីៗ ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច និងអ្វីៗដែលតែងតែប្រែប្រួល ហើយត្រូវពង្រឹងតម្លៃនៃការរស់នៅជាគូស្វាមីភរិយា និងជាក្រុមគ្រួសារយ៉ាងសកម្ម។ គេនឹងផ្ដល់សក្ខីភាពអំពីការរស់នៅរបស់ខ្លួនគេផ្ទាល់ផង និងដោយរួមសហការជាមួយអស់មនុស្ស ដែលមានឆន្ទៈល្អផង។ ធ្វើដូច្នេះគេដកសេចក្ដីពិបាកចេញពីក្រុមគ្រួសារ ផ្គត់ផ្គង់សេចក្ដីត្រូវការរបស់ក្រុមគ្រួសារ និងធានាឲ្យក្រុមគ្រួសារទាំងនោះ ទទួលអត្ថប្រយោជន៍នៃសម័យទំនើបដូចគេដែរ។ គំនិតទូទៅរបស់គ្រីស្តបរិស័ទ មនសិការដ៏ទៀងត្រង់របស់មនុស្សលោក ខាងសីលធម៌ ប្រាជ្ញា និងសមត្ថភាពរបស់អស់អ្នកដែលរៀនខាងវិទ្យាសាសនា មុខជានឹងជួយយ៉ាងខ្លាំង ឲ្យគោលការណ៍ទាំងនោះបានសម្រេច។

ឃ. អ្នកបច្ចេកទេសខាងវិទ្យាសាស្ត្រ ជាពិសេសអ្នកបច្ចេកទេសខាងជីវវិទ្យា វិជ្ជាពេទ្យ សង្គមវិទ្យា ចិត្តវិទ្យា សុទ្ធតែអាចជួយ ពង្រឹងការរស់នៅជាគូស្វាមីភរិយា និងក្រុមគ្រួសារ និងជួយធ្វើឲ្យមនសិការបានស្ងប់

ស្មៀម។ អ្នកបច្ចេកទេសទាំងនោះ អាចធ្វើការសិក្សាសំដៅទៅទិសដៅតែមួយ និងយកចិត្តទុកដាក់បញ្ជាក់កាន់តែច្បាស់អំពីសភាពការណ៍ ដែលជួយមនុស្សក្នុងកិច្ចពន្យារកំណើតកូនផង។

ង. អស់លោកបូជាចារ្យ ដែលទទួលការអប់រំអំពីក្រុមគ្រួសារ មានភារកិច្ចជួយគាំទ្រគូស្វាមីភរិយា ឲ្យរស់នៅតាមឋានៈរបស់ខ្លួនជារបៀបរស់នៅ ដែលព្រះជាម្ចាស់ត្រាស់ហៅគេ។ ត្រូវជួយគេតាមមធ្យាបាយផ្សេងៗនៃការណែនាំ ដោយធ្វើពិធីអត្ថាធិប្បាយព្រះបន្ទូលព្រះជាម្ចាស់ជូនគេ ដោយធ្វើពិធីគោរពប្រណិប័តន៍ផ្សេងៗ និងដោយផ្តល់ជំនួយឯទៀតៗខាងព្រះវិញ្ញាណផង។ ត្រូវមានចិត្តមេត្តានិងអត់ធ្មត់ខន្តី ជួយពង្រឹងគេឲ្យឆ្លងកាត់ការពិបាកនានារបស់គេ។ ត្រូវលើកទឹកចិត្តគេដោយចិត្តស្រឡាញ់ ដើម្បីឲ្យគេទៅជាក្រុមគ្រួសារបញ្ចេញរស្មីដ៏ត្រចះត្រចង់អំពីសុខដុមរមនាយ៉ាងពិតប្រាកដ។

ច. មានអង្គការផ្សេងៗ ដូចជាសមាគមក្រុមគ្រួសារ យកចិត្តទុកដាក់បង្រៀនលទ្ធិនៃគ្រីស្តសាសនា និងមានសកម្មភាព បង្រៀនយុវជន និងគូស្វាមីភរិយាជាពិសេសគូស្វាមីភរិយាថ្មីៗ ឲ្យរស់នៅជាក្រុមគ្រួសារ ក្នុងសង្គម និងឲ្យទៅជាគ្រីស្តទូតថែមទៀតផង។

ឆ. នៅទីបញ្ចប់ សូមឲ្យគូស្វាមីភរិយា ដែលព្រះជាម្ចាស់ប្រតិស្ឋានឲ្យមានលក្ខណៈដូចព្រះអង្គ ដែលមានព្រះជន្មគង់នៅ គឺគូស្វាមីភរិយាដែលរស់នៅ តាមរបៀបរៀបរយដ៏ពិតប្រាកដ សូមរួមគ្នាដោយចិត្តថ្លើមតែមួយ មានគំនិតតែមួយ ជួយគ្នាឲ្យបានវិសុទ្ធទៅវិញទៅមក។ សូមដើរតាមព្រះគ្រីស្ត ជាដើមកំណើតនៃជីវិត (រម ៥, ១៥ និង ១៨; ៦, ៥-១១; កាឡ ២, ២០)ទាំងឆ្លងកាត់អំណរសប្បាយ ទាំងបូជាជីវិតតាមតែព្រះជាម្ចាស់ត្រាស់ហៅ ឲ្យរស់នៅជាគូស្វាមីភរិយានោះ។ ដោយសេចក្តីស្រឡាញ់ដ៏ស្មោះភក្តីថែមទៀត សូមឲ្យគូស្វាមីភរិយាទាំងនោះ ទៅជាសាក្សីអំពីគម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យស្រឡាញ់ ដែលព្រះអម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់ ដោយព្រះអង្គសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង។ (ភាគ ទី២)

# ជំពូក ២

## អំពីការចម្រើននៃវប្បធម៌

**៥៣- អារម្ភកថា**

ក. មនុស្សបានពេញលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ ដោយសារអរិយធម៌។ មានតែមនុស្សប៉ុណ្ណោះទេ ដែលមានដូច្នេះ គឺថាមនុស្សចេះថែទាំសម្បត្តិធម្មជាតិ និងអ្វីដែលមានតម្លៃក្នុងធម្មជាតិនោះ។ ធម្មជាតិ និងវប្បធម៌ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធបំផុត នៅគ្រប់ពេលដែលយើងនិយាយអំពីជីវិតមនុស្ស។

ខ. តាមអត្ថន័យទូលំទូលាយ ពាក្យ *"វប្បធម៌"* សំដៅទៅលើអ្វីៗដែលមនុស្សប្រើប្រាស់ ដើម្បីសំលៀងចិត្តគំនិតឲ្យកាន់តែស្រួច និងដើម្បីពង្រឹងសមត្ថភាពផ្សេងៗនៃវិញ្ញាណ និងរូបកាយរបស់ខ្លួនផង។ មនុស្សខិតខំរៀនឲ្យមានចំណេះចេះដឹង និងធ្វើការដើម្បីត្រួតត្រាពិភពលោក ធ្វើឲ្យការរស់នៅរបស់ខ្លួនក្នុងសង្គម ទាំងការរស់នៅជាក្រុមគ្រួសារក្ដី ទាំងការរស់នៅជាប្រជាពលរដ្ឋក្ដី មានលក្ខណៈជាមនុស្ស ដោយអភិវឌ្ឍន៍កិរិយាមារយាទឲ្យកាន់តែប្រសើរឡើង និងធ្វើឲ្យស្ថាប័ននានាចម្រើនឡើង។ មនុស្សតែងតែចែករំលែកបទពិសោធន៍ដ៏ប្រសើរខាងវិញ្ញាណ និងសេចក្ដីប៉ងប្រាថ្នាដ៏សំខាន់ៗរបស់មនុស្សជាតិ បញ្ជូនឲ្យអ្នកដទៃស្គាល់ ដោយបញ្ចេញបទពិសោធន៍នោះ រក្សាទុកតាមស្នាដៃរបស់ខ្លួន ដើម្បីជួយអភិវឌ្ឍន៍មនុស្សជាច្រើន និងមនុស្សលោកទាំងមូលទៀតផង។

គ. ហេតុនោះហើយ បានជាវប្បធម៌របស់មនុស្សពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រនិងសង្គម ជៀសផុតមិនបាន។ បើដូច្នេះមែន តាមធម្មតាពាក្យ *"វប្បធម៌"* ទទួលអត្ថន័យសំដៅទៅលើការរស់នៅក្នុងសង្គម និងសំដៅទៅលើរបៀបរស់នៅតាមជាតិសាសន៍នានាដែរ។ បើយល់តាមរបៀបនេះ យើងអាចនិយាយថា មានវប្បធម៌ជាច្រើនអនេក។ មនុស្សរស់នៅតាមរបៀបប្លែកៗពីគ្នា គេតែងតែរាប់អ្វីៗដែលថ្លៃជាងគេ និងអ្វីៗថោកទាបជាងគេ តាមរបៀបប្លែកៗពីគ្នា នេះមកពីរបៀបមនុស្សធ្លាប់ប្រើប្រាស់វត្ថុ មកពីរបៀបគេធ្លាប់ធ្វើការ មកពីរបៀបគេធ្លាប់និយាយ ឬបញ្ចេញយោបល់ មកពីរបៀបគេកាន់សាសនា មកពីរបៀបគេកាន់កិរិយាមាយាទ មកពីគេបង្កើតច្បាប់ប្លែកពីគ្នា មកពីគេតែងតាំងស្ថាប័នកាត់ក្ដីប្លែកពីគ្នា មកពីរបៀបគេពង្រឹងវិទ្យាសាស្ត្រ និងសិល្បៈប្លែកពីគ្នា និងជួយថែរក្សាអ្វីៗដ៏ល្អប្រណិតដែរ។ ហេតុនេះ តាមទំនៀមទម្លាប់ជាកេរអាករពីដូនតាមក ក្នុងសហគមន៍មនុស្សនីមួយៗ កើតបេតិកភ័ណ្ឌផ្ទាល់របស់គេ។ យ៉ាងណាមិញ មានកើតបរិស្ថានវប្បធម៌ម្យ៉ាងខាងប្រវត្តិសាស្ត្រ ហើយមនុស្សម្នាក់ៗ ទោះជាជាតិណាឬរស់នៅសតវត្សណាក្ដី ក៏ចូលរស់នៅក្នុងបរិស្ថាននោះ។ មនុស្សក៏យោងនូវអ្វីៗដែលខ្លួនរាប់ថា មានតម្លៃដ៏ថ្លៃថ្នូរជាងគេពីបេតិកភ័ណ្ឌនោះយកមកអភិវឌ្ឍន៍អរិយធម៌។

# វគ្គ ទី ១

## សភាពការណ៍នៃវប្បធម៌ ក្នុងពិភពលោកនាបច្ចុប្បន្នកាល

### ៥៤- របៀបរស់នៅថ្មី

សភាពការណ៍មនុស្សទំនើប ទាំងតាមផ្លូវសង្គមក្តី ទាំងតាមផ្លូវវប្បធម៌ក្តី បានប្រែប្រួលជាច្រើន ហេតុដូច្នេះហើយ បានជាយើងអាចនិយាយអំពីយុគសម័យថ្មី ដែលកើតក្នុងប្រវត្តិសាស្ត្រមនុស្សលោក។ ហេតុនេះ មានមាគ៌ាថ្មីៗជាច្រើន អាចជួយពង្រឹងវប្បធម៌ឲ្យកាន់តែប្រសើរឡើង និងអាចជួយពង្រីកវប្បធម៌លើគ្រប់វិស័យ។ វិទ្យាសាស្ត្រធម្មជាតិ វិទ្យាសាស្ត្រមនុស្សជាតិ និងវិទ្យាសាស្ត្រសង្គមអភិវឌ្ឍន៍យ៉ាងច្រើនសន្ធឹក បច្ចេកទេស និងមធ្យោបាយទូរគមនាគមន៍ក៏អភិវឌ្ឍន៍ ឡើងនិងចាត់ចែងកាន់តែប្រសើរឡើង បានជួយបើកមាគ៌ាថ្មីៗនោះយ៉ាងសកម្ម។ យើងអាចសន្និដ្ឋានថា វប្បធម៌ទំនើបមានលក្ខណៈដូចតទៅ៖

* វិទ្យាសាស្ត្រដែលសំអាងលើគណិតសាស្ត្រ បណ្តោយឲ្យមនុស្សចេះរិះគន់ថ្លឹងថ្លែងយ៉ាងខ្លាំងជាអតិបរមា។
* ការស្រាវជ្រាវរកអំពីចិត្តសាស្ត្រទំនើបៗ ពន្យល់សកម្មភាពរបស់មនុស្សដោយពិនិត្យមើលជម្រៅចិត្តរបស់គេ។
* ប្រវត្តិវិទ្យាជំរុញមនុស្សឲ្យយល់ឃើញថា អ្វីៗទាំងអស់ចេះតែប្រែប្រួលនិងវិវឌ្ឍន៍ជានិច្ច។
* ទំនៀមទម្លាប់ និងរបៀបរស់នៅរបស់មនុស្សទូទៅ តម្រង់ទៅរស់នៅតាមរបៀបដូចគ្នាដដែលៗកាន់តែខ្លាំងឡើងៗ។
* ឧស្សាហូបនិយកម្ម (ការរស់នៅតាមប្រទេសមានរោងចក្រជាច្រើន) នគរូបនិយកម្ម (ប្រជាជននៅជនបទមករស់នៅទីក្រុង) និងមូលហេតុផ្សេងៗទៀត ដែលជួយដល់ការរស់នៅរួមជាមួយគ្នា ឲ្យបង្កើតទៅជាវប្បធម៌ប្លែកពីមុន គឺវប្បធម៌ *"មនុស្សរួម"*។ ពីវប្បធម៌មនុស្សរួមនោះ កើតរបៀបគិតគូរថ្មី របៀបប្រព្រឹត្តថ្មី និងរបៀបប្រើប្រាស់ពេលលំហែកាយថ្មី។ នៅពេលជាមួយគ្នានេះ ជាតិនានានិងក្រុមសង្គមផ្សេងៗ ចេះតែប្តូរអ្វីៗដែលគេមាន ជាមួយជាតិ និងក្រុមឯទៀតៗកាន់តែច្រើនឡើងៗដែរ ដែលនាំឲ្យជាតិនានា និងក្រុមផ្សេងៗគ្នាក្នុងសង្គមម្នាក់ៗ និងមនុស្សទាំងអស់នាំគ្នាស្គាល់តម្លៃដ៏ថ្លៃថ្នូរនៃវប្បធម៌ផ្សេងៗ។ បន្តិចម្តងៗ មានកើតវប្បធម៌កាន់តែសកលម្យ៉ាង ដែលជំរុញឲ្យមនុស្សរួបរួមគ្នាជាធ្លុងតែមួយ។ វប្បធម៌សកលបែបនោះ សម្តែងបញ្ជាក់ពីការរួបរួមគ្នានោះ លុះត្រាតែការរួបរួមគ្នានោះគោរពវប្បធម៌នីមួយៗ ដែលមានតម្លៃប្លែកៗពីគ្នានោះ។

### ៥៥- មនុស្សធ្វើឲ្យវប្បធម៌ចម្រើនឡើង

បុរសនិងស្ត្រី ទោះជាជាតិសាសន៍ឬជាក្រុមណាក្តី មានចំនួនកាន់តែកើនឡើងជាលំដាប់ ដែលដឹងខ្លួនថា គេបង្កើត និងពង្រឹងវប្បធម៌សហគមន៍របស់គេ។ បំណងអំពីស្វ័យភាពនិងបំណងចង់ទទួលខុសត្រូវ ក៏នៅតែចម្រើនឡើងក្នុង

ពិភពលោកទាំងមូលដែរ។ បំណងទាំងពីរនោះ មានសារៈសំខាន់សម្រាប់ឲ្យមនុស្សជាតិបានពេញវ័យតាមវិញ្ញាណផង និងតាមសីលធម៌ផង។ យើងជាគ្រីស្តបរិស័ទមានភារកិច្ចប្រមែប្រមូលមនុស្សលោក ឲ្យរួបរួមគ្នាជាធ្លុងតែមួយ និងមានបេសកកម្មសាងសង់ពិភពលោកឲ្យកាន់តែល្អប្រសើរឡើងៗ តាមសេចក្តីពិត និងយុត្តិធម៌យើងមុខជាឃើញសេចក្តីនេះកាន់តែច្បាស់។ ហេតុនេះ យើងជាសាក្សីឃើញថា មានលទ្ធិមនុស្សនិយមថ្មីកើតឡើង គឺរបៀបរស់នៅថ្មី ក្នុងឋានៈជាមនុស្ស។ តាមលទ្ធិមនុស្សនិយមថ្មីនោះ គឺគេរាប់រកតម្លៃមនុស្ស ដោយខ្លួនគេចេះទទួលខុសត្រូវលើមនុស្សឯទៀតៗ ជាបងប្អូន និងនៅចំពោះមុខប្រវត្តិសាស្ត្រទៀតផង។

## ៥៦- ការពិបាក និងភារកិច្ច

ក. ក្នុងសភាពការណ៍បែបនេះមិនគួរឲ្យឆ្ងល់ថា មនុស្សដែលដឹងខ្លួនថា គេជាអ្នកទទួលខុសត្រូវ លើការអភិវឌ្ឍន៍វប្បធម៌ ម្យ៉ាងមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងណាស់ ម្យ៉ាងព្រួយបារម្ភណ៍ ដោយខ្លួនត្រូវដោះស្រាយបញ្ហាខ្លះ ដែលជំទាស់គ្នា។

ខ. មនុស្សប្តូរអ្វីៗតាមផ្លូវវប្បធម៌កាន់តែច្រើនឡើង។ ការប្តូរទាំងនោះអាចបណ្តោយឲ្យក្រុម និងជាតិផ្សេងៗ អាចសន្ទនាជាមួយគ្នាបានយ៉ាងពិតប្រាកដ និងអាចបង្កើតផលផ្លែល្អបានដែរ។ តើត្រូវធ្វើយ៉ាងណា កុំឲ្យការប្តូរទាំងនោះ បណ្តាលឲ្យការរស់របស់សហគមន៍នានាជ្រួលច្របល់ គឺនាំឲ្យប្រាជ្ញាញាណពីបរមបុរាណមកបរាជ័យវិនាសបាត់បង់? ឬក៏នាំឲ្យទេពកោសល្យរបស់ប្រជាជននីមួយៗវិនាសបាត់បង់?

គ. បើយើងជួយវប្បធម៌ថ្មីនោះ ឲ្យមានកម្លាំង និងមានជីវិតរស់រវើក ព្រមទាំងជួយឲ្យវប្បធម៌ថ្មីនោះ លាតត្រដាងកាន់តែឆ្ងាយទៅៗ តើត្រូវធ្វើយ៉ាងណាឲ្យមនុស្សកាន់តាមបេតិកភ័ណ្ឌនៃប្រពៃណីរបស់ខ្លួន បានដោយមិនវិនាសបាត់បង់? បញ្ហានេះចោទឡើងយ៉ាងធ្ងន់ធ្ងរ ជាពិសេសនៅពេលត្រូវសម្រួលវប្បធម៌ ដែលជាលទ្ធផលដ៏សន្ធឹករបស់វិទ្យាសាស្ត្រ និងរបស់បច្ចេកទេស ឲ្យបានស្របតាមវប្បធម៌ដែលកើតឡើងពីការសិក្សាធម្មតាខាងអក្សរសិល្ប៍ពីបុរាណមក ត្រូវតាមប្រពៃណីប្រជាជននីមួយៗនោះ។

ឃ. ការសិក្សាឯកទេសប្លែកៗពីគ្នាយ៉ាងឆាប់រហ័ស និងកាន់ខ្លាំងលឿនទៅៗ។ តើត្រូវធ្វើយ៉ាងណាឲ្យការសិក្សាបែបនោះ អាចសម្រួលគ្នានឹងធ្វើសំយោគជាចាំបាច់បាន? តើសភាពការណ៍នេះ អាចសម្រួលជាមួយភារកិច្ចរក្សាទុក ឲ្យមនុស្សលោកមានសមត្ថភាពអាចតាំងអារម្មណ៍ធ្វើសមាធិ និងស្ញើចសរសើរព្រះជាម្ចាស់ ជាកិច្ចអាចណែនាំមនុស្សទៅកាន់ប្រាជ្ញាញាណបាន?

ង. តើត្រូវធ្វើយ៉ាងណាឲ្យមនុស្សទាំងអស់អាចទទួលចំណែកនៃវប្បធម៌បាន បើវប្បធម៌របស់អភិជន ចេះតែខ្ពស់ឡើងៗ ហើយកាន់តែស្មុគស្មាញទៀតផង?

ច. វប្បធម៌ទាមទារស្វ័យភាពដ៏ត្រឹមត្រូវ។ តើត្រូវធ្វីយ៉ាងណាដើម្បីកុំឲ្យវប្បធម៌ ទៅជាទ្រឹស្តីមនុស្សនិយមដែលកើតពីលោកិយសុទ្ធសាធ បណ្តាលឲ្យជំទាស់នឹងសាសនា?

ឈ. សព្វថ្ងៃវប្បធម៌ត្រូវតែចម្រើនឡើង ដោយឆ្លងកាត់បញ្ហាទាំងប៉ុន្មាននោះ ដែលទាស់ទែងគ្នា។ វប្បធម៌ត្រូវជួយឲ្យបុគ្គលម្នាក់ៗរីកចម្រើនឡើងទាំងស្រុង តាមសម្រួល។ វប្បធម៌ក៏ត្រូវជួយមនុស្សលោក ឲ្យបំពេញបន្ទុករបស់ខ្លួនដែរ តាមតែព្រះជាម្ចាស់បានត្រាស់ហៅ ជាពិសេសវប្បធម៌ក៏ត្រូវជួយគ្រីស្តបរិស័ទ ដែលរួមគ្នា ជាបងប្អូន ក្នុងរង្វង់នៃមហាគ្រួសារតែមួយរបស់មនុស្សលោក។

# វគ្គ ទី ២

## គោលការណ៍ខ្លះៗអំពីការចម្រើនវប្បធម៌

### ៥៧- ជំនឿនិងវប្បធម៌

ក. គ្រីស្តបរិស័ទកំពុងតែធ្វើដំណើរទៅកាន់បុរីនៃលោកខាងមុខ។ គេត្រូវស្វែងរក និងភ្លកឱជារសនៃអ្វីៗនៅស្ថានលើ (កូឡ ៣, ១-២)។ សេចក្តីនេះ បន្ថែមកាតព្វកិច្ចយ៉ាងធ្ងន់របស់គេ ឲ្យរួមសហការជាមួយមនុស្សទាំងអស់ សាងសង់ពិភពលោក ដែលមានលក្ខណៈជាមនុស្សដ៏ពិតប្រាកដ។ ការស្វែងរកអ្វីនៅស្ថានលើ មិនបន្ថយកាតព្វកិច្ចនេះសោះ។ តាមពិតជំនឿរបស់គ្រីស្តបរិស័ទចំពោះព្រះយេស៊ូ ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ជំរុញនិងគាំទ្រគេយ៉ាងខ្លាំង គឺនាំឲ្យសម្ទុះនៃការប្តេជ្ញាចិត្តបំពេញបន្ទុកនេះ ហើយជាពិសេស ធ្វើឲ្យគេអាចទទួលស្គាល់អត្ថន័យពេញលេញ នៃសមកម្មភាពទាំងប៉ុន្មានដែលអាចផ្តល់ឲ្យវប្បធម៌មានមុខងារដ៏សំខាន់ តាមទីដៅដែលព្រះជាម្ចាស់ បានកំណត់ទុកឲ្យមនុស្សលោក។

ខ. ពេលកសិករភ្ជួររាស់ស្រែចម្ការរបស់ខ្លួនដោយផ្ទាល់ដៃ ឬដោយប្រើម៉ាស៊ីនតាមបច្ចេកទេសទំនើប គេចង់ឲ្យស្រែនេះ ផ្តល់ភោគផល និងទៅជាដំណាក់ដ៏គួរសម សម្រាប់មហាគ្រួសារទាំងមូលរបស់មនុស្ស។ យ៉ាងណាមិញ ពេលមនុស្សទទួលចំណែកក្នុងការរស់នៅរបស់ក្រុមផ្សេងៗក្នុងសង្គម គេធ្វើឲ្យគម្រោងការរបស់ព្រះជាម្ចាស់បានសម្រេច។ តាំងពីដើមដំបូងមកម្ល៉េះ ព្រះអង្គបានសម្តែងគម្រោងការនេះ គឺឲ្យមនុស្សត្រួតត្រាផែនដី (កណ ១, ២៨)។ គេបង្ហើយព្រះរាជកិច្ចរបស់ព្រះអង្គ ដែលប្រតិស្ឋានសត្វលោក ហើយគេក៏ថែទាំខ្លួនឯងផង។ នៅពេលជាមួយគ្នានោះ មនុស្សធ្វើតាមព្រះបញ្ញាដ៏ប្រសើរបំផុតរបស់ព្រះគ្រីស្ត ដែលព្រះអង្គសូមឲ្យប្តេជ្ញាចិត្តបម្រើមនុស្សដូចគ្នាទុកជាបងប្អូន។

គ. លើសពីនេះទៅទៀត ពេលមនុស្សយកចិត្តទុកដាក់រៀនវិទ្យាផ្សេងៗ គឺទស្សនវិទ្យា ប្រវត្តិវិទ្យា គណិតវិទ្យា វិទ្យាសាស្ត្រ ធម្មជាតិ។ល។ ពេលមនុស្សយកចិត្តទុកដាក់នឹងសិល្បៈ គេអាចជួយណែនាំមហាគ្រួសាររបស់មនុស្សលោក ឲ្យយកចិត្តទុកដាក់និងអ្វីៗ ដែលមានតម្លៃដ៏ថ្លៃថ្នូរ គឺអ្វីៗដែលពិត អ្វីៗដែលល្អ អ្វីដែលសប្បុរស ព្រមទាំងឲ្យយល់ដល់អ្វីដែលមានតម្លៃសកល។ គាត់ទទួលរស្មីថ្មី ពីព្រះប្រាជ្ញាញាណដ៏គួរស្ញើចសរសើរ ដែលគង់នៅក្បែរព្រះអង្គតាំងពីដើមរៀងមក ធ្វើជាមេជាងចាត់ចែងអ្វីៗទាំងអស់ រួមជាមួយព្រះអង្គ លេងកំសាន្តនៅលើផែនដី ហើយមានអំណរនៅក្នុងចំណោមមនុស្សលោក (សភ ៨, ៣០-៣១)។

ឃ.ដោយមនុស្សធ្វើដូច្នេះ ចិត្តគំនិតរបស់គេ លែងទៅជាទាសកររបស់វត្ថុទាំងឡាយទៀតហើយ គេស្រួលលើកខ្លួន ឲ្យស្ងប់ស្ងាត់ធ្វើសមាធិ និងសញ្ជឹងគិតដល់ព្រះអាទិករ។ លើសពីនេះទៅទៀត ដោយព្រះជាម្ចាស់ប្រោសប្រណីគេរៀបខ្លួន ដើម្បីទទួលស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មុនពេលព្រះបន្ទូលនោះ ប្រសូត

ជាមនុស្ស ដើម្បីសង្គ្រោះមនុស្សលោក និងប្រមូលអ្វីៗទាំងអស់ក្នុងអង្គព្រះគ្រីស្តជាម្ចាស់តែមួយ ព្រះបន្ទូលគង់នៅក្នុងពិភពលោករួចហើយ ក្នុងឋានៈជាពន្លឺបំភ្លឺមនុស្សគ្រប់ៗរូប (យហ ១, ៩-១០)។

ង. ការអភិវឌ្ឍន៍ទំនើបនៃវិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងៗ តាមវិធីផ្ទាល់របស់ខ្លួនគ្មានសមត្ថភាព ស្ទង់មើលអត្ថន័យដ៏ជ្រៅនៃវត្ថុទាំងឡាយទេ។ ប្រសិនបើមនុស្សប្រើវិធីស្រាវជ្រាវ តាមវិទ្យាសាស្ត្រ និងបច្ចេកទេសទាំងនោះ ទុកជាក្បួនតម្រាដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការស្វែងរកសេចក្តីពិត គេមុខជានឹងស្គាល់តែអភូតហេតុខាងក្រៅប៉ុណ្ណោះ ហើយមិនអាចស្គាល់ព្រះណាបានឡើយ។ នៅពេលជាមួយគ្នានេះ យើងក្រែងខ្លាចថា មនុស្សទុកចិត្តខ្លាំងពេកលើអ្វីៗដែលគេបានរកឃើញ តាមវិទ្យាសាស្ត្រទំនើបផ្សេងៗទាំងនោះ ហើយនាំគ្នាស្មានថា ជីវិតអាស្រ័យតែលើខ្លួនផ្ទាល់ មិនត្រូវការស្វែងរកអ្វីដ៏មានតម្លៃប្រសើរជាងនេះទៀតទេ។

ច. ទោះជាវប្បធម៌ទំនើបបណ្តាលឲ្យកើតផលអវិជ្ជមាន គឺផលអាក្រក់ក្តី ក៏យើងមិនត្រូវចាញ់ការល្បួងដោយស្មានថា ផលអាក្រក់ទាំងប៉ុន្មាននោះ ហូរចេញមកពីលក្ខណៈនៃវប្បធម៌ទំនើបនោះដែរ។ ផ្ទុយទៅវិញ យើងត្រូវយកចិត្តទុកដាក់ ទទួលតម្លៃដ៏ខ្ពង់ខ្ពស់នៃវប្បធម៌នោះ ដែលអាចជួយមនុស្សលោកបាន។ ក្នុងចំណោមផលវិជ្ជមានទាំងនោះ យើងត្រូវកត់សម្គាល់សេចក្តីដូចតទៅគឺ៖

* មនុស្សចូលចិត្តនឹងវិទ្យាសាស្ត្រ ហើយមានចិត្តស្មោះភក្តី ដែលមិនចេះរសាយទៅលើសេចក្តីពិត ក្នុងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ
* មនុស្សត្រូវការធ្វើការរួមគ្នាជាពួកៗ ក្នុងក្រុមដែលមានឯកទេស
* មនុស្សមានគំនិតសាមគ្គីអន្តរជាតិ កាន់តែខ្លាំងឡើងៗ
* អ្នកប្រាជ្ញមានមនសិការទទួលខុសត្រូវកាន់តែច្បាស់ថា ខ្លួនមានបន្ទុកជួយនិងការពារមនុស្សលោក
* គេមានបំណងចង់ឲ្យមនុស្សទាំងអស់មានជីវភាពគួរសម ជាពិសេសអស់អ្នក ដែលមិនអាចទទួលខុសត្រូវបាន ឬដែលខ្វះខាតខាងវប្បធម៌។
* តម្លៃទាំងនោះ ហាក់ដូចជារៀបចំចិត្តគំនិតមនុស្សលោក ឲ្យទទួលសារនៃដំណឹងល្អ និងទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ត ដែលយាងមកសង្គ្រោះមនុស្សលោក និងធ្វើឲ្យមនុស្សទទួលស្គាល់ព្រះអង្គយ៉ាងពិតប្រាកដ។

## ៥៨- ដំណឹងល្អរបស់ព្រះគ្រីស្ត មានទំនាក់ទំនងជាច្រើនជាមួយវប្បធម៌

ក. ដំណឹងល្អអំពីការសង្គ្រោះរបស់ព្រះគ្រីស្ត មានចំណងពាក់ព័ន្ធជាច្រើនផ្នែកជាមួយវប្បធម៌។ ព្រះជាម្ចាស់បានសម្តែងព្រះអង្គ ឲ្យប្រជារាស្ត្រព្រះអង្គស្គាល់ តាមវប្បធម៌ច្រើនបែប នៃប្រជារាស្ត្រនេះ ស្របតាមសម័យនីមួយៗរហូតដល់ពេលសម្តែងព្រះអង្គយ៉ាងពេញលេញ សព្វគ្រប់ឲ្យមនុស្សលោកស្គាល់ ដោយព្រះបុត្រាដែលប្រសូតជាមនុស្ស។

ខ. យ៉ាងណាមិញ តាំងពីដើមរៀងមក ព្រះសហគមន៍បានរស់នៅតាមរបៀបផ្សេងៗពីគ្នាដែរ។ ព្រះសហគមន៍ក៏បានប្រើធនធាននៃអរិយធម៌ផ្សេងៗ តាមប្រជាជាតិនានា និងតាមសម័យនីមួយៗ ដើម្បីផ្សព្វផ្សាយ និង

បកស្រាយដំណឹងល្អរបស់ព្រះគ្រីស្តនេះ ឲ្យជនជាតិទាំងឡាយ និងដើម្បីយល់អត្ថន័យដំណឹងល្អនេះ កាន់តែច្បាស់ និងកាន់តែជ្រៅទៅៗថែមទៀត។ ព្រះសហគមន៍ក៏បានប្រើធនធាននៃអរិយធម៌ផ្សេងៗទាំងនោះ ដើម្បីប្រកាសដំណឹងល្អឲ្យកាន់តែប្រសើរឡើង តាមពិធីគោរពប្រណិប័តន៍នានាៗ និងតាមរបៀបរស់នៅប្លែកៗពីគ្នា នៃសហគមន៍គ្រីស្តបរិស័ទទៀតដែរ។

គ. ព្រះជាម្ចាស់ចាត់ព្រះសហគមន៍ឲ្យទៅប្រកាសដំណឹងល្អ ជូនមនុស្សគ្រប់ជាតិសាសន៍ និងនៅគ្រប់សម័យ និងទៅគ្រប់ទីកន្លែង។ ដូច្នេះ ព្រះសហគមន៍មិនជាប់ចំណាង ដែលស្រាយមិនបានជាមួយសាសន៍ណា ឬជាតិណាមួយសោះ។ ព្រះសហគមន៍ ក៏មិនជាប់ចំណងនឹងរបៀបរស់នៅនៃប្រទេសណាមួយ ឬជាប់ចំណងនឹងទំនៀមទម្លាប់ចាស់ ឬថ្មីដែរ។ ទោះបីព្រះសហគមន៍ ស្មោះនឹងការបញ្ជូនបន្តរបស់ខ្លួនផ្ទាល់ក្តី ក៏ព្រះសហគមន៍ដឹងច្បាស់ថា ព្រះជាម្ចាស់បានផ្ញើបេសកកម្មសម្រាប់មនុស្សគ្រប់ជាតិសាសន៍ ក្នុងពិភពលោកទាំងមូលដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍អាចទាក់ទង និងចូលរួបរួមជាមួយអរិយធម៌នានាបាន។ ធ្វើដូច្នេះ ព្រះសហគមន៍មុខជាទទួលផលដ៏ប្រសើរសម្រាប់ខ្លួនផ្ទាល់ និងបង្កើតផលដ៏ប្រសើរសម្រាប់វប្បធម៌នានាផងដែរ។

ឃ.ដំណឹងល្អរបស់ព្រះគ្រីស្ត ប្រែការរស់នៅ និងវប្បធម៌របស់មនុស្សបាបឲ្យបានថ្មីជានិច្ច។ ដំណឹងល្អនេះ តទល់ប្រឆាំងនឹងគំនិតវង្វេង ព្រមទាំងប្រឆាំងនឹងការអាក្រក់គ្រប់យ៉ាង ដែលបណ្តាលមកពីកិលេសតណ្ហា បញ្ឆោតមនុស្សឥតឈប់ឈរ ឲ្យប្រព្រឹត្តអំពើបាប។ ដំណឹងល្អនេះ ក៏នៅតែជម្រះ និងលើកសីលធម៌ ប្រជាជននានា ឲ្យកាន់តែប្រសើរឡើងថែមទៀតផង។ ដោយព្រះសហគមន៍ទទួលសម្បត្តិសួគ៌ពីព្រះជាម្ចាស់មក ព្រះសហគមន៍ហាក់ដូចជាអាចប្រោសអរិយធម៌ ពីខាងក្នុងធ្វើឲ្យគុណសម្បត្តិខាងវិញ្ញាណ និងទេពកោសល្យផ្ទាល់របស់ប្រជាជននីមួយៗ និងរស់នៅក្នុងសម័យនីមួយៗអាចបង្កើតផលបាន។ ព្រះសហគមន៍ពង្រឹងគុណសម្បត្តិ និងទេពកោសល្យទាំងនោះ ឲ្យបានរឹងប៉ឹងនិងប្រោសឲ្យបានពេញលក្ខណៈ ព្រមទាំងឲ្យមានកម្លាំងថ្មី ដោយរួមក្នុងអង្គព្រះគ្រីស្ត (អភ ១, ១០)។ ដូច្នេះ ពេលព្រះសហគមន៍បំពេញបេសកកម្មរបស់ខ្លួន ព្រះសហគមន៍ក៏រួមសហការជាមួយអ្នកដទៃ រួចហើយធ្វើឲ្យអរិយធម៌របស់គេរីកចម្រើនឡើង និងជំរុញគេ ធ្វើឲ្យអរិយធម៌ជាតិខ្លួនចម្រើនឡើងដែរ។ សកម្មភាពរបស់ព្រះសហគមន៍ សូម្បីបើតែសកម្មភាពខាងពិធីគោរពប្រណិប័តន៍ ក៏ជួយអប់រំសេរីភាពក្នុងចិត្តរបស់មនុស្ស។

## ៥៩- ត្រូវសម្រួលវប្បធម៌

ក. តាមសេចក្តីដែលយើងបានចែងខាងលើ ព្រះសហគមន៍រំឭកមនុស្សទាំងអស់ថា វប្បធម៌ត្រូវមានគោលដៅអភិវឌ្ឍន៍បុគ្គលម្នាក់ៗទាំងស្រុង ព្រមទាំងនាំផលប្រយោជន៍ដល់សហគមន៍ និងដល់មនុស្សជាតិទាំងមូល។ ហេតុនេះ ត្រូវយកចិត្តទុកដាក់អប់រំចិត្តគំនិតមនុស្ស ដើម្បីពង្រីកសមត្ថភាពរបស់គេ ឲ្យចេះស្ញើចសរសើរ ឲ្យចេះនឹកសញ្ជឹងគិត និងឲ្យចេះវិនិច្ឆ័យដោយផ្ទាល់ខ្លួនបាន ព្រមទាំងនាំគេឲ្យចេះគិតដល់សាសនា ដល់សីលធម៌ និងដល់សង្គមផង។

ខ. ដោយវប្បធម៌ហូរចេញមកពីលក្ខណៈមនុស្ស ដែលចេះរិះគិត និងរស់នៅក្នុងសង្គម វប្បធម៌ត្រូវការសេរីភាពយ៉ាងត្រឹមត្រូវជានិច្ច ទើបវប្បធម៌អាចរីកចម្រើនឡើងបាន។ វប្បធម៌ក៏ត្រូវការស្វ័យភាព ដ៏គួរសម

ទើបអាចប្រព្រឹត្តកិច្ចការស្របតាមគោលការណ៍របស់ខ្លួន។ ហេតុនេះ ប្រសិនបើវប្បធម៌រក្សាសិទ្ធិបុគ្គលម្នាក់ៗ និងរក្សាសិទ្ធិសង្គម ដោយយកប្រយោជន៍រួមជាព្រំដែន វប្បធម៌មានសិទ្ធិឲ្យគេគោរព ហើយក៏មិនត្រូវឲ្យគេរំលោភសិទ្ធិសេរីភាពរបស់ខ្លួនដែរ។

គ. មហាសន្និបាតដ៏វិសុទ្ធនេះ យកសេចក្តីប្រៀនប្រដៅនៃមហាសន្និបាតវ៉ាទីកង់ ទី១ ទុកជាការប្រៀនប្រដៅរបស់ខ្លួនផ្ទាល់ សូមប្រកាសថា *"មានកម្រិតចំណេះចេះដឹងពីរយ៉ាងប្លែកពីគ្នា"* គឺមួយជាចំណេះចេះដឹងតាមជំនឿ ហើយមួយទៀតជា ចំណេះចេះដឹងតាមប្រាជ្ញា។ ព្រះសហគមន៍មិនជំទាស់នឹង សិល្បៈ និងចំណេះវិទ្យារបស់មនុស្សលោក ដែលយកគោលការណ៍ និងវិធីផ្ទាល់ មកប្រើតាមវិស័យរៀងៗខ្លួនឡើយ។ ហេតុនេះ ព្រះសហគមន៍ *"ទទួលស្គាល់សេរីភាពដ៏ត្រឹមត្រូវនេះ"* ហើយសូមប្រកាសថា វប្បធម៌ ជាពិសេសវិទ្យាសាស្ត្រនានាមានស្វ័យភាពពិតមែន។

ឃ.ការទាំងនេះ ទាមទារឲ្យមនុស្សមានសេរីភាព អាចស្វែងរកសេចក្តីពិតម ានសិទ្ធិធ្វើឲ្យគេស្គាល់យោបល់របស់ខ្លួន និងមានសិទ្ធិសេរីភាពផ្សព្វផ្សាយយោបល់របស់ខ្លួន ព្រមទាំងធ្វើតាមទំនោរចិត្តខាងសិល្បៈ តាមខ្លួនជ្រើសរើស។ មនុស្សមានសេរីភាពបែបនេះ លុះត្រាតែគេនៅតែរក្សារបៀបរៀបរយខាងសីលធម៌ និងមិនបំផ្លាញប្រយោជន៍រួម។ ត្រូវឲ្យគេទទួលស្គាល់ព្រឹត្តិការណ៍នៃជីវិតសាធារណៈថែមទៀតផង។

ង. ចំពោះរដ្ឋអំណាចវិញ រដ្ឋអំណាចមានភារកិច្ចតែងតាំងសភាពការណ៍ និងចាត់ចែងវិធានការណ៍ ដើម្បីជួយជីវិតវប្បធម៌ ឲ្យមានប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ ដោយមិនបំភ្លេចជនភាគតិច។ រដ្ឋអំណាច គ្មានភារកិច្ចបញ្ជាក់អំពីលក្ខណៈពិសេសនៃអរិយធម៌ទេ។ ហេតុនេះហើយ បានជាត្រូវជៀសវាង មិនឲ្យគេយកវប្បធម៌ មកប្រើខុសពីគោលដៅរបស់ខ្លួន និងមិនឲ្យស្ថិតនៅក្រោមអំណាចអ្នកនយោបាយ ឬអំណាចអ្នកសេដ្ឋកិច្ចជាដាច់ខាត។

# វគ្គទី ៣

## អំពីភារកិច្ចជាបន្ទាន់ខ្លះរបស់គ្រីស្តបរិស័ទចំពោះវប្បធម៌

### ៦០- មនុស្សទាំងអស់មានសិទ្ធិស្គាល់វប្បធម៌និងប្រព្រឹត្តកិច្ចការផ្សេងៗតាមវប្បធម៌ដែរ

ក. សព្វថ្ងៃ យើងមានលទ្ធភាពរំដោះមនុស្សភាគច្រើន ឲ្យរួចពីវិបត្តិនៃភាពអវិជ្ជា។ ហេតុនេះ មនុស្សសម័យឥឡូវ ជាពិសេសគ្រីស្តបរិស័ទ មានភារកិច្ចដ៏សំខាន់មួយ គឺខិតខំធ្វើយ៉ាងណា ឲ្យគេសម្រេចវិធានការជាគ្រឹះ ទាំងនៅវិស័យសេដ្ឋកិច្ចក្តី នៅវិស័យនយោបាយក្តី ទោះនៅក្នុងប្រទេសរបស់ខ្លួនក្តី នៅអន្តរជាតិក្តី ដើម្បីឲ្យគេទទួលស្គាល់ថា មនុស្សទាំងអស់នៅគ្រប់កន្លែង ដោយឥតប្រកាន់ជាតិសាសន៍ ប្រកាន់ភេទ សាសនា ជាតិ ឋានៈ វណ្ណៈ មានសិទ្ធិស្គាល់វប្បធម៌ និងយកមកអនុវត្តតាមដែរ។ សិទ្ធិនេះ ពិតជាស្របតាមតម្លៃដ៏ថ្លៃថ្នូររបស់មនុស្សមែន។ ហេតុនេះ ត្រូវផ្តល់សម្បត្តិ គ្រប់គ្រាន់ខាងវប្បធម៌ ជាពិសេសសម្បត្តិវប្បធម៌ជាគ្រឹះជូនមនុស្សម្នាក់ៗ ដើម្បីឲ្យមនុស្សទាំងអស់អាចរួមសហការរកប្រយោជន៍រួម តាមលក្ខណៈជាមនុស្សសុទ្ធសាធ។ សព្វថ្ងៃនៅតែមានមនុស្សមួយចំនួនធំណាស់ មិនអាចរួមសហការក្នុងការរកប្រយោជន៍រួមនេះ ព្រោះគេមិនចេះអក្សរ ហើយគ្មានគំនិតផ្តើមកិច្ចការអ្វីមួយឡើយ។ ត្រូវតែជួយអ្នកទាំងនោះ កុំឲ្យភាពអវិជ្ជារាំងផ្លូវគេឡើយ។

ខ. ហេតុនេះ ត្រូវខិតខំជួយអស់អ្នកដែលមានសមត្ថភាព ឲ្យរៀនខាងឧត្តមសិក្សា។ ពេលគេមានការងារប្រសិនបើគេអាចធ្វើបាន គេនឹងជួយបម្រើអ្នកដទៃក្នុងសង្គម ស្របតាមទេពកោល្យរបស់គេ និងតាមសមត្ថភាពដែលគេបានទទួលនោះ។ ដូច្នេះមនុស្សគ្រប់ៗរូប និងក្រុមទាំងប៉ុន្មានក្នុងសង្គម នៃប្រជាជននានា អាចទៅជាមនុស្សពេញលក្ខណៈខាងផ្លូវវប្បធម៌ ស្របតាមទេពកោសល្យ និងតាមប្រពៃណីរបស់គេ។

គ. ត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីឲ្យមនុស្សម្នាក់ៗភ្ញាក់ស្មារតី និងដឹងថា ខ្លួនមានសិទ្ធនិងមានភារកិច្ចអប់រំខ្លួនឯងខាងវប្បធម៌ ដូចខ្លួនមានភារកិច្ចជួយអ្នកដទៃ ឲ្យអប់រំខ្លួនគេខាងវប្បធម៌ដែរ។ នៅតំបន់ខ្លះ ជីវភាព និងសភាពការណ៍ការងារ ធ្លាប់រារាំងការខិតខំរបស់មនុស្ស មិនឲ្យឆ្លងទៅរកវប្បធម៌បាន ព្រមទាំងបំបាត់បំណង ដែលចង់ទទួលវប្បធម៌ទៀតផង។ សេចក្តីនេះ ចោទយ៉ាងពិសេសដល់ពួកកសិករ និងកម្មករ។ ត្រូវធ្វើយ៉ាងណាឲ្យប្រែសភាពការណ៍ការងារ កុំឲ្យរាំងគេក្នុងការទទួលវប្បធម៌ តែត្រូវជំរុញគេវិញ។ សព្វថ្ងៃ ស្ត្រីមានការងារស្ទើរតែនៅគ្រប់ផ្នែកក្នុងសកម្មភាពនានា។ ត្រូវផ្តល់ឲ្យស្ត្រីៗទាំងនោះ មានលទ្ធភាពអាចបំពេញតួនាទីក្នុងសង្គម តាមទេពកោសល្យរៀងៗខ្លួន។ មនុស្សទាំងអស់ មានភារកិច្ចទទួលស្គាល់ថា ស្ត្រីៗរួមសហការយ៉ាងពិសេស និងចាំបាច់ក្នុងជីវិតវប្បធម៌ ដូច្នេះត្រូវជួយស្ត្រីឲ្យពង្រីកចំណែករួមសហការនោះ។

## ៦១- ការអប់រំឲ្យទទួលវប្បធម៌រួម

ក. សព្វថ្ងៃ ពិបាកធ្វើសំយោគវិទ្យា និងផ្នែកទាំងប៉ុន្មាននៃចំណេះចេះដឹង។ ពិតជាពិបាកជាងពីសម័យមុនៗមែន។ មានកត្តាខាងវប្បធម៌កាន់តែច្រើនឡើងៗ និងប្លែកៗពីគ្នា តែនៅពេលជាមួយគ្នានេះ មនុស្សម្នាក់ៗមានសមត្ថភាពកាន់តែតិចឡើងៗ មិនអាចចាប់អារម្មណ៍នឹងកត្តាទាំងនោះ និងមិនអាចសម្រួលកត្តាទាំងនោះ ឲ្យបានភ្ជាប់ជាមួយគ្នាបាន។ ហេតុនេះ និមិត្តសញ្ញារបស់មនុស្សសកលជាគោលដៅនៃវប្បធម៌ ក៏កាន់តែរលាយបាត់ទៅៗ។ ប៉ុន្តែមនុស្សម្នាក់ៗ ក៏នៅតែមានភារកិច្ចរក្សាបុគ្គលិកលក្ខណៈរបស់ខ្លួនទាំងស្រុង គឺក្នុងបុគ្គលិកលក្ខណៈនេះ មនុស្សត្រូវរក្សាប្រាជ្ញា ចេតនា មនសិការ បំណងចង់រស់នៅជាមួយអ្នកដទៃទុកជាបងប្អូន។ សេចក្ដីទាំងនោះ សុទ្ធតែមានតម្លៃដែលចាក់ឫស ក្នុងព្រះជាម្ចាស់ ជាព្រះអាទិកររបស់មនុស្សលោក។ ព្រះគ្រីស្ដក៏បានព្យាបាលសេចក្ដីទាំងនេះឲ្យបានជា និងលើកតម្កើងយ៉ាងអស្ចារ្យ ក្នុងព្រះអង្គផ្ទាល់។

ខ. ជាបឋម ក្រុមគ្រួសារផ្ដល់ការអប់រំបែបនេះ ហាក់ដូចជាម្ដាយដែលចិញ្ចឹមកូនដូច្នោះដែរ។ ក្នុងក្រុមគ្រួសារឪពុកម្ដាយស្រឡាញ់កូនៗជាខ្លាំង កូនក៏ទទួលស្គាល់តម្លៃផ្សេងៗ តាមលំដាប់លំដោយដែរ។ កត្តានៃវប្បធម៌ ដែលដូនតាបានល្បងលមើលរួចហើយ ចាក់ក្នុងមនសិការកូនជំទង់ ដោយគេមិនដឹងខ្លួន នៅពេលគេកាន់តែធំធាត់ឡើងៗ។

គ. សង្គមនាបច្ចុប្បន្នកាល មានធនធានខាងវប្បធម៌ជាច្រើន ដែលអាចជួយអប់រំតាមវប្បធម៌បែបសកលនេះបាន។ ជាពិសេស មានបោះពុម្ពផ្សាយសៀវភៅកាន់តែច្រើនឡើង និងមានមធ្យោបាយទូរគមនាគមន៍ថ្មីៗខាងវប្បធម៌ និងខាងសង្គមផង ជាធនធានដែលអាចជួយបានតាមសេចក្ដីត្រូវការ។ សព្វថ្ងៃ មនុស្សស្ទើរតែទាំងអស់ ធ្វើការមានចំនួនម៉ោងកាន់តែតិចទៅៗ។ ដូច្នេះ មនុស្សភាគច្រើន មានឱកាសអប់រំខ្លួនខាងវប្បធម៌កាន់តែច្រើនឡើងៗដែរ។ សូមប្រើពេលលំហែកាយ តាមរបៀបឆ្លាតវាងវៃ គឺយកពេលនោះ ទៅសម្រាកពង្រឹងសុខភាពខាងវិញ្ញាណ និងខាងរូបកាយ។ គេប្រព្រឹត្តសកម្មភាពដោយសេរី សិក្សាដោយគ្មានរកប្រយោជន៍ភ្លាមៗទេ។ ក្នុងឱកាសធ្វើដំណើរទស្សនាប្រទេសផ្សេងៗ គឺធ្វើទេសចរណ៍ ត្រូវឆ្លៀតឱកាសសម្រួចចិត្តគំនិតឲ្យមោះមុត ទទួលផលប្រយោជន៍តាមការស្គាល់ប្រជាជនប្លែកៗគ្នា។ ការហាត់ប្រាណ ឬកីឡា ជួយឲ្យមានសុខភាពល្អខាងវិញ្ញាណរបស់បុគ្គលម្នាក់ៗ និងរបស់សង្គម ហើយក៏បណ្ដាលឲ្យកើតទំនាក់ទំនងដូចបងប្អូន ជាមួយមនុស្ស ឋានៈ វណ្ណៈគ្រប់ស្រទាប់ និងគ្រប់ជាតិសាសន៍ទៀតផង។ សូមគ្រីស្ដបរិស័ទ ចូលរួមក្នុងការសម្ដែងវប្បធម៌រួម ស្របតាមសម័យ ហើយសូមជួយឲ្យការសម្ដែងទាំងនោះបាន ប្រកបដោយលក្ខណៈជាមនុស្សសុទ្ធសាធ និងជ្រួតជ្រាបដោយគំនិតជាគ្រីស្ដបរិស័ទទៀតដែរ។

ឃ. ប៉ុន្តែ អត្ថប្រយោជន៍ទាំងនោះ អាចអប់រំមនុស្សទាំងស្រុងខាងវប្បធម៌បាន លុះត្រាតែនៅពេលជាមួយគ្នានោះ គេយកចិត្តទុកដាក់សួរសំណួរដ៏សំខាន់ គឺស្វែងរកអត្ថន័យដ៏ជ្រៅនៃវប្បធម៌ និងនៃវិទ្យាសាស្ត្រ ចំពោះមនុស្សយើង។

## ៦២- វប្បធម៌និងគ្រីស្ដសាសនា

ក. ទោះបីកាលពីដើម ព្រះសហគមន៍បានជួយពង្រីកវប្បធម៌យ៉ាងណាក្ដី ក៏បទពិសោធន៍បង្ហាញឲ្យដឹងថា

វប្បធម៌ និងគ្រីស្តសាសនា មិនងាយស្រុះស្រួលគ្នាបានទេ ដោយមានមូលហេតុផ្សេងៗកើតឡើង តាមសម័យនីមួយៗ។

ខ. ការពិបាកទាស់ទែងទាំងនោះ មិនបណ្តាលឲ្យជីវិតរស់រវើកនៃជំនឿអន់ថយទេ ជួនកាលការពិបាកទាំងនោះ អាចជួយគ្រីស្តបរិស័ទឲ្យយល់អំពីជំនឿកាន់តែត្រឹមត្រូវ និងកាន់តែជ្រៅផង។ ឧបមាថា សេចក្តីដែលវិទ្យាសាស្ត្របានស្រាវជ្រាវរកឃើញថ្មីៗ និងសេចក្តីដែលប្រវត្តិសាស្ត្រ និងទស្សនវិទ្យាបានស្វែងរក និងរកឃើញថ្មីនោះដែរ ចោទសំណួរថ្មីៗ ដែលមានផលសម្រាប់ជីវិតមនុស្សយើងផ្ទាល់ និងទាមទារឲ្យទេវវិទូយកចិត្តទុកដាក់សិក្សា និងស្វែងរកតទៅទៀតដែរ។ អស់លោកគោរពវិធី និងក្បួនតម្រាផ្ទាល់របស់វិទ្យាសាស្ត្រនៃទេវវិទ្យា តែអស់លោកត្រូវយកចិត្តទុកដាក់ ខិតខំពន្យល់ និងចែករំលែកលទ្ធិនៃគ្រីស្តសាសនា ឲ្យមនុស្សនាសម័យរបស់អស់លោកយល់កាន់តែស្រួល តាមសម័យគេរស់នៅ។ មានបញ្ញើដ៏ថ្លៃថ្នូរនៃជំនឿ និងសេចក្តីពិតរបស់ជំនឿមែន។ ក៏ប៉ុន្តែ របៀបរៀបរាប់ពន្យល់ និងប្រកាសសេចក្តីទាំងនោះ ប្លែកពីរបៀបកត់ត្រាទុកក្នុងបញ្ញើនៃជំនឿ ដែលទេវវិទូត្រូវតែរក្សាទុកអត្ថន័យ និងទិសដៅតែប៉ុណ្ណោះ។ សូមអស់លោកដែលទទួលបន្ទុកណែនាំគ្រីស្តបរិស័ទ ត្រូវមានចំណេះចេះដឹងគ្រប់គ្រាន់ អំពីសេចក្តី ដែលវិទ្យាសាស្ត្របានរកឃើញតាមផ្លូវលោក ជាពិសេសអំពីចិត្តសាស្ត្រ និងសង្គមវិទ្យា ដោយមិនគ្រាន់តែស្គាល់គោលការណ៍នៃទេវវិទ្យាប៉ុណ្ណោះទេ។ សូមប្រើវិទ្យាទាំងប៉ុន្មាននោះទៀតផង។ ដូច្នេះ គ្រីស្តបរិស័ទក៏នឹងមានជំនឿកាន់តែបរិសុទ្ធ និងកាន់តែទៅជាមនុស្សពេញវ័យ តាមជំនឿទៀតផង។

គ. អក្សរសាស្ត្រ និងសិល្បៈ មានសារៈសំខាន់ក្នុងការរស់នៅរបស់ព្រះសហគមន៍ តាមវិស័យរៀងៗខ្លួន។ អក្សរសាស្ត្រ និងសិល្បៈ ខិតខំបង្ហាញអំពីលក្ខណៈផ្ទាល់របស់មនុស្ស សម្តែងអំពីបញ្ហារបស់គេ អំពីការប៉ុនប៉ងឲ្យស្គាល់ខ្លួនឯងកាន់តែច្បាស់ និងអំពីការប៉ុនប៉ងធ្វើឲ្យខ្លួន និងមនុស្សលោកចម្រើនឡើងផង។ អក្សរសាស្ត្រ និងសិល្បៈ យកចិត្តទុកដាក់រកកន្លែង និងតួនាទីរបស់មនុស្សក្នុងប្រវត្តិសាស្ត្រ និងក្នុងពិភពលោក និងសម្តែងទាំងភាពកម្សត់របស់មនុស្សផង និងអំណរសប្បាយរបស់គេផង។ អក្សរសាស្ត្រ និងសិល្បៈ បង្ហាញសេចក្តីត្រូវការ និងកម្លាំងចិត្តរបស់មនុស្សលោក និងសម្តែងការព្រាងទុកនៃវាសនាមនុស្សដ៏សប្បាយជាងសម័យឥឡូវ។ ដូច្នេះ អក្សរសាស្ត្រនិងសិល្បៈ អាចលើកស្ទួយជីវិតមនុស្ស ដោយចែងតាមរបៀបផ្សេងៗ ស្របតាមសម័យ និងតាមកន្លែងផ្សេងៗក្នុងពិភពលោកផង។

ឃ. ហេតុនេះ ត្រូវឲ្យអស់អ្នកជំនាញខាងអក្សរសាស្ត្រនិងសិល្បៈ យល់ឃើញថា ព្រះសហគមន៍រាប់រកគេ ហើយពេញចិត្តនឹងស្នាដៃរបស់គេ។ សូមឲ្យគេមានសិទ្ធិសេរីភាពជាធម្មតា និងមានទំនាក់ទំនងយ៉ាងស្រួលជាមួយសហគមន៍នៃគ្រីស្តបរិស័ទ។ សូមព្រះសហគមន៍ទទួលស្គាល់សិល្បៈថ្មី តាមទំនើបចិត្តរបស់មនុស្សសម័យឥឡូវ ស្របតាមទេពកោសល្យប្រជាជននានា ហើយក៏ស្របតាមតំបន់ដែរ។ ពេលសិល្បៈទាំងនោះស្របតាមអរិយធម៌របស់គេ និងត្រូវតាមក្បួនវិន័យពីធីគោរពប្រណិប័តន៍ សឹមព្រះសហគមន៍ទទួលសិល្បៈទាំងនោះក្នុងព្រះវិហារ (ពិធី ១២៣)។

ង. ធ្វើដូច្នោះ មុខជាសិរីរុងរឿងរបស់ព្រះជាម្ចាស់ លេចចេញធ្លោកាន់តែត្រចះត្រចង់ឡើង មនុស្សយល់ការប្រកាសដំណឹងល្អកាន់តែច្បាស់ ហាក់ដូចជារបៀបធម្មតានៃការរស់នៅរបស់គេ។

ច. សូមឲ្យគ្រីស្តបរិស័ទ រស់នៅរួមយ៉ាងជិតស្និទ្ធជាមួយមនុស្សឯទៀតៗ នៅសម័យរបស់គេ។ សូមឲ្យគ្រីស្ត

បរិស័ទយកចិត្តទុកដាក់ខិតខំយល់ឲ្យមែនទែន អំពីរបៀបរិះគិតទាំងស្រុងរបស់គេ និងអំពីរបៀបយល់ឃើញក្នុងការរស់នៅរបស់គេ តាមវប្បធម៌ដែលសម្ដែងចេញមក។ សូមឲ្យគ្រីស្តបរិស័ទទទួលចំណេះចេះដឹងនៃវិទ្យាសាស្ត្រ និងនៃទ្រឹស្តីថ្មីៗ ព្រមទាំងយកសេចក្ដី ដែលអ្នកប្រាជ្ញរកឃើញថ្មីៗនោះដែរ មកបញ្ចូលរួមជាមួយកិរិយាមារយាទ និងលទ្ធិនៃគ្រីស្តសាសនាផង។ ធ្វើដូច្នេះ គេអាចយល់ថា គំនិតអំពីសាសនា និងសីលធម៌ដ៏ទៀងត្រង់ អាចរួមជាមួយចំណេះចេះដឹងខាងវិទ្យាសាស្ត្រ និងជាមួយការចម្រើនដ៏ឥតឈប់ឈរនៃបច្ចេកទេសផង។ ហេតុនេះ គ្រីស្តបរិស័ទអាចចូលចិត្តរាប់រកនិងបកស្រាយអត្ថន័យអ្វីៗទាំងអស់ ដោយមានចិត្តគំនិតជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដមែន។

ឆ. សូមអស់គ្រីស្តបរិស័ទកំពុងតែរៀនវិទ្យាសាស្ត្រនៃទេវវិទ្យា ក្នុងទេវវិទ្យាល័យនិងសកលវិទ្យាល័យ យកចិត្តទុកដាក់ រួមសហការជាមួយមនុស្សស្ទាត់ជំនាញ ខាងវិទ្យាសាស្ត្រផ្សេងៗ យកកម្លាំង និងទស្សនៈរបស់ខ្លួនមកដាក់រួមគ្នា។ ការស្រាវជ្រាវខាងទេវវិទ្យា រិះគិតឲ្យកាន់តែជ្រៅអំពីសេចក្ដីពិត ដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់។ តែការស្រាវជ្រាវនោះ ក៏ត្រូវមានទំនាក់ទំនងជាមួយមនុស្សលោកនាសម័យរបស់ខ្លួនដែរ ដើម្បីជួយមនុស្សឲ្យមានវប្បធម៌ខ្ពស់ តាមសាខានៃចំណេះចេះដឹងរបស់ខ្លួន អាចយល់លទ្ធិនៃជំនឿឲ្យកាន់តែច្បាស់ឡើងៗផង។ ការយល់ចិត្តគំនិតគ្នាដូច្នេះ ពិតជានឹងជួយបម្រើក្នុងការអប់រំអ្នកបំពេញមុខងារបម្រើព្រះសហគមន៍ជាពុំខាន។ អ្នកបំពេញមុខងារបម្រើទាំងនោះ នឹងមានសមត្ថភាពអាចសម្ដែងលទ្ធិរបស់ព្រះសហគមន៍អំពីព្រះជាម្ចាស់ អំពីមនុស្ស អំពីពិភពលោក ស្របតាមរបៀបមនុស្សលោកនាសម័យយើងបាន។ អ្នកដទៃ មុខជានឹងកាន់តែសុខចិត្តទទួលពាក្យសម្ដីរបស់អស់លោកជាពុំខាន (ហ្វឹកហ្វឺន)។ លើសពីនេះទៅទៀត យើងត្រូវសំណូមពរ ឲ្យមានគ្រីស្តបរិស័ទធម្មតាជាច្រើន ទទួលការអប់រំគ្រប់គ្រាន់ ខាងវិទ្យានៃគ្រីស្តសាសនាយើង ព្រមទាំងឲ្យមានគ្នាច្រើនយកចិត្តទុកដាក់ រៀនវិទ្យាទាំងនោះតាមរយៈសាស្ត្រាចារ្យ និងរៀនឲ្យកាន់តែជ្រៅទៅៗទៀតផង។ ប៉ុន្តែ សូមព្រះសហគមន៍ ទទួលស្គាល់សិទ្ធិសេរីភាពដ៏ត្រឹមត្រូវរបស់គ្រីស្តបរិស័ទ ទាំងអ្នកដែលទទួលអគ្គសញ្ញាតែងតាំង ទាំងគ្រីស្តបរិស័ទធម្មតា ក្នុងការស្រាវជ្រាវនិងក្នុងការរិះគិត។ សូមឲ្យអ្នកទាំងនោះមានសិទ្ធិសេរីភាពដ៏ត្រឹមត្រូវ និងសម្ដែងទស្សនៈរបស់គេក្នុងវិស័យនៃសមត្ថភាពរបស់ខ្លួន ដោយចិត្តសុភាពរាបសា និងដោយចិត្តក្លាហានដែរ (ពន្លឺ ៣៧)។

# ជំពូក ៣

## ការរស់នៅក្នុងសង្គម និង សេដ្ឋកិច្ច

### ៦៣- លក្ខណៈខ្លះនៃសេដ្ឋកិច្ចនាបច្ចុប្បន្នកាល

ក- ក្នុងការរស់នៅក្នុងសង្គមនិងតាមសេដ្ឋកិច្ច យើងត្រូវតែគោរព និងពង្រីកតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស តាមព្រះជាម្ចាស់ បានកំណត់ទុក និងត្រាស់ហៅ ហើយក៏ត្រូវគិតដល់ផលប្រយោជន៍របស់សង្គមទាំងមូលដែរ។ មនុស្សជាអ្នកបង្កើត ការរស់នៅក្នុងសង្គមនិងជាអ្នកបង្កើតសេដ្ឋកិច្ច។ សង្គម និងសេដ្ឋកិច្ច មានទិសដៅបម្រើមនុស្ស។

ខ- សេដ្ឋកិច្ចទំនើប ក៏ដូចវិស័យឯទៀតៗទាំងអស់ នៃការរស់នៅក្នុងសង្គមដែរ គឺបង្ហាញបញ្ជាក់អំពីអំណាចរបស់មនុស្សកាន់តែខ្លាំងឡើងទៅលើធម្មជាតិ បង្ហាញអំពីទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ក្រុម និងប្រជាជននានាកាន់តែច្រើន និងកាន់តែខ្លាំងឡើងៗ។ បុគ្គល ក្រុម និងប្រជាជននានាត្រូវការគ្នាទៅវិញទៅមកកាន់តែខ្លាំងដែរ។ ម៉្យាងទៀត រដ្ឋអំណាចធ្លាប់ធ្វើអន្តរាគមន៍កាន់តែញឹកញាប់ ក្នុងការរស់នៅក្នុងសង្គម និងក្នុងសេដ្ឋកិច្ច។ នៅពេលជាមួយគ្នានេះ មធ្យោបាយក្នុងការបង្កើតផលិតផលចម្រើនឡើង ហើយការចាត់ចែងការលក់ដូរទំនិញ និងសេវាកម្មក៏ចម្រើនឡើងដែរ បណ្តាលឲ្យសេដ្ឋកិច្ចទៅជាគ្រឿងអាចបំពេញតម្រូវការនៃមហាគ្រួសារមនុស្សលោក ហើយតម្រូវការនេះមានកាន់តែច្រើនៗ។

គ- ប៉ុន្តែ មានមូលហេតុជាច្រើន បណ្តាលឲ្យព្រួយបារម្ភដ៏ចតទៅ៖ មានមនុស្សជាច្រើន ជាពិសេសក្នុងប្រទេសសេដ្ឋកិច្ចជឿនលឿន ហាក់ដូចជានៅក្រោមការត្រួតត្រារបស់សេដ្ឋកិច្ចតែម្តង។ ស្ទើរតែគ្រប់ពេលគេរស់នៅដោយតម្រង់យកសេដ្ឋកិច្ចធ្វើជាគោលណែនាំការរស់របស់គេ ទាំងក្នុងឋានៈគេជាបុគ្គល ទាំងក្នុងឋានៈគេជាប្រជាពលរដ្ឋរួមរស់ក្នុងសង្គម។ សូម្បីតែនៅប្រទេសកាន់សេដ្ឋកិច្ចសង្គមនិយមក្តី ឬកាន់របបសេដ្ឋកិច្ចផ្សេងក្តី ក៏មានសភាពការណ៍បែបនេះដែរ។ ប្រសិនបើមនុស្សចេះតម្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យមានរបៀបរៀបរយ និងតាមប្រាជ្ញាក្នុងលក្ខណៈខ្លួនជាមនុស្ស មុខជាការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ អាចជួយបំបាត់ភាពមិនស្មើគ្នាខ្លះក្នុងសង្គម។ តែតាមពិត ការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ ជាញឹកញាប់បណ្តាលឲ្យមនុស្សមានឋានៈ វណ្ណៈ កាន់តែមិនស្មើគ្នាវិញ។ ជួនកាលសភាពការណ៍សង្គមរបស់អ្នកទន់ខ្សោយកាន់តែធ្ងន់ធ្ងរ ហើយអ្នកក្រីក្រត្រូវគេមើលងាយទៀតផង។ ពេលមហាជនដ៏ច្រើនអនេកខ្វះខាតអ្វី ដែលគេត្រូវការជាចាំបាច់ ក៏មានអ្នកខ្លះ រស់នៅដោយមានទ្រព្យសម្បត្តិស្តុកស្តម្ភ ចេះតែចាយវាយខ្ជះខ្ជាយទៀតផងដែរ។ សូម្បីតែក្នុងតំបន់សេដ្ឋកិច្ចអន់ក៏មានដូច្នេះដែរ។ អ្នកមានបរិបូរណ៍ហូរហៀរ រស់នៅក្បែរអ្នកក្រីក្រតោកយ៉ាក។ ក្រុមមនុស្សមួយចំនួនតូច កាន់អំណាចយ៉ាងទូលំទូលាយ អាចសម្រេចអ្វីទាំងអស់ ក៏បាន តែមនុស្សមួយចំនួនធំ ស្ទើរតែគ្មានលទ្ធភាពចាប់ផ្តើមធ្វើអ្វីកើតដោយខ្លួនផ្ទាល់ ហើយក៏មិនអាច

ទទួលខុសត្រូវលើអ្វីបានសោះ។ ជាទូទៅអ្នកទាំងនោះ រស់នៅនិងធ្វើការ មិនសមតាមឋានៈខ្លួនជាមនុស្ស ក៏មានដែរ។

ឃ-សភាពការណ៍គ្មានរបៀបតាមសេដ្ឋកិច្ចនិងតាមសង្គមទាំងនោះ កើតឡើងក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មចំណែកជីវភាពរបស់ប្រជាជន តាមតំបន់ផ្សេងៗក្នុងប្រទេសតែមួយ ក៏មិនស្មើគ្នាដែរ។ ប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងប្រទេសឯទៀតៗ ទាស់ទែងគ្នាកាន់តែខ្លាំងឡើងៗ។ សភាពការណ៍នេះ អាចបណ្ដាលឲ្យបំផ្លាញសន្តិភាពក្នុងពិភពលោក។

ង- មនុស្សនាសម័យឥឡូវ ដឹងខ្លួនកាន់តែច្បាស់អំពីភាពមិនស្មើគ្នានោះ។ គេជឿជាក់ថា បច្ចេកទេសថ្មី និងធនធានសេដ្ឋកិច្ច ដែលមនុស្សលោកមានកាន់តែច្រើនឡើងៗ អាចនឹងត្រូវកែសម្រួលសភាពការណ៍ដ៏អាក្រក់នេះបាន។ ប៉ុន្តែ ត្រូវកែទម្រង់សេចក្ដីជាច្រើន ក្នុងការរស់នៅខាងសេដ្ឋកិច្ច និងក្នុងសង្គមជាចាំបាច់។ ត្រូវឲ្យមនុស្សទាំងអស់ ប្រែចិត្តគំនិតនិងកែឥរិយាបថ។ តាមដំណើរសតវត្សទាំងប៉ុន្មានកន្លងមក ព្រះសហគមន៍បានយកពន្លឺនៃដំណឹងល្អ មកបញ្ចេញបញ្ជាក់គោលការណ៍ផ្សេងៗ សម្រាប់ណែនាំមនុស្សក្នុងវិស័យយុត្តិធម៌ និងសមភាព ស្របតាមប្រាជ្ញាដ៏ទៀងត្រង់របស់មនុស្ស។ គោលការណ៍ទាំងនោះ អាចណែនាំការរស់នៅរបស់បុគ្គលម្នាក់ ណែនាំសង្គម ព្រមទាំងណែនាំការរស់នៅអន្តរជាតិផងដែរ។ ព្រះសហគមន៍បានប្រកាសគោលការណ៍ទាំងនោះ ជាពិសេសនៅប៉ុន្មានឆ្នាំកន្លងមកនេះ។ ដោយចាប់អារម្មណ៍នឹងសភាពការណ៍នាបច្ចុប្បន្នកាលនេះ មហាសន្និបាតមានបំណងចង់បញ្ជាក់គោលការណ៍ទាំងនោះ និងបង្ហាញការណែនាំខ្លះទៀត ជាពិសេសដោយយល់ដល់សេចក្ដីទាមទារនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។

# វគ្គទី ១

## ការអភិវឌ្ឍន៍សេដ្ឋកិច្ច

### ៦៤-ការអភិវឌ្ឍន៍សេដ្ឋកិច្ចត្រូវបម្រើមនុស្ស

នៅសម័យឥឡូវជាងនៅសម័យមុនៗទៅទៀត មនុស្សខិតខំពង្រីកផលិតផល ទាំងខាងកសិកម្ម ទាំងខាងឧស្សាហកម្ម ទាំងខាងសេវាកម្មផ្សេងៗជូនប្រជាជនដែរ។ គេខិតខំនេះល្អត្រឹមត្រូវដូច្នេះ ដើម្បីទប់ទល់នឹងសេចក្តីត្រូវការរបស់មនុស្ស ដែលមានចំនួនកើនឡើងជាលំដាប់ និងដើម្បីតបឆ្លើយនឹងសេចក្តីប៉ងប្រាថ្នាកាន់តែទូលំទូលាយរបស់មនុស្សជាតិទៀតផង។ ហេតុនេះហើយ ត្រូវតែជួយគាំទ្របច្ចេកទេស ដែលជឿនលឿនជាលំដាប់ ជួយគាំទ្រអ្នកមានគំនិតចង់កែប្រែអ្វីៗឲ្យបានទំនើប ជួយគាំទ្រអ្នកបង្កើត និងពង្រីកសហគ្រាស ជួយគាំទ្រអ្នកខិតខំធ្វើឲ្យមធ្យោបាយបង្កើតផលិតផលនានាបាន ស្របតាមសម័យ ព្រមទាំងជួយគាំទ្រអស់អ្នកដែលខិតខំរួមបង្កបង្កើតផលិតផល។ សរុបសេចក្តីមក ត្រូវជួយគាំទ្រអ្វីៗទាំងអស់ ដែលអាចជួយឲ្យសេដ្ឋកិច្ចលូតលាស់ឡើង។ ប៉ុន្តែត្រូវនឹកចាំថា ការបង្កបង្កើនផលិតផលនោះ ពុំគ្រាន់តែមានគោលដៅឲ្យប្រជាជន បានទ្រព្យសម្បត្តិជាច្រើន ពុំមែនឲ្យគេប្រមូលធនធានបាន ឬឲ្យមានអំណាចខ្លាំងក្លាប៉ុណ្ណោះទេ។ ការបង្កើនផលិតផល មានគោលដៅកំពូលតែមួយ គឺបម្រើមនុស្សទាំងស្រុង តាមសេចក្តីត្រូវការរបស់ខ្លួន ដែលមានតម្លៃតាមលំដាប់លំដោយ មានសេចក្តីត្រូវការខាងសម្ភារៈប្រើប្រាស់ សេចក្តីត្រូវការជីវិតខាងប្រាជ្ញា សេចក្តីត្រូវការខាងសីលធម៌ សេចក្តីត្រូវការខាងវិញ្ញាណ និងខាងសាសនា។ ការបង្កើនផលិតផល ក៏មានគោលដៅបម្រើមនុស្សគ្រប់ៗរូបគ្រប់ ក្រុមដោយមិនរើសជាតិសាសន៍ ឬទីបណាឡើយ។ ហេតុនេះហើយបានជាសកម្មភាពខាងសេដ្ឋកិច្ច ដែលតែងតែអនុវត្តតាមមធ្យោបាយ និងតាមក្បួនច្បាប់របស់ខ្លួនក៏ត្រូវតែអនុវត្តតាមរបៀបរៀបរយ នៃសីលធម៌បានកំណត់ដែរ ដើម្បីបំពេញគម្រោងការរបស់ព្រះជាម្ចាស់អំពីមនុស្ស (មថ ១៦, ២៦; លក ១៦, ១-៣១; កូឡ ៣, ១៧)។

### ៦៥- មនុស្សត្រូវត្រួតត្រាការអភិវឌ្ឍន៍សេដ្ឋកិច្ច

ក- មនុស្សត្រូវតែត្រួតត្រាការអភិវឌ្ឍន៍សេដ្ឋកិច្ច។ កុំទុកការអភិវឌ្ឍន៍សេដ្ឋកិច្ច ឲ្យស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សតែមួយចំនួនតូច ដែលអាចសម្រេចអ្វីៗទាំងអស់តាមទំនើងចិត្តរបស់គេ។ កុំទុកការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ ឲ្យស្ថិតនៅក្នុងកណ្តាប់ដៃក្រុមតូចមួយចំនួន ដែលមានអំណាចខាងសេដ្ឋកិច្ចខ្លាំងពេក ក៏កុំទុកការអភិវឌ្ឍន៍សេដ្ឋកិច្ច ឲ្យស្ថិតនៅក្នុងកណ្តាប់ដៃសហគមន៍របស់អ្នកនយោបាយ ឬរបស់មហាអំណាចមួយចំនួនត្រួតឡើយ។ ផ្ទុយទៅវិញ ត្រូវឲ្យមានចំនួនមនុស្សច្រើនពីគ្រប់កម្រិតតាមតែអាចរកបាន និងពីគ្រប់ប្រជាជាតិ តាមអន្តរជាតិ រួមចំណែកយ៉ាងសកម្មក្នុងការតម្រង់ទីដៅនៃការអភិវឌ្ឍន៍នោះ។ ត្រូវឲ្យបុគ្គលដែលមានគំនិតចង់ចាប់ផ្តើមធ្វើការអ្វីមួយដោយខ្លួនឯង និងសមាគមសេរីរបស់គេ រួមសហការជាមួយរដ្ឋអំណាច ហើយមានទំនាក់ទំនងជាមួយគ្នាតាមសម្រួលទៀតផង។

ខ- មិនត្រូវបណ្តោយឲ្យបុគ្គលនានា ត្រួតត្រាការអភិវឌ្ឍន៍ ដោយសកម្មភាពខាងសេដ្ឋកិច្ចរបស់គេ ហាក់ដូចជាតាមការស្វ័យប្រវត្តិ ក៏មិនត្រូវបណ្តោយឲ្យរដ្ឋអំណាចត្រួតត្រាការអភិវឌ្ឍន៍ដោយឯកឯងឡើយ។ ហេតុនេះ ត្រូវបដិសេធយោបល់ខុសទំនង និងលទ្ធិខ្លះដែលជំទាស់នឹងការកែទម្រង់សេដ្ឋកិច្ច ព្រោះគេយល់ច្រឡំអំពីសេរីភាព។ តាមពិតសេដ្ឋកិច្ចត្រូវតែកែទម្រង់ជាចាំបាច់។ លទ្ធិទាំងនោះ មិនរវីរវល់និងសិទ្ធិបុគ្គល និងសិទ្ធិរបស់ក្រុម តែបែរជាមានបំណងចង់ចាត់ចែងការបង្កើនផលិតផលជាសមូហភាពវិញ។

គ- ម៉្យាងទៀត ប្រជាពលរដ្ឋត្រូវនឹកចងចាំជានិច្ចថា ខ្លួនមានសិទ្ធិនិងមានភារកិច្ចរួមសហការតាមលទ្ធភាពរបស់ខ្លួន នាំឲ្យសហគមន៍របស់ខ្លួនអភិវឌ្ឍន៍ឡើងយ៉ាងពិតប្រាកដ។ រដ្ឋអំណាចក៏ត្រូវទទួលស្គាល់សិទ្ធិ និងភារកិច្ចទាំងនោះដែរ។ ជាពិសេស នៅប្រទេសកំពុងតែអភិវឌ្ឍន៍ឡើង ត្រូវប្រើអ្វីៗទាំងអស់ ដែលអាចប្រើបានជាបន្ទាន់ ដើម្បីឲ្យប្រទេសនោះអាចលូតលាស់ឡើងបានជាចាំបាច់។ អស់អ្នកដែលទុកធនធានរបស់ខ្លួន មិនឲ្យគេប្រើប្រាស់អ្នកទាំងនោះ បំផ្លាញប្រយោជន៍រួមជាខ្លាំង។ អស់អ្នកដែលដកហូតទ្រព្យ ខាងសម្ភារៈក្តី ខាងវិញ្ញាណក្តី ពីសហគមន៍របស់ខ្លួន ដែលត្រូវការធនធានទាំងនោះជាចាំបាច់ ក៏បំផ្លាញប្រយោជន៍រួមដែរ។ ប៉ុន្តែ ត្រូវរក្សាទុកសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ ឲ្យចេញពីប្រទេសរបស់ខ្លួនទៅរស់នៅប្រទេសផ្សេងបាន។

## ៦៦- ត្រូវខិតខំធ្វើឲ្យមនុស្សបានស្មើគ្នាខាងសេដ្ឋកិច្ច និងក្នុងសង្គម

ក- ត្រូវខិតខំយ៉ាងខ្លាំងបំផុត បំបាត់ឲ្យបានឆាប់រហ័ស នូវភាពមិនស្មើដ៏ធំទំលំទូលាយខាងសេដ្ឋកិច្ច ដែលបណ្តាលឲ្យរើសអើងបុគ្គលនិងសង្គម។ ធ្វើដូច្នេះ ទើបយើងអាចតបឆ្លើយនិងយុត្តិធម៌និងភាពស្មើគ្នាបាន។ ប៉ុន្តែ ត្រូវគោរពសិទ្ធិបុគ្គលម្នាក់ៗ និងគោរពទេពកោសល្យរបស់ប្រជាជាតិនីមួយៗដែរ។ នាបច្ចុប្បន្នកាល សេដ្ឋកិច្ចនៅតែមានភាពមិនស្មើគ្នា ហើយភាពមិនស្មើនោះកាន់តែធ្ងន់ធ្ងរទៀតផង។ នៅតំបន់ជាច្រើនពិបាកបង្កើតផលិតផលកសិកម្ម និងលក់ផលិតផលទាំងនោះ ដោយមូលហេតុផ្សេងៗ។ ក្នុងតំបន់ទាំងនោះ ត្រូវជួយកសិករឲ្យពង្រីកការបង្កបង្កើតផលិតផល និងជួយឲ្យគេអាចលក់ផលិតផលបាន ឲ្យប្រែរបៀបបង្កបង្កើតផល និងឲ្យរកមធ្យោបាយថ្មីតាមសេចក្តីត្រូវការ ព្រមទាំងឲ្យគេមានកម្រៃគួរសមផង។ បើពុំនោះទេ កសិករទាំងនោះនឹងនៅតែជាប្រជាពលរដ្ឋកម្រិតទាបទៀត ដូចមាននៅតំបន់ជាច្រើន។ រីឯកសិករវិញ ជាពិសេសយុវជន ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង ពង្រីកសមត្ថភាពរបស់ខ្លួនខាងចំណេះកសិកម្ម។ បើកសិករគ្មានសមត្ថភាពខាងអាជីវកម្មរបស់ខ្លួនទេ កសិកម្មមិនអាចចម្រើនលូតលាស់បានឡើយ។

ខ- កម្មករត្រូវតែផ្លាស់ប្តូរកន្លែងនិងអាជីវកម្ម តាមតម្រូវការនៃសេដ្ឋកិច្ចដែលកំពុងតែចម្រើនឡើង។ ប៉ុន្តែ ត្រូវចាត់ចែងការផ្លាស់ប្តូរនេះ ដើម្បីឲ្យបុគ្គលនានា និងក្រុមគ្រួសារមានសភាពការណ៍ជីវភាពនឹងន ហើយស្ថិតស្ថេរ។ ពលករមកពីបរទេសឬមកពីតំបន់ដទៃ ជួយសេដ្ឋកិច្ចប្រជាជនប្រទេស ឬតំបន់ដែលគេទៅរស់នៅ។ ត្រូវប្រុងប្រយ័ត្ន កុំរើសអើងគេគ្រប់យ៉ាង គឺរើសអើងខាងបៀវត្ស កុំឲ្យមានប្រាក់ឈ្នួលតិចជាងអ្នកកើតក្នុងស្រុក រើសអើងខាងសភាពការណ៍ការងារ កុំឲ្យធ្វើការតាមរបៀបពិបាកជាងអ្នកកើតក្នុងស្រុក។ល។ ម៉្យាងទៀត សមាជិកទាំងអស់ក្នុងសង្គម ជាពិសេសរដ្ឋអំណាច ត្រូវរាប់រកគេទុកជាមនុស្ស ពុំរាប់គេទុកជាគ្រឿងឧបករណ៍បង្កបង្កើតផលិតផលនោះទេ។ ត្រូវសម្រួលឲ្យក្រុមគ្រួសាររបស់គេ អាច

មករស់នៅជាមួយ ជួយរកផ្ទះឲ្យគេនៅយ៉ាងគួរសម និងជួយគេឲ្យចូលរួមក្នុងសង្គមប្រទេស ឬតំបន់ដែលគេមករស់នៅថ្មីនោះ។ ក៏ប៉ុន្តែ ប្រសិនបើអាចធ្វើបាន ត្រូវជួយបង្កើតការងារក្នុងប្រទេស និងតំបន់កំណើតរបស់គេ។

គ- ក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងតែផ្លាស់ប្ដូរ ក៏ដូចរបៀបរស់នៅថ្មីតាមសង្គមខាងសេដ្ឋកិច្ចដែរ (ឧបមាសេដ្ឋកិច្ច ដែលមានគ្រឿងម៉ាស៊ីនធ្វើការស្វយ័តជំនួសមនុស្សកាន់តែច្រើនឡើង) ត្រូវចាប់អារម្មណ៍ផ្ដល់ការងារគ្រប់គ្រាន់ និងត្រូវតាមសមត្ថភាពកម្មករ។ ត្រូវផ្ដល់ឲ្យកម្មករមានលទ្ធភាពទទួលការអប់រំខាងបច្ចេកទេស និងខាងអាជីវកម្ម។ ត្រូវធានាជីវភាពរបស់អស់អ្នកដែលរស់នៅយ៉ាងពិបាកជាងគេ ជាពិសេសអ្នកមានជំងឺ មនុស្សចាស់ជរា ឲ្យរស់សមនឹងឋានៈរបស់ខ្លួនជាមនុស្ស។

# ជំពូកទី ២

## គោលការណ៍ណែនាំជាទូទៅក្នុងការរស់នៅតាមសេដ្ឋកិច្ចនិងសង្គម

### ៦៧- ការងារ សាភាពការណ៍ការងារ និងការលំហែកាយ

ក- ការងាររបស់មនុស្សលោក គឺការងារដែលផលិតទ្រព្យសម្បត្តិផ្សេងៗ និងប្តូរទ្រព្យសម្បត្តិទាំងនោះ ទៅវិញទៅមក ឬជូនសេវាកម្មខាងសេដ្ឋកិច្ច ពិតជាផ្នែកសំខាន់ជាងគេ លើសផ្នែកឯទៀតៗនៃជីវិតសេដ្ឋកិច្ច ដែលគ្រាន់តែជាគ្រឿងជួយការងារមនុស្សប៉ុណ្ណោះ។

ខ- ទោះជាមនុស្សប្រព្រឹត្តការងារនេះដោយខ្លួនឯងជាម្ចាស់ក្តី ឬដោយមានពាក្យសន្យាជាមួយថៅកែក្តី ក៏ការងារហូរចេញមកពីបុគ្គលតែម្តង។ បុគ្គលហាក់ដូចជាចាក់ស្នាមរបស់ខ្លួនលើធម្មជាតិ និងបង្ក្រាបធម្មជាតិ តាមបំណងរបស់ខ្លួនដែរ។ ជាធម្មតា មនុស្សចិញ្ចឹមជីវិតរបស់ខ្លួន និងក្រុមគ្រួសារ ដោយសារការងាររបស់គាត់។ ដោយសារការងារគាត់ ក៏រួមជាមួយមនុស្សឯទៀតៗជាបងប្អូនជួយគេ ហើយមានសមត្ថភាពអាចសម្តែងសេចក្តីស្រឡាញ់ដ៏ពិតប្រាកដចំពោះគេ គាត់ក៏រួមសហការជាមួយព្រះជាម្ចាស់ ក្នុងកិច្ចប្រតិស្ឋានពិភពលោកដែរ។ លើសពីនេះទៅទៀត មនុស្សគោរពព្រះជាម្ចាស់ ដោយសារការងាររបស់គាត់នេះឯង។ យើងក៏ជឿទៀតថា ដោយសារការងារព្រះជាម្ចាស់ បង្រួមមនុស្សឲ្យរួមសហការជាមួយព្រះយេស៊ូគ្រីស្ត ដែលរំដោះមនុស្សលោក គឺថា ដោយព្រះយេស៊ូប្រព្រឹត្តការងារផ្ទាល់ព្រះហស្ត នៅភូមិណាសារ៉ែត ព្រះអង្គបានប្រទានឲ្យការងារ មានកិត្តិយសដ៏ថ្លៃថ្នូរបំផុត។ ហេតុនេះហើយ បានជាមនុស្សម្នាក់ៗ មានភារកិច្ចធ្វើការដោយចិត្តស្មោះ និងមានសិទ្ធិធ្វើការបានដែរ។ តាមកាលៈទេសៈ សង្គមត្រូវជួយប្រជាពលរដ្ឋ ឲ្យមានការងារធ្វើគ្រប់គ្រាន់។ មិនតែប៉ុណ្ណោះ ប្រាក់ឈ្នួលការងារនោះ ត្រូវធានាឲ្យមនុស្សមានធនធានល្មម ទាំងខ្លួន ទាំងក្រុមគ្រួសារ អាចរស់នៅយ៉ាងសមគួរក្នុងវិស័យសង្គម ក្នុងវិស័យវប្បធម៌ និងក្នុងវិស័យខាងវិញ្ញាណ ស្រេចតែមុខងាររបស់ម្នាក់ៗ តាមសមត្ថភាពរបស់ម្នាក់ៗ ទាំងគិតគូរដល់សភាពការណ៍សហគ្រាស និងដល់ប្រយោជន៍រួមផង។

គ- តាមធម្មតា មនុស្សរួមគ្នាធ្វើសហការ ក្នុងសកម្មភាពសេដ្ឋកិច្ច។ ហេតុនេះ បើការចាត់ចែងសេដ្ឋកិច្ចនេះបណ្តាលឲ្យខូចប្រយោជន៍ដល់កម្មករ សូម្បីតែម្នាក់ ពិតជាអយុត្តិធម៌ និងខុសលក្ខណៈជាមនុស្ស។ តាមពិត ជាញឹកញាប់ សូម្បីតែសព្វថ្ងៃ អស់អ្នកដែលធ្វើការគិតតែពីផលិតផលទុកជាការសំខាន់បំផុត។ គេយល់ខុសអំពីបទដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ដែលនាំឲ្យសភាពការណ៍ដ៏អាក្រក់បែបនេះកើតឡើង។ ហេតុនេះ ត្រូវសម្របសម្រួលដំណើរនៃការងារបង្កើតផល តាមសេចក្តីត្រូវការរបស់បុគ្គល និងស្របតាមរបៀបការរស់នៅរបស់គេ ជាពិសេសតាមរបៀបរស់នៅក្នុងក្រុមគ្រួសារ ដោយយល់គិតដល់ភេទ និងដល់អាយុជានិច្ចផង។ ត្រូវចាប់អារម្មណ៍យ៉ាងពិសេស ចំពោះស្ត្រីៗដែលមានកូន។ ពលករត្រូវមានសមត្ថភាព

ពង្រីកទេពកោសល្យ និងបុគ្គលិកលក្ខណៈរបស់ខ្លួនឲ្យចម្រើនឡើង ដោយប្រព្រឹត្តកិច្ចការរបស់ខ្លួនដែរ។ ពលករត្រូវយកចិត្តទុកដាក់ធ្វើការតាមពេលវេលា និងតាមកម្លាំងរបស់ខ្លួន។ ប៉ុន្តែ សូមឲ្យពលករទាំងអស់មានពេលសម្រាក និងពេលលំហែកាយគ្រប់គ្រាន់ ដោយបណ្តាលឲ្យគេមានជីវិតរស់នៅតាមក្រុមគ្រួសារ តាមវប្បធម៌ តាមសង្គម និងតាមសាសនាទៀតដែរ។ លើសពីនេះទៅទៀត គេត្រូវមានសមត្ថភាពលាតត្រដាងទេពកោសល្យ និងលក្ខណៈសម្បត្តិរបស់ខ្លួន ដែលគ្មានឱកាសប្រើនៅពេលបំពេញអាជីវកម្មរបស់ខ្លួន។

## ៦៨- ពលករទទួលចំណែកក្នុងការចាត់ចែងសហគ្រាស

ក- ក្នុងសហគ្រាសសេដ្ឋកិច្ច មនុស្សរួមគ្នាធ្វើការ គឺជាបុគ្គលមានសេរីភាពនិងស្វយ័ត ដែលព្រះជាម្ចាស់បានប្រតិស្ឋានឲ្យមានលក្ខណៈដូចព្រះអង្គ។ ហេតុនេះ ត្រូវជួយណែនាំឲ្យបុគ្គលិកទាំងអស់ក្នុងសហគ្រាសទទួលចំណែកយ៉ាងសកម្ម ក្នុងការគ្រប់គ្រងសហគ្រាស តាមបែបបទដែលត្រូវបានបញ្ជាក់ជាមួយគ្នា។ ក្នុងករណីនេះ ត្រូវគិតគូរដល់មុខងាររបស់បុគ្គលិកម្នាក់ៗ គឺម្ចាស់សហគ្រាស ថៅកែជួលកម្មករ អ្នកក្នុងក្របខ័ណ្ឌ និងកម្មករ។ ត្រូវថែរក្សាឲ្យមានឯកភាពក្នុងការណែនាំផង។ ប៉ុន្តែ ជារឿយៗផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម មិនសម្រេចនៅលើកម្រិតសហគ្រាសទេ តែសម្រេចនៅកម្រិតខាងលើទៅទៀត។ រីឯអនាគតក្រុមពលករ និងអនាគតកូនគេវិញ ក៏អាស្រ័យនៅលើសេចក្តីសម្រេចទាំងនោះដែរ។ ហេតុនេះហើយ បានជាពលករត្រូវទទួលចំណែកក្នុងកិច្ចសម្រេចទាំងនោះ ដោយខ្លួនគេផ្ទាល់ ឬដោយតំណាងដែលគេបានជ្រើសរើសដោយសេរី។

ខ- ក្នុងចំណោមសិទ្ធិមនុស្សជាគ្រឹះ ពលករមានសិទ្ធិបង្កើតសមាគមដោយសេរី គឺសមាគម ដែលអាចទៅជាតំណាងរបស់គេយ៉ាងត្រឹមត្រូវ និងដែលអាចសហការក្នុងការចាត់ចែងជីវិតសេដ្ឋកិច្ចឲ្យបានល្អ។ គេហៅសមាគមទាំងនោះថា *"សហជីព"*។ ពលករក៏មានសិទ្ធិចូលរួមក្នុងសកម្មភាពសមាគមទាំងនោះដោយសេរី ដោយមិនខ្លាចនរណាបៀតបៀន។ ដោយពលកររួមចំណែកក្នុងការចាត់ចែងសហគ្រាសនេះ និងដោយគេទទួលការអប់រំខាងសេដ្ឋកិច្ចនិងខាងសង្គម បុគ្គលិកទាំងអស់ក្នុងសហគ្រាស នឹងមានគំនិតទទួលខុសត្រូវកាន់តែខ្លាំងឡើងៗ។ គេមុខជានឹងយល់ឃើញថា គេចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ព្រមទាំងបង្កើតប្រយោជន៍រួមសកល តាមសមត្ថភាព និងតាមទេពកោសល្យរបស់គេផង។

គ- នៅពេលកើតជម្លោះទាស់ទែងគ្នាខាងសង្គម ត្រូវយកចិត្តទុកដាក់ រកដំណោះស្រាយដោយសន្តិវិធី។ បដិបក្សទាំងពីរ ត្រូវចចារជាមួយគ្នាជានិច្ចដោយចិត្តស្មោះ។ ប៉ុន្តែ ជួនកាលក្នុងសភាពកាណ៍ខ្លះនាបច្ចុប្បន្នកាល ប្រសិនបើ បានប្រើគ្រប់មធ្យោបាយឯទៀតៗនៅតែដោះស្រាយមិនបាន ត្រូវធ្វើកូដកម្ម ដើម្បីការពារសិទ្ធិរបស់ពលករ និងជួយឲ្យសេចក្តីប៉ងប្រាថ្នាដ៏ត្រឹមត្រូវរបស់គេបានសម្រេច។ ប៉ុន្តែ សូមចចារឡើងវិញនៅពេលឆាប់ៗ ប្រសិនបើអាចធ្វើបាន ដើម្បីធ្វើការព្រមព្រៀងគ្នា។

## ៦៩- មនុស្សទាំងអស់មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិទាំងអស់ក្នុងលោកនេះ

ក- ព្រះជាម្ចាស់បានតម្រង់ផែនដី និងអ្វីៗទាំងអស់ដែលនៅលើផែនដីឲ្យមនុស្សទាំងអស់ និងឲ្យប្រជាជនទាំងអស់ប្រើប្រាស់។ ដូច្នេះ ភោគទ្រព្យទាំងអស់ដែលមានក្នុងពិភពលោកនេះ ត្រូវហូរមកដល់មនុស្សទាំងអស់

តាមសេចក្តីត្រូវការរបស់គេ និងត្រូវតាមក្បួនយុត្តិធម៌ ដែលបំបែកពីសេចក្តីស្រឡាញ់មិនបាន។ ទោះបីកម្មសិទ្ធិមានរបៀបផ្សេងៗ ស្របតាមការចាត់ចែងដ៏ត្រឹមត្រូវរបស់ប្រជាជាតិនីមួយៗ និងតាមកាលៈទេសៈផ្សេងៗ ដែលតែងតែប្រែប្រួលក្តី ក៏ត្រូវនឹកចងចាំជានិច្ចថា ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលខ្លួនមានតម្រូវឲ្យមនុស្សទាំងអស់ប្រើប្រាស់។ ហេតុនេះហើយ បានជាពេលមនុស្សម្នាក់ប្រើប្រាស់ទ្រព្យសម្បត្តិ គេមិនត្រូវចាត់ទុកថា ទ្រព្យសម្បត្តិដែលខ្លួនមាន ត្រឹមត្រូវតាមច្បាប់នោះ ជាកម្មសិទ្ធផ្ទាល់ខ្លួនទេ តែត្រូវចាត់ទុកថា ជាកម្មសិទ្ធរួមវិញ។ ហេតុនេះ មិនគ្រាន់តែខ្លួនគេទេ អាចប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះបាន តែមនុស្សឯទៀតៗ ក៏អាចប្រើប្រាស់បានដែរ។ ម្យ៉ាងទៀត មនុស្សទាំងអស់មានសិទ្ធិ នឹងបានទ្រព្យសម្បត្តិគ្រប់គ្រាន់ល្មមសម្រាប់ខ្លួនគេ និងសម្រាប់ក្រុមគ្រួសាររបស់គេដែរ។ អស់គ្រូបាធ្យាយ និងបណ្ឌិត ដែលបានបង្រៀនកាលពីដើម តែងមានគំនិតដូច្នោះដែរ គឺអស់លោកតែងប្រៀនប្រដៅថា គ្រីស្តបរិស័ទត្រូវជួយអ្នកក្រីក្រ មិនគ្រាន់តែដោយយកអ្វីដែលគេសេសសល់ប៉ុណ្ណោះឡើយ តែដោយយកអ្វីដែលជាចាំបាច់សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួន យកទៅចែកដល់អ្នកក្រីក្រវិញ។ រីឯអ្នកដែលខ្វះខាតទ័លក្រវិញ គេក៏មានសិទ្ធិយកទ្រព្យសម្បត្តិដ៏សម្បូរណ៍របស់គេ មកទប់ទល់នឹងសេចក្តីត្រូវការដ៏ចាំបាច់របស់ខ្លួន។ ដោយមហាសន្និបាតឃើញថា មនុស្សខ្វះអាហារបរិភោគច្រើនក្រៃលែង ក្នុងពិភពលោកមហាសន្និបាត សូមអំពាវនាវចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះអ្នកកាន់អំណាច សូមនឹកដល់ពាក្យរបស់គ្រូបាធ្យាយ ដែលចែងថា *"ចូលចែកអាហារដល់អ្នកដែលស្រេកឃ្លានជិតដាច់ពោះទៅ! ប្រសិនបើ អ្នកមិនចែកអាហារឲ្យគេបរិភោគទេ អ្នកដូចជាប្រហារជីវិតគេហើយ"*។ សូមឲ្យមនុស្សគ្រប់ៗរូប ប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងពិតប្រាកដ និងចែកឲ្យអ្នកក្រីក្រតាមសមត្ថភាពរៀងៗខ្លួន ដោយប្រគល់ឲ្យទាំងបុគ្គល ទាំងប្រជាជននានាមានមធ្យោបាយ អាចទប់ទល់សេចក្តីខ្វះខាតរបស់គេដោយខ្លួនឯង និងអាចអភិវឌ្ឍន៍ខ្លួនថែមទៀតផង។

ខ- ក្នុងប្រទេសក្រីក្រ ដែលមានសេដ្ឋកិច្ចតិចជាងគេ ប្រពៃណី និងទំនៀមទម្លាប់ នាំឲ្យប្រជាជនចែកទ្រព្យសម្បត្តិប្រើរួម គឺធានាឲ្យសមាជិកម្នាក់ៗ មានទ្រព្យសម្បត្តិដែលខ្លួនត្រូវការជាចាំបាច់ ច្រើនជាងគេ។ ប្រសិនបើប្រពៃណី និងទំនៀមទម្លាប់ទាំងនោះ មិនតបឆ្លើយនឹងសេចក្តីទាមទាររបស់មនុស្សបច្ចុប្បន្នកាលនេះ ត្រូវប្រយ័ត្នកុំយល់ថា ប្រពៃណី និងទំនៀមទម្លាប់ខ្លះ មិនអាចប្រែប្រួលបាន។ ផ្ទុយទៅវិញ កុំប៉ះពាល់ទំនៀមទម្លាប់ដ៏ទៀងត្រង់ ដែលអាចជួយប្រជាជនយ៉ាងខ្លាំងតទៅទៀត លើកលែងតែគេប្រែប្រួលទំនៀមទម្លាប់ ឲ្យបានទំនើបយ៉ាងត្រឹមត្រូវ។ យ៉ាងណាមិញ ក្នុងប្រទេសជឿនលឿនខ្លាំង មានបណ្តាញស្ថាប័នខាងសង្គម ខាងធានារ៉ាប់រង និងខាងសុវត្ថិភាពក្នុងសង្គម អាចជួយចែកទ្រព្យសម្បត្តិខ្លះ ឲ្យគេប្រើប្រាស់គ្រប់គ្នា។ ត្រូវការបន្តអភិវឌ្ឍន៍សេវាកម្មសម្រាប់ក្រុមគ្រួសារ និងសង្គម ជាពិសេសសេវាកម្មដែលជួយខាងវប្បធម៌និងការអប់រំ។ ក៏ប៉ុន្តែ ក្នុងកិច្ចសម្រួលស្ថាប័នទាំងនោះ ត្រូវប្រយ័ត្នកុំបណ្តោយឲ្យប្រជាពលរដ្ឋមានឥរិយាបថ ចង់តែទទួលអំណោយ ដោយមិនធ្វើអ្វីសងវិញ មិនព្រមទទួលខុសត្រូវ ហើយមិនព្រមបម្រើអ្នកដទៃ។

## ៧០- វិនិយោគ និងបញ្ហារូបិយវត្ថុ

ចំណែកឯវិនិយោគវិញ ត្រូវធានាឲ្យប្រជាជនមានការងារធ្វើ និងជូនកម្រៃគ្រប់គ្រាន់ដល់គេនាបច្ចុប្បន្នកាល និង

អនាគតកាល។ អស់អ្នកសម្រេចធ្វើវិនិយោគ ដូចអស់អ្នកដែលមានតួនាទីសម្រេច និងចាត់ចែងជីវិតសេដ្ឋកិច្ច ពោលគឺ បុគ្គល ក្រុម និងរដ្ឋអំណាច ត្រូវយកចិត្តទុកដាក់នឹងគោលដៅទាំងនេះ និងដឹងខ្លួនអំពីភារកិច្ចដ៏ធ្ងន់ធ្ងររបស់ខ្លួន។ ម្យ៉ាង អស់លោកត្រូវចាត់វិធានការ ដើម្បីទប់ទល់នឹងសេចក្តីត្រូវការជូនប្រជាជនទាំងបុគ្គល ទាំងសហគមន៍ទាំងមូល ឲ្យមាន ជីវភាពសមរម្យ។ ម្យ៉ាងទៀត ត្រូវគ្រោងទុកអនាគត និងធានាតុល្យភាពដ៏ត្រឹមត្រូវ រវាងសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗ និងសហគមន៍នាបច្ចុប្បន្ន ហើយនិងវិនិយោគសម្រាប់អនាគត គឺបុគ្គលម្នាក់ៗ និងសហគមន៍នាបច្ចុប្បន្ន ចង់បាន ទ្រព្យសម្បត្តិប្រើប្រាស់ភ្លាម ប៉ុន្តែ ត្រូវគិតដល់វិនិយោគ តាមសេចក្តីត្រូវការសម្រាប់កូនចៅ នៅពេលអនាគតទៀតផង។ ត្រូវនឹកគិតជានិច្ច អំពីសេចក្តីត្រូវការជាចាំបាច់របស់ប្រជាជាតិនានា និងតំបន់ដែលមានសេដ្ឋកិច្ចអន់ជាងគេ។ រីឯខាង រូបិយវត្ថុវិញ ត្រូវប្រយ័ត្ន កុំបង្ខូចផលប្រយោជន៍ប្រទេសរបស់ខ្លួន និងផលប្រយោជន៍ប្រជាជាតិដទៃទៀតផង។ ត្រូវ ប្រយ័ត្ន មិនត្រូវបណ្តាលឲ្យអស់អ្នកក្រជាងគេ ត្រូវបង់ខាតយ៉ាងអយុត្តិធម៌ ដោយផ្លាស់ប្តូរតម្លៃនៃរូបិយវត្ថុ។

## ៧១- ផ្លូវចូលទៅកាន់កម្មសិទ្ធ និងកាន់សម្បត្តិទ្រព្យឯកជន

ក- កម្មសិទ្ធ និងការកាន់សម្បត្តិទ្រព្យឯកជន តាមរបៀបឯទៀតៗ ជួយឲ្យមនុស្សអាចបញ្ចេញលក្ខណៈ សម្បត្តិរបស់ខ្លួន ព្រមទាំងហុចឱកាសឲ្យគេទទួលខុសត្រូវក្នុងសង្គម និងក្នុងសេដ្ឋកិច្ច។ ហេតុនេះហើយ ត្រូវជួយបុគ្គល និងក្រុមផ្សេងៗ ឲ្យមានផ្លូវចូលទៅកាន់អំណាចខ្លះលើសម្បត្តិទ្រព្យ។ ការនេះ មានសារៈ សំខាន់ខ្លាំងណាស់។

ខ- កម្មសិទ្ធឯកជន និងអំណាចខ្លះលើសម្បត្តិទ្រព្យ ធានាឲ្យមនុស្សម្នាក់ៗ និងក្រុមគ្រួសារ បានស្វ័យភាព ដែលខ្លួនត្រូវការជាចាំបាច់។ ត្រូវចាត់កម្មសិទ្ធឯកជន ទុកជាគ្រឿងបន្តសេរីភាពរបស់មនុស្ស។ មិនតែ ប៉ុណ្ណោះកម្មសិទ្ធឯកជន ជួយឲ្យមនុស្សចេះទទួលខុសត្រូវកាន់តែខ្លាំងឡើងៗ។ កម្មសិទ្ធឯកជន ពិតជា លក្ខ័ណ្ឌមួយ ជួយឲ្យមានសេរីភាពក្នុងសង្គម។

គ- របៀបកាន់អំណាចលើសម្បត្តិទ្រព្យ និងកម្មសិទ្ធឯកជន មានរបៀបផ្សេងៗពីគ្នានាសម័យបច្ចុប្បន្ន ហើយ ត្រូវតែមានរបៀបផ្សេងៗកាន់តែច្រើន នៅពេលអនាគតទៀតជាមិនខាន។ ប៉ុន្តែ របៀបកាន់កាប់ទ្រព្យ និងកម្មសិទ្ធឯកជនទាំងនោះ នៅតែជាប្រភពនៃសុវត្ថិភាពក្នុងសង្គមដ៏មានតម្លៃ។ ត្រូវរាប់បញ្ចូលមូលនិធី ផ្សេងៗក្នុងសង្គម សិទ្ធិនិងសេវាកម្មដែលសង្គមធានារ៉ាប់រងទៀតដែរ។ សេចក្តីនេះ មិនត្រឹមត្រូវចំពោះតែ កម្មសិទ្ធិខាងសម្ភារៈប៉ុណ្ណោះទេ តែត្រឹមត្រូវចំពោះសម្បត្តិទ្រព្យអរូបី ដែលមានសមត្ថភាពខាងអាជីវកម្ម ជាដើមដែរ។

ឃ-ការកាន់កាប់កម្មសិទ្ធឯកជនជាការត្រឹមត្រូវ ដែលមិនទាស់នឹងរបៀបផ្សេងៗ សម្រាប់កាន់កាប់កម្មសិទ្ធ សាធារណៈទេ។ ប៉ុន្តែ រដ្ឋអំណាច អាចផ្ទេរកម្មសិទ្ធិឯកជនទៅជាកម្មសិទ្ធសាធារណៈបាន លុះត្រាតែមាន ប្រយោជន៍រួម និងតាមព្រំដែននៃប្រយោជន៍រួមនោះ។ រដ្ឋអំណាចត្រូវបង់ប្រាក់ ជាថ្នូរឲ្យបានសមរម្យ។ រដ្ឋអំណាច មានសមត្ថកិច្ចជៀសវាង មិនឲ្យគេប្រើកម្មសិទ្ធឯកជនហួសព្រំដែន គឺផ្ទុយនឹងប្រយោជន៍រួម ដែរ។

ង- ដោយលក្ខណៈផ្ទាល់របស់កម្មសិទ្ធឯកជន កម្មសិទ្ធឯកជននោះ ក៏មានលក្ខណៈជាសង្គមដែរ ដោយសំអាង លើច្បាប់វិន័យតម្រូវឲ្យមនុស្សទាំងអស់ អាចប្រើប្រាស់ទ្រព្យសម្បត្តិនោះបាន។ មនុស្សមានចិត្តលោភលន់

មិនគោរពលក្ខណៈសង្គមនៃកម្មសិទ្ធិឯកជន ហើយកើតអសន្តិសុខជាទម្ងន់។ សភាពការណ៍នេះ ជាមូលហេតុ នាំឲ្យអស់អ្នកដែលជំទាស់នឹងសិទ្ធិកាន់កាប់កម្មសិទ្ធ អាចតវ៉ាបាន។

ច- ក្នុងតំបន់ជាច្រើន ដែលមានសេដ្ឋកិច្ចមិនជឿនលឿន មានអ្នកខ្លះកាន់កាប់ស្រែចម្ការដ៏ធំទូលំទូលាយ សម្បើមទុកជាកម្មសិទ្ធឯកជន។ តែម្ចាស់កម្មសិទ្ធទាំងនោះ មិនសូវអភិវឌ្ឍន៍ដីនោះទេ ឬទុកសម្រាប់កេងកម្រៃនៅពេលក្រោយវិញ។ នៅពេលជាមួយគ្នានោះ ប្រជាជនភាគច្រើនគ្មានដីធ្វើស្រែចម្ការ ឬមានដីទំហំតូចពេក។ ម៉្យាងទៀត មនុស្សលោកត្រូវការភោគផលកសិកម្មជាបន្ទាន់យ៉ាងជាក់ច្បាស់។ ធម្មតា កូនឈ្នួលរបស់ម្ចាស់ដីស្រែដ៏ធំល្វឹងល្វើយទាំងនោះ ជួលតែក្បាលដីតូច ឬទទួលកម្រៃ និងបៀវត្សមិនសមនឹងឋានៈជាមនុស្ស គ្មានកន្លែងរស់នៅសមរម្យ និងត្រូវអ្នកកណ្តាលជិះជាន់កេងបន្លំទៀតផង។ គេគ្មានការងារជាប់លាប់ រស់នៅជាចំណុះម្ចាស់គេ មិនអាចទទួលខុសត្រូវឬចាប់ផ្តើមគំនិត មិនអាចចម្រើនខាងវប្បធម៌ មិនអាចចូលរួមសហការក្នុងសង្គម និងនយោបាយជាដើម។ ហេតុនេះ ត្រូវតែកែទម្រង់សភាពការណ៍ដ៏អាក្រក់នេះ ដើម្បីឲ្យកសិករមានកម្រៃច្រើនជាង ឲ្យមានរបៀបធ្វើការស្រួលជាង ឲ្យមានការងារជាប់រហូត ជួយឲ្យគេមានគំនិតផ្ទាល់។ ត្រូវយកដីដែលគេមិនទាន់អភិវឌ្ឍ យកទៅចែកដល់មនុស្ស ដែលអាចភ្ជួររាស់ដីទាំងនោះឲ្យបានភោគផល។ ក្នុងករណីនេះ ត្រូវផ្តល់ឲ្យគេមានធនធាន មានប្រដាប់ប្រដា ដែលគេត្រូវការជាចាំបាច់ ជាពិសេស ត្រូវផ្តល់ឲ្យគេមានមធ្យោបាយអប់រំខ្លួន និងសមត្ថភាពចាត់ចែងតាមរបៀបជាសហករណ៍។ គ្រប់ពេលប្រយោជន៍រួម ទាមទារឲ្យដកហូតក្បាលដីពីឯកជនម្នាក់ៗ ត្រូវមានសំណងតាមយុត្តិធម៌ ដោយរិះគិតពីគ្រប់សភាពការណ៍ផង។

## ៧២- សកម្មភាពសេដ្ឋកិច្ចនិងសង្គម ទាក់ទិននឹងព្រះរាជ្យរបស់ព្រះជាម្ចាស់

ក- គ្រីស្តបរិស័ទដែលអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមយ៉ាងសកម្ម និងដែលតយុទ្ធដើម្បីយុត្តិធម៌ និងសេចក្តីស្រឡាញ់ ត្រូវជឿជាក់ថា ដោយប្រព្រឹត្តដូច្នេះ គេអាចជួយយ៉ាងខ្លាំងឲ្យមនុស្សជាតិចម្រើនឡើង និងមានសន្តិភាពក្នុងពិភពលោក។ ពួកគេទោះជាបុគ្គលម្នាក់ៗក្តី ឬរួមគ្នាក្តី ក៏ចាំងពន្លឺដោយធ្វើគំរូដល់អ្នកដទៃ ក្នុងសកម្មភាពទាំងនោះ។ ពួកគេត្រូវមានសមត្ថភាព និងបទពិសោធន៍ជាចាំបាច់បំផុត។ ក្នុងចំណោមកិច្ចការក្នុងលោកនេះ សូមឲ្យគេកាន់តាមអ្វីៗដ៏មានតម្លៃច្រើនជាងគេ គឺសូមឲ្យគេមានចិត្តស្មោះនឹងព្រះគ្រីស្ត និងដំណឹងល្អរបស់ព្រះអង្គ ដើម្បីឲ្យការរស់នៅទាំងមូលរបស់គេម្នាក់ៗ ឬរួមគ្នា ជ្រួតជ្រាបដោយគំនិតរបស់ព្រះយេស៊ូ ដែលប្រកាសអំពីសុភមង្គលដ៏ពិតប្រាកដ ជាពិសេស ឲ្យគេដាក់ខ្លួនជាមនុស្សក្រីក្រ។

ខ- អស់អ្នកដើរតាមព្រះគ្រីស្ត ត្រូវស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុនសិន។ គេរកឃើញសេចក្តីស្រឡាញ់យ៉ាងខ្លាំង និងបរិសុទ្ធ ដើម្បីជួយមនុស្សទាំងអស់ជាបងប្អូន និងជួយតែងតាំងយុត្តិធម៌ ដោយសេចក្តីស្រឡាញ់ជំរុញគេផង។ (សូមអាន លក ៣,១១; ១០, ៣០ត; ១១, ៤១ ១សល ៥, ៣; មក ៨, ៣៦; ១២, ២៩-៣១; យក ៥, ១-៦; ១ធម ៤, ២៨; អភ ៤, ២៨; ២ករ ៨, ១៣ត; ១យហ ៣, ១៧-១៨)។

# ជំពូក ៤

## ការរស់នៅនៃសហគមន៍នយោបាយ

### ៧៣. ការរស់នៅសាធារណៈនាបច្ចុប្បន្នកាល

ក- សព្វថ្ងៃ យើងអាចសង្កេតឃើញថា រចនាសម្ព័ន្ធ និងស្ថាប័នប្រជាជនជាច្រើនប្រែប្រួលយ៉ាងខ្លាំង។ ការប្រែប្រួលទាំងនោះ ក៏ស្របតាមការវិវឌ្ឍន៍ វប្បធម៌ សេដ្ឋកិច្ច និងសង្គមប្រជាជនទាំងនោះដែរ។ ការប្រែប្រួលទាំងនោះ មានឥទ្ធិពលជាខ្លាំងលើការរស់នៅរបស់សហគមន៍នយោបាយ ជាពិសេសក្នុងវិស័យសិទ្ធិ និងភារកិច្ចរបស់មនុស្សម្នាក់ៗ ដែលប្រើសិទ្ធិសេរីភាព ក្នុងឋានៈជាប្រជាពលរដ្ឋ និងដែលចង់ស្វែងរកប្រយោជន៍រួម។ ការប្រែប្រួលទាំងនោះ ក៏មានឥទ្ធិពលលើការចាត់ចែងទំនាក់ទំនង របស់ប្រជាពលរដ្ឋទៅវិញទៅមក និងក្នុងការចាត់ចែងទំនាក់ទំនង របស់គេជាមួយរដ្ឋអំណាចផងដែរ។

ខ- មនុស្សនាបច្ចុប្បន្ន ដឹងខ្លួនកាន់តែច្បាស់អំពីកិត្តិយសរបស់ខ្លួនជាមនុស្ស។ ហេតុនេះ តាមតំបន់ផ្សេងៗក្នុងពិភពលោក មនុស្សខិតខំតែងតាំងរបៀបរៀបរយនយោបាយ និងច្បាប់ ដែលអាចការពារសិទ្ធិរបស់បុគ្គលម្នាក់ៗ ក្នុងការរស់នៅជាសាធារណៈ។ ឧបមាថា សិទ្ធិជួបជុំគ្នានិងបង្កើតសមាគម សិទ្ធិបញ្ចេញមតិផ្ទាល់ខ្លួន និងប្រកាសសាសនារបស់ខ្លួន ទាំងនៅទីឯកជន និងនៅទីសាធារណៈ។ល។ ការធានារ៉ាប់រងសិទ្ធិបុគ្គល ពិតជាលក្ខខណ្ឌដ៏ចាំបាច់មិនអាចខានបាន ដើម្បីឲ្យប្រជាពលរដ្ឋ ទាំងបុគ្គលម្នាក់ៗ ទាំងក្រុម អាចចូលរួមយ៉ាងសកម្មក្នុងការរស់នៅជាសាធារណៈ និងក្នុងការគ្រប់គ្រងកិច្ចការសាធារណៈផងដែរ។

គ- មនុស្សមួយចំនួនធំ បញ្ជាក់បំណងរបស់ខ្លួនចង់ទទួលចំណែកក្នុងការចាត់ចែងនៃសហគមន៍នយោបាយ។ បំណងនេះ ក៏ភ្ជាប់យ៉ាងស្អិតល្មួតជាមួយការចម្រើនខាងវប្បធម៌ ខាងសេដ្ឋកិច្ច និងខាងសង្គម។ មនុស្សជាច្រើន មានមនសិការកាន់តែខ្លាំងឡើងៗ ចង់រក្សាទុកសិទ្ធិជនជាតិភាគតិចក្នុងប្រទេសនីមួយៗ ទាំងយកចិត្តទុកដាក់ នឹងភារកិច្ចរបស់ខ្លួនចំពោះសហគមន៍នយោបាយ។ ម្យ៉ាងទៀត មនុស្សកាន់តែខ្លាំងឡើងៗ មិនជំទាស់នឹងអ្នក ដែលមានយោបល់ឬដែលកាន់សាសនាប្លែកពីគេ។ កាលពីមុនមានមនុស្សតែមួយចំនួនតូចប៉ុណ្ណោះ មានឯកសិទ្ធិអាចប្រើសិទ្ធិបុគ្គលបាន។ ឥឡូវមានមនុស្សជាច្រើន រួមសហការគ្នាកាន់តែខ្លាំងឡើងៗ អាចជួយឲ្យប្រជាពលរដ្ឋទាំងអស់ប្រើសិទ្ធិរបស់ខ្លួន។

ឃ-ផ្ទុយទៅវិញមនុស្សនាបច្ចុប្បន្ន តែងបោះបង់ចោលរបបនយោបាយដែលរារាំង សិទ្ធិសេរីភាពក្នុងសង្គម ឬរារាំងសិទ្ធិសេរីភាពខាងសាសនា ដូចមានតាមតំបន់ផ្សេងៗក្នុងពិភពលោក។ របបនយោបាយទាំងនោះ បណ្តាលឲ្យមានជនរងគ្រោះជាច្រើន ដោយអំពើហឹង្សា ឬដោយអំពើឧក្រិដ្ឋខាងនយោបាយ។ របបទាំងនោះ ក៏ប្រែសកម្មភាពនៃរដ្ឋអំណាច ដើម្បីជាប្រយោជន៍ដល់គណៈតូចមួយ ឬដល់អ្នកកាន់អំណាច មិនយកសកម្មភាពនោះ មកបម្រើប្រយោជន៍រួម។

ង- គ្មានអ្វីសំខាន់ជាងការអភិវឌ្ឍន៍ចិត្តគំនិតមនុស្ស ឲ្យស្រឡាញ់យុត្តិធម៌ ឲ្យមានចិត្តសប្បុរស ឲ្យយកចិត្តទុកដាក់នឹងប្រយោជន៍រួម។ ត្រូវពង្រឹងគំនិតជាគ្រឹះអំពីលក្ខណៈដ៏ពិតប្រាកដនៃសហគមន៍នយោបាយ និងអំពីគោលដៅសហគមន៍នេះហើយ អំពីរបៀបរដ្ឋប្រើប្រាស់អំណាចរបស់ខ្លួន ដែលមានកំណត់ព្រំដែន។ ប្រសិនបើ មានគេអប់រំដូច្នេះ មុខជាការរស់នៅខាងនយោបាយ មានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដមែន។

## ៧៤ លក្ខណៈ និងគោលដៅនៃសហគមន៍នយោបាយ

ក- បុគ្គលម្នាក់ៗ ក្រុមគ្រួសារ ក្រុមផ្សេងៗ និងអស់អ្នកដែលរួមគ្នាជាសហគមន៍ប្រជាពលរដ្ឋ ក៏ដឹងខ្លួនថា គេមិនអាចរស់នៅតែម្នាក់ឯង ដោយមិនពេញលក្ខណៈជាមនុស្សបានទេ។ គេយល់ឃើញថា គេត្រូវការសហគមន៍ធំជាង គឺមនុស្សទាំងអស់ នឹងរួមកម្លាំងគ្នាជារៀងរាល់ថ្ងៃ បង្កើតប្រយោជន៍រួមឲ្យកាន់តែប្រសើរឡើងៗក្នុងសហគមន៍នេះ។ ហេតុនេះហើយ បានជាគេតែងតាំងសហគមន៍នយោបាយ តាមរចនាសម្ព័ន្ធផ្សេងៗពីគ្នា។ សហគមន៍នយោបាយនេះ កើតឡើងដើម្បីជាប្រយោជន៍រួម ត្រូវកើតឡើងត្រឹមត្រូវ និងមានអត្ថន័យ ដោយសារតែប្រយោជន៍រួមនេះប៉ុណ្ណោះ។ សហគមន៍នយោបាយនេះ បង្កើតច្បាប់ទាំងប៉ុន្មាន ដោយយកប្រយោជន៍រួមនេះជាប្រភព។ រីឯប្រយោជន៍រួមវិញ មានន័យថា គ្រប់នៃការរស់នៅក្នុងសង្គម ដែលបណ្តាលឲ្យមនុស្ស ឲ្យក្រុមគ្រួសារ ឲ្យក្រុមផ្សេងៗបានពេញលក្ខណៈ កាន់តែពេញលេញ និងស្រួលផង។

ខ- ប៉ុន្តែ មនុស្សរួមក្នុងសហគមន៍នយោបាយមានច្រើន ហើយប្លែកពីគ្នា និងមានយោបល់ប្លែកៗគ្នាថែមទៀតផង តាមសិទ្ធិដ៏ត្រឹមត្រូវរបស់គេ។ បើម្នាក់ៗប្រព្រឹត្តតាមយោបល់រៀងៗខ្លួន មុខជាសហគមន៍នយោបាយបាក់បែកគ្នាពុំខាន។ ដូច្នេះ ត្រូវមានអំណាចមួយត្រួតត្រាពីលើ ដែលអាចតម្រង់ថាមពលរបស់មនុស្សទាំងអស់បាន។ អំណាចនោះ មិនត្រូវតម្រង់ថាមពលទាំងនោះដូចជាគ្រឿងម៉ាស៊ីន ឬដោយត្រួតត្រាបែបផ្តាច់ការបានទេ តែអំណាចនោះ បំពេញមុខងាររបស់ខ្លួនហាក់ដូចជាកម្លាំងខាងវិញ្ញាណ ដែលសំអាងលើសេរីភាព និងលើគំនិតរបស់មនុស្សទទួលខុសត្រូវ។

គ- សហគមន៍នយោបាយ និងរដ្ឋអំណាចមានគ្រឹះយ៉ាងជាក់ច្បាស់ ក្នុងលក្ខណៈរបស់មនុស្ស។ បើដូច្នេះមែនសហគមន៍នយោបាយ និងរដ្ឋអំណាចក៏ហូរមកពីរបៀបរៀបរយ ដែលព្រះជាម្ចាស់បានកំណត់ហើយនោះដែរ។ ប៉ុន្តែ ចំពោះការបញ្ជាក់របបនយោបាយ និងការជ្រើសរើសអ្នកដឹកនាំប្រទេសវិញ ស្រេចតែប្រជាពលរដ្ឋ ជ្រើសរើសដោយសេរី តាមបំណងប្រាថ្នារបស់ខ្លួន (រម ១៣, ១-៥)។

ឃ-យោងតាមសេចក្តីនេះ រដ្ឋអំណាច ទោះបីគេប្រើអំណាចក្នុងរង្វង់សហគមន៍នយោបាយក្តី ឬតាមស្ថាប័នជាតំណាងរបស់រដ្ឋក្តី ត្រូវតែប្រើតាមព្រំដែននៃរបៀបរៀបរយនៃសីលធម៌ជានិច្ច។ រដ្ឋក៏ត្រូវប្រើអំណាចដើម្បីជាប្រយោជន៍រួម ស្របតាមក្បួនច្បាប់ ដែលប្រជាពលរដ្ឋបានតែងតាំងរួចហើយ ឬត្រូវតែងតាំងនៅពេលអនាគត (ត្រូវគិតគូរអំពីប្រយោជន៍រួមដូចជាកម្លាំងមួយ)។ បើពិតជាដូច្នេះមែន ទើបប្រជាពលរដ្ឋត្រូវតែស្តាប់តាមបញ្ជារបស់រដ្ឋអំណាច តាមមនសិការរបស់ខ្លួន (រម ១៣, ៥)។ ហេតុនេះហើយ បានជាប្រជាពលរដ្ឋត្រូវទទួលស្គាល់ថា អ្នកកាន់អំណាចជាអ្នកទទួលខុសត្រូវ មានកិត្តិយសយ៉ាងថ្លៃថ្នូរ និងមានមុខងារដ៏សំខាន់មែន។

ង- ប្រសិនបើរដ្ឋអំណាចប្រព្រឹត្តហួសពីសមត្ថកិច្ចរបស់ខ្លួន បែរទៅជិះជាន់ប្រជាជន ពេលនោះ ប្រជាពលរដ្ឋមិនត្រូវរាញរាធ្វើកិច្ចការ ដែលមានប្រយោជន៍រួមយ៉ាងជាក់ច្បាស់នោះទេ។ ប៉ុន្តែ ប្រជាជនត្រូវមានច្បាប់អនុញ្ញាត ដែលអាចឲ្យគេការពារសិទ្ធិរបស់ខ្លួន និងសិទ្ធិប្រជាពលរដ្ឋឯទៀតៗ ដែលត្រូវរងគ្រោះដោយរដ្ឋអំណាចជិះជាន់នោះ។ ប្រជាជនត្រូវតែគោរពព្រំដែននៃច្បាប់ ដែលមកពីធម្មជាតិ និងធម្មវិន័យមកពីដំណឹងល្អផងដែរ។

ច- រីឯសហគមន៍នយោបាយតែងតាំងរចនាសម្ព័ន្ធរបស់ខ្លួន និងចាត់ចែងតុល្យភាពយ៉ាងស្រួលនៃរដ្ឋអំណាចមានរបៀបជាច្រើនប្លែកៗពីគ្នា ស្របតាមទេពកោសល្យប្រជាជននីមួយៗ និងស្របតាមដំណើរនៃប្រវត្តិសាស្ត្រ។ ក៏ប៉ុន្តែ រចនាសម្ពន្ធទាំងនោះ ត្រូវបម្រើការអប់រំមនុស្សជានិច្ច គឺអប់រំគេឲ្យមានវប្បធម៌ ឲ្យស្រឡាញ់សន្តិភាព ឲ្យមានចិត្តមេត្តាករុណាចំពោះមនុស្សគ្រប់ៗរូប ដើម្បីជាប្រយោជន៍ដល់មហាគ្រួសារនៃមនុស្សជាតិទាំងមូល។

## ៧៥ ប្រជាពលរដ្ឋទាំងអស់ រួមសហការក្នុងការរស់នៅជាសាធារណៈ

ក- រចនាសម្ព័ន្ធនយោបាយ និងក្បួនច្បាប់ដែលផ្តល់ឲ្យប្រជាពលរដ្ឋទាំងអស់មានលទ្ធភាព ដោយសេរី និងយ៉ាងសកម្មកាន់តែទូលំទូលាយឡើង ទាំងមិនរើសមុខនរណាសោះឡើយ ពិតជាត្រឹមត្រូវតាមលក្ខណៈរបស់មនុស្សមែន គឺប្រជាពលរដ្ឋត្រូវមានលទ្ធភាពទទួលចំណែក ក្នុងការតែងតាំងគ្រឹះនៃក្បួនច្បាប់របស់សហគមន៍នយោបាយ និងក្នុងការត្រួតត្រាលើកិច្ចសាធារណៈ។ ប្រជាពលរដ្ឋ ក៏ត្រូវមានលទ្ធភាពទទួលចំណែក ក្នុងការកំណត់សកម្មភាព និងគោលដៅនៃស្ថាប័ននានា និងក្នុងការបោះឆ្នោតរើសអ្នកដឹកនាំដែរ។ សូមប្រជាពលរដ្ឋទាំងអស់នឹកចងចាំថា គេមានសិទ្ធិ និងភារកិច្ចប្រើសន្លឹកឆ្នោតដោយសេរី ដើម្បីជាប្រយោជន៍រួម។ ព្រះសហគមន៍រាប់រកយ៉ាងខ្លាំង និងសរសើរសកម្មភាពរបស់អស់អ្នកដែលប្តេជ្ញាចិត្ត បម្រើកិច្ចការសាធារណៈ និងដែលទទួលបន្ទុកបម្រើមនុស្សទាំងអស់។

ខ- ត្រូវការមានលក្ខន្តិកៈច្បាប់ជាចាំបាច់ ចាត់ចែងនិងចែកមុខនាទី និងស្ថានប័ននានានៃរដ្ឋអំណាចយ៉ាងសមរម្យ។ ត្រូវមានអង្គភាពឯករាជ្យមួយ ការពារសិទ្ធិយ៉ាងសកម្ម ដែលមិននៅជាចំណុះនរណាឡើយដែរ។ ដូច្នេះ ប្រជាពលរដ្ឋដែលទទួលការខុសត្រូវ អាចរួមសហការគ្នា និងអាចបង្កើតផលល្អដ៏ប្រសើរក្នុងការរស់នៅតាមនយោបាយប្រចាំថ្ងៃ។ សូមឲ្យរដ្ឋអំណាច ទទួលស្គាល់សិទ្ធិរបស់បុគ្គលទាំងអស់ សិទ្ធិរបស់ក្រុមគ្រួសារ និងសិទ្ធិរបស់ក្រុមនានា ហើយសូមឲ្យរដ្ឋអំណាចអនុញ្ញាតឲ្យគេអាចប្រព្រឹត្តតាមសិទ្ធិទាំងនោះបាន។ សូមឲ្យរដ្ឋអំណាចគោរព និងលើកតម្លៃនៃសិទ្ធិទាំងនោះ។សូមឲ្យរដ្ឋអំណាចទទួលស្គាល់ភារកិច្ចដែលប្រជាពលរដ្ឋទាំងអស់ត្រូវអនុវត្តតាម។ ត្រូវរំឭកប្រជាពលរដ្ឋថា ក្នុងចំណោមភារកិច្ចទាំងនោះ មានភារកិច្ចបម្រើរដ្ឋដោយបង់ពន្ធដារ ឬដោយកម្លាំងពលកម្ម តាមតែប្រយោជន៍រួមទាមទារ។ អ្នកដឹកនាំ មិនត្រូវបង្កើតឧបសគ្គដល់សមាគមនានា គឺដល់សមាគមក្រុមគ្រួសារ ដល់សមាគមក្នុងសង្គម ដល់សមាគមវប្បធម៌ ដល់អង្គភាព និងដល់ស្ថាប័នកណ្តាល ហើយក៏មិនត្រូវឃាត់ឃាំងសកម្មភាពដ៏ត្រឹមត្រូវ តាមច្បាប់នៃសហគមន៍និងក្រុមទាំងនោះជាដាច់ខាត។ ផ្ទុយទៅវិញ សូមឲ្យរដ្ឋអំណាច យកចិត្តទុកដាក់ជួយសមាគម និងក្រុមទាំងនោះឲ្យមានរបៀបរៀបរយ។ រីឯប្រជាពលរដ្ឋវិញ ម្នាក់ៗក្តី រួមជាក្រុមក្តី សូមជៀសវាង កុំប្រគល់អំណាចខ្លាំងពេកដល់រដ្ឋអំណាច។ សូមកុំអង្វររដ្ឋអំណាចខុសពេល ដើម្បីទាមទារ

ជំនួយ និងអត្ថប្រយោជន៍ហួសហេតុ ដែលអាចបណ្តាលឲ្យបុគ្គលឲ្យគ្រួសារ និងឲ្យក្រុមនានាក្នុងសង្គម ទទួលខុសត្រូវតិចជាងពីមុន។

គ- នៅសម័យយើងនេះ សភាពការណ៍កាន់តែស្មុគស្មាញឡើងៗ បង្ខំឲ្យរដ្ឋអំណាច ធ្វើអន្តរាគមន៍កាន់តែមមាញឹក ក្នុងវិស័យសង្គម វិស័យសេដ្ឋកិច្ច និងវិស័យវប្បធម៌ ដើម្បីរៀបចំលក្ខ័ណ្ឌងាយស្រួល នាំឲ្យប្រជាពលរដ្ឋ និងក្រុមនានាអាចរកប្រយោជន៍ទាំងស្រុងរបស់មនុស្ស ក្នុងសេរីភាព កាន់តែសកម្មឡើង។ តាមពិត ត្រូវយល់អំពីទំនាក់ទំនងរវាងសង្គមូបនិយកម្មនិងស្វ័យភាព ឬការអភិវឌ្ឍន៍បុគ្គលម្នាក់ៗ តាមរបៀបផ្សេងៗពីគ្នា ស្របតាមតំបន់ និងស្របតាមការវិវឌ្ឍន៍នៃប្រជាជាតិនានា។ ប៉ុន្តែ ប្រសិនបើរដ្ឋអំណាចបន្ថយសិទ្ធិមនុស្សមួយរយៈពេល ដោយគិតដល់ប្រយោជន៍រួម ត្រូវដាក់ចូលសិទ្ធិទាំងនោះ ឡើងវិញ នៅពេលសភាពការណ៍ប្រែជាធម្មតា។ រដ្ឋាភិបាលដែលប្រើអំណាចលទ្ធិផ្តាច់ការ ពិតជាអមនុស្សធម៌មែន គឺខុសលក្ខណៈជាមនុស្ស ព្រោះរដ្ឋាភិបាលនោះបំបាត់សិទ្ធិមនុស្ស និងសិទ្ធិក្រុមនានាក្នុងសង្គម ជាទម្ងន់។

ឃ-សូមឲ្យប្រជាពលរដ្ឋ ពង្រឹងមនោសញ្ចេតនាស្នេហាជាតិ ដោយចិត្តទូលាយ និងដោយចិត្តស្មោះ ក៏ប៉ុន្តែ កុំចង្អៀតចិត្តឲ្យសោះ គឺថា នៅពេលជាមួយគ្នានោះ ឲ្យគេនឹកគិតដល់ប្រយោជន៍មហាគ្រួសារទាំងមូល នៃមនុស្សលោកជានិច្ច ជាមហាគ្រួសារដែលប្រមូលមនុស្សគ្រប់ជាតិសាសន៍ គ្រប់ប្រជាជន គ្រប់ប្រជាជាតិ ដែលភ្ជាប់គ្នាដោយចំណងជាច្រើនយ៉ាង។

ង- គ្រីស្តបរិស័ទទាំងអស់ត្រូវដឹងខ្លួនថា គេមានតួនាទីពិសេសផ្ទាល់ក្នុងសហគមន៍នយោបាយ គឺគេត្រូវធ្វើជាគំរូល្អ ដោយមានគំនិតសុខចិត្តទទួលខុសត្រូវ និងស្ម័គ្រចិត្តរកប្រយោជន៍រួមកាន់តែខ្លាំងឡើងៗ។ គ្រីស្តបរិស័ទ ត្រូវប្រព្រឹត្តកិច្ចការដែលបង្ហាញឲ្យដឹងថា រដ្ឋអំណាចនិងសេរីភាពអាចចុះសម្រុងគ្នាបាន គំនិតផ្តើមដោយខ្លួនឯង និងសាមគ្គី ហើយអ្វីៗដែលសង្គមទាមទារអាចចុះសម្រុងគ្នា អត្ថប្រយោជន៍នៃការរួបរួមគ្នាជាធ្លុងតែមួយ និងគំនិតផ្សេងៗដែលបង្កើតផលក៏អាចចុះសម្រុងគ្នាដែរ។ ចំពោះការចាត់ចែងអ្វីៗនៅលើផែនដីនេះ សូមឲ្យគ្រីស្តបរិស័ទចាត់ទុកថា អ្នកដែលមានទស្សនៈផ្សេងៗទាស់ទែងគ្នា មានសិទ្ធិកាន់ទស្សនៈនោះ ហើយត្រូវគោរពក្រុមប្រជាពលរដ្ឋ ដែលការពារយោបល់របស់ខ្លួនដោយចិត្តស្មោះ។ រីឯបក្សនយោបាយវិញ គេមានភារកិច្ចលើកស្ទួយអ្វីៗដែលគេយល់ឃើញថា ប្រយោជន៍រួមទាមទារ។ ប៉ុន្តែគេមិនដែលមានសិទ្ធិរកប្រយោជន៍ផ្ទាល់ខ្លួន ជំនួសប្រយោជន៍រួមទេ។

ច- យើងត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង នឹងពង្រីកការអប់រំខាងសង្គមនិងខាងនយោបាយ ដើម្បីឲ្យប្រជាពលរដ្ឋទាំងអស់ អាចបំពេញតួនាទីរបស់ខ្លួន ក្នុងការរស់នៅក្នុងសហគមន៍នយោបាយ។ សព្វថ្ងៃ ការអប់រំនេះមានសារៈសំខាន់ជាពិសេសសម្រាប់ប្រជាជនទូទៅ មានយុវជនជាដើម។ អស់អ្នកដែលមានសមត្ថភាព ឬអាចមានសមត្ថភាពបំពេញមុខងារខាងនយោបាយ ត្រូវដឹងថា មុខងារនេះពិបាកបំផុត តែប្រសើរបំផុតដែរ ត្រូវតែរៀបចំខ្លួន ដើម្បីបំពេញមុខងារនេះបាន។ សូមឲ្យអស់លោកខ្នះខ្នែងបំពេញមុខងារនេះ ដោយមិនគិតគូរដល់ប្រយោជន៍ផ្ទាល់ខ្លួន ឬរកអត្ថប្រយោជន៍ខាងសម្ភារៈនោះទេ។ អស់លោកត្រូវប្រយុទ្ធដោយចិត្តសុចរិត និងប្រុងប្រយ័ត្ន ប្រឆាំងនឹងអយុត្តិធម៌ និងការជិះជាន់ ព្រមទាំងប្រឆាំងនឹងអំណាចផ្តាច់ការមិនចេះអត់ឱន ទោះជាអំណាចផ្តាច់ការរបស់បុគ្គលម្នាក់ ឬជាអំណាចរបស់បក្សមួយណាក្តី។ អស់លោក

នឹងត្រូវស៊ូប្ដូរជីវិត ដើម្បីជាប្រយោជន៍របស់មនុស្សទាំងអស់ដោយចិត្តស្មោះ និងទៀងត្រង់។ លើសពីនេះទៅទៀត អស់លោកត្រូវប្ដេជ្ញាចិត្តបម្រើប្រជាជន ដោយសេចក្ដីស្រឡាញ់ និងសេចក្ដីក្លាហានតាមការរស់នៅខាងនយោបាយនោះ។

## ៧៦- សហគមន៍នយោបាយ និងព្រះសហគមន៍

ក- នៅប្រទេសមានជាតិសាសន៍ច្រើនលាយគ្នា ត្រូវមានទស្សនៈត្រឹមត្រូវ អំពីទំនាក់ទំនងសហគមន៍ នយោបាយ និងព្រះសហគមន៍។ គ្រីស្ដបរិស័ទ ទោះជាបុគ្គលក្ដី ឬជាក្រុមក្ដី តែងតែប្រព្រឹត្តកិច្ចការខ្លះ ក្នុងឋានៈខ្លួនជាប្រជាពលរដ្ឋ តាមមនសិការជាគ្រីសស្ដបរិស័ទ។ គេក៏តែងប្រព្រឹត្តកិច្ចការខ្លះផ្សេងទៀត ក្នុងនាមព្រះសហគមន៍ ទាំងរួមជាមួយអស់លោកគង្វាល។ ត្រូវវែកញែកឲ្យបានច្បាស់អំពីកិច្ចការទាំងពីរប្រភេទ ដែលគ្រីស្ដបរិស័ទតែងប្រព្រឹត្តនោះ ក្នុងឋានៈជាប្រជាពលរដ្ឋ និងក្នុងឋានៈជាសមាជិកនៃព្រះសហគមន៍។

ខ- ព្រះសហគមន៍ទទួលបន្ទុកពីព្រះគ្រីស្ដ និងមានសមត្ថភាពផ្ទាល់។ ដូច្នេះ ព្រះសហគមន៍មិនលាយឡំនឹងសហគមន៍ នយោបាយទាល់តែសោះ ហើយក៏មិនភ្ជាប់ជាមួយរបបនយោបាយណាមួយឡើយ។ ព្រះសហគមន៍ ជាសញ្ញាសម្គាល់អំពីលក្ខណៈដ៏ខ្ពង់ខ្ពស់ ហួសពីលោកនេះរបស់បុគ្គលម្នាក់ៗ ហើយក៏ថែរក្សាការពារលក្ខណៈដ៏ប្រសើរនោះផង។

គ- សហគមន៍នយោបាយនិងព្រះសហគមន៍ នៅដោយឡែកពីគ្នានិងស្វយ័តតាមវិស័យរៀងៗខ្លួន។ ប៉ុន្តែសហគមន៍នយោបាយ និងព្រះសហគមន៍ ទោះបីមានមុខនាទីប្លែកពីគ្នាក្ដី ក៏បម្រើទិសដៅ កំណត់តាមព្រះជាម្ចាស់ត្រាស់ហៅ របស់មនុស្សតែមួយដដែល ទាំងក្នុងឋានៈជាបុគ្គល ទាំងក្នុងឋានៈជាសង្គម។ សហគមន៍ទាំងពីរនឹងបំពេញមុខនាទីនេះ ដើម្បីជាប្រយោជន៍របស់មនុស្ស SOLDE de TOUT COMPTE ទាំងអស់ កាន់តែសកម្ម ដោយខិតខំរួមសហការយ៉ាងត្រឹមត្រូវជាមួយគ្នា ទាំងគិតគូរដល់សភាពការណ៍នៃប្រវត្តិសាស្ត្រ និងនៃប្រទេស។ អនាគតមនុស្ស មិនគ្រាន់តែមានព្រំដែននៅលើផែនដីនេះប៉ុណ្ណោះទេ ទោះបីមនុស្សរស់នៅតាមប្រវត្តិសាស្ត្ររបស់មនុស្សជាតិក្ដី ក៏មនុស្សនៅតែរក្សាទិសដៅកំណត់របស់ខ្លួន ពោលគឺ ជីវិតរួមជាមួយព្រះជាម្ចាស់ ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច។ រីឯព្រះសហគមន៍វិញព្រះគ្រីស្ដជាព្រះសង្គ្រោះ តែងតាំងដោយព្រះហឫទ័យស្រឡាញ់ ព្រះសហគមន៍នៅតែជួយនាំយុត្តិធម៌ និងសេចក្ដីស្រឡាញ់ឲ្យគ្រងរាជ្យកាន់តែខ្លាំងឡើងៗក្នុងផ្ទៃជាតិនីមួយៗ និងរវាងប្រជាជាតិនានា។ ព្រះសហគមន៍ ប្រកាសសេចក្ដីពិតនៃដំណឹងល្អ ហើយក៏យកលទ្ធិរបស់ខ្លួន និងសក្ខីភាពរបស់គ្រីស្ដបរិស័ទ មកបំភ្លឺសកម្មភាពរបស់មនុស្សក្នុងគ្រប់វិស័យ។ ដោយធ្វើដូច្នេះ ព្រះសហគមន៍គោរព និងលើកស្ទួយសេរីភាពខាងនយោបាយឡើង និងជួយឲ្យប្រជាពលរដ្ឋទទួលខុសត្រូវបានផង។

ឃ-ព្រះគ្រីស្ដ ជាព្រះសង្គ្រោះរបស់មនុស្សលោក បានចាត់ក្រុមគ្រីស្ដទូត និងអស់អ្នកដែលបន្តមុខងារពីគ្រីស្ដទូត ព្រមទាំងសហការីរបស់អស់លោក ឲ្យប្រកាសដំណឹងល្អរបស់ព្រះអង្គ។ កិច្ចការរបស់អស់លោកជាគ្រីស្ដទូត សំអាងលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលសម្ដែងកម្លាំងនៃដំណឹងល្អ ដោយសារសក្ខីភាពរបស់មនុស្សទន់ខ្សោយ។ ត្រូវឲ្យអស់អ្នកដែលប្ដេជ្ញាចិត្តបម្រើព្រះបន្ទូល ប្រើមាគ៌ាផ្ទាល់នៃដំណឹងល្អ ដែលប្លែកពីមាគ៌ានៃបុរីនៅលើផែនដីនេះ គ្រប់ប្រការជាច្រើន។

ង- តាមពិត អ្វីៗដែលស្ថិតនៅក្នុងលោកនេះ នឹងអ្វីៗក្នុងលក្ខណៈមនុស្ស ដែលហួសពីលោកនេះ ក៏ភ្ជាប់ជាមួយគ្នាយ៉ាងស្អិតល្មួត។ ព្រះសហគមន៍ក៏ប្រើគ្រឿងឧបករណ៍នៃលោកនេះ តាមតែសេចក្តីត្រូវការ នៃបេសកកម្មរបស់ខ្លួនទាមទារ។ ប៉ុន្តែ ព្រះសហគមន៍មិនយកឯកសិទ្ធិ ដែលរដ្ឋអំណាចផ្តល់ឲ្យ មកធ្វើជាគ្រឹះនៃសេចក្តីសង្ឃឹមរបស់ខ្លួនឡើយ។ លើសពីនេះទៅទៀតប្រសិនបើ ការប្រើប្រាស់ឯកសិទ្ធិខ្លះ បណ្តាលឲ្យគេមានមន្ទិលសង្ស័យថា សក្ខីភាពរបស់ព្រះសហគមន៍មិនបរិសុទ្ធទេ ឬប្រសិនបើសភាពការណ៍ថ្មីទាមទារការតែងតាំងផ្សេងទៀត ព្រះសហគមន៍ត្រូវតែលះបង់ឯកសិទ្ធិខ្លះចោល ទោះបីព្រះសហគមន៍បានទទួលឯកសិទ្ធិទាំងនោះត្រឹមត្រូវតាមច្បាប់ក្តី។ ព្រះសហគមន៍ ត្រូវមានសិទ្ធិអាចប្រកាសជំនឿរបស់ខ្លួននៅគ្រប់ទីកន្លែងនិងជានិច្ច ដោយមានសេរីភាពយ៉ាងពិតប្រាកដ ត្រូវមានសិទ្ធិបង្រៀនលទ្ធិរបស់ខ្លួនអំពីសង្គម មានសិទ្ធិបំពេញបេសកកម្មរបស់ខ្លួន ក្នុងចំណោមមនុស្សលោកដោយគ្មានឧបសគ្គរារាំង។ នៅពេលណាសិទ្ធិមនុស្ស ឬការសង្គ្រោះខាងផ្លូវធម៌ទាមទារនោះ ព្រះសហគមន៍មានសិទ្ធិអាចវិនិច្ឆ័យតាមសីលធម៌បានសូម្បីតែ ក្នុងវិស័យពាក់ព័ន្ធនឹងនយោបាយដែរ។ ព្រះសហគមន៍ត្រូវប្រើគ្រប់មធ្យោបាយ ស្របតាមដំណឹងល្អ និងដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ ស្របតាមសភាពការណ៍និងកាលៈទេសៈ ដែលប្លែកៗពីគ្នា។

ច- ព្រះសហគមន៍ផ្ចង់ចិត្ត ហើយស្មោះត្រង់នឹងដំណឹងល្អ។ ពេលព្រះសហគមន៍បំពេញបេសកកម្មក្នុងលោកនេះ ព្រះសហគមន៍ជួយ និងពង្រឹងអ្វីៗដ៏ទៀងត្រង់ដ៏ពិតប្រាកដ ដ៏ល្អក្នុងសហគមន៍មនុស្សលោក (ពន្លឺ ១៣) ហើយក៏ពង្រឹងសន្តិភាពក្នុងចំណោមមនុស្ស ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (លក ២, ១៤)។

# ជំពូក ៥

## ការរក្សាការពារសន្តិភាព និង ការសាងសង់សហគមន៍ប្រជាជាតិ

### ៧៧. អារម្ភកថា

ក- ប៉ុន្មានឆ្នាំកន្លងមក សង្គ្រាមបានបំផ្លាញអ្វីៗទាំងអស់ បណ្ដាលឲ្យមានទុក្ខវេទនាជាទម្ងន់។ សព្វថ្ងៃបញ្ហានេះ នៅតែសង្កត់សង្កិនយ៉ាងធ្ងន់ធ្ងរលើយើងនៅឡើយ មនុស្សចេះតែតប់ប្រមល់ជាខ្លាំងថា សង្គ្រាមអាចនឹងផ្ទុះឡើងបាន។ មហាគ្រួសាររបស់មនុស្សជាតិទាំងមូល រស់នៅក្នុងសម័យដ៏សំខាន់បំផុត ក្នុងការវិវឌ្ឍន៍របស់ខ្លួន និងសម្រាប់អនាគតផង។ មហាគ្រួសាររបស់មនុស្សជាតិប្រមូលផ្ដុំគ្នាបន្តិចម្ដងៗ ហើយនៅគ្រប់ទីកន្លែងដឹងកាន់តែច្បាស់ថា គេកំពុងរួមគ្នាជាធ្លុងតែមួយ។ ឥឡូវនេះ មហាគ្រួសារនេះត្រូវសម្រេចកិច្ចមួយដ៏អស្ចារ្យឲ្យបានជាស្រេច គឺកសាងពិភពលោកដែលមានលក្ខណៈជាមនុស្សកាន់តែប្រសើរឡើងៗ ជូនមនុស្សទាំងអស់ និងនៅគ្រប់ទីកន្លែង។ មនុស្សអាចសម្រេចកិច្ចការនេះបាន លុះត្រាតែគេប្រែចិត្តគំនិតជាថ្មីទាំងអស់គ្នា បែរទៅកសាងសន្តិភាពដ៏ពិតប្រាកដ។ ពេលនោះ ទើបសារនៃដំណឹងល្អនឹងចាំងពន្លឺថ្មីដ៏ត្រចះត្រចង់នៅសម័យយើង គឺដំណឹងល្អដែលប្រកាសថា អ្នកកសាងសន្តិភាពពិតជាមានសុភមង្គលហើយ «ដ្បិតពួកគេនឹងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់» (មថ ៥, ៩)។ សារនៃដំណឹងល្អនេះ ក៏ស្របតាមសេចក្ដីប៉ងប្រាថ្នា និងឧត្ដមគតិដ៏ខ្ពស់ជាងគេរបស់មនុស្សជាតិដែរ។

ខ- ហេតុនេះហើយ បានជាមហាសន្និបាតសូមពន្យល់យ៉ាងពិស្ដារ អំពីទស្សនៈដ៏ពិតប្រាកដ និងដ៏ឧត្ដុង្គឧត្ដមបំផុតនៃសន្តិភាព ព្រមទាំងដាក់ទោសសង្គ្រាមដ៏ព្រៃផ្សៃ។ មហាសន្និបាតក៏សូមអំពាវនាវយ៉ាងក្លៀវក្លា ឲ្យគ្រីស្តបរិស័ទរួមសហការជាមួយមនុស្សទាំងអស់ ដើម្បីជួយពង្រឹងសន្តិភាពរវាងគ្នា និងគ្នា តាមយុត្តិធម៌ និងសេចក្ដីស្រឡាញ់ផង។ សូមគ្រីស្តបរិស័ទ រៀបចំមធ្យោបាយកសាងសន្តិភាព ដោយមានព្រះគ្រីស្តដែលបង្កើតសន្តិភាព ជួយឧបត្ថមផងដែរ។

### ៧៨. លក្ខណៈនៃសន្តិភាព

ក- សន្តិភាពមិនគ្រាន់តែមានន័យថា គ្មានសង្គ្រាមទេ ក៏មិនគ្រាន់តែឲ្យកម្លាំងអាវុធរបស់គូបដិបក្ខស្មើគ្នាទេ។ សន្តិភាព ក៏មិនមកពីមានប្រទេសមួយត្រួតត្រាផ្ដាច់ការលើប្រទេសឯទៀតៗដែរ។ តែសន្តិភាព មានន័យយ៉ាងពិតប្រាកដថា ជាផលនៃសេចក្ដីសុចរិត (អស ៣២, ១៧)។ សន្តិភាពពិតជាផលនៃរបៀបរៀបរយដែលព្រះអាទិករបានចាក់ក្នុងសង្គមមនុស្ស។ មនុស្សទាំងអស់ នៅតែសង្វាតស្វះស្វែងរក ចង់បានសន្តិភាពកាន់តែប្រសើរឡើងៗ ហើយក៏ត្រូវកសាងសន្តិភាពនោះដែរ។ ធម្មវិន័យរបស់ព្រះជាម្ចាស់ពិតជាគ្រឹះណែនាំប្រយោជន៍រួមរបស់មនុស្សលោក។ ប៉ុន្តែ តាមសេចក្ដីត្រូវការជាក់ច្បាស់ប្រចាំថ្ងៃ ប្រយោជន៍រួមនោះ ត្រូវ

ជួបការប្រែប្រួលឥតឈប់ឈរ តាមដំណើរនៃពេលវេលាដែរ។ មនុស្សមិនដែលបានសន្តិភាពម្តងជាស្រេចទេ តែត្រូវសាងសង់សន្តិភាពរហូតជានិច្ច។ បំណងប្រាថ្នារបស់មនុស្សទន់ខ្សោយ ហើយត្រូវរបួស ដោយសារអំពើបាប។ ហេតុនេះហើយ បានជាសន្តិភាពទាមទារឲ្យមនុស្សម្នាក់ៗ រំងាប់តណ្ហារបស់ខ្លួន និងត្រូវឲ្យរដ្ឋអំណាចដ៏ត្រឹមត្រូវ ខំព្យាយាមកសាងយុត្តិធម៌ផងដែរ។

ខ- ប៉ុន្តែ សេចក្តីទាំងនោះ មិនទាន់គ្រប់គ្រាន់ទេ។ សន្តិភាពដែលយើងនិយាយនេះ អាចកើតឡើងនៅលើផែនដីបាន លុះត្រាតែរដ្ឋអំណាចរក្សាទុកសេចក្តីសុខសាន្តរបស់មនុស្សម្នាក់ៗ។ មនុស្សក៏ត្រូវចែកចាយដោយសេរី និងដោយទុកចិត្តគ្នាទៅវិញទៅមក នូវយោបល់ដ៏ថ្លៃថ្នូរដែលផុសចេញពីវិញ្ញាណរបស់ខ្លួន និងអ្វីៗដែលគេបង្កើតតាមទេពកោសល្យរបស់ខ្លួន។ ត្រូវឲ្យមនុស្សមានបំណងរឹងប៉ឹងចង់គោរពអ្នកដទៃ និងប្រជាជាតិដទៃ ព្រមទាំងគោរពកិត្តិយសដ៏ថ្លៃថ្នូររបស់គេ។ មនុស្សម្នាក់ៗត្រូវព្យាយាមរាប់រកអ្នកដទៃទុកជាបងប្អូន។ កិច្ចការទាំងនោះ សុទ្ធតែជាកិច្ចការដ៏ចាំបាច់បំផុតក្នុងការកសាងសន្តិភាព។ ហេតុនេះហើយ បានជាសន្តិភាពក៏ជាផលនៃសេចក្តីស្រឡាញ់ គឺហួសពីអ្វីៗដែលយុត្តិធម៌អាចនាំមកបាន។

គ- សន្តិភាពនៅលើផែនដី កើតមកពីការស្រឡាញ់អ្នកដទៃ។ សន្តិភាពនេះ ជានិមិត្តសញ្ញានិងជាផលនៃសន្តិភាព ដែលព្រះគ្រីស្តប្រទានឲ្យ ហើយក៏ជាសន្តិភាព ដែលហូរពីព្រះបិតាមកដែរ។ ព្រះបុត្រាផ្ទាល់ប្រសូតជាមនុស្ស ព្រះអង្គជាអម្ចាស់នៃសន្តិភាព គឺព្រះអង្គបានសម្រុះសម្រួលមនុស្សទាំងអស់ ឲ្យបានជានាជាមួយនឹងព្រះជាម្ចាស់ ដោយទ្រង់សោយទិវង្គតនៅលើឈើឆ្កាង ព្រះអង្គប្រមែប្រមូលមនុស្សទាំងអស់ ឲ្យរួមគ្នាជាប្រជាជនតែមួយ និងជារូបកាយតែមួយដែរ។ ព្រះអង្គបានសម្លាប់ការស្អប់គ្នាក្នុងព្រះកាយផ្ទាល់របស់ព្រះអង្គ (អភ ២, ១៩; កូឡ ១, ២០.២២)។ ក្រោយពីព្រះអង្គមានជ័យជម្នះ គឺក្រោយពីពេលព្រះអង្គមានព្រះជន្មថ្មីដ៏រុងរឿងនោះ ទ្រង់ចាក់បង្ហូរព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់ ក្នុងដួងចិត្តមនុស្សលោក។

ឃ-ហេតុនេះហើយ បានជាគ្រីស្តបរិស័ទទាំងអស់ ដែលតែងតែប្រព្រឹត្តតាមសេចក្តីពិតដោយចិត្តស្រឡាញ់ (អភ ៤, ១៥) ព្រះជាម្ចាស់ត្រាស់ហៅគេ ឲ្យរួមសហការជាមួយមនុស្ស ដែលពិតជាស្នេហាសន្តិភាពមែន អង្វរព្រះជាម្ចាស់ សូមព្រះអង្គតែងតាំងសន្តិភាពបែបនោះផង។

ង- យើងក៏មានចិត្តគំនិតចង់កសាងសន្តិភាពដូច្នេះដែរ។ យើងក៏ត្រូវនាំគ្នាសរសើរអស់អ្នកដែលតយុទ្ធថែរក្សាការពារសិទ្ធិនានា ដោយមិនប្រើអំពើហិង្សា។ សូម្បីតែអ្នកទន់ខ្សោយក៏មានលទ្ធភាពអាចប្រើមធ្យោបាយអហិង្សានោះដែរ។ ក៏ប៉ុន្តែ ការតយុទ្ធរបស់គេនោះ មិនត្រូវបង្ខូចសិទ្ធិនិងភារកិច្ចមនុស្សឯទៀតៗ ឬសិទ្ធិរបស់សហគមន៍នោះទេ។

ច- ដោយយើងដឹងថា មនុស្សយើងជាអ្នកបាប យើងត្រូវភ័យខ្លាចថាសង្គ្រាមអាចផ្ទុះឡើងជានិច្ច គឺត្រូវខ្លាចដូច្នេះ រហូតដល់ពេលព្រះគ្រីស្តយាងមកវិញ។ ក៏ប៉ុន្តែ បើមនុស្សរួបរួមគ្នាដោយសេចក្តីស្រឡាញ់ ហើយឈ្នះអំពើបាបទៀត គេក៏អាចឈ្នះហិង្សាបានដែរ រហូតដល់ពេលព្រះបន្ទូលព្រះជាម្ចាស់កើតជារូបរាងហើយ គឺថា «ពួកគេនឹងយកដាវរបស់ខ្លួនមករំលាយធ្វើជាផាលនង្គ័ល ហើយយកលំពែង មករំលាយធ្វើជាកណ្តៀវ។ ប្រជាជាតិមួយឈប់ច្បាំងនឹងប្រជាជាតិមួយទៀត ហើយគេក៏លែងហាត់រៀនធ្វើសង្គ្រាមទៀតដែរ» (អស ៤, ២)។

# វគ្គទី ១

## ត្រូវជៀសវាងកុំឲ្យកើតសង្គ្រាមជាដាច់ខាត

### ៧៩.សូមឈប់ធ្វើសង្គ្រាមដ៏ព្រៃផ្សៃ

ក- សង្គ្រាមសកលទាំងពីរលើក បានបណ្តាលឲ្យមនុស្សលោកកើតទុក្ខយ៉ាងសាហាវបំផុត ទាំងផ្នែកសម្ភារៈ ទាំងក្នុងវិស័យសីលធម៌។ ប៉ុន្តែ នាបច្ចុប្បន្នកាល សង្គ្រាមនៅតែបន្តបំផ្លាញតំបន់ខ្លះក្នុងពិភពលោកជារៀងរាល់ថ្ងៃដែរ។ លើសពីនេះទៅទៀត មនុស្សយកសាស្ត្រាវុធទំនើបគ្រប់យ៉ាង តាមវិទ្យាសាស្ត្រមកប្រើដើម្បីច្បាំងគ្នា ហេតុនេះហើយ បានជាសង្គ្រាមកាន់តែសាហាវឃោរឃៅទៅៗ បណ្តាលឲ្យកងទ័ពប្រព្រឹត្តអំពើអមនុស្សធម៌អាក្រក់ជាងសម័យមុនៗដែរ។ ម្យ៉ាងទៀត សភាពការណ៍ស្មុគ្រស្មាញនាបច្ចុប្បន្ន ហើយទំនាក់ទំនងអន្តរជាតិក៏ប្រទាក់ឆ្វាក់គ្នាដែរ បានជាកើតវិធីថ្មីដែលមានកលល្បិច និងវិទ្ធង្សនា បណ្តាលឲ្យកើតសង្គ្រាមមិនចេញមុខ និងបណ្តាលឲ្យការរកសន្តិភាពមានភាពយឺតយ៉ាវ។ ក្នុងករណីជាច្រើន គេប្រើភេរវកម្មទុកជារបៀបថ្មីក្នុងការធ្វើសង្គ្រាម។

ខ- ដោយឃើញសភាពការណ៍ដ៏សែនអាណោចអាធ័មរបស់មនុសលោកនេះ ជាបឋម មហាសន្និបាតសូមរំឭកនូវតម្លៃដ៏ថ្លៃថ្នូរនៃសិទ្ធិមនុស្ស ដែលនៅស្ថិតស្ថេរជានិច្ច និងរំឭកគោលការណ៍សកលនៃសិទ្ធិទាំងនោះ។ មនសិការរបស់មនុស្សជាតិ តែងតែប្រកាសគោលការណ៍ទាំងនោះឲ្យកាន់តែម៉ឺងម៉ាត់ និងយ៉ាងខ្លាំងក្លាឡើងៗ។ កិច្ចការផ្ទុយនឹងគោលកាណ៍ទាំងនោះ ដែលមនុស្សប្រព្រឹត្តទាំងដឹងខ្លួននិងដោយសេរី ពិតជាអំពើឧក្រិដ្ឋមែន។ អ្នកបញ្ជាឲ្យប្រព្រឹត្តកិច្ចទាំងនោះ ក៏ជាជនឧក្រិដ្ឋដែរ។ អ្នកស្តាប់បង្គាប់ដោយមិនរិះគិតមិនអាចដោះសារខ្លួនបានសោះ។ ក្នុងចំណោមអំពើឧក្រិដ្ឋទាំងនោះ ជាបឋម ត្រូវរាប់បញ្ចូលការប្រល័យពូជសាសន៍មួយទាំងមូល ប្រល័យជាតិមួយ ឬប្រល័យជនជាតិភាគតិច ទោះជាមានមូលហេតុ ឬប្រើវិធីយ៉ាងណាក៏ដោយ។ ត្រូវដាក់ទោសចំពោះអំពើឧក្រិដ្ឋទាំងនោះដោយដាច់អហង្ការ និងចាត់ទុកជាអំពើឧក្រិដ្ឋគួរឲ្យស្អប់ខ្ពើមណាស់។ យើងសូមសរសើរមិនដាច់ពីមាត់ នូវអស់អ្នកដែលមានចិត្តក្លាហានហ៊ានចេញមុខប្រឆាំងនឹងមនុស្ស ដែលប្រព្រឹត្តអំពើព្រៃផ្សៃទាំងនោះ។

គ- មានការព្រមព្រៀងអន្តរជាតិផ្សេងៗជាច្រើនស្តីអំពីសង្គ្រាម ដើម្បីឲ្យកាត់បន្ថយភាពអមនុស្សធម៌នៃសង្គ្រាម និងកាត់បន្ថយលទ្ធផលដ៏អាក្រក់នៃចម្បាំងទាំងនោះ។ ប្រទេសមួយចំនួនធំ បានអនុវត្តតាមការព្រមព្រៀងទាំងនោះ គឺមានការព្រមព្រៀងស្តីអំពីទាហានដែលត្រូវរបួស អំពីទាហានដែលត្រូវគេចាប់ជាឈ្លើយសង្គ្រាម និងការព្រមព្រៀងផ្សេងៗទៀត។ ត្រូវតែអនុវត្តតាមការព្រមព្រៀងទាំងនោះ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋទាំងអស់ ជាពិសេសរដ្ឋអំណាចនិងឥស្សរជនដែលមានសមត្ថកិច្ច ត្រូវខិតខំកែសម្រួលការព្រមព្រៀងទាំងនោះ ឲ្យកាន់តែប្រសើរឡើងៗប្រសិនបើគេអាចធ្វើបាន។ ដូច្នេះ ការព្រម

ព្រៀងទាំងនោះ អាចកាត់បន្ថយភាពអមនុស្សធម៌នៃសង្គ្រាមយ៉ាងសកម្ម។ លើសពីនេះទៅទៀត យើងយល់យើងថា គួឲ្យរដ្ឋអំណាចត្រូវមានមនុស្សធម៌ បង្កើតច្បាប់គិតគូរចំពោះអស់អ្នកដែលមិនព្រមកាន់អាវុធ ដោយករណីមនសិការ។ ប៉ុន្តែ អ្នកទាំងនោះត្រូវសុខចិត្តបម្រើសហគមន៍មនុស្សតាមរបៀបផ្សេងវិញ។

ឃ-ពិតមែនហើយ សង្គ្រាមមិនទាន់បាត់ពីគំនិតមនុស្សលោកទេ។ ដរាបណាគ្មានអំណាចអន្តរជាតិ ដែលមានសមត្ថកិច្ច និងមានកងទ័ពគ្រប់គ្រាន់បង្ការកុំឲ្យមានសង្គ្រាមផ្ទុះឡើង។ ប៉ុន្តែ រដ្ឋាភិបាលនានាមានសិទ្ធិដ៏ត្រឹមត្រូវនឹងការពារប្រទេសរបស់ខ្លួនដោយប្រើអាវុធបាន លុះត្រាតែ គេបានប្រើគ្រប់មធ្យោបាយ ក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធីជាមុនសិន។ ហេតុនេះ អស់ប្រមុខរដ្ឋ និងអស់លោកអ្នកដែលទទួលខុសត្រូវក្នុងកិច្ចការសាធារណៈ មានភារកិច្ចការពារប្រជាជនរបស់គេ គឺត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងគិតអំពីសេចក្ដីដ៏សំខាន់បំផុតទាំងនោះ។ ប៉ុន្តែត្រូវយល់ថា ការបង្កើតសង្គ្រាមដើម្បីការពារប្រជាជនរបស់ខ្លួនយ៉ាងត្រឹមត្រូវតាមច្បាប់ និងបំណងចង់ត្រួតត្រាប្រជាតិផ្សេងដោយប្រើអាវុធ គឺពិតជាករណីផ្សេងពីគ្នាទាំងស្រុង។ កម្លាំងអាវុធគ្មានន័យថា យើងមានសិទ្ធិប្រើអាវុធទាំងនោះបាន តាមគោលដៅនយោបាយ ឬតាមគោលដៅយោធាទេ។ប្រសិនបើសង្គ្រាមត្រូវនឹងផ្ទុះឡើង កុំនឹកស្មានថា ពេលនោះគូបដិបក្ខអាចប្រព្រឹត្តអ្វីៗបានតាមអំពើចិត្ត។

ង- ចំពោះអស់លោកអ្នកដែលប្ដេជ្ញាចិត្តបម្រើមាតុភូមិ ក្នុងឋានៈជាទាហាន សូមចាត់ខ្លួនទុកជាអ្នកបម្រើសន្តិសុខ និងបម្រើសេរីភាពរបស់ប្រជាជននានា។ ប្រសិនបើគេបំពេញកិច្ចការនេះយ៉ាងត្រឹមត្រូវ គេពិតជាជួយថែរក្សាសន្តិភាពមែន។

## ៨០. សង្គ្រាមបរមាណូ

ក- សាស្ត្រាវុធវិទ្យាសាស្ត្រ តែងតែចម្រើនឡើងជាលំដាប់ បណ្ដាលឲ្យសង្គ្រាមកាន់តែអាក្រក់ហួសប្រមាណ និងកំណាចគួរឲ្យស្អប់ខ្ពើមជាអតិបរមា។ ពេលប្រទេសមួយប្រើអាវុធវិទ្យាសាស្ត្រ បែបគ្រឿងបរមាណូ ហើយប្រសិនបើគេមិនបានរិះគិតឲ្យបានច្បាស់អំពីគោលដៅ ដែលគេចង់បាញ់នោះទេ គេមុខជានឹងបង្កើតវិនាសកម្មយ៉ាងសម្បើម ហួសពីបំណងដ៏ត្រឹមត្រូវក្នុងការការពារប្រទេសខ្លួន។ លើសពីនេះទៅទៀត ប្រសិនបើ មនុស្សយើងប្រើគ្រឿងបរមាណូ ដែលមហាអំណាចប្រមូលទុកក្នុងឃ្លាំងរបស់គេហើយ មនុស្សជាតិមុខជានឹងត្រូវវិនាសអន្តរាយស្លាប់ស្ទើរតែទាំងអស់ គូរបដិបក្ខនឹងត្រូវបំផ្លាញគ្នាទៅវិញទៅមក ឲ្យវិនាសអស់គ្មានសល់ ហើយពិភពលោកក៏ត្រូវខូចខាតជាទម្ងន់ដែរ។

ខ- សេចក្ដីទាំងនេះ បង្ខំយើងឲ្យរិះគិតតាមរបៀបថ្មីទាំងស្រុងអំពីសង្គ្រាម។ សូមឲ្យមនុស្សនាបច្ចុប្បន្នកាលដឹងថា ខ្លួនត្រូវទទួលទោសដោយបានបង្កើតសង្គ្រាមបែបនោះ។ អនាគតពិភពលោកអាស្រ័យលើសេចក្ដីដែលគេសម្រេចសព្វថ្ងៃ។

គ- ក្នុងសភាពការណ៍នោះ មហាសន្និបាតយល់ស្របតាមពាក្យរបស់អភិបាលនានា នៃព្រះសហគមន៍ក្រុងរ៉ូមកាលពីមុនៗនេះ ដែលដាក់ទោសសង្គ្រាមសកលដូចតទៅថា៖

ឃ-ចម្បាំងតម្រង់ទៅបំផ្លាញក្រុងទាំងមូល និងតំបន់ដ៏ធំធេង ព្រមទាំងបំផ្លាញមនុស្សដែលរស់នៅក្នុងកន្លែង

ទាំងនោះ ដោយមិនយោគយល់ ចម្បាំងនេះពិតជាអំពើឧក្រិដ្ឋទាស់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងប្រឆាំងមនុស្សជាតិដែរ។ ត្រូវតែដាក់ទោសអំពើទាំងនោះយ៉ាងម៉ឺងម៉ាត់ដោយមិនរួញរាឡើយ។

ង- សង្គ្រាមទំនើបអាចបង្កើតគ្រោះកាចដ៏សាហាវបំផុត ព្រោះសង្គ្រាមបែបនោះ ហុចឱកាសឲ្យអស់អ្នកដែលមានអាវុធវិទ្យាសាស្ត្រទំនើបជាងគេ ប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះបាន។ សង្គ្រាមនេះ ក៏អាចបណ្តាលឲ្យគូបដិបក្ខប្រព្រឹត្តអំពើឧក្រិដ្ឋតៗគ្នាជៀសមិនផុត នឹងជំរុញឲ្យមនុស្សសម្រេចធ្វើអំពើអាក្រក់បំផុត ហួសពីការស្មាន។ អភិបាលព្រះសហគមន៍ក្នុងពិភពលោកទាំងមូល ដែលប្រជុំគ្នាជាធ្លុងតែមួយ សូមអង្វរមនុស្សទាំងអស់ ជាពិសេសទទូចអង្វរប្រមុខរដ្ឋ និងអ្នកកាន់អំណាចលើកងទ័ព សូមថ្លឹងថ្លែងការខុស និងត្រូវជានិច្ច នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និងចំពោះមនុស្សជាតិទាំងមូល កុំឲ្យមហន្តរាយកើតឡើង ជាដាច់ខាត។

## ៨១. ការប្រណាំងចង់បានអាវុធកាន់តែច្រើនឡើងៗ

ក- តាមពិត មេដឹកនាំប្រទេសមិនបានប្រមូលទុកអាវុធវិទ្យាសាស្ត្រក្នុងគោលបំណង ប្រើប្រាស់នៅពេលកើតសង្គ្រាមប៉ុណ្ណោះទេតែអស់លោកយល់ថា កម្លាំងការពារប្រទេសរបស់គេ អាស្រ័យលើការសងសឹកយ៉ាងឆាប់រហ័សបំផុត។ ហេតុនេះ គេប្រមូលទុកអាវុធទាំងនោះកាន់តែច្រើនឡើងៗជារៀងរាល់ឆ្នាំមកបំភ័យសត្រូវហើយឃាត់សត្រូវមិនឲ្យបង្កើតសង្គ្រាម។ មានមនុស្សជាច្រើនយល់ឃើញថា ការប្រមូលទុកអាវុធបែបនោះ ពិតជាមធ្យោបាយដ៏មានប្រសិទ្ធភាពធានាសន្តិភាពម៉្យាងនៅលើពិភពលោក។

ខ- មានប្រទេសជាច្រើន ប្រណាំងប្រជែងចង់បានអាវុធកាន់តែច្រើនឡើងៗជាលំដាប់។ ទោះជាយើងគិតអំពីវិធីឃាត់សង្គ្រាមតាមបែបនេះយ៉ាងណាក្តី ក៏ត្រូវដឹងយ៉ាងជាក់ច្បាស់ថា ការប្រណាំងប្រជែងនោះបង្កើត «តុល្យភាពនៃការភ័យ» ដែលមិនមែនជាមាគ៌ាកសាងសន្តិភាពយ៉ាងស្ថិតស្ថេរ និងយ៉ាងពិតប្រាកដទេ។ ការប្រណាំងប្រជែងនោះ មិនបំបាត់មូលហេតុបណ្តាលឲ្យកើតសង្គ្រាមទេ ផ្ទុយទៅវិញ វាអាចបណ្តាលឲ្យមូលហេតុទាំងនោះ កាន់តែធ្ងន់ធ្ងរទៅៗ។ ប្រទេសចាយវាយធនធានរបស់ខ្លួនយ៉ាងសម្បើម មកបង្កើតអាវុធថ្មីៗ ប៉ុន្តែ គេមិនអាចជួយអ្នករងទុក្ខក្នុងពិភពលោកទាំងមូល ឲ្យបានរស់នៅសមរម្យទេ។ សភាពការណ៍នេះ មិនធ្វើឲ្យប្រទេសនឹងប្រទេសលែងទាស់ទែងគ្នា សូម្បីតែបន្តិចសោះ ព្រោះការប្រណាំងប្រជែង ចង់បានអាវុធកាន់តែច្រើនឡើង មិនព្យាបាលឫសនៃការទាស់ទែងនោះទេ។ ផ្ទុយទៅវិញ សភាពការណ៍នេះ បណ្តាលឲ្យការទាស់ទែងរាលដាលដល់តំបន់ផ្សេងៗទៀតក្នុងពិភពលោក។ ហេតុនេះ ត្រូវជ្រើសរើសមាគ៌ាថ្មី គឺត្រូវចាប់ផ្តើមពីការកែទម្រង់ចិត្តគំនិតមនុស្ស ដើម្បីបញ្ឈប់ការណ៍ដ៏អាក្រក់នេះ ហើយរំដោះមនុស្សលោក ឲ្យបានរួចពីការតប់ប្រមល់ ដែលសង្កត់សង្កិនគេ។ ធ្វើដូច្នេះ ទើបសន្តិភាពដ៏ពិតប្រាកដ កើតមកក្នុងពិភពលោកមួលបាន។

គ- ហេតុនេះហើយ បានជាយើងសូមប្រកាសម្តងទៀតថា ការប្រណាំងប្រជែងចង់បានអាវុធកាន់តែច្រើនឡើងពិតជាមុខរបួសយ៉ាងធ្ងន់ធ្ងរបំផុតរបស់មនុស្សជាតិ និងបណ្តាលឲ្យមានអយុត្តិធម៌ហួសហេតុ ដល់អ្នកក្រីក្រទ្រាំមិនបាន។ ប្រសិនបើ នៅតែមានការប្រណាំងប្រជែង ចង់បានអាវុធតទៅមុខទៀត ការណ៍នោះ មុខជានឹងបណ្តាលឲ្យកើតមហាវិនាសកម្មជាពុំខាន។

ឃ-យើងស្គាល់អន្តរាយ ដែលមនុស្សជាតិបានបង្កើតហើយនោះ។ ដូច្នេះ យើងដឹងខ្លួនកាន់តែច្បាស់អំពីការទទួលខុសត្រូវរបស់ខ្លួនម្នាក់ៗផ្ទាល់ ហើយនាំគ្នាប្រើរយៈពេល ដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យនេះ ដើម្បីស្វែងរកវិធីផ្សេងៗ ដែលជួយយើងឲ្យដោះស្រាយទំនាស់ តាមរបៀបសមរម្យស្របតាមលក្ខណៈរបស់ខ្លួនជាមនុស្ស។ ព្រះជាម្ចាស់ដែលថែរក្សាការពារមនុស្សលោក ទាមទារយ៉ាងខ្លាំង ឲ្យយើងរំដោះខ្លួនឲ្យរួចពីធ្វើជាទាសករនៃសង្គ្រាម ដែលមានតាំងពីដើមរៀងមក។ ប្រសិនបើ យើងមិនព្រមខិតខំបែបនេះទេ យើងមិនដឹងថា មាគ៌ាដ៏អាក្រក់ដែលយើងដើរសព្វថ្ងៃ នាំយើងឲ្យវិនាសដល់ណាទេ។

## ៨២. ត្រូវហាមកុំឲ្យកើតសង្គ្រាមជាដាច់ខាត

ក- យើងដឹងច្បាស់ថា យើងត្រូវខិតខំអស់ពីសមត្ថភាព ប្រមូលកម្លាំងទាំងអស់ ដើម្បីរៀបចំពេលដែលប្រជាជាតិទាំងអស់ព្រមព្រៀងគ្នា ហាមមិនឲ្យកើតសង្គ្រាមទៀតទេ។ ដើម្បីបំបាត់សង្គ្រាមនោះ ត្រូវបង្កើតអំណាចសាធារណៈសកលមួយ ដែលមនុស្សទាំងអស់ទទួលស្គាល់។ អំណាចនោះ ត្រូវមានកងកម្លាំងប្រកបដោយប្រសិទ្ធភាព អាចធានាសន្តិសុខដល់មនុស្សទាំងអស់ អាចគោរពយុត្តិធម៌ និងធានាការពារសិទ្ធិមនុស្ស។ ក៏ប៉ុន្តែ មុនអំណាចដែលយើងប្រាថ្នាឲ្យកើតនោះ ត្រូវឲ្យស្ថាប័នអន្តជាតិដ៏ខ្ពង់ខ្ពស់បំផុតដែលមានសព្វថ្ងៃ យកចិត្តទុកដាក់ដោយពេញទំហឹងសិក្សារកមធ្យោបាយ ដែលអាចផ្តល់សន្តិសុខរួម។ សន្តិភាពត្រូវតែកើតដោយប្រជាជាតិទុកចិត្តគ្នាទៅវិញទៅមក តែមិនមកដោយមានប្រទេសមួយបង្ក្រាបជាតិឯទៀតៗដោយប្រើអាវុធទេ។ ហេតុនេះ ប្រទេសទាំងអស់ត្រូវរួមសហការគ្នាបញ្ឈប់ការប្រណាំងប្រជែងចង់បានអាវុធ។ មិនត្រូវឲ្យមានប្រទេសតែមួយបន្ថយចំនួនអាវុធទេ តែត្រូវគ្រប់គ្នាបន្ថយចំនួនអាវុធនៅពេលជាមួយគ្នា តាមល្បឿនដូចគ្នា តាមការព្រមព្រៀង និងដោយមានការធានាការពារយ៉ាងពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព ទើបប្រទេសទាំងអស់អាចចាប់ផ្តើមបន្ថយចំនួនអាវុធបាន។

ខ- នៅពេលនេះ យើងត្រូវសរសើរមនុស្ស ដែលបានខិតខំបំបាត់សង្គ្រាម ហើយនៅតែកំពុងខិតខំបំបាត់សង្គ្រាមតទៅទៀតដែរ។ ត្រូវគាំទ្រឆន្ទៈល្អរបស់អ្នកដឹកនាំប្រទេសជាច្រើន ដែលទទួលខុសត្រូវជាទម្ងន់បំផុត និងខ្វល់ខ្វាយយ៉ាងខ្លាំង តាមបន្ទុកដ៏ខ្ពង់ខ្ពស់របស់ខ្លួន ដើម្បីបំបាត់សង្គ្រាម ដែលអស់លោកអ្នកស្អប់ខ្ពើម ទាំងមិនបំភ្លេចថា សភាពការណ៍នាសម័យបច្ចុប្បន្នស្មុគស្មាញណាស់។ ម៉្យាងទៀត យើងជាគ្រីស្តបរិស័ទ ត្រូវទទូចអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានឲ្យអស់លោកអ្នកមានកម្លាំងចិត្តចាប់ផ្តើម និងបន្តកសាងសន្តិភាពដោយចិត្តព្យាយាម។ កិច្ចដ៏សំខាន់នេះ ពិតជាហូរមកពីសេចក្តីស្រឡាញ់យ៉ាងទូលំទូលាយ ចំពោះមនុស្សលោក។ សព្វថ្ងៃ អស់លោកអ្នកត្រូវតែបើកប្រាជ្ញានិងចិត្ត ទៅគិតគូរដល់ប្រទេសដទៃក្រៅពីប្រទេសរបស់អស់លោកអ្នក សូមអស់លោកអ្នកលះបង់អត្តទត្ថបុគ្គលនិយមនៃជាតិរបស់ខ្លួន និងលះបង់បំណងប្រាថ្នាចង់ត្រួតត្រាប្រជាជាតិឯទៀតៗ។ សូមអស់លោកអ្នកគោរពយ៉ាងខ្លាំងបំផុតចំពោះមនុស្សជាតិទាំងមូល ដែលកំពុងតែធ្វើដំណើរឈានទៅឲ្យបានរួបរួមគ្នាកាន់តែជិតស្និទ្ធឡើងៗ។

គ- ក្នុងកិច្ចកសាងសន្តិភាព និងការដាក់អាវុធ ត្រូវនឹកគិតគូរដល់ការសិក្សាយ៉ាងជ្រៅដែលអ្នកស្រាវជ្រាវបានប្រព្រឹត្តរួចហើយ ដោយឥតឈប់ឈរ និងដោយចិត្តក្លាហាន។ ត្រូវគិតគូរដល់ការប្រជុំអន្តរជាតិនានា ដែលបានរិះគិតអំពីបញ្ហាទាំងនោះ។ ត្រូវចាត់ទុកថាការសិក្សាទាំងនោះ ជាជំហានដើមដំបូងក្នុងការរកដំណោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរទាំងនោះ។ ត្រូវតែបន្តការសិក្សានេះ យ៉ាងខ្លាំងជាងមុនទៅទៀត ទើបបានលទ្ធផល

គួរឲ្យប្រតិបត្តិតាម។ ក៏ប៉ុន្តែ ត្រូវប្រយ័ត្នកុំផ្ញើជីវិតលើមនុស្សតែមួយចំនួនតូចដែលខិតខំនោះ តែម្នាក់ៗ ត្រូវចាប់អារម្មណ៍នឹងសន្តិភាពដោយខ្លួនឯងផ្ទាល់។ ប្រមុខរដ្ឋតែងតែទទួលខុសត្រូវលើប្រយោជន៍រួម នៃប្រជាជាតិរបស់ខ្លួន ហើយនៅពេលជាមួយគ្នានោះ គេក៏លើកស្ទួយប្រយោជន៍រួមសកលដែរ។ តែប្រមុខរដ្ឋទាំងនោះ តែងតែប្រព្រឹត្តតាមមតិនិងតាមមនោសញ្ចេតនារបស់ប្រជាពលរដ្ឋរបស់គេ។ ហេតុនេះ ប្រសិនបើ ប្រជាពលរដ្ឋនៅតែបាក់បែកគ្នា និងទាស់ទែងដោយសារមនោគមវិជ្ជាផ្សេងៗ បើគេមិនទុកចិត្តគ្នា ហើយនៅតែប្រកាន់ពូជសាសន៍ និងចាត់ទុកគេជាសត្រូវនៅឡើយ អស់លោកអ្នកមិនអាចកសាងសន្តិភាពបានទេ។ ហេតុនេះ ត្រូវប្រែរបៀបអប់រំចិត្តគំនិតប្រជាជនឲ្យបានជាថ្មី និងប្រែមតិសាធារណៈជាចាំបាច់បំផុត។ សូមឲ្យអស់អ្នកដែលរួមសហការក្នុងកិច្ចអប់រំណាមួយ ជាពិសេសអ្នកអប់រំយុវជន ឬអ្នកបង្កើតមតិសាធារណៈសូមរាប់ថា គេមានមុខងារសំខាន់ជាងគេ គឺនាំមនោសញ្ចេតនាថ្មីដែលអាចបង្កើតសន្តិភាពចូលក្នុងចិត្តគំនិតមនុស្សទាំងអស់។ តាមពិតយើងទាំងអស់គ្នា ត្រូវប្រែចិត្តគំនិត និងចាប់អារម្មណ៍នឹងពិភពលោក។ យើងក៏ត្រូវខិតខំធ្វើកិច្ចការដែលយើងអាចប្រព្រឹត្តរួមគ្នាបាន ដើម្បីឲ្យមនុស្សជាតិចម្រើនឡើង។

ឃ-តែយើងមិនត្រូវបញ្ឆោតខ្លួនឯងដោយមានសេចក្តីសង្ឃឹមផ្តេសផ្តាសឡើយ។ ទោះបីយើងបំបាត់គំនុំគុំកួន និងការស្អប់គ្នាក្តី ទោះបី មនុស្សមានចំណេះយ៉ាងអស្ចារ្យគួរឲ្យសរសើរក្តី ប្រសិនបើយើងមិនចុះហត្ថលេខាលើការព្រមព្រៀងយ៉ាងរឹងប៉ឹង និងប្រកបដោយយុត្តិធម៌ ដែលធានាសន្តិភាពសកលនោះទេ មនុស្សជាតិដែលកំពុងប្រឈមមុខនឹងគ្រោះកាចយ៉ាងធ្ងន់ធ្ងរ មុខជាមិនស្គាល់សន្តិភាពណាផ្សេងពីសន្តិភាពដ៏អាក្រក់បំផុតបណ្តាលមកពីសេចក្តីស្លាប់។ ប៉ុន្តែ នៅពេលព្រះសហគមន៍របស់ព្រះគ្រីស្ត ចែករំលែកសេចក្តីតប់ប្រមល់របស់មនុស្សជាតិនាបច្ចុប្បន្នកាល និងប្រកាសសេចក្តីទាំងនេះ ក៏ព្រះសហគមន៍នៅតែមានសេចក្តីសង្ឃឹមយ៉ាងមាំមួនដែរ។ ព្រះសហគមន៍មានគោលបំណងចង់ប្រកាស ទោះត្រូវពេលវេលាក្តី ខុសពេលវេលាក្តី នូវសារដែលខ្លួនបានទទួលបន្តពីក្រុមគ្រីស្តទូត ឲ្យមនុស្សនាសម័យនេះដឹងគឺថា *"គ្រាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យគឺឥឡូវនេះហើយ!"* ជាគ្រាមនុស្សប្រែចិត្តគំនិត។ *"ឥឡូវនេះហើយ ជាថ្ងៃដែលព្រះជាម្ចាស់សង្គ្រោះមនុស្សលោក!"* (២ករ ៦, ២)។

# ជំពូកទី ២

## ការកសាងសហគមន៍អន្តរជាតិ

### ៨៣. មូលហេតុបណ្តាលឲ្យមនុស្សបាក់បែកគ្នា និងការព្យាបាល

បើយើងចង់កសាងសន្តិភាព ត្រូវបំបាត់មូលហេតុទាំងប៉ុន្មាន បណ្តាលឲ្យមនុស្សទាស់ទែងគ្នា មានអយុត្តិធម៌ជាដើម ដែលនាំឲ្យកើតសង្គ្រាម។ នេះជាលក្ខ័ណ្ឌសំខាន់ជាងគេ។ អយុត្តិធម៌ជាច្រើន បណ្តាលមកពីសភាពការណ៍សេដ្ឋកិច្ចមិនស្មើគ្នាហួសហេតុ និងមកពីការយឺតយ៉ាវពេក ក្នុងការកែប្រែសភាពការណ៍មិនស្មើគ្នាទាំងនោះ។ មានមូលហេតុផ្សេងៗទៀត គឺមកពីមនុស្សមានចិត្តទោសៈចង់ត្រួតត្រាគេ និងមកពីគេមើលងាយអ្នកដទៃ។ ប្រសិនបើ យើងរិះគិតដល់មូលហេតុ ឲ្យបានជ្រៅជាងទៅទៀត យើងមុខជានឹងឃើញថា មានចិត្តច្រណែនឈ្នានីស ការមិនទុកចិត្តគ្នាចិត្តក្រអឺតក្រទមនិងតណ្ហាឯទៀតៗ នាំឲ្យមនុស្សគិតតែពីខ្លួនឯង។ ដោយមនុស្សមិនអាចស៊ូទ្រាំនឹងអយុត្តិធម៌ច្រើនយ៉ាងនេះ ទោះបើមិនកើតសង្គ្រាមដ៏ឃោរឃៅក្តី ក៏មនុស្សលោកនៅតែជ្រួលច្របល់ជានិច្ច ដោយមានគេប្រកួតប្រជែងគ្នានិងប្រព្រឹត្តអំពើហិង្សាទៀតផង។ លើសពីនេះទៅទៀត សេចក្តីអាក្រក់ទាំងនេះ នៅតែមានក្នុងទំនាក់ទំនងជាតិ និងជាតិដែរ។ ហេតុនេះហើយ ស្ថាប័នអន្តរជាតិត្រូវពង្រីក និងពង្រឹងការសហការគ្នាឲ្យកាន់តែខ្លាំងឡើង។ ការនេះពិតជាចាំបាច់បំផុត។ ធ្វើដូច្នេះ ស្ថាប័នអន្តរជាតិមុខជានឹងបំបាត់សេចក្តីអាក្រក់ទាំងនោះ ឬជៀសវាងមិនឲ្យកើតឡើង ព្រមទាំងទប់ទល់ហិង្សាទៀតផង។ ហេតុនេះ សូមព្យាយាមដាស់តឿនឲ្យគេបង្កើតស្ថាប័នសម្រាប់លើកស្ទួយសន្តិភាព ដោយមិនណាយចិត្តឡើយ។

### ៨៤. សហគមអន្តរជាតិ និងស្ថាប័នអន្តរជាតិ

ក- នៅសម័យឥឡូវ ប្រជាពលរដ្ឋនិងប្រជាជនទាំងអស់នៅលើផែនដី មានចំណងទាក់ទងគ្នា គឺត្រូវការគ្នាទៅវិញទៅមកកាន់តែខ្លាំងឡើងៗ។ គេក៏ស្វែងរកប្រយោជន៍រួមយ៉ាងត្រឹមត្រូវនិងបង្កើតប្រយោជន៍រួមយ៉ាងសកម្មផងដែរ។ ហេតុការណ៍ទាំងនោះ ទាមទារឲ្យសហគមន៍ប្រជាជាតិនានា ចាត់ចែងគ្នាតាំងពីពេលឥឡូវនេះ តាមរបៀបរៀបរយស្របតាមបន្ទុកនាបច្ចុប្បន្ន។ យើងគិតជាពិសេសអំពីតំបន់ជាច្រើន ដែលរងគ្រោះដោយខ្វះខាតគ្មានស្បៀងអាហារបរិភោគ ជាគ្រោះកាចដែលទ្រាំមិនបាន។

ខ- ស្ថាប័នសហគមន៍អន្តរជាតិ ត្រូវផ្គត់ផ្គង់តាមចំណែករៀងៗខ្លួន នូវសេចក្តីត្រូវការនានារបស់មនុស្ស ក្នុងវិស័យសង្គមពោលគឺ ផ្គត់ផ្គង់ស្បៀងអាហារ សុខាភិបាល ការអប់រំ ការងារ។ល។ ស្ថាប័នសហគមន៍អន្តរជាតិក៏ត្រូវមានសមត្ថភាពអាចប្រឈមមុខនឹងហេតុការណ៍ផ្សេងៗ ដែលកើតក្នុងតំបន់ខ្លះ ឧបមាថាជួយប្រទេសកំពុងអភិវឌ្ឍន៍ឲ្យចម្រើនឡើង ជួយសម្រាលទុក្ខជនភៀសខ្លួន ដែលខ្ចាត់ខ្ចាយក្នុងពិភពលោកទាំងមូល ឬផ្តល់ជំនួយដល់ជនអន្តោប្រវេសន៍និងក្រុមគ្រួសារគេផង។

គ- ស្ថាប័នអន្តរជាតិដែលសព្វថ្ងៃមានរួចហើយ ទាំងស្ថាប័នអន្តរជាតិ ស្ថាប័នតាមតំបន់ មានគុណជាច្រើនដល់មនុស្សជាតិមែន។ ស្ថាប័នទាំងនោះហាក់ដូចជាការព្រាងទុកដើមដំបូងអំពីគ្រឹះអន្តរជាតិ សម្រាប់សាងសង់សហគមន៍មនុស្សជាតិទាំងមូល ដើម្បីដោះស្រាយបញ្ហាសំខាន់ៗនាសម័យឥឡូវ ពោលគឺ លើកស្ទួយការចម្រើនឡើងនៅគ្រប់តំបន់នៃផែនដី និងជៀសវាងមិនឲ្យកើតសង្គ្រាមគ្រប់យ៉ាង។ ព្រះសហគមន៍មានអំណរសប្បាយដោយឃើញថា ក្នុងគ្រប់វិស័យ គ្រីស្តបរិស័ទនិងអ្នកដែលមិនកាន់គ្រីស្តសាសនា មានចិត្តគំនិតចាត់អ្នកដទៃទុកជាបងប្អូនយ៉ាងពិតប្រាកដកាន់តែខ្លាំងឡើងៗ។ គេក៏នៅតែខិតខំសម្រាលទុក្ខដ៏ធំធេងរបស់មនុស្សលោកកាន់តែខ្លាំងឡើងៗទៀតដែរ។

## ៨៥. សហគមន៍អន្តរជាតិរួមសហការក្នុងវិស័យសេដ្ឋកិច្ច

ក- មនុស្សជាតិនាបច្ចុប្បន្នរួមសាមគ្គីគ្នា។ ហេតុនេះ គ្រប់ប្រទេសត្រូវរួមសហការគ្នាក្នុងវិស័យសេដ្ឋកិច្ច ឲ្យកាន់តែជិតស្និទ្ធឡើងៗ។ ទោះបីប្រជាជនស្ទើរតែទាំងអស់ បានឯករាជ្យខាងនយោបាយក្តី ក៏ប្រជាជនទាំងនោះមិនទាន់បានរួចផុតពីភាពមិនស្មើគ្នានៅឡើយទេ ហើយក៏នៅតែជាចំណុះប្រទេសដទៃហួសហេតុគ្រប់យ៉ាងដែរ។ គេក៏មិនទាន់រួចពីគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនៅផ្ទៃក្នុងរបស់គេនៅឡើយដែរ។

ខ- ប្រទេសមួយអាចចម្រើនឡើងបាន អាស្រ័យតែលើធនធានមនុស្ស និងហិរញ្ញវត្ថុរបស់ខ្លួនដែរ។ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវតែរៀបចំប្រជាពលរដ្ឋនៃប្រជាជាតិនីមួយៗ ឲ្យមានសមត្ថភាព អាចបំពេញគ្រប់បន្ទុកខាងសេដ្ឋកិច្ច និងខាងសង្គមបាន។ ហេតុនេះ ត្រូវការអ្នកជំនាញការអន្តរជាតិមកជួយ។ ប៉ុន្តែ អស់អ្នកជំនាញការដែលមកជួយនោះ មិនត្រូវមានឥរិយាបទធ្វើដូចជាម្ចាស់ត្រួតត្រាគេទេ តែទុកជាអ្នកជំនួយ និងជាសហការីវិញ។ ចំពោះជំនួយជាសម្ភារៈដល់ប្រជាជាតិកំពុងអភិវឌ្ឍន៍វិញ ជំនួយទាំងនោះមុខជានឹងបណ្តាលឲ្យទម្លាប់ខាងពាណិជ្ជកម្ម នាសម័យឥឡូវប្រែប្រួលយ៉ាងខ្លាំង។ ប្រជាជាតិដែលមានសេដ្ឋកិច្ចជឿនលឿន ត្រូវជួយគេតាមរបៀបផ្សេងទៀត ដូចជាផ្តល់អំណោយ កម្ចី ឬផ្តល់វិនិយោគជាប្រាក់។ ប្រជាជាតិទាំងនោះ ត្រូវជួយបម្រើដោយចិត្តទូលំទូលាយ និងដោយចិត្តទៀងត្រង់ រីឯប្រទេសដែលទទួលជំនួយវិញមិនត្រូវមានចិត្តលោភលន់ឡើយ។

គ- ប្រសិនបើសហគមន៍អន្តរជាតិចង់កសាងរបៀបរៀបរយដ៏ពិតប្រាកដ ខាងសេដ្ឋកិច្ចក្នុងពិភពលោក ត្រូវបញ្ឈប់ចិត្តលោភលន់ចង់បានកម្រៃហួសហេតុ ត្រូវបញ្ឈប់ចិត្តទោសៈចង់ត្រួតត្រាប្រទេសដទៃ ខាងនយោបាយ ត្រូវបញ្ឈប់យុទ្ធសាស្ត្រយោធា ព្រមទាំងត្រូវបញ្ឈប់កលល្បិចដែលមានគោលដៅផ្សព្វផ្សាយមនោគមវិជ្ជាមួយ ឬបង្ខំឲ្យគេយកមនោគមវិជ្ជានោះ។ ទោះបីមានប្រព័ន្ធសេដ្ឋកិច្ចនិងសង្គមជាច្រើនប្លែកៗពីគ្នាក្តី ក៏ត្រូវឲ្យមនុស្សមានសមត្ថភាព អាចរកគ្រឹះរួមសម្រាប់បង្កើតពាណិជ្ជកម្មសកលដែរ។ ប្រសិនបើម្នាក់ៗ លះបង់គំនិតដែលគេបានគិតទុកជាមុន ហើយសុខចិត្តសន្ទនាដោយចិត្តស្មោះដោយមិនយឺតយ៉ាវ ទើបគេអាចរកឃើញគ្រឹះនេះបាន។

## ៨៦. គោលការណ៍ខ្លះដែលអាចជួយណែនាំបាន

ក- យើងយល់ឃើញ គួរអនុវត្តតាមគោលការណ៍ដើម្បីសហការគ្នា ដូចតទៅ ៖

ខ. ប្រជាជាតិកំពុងអភិវឌ្ឍន៍ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងថា គោលដៅនៃការអភិវឌ្ឍន៍មានតែមួយគត់ គឺនាំ

ឲ្យប្រជាពលរដ្ឋរីកចម្រើនយ៉ាងពេញលេញ ក្នុងឋានៈគេជាមនុស្ស។ ប្រជាជាតិទាំងនោះ ត្រូវតែបញ្ជាក់គោលដៅនេះយ៉ាងច្បាស់ ដោយមិនអាចភាន់ច្រឡំបានឡើយ។ ប្រជាជាតិទាំងនោះ ត្រូវនឹកចងចាំថា មានតែកិច្ចការដែលប្រជាជនធ្វើ និងការប៉ិនប្រសប់របស់គេទេ ដែលបណ្ដោយឲ្យប្រជាជាតិរបស់ខ្លួនអាចចម្រើនឡើងបាន និងឲ្យការចម្រើននេះមានកម្លាំងរស់រវើក។ ការអភិវឌ្ឍន៍នោះ មិនសំអាងតែលើជំនួយបរទេសតែប៉ុណ្ណោះទេ តែត្រូវប្រើប្រាស់ធនធានរបស់ប្រទេសយ៉ាងពេញលេញវិញ ត្រូវសំអាងលើវប្បធម៌ និងលើប្រពៃណីរបស់ខ្លួនផ្ទាល់ ទើបចម្រើនឡើងតាមសម្រួលបាន។ ក្នុងករណីនេះ អស់អ្នកដែលមានឥទ្ធិពលខ្លាំងជាងគេ លើអ្នកដទៃត្រូវធ្វើជាគំរូឲ្យគេ។

គ- ប្រជាជាតិដែលមានសេដ្ឋកិច្ចជឿនលឿន មានភារកិច្ចយ៉ាងធំបំផុត គឺជួយប្រជាជាតិកំពុងអភិវឌ្ឍន៍ឲ្យបំពេញបន្ទុកទាំងនោះយ៉ាងស្រួល។ សូមឲ្យប្រជាជាតិដែលមានសេដ្ឋកិច្ចជឿនលឿន រិះគិតនិងប្រែចិត្តគំនិតរបស់គេ គឺប្រែទាំងខាងវិញ្ញាណ ទាំងខាងសម្ភារៈ ដើម្បីឲ្យគេអាចសហការជាសកលបាន។

ឃ-ហេតុនេះហើយ បានជានៅពេលប្រជាជាតិដែលមានសេដ្ឋកិច្ចជឿនលឿនចចារជាមួយប្រជាជាតិដែលមានសេដ្ឋកិច្ចទន់ខ្សោយនិងប្រជាជាតិក្រជាងគេ ត្រូវយល់ដល់ផលប្រយោជន៍របស់គេនោះផង ដ្បិតពេលប្រជាជាតិក្រីក្រលក់ផលិតផលរបស់ខ្លួនគេទទួលផលដែលគេត្រូវការជាចាំបាច់សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួន។

ង- សហគមន៍អន្តរជាតិ មានតួនាទីសម្របសម្រួល និងលើកស្ទួយការអភិវឌ្ឍន៍ ដោយយកចិត្តទុកដាក់ចែកចាយធនធាន ដែលគេគ្រោងទុកដោយប្រសិទ្ធភាព និងយ៉ាងត្រឹមត្រូវជាអតិបរមា។ ប៉ុន្តែ ត្រូវគិតដល់គោលការណ៍ *"ទុកអំណាចបន្ទាប់បន្សំ"* គឺទុកឲ្យប្រជាជាតិកំពុងតែអភិវឌ្ឍន៍ទាំងនោះ ទទួលខុសត្រូវខ្លួនឯង គឺសហគមន៍អន្តរជាតិមានតួនាទីចាត់ចែងទំនាក់ទំនង ខាងសេដ្ឋកិច្ចក្នុងពិភពលោកទាំងមូល ឲ្យមានរបៀបរៀបរយ ដើម្បីចែកចាយជំនួយតាមក្បួនយុត្តិធម៌។

ច- សូមតែងតាំងស្ថាប័ន ដែលមានសមត្ថភាពលើកស្ទួយ និងណែនាំពាណិជ្ជកម្មអន្តរជាតិ ជាពិសេសពាណិជ្ជកម្ម ជាមួយប្រជាជាតិដែលមានសេដ្ឋកិច្ចទន់ខ្សោយជាងគេ។ ស្ថាប័នទាំងនោះ អាចកែសម្រួលផលអាក្រក់ ដែលបណ្ដាលមកពីភាពមិនស្មើគ្នាហួសហេតុនៃប្រជាជាតិនានា។ ការកែសម្រួលនេះ និងជំនួយខាងបច្ចេកទេស ជំនួយខាងវប្បធម៌ និងជំនួយខាងហិរញ្ញវត្ថុ មុខជានឹងផ្ដល់ឲ្យប្រជាជាតិ កំពុងអភិវឌ្ឍន៍ទាំងនោះ មានមធ្យាយោបាយ ដើម្បីបន្តការខិតខំរបស់ខ្លួន និងនាំឲ្យសេដ្ឋកិច្ចរបស់គេចម្រើនឡើងតាមសម្រួល។

ឆ- ក្នុងករណីជាច្រើន ត្រូវប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមទាំងស្រុងជាបន្ទាន់។ ប៉ុន្តែត្រូវប្រយ័ត្ន កុំយកដំណោះស្រាយមិនទាន់ស្ទាត់ជំនាញខាងបច្ចេកទេស ជាពិសេសកុំយកដំណោះស្រាយ ដែលផ្ដល់អត្ថប្រយោជន៍តែខាងសម្ភារៈប៉ុណ្ណោះទេ។ ការអភិវឌ្ឍន៍មិនត្រូវទាស់នឹងលក្ខណៈរបស់មនុស្សខាងផ្លូវវិញ្ញាណ ហើយក៏មិនត្រូវទាស់នឹងការចម្រើនដ៏ពេញលេញរបស់ខ្លួនដ្បិត *"មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញមកពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ"* (មថ ៤,៤)។ មនុស្សម្នាក់ៗ មានចំណែកមួយនៃទ្រព្យសម្បត្តិដ៏ថ្លៃថ្នូរកប់ទុកក្នុងខ្លួន និងក្នុងប្រពៃណីដ៏ប្រសើរ

របស់គេ ដែលព្រះជាម្ចាស់បានផ្ញើទុកដល់មនុស្សជាតិ ទោះបី មានគ្នាច្រើនមិនស្គាល់ប្រភពនៃកំណប់ដ៏ថ្លៃថ្នូរនេះក្តី។

## ៨៧- ការសហការអន្តរជាតិ និងកំណើននៃចំនួនមនុស្ស

ក- មានប្រជាជាតិមួយចំនួន ត្រូវការរួមសហការអន្តរជាតិជាចាំបាច់បំផុតអាក់ខានមិនបាន។ ក្នុងចំណោមបញ្ហាជាច្រើន។ ប្រជាជាតិទាំងនោះ ត្រូវប្រឈមមុខនឹងបញ្ហាសំខាន់ជាងគេ គឺចំនួនប្រជាជនកើនឡើងយ៉ាងឆាប់រហ័ស។ ហេតុនេះ ត្រូវស្វែងរកមធ្យោបាយ ជួយរៀបចំអ្វីៗដែលគេត្រូវការ ដើម្បីឲ្យមនុស្សទាំងអស់មានស្បៀងអាហារបរិភោគគ្រប់គ្រាន់ ឲ្យគេមានការសិក្សាសមរម្យ ដើម្បីជាប្រយោជន៍ដល់សហគមន៍មនុស្សលោកទាំងមូល។ មនុស្សទាំងអស់ ជាពិសេសប្រជាជាតិដែលសម្បូរណ៍ដោយទ្រព្យសម្បត្តិ ត្រូវរួមសហការយ៉ាងពេញលេញ និងយ៉ាងព្យាយាមជួយឧបត្ថមគេ។ ប្រសិនបើប្រជាជាតិមួយចំនួនធំទទួលការបង្រៀនយ៉ាងសមរម្យ គេអាចធ្វើឲ្យជីវភាពប្រជាជនរបស់ខ្លួនចម្រើនឡើងបានយ៉ាងខ្លាំង គឺគេមុខជានឹងឆ្លងកាត់ពីកសិកម្មបុរាណ មកប្រើបច្ចេកទេសទំនើប ដោយប្រុងប្រយ័ត្នតាមតម្រូវការ និងស្របតាមសភាពការណ៍របស់គេ។ គេក៏ត្រូវចែករំលែកដីធ្លីឲ្យប្រជាជនប្រើប្រាស់តាមយុត្តិធម៌ ទើបកើតរបៀបរៀបរយល្អក្នុងសង្គម។

ខ- ចំពោះបញ្ហាចំនួនប្រជាជនក្នុងប្រជាជាតិនីមួយៗ រដ្ឋាភិបាលនានា ពិតជាមានសិទ្ធិនិងភារកិច្ច តាមព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន ឧបមាថា រដ្ឋាភិបាលមានសិទ្ធិ និងភារកិច្ចតែងច្បាប់អំពីសង្គម និងអំពីក្រុមគ្រួសារ អំពីប្រជាជនស្រុកស្រែចម្ការដែលមករស់នៅក្នុងទីក្រុង អំពីពត៌មានស្តីអំពីសភាពការណ៍ និងអំពីតម្រូវការនៃប្រទេស។ សព្វថ្ងៃមានមនុស្សជាច្រើនយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីបញ្ហានេះ។ ហេតុនេះ មហាសន្និបាតប្រាថ្នាចង់ឲ្យមានគ្រីស្តបរិស័ទកាតូលិក ដែលមានសមត្ថភាពក្នុងវិស័យទាំងនោះ ជាពិសេសក្នុងសកលវិទ្យាល័យ បន្តការស្រាវជ្រាវដែលមនុស្សផ្សេងៗ ចាប់ផ្តើមសិក្សាឲ្យកាន់តែទូលំទូលាយឡើង។

គ- មានមនុស្សជាច្រើនតែងតែប្រកាសថា ត្រូវបន្ថយកំណើននៃចំនួនមនុស្សនៅលើផែនដី ជាដាច់ខាតយ៉ាងហោចណាស់ សូមបន្ថយចំនួនកំណើតកូនក្នុងប្រទេសមួយចំនួន ដោយប្រើគ្រប់មធ្យោបាយ ហើយរដ្ឋអំណាចត្រូវបញ្ចេញក្រឹត្យក្រមគ្រប់យ៉ាង ដើម្បីបន្ថយចំនួនមនុស្ស។ មហាសន្និបាតសូមក្រើនរំឭកដាស់តឿនមនុស្សទាំងអស់ថា កុំប្រើវិធីផ្ទុយនឹងវិន័យនៃសីលធម៌ ទោះបីគេទូន្មានឲ្យប្រើវិធីទាំងនោះ ជាសាធារណៈក្តី ឬជាឯកជនក្តី ឬទោះជាគេបង្ខំឲ្យប្រើក៏ដោយ។ មនុស្សមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបន្តពូជ ជាសិទ្ធិដែលគ្មាននរណាអាចដកហូតបានជាដាច់ខាត។ ហេតុនេះ មានតែគូស្វាមីភរិយាទេ ដែលអាចសម្រេចអំពីចំនួនកូនរបស់ខ្លួនបាន ក្រោយពីបានរិះគិតថ្លឹងថ្លែងយ៉ាងត្រឹមត្រូវ។ រដ្ឋអំណាចគ្មានសិទ្ធិសម្រេចជំនួសគេបានសោះ។ ឪពុកម្តាយត្រូវសម្រេចដោយមានមនសិការអប់រំយ៉ាងល្អ។ ហេតុនេះ ត្រូវជួយមនុស្សទាំងអស់ ឲ្យមានសមត្ថភាពអាចទទួលខុសត្រូវ ស្របតាមសីលធម៌និងស្របតាមលក្ខណៈរបស់ខ្លួនជាមនុស្ស ដោយគិតគូរដល់ធម្មវិន័យរបស់ព្រះជាម្ចាស់ និងដោយមិនបំភ្លេចដល់សភាពការណ៍ទាំងប៉ុន្មាននៃការរស់នៅដែរ។ ដូច្នេះ ត្រូវប្រើគរុកោសល្យអប់រំឲ្យកាន់តែប្រសើរឡើង និងធ្វើឲ្យសភាពការណ៍ក្នុងសង្គមចម្រើនឡើងផងដែរ។ ជាបឋម ត្រូវផ្តល់ឱកាសឲ្យប្រជាជន អាចទទួលការអប់រំខាងសាសនា ឬយ៉ាងហោចណាស់ឲ្យទទួលការអប់រំខាងសីលធម៌ ដែលមានគុណភាពល្អ។ ម្យ៉ាងទៀត

ត្រូវផ្ដល់ព័ត៌មានសមរម្យដល់ប្រជាជនឲ្យបានដឹងអំពីការចម្រើននៃវិទ្យាសាស្ត្រ ក្នុងការស្វែងរកវិធី ដែលអាចជួយគូស្វាមីភរិយាក្នុងការពន្យារកំណើតកូន។ គេអាចប្រើវិធីទាំងនោះបាន លុះត្រាតែវិធីទាំងនោះមានតម្លៃយ៉ាងច្បាស់ និងពិតជាស្រុបតាមសីលធម៌។

## ៨៨. តួនាទីរបស់គ្រីស្តបរិស័ទក្នុងជំនួយអន្តរជាតិ

ក- គ្រីស្តបរិស័ទត្រូវសុខចិត្តរួមសហការដោយចិត្តស្មោះ និងដោយចិត្តទូលាយ ក្នុងការកសាងរបៀបរៀបរយអន្តរជាតិ។ ត្រូវកសាងរបៀបរៀបរយនេះដោយគោរពយ៉ាងស្មោះ ចំពោះសេរីភាពដ៏ត្រឹមត្រូវ និងដោយស្រឡាញ់មនុស្សទាំងអស់ទុកជាបងប្អូន។ គ្រីស្តបរិស័ទ រឹតតែស្ម័គ្រចិត្ត ជួយកសាងរបៀបរៀបរយនេះដោយដឹងថា មនុស្សភាគច្រើននៅក្នុងលោកនេះ ស្ថិតនៅក្នុងភាពក្រីក្រតោកយ៉ាក ហើយតាមរយៈអ្នកក្រីក្រទាំងនោះ ព្រះគ្រីស្តទាមទារយ៉ាងខ្លាំង ឲ្យក្រុមសាវ័កព្រះអង្គមានចិត្តមេត្តាករុណា។ សូមបំបាត់សភាពការ ដែលទាស់ភ្នែកនេះដែលមានដូចតទៅ គឺថា មានប្រជាជាតិខ្លះដែលប្រជាពលរដ្ឋភាគច្រើនជាគ្រីស្តបរិស័ទ មានទ្រព្យសម្បត្តិហូរហៀរតែនៅពេលជាមួយគ្នានោះ មានប្រជាជាតិខ្លះខ្វះខាត គ្មានអ្វីៗដែលគេត្រូវការសម្រាប់ទប់ទល់ជីវភាព គេរងគ្រោះដោយទុរ្ភិក្ស គ្មានអាហារបរិភោគ មានជំងឺរាតត្បាត និងកើតទុក្ខលំបាកគ្រប់បែបយ៉ាង។គំនិតរបស់អ្នកដែលចង់ដាក់ខ្លួនជាអ្នកក្រីក្រ និងមានសេចក្ដីស្រឡាញ់ពិតជាសិរីរុងរឿង និងជាសញ្ញាសម្គាល់នៃព្រះសហគមន៍របស់ព្រះគ្រីស្ត។

ខ- ហេតុនេះ ត្រូវលើកតម្កើង និងលើកទឹកចិត្តគ្រីស្តបរិស័ទទាំងប៉ុន្មាន ជាពិសេសយុវជន ដែលស្ម័គ្រចិត្តថ្វាយខ្លួនជួយបម្រើមនុស្សឯទៀតៗ និងប្រជាជនផ្សេងៗ។ លើសពីនេះទៅទៀត ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល មានតួនាទីសម្រាលទុក្ខមនុស្សសម័យឥឡូវ តាមសមត្ថភាពរៀងៗខ្លួន ដោយមានអភិបាលព្រះសហគមន៍លើកទឹកចិត្តគេ ទាំងមានប្រសាសន៍និងធ្វើគំរូផងដែរ។ គេមិនគ្រាន់តែយកអ្វីដែលនៅសេសសល់មកចែកដល់អ្នកក្រីក្រប៉ុណ្ណោះទេ តែគេយកអ្វីៗដែលខ្លួនត្រូវការជាចាំបាច់សម្រាប់ចិញ្ចឹមជីវិតមកចែកឲ្យគេវិញ ដូចព្រះសហគមន៍ពីដើមធ្លាប់ធ្វើ។

គ- ត្រូវចាត់ចែងការប្រមូលធនធានឲ្យមានរបៀបរៀបរយ តាមភូមិភាគ តាមប្រជាជាតិនានា និងនៅតាមសកលលោកទាំងមូល ទោះបីរបៀបប្រមូលប្រាក់និងចែកជំនួយមិនដូចគ្នានៅគ្រប់កន្លែងក្តី។ សូមគ្រីស្តបរិស័ទកាតូលិករួមសហការជាមួយបងប្អូនគ្រីស្តបរិស័ទនិកាយឯទៀតៗ នៅកន្លែងណាដែលគេឃើញថាគួរឲ្យធ្វើការរួមគ្នា។ សេចក្ដីស្រឡាញ់ទាមទារឲ្យអ្នកប្រព្រឹត្តកិច្ចការតាមសង្គម និងកិច្ចជួយដល់អ្នកដទៃគិតគូរដល់អនាគត និងធ្វើការដោយមានរបៀបរៀបរយ។ ហេតុនេះ អស់អ្នកដែលចង់បម្រើប្រជាជាតិដែលកំពុងអភិវឌ្ឍន៍ ត្រូវទទួលការអប់រំតាមរបៀបសមរម្យក្នុងគ្រឹះស្ថានឯកទេស មុនចេញទៅបម្រើអ្នកដទៃ។

## ៨៩. វត្តមានរបស់ព្រះសហគមន៍ក្នុងសហគមន៍អន្តរជាតិ

ក- ព្រះសហគមន៍ប្រកាសដំណឹងល្អឲ្យមនុស្សទាំងអស់ តាមបេសកកម្មដែលខ្លួនបានទទួល ពីព្រះជាម្ចាស់មក។ ពេលនោះ ព្រះសហគមន៍ចែករំលែកព្រះហឫទ័យប្រោសប្រណីដ៏ថ្លៃថ្នូររបស់ព្រះអង្គឲ្យគេ និងជួយពង្រឹងសន្តិភាព ហើយតែងតាំងគ្រឹះដ៏មាំមួន ជូនសហគមន៍មនុស្សលោកជាបងប្អូន គឺនាំឲ្យគេស្គាល់

ធម្មវិន័យរបស់ព្រះជាម្ចាស់ និងស្គាល់ធម្មវិន័យរបស់ធម្មជាតិដែរ។ ហេតុនេះ ព្រះសហគមន៍ត្រូវតែមានវត្តមានក្នុងសហគមន៍ប្រជាជាតិជាចាំបាច់ ដើម្បីលើកទឹកចិត្ត និងដាស់តឿនមនុស្សទាំងអស់ឲ្យរួមសហការគ្នា។ ព្រះសហគមន៍ត្រូវមានវត្តមានតាមស្ថាប័នជាផ្លូវការ និងដោយគ្រីស្តបរិស័ទទាំងអស់ រួមសហការដោយចិត្តស្មោះ។ គ្រីស្តបរិស័ទរួមសហការដូច្នេះ ដោយមានបំណងតែមួយ គឺជួយដល់ប្រយោជន៍មនុស្សទាំងអស់។

ខ- ប្រសិនបើគ្រីស្តបរិស័ទដឹងអំពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងឋានៈជាមនុស្សផង និងក្នុងឋានៈជាគ្រីស្តបរិស័ទផង គេមុខជានឹងនាំគ្នាដាស់តឿនមនុស្សនៅកន្លែងគេរស់នៅ ឲ្យមានបំណងរួមសហការជាមួយសហគមន៍អន្តជាតិ ដោយចិត្តទូលាយ។ ដូច្នេះ គេមុខជានឹងបានលទ្ធផលនោះពុំខាន។ ក្នុងករណីនេះ ត្រូវចាប់អារម្មណ៍យ៉ាងពិសេសនឹងការអប់រំយុវជន ទាំងខាងសង្គម ទាំងខាងសាសនា។

## ៩០. តួនាទីគ្រីស្តបរិស័ទក្នុងស្ថានប័នអន្តរជាតិ

ក- គ្រីស្តបរិស័ទទាំងបុគ្គលម្នាក់ៗក្តី ទាំងជាក្រុមក្តី ត្រូវជួយស្ថាប័ន ដែលមានគោលដៅពង្រីកការសហការអន្តរជាតិ ទោះបីស្ថាប័នទាំងនោះកើតរួចហើយក្តី ឬក៏ត្រូវបង្កើតនៅពេលអនាគតក្តី។ ការនេះពិតជាសកម្មភាពមួយដ៏ល្អប្រពៃរបស់គេ។ សមាគមកាតូលិកអន្តរជាតិនានាអាចជួយបម្រើជាច្រើនយ៉ាងក្នុងកិច្ចកសាងសហគមន៍សកលប្រកបដោយសន្តិភាពនិងដែលមានមនុស្សរាប់អានគ្នាទុកជាបងប្អូនថែមទៀត។ ត្រូវតែពង្រឹងសមាគមទាំងនោះ ដោយផ្តល់បុគ្គលិកច្រើនជាងពីមុនមកធ្វើការជាមួយ គឺបុគ្គលិក ដែលទទួលការអប់រំយ៉ាងល្អជាមុន។ ត្រូវតែពង្រឹងសមាគមទាំងនោះ ដោយបន្ថែមសម្ភារៈដែលគេត្រូវការ និងដោយសម្រួលកម្លាំងរបស់គេឲ្យរួមសហការគ្នា។ សព្វថ្ងៃ ត្រូវតែធ្វើកិច្ចការរួម ទើបសកម្មភាពនោះ មានប្រសិទ្ធភាព និងត្រូវតាមសេចក្តីដ៏ចាំបាច់នៃការសន្ទនាគ្នាដែរ។ ម៉្យាងទៀត សមាគមទាំងនោះជួយពង្រីកគំនិតមនុស្ស ឲ្យនាំគ្នាគិតដល់ប្រយោជន៍សកល ជាគំនិតដែលគ្រីស្តបរិស័ទកាតូលិកពេញចិត្ត។ សមាគមទាំងនោះ ក៏ជួយបង្កើតមនសិការសាមគ្គី និងឲ្យគេទទួលខុសត្រូវជាសកលដ៏ពិតប្រាកដ។

ខ- នៅទីបញ្ចប់ យើងប្រាថ្នាចង់ឲ្យគ្រីស្តបរិស័ទកាតូលិក ខិតខំរួមសហការយ៉ាងសកម្ម និងដែលមានប្រយោជន៍ ជាមួយបងប្អូនគ្រីស្តបរិស័ទនីកាយឯទៀតៗ ដែលប្រកាសអំពីសេចក្តីស្រឡាញ់ ស្របតាមដំណឹងល្អ។ គ្រីស្តបរិស័ទកាតូលិក ក៏ត្រូវរួមសហការជាមួយអស់អ្នកដែលស្វែងរកសន្តិភាពដ៏ពិតប្រាកដ។

គ- មហាសន្និបាតយល់ឃើញថា សព្វថ្ងៃមនុស្សជាតិភាគច្រើន កំពុងរងទុក្ខលំបាកសែនវេទនា។ មហាសន្និបាត មានបំណងជួយឲ្យយុត្តិធម៌កើតឡើង និងមានបំណងចង់ឲ្យមនុស្សទាំងអស់ មានសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ចំពោះអ្នកក្រីក្រនៅគ្រប់កន្លែង។ ហេតុនេះ មហាសន្និបាតយល់ឃើញថា គួរបង្កើតស្ថាប័នរបស់ព្រះសហគមន៍សកល ដែលមានគោលដៅដាស់តឿនសហគមន៍កាតូលិកឲ្យលើកស្ទួយការអភិវឌ្ឍន៍តំបន់ក្រីក្រ និងពង្រីកយុត្តិធម៌ក្នុងសង្គមនៃប្រជាជាតិនានា។

# ពាក្យបញ្ចប់

## ៩១. តួនាទីរបស់គ្រីស្តបរិស័ទម្នាក់ៗ និងរបស់ព្រះសហគមន៍តាមភូមិភាគ

ក- មហាសន្និបាតដ៏វិសុទ្ធ បានផ្តល់យោបល់ទាំងអស់ខាងលើនេះ យោងពីទ្រព្យសម្បត្តិដ៏ថ្លៃថ្នូរ នៃលទ្ធិព្រះសហគមន៍ ដើម្បីជួយមនុស្សនាសម័យឥឡូវ ទោះជាគេផ្ញើជីវិតលើព្រះជាម្ចាស់ក្តី ឬមិនទទួលស្គាល់ព្រះអង្គយ៉ាងច្បាស់ក្តី ឲ្យគេយល់ឃើញកាន់តែច្បាស់នូវអត្ថន័យយ៉ាងពេញលេញ នៃជីវិតរបស់ខ្លួន តាមព្រះជាម្ចាស់បានកំណត់ទុក។ មហាសន្និបាតក៏មានបំណងជួយឲ្យមនុស្សលោកនេះ កាន់តែមានលក្ខណៈដ៏ថ្លៃថ្នូរប្រសើរបំផុតជាមនុស្ស និងឲ្យយកចិត្តទុកដាក់កសាងសង្គមសកលជាបងប្អូន ដែលមានគ្រឹះយ៉ាងមាំមួន និងជ្រៅ។ មហាសន្និបាតក៏មានបំណងជួយឲ្យមនុស្សលោកនេះខិតខំរួមគ្នាតបឆ្លើយយ៉ាងទូលាយនឹងការស្រែកហៅយ៉ាងខ្លាំងជាងគេ របស់មនុស្សនៅនាសម័យយើងនេះ ក្រោមការណែនាំនៃសេចក្តីស្រឡាញ់។

ខ. តាមពិត មានសភាពការណ៍និងអរិយធម៌ប្លែកៗពីគ្នាជាច្រើន។ ដូច្នេះ សេចក្តីដែលយើងបានសរសេរនោះមានលក្ខណៈជាទូទៅត្រង់ចំណុចជាច្រើនមែន។ ហេតុនេះ យើងមិនព្រមបញ្ជាក់សេចក្តីដោយចេតនា។ ម្យ៉ាងទៀត បញ្ហាទាំងនោះនៅតែប្រែប្រួលជានិច្ចឥតឈប់ឈរ។ ហេតុនេះ នៅពេលអនាគតត្រូវតែបន្តនិងពង្រីកសេចក្តីបង្រៀននេះតទៅទៀត។ តាមពិតសេចក្តីបង្រៀននេះ ជាសេចក្តីដែលគ្រីស្តបរិស័ទបានទទួលក្នុងព្រះសហគមន៍រួចហើយ។ ប៉ុន្តែយើងសង្ឃឹមថា សេចក្តីជាច្រើនដែលយើងបានសរសេរខាងលើនេះ ដោយសំអាងលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសំអាងលើគោលគំនិតនៃដំណឹងល្អ អាចជួយមនុស្សទាំងអស់បានយ៉ាងសកម្ម ជាពិសេសមានប្រយោជន៍ អាចជួយគ្រីស្តបរិស័ទនៅពេលគេខិតខំសម្របសេចក្តីទាំងនេះ ឲ្យបានស្របតាមប្រជាជាតិនីមួយៗ ដែលមានអរិយធម៌ប្លែកៗពីគ្នា ក្រោមការណែនាំរបស់គង្វាលរបស់ខ្លួន។

## ៩២. ការសន្ទនារវាងមនុស្សទាំងអស់

ក- ព្រះសហគមន៍មានបេសកកម្មយកពន្លឺនៃដំណឹងល្អ មកបំភ្លឺពិភពលោកលោកទាំងមូល ព្រមទាំងប្រមែប្រមូលមនុស្សគ្រប់ជាតិសាសន៍ គ្រប់វប្បធម៌ ឲ្យរួបរួមគ្នាក្នុងព្រះវិញ្ញាណតែមួយដែរ។ ដូច្នេះព្រះសហគមន៍លេចមកហាក់ដូចជា សញ្ញាសម្គាល់អំពីការស្រឡាញ់គ្នាជាបងប្អូន ដែលបណ្តោយឲ្យមនុស្សទាំងអស់អាចនិយាយសន្ទនាគ្នាដោយចិត្តស្មោះ និងពង្រឹងការសន្ទនានោះទៀតផង។

ខ- ហេតុនេះហើយ ជាបឋម ក្នុងផ្ទៃព្រះសហគមន៍យើងត្រូវរាប់អានគ្នា គោរពគ្នា ស្រុះស្រួលគ្នាទាំងទទួលស្គាល់ថា យើងប្លែកៗពីគ្នាជាច្រើនបែប ដើម្បីឲ្យអស់អ្នកដែលចូលរួមជាប្រជារាស្ត្រតែមួយរបស់ព្រះជាម្ចាស់ ជាគង្វាលក្តី ជាគ្រីស្តបរិស័ទឯទៀតៗក្តី អាចសន្ទនាជាមួយគ្នាបាន។ ការសន្ទនានោះ មុខជានឹងបង្កើតលទ្ធផលកាន់តែប្រសើរឡើងៗ។ អ្វីៗដែលបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យភ្ជាប់គ្នា មានកម្លាំងខ្លាំង

ជាងអ្វីៗដែលបណ្តាលឲ្យបាក់បែកគ្នា គឺគ្រីស្តបរិស័ទត្រូវរួមគ្នាក្នុងសេចក្តីដែលសំខាន់ជាចាំបាច់ មានសេរីភាពក្នុងសេចក្តីដែលកំពុងតែជជែកគ្នា ប៉ុន្តែ ក្នុងគ្រប់ករណីទាំងអស់ ត្រូវមានចិត្តស្រឡាញ់ជានិច្ច (សន្តៈ អូហ្គូស្តាំង)។

គ- នៅពេលជាមួយគ្នានេះ យើងនឹកគិតដល់បងប្អូនទាំងអស់ ដែលមិនទាន់រួបរួមជាមួយយើងយ៉ាងពេញលេញនៅឡើយ យើងក៏នឹកគិតដល់សហគមន៍របស់គេដែរ។ យើងទាំងអស់រួមគ្នាដោយប្រកាសជំនឿផ្ញើជីវិតលើព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ព្រមទាំងដោយចំណងនៃសេចក្តីស្រឡាញ់។ យើងក៏ចងចាំថា សូម្បីតែមនុស្សមួយចំនួនធំដែលមិនផ្ញើជីវិតលើព្រះគ្រីស្ត ក៏ទន្ទឹងរង់ចាំ និងមានបំណង ចង់ឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយដែរ។ គ្រីស្តបរិស័ទគ្រប់និកាយរួបរួមគ្នាក្នុងសេចក្តីពិត និងក្នុងសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើងៗយ៉ាងណា ព្រះសហគមន៍នឹងទៅជាប្រផ្នូលអំពីពិភពលោកទាំងមូលរួបរួមគ្នាប្រកបដោយសន្តិភាព កាន់តែខ្លាំងយ៉ាងនោះដែរ ដោយឫទ្ធានុភាពដ៏ខ្លាំងក្លានៃព្រះវិញ្ញាណដ៏វិសុទ្ធ ជួយឧបត្ថម្ភផង។ ហេតុនេះហើយ យើងនាំគ្នារួមកម្លាំងចិត្តកម្លាំងកាយ តាមរបៀបកាន់តែស្របនឹងគោលបំណង ដែលយើងស្វែរកសព្វថ្ងៃយ៉ាងសកម្ម។ យើងត្រូវមានចិត្តស្មោះនឹងដំណឹងល្អកាន់តែខ្លាំងឡើងៗ។ យើងត្រូវយកចិត្តទុកដាក់រួមសហការ បម្រើមហាគ្រួសារនៃមនុស្សជាតិដូចបងប្អូន ដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យទៅជាមហាគ្រួសាររបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រីស្តយេស៊ូ។

ឃ-យើងនឹកគិតដល់បងប្អូនទាំងអស់ ដែលទទួលស្គាល់ព្រះជាម្ចាស់ហើយដែលមានសេចក្តីដ៏ថ្លៃថ្នូរជាច្រើនខាងសាសនា និងខាងមនុស្សជាតិ កប់ទុកក្នុងប្រពៃណីរបស់គេ។ យើងអង្វរព្រះអង្គ សូមប្រោសឲ្យយើងទាំងអស់អាចសន្ទនាជាមួយគ្នាបាន ដោយទុកចិត្តគ្នា សុខចិត្តទទួលការត្រាស់ហៅនៃព្រះវិញ្ញាណ ដោយចិត្តទៀងត្រង់ និងប្រព្រឹត្តតាមដោយចិត្តក្លៀវក្លាទៀតផង។

ង- ចំពោះយើងវិញ យើងមានបំណងចង់សន្ទនាបែបនេះ ដោយមានតែការស្រឡាញ់សេចក្តីពិតណែនាំ ទាំងប្រុងប្រយ័ត្នផង។ យើងមិនរើសអើងនរណាសោះឡើយ គឺមិនបោះបង់ចោលអស់អ្នក ដែលគោរពតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស ទោះបីគេមិនទាន់ស្គាល់ព្រះជាម្ចាស់ ដែលជាប្រភពនៃតម្លៃដ៏ថ្លៃថ្នូរទាំងនោះក៏ដោយ។ យើងក៏មិនបោះបង់ចោលអស់អ្នក ដែលប្រឆាំងជំទាស់នឹងព្រះសហគមន៍ ហើយបៀតបៀនព្រះសហគមន៍តាមរបៀបផ្សេងៗទៀតដែរ។ ដោយព្រះជាម្ចាស់ពិតជាព្រះបិតា ជាដើមកំណើត និងជាចុងបំផុតនៃជីវិតរបស់មនុស្សទាំងអស់ ព្រះអង្គត្រាស់ហៅយើងទាំងអស់គ្នាឲ្យទៅជាបងប្អូន។ ប្រសិនបើព្រះអង្គកំណត់ទុកឲ្យមនុស្សមានទិសដៅតែមួយដដែលដូច្នេះនោះ យើងក៏អាច (ហើយត្រូវ) រួមសហការគ្នាកសាងពិភពលោក ប្រកបដោយសន្តិភាពដ៏ពិតប្រាកដ ដោយគ្មានហិង្សា និងដោយគ្មានប្រើកលល្បិចឡើយ។

## ៩៣. យើងត្រូវកសាងពិភពលោក និងនាំពិភពលោកឲ្យបានដល់ទិសដៅរបស់ខ្លួន

ក- យើងនឹកចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់ថា៖ «បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់ មុខជានឹងដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន» (យហ ១៣, ៣៥)។ ហេតុនេះ គ្រីស្តបរិស័ទមានសេចក្តីប៉ងប្រាថ្នាតែមួយយ៉ាងខ្លាំង គឺចង់ជួយបម្រើមនុស្សនៅសម័យរបស់ខ្លួន ដោយមានចិត្តទូលំទូលាយកាន់តែខ្លាំងឡើងៗ និងកាន់តែសកម្មទៀត។ គេសុខចិត្តធ្វើតាមដំណឹងល្អ និងទទួលកម្លាំង

ពីដំណឹងល្អនេះ ព្រមទាំងរួមជាមួយអស់អ្នកដែលស្រឡាញ់ និងប្រព្រឹត្តតាមយុត្តិធម៌។ គ្រីស្តបរិស័ទក៏មានភារកិច្ចបំពេញបន្ទុកមួយដ៏ធំសម្បើមក្នុងពិភពលោក។ នៅថ្ងៃចុងក្រោយបំផុត គេត្រូវធ្វើសេចក្តីរាយការណ៍នៅចំពោះព្រះគ្រីស្ត ដែលនឹងវិនិច្ឆ័យមនុស្សទាំងអស់។ *"អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា «ព្រះអម្ចាស់! ព្រះអម្ចាស់!» ប៉ុណ្ណោះទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខនោះវិញ"* (មថ ៧, ២១) គឺអស់អ្នកដែលប្រព្រឹត្តកិច្ចការដោយចិត្តក្លាហាន។ ព្រះបិតាសព្វព្រះហឫទ័យឲ្យយើងទទួលស្គាល់ព្រះគ្រីស្ត ជារៀមច្បង ក្នុងមនុស្សគ្រប់ៗរូប ព្រមទាំងឲ្យយើងស្រឡាញ់មនុស្សម្នាក់ៗយ៉ាងពិតប្រាកដដោយពាក្យសម្តី និងដោយប្រព្រឹត្តកិច្ចការផង។ ដូច្នេះ យើងពិតជាផ្តល់សក្ខីភាពដល់សេចក្តីពិតមែន។ ព្រះអង្គក៏សព្វព្រះហឫទ័យឲ្យយើងចែករំលែកគម្រោងការដ៏អស្ចារ្យ នៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ឲ្យមនុស្សលោកដែរ។ ប្រសិនបើ យើងជាគ្រីស្តបរិស័ទរស់នៅតាមបែបនោះ យើងមុខជានឹងនាំឲ្យមនុស្សទាំងអស់ដែលរស់នៅពាសពេញនៅលើផែនដីទាំងមូល មានសេចក្តីសង្ឃឹមយ៉ាងមាំមួនថា គេមុខជានឹងត្រូវរាប់បញ្ចូលក្នុងសេចក្តីសុខសាន្ត និងក្នុងបរមសុខ នៅមាតុភូមិដែលចែងចាំងដោយសិរីរុងរឿងរបស់ព្រះអម្ចាស់។ សេចក្តីសង្ឃឹមនេះក៏ជាព្រះអំណោយទានរបស់ព្រះវិញ្ញាណ។

ខ- *"ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ហួសពីសេចក្តីសុំនិងហួសពីអ្វីៗដែលយើងនឹកគិត ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ដែលបំពេញសកម្មភាពនៅក្នុងយើង។ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ក្នុងព្រះសហគមន៍ និងក្នុងព្រះគ្រីស្តយេស៊ូនៅគ្រប់ជំនាន់អស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន"*។ (អភ៣, ២០.២១)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងធម្មនុញ្ញទាំងមូលនេះព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញស្របតាមអំណាច ដែលព្រះគ្រីស្តបានប្រគល់ឲ្យក្នុងឋានៈជាគ្រីស្តទូតរួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផង យើងក៏យល់ព្រមសម្រេចនឹងចេញជាក្រឹត្យដែរ។យើងបង្គាប់ឲ្យសេចក្តី ដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ព្រះគ្រីស្តជាអម្ចាស់

**(អំពីមុខងារបម្រើរបស់អស់លោកអភិបាល)**

## CHRISTUS DOMINUS

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាល ដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

## ក្រឹត្យក្រម ស្តីអំពីមុខងាររបស់អស់លោកអភិបាលជាគង្វាលក្នុងព្រះសហគមន៍

**១-បុព្វកថា**

ព្រះគ្រីស្តជាព្រះអម្ចាស់ ជាព្រះបុត្រារបស់ព្រះដ៏មានព្រះជន្មគង់នៅ ព្រះអង្គយាងមកសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គឲ្យរួចពីបាប (មថ ១, ២១) និងប្រោសឲ្យមនុស្សទាំងអស់បានវិសុទ្ធ។ ព្រះបិតាចាត់ព្រះបុត្រាឲ្យយាងមកយ៉ាងណា ព្រះអង្គក៏ចាត់ក្រុមគ្រីស្តទូតរបស់ព្រះអង្គឲ្យទៅយ៉ាងនោះដែរ (យហ ២០, ២១)។ ព្រះអង្គក៏ប្រោសគ្រីស្តទូតទាំងនោះឲ្យបានវិសុទ្ធដោយប្រទានព្រះ វិញ្ញាណដ៏វិសុទ្ធឲ្យអស់លោកដែរ។ ដូច្នេះក្រុមគ្រីស្តទូតអាចលើកតម្កើងព្រះបិតានៅលើផែនដី និងនាំការសង្គ្រោះដល់មនុស្សលោក "ដើម្បីកសាងព្រះកាយរបស់ព្រះគ្រីស្តឡើង" (អភ ៤, ១២)។

២-ព្រះគ្រីស្តផ្ញើបេសកកម្មឃ្វាលហ្វូងចៀមនិងកូនចៀមរបស់ព្រះអង្គឲ្យគ្រីស្តទូតសិលា។ ហេតុនេះហើយបានជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ក្នុងឋានៈលោកបន្តមុខងារពីគ្រីស្តទូតសិលាមក មានអំណាចដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះសហគមន៍របស់ព្រះគ្រីស្ត តាមការចាត់ចែងរបស់ព្រះជាម្ចាស់។ អភិបាលព្រះសហគមន៍ក្រុងរ៉ូមមានអំណាចពេញលេញ អំណាចចំៗលើគ្រីស្តបរិស័ទ និងអំណាចសកល ដើម្បីថែទាំវិញ្ញាណមនុស្សលោក។ ហេតុនេះហើយបានជាក្នុងឋានៈលោកជាគង្វាលណែនាំគ្រីស្តបរិស័ទទាំងអស់ និងដោយព្រះជាម្ចាស់ចាត់លោកឲ្យរកប្រយោជន៍រួមរបស់ព្រះសហគមន៍សកល និងរកប្រយោជន៍របស់ព្រះសហគមន៍នីមួយៗ លោកជាប្រធានដែលមានអំណាចជាធម្មតាលើព្រះសហគមន៍ទាំងឡាយ។

ព្រះវិញ្ញាណដ៏វិសុទ្ធក៏បានតែងតាំងអស់លោកអភិបាលដែរ។ អស់លោកបន្តមុខងារពីក្រុមគ្រីស្តទូតមកក្នុងឋានៈជាគង្វាលនៃវិញ្ញាណរបស់មនុស្សលោក។ ព្រះគ្រីស្តចាត់អស់លោកឲ្យបន្តព្រះរាជកិច្ចរបស់ព្រះគ្រីស្ត ជាគង្វាលដែលស្ថិត

នៅអស់កល្បជានិច្ច ដើម្បីឲ្យព្រះរាជកិច្ចរបស់ព្រះអង្គនោះស្ថិតស្ថេរនៅរហូតតរៀងទៅ។ អស់លោកបំពេញកិច្ចការនេះរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងក្រោមអំណាចរបស់លោក។ ព្រះគ្រីស្តប្រទានអំណាច និងបញ្ជាឲ្យក្រុមគ្រីស្តទូត និងឲ្យអស់លោកដែលបន្តមុខងារពីក្រុមគ្រីស្តទូតទាំងនោះ បង្រៀនមនុស្សគ្រប់ជាតិសាសន៍ និងប្រោសមនុស្សឲ្យបានវិសុទ្ធក្នុងសេចក្តីពិត ព្រមទាំងណែនាំហ្វូងចៀមរបស់ព្រះអង្គ។ ហេតុនេះហើយ បានជាព្រះគ្រីស្តប្រទានព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះបិតាឲ្យអស់លោកអភិបាល ដើម្បីតែងតាំងអស់លោកឲ្យធ្វើជាគ្រូបង្រៀនលទ្ធិនៃជំនឿយ៉ាងពិតប្រាកដ និងយ៉ាងត្រឹមត្រូវ និងឲ្យធ្វើជាមហាបូជាចារ្យ និងជាគង្វាលផងដែរ (ពន្លឺ ២១.២៤.២៥)។

៣-ដោយសារអគ្គសញ្ញាតែងតាំង អស់លោកទទួលបន្ទុកជាអភិបាល ហើយរួមគ្នាយកចិត្តទុកដាក់ថែទាំព្រះសហគមន៍ទាំងឡាយ (ពន្លឺ ២១)។ អស់លោកក៏បំពេញបន្ទុករបស់ខ្លួនចំពោះព្រះសហគមន៍សកលរបស់ព្រះជាម្ចាស់ គឺបង្រៀននិងគ្រប់គ្រងព្រះសហគមន៍សកលនេះ ដោយរួបរួមទាំងអស់គ្នាជាក្រុមអភិបាល ដូចជារូបកាយមួយ និងរួបរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម និងក្រោមអំណាចរបស់លោក។

លោកអភិបាលម្នាក់ៗបំពេញបន្ទុករបស់ខ្លួន ចំពោះចំណែកនៃហ្វូងចៀមរបស់ព្រះអម្ចាស់ ដែលព្រះអង្គបានផ្ញើទុកឲ្យលោកថែរក្សា គឺលោកម្នាក់ៗទទួលបន្ទុកលើព្រះសហគមន៍ដោយឡែក ដែលព្រះអង្គបានផ្ញើទុកមកនោះ ឬលើព្រះសហគមនជាច្រើន។ អស់លោកក៏រួមគ្នាផ្គត់ផ្គង់ដល់តម្រូវការរួមរបស់ព្រះសហគមន៍ឯទៀតដែរ។ ហេតុនេះហើយបានជាមហាសន្និបាតដ៏វិសុទ្ធ មានបំណងចង់បញ្ជាក់ឲ្យបានច្បាស់ នូវបន្ទុកជាគង្វាលរបស់អស់លោកអភិបាល ដោយគិតគូរជាពិសេសដល់សភាពការណ៍នានា នៃសហគមន៍មនុស្សនាបច្ចុប្បន្នកាលដែលតែងតែវិវឌ្ឍឡើងៗ បានសម្រេចសេចក្តីដូចតទៅ៖

# ជំពូក ១

## ទំនាក់ទំនងរបស់អស់លោកអភិបាលនិងព្រះសហគមន៍សកល

### ១-តួនាទីរបស់អស់លោកអភិបាលចំពោះព្រះសហគមន៍សកល

### ៤-របៀបក្រុមអភិបាលប្រើអំណាចរួម

អស់លោកអាភិបាល ជាសមាជិកនៃក្រុមអភិបាល ដោយអានុភាពនៃអគ្គសញ្ញាតែងតាំង និងដោយការរួបរួម ជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំ ហើយដោយរួបរួមជាមួយសមាជិកនៃក្រុមអភិបាលឯទៀតៗ តាមលំដាប់លំដោយ (ពន្លឺ ២២)។ *"ក្រុមអភិបាល ដែលបន្តមុខងារបម្រើពីក្រុមគ្រីស្តទូតមក គឺមុខងារបង្រៀន និងគ្រប់គ្រងក្នុងឋានៈជាគង្វាល (បើនិយាយយ៉ាងប្រសើរជាងក្រុមគ្រីស្តទូតបន្តជីវិតរបស់ខ្លួន ដោយសារក្រុមអភិបាល)។ អស់លោកក៏មានអំណាចដ៏ខ្ពង់ខ្ពស់បំផុត និងអំណាចពេញលេញលើព្រះសហគមន៍សកលដែរ លុះត្រាតែក្រុមអភិបាលរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំក្រុមអភិបាលនោះ គឺមិនត្រូវដាច់ពីអភិបាលព្រះសហគមន៍ក្រុងរ៉ូមឡើយ។ ក្រុមអភិបាលអាចប្រើអំណាចនេះបាន លុះត្រាតែអភិបាលព្រះសហគមន៍ក្រុងរ៉ូមយល់ស្រប។"*

*"ក្រុមអភិបាលប្រើអំណាចនេះយ៉ាងឱឡារិក នៅពេលអស់លោកប្រជុំគ្នាជាមហាសន្និបាតសកល។"* (ពន្លឺ ២២)។ ហេតុនេះហើយ បានជាមហាសន្និបាតសម្រេចថា អភិបាលទាំងប៉ុន្មាន ក្នុងឋានៈអស់លោកជាសមាជិកនៃក្រុមអភិបាល មានសិទ្ធិចូលរួមក្នុងមហាសន្និបាតសកលទាំងអស់គ្នាបាន។

*"អស់លោកអភិបាល ដែលរស់នៅលើផែនដីទាំងមូល អាចប្រើអំណាចរួមនេះ រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូមបាន លុះត្រាតែអភិបាលព្រះសហគមន៍ក្រុងរ៉ូម ជាមេដឹកនាំក្រុមអភិបាល កោះហៅអស់លោកឲ្យបំពេញការងាររួម ឬយ៉ាងហោចណាស់ លុះត្រាតែលោកយល់ស្របឲ្យអភិបាលដែលខ្ចាត់ខ្ចាយនៅលើផែនដីទាំងមូលបំពេញការងាររួមនេះ ឬសុខចិត្តទទួលស្គាល់នូវសេចក្តីសម្រេចនៃមហាសន្និបាតនោះ ដោយលោកមានសេរីភាពពេញទី ទើបកិច្ចការរបស់អស់លោក ពិតទៅជាកិច្ចរួមនៃក្រុមអភិបាលបាន"* (ពន្លឺ ២២)។

### ៥-ក្រុមប្រឹក្សា ឬសន្និបាតអភិបាល

ត្រូវជ្រើសរើសអភិបាល តាមតំបន់ផ្សេងៗក្នុងពិភពលោក តាមរបៀប និងតាមសេចក្តីណែនាំ ដែលអភិបាលព្រះសហគមន៍ក្រុងរ៉ូមបានចាត់ចែងរួចហើយ ឬតាមរបៀប និងតាមសេចក្តីណែនាំ ដែលលោកនឹងចាត់ចែងនៅពេលខាងមុខ។ អស់លោកជួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលជាគង្វាលដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះសហគមន៍ យ៉ាងស័ក្តិសិទ្ធិ ដោយរួមក្នុងក្រុមប្រឹក្សាដែលទទួលឈ្មោះថា *"សន្និបាតអភិបាល"*។ ដោយសន្និបាតអភិបាលនោះ បំពេញការងារក្នុងនាមក្រុមអភិបាលកាតូលិកទាំងមូល សន្និបាតអភិបាលនោះពិតជា សញ្ញាសម្គាល់បញ្ជាក់ថា អស់លោកអភិបាលពិតជារួបរួមគ្នាតាមលំដាប់លំដោយ យកចិត្តទុកដាក់ថែទាំព្រះសហគមន៍សកលមែន (ពន្លឺ ២៣)។

### ៦- អភិបាលទាំងអស់រួមគ្នាយកចិត្តទុកដាក់ថែរក្សាព្រះសហគមន៍ទាំងឡាយ

អស់លោកអភិបាលបន្តមុខងារពីក្រុមគ្រីស្តទូតយ៉ាងត្រឹមត្រូវ និងជាសមាជិកនៃក្រុមអភិបាល។ ហេតុនេះហើយបានជាអស់លោកត្រូវដឹងថា អស់លោករួបរួមគ្នាជានិច្ច និងត្រូវយកចិត្តទុកដាក់នឹងព្រះសហគមន៍ទាំងឡាយ។ អភិបាលម្នាក់ៗទទួលខុសត្រូវលើព្រះសហគមន៍សកលរួមជាមួយអភិបាលឯទៀតៗ ព្រោះព្រះជាម្ចាស់ចាត់ចែងដូច្នេះហើយ និងតាមភារកិច្ចនៃបន្ទុករបស់ខ្លួនជាគ្រីស្តទូតដែរ។ ជាពិសេស សូមអស់លោកយកចិត្តទុកដាក់ នឹងតំបន់ក្នុងពិភពលោកដែលមិនទាន់ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅឡើយ ឬតំបន់ដែលមានចំនួនគង្វាលតិចពេក បណ្តាលឲ្យគ្រីស្តបរិស័ទឃ្លាតឆ្ងាយពីវិន័យណែនាំ ការរស់នៅរបស់ខ្លួនជាគ្រីស្តបរិស័ទ និងបាត់បង់ជំនឿទៀតផង។

ហេតុនេះ អស់លោកត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ណែនាំឲ្យគ្រីស្តបរិស័ទទាំងអស់គាំទ្រ និងពង្រីកយ៉ាងក្លៀវក្លា នូវកិច្ចការប្រកាសដំណឹងល្អ និងកិច្ចការជាគ្រីស្តទូត។ លើសពីនេះទៅទៀត អស់លោកអភិបាលត្រូវគិតគូរអប់រំគង្វាលដែលមានសមត្ថភាព ហើយសហការី ទាំងបព្វជិត បព្វជិតា និងគ្រីស្តបរិស័ទធម្មតាឲ្យត្រៀមខ្លួន ទៅបម្រើព្រះសហគមន៍ ឬទៅរស់នៅក្នុងប្រទេសដែលខ្វះគង្វាល។ អស់លោកអភិបាលក៏ត្រូវយកចិត្តទុកដាក់ ចាត់លោកគង្វាលខ្លះនៃភូមិភាគរបស់ខ្លួន ទៅបម្រើព្រះសហគមន៍ និងភូមិភាគទាំងនោះ ដើម្បីបំពេញមុខងារដ៏សក្ការៈជាបណ្តោះអសន្ន ឬជាអចិន្ត្រៃយ៍ក៏បានដែរ។ ម៉្យាងទៀត ចំពោះការប្រើប្រាស់ធនធានរបស់ព្រះសហគមន៍ អស់លោកអភិបាល មិនត្រូវគិតតែអំពីតម្រូវការនៃភូមិភាគរបស់ខ្លួនប៉ុណ្ណោះទេ តែត្រូវគិតដល់តម្រូវការនៃព្រះសហគមន៍ឯទៀតៗដែរ ព្រោះព្រះសហគមន៍ទាំងនោះ ក៏ជាចំណែកនៃព្រះសហគមន៍តែមួយគត់របស់ព្រះគ្រីស្ត។ មិនតែប៉ុណ្ណោះ សូមឲ្យអស់លោកអភិបាលចាប់អារម្មណ៍សម្រាលទុក្ខគ្រីស្តបរិស័ទ តាមសមត្ថភាពរៀងៗខ្លួន ក្នុងភូមិភាគឯទៀតៗ ឬក្នុងតំបន់ខ្លះ ដែលជួបគ្រោះកាច។

### ៧-សេចក្តីស្រឡាញ់យ៉ាងសកម្មចំពោះអភិបាលឯទៀតៗ ដែលត្រូវគេបៀតបៀនធ្វើបាប

លើសពីនេះទៅទៀត សូមឲ្យអស់លោកអភិបាលមានចិត្តស្រឡាញ់អភិបាលដែលត្រូវគេមួលបង្កាច់ ត្រូវគេបៀតបៀនធ្វើបាប ព្រោះតែព្រះគ្រីស្ត គឺអភិបាលដែលត្រូវជាប់ឃុំឃាំង ឬត្រូវគេរារាំងមិនឲ្យបំពេញមុខងារបម្រើរបស់ខ្លួនបាន។ សូមស្ម័គ្រស្លាប់រស់យ៉ាងពិតប្រាកដ និងយ៉ាងសកម្មចំពោះអស់លោក ដើម្បីជួយសម្រាលទុក្ខលំបាករបស់អស់លោក ដោយអធិដ្ឋាន និងដោយធ្វើការរួមជាមួយអភិបាលឯទៀតៗផង។

## ២-ទំនាក់ទំនងរវាងអស់លោកអភិបាលនឹងអាសនៈគ្រីស្តទូតសិលា

### ៨-អំណាចរបស់អស់លោកអភិបាលក្នុងភូមិភាគរបស់ខ្លួន

ក- ដោយអស់លោកអភិបាលបន្តមុខងារពីក្រុមគ្រីស្តទូតមក អស់លោកមានអំណាចធម្មតា យ៉ាងពេញលេញជាអំណាចផ្ទាល់ និងចំៗលើគ្រីស្តបរិស័ទ គឺមានអំណាចដែលអស់លោកត្រូវការសម្រាប់បំពេញបន្ទុករបស់អស់លោកជាគង្វាលក្នុងភូមិភាគរបស់ខ្លួន។ មានករណីខ្លះ អភិបាលព្រះសហគមន៍ក្រុងរ៉ូម ទុកឲ្យលោកសម្រេចដោយខ្លួនលោកផ្ទាល់ ឬដោយអ្នកផ្សេងទៀត។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម មានអំណាចធ្វើដូច្នេះជានិច្ចបាន ក្នុងឋានៈលោកមានបន្ទុកជាគង្វាលសកល។

ខ- អភិបាលភូមិភាគនីមួយៗ មានសិទ្ធិអនុគ្រោះគ្រីស្តបរិស័ទ ដែលស្ថិតនៅក្រោមអំណាចដ៏ត្រឹមត្រូវរបស់

លោកឲ្យលែងជាចំណុះនៃច្បាប់ទូទៅ របស់ព្រះសហគមន៍បានក្នុងករណីពិសេសមួយ គ្រប់ពេលណា ដែលលោកយល់ឃើញថា ការអនុគ្រោះនោះនឹងផ្ដល់ផលប្រយោជន៍ខាងវិញ្ញាណដល់គេ លើកលែងក្នុង ករណីណាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលកាន់អំណាចដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះសហគមន៍ ទុកយ៉ាង ពិសេសឲ្យលោកសម្រេចដោយខ្លួនលោកផ្ទាល់។

## ៩-ក្រសួងក្នុងរដ្ឋបាលអភិបាលព្រះសហគមន៍ក្រុងរ៉ូម

អភិបាលព្រះសហគមន៍ក្រុងរ៉ូមតែងប្រើក្រសួងនានានៃរដ្ឋបាល ដើម្បីជួយលោកក្នុងកិច្ចប្រើអំណាចរបស់លោក ផ្ទាល់លើព្រះសហមន៍សកល ជាអំណាចដ៏ខ្ពង់ខ្ពស់បំផុត ជាអំណាចដ៏ពេញលេញ និងដ៏ចំៗលើគ្រីស្តបរិស័ទ។ ក្រសួង ទាំងនោះ បំពេញបន្ទុករបស់ខ្លួនក្នុងនាមលោក និងដោយមានអំណាចរបស់លោក ដើម្បីជាប្រយោជន៍ដល់ព្រះសហ គមន៍នានា និងដើម្បីជួយបម្រើអភិបាលនានាទៀតផង។

ជាយូរឆ្នាំកន្លងមក ក្រសួងទាំងនោះតែងតែជួយអភិបាលព្រះសហគមន៍ក្រុងរ៉ូមយ៉ាងល្អប្រសើរ និងបានជួយ អភិបាលនៃព្រះសហគមន៍នានា។ ប៉ុន្តែ អស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាត ប្រាថ្នាចង់ចាត់ចែងក្រសួង ទាំងនោះតាមរបៀបថ្មី ស្របតាមតម្រូវការរបស់សម័យឥឡូវនេះ គឺស្របតាមតម្រូវការរបស់ប្រទេសនានា និងតាមតម្រូវ ការនៃរបៀបរបបផ្សេង ៗទៀត។ ជាពិសេសត្រូវចាត់ចែងក្រសួងទាំងនោះ តាមរបៀបថ្មី ចំពោះចំនួនក្រសួង ចំពោះឈ្មោះ ចំពោះសមត្ថភាព ចំពោះវិធីបំពេញការងារ និងចំពោះការរួមសហការជាមួយគ្នាក្នុងកិច្ចការរបស់ខ្លួន។ អស់លោកក៏ប្រាថ្នា ថា សូមបញ្ជាក់យ៉ាងច្បាស់ជាងពីមុន អំពីតួនាទីរបស់ទូតនៃអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដោយគិតគូរដល់មុខងារ ផ្ទាល់របស់អស់លោកអភិបាលជាគង្វាលផងដែរ។

## ១០-អំពីសមាជិក និងនិស្នាក់ងារក្នុងក្រសួងនានា

លើសពីនេះទៅទៀត នៅសម័យបុរាណ គេតែងតាំងក្រសួងទាំងនោះ ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ សកល។ ហេតុនេះហើយបានជា អស់លោកអភិបាលប្រាថ្នាចង់ សូមជ្រើសរើសសមាជិក បុគ្គលិក និងទីប្រឹក្សានៃក្រសួង ក្រសួងទាំងនោះ ពីតំបន់ផ្សេង ៗជាកន្លែងព្រះសហគមន៍ស្ថិតនៅ ប្រសិនបើអាចធ្វើបាន។ សូម្បីតែទូត អភិបាលព្រះសហ គមន៍ក្រុងរ៉ូម ក៏ត្រូវជ្រើសរើសពីតំបន់នានាដែរ។ ធ្វើដូច្នេះ ទើបក្រុមគ្រប់គ្រង និងអង្គការមជ្ឈិមនៃព្រះសហគមន៍ កាតូលិកយើង មុខជានឹងមានលក្ខណៈសកលប្រាកដមែន។ អស់លោកក៏ប្រាថ្នាចង់សូមឲ្យមានអភិបាល ជាពិសេស អភិបាលភូមិភាគ ធ្វើជាសមាជិកក្នុងក្រសួងទាំងនោះ។ អភិបាលភូមិភាគទាំងនោះអាចនាំមតិ គំនិត បំណងប្រាថ្នា និង តម្រូវការនៃព្រះសហគមន៍ទាំងឡាយ ជូនលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមឲ្យបានសព្វគ្រប់ជាងពីមុន។

លើសពីនេះទៅទៀត អស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតយល់ឃើញថា ក្រសួងទាំងនោះ ត្រូវ ស្ដាប់គ្រីស្តបរិស័ទធម្មតាឲ្យបានច្រើន គឺគ្រីស្តបរិស័ទដែលល្បីឈ្មោះដោយគុណសម្បត្តិ ដោយចំណេះវិទ្យា និងដោយបទ ពិសោធន៍របស់គេ ដើម្បីឲ្យគ្រីស្តបរិស័ទធម្មតាអាចបំពេញតួនាទីរបស់ខ្លួនក្នុងព្រះសហគមន៍។ ធ្វើដូច្នោះ ពិតជាមាន ប្រយោជន៍យ៉ាងខ្លាំងមែន។

# ជំពូក ២

## អស់លោកអភិបាល និងព្រះសហគមន៍ដោយឡែក ឬព្រះសហគមន៍ភូមិភាគ

### ១-អភិបាលភូមិភាគ

### ១១-ពាក្យ "ភូមិភាគ" និងតួនាទីរបស់អភិបាលក្នុងភូមិភាគរបស់ខ្លួន

ភូមិភាគជាចំណែកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គផ្ញើទុកឲ្យអភិបាលម្នាក់ធ្វើជាគង្វាល ដោយមានក្រុមគង្វាលជួយឧបត្ថមផង។ ដូច្នេះ ភូមិភាគជាប់ជាមួយនឹងអភិបាលរបស់ខ្លួនជាគង្វាល។ លោកប្រមែប្រមូលគ្រីស្តបរិស័ទភូមិភាគក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារដំណឹងល្អ និងដោយសារអគ្គសញ្ញាអរព្រះគុណ។ ភូមិភាគជាព្រះសហគមន៍មួយដោយឡែក ដែលមានវត្តមានយ៉ាងពិតប្រាកដ និងមានសកម្មភាពរបស់ព្រះសហគមន៍របស់ព្រះគ្រីស្តតែមួយគត់ គឺព្រះសហគមន៍ដ៏វិសុទ្ធ កាតូលិក និងដែលកាន់ជំនឿតាមក្រុមគ្រីស្តទូតជាគ្រឹះទៀតផង។

ព្រះជាម្ចាស់ផ្ញើឲ្យអភិបាលម្នាក់ៗថែទាំព្រះសហគមន៍មួយដោយឡែក។ លោកថែរក្សាហ្វូងចៀមរបស់ខ្លួន ក្នុងនាមព្រះអម្ចាស់ ក្រោមអំណាចរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម។ លោកមានមុខងារជាគង្វាលដោយផ្ទាល់ ជាអំណាចធម្មតា ជាអំណាចចំៗលើគ្រីស្តបរិស័ទ គឺលោកបំពេញបន្ទុកបង្រៀនគេ ប្រោសឲ្យគេបានវិសុទ្ធ និងគ្រប់គ្រងទៀតផង។ ក៏ប៉ុន្តែ លោកត្រូវទទួលស្គាល់សិទ្ធិដ៏ត្រឹមត្រូវរបស់អភិបាលដ៏ប្រសើរឧត្តមនៃព្រះសហគមន៍បូព៌ាប្រទេស ឬអំណាចឯទៀតក្នុងព្រះសហគមន៍ តាមលំដាប់លំដោយ (បូព៌ា ៧-១១)។

សូមឲ្យលោកអភិបាលយកចិត្តទុកដាក់ បំពេញបន្ទុករបស់ខ្លួនជាគ្រីស្តទូត ក្នុងឋានៈលោកជាសាក្សីរបស់ព្រះគ្រីស្តនៅចំពោះមុខមនុស្សទាំងអស់។ លោកមិនគ្រាន់តែយកចិត្តទុកដាក់ នឹងអស់អ្នកដែលតាមព្រះអង្គម្ចាស់នៃគង្វាលទាំងឡាយប៉ុណ្ណោះទេ តែត្រូវយកចិត្តទុកដាក់ដោយស្មោះអំពីចិត្តនឹងអស់អ្នកដែលងាកចេញពីមាគ៌ានៃសេចក្ដីពិត ឬដែលមិនស្គាល់ដំណឹងល្អ ឬមិនស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះគ្រីស្ត ដែលសង្គ្រោះមនុស្សលោកទៀតដែរ។ ហេតុនេះហើយ បានជាអស់លោកនឹងបំពេញការងារ រហូតដល់ពេលមនុស្សទាំងអស់នឹងដើរ *"តាមសេចក្ដីសប្បុរស សេចក្ដីសុចរិត និងតាមសេចក្ដីពិតគ្រប់បែបយ៉ាង"* ជាស្ថាពរ (អភ ៥, ៩)។

### ១២-បន្ទុកបង្រៀន

ក្នុងពេលបំពេញបន្ទុកបង្រៀន សូមឲ្យអភិបាលទាំងឡាយ ប្រកាសដំណឹងល្អរបស់ព្រះគ្រីស្តឲ្យមនុស្សលោក។ បន្ទុកនេះ សំខាន់ជាងបន្ទុកឯទៀតៗទាំងអស់។ ដោយមានឫទ្ធានុភាពនៃព្រះវិញ្ញាណជួយឧបត្ថមផង សូមអស់លោកហៅមនុស្សឲ្យផ្ញើជីវិតលើព្រះគ្រីស្ត និងសូមគាំទ្រជំនឿដ៏រស់រវើករបស់គេដែរ។ សូមរៀបរាប់គម្រោងការដ៏អស្ចារ្យទាំងមូលរបស់ព្រះគ្រីស្ត គឺសេចក្ដីពិតទាំងប៉ុន្មានដែលគេត្រូវតែស្គាល់។ ប្រសិនបើមនុស្ស មិនស្គាល់សេចក្ដីពិតទាំងនោះ

គេមិនអាចស្គាល់ព្រះគ្រីស្តបានទេ។ អស់លោកត្រូវបង្ហាញមាគ៌ាដែលព្រះជាម្ចាស់បានសម្តែងមក ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ និងទទួលការសង្គ្រោះដោយបំពេញការនេះ (ពន្លឺ ២៥)។

អស់លោកអភិបាលត្រូវបង្ហាញឲ្យមនុស្សលោកដឹងថា កិច្ចការនៅលើផែនដី និងស្ថាប័នលោកីយ៍ សុទ្ធតែបែរតម្រង់ទៅរកការសង្គ្រោះរបស់មនុស្សលោក តាមគម្រោងការរបស់ព្រះជាម្ចាស់ដែលប្រតិស្ឋានអ្វីៗទាំងអស់។ ដូច្នេះ កិច្ចការ និងស្ថាប័នទាំងនោះអាចជួយជាខ្លាំងឲ្យកសាងព្រះកាយព្រះគ្រីស្តបាន។

ហេតុនេះ អស់លោកត្រូវបង្រៀនតាមលទ្ធិនៃព្រះសហគមន៍ថា ត្រូវរាប់តម្លៃរបស់បុគ្គលម្នាក់ៗ ត្រូវរាប់តម្លៃនៃសេរីភាពរបស់គេ សូម្បីតែការរស់នៅតាមរូបកាយ ក៏ត្រូវរាប់ទុកថាមានតម្លៃដែរ។ ត្រូវបង្រៀនក្រុមគ្រួសារឲ្យចេះរួមគ្នាជាធ្លុងតែមួយឲ្យនៅស្ថិតស្ថេរ ឲ្យបន្តពូជ និងអប់រំកូន។ ត្រូវបង្រៀនអំពីសង្គម និងរដ្ឋអំណាច ដែលមានច្បាប់ និងអំពីមុខងារផ្ទាល់ផ្សេងៗ អំពីការនឿយហត់និងអំពីការលំហែកាយ អំពីសិល្បៈ និងបច្ចេកទេស អំពីភាពក្រីក្រនិងភាពសម្បូរហូរហៀរទៀត។ អស់លោកត្រូវរៀបរាប់អំពីរបៀបដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរបំផុត គឺអំពីការកាន់កាប់ទ្រព្យសម្បត្តិ អំពីរបៀបទ្រព្យសម្បត្តិទាំងនោះចម្រើនឡើង និងអំពីការចែករំលែកទ្រព្យសម្បត្តិតាមយុត្តិធម៌។ ត្រូវរៀបរាប់អំពីសន្តិភាព និងសង្គ្រាម អំពីប្រជាជាតិទាំងឡាយរួបរួមគ្នាជាសហគមន៍តែមួយ ដែលសុទ្ធតែជាបងប្អូន។

## ១៣-របៀបរៀបរាប់លទ្ធិនៃគ្រីស្តសាសនាជូនគេ

អស់លោកអភិបាល ត្រូវរៀបរាប់លទ្ធិនៃគ្រីស្តសាសនាជូនមនុស្សលោក តាមរបៀបស្របនឹងតម្រូវការនៃពេលវេលា គឺដោយមានបំណងចង់តបឆ្លើយនឹងការពិបាក និងបញ្ហាដែលបណ្តាលឲ្យមនុស្សតប់ប្រមល់យ៉ាងខ្លាំង។ អស់លោកត្រូវយកចិត្តទុកដាក់រក្សាការពារលទ្ធិនោះ ទាំងបង្ហាត់ឲ្យគ្រីស្តបរិស័ទចេះការពារ និងផ្សព្វផ្សាយលទ្ធិនោះទៀតផង។ នៅពេលបញ្ជូនបន្តលទ្ធិនោះ ត្រូវសម្តែងសេចក្តីស្រឡាញ់របស់ព្រះសហគមន៍ជាមាតាមកមនុស្សទាំងអស់ ទោះជាគ្រីស្តបរិស័ទ មិនគ្រីស្តបរិស័ទក្តី។ សូមចាប់អារម្មណ៍យ៉ាងពិសេសចំពោះអ្នកក្រីក្រ និងអ្នកតូចតាច ព្រោះព្រះអម្ចាស់ចាត់អស់លោក ឲ្យទៅប្រកាសដំណឹងល្អដល់អ្នកទាំងនោះ។

ព្រះសហគមន៍មានភារកិច្ចនិយាយសន្ទនាជាមួយសង្គមមនុស្ស ជាកន្លែងព្រះសហគមន៍រស់នៅ។ ហេតុនេះ អស់លោកអភិបាលមានបន្ទុកជាចម្បងទៅរកមនុស្ស ហើយសូមសន្ទនាជាមួយ ហើយលើកស្ទួយការសន្ទនានោះទៀតផង។ ប្រសិនបើអស់លោកចង់ឲ្យសេចក្តីពិតនិងសេចក្តីស្រឡាញ់ ប្រាជ្ញានិងការរាប់អាន ជាប់ជាមួយគ្នាជានិច្ចក្នុងការសន្ទនាដែលសង្គ្រោះគេនោះ អស់លោកត្រូវនិយាយតាមរបៀបប្លែកពីការសន្ទនាធម្មតា គឺត្រូវនិយាយយ៉ាងច្បាស់ ទាំងមានចិត្តសុភាពរាបសា និងចិត្តមេត្តាករុណា ហើយប្រុងប្រយ័ត្នយ៉ាងសមគួរ ទាំងទុកចិត្តគេផង។ ការទុកចិត្តនេះជួយនាំការរាប់អានគ្នា និងតាមធម្មតាបណ្តោយឲ្យមនុស្សរួបរួមដោយមានចិត្តគំនិតតែមួយផង។

លោកអភិបាលត្រូវប្រើមធ្យោបាយផ្សេងៗ ដែលព្រះសហគមន៍អាចប្រើប្រាស់សព្វថ្ងៃបាន ដើម្បីប្រកាសលទ្ធិនៃគ្រីស្តសាសនា។ មុនអ្វីៗទាំងអស់ ត្រូវធ្វើពិធីអត្ថាធិប្បាយព្រះគម្ពីរ និងត្រូវអប់រំជំនឿ ជាកិច្ចការដែលសំខាន់ជាងគេ។ ត្រូវរៀបរាប់ពន្យល់លទ្ធិនៃគ្រីស្តសាសនានៅក្នុងសាលា និងក្នុងមហាវិទ្យាល័យដោយធ្វើសន្និសិទ្ធ និងប្រជុំគ្រប់យ៉ាង។ មិនតែប៉ុណ្ណោះ ក្នុងឱកាសខ្លះ គឺពេលកើតព្រឹត្តិការណ៍សំខាន់ៗ ត្រូវផ្សព្វផ្សាយសេចក្តីប្រកាសជាសាធារណៈទៀតដែរ។ ត្រូវប្រើកាសែត និងមធ្យោបាយផ្សេងៗនៃទូរគមនាគមន៍ក្នុងសង្គម ដើម្បីប្រកាសដំណឹងល្អរបស់ព្រះគ្រីស្តឲ្យបានទូលំទូលាយ (ទរ)។

## ១៤-ការអប់រំជំនឿ

អស់លោកអភិបាលត្រូវយកចិត្តទុកដាក់អប់រំជំនឿរបស់ក្មេងៗ កូនជំទង់ យុវជន យុវនារី សូម្បីតែមនុស្សពេញវ័យ ក៏ត្រូវអប់រំជំនឿរបស់គេដែរ ក្នុងគោលបំណងឲ្យមនុស្សមានជំនឿរស់រវើក មានជំនឿជាក់ច្បាស់ និងជំនឿ ដែលបង្កើតផល។ ត្រូវយកលទ្ធិនៃគ្រីស្តសាសនាមកបំភ្លឺជំនឿនេះទៀតផង។ ត្រូវបង្រៀនតាមលំដាប់លំដោយ និងដោយប្រើវិធី ដែលមិនគ្រាន់តែស្របតាមប្រធានបទប៉ុណ្ណោះទេ តែស្របតាមបុគ្គលិកលក្ខណៈ តាមទេពកោសល្យ តាមអាយុ និងតាមសភាពការណ៍ជីវភាពរបស់អ្នកស្តាប់ថែមទៀតដែរ។ ត្រូវបង្រៀនគេដោយយកគម្ពីរ យកសេចក្តីបញ្ញូនបន្ត ក្បួនការបង្រៀននៃការណែនាំព្រះសហគមន៍ និងការរស់នៅរបស់ព្រះសហគមន៍ជាមូលដ្ឋាន។ លើសពីនេះទៅទៀត អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ឲ្យអ្នកអប់រំជំនឿ ទទួលការអប់រំយ៉ាងល្អត្រឹមត្រូវ និងមានសមត្ថភាពអាចបំពេញបន្ទុករបស់ខ្លួនបាន។ ត្រូវឲ្យអ្នកអប់រំជំនឿទាំងនោះ ស្គាល់លទ្ធិនៃព្រះសហគមន៍យ៉ាងច្បាស់ ហើយរៀនចិត្តសាស្ត្រ និងរៀនទ្រឹស្តីនៃក្បួនគរុកោសល្យ ហើយធ្វើការអនុវត្តន៍តាមថែមទៀត។

អស់លោកអភិបាល ក៏ត្រូវខិតខំតែងតាំងការអប់រំជំនឿមនុស្សពេញវ័យ តាមដំណាក់កាលឡើងវិញ ហើយក៏ត្រូវសម្រួលការអប់រំនេះតាមតម្រូវការដែរ។

## ១៥-អស់លោកអភិបាលទទួលបន្ទុកប្រោសឲ្យមនុស្សបានវិសុទ្ធ

អស់លោកអភិបាលទទួលបន្ទុកប្រោសឲ្យមនុស្សបានវិសុទ្ធ។ ពេលបំពេញបន្ទុកនោះ អស់លោកត្រូវនឹកចងចាំថា ព្រះជាម្ចាស់បាន *"ជ្រើសរើសអស់លោកពីក្នុងចំណោមមនុស្ស ហើយតែងតាំងអស់លោក សម្រាប់ទាក់ទងជាមួយព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ក្នុងការថ្វាយតង្វាយ និងថ្វាយយញ្ញបូជារំដោះគេឲ្យរួចពីបាប"*។ (ហប ៥, ១)។ អស់លោកអភិបាល ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យយ៉ាងពេញលេញ។ អស់លោកគង្វាល និងឧបដ្ឋាក អាចប្រើអំណាចរបស់ខ្លួនបាន លុះត្រាតែអស់លោកភ្ជាប់ជាមួយអស់លោកអភិបាលប៉ុណ្ណោះ។ អស់លោកគង្វាល ត្រូវបានប្រសិទ្ធិជាគង្វាលដ៏ពិតប្រាកដនៃសម្ពន្ធមេត្រីថ្មី ដើម្បីឲ្យទៅជាសហការីដ៏ឈ្លាសវៃនៃក្រុមអភិបាល។ រីឯអស់លោកឧបដ្ឋាកវិញ ត្រូវបានតែងតាំងដើម្បីបម្រើព្រះសហគមន៍ គឺបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ទាំងរួបរួមជាមួយលោកអភិបាលនិងជាមួយក្រុមគង្វាល។ ហេតុនេះហើយ បានជាអស់លោកអភិបាលពិតជាអ្នកដ៏សំខាន់ជាងគេក្នុងការចែកចាយគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ហាក់ដូចជាអ្នកចាត់ចែង ជាអ្នកលើកស្ទួយ ជាអ្នកថែរក្សាទុកពិធីបុណ្យទាំងមូល ឲ្យមានជីវិតរស់រវើកក្នុងព្រះសហគមន៍ដែលព្រះជាម្ចាស់បានផ្ញើទុកមកលោក (ពិធី)។

ហេតុនេះ អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ ណែនាំគ្រីស្តបរិស័ទឲ្យស្គាល់គម្រោងការដ៏អស្ចារ្យ អំពីព្រះគ្រីស្តសោយទិវង្គត និងមានព្រះជនថ្មីដ៏រុងរឿង និងទទួលជីវិតពីគម្រោងការនោះដោយសារអគ្គសញ្ញាអរព្រះគុណ ដើម្បីឲ្យគេត្រឡប់ទៅជាព្រះកាយតែមួយគត់ ភ្ជាប់រួមជាមួយគ្នាយ៉ាងជិតស្និទ្ធ ដោយព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជាចំណង។ អស់លោកអភិបាលដែលព្យាយាម *"គិតតែពីអធិដ្ឋាន និងបម្រើព្រះបន្ទូល"* (កក ៦, ៤) លោកត្រូវខិតខំធ្វើឲ្យអស់អ្នកដែលនៅក្នុងបន្ទុក មានចិត្តគំនិតព្យាយាមអធិដ្ឋានដែរ (កក ១, ១៤ និង ២, ៤៦)។ ដោយគ្រីស្តបរិស័ទទាំងនោះ ទទួលអគ្គសញ្ញានានា ព្រះជាម្ចាស់ប្រោសប្រណីដល់គេកាន់តែច្រើនឡើង ហើយគេអាចទៅជាសាក្សីដ៏ស្មោះត្រង់ថ្វាយព្រះអម្ចាស់។

អស់លោកអភិបាល ជាគ្រូណែនាំគ្រីស្តបរិស័ទឲ្យបានពេញលក្ខណៈ។ ហេតុនេះ អស់លោកត្រូវខិតខំឲ្យក្រុមអ្នក

ទទួលអគ្គសញ្ញាតែងតាំង អស់បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតាកាន់តែវិសុទ្ធឡើងៗ គឺម្នាក់ៗតាមបែបបទ ដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យគេរស់នៅ (ពន្លឺ ៤៤-៤៥)។ តែអស់លោកត្រូវនឹកចងចាំថា អស់លោកមានភារកិច្ចធ្វើជាគំរូអំពីភាពដ៏វិសុទ្ធនេះ ដោយមានចិត្តស្រឡាញ់ និងរស់នៅយ៉ាងសុភាពរាបសា។ សូមអស់លោកប្រោសឲ្យព្រះសហគមន៍ ដែលព្រះជាម្ចាស់បានធ្វើទុកមកលោកបានវិសុទ្ធ ដើម្បីឲ្យមនោសញ្ចេតនានៃព្រះសហគមន៍សកល របស់ព្រះគ្រីស្ត លេចចេញមកយ៉ាងច្បាស់ក្នុងព្រះសហគមន៍ដែលនៅក្នុងបន្ទុករបស់លោក។ ដោយមានចិត្តគំនិតបែបនេះ សូមអស់លោកជួយលើកស្ទួយអស់អ្នក ដែលឲ្យព្រះជាម្ចាស់ត្រាស់ហៅឲ្យធ្វើជាគង្វាល និងទៅជាបព្វជិតបព្វជិតា ជាពិសេសឲ្យទៅជាសាសនទូតទៀតផង។

## ១៦-អស់លោកអភិបាលមានបន្ទុកគ្រប់គ្រងនិងឃ្វាលណែនាំ

អស់លោកអភិបាលមានបន្ទុកធ្វើជាឪពុកនិងគង្វាល។ ពេលបំពេញបន្ទុកនេះ សូមឲ្យអស់លោករស់នៅ កណ្តាលប្រជាជនរបស់ខ្លួន ទុកជាអ្នកបម្រើ (លក ២២, ២៦-២៧) ទុកជាគង្វាលដ៏ល្អដែលស្គាល់ចៀមរបស់ខ្លួន ហើយដែលចៀមស្គាល់ដែរ។ សូមឲ្យអស់លោកទៅជាឪពុកដ៏ពិតប្រាកដ ដែលមនុស្សគោរព ដោយអស់លោកមានចិត្តស្រឡាញ់ និងមានចិត្តទូលំទូលាយចំពោះមនុស្សទាំងអស់។ សូមឲ្យមនុស្សទាំងអស់ ទទួលស្គាល់អំណាចរបស់អស់លោក ទុកជាអំណាចមកពីព្រះជាម្ចាស់ ទាំងអរព្រះគុណផង។ អស់លោកអភិបាលត្រូវប្រមែប្រមូលមហាគ្រួសារនៃហ្វូងចៀមទាំងមូលរបស់ខ្លួន និងផ្តល់ឲ្យមហាគ្រួសារនោះមានជីវិតរស់រវើក។ ដូច្នេះគ្រីស្តបរិស័ទទាំងអស់ មុខជានឹងភ្ញាក់ស្មារតីដឹងអំពីភារកិច្ចរបស់ខ្លួន និងរស់នៅហើយប្រព្រឹត្តកិច្ចការនានា ទាំងរួបរួមគ្នាដោយសេចក្តីស្រឡាញ់។

អស់លោកអភិបាលដែល *"ប្រុងខ្លួនសម្រាប់ធ្វើអំពើល្អគ្រប់យ៉ាង"* (២ធម ២, ២១) និង *"សុខចិត្តស៊ូទ្រាំគ្រប់បែបយ៉ាង ដោយយល់ដល់អស់អ្នកដែលព្រះជាម្ចាស់បានជ្រើសរើស"* (២ធម ២, ១០) ត្រូវរស់នៅ ឲ្យបានស្របតាមតម្រូវការនៃសម័យរបស់ខ្លួន ទើបអស់លោកមានសមត្ថភាពយ៉ាងពិតប្រាកដអាចបំពេញបន្ទុកនេះបាន។ សូមឲ្យអស់លោកអភិបាល ស្រឡាញ់គង្វាលយ៉ាងពិសេស ព្រោះគង្វាលបំពេញបន្ទុករបស់អស់លោកមួយចំណែក និងរួមកង្វល់របស់អស់លោក ហើយប្ជាកម្លាំងកាយកម្លាំងចិត្តបំពេញកិច្ចការនេះជារៀងរាល់ថ្ងៃ។ ត្រូវរាប់អស់លោកគង្វាលទុកជាកូន និងទុកជាមិត្តសម្លាញ់ (យហ ១៥, ១៥) ត្រូវប្រុងស្តាប់គេជានិច្ច មានទំនាក់ទំនងជាមួយគេទាំងទុកចិត្ត។ ធ្វើដូច្នេះ អស់លោកមុខជានឹងលើកស្ទួយកិច្ចការជាគង្វាលរួម និងណែនាំភូមិភាគទាំងមូល។

អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ នឹងសភាពការណ៍របស់អស់លោកគង្វាលរបស់ខ្លួន ខាងផ្លូវវិញ្ញាណ ខាងចំណេះចេះដឹង និងខាងសេដ្ឋកិច្ច ដើម្បីឲ្យលោកគង្វាលមានលទ្ធភាពអាចរស់នៅតាមរបៀបដ៏វិសុទ្ធ និងដោយគោរពប្រណិប័តន៍ព្រះជាម្ចាស់ ព្រមទាំងអាចបំពេញមុខងារបម្រើរបស់ខ្លួនដោយចិត្តស្មោះ និងទាំងបង្កើតផលផង។ ហេតុនេះហើយ បានជាអស់លោកអភិបាលត្រូវជួយស្ថាប័ន និងចាត់ចែងប្រជុំពិសេស ដើម្បីផ្តល់ឱកាសឲ្យអស់លោកគង្វាលរួបរួមគ្នាយូរៗម្តង។ ត្រូវចាត់ចែងសំណាក់ធម៌យ៉ាងវែងបន្តិច ដែលអាចផ្លាស់ប្រែការរស់នៅរបស់អស់លោកឲ្យបានជាថ្មី។ ត្រូវចាត់ចែងឲ្យគង្វាល រៀនវិទ្យាព្រះសហគមន៍ឲ្យកាន់តែស៊ីជម្រៅទៅៗ ជាពិសេសរៀនព្រះគម្ពីរ និងទេវវិទ្យា សិក្សាបញ្ហាសំខាន់ៗក្នុងសង្គម និងវិធីថ្មីក្នុងមុខងារជាគង្វាលទៀតផង។ អស់លោកអភិបាលត្រូវមានចិត្តមេត្តាយ៉ាងសកម្មចំពោះលោកគង្វាលណាដែលជួបប្រទះគ្រោះកាច ទោះជាគ្រោះកាចណាក៏ដោយ ឬលោកគង្វាលដែលភ្លាត់ត្រង់ចំណុចណាមួយក៏ដោយដែរ។

អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ ស្គាល់តម្រូវការរបស់គ្រីស្តបរិស័ទ តាមសភាពការណ៍សង្គម ដែលគេរស់នៅ ដើម្បីជួយផ្គត់ផ្គង់គេម្នាក់ៗ ស្របតាមសភាពការណ៍រៀងៗខ្លួន។ ត្រូវប្រើវិធីយ៉ាងសមគួរដើម្បីសិក្សាអំពីតម្រូវការទាំងនោះ ជាពិសេសត្រូវធ្វើអង្កេតស៊ើបសួររកពត៌មានក្នុងសង្គម។ អស់លោកត្រូវចាប់អារម្មណ៍នឹងមនុស្សទាំងអស់ ទោះបីគេស្ថិតនៅក្នុងវ័យណាក្តី សភាពការណ៍ក្នុងសង្គមណាក្តី ប្រទេសណាក្តី ជាអ្នកកើតក្នុងស្រុកឬជាជនបរទេសក្តី ឬជាអ្នកធ្វើដំណើរក្តី។ ពេលអស់លោកសម្តែងសេចក្តីស្រឡាញ់ក្នុងការណែនាំនោះ សូមអស់លោកចាត់ចែងឲ្យគ្រីស្តបរិស័ទ មានចំណែករបស់គេក្នុងកិច្ចការរបស់ព្រះសហគមន៍។ សូមអស់លោកទទួលស្គាល់ថា គេមានភារកិច្ច និងសិទ្ធិធ្វើការយ៉ាងសកម្ម ក្នុងការសាងសង់ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត។

អស់លោកអភិបាលត្រូវគិតគូរយ៉ាងពិសេស ដល់បងប្អូនដែលបែកចេញពីព្រះសហគមន៍កាតូលិកយើង ទាំងទូន្មានឲ្យគ្រីស្តបរិស័ទកាតូលិករាប់រកគេដោយមនុស្សធម៌ និងដោយសេចក្តីស្រឡាញ់យ៉ាងខ្លាំង។ សូមលើកទឹកចិត្តគ្រីស្តបរិស័ទកាតូលិក ឲ្យចូលក្នុងចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ តាមគោលគំនិតនៃព្រះសហគមន៍ (បង្រួប)។ អស់លោក ក៏ត្រូវស្រឡាញ់អ្នកដែលមិនបានទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងខ្លាំងដែរ ដើម្បីឲ្យពន្លឺនៃព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តយេស៊ូចាំងលើគេ ព្រោះអស់លោកអភិបាល ជាសាក្សីថ្វាយព្រះអង្គនៅចំពោះមុខមនុស្សទាំងអស់។

## ១៧-របៀបបំពេញកិច្ចជាគ្រីស្តទូត

ត្រូវជួយលើកទឹកចិត្តគ្រីស្តបរិស័ទ ដែលបំពេញកិច្ចការជាគ្រីស្តទូតតាមរបៀបផ្សេងៗ។ ក្នុងភូមិភាគទាំងប៉ុន្មាន និងក្នុងតំបន់ពិសេសនានា ត្រូវជួយឲ្យគ្រីស្តបរិស័ទទាំងអស់ដែលបំពេញកិច្ចការជាគ្រីស្តទូត រួមសហការគ្នាកាន់តែជិតស្និទ និងកាន់តែខ្លាំងឡើងៗ ក្រោមការណែនាំរបស់លោកអភិបាល។ ដូច្នេះ កិច្ចការអ្វីៗដែលគេចាប់ផ្តើមធ្វើ និងស្ថាប័ននានា គឺការអប់រំជំនឿ ការប្រកាសដំណឹងល្អ កិច្ចការខាងមនុស្សធម៌ សង្គមកិច្ច ការបង្រៀនសិស្ស និងកិច្ចការជាគង្វាល ណែនាំគ្រីស្តបរិស័ទតាមបែបផ្សេងៗឯទៀត មុខជានឹងរួមសហការគ្នាពុំខាន។ ដូច្នេះ ភូមិភាគសម្តែងឲ្យកាន់តែច្បាស់ថា ខ្លួនរួបរួមជាធ្លុងតែមួយមែន។

ត្រូវគូសសង្កត់ជាខ្លាំងថា គ្រីស្តបរិសទមានភារកិច្ចបំពេញកិច្ចការជាគ្រីស្តទូត គឺម្នាក់ៗតាមសភាពការណ៍ និងតាមទេពកោសល្យរៀងៗខ្លួន។ ហេតុនេះ ត្រូវទូន្មានគេឲ្យចូលរួមនិងជួយសកម្មភាពផ្សេងៗក្នុងកិច្ចការរបស់គ្រីស្តបរិស័ទធម្មតាក្នុងឋានៈជាគ្រីស្តទូត ជាពិសេសចូលរួមនិងជួយសកម្មភាពកាតូលិក។ អស់លោកអភិបាលក៏ត្រូវលើកស្ទួយ និងជួយគាំទ្រសមាគមដែលមានទិសដៅទៅលោកខាងមុខ ទោះបីគេបញ្ជាក់គោលដៅនេះយ៉ាងចំៗក្តី ឬមិនចំៗក្តី។ សមាគមទាំងនោះ តែងតែខិតខំរស់នៅកាន់តែពេញលក្ខណៈ ឬប្រកាសដំណឹងល្អរបស់ព្រះគ្រីស្តដល់មនុស្សទាំងអស់ ឬផ្សព្វផ្សាយលទ្ធិនៃគ្រីស្តសាសនា ឬធ្វើឲ្យពិធីបុណ្យចម្រើនឡើងជាសាធារណៈ ឬមានគោលដៅខាងសង្គម ឬបំពេញកិច្ចគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងកិច្ចការមនុស្សធម៌។ល។ និង។ល។

កិច្ចការជាគ្រីស្តទូតទាំងប៉ុន្មាន ត្រូវសមស្របយ៉ាងច្បាស់តាមតម្រូវការនាបច្ចុប្បន្នកាល មិនត្រឹមតែដោយគិតគូរដល់សភាពការណ៍ខាងវិញ្ញាណ និងខាងសីលធម៌ប៉ុណ្ណោះទេ តែត្រូវគិតគូរដល់សភាពការណ៍ក្នុងសង្គម និងដល់សភាពការណ៍នៃប្រជាសាស្ត្រ ហើយនិងសភាពការណ៍សេដ្ឋកិច្ចទៀតផង។ ត្រូវប្រើសេចក្តីរាយការណ៍របស់អ្នកជំនាញការខាងសង្គមវិទ្យាណែនាំ និងខាងសង្គមសាស្ត្រសាសនា ដែលអាចជួយយ៉ាងសកម្មឲ្យស្គាល់តម្រូវការតាមរបៀប ដែល

មានប្រយោជន៍។ ហេតុនេះ មហាសន្និបាតទូន្មានយ៉ាងខ្លាំងឲ្យធ្វើអង្កេតទាំងនោះ។

### ១៨-អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ស្រឡាញ់ក្រុមពិសេសខ្លះ

អស់លោកអភិបាលត្រូវយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះក្រុមគ្រីស្តបរិស័ទខ្លះ ដែលរស់នៅតាមសភាពការណ៍មួយ ដែលបណ្តាលឲ្យលោកគង្វាល ទទួលខុសត្រូវលើសហគមន៍នានា មិនអាចបម្រើគេជាធម្មតាទូទៅឲ្យបានគ្រប់គ្រាន់ទេ ឬមិនអាចបម្រើគេទាល់តែសោះ គឺមានអន្តោប្រវេសន៍ថ្មីៗ ជនដែលត្រូវគេនិរទេស ជនភៀសខ្លួន ពួកនាវិក និងអ្នកបើកយន្តហោះ ពនេចរ និងក្រុមមនុស្សប្រភេទដូចគ្នា។ អភិបាលត្រូវជួយពង្រីកវិធីឃ្វាលណែនាំគ្រីស្តបរិស័ទយ៉ាងស្របតាមសភាពការណ៍ ដើម្បីជួយគាំទ្រជីវិតខាងវិញ្ញាណ របស់អស់អ្នកដែលទៅកាន់ប្រទេសដទៃមួយរយៈពេល ដើម្បីលំហែកាយ។

ក្រុមអភិបាល ជាពិសេសក្រុមអភិបាលតាមប្រទេសនីមួយៗ ត្រូវសិក្សាយ៉ាងហ្មត់ចត់នូវបញ្ហាជាបន្ទាន់ជាង គេដែលពាក់ព័ន្ធនឹងក្រុមគ្រីស្តបរិស័ទទាំងនោះ។ ត្រូវផ្គត់ផ្គង់ថែទាំគ្រីស្តបរិស័ទទាំងនោះតាមផ្លូវវិញ្ញាណ ស្របតាមអស់លោកអាចធ្វើបាន ដោយប្រើវិធីនិងស្ថាប័នស្របតាមតម្រូវការរបស់គេ និងដោយគ្រីស្តបរិស័ទខិតខំប្រឹងប្រែងទាំងអស់គ្នា។ ក្នុងករណីនេះ ត្រូវនឹកគិតដល់សេចក្តីណែនាំនិងវិន័យដែលអាសនៈនៃគ្រីស្តទូតសិលាបានចាត់ចែងរួចហើយ ឬដែលអាសនៈនៃគ្រីស្តទូតសិលាត្រូវចាត់ចែងនៅពេលខាងមុខទៀតផង។ ប៉ុន្តែ ត្រូវសម្រួលសេចក្តីណែនាំនិងវិន័យទាំងនោះ ស្របតាមសភាពការណ៍នៃកាលៈទេសៈនៃទីកន្លែង និងរបស់មនុស្សទៀតដែរ។

### ១៩-អស់លោកអភិបាលមានសេរីភាព និងទំនាក់ទំនងរបស់អស់លោកជាមួយរដ្ឋអំណាច

អស់លោកអភិបាលមានសេរីភាពពេញទី និងពេញលក្ខណៈ មិនចំណុះនឹងរដ្ឋអំណាចណាមួយឡើយ ដើម្បីឲ្យអស់លោកអាចបំពេញមុខងារបម្រើរបស់ខ្លួនជាគ្រីស្តទូតបាន ដែលមានទិសដៅសង្គ្រោះវិញ្ញាណមនុស្ស។ ហេតុនេះ គ្មាននរណាមានសិទ្ធិឃាត់អស់លោកដោយចំៗក្តី ឬដោយបញ្ឆិតបញ្ឆៀងក្តី មិនឲ្យបំពេញមុខងាររបស់ខ្លួនក្នុងព្រះសហគមន៍ ឬហាមអស់លោកមិនឲ្យទាក់ទងជាមួយអាសនៈរបស់គ្រីស្តទូតសិលាដោយសេរី ឬជាមួយអំណាចឯទៀតៗ ក្នុងព្រះសហគមន៍ ឬជាមួយអ្នកដែលនៅក្រោមបញ្ជារបស់អស់លោកទៀតផង។

តាមពិត ដោយអស់លោកយកចិត្តទុកដាក់ថែរក្សាហ្វូងរបស់ខ្លួនតាមវិញ្ញាណ អស់លោកក៏ជួយឲ្យសង្គមចម្រើនឡើង និងឲ្យមនុស្សបានសុភមង្គលដែរ គឺអស់លោកប្រើអំណាចផ្ទាល់តាមបន្ទុករបស់ខ្លួន និងសមនឹងឋានៈរបស់ខ្លួនជាអភិបាល ក៏រួមសហការជាមួយរដ្ឋអំណាចក្នុងគោលបំណងឲ្យសង្គមចម្រើនឡើង គឺអស់លោកទូន្មានឲ្យគ្រីស្តបរិស័ទប្រតិបត្តិតាមច្បាប់ដ៏ត្រឹមត្រូវ និងគោរពរដ្ឋអំណាចតែងតាំងស្របតាមច្បាប់។

### ២០-សេរីភាពក្នុងការតែងតាំងអភិបាល

ព្រះគ្រីស្តជាអម្ចាស់តែងតាំងអស់លោកអភិបាលឲ្យមានបន្ទុកជាគ្រីស្តទូត អស់លោកក៏មានគោលដៅខាងវិញ្ញាណជាទិសដៅនៅលោកខាងមុខ។ ហេតុនេះ មហាសន្និបាតសកលដ៏វិសុទ្ធនេះប្រកាសថា មានតែអំណាច ដែលមានសមត្ថកិច្ចក្នុងព្រះសហគមន៍ប៉ុណ្ណោះទេ មានសិទ្ធិតែងតាំងអភិបាលបាន។ សិទ្ធិនោះ ជាសិទ្ធិផ្ទាល់របស់អំណាច ដែលមានសមត្ថកិច្ចក្នុងព្រះសហគមន៍ គ្មាននរណាមានសិទ្ធិនោះទាល់តែសោះ។

ហេតុនេះហើយ បានជាមហាសន្និបាតមានបំណងប្រាថ្នាថា នៅពេលអនាគត កុំបណ្តោយឲ្យរដ្ឋអំណាចមានសិទ្ធិ ឬឯកសិទ្ធិជ្រើសរើស ឬតែងតាំង ឬបង្ហាញឈ្មោះ ឬដាក់ឈ្មោះនរណា ឲ្យទទួលបន្ទុកជាអភិបាលឡើយ។ ធ្វើដូច្នេះ មហាសន្និបាត ការពារសិទ្ធិសេរីភាពរបស់ព្រះសហគមន៍យ៉ាងត្រឹមត្រូវ និងជួយជាប្រយោជន៍ដល់គ្រីស្តបរិស័ទស្របតាមជំនឿ និងងាយស្រួលប្រតិបត្តិ។ មហាសន្និបាតទទួលស្គាល់វិធានការរបស់រដ្ឋអំណាចខ្លះចំពោះព្រះសហគមន៍ និងរាប់រកវិធានការទាំងនោះទុកជាមានតម្លៃ ទាំងអរគុណផង។ ប៉ុន្តែ មហាសន្និបាតសូមជម្រាប រដ្ឋអំណាចដោយគោរពជាទីបំផុតថា សូមឲ្យរដ្ឋអំណាចទាំងនោះ លែងទាមទារសិទ្ធិ និងឯកសិទ្ធិដែលខ្លួនមានតាមកិច្ចព្រមព្រៀង ឬតាមប្រពៃណីស្រុកទេស សូមលះបង់សិទ្ធិ និងឯកសិទ្ធិទាំងនោះ ដោយខ្លួនឯងក៏បាន ឬដោយធ្វើកិច្ចព្រមព្រៀងជាមួយសន្តៈ អាសនៈក៏បានដែរ។

## ២១-ការលាលែងបន្ទុកជាអភិបាល

បន្ទុករបស់អភិបាលជាគង្វាល មានសារៈសំខាន់យ៉ាងខ្លាំងណាស់ និងធ្ងន់ធ្ងរជាទីបំផុត។ ហេតុនេះ ប្រសិនបើអស់លោកអភិបាលភូមិភាគ និងអភិបាលឯទៀតៗដែលនៅក្រោមសេចក្តីចាត់ចែងនៃក្បួនច្បាប់ដដែលនោះ មិនសូវមានលទ្ធភាពបំពេញបន្ទុករបស់ខ្លួនតទៅទៀតបាន ព្រោះអស់លោកមានវ័យចាស់ជរា ឬដោយមូលហេតុផ្សេងៗដ៏ធ្ងន់ធ្ងរ មហាសន្និបាត សុំឲ្យលោកលាលែងការងាររបស់ខ្លួនដោយខ្លួនឯង ឬដោយអំណាច ដែលមានសមត្ថកិច្ច អញ្ជើញលោកឲ្យលាលែង។ ប្រសិនបើអំណាច ដែលមានសមត្ថកិច្ចសុខចិត្តទទួលការលាលែងការងារ អំណាចនោះ ក៏ត្រូវយកចិត្តទុកដាក់ធានា ឲ្យអស់លោកដែលលាលែងការងារបានជីវភាពយ៉ាងសមគួរ និងទទួលស្គាល់សិទ្ធិពិសេសរបស់អស់លោកទៀតផង។

# ២-ការកំណត់ព្រំដែនភូមិភាគ

## ២២-ត្រូវកែសម្រួលព្រំដែនភូមិភាគ

ភូមិភាគអាចបំពេញគោលដៅរបស់ខ្លួនបាន ទីមួយ លុះត្រាតែគេឃើញយ៉ាងច្បាស់ថា ភូមិភាគនោះ មានលក្ខណៈជាព្រះសហគមន៍ គឺជាចំណែកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ទីពីរ លុះត្រាតែអភិបាលទាំងប៉ុន្មានអាចបំពេញបន្ទុកនានារបស់ខ្លួនជាគង្វាលយ៉ាងសកម្មបាន។ ទីបី លុះត្រាតែលោកអភិបាលអាចជួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ឲ្យទៅកាន់ការសង្គ្រោះបាន តាមរបៀបកាន់តែល្អប្រសើរឡើងៗ។

ហេតុនេះហើយ បានជាត្រូវកំណត់ព្រំដែនភូមិភាគយ៉ាងសមគួរ ហើយក៏ត្រូវគិតគូរអំពីការចែកចាយអស់ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង និងធនធាននានាយ៉ាងសមរម្យ ស្របតាមតម្រូវការនៃកិច្ចការជាគ្រីស្តទូត។ ការណ៍ទាំងនោះ មិនគ្រាន់តែបម្រើប្រយោជន៍របស់អស់ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង និងគ្រីស្តបរិស័ទឯទៀតៗប៉ុណ្ណោះទេ តែបម្រើប្រយោជន៍របស់ព្រះសហគមន៍កាតូលិកទាំងមូលទៀតផង។

ហេតុនេះ មហាសន្និបាតសម្រេចថា ត្រូវកែសម្រួលព្រំដែនភូមិភាគ ឲ្យបានត្រឹមត្រូវដោយប្រុងប្រយ័ត្ន និងនៅពេលឆាប់ៗខាងមុខនេះ តាមតែប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទទាមទារឲ្យកែសម្រួល។ ជូនកាលត្រូវចែកភូមិភាគ ជូនកាលត្រូវបំបែកភូមិភាគ ជូនកាលត្រូវបង្រួបបង្រួមភូមិភាគខ្លះឲ្យទៅជាភូមិភាគតែមួយ ជូនកាលត្រូវកែសម្រួលព្រំដែន ឬត្រូវតែងតាំងអាសនៈរបស់លោកអភិបាលនៅកន្លែងស្រួល។ ក្នុងភូមិភាគ ខ្លះដែលមានក្រុងធំៗត្រូវចាត់ចែងផ្ទៃក្នុងតាមរបៀបថ្មី។

## ២៣-សេចក្ដីណែនាំក្នុងករណីកំណត់ព្រំដែនភូមិភាគ

ពេលកែសម្រួលព្រំដែនភូមិភាគ ត្រូវធានាឲ្យបុគ្គលទាំងអស់ ការិយាល័យនិងស្ថាប័នទាំងប៉ុន្មាន អាចរួបរួមផ្ទៃក្នុង ដូចជារូបកាយដែលមានជីវិតរស់រវើក។ នេះជាការសំខាន់ជាងគេ។ ក្នុងករណីនីមួយៗ ត្រូវពិនិត្យមើលសភាពការណ៍ទាំងអស់យ៉ាងហ្មត់ចត់សិន ទើបសូមគិតដល់សេចក្ដីទូទៅដូចតទៅ៖

ក- ក្នុងការកំណត់ព្រំដែនភូមិភាគ ប្រសិនបើអាចធ្វើបាន ត្រូវគិតគូរដល់ក្រុមផ្សេងៗនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ការគិតគូរដល់ក្រុមទាំងនោះ អាចជួយលោកអភិបាលយ៉ាងខ្លាំងឲ្យបំពេញបន្ទុកជាគង្វាលយ៉ាងល្អប្រសើរ។ នៅពេលជាមួយគ្នានេះ ប្រសិនបើអាចធ្វើបាន ត្រូវយកចិត្តទុកដាក់រកទុកប្រជុំជន នៃប្រជារាស្ត្រនេះ នៅរួបរួមជាមួយការិយាល័យរដ្ឋការ និងស្ថាប័នក្នុងសង្គម ដែលសុទ្ធតែជារចនាសម្ព័ន្ធផ្ទៃក្នុងនៃប្រជុំជនទាំងនោះ។ ហេតុនេះ ដែនដីនៃភូមិភាគនីមួយៗត្រូវជាប់ជាមួយគ្នា មិនត្រូវមានតំបន់ផ្សេងៗដាច់ពីគ្នាៗឡើយ។

ជួនកាលត្រូវយកចិត្តទុកដាក់នឹងព្រំដែនតំបន់រដ្ឋការ និងគិតគូរដល់សភាពការណ៍ពិសេសរបស់បុគ្គលនានា ឬរបស់តំបន់នីមួយៗ គឺត្រូវគិតគូរដល់ចិត្តសាស្ត្រ ដល់សេដ្ឋកិច្ច ដល់ភូមិសាស្ត្រ និងដល់ប្រវត្តិសាស្ត្រ។

ខ- តាមធម្មតា ទំហំភូមិភាគ ឬចំនួនមនុស្សរស់នៅក្នុងភូមិភាគ ត្រូវស្របតាមសេចក្ដីសំខាន់ពីរខាងក្រោមនេះ ទីមួយ ទោះបីមានគង្វាល ជួយលោកអភិបាលក៏ដោយ លោកអភិបាលត្រូវមានសមត្ថភាពធ្វើពិធីដោយខ្លួនលោកផ្ទាល់ក្នុងឋានៈជាអភិបាល និងធ្វើទស្សនកិច្ចយ៉ាងស្រួលក្នុងឋានៈជាគង្វាល ហើយណែនាំនិងចាត់ចែងកិច្ចការជាគ្រីស្តទូតទាំងប៉ុន្មាន ក្នុងភូមិភាគយ៉ាងត្រឹមត្រូវ ជាពិសេសលោកត្រូវស្គាល់អស់លោកគង្វាលបព្វជិត បព្វជិតា និងគ្រីស្តបរិស័ទធម្មតាដែលទទួលចំណែករួមក្នុងកិច្ចការនានានៃភូមិភាគ។ ទីពីរ ភូមិភាគត្រូវធំទូលាយល្មមនិងគួរសម ដើម្បីឲ្យលោកអភិបាល និងក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំងអាចប្រើកម្លាំងកាយកម្លាំងចិត្ត បំពេញមុខងារបម្រើរបស់ខ្លួនយ៉ាងល្អ ទាំងមិនដែលបំភ្លេចតម្រូវការនៃព្រះសហគមន៍សកលទាំងមូលផង។

គ- មិនតែប៉ុណ្ណោះ លោកអភិបាលត្រូវមានសមត្ថភាព អាចបំពេញមុខងារបម្រើការសង្គ្រោះក្នុងភូមិភាគ តាមរបៀបស្របនឹងសភាពការណ៍។ ហេតុនេះ ត្រូវកាន់តាមគោលការណ៍ទាំងប៉ុន្មានខាងក្រោមនេះ៖

- ក្នុងភូមិភាគនីមួយៗ ត្រូវមានចំនួនអ្នកទទួលអគ្គសញ្ញាតែងតាំងឲ្យបានគ្រប់គ្រាន់ និងត្រូវឲ្យលោកទាំងនោះមានគុណសម្បត្តិល្អដែរ ដើម្បីឃ្វាលប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមរបៀបដែលត្រូវឃ្វាល។
- ត្រូវមានការិយាល័យបម្រើស្ថាប័ននិងអង្គការផ្ទាល់របស់ព្រះសហគមន៍ដោយឡែក គឺការិយាល័យស្ថាប័ន និងអង្គការដែលមានសារៈសំខាន់ជាចាំបាច់ ដើម្បីគ្រប់គ្រងភូមិភាគយ៉ាងល្អ និងសម្រាប់បំពេញកិច្ចការជាគ្រីស្តទូត។
- ភូមិភាគត្រូវមានធនធានដែលត្រូវការដើម្បីផ្គត់ផ្គង់បុគ្គលិក និងស្ថាប័នទាំងប៉ុន្មានរបស់ខ្លួន គឺយ៉ាងហោចណាស់ ត្រូវប្រុងប្រយ័ត្នចាត់ចែងអ្វីៗកុំឲ្យភូមិភាគខ្វះធនធានទាំងនោះនៅពេលអនាគត។

នៅតំបន់ណាដែលមានគ្រីស្តបរិស័ទ កាន់តាមរបៀបរបបពិធីប្លែកៗពីគ្នា អភិបាលភូមិភាគត្រូវបំពេញតម្រូវការខាងវិញ្ញាណរបស់គេ។ ត្រូវប្រើវិធីផ្សេងៗដូចតទៅ៖

- ត្រូវចាត់ចែងឲ្យមានគង្វាល ឬចាត់ចែងឲ្យមានសហគមន៍ ដែលកាន់តាមរបៀបរបបពិធីតែមួយដូចគ្នានោះ។
- ឬត្រូវតែងតាំងតំណាងអភិបាលម្នាក់ប្រកប ដោយអំណាចគ្រប់គ្រាន់។ ប្រសិនបើត្រូវការ តំណាងនេះ អាចទទួលអគ្គសញ្ញាតែងតាំងជាអភិបាលបាន។
- ឬលោកអភិបាលផ្ទាល់បំពេញមុខងារជាអភិបាលលើក្រុមទាំងនោះ ដែលកាន់តាមរបៀបរបបពិធីប្លែកៗពីគ្នាក៏បានដែរ។
- ប្រសិនបើមានមូលហេតុពិសេសបណ្ដាលឲ្យកិច្ចការទាំងអស់ខាងលើនេះ មិនអាចធ្វើទៅបានទេ តាមការវិនិច្ឆ័យរបស់សន្ដអាសនៈ ត្រូវតែងតាំងអភិបាលម្នាក់សម្រាប់ណែនាំក្រុមគ្រីស្ដបរិស័ទ ដែលកាន់តាមរបៀបរបបពិធីនីមួយៗ (បូព៌ា ៤)។

ក្នុងសភាពការណ៍ស្រដៀងនឹងសភាពការណ៍ខាងលើនោះ ត្រូវផ្គត់ផ្គង់តម្រូវការខាងវិញ្ញាណរបស់គ្រីស្ដបរិស័ទ ដែលនិយាយភាសាផ្សេងដោយប្រើវិធីដូចតទៅ៖ ត្រូវចាត់ចែងឲ្យមានគង្វាល ឬចាត់ចែងឲ្យមានសហគមន៍ដែលនិយាយភាសានោះ ឬត្រូវចាត់ចែងឲ្យមានតំណាងអភិបាលម្នាក់ ដែលចេះនិយាយភាសានោះយ៉ាងជ្រៅ ឬតំណាងអភិបាលនេះត្រូវទទួលអគ្គសញ្ញាតែងតាំងជាអភិបាល ឬម៉្យាងទៀត ត្រូវប្រើវិធីផ្សេងទៀតស្របតាមសភាពការណ៍នោះឲ្យបានស្រួល។

## ២៤-ត្រូវសូមឲ្យក្រុមអភិបាលបោះឆ្នោត

ព្រះសហគមន៍ខាងបូព៌ាប្រទេសកាន់ក្បួនវិន័យដោយខ្លួន។ ក្នុងករណីកែសម្រួលព្រំដែនភូមិភាគ ឬបង្កើតអ្វីជាថ្មីតាមលេខ ២២-២៣ ខាងលើនេះ ក្រុមអភិបាលដែលមានសមត្ថកិច្ច ត្រូវពិនិត្យមើលរឿងទាំងនោះ តាមតំបន់រៀងៗខ្លួន។ប្រសិនបើក្រុមអភិបាលយល់ឃើញថា ការកែសម្រួលព្រំដែនភូមិភាគមានប្រយោជន៍មែន ត្រូវបង្កើតគណៈកម្មាធិការពិសេសរបស់ក្រុមអភិបាល។ ប៉ុន្ដែក្នុងករណីនេះ ត្រូវស្ដាប់យោបល់ជាអាទិ៍របស់អភិបាលនៃតំបន់ ឬនៃដែនដី ដែលពាក់ព័ន្ធនឹងរឿងនោះ។ ក្រោយមក ក្រុមអភិបាលត្រូវផ្ដល់យោបល់ និងសេចក្ដីប៉ងប្រាថ្នារបស់ខ្លួន គោរពជម្រាបជូនដល់អាសនៈរបស់គ្រីស្ដទូតសិលា។

## ៣-សហការីរបស់អភិបាលភូមិភាគ ក្នុងកិច្ចបំពេញបន្ទុកជាគង្វាល

### ក-អភិបាលរងនិងអគបាលជាឧបការី

## ២៥-សេចក្ដីណែនាំដើម្បីតែងតាំងអភិបាលរង និងអភិបាលឧបការី

ក្នុងកិច្ចគ្រប់គ្រងភូមិភាគ ត្រូវផ្ញើបន្ទុកជាគង្វាលរបស់លោកអភិបាល ដោយគិតគូរដល់ប្រយោជន៍ហ្វូងរបស់ព្រះអម្ចាស់ជានិច្ច។ នេះគឺជាគោលសំខាន់ដ៏ខ្ពង់ខ្ពស់ជាងគេបំផុត។ ប្រសិនបើអភិបាលភូមិភាគគ្មានសមត្ថភាពបំពេញមុខងារទាំងប៉ុន្មានរបស់ខ្លួនដោយផ្ទាល់បាន ព្រោះភូមិភាគមានទំហំធំពេក ឬព្រោះប្រជាជនមានចំនួនច្រើនពេក ឬព្រោះសភាពការណ៍ពិសេសនៃកិច្ចការជាគ្រីស្ដទូត ឬព្រោះមូលហេតុផ្សេងៗទៀត ត្រូវតែងតាំងអភិបាលរងម្នាក់។ ធ្វើដូច្នេះទើបលោកអភិបាលអាចផ្គត់ផ្គង់ដល់ប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្ដបរិស័ទ ក្នុងភូមិភាគតាមតម្រូវការរបស់គេបាន។ លើសពីនេះទៅទៀត ប្រសិនបើមានតម្រូវការពិសេស ត្រូវតែងតាំងអភិបាលឧបការីម្នាក់ដើម្បីជួយអភិបាលក្នុងភូមិភាគ។

ត្រូវផ្ដល់ឲ្យអភិបាលរងនិងអភិបាលឧបការីមានអំណាចគ្រប់គ្រាន់ ដើម្បីឲ្យអស់លោកអាចបំពេញកិច្ចការរបស់ខ្លួនបានដោយប្រសិទ្ធភាព និងរក្សាកិត្តិយសនៃឋានៈរបស់លោកជាអភិបាលទៀតផង។ ប៉ុន្តែ ត្រូវនៅតែគ្រប់គ្រងភូមិភាគរួបរួមគ្នា និងត្រូវគោរពអំណាចអភិបាលភូមិភាគជានិច្ច។

លើសពីនេះទៅទៀត ព្រះសហគមន៍ត្រាស់ហៅអភិបាលរង និងអភិបាលឧបការីឲ្យចែករំលែកកិច្ចការរបស់អភិបាលភូមិភាគ។ ហេតុនេះ អភិបាលរង និងអភិបាលឧបការីត្រូវបំពេញបន្ទុករបស់ខ្លួន ដោយសម្រេចកិច្ចការទាំងអស់រួបរួមជាមួយអភិបាលភូមិភាគ ដោយមានចិត្តថ្លើមតែមួយ។ អភិបាលរង និងអភិបាលឧបការីត្រូវសុខចិត្តស្ថិតនៅក្រោមអំណាចអភិបាលភូមិភាគនិងគោរពលោកជានិច្ច។ រីឯអភិបាលភូមិភាគវិញ លោកត្រូវស្រឡាញ់អភិបាលរង និងអភិបាលឧបការីទុកជាបងប្អូន និងត្រូវរាប់អស់លោកទាំងនោះទុកជាអ្នកមានតម្លៃទៀតផង។

## ២៦-អំណាចអភិបាលរង និងអភិបាលឧបការី

ប្រសិនបើប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទទាមទារ អភិបាលភូមិភាគមិនត្រូវរួញរាសុំឲ្យអំណាច ដែលមានសមត្ថកិច្ចតែងតាំងអភិបាលរងម្នាក់ ឬច្រើននាក់។ អភិបាលរង គឺជាអភិបាលតែងតាំង សម្រាប់ជួយភូមិភាគមួយ ប៉ុន្តែ នៅពេលលអភិបាលភូមិភាគ លែងបំពេញមុខងាររបស់ខ្លួន អភិបាលរងគ្មានសិទ្ធិបន្តមុខងារ ធ្វើជាអភិបាលនៃភូមិភាគនោះបានឡើយ។ ប្រសិនបើលិខិតតែងតាំងអភិបាលរងមិនបញ្ជាក់សេចក្ដីនេះទេ អភិបាលភូមិភាគ ត្រូវតែងតាំងអភិបាលរងម្នាក់ ឬច្រើននាក់ជាតំណាងពេញសិទ្ធិរបស់ខ្លួន ឬយ៉ាងហោចណាស់ តែងតាំងលោក ឬអស់លោកជាតំណាងអភិបាល ដែលចុះចូលក្រោមអំណាចរបស់លោកអភិបាលតែម្នាក់គត់។ សូមឲ្យលោកអភិបាល សួរយោបល់អភិបាលរងទាំងនោះ ក្នុងករណីដ៏សំខាន់ៗ ជាពិសេសក្នុងករណីដែលមានលក្ខណៈឃ្វាលណែនាំគ្រីស្តបរិស័ទ។ អំណាចនិងឯកសិទ្ធិរបស់អភិបាលរងតាមក្បួនច្បាប់រួមនៃព្រះសហគមន៍ មិនផុតនៅពេលអភិបាលភូមិភាគឈប់បំពេញបន្ទុករបស់ខ្លួនទេ លើកលែងតែអំណាចដែលមានសមត្ថកិច្ចបានសម្រេចតាមរបៀបផ្សេង។ ប្រសិនបើ គ្មានអភិបាលណែនាំភូមិភាគទេ គួរផ្ញើបន្ទុកគ្រប់គ្រងភូមិភាគឲ្យអភិបាលរង ឬប្រសិនបើមានអភិបាលរងច្រើន ឲ្យអភិបាលរងម្នាក់គ្រប់គ្រង លើកលែងតែ មានមូលហេតុដ៏សំខាន់ៗបណ្ដាលឲ្យប្រព្រឹត្តតាមរបៀបផ្សេង។

អភិបាលឧបការី គឺជាអភិបាលតែងតាំងដោយមានសិទ្ធិបន្តមុខងារអភិបាលភូមិភាគ។ អភិបាលភូមិភាគត្រូវតែងតាំងអភិបាលឧបការីទុកជាតំណាងពេញសិទ្ធិរបស់ខ្លួនជានិច្ច។ ក្នុងករណីពិសេស អំណាចដែលមានសមត្ថកិច្ចអាចផ្ដល់សិទ្ធិទូលំទូលាយជាងទៅទៀតបានផង។

អភិបាលដែលមានឧបការី និងអភិបាលឧបការីផ្ទាល់ ត្រូវតែពិគ្រោះគ្នាទៅវិញទៅ មកអំពីបញ្ហាដ៏សំខាន់ៗ ដើម្បីជាប្រយោជន៍នាពេលបច្ចុប្បន្ន និងនៅពេលអនាគតនៃភូមិភាគដែរ។

## ខ-រដ្ឋបាល និងក្រុមប្រឹក្សាភូមិភាគ

## ២៧-ការចាត់ចែងរដ្ឋបាល និងការបង្កើតក្រុមប្រឹក្សាគង្វាលណែនាំ

ក្នុងរដ្ឋបាលភូមិភាគ គឺតំណាងពេញសិទ្ធិមានមុខងារសំខាន់ជាងគេ។ ប៉ុន្តែ ពេលណាការគ្រប់គ្រងរបស់ភូមិភាគទាមទារនោះ លោកអភិបាលមានសិទ្ធិអាចតែងតាំងតំណាងអភិបាលម្នាក់ ឬច្រើននាក់។ តំណាងអភិបាលទាំងនោះមានអំណាចទាំងប៉ុន្មានរបស់តំណាងពេញសិទ្ធិ តាមក្បួនច្បាប់រួមនៃព្រះសហគមន៍ លើផ្នែកមួយនៃភូមិភាគ ឬលើករណី

ពិសេសខ្លះ ឬលើគ្រីស្តបរិស័ទនៃរបៀបរបបពីធីដោយឡែកមួយក្រុម។

ក្នុងចំណោមសហការីរបស់លោកអភិបាលក្នុងកិច្ចគ្រប់គ្រងភូមិភាគ មានអស់លោកគង្វាល ដែលចូលក្នុងក្រុមប្រឹក្សា ដែលជាព្រឹទ្ធសភារបស់លោកអភិបាល មានក្រុមព្រះវិហារវិសាល មានក្រុមជំនាញការ និងក្រុមផ្សេងៗ ស្រេចតែសភាពការណ៍និងកន្លែងផ្សេងៗ។ ត្រូវចាត់ចែងស្ថាប័នទាំងនោះ ជាពិសេសក្រុមព្រះវិហារវិសាល តាមរបៀបថ្មី ស្របតាមតម្រូវការនាបច្ចុប្បន្នកាល។

អស់លោកគង្វាល និងគ្រីស្តបរិស័ទធម្មតា ដែលជាសមាជិកនៃរដ្ឋបាលភូមិភាគ ត្រូវដឹងច្បាស់ថា អស់លោកអ្នកបំពេញមុខងារបម្រើរួមជាមួយលោកអភិបាលជាគង្វាលណែនាំ។ ត្រូវចាត់ចែងរដ្ឋបាលភូមិភាគ ដើម្បីឲ្យបានទៅជាឧបករណ៍មួយ មិនគ្រាន់តែសម្រាប់ជួយគ្រប់គ្រងភូមិភាគប៉ុណ្ណោះទេ តែសម្រាប់បំពេញកិច្ចការនានា ជាគ្រីស្តទូតថែមទៀតផង។

ក្នុងភូមិភាគនីមួយៗ គួរតែតែងតាំងក្រុមប្រឹក្សាគង្វាលណែនាំពិសេស ដោយមានលោកអភិបាលភូមិភាគផ្ទាល់ជាប្រធាន។ មានក្រុមលោកគង្វាល បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតាដែលអភិបាលបានជ្រើសរើសយ៉ាងពិសេសចូលក្នុងក្រុមប្រឹក្សាណែនាំនោះ។ ក្រុមប្រឹក្សាណែនាំមានភារកិច្ចស្វែងរកអ្វីៗ ដែលពាក់ព័ន្ធនឹងការងារឃ្វាលណែនាំគ្រីស្តបរិស័ទ ពិនិត្យមើលអ្វីៗទាំងនោះ និងចែងសេចក្តីសម្រេចសម្រាប់ឲ្យគេអនុវត្តតាម។

## គ-ក្រុមអស់លោកគង្វាលភូមិភាគ

### ២៨-ក្រុមអស់លោកគង្វាល ភូមិភាគ

លោកគង្វាលទាំងអស់ ទោះជាគង្វាលភូមិភាគក្តី គង្វាលបព្វជិតក្តី ទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យតែមួយ រួមជាមួយលោកអភិបាល ហើយអស់លោកក៏បំពេញមុខងារជាបូជាចារ្យនេះរួមជាមួយលោកដែរ។ ហេតុនេះហើយ បានជាអស់លោកជាសហការីដ៏ឈ្លាសវៃនៃក្រុមអភិបាល។ អស់លោកគង្វាល ភូមិភាគមានមុខងារសំខាន់ជាងគេក្នុងកិច្ចថែរក្សាវិញ្ញាណមនុស្ស ព្រោះអស់លោកភ្ជាប់ក្នុងបញ្ជីក្រុមបូជាចារ្យភូមិភាគមួយ ឬជាប់នឹងព្រះសហគមន៍ដោយឡែកមួយ។ អស់លោកសុខចិត្តប្តូរជាកម្លាំងកាយ កម្លាំងចិត្តបម្រើព្រះសហគមន៍ដោយឡែកនោះ ដើម្បីឃ្វាលថែរក្សាចំណែកនៃហ្វូងរបស់ព្រះអម្ចាស់តែមួយទាំងអស់គ្នា។ ហេតុនេះហើយ បានជាអស់លោករួមគ្នាជាក្រុមលោកគង្វាលតែមួយ ជាក្រុមគ្រួសារតែមួយដែលមានលោកអភិបាលជាឪពុក។ លោកអភិបាលត្រូវមានសេរីភាពតាមតម្រូវការ ក្នុងការប្រមូលពន្ធដារនិងកម្រៃ ដើម្បីចែកចាយមុខងារផ្សេងៗឲ្យអស់លោកគង្វាលរបស់លោកយ៉ាងសមគួរ និងតាមយុត្តិធម៌។ ហេតុនេះហើយ ត្រូវលប់បំបាត់សិទ្ធិ និងឯកសិទ្ធិទាំងប៉ុន្មាន ទោះជាតាមរបៀបណាក៏ដោយដែលរារាំងសេរីភាពនោះ។

លោកអភិបាលនិងអស់លោកគង្វាល ត្រូវមានចំណងទំនាក់ទំនងគ្នា ដោយសេចក្តីស្រឡាញ់មកពីព្រះវិញ្ញាណ។ ដូច្នេះ បំណងប្រាថ្នារបស់អស់គង្វាល បានឯកភាពជាមួយបំណងប្រាថ្នារបស់លោកអភិបាលបណ្តាលឲ្យកិច្ចការណែនាំគ្រីស្តបរិស័ទបានផលផ្លែកាន់តែច្រើនឡើងៗ។ សូមឲ្យលោកអភិបាល យកចិត្តទុកដាក់លើកស្ទួយកិច្ចបម្រើវិញ្ញាណរបស់មនុស្សឲ្យកាន់តែច្រើនឡើងៗ និងអញ្ជើញគង្វាលឲ្យនិយាយសន្ទនាជាមួយលោក ព្រមទាំងនិយាយសន្ទនា រួមជាមួយលោកគង្វាលឯទៀតៗផង។ កិច្ចសន្ទនានោះ ត្រូវស្តីអំពីការណែនាំគ្រីស្តបរិស័ទជាដើម។ មិនត្រូវនិយាយសន្ទនា

ដូច្នេះ តែក្នុងពេលមានឱកាសដោយចៃដន្យប៉ុណ្ណោះទេ តែត្រូវនិយាយសន្ទនាតាមពេលកំណត់ថែមទៀតផង ប្រសិនបើអាចធ្វើបាន។

លើសពីនេះទៅទៀត សូមឲ្យគង្វាលទាំងអស់រួបរួមគ្នាជាចិត្តថ្លើមតែមួយ និងយកចិត្តទុកដាក់នឹងផលប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទក្នុងភូមិភាគទាំងមូល។ អស់លោកគង្វាលត្រូវនឹកចាំថា ទ្រព្យសម្បត្តិដែលអស់លោកប្រមូលបាន ដោយបំពេញការងារក្នុងព្រះសហគមន៍ សុទ្ធតែភ្ជាប់នឹងបន្ទុកដ៏សក្ការៈនោះ។ ហេតុនេះ អស់លោកត្រូវផ្គត់ផ្គង់តម្រូវការជាសម្ភារៈរបស់ភូមិភាគ ដោយចិត្តទូលំទូលាយ តាមធនធានរបស់ខ្លួន ស្របតាមសេចក្តីចាត់ចែងរបស់លោកអភិបាល។

## ២៩-អស់លោកគង្វាលភ្ជាប់ នឹងកិច្ចការអន្តរភូមិភាគ

ក្នុងចំណោមសហការីដ៏ជិតស្និទ្ធជាងគេរបស់លោកអភិបាល លោកផ្ញើបន្ទុកណែនាំ ឬកិច្ចការជាគ្រីស្តទូត ដែលមានលក្ខណៈអន្តរសហគមន៍ឲ្យលោកគង្វាលខ្លះៗ។ អស់លោកប្រព្រឹត្តកិច្ចការជាគ្រីស្តទូតទាំងនោះនៅតំបន់មួយក្នុងភូមិភាគ ឬក្នុងចំណោមក្រុមពិសេសខ្លះរបស់គ្រីស្តបរិស័ទ ឬបំពេញកិច្ចការពិសេសម្យ៉ាងផ្សេងទៀត។

លោកអភិបាល ក៏ផ្ញើបន្ទុកជាកិច្ចការគ្រីស្តទូតឲ្យគង្វាលខ្លះ គឺក្នុងសាលារៀន ក្នុងស្ថាប័នឯទៀតៗ និងក្នុងសមាគមនានា។ លោកទាំងនោះ តែងតែជួយយ៉ាងល្អប្រសើរ។ គួរឲ្យអភិបាលភូមិភាគយកចិត្តទុកដាក់យ៉ាងពិសេសចំពោះអស់លោកគង្វាល ដែលបំពេញបន្ទុកអន្តរភូមិភាគ ហើយដែលរស់នៅក្នុងភូមិភាគរបស់លោក ព្រោះគង្វាលទាំងនោះ បំពេញកិច្ចការជាគ្រីស្តទូតដែលមានសារៈសំខាន់ខ្លាំងណាស់។

## ៣០-លោកគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ

អស់លោកគង្វាល ដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ជាសហការីពិសេសរបស់លោកអភិបាល។ លោកអភិបាល បានផ្ញើឲ្យគង្វាលទាំងនោះ ថែទាំវិញ្ញាណរបស់គ្រីស្តបរិស័ទ ក្នុងមួយចំណែកនៃភូមិភាគរបស់លោកក្នុងឋានៈជាគង្វាល និងក្រោមអំណាចរបស់លោក។

ក- គង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ រួមជាមួយសហការី បំពេញបេសកកម្មរបស់ខ្លួន គឺមានបន្ទុកបង្រៀន នាំមនុស្សឲ្យបានវិសុទ្ធ ហើយគ្រប់គ្រងគេ។ អស់លោកត្រូវណែនាំគ្រីស្តបរិស័ទ និងព្រះសហគមន៍ឲ្យដឹងខ្លួនថា គេពិតជាសមាជិករបស់ភូមិភាគនិងរបស់ព្រះសហគមន៍សកលទាំងមូល។ ហេតុនេះហើយ បានជាគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ត្រូវរួមសហការជាមួយគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍ឯទៀតៗ ត្រូវរួមសហការជាមួយគង្វាល ដែលបំពេញបន្ទុកជាគង្វាលនៅលើតំបន់នោះ មានតំណាងអភិបាល និងប្រធានក្រុមគង្វាល ជាដើម។ ត្រូវរួមសហការជាមួយគង្វាល ដែលបំពេញកិច្ចការប្រកបដោយលក្ខណៈហួសពីព្រំដែនព្រះសហគមន៍មួយ ដើម្បីឲ្យការណែនាំគ្រីស្តបរិស័ទភូមិភាគទាំងមូលបានឯកភាព និងបានប្រសិទ្ធិភាពទៀតផង។

អស់លោកគង្វាល ត្រូវថែទាំវិញ្ញាណគ្រីស្តបរិស័ទ ដោយមានគោលគំនិតជាសាសនទូតជ្រួតជ្រាបក្នុងខ្លួនជានិច្ច គឺចង់ថែទាំអស់អ្នកដែលរស់នៅក្នុងព្រះសហគមន៍នោះ តាមរបៀបស្របនឹងសភាពការណ៍របស់គេ។ ប្រសិនបើគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយនោះ មិនអាចឈានទៅដល់ក្រុមមនុស្សខ្លះ ត្រូវតែសូមអ្នកឯទៀតៗជួយ

សូម្បីតែគ្រីស្តបរិស័ទធម្មតាក៏អាចជួយក្នុងកិច្ចការជាគ្រីស្តទូតរបស់អស់លោកដែរ។

មហាសន្និបាតទូន្មានយ៉ាងខ្លាំងថា សូមអស់លោកគង្វាល ជាពិសេសអស់លោកដែលរួមទទួលខុសត្រូវលើព្រះសហគមន៍មួយ ត្រូវរួមរស់ជាមួយគ្នា ទើបការថែទាំវិញ្ញាណគ្រីស្តបរិស័ទ ដោយប្រសិទ្ធិភាពយ៉ាងពេញលេញបាន។ ការរួមរស់ជាមួយគ្នានោះជួយអស់លោកក្នុងកិច្ចការជាគ្រីស្តទូត ហើយក៏បង្ហាញគំរូអំពីសេចក្តីស្រឡាញ់ និងអំពីការរួបរួមគ្នាជាធ្លុងតែមួយ ឲ្យគ្រីស្តបរិស័ទឃើញថែមទៀតដែរ។

ខ- អស់លោកគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ត្រូវបំពេញបន្ទុកបង្រៀនរបស់ខ្លួន ដោយធ្វើពិធីអត្ថាធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យគ្រីស្តបរិស័ទទាំងអស់ស្តាប់ ដើម្បីឲ្យគេចម្រើនឡើង ក្នុងអង្គព្រះគ្រីស្ត និងចាក់ឫសក្នុងជំនឿ ក្នុងសេចក្តីសង្ឃឹម និងក្នុងសេចក្តីស្រឡាញ់។ ធ្វើដូច្នេះ ទើបសហគមន៍គ្រីស្តបរិស័ទ អាចផ្តល់សក្ខីភាពដ៏ល្អប្រសើរអំពីសេចក្តីស្រឡាញ់បាន តាមព្រះបញ្ជារបស់ព្រះអម្ចាស់ (យហ ១៣, ៣៥)។ អស់លោកក៏ត្រូវអប់រំជំនឿ គឺណែនាំគ្រីស្តបរិស័ទឲ្យស្គាល់គម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះយ៉ាងច្បាស់ស្របតាមអាយុរបស់គេ។ អស់លោកត្រូវសូមឲ្យគ្រីស្តបរិស័ទធម្មតារួមសហការក្នុងការអប់រំជំនឿ មិនគ្រាន់តែសូមឲ្យបព្វជិតបព្វជិតារួមសហការប៉ុណ្ណោះទេ។ ត្រូវបង្កើតសមាគមអ្នកបង្រៀនលទ្ធិនៃគ្រីស្តសាសនាថែមទៀតផង។

អស់លោកគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ក៏បំពេញបន្ទុកនាំគ្រីស្តបរិស័ទឲ្យបានវិសុទ្ធដែរ។ អស់លោកត្រូវយកចិត្តទុកដាក់ធ្វើឲ្យអភិបូជាទៅជាស្នូល និងទៅជាកំពូលនៃការរស់នៅទាំងមូល របស់សហគមន៍គ្រីស្តបរិស័ទនោះ។ អស់លោកត្រូវខិតខំចែកចាយអាហារខាងវិញ្ញាណដល់គ្រីស្តបរិស័ទរបស់ខ្លួន ដោយណែនាំគេឲ្យទទួលអគ្គសញ្ញាជាញឹកញាប់ទាំងមានចិត្តគោរពប្រណិប័តន៍ ហើយដោយណែនាំគេឲ្យទទួលចំណែកយ៉ាងសកម្ម ក្នុងពិធីគោរពបម្រើព្រះជាម្ចាស់ ទាំងដឹងខ្លួនទៀតផង។ អស់លោកគង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ត្រូវនឹកចងចាំថា អ្នកទទួលអគ្គសញ្ញាលើកលែងទោស ពិតជានឹងបានផលប្រយោជន៍យ៉ាងទូលំទូលាយខាងវិញ្ញាណ គឺគេរស់នៅតាមឋានៈជាគ្រីស្តបរិស័ទកាន់តែប្រសើរឡើងៗ។ ហេតុនេះហើយ បានជាអស់លោកត្រូវសុខចិត្តស្តាប់គ្រីស្តបរិស័ទមកលន់តួ។ ប្រសិនបើមានតម្រូវការ ត្រូវហៅលោកគង្វាលឯទៀតៗ ដែលនិយាយភាសាផ្សេងៗថែមទៀតផង។

អស់គង្វាលដែលទទួលខុសត្រូវថែទាំព្រះសហគមន៍មួយ ត្រូវបំពេញភារកិច្ចជាគង្វាល ដោយយកចិត្តទុកដាក់ស្គាល់ហ្វូងចៀមរបស់ខ្លួន។ អស់លោកជាអ្នកបម្រើរបស់ចៀមទាំងអស់។ ហេតុនេះហើយ បានជាអស់លោកត្រូវខិតខំណែនាំឲ្យគេរស់នៅតាមបែបជាគ្រីស្តបរិស័ទកាន់តែប្រសើរឡើងៗ គឺទាំងគ្រីស្តបរិស័ទម្នាក់ៗ ទាំងក្រុមក្រុមគ្រួសារ សមាគមនានា ជាពិសេសមាគមនៃកិច្ចការជាគ្រីស្តទូត នឹងព្រះសហគមន៍ទាំងមូលរបស់ខ្លួនទៀតផង។ ហេតុនេះ អស់លោកត្រូវទៅសួរសុខទុក្ខគ្រីស្តបរិស័ទនៅផ្ទះគេ ត្រូវទៅសាលារៀនតាមបន្ទុករបស់ខ្លួនជាគង្វាល ទាមទារឲ្យអស់លោកធ្វើជាចាំបាច់។ អស់លោកត្រូវឧស្សាហ៍យកចិត្តទុកដាក់នឹងកូនជំទង់ ហើយយុវជនយុវនារី។ ត្រូវស្រឡាញ់អ្នកក្រីក្រ និងអ្នកជំងឺ ដូចឪពុកស្រឡាញ់កូនរបស់ខ្លួនដូច្នោះដែរ។ លើសពីនេះទៅទៀត ត្រូវយកចិត្តទុកដាក់យ៉ាងពិសេសនឹងក្រុមពលករ ព្រមទាំងដាស់តឿនគ្រីស្តបរិស័ទឲ្យចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការជាគ្រីស្តទូត។

៣- លោកគង្វាលដែលជាតំណាងជំនួយ គឺសហការីរបស់លោកគង្វាលដែលទទួលខុសត្រូវថែទាំសហគមន៍មួយ។ អស់លោកជួយយ៉ាងខ្លាំង និងយ៉ាងសកម្មជារៀងរាល់ថ្ងៃក្នុងកិច្ចបម្រើព្រះសហគមន៍ ក្រោមអំណាចរបស់គង្វាល ដែលទទួលខុសត្រូវថែទាំសហគមន៍នោះ។ ហេតុនេះហើយ បានជាគង្វាលដែលទទួលខុសត្រូវថែទាំសហគមន៍ និងតំណាង

ជំនួយរបស់លោក ត្រូវស្រឡាញ់គ្នាដូចបងប្អូន ត្រូវរាប់អានគ្នា ត្រូវគោរពគ្នាទៅវិញទៅមកជានិច្ច ត្រូវជួយគ្នាទៅវិញទៅមក ដោយផ្ដល់ដំបូន្មាន រួមសហការគ្នា និងធ្វើជាគំរូឲ្យគ្នាផង។ ធ្វើដូច្នោះ ទើបអស់លោកមុខជានឹងបម្រើសហគមន៍នោះ ដោយមានចិត្តថ្លើមតែមួយ មានបំណងប្រាថ្នាតែមួយ និងមានចិត្តឧស្សាហ៍តែមួយថែមទៀតផង។

### ៣១-ការតែងតាំងគង្វាលដែលទទួលខុសត្រូវថែទាំសហគមន៍មួយ

លោកអភិបាល ត្រូវរិះគិតពិចារណាអំពីសមត្ថភាពរបស់គង្វាល ឲ្យមានលទ្ធភាពអាចគ្រប់គ្រងណែនាំសហគមន៍មួយបាន ដោយគិតគូរមិនគ្រាន់តែដល់លទ្ធិនៃជំនឿរបស់លោកប៉ុណ្ណោះទេ តែត្រូវគិតគូរដល់ការគោរពប្រណិប័តន៍ព្រះជាម្ចាស់របស់លោក ដល់ចិត្តឧហ្សាហ៍ធ្វើកិច្ចការជាគ្រីស្តទូត និងគិតគូរដល់ព្រះអំណោយទានឯទៀតៗ និងគុណសម្បត្តិផ្សេងៗ ដែលលោកត្រូវតែមានដើម្បីថែទាំគ្រីស្តបរិស័ទយ៉ាងល្អ។

គោលដៅនៃបន្ទុកជាគង្វាលណែនាំគ្រីស្តបរិស័ទ គឺរកផលប្រយោជន៍របស់គេខាងវិញ្ញាណ។ ហេតុនេះហើយបានជាលោកអភិបាលត្រូវផ្ដត់ផ្ដង់សហគមន៍នានាឲ្យមានគង្វាលតាមរបៀបស្រួល និងស្របតាមសភាពការណ៍។ ហេតុនេះ សូមបំបាត់ឯកសិទ្ធិទាំងប៉ុន្មានពីបុរាណ គឺសិទ្ធិបង្ហាញបេក្ខជន និងឲ្យតែងតាំងគេ សិទ្ធិទុកកន្លែងមួយសម្រាប់បេក្ខជនរបស់ខ្លួន។ សូមបំបាត់ការប្រកួតប្រជែងជាទូទៅ ឬដោយឡែក ឲ្យទៅជាគង្វាលទទួលខុសត្រូវថែទាំសហគមន៍មួយ ដូចទម្លាប់មានកន្លែងខ្លះ។ ប៉ុន្តែ ត្រូវគោរពសិទ្ធិរបស់បព្វជិត។

ក្នុងសហគមន៍នីមួយៗ លោកគង្វាលដែលទទួលខុសត្រូវថែទាំ ត្រូវកាន់មុខងាររបស់ខ្លួនយ៉ាងស្ថិតស្ថេរ ដើម្បីជាប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទ។ ហេតុនេះ មហាសន្និបាតសូមលុបបំបាត់ឋានៈគង្វាលទទួលខុសត្រូវថែទាំដែលអភិបាលគ្មានសិទ្ធិផ្លាស់ប្ដូរបាន។ ត្រូវកែសម្រួលរបៀបផ្លាស់ប្ដូរគង្វាល ដែលទទួលខុសត្រូវថែទាំ ដើម្បីឲ្យលោកអភិបាលអាចគោរពតាមយុត្តិធម៌ (តាមអត្ថន័យធម្មតាផង និងតាមអត្ថ័យក្បួនច្បាប់ក្នុងព្រះសហគមន៍ផង) ព្រមទាំងអាចផ្ដត់ផ្ដង់សហគមន៍នានាយ៉ាងស្រួលឲ្យមានគង្វាល តាមតែប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទទាមទារនោះ។

មហាសន្និបាតសូមអង្វរយ៉ាងខ្លាំងអស់លោកគង្វាល ដែលទទួលខុសត្រូវថែទាំសហគមន៍មួយ តែមិនអាចបំពេញមុខងាររបស់ខ្លួនយ៉ាងសមរម្យបាន ឬមិនអាចបង្កើតផលបាន ព្រោះលោកចាស់ជរាហើយ ឬព្រោះមានមូលហេតុជាទម្ងន់ផ្សេងទៀត ឲ្យលាលែងមុខតំណែងរបស់ខ្លួនដោយខ្លួនឯងក៏បាន ឬដោយលោកអភិបាលអញ្ជើញឲ្យលាលែងក៏បានដែរ។ លោកអភិបាលត្រូវតែធានាឲ្យលោកដែលលាលែងមុខតំណែងនោះ មានមធ្យោបាយទប់ទល់ជីវិភាពគ្រប់គ្រាន់បាន។

### ៣២-ការបង្កើតសហគមន៍ និងបង្កើតអ្វីៗជាថ្មី

ក្នុងគោលបំណងជួយសង្គ្រោះមនុស្សដដែលនោះ ត្រូវបញ្ជាក់ ឬកែសម្រួលការតែងតាំងសហគមន៍ ឬលប់បំបាត់សហគមន៍ខ្លះ ឬកែសម្រួលអ្វីៗផ្សេងទៀត។ ក្នុងករណីទាំងនោះ លោកអភិបាលអាចសម្រេច ដោយអំណាចរបស់លោកផ្ទាល់។

## ៤-ក្រុមបព្វជិត

### ៣៣-ក្រុមបព្វជិត និងកិច្ចការជាគ្រីស្តទូត

សេចក្ដីចាត់ចែងខាងក្រោមនេះ បានការសម្រាប់ក្រុមបព្វជិតទាំងអស់ ព្រមទាំងសមាជិកគ្រឹះស្ថានឯទៀតៗ ដែល

ធ្វើពិធីសច្ចាប្រណិធានកាន់តាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ ដែលភ្ជាប់ជាមួយបព្វជិតនោះ គឺម្នាក់ៗ តាមរបៀបព្រះជាម្ចាស់ត្រាស់ហៅឲ្យរស់នៅ។ អស់បព្វជិតមានភារកិច្ចជួយសាងសង់ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តទាំងមូល និងធ្វើឲ្យព្រះកាយនេះចម្រើន ដើម្បីជាប្រយោជន៍ខាងវិញ្ញាណរបស់ព្រះសហគមន៍នីមួយៗ។ អស់លោកត្រូវបូជាអស់កម្លាំងកាយកម្លាំងចិត្ត និងមានចិត្តឧស្សាហ៍។ អស់បព្វជិតត្រូវតែខិតខំតម្រង់ខ្លួនតាម ទិសដៅទាំងនោះ ដោយអធិដ្ឋានជាដើម ដោយបំពេញទុក្ករកិរិយា និងដោយរស់នៅធ្វើជាគំរូដល់គេ។ មហាសន្និបាតដាស់តឿនបព្វជិតទាំងអស់យ៉ាងខ្លាំងឲ្យស្រឡាញ់និងពង្រីកកិច្ចការទាំងនោះ ដោយឥតឈប់ឈរឡើយ។ ក៏ប៉ុន្តែ សូមឲ្យបព្វជិតយកចិត្តទុកដាក់ បំពេញកិច្ចការជាគ្រីស្តទូតក្រៅគ្រឹះស្ថានរបស់ខ្លួន តាមតែលក្ខណៈ សម្បត្តិផ្ទាល់នៃគ្រឹះស្ថាននីមួយៗអនុញ្ញាតឲ្យ។

## ៣៤-បព្វជិតជាសហការីរបស់លោកអភិបាលក្នុងកិច្ចការជាគ្រីស្តទូត

បព្វជិតជាគង្វាល ទទួលអគ្គសញ្ញាតែងតាំងជាគង្វាល ដើម្បីឲ្យធ្វើជាសហការីដ៏ឈ្លាសវៃនៃក្រុមអភិបាល ដូចគង្វាលភូមិភាគដែរ។ សព្វថ្ងៃបព្វជិតទាំងនោះ អាចជួយលោកអភិបាលយ៉ាងច្រើនជាងពីមុនទៅទៀត ព្រោះមានតម្រូវការខាងវិញ្ញាណរបស់គ្រីស្តបរិស័ទកាន់តែច្រើនឡើងៗ។ ហេតុនេះ យើងត្រូវប្រាប់យ៉ាងត្រឹមត្រូវម៉្យាងថា បព្វជិតពិតជាសមាជិកនៃក្រុមគង្វាលភូមិភាគដែរ ព្រោះអស់លោកបំពេញការងារជា ប្រយោជន៍ខាងវិញ្ញាណរបស់គ្រីស្តបរិស័ទ ហើយក៏ជួយក្នុងកិច្ចការជាគ្រីស្តទូត ក្រោមអំណាចរបស់អស់លោកអភិបាលដែរ។

សមាជិកឯទៀតៗនៃគ្រឹះស្ថាន ទាំងបុរសក្តី ទាំងស្ត្រីក្តី ដែលជាសមាជិកនៃមហាគ្រួសារភូមិភាគតាមរបៀបមួយក៏ជួយអស់លោកអភិបាលយ៉ាងល្អប្រសើរដែរ។ គេអាច (និងត្រូវ) ជួយកាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃ ព្រោះតម្រូវការនៃកិច្ចការជាគ្រីស្តទូត កាន់តែមានចំនួនចម្រើនឡើងជាលំដាប់ដែរ។

## ៣៥-គោលការណ៍សម្រាប់កិច្ចការជាគ្រីស្តទូតរបស់បព្វជិតក្នុងភូមិភាគ

មហាសន្និបាតតែងតាំងគោលការណ៍ដូចខាងក្រោមនេះ ដើម្បីឲ្យអស់អ្នកបំពេញកិច្ចការជាគ្រីស្តទូតរួបរួមគ្នាដោយរួមចិត្តថ្លើមតែមួយជានិច្ចក្នុងភូមិភាគនីមួយៗ ទាំងរក្សាទុកវិន័យតែមួយក្នុងភូមិភាគទៀតផង។ សេចក្តីសម្រេចមានដូចតទៅៈ

ក- សូមឲ្យបព្វជិតទាំងអស់សុខចិត្តស្ថិតនៅក្រោមអំណាចរបស់អស់លោកអភិបាលជានិច្ច ដោយគោរពលោកក្នុងនាមសាសនា ហើយក្នុងឋានៈអស់លោកបន្តមុខងារពីក្រុមគ្រីស្តទូតមក។ ពេលណាអភិបាលហៅបព្វជិតយ៉ាងត្រឹមត្រូវឲ្យបំពេញការងារជាគ្រីស្តទូត បព្វជិតក៏ត្រូវបំពេញបន្ទុករបស់ខ្លួននោះក្នុងឋានៈជាសហការីដែលព្យាយាម សុខចិត្តធ្វើការក្រោមអំណាចរបស់អស់លោកអភិបាលដែរ។ លើសពីនេះទៅទៀតបព្វជិតត្រូវសុខចិត្តភ្លាមនិងដោយចិត្តស្មោះ ធ្វើតាមសេចក្តីសុំ និងតាមបំណងប្រាថ្នារបស់អស់លោកអភិបាល ដែលសូមឲ្យគេយកចំណែកកាន់តែទូលំទូលាយ ក្នុងកិច្ចបម្រើការសង្គ្រោះរបស់មនុស្សលោក។ ក៏ប៉ុន្តែបុព្វជិតត្រូវបំពេញការបម្រើនោះ ដោយគោរពតាមលក្ខណៈសម្បត្តិ និងស្របតាមធម្មនុញ្ញនៃគ្រឹះស្ថានរបស់ខ្លួន។ ប្រសិនបើមានតម្រូវការ ត្រូវកែសម្រួលធម្មនុញ្ញរបស់គ្រឹះស្ថានទាំងនោះ តាមគោលការណ៍នៃក្រឹត្យក្រមរបស់មហាសន្និបាតនេះ។ ដោយមនុស្សមានតម្រូវការខាងវិញ្ញាណជាបន្ទាន់ និងដោយខ្វះបូជាចារ្យភូមិភាគ អស់លោកអភិបាលអាចហៅគ្រឹះស្ថានបព្វជិត ដែលគ្មានគោលដៅតែ

ស្មឹងស្មាធិ៍ ឲ្យជួយបំពេញមុខងារបម្រើផ្សេងៗក្នុងព្រះសហគមន៍ដែរ។ ប៉ុន្តែ ត្រូវគិតគូរដល់លក្ខណៈសម្បត្តិនៃគ្រឹះស្ថាននីមួយៗផង។ មេដឹកនាំគ្រឹះស្ថាន ត្រូវជួយដោយលើកស្ទួយឲ្យបព្វជិតទទួលបន្ទុកលើព្រះសហគមន៍នានា សូម្បីតែសម្រាប់មួយរយៈពេលប៉ុណ្ណោះ តាមតែគេអាចធ្វើបាន។

ខ- សូមឲ្យបព្វជិតដែលមេដឹកនាំចាត់ឲ្យបំពេញមុខងារជាគ្រីស្តទូតនៅខាងក្រៅគ្រឹះស្ថាន រក្សាទុកគោលគំនិតរបស់គ្រឹះស្ថានរបស់ខ្លួនជ្រួតជ្រាបក្នុងចិត្ត និងកាន់តាមវិន័យគ្រឹះស្ថានជារៀងរាល់ថ្ងៃតទៅទៀត ព្រមទាំងសុខចិត្តស្ថិតនៅក្រោមអំណាចមេដឹកនាំគ្រឹះស្ថានរបស់ខ្លួន។ អស់លោកអភិបាលត្រូវរំឭកបព្វជិត អំពីកាតព្វកិច្ចនេះ។

គ- ឯកសិទ្ធិភ្ជាប់បព្វជិត នឹងអភិបាលព្រះសហគមន៍ក្រុងរ៉ូម ឬភ្ជាប់នឹងអំណាចមួយផ្សេងទៀតក្នុងព្រះសហគមន៍ ធ្វើឲ្យបព្វជិតមិនស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់លោកអភិបាល។ ឯកសិទ្ធិនោះពាក់ព័ន្ធយ៉ាងពិសេសនឹងរចនាសម្ព័ន្ធផ្ទៃក្នុងរបស់គ្រឹះស្ថានទាំងនោះ។ ឯកសិទ្ធិទាំងនោះមានគោលដៅតែមួយ គឺជួយចាត់ចែងការរស់នៅរបស់បព្វជិត ព្រមទាំងជួយឲ្យការរស់នៅរួមជាបព្វជិតចម្រើនឡើង ហើយនាំឲ្យគេបានពេញលក្ខណៈ។ ឯកសិទ្ធិរបស់បព្វជិត ដែលមិនស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់អភិបាល ក៏បណ្ដោយឲ្យអភិបាលព្រះសហគមន៍ក្រុងរ៉ូម អាចចាត់ចែងបព្វជិតទាំងនោះ តាមប្រយោជន៍របស់ព្រះសហគមន៍សកល ឬឲ្យអំណាចមួយផ្សេងទៀត ដែលមានសមត្ថកិច្ចក្នុងព្រះសហគមន៍អាចប្រើបានដើម្បីជាប្រយោជន៍របស់ព្រះសហគមន៍នានា ដែលស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ខ្លួន។

ក៏ប៉ុន្តែឯកសិទ្ធិនេះ មិនឃាត់ឲ្យបព្វជិតទាំងនោះ ចុះចូលក្រោមអំណាចគ្រប់គ្រងរបស់អភិបាល ក្នុងភូមិភាគនីមួយៗទេ តាមតែបន្ទុករបស់បព្វជិតជាគង្វាល និងការចាត់ចែងការបម្រើវិញ្ញាណមនុស្សទាមទារ។

ឃ-បព្វជិតទាំងអស់ ទាំងបព្វជិតដែលមិនស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់អភិបាល ទាំងបព្វជិត ដែលស្ថិតនៅក្រោមអំណាចរបស់លោក ក៏ត្រូវសុខចិត្តធ្វើការក្រោមអំណាចធម្មតារបស់លោកអភិបាលភូមិភាគនៅពេលធ្វើពីធីបម្រើព្រះជាម្ចាស់ជាសាធារណៈ (ប៉ុន្តែ ត្រូវទុកឲ្យអស់លោកអនុវត្តតាមរបៀបរបបពិធីរបស់ខ្លួន) នៅពេលថែទាំវិញ្ញាណមនុស្ស នៅពេលធ្វើពិធីអត្ថាធិប្បាយព្រះគម្ពីរសម្រាប់ប្រជាជន ក្នុងការបង្រៀនលទ្ធិនៃគ្រីស្តសាសនា និងអប់រំសីលធម៌ ជាពិសេសក្នុងការអប់រំជំនឿកូនក្មេង ក្នុងការអប់រំខាងពិធីគោរពបម្រើព្រះជាម្ចាស់ និងអំពីក្រុមបូជាចារ្យ (អាចារ្យ) កាន់វិន័យយ៉ាងត្រឹមត្រូវទៀតផង។ ក្នុងកិច្ចការផ្សេងៗជាគ្រីស្តទូត បព្វជិតក៏ត្រូវក្រោមអំណាចរបស់អភិបាលភូមិភាគដូច្នោះដែរ។ បព្វជិតដែលណែនាំសាលារៀន ក៏ត្រូវក្រោមអំណាចរបស់អភិបាលភូមិភាគ ត្រង់ការចាត់ចែងជាទូទៅ និងត្រង់ការត្រួតពិនិត្យ ប៉ុន្តែ ត្រូវរក្សាទុកឲ្យបព្វជិតមានសិទ្ធិគ្រប់គ្រងសាលារៀនទាំងនោះ។ យ៉ាងណាមិញ បព្វជិតត្រូវអនុវត្តតាមបទបញ្ជាទាំងប៉ុន្មានដែលមហាសន្និបាតនានា និងក្រុមអភិបាលទាំងប៉ុន្មានបានបង្គាប់យ៉ាងត្រឹមត្រូវតាមច្បាប់ឲ្យគ្រីស្តបរិស័ទទាំងអស់អនុវត្តតាម។

ង- អស់លោកអភិបាលត្រូវជួយលើកស្ទួយ ឲ្យមានរចនាសម្ព័ន្ធសម្រាប់ឲ្យគ្រឹះស្ថានបព្វជិតផ្សេងៗ រួមសហការគ្នា និងរួមសហការជាមួយក្រុមគង្វាលក្នុងភូមិភាគដែរ។ លើសពីនេះទៅទៀត ត្រូវឲ្យកិច្ចការ និងសកម្មភាពជាគ្រីស្តទូតទាំងប៉ុន្មាន រួមសហការគ្នាជាចាំបាច់។ ការរួមសហការនេះ អាស្រ័យលើការតម្រង់ចិត្តគំនិតទៅរកព្រះជាម្ចាស់ ហើយចាក់ឫសលើសេចក្តីស្រឡាញ់ជាគ្រឹះ។ អាសនៈរបស់គ្រីស្តទូតសិលា

មានភារកិច្ចណែនាំឲ្យកិច្ចការ និងសកម្មភាពជាគ្រីស្តទូតទាំងប៉ុន្មានក្នុងព្រះសហគមន៍សកល រួមសហការគ្នា។ អភិបាលក៏មានភារកិច្ចបង្កើតការរួមសហការនេះក្នុងភូមិភាគរៀងៗខ្លួន។ មិនតែប៉ុណ្ណោះ សន្និបាតអភិបាលដ៏ប្រសើរឧត្តម និងក្រុមអភិបាលក្នុងប្រទេសនានា ក៏មានភារកិច្ចបង្កើតការរួមសហការនោះ ក្នុងតំបន់រៀងៗខ្លួនដែរ។

អភិបាល និងក្រុមអភិបាលក្នុងប្រទេសម្ខាង មេដឹកនាំគ្រឹះស្ថានបព្វជិត និងក្រុមមេដឹកនាំដ៏ឧត្តមម្ខាង ត្រូវចែកចាយគម្រោងការនានារបស់ខ្លួន អំពីកិច្ចការជាគ្រីស្តទូតដែលបព្វជិតបំពេញនោះ។

ច- អភិបាល និងក្រុមមេដឹកនាំក្រុមគ្រួសារបព្វជិត ត្រូវជួបជុំគ្នាតាមពេលកំណត់ និងនៅពេលដែលអស់លោកយល់ឃើញថា ត្រូវជួបជុំគ្នា ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការទាំងមូលជាគ្រីស្តទូតក្នុងតំបន់របស់អស់លោក។

# ជំពូក ៣

# អស់លោកអភិបាលសហការគ្នា ដើម្បីជាប្រយោជន៍រួមរបស់ព្រះសហគមន៍ជាច្រើន

## ១- សន្និបាត មហាសន្និបាត ជាពិសេសក្រុមអភិបាល

### ៣៦-សន្និបាត និងមហាសន្និបាតដោយឡែក

តាំងពីសតវត្សដើមដំបូងនៃព្រះសហគមន៍ អស់លោកអភិបាលដែលណែនាំព្រះសហគមន៍ដោយឡែក តែងតែយកចិត្តទុកដាក់បង្រួមកម្លាំងនិងប៉ងប្រាថ្នារបស់ខ្លួន លើកស្ទួយប្រយោជន៍រួមរបស់ព្រះសហគមន៍ទាំងប៉ុន្មាន និងរបស់ព្រះសហគមន៍នីមួយៗ។ អស់លោកធ្វើដូច្នេះ ដោយមានបំណងរួបរួមគ្នាដោយស្រឡាញ់គ្នាដូចបងប្អូន និងដោយគិតគូរដល់បេសកកម្មសកលដែលព្រះគ្រីស្តបានផ្ញើទុកឲ្យក្រុមគ្រីស្តទូតមក។ ហេតុនេះហើយ បានជាអស់លោកតែងតែចាត់ចែងសន្និបាត និងមហាសន្និបាតតាមតំបន់ ហើយមហាសន្និបាតសកលទៀតផង។ ក្នុងអង្គប្រជុំទាំងនោះ អស់លោកអភិបាលសម្រេចអំពីវិន័យដែលព្រះសហគមន៍នានាត្រូវអនុវត្តតាមដូចគ្នា ដើម្បីបង្រៀនសេចក្ដីពិតអំពីលទ្ធិនៃជំនឿ និងចាត់ចែងវិន័យក្រុមបូជាចារ្យ។

មហាសន្និបាតដ៏វិសុទ្ធនេះ ប៉ងប្រាថ្នាយ៉ាងខ្លាំងឲ្យចាត់ចែងសន្និបាត និងឲ្យមានមហាសន្និបាត តាមទម្លាប់ពីបុរាណដ៏គួរគោរព ដើម្បីជួយពង្រីកនិងពង្រឹងជំនឿយ៉ាងសកម្ម តាមរបៀបសមស្របនឹងសភាពការណ៍ ព្រមទាំងដើម្បីរក្សាវិន័យក្នុងព្រះសហគមន៍ផ្សេងៗទៀតផង។

### ៣៧-សារៈសំខាន់នៃក្រុមអភិបាល

នៅបច្ចុប្បន្នកាលយើងនេះ ប្រសិនបើអស់លោកអភិបាល មិនរួមជាមួយអភិបាលឯទៀតៗកាន់តែជិតស្និទ្ធ ជារៀងរាល់ថ្ងៃ ហើយរួមសហការក្នុងសកម្មភាពរបស់ខ្លួនកាន់តែខ្លាំងឡើងៗ អស់លោកមុខជាមិនអាចបំពេញបន្ទុករបស់ខ្លួនបានយ៉ាងសមរម្យ និងតាមរបៀបដែលបង្កើតផលបាន។ មានតែងតាំងក្រុមអភិបាលក្នុងប្រទេសជាច្រើនរួចហើយ ក្រុមទាំងនោះ ក៏បានផ្ដល់ភស្តុតាងយ៉ាងអស្ចារ្យបញ្ជាក់ថា បានបង្កើតផលខាងកិច្ចការជា គ្រីស្តទូត ដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតយល់ឃើញថា អស់លោកអភិបាលក្នុងប្រជាជាតិតែមួយ ក្នុងតំបន់តែមួយ នៅគ្រប់កន្លែងត្រូវតែងតាំងក្រុមអភិបាលតែមួយ ហើយប្រជុំគ្នាតាមពេលកំណត់ ដើម្បីចែកចាយពន្លឺនៃបទពិសោធន៍ដ៏ឈ្លាសវៃរបស់ខ្លួន។ បើធ្វើដូច្នេះ ទើបអស់លោកនឹងអាចចែករំលែកគំនិតគ្នាទៅវិញទៅមក និងអាចរួមកម្លាំង ឲ្យមានរបៀបរៀបរយ ដើម្បីជាប្រយោជន៍រួមនៃព្រះសហគមន៍ទាំងឡាយ។

ហេតុនេះហើយ បានជាមហាសន្និបាតសម្រេចសេចក្ដីអំពីក្រុមអភិបាលដូចតទៅ៖

## ៣៨-រចនាសម្ព័ន្ធ សមត្ថភាព និងការរួមសហការរបស់ក្រុមអភិបាលនានា

ក- ក្រុមអភិបាលហាក់ដូចជាអង្គប្រជុំមួយ សម្រាប់ឲ្យអស់អភិបាលក្នុងប្រទេសមួយ ឬក្នុងតំបន់មួយបំពេញបន្ទុកជាគង្វាលរួមជាមួយគ្នា ដើម្បីលើកស្ទួយប្រយោជន៍របស់ព្រះសហគមន៍កាន់តែខ្លាំងឡើងៗ ជាសម្បត្តិសួគ៌ ដែលព្រះសហគមន៍ជូនដល់មនុស្សលោក ជាពិសេសតាមរបៀបនិងតាមវិធីបំពេញបន្ទុករបស់ខ្លួនជាគ្រីស្តទូត ស្របតាមសភាពការណ៍នាបច្ចុប្បន្នកាល។

ខ- អភិបាលភូមិភាគទាំងប៉ុន្មាន (លើកលែងតែតំណាងពេញសិទ្ធិ) ទោះកាន់តាមរបៀបរបបពិធីណាក៏ដោយ អភិបាលឧបការី អភិបាលរង និងអភិបាលឯទៀតៗដែលមានឈ្មោះតាមអាសនៈព្រះសហគមន៍ពីដើម ហើយដែលទទួលបន្ទុកពិសេសពីអាសនៈគ្រីស្តទូតសិលាម ឬពីក្រុមអភិបាលសុទ្ធតែជាសមាជិកនៃក្រុមអភិបាលនោះ។ រីឯអភិបាលឯទៀតៗ ដែលមានឈ្មោះតាមអាសនៈព្រះសហគមន៍ពីដើម គ្មានសិទ្ធិជាសមាជិកក្រុមអភិបាលទេ។ ទូតរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ក៏មិនមែនជាសមាជិកក្រុមអភិបាលដែរ ដោយយល់ដល់បេសកកម្មពិសេសរបស់លោកក្នុងតំបន់នោះ។

អភិបាលភូមិភាគនិងអភិបាលឧបការីទាំងប៉ុន្មាន មានសំឡេងបោះឆ្នោតបាន។ ចំពោះអភិបាលរងនិងអភិបាលឯទៀតៗ ដែលមានសិទ្ធិចូលរួមក្នុងក្រុមអភិបាល ត្រូវមានលក្ខន្តិកៈក្រុមអភិបាល ផ្តល់សំឡេងបោះឆ្នោតក៏បាន ឬផ្តល់តែសំឡេងប្រឹក្សាពិគ្រោះប៉ុណ្ណោះក៏បានដែរ។

គ- ក្រុមអភិបាលនីមួយៗ ត្រូវសរសេរលក្ខន្តិកៈរបស់ខ្លួន។ អាសនៈគ្រីស្តទូតសិលាត្រូវទទួលស្គាល់លក្ខន្តិកៈទាំងនោះ។ ក្នុងលក្ខន្តិកៈទាំងនោះ ត្រូវចាត់ចែងឲ្យមានស្ថាប័នសម្រាប់ជួយឲ្យក្រុមអភិបាលអាចបំពេញគោលដៅរបស់ខ្លួនយ៉ាងសកម្មបាន ពោលគឺ ត្រូវមានក្រុមប្រឹក្សាអចិន្ត្រៃយ៍ មានគណៈកម្មាធិការនានា មានលេខាធិការដ្ឋានទូទៅជាដើម។ល។ និង។ល។

ឃ-ក្រុមអភិបាលសម្រេចសេចក្តីត្រឹមត្រូវតាមច្បាប់ លុះត្រាតែមានចំនួនសំឡេងយ៉ាងហោចណាស់ពីរ ភាគបីនៃចំនួនអភិបាលដែលមានសំឡេងបោះឆ្នោតក្នុងក្រុមអភិបាល ហើយលុះត្រាតែ អាសនៈគ្រីស្តទូតសិលាបានទទួលស្គាល់ក្រុមអភិបាលនោះ។ គ្រីស្តបរិស័ទត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមអភិបាល តែក្នុងករណីណាក្បួនច្បាប់ទូទៅ បញ្ជាឲ្យអនុវត្តប៉ុណ្ណោះទេ ឬក្នុងករណីណាមានបទបញ្ជាពិសេស របស់អាសនៈគ្រីស្តទូតសិលាដោយខ្លួនឯង ឬដោយក្រុមអភិបាលបានសុំអាសនៈគ្រីស្តទូតសិលាបញ្ជានោះ។

ង- ក្នុងករណីណាមានសភាពការណ៍ពិសេសទាមទារ អភិបាលប្រជាជាតិជាច្រើន អាចចូលរួមជាក្រុមអភិបាលតែមួយ ដោយមានអាសនៈគ្រីស្តទូតសិលាយល់ស្រប។ លើសពីនេះទៅទៀត ត្រូវលើកទឹកចិត្តអភិបាលឲ្យក្រុម អភិបាលប្រជាជាតិផ្សេងៗមានទំនាក់ទំនងជាមួយគ្នា ដើម្បីលើកស្ទួយប្រយោជន៍នៃព្រះសហគមន៍កាន់តែច្រើនឡើងៗ។

ច- អភិបាលនៃព្រះសហគមន៍នៅបូព៌ាប្រទេស តែងតែប្រួមគ្នាជាសន្និបាត ដើម្បីលើកស្ទួយវិន័យក្នុងព្រះសហគមន៍របស់ខ្លួន និងដើម្បីលើកទឹកចិត្តគ្រីស្តបរិស័ទយ៉ាងសកម្ម ឲ្យគេបំពេញកិច្ចការសម្រាប់ជាប្រយោជន៍សាសនា។ មហាសន្និបាតសូមទូន្មានយ៉ាងខ្លាំង ឲ្យអភិបាលទាំងនោះគិតគូរដល់ប្រយោជន៍

រួមនៃតំបន់ទាំងមូល នៅកន្លែងមានសហគមន៍ជាច្រើនដែលកាន់តាមរបៀបរបបពិធីប្លែកៗពីគ្នា។ អស់លោកអភិបាលត្រូវបង្កើតការចែកចាយយោបល់គ្នាទៅវិញទៅមក ក្នុងប្រជុំអន្តររបៀបរបបពិធី តាមវិន័យដែលអំណាចមានសមត្ថកិច្ចនឹងតែងតាំងនៅពេលខាងមុខ។

## ២-ព្រំដែនតំបន់ព្រះសហគមន៍ ហើយការតែងតាំងតំបន់ព្រះសហគមន៍

### ៣៩-គោលការណ៍អំពីការកែសម្រួលព្រំដែនភូមិភាគ

ភូមិភាគត្រូវមានព្រំដែនស្របតាមសភាពការណ៍ ដើម្បីជាប្រយោជន៍ខាងវិញ្ញាណសម្រាប់គ្រីស្តបរិស័ទ។ មិនតែប៉ុណ្ណោះ ភូមិភាគផ្សេងៗក៏ត្រូវរួមគ្នាជាតំបន់ដែលមានព្រំដែនស្របតាមសភាពការណ៍ដែរ។ លើសពីនេះទៅទៀត ត្រូវតែងតាំងតំបន់ថ្មីដែលអាចជួយផ្គត់ផ្គង់តម្រូវការនៃកិច្ចការជាគ្រីស្តទូតបាន ស្របតាមសភាពការណ៍ក្នុងសង្គម និងសភាពការណ៍តាមតំបន់។ ដូច្នេះ អភិបាលទាំងប៉ុន្មានអាចទាក់ទងជាមួយគ្នាយ៉ាងស្រួល ហើយទំនាក់ទំនងទាំងនោះនឹងមានប្រយោជន៍ច្រើនជាពុំខាន។ អស់លោកអភិបាលក៏នឹងមានទំនាក់ទំនងជាមួយអភិបាលនៃទីក្រុងធំៗ និងជាមួយអភិបាលឯទៀតៗក្នុងប្រទេសនោះ។ ទំនាក់ទំនងរបស់អស់លោកអភិបាល ជាមួយរដ្ឋអំណាចក៏ស្រួលថែមទៀតផង។

### ៤០-វិន័យដែលត្រូវអនុវត្តតាម

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធសម្រេចឲ្យតែងតាំងវិន័យដូចតទៅ ដើម្បីឲ្យបានលទ្ធផលតាមបំណងគឺៈ

ក- ត្រូវកែសម្រួលទំហំតំបន់ព្រះសហគមន៍តាមសេចក្ដីសមគួរ ហើយត្រូវបញ្ជាក់សិទ្ធិ និងឯកសិទ្ធិអភិបាលព្រះសហគមន៍ក្នុងក្រុងធំៗ តាមសេចក្ដីណែនាំថ្មី និងស្របតាមសភាពការណ៍។

ខ- ភូមិភាគទាំងអស់ និងដែនដីឯទៀតៗទាំងអស់ដែលមានការចាត់ចែងដូចគ្នា តាមក្បួនច្បាប់រួមរបស់ព្រះសហគមន៍ ត្រូវភ្ជាប់ជាមួយតំបន់ព្រះសហគមន៍តែមួយ។ ហេតុនេះហើយ បានជាភូមិភាគទាំងអស់ដែលសព្វថ្ងៃស្ថិតនៅក្រោមអំណាចអាសនៈគ្រីស្តទូតសិលា ហើយដែលមិនជាប់នឹងភូមិភាគណាមួយ ត្រូវរួបរួមក្នុងតំបន់ព្រះសហគមន៍ថ្មីនោះប្រសិនបើអាចធ្វើបាន ឬត្រូវភ្ជាប់ជាមួយនឹងតំបន់ព្រះសហគមន៍ដែលនៅជិតជាង ឬដែលស្រួលជាងគេ។ ដូច្នេះភូមិភាគទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចរបស់អគ្គអភិបាលនៃក្រុមធំៗ តាមវិន័យនៃក្បួនច្បាប់រួមទូទៅ។

គ- នៅកន្លែងណាប្រយោជន៍ទាមទារ ត្រូវបង្រួមតំបន់ព្រះសហគមន៍ ជាតំបន់ព្រះសហគមន៍ធំ។ ត្រូវបញ្ជាក់ការចាត់ចែងតំបន់ទាំងនោះ តាមក្បួនច្បាប់នៅពេលខាងមុខ។

### ៤១-ត្រូវសូមឲ្យក្រុមអភិបាលបោះឆ្នោត

គួរឲ្យក្រុមអភិបាលដែលមានសមត្ថកិច្ច ពិនិត្យមើលបញ្ហាកំណត់ព្រំដែនតំបន់ព្រះសហគមន៍ទាំងនោះ ឬបញ្ហាតែងតាំងភូមិភាគ តាមច្បាប់ដែលចាត់ចែងរួចហើយសម្រាប់កំណត់ព្រំដែនភូមិភាគ (លក ២៣ និង ២៤) រួច សុំឲ្យក្រុមអភិបាលផ្ដល់យោបល់ និងសេចក្ដីប៉ងប្រាថ្នារបស់ខ្លួនជូនទៅអាសនៈគ្រីស្តទូតសិលា។

## ៣-អភិបាលដែលបំពេញការងារអន្តរភូមិភាគ

### ៤២-ការតែងតាំងការិយាល័យពិសេស និងសហការជាមួយអស់លោកអភិបាល

តម្រូវការណែនាំគ្រីស្តបរិស័ទ ទាមទារឲ្យអស់លោកអភិបាលរួមគ្នាបំពេញនិងពង្រីកកិច្ចការណែនាំខ្លះ ដោយចិត្តថ្លើមតែមួយ។ ហេតុនេះហើយបានជាត្រូវតែងតាំងការិយាល័យមួយចំនួន សម្រាប់បម្រើភូមិភាគទាំងអស់ ឬបម្រើភូមិភាគទាំងប៉ុន្មានក្នុងតំបន់មួយ ឬក្នុងប្រទេសមួយ។ គេអាចផ្ញើឲ្យអភិបាលម្នាក់ទទួលខុសត្រូវ លើការិយាល័យមួយចំនួននោះបាន។

មហាសន្និបាតទូន្មានឲ្យអភិបាលដែលបំពេញបន្ទុកទាំងនោះ អភិបាលភូមិភាគ និងក្រុមអភិបាល រួបរួមគ្នាដូចបងប្អូនជានិច្ច រួមគោលបំណងប្រាថ្នាក្នុងកិច្ចការជាគង្វាលណែនាំ តាមលក្ខណៈដែលក្បួនច្បាប់ទូទៅត្រូវបញ្ជាក់នៅពេលខាងមុខ។

### ៤៣-អភិបាលសម្រាប់កងទ័ព

ត្រូវយកចិត្តទុកដាក់យ៉ាងពិសេសនឹងថែទាំទាហានខាងវិញ្ញាណ ព្រោះគេមានរបៀបរស់នៅប្លែកពីគេ។ ហេតុនេះត្រូវតែងតាំងអភិបាលសម្រាប់កងទ័ព តាមសមត្ថភាពក្រុមអភិបាលនីមួយៗ។ អភិបាលកងទ័ព និងបូជាចារ្យ (អាចារ្យ) ត្រូវបូជាកម្លាំងកាយកម្លាំងចិត្តដោយឥតសំចៃ បំពេញមុខងារដ៏ពិបាកនោះ ទាំងរួមសហការយ៉ាងពេញលេញជាមួយនឹងអភិបាលភូមិភាគនានា។

ហេតុនេះ អភិបាលភូមិភាគនានាត្រូវជូនបូជាចារ្យមួយចំនួនល្មមទៅដល់អភិបាលកងទ័ព គឺគង្វាល ដែលមានសមត្ថភាពអាចបំពេញបន្ទុកដ៏ធ្ងន់ធ្ងរនេះ។ នៅពេលជាមួយគ្នានោះ អស់លោកក៏ត្រូវលើកស្ទួយកិច្ចការផ្សេងៗ ដើម្បីជាប្រយោជន៍ខាងព្រះវិញ្ញាណរបស់ទាហានថែមទៀតផង។

# បទបញ្ញាទូទៅ

៤៤-មហាសន្និបាតសម្រេចថា ពេលកែសម្រួលក្បួនច្បាប់ព្រះសហគមន៍ ត្រូវបង្កើតច្បាប់តាមតម្រូវការ និងស្រប តាមគោលការណ៍បញ្ជាក់ក្នុងក្រឹត្យក្រមនេះ ដោយនឹកគិតដល់សេចក្ដីសង្កេតឃើញ នៃគណៈកម្មាធិការរបស់មហា សន្និបាត និងរបស់អភិបាលដែលចូលរួមក្នុងមហាសន្និបាតនេះផង។

មហាសន្និបាតសម្រេចទៀតថា ត្រូវចែងសេចក្ដីណែនាំទូទៅសម្រាប់ថែទាំងវិញ្ញាណ ដើម្បីជួយអស់លោក អភិបាល និងគង្វាល ដែលទទួលខុសត្រូវថែទាំគ្រីស្ដបរិស័ទក្នុងព្រះសហគមន៍មួយ។ សេចក្ដីណែនាំដ៏មាំមួនទាំងនោះ មុខជានឹងជួយអស់លោក ឲ្យបំពេញបន្ទុករបស់ខ្លួនជាគង្វាលយ៉ាងស្រួល និងកាន់តែពេញលក្ខណៈ។

សូមចែងសេចក្ដីណែនាំពិសេសសម្រាប់ជួយអភិបាល និងគង្វាល ដែលណែនាំក្រុមគ្រីស្ដបរិស័ទប្លែកពីគេ តាម សភាពការណ៍ផ្សេងៗរបស់ជាតិនានា ឬស្របតាមសភាពការណ៍តំបន់ផ្សេងទៀតដែរ។ ត្រូវចែងសេចក្ដីណែនាំអំពីការ អប់រំជំនឿប្រជាជនគ្រីស្ដបរិស័ទ។ សេចក្ដីណែនាំត្រូវចែងអំពីគោលជាគ្រឹះមូលដ្ឋាន និងអំពីការចាត់ចែងនៃការបង្រៀន នោះ។ ត្រូវនិពន្ធសៀវភៅអំពីសេចក្ដីទាំងនោះ។ ពេលនិពន្ធសៀវភៅណែនាំទាំងនោះ ត្រូវនឹកគិតដល់សេចក្ដីសង្កេត ឃើញ នៃគណៈកម្មាធិការមហាសន្និបាត និងរបស់អភិបាលដែលចូលរួមក្នុងមហាសន្និបាតនេះផង។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ ព្រមទាំងគោលការណ៍ នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្ដ បានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្ដទូត រួមជាមួយអស់ លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ ឲ្យសេចក្ដីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ច និរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្ដ: សិលា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ក្រុមលោកគង្វាល

**(អំពីមុខងារបម្រើ និងការរស់នៅរបស់លោកគង្វាល)**

## PRESBYTERORUM ORDINIS

**ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់**
**រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធ**
**សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យនឹកចងចាំរហូតតរៀងទៅ។**

## ក្រឹត្យក្រមស្ដីអំពី
## មុខងារបម្រើ និងការរស់នៅរបស់អស់លោកគង្វាល

### បុព្វកថា

១-មហាសន្និបាតដ៏វិសុទ្ធនេះ បានរំឭកគ្រីស្តបរិស័ទជាច្រើនដងមកហើយថា ក្រុមលោកកគង្វាលមានសារៈសំខាន់បំផុតក្នុងព្រះសហគមន៍ (ពិធី ពន្លឺ អភិបាល ហ្វឹកហ្វឺន)។ នៅពេលព្រះសហគមន៍របស់ព្រះគ្រីស្ត កំពុងតែប្រែសម្រួលឲ្យបានជាថ្មី ក្រុមលោកគង្វាលនេះបំពេញតួនាទីដ៏សំខាន់ណាស់ ប៉ុន្តែតួនាទីនេះ កាន់តែពិបាកឡើងៗដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតយល់ឃើញថា ត្រូវរិះគិតអំពីមុខងារជាគង្វាលឲ្យពិស្តារ និងកាន់តែស៊ីជម្រៅ ការរិះគិតនេះពិតជាមានប្រយោជន៍ខ្លាំងណាស់។ អ្វីៗដែលមានចែងក្នុងក្រឹត្យក្រមនេះ គឺពាក់ព័ន្ធនឹងគង្វាលទាំងឡាយ ជាពិសេសពាក់ព័ន្ធនឹងគង្វាលដែលបំពេញមុខងារជាគង្វាល។ ចំពោះបូជាចារ្យដែលជាបព្វជិតវិញ ត្រូវកែសម្រួលសេចក្ដីក្នុងក្រឹត្យក្រមនេះ ស្របតាមតម្រូវការ។

ដោយអស់លោកគង្វាលបានទទួលអគ្គសញ្ញាតែងតាំង និងបានទទួលបេសកកម្មពីលោកអភិបាលមក អស់លោកបម្រើព្រះគ្រីស្តជាព្រះបរមគ្រូ ជាមហាបូជាចារ្យ និងជាព្រះមហាក្សត្រ។ អស់លោកក៏ទទួលចំណែកក្នុងមុខងាររបស់ព្រះអង្គ ដែលតែងតែសាងសង់ព្រះសហគមន៍នៅលើផែនដីនេះជារៀងរាល់ថ្ងៃ ឲ្យទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាព្រះកាយរបស់ព្រះគ្រីស្ត និងជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ហេតុនេះហើយ បានជាមហាសន្និបាតត្រូវជួយគាំទ្រអស់លោកគង្វាល ឲ្យកាន់តែស័ក្តិសិទ្ធិឡើងៗ ក្នុងកិច្ចបំពេញមុខងារបម្រើរបស់ខ្លួន និងជួយអស់លោកឲ្យរស់នៅកាន់តែល្អប្រសើរឡើង ក្នុងសភាពការណ៍មនុស្សលោកដែលតែងតែប្រែប្រួលជានិច្ច។ ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធនេះសម្រេចនិងប្រកាសសេចក្ដីដូចតទៅ៖

# ជំពូក ១

## មុខងារជាគង្វាល ក្នុងបេសកកម្មរបស់ព្រះសហគមន៍

២-ព្រះអម្ចាស់យេស៊ូដែល *"ព្រះបិតាប្រោសឲ្យបានវិសុទ្ធ និងចាត់ឲ្យយាងមកក្នុងពិភពលោក"* (យហ ១០, ៣៦) ព្រះអង្គប្រោសឲ្យព្រះកាយដ៏អាថ៌កំបាំងទាំងមូលរបស់ព្រះអង្គ រួមជាមួយព្រះអង្គដែលព្រះវិញ្ញាណដ៏វិសុទ្ធ ចាក់ប្រេងអភិសេកដែរ (មថ ៣, ១៦; លក ៤, ១៨; កក ៤, ២៧; ១០, ៣៨)។ ក្នុងអង្គព្រះគ្រីស្ត អស់គ្រីស្តបរិស័ទទៅជា *"ក្រុមបូជាចារ្យដ៏វិសុទ្ធរបស់ព្រះមហាក្សត្រ ដែលថ្វាយយញ្ញបូជាខាងវិញ្ញាណទៅព្រះជាម្ចាស់តាមរយៈព្រះយេស៊ូគ្រីស្ត ហើយប្រកាសដំណឹងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ ដែលបានហៅគេឲ្យចេញពីទីងងឹត មកកាន់ពន្លឺដ៏រុងរឿងរបស់ព្រះអង្គ"* (១សលធ ២, ៥ និង ៩)។ ហេតុនេះហើយ សមាជិកគ្រប់ៗរូប សុទ្ធតែមានចំណែកក្នុងបេសកកម្មនៃព្រះកាយទាំងមូល។ ប៉ុន្តែ ម្នាក់ៗត្រូវតែទុកឲ្យព្រះគ្រីស្តសម្តែងព្រះបារមីក្នុងចិត្តគំនិតរបស់ខ្លួន (១សលធ ៣, ១៥) និងផ្តល់សក្ខីភាពអំពីព្រះយេស៊ូ ដោយ *"ព្រះវិញ្ញាណរបស់ព្រះអង្គ ថ្លែងព្រះបន្ទូលក្នុងនាមព្រះជាម្ចាស់"* (វវ ១៩, ១០; ពន្លឺ ៣៥)។

ព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជារូបកាយតែមួយ ហើយក្នុងរូបកាយនោះ *"សរីរាង្គនីមួយៗមានមុខងារខុសៗគ្នា"* (រម ១២, ៤) ដូច្នេះ ក្នុងចំណោមគ្រីស្តបរិស័ទ ព្រះអង្គតែងតាំងអ្នកខ្លះឲ្យមានមុខងារបម្រើ។ ក្នុងសហគមន៍គ្រីស្តបរិស័ទ អ្នកទាំងនេះទទួលអំណាចដ៏សក្ការៈ គឺអំណាចមកពីព្រះជាម្ចាស់ ដោយអគ្គសញ្ញាតែងតាំង ដើម្បីឲ្យអស់លោកអាចថ្វាយសក្ការបូជា និងលើកលែងទោសឲ្យគេរួចពីបាប។ លោកទាំងនោះ បំពេញមុខងារជាបូជាចារ្យជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់មនុស្សលោកក្នុងនាមព្រះគ្រីស្ត។ ហេតុនេះហើយ ព្រះគ្រីស្តបានចាត់ក្រុមគ្រីស្តទូត ឲ្យទៅដូចព្រះបិតាបានចាត់ព្រះអង្គឲ្យយាងមកដែរ (យហ ២០, ២១)។ បន្ទាប់មក ដោយសារក្រុមគ្រីស្តទូត ព្រះគ្រីស្តក៏បានប្រោសឲ្យអស់លោកអភិបាល ដែលបន្តមុខងារពីក្រុមគ្រីស្តទូតមក (ពន្លឺ ២៨) រួមជាមួយព្រះអង្គ ដែលត្រូវញែកប្រសិទ្ធិឲ្យបានវិសុទ្ធ និងរួមចំណែកក្នុងបេសកកម្មរបស់ព្រះអង្គផងដែរ។ ព្រះសហគមន៍បញ្ជូនបន្តមុខងារបម្រើរបស់លោកអភិបាលទៅដល់លោកគង្វាល តាមកម្រិតទាបជាង (ពន្លឺ ២៨)។ អស់លោកជាក្រុមគង្វាល ត្រូវបានតែងតាំង ដើម្បីទៅជាសហការីរបស់ក្រុមអភិបាល ក្នុងកិច្ចបំពេញបេសកកម្មជាគ្រីស្តទូត ដែលព្រះគ្រីស្តបានផ្ញើទុកឲ្យក្រុមអភិបាល។

អស់លោកគង្វាល មានការងារភ្ជាប់ជាមួយនឹងក្រុមលោកអភិបាល ហើយទទួលចំណែកក្នុងអំណាចរបស់ព្រះគ្រីស្តផ្ទាល់ ដែលសាងសង់ គ្រប់គ្រង និងប្រោសឲ្យព្រះកាយបានវិសុទ្ធ។ ហេតុនេះហើយ ព្រះសហគមន៍ផ្ញើមុខងារជាបូជាចារ្យឲ្យលោកគង្វាល ដោយសារអគ្គសញ្ញាដ៏ពិសេសមួយ គឺអគ្គសញ្ញាតែងតាំង។ ដោយអគ្គសញ្ញាតែងតាំងនេះ ព្រះវិញ្ញាណដ៏វិសុទ្ធចាក់ប្រេងអភិសេក ដៅចំណាំអស់លោកឲ្យមានលក្ខណៈពិសេសមួយ គឺព្រះអង្គប្រោសឲ្យអស់លោកបានដូចព្រះគ្រីស្តជាមហាបូជាចារ្យ ដើម្បីឲ្យអស់លោកមានសមត្ថភាពអាចប្រព្រឹត្តកិច្ចការក្នុងនាមព្រះគ្រីស្តផ្ទាល់ជាព្រះសិរសា (ពន្លឺ ១០)។ ប៉ុន្តែ អស់លោកត្រូវទទួលអគ្គសញ្ញាទាំងបីនៃការបញ្ចូលគ្រីស្តសាសនាជាមុនសិន។

ដោយលោកគង្វាល រួមចំណែកក្នុងមុខងាររបស់ក្រុមគ្រីស្តទូតនោះ ព្រះជាម្ចាស់ប្រោសប្រទានព្រះអំណោយទានឲ្យអស់លោក តែងតាំងអស់លោកឲ្យ "មានមុខងារបម្រើព្រះគ្រីស្តយេស៊ូ នៅកណ្តាលចំណោមសាសន៍ដទៃ គឺឲ្យបំពេញមុខងារដ៏សក្ការៈប្រកាសដំណឹងល្អ ដើម្បីនាំសាសន៍ដទៃមកថ្វាយខ្លួន ទុកជាតង្វាយដែលគាប់ព្រះហឫទ័យព្រះអង្គ ជាតង្វាយដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យបានវិសុទ្ធ" (រម ១៥, ១៦)។ ដោយក្រុមគ្រីស្តទូតប្រកាសដំណឹងល្អ អស់លោកកោះហៅប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឲ្យជួបជុំគ្នា ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ប្រោសឲ្យសមាជិកទាំងអស់នៃប្រជារាស្ត្រនេះបានវិសុទ្ធ ហើយថ្វាយខ្លួន *"ទុកជាយញ្ញដែលមានជីវិត ជាយញ្ញដ៏វិសុទ្ធ ហើយគាប់ព្រះហឫទ័យព្រះជាម្ចាស់"* (រម ១២, ១)។ ក៏ប៉ុន្តែ សក្ការបូជាខាងវិញ្ញាណរបស់គ្រីស្តបរិស័ទ បានពេញលក្ខណៈ គឺរួមជាមួយនឹងសក្ការៈបូជារបស់ព្រះគ្រីស្តដែលជាស្ពានមេត្រីតែមួយគត់ ដោយសារមុខងារបម្រើរបស់អស់លោកគង្វាល។ នៅពេលអស់លោកធ្វើពិធីអរព្រះគុណ អស់លោកថ្វាយសក្ការបូជានេះក្នុងនាមព្រះសហគមន៍ទាំងមូល ជាសក្ការបូជាដែលមិនបង្ហូរឈាម និងតាមលក្ខណៈជាអគ្គសញ្ញា រហូតដល់ពេលព្រះអម្ចាស់យាងមក (១ករ ១១, ២៦)។ សក្ការបូជាអរព្រះគុណនេះ ជាកំពូលនៃមុខងារបម្រើរបស់គង្វាល ហើយក៏ធ្វើឲ្យមុខងារនេះបានពេញលក្ខណៈដែរ។ មុខងារបម្រើនេះចាប់ផ្តើមដោយការប្រកាសដំណឹងល្អ ហើយមានកម្លាំង និងអានុភាពដោយសារសក្ការបូជារបស់ព្រះគ្រីស្ត។ មុខងារបម្រើជាគង្វាលនេះ នឹងដល់កំពូលនៅពេល *"គេយកបុរីទាំងមូលដែលព្រះជាម្ចាស់បានរំដោះ ពោលគឺ សង្គម និងសហគមន៍របស់ជនដ៏វិសុទ្ធទាំងឡាយ ទៅថ្វាយព្រះជាម្ចាស់ ទុកជាសក្ការបូជាសកល ដោយសារព្រះគ្រីស្តជាមហាបូជាចារ្យ ដែលទ្រង់បានថ្វាយព្រះអង្គផ្ទាល់ នៅពេលព្រះអង្គរងទុក្ខលំបាកសម្រាប់យើង ដើម្បីឲ្យយើងទៅជាព្រះកាយរបស់ព្រះសិរសាដ៏ឧត្តុង្គឧត្តមបំផុតនោះ"*។ (សន្តៈ អូហ្គូស្តាំង)។

ដូច្នេះ មុខងារបម្រើរបស់អស់លោកគង្វាល និងការរស់នៅរបស់អស់លោក មានគោលដៅតែមួយ គឺលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតាក្នុងអង្គព្រះគ្រីស្ត។ សិរីរុងរឿងនេះមានន័យថា ឲ្យមនុស្សលោកសុខចិត្តទទួលស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលទ្រង់បានសម្រេចក្នុងអង្គព្រះគ្រីស្ត ទាំងដឹងខ្លួន ទាំងមានសេរីភាព និងទាំងអរព្រះគុណទៀតផង។ មនុស្សលោកក៏សម្តែងស្នាព្រះហស្តរបស់ព្រះជាម្ចាស់នោះ តាមគ្រប់កិច្ចការប្រចាំការរស់នៅរបស់គេ។ ហេតុនេះហើយ បានជាអស់លោកគង្វាល ទោះជាពេលអធិដ្ឋានក្តី នមស្ការថ្វាយបង្គំព្រះជាម្ចាស់ក្តី ប្រកាសព្រះបន្ទូលក្តី ថ្វាយសក្ការបូជាអរព្រះគុណក្តី ធ្វើអគ្គសញ្ញាឯទៀតៗជូនគ្រីស្តបរិស័ទក្តី បំពេញកិច្ចបម្រើផ្សេងៗសម្រាប់មនុស្សលោកក្តី ក៏អស់លោករួមធ្វើឲ្យសិរីរុងរឿងរបស់ព្រះជាម្ចាស់លេចចាំងឲ្យកាន់តែភ្លឺឡើង ព្រមទាំងជួយនាំមនុស្សឲ្យធ្វើដំណើរទៅទទួលព្រះជន្មរបស់ព្រះអង្គកាន់តែច្រើនឡើងទៀតផង។ ការទាំងអស់នេះ សុទ្ធតែហូរមកពីបុណ្យចម្លងរបស់ព្រះគ្រីស្ត គឺហូរមកពីព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ហើយនឹងបានសម្រេចជាស្ថាពរនៅពេលព្រះអម្ចាស់យាងមកវិញប្រកបដោយសិរីរុងរឿង គឺនៅពេលព្រះអង្គ នឹងប្រគល់ព្រះរាជ្យថ្វាយព្រះជាម្ចាស់ជាព្រះបិតា (១ករ ១៥, ២៤)។

### ៣-សភាពការណ៍របស់លោកគង្វាលក្នុងពិភពលោក

លោកបូជាចារ្យត្រូវគេជ្រើសរើសពីចំណោមមនុស្ស ហើយត្រូវគេតែងតាំងសម្រាប់ជួយមនុស្សឲ្យទាក់ទងជាមួយព្រះជាម្ចាស់ ដើម្បីជាប្រយោជន៍ដល់មនុស្សលោក ក្នុងការថ្វាយតង្វាយ និងថ្វាយយញ្ញបូជារំដោះបាប (ហប ៥, ១)។ ហេតុនេះ លោកគង្វាលរស់នៅក្នុងចំណោមមនុស្ស ដោយចាត់ទុកគេជាបងប្អូន។ ព្រះអម្ចាស់យេស៊ូក៏ប្រព្រឹត្តដូច្នេះដែរ គឺព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាមនុស្សដែលព្រះបិតាចាត់ឲ្យមករកមនុស្សលោក ព្រះអង្គបានគង់នៅក្នុង

ចំណោមមនុស្សយើង ហើយសព្វព្រះហឫទ័យឲ្យមានលក្ខណៈដូចបងប្អូនរបស់ព្រះអង្គ តាមគ្រប់ជំពូកទាំងអស់ តែទ្រង់ពុំបានប្រព្រឹត្តអំពើបាបសោះឡើយ (ហប ២, ១៧; ៤, ១៥)។ ក្រុមសន្តគ្រីស្តទូតយក តម្រាប់តាមព្រះអម្ចាស់យេស៊ូរួចហើយ។ សន្តៈប៉ូល ជាគ្រូបាធ្យាយរបស់សាសន៍ដទៃ ហើយដែលព្រះជាម្ចាស់បាន *"ជ្រើសរើសញែកទុកដោយឡែក... ដើម្បីប្រកាសដំណឹងល្អរបស់ព្រះអង្គ"* (រម ១, ១) បញ្ជាក់ថា លោកសុខចិត្តធ្វើឲ្យបានដូចមនុស្សទាំងអស់ ក្នុងគ្រប់កាលៈទេសៈ ដើម្បីសង្គ្រោះមនុស្សទាំងអស់ (១ករ ៩, ១៩-២៣)។ អស់គង្វាលនៃសម្ពន្ធមេត្រីថ្មីក៏ត្រូវព្រះជាម្ចាស់ញែកទុកដោយឡែកម្យ៉ាងពីចំណោមប្រជារាស្ត្ររបស់ព្រះអង្គ ដោយព្រះអង្គត្រាស់ហៅអស់លោក និងដោយអស់លោកទទួលអគ្គសញ្ញាតែងតាំង។ ក៏ប៉ុន្តែ អស់លោកមិនផ្តាច់ពីប្រជារាស្ត្រនោះ ឬពីមនុស្សណាឡើយ ផ្ទុយទៅវិញព្រះជាម្ចាស់ញែកទុកអស់លោកដោយឡែកដូច្នេះ ដើម្បីបូជាកម្លាំងកាយកម្លាំងចិត្តបំពេញកិច្ចការដែលព្រះអម្ចាស់បានដាក់ឲ្យធ្វើ (កក ១៣, ២)។ ប្រសិនបើ អស់លោកមិនមែនជាសាក្សីអំពីជីវិតប្លែកពីជីវិតលោកីយ៍នេះ និងមិនមែនជាអ្នកចែកចាយពីជីវិតនោះឲ្យមនុស្សម្នាទេ អស់លោកមិនអាចបំពេញមុខងារជាអ្នកបម្រើរបស់ព្រះគ្រីស្តបានឡើយ។ ក៏ប៉ុន្តែ ប្រសិនបើអស់លោករស់នៅដាច់ដោយឡែកពីការរស់នៅ និងពីសភាពការណ៍ជីវភាពរបស់មនុស្សវិញ ក៏អស់លោកគ្មានប្រយោជន៍ក្នុងកិច្ចបម្រើមនុស្សលោកដែរ។ អស់លោកគង្វាល មិនត្រូវយកតម្រាប់តាមលោកីយ៍នេះឡើយ (រម ១២, ២) ព្រោះមុខងារបម្រើនោះទាមទារយ៉ាងពិសេសមិនឲ្យយកតម្រាប់តាមគេទេ ក៏ប៉ុន្តែមុខងារបម្រើនោះ ទាមទារឲ្យអស់លោករស់នៅក្នុងលោកីយ៍នេះ គឺនៅក្នុងចំណោមមនុស្សលោក។ ដូច្នេះ អស់លោកត្រូវតែជាគង្វាលដ៏ល្អដែលស្គាល់ចៀមរបស់ខ្លួន ហើយខិតខំស្វែងរកអស់ចៀមដែលមិននៅក្នុងក្រោលនេះ ដើម្បីឲ្យអ្នកទាំងនោះ អាចស្តាប់ព្រះសូរសៀងរបស់ព្រះគ្រីស្ត ក្នុងគោលបំណងឲ្យមានហ្វូងចៀមតែមួយ និងគង្វាលតែមួយ (យហ ១០, ១៤-១៦)។

គង្វាលត្រូវមានគុណសម្បត្តិខ្លះៗ ដែលជួយយ៉ាងខ្លាំងឲ្យកិច្ចការទាំងនោះបានសម្រេច គឺគុណសម្បត្តិដែលមនុស្សតែងតែចូលចិត្តយ៉ាងត្រឹមត្រូវក្នុងទំនាក់ទំនងជាមួយមនុស្សឯទៀតៗ គឺត្រូវមានចិត្តសប្បុរស ចិត្តស្មោះត្រង់ ចិត្តគំនិតរឹងប៉ឹង ចិត្តនឹងន ចិត្តព្យាយាមខន្តី ចិត្តឧស្សាហ៍ ស្វែងរកយុត្តិធម៌ ចិត្តទន់ភ្លន់ជាដើម។ គ្រីស្តទូតប៉ូល ផ្តែផ្តាំឲ្យមានគុណសម្បត្តិផ្សេងៗទៀត ដោយមានប្រសាសន៍ថា៖ *"សូមបងប្អូនគិតតែអំពីអ្វីៗដែលពិត ថ្លៃថ្នូរ សុចរិត បរិសុទ្ធ គួរឲ្យស្រឡាញ់ គួរឲ្យគោរព និងគំនិតណាដែលល្អឥតខ្ចោះគួរឲ្យកោតសរសើរ"* (ភល ៤, ៨)។

# ជំពូក ២

## មុខងារបម្រើរបស់អស់លោកគង្វាល

### ផ្នែកទី ១-បន្ទុករបស់អស់លោកគង្វាល

### ៤-លោកគង្វាលមានមុខងារបម្រើព្រះបន្ទូល

ជាបឋម ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ជួបជុំគ្នា ដោយសារព្រះបន្ទូលរបស់ព្រះអង្គ ដែលមានព្រះជន្មគង់នៅ (១សល ១, ២៣; កក ៦, ៧; ១២, ២៤)។ មនុស្សត្រូវតែស្ដាប់ព្រះបន្ទូលនេះយ៉ាងពិសេស ពីមាត់របស់អស់លោកគង្វាល (មឡ ២, ៧; ១ធម ៤, ១១-១៣; ២ធម ៤, ៥; ទត ១, ៩)។ ប្រសិនបើគេមិនផ្ញើជីវិតលើព្រះគ្រីស្ដទេ គ្មាននរណាម្នាក់អាចទទួលការសង្គ្រោះបានឡើយ (មក ១៦, ១៦)។ ហេតុនេះហើយ បានជាអស់លោកគង្វាលក្នុងឋានៈអស់លោកជាសហការីរបស់ក្រុមអភិបាល មានភារកិច្ចចម្បង គឺប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ឲ្យមនុស្សទាំងអស់ (២ករ ១១, ៧; ពន្លឺ ២៥)។ ដោយអស់លោកប្រតិបត្តិតាមព្រះបញ្ជារបស់ព្រះអម្ចាស់ថា *"អញ្ជើញនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់"* (មក ១៦, ១៥) អស់លោកតែងតាំងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ហើយធ្វើឲ្យប្រជារាស្ត្រនោះចម្រើនឡើងទៀតផង។ ព្រះបន្ទូលស្ដីអំពីការសង្គ្រោះ នាំឲ្យអ្នកមិនកាន់គ្រីស្ដសាសនា ភ្ញាក់ស្មារតីផ្ញើជីវិតលើព្រះគ្រីស្ដ ហើយក៏ចិញ្ចឹមជំនឿរបស់គ្រីស្ដបរិស័ទដែរ។ ជំនឿនេះក៏ធ្វើឲ្យសហគមន៍អ្នកជឿកើតនិងចម្រើនឡើង ស្របតាមគ្រីស្ដទូតមានប្រសាសន៍ថា៖ *"ជំនឿកើតមកពីសេចក្ដីដែលយើងបានស្ដាប់ឮ រីឯសេចក្ដីដែលយើងបានស្ដាប់ឮនោះ កើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ដ"* (រម ១០, ១៧)។

ដូច្នេះ អស់លោកគង្វាល មានកាតព្វកិច្ចចែករំលែកសេចក្ដីពិត នៃដំណឹងល្អដល់មនុស្សទាំងអស់ (កាឡ ២, ៥) គឺសេចក្ដីពិតដែលព្រះអម្ចាស់បានប្រោសឲ្យអស់លោកទទួលផ្ទាល់។ ហេតុនេះហើយ នៅពេលអស់លោកកាន់កិរិយាមារយាទឲ្យបានថ្លៃថ្នូរក្នុងចំណោមសាសន៍ដទៃ ដើម្បីនាំគេឲ្យលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (១សល ២, ១២) នៅពេលអស់លោកប្រកាសគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ដ ដោយប្រកាសដំណឹងល្អជាសាធារណៈ ឲ្យអស់អ្នកដែលពុំមានជំនឿស្ដាប់ឮ នៅពេលអស់លោកបញ្ជូនបន្តសេចក្ដីបង្រៀននៃគ្រីស្ដសាសនា ឬរៀបរាប់ពន្យល់លទ្ធិនៃព្រះសហគមន៍ ហើយនៅពេលអស់លោកសិក្សានិងខិតខំរកដំណោះស្រាយបញ្ហានានានៃសម័យឥឡូវ ដោយយកព្រះពន្លឺព្រះគ្រីស្ដមកបំភ្លឺ ក្នុងករណីទាំងនោះ អស់លោកមិនត្រូវបង្រៀនសេចក្ដីកើតមកពីប្រាជ្ញារបស់ខ្លួនផ្ទាល់នោះទេ តែត្រូវបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ជានិច្ចវិញ។ អស់លោកក៏ត្រូវទទូចអញ្ជើញមនុស្សទាំងអស់ឲ្យប្រែចិត្តគំនិតមករកព្រះជាម្ចាស់ និងឲ្យបានទៅជាជនដ៏វិសុទ្ធទៀតផង។ តាមពិត អស់លោកបូជាចារ្យសែនពិបាកប្រកាសសេចក្ដីទាំងនោះ ក្នុងសភាពការណ៍ពិភពលោកនាបច្ចុប្បន្នកាល។ ប្រសិនបើអស់លោកចង់ឲ្យអ្នកស្ដាប់រំភើបចិត្តចាប់អារម្មណ៍នឹងសេចក្ដីដែលអស់លោកប្រកាសយ៉ាងពិតមែន អស់លោកមិនត្រូវត្រឹមតែរៀបរាប់ពន្យល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់

តាមរបៀបទូទៅ និងតាមរបៀបជាអរូបីប៉ុណ្ណោះទេ តែត្រូវយកសេចក្តីពិតនៃដំណឹងល្អដែលនៅស្ថិតស្ថេររហូតមកបំភ្លឺសភាពការណ៍ដ៏ពិតប្រាកដនៃការរស់នៅរបស់មនុស្សវិញ។

គង្វាលបំពេញមុខងារបម្រើព្រះបន្ទូលតាមរបៀបផ្សេងៗជាច្រើន តាមតម្រូវការនានារបស់អ្នកស្តាប់ និងតាមព្រះអំណោយទានរបស់អ្នកប្រកាស។ នៅតំបន់ណា ឬក្នុងក្រុមក្នុងសង្គមណា ដែលគ្មានគ្រីស្តបរិស័ទរស់នៅ ត្រូវណែនាំឲ្យមនុស្សមកផ្ញើជីវិតលើព្រះគ្រីស្ត និងទទួលអគ្គសញ្ញានៃការសង្គ្រោះបាន ដោយប្រកាសដំណឹងល្អ (មថ ២៨, ១៩; មក ១៦, ១៦)។ រីឯក្នុងសហគមន៍គ្រីស្តបរិស័ទវិញ ជាពិសេសចំពោះអស់អ្នកដែលហាក់ដូចជាមិនសូវមានជំនឿ ឬមិនយល់អំពីមូលហេតុនៃអ្វីដែលគេកំពុងប្រតិបត្តិនោះ ត្រូវតែប្រកាសព្រះបន្ទូលជាចាំបាច់។ អគ្គសញ្ញាទាំងប៉ុន្មាន សុទ្ធតែជាអគ្គសញ្ញាបញ្ជាក់ជំនឿ ហេតុការណ៍ប្រកាសព្រះបន្ទូល គឺភ្ជាប់នឹងមុខងារបម្រើធ្វើអគ្គសញ្ញា។ រីឯជំនឿវិញ កើតមកពីព្រះបន្ទូល ហើយមានជីវិតរស់រវើក ក៏ដោយសារព្រះបន្ទូលដែរ (ពិធី ២៥)។ សេចក្តីនេះ មានសារៈសំខាន់ពិសេសចំពោះពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់ក្នុងអភិបូជា។ ក្នុងអភិបូជា គឺមានប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ភ្ជាប់ជាមួយនឹងចម្លើយរបស់ប្រជាជនដែលស្តាប់ឮ ហើយក៏ភ្ជាប់នឹងព្រះគ្រីស្តដែលបូជាព្រះជន្មថ្វាយ និងចងសម្ពន្ធមេត្រីថ្មី ដោយបង្ហូរព្រះលោហិតព្រះអង្គ។ អស់អ្នកជឿក៏រួបរួមជាមួយព្រះគ្រីស្តដែលបូជាព្រះជន្មនោះ ដោយអធិដ្ឋានផង និងដោយទទួលអគ្គសញ្ញាអរព្រះគុណផង (ពីធី ៣៣.៣៥.៤៨.៥២.)។

## ៥-គង្វាល ជាអ្នកបម្រើអគ្គសញ្ញានានា និងអគ្គសញ្ញាអរព្រះគុណ

មានតែព្រះជាម្ចាស់មួយព្រះអង្គគត់ ជាព្រះដ៏វិសុទ្ធ ដែលអាចប្រោសមនុស្សឲ្យបានវិសុទ្ធបាន។ ព្រះអង្គ សព្វព្រះហឫទ័យលើកយកមនុស្សធ្វើជាសហការី និងធ្វើជាអ្នកបម្រើដ៏សុភាពរាបសាក្នុងព្រះរាជកិច្ចប្រោសឲ្យ មនុស្សបានវិសុទ្ធនោះ។ ហេតុនេះហើយ ព្រះជាម្ចាស់ញែកគង្វាលឲ្យរួមចំណែកតាមរបៀបពិសេស ក្នុងមុខងារបម្រើរបស់ព្រះគ្រីស្តជាមហាបូជាចារ្យ តាមរយៈមុខងារបម្រើរបស់អភិបាល។ អស់លោកគង្វាលប្រព្រឹត្តកិច្ចការក្នុងឋានៈជាអ្នកបម្រើរបស់ព្រះអង្គក្នុងពិធីដ៏សក្ការៈនានា គឺក្នុងពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ទាំងនោះ ព្រះគ្រីស្តបំពេញមុខងាររបស់ព្រះអង្គជាមហាបូជាចារ្យជានិច្ចនិរន្តរ៍ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីជាប្រយោជន៍ដល់យើង។ ដោយអស់លោកធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ អស់លោកបញ្ចូលមនុស្សទៅក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ដោយធ្វើអគ្គសញ្ញាលើកលែងទោស អស់លោកសម្រុះសម្រួលអ្នកបាបឲ្យជានាជាមួយព្រះជាម្ចាស់ និងជានាជាមួយព្រះសហគមន៍។ ដោយអស់លោកធ្វើអគ្គសញ្ញាលាបប្រេងអ្នកជំងឺ អស់លោកជួយសម្រាលទុក្ខអស់អ្នកដែលឈឺចុកចាប់។ ជាពិសេសនៅពេលថ្វាយអភិបូជា អស់លោកថ្វាយសក្ការបូជារបស់ព្រះគ្រីស្ត តាមរបៀបជាអគ្គសញ្ញា។ ពេលណាអស់លោកធ្វើអគ្គសញ្ញាមួយក្នុងចំណោមអគ្គសញ្ញាទាំងនោះ អស់លោកគង្វាលក៏នៅភ្ជាប់ជាមួយលោកអភិបាល តាមលំដាប់លំដោយ និងតាមរបៀបផ្សេងៗ ហាក់ដូចជាធ្វើឲ្យលោកអភិបាលមានវត្តមានម៉្យាង ក្នុងសហគមន៍គ្រីស្តបរិស័ទនីមួយៗដែរ (ពន្លឺ ២៨)។ តាំងពីជំនាន់ដើមនៃព្រះសហគមន៍មកម្ល៉េះ សន្តៈអ៊ីញ៉ាស ជាមរណសាក្សីបញ្ជាក់រួចមកហើយថា អស់លោកគង្វាលក៏នៅភ្ជាប់ជាមួយលោកអភិបាលដូច្នោះដែរ។

អគ្គសញ្ញានានា និងមុខងារបម្រើទាំងអស់ក្នុងព្រះសហគមន៍ ព្រមទាំងគ្រប់កិច្ចការជាគ្រីស្តទូត គឺជាប់ពាក់ព័ន្ធជាមួយនឹងអគ្គសញ្ញាអរព្រះគុណដ៏សក្ការៈ ហើយក៏តម្រង់ទៅរកអគ្គសញ្ញាអរព្រះគុណនេះដែរ។ ក្នុងអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធបំផុត មានកប់ទុកសម្បត្តិដ៏មានតម្លៃទាំងមូលខាងព្រះវិញ្ញាណរបស់ព្រសហគមន៍ ពោលគឺព្រះគ្រីស្តផ្ទាល់តែម្តង ព្រះអង្គពិតជាយញ្ញបូជាថ្វាយក្នុងឱកាសបុណ្យចម្លងរបស់យើង ព្រះអង្គពិតជានំប៉័ងដែលមានជីវិត។ ដោយ

ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសឲ្យសាច់ឈាមរបស់ព្រះអង្គទទួលព្រះជន្មថ្មីដ៏រុងរឿង និងអាចផ្ដល់ជីវិតព្រះអង្គ ក៏ផ្ដល់ជីវិតឲ្យមនុស្សលោក។

ព្រះគ្រីស្តអញ្ជើញ និងណែនាំមនុស្សលោកឲ្យថ្វាយខ្លួនរួមជាមួយព្រះអង្គ គឺថ្វាយទាំងខ្លួនគេផ្ទាល់ ការងាររបស់គេ និងសត្វលោកទាំងប៉ុន្មានដែលព្រះជាម្ចាស់ប្រតិស្ឋានមក។ ដូច្នេះ អគ្គសញ្ញាអរព្រះគុណលេចចេញយ៉ាងជាក់ច្បាស់ថា ជាប្រភព និងជាកំពូលនៃកិច្ចប្រកាសដំណឹងល្អគ្រប់យ៉ាង។ ព្រះសហគមន៍ណែនាំអ្នកកំពុងស្តាប់ព្រះបន្ទូលលាន់ឮឡើង ត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ឲ្យរួមចូលក្នុងអភិបូជាបន្តិចម្ដងៗ។ រីឯគ្រីស្តបរិស័ទ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្ងាសរួចហើយ គេក៏ចូលរួមយ៉ាងពេញលក្ខណៈក្នុងព្រះកាយព្រះគ្រីស្ត ដោយសារអគ្គសញ្ញាអរព្រះគុណដែរ។ ហេតុនេះហើយ បានជាអង្គប្រជុំដែលថ្វាយអភិបូជា ពិតជាស្នូលនៃសហគមន៍គ្រីស្តបរិស័ទ ដែលមានលោកគង្វាលជាប្រធាន។ ហេតុនេះ លោកគង្វាលត្រូវតែអប់រំគ្រីស្តបរិស័ទឲ្យថ្វាយយញ្ញរបស់ព្រះអម្ចាស់ទៅព្រះបិតាក្នុងអភិបូជា ព្រមទាំងឲ្យថ្វាយការរស់នៅរបស់គេទៅព្រះបិតា ភ្ជាប់នឹងយញ្ញនោះផងដែរ។ ដោយយោងតាមគោលគំនិតរបស់ព្រះគ្រីស្តជាគង្វាល អស់លោកគង្វាលត្រូវអប់រំគ្រីស្តបរិស័ទ ឲ្យលន់តួអំពើបាបរបស់ខ្លួនចំពោះព្រះសហគមន៍ក្នុងអគ្គសញ្ញាលើកលែងទោស ដោយចិត្តសោកស្ដាយថា ខ្លួនបានប្រព្រឹត្តអំពើបាបមែន។ ដូច្នេះ គេប្រែចិត្តគំនិតបែរទៅរកព្រះអម្ចាស់ឲ្យកាន់តែជិតស្និទ្ធឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ទាំងនឹកដល់ព្រះបន្ទូលរបស់ព្រះអង្គថា៖ *"ចូរប្រែចិត្តគំនិត ដ្បិតព្រះដ៏ខ្ពង់ខ្ពស់បំផុតយាងមកគ្រងរាជ្យ នៅពេលឆាប់ៗខាងមុខនេះហើយ!"* (មថ ៤, ១៧)។ លោកគង្វាល ក៏ត្រូវបង្រៀនគ្រីស្តបរិស័ទឲ្យចូលរួមក្នុងពិធីនានា គោរពប្រណិប័តន៍ព្រះជាម្ចាស់ តាមរបៀបគេអាចអធិដ្ឋានដោយចិត្តស្មោះក្នុងពិធីទាំងនោះ។ អស់លោកត្រូវណែនាំគ្រីស្តបរិស័ទ ឲ្យមានចិត្តគំនិតអធិដ្ឋានឲ្យកាន់តែប្រសើរឡើងៗជានិច្ច ក្នុងគ្រប់កាលៈទេសៈប្រចាំជីវិតរបស់គេ តាមតែព្រះអំណោយទាន និងតាមតម្រូវការរបស់ម្នាក់ៗ។ អស់លោកគង្វាលត្រូវណែនាំគ្រីស្តបរិស័ទទាំងអស់ ឲ្យមានបំណងប្រាថ្នាបំពេញគ្រប់ភារកិច្ច តាមសភាពកាណ៍ជាប្រចាំ តាមការរស់នៅរបស់ខ្លួន។ អស់លោកក៏ត្រូវណែនាំគ្រីស្តបរិស័ទ ដែលមានបទពិសោធន៍អំពីព្រះយេស៊ូយ៉ាងជ្រៅជាងគេ ឲ្យរស់នៅតាមព្រះដំបូន្មានដែលមានចែងក្នុងគម្ពីរដំណឹងល្អ សមស្របតាមសមត្ថភាពរៀងៗខ្លួន។ សរុបសេចក្ដីមក អស់លោកគង្វាល ត្រូវបង្រៀនគ្រីស្តបរិស័ទ ឲ្យលើកតម្កើងព្រះអម្ចាស់អស់ពីជម្រៅចិត្ត ដោយប្រើបទសរសើរ និងបទចម្រៀងមកពីព្រះវិញ្ញាណ ព្រមទាំងអរព្រះគុណព្រះជាម្ចាស់ ជាព្រះបិតានៅគ្រប់ពេលវេលា និងក្នុងគ្រប់កិច្ចការក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង (អភ ៥, ១៩-២០)។

លោកគង្វាលលើកកម្ដើង និងអរព្រះគុណព្រះជាម្ចាស់នៅពេលអស់លោកថ្វាយអភិបូជា។ អស់លោកបន្តកិច្ចនោះនៅគ្រប់ម៉ោងប្រចាំថ្ងៃ ដោយពិធីលើកតម្កើងព្រះអង្គតាមពេលកំណត់។ ក្នុងពិធីតាមពេលកំណត់ទាំងនោះ អស់លោកអធិដ្ឋានក្នុងនាមព្រះសហគមន៍សម្រាប់ប្រជាជនទាំងមូល ដែលព្រះជាម្ចាស់បានផ្ញើមកឲ្យអស់លោក និងសម្រាប់ពិភពលោកទាំងមូលផងដែរ។

ដំណាក់អធិដ្ឋាន ជាកន្លែងថ្វាយអភិបូជាដ៏វិសុទ្ធបំផុត និងជាកន្លែងរក្សាទុកនំប៉័ងប្រសិទ្ធិ ក៏ជាកន្លែងគ្រីស្តបរិស័ទតែងតែជួបជុំគ្នាដែរ។ នៅកន្លែងនោះ គ្រីស្តបរិស័ទតែងនមស្សការថ្វាយបង្គំព្រះបុត្រារបស់ព្រះជាម្ចាស់ ជាព្រះសង្គ្រោះនៃយើង ដែលយើងថ្វាយលើតុនៃសក្ការបូជា។ គ្រីស្តបរិស័ទនមស្សការថ្វាយបង្គំព្រះអង្គដែលមានវត្តមាននៅទីនោះ ដើម្បីជួយគាំទ្រ និងសម្រាលទុក្ខគេ។ ហេតុនេះហើយ ត្រូវឲ្យដំណាក់អធិដ្ឋាននេះបានស្អាតល្អប្រណិត និងសមរម្យសម្រាប់អធិដ្ឋាន និងធ្វើពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់។ ព្រះជាម្ចាស់អញ្ជើញទាំងគង្វាល ទាំងគ្រីស្តបរិស័ទឲ្យមកឆ្លើយ

តបស្នងសងគុណនឹងព្រះអំណោយទានរបស់ព្រះគ្រីស្ត ដែលទ្រង់រមែងតែចាក់បង្ហូរព្រះជន្មរបស់ព្រះជាម្ចាស់ មកក្នុងសរីរាង្គនៃព្រះកាយព្រះអង្គឥតឈប់ឈរ តាមរយៈសាច់ឈាមព្រះអង្គក្នុងឋានៈជាមនុស្ស។ អស់លោកគង្វាល ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលខ្លួនឲ្យមានចំណេះចេះដឹងយ៉ាងសមគួរអំពី វិទ្យានៃពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងអំពីសិល្បៈក្នុងពិធីទាំងនោះ ឲ្យកាន់តែល្អឡើងៗដែរ។ ដូច្នេះ អស់លោកបំពេញមុខងារបម្រើការគោរពប្រណិប័តន៍ព្រះជាម្ចាស់ ទាំងណែនាំគ្រីស្តបរិស័ទដែលព្រះសហគមន៍ផ្ញើមកអស់លោក លើកតម្កើងព្រះជាម្ចាស់ គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យកាន់តែប្រសើរឡើងៗទៀតផង។

## ៦-លោកគង្វាល ជាមេដឹកនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់

អស់លោកគង្វាលបំពេញបន្ទុករបស់ព្រះគ្រីស្តជាគង្វាល និងជាព្រះសិរសា ក្នុងនាមលោកអភិបាល តាមចំណែកនៃអំណាចរបស់ខ្លួនផ្ទាល់។ អស់លោកប្រមូលមហាគ្រួសាររបស់ព្រះជាម្ចាស់ ជាក្រុមបងប្អូនដែលមានចិត្តថ្លើមតែមួយ ព្រមទាំងណែនាំគេទៅកាន់ព្រះជាម្ចាស់ជាព្រះបិតា ដោយអង្គព្រះគ្រីស្ត រួមក្នុងព្រះវិញ្ញាណដ៏វិសុទ្ធផង (ពន្លឺ ២៨)។ អស់លោកទទួលសមត្ថភាពម្យ៉ាង ខាងព្រះវិញ្ញាណសម្រាប់បំពេញមុខងារបម្រើនោះ ក៏ដូចជាសម្រាប់បំពេញបន្ទុកឯទៀតៗដែរ។ ព្រះជាម្ចាស់ប្រទានសមត្ថភាពនេះ ដើម្បីកសាងព្រះសហគមន៍ (២ករ ១០, ៨; ១៣, ១០)។ ក្នុងកិច្ចកសាងព្រះសហគមន៍នេះ អស់លោកគង្វាលត្រូវមានចិត្តសប្បុរសហួសពន់ប្រមាណ ចំពោះមនុស្សទាំងអស់ គឺត្រូវយកតម្រាប់តាមព្រះអម្ចាស់ជាគំរូ។ ក៏ប៉ុន្តែ អស់លោកមិនត្រូវប្រព្រឹត្តចំពោះមនុស្ស ដោយចង់ផ្គាប់ចិត្តគេទេ (១ករ ៤, ១៤) តែត្រូវប្រព្រឹត្តចំពោះគេតាមការទាមទារនៃលទ្ធិគ្រីស្តសាសនា និងរបៀបរស់នៅជាគ្រីស្តបរិស័ទ គឺត្រូវបង្រៀន និងអប់រំគេដូចកូនដ៏ជាទីស្រឡាញ់ ស្របតាមគ្រីស្តទូតប៉ូលមានប្រសាសន៍ថា៖ *"ទោះមានឱកាសល្អក្តី មិនល្អក្តី ត្រូវពន្យល់គេឲ្យដឹងខុសត្រូវ ស្តីបន្ទោស ដាស់តឿន និងបង្រៀនគេ ដោយចិត្តអត់ធ្មត់គ្រប់ជំពូក"* (២ធម ៤, ២)។

តាមឋានៈជាអ្នកអប់រំជំនឿ អស់លោកគង្វាល ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលគ្រីស្តបរិស័ទម្នាក់ៗ ដោយខ្លួនលោកផ្ទាល់ ឬដោយសារអ្នកផ្សេងៗទៀត ឲ្យគេបានទៅជាមនុស្សពេញលក្ខណៈ តាមដំណឹងល្អក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងស្របតាមព្រះជាម្ចាស់ត្រាស់ហៅ។ ត្រូវអប់រំគេឲ្យមានសេចក្តីស្រឡាញ់យ៉ាងស្មោះ និងសកម្ម ព្រមទាំងឲ្យមានសេរីភាពដ៏ពិតប្រាកដ ជាសេរីភាពដែលព្រះគ្រីស្តបានប្រើ ដើម្បីរំដោះយើង (កាឡ ៤, ៣; ៥, ១.១៣)។ ពិធីនានាទោះបីរុងរឿងយ៉ាងណាក្តី ប្រជុំនានាទោះបីធំៗយ៉ាងណាក្តី មានសារៈប្រយោជន៍ លុះត្រាតែពិធី និងប្រជុំទាំងនោះ អប់រំមនុស្សឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ។ អស់លោកគង្វាលអប់រំមនុស្សឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ដោយជួយគេឲ្យយល់ដឹងពីអត្ថន័យព្រឹត្តិការណ៍នានាទាំងធំ ទាំងតូច គឺយល់អំពីអ្វីដែលសភាព ការណ៍ទាមទារឲ្យគេប្រព្រឹត្តជាអ្វីៗ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេធ្វើ។ ម្យ៉ាងទៀត ត្រូវអប់រំគ្រីស្តបរិស័ទមិនត្រូវឲ្យគេរស់សម្រាប់តែខ្លួនឯងប៉ុណ្ណោះទេ តែត្រូវឲ្យរស់នៅសម្រាប់បម្រើអ្នកឯទៀតៗវិញ តាមតែព្រះអំណោយទាន ដែលម្នាក់ៗបានទទួល គឺឲ្យបានស្របតាមធម្មវិន័យថ្មី ស្តីអំពីសេចក្តីស្រឡាញ់ទាមទារនោះ។ (១សល ៤, ១០ត)។ ដូច្នេះគ្រីស្តបរិស័ទទាំងអស់ នឹងបំពេញតួនាទីរបស់ខ្លួនក្នុងសហគមន៍មនុស្ស។

អស់លោកគង្វាល មានភាតព្វកិច្ច បម្រើមនុស្សទាំងអស់ ក៏ប៉ុន្តែ អស់លោកត្រូវយល់ឃើញថា ព្រះអម្ចាស់ផ្ញើទុកជនក្រីក្រ និងអ្នកទន់ខ្សោយជាងគេ ឲ្យអស់លោកថែទាំយ៉ាងពិសេស។ ព្រះអម្ចាស់ផ្ទាល់នៅភ្ជាប់ជាមួយជនទាំងនោះ (មថ ២៥, ៣៤-៤៥) ព្រះអង្គក៏លើកការប្រកាសដំណឹងល្អដល់អ្នកទាំងនោះ ទុកជាសញ្ញាសម្គាល់ អំពីព្រះរាជកិច្ចរបស់

ព្រះគ្រីស្តផងដែរ (លក ៤, ១៨)។ អស់លោកគង្វាល ក៏ត្រូវយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះយុវជនយុវនារី ចំពោះគូស្វាមីភរិយា និងចំពោះអស់អ្នកដែលជាឪពុកម្ដាយផងដែរ។ គួរណាស់ឲ្យអ្នកទាំងនេះជួបជុំគ្នាជាក្រុមមិត្តសម្លាញ់ ដើម្បីជួយគ្នាទៅវិញទៅមកឲ្យរស់នៅក្នុងឋានៈជាគ្រីស្តបរិស័ទ ឲ្យកាន់តែស្រួលនិងកាន់តែប្រសើរឡើង ក្នុងសភាពការណ៍ដ៏លំបាករបស់គេ។ អស់លោកមិនត្រូវបំភ្លេចបព្វជិតបព្វជិតា ព្រោះថា បព្វជិតបព្វជិតាជាចំណែកដ៏ប្រសើរជាងគេ ក្នុងព្រះដំណាក់របស់ព្រះអម្ចាស់ ដែលសមឲ្យលោកគង្វាលថែទាំគេយ៉ាងពិសេស ដើម្បីឲ្យជីវិតខាងព្រះវិញ្ញាណរបស់គេចម្រើនឡើង សម្រាប់ជាប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។ មិនតែប៉ុណ្ណោះ អស់លោកគង្វាលត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតចំពោះអស់អ្នកជំងឺ និងអ្នកហៀបនឹងទទួលមរណភាព គឺត្រូវទៅសួរសុខទុក្ខគេ និងលើកទឹកចិត្តគេដោយរួមក្នុងអង្គព្រះអម្ចាស់ (ពន្លឺ ១៨)។

បន្ទុកជាគង្វាល មិនមែនត្រឹមតែសំដៅឲ្យថែរក្សាគ្រីស្តបរិស័ទម្នាក់ៗប៉ុណ្ណោះទេ តែភ្ជាប់ទៅនឹងបន្ទុកបង្កើតសហគមន៍គ្រីស្តបរិស័ទយ៉ាងពិតប្រាកដថែមទៀតដែរ។ ប៉ុន្តែ សហគមន៍មានគំនិតជាសហគមន៍ពិតមែន លុះត្រាតែគេមិនគិតតែពីព្រះសហគមន៍ក្នុងតំបន់មួយប៉ុណ្ណោះទេ តែគេត្រូវនឹកគិតដល់ព្រះសហគមន៍សកលថែមទៀតផង។ សហគមន៍នៅតំបន់នីមួយៗ មិនត្រូវគិតគូរត្រឹមតែថែទាំគ្រីស្តបរិស័ទរបស់ខ្លួនប៉ុណ្ណោះទេ តែត្រូវមានចិត្តឧហ្សាហ៍បំពេញកិច្ចជាគ្រីស្តទូត និងត្រួសត្រាយផ្លូវឲ្យមនុស្សទាំងអស់ ឆ្ពោះទៅកាន់ព្រះគ្រីស្តទៀតផង។ សហគមន៍នៅតំបន់នីមួយៗ ត្រូវយកចិត្តទុកដាក់យ៉ាងពិសេស នឹងអស់អ្នកដែលកំពុងស្តាប់ព្រះបន្ទូលលាន់ឮឡើង ត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក ព្រមទាំងនឹងអស់អ្នកដែលទើបនឹងទទួលអគ្គសញ្ញាជ្រមុជទឹកដែរ។ ត្រូវអប់រំណែនាំគេបន្តិចម្តងៗឲ្យស្គាល់ជីវិត តាមរបៀបជាគ្រីស្តបរិស័ទ និងស្គាល់ការរស់នៅតាមគ្រីស្តសាសនា។

ទោះជាយ៉ាងណាក៏ដោយ គ្មានសហគមន៍គ្រីស្តបរិស័ទណាអាចកសាងខ្លួនឡើងបានឡើយ បើមិនយកអភិបូជាធ្វើជាឫសនិងជាស្នូល។ ហេតុនេះហើយ បានជាត្រូវចាប់ផ្តើមអប់រំគ្រីស្តបរិស័ទឲ្យមានគំនិតជាសហគមន៍គ្រប់យ៉ាងដោយអភិបូជានេះ។ ក៏ប៉ុន្តែ ប្រសិនបើគ្រីស្តបរិស័ទថ្វាយអភិបូជាដោយចិត្តស្មោះ និងយ៉ាងពេញលេញ គេមុខជានឹងបង្កើតសកម្មភាពផ្សេងៗ សម្តែងសេចក្តីស្រឡាញ់ និងជួយគ្នាទៅវិញទៅមក ព្រមទាំងនាំគ្នាប្រកាសដំណឹងល្អ ហើយផ្តល់សក្ខីភាពគ្រប់យ៉ាងទៀតផង។

ម្យ៉ាងទៀត ដោយសហគមន៍គ្រីស្តបរិស័ទមានសេចក្តីស្រឡាញ់ ដោយអធិដ្ឋាន ដោយធ្វើជាគំរូល្អដល់គេ និងខិតខំប្រែចិត្តគំនិត ព្រះសហគមន៍បំពេញតួនាទីជាម្តាយដ៏ពិតប្រាកដ ដើម្បីណែនាំមនុស្សទៅកាន់ព្រះគ្រីស្តមែន។ សហគមន៍គ្រីស្តបរិស័ទ ក៏ពិតជាឧបករណ៍ដ៏ស័ក្តិសិទ្ធិ ដែលបង្ហាញ និងសម្រួលផ្លូវឆ្ពោះទៅកាន់ព្រះគ្រីស្ត និងឆ្ពោះទៅកាន់ព្រះសហគមន៍របស់ព្រះអង្គ សម្រាប់អស់អ្នកដែលពុំទាន់មានជំនឿ។ ម្យ៉ាងទៀត ព្រះសហគមន៍ក៏ជាឧបករណ៍ដ៏ស័ក្តិសិទ្ធិមួយ ក្នុងការដាស់តឿនអស់គ្រីស្តបរិស័ទ ឲ្យភ្ញាក់ស្មារតី ចិញ្ចឹមជំនឿរបស់គេ និងផ្តល់កម្លាំងសម្រាប់តយុទ្ធខាងវិញ្ញាណផងដែរ។

ពេលសាងសង់សហគមន៍គ្រីស្តបរិស័ទ អស់លោកគង្វាលមិនត្រូវបម្រើមនោគមវិជ្ជាណាមួយជាដាច់ខាត ហើយក៏មិនត្រូវបម្រើក្រុមណាមួយឡើយ។ លោកគង្វាល ក្នុងឋានៈជាអ្នកប្រកាសដំណឹងល្អ និងជាគង្វាលរបស់ព្រះសហគមន៍ត្រូវបូជាកម្លាំងកាយកម្លាំងចិត្ត ដើម្បីឲ្យព្រះកាយរបស់ព្រះគ្រីស្តចម្រើនឡើងខាងព្រះវិញ្ញាណវិញ។

## ផ្នែកទី ២-ទំនាក់ទំនងរវាងលោកគង្វាល និងមនុស្សឯទៀត។

### ៧-ទំនាក់ទំនងរវាងអភិបាលនឹងក្រុមគង្វាល

អស់លោកគង្វាលរួមជាមួយលោកអភិបាល សុទ្ធតែរួមចំណែកក្នុងមុខងារបម្រើរបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យ។ អាស្រ័យហេតុនេះហើយ ដោយសារព្រះជាម្ចាស់ញែកអស់លោកប្រសិទ្ធិទៅជាបូជាចារ្យដូចគ្នា និងប្រទានបេសកកម្មតែមួយឲ្យអស់លោក ទើបអស់លោកត្រូវរួបរួមជាមួយក្រុមអភិបាល តាមលំដាប់លំដោយ (ពន្លឺ ២៨)។ យើងឃើញយ៉ាងជាក់ច្បាស់ថា ក្រុមគង្វាល និងក្រុមអភិបាលរួបរួមគ្នាដូច្នេះ នៅពេលអស់លោករួមថ្វាយអភិបូជាជាមួយគ្នា នៅពេលអស់លោកគង្វាលថ្វាយអភិបូជាម្តងៗ លោកប្រកាសបញ្ជាក់យ៉ាងច្បាស់ថា លោករួបរួមជាមួយក្រុមអភិបាលដែរ។ ហេតុនេះហើយ ក្រុមអភិបាលត្រូវចាត់អស់លោកគង្វាល ទុកជាសហការីនិងជាទីប្រឹក្សាដ៏ចាំបាច់ដោយអាក់ខានមិនបាន ក្នុងកិច្ចបំពេញបន្ទុក និងមុខងារបម្រើព្រះសហគមន៍របស់អស់លោក គឺបង្រៀន និងនាំឲ្យមនុស្សលោកបានវិសុទ្ធ ព្រមទាំងធ្វើជាគង្វាលនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ផងដែរ ព្រោះលោកគង្វាល ទាំងប៉ុន្មានបានទទួលព្រះអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលអស់លោកទទួលអគ្គសញ្ញា\តែងតាំង។ តាំងពីដើមកំណើតនៃព្រះសហគមន៍មក ឯកសារនានាស្តីអំពីពិធីគោរពបម្រើព្រះជាម្ចាស់ គូសសង្កត់ការរួបរួមនេះ គឺក្នុងឯកសារទាំងនោះមានចែងពាក្យអង្វរព្រះជាម្ចាស់យ៉ាងឱឡារិក សូមព្រះអង្គចាក់បង្ហូរ *"ព្រះវិញ្ញាណនៃព្រះហឫទ័យប្រោសប្រណី និងនៃព្រះប្រាជ្ញាញាណដើម្បីឲ្យអ្នកដែលទទួលអគ្គសញ្ញាតែងតាំង អាចជួយថែរក្សានិងគ្រប់គ្រងប្រជារាស្ត្រ ដោយចិត្តបរិសុទ្ធទៀងត្រង់ផង"*។ កាលពីដើមក៏ដូច្នេះដែរ គឺនៅវាលរហោស្ថាន ព្រះជាម្ចាស់យកវិញ្ញាណរបស់លោកម៉ូសេ ដាក់ក្នុងព្រឹទ្ធាចារ្យឆ្លាតវាងវៃចិតសិបនាក់ (ជប ១១, ១៦-២៥) *"ដើម្បីឲ្យលោកម៉ូសេ អាចគ្រប់គ្រងប្រជាជាតិដ៏ច្រើនឥតគណនា យ៉ាងងាយស្រួលតាមរយៈព្រឹទ្ធាចារ្យទាំងនោះ"*។

ហេតុនេះហើយ ដោយអស់លោកគង្វាល និងអភិបាលរួបរួមគ្នាក្នុងឋានៈជាបូជាចារ្យ និងក្នុងមុខងារបម្រើតែមួយដូច្នេះ អភិបាលត្រូវតែចាត់ទុកអស់លោកគង្វាល ជាបងប្អូន និងទុកជាមិត្តសម្លាញ់ផងដែរ (ពន្លឺ ២៨)។ អភិបាលត្រូវយកចិត្តទុកដាក់នឹងតម្រូវការរបស់លោកគង្វាល ខាងសម្ភារៈជាមុន និងយកចិត្តទុកដាក់ជាពិសេសផងដែរ នឹងតម្រូវការខាងវិញ្ញាណរបស់អស់លោក តាមតែអស់លោកអភិបាលអាចធ្វើបាន។ អស់លោកអភិបាលមានភារកិច្ចដ៏សំខាន់ គឺណែនាំអស់លោកបូជាចារ្យរបស់អស់លោកឲ្យបានវិសុទ្ធ។ ម្ល៉ោះហើយ អភិបាលត្រូវតែយកចិត្តទុកដាក់យ៉ាងខ្លាំងជាទីបំផុត បណ្តុះបណ្តាលក្រុមគង្វាលភូមិភាគរបស់អស់លោកជាអចិន្ត្រៃយ៍ (អភិបាល ១៥.១៦)។ អភិបាលត្រូវតែស្តាប់អស់លោក សួរយោបល់របស់អស់លោក ហើយសន្ទនាពិគ្រោះជាមួយអស់លោកអំពីកិច្ចនានាជាគង្វាល និងអំពីអ្វីៗដែលជាប្រយោជន៍ដល់ភូមិភាគទាំងមូល។ ត្រូវតែងតាំងក្រុមមួយ ឬគណៈកម្មាធិការបូជាចារ្យមួយជាតំណាងក្រុមគង្វាល សមស្របតាមសភាពកាលណ៍ និងតាមតម្រូវការនាបច្ចុប្បន្នកាលនេះ ដើម្បីឲ្យសេចក្តីណែនាំនេះកើតជារូបរាងបាន។ ត្រូវបញ្ជាក់រចនាសម្ពន្ធមួយ និងដំណើរការក្រុមនេះតាមក្បួនច្បាប់ ដើម្បីឲ្យក្រុមនេះ ផ្តល់យោបល់អាចជួយលោកអភិបាលយ៉ាងសកម្ម ក្នុងការគ្រប់គ្រងភូមិភាគបាន។

ចំពោះអស់លោកគង្វាលវិញ អស់លោកត្រូវនឹកគិតជានិច្ចថា អភិបាលបានទទួលអគ្គសញ្ញាតែងតាំងជា បូជាចារ្យយ៉ាងពេញលក្ខណៈ ហេតុនេះហើយអស់លោកគង្វាល ត្រូវគោរពអភិបាលដោយចាត់ទុកអស់លោកថា មានអំណាចរបស់ព្រះគ្រីស្តដែលជាគង្វាលដ៏ខ្ពង់ខ្ពស់បំផុត។ សូមអស់លោកផ្ចង់ចិត្តនឹងអភិបាលរបស់ខ្លួនដោយស្មោះ ដោយចិត្ត

ស្រឡាញ់ និងដោយស្តាប់តាមបង្គាប់ទៀតផង។ បូជាចារ្យត្រូវស្តាប់តាមបង្គាប់លោកអភិបាល ទាំងមានចិត្តចង់សហការជាមួយលោកជានិច្ចដូច្នេះ មកពីខ្លួនរួមចំណែកក្នុងមុខងារបម្រើរបស់លោកអភិបាល គឺចំណែកដែលអស់លោកគង្វាលមាន ដោយទទួលអគ្គសញ្ញាតែងតាំង និងដោយទទួលបេសកកម្មតាមច្បាប់ព្រះសហគមន៍ផងដែរ។

អស់លោកគង្វាល និងអភិបាលទាំងប៉ុន្មានត្រូវរួបរួមគ្នា ពិតជាការចាំបាច់សម្រាប់សព្វថ្ងៃមែន ព្រោះនៅសម័យឥឡូវ មានមូលហេតុផ្សេងៗជាច្រើន បណ្តាលឲ្យកិច្ចការជាគ្រីស្តទូតមានច្រើនបែប ព្រមទាំងត្រូវលាតសន្ធឹងហួសពីព្រំដែននៃសហគមន៍មួយ ឬហួសពីព្រំដែនភូមិភាគមួយដែរ។ ហេតុនេះ គ្មានគង្វាលណាម្នាក់មានសមត្ថភាពអាចបំពេញបេសកកម្មរបស់ខ្លួនគ្រប់គ្រាន់បានតែម្នាក់ឯង ឬក្នុងនាមរបស់ខ្លួនផ្ទាល់ទេ។ អស់លោកគង្វាល ត្រូវតែរួមកម្លាំងសហការជាមួយគង្វាលឯទៀតៗ ក្រោមការណែនាំរបស់អស់អភិបាលជាប្រធានព្រះសហគមន៍ ទើបអាចធ្វើបាន។

## ៨-អស់លោកគង្វាលរួបរួមគ្នាជាបងប្អូន និងសហការគ្នា

ដោយអស់លោកគង្វាលទទួលអគ្គសញ្ញាតែងតាំង អស់លោកចូលក្នុងក្រុមគង្វាល ហើយក៏ភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធដូចជាបងប្អូន ដោយទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យតែមួយដូចគ្នា។ អស់លោករួមគ្នាយ៉ាងពិសេស ជាក្រុមគង្វាលតែមួយគត់ ក្រោមអំណាចអភិបាលភូមិភាគ ព្រោះអស់លោកអស់ទទួលមុខងារបម្រើភូមិភាគនោះ។ ទោះបីអស់លោកគង្វាលទទួលការងារប្លែកៗពីគ្នាក៏ដោយ ក៏អស់លោកបំពេញមុខងារបម្រើ ជាបូជាចារ្យតែមួយសម្រាប់មនុស្សលោកដែរ។ ព្រះសហគមន៍ចាត់គង្វាលទាំងអស់ឲ្យរួមសហការបំពេញកិច្ចតែមួយ គឺទោះជាគង្វាលបំពេញមុខងារក្នុងសហគមន៍មួយក្តី ឬបំពេញមុខងារអន្តរសហគមន៍ក្តី ទោះជាគង្វាលបូជាកម្លាំងកាយកម្លាំងចិត្តស្រាវជ្រាវតាមវិទ្យាសាស្ត្រ ឬបង្រៀនក្តី ទោះជាគង្វាលធ្វើការដោយដៃផ្ទាល់ និងរួមរស់ជាមួយវណ្ណៈកម្មករក្តី (លុះត្រាតែអំណាច ដែលមានសមត្ថកិច្ចក្នុងព្រះសហគមន៍អនុញ្ញាតឲ្យ ដោយយល់ឃើញថា មុខងារបម្រើនេះមានប្រយោជន៍) ទោះជាគង្វាលបំពេញកិច្ចការផ្សេងៗជាគ្រីស្តទូត ឬធ្វើកិច្ចការតម្រង់ទៅជាគ្រីស្តទូតក្តី ក៏អស់លោករួមសហការទាំងអស់គ្នា បំពេញកិច្ចតែមួយដែរ។ ពិតមែនហើយ អស់លោកគង្វាល រួមគ្នាដោយមានគោលបំណងតែមួយដូចគ្នា គឺសាងសង់ព្រះកាយព្រះគ្រីស្ត។ ជាពិសេសនាសម័យយើងនេះ អស់លោកត្រូវប្រព្រឹត្តតាមគោលបំណងនេះ ដោយអស់លោកមានបន្ទុកជាច្រើនបែប និងត្រូវសម្រួលឲ្យស្របតាមតម្រូវការថ្មីៗទៀតផង។ ហេតុនេះហើយ ត្រូវឲ្យគង្វាលទាំងប៉ុន្មាន គឺទាំងគង្វាលភូមិភាគ និងទាំងគង្វាលបព្វជិត ជួយគ្នាទៅវិញទៅមក និងសហការគ្នារួមជាមួយសេចក្តីពិតជានិច្ច (៣ យហ ៨)។ គង្វាលម្នាក់ៗ ត្រូវទាក់ទងជាមួយសមាជិកឯទៀតៗនៃក្រុមគង្វាល ដោយចងចំណងពិសេសនៃសេចក្តីស្រឡាញ់ក្នុងឋានៈជាគ្រីស្តទូត ចងចំណងនៃមុខងារបម្រើតែមួយដូចគ្នា និងចងចំណងជាបងប្អូនគ្នា។ តាំងពីសម័យបុរាណមកពីធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ សម្តែងចំណងនៃសេចក្តីស្រឡាញ់នេះយ៉ាងច្បាស់ ដោយលោកអភិបាល អញ្ជើញគង្វាលទាំងប៉ុន្មាន ដែលរួមក្នុងពិធីតែងតាំងគង្វាល ឲ្យដាក់ដៃលើបេក្ខជនថ្មី រួមជាមួយលោក។ នៅពេលអស់លោកគង្វាល រួមថ្វាយអភិបូជាដោយមានចិត្តថ្លើមតែមួយ អស់លោកក៏សម្តែងចំណងនៃសេចក្តីស្រឡាញ់នេះដែរ។ ហេតុនេះបានជាគង្វាលម្នាក់ៗ ភ្ជាប់ជាមួយគង្វាលឯទៀតៗជាបងប្អូន ដោយចំណងនៃសេចក្តីស្រឡាញ់ ដោយអធិដ្ឋានរួមគ្នា និងដោយសហការជាមួយគ្នាគ្រប់យ៉ាង។ ធ្វើបែបនេះ អស់លោកសម្តែងថា កូនចៅរបស់ព្រះគ្រីស្តរួបរួមគ្នាជាធ្លុងតែមួយតាមព្រះហឫទ័យព្រះអង្គ ដើម្បីឲ្យមនុស្សលោកទទួលស្គាល់ថា ព្រះបិតាពិតជាបានចាត់ព្រះបុត្រាឲ្យយាងមកមែន (យហ ១៧, ២៣)។

ហេតុនេះ គង្វាលចាស់ជាងគេត្រូវទទួលគង្វាលក្មេងៗទុកជាប្អូនបង្កើត ហើយក៏ត្រូវ ជួយគេនៅពេលគេចាប់ផ្ដើមខិតខំបំពេញកិច្ចរបស់ខ្លួន និងទទួលខុសត្រូវក្នុងមុខងារបម្រើដើមដំបូង។ ម៉្យាងវិញទៀត គង្វាលចាស់ៗ គួរតែខិតខំយល់ចិត្តគំនិតរបស់គង្វាលក្មេងៗ ទោះបីចិត្តគំនិតគង្វាលក្មេងៗខុសប្លែកពីចិត្តគំនិតរបស់ខ្លួនក៏ដោយ។ គង្វាលចាស់ៗក៏គួរតែមើលអ្វីៗដែលគង្វាលក្មេងៗ ខិតខំធ្វើដំបូងនោះ ដោយមានចិត្តមេត្តាដែរ។ រីឯគង្វាលក្មេងវិញ គប្បីតែគោរពអាយុ និងបទពិសោធន៍របស់គង្វាលចាស់ៗដែរ ពិគ្រោះជាមួយអស់លោកអំពីការថែទាំវិញ្ញាណមនុស្ស និងសុខចិត្តសហការជាមួយអស់លោកដោយចិត្តរីករាយទៀតផង។

អស់លោកគង្វាល មិនត្រូវភ្លេចនឹងទទួលភ្ញៀវ ដោយរាប់មនុស្សឯទៀតទុកជាបងប្អូន (ហប ១៣,១៦)។ ត្រូវគិតដល់ការសម្ដែងមេត្តាករុណាជានិច្ច និងចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន (ហប ១៣, ១៦)។ អស់លោកត្រូវ យកចិត្តទុកដាក់ ចាប់អារម្មណ៍យ៉ាងពិសេសចំពោះអ្នកជំងឺ អ្នកកើតទុក្ខ អ្នកធ្វើការហួសកម្លាំង អ្នករស់នៅឯកោ ជនដែលត្រូវគេនិរទេស និងអ្នកដែលត្រូវគេបៀតបៀនទៀតផង។ ប៉ុន្តែ អស់លោកគួរតែជួបជុំគ្នាយ៉ាងសប្បាយរីករាយ យូរៗម្ដងដើម្បីសម្រាកលំហែកាយ ដោយនឹកដល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលអញ្ជើញក្រុមគ្រីស្ដទូត ដែលហាត់នឿយថា៖ *"ចូរនាំគ្នាមករកកន្លែងស្ងាត់ដាច់ឡែកពីបណ្ដាជន សម្រាកបន្ដិចសិន"* (មក ៦, ៣១)។

លើសពីនេះទៅទៀត អស់លោកគង្វាលត្រូវជួយគ្នាទៅវិញទៅមកជាចាំបាច់ ដើម្បីឲ្យជីវិតរបស់អស់លោកតាមព្រះវិញ្ញាណ និងខាងចំណេះដឹងចម្រើនឡើង ហើយដើម្បីជួយសម្រួលសហការបំពេញមុខងារបម្រើរបស់អស់លោក ព្រមទាំងជៀសផុតពីបញ្ហាដ៏ធ្ងន់ធ្ងរ ដែលតែងតែកើតឡើងដោយខ្លួនរស់នៅឯកោ។ មូលហេតុទាំងនោះ ដាស់តឿនគង្វាល ឲ្យរស់នៅរួមគ្នាតាមរបៀបម៉្យាង ឬឲ្យចែកចាយការរស់នៅខ្លះជាមួយគ្នា។ ការរួមរស់ជាមួយគ្នានោះ មានរបៀបផ្សេងៗជាច្រើន តាមតម្រូវការរបស់គង្វាលម្នាក់ៗ ឬតាមតម្រូវការនៃមុខងារជាគង្វាល គឺអស់លោករួមរស់នៅជាមួយគ្នានៅផ្ទះតែមួយក៏បាន ឬទទួលទានជុំគ្នាក៏បាន ឬយ៉ាងហោចណាស់ក៏ជួបជុំជាញឹកតាមពេលកំណត់ដែរ។ គប្បីរាប់រកសមាគមបូជាចារ្យទុកជាមានតម្លៃខ្ពង់ខ្ពស់ និងគួរឲ្យលើកស្ទួយគាំទ្រទៀតផង។ ត្រូវឲ្យអំណាចដែលមានសមត្ថកិច្ច ក្នុងព្រះសហគមន៍ទទួលស្គាល់លក្ខន្តិកៈសមាគមទាំងនោះ។ សមាគមទាំងនោះ ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវរួចហើយ ត្រូវផ្ដល់សេចក្ដីណែនាំស្របតាមការរស់នៅរបស់គង្វាល ជួយគាំទ្រគង្វាលក្នុងឋានៈជាបងប្អូន និងជួយឲ្យអស់លោកកាន់តែវិសុទ្ធ ដោយបំពេញមុខងារបម្រើរបស់ខ្លួន។ ហេតុនេះ សមាគមទាំងនោះជួយក្រុមគង្វាលទាំងមូលតែម្ដង។

មិនតែប៉ុណ្ណោះ ដោយអស់លោកគង្វាល រួបរួមគ្នាដោយមានឋានៈជាបូជាចារ្យ គួរតែឲ្យអស់លោកចាប់អារម្មណ៍នឹងគង្វាលឯទៀតៗ ដែលខ្លះកំពុងជួបប្រទះការលំបាក។ អស់លោកត្រូវលើកទឹកចិត្តគេនៅពេលដ៏សមរម្យ ហើយប្រសិនបើត្រូវការ ត្រូវជួយដាស់តឿនគេដោយស្ងាត់ៗផងដែរ។ ចំពោះគង្វាលណាដែលភ្លាត់ក្នុងរឿងណាមួយ គង្វាលឯទៀតត្រូវបង្ហាញសេចក្ដីស្រឡាញ់ទុកជាបងប្អូន និងត្រូវមានចិត្តទូលំទូលាយចំពោះគេជានិច្ច។ ត្រូវទទូចអង្វរព្រះជាម្ចាស់សម្រាប់លោកទាំងនោះ ព្រមទាំងរាប់គេទុកជាបងប្អូន និងជាមិត្តសម្លាញ់ដ៏ពិតប្រាកដតទៅទៀតផង។

## ៩-អំពីទំនាក់ទំនងរបស់បូជាចារ្យជាមួយនឹងគ្រីស្ដបរិស័ទធម្មតា

ក្នុងចំណោមប្រជារាស្ដ្ររបស់ព្រះជាម្ចាស់ អស់លោកគង្វាលនៃសម្ពន្ធមេត្រីថ្មីទទួលបន្ទុកមួយដ៏ប្រសើរបំផុត និងដ៏ចាំបាច់អាក់ខានមិនបាន ដើម្បីជាប្រយោជន៍យ៉ាងខ្លាំងដល់ប្រជារាស្ដ្រទាំងមូល។ ដោយអស់លោកទទួលអគ្គសញ្ញាតែងតាំង អស់លោកទទួលបន្ទុកធ្វើជាឪពុក និងជាគ្រូបាធ្យាយផងដែរ។ ប៉ុន្តែ អស់លោកក៏ជាសាវ័ករបស់ព្រះអម្ចាស់រួម

ជាមួយគ្រីស្តបរិស័ទឯទៀតៗ ព្រះជាម្ចាស់ក៏ប្រោសប្រណីត្រាស់ហៅ អស់លោកឲ្យទទួលចំណែកក្នុងព្រះរាជ្យរបស់ព្រះអង្គដែរ (១ថស ២, ១២ ; កូឡ ១, ១៣)។ ក្នុងចំណោមអ្នកទាំងអស់ដែលបានកើតជាថ្មី ដោយអគ្គសញ្ញាជ្រមុជទឹក អស់លោកគង្វាលជាបងប្អូនរស់នៅក្នុងចំណោមបងប្អូនរបស់គេ (មថ ២៣, ៨) ហើយក៏ជាសរីរាង្គនៃព្រះកាយតែមួយរបស់ព្រះគ្រីស្ត ព្រះអង្គក៏ផ្ញើបន្ទុកសាងសង់ព្រះកាយនោះឡើងឲ្យគ្រីស្តបរិស័ទគ្រប់គ្នាដែរ (អភ ៤, ៧.១៤)។

ហេតុនេះហើយ បានជាអស់គង្វាល ក្នុងឋានៈជាអ្នកនាំមុខសហគមន៍ ត្រូវតែស្វែងរកប្រយោជន៍របស់ព្រះយេស៊ូគ្រីស្ត (ភល ២, ២១) មិនត្រូវស្វែងរកប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ត្រូវរួមសហការជាមួយគ្រីស្តរិស័ទធម្មតា ហើយត្រូវរស់នៅក្នុងចំណោមពួកគេតាមគំរូរបស់ព្រះយេស៊ូជាបរមគ្រូ គឺព្រះអង្គយាងមកក្នុងចំណោមមនុស្សលោក *"មិនមែនដើម្បីឲ្យគេបម្រើលោកទេ តែលោកមកបម្រើគេវិញ ព្រមទាំងបូជាជីវិត ដើម្បីលោះមនុស្សទាំងអស់ផង"* (មថ ២០, ២៨)។ លោកគង្វាល ត្រូវទទួលស្គាល់តម្លៃដ៏ថ្លៃថ្នូររបស់គ្រីស្តបរិស័ទដោយចិត្តស្មោះ និងលើកស្ទួយតម្លៃដ៏ថ្លៃថ្នូរនេះ ព្រមទាំងទទួលស្គាល់ និងលើកស្ទួយតួនាទីរបស់គេក្នុងបេសកកម្មរបស់ព្រះសហគមន៍ថែមទៀត។ អស់លោកត្រូវគោរពសិទ្ធិសេរីភាពដ៏ត្រឹមត្រូវរបស់មនុស្សទាំងអស់នៅផែនដីនេះ ត្រូវចូលចិត្តស្តាប់យោបល់របស់គ្រីស្ត បរិស័ទធម្មតា យោគយល់ដល់បំណងប្រាថ្នារបស់គេ ក្នុងឋានៈជាបងប្អូនរបស់គេ។ អស់លោកត្រូវទទួលស្គាល់បទពិសោធន៍ និងសមត្ថភាពរបស់គេក្នុងផ្នែកនានា នៃសកម្មភាពមនុស្សលោក ដើម្បីឲ្យយល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្តែងតាមសញ្ញាសម្គាល់នាសម័យនេះ។ អស់លោកត្រូវល្បងលវិញ្ញាណមើលឲ្យដឹងថា វិញ្ញាណទាំងនោះមកពីព្រះជាម្ចាស់ ឬក៏អត់ (១យហ ៤, ១) ហើយដោយសារជំនឿ អស់លោកត្រូវរកឃើញព្រះអំណោយទាន និងពិចារណាថ្លឹងថ្លែងអំពីព្រះអំណោយទានគ្រប់បែបយ៉ាងរបស់គ្រីស្តបរិស័ទធម្មតា តាំងពីព្រះអំណោយទានតូចជាងគេ រហូតដល់ព្រះអំណោយទានដ៏ប្រសើរថ្លៃថ្នូរជាងគេ។ អស់លោកត្រូវទទួលស្គាល់ព្រះអំណោយទានទាំងនោះដោយអំណរ ហើយត្រូវខិតខំធ្វើឲ្យព្រះអំណោយទានទាំងនោះចម្រើនឡើងថែមទៀតផង។ ក្នុងចំណោមព្រះអំណោយទានជាច្រើនបរិបូរណ៍ដែលអស់លោករកឃើញនោះ លោកគង្វាលត្រូវចាប់អារម្មណ៍យ៉ាងពិសេសនឹងព្រះអំណោយទានដែលទាក់ទាញចិត្តគ្រីស្តបរិស័ទជាច្រើន ចង់ឲ្យជីវិតខាងព្រះវិញ្ញាណរបស់គេចម្រើនឡើងកាន់តែជ្រៅទៅៗ។ ម្យ៉ាងទៀតលោកគង្វាល គួរតែទុកចិត្តលើគ្រីស្តបរិស័ទធម្មតា ហើយប្រគល់ភារកិច្ចបម្រើព្រះសហគមន៍ផ្សេងៗឲ្យគេ ទាំងទុកសេរីភាព និងលទ្ធភាពឲ្យគេអាចធ្វើការបាន។ លើសពីនេះទៅទៀត នៅពេលមានឱកាសហុចឲ្យនោះ អស់លោកក៏គួរអញ្ជើញគេ ឲ្យផ្តើមកិច្ចការខ្លះដោយខ្លួនឯងផង (ពន្លឺ ៣៧)។

សរុបសេចក្តីមក ព្រះជាម្ចាស់ដាក់ឲ្យលោកគង្វាលស្ថិតនៅក្នុងចំណោមគ្រីស្តបរិស័ទធម្មតា ដើម្បីណែនាំគេឲ្យរួបរួមគ្នាជាធ្លុងតែមួយក្នុងសេចក្តីស្រឡាញ់ គឺឲ្យ *"ស្រឡាញ់រាប់អានគ្នាទៅវិញទៅមក ទុកដូចជាបងប្អូនបង្កើត...ទាំងលើកកិត្តិយសគ្នាទៅវិញទៅមក ដោយចិត្តគោរព"* (រម ១២, ១០)។ ដូច្នេះ អស់លោកត្រូវតែណែនាំ បង្រួបបង្រួមអ្នកដែលមានចិត្តគំនិតខុសប្លែកៗពីគ្នា ឲ្យទាក់ទងគ្នា កុំឲ្យមាននរណាម្នាក់មានអារម្មណ៍ថា ខ្លួនជាជនបរទេស ក្នុងព្រះសហគមន៍គ្រីស្តបរិស័ទឡើយ។ អស់លោកត្រូវតែការពារផលប្រយោជន៍រួម ព្រោះអស់លោកទទួលខុសត្រូវ ក្នុងនាមលោកអភិបាល។ ទន្ទឹមនឹងនេះ អស់លោកក៏ត្រូវប្រកាសសេចក្តីពិតដោយចិត្តអង់អាច កុំឲ្យគ្រីស្តបរិស័ទ បណ្តោយខ្លួនតាមខ្យល់នៃគោលលទ្ធិនានាដែលតែងតែផាត់ចុះផាត់ឡើង (អភ ៤, ១៤)។ អស់លោកត្រូវយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះអស់គ្រីស្តបរិស័ទដែលលែងទទួលអគ្គសញ្ញានានា និងចំពោះអស់អ្នកដែលបាត់បង់ជំនឿតែម្តង។ សូមទៅរកអ្នកទាំងនេះ ដូចគង្វាលដ៏សប្បុរសទៅរកចៀមដែលវង្វេង។

អស់លោកគង្វាល ត្រូវចាប់អារម្មណ៍នឹងសេចក្ដីបញ្ជារបស់មហាសន្និបាត ស្ដីអំពីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ មិនត្រូវបំភ្លេចបងប្អូនគ្រីស្តបរិស័ទ ដែលមិនរួបរួមក្នុងព្រះសហគមន៍យ៉ាងពេញលេញជាមួយយើងនោះទេ។ (បង្រួប)។

មិនតែប៉ុណ្ណោះ អស់លោកត្រូវដឹងថា ព្រះជាម្ចាស់បានផ្ញើអស់អ្នក ដែលពុំទាន់ទទួលស្គាល់ព្រះគ្រីស្ត ទុកជាព្រះសង្គ្រោះរបស់គេ ឲ្យអស់លោកដែរ។

រីឯគ្រីស្តបរិស័ទវិញ ត្រូវដឹងខ្លួនអំពីភារកិច្ចរបស់គេចំពោះបូជាចារ្យរបស់គេ គឺត្រូវស្រឡាញ់អស់លោក ដែលជាគង្វាល និងជាឪពុករបស់ពួកគេ ដូចកូនស្រឡាញ់ឪពុកដូច្នោះដែរ។ ត្រូវចែករំលែកទុក្ខកង្វល់របស់អស់លោក ហើយជួយអស់លោកតាមសមត្ថភាពរបស់ខ្លួន ដោយអធិដ្ឋាន និងជួយធ្វើកិច្ចការរបស់អស់លោកដែរ។ ដូច្នេះ អស់លោកអាចពុះពារឧបសគ្គដ៏ពិបាកនានា និងអាចបំពេញភារកិច្ចរបស់ខ្លួនបានទាំងបង្កើតផលផ្លែជាច្រើនថែមទៀតផង(ពន្លឺ ៣៧)។

## ផ្នែកទី ៣ បូជាចារ្យមានបេសកកម្មសកល និងអំពីព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ

### ១០-លោកគង្វាលមានបេសកកម្មសកល

ពេលលោកគង្វាលបានទទួលអគ្គសញ្ញាតែងតាំង អស់លោកទទួលព្រះអំណោយទានពីព្រះវិញ្ញាណ ជាព្រះអំណោយទានរៀបចំឲ្យអស់លោកបំពេញបេសកកម្ម ដែលមិនមានកម្រិតនោះទេ តែឲ្យបំពេញបេសកកម្មដ៏ទូលំទូលាយបំផុត ជាបេសកកម្មសកលនាំការសង្គ្រោះ *"រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី"* (កក ១, ៨)។ ក្នុងគ្រប់កិច្ចបម្រើក្នុងឋានៈលោកជាបូជាចារ្យ អស់លោករួមចំណែកក្នុងបេសកកម្មសកល ដែលព្រះគ្រីស្តបានផ្ញើទុកឲ្យក្រុមគ្រីស្តទូត។ លោកគង្វាលទាំងប៉ុន្មានទទួលចំណែកយ៉ាងពិតប្រាកដ ក្នុងមុខងាររបស់ព្រះគ្រីស្តជាមហាបូជាចារ្យ ជាមុខងារបែរទៅរកប្រជាជាតិនានា នៅគ្រប់សម័យដោយគ្មានគិតគូរដល់ពណ៌សម្បុរ ជាតិសាសន៍ ឬសម័យកាលណាឡើយ ដូចព្រះបាទម៉ែលគីសេដែក ធ្វើជាប្រផ្នូលបែបជាអាថ៌កំបាំង កាលពីដើមដែរ (ហប ៧, ៣)។ ហេតុនេះហើយ អស់លោកគង្វាលត្រូវនឹកចងចាំថា អស់លោកត្រូវយកចិត្តទុកដាក់នឹកគិតដល់ព្រះសហគមន៍ទាំងឡាយ។ អាស្រ័យហេតុនេះហើយ លោកគង្វាលនៅក្នុងភូមិភាគណាដែលសម្បូណ៌ទៅដោយ អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាគង្វាលនោះ ក៏ត្រូវស្ម័គ្រចិត្តត្រៀមខ្លួនចេញទៅបំពេញមុខងារបម្រើរបស់ខ្លួននៅតំបន់ផ្សេង ឬនៅប្រទេសដែលមានគ្រីស្តបរិស័ទចំនួនតិច ឬទៅបំពេញសកម្មភាពផ្សេងៗ ដែលខ្វះគង្វាលនោះ។ ប៉ុន្តែ ត្រូវមានការយល់ស្រប និងអនុញ្ញាតពីអភិបាលភូមិភាគរបស់ខ្លួនដែរ។

ត្រូវកែសម្រួលច្បាប់វិន័យ ស្ដីអំពីច្បាប់ភ្ជាប់គង្វាលម្នាក់ទៅនឹងក្រុមគង្វាលក្នុងភូមិភាគ និងច្បាប់វិន័យស្ដីអំពីការដកចេញពីក្រុមគង្វាលភូមិភាគដែរ។ ទោះបីត្រូវរក្សាទុករចនាសម្ពន្ធបុរាណនោះក្ដី ក៏ត្រូវកែសម្រួលច្បាប់វិន័យទាំងនោះស្របតាមតម្រូវការនៃមុខងារបម្រើព្រះសហគមន៍នាបច្ចុប្បន្នដែរ។ នៅកន្លែងណា ដែលសភាពការណ៍នៃកិច្ចការជាគ្រីស្តទូតទាមទារនោះ គួរជួយកែសម្រួល មិនត្រឹមតែការចាត់ចែងឲ្យមានគង្វាលនៅគ្រប់មជ្ឈដ្ឋានប៉ុណ្ណោះទេ តែគួរចាត់ចែងសកម្មភាពពិសេសៗនៃកិច្ចការណែនាំគ្រីស្តបរិស័ទ តាមក្រុមវណ្ណៈផ្សេងៗក្នុងសង្គម តាមតំបន់មួយ ឬតាមប្រទេសមួយ ឬតាមទ្វីបមួយដែរ។ គួរបង្កើតទេវវិទ្យាល័យអន្តរជាតិដើម្បីសម្រេចតាមគោលការណ៍នេះ ឬក៏បង្កើតភូមិភាគពិសេសដោយឡែក ឬឲ្យមានអភិបាលសម្រាប់ថែទាំក្រុមជនជាតិមួយ។ ត្រូវបង្កើតស្ថាប័នផ្សេងៗ សម្រាប់ឲ្យគង្វាលអាចភ្ជាប់

ខ្លួនជាមួយស្ថាប័ននោះ និងចាត់ឲ្យទៅ ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។ ត្រូវចៃងរបៀបអនុវត្តតាមច្បាប់ក្នុងករណីនីមួយៗ ដោយគោរពសិទ្ធិរបស់អភិបាលភូមិភាគជានិច្ច។ ប្រសិនបើអាចធ្វើបាន មិនត្រូវចាត់គង្វាលតែម្នាក់ឯងឲ្យទៅតំបន់មួយផ្សេងទេ ជាពិសេសបើលោកពុំទាន់ចេះភាសា និងមិនទាន់ស្គាល់ទំនៀមទម្លាប់តំបន់នោះយ៉ាងច្បាស់លាស់នៅឡើយ។ ផ្ទុយទៅវិញ ត្រូវចាត់គង្វាល ឲ្យទៅជាក្រុមៗដែលមានគ្នាពីរ ឬបីនាក់ដើម្បីឲ្យអស់លោក អាចជួយគ្នាទៅវិញទៅមក ដោយយកតម្រាប់តាមក្រុមសាវ័កព្រះគ្រីស្ត (លក ១០, ១)។ ត្រូវយកចិត្តទុកដាក់នឹងជីវិតខាងព្រះវិញ្ញាណរបស់អស់លោក និងអំពីសុខភាពខាងផ្លូវកាយ និងផ្លូវចិត្ត។ ប្រសិនបើអាចធ្វើបាន គួរតែតម្រូវទីកន្លែង និងសភាពការណ៍ការងារ សមស្របតាមសមត្ថភាពផ្ទាល់របស់គង្វាលម្នាក់ៗ។

អស់លោកគង្វាល ដែលចេញទៅនៅប្រទេសមួយផ្សេងនោះ ត្រូវរៀនភាសាប្រជាជនតំបន់នោះឲ្យបានច្បាស់។ ការនេះសំខាន់ណាស់។ មិនតែប៉ុណ្ណោះ អស់លោកក៏ត្រូវរៀនឲ្យស្គាល់ចរិតលក្ខណៈ និងរបៀបរស់ នៅក្នុងសង្គមនៃប្រជាជនតំបន់នោះទៀតផង។ ប្រសិនបើ អស់លោកមានបំណងបម្រើប្រជាជននោះ ដោយចិត្តសុភាពរាបសា ត្រូវទាក់ទងជាមួយប្រជាជននោះយ៉ាងជ្រៅបំផុត តាមតែគេអាចធ្វើបាន ទាំងយកតម្រាប់តាមគ្រីស្តទូតប៉ូល គឺលោកហ៊ានមានប្រសាសន៍អំពីខ្លួនលោកថា៖ *"ទោះបីខ្ញុំជាមនុស្សមានសេរីភាព គ្មានជាប់ចំណងរបស់នរណាក៏ដោយ ក៏ខ្ញុំសុខចិត្តដាក់ខ្លួនធ្វើជាអ្នកបម្រើរបស់មនុស្សទាំងអស់ដែរ ដើម្បីនាំមនុស្សជាច្រើនឲ្យផ្ញើជីវិតលើព្រះគ្រីស្ត។ កាលខ្ញុំនៅជាមួយសាសន៍យូដា ខ្ញុំធ្វើដូចសាសន៍យូដា ដើម្បីឲ្យសាសន៍យូដាជឿលើព្រះគ្រីស្ត..."* (១ករ ៩, ១៩-២០)។

## ១១-អស់លោកគង្វាលត្រូវយកចិត្តទុកដាក់ ឲ្យមានគេស្តាប់ឮព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ

ព្រះអម្ចាស់ជាគង្វាល និងជាអ្នកថែរក្សាវិញ្ញាណយើង (១សល ២, ២៥)។ ព្រះអង្គបង្កើតព្រះសហគមន៍របស់ព្រះអង្គ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស និងបានរំដោះមកដោយព្រះលោហិតព្រះអង្គផ្ទាល់ (កក ២០, ២៣) មានបូជាចារ្យរបស់ខ្លួនជានិច្ចរហូតដល់អវសានកាលនៃពិភពលោក កុំឲ្យគ្រីស្តបរិស័ទក្លាយទៅជាហ្វូងចៀមដែលគ្មានគង្វាលថែទាំឡើយ (មថ ៩, ៣៦)។ ក្រុមគ្រីស្តទូតទទួលស្គាល់ព្រះបំណងរបស់ព្រះគ្រីស្តនោះហើយ ដោយព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតផង ក៏យល់ឃើញថា អស់លោកមានភារកិច្ចជ្រើសរើសអ្នកបម្រើព្រះសហគមន៍ ដែល *"មានសមត្ថភាពអាចបង្រៀនបន្តទៅអ្នកផ្សេងទៀត"* បានដែរ (១ធម ២, ២)។ ភារកិច្ចនេះហូរមកពីបេសកកម្មផ្ទាល់របស់បូជាចារ្យ គឺដោយសារបេសកកម្មនោះ លោកគង្វាលទទួលចំណែកក្នុងកង្វល់របស់ព្រះសហគមន៍ទាំងមូល ដែលចង់ជៀសវាងកុំឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់ នៅលើផែនដីនេះខ្វះអ្នកបម្រើ។

ប៉ុន្តែ ដោយ *"អ្នកបើកកប៉ាល់និងអ្នកជិះទាំងប៉ុន្មាន រួមវាសនាតែមួយជាមួយគ្នា"* ដូច្នេះ ត្រូវណែនាំប្រជាជនគ្រីស្តបរិស័ទទាំងមូលឲ្យយល់ថា គេមានភារកិច្ចរួមសហការតាមរបៀបផ្សេងៗ ដើម្បី ឲ្យព្រះសហគមន៍មានបូជាចារ្យជារៀងរហូត តាមសេចក្តីត្រូវការសម្រាប់បំពេញបេសកកម្ម ដែលព្រះសហគមន៍ទទួលពីព្រះជាម្ចាស់មក។

ប្រជាជនគ្រីស្តបរិស័ទអាចសហការក្នុងកិច្ចដ៏សំខាន់នេះ ដោយអធិដ្ឋានក៏បាន ឬដោយវិធីផ្សេងៗទៀត ដែលគេមានក៏បានដែរ (ហ្វឹកហ្វឺន ២)។ ជាបឋម គង្វាលត្រូវពន្យល់បញ្ជាក់យ៉ាងច្បាស់ឲ្យគ្រីស្តបរិស័ទយល់ថា មុខងារជាបូជាចារ្យពិតជាមុខងារដ៏ឧត្តុង្គឧត្តម និងត្រូវការជាចាំបាច់។ អស់លោកអាចណែនាំឲ្យគ្រីស្តបរិស័ទយល់សេចក្តីនេះ ដោយបំពេញមុខងារបម្រើព្រះបន្ទូលផង និងដោយរបៀបរស់នៅរបស់ខ្លួនផង គឺអស់លោកត្រូវសម្តែង សក្ខីភាពអំពីចិត្ត

គំនិតជាអ្នកបម្រើ និងសម្តែងអំពីអំណរសប្បាយដ៏ពិតប្រាកដដែលមកពីព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង ឲ្យគេឃើញយ៉ាងច្បាស់។

ក្រោយពីអស់លោកបានថ្លឹងថ្លែងពិចារណាហើយយល់ឃើញថា យុវជន ឬមនុស្សពេញវ័យខ្លះមានសមត្ថភាពអាចបំពេញមុខងារបម្រើដ៏ប្រសើរនេះ អស់លោកត្រូវខិតខំជួយគេដោយឥតសំចៃកម្លាំង ទោះបីត្រូវជួបការពិបាកយ៉ាងណាក៏ដោយ ត្រូវឲ្យគេរៀបចំខ្លួនតាមសមគួរ រហូតដល់ពេលអស់លោកអភិបាលអាចត្រាស់ហៅគេបាន ដោយគេមានសេរីភាពដ៏ពេញលេញ ដោយគ្មាននរណាបង្ខំទាំងខាងផ្លូវចិត្ត ទាំងមជ្ឈដ្ឋានខាងក្រៅឡើយ។ ត្រូវណែនាំគេ ឲ្យរស់នៅតាមព្រះវិញ្ញាណយ៉ាងចាំបាច់បំផុត ដើម្បីរៀបចំគេទៅកាន់គោលដៅនោះ។ ឪពុកម្ដាយ គ្រូបង្រៀន និងអស់អ្នកអប់រំឯទៀតៗ ត្រូវយកចិត្តទុកដាក់អប់រំឲ្យក្មេងៗ និងយុវជនឲ្យយល់អំពីព្រះហឫទ័យស្រឡាញ់របស់ព្រះអម្ចាស់ ដែលនាំហ្វូងចៀមរបស់ព្រះអង្គផង ព្រមទាំងឲ្យដឹងអំពីតម្រូវការដ៏ចាំបាច់របស់ព្រះសហគមន៍ផង។ ត្រូវយកចិត្តទុកដាក់អប់រំឲ្យក្មេងៗ និងយុវជនឲ្យរិះគិត និងត្រៀមខ្លួនឆ្លើយតបដោយចិត្តទូលាយនឹងព្រះអម្ចាស់ ពេលព្រះអង្គត្រាស់ហៅគេ ទាំងពោលដូចព្យាការីអេសាយថា៖ *"ខ្ញុំនៅទីនេះស្រាប់ហើយ! សូមព្រះអង្គចាត់ខ្ញុំឲ្យទៅចុះ!"* (អស ៦, ៨)។ ប៉ុន្តែ អ្នកដែលនឹងទៅជាគង្វាលនៅពេលអនាគត មិនត្រូវរង់ចាំស្ដាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ដែលត្រាស់ហៅនោះ ដោយផ្ទាល់ត្រចៀកយ៉ាងអស្ចារ្យនោះឡើយ។ ផ្ទុយទៅវិញ គេត្រូវទទួលស្គាល់ព្រះសូរសៀងនោះ ដោយរិះគិតពិចារណាតាមសញ្ញាសម្គាល់ ដែលព្រះជាម្ចាស់រមែងតែងតែសម្ដែងឲ្យគ្រីស្តបរិស័ទដ៏ឆ្លាតវាងវៃយល់ជារៀងរាល់ថ្ងៃ។ អស់គង្វាលក៏ត្រូវចាប់អារម្មណ៍ពិចារណាសញ្ញាសម្គាល់ទាំងនោះយ៉ាងខ្លាំងផងដែរ។

ដូច្នេះ មហាសន្និបាតទូន្មានឲ្យអស់គង្វាលចូលរួមក្នុងសកម្មភាព ជួយទ្រទ្រង់អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅនោះ ទោះជាសកម្មភាពក្នុងភូមិភាគក្ដី ឬសកម្មភាពក្នុងប្រទេសក្ដី។ ពិធីអត្ថាធិប្បាយព្រះគម្ពីរ ការអប់រំជំនឿ និងការនិពន្ធព្រឹត្តិបត្រនានា ត្រូវតែរៀបរាប់យ៉ាងជាក់ច្បាស់ អំពីតម្រូវការរបស់ព្រះសហគមន៍ភូមិភាគ និងអំពីតម្រូវការរបស់ព្រះសហគមន៍សកល ហើយក៏ត្រូវរៀបរាប់បញ្ជាក់យ៉ាងច្បាស់ផងដែរ អំពីអត្ថន័យនៃមុខងារបម្រើដ៏ប្រសើរថ្លៃថ្លារបស់បូជាចារ្យ។ ត្រូវបង្ហាញឲ្យដឹងថា ក្នុងការងារដ៏ធ្ងន់ជាច្រើននោះ គេក៏អាចរកឃើញអំណរជាច្រើនផងដែរ។ ជាពិសេសត្រូវពន្យល់ថា អ្នកសុខចិត្តធ្វើជាគង្វាល ផ្ដល់សក្ខីភាពអំពីសេចក្ដីស្រឡាញ់ដ៏ប្រសើរបំផុតចំពោះព្រះគ្រីស្ត ដូចគ្រូបាធ្យាយនៃព្រះសហគមន៍តែងតែបង្រៀនដែរ។

# ជំពូក ៣

## ការរស់នៅរបស់គង្វាល

### ផ្នែកទី ១-ព្រះជាម្ចាស់ត្រាស់ហៅគង្វាលឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ

១២- អគ្គសញ្ញាតែងតាំងដ៏វិសុទ្ធ ធ្វើឲ្យគង្វាលបានដូចព្រះគ្រីស្តជាមហាបូជាចារ្យ។ អស់លោកក៏ជាអ្នកបម្រើរបស់ព្រះគ្រីស្តជាព្រះសិរសា ដើម្បីសាងសង់ និងថែទាំព្រះកាយព្រះគ្រីស្តទាំងមូល ពោលគឺព្រះសហគមន៍ក្នុងឋានៈអស់លោកជាសហការីរបស់ក្រុមអភិបាល។ ពេលអស់លោកថ្វាយខ្លួនដោយទទួលអគ្គសញ្ញាជ្រមុជទឹក អស់លោកក៏បានទទួលសញ្ញា និងព្រះអំណោយទានពីព្រះជាម្ចាស់ដែលត្រាស់ហៅអស់លោក ដូចព្រះអង្គត្រាស់ហៅគ្រីស្តបរិស័ទឯទៀតៗដែរ គឺទោះបីគេជាមនុស្សទន់ខ្សោយក៏ដោយ ក៏ព្រះអង្គប្រោសប្រណីឲ្យគេមានសមត្ថភាព និងកាតព្វកិច្ចខិតខំតម្រង់ខ្លួនឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ តាមព្រះអម្ចាស់មានព្រះបន្ទូលថា៖ *"ព្រះបិតារបស់អ្នករាល់គ្នាដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់គ្រប់លក្ខណ៍យ៉ាងណា សុំឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍យ៉ាងនោះដែរ"* (មថ ៥, ៤៨)។ ប៉ុន្តែបូជាចារ្យត្រូវខិតខំ ឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ដោយមូលហេតុពិសេសមួយ គឺថានៅពេលអស់លោក ទទួលអគ្គសញ្ញាតែងតាំងព្រះជាម្ចាស់ញែកអស់លោកប្រសិទ្ធិថ្វាយទៅព្រះអង្គតាមរបៀបថ្មី ដើម្បីឲ្យទៅជាឧបករណ៍ដ៏មានជីវិតរបស់ព្រះគ្រីស្តជាមហាបូជាចារ្យដែលមានព្រះជន្មគង់នៅជានិច្ចនិរន្តរ៍។ អស់លោកអាចបន្តព្រះរាជ្យកិច្ចដ៏អស្ចារ្យរបស់ព្រះអង្គនៅគ្រប់សម័យតៗទៅ គឺប្រោសឲ្យមនុស្សលោកទាំងមូលបានជាថ្មី ដោយឫទ្ធានុភាពរបស់ព្រះអង្គដែលគ្រប់គ្រងមនុស្សលោក។ ហេតុនេះហើយ បានជាបូជាចារ្យម្នាក់ៗ ដែលបំពេញមុខងារជំនួសព្រះគ្រីស្តផ្ទាល់តែម្តង តាមរបៀបរៀងៗខ្លួន ក៏បានទទួលព្រះអំណោយទានពិសេសផ្ទាល់ដែរ។ ព្រះអំណោយទាននោះ ជួយលោកឲ្យតម្រង់ខ្លួនទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ក្នុងឋានៈខ្លួនជាតំណាងរបស់ព្រះគ្រីស្ត។ លោកអាចពេញលក្ខណៈដូច្នេះបាន ដោយបម្រើមនុស្សដែលព្រះអង្គបានផ្ញើទុកមកលោក និងដោយបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូលដែរ។ ដោយព្រះជាម្ចាស់ប្រោសប្រណី ដូច្នេះព្រះគ្រីស្តដែលទៅជាមហាបូជាចារ្យ *"ដ៏វិសុទ្ធ ស្លូតត្រង់ ឥតសៅហ្មង ខុសប្លែកពីមនុស្សបាប"* (ហប ៧, ២៦) សម្រាប់យើង ព្រះអង្គព្យាបាលបូជាចារ្យម្នាក់ៗ ជាមនុស្សលោកីយ៍ដ៏ទន់ខ្សោយ។

ព្រះបិតាបានប្រោសឲ្យព្រះគ្រីស្តបានវិសុទ្ធ គឺអភិសេកព្រះអង្គ និងចាត់ឲ្យយាងមកក្នុងពិភពលោក (យហ ១០, ៣៦)។ ព្រះគ្រីស្ត *"បានបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់សម្រាប់យើង ដើម្បីលោះយើងឲ្យរួចផុតពីអំពើទុច្ចរិតគ្រប់យ៉ាង និងជម្រះប្រជារាស្ត្រមួយ ទុកសម្រាប់ព្រះអង្គផ្ទាល់ជាប្រជារាស្ត្រដែលខ្នះខ្នែងប្រព្រឹត្តអំពើល្អ"* (ទត ២, ១៤)។ ព្រះអង្គក៏យាងចូលក្នុងសិរីរុងរឿងរបស់ព្រះអង្គ ដោយឆ្លងកាត់ទុក្ខលំបាក (លក ២៤, ២៦)។ យ៉ាងណាមិញ អស់បូជាចារ្យដែលព្រះវិញ្ញាណដ៏វិសុទ្ធបានអភិសេក និងដែលព្រះគ្រីស្តចាត់ឲ្យទៅរំងាប់អំពើនៃកិលេសតណ្ហាលោកីយ៍ក្នុងខ្លួន ព្រមទាំងបូជាកម្លាំងកាយកម្លាំងចិត្តបម្រើមនុស្សលោក។ នេះហើយ ជាលក្ខណៈដ៏វិសុទ្ធដែលព្រះគ្រីស្តប្រទាន ឲ្យអស់លោកដើម្បីតម្រង់ខ្លួនទៅជាមនុស្សដ៏ពេញលក្ខណៈ (អភ ៤, ១៣)។

ហេតុនេះហើយ បានជាពេលអស់លោកបំពេញមុខងារបម្រើព្រះវិញ្ញាណ និងសេចក្តីសុចរិត អស់លោកចាក់ឫស ក្នុងជីវិតខាងព្រះវិញ្ញាណឲ្យកាន់តែមាំមួនឡើងៗ លុះត្រាតែអស់លោកសុខចិត្តធ្វើតាមព្រះវិញ្ញាណរបស់ព្រះគ្រិស្ត ដែលប្រទានជីវិតឲ្យអស់លោក និងណែនាំអស់លោក។ អស់លោកតម្រង់ខ្លួនឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ដោយធ្វើពិធីគោរពប្រណិប័តន៍ជារៀងរាល់ថ្ងៃ និងដោយបំពេញមុខងារបម្រើទាំងមូល ទាំងរួបរួមជាមួយលោកអភិបាល និងអស់លោកគង្វាលឯទៀតៗដែរ។ ម្យ៉ាងទៀតមុខងារបម្រើរបស់អស់លោកនឹងបានផលល្អ លុះត្រាតែអស់លោកមានលក្ខណៈវិសុទ្ធក្នុងខ្លួន។ ទោះបីព្រះជាម្ចាស់អាចប្រោសប្រណីសម្រេចការសង្គ្រោះមនុស្សលោក ដោយប្រើអ្នកបម្រើមិនសមគួរក៏ដោយ ក៏ប៉ុន្តែតាមធម្មតា ព្រះអង្គសព្វព្រះហឫទ័យសម្តែងស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ តាមរយៈអ្នកដែលសុខចិត្តទទួលឫទ្ធានុភាព និងការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធវិញ ហើយដែលរួបរួមយ៉ាងស្និទ្ធស្នាលជាមួយព្រះគ្រិស្តទៀតផង។ ដោយអ្នកទាំងនោះរស់នៅបែបវិសុទ្ធ គេអាចពោលរួមជាមួយគ្រីស្តទូតប៉ូលថា៖ *"បើខ្ញុំរស់ មិនមែនខ្ញុំទៀតទេដែលរស់ គឺព្រះគ្រិស្តទេតើ ដែលមានព្រះជន្មរស់នៅក្នុងខ្លួនខ្ញុំវិញ"* (កាឡ ២, ២០)។

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធ សូមក្រើនដាស់តឿនយ៉ាងខ្លាំងដល់បូជាចារ្យទាំងអស់ឲ្យខិតខំរស់នៅតាមបែបកាន់តែវិសុទ្ធឡើងៗ ជាផ្លូវនាំឲ្យអស់លោកក្លាយទៅជាឧបករណ៍កាន់តែប្រសើរឡើងៗសម្រាប់បម្រើប្រជារាស្ត្រទាំងមូលរបស់ព្រះជាម្ចាស់។ អស់លោកត្រូវប្រើគ្រប់មធ្យោបាយសមស្របតាមតម្រូវការ ដែលព្រះសហគមន៍ជូនអស់លោក ដើម្បីជួយឲ្យអស់លោកបានវិសុទ្ធបែបនោះ។ ធ្វើដូច្នោះ មហាសន្និបាតអាចបានទៅដល់គោលដៅនៃការណែនាំរបស់ខ្លួន គឺនាំឲ្យព្រះសហគមន៍កែសម្រួលផ្ទៃក្នុងឲ្យបានជាថ្មី អាចប្រកាសដំណឹងល្អក្នុងពិភពលោកទាំងមូល ព្រមទាំងឲ្យនិយាយសន្ទនាជាមួយមនុស្សលោកនាសម័យបច្ចុប្បន្ន។

## ១៣-មុខងារនាំឲបីរបស់បូជាចារ្យ នាមនារឲ្យអស់លោកបានវិសុទ្ធផង និងជួយឲ្យលោកបានវិសុទ្ធ

ប្រសិនបើអស់លោកគង្វាល បំពេញបន្ទុកទាំងប៉ុន្មានរបស់ខ្លួនដោយចិត្តស្មោះ និងដោយឥតឈប់ឈរ ទាំងមានព្រះវិញ្ញាណរបស់ព្រះគ្រិស្តណែនាំផង អស់លោកពិតជាមានមធ្យោបាយដ៏ពិតប្រាកដអាចទៅជាវិសុទ្ធបាន។ ក្នុងឋានៈអស់លោកជាអ្នកបំពេញមុខងារបម្រើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺអស់លោកតែងតែអាន និងស្តាប់ព្រះបន្ទូលនេះ ជារៀងរាល់ថ្ងៃ ដើម្បីបង្រៀនអ្នកដទៃ។ ទន្ទឹមនឹងនេះ ប្រសិនបើអស់លោកយកចិត្តទុកដាក់ទទួលព្រះបន្ទូលទុកក្នុងខ្លួនពិតមែននោះ អស់លោកក៏នឹងក្លាយទៅជាសាវ័ករបស់ព្រះអម្ចាស់កាន់តែពេញលក្ខណៈឡើងៗ ស្របតាមគ្រីស្តទូតប៉ូលដែលមានប្រសាសន៍ទៅកាន់លោកធីម៉ូថេថា៖ *"ត្រូវយកចិត្តទុកដាក់បំពេញមុខងារនេះ និងព្យាយាមតទៅមុខទៀតដើម្បីឲ្យគ្រប់គ្នាឃើញថា លោកប្អូនពិតជាបានចម្រើនឡើងមែន។ ត្រូវប្រយ័ត្នប្រយែងចំពោះខ្លួនឯង ប្រយ័ត្នប្រយែងនឹងសេចក្តីដែលលោកប្អូនបង្រៀនដោយព្យាយាម។ ធ្វើដូច្នេះ លោកប្អូននឹងសង្គ្រោះទាំងខ្លួនលោកប្អូនផង ទាំងបងប្អូនដែលស្តាប់លោកប្អូនទៀតផង"* (១ធម ៤, ១៥-១៦)។ ពេលអស់លោកខិតខំស្វែងរករបៀបដ៏ស្រួលជាងគេ ដើម្បីបញ្ជូនបន្តដល់អ្នកដទៃនូវសេចក្តីទាំងប៉ុន្មាន ដែលខ្លួនបានរកឃើញដោយស្ញឹងស្ញាច់នោះ អស់លោកមុខជានឹងក្រេបជញ្ជក់កាន់តែខ្លាំងឡើងៗនូវ *"សម្បត្តិដ៏បរិបូណ៌របស់ព្រះគ្រីស្ត"* (អភ ៣, ៨) និង *"ប្រាជ្ញាញាណគ្រប់វិស័យរបស់ព្រះជាម្ចាស់"* ដែរ (អភ ៣, ៩-១០)។ ប្រសិនបើអស់លោកនឹកចងចាំជានិច្ចថា គឺព្រះជាម្ចាស់ទេតើដែលបើកចិត្តគំនិតមនុស្ស (កក ១៦, ១៤) ហើយនឹកចងចាំទៀតថា មុខងារដ៏ប្រសើររបស់អស់លោកមកពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់ (២ករ ៤, ៧) មិនមែនមកពីខ្លួនអស់លោកទេ នោះក្នុងកិច្ចបញ្ជូនបន្តព្រះបន្ទូល អស់លោកមុខជានឹងរួបរួមកាន់តែជិតស្និទ្ធិជាមួយព្រះគ្រិស្ត

ជាព្រះបរមគ្រូ និងបណ្ដោយឲ្យព្រះវិញ្ញាណរបស់ព្រះអង្គដែលណែនាំអស់លោក។ ដោយអស់លោកមានទំនាក់ទំនងជាមួយព្រះគ្រីស្ដដូច្នេះ អស់លោកក៏ទទួលចំណែកក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ជាគម្រោងការដ៏អស្ចារ្យលាក់ទុកតាំងពីដើមរៀងមក (អភ ៣, ៩) ហើយដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់ក្នុងអង្គព្រះគ្រីស្ដ។

ក្នុងឋានៈអស់លោក ជាអ្នកបំពេញមុខងារបម្រើពិធីគោរពប្រណិប័តន៍ផ្សេងៗ ជាពិសេសពេលថ្វាយសក្ការបូជានៃអភិបូជា អស់លោកគង្វាលជាតំណាងយ៉ាងពិសេសរបស់ព្រះគ្រីស្ដផ្ទាល់ គឺជាតំណាងរបស់ព្រះអង្គ ដែលបានបូជាព្រះជន្មធ្វើជាយញ្ញ ដើម្បីប្រោសឲ្យមនុស្សលោកបានវិសុទ្ធ។ ហេតុនេះហើយ បានជាអស់លោកត្រូវរស់នៅឲ្យបានសមស្របតាមកិច្ចដែលអស់លោកប្រព្រឹត្តិក្នុងពិធីនោះ គឺពេលធ្វើពិធីលើកតម្កើងគម្រោងការដ៏អស្ចារ្យរបស់ព្រះអម្ចាស់ ដែលចូលទិវង្គត អស់លោកត្រូវខិតខំយកចិត្តទុកដាក់រំងាប់កិលេសតណ្ហាក្នុងខ្លួន និងជៀសវាងឲ្យផុតពីទម្លាប់ និងលម្អៀងអាក្រក់គ្រប់យ៉ាងទៀតផង។

ក្នុងគម្រោងការដ៏អស្ចារ្យនៃសក្ការៈបូជាអរព្រះគុណនោះ អស់លោកបូជាចារ្យបំពេញបន្ទុកចម្បងរបស់អស់លោក គឺព្រះគ្រីស្ដរំដោះមនុស្សយើងជានិច្ចនិរន្ដរ៍តទៅ។ ហេតុនេះហើយ បានជាមហាសន្និបាត ទូន្មានយ៉ាងខ្លាំងឲ្យអស់លោកថ្វាយអភិបូជាជារៀងរាល់ថ្ងៃ។ ទោះបីគ្រីស្ដបរិស័ទពុំអាចមានវត្តមានបានក៏ដោយ ក៏អភិបូជានៅតែជាកិច្ចរបស់ព្រះគ្រីស្ដ និងរបស់ព្រះសហគមន៍ដែរ។ ពេលអស់លោករួមក្នុងកិច្ចរបស់ព្រះគ្រីស្ដជាមហាបូជាចារ្យ អស់លោកក៏ថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់ដែរ។ ពេលអស់លោកទទួលព្រះកាយរបស់ព្រះគ្រីស្ដទុកជាអាហារ អស់លោកក៏រួមចំណែកយ៉ាងជ្រៅក្នុងចិត្ត អំពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ដែលប្រទានព្រះអង្គផ្ទាល់ឲ្យគ្រីស្ដបរិស័ទទុកជាអាហារ។

យ៉ាងណាមិញ ពេលអស់លោកធ្វើអគ្គសញ្ញានានាជូនគ្រីស្ដបរិស័ទ អស់លោកក៏រួមក្នុងបំណងរបស់ព្រះគ្រីស្ដ ដែលស្រឡាញ់មនុស្សលោក។ អស់លោករួមជាមួយព្រះគ្រីស្ដយ៉ាងពិសេស ដោយសុខចិត្តបង្ហាញថា អស់លោកមានពេលទំនេរអាចធ្វើអគ្គសញ្ញាលើកលែងទោស នៅគ្រប់ពេលគ្រីស្ដបរិស័ទសូម ប៉ុន្ដែ លុះត្រាតែគេសូមយ៉ាងសមគួរនឹងធ្វើជូនបាន។ ពេលអស់លោកធ្វើពិធីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមពេលកំណត់ អស់លោករួមសំឡេងជាមួយព្រះសហគមន៍ ដែលព្យាយាមអង្វរព្រះជាម្ចាស់ដោយឥតឈប់ឈរ ក្នុងនាមមនុស្សលោកទាំងមូល ដោយរួបរួមជាមួយព្រះគ្រីស្ដដែល *"មានព្រះជន្មគង់នៅរហូត ដើម្បីទូលអង្វរព្រះជាម្ចាស់ឲ្យយើង"* (ហប ៧, ២៥)។

ក្នុងឋានៈអស់លោកជាអ្នកណែនាំ និងជាគង្វាលថែទាំប្រជារាស្ដ្ររបស់ព្រះជាម្ចាស់ ព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូជាគង្វាលដ៏ល្អ ជំរុញឲ្យអស់លោកស៊ូប្ដូរជីវិតសម្រាប់កូនចៀមរបស់ខ្លួន (យហ ១០, ១១) ប្រុងខ្លួនបូជាជីវិតទុកជាសក្ការបូជាដ៏ខ្ពង់ខ្ពស់បំផុត ដោយយកតម្រាប់តាមបូជាចារ្យមួយចំនួនដែលពុំរួញរាបូជាជីវិតកាលពីដើម និងដូចសព្វថ្ងៃដែរ។

ក្នុងឋានៈអស់លោកជាអ្នកអប់រំខាងជំនឿ អស់លោក *"មានចិត្តរឹងប៉ឹងចូលមកក្នុងទីសក្ការៈ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូ"* (ហប ១០, ១៩) អស់លោកក៏ចូលទៅជិតព្រះជាម្ចាស់ *"ដោយចិត្តទៀងត្រង់ ពោរពេញដោយជំនឿមាំមួន"* (ហប ១០, ២២)។ ដូច្នេះអស់លោកជួយឲ្យគ្រីស្ដបរិស័ទ មានសេចក្ដីសង្ឃឹមដ៏មុតមាំ (២ករ ១, ៧) ថាព្រះជាម្ចាស់នឹងសម្រាលទុក្ខគេ ដើម្បីឲ្យគេអាចសម្រាលទុក្ខអស់អ្នកដែលរងទុក្ខវេទនាគ្រប់យ៉ាងដែរ (២ករ ១, ៤)។

ក្នុងឋានៈអស់លោកជាជាអ្នកដឹកនាំសហគមន៍ អស់លោកត្រូវរស់នៅដោយធ្វើតបធម៌ តាមរបៀបរបស់គង្វាលនៃវិញ្ញាណគ្រីស្ដបរិស័ទ គឺអស់លោកត្រូវលះបង់ការស្រណុកផ្ទាល់ខ្លួនចោលមិនរកប្រយោជន៍ផ្ទាល់ខ្លួនទេ *"តែត្រូវស្វែង*

*រកប្រយោជន៍រួមសម្រាប់មនុស្សទាំងអស់ ដើម្បីឲ្យគេបានទទួលការសង្គ្រោះ"* (១ករ ១០, ៣៣)។ អស់លោកក៏ត្រូវបំពេញកិច្ចការជាគង្វាលឲ្យកាន់តែល្អប្រសើរតទៅមុខ។ ប្រសិនបើមានតម្រូវការ អស់លោកក៏ត្រូវប្រុងខ្លួនប្រើវិធីឃ្វាលថ្មីៗ តាមព្រះវិញ្ញាណនៃសេចក្ដីស្រឡាញ់ណែនាំ គឺព្រះអង្គដែលសព្វព្រះហឫទ័យបក់ទៅទិសណាក៏បាន (យហ ៣, ៨)។

## ១៤-លោកគង្វាល ត្រូវសង្រួមចិត្តមិនឲ្យចិត្តគំនិតរវើរវាយ

ក្នុងពិភពលោកនាបច្ចុប្បន្នកាលនេះ មនុស្សម្នាក់ៗមុខជានឹងត្រូវតែបំពេញកិច្ចការជាច្រើនឥតគណនាមិនខានហើយមានបញ្ហាផ្សេងៗសង្កត់សង្កិនខ្លួនថែមទៀត ដែលត្រូវដោះស្រាយជាបន្ទាន់មិនអាចបង្អង់បានឡើយ។ ហេតុនេះមនុស្សភាគច្រើនវិលវល់ក្នុងចិត្ត មានចិត្តគំនិតប្រទាញប្រទង់គ្នា។ អស់លោកគង្វាលក៏ដូចគេដែរ គឺអស់លោកជំពាក់ជំពិន នឹងភារកិច្ចជាច្រើនតាមបន្ទុករបស់ខ្លួន មានចិត្តគំនិតប្រទាញប្រទង់គ្នា។ ជួនកាល អស់លោកក៏ដណ្ដឹងសួរខ្លួនឯងទាំងតប់ប្រមល់ថា តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យការរស់តាមព្រះវិញ្ញាណនៅខាងក្នុង អាចស៊ីជាមួយសកម្មភាពនៅខាងក្រៅបាន? អស់លោកមិនអាចធ្វើឲ្យជីវិតតាមព្រះវិញ្ញាណនៅខាងក្នុង និងសកម្មភាពនានាខាងក្រៅអាចស៊ីគ្នាបាន ដោយគ្រាន់តែចាត់ចែងកាលវិភាគធ្វើកិច្ចការតាមមុខងារបម្រើប៉ុណ្ណោះទេ ហើយទោះជាកិច្ចផ្សេងៗដែលបំប៉នវិញ្ញាណទាំងប៉ុន្មានជារៀងរាល់ថ្ងៃ អាចជួយយ៉ាងខ្លាំងយ៉ាងណាក៏ដោយ ក៏ការប្រព្រឹត្តកិច្ចទាំងនោះមិនអាចធ្វើឲ្យចិត្តគំនិត និងសមក្ខភាពស៊ីសង្វាក់គ្នាបានដែរ។ មានផ្លូវតែមួយដែលអាចជួយឲ្យអស់លោកសង្រួមចិត្តគំនិត មិនឲ្យប្រទាញប្រទង់គ្នាគឺនៅពេលអស់លោកបំពេញមុខងារបម្រើរបស់ខ្លួន អស់លោកត្រូវយកតម្រាប់តាមព្រះគ្រីស្ដជាព្រះអម្ចាស់ ដែលព្រះអង្គចាត់ទុកការធ្វើតាមព្រះហឫទ័យរបស់ព្រះបិតា ដែលចាត់ព្រះអង្គឲ្យយាងមក ព្រមទាំងបង្ហើយកិច្ចការនោះឲ្យបានសម្រេចជាអាហាររបស់ព្រះអង្គ (យហ ៤, ៣៤)។

តាមពិត ព្រះគ្រីស្ដប្រើអ្នកបម្រើរបស់ព្រះអង្គ ឲ្យធ្វើតាមព្រះហឫទ័យព្រះបិតាដដែលនោះ ក្នុងពិភពលោកនេះតទៅទៀតជានិច្ច ដោយសារព្រះសហគមន៍។ ហេតុនេះហើយ បានជាព្រះគ្រីស្ដនេះ នៅតែជាប្រភពដែលអាចធ្វើឲ្យការរស់នៅរបស់គង្វាលស៊ីគ្នាយ៉ាងសុខដុមរមនាបាន។ ដូច្នេះ លោកគង្វាលនឹងធ្វើឲ្យការរស់នៅរបស់ខ្លួនស៊ីគ្នា ដោយរួមរស់ភ្ជាប់ជាមួយព្រះគ្រីស្ដ ដើម្បីទទួលស្គាល់ព្រះហឫទ័យរបស់ព្រះបិតា និងដើម្បីបូជាខ្លួនទាំងស្រុងទុកជាប្រយោជន៍ដល់ហ្វូងចៀមដែលព្រះជាម្ចាស់បានផ្ញើទុកមកអស់លោក (១យហ ៣, ១៦)។ ដោយអស់លោករស់នៅតាមរបៀបរស់នៅរបស់ព្រះយេស៊ូជាគង្វាលដ៏ល្អប្រសើរនោះ អស់លោកមុខជានឹងប្រព្រឹត្តតាមសេចក្ដីស្រឡាញ់ក្នុងឋានៈខ្លួនជាគង្វាលទើបអស់លោកអាចរកឃើញចំណងនៃការរស់នៅរបស់ខ្លួនជាបូជាចារ្យដ៏ពេញលក្ខណៈ ដែលធ្វើឲ្យការរស់នៅរបស់អស់លោកបានចុះសម្រុងគ្នាយ៉ាងសុខដុមរមនា។ រីឯសេចក្ដីស្រឡាញ់ក្នុងឋានៈ ជាគង្វាលនេះវិញ ក៏ហូរចេញមកជាពិសេសពីសក្ការៈបូជាអរព្រះគុណ ដែលជាស្នូលនិងជាឫសនៃការរស់នៅទាំងមូលរបស់លោកគង្វាល។ ដោយមានចិត្តគំនិតជាបូជាចារ្យ លោកត្រូវខិតខំយកសក្ការបូជារបស់ព្រះគ្រីស្ដ ដែលលោកថ្វាយនៅលើតុសក្ការៈ ដាក់ជាប់ក្នុងនៅចិត្តរបស់លោក។ ប៉ុន្តែ អស់លោកបូជាចារ្យអាចសម្រេចការនេះបាន លុះត្រាតែ អស់លោកតែងតែអធិដ្ឋានស្នឹងស្នាធ៏ធ្វើឲ្យគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ដ ជ្រួតជ្រាបក្នុងចិត្តអស់លោកកាន់តែជ្រៅទៅៗ។

លោកគង្វាលអាចពិនិត្យមើលថា ការរស់នៅរបស់ខ្លួនស៊ីគ្នាយ៉ាងសុខដុមរមនាពិតប្រាកដមែននោះ ដោយពិនិត្យមើលគ្រប់កិច្ចការលោកប្រព្រឹត្ត ដើម្បីឲ្យចេះពិចារណាថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះ (រម ១២, ២) ពោលគឺរិះគិតឲ្យដឹងថា តើកិច្ចការទាំងប៉ុន្មានដែលអស់លោកប្រព្រឹត្តនោះ ស្របតាមគោលនៃបេសកកម្ម របស់ព្រះសហគមន៍ដែលប្រកាសដំណឹងល្អ ឬក៏អត់។ ចិត្តស្មោះត្រង់ភក្ដីចំពោះព្រះគ្រីស្ដ ពុំអាចផ្ដាច់ចេញពីចិត្ត ស្មោះត្រង់ភក្ដីចំពោះ

ព្រះសហគមន៍របស់ព្រះអង្គបានឡើយ។ ហេតុនេះហើយ បានជាសេចក្ដីស្រឡាញ់ក្នុងឋានៈលោកជាគង្វាល តម្រូវឲ្យអស់គង្វាលធ្វើការរួបរួមជាមួយលោកអភិបាល និងជាមួយគង្វាលឯទៀតៗជាបងប្អូន ដែលទទួលមុខងារបម្រើជាបូជាចារ្យរួមគ្នាជានិច្ច កុំឲ្យកិច្ចការរបស់ខ្លួនត្រឡប់ទៅជាអសារឥតការឡើយ (កឡ ២, ២)។ ប្រសិនបើអស់លោកគង្វាលប្រព្រឹត្តដូច្នេះ អស់លោកមុខជានឹងធ្វើឲ្យការរស់នៅរបស់ខ្លួនស៊ីគ្នាយ៉ាងសុខដុមរមនា ដោយចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍ទៀតផង។ អស់លោកក៏នឹងរួមភ្ជាប់ជាមួយព្រះអម្ចាស់របស់ខ្លួន ហើយដោយសារព្រះអង្គអស់លោកក៏រួបរួមជាមួយព្រះបិតា ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ហេតុនេះហើយ បានជាអស់លោកនឹងបានធូរស្បើយក្នុងចិត្តយ៉ាងច្រើន ព្រមទាំងមានអំណរសប្បាយពន់ប្រមាណ (២ករ ៧, ៤)។

## ផ្នែកទី ២-តម្រូវការពិសេសខាងព្រះវិញ្ញាណក្នុងការរស់នៅរបស់អស់លោកគង្វាល

### ១៥-លោកគង្វាលត្រូវមានចិត្តសុភាពរាបសា និងសុខចិត្តស្ដាប់បង្គាប់

ក្នុងចំណោមគុណធម៌ដែលលោកគង្វាល ត្រូវមានជាចាំបាច់ខានពុំបានដើម្បីបំពេញមុខងារបម្រើរបស់ខ្លួននោះ គឺមានចិត្តគំនិតត្រៀមខ្លួនជានិច្ច ស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលចាត់អស់លោកឲ្យទៅ មិនមែនស្វែងរកធ្វើតាមបំណងរបស់ខ្លួនឡើយ (យហ ៤, ៣៤; ៥, ៣០; ៦, ៣៨)។ ព្រះវិញ្ញាណដ៏វិសុទ្ធត្រាស់ហៅអស់លោកឲ្យបំពេញព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ (កក ១៣, ២) ជាព្រះរាជកិច្ចហួសពីកម្លាំង និងពីប្រាជ្ញាគ្រប់យ៉ាងរបស់មនុស្សលោក ដ្បិត *"ព្រះជាម្ចាស់បានជ្រើសរើសអ្វីៗដែលមនុស្សលោកចាត់ទុកថាទន់ខ្សោយក្នុងលោកីយ៍នេះ មកផ្ចាញ់ពួកអ្នកខ្លាំងពូកែវិញ"* (១ករ ១, ២៧)។ ហេតុនេះហើយ បានជាអ្នកបំពេញមុខងារបម្រើដ៏ពិតប្រាកដរបស់ព្រះគ្រីស្ដតែងដឹងថា ខ្លួនជាមនុស្សទន់ខ្សោយ ដាក់ខ្លួនធ្វើការដោយចិត្តសុភាពរាបសា ទាំងរិះគិតពិចារណាថា អ្វីដែលគាប់ព្រះហឫទ័យព្រះអម្ចាស់ (អភ ៥, ១០)។ ព្រះវិញ្ញាណដ៏វិសុទ្ធហាក់ដូចជាទាក់ទាញចិត្តគង្វាល (កក ២០, ២២) ទើបលោកបណ្ដោយខ្លួនឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ណែនាំក្នុងគ្រប់កិច្ចការទាំងអស់ គឺតាមព្រះហឫទ័យរបស់ព្រះអង្គ ដែលសព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ។ លោកគង្វាលអាចរកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងផ្ចង់ចិត្តធ្វើតាមក្នុងគ្រប់កិច្ចការប្រចាំថ្ងៃបាន ដ្បិតលោកដាក់ខ្លួនបម្រើអស់អ្នកដែលព្រះជាម្ចាស់បានផ្ញើទុកមកលោក ស្របតាមបន្ទុកដែលលោកបានទទួល និងស្របតាមព្រឹត្តិការណ៍ជាច្រើនដែលកើតឡើងក្នុងការរស់នៅរបស់ខ្លួនផង។

ប៉ុន្ដែ មុខងារបម្រើជាបូជាចារ្យ ជាមុខងារបម្រើរបស់ព្រះសហគមន៍តែម្ដង។ ហេតុនេះហើយ បានជាគ្មាននរណាអាចបំពេញមុខងារបម្រើនេះបាន ដោយមិនរួបរួមជាមួយអស់លោកអភិបាល ដែលកាន់អំណាចលើព្រះកាយទាំងមូលតាមលំដាប់លំដោយ។ ហេតុនេះ ដោយយល់ដល់ការរួបរួមគ្នាជាព្រះសហគមន៍ សេចក្ដីស្រឡាញ់របស់អស់លោក ក្នុងឋានៈជាគង្វាល ជំរុញអស់លោកឲ្យបូជាបំណងប្រាថ្នារបស់ខ្លួនផ្ទាល់ថ្វាយព្រះជាម្ចាស់ ដើម្បីបម្រើព្រះអង្គ និងបងប្អូន។ អស់លោកក៏ត្រូវសុខចិត្តទទួលស្គាល់ហើយអនុវត្ត តាមបញ្ញា និងដំបូន្មានអភិបាលព្រះសហគមន៍ក្រុងរ៉ូម អភិបាលរបស់ខ្លួន និងមេដឹកនាំឯទៀតៗ ដោយមានឆន្ទៈជាអ្នកផ្ញើជីវិតលើព្រះគ្រីស្ដ។ អស់លោកក៏ត្រូវសុខចិត្តចំណាយអ្វីដែលខ្លួនមាន ហើយក៏ចំណាយកម្លាំងកាយកម្លាំងចិត្តថែមទៀតផង (២ករ ១២, ១៥) ដើម្បីបំពេញគ្រប់បន្ទុកផ្ញើមកឲ្យអស់ដោយមានឆន្ទៈជាអ្នកផ្ញើជីវិតលើព្រះអង្គោក ទោះបីជាបន្ទុកតូច ឬមិនសំខាន់ក្ដី។ ដោយប្រព្រឹត្តដូច្នេះ អស់លោករក្សាទុក និងពង្រឹងការរួបរួមគ្នាដ៏ចាំបាច់ជាមួយគង្វាលឯទៀតៗជាបងប្អូន ដែលទទួលមុខងារបម្រើរួមគ្នា ហើយជាពិសេសជាមួយនឹងអស់លោកអភិបាល ដែលព្រះអម្ចាស់ចាត់តាំងជាមេដឹកនាំរបស់ព្រះសហគមន៍ព្រះអង្គ ដែលមនុស្សអាច

មើលឃើញបាន។ អស់លោកគង្វាល ក៏រួមគ្នាកសាងព្រះកាយព្រះគ្រីស្ដដែលចម្រើនឡើង *"ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មាន ដែលបម្រើព្រះកាយ តាមកម្រិតសមត្ថភាពរបស់សរីរាង្គនីមួយៗ"* (អភ ៤, ១១.១៦)។ ដោយអស់លោកស្ដាប់បង្គាប់បែបនេះ អស់លោកមុខជានឹងរស់នៅតាមសេរីភាពនៃបុត្រធីតាដ៏ពេញវ័យរបស់ព្រះជាម្ចាស់។ ពេលអស់លោកបំពេញបន្ទុករបស់ខ្លួន និងដោយមានសេចក្ដីស្រឡាញ់ជំរុញទៀតផង មានលោកគង្វាលខ្លះ រិះគិតពិចារណា ស្វះស្វែងរកវិធីថ្មីៗ ដើម្បីជាប្រយោជន៍ព្រះសហគមន៍។ ដោយអស់លោកសុខចិត្តស្ដាប់បង្គាប់ អស់លោកត្រូវរៀបរាប់អំពីគម្រោងការរបស់ខ្លួនឲ្យលោកអភិបាលដឹង ដោយសេចក្ដីទុកចិត្ត ទាំងគូសង្កត់លើតម្រូវការរបស់ហ្វូងចៀមដែលព្រះជាម្ចាស់បានផ្ញើទុកមក ទាំងប្រុងខ្លួនជានិច្ច ធ្វើតាមការវិនិច្ឆ័យរបស់អភិបាល ដែលទទួលបន្ទុកគ្រប់គ្រងលើព្រះសហគមន៍របស់ព្រះជាម្ចាស់ដែរ។ ការដាក់ខ្លួន និងសម្រេចចិត្តស្ដាប់បង្គាប់ទាំងទទួលខុសត្រូវបែបនេះ មុខជានឹងធ្វើឲ្យលោកគង្វាលបានដូចព្រះគ្រីស្ដ (អភ ៤, ១១-១៦)។ អស់លោកមុខជានឹងមានមនោសញ្ចេតនា ដូចព្រះគ្រីស្ដយេស៊ូដែលទ្រង់ *"បានលះបង់អ្វីៗទាំងអស់ មកយកឋានៈជាអ្នកបម្រើ... ធ្វើតាមព្រះបញ្ជារហូតដល់សោយទិវង្គត"* (ភល ២, ៧-៩)។ ដោយព្រះគ្រីស្ដស្ដាប់បង្គាប់បែបនេះឯង ព្រះអង្គបានជ័យជម្នះ និងរំដោះយើងឲ្យបានរួចពីបាបកម្មរបស់លោកអដាំ ដែលមិនបានស្ដាប់បង្គាប់វិញ ដូចគ្រីស្ដទូតធ្វើជាសាក្សីថា៖ *"មនុស្សទាំងអស់ជាប់បាប ដោយសារមនុស្សតែម្នាក់យ៉ាងណា ព្រះជាម្ចាស់ក៏នឹងប្រោសមនុស្សទាំងអស់ឲ្យបានសុចរិត ដោយសារមនុស្សតែម្នាក់ បានស្ដាប់បង្គាប់យ៉ាងនោះដែរ"* (រម ៥, ១៩)។

១៦-លោកគង្វាល ត្រូវកាន់ព្រហ្មចរិយធម៌ ហើយចាត់ព្រហ្មចរិយធម៌នេះ ទុកជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ ព្រះគ្រីស្ដជាព្រះអម្ចាស់ ទូន្មានឲ្យសាវ័ករស់នៅដោយកាន់ព្រហ្មចរិយធម៌យ៉ាងពេញលក្ខណៈ និងអស់មួយជីវិត ដោយយល់ដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ (មថ ១៩, ១២)។ តាំងពីជំនាន់ដើមរៀងមក រហូតមកដល់សព្វថ្ងៃមានគ្រីស្ដបរិស័ទជាច្រើន ស្ម័គ្រចិត្តកាន់ព្រហ្មចរិយធម៌បែបនេះដោយចិត្តរីករាយ ហើយបានកាន់តាមដោយគ្មានសៅហ្មងអ្វីឡើយ គួរឲ្យសរសើរមែន។ ព្រះសហគមន៍ក៏តែងតែចាត់ទុកជានិច្ចថា ការកាន់ព្រហ្មចរិយធម៌ ពិតជារបៀបរស់នៅដ៏ប្រសើរ ជាពិសេសសម្រាប់អស់លោកបូជាចារ្យ។ ការរស់ដោយកាន់តាមព្រហ្មចរិយធម៌ជាសញ្ញាសម្គាល់អំពីសេចក្ដីស្រឡាញ់របស់គង្វាលផង និងជំរុញឲ្យសេចក្ដីស្រឡាញ់នោះចម្រើនឡើងទៀតផង។ ម្យ៉ាងទៀត ការរស់ដោយកាន់តាមព្រហ្មចរិយធម៌ក៏ពិតជាប្រភពដ៏ពិសេសមួយ បង្កើតផលផ្លែខាងព្រះវិញ្ញាណ ក្នុងពិភពលោកផងដែរ (ពន្លឺ ៤២)។ ពិតមែនលក្ខណៈនៃមុខងារជាបូជាចារ្យ មិនទាមទារឲ្យអស់លោកកាន់តាមព្រហ្មចរិយធម៌នោះទេ ដូចទំនៀមទម្លាប់នៃព្រះសហគមន៍ជំនាន់ដើម (១ធម ៣, ២-៥; ទត ១, ៦) និងប្រពៃណីព្រះសហគមន៍នៅបូព៌ាប្រទេសជាសាក្សីស្រាប់។ ព្រះសហគមន៍នៅបូព៌ាប្រទេសមានគង្វាលខ្លះ ជ្រើសរើសរស់នៅដោយកាន់តាមព្រហ្មចារីយ៍ធម៌ ទុកជាព្រះអំណោយទានមកពីព្រះជាម្ចាស់។ អស់លោកអភិបាលរស់នៅដោយកាន់តាមព្រហ្មចរិយធម៌។ ក៏ប៉ុន្តែ មានលោកគង្វាលខ្លះមានគ្រួសារ។ អស់លោកក៏ពិតជាគង្វាលដ៏ល្អប្រសើរដែរ។ ទោះបីមហាសន្និបាតដ៏វិសុទ្ធនេះ ទូន្មានឲ្យអស់លោកគង្វាលរស់ដោយកាន់តាមព្រហ្មចរិយធម៌ក្ដី ក៏មហាសន្និបាតពុំមានបំណងចង់ផ្លាស់ប្រែវិន័យប្លែក ដែលមានកាន់យ៉ាងត្រឹមត្រូវក្នុងព្រះសហគមន៍នៅបូព៌ាប្រទេសនោះទេ។ ផ្ទុយទៅវិញ ដោយសេចក្ដីស្រឡាញ់យ៉ាងខ្លាំងជាទីបំផុត មហាសន្និបាតសូមដាស់តឿនអស់បុរស ដែលបានរៀបអាពាហ៍ពិពាហ៍ ហើយដែលបានទទួលអគ្គសញ្ញាតែងតាំង ជាគង្វាល ឲ្យព្យាយាមបំពេញមុខងារដ៏វិសុទ្ធរបស់ខ្លួនតទៅទៀត តាមតែព្រះជាម្ចាស់ត្រាស់ហៅ និងឲ្យស៊ូប្ដូរជីវិតទាំងស្រុងដោយចិត្តទូលាយសម្រាប់ហ្វូងចៀមដែលព្រះជាម្ចាស់បានផ្ញើទុកមក។

ក៏ប៉ុន្តែ ការរស់នៅដោយកាន់ព្រហ្មចរិយធម៌ សមនឹងមុខងារជាបូជាចារ្យត្រង់ប្រការជាច្រើន។ បេសកកម្មរបស់

បូជាចារ្យ គឺបូជាកម្លាំងកាយកម្លាំងចិត្តទាំងស្រុង ដើម្បីបម្រើមនុស្សលោកថ្មីដែលព្រះគ្រីស្តបានប្រតិស្ឋានមក។ ព្រះគ្រីស្ត ដែលមានជ័យជម្នះលើសេចក្តីស្លាប់ ព្រះអង្គប្រតិស្ឋានមនុស្សជាតិថ្មីនោះ នៅក្នុងលោកីយដោយសារព្រះវិញ្ញាណរបស់ព្រះអង្គ។ មនុស្សជាតិថ្មីនោះ មានដើមកំណើត *"ពុំមែនពីលោហិត ឬពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សឡើយ គឺកើតពីព្រះជាម្ចាស់វិញ"* (យហ ១, ១៣)។ ដោយអស់លោកគង្វាលកាន់តាមព្រហ្មចរិយធម៌ ឬដោយមិនរួមបវេណី ព្រោះខ្លួនគិតដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ (មថ ១៩, ១២) អស់លោកញែកខ្លួនប្រសិទ្ធិថ្វាយព្រះគ្រីស្តតាមរបៀបមួយថ្មី និងយ៉ាងប្រសើរបំផុត។ អស់លោកនឹងផ្ចង់ចិត្តទៅនឹងព្រះអង្គ ងាយជាងអ្នកមានគ្រួសារ ដោយគ្មានចិត្តប្រទាញប្រទង់ (១ករ ៧, ៣២-៣៤)។ អស់លោកក៏មានសេរីភាពច្រើនជាងអ្នកមានគ្រួសារ ថ្វាយកម្លាំងចិត្តកម្លាំងកាយបម្រើព្រះជាម្ចាស់ផង និងបម្រើមនុស្សលោកផង ក្នុងអង្គព្រះគ្រីស្ត និងដោយព្រះគ្រីស្ត។ អស់លោកក៏មានលទ្ធភាពច្រើនជាងអ្នកមានគ្រួសារដោយមិនជំពាក់ជំពិនអ្វីមួយ អាចបម្រើព្រះរាជ្យរបស់ព្រះអង្គ និងជួយធ្វើកិច្ចបង្កើតមនុស្សជាថ្មីតាមលោកខាងមុខ។ អស់លោកក៏មានសមត្ថភាពច្រើនជាងអ្នកមានគ្រួសារ អាចទទួលមុខងារជាឪពុកដ៏ទូលំទូលាយក្នុងអង្គព្រះគ្រីស្ត។ ដូច្នេះ អស់លោករស់នៅដោយកាន់តាមព្រហ្មចរិយធម៌បែបនោះ ប្រកាសចំពោះមុខមនុស្សលោកថា គេសុខចិត្តបូជាកម្លាំងកាយកម្លាំងចិត្ត ដោយគ្មានប្រទាញប្រទង់ បំពេញកិច្ចការដែលព្រះជាម្ចាស់បានផ្ញើទុកឲ្យធ្វើ ពោលគឺដណ្តឹងគ្រីស្តបរិស័ទឲ្យថ្វាយទៅព្រះគ្រីស្ត ជាព្រះស្វាមីតែមួយគត់ ទុកដូចជាក្រមុំព្រហ្មចារីដ៏បរិសុទ្ធ (២ករ ១១, ២)។ អស់លោកនាំឲ្យមនុស្សស្រមៃឃើញអំពីអាពាហ៍ពិពាហ៍តាមគម្រោងការដ៏អស្ចារ្យ គឺព្រះសហគមន៍នឹងរៀបអភិសេកជាមួយព្រះគ្រីស្តជាព្រះស្វាមីតែមួយគត់ (ពន្លឺ ៤២.៤៤; សម្រួល ១២)។ ព្រះជាម្ចាស់សព្វព្រះហឫទ័យមានគម្រោងការនេះ ដែលនឹងលេចចេញមកយ៉ាងពេញលេញនៅពេលអនាគត។ លើសពីនេះទៅទៀត អស់លោកក្លាយទៅជាសញ្ញាសម្គាល់ដ៏មានជីវិតរស់រវើក អំពីលោកខាងមុខ ដែលមានវត្តមានក្នុងលោកនេះរួចហើយ ដោយសារជំនឿ និងដោយសេចក្តីស្រឡាញ់ ពោលគឺ នៅក្នុងលោកខាងមុខនោះ បុត្រធីតាដែលព្រះជាម្ចាស់ ប្រោសឲ្យមានជីវិតថ្មីដ៏រុងរឿង លែងរៀបការប្តីប្រពន្ធទៀតហើយ ( លក ២០, ៣៥-៣៦)។

កាលពីដំបូង ព្រះសហគមន៍គ្រាន់តែទូន្មានឲ្យបូជាចារ្យកាន់តាមព្រហ្មចរិយធម៌ប៉ុណ្ណោះ ព្រោះតែសម្អាងលើគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងលើបេសកកម្មរបស់ព្រះអង្គជាមូលដ្ឋាន។ ក្រោយមក ក្នុងព្រះសហគមន៍ ដែលកាន់តាមរបៀបរបបពិធីភាសាឡាតាំង ព្រះសហគមន៍បង្កើតច្បាប់វិន័យ បញ្ជាឲ្យអស់អ្នកដែលទទួលអគ្គសញ្ញាតែងតាំងត្រូវកាន់ព្រហ្មចរិយធម៌នោះ។ មហាសន្និបាតដ៏វិសុទ្ធនេះ ក៏យល់ស្របតាម និងបញ្ជាក់ច្បាប់វិន័យនេះសាជាថ្មីចំពោះអស់អ្នកដែលនឹងទទួលអគ្គសញ្ញាតែងតាំងជាគង្វាល។ មហាសន្និបាតមានសេចក្តីសង្ឃឹមលើព្រះវិញ្ញាណ ហើយជឿជាក់ថា ព្រះបិតាមុខជានឹងប្រទានព្រះអំណោយទានយ៉ាងទូលំទូលាយឲ្យគ្រីស្តបរិស័ទរស់នៅ ដោយកាន់តាមព្រហ្មចរិយធម៌ដែលពិតជាសមរម្យស្របនឹងមុខងារជាបូជាចារ្យនៃសម្ពន្ធមេត្រីថ្មី។ អស់លោកគង្វាល ដែលរួមចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាមហាបូជាចារ្យ ដោយអគ្គសញ្ញាតែងតាំងនោះ ជាពិសេសទៅទៀតព្រះសហគមន៍ទាំងមូល ត្រូវតែនាំគ្នាទទូចអង្វរព្រះបិតា ដោយចិត្តសុភាពរាបសា សូមព្រះអង្គប្រោសប្រទានព្រះអំណោយទាននេះផង។ ម្យ៉ាងទៀត មហាសន្និបាតដ៏វិសុទ្ធនេះ ក៏សូមដាស់តឿនអស់លោកគង្វាល ដែលបានផ្ញើជីវិតលើព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ ហើយដែលបានជ្រើសរើសដោយសេរី ស្ម័គ្រចិត្តរស់នៅដោយកាន់តាមព្រហ្មចរិយធម៌ដោយយកតម្រាប់តាមព្រះគ្រីស្ត សូមអស់លោកផ្ចង់ចិត្តយ៉ាងទូលំទូលាយ នឹងព្រហ្មចរិយធម៌នេះដោយស្មោះអំពីចិត្ត។ សូមកាន់តាមសភាពការណ៍នេះដោយចិត្តភក្តី សូមទទួលស្គាល់តម្លៃដ៏ប្រសើរនៃព្រះអំណោយទានរបស់ព្រះបិតានេះ មកអស់លោក ហើយដែលព្រះអម្ចាស់សរសើរលើកតម្កើងយ៉ាង ច្បាស់លាស់ផង (មថ ១៩, ១១)។ សូមអស់លោកស្នឹងស្មាធិ៍រិះគិតអំពីគម្រោងការ

ដ៏សម្បើមអស្ចារ្យនៃការរស់នៅ តាមព្រហ្មចរិយធម៌នេះ អស់លោកជាសញ្ញាសម្គាល់នៃគម្រោងការដ៏អស្ចារ្យនេះ ហើយបានសម្រេចរួចហើយទៀតដែរ។ ពិតមែនក្នុងពិភពលោកនាបច្ចុប្បន្នកាល មានមនុស្សជាច្រើនតែងប្រកាសថា គ្មាននរណាអាចកាន់តាមព្រហ្មចរិយធម៌យ៉ាងពិតប្រាកដអស់មួយជីវិតបានឡើយ។ នេះជាមូលហេតុមួយទៀត ជំរុញអស់លោកគង្វាល ឲ្យកាន់តែព្យាយាមទទូចអង្វរព្រះជាម្ចាស់ ដោយចិត្តកាន់តែសុភាពរាបសា រួមជាមួយព្រះសហគមន៍ផង សូមព្រះអង្គប្រទានព្រះអំណោយទាននៃភក្ដីភាពមកផង។ ព្រះអង្គពុំដែលបដិសេធប្រទានព្រះអំណោយទាននេះ ឲ្យអ្នកដែលអង្វរសូមឡើយ។ ទន្ទឹមនឹងនេះ អស់លោកត្រូវប្រើគ្រប់ជំនួយទាំងអស់ ទាំងនៅខាងលោកនេះក្ដី ទាំងនៅខាងលោកខាងមុខក្ដី ដែលអ្នកណាក៏អាចយកមកប្រើបានដែរ ដើម្បីឲ្យខ្លួនអាចកាន់តាមព្រហ្មចរិយធម៌បាន។ ម៉្យាងទៀត សេចក្ដីណែនាំរបស់ព្រះសហគមន៍ ជាពិសេសសេចក្ដីណែនាំឲ្យប្រព្រឹត្ដតាមតបធម៌ ដែលព្រះសហគមន៍មានបទពិសោធន៍ល្បងលមើលរួចហើយ ក៏មានសារៈសំខាន់ដ៏ចាំបាច់ក្នុងពិភពលោកនាសម័យនេះ។ សូមអស់លោកគង្វាលកាន់តាមសេចក្ដីណែនាំទាំងនោះផង។ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធ អញ្ជើញមិនត្រឹមតែបូជាចារ្យប៉ុណ្ណោះទេ តែអញ្ជើញអស់គ្រីស្ដបរិស័ទដែរ ឲ្យរាប់រកព្រហ្មចរិយធម៌របស់បូជាចារ្យទុកជាព្រះអំណោយដ៏មានតម្លៃនេះ ហើយឲ្យទាំងអស់គ្នាអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះអំណោយទាននៃព្រហ្មចរិយធម៌នេះយ៉ាងបរិបូណ៌ឲ្យព្រះសហគមន៍របស់ព្រះអង្គជានិច្ចផង។

## ១៧-ឥរិយាបថរបស់លោកគង្វាល ចំពោះពិភពលោក និងសម្បត្តិលោកីយ៍

អស់លោកគង្វាល តែងតែទាក់ទងជាមួយគ្នាទៅវិញទៅមក និងជាមួយអ្នកឯទៀតៗទុកជាបងប្អូន និងទុកជាមិត្តសម្លាញ់។ ដូច្នេះ អស់លោកបង្ហាត់ខ្លួនឲ្យស្គាល់ និងគោរពតម្លៃដ៏ថ្លៃថ្នូរនៃការរស់នៅរបស់មនុស្ស ព្រមទាំងរាប់អ្វីៗ ទាំងអស់ដែលព្រះជាម្ចាស់បានប្រតិស្ឋានមក ទុកជាព្រះអំណោយទានរបស់ព្រះអង្គ។ អស់លោករស់នៅក្នុងលោកនេះ ប៉ុន្តែអស់លោកតោងនឹកគិតជានិច្ចថា អស់លោកមិនមែនកើតពីលោកីយ៍ទេ ស្របតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះបរមគ្រូនៃយើង (យហ ១៧, ១៤-១៦)។ ដូច្នេះ អស់លោកប្រើប្រាស់សម្បត្តិលោកីយ៍ដោយកាន់ចិត្តថាខ្លួនមិនមែនជាម្ចាស់លើអ្វីៗទាំងនោះ (១ករ ៧, ៣១)។ ចិត្តគំនិតនេះ មុខជានឹងនាំឲ្យអស់លោកឈានទៅដល់សេរីភាព ដែលរំដោះអស់លោកឲ្យរួចផុតពីគ្រប់កង្វល់ដ៏រាយប៉ាយហួសហេតុពេក ព្រមទាំងនាំឲ្យអស់លោកសុខចិត្តស្ដាប់បង្គាប់ព្រះជាម្ចាស់ ដែលមានព្រះបន្ទូលតាមរយៈការរស់នៅប្រចាំថ្ងៃ។ សេរីភាព និងចិត្តចង់ស្ដាប់តាមបង្គាប់នេះ បណ្ដោយឲ្យអស់លោកចេះថ្លឹងថ្លែងអ្វីៗតាមបែបព្រះវិញ្ញាណ គឺនាំឲ្យអស់លោករកឃើញឥរិយាថដ៏ត្រឹមត្រូវចំពោះមនុស្សលោក និងចំពោះសម្បត្តិលោកីយទៀតផង។ ឥរិយាបថនេះ ពិតជាមានសារៈសំខាន់ជាចាំបាច់ចំពោះលោកគង្វាល ព្រោះព្រះសហគមន៍ បំពេញបេសកកម្មរបស់ខ្លួនក្នុងពិភពលោក ហើយសម្បត្តិលោកីយ៍ដែលព្រះជាម្ចាស់ប្រតិស្ឋានមក ក៏មានសារៈសំខាន់ជាចាំបាច់បំផុតសម្រាប់ឲ្យមនុស្សម្នាក់ៗអាចចម្រើនឡើងបានដែរ។ អស់លោកត្រូវតែដឹងគុណព្រះបិតាដ៏ខ្ពង់ខ្ពស់បំផុត ចំពោះអ្វីៗទាំងអស់ដែលព្រះអង្គប្រទានមកឲ្យអស់លោកដើម្បីរស់នៅយ៉ាងសមរម្យ។ ប៉ុន្តែ ត្រូវឲ្យពន្លឺនៃជំនឿបំភ្លឺចិត្តគំនិតអស់លោក ឲ្យចេះរិះគិតពិចារណាអំពីអ្វីៗទាំងអស់ដែលអស់លោកជួបប្រទះ ដើម្បីឲ្យអស់លោកចេះប្រើប្រាស់សម្បត្តិទាំងអស់យ៉ាងត្រឹមត្រូវសមស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រមទាំងឲ្យចេះលះបង់ចោលអ្វីៗទាំងអស់ ដែលអាចរារាំងបេសកកម្មរបស់អស់លោកទៀតផង។

អស់លោកបូជាចារ្យបានទទួលព្រះអម្ចាស់ទុកជា *"ចំណែកមរតក"* (ជរ ១៨, ២០) របស់ខ្លួនរួចហើយ។

ហេតុនេះ អស់លោកត្រូវប្រើប្រាស់សម្បត្តិលោកីយ៍ សម្រាប់តែបំពេញគម្រោងការណាដែលលទ្ធិរបស់ព្រះគ្រីស្ត និង សេចក្ដីណែនាំរបស់ព្រះសហគមន៍អនុញ្ញាតឲ្យប៉ុណ្ណោះ។

ចំពោះសម្បត្តិជាកម្មសិទ្ធិព្រះសហគមន៍ផ្ទាល់វិញ អស់លោកបូជាចារ្យត្រូវគ្រប់គ្រងសម្បត្តិទាំងនោះ ស្របតាមលក្ខណៈរបស់វា និងស្របតាមសេចក្ដីណែនាំនៃច្បាប់របស់ព្រះសគមន៍។ប្រសិនបើអាចធ្វើបាន សូមឲ្យគ្រីស្តបរិស័ទធម្មតា ដែលមានសមត្ថភាពជួយគ្រប់គ្រងសម្បត្តិទាំងនោះ។ ត្រូវប្រើសម្បត្តិទាំងនោះសម្រាប់តែគម្រោងការណា ដែលអនុញ្ញាតឲ្យព្រះសហគមន៍សមនឹងកាន់កាប់សម្បត្តិលោកីយ៍ ពោលគឺ សម្រាប់ចាត់ចែងពិធីគោរពបម្រើព្រះជាម្ចាស់ និងសម្រាប់ផ្គត់ផ្គង់ជីវភាពយ៉ាងសមរម្យឲ្យក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង ហើយសម្រាប់បំពេញកិច្ចការជាគ្រីស្តទូត និងកិច្ចមេត្តាករុណា ជាពិសេសចំពោះអ្នកខ្វះខាត។ ចំពោះសម្បត្តិដែលអភិបាលឬអស់លោកគង្វាលបានពីការ បំពេញការងារអ្វីមួយក្នុងព្រះសហគមន៍ អស់លោកត្រូវប្រើប្រាស់សម្រាប់ធានាជីវភាពរបស់ខ្លួនយ៉ាងសមរម្យ និងសម្រាប់បំពេញភារកិច្ចនានានៃមុខងាររបស់ខ្លួនជាមុនសិន។ ចំពោះអ្វីៗដែលនៅសេសសល់ អស់លោកត្រូវយកចិត្តទុកដាក់ប្រើដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ ឬសម្រាប់កិច្ចមេត្តាករុណាវិញ។ ប៉ុន្តែ ត្រូវប្រើប្រាស់សម្បត្តិតាមរបៀបនេះលុះត្រាតែ គ្មានច្បាប់អនុញ្ញាតឲ្យប្រើតាមរបៀបផ្សេង។ សរុបសេចក្ដីមក មុខតំណែងក្នុងព្រះសហគមន៍ មិនត្រូវក្លាយទៅជារបររកស៊ីឡើយ។ អស់លោកគង្វាលមិនត្រូវយកប្រាក់ចំណេញពីសម្បត្តិព្រះសហគមន៍ មកបង្កើនទ្រព្យកម្មសិទ្ធផ្ទាល់ខ្លួនជាដាច់ខាត។ ហេតុនេះហើយ បានជាបូជាចារ្យមិនត្រូវជំពាក់ចិត្តនឹងទ្រព្យសម្បត្តិឡើយ (ទន ៦២, ១១) ផ្ទុយទៅវិញ ត្រូវជៀសវាងឲ្យផុតពីចិត្តលោភលន់គ្រប់យ៉ាងជានិច្ច និងប្រយ័ត្នប្រយែងមិនប្រព្រឹត្តអ្វី ដែលហាក់ដូចជាជំនួញរកស៊ីនោះឡើយ។

ផ្ទុយទៅវិញ ព្រះសហគមន៍អញ្ជើញអស់លោកឲ្យស្ម័គ្រចិត្តរស់នៅក្នុងឋានៈ ជាអ្នកក្រីក្រ ដើម្បីឲ្យអស់លោកកាន់តែបានដូចព្រះគ្រីស្ត និងឲ្យមានចិត្តប្រុងខ្លួនបំពេញមុខងារបម្រើដ៏សក្ការៈរបស់ខ្លួនកាន់តែខ្លាំងឡើងៗដែរ។ *"ព្រះគ្រីស្តដែលមានសម្បត្តិដ៏ច្រើនយ៉ាងណា ព្រះអង្គដាក់ខ្លួនមកជាអ្នកក្រ ព្រោះតែយើង ដើម្បីឲ្យយើងបានទៅជាអ្នកមាន ដោយភាពក្រីក្ររបស់ព្រះអង្គ"* (២ករ ៨, ៩)។ ក្រុមគ្រីស្តទូតក៏ធ្វើជាគំរូ និងបានផ្ដល់សក្ខីភាពថា ត្រូវចែកឲ្យអ្នកដទៃដោយឥតគិតថ្លៃនូវអ្វីៗ ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើងដោយឥតគិតថ្លៃដែរ (កក ៨, ១៨-២៥) ក្រុមគ្រីស្តទូតក៏ចេះរស់នៅដោយមានបរិបូណ៌ផង និងដោយខ្វះខាតផង (ភល ៤, ១២)។ ប្រសិនបើអស់លោកគង្វាលយកទ្រព្យសម្បត្តិខ្លះរបស់ខ្លួនមកដាក់ឲ្យប្រើប្រាស់រួមគ្នា តាមរបៀបដែលប្រវត្តិសាស្ត្រព្រះសហគមន៍ដើមដំបូងតែងតែសរសើរនោះ (កក ២, ៤២-៤៧) អស់លោកមុខជាមានផ្លូវមួយដ៏ប្រសើរ ឈានទៅកាន់សេចក្ដីស្រឡាញ់ក្នុងឋានៈខ្លួនជាគង្វាលពុំខាន។ របៀបរស់នៅដ៏គួរឲ្យសរសើរបែបនេះ ពិតជានឹងបណ្ដោយឲ្យអស់លោកគង្វាល អាចប្រព្រឹត្តតាមចិត្តគំនិតជាអ្នកក្រីក្រតាមដំបូន្មានរបស់ព្រះគ្រីស្តមែន។

សូមឲ្យអស់លោកគង្វាល និងអភិបាលបណ្ដោយខ្លួនឲ្យព្រះវិញ្ញាណរបស់ព្រះអម្ចាស់ណែនាំ គឺព្រះវិញ្ញាណ ដែលចាក់ប្រេងអភិសេកព្រះសង្គ្រោះ និងចាត់ព្រះអង្គឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ (លក ៨, ១៨)។ សូមអស់លោកជៀសវាងអ្វីៗទាំងអស់ ទោះជាអ្វីណាក៏ដោយ ដែលបណ្ដាលឲ្យជនក្រីក្រឃ្លាតឆ្ងាយពីអស់លោក។ សូមលះបង់អំណួតគ្រប់យ៉ាង ដោយខ្លួនអះអាងលើទ្រព្យសម្បត្តិផ្ទាល់ គឺលះបង់ឲ្យបានលើសពីសាវ័ករបស់ព្រះគ្រីស្តឯទៀតៗផងដែរ។ សូមអស់លោកចាត់ចែងផ្ទះរបស់ខ្លួន តាមរបៀបដែលគ្មាននរណាម្នាក់ស្មានថាគេមិនអាចចូលបាន គឺត្រូវចាត់ចែងផ្ទះតាមរបៀប ដែលសូម្បីតែអ្នកតូចតាចជាងគេ ក៏មិនត្រូវខ្មាសនឹងចូលដែរ។

## ផ្នែកទី ៣-ជំនួយសម្រាប់ជួយក្នុងការរស់នៅរបស់អស់លោកគង្វាល

### ១៨-មធ្យោបាយជួយឲ្យជីវិតតាមព្រះវិញ្ញាណរបស់អស់លោកគង្វាលអាចចម្រើនឡើងបាន

អស់លោកគង្វាលត្រូវរួមរស់ភ្ជាប់ជាមួយព្រះគ្រីស្ត ក្នុងគ្រប់កាលៈទេសៈប្រចាំជីវិត។ អស់លោកតែងតែបំពេញមុខងារបម្រើរបស់ខ្លួនដោយដឹងពីអត្ថន័យដ៏ជ្រៅ ទុកជាមធ្យោបាយចម្បង ដើម្បីពង្រឹងការរួមរស់ភ្ជាប់ជាមួយព្រះគ្រីស្ត ឲ្យកាន់តែជិតស្និទ្ធឡើងៗ។ ក្រៅពីនេះ អស់លោកអាចប្រើមធ្យោបាយផ្សេងៗទៀត គឺមានមធ្យោបាយទូទៅ និងមធ្យោបាយពិសេស មានមធ្យោបាយចាស់និងមធ្យោបាយថ្មីៗទៀត។ ព្រះវិញ្ញាណដ៏វិសុទ្ធពុំដែលឈប់បង្កើតមធ្យោបាយទាំងនោះក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឡើយ។ ព្រះសហគមន៍ដែលយកចិត្តទុកដាក់ ឲ្យសមាជិករបស់ខ្លួនបានវិសុទ្ធតែងទូន្មាន (និងជួនកាលបញ្ជា) ឲ្យអស់លោកគង្វាលប្រើមធ្យោបាយខ្លះៗដែរ។ ក្នុងចំណោមមធ្យោបាយដែលធ្វើឲ្យជីវិតខាងព្រះវិញ្ញាណចម្រើនឡើង កិច្ចដ៏ល្អប្រសើរជាងគេ គឺកិច្ចទាំងប៉ុន្មាន ដែលធ្វើឲ្យគ្រីស្តបរិស័ទចិញ្ចឹមជីវិតខាងព្រះវិញ្ញាណ ដោយសារព្រះបន្ទូលដែលប្រសូតជាមនុស្ស ពីតុដែលផ្តល់អាហារពីរយ៉ាង ពោលគឺ ព្រះគម្ពីរនិងអគ្គសញ្ញាអរព្រះគុណ (បុព្វជិត ៦; ពិធី ២១)។ នរណាក៏ដឹងស្រាប់ហើយថា ការព្យាយាមប្រើជំនួយពីតុទាំងពីរនេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឲ្យអស់លោកគង្វាលបានវិសុទ្ធ។

អស់លោកគង្វាលជាអ្នកបំពេញមុខងារបម្រើ ចែករំលែកព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ តាមអគ្គសញ្ញានានា។ ពេលអស់លោកទទួលអគ្គសញ្ញាទាំងនោះ តាមរបៀបដែលបង្កើតផល ពេលនោះអស់លោកក៏រួបរួមភ្ជាប់យ៉ាងជិតស្និទ្ធជាមួយព្រះគ្រីស្តជាព្រះសង្គ្រោះ និងជាគង្វាល ជាពិសេសនៅពេលអស់លោកទទួលអគ្គសញ្ញាលើកលែងទោសជាញឹកញាប់។ អស់លោកត្រូវរៀបចំខ្លួនទទួលអគ្គសញ្ញាលើកលែងទោសនេះ ដោយពិនិត្យមនសិការរបស់ខ្លួនជារៀងរាល់ថ្ងៃ ជាកិច្ចមួយជួយឲ្យអស់លោកប្រែចិត្តគំនិតជាចាំបាច់ និងជួយឲ្យអស់លោកស្រឡាញ់ព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណាគ្រប់យ៉ាង។ អស់លោកចិញ្ចឹមជំនឿរបស់ខ្លួន ដោយអានព្រះគម្ពីរទាំងស្ទឹងស្មាធិ៍។ ដោយអស់លោកគង្វាលមានពន្លឺនៃជំនឿនេះបំភ្លឺចិត្តគំនិត អស់លោកមានសមត្ថភាពអាចស្វែងរក ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានតាមសញ្ញាសម្គាល់ផ្សេងៗ និងស្វែងរកព្រះហឫទ័យប្រោសប្រណីរបស់ព្រះអង្គតាមព្រឹត្តិការណ៍នានាប្រចាំជីវិត។ ដោយធ្វើដូច្នេះ អស់លោកកាន់តែធ្វើតាមបង្គាប់នៃបេសកកម្ម ដែលអស់លោកបានសុខចិត្តទទួលដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ អស់លោកត្រូវយកព្រះនាងព្រហ្មចារិនីម៉ារី ធ្វើជាគំរូដ៏ប្រសើរគ្រប់ពេលវេលា គឺព្រះនាងក៏បានស្តាប់តាមបង្គាប់ដែរ។ ដោយព្រះវិញ្ញាណដ៏វិសុទ្ធណែនាំ ព្រះនាងថ្វាយខ្លួនទាំងស្រុងបម្រើគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តដែលរំដោះមនុស្សលោក (ពន្លឺ ៦៥)។ អស់លោកគង្វាល គប្បីគោរពនិងស្រឡាញ់ព្រះនាងដូចកូនស្រឡាញ់ម្តាយដូច្នោះដែរ ក្នុងឋានៈព្រះនាងជាព្រះមាតារបស់មហាបូជាចារ្យដ៏មានព្រះជន្មជានិច្ចនិរន្ត៍ ជាព្រះមហាក្សត្រីយានីនៃក្រុមគ្រីស្តទូតនិងជាអ្នកជួយគាំទ្រមុខងារបម្រើរបស់អស់លោក។

អស់លោកត្រូវយកចិត្តទុកដាក់ នឹងសន្ទនាជាមួយព្រះគ្រីស្តជាអម្ចាស់ជារៀងរាល់ថ្ងៃ នៅពេលទៅគាល់ព្រះអង្គនិងនមស្សការថ្វាយបង្គំចំពោះអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធដោយខ្លួនផ្ទាល់ ដើម្បីឲ្យអស់លោកអាចបំពេញមុខងារបម្រើរបស់ខ្លួនដោយចិត្តស្មោះភក្តី។ អស់លោកក៏ត្រូវចូលចិត្តសំណាក់ធម៌តាមព្រះវិញ្ញាណ និងចាត់ទុកការណែនាំជីវិតខាងព្រះវិញ្ញាណថា មានតម្លៃខ្ពង់ខ្ពស់។ មានមធ្យោបាយផ្សេងៗដែលជួយអស់លោកគង្វាល ឲ្យស្វែងរកព្រះជាម្ចាស់ និងអង្វរព្រះអង្គ សូមព្រះអង្គប្រទានព្រះវិញ្ញាណណែនាំឲ្យអស់លោក ចេះថ្វាយបង្គំនមស្សការព្រះអង្គយ៉ាងពិតប្រាកដ គឺវិធីនឹក

សញ្ជឹងគិតស្ញឹងស្មាធិ៍ដែលព្រះសហគមន៍យល់ស្របអនុញ្ញាតឲ្យ និងរបៀបអធិដ្ឋានផ្សេងទៀតដែលអស់លោកជ្រើសរើសដោយសេរី។ ដោយព្រះវិញ្ញាណនេះ អស់លោករួមជាមួយប្រជាជនដែលព្រះជាម្ចាស់ផ្ញើទុកឲ្យ អាចភ្ជាប់ចិត្តរួមជាមួយព្រះគ្រីស្ត ដែលជាស្ពាននៃសម្ពន្ធមេត្រីថ្មី។ ពេលនោះ អស់លោកក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ អាចបន្លឺសំឡេងឡើងថា *"អប្បា! ឱព្រះបិតា!"* (រម ៨, ១៥)។

## ១៩-ការសិក្សា និងយល់ដឹងអំពីមុខងារជាគង្វាល

ពេលលោកគង្វាល ទទួលអគ្គសញ្ញាតែងតាំង លោកអភិបាលអញ្ជើញអស់លោកឲ្យ *"មានចិត្តជាអ្នកចាស់ទុំ ដោយសារចំណេះដឹងរបស់ខ្លួន"* និងឲ្យលទ្ធិដែលអស់លោកបង្រៀនទៅជា *"ថ្នាំសង្កូវព្យាបាលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ តាមផ្លូវវិញ្ញាណ"* ទៀតផង។ ចំណេះដឹងរបស់អ្នកបំពេញមុខងារបម្រើដ៏សក្ការៈនេះ ពិតជាសក្ការៈមែន ព្រោះចំណេះដឹងនេះហូរមកពីប្រភពដ៏សក្ការៈ ហើយក៏តម្រង់ឆ្ពោះទៅកាន់គោលដៅដ៏សក្ការៈដែរ។ អស់លោកគង្វាល យោងចំណេះដឹងនេះជាពិសេសដោយអាន និងសញ្ជឹងគិតស្ញឹងស្មាធិ៍អំពីព្រះគម្ពីរ (ព្រះបន្ទូល ២៥)។ អស់លោកក៏ពង្រឹងចំណេះដឹងនេះ តាមរបៀបបង្កើតផល ដោយសិក្សាស្នាដៃរបស់គ្រូបាធ្យាយ បណ្ឌិត និងសាក្សីឯទៀតៗនៃការបញ្ជូនបន្តរបស់ព្រះសហគមន៍។ លើសពីនេះទៅទៀត អស់លោកគង្វាល ត្រូវតែស្គាល់យ៉ាងច្បាស់នូវឯកសារនានានៃការណែនាំព្រះសហគមន៍ ជាពិសេសឯកសាររបស់មហាសន្និបាតនានា និងរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម ដើម្បីឲ្យអស់លោកអាចឆ្លើយតបយ៉ាងត្រឹមត្រូវនឹងសំណួរដែលមនុស្សសព្វថ្ងៃកំពុងចោទសួរ។ អស់លោកក៏ត្រូវតែសួរយោបល់អ្នកនិពន្ធសៀវភៅខាងទេវវិទ្យាដ៏ប្រសើរជាងគេ ហើយដែលព្រះសហគមន៍ទទួលស្គាល់ផងដែរ។

នៅសម័យយើងនេះ វប្បធម៌របស់មនុស្សលោកតែងតែចម្រើនឡើងយ៉ាងលឿនជាលំដាប់ សូម្បីតែវិទ្យានានាខាងគ្រីស្តសាសនាក៏ចម្រើនឡើងយ៉ាងលឿន ហើយក៏ប្រែតាមបែបថ្មីៗដែរ។ ហេតុនេះហើយ បានជាអស់លោកគង្វាលត្រូវតែខិតខំពង្រីក និងពង្រឹងចំណេះដឹងរបស់ខ្លួនឲ្យចម្រើនឡើងដោយឥតឈប់ឈរ ទាំងផ្នែកខាងសាសនា ទាំងផ្នែកខាងមនុស្សលោក ឲ្យកាន់តែស្របតាមសភាពការណ៍ឡើង។ ធ្វើបែបនេះ អស់លោករៀបចំខ្លួនដើម្បីឲ្យអស់លោក អាចជជែកវែកញែកជាមួយមនុស្ស ដែលរស់នៅជាមួយគ្នាសព្វថ្ងៃឲ្យកាន់តែល្អឡើងៗ។

អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ ប្រគល់អ្វីៗទាំងអស់ដែលអស់លោកគង្វាលត្រូវការ ដើម្បីសម្រួលការសិក្សារបស់ខ្លួន និងដើម្បីឲ្យអស់លោកស្គាល់វិធីប្រកាសដំណឹងល្អ និងវិធីជាគ្រីស្តទូតឲ្យកាន់តែមានប្រសិទ្ធភាពឡើង។ ត្រូវចាត់ចែងសិក្ខាសាលានិងប្រជុំ ត្រូវបង្កើតមណ្ឌលសិក្សាអំពីវិទ្យាជាគង្វាល ត្រូវបង្កើតបណ្ណាល័យ និងត្រូវធ្វើការចាត់ចែងការសិក្សានោះឲ្យអ្នកមានសមត្ថភាពណែនាំ តាមសភាពការណ៍តំបន់នីមួយៗ។ អស់លោកអភិបាលម្នាក់ៗក្នុងភូមិភាគរបស់ខ្លួន ឬរួមជាមួយអភិបាលឯទៀតៗ ត្រូវគិតគូររកមធ្យោបាយដ៏ល្អជាងគេ ចាត់ចែងឲ្យលោកគង្វាលទាំងអស់មានលទ្ធភាពអាចចូលរួមក្នុងកម្មវិធីសិក្សាម្តងៗ តាមពេលកំណត់ ជាពិសេសអស់លោកគង្វាល ដែលបានទទួលអគ្គសញ្ញាតែងតាំង មិនសូវយូរឆ្នាំប៉ុន្មាន។ ដូច្នេះ អស់លោកមានឱកាស ពង្រីកនិងពង្រឹងចំណេះដឹងរបស់ខ្លួនអំពីវិធីនានាខាងមុខងារជាគង្វាល និងអំពីទេវវិជ្ជា។ អស់លោកក៏អាចពង្រឹងជីវិតខាងព្រះវិញ្ញាណរបស់ខ្លួន ព្រមទាំងចែករំលែកបទពិសោធន៍អំពីកិច្ចការជាគ្រីស្តទូតជាមួយគង្វាលឯទៀតៗ ជាបងប្អូនទៅវិញទៅមកទៀតផង (អភិបាល ១៦)។ ត្រូវប្រើមធ្យោបាយទាំងនេះ ឬមធ្យោបាយផ្សេងៗទៀត ដែលសមស្របជាងមកជួយ ជាពិសេសអស់លោកដែលទើបនឹងបានទទួលតួនាទីទទួលខុសត្រូវថ្មីលើព្រះសហគមន៍មួយ ឬគង្វាលណា ដែលផ្លាស់ប្តូរតួនាទីជាគង្វាលតាមរបៀបថ្មី ឬលោកណា ដែលផ្លាស់ភូមិភាគ ឬប្រទេសទៀតផង។

មិនតែប៉ុណ្ណោះ លោកអភិបាលត្រូវយកចិត្តទុកដាក់ឲ្យគង្វាលខ្លះ ថ្វាយកម្លាំងកាយ កម្លាំងចិត្ត រៀនវិជ្ជានានាខាងសាសនាឲ្យបានកាន់តែជ្រៅ កុំឲ្យព្រះសហគមន៍ខ្វះខាតសាស្ត្រាចារ្យ ដែលមានសមត្ថភាពអាចអប់រំអស់លោកគង្វាលតទៅទៀត ព្រមទាំងបូជាចារ្យឯទៀតៗ និងគ្រីស្តបរិស័ទឯទៀតៗផង ឲ្យបានចំណេះដឹងដែលគេត្រូវការជាចាំបាច់។ ធ្វើដូច្នេះ អស់លោកក៏ជួយឲ្យវិទ្យាខាងសាសនាចម្រើនឡើងយ៉ាងត្រឹមត្រូវ ជាកិច្ចដែលព្រះសហគមន៍ត្រូវការជាចាំបាច់ មិនអាចអាក់ខានបានឡើយ។

## ២០-ត្រូវធានាជីវភាពរបស់អស់លោកគង្វាល ឲ្យបានសមរម្យ

អស់លោកគង្វាលថ្វាយកម្លាំងកាយកម្លាំងចិត្តបម្រើព្រះជាម្ចាស់ ដោយបំពេញការងារដែលព្រះសហគមន៍ផ្ញើឲ្យអស់លោក។ ហេតុនេះហើយ បានជាអស់លោកត្រូវតែទទួលលាភសក្ការៈដ៏សមរម្យ ដ្បិត *"អ្នកធ្វើការតែងតែទទួលប្រាក់ឈ្នួល"* (លក ១០, ៧; មថ ១០, ១០; ១ករ ៩, ៧; ១ធម ៥, ១៨) ហើយ *"ព្រះអម្ចាស់បានបង្គាប់មកថា អស់អ្នកដែលប្រកាសដំណឹងល្អ ត្រូវតែចិញ្ចឹមជីវិតដោយសារដំណឹងល្អនោះ"* (១ករ ៩, ១៤)។ នៅកន្លែងណាដែលលោកគង្វាល ពុំទទួលលាភសក្ការៈគ្រប់គ្រាន់សម្រាប់ធានាជីវភាពឲ្យបានសមរម្យ គ្រីស្តបរិស័ទពិតជាមានកាតព្វកិច្ចផ្តល់ជំនួយដ៏ចាំបាច់នោះ ព្រោះគង្វាលបំពេញកិច្ចការជាប្រយោជន៍ដល់ពួកគេ។ លោកអភិបាលក៏មានភារកិច្ចរំឭកដាស់តឿនគ្រីស្តបរិស័ទអំពីកាតព្វកិច្ចនេះ។ អភិបាលម្នាក់ៗក្នុងភូមិភាគរៀងៗខ្លួន ឬដើម្បីឲ្យបានប្រសើរជាង ត្រូវរួមជាមួយអភិបាលឯទៀតក្នុងតំបន់មួយ បង្កើតសេចក្តីណែនាំសម្រាប់ធានាឲ្យអស់អ្នកដែលកំពុងបំពេញតួនាទី ឬដែលធ្លាប់មានតួនាទីបម្រើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ មានជីវភាពដ៏សមរម្យ។ ត្រូវគិតគូរអំពីលាភសក្ការៈរបស់លោកគង្វាលម្នាក់ៗ តាមលក្ខណៈនៃមុខតំណែងរបស់លោក តាមសភាពការណ៍នៃសម័យ និងនៃទីកន្លែង។ ប៉ុន្តែអស់លោកដែលរស់នៅតាមសភាពការណ៍ដដែលដូចគ្នា ត្រូវទទួលលាភសក្ការៈនេះប្រហាក់ប្រហែលគ្នា។ លាភសក្ការៈនេះគួរតែសមស្របតាមសភាពការណ៍របស់អស់លោក។ លើសពីនេះទៅទៀត លាភសក្ការៈត្រូវបណ្តោយឲ្យអស់លោកគង្វាលមានលទ្ធភាពអាចបើកប្រាក់ឈ្នួលដ៏សមរម្យដល់អស់អ្នក ដែលថ្វាយកម្លាំងបម្រើអស់លោក ថែមទាំងឲ្យអស់លោកអាចផ្តល់ជំនួយផ្ទាល់ខ្លួន ដល់អ្នកដែលខ្វះខាត ដ្បិតតាំងពីដើមរៀងមកព្រះសហគមន៍ រមែងតែងសរសើរតម្កើងកិច្ចបម្រើអ្នកក្រីក្របែបនេះ។ លាភសក្ការៈនោះ គឺត្រូវផ្តល់ឲ្យអស់លោកគង្វាលមានជាវិស្សមកាលដែលអស់លោកត្រូវការជារៀងរាល់ឆ្នាំ ដែលមានអស់រយៈពេលសមរម្យ។ លោកអភិបាលត្រូវយកចិត្តទុកដាក់ ឲ្យអស់លោកគង្វាល មានវិស្សមកាលនេះផង។

ប៉ុន្តែ ត្រូវចាត់មុខងាររបស់លោកជាអ្នកបម្រើដ៏សក្ការៈ ទុកជាមានសារៈសំខាន់ជាងគេបង្អស់។ ហេតុនេះហើយ បានជាត្រូវលះបង់របៀបរកកម្រៃ ពីមុខងាររបស់ខ្លួនក្នុងព្រះសហគមន៍ (ហៅថា *"ប្រព័ន្ធនៃប្រតិលាភ"*) ចោល ឬយ៉ាងហោចណាស់ ត្រូវកែទម្រង់របបនោះ ដើម្បីឲ្យគេចាត់ទុកសិទ្ធិទទួលកម្រៃភ្ជាប់នឹងមុខតំណែងមួយនោះ ជាអ្វីមួយដ៏មិនសំខាន់សោះ។ ក្នុងក្បួនច្បាប់នៃព្រះសហគមន៍ ត្រូវផ្តល់អាទិភាពដល់មុខតំណែងក្នុងព្រះសហគមន៍នោះវិញ។ តាំងពីពេលនេះតទៅត្រូវយល់ថា ពាក្យ *"មុខតំណែងក្នុងព្រះសហគមន៍"* គឺសំដៅតែលើបន្ទុកទាំងប៉ុន្មាន ដែលព្រះសហគមន៍ប្រគល់យ៉ាងស្ថិតស្ថេរ ឲ្យគង្វាលបំពេញក្នុងគោលដៅខាងវិញ្ញាណប៉ុណ្ណោះ។

## ២១-ត្រូវបង្កើតមូលនិធិរួម និងសុវត្ថិភាពក្នុងសង្គម

ត្រូវនឹកគិតដល់គ្រីស្តបរិស័ទនៃព្រះសហគមន៍ដើមដំបូង នៅក្រុងយេរូសាឡឹមទុកជាគំរូជានិច្ច។ "អ្នកជឿទាំងអម្បាលម៉ានយកទ្រព្យសម្បត្តិរបស់ខ្លួនមកដាក់ជាសម្បត្តិរួមទាំងអស់" (កក ៤, ៣២) និង *"គេចែកឲ្យម្នាក់ៗ តាម*

*សេចក្តីត្រូវការរៀងៗខ្លួន"* (កក ៤, ៣៥)។ ហេតុនេះហើយ បានជាយ៉ាងហោចណាស់នៅប្រទេសណាដែលជីវភាពរបស់ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង អាស្រ័យទាំងស្រុង ឬអាស្រ័យភាគច្រើនទៅលើប្រាក់តង្វាយរបស់គ្រីស្តបរិស័ទ គប្បីឲ្យមានស្ថាប័នមួយក្នុងភូមិភាគនីមួយៗ ប្រមែប្រមូលប្រាក់តង្វាយសម្រាប់ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំងនោះ។ លោកអភិបាលត្រូវគ្រប់គ្រងស្ថាប័ននេះ ដោយមានលោកបូជាចារ្យខ្លះជាតំណាងជួយលោកផង។ នៅកន្លែងណា ដែលអភិបាលយល់ឃើញថាមានប្រយោជន៍មែននោះ ត្រូវឲ្យគ្រីស្តបរិស័ទធម្មតា ជំនាញការផ្នែកហិរញ្ញវត្ថុជួយផងដែរ។ ប្រសិនបើអាចធ្វើបាន ភូមិភាគនីមួយៗ ឬភូមិភាគទាំងប៉ុន្មានក្នុងប្រទេសទាំងមូល គួរគប្បីបង្កើតមូលនិធិរួមមួយ ដែលបណ្តោយឲ្យអភិបាលនានាអាចបំពេញករណីកិច្ចផ្សេងៗ ចំពោះអស់អ្នកដែលធ្វើការបម្រើព្រះសហគមន៍ ព្រមទាំងអាចបំពេញតម្រូវការនានាក្នុងភូមិភាគ។ មូលនិធិនេះ បណ្តោយឲ្យភូមិភាគណាដែលមានធនធានច្រើនជាង អាចជួយផ្គត់ផ្គង់ភូមិភាគណាដែលក្រជាងដែរ ដើម្បីឲ្យអ្វីៗដែលអ្នកខ្លះមានលើសពីសេចក្តីត្រូវការ យកទៅផ្គត់ផ្គង់អស់អ្នកដែលខ្វះខាត (២ករ ៨, ១៤)។ មូលនិធិនេះ មានប្រាក់ភាគច្រើនមកពីតង្វាយរបស់គ្រីស្តបរិស័ទ និងពីប្រភពឯទៀតៗ ដែលក្បួនច្បាប់វិន័យនៃព្រះសហគមន៍ត្រូវបញ្ជាក់តាមក្រោយផងដែរ។

លើសពីនេះទៅទៀត នៅប្រទេសណាដែលពុំទាន់មានការចាត់ចែងសុវត្ថិភាពក្នុងសង្គមយ៉ាងសមរម្យ សម្រាប់ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង ក្រុមអភិបាលត្រូវយកចិត្តទុកដាក់ឲ្យមានអង្គការផ្សេងៗក្នុងភូមិភាគនីមួយៗ (ដែលអាចរួមជាសហព័ន្ធមួយបាន) ឬឲ្យមានអង្គការអន្តរភូមិភាគមួយចំនួន ឬសមាគមសម្រាប់តំបន់មួយទាំងមូល។ តែត្រូវអនុលោមតាមច្បាប់រដ្ឋ និងតាមក្បួនច្បាប់ព្រះសហគមន៍ជានិច្ចផង។ ក្រោមការត្រួតត្រារបស់ក្រុមអភិបាល អង្គការទាំងនេះមានតួនាទីធានារ៉ាប់រងសុខភាពក្រុមលោកគង្វាលយ៉ាងគួរសមគ្រប់គ្រាន់ ធានារ៉ាប់រងផ្គត់ផ្គង់អស់លោកគង្វាលពិការ ឬដែលមិនអាចធ្វើការបាន ឬចាស់ជរាដែរ។ បូជាចារ្យត្រូវជួយគាំទ្រអង្គការ ដែលកើតមករួចហើយទាំងនោះ ដោយមានចិត្តគំនិតរួមសាមគ្គីជាមួយបូជាចារ្យឯទៀតៗជាបងប្អូន ដោយរួមទុក្ខជាមួយគេផង (ភល ៤, ១៤)។ ទន្ទឹមនឹងនេះ អស់លោកមុខជានឹងត្រូវយល់ឃើញថា ខ្លួនបានរួចពីការខ្វល់ខ្វាយដល់អនាគត ជាហេតុនាំឲ្យអស់លោកអាចរស់នៅក្នុងឋានៈជាជនក្រីក្រយ៉ាងខ្លាំងជាងពីមុន តាមរបៀបដំណឹងល្អ ព្រមទាំងអាចបូជាកម្លាំងកាយកម្លាំងចិត្តចំពោះកិច្ចសង្គ្រោះរបស់មនុស្សលោក។ អ្នកដែលត្រូវទទួលខុសត្រូវ ក៏ត្រូវតែខិតខំធ្វើឲ្យអង្គការជាតិនានា មានចំណងទាក់ទងជាមួយគ្នា។ ដូច្នេះ អង្គការជាតិនានាទាំងនោះ នៅកាន់តែស្អិតស្អែរមាំមួនឡើង និងរីកសុះសាយឲ្យគេស្គាល់ទៀតផង។

# ពាក្យបញ្ចប់ និងពាក្យដាស់តឿន

២២-មហាសន្និបាតដ៏វិសុទ្ធនេះ តែងតែនឹកគិតអំពីអំណរសប្បាយរបស់លោកបូជាចារ្យ ក្នុងការរស់នៅរបស់ខ្លួន ក៏ប៉ុន្តែ មហាសន្និបាតពុំអាចធ្វើព្រងើយកន្តើយថា អស់លោកគង្វាល ក៏តែងតែជួបប្រទះការលំបាកនានា តាមសភាពការណ៍នៃការរស់នៅនាសម័យនេះផងដែរ។ មហាសន្និបាតក៏ជ្រាបថា សភាពការណ៍សេដ្ឋកិច្ច និងសង្គមប្រែប្រួល សូម្បីតែសីលធម៌មនុស្សលោកក៏ប្រែប្រួលដែរ។ មនុស្សលោកផ្លាស់ប្ដូរទស្សនៈ ចំពោះអ្វីដែលគេចាត់ទុកថា មានតម្លៃតាមលំដាប់លំដោយ។ ហេតុនេះហើយ បានជាអ្នកបំពេញមុខងារបម្រើព្រះសហគមន៍ ហើយជួនកាលគ្រីស្តបរិស័ទឯទៀតៗ មានអារម្មណ៍ ហាក់ដូចជាខ្លួនជាជនបរទេសក្នុងលោកនេះ។ គេតប់ប្រមល់ ស្វែងរកវិធីនិងពាក្យសម្ដីសមគួរ ដែលបណ្ដោយឲ្យខ្លួនអាចទាក់ទងជាមួយមនុស្សឯទៀតៗ។ ដោយមានឧបសគ្គថ្មីៗប្រឆាំងនឹងជំនឿ ដោយអស់លោកយល់ឃើញថា កិច្ចរបស់ខ្លួនហាក់ដូចជាគ្មានបានផល ដោយលោកគង្វាលរស់នៅឯកោយ៉ាងសែនជូចត់សុទ្ធតែជាមូលហេតុអាចបណ្ដាលឲ្យអស់លោកធ្លាក់ទឹកចិត្តបាន។

ប៉ុន្តែ ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ គឺមនុស្សលោកសព្វថ្ងៃនេះឯង។ ហេតុនេះហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមកមនុស្សលោក (យហ ៣, ១៦)។ ព្រះអង្គក៏បានផ្ញើមនុស្សលោកនេះឲ្យអស់លោកគង្វាលព្រះសហគមន៍ស្រឡាញ់និងបម្រើ។ តាមពិតមនុស្សលោកនេះជំពាក់ជំពិននឹងបាបជាច្រើនមែន តែក៏មានសមត្ថភាពដ៏ល្អជាច្រើនហូរហៀរដែរ។ មនុស្សលោកនេះ ប្រគល់ថ្មដ៏មានជីវិតជូនព្រះសហគមន៍ (១សល ២, ៥) ហើយថ្មដ៏មានជីវិតទាំងនោះ ក៏ផ្គុំគ្នាឡើងកសាងជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណដែរ (អភ ២, ២២)។ ព្រះវិញ្ញាណដ៏វិសុទ្ធក៏ជំរុញព្រះសហគមន៍ឲ្យបើកផ្លូវថ្មី ដើម្បីទៅជួបមនុស្សលោកសព្វថ្ងៃនេះដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានគំនិតឲ្យផ្លាស់ប្ដូររបៀបបំពេញមុខងារបម្រើជាបូជាចារ្យ ហើយក៏និងគាំទ្រគំនិតទាំងនោះផង។

សូមអស់លោកគង្វាលនឹកចងចាំថា ពេលអស់លោកបំពេញកិច្ចការរបស់ខ្លួននោះ អស់លោកពុំដែលនៅម្នាក់ឯងទេ តែព្រះដ៏មានឫទ្ធានុភាពសព្វប្រការគាំទ្រអស់លោកដែរ។ អស់លោកផ្ញើជីវិតលើព្រះគ្រីស្តដែលត្រាស់ហៅអស់លោកឲ្យទទួលចំណែកក្នុងមុខងាររបស់ព្រះអងជាមហាបូជាចារ្យ សូមព្រះអង្គជួយអស់លោកឲ្យថ្វាយកម្លាំងកាយកម្លាំងចិត្តបំពេញមុខងាររបស់ខ្លួន ដោយទុកចិត្តលើព្រះអង្គទាំងស្រុង ដ្បិតអស់លោកដឹងថា ព្រះជាម្ចាស់មានឫទ្ធានុភាពអាចប្រោសឲ្យសេចក្ដីស្រឡាញ់ចម្រើនឡើងក្នុងចិត្តអស់លោកបាន។ ម៉្យាងវិញទៀត សូមអស់លោកកុំភ្លេចថា អស់លោកមានបងប្អូនឯទៀតៗរួមក្នុងមុខងារជាបូជាចារ្យដែរ ហើយមានគ្រីស្តបរិស័ទក្នុងសកលលោកទាំងមូលជាមិត្តសម្លាញ់របស់ខ្លួនផង។ អស់លោកគង្វាលរួមសហការគ្នាបំពេញបំណងប្រាថ្នារបស់ព្រះជាម្ចាស់ ដែលសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក គឺគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តលាក់ទុកតាំងពីអស់កល្បជានិច្ចរាំងមកក្នុងព្រះជាម្ចាស់ផ្ទាល់ (អភ ៣, ៩)។ គម្រោងការដ៏អស្ចារ្យនេះកើតជារូបរៀងបន្តិចម្ដងៗ ដោយអស់អ្នកដែលទទួលមុខងារបម្រើផ្សេងៗខិតខំ រួមសហការគ្នាកសាងព្រះកាយ របស់ព្រះគ្រីស្តរហូតដល់កម្ពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីទាំងអស់។ តាមពិតគម្រោងការនេះ *"កប់ទុកជាមួយព្រះគ្រីស្តក្នុងព្រះជាម្ចាស់"* មែន (កូឡ ៣, ៣)។ យើងអាចស្គាល់សេចក្ដីទាំងនោះបាន ដោយសារ

តែជំនឿប៉ុណ្ណោះ។ ហេតុនេះហើយបានជាអ្នកដឹកនាំប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ត្រូវតែធ្វើដំណើរដោយមានជំនឿ ទាំងយកលោកអប្រាហាំជាមនុស្សស្មោះត្រង់ធ្វើជាគំរូ គឺ *"ដោយសារជំនឿ លោកអប្រាហាំស្ដាប់បង្គាប់ព្រះជាម្ចាស់ ដែលត្រាស់ហៅលោក ហើយចេញដំណើរទៅកាន់ស្រុកមួយដែលលោកនឹងទទួលទុកជាមរតក។ លោកចេញដំណើរទៅ ទាំងពុំដឹងថា លោកទៅទីណាផង"* (ហប ១១, ៨)។ តាមពិតអ្នកទទួលខុសត្រូវលើគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ប្រៀបដូចជាមនុស្សម្នាក់ ដែលព្រោះគ្រាប់ពូជលើដី ហើយដែលព្រះអម្ចាស់មានព្រះបន្ទូលថា *"ទោះបីគាត់ដេកក្ដី ក្រោកក្ដី យប់ក្ដី ថ្ងៃក្ដី គ្រាប់ពូជនៅតែមានពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ"* (មក ៤, ២៧)។ ម៉្យាងទៀត ព្រះយេស៊ូមានព្រះបន្ទូលថា *"ចូរមានសង្ឃឹមឡើង! ខ្ញុំឈ្នះលោកនេះហើយ!"* (យហ ១៦, ៣៣)។ ប៉ុន្ដែ ពេលព្រះអង្គមានព្រះបន្ទូលនេះ ទ្រង់ពុំបានសន្យាថា ព្រះសហគមន៍របស់ព្រះអង្គនឹងបានជ័យជម្នះទាំងស្រុងក្នុងលោកនេះទេ។ មហាសន្និបាតដ៏វិសុទ្ធនេះ មានអំណរសប្បាយដោយឃើញថា ផែនដីដែលបានទទួលគ្រាប់ពូជនៃដំណឹងល្អ ឥឡូវកំពុងតែបង្កើតផលនៅកន្លែងជាច្រើន ក្រោមការណែនាំរបស់ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ដែលគង់សណ្ឋិតនៅពាសពេញក្នុងពិភពលោកទាំងមូល។ ព្រះវិញ្ញាណនេះក៏បានដាស់តឿនឲ្យបូជាចារ្យ និងគ្រីស្ដបរិស័ទជាច្រើន មានចិត្តគំនិតជាអ្នកចេញទៅប្រកាសដំណឹងល្អយ៉ាងពិតប្រាកដ។ ហេតុនេះហើយ បានជាមហាសន្និបាត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកគង្វាលទាំងអស់ក្នុងពិភពលោកទាំងមូល។ *"ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ ហួសពីសេចក្ដីសុំ និងហួសពីអ្វីៗដែលយើងនឹកគិតដល់ ដោយសារឫទ្ធានុភាពរបស់ព្រះអង្គ ដែលបំពេញសកម្មភាពនៅក្នុងយើង សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គក្នុងព្រះសហគមន៍ និងក្នុងព្រះគ្រីស្ដយេស៊ូ"* (អភ ៣, ២០-២១)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ ព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្ដបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្ដទូត រួមជាមួយអស់លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្ដីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្ដៈសិលា ថ្ងៃទី៧ ធ្នូ ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ការប្រែប្រួលនៃព្រះសហគមន៍តាមសេចក្តីប៉ងប្រាថ្នា

(អំពីការហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យ)

**OPTATAM TOTIUS ECCLESIAE RENOVATIONEM**

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេចងចាំរហូតតរៀងទៅ។

## ក្រឹត្យក្រម
## អំពីការហ្វឹកហ្វឺនឲ្យទៅជាគង្វាល

### បុព្វកថា

មហាសន្និបាតដ៏វិសុទ្ធដឹងជាក់ច្បាស់ថា ព្រះសហគមន៍ទាំងមូលនឹងប្រែជាថ្មីបាន តាមសំណូមពររបស់គ្រីស្តបរិស័ទទាំងអស់ អាស្រ័យយ៉ាងពិសេសទៅលើរបៀបអស់លោកគង្វាល បំពេញមុខងារបម្រើរបស់ខ្លួន ក្រោមការណែនាំនៃព្រះវិញ្ញាណរបស់ព្រះគ្រីស្ត។ ហេតុនេះហើយ បានជាមហាសន្និបាតសូមប្រកាសបញ្ជាក់ថា ការហ្វឹកហ្វឺនឲ្យទៅជាគង្វាល មានសារៈសំខាន់យ៉ាងខ្លាំងបំផុត។ មហាសន្និបាតក៏សូមប្រកាសគោលការណ៍ខ្លះៗជាគ្រឹះ សម្រាប់ណែនាំការហ្វឹកហ្វឺននេះ។ គោលការណ៍ទាំងនោះនឹងបញ្ជាក់វិន័យ ដែលព្រះសហគមន៍យល់ស្របតាមបទពិសោធន៍ជាច្រើនសតវត្សមកហើយ។ យើងនឹងបញ្ចូលសេចក្តីថ្មីខ្លះៗ ស្របតាមធម្មនុញ្ញនិងក្រឹត្យក្រមនានា ដែលមហាសន្និបាតអនុម័តរួចហើយ ដើម្បីតបឆ្លើយនឹងការប្រែប្រួលនាបច្ចុប្បន្នកាលផង។ ការហ្វឹកហ្វឺនឲ្យទៅជាគង្វាលនេះ មានការចាំបាច់សម្រាប់ក្រុមគង្វាលភូមិភាគផង និងសម្រាប់ក្រុមគង្វាលជាបព្វជិតផង ព្រមទាំងសម្រាប់គ្រប់ព្រះសហគមន៍ ដែលកាន់តាមគ្រប់របៀបរបបពិធីគោរពប្រណិប័តន៍ ព្រោះថាមុខងារជាបូជាចារ្យកាតូលិកមានតែមួយគត់។ ហេតុនេះហើយ បានជាបទបញ្ញត្តិខាងក្រោមនេះសំដៅចំទៅលើក្រុមគង្វាលភូមិភាគ ហើយក្រុមឯទៀតៗក៏ត្រូវអនុវត្តតាមដែរ ទោះបីត្រូវសម្រួលបទបញ្ញត្តិខ្លះៗតាមសេចក្តីត្រូវការ។

### ១-អំពីរបៀបអប់រំក្រុមបូជាចារ្យដែលត្រូវតែងតាំងក្នុងគ្រប់ប្រទេស

១-ដោយមានប្រជាជន និងតំបន់ប្លែកពីគ្នាជាច្រើនអនេក មហាសន្និបាតគ្រាន់តែចាត់ចែងវិន័យជាទូទៅប៉ុណ្ណោះ។ ហេតុនេះ ក្នុងប្រជាជាតិនីមួយៗ ឬក្នុងព្រះសហគមន៍ដែលកាន់តាមរបៀបរបបពិធីគោរពនានា ត្រូវចាត់ចែង" *របៀប*

*ហ្វឹកហ្វឺនឲ្យទៅជាបូជាចារ្យ*" ដោយឡែកពីគ្នា។ ក្រុមអភិបាលព្រះសហគមន៍ក្នុងប្រទេសនីមួយៗ ត្រូវចាត់ចែងរបបនោះដែលត្រូវកែសម្រួលតាមពេលកំណត់ ដោយសន្តអាសនៈនៃគ្រីស្តទូតសិលាយល់ស្របផងដែរ។ ដូច្នេះក្បួនច្បាប់វិន័យសកលទូទៅ នឹងសម្របតាមសភាពការណ៍ដោយឡែក តាមទីកន្លែងនិងតាមកាលៈទេសៈ ដើម្បីឲ្យការហ្វឹកហ្វឺនឲ្យទៅជាបូជាចារ្យ តបឆ្លើយនឹងសេចក្តីត្រូវការនៃការណែនាំព្រះសហគមន៍តាមតំបន់ ជាកន្លែងអស់លោកបូជាចារ្យនឹងបំពេញមុខងារបម្រើរបស់ខ្លួន។

## ២-អំពីការថែរក្សាអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ

២-ព្រះសហគមន៍គ្រីស្តបរិស័ទទាំងមូល មានភារកិច្ចលើកស្ទួយថែទាំ អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាគង្វាល។ ព្រះសហគមន៍បំពេញភារកិច្ចនេះ ជាពិសេសដោយរស់នៅតាមបែបជាគ្រីស្តបរិស័ទយ៉ាងពេញលេញ។ ក្រុមគ្រួសារ និងព្រះសហគមន៍តាមភូមិ ត្រូវរួមសហការគ្នាក្នុងកិច្ចការនេះ គឺក្រុមគ្រួសារត្រូវមានជំនឿ សេចក្តីស្រឡាញ់ និងការគោរពប្រណិប័តន៍តាមព្រះជាម្ចាស់ណែនាំ ហាក់ដូចជាទេវវិទ្យាល័យដើមដំបូងម៉្យាង។ រីឯព្រះសហគមន៍តាមភូមិវិញត្រូវជួយឲ្យកូនជំទង់ទទួលចំណែកនៃជីវិតដែលបង្កើតផលរបស់ខ្លួននោះ។ គ្រូៗ និងអស់អ្នកដែលទទួលខុសត្រូវក្នុងការអប់រំក្មេងៗ និងយុវជន ទោះជាតាមបែបណាក៏ដោយ ជាពិសេសព្រះសហមគមន៍កាតូលិកត្រូវយកចិត្តទុកដាក់ និងអប់រំកូនជំទង់ដែលមាតាបិតាផ្ញើទុក តាមរបៀបណែនាំឲ្យកូនទាំងនោះអាចយល់ឃើញថា ព្រះជាម្ចាស់ត្រាស់ហៅគេ និងឲ្យគេអាចតបឆ្លើយនឹងព្រះអង្គដោយចិត្តទូលាយ។ អស់គង្វាលត្រូវខ្នះខ្នែងយ៉ាងខ្លាំងជាទីបំផុតក្នុងឋានៈជាគ្រីស្តទូត ដើម្បីលើកស្ទួយថែទាំអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅនោះ។ អស់លោកត្រូវទាក់ទាញចិត្តយុវជនឲ្យទៅជាបូជាចារ្យ ដោយគំរូរបស់ខ្លួនរស់នៅបែបសុភាពរាបសា និងដោយឧហ្សាហ៍ធ្វើការទាំងមានចិត្តសប្បាយរីករាយ ហើយដោយមានទំនាក់ទំនងទៅវិញទៅមក ប្រកបដោយសេចក្តីស្រឡាញ់ក្នុងឋានៈជាបូជាចារ្យ និងដោយសហការគ្នាទុកជាបងប្អូន។

អស់លោកអភិបាលមានភារកិច្ចដាស់តឿនក្រុមគ្រីស្តបរិស័ទ លើកស្ទួយឲ្យមានអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅ។ អស់លោកត្រូវយកចិត្តទុកដាក់ចំពោះធនធានទាំងអស់ និងការខិតខំទាំងប៉ុន្មានក្នុងភូមិភាគឲ្យរួមសហការគ្នា។ ក្នុងឋានៈអស់លោកជាឪពុកដ៏ពិតប្រាកដ អស់លោកនឹងជួយដោយអស់ពីសមត្ថភាពដល់អស់អ្នក ដែលអស់លោកយល់ឃើញថាព្រះអម្ចាស់ត្រាស់ហៅ ឲ្យទៅជាចំណែកផ្ទាល់របស់ព្រះអង្គ។

ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល ដែលព្រមព្រៀងគ្នាបែបនេះ ក្នុងគោលបំណងលើកស្ទួយថែទាំអ្នក ដែលព្រះជាម្ចាស់ត្រាស់ហៅនោះ ពិតជាតបឆ្លើយនឹងព្រះអង្គដែលថែរក្សាណែនាំមនុស្សលោក ដោយព្រះហឫទ័យស្រឡាញ់ គឺព្រះជាម្ចាស់នេះហើយ ដែលជ្រើសរើសមនុស្សខ្លះឲ្យទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្ត ជាមហាបូជាចារ្យ តាមលំដាប់លំដោយ។ ព្រះអង្គក៏ប្រទានព្រះអំណោយទានដែលគេត្រូវការ និងប្រណីសន្ដោសគេទៀតផង។ ព្រះអង្គ ដែលថែរក្សាមនុស្សលោក ដោយព្រះហឫទ័យស្រឡាញ់ ក៏ធ្វើទុកឲ្យអស់លោកអភិបាលដែលត្រូវបានគេតែងតាំងយ៉ាងត្រឹមត្រូវតាមច្បាប់ មានបេសកកម្មត្រាស់ហៅបេក្ខជនទាំងប៉ុន្មាន និងតែងតាំងជាគង្វាល ឲ្យទទួលមុខងារគោរពបម្រើព្រះជាម្ចាស់ផង និងបម្រើព្រះសហគមន៍ផង ទាំងដៅចំណាំគេដោយព្រះវិញ្ញាណ។ អស់លោកអភិបាលត្រូវទទួលស្គាល់ថាបេក្ខជនទាំងនោះមានសមត្ថភាព ហើយអស់លោកត្រូវល្បងលមើលគេជាមុនសិន។ បេក្ខជនទាំងនោះ ក៏ត្រូវទទួលបន្ទុកដ៏ធំធេងជាគង្វាលនោះ ដោយចិត្តទៀងត្រង់ និងដោយមានសេរីភាពពេញលេញដែរ។

ជាបឋម មហាសន្និបាតផ្ដែផ្ដាំឲ្យប្រើគ្រប់មធ្យោបាយតាមប្រពៃណី សម្រាប់សហការគ្រប់បែបយ៉ាង គឺទទូចអង្វរព្រះជាម្ចាស់ និងធ្វើតបៈធម៌តាមរបៀបគ្រីស្តសាសនា ហើយអប់រំគ្រីស្តបរិស័ទឲ្យដំណឹងល្អកាន់តែស៊ីជម្រៅជារៀងរាល់

ថ្ងៃ។ ត្រូវអប់រំគ្រីស្តបរិស័ទ ដោយធ្វើពិធីអត្ថាធិប្បាយព្រះគម្ពីរ និងអប់រំជំនឿជាដើម ព្រមទាំងដោយប្រើគ្រប់មធ្យោបាយនៃទូរគមនាគមន៍ក្នុងសង្គមទៀតផង។ ត្រូវបញ្ជាក់អំពីការចាំបាច់ និងអំពីលក្ខណៈ ហើយអំពីតម្លៃដ៏ប្រសើរឧត្តមនៃមុខងារជាបូជាចារ្យ តាមព្រះជាម្ចាស់ត្រាស់ហៅនោះ។ លើសពីនេះទៅទៀត មហាសន្និបាតបញ្ជាឲ្យក្រុមទាំងប៉ុន្មានដែលទទួលការខុសត្រូវលើកស្ទួយថែទាំអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅ គឺក្រុមដែលកើតរួចទៅហើយ និងក្រុមដែលត្រូវបង្កើតនៅពេលក្រោយ តាមភូមិភាគនីមួយៗ តាមតំបន់ក្តី និងតាមប្រទេសនីមួយៗក្តី ឲ្យចាត់ចែងការណែនាំគ្រប់យ៉ាងដើម្បីលើកស្ទួយថែទាំអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅនោះ ដោយមានរបៀបរៀបរយ និងជាប់ទាក់ទងគ្នា។ ត្រូវចាត់ចែងកិច្ចការទាំងនោះ ដោយប្រាជ្ញានិងដោយចិត្តខ្នះខ្នែង។ ត្រូវប្រើមធ្យោបាយដ៏សមរម្យតាមចិត្តសាស្ត្រ និងសង្គមសាស្ត្រដូចយើងស្គាល់នៅសម័យឥឡូវស្រាប់។

កិច្ចការដែលគេធ្វើសម្រាប់លើកស្ទួយថែទាំ អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅនោះ ត្រូវធ្វើដោយចិត្តទូលាយ គឺហួសពីព្រំដែនភូមិភាគនីមួយៗ និងហួសពីព្រំដែនជាតិ ហើយក៏ហួសពីព្រំដែនក្រុមគ្រួសារបព្វជិត ព្រមទាំងហួសពីព្រំដែនព្រះសហគមន៍ដែលកាន់តាមរបៀបរបប ពិធីគោរពប្រណិប័តន៍ដោយឡែកដែរ។ ទោះបីត្រូវគិតគូរដល់តម្រូវការរបស់ព្រះសហគមន៍សកលក្តី ក៏ត្រូវជួយព្រះសហគមន៍យ៉ាងពិសេស នៅតំបន់ដែលទាមទារកម្មករឲ្យធ្វើការក្នុងចម្ការរបស់ព្រះអម្ចាស់យ៉ាងបន្ទាន់ជាងគេ។

៣-អនុទេវវិទ្យាល័យកើតឡើង ដើម្បីលើកស្ទួយថែទាំពន្លកក្នុងចិត្តអ្នក ដែលព្រះជាម្ចាស់ត្រាស់ហៅ។ ក្នុងអនុទេវវិទ្យាល័យទាំងនោះ ត្រូវអប់រំកូនសិស្សឲ្យដើរតាមព្រះគ្រីស្តជាព្រះសង្គ្រោះ ដោយចិត្តទូលាយ និងដោយចិត្តបរិសុទ្ធទៀងត្រង់ គឺត្រូវអប់រំគេអំពីគ្រីស្តសាសនាយ៉ាងពិសេស ហើយត្រូវណែនាំគេឲ្យរស់នៅខាងព្រះវិញ្ញាណយ៉ាងសមរម្យ ដែលជាកិច្ចសំខាន់ជាងគេ។ ត្រូវឲ្យកូនសិស្សរស់នៅឲ្យបានស្របតាមអាយុ ស្របតាមមតិ និងស្របតាមការអភិវឌ្ឍន៍របស់កូនជំទង់ ហើយក៏ស្របយ៉ាងពេញលេញតាមក្បួនតម្រានៃចិត្តសាស្ត្រដ៏ល្អត្រឹមត្រូវ ក្រោមការណែនាំរបស់អស់លោកប្រធានអនុទេវវិទ្យាល័យដែលប្រៀបដូចឪពុករបស់គេ។ អស់លោកក៏ត្រូវសហការជាមួយមាតាបិតាសិស្ស ដែលជាការដ៏ចាំបាច់បំផុតដែរ។ សូមកុំភ្លេចផ្តល់ឱកាសឲ្យសិស្សមានបទពិសោធន៍យ៉ាងគួរសមអំពីការរស់នៅរបស់មនុស្ស និងឲ្យគេមានទំនាក់ទំនងធម្មតាជាមួយក្រុមគ្រួសាររបស់គេ។ លើសពីនេះទៅទៀត ត្រូវសម្រួលសេចក្តីបញ្ញាខាងក្រោយនេះស្តីអំពីទេវវិទ្យាល័យ មកអនុវត្តក្នុងអនុទេវវិទ្យាល័យដែរ តាមតែបញ្ញាទាំងនោះបានស្របតាមគោលដៅនិងតាមរបៀបរស់នៅក្នុងអនុទេវវិទ្យាល័យ។ ត្រូវចាត់ចែងការសិក្សា ដើម្បីឲ្យកូនសិស្ស ដែលចង់ដូររបៀបរស់នៅ លែងចង់ទៅជាបូជាចារ្យ អាចបន្តការសិក្សានៅកន្លែងផ្សេងទៀតបាន ដោយមិនជួបឧបសគ្គអ្វីឡើយ។

ប្រសិនបើមានសភាពការណ៍ពិសេសក្នុងតំបន់ ត្រូវថែទាំពន្លកក្នុងចិត្តកូនជំទង់ និងយុវជនដែលព្រះជាម្ចាស់ត្រាស់ហៅ ក្នុងគ្រឹះស្ថានផ្សេងៗដោយឡែក ដែលមានទិសដៅស្រដៀងនឹងអនុទេវវិទ្យាល័យ ដោយយកចិត្តទុកដាក់តាមបែបដដែលនោះ។ ត្រូវយកចិត្តទុកដាក់ថែទាំពន្លកក្នុងចិត្តរបស់អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅ ហើយដែលសិក្សានៅសាលារៀន ឬនៅកន្លែងអប់រំផ្សេងទៀត។ ត្រូវយកចិត្តទុកដាក់នឹងស្ថាប័នហើយនឹងគេហដ្ឋានសងឡើង សម្រាប់អស់អ្នកអាយុចាស់ជាង ដែលតបឆ្លើយនឹងព្រះជាម្ចាស់ត្រាស់ហៅដែរ។

## ៣-ការចាត់ចែងរបស់ទេវវិទ្យាល័យ

៤-ត្រូវការទេវវិទ្យាល័យសម្រាប់ហ្វឹកហ្វឺនគ្រីស្តបរិស័ទឲ្យទៅជាបូជាចារ្យ។ ការហ្វឹកហ្វឺនទាំងមូលក្នុងទេវវិទ្យាល័យ

មានគោលដៅណែនាំនិស្សិត ឲ្យទៅជាគង្វាលដ៏ពិតប្រាកដរបស់គ្រីស្តបរិស័ទ តាមគំរូរបស់ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង ជាព្រះបរមគ្រូ ជាមហាបូជាចារ្យ និងជាគង្វាល (ពន្លឺ ២៨)។

ហេតុនេះត្រូវរៀបចំនិស្សិតឲ្យ៖

- បំពេញមុខងារបម្រើព្រះបន្ទូល គឺឲ្យយល់ព្រះបន្ទូលកាន់តែច្បាស់ឡើងៗ ជាព្រះបន្ទូលដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ ដោយគេនឹកសញ្ជឹងនិងស្ទឹងស្មាធិ៍ព្រះបន្ទូល មុខជាព្រះបន្ទូលនេះនឹងជ្រួតជ្រាបក្នុងចិត្តគេ គេក៏ត្រូវចេះប្រកាសព្រះបន្ទូលដោយពាក្យសម្តីផង និងដោយកិរិយាមារយាទផងដែរ។
- បំពេញមុខងារបម្រើពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងនាំឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ។ ដោយអធិដ្ឋានដោយធ្វើពិធីដ៏វិសុទ្ធផ្សេងៗ និងដោយថ្វាយសក្ការបូជាអរព្រះគុណ ហើយដោយធ្វើអគ្គសញ្ញាផ្សេងៗ ជូនគ្រីស្តបរិស័ទ គេនាំការសង្គ្រោះដល់មនុស្សលោក។
- បំពេញមុខងារបម្រើព្រះសហគមន៍ក្នុងឋានៈជាគង្វាលគឺនាំឲ្យមនុស្សលោកដឹងថាព្រះគ្រីស្តគង់នៅជាមួយគេ គឺព្រះអង្គយាងមកក្នុងពិភពលោកនេះ «មិនមែនដើម្បីឲ្យគេបម្រើលោកឡើយ គឺយាងមកបម្រើគេវិញព្រមទាំងបូជាជីវិតដើម្បីលោះមនុស្សទាំងអស់ផង» (មក ១០, ៤៥ និង យហ ១៣, ១២.១៧)។ ដោយគេទៅជាអ្នកបម្រើរបស់មនុស្សទាំងអស់ គេនាំមនុស្សជាច្រើនមកថ្វាយព្រះគ្រីស្ត (១ករ ៩, ២២)។

ហេតុនេះហើយ បានជាត្រូវតម្រង់ការហ្វឹកហ្វឺនក្នុងគ្រប់វិស័យទៅរកទិសដៅតែមួយ គឺអប់រំនិស្សិតឲ្យធ្វើជាគង្វាលណែនាំគ្រីស្តបរិស័ទ គឺទាំងការហ្វឹកហ្វឺនឲ្យរស់នៅតាមព្រះវិញ្ញាណ ទាំងការហ្វឹកហ្វឺនខាងចំណេះដឹងទាំងការហ្វឹកហ្វឺនឲ្យអនុវត្តតាមក្បួនវិន័យ ត្រូវឲ្យវិស័យទាំងនោះស៊ីសង្វាក់គ្នា គឺអប់រំនិស្សិតឲ្យធ្វើជាគង្វាលណែនាំគ្រីស្តបរិស័ទ។ អស់លោកដែលទទួលខុសត្រូវលើទេវវិទ្យាល័យនិងសាស្ត្រាចារ្យទាំងអស់ ត្រូវយកចិត្តទុកដាក់ទៅកាន់គោលដៅនេះ ដោយរួមចិត្តគំនិតគ្នា ទាំងសុខចិត្តគោរពបញ្ជារបស់លោកអភិបាលដោយចិត្តស្មោះ។

៥-ការអប់រំនិស្សិតទេវវិទ្យាល័យមិនអាស្រ័យទៅលើវិន័យដ៏ល្អទេ តែអាស្រ័យលើអ្នកអប់រំដ៏មានគុណភាពល្អវិញ។ ហេតុនេះ ត្រូវជ្រើសរើសអស់លោកជាអ្នកណែនាំ និងសាស្ត្រាចារ្យ ក្នុងចំណោមគង្វាលដ៏ល្អប្រសើរជាងគេ។ លោកទាំងនោះត្រូវរៀបចំខ្លួន ដោយរៀនលទ្ធិគ្រីស្តសាសនាយ៉ាងមាំមួន ដោយមានបទពិសោធន៍ក្នុងការឃ្វាលណែនាំគ្រីស្តបរិស័ទយ៉ាងសមរម្យ និងដោយទទួលការអប់រំពិសេសអំពីការរស់នៅតាមព្រះវិញ្ញាណ និងអំពីគរុកោសល្យ។ ត្រូវចាត់ចែងគ្រឹះស្ថាន ដែលជួយសាស្ត្រាចារ្យឲ្យអាចទទួលការអប់រំបែបនេះបាន យ៉ាងហោចណាស់ត្រូវចាត់ចែងសិក្ខាសាលា តាមសេចក្តីត្រូវការទាំងនោះ ព្រមទាំងត្រូវឲ្យអស់លោកជាអ្នកណែនាំទេវវិទ្យាល័យជួបជុំគ្នាតាមពេលកំណត់។

អស់លោកជាអ្នកណែនាំ និងសាស្ត្រាចារ្យត្រូវដឹងជាក់ច្បាស់ថា របៀបអស់លោករិះគិត និងប្រតិបត្តិមានសារៈសំខាន់យ៉ាងខ្លាំង លើការហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យឲ្យបានជោគជ័យ។ អស់លោកនឹងរួបរួមចិត្តគំនិតយ៉ាងជិតស្និទ្ធហើយរួបរួមគ្នាប្រតិបត្តិ ក្រោមការណែនាំរបស់លោកប្រធាន រួមជាមួយនិស្សិតទេវវិទ្យាល័យ ធ្វើជាក្រុមគ្រួសារមួយ តាមពាក្យអង្វររបស់ព្រះអម្ចាស់ថា៖ «សូមឲ្យគេរួមគ្នាជាអង្គតែមួយ» (យហ ១៧, ១១)។ ក្រុមគ្រួសារនេះ នឹងបណ្តាលឲ្យនិស្សិតទេវវិទ្យាល័យ មានអំណរសប្បាយយ៉ាងស្ថិតស្ថេរ ដោយព្រះជាម្ចាស់ត្រាស់ហៅគេ។ លោកអភិបាលត្រូវមានចិត្តស្រឡាញ់និងព្យាយាមខន្តី យកចិត្តទុកដាក់ណែនាំអស់លោកដែលធ្វើការនៅទេវវិទ្យាល័យ ព្រមទាំងមានទំនាក់ទំនង

ជាមួយនិស្សិត ទុកដូចជាឳពុកដ៏ពិតប្រាកដក្នុងអង្គព្រះគ្រីស្ត។ មិនតែប៉ុណ្ណោះ អស់បូជាចារ្យត្រូវរាប់ទេវវិទ្យាល័យទុកជាបេះដូងនៃភូមិភាគ ហើយក៏ត្រូវជួយទេវវិទ្យាល័យដោយខ្លួនឯងផ្ទាល់ទៀតផង។

៦-ត្រូវសិក្សាដោយពិនិត្យពិច័យឲ្យមែនទែន ដោយគិតគូរដល់អាយុនិងការចម្រើនរបស់គេថា តើបេក្ខជនម្នាក់ៗមានបំណងទៀងត្រង់ និងមានសេរីភាពក្នុងការសម្រេចឬយ៉ាងណា? ត្រូវពិនិត្យពិច័យលទ្ធភាពរបស់គេឲ្យរស់នៅតាមព្រះវិញ្ញាណ និងឲ្យរស់នៅតាមសីលធម៌ តើគេមានបញ្ញាស្មារតីគ្រប់គ្រាន់ឬយ៉ាងណា? ត្រូវពិនិត្យមើលសុខភាព ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត តើគេមានសុខភាពគ្រប់គ្រាន់ឬយ៉ាងណា? ត្រូវនឹកគិតដល់សុខភាពរបស់ញាតិសន្តានគេដែរ។ ត្រូវពិនិត្យមើកលទ្ធភាពរបស់គេ ឲ្យទទួលបន្ទុកជាបូជាចារ្យ និងឲ្យបំពេញភារកិច្ចណែនាំគ្រីស្តបរិស័ទទៀតផង។

ទោះបីយើងស្តាយដោយខ្វះគង្វាលក្តី ក៏ត្រូវកាន់ចិត្តរឹងប៉ឹងជានិច្ច ចំពោះការជ្រើសរើសនិងការល្បងលមើលចិត្តគំនិតនិស្សិតទេវវិទ្យាល័យ។ ប្រសិនបើយើងតែងតាំងតែបេក្ខជនដ៏សមគួរឲ្យទៅជាបូជាចារ្យ ពិតជាមានចំនួនបូជាចារ្យតិច ប៉ុន្តែយើងជឿជាក់ថា ព្រះជាម្ចាស់គង់តែប្រទានឲ្យព្រះសហគមន៍មានអ្នកបម្រើគ្រប់គ្រាន់ជាពុំខាន។ ត្រូវទូន្មាន ដូចឳពុកទូន្មានកូន តម្រង់អស់បេក្ខជនណាដែលគ្មានសមត្ថភាពគ្រប់គ្រាន់ ឲ្យទៅទទួលខុសត្រូវផ្សេង នៅពេលដ៏សមគួរកុំចាំយូរពេក។ ត្រូវជួយគេឲ្យមានអំណរសប្បាយ បំពេញកិច្ចការជាគ្រីស្តទូតរបស់គ្រីសបរិស័ទធម្មតា ទាំងដឹងថាព្រះជាម្ចាស់ត្រាស់ហៅគេឲ្យទៅជាគ្រីស្តបរិស័ទ។

៧-ប្រសិនបើភូមិភាគនីមួយៗគ្មានលទ្ធភាពចាត់ចែងទេវវិទ្យាល័យយ៉ាងសមរម្យដោយផ្ទាល់បាន ត្រូវតែងតាំងនិងទ្រទ្រង់ទេវវិទ្យាល័យរួម សម្រាប់ភូមិភាគជាច្រើន ឬសម្រាប់តំបន់មួយ ឬសម្រាប់ប្រទេសទាំងមូល ដើម្បីហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យយ៉ាងស័ក្តិសិទ្ធិ និងយ៉ាងហ្មត់ចត់។ ក្នុងករណីនេះ ត្រូវចាត់ការហ្វឹកហ្វឺនដ៏ស័ក្តិសិទ្ធិនិងហ្មត់ចត់នេះទុកជាគោលការណ៍ដ៏ខ្ពង់ខ្ពស់បំផុត។ អស់លោកអភិបាលព្រះសហគមន៍នៃភូមិភាគទាំងនោះ ត្រូវចាត់ចែងក្បួនវិន័យសម្រាប់ទេវវិទ្យាល័យទាំងនោះ ទាំងទេវវិទ្យាល័យតំបន់ ទាំងទេវវិទ្យាល័យជាតិ។ អាសនៈរបស់គ្រីស្តទូតសិលា ក៏ត្រូវយល់ព្រមតាមក្បួនវិន័យនោះថែមទៀតផង។

ប្រសិនបើមាននិស្សិតច្រើនពេកក្នុងទេវវិទ្យាល័យមួយ ត្រូវបែងចែកនិស្សិតទាំងនោះ ជាក្រុមតូចៗជាងយ៉ាងសមរម្យ ដើម្បីឲ្យបុគ្គលិកលក្ខណៈរបស់ស្សិតម្នាក់ៗចម្រើនឡើងបានយ៉ាងល្អ។ ប៉ុន្តែ ត្រូវរក្សាទុកការត្រួតត្រាណែនាំនិងការបង្រៀនរួម។

## ៤-ការពង្រឹងអប់រំនិស្សិតឲ្យរស់នៅតាមព្រះវិញ្ញាណ

៨-ត្រូវភ្ជាប់ការអប់រំនិស្សិតឲ្យរស់នៅតាមព្រះវិញ្ញាណ នឹងការបង្រៀនលទ្ធិគ្រីស្តសាសនា ទន្ទឹមនឹងការហ្វឹកហ្វឺនឲ្យចេះណែនាំគ្រីស្តបរិស័ទ។ លោកដែលណែនាំជីវិតនិស្សិតម្នាក់ៗតាមព្រះវិញ្ញាណ មានភារកិច្ចសំខាន់ជាងគេក្នុងការអប់រំនោះ។ លោកត្រូវណែនាំគេឲ្យរួមរស់យ៉ាងស្និទ្ធស្នាលជាមួយព្រះបិតាជានិច្ច ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រា ក្នុងអង្គព្រះវិញ្ញាណដ៏វិសុទ្ធ។ ពេលនិស្សិតទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ គេនឹងបានដូចព្រះគ្រីស្តជាមហាបូជាចារ្យ។ ដូច្នេះ គេត្រូវតែមានទម្លាប់រួមរស់ជាមួយព្រះអង្គយ៉ាងស្និទ្ធស្នាលជាទីបំផុត គ្រប់ករណីប្រចាំជីវិត ដូចមិត្តសម្លាញ់តែងរួមរស់ជាមួយគ្នាដូច្នោះដែរ។ គេត្រូវរួមរស់ជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងយ៉ាងជិតស្និទ្ធបំផុត ទើបគេអាចណែនាំប្រជាជន ដែលព្រះសហគមន៍នឹងផ្ញើឲ្យគេនៅពេលក្រោយ ឲ្យរួបរួមជាមួយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿងនេះដែរ។ ត្រូវអប់រំគេឲ្យស្វែងរកព្រះគ្រីស្ត ដោយនឹកសញ្ជឹង

ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងស្មោះ ដោយរួបរួមយ៉ាងសកម្មក្នុងពិធីគោរពប្រណិប័តន៍ដ៏វិសុទ្ធបំផុតទាំងប៉ុន្មាន នៃព្រះសហគមន៍ ជាពិសេសក្នុងអគ្គសញ្ញាអរព្រះគុណ និងពិធីលើកតម្កើងព្រះជាម្ចាស់តាមពេលកំណត់។ គេត្រូវស្វែងរកព្រះគ្រីស្ត ក្នុងលោកអភិបាលដែលចាត់គេឲ្យទៅ និងក្នុងចំណោមមនុស្សដែលលោកចាត់ឲ្យបម្រើនោះ ជាពិសេសក្នុងរូបអ្នកក្រីក្រ កូនក្មេង អ្នកជំងឺ អ្នកបាប និងក្នុងរូបអ្នកដែលគ្មានជំនឿ។ គេត្រូវគោរព និងស្រឡាញ់ព្រះនាងព្រហ្មចារិនីម៉ារី ដូចកូនតែងស្រឡាញ់និងផ្ញើជីវិតលើម្ដាយដូច្នេះដែរ គឺនាងម៉ារី ដែលព្រះយេស៊ូបានប្រគល់ឲ្យសាវ័កយ៉ូហាន ទុកជាម្ដាយ នៅពេលព្រះអង្គហៀបនឹងសោយទិវង្គតនៅលើឈើឆ្កាង។

ត្រូវចាប់អារម្មណ៍យ៉ាងខ្លាំងនឹងការហ្វឹកហ្វឺនផ្សេងៗ នាំឲ្យគោរពប្រណិប័តន៍ព្រះជាម្ចាស់ តាមទម្លាប់គួរឲ្យគោរពរបស់ព្រះសហគមន៍ដែលផ្ដែផ្ដាំឲ្យធ្វើជាយូរសតវត្សមកហើយ។ ក៏ប៉ុន្តែ ត្រូវប្រយ័ត្នកុំស្មានថា ការអប់រំឲ្យរស់នៅតាមព្រះវិញ្ញាណ អាស្រ័យតែនឹងការបំពេញពិធីទាំងនោះប៉ុណ្ណោះទេ និងគ្រាន់តែឲ្យគេរំភើបចិត្ត តាមសាសនាប្រជាប្រិយប៉ុណ្ណោះដែរ។ ជាពិសេសនិស្សិតត្រូវរៀនរស់នៅស្របតាមរបៀបដំណឹងល្អ គឺឲ្យពង្រឹងជំនឿ ពង្រឹងសេចក្ដីសង្ឃឹម និងពង្រឹងសេចក្ដីស្រឡាញ់របស់ខ្លួនឲ្យកាន់តែមាំមួនឡើងៗ។ ដោយប្រតិបត្តិតាមគុណធម៌ទាំងបីនោះ គេនឹងមានចិត្តគំនិតជាអ្នកធ្លាប់អធិដ្ឋាន គេពង្រឹង និងការពារនូវការតបឆ្លើយរបស់ខ្លួន ចំពោះព្រះជាម្ចាស់ដែលត្រាស់ហៅគេ។ គេត្រូវប្រតិបត្តិតាមគុណធម៌ទាំងបីនោះ ទើបព្រហ្មវិហារធម៌ឯទៀតៗរឹងប៉ឹងឡើង ហើយគេខ្នះខ្នែងជំរុញខ្លួនឲ្យនាំមនុស្សទាំងអស់ឲ្យទៅជាកម្មសិទ្ធិរបស់ព្រះគ្រីស្ត។

៩-ត្រូវឲ្យចិត្តគំនិតរបស់និស្សិតជ្រួតជ្រាបយ៉ាងជ្រៅបំផុត តាមគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍ តាមមហាសន្និបាតបានពន្យល់យ៉ាងពិស្ដាររួចហើយ។ ដូច្នេះ គេផ្ចង់ចិត្ត និងអភិបាលព្រះសហគមន៍ក្រុងរ៉ូមជាតំណាងព្រះគ្រីស្ត ដោយចិត្តសុភាពរាបសាដូចកូនស្រឡាញ់ឪពុកដូច្នោះដែរ។ ពេលគេទៅជាបូជាចារ្យ (អាចារ្យ) រួចហើយ គេក៏នឹងរួមចិត្តគំនិតជាមួយអភិបាលរបស់ខ្លួន ក្នុងឋានៈខ្លួនជាសហការីដ៏ស្មោះត្រង់របស់លោក ហើយបំពេញការងាររួមជាមួយបូជាចារ្យ (អាចារ្យ) ឯទៀតៗជាបងប្អូន។ គេក៏នឹងផ្ដល់សក្ខីភាពអំពីព្រះសហគមន៍រួបរួមជាធ្លុងតែមួយ ជាមូលហេតុទាក់ទាញចិត្តមនុស្សឲ្យមករកព្រះគ្រីស្ត (ពន្លឺ ២៨)។ សូមឲ្យគេបង្ហាត់ខ្លួនឲ្យចូលរួមក្នុងការរស់នៅរបស់ព្រះសហគមន៍ទាំងមូល ដោយចិត្តទូលំទូលាយ តាមពាក្យពេចន៍របស់សន្តៈអូគូស្ដាំងថា *"ម្នាក់ៗស្រឡាញ់ព្រះសហគមន៍តាមកម្រិតណា គេក៏ទទួលព្រះវិញ្ញាណតាមកម្រិតនោះដែរ"*។ ត្រូវឲ្យគេយល់យ៉ាងជាក់ច្បាស់ថា មុខងារជាបូជាចារ្យដែលគេនឹងទទួលនៅពេលខាងមុខនេះ មិនផ្ដល់ឲ្យគេមានអំណាចគ្រប់គ្រងជិះជាន់អ្នកដទៃទេ ហើយក៏មិនផ្ដល់ឲ្យគេមានកិត្តិយសដែរ តែផ្ទុយទៅវិញ គេត្រូវបូជាជីវិតទាំងស្រុងក្នុងកិច្ចបម្រើព្រះជាម្ចាស់ និងក្នុងមុខងារបម្រើណែនាំអ្នកឯទៀតៗផង។ អ្នកទទួលខុសត្រូវលើទេវវិទ្យាល័យ ត្រូវយកចិត្តទុកដាក់អប់រំគេឲ្យត្រូវចេះស្ដាប់បង្គាប់ ក្នុងឋានៈជាបូជាចារ្យ និងចូលចិត្តរស់នៅតាមរបៀបជាអ្នកក្រីក្រ ព្រមទាំងមានចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួនចោល (ពន្លឺ ៨)។ ដូច្នេះ គេធ្លាប់លះបង់អ្វីៗភ្លាមចោល សូម្បីអ្វីៗដែលគេមានសិទ្ធិកាន់កាប់តែឥតបានការ។ គេក៏សុខចិត្តឲ្យបានដូចព្រះគ្រីស្តដែលត្រូវគេឆ្កាងដែរ។

ត្រូវជម្រាបគេអំពីបន្ទុកដែលគេត្រូវបំពេញនៅពេលក្រោយ ដោយមិនលាក់លៀមនូវការពិបាក ក្នុងការរស់នៅជាបូជាចារ្យឡើយ។ ក៏ប៉ុន្តែ កុំឲ្យគេគិតតែពីការពិបាកដែលគេត្រូវជួបប្រទះប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ ត្រូវអប់រំគេឲ្យពង្រឹងការរស់នៅតាមព្រះវិញ្ញាណ ដោយសារកិច្ចការណែនាំរបស់ខ្លួន។

១០-ត្រូវអប់រំនិស្សិតទេវវិទ្យាល័យដោយយកចិត្តទុកដាក់យ៉ាងខ្លាំង ឲ្យកាន់តាមព្រហ្មចារិយធម៌ ក្នុងឋានៈជា

បូជាចារ្យ តាមក្បួនវិន័យនៃរបៀបរបបពិធីគោរពប្រណិប័តន៍របស់ខ្លួន ដែលជាប្រពៃណីដ៏មាំមួនគួរគោរព។ គេលះបង់ការរួមរស់ជាគូស្វាមីភរិយា មកពីគេយល់ដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ (មថ ១៩, ១២)។ គេផ្ចង់ចិត្តនឹងព្រះអម្ចាស់ ដោយសេចក្ដីស្រឡាញ់ ដោយមិនរារែកចិត្តស្របតាមសម្ព័ន្ធមេត្រីថ្មី។ គេផ្ដល់សក្ខីភាព អំពីជីវិតថ្មីដ៏រុងរឿងនៃលោកខាងមុខ (លក ២០, ៣៦)។ គេក៏យោងកម្លាំងពីព្រហ្មចារិយធម៌នេះទុកជាជំនួយពិសេស ដើម្បីប្រតិបត្តិឥតឈប់ឈរ តាមសេចក្ដីស្រឡាញ់ដ៏ពេញលក្ខណៈនេះ ដែលបណ្ដោយឲ្យគេអាចបម្រើមនុស្សទាំងអស់នៅគ្រប់វិស័យ តាមមុខងារបម្រើរបស់ខ្លួនជាបូជាចារ្យ។ គេត្រូវដឹងក្នុងជម្រៅចិត្តថា គេត្រូវអរព្រះគុណព្រះជាម្ចាស់ចំពោះការរស់នៅជាព្រហ្មចារី មិនគ្រាន់តែមកពីវិន័យមួយនៃព្រះសហគមន៍បញ្ញាប៉ុណ្ណោះទេ តែមកពីការរស់នៅបែបនេះជាព្រះអំណោយទានដ៏ថ្លៃថ្នូររបស់ព្រះជាម្ចាស់។ ត្រូវតែអង្វរព្រះអង្គដោយចិត្តសុភាពរាបសា សូមទ្រង់ប្រទានព្រះអំណោយទាននេះផង។ គេត្រូវប្រញាប់ប្រញាល់តបឆ្លើយនឹងព្រះអំណោយទាននេះដោយសេរី និងដោយចិត្តទូលាយ ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធប្រណីសន្ដោស និងជួយលើកស្ទួយផង។

ត្រូវឲ្យនិស្សិតទេវវិទ្យាល័យដឹងច្បាស់អំពីភារកិច្ច និងអំពីតម្លៃដ៏ថ្លៃថ្នូរនៃការរស់នៅជាគូស្វាមីភរិយាគ្រីស្ដបរិស័ទ ដែលជានិមិត្តរូបអំពីសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ដ និងព្រះសហគមន៍ (អភ ៥, ៣២) ប៉ុន្តែត្រូវឲ្យគេយល់ថា ការរស់នៅ ជាព្រហ្មចារីថ្វាយព្រះគ្រីស្ដប្រសើរជាងទៅទៀត។ ដូច្នេះ គេអាចប្រគល់ខ្លួនទាំងស្រុង ទាំងរូបកាយ ទាំងវិញ្ញាណថ្វាយព្រះអម្ចាស់ ដោយធ្វើជម្រើសមួយដ៏ល្អប្រសើរ ដែលគេថ្លឹងថ្លែងជ្រើសរើសយកយ៉ាងហ្មត់ចត់។

ត្រូវជម្រាបនិស្សិតទេវវិទ្យាល័យ ឲ្យស្គាល់អំពីការពិបាក ដែលគេមុខជានឹងជួបប្រទះ ក្នុងការកាន់តាមព្រហ្មចារិយធម៌ ជាពិសេសក្នុងសង្គមនាបច្ចុប្បន្នកាលនេះ។ ដោយមានជំនួយខាងលោកីយ៍ និងជំនួយរបស់ព្រះជាម្ចាស់យ៉ាងសមរម្យ គេត្រូវហាត់ខ្លួនឲ្យសុខចិត្តលះបង់ការរស់នៅជាគូស្វាមីភរិយា ក្នុងជម្រៅចិត្តរបស់គេយ៉ាងស្រគត់ស្រគំ។ ដូច្នេះ ព្រហ្មចារិយធម៌របស់គេ មិនបណ្ដាលឲ្យគេខូចខាតអ្វីឡើយក្នុងការរស់នៅរបស់ខ្លួន និងក្នុងសកម្មភាពរបស់គេ។ ផ្ទុយទៅវិញ ព្រហ្មចារិយធម៌នេះ នឹងបណ្ដាលឲ្យគេធ្វើជាម្ចាស់ចិត្តគំនិត និងធ្វើជាម្ចាស់រូបកាយឲ្យកាន់តែប្រសើរឡើងៗ ព្រមទាំងឲ្យទៅជាមនុស្សរម្យទមពេញវ័យកាន់តែពេញលេញឡើង។ គេក៏ទទួលអំណរមកពីដំណឹងល្អកាន់តែពេញលក្ខណៈទៀតផង។

១១-ត្រូវអនុវត្តតាមគោលការណ៍អប់រំ បែបជាគ្រីស្ដបរិស័ទ ដោយមានចិត្តចង់គោរពសាសនា។ ប៉ុន្តែ ត្រូវបន្ថែមសេចក្ដីដែលអ្នកប្រាជ្ញបានរកឃើញថ្មីៗនេះអំពីចិត្តសាស្ត្រ និងអំពីគរុកោសល្យដ៏ពិតប្រាកដ។ ការហ្វឹកហ្វឺនដែលណែនាំដោយប្រាជ្ញា ត្រូវបណ្ដុះបណ្ដាលឲ្យនិស្សិតទៅជាមនុស្សរម្យទម ចាស់ចិត្តចាស់គំនិត ដែលមនុស្សលោកត្រូវការ។ យើងស្គាល់មនុស្សរម្យទមពេញវ័យ ដោយគេមានចិត្តនឹងនរយ៉ាងសមរម្យ និងដោយគេអាចសម្រេចកិច្ចការបានក្រោយពីបានរិះគិតជាមុន ព្រមទាំងដោយគេចេះថ្លឹងថ្លែងពីអត្ថន័យព្រឹត្តិការណ៍ដែលកើតឡើង និងការវាយតម្លៃមនុស្សផងដែរ។ និស្សិតទេវវិទ្យាល័យត្រូវហាត់ខ្លួនឲ្យចេះទប់ទល់ចរិតលក្ខណៈរបស់ខ្លួន ត្រូវហាត់ឲ្យមានចិត្តរឹងប៉ឹង និងហាត់ឲ្យរាប់រកគុណធម៌ ដែលមនុស្សលោកចូលចិត្តជាខ្លាំងនោះ ហើយដែលនាំគេឲ្យរាប់អានអ្នកបម្រើរបស់ព្រះគ្រីស្ដ គឺថា ត្រូវមានចិត្តស្មោះត្រង់ នឹកគិតដល់យុត្តិធម៌ជានិច្ច ធ្វើតាមពាក្យសន្យា មានចរិយាចេះគួរសម មានចិត្តរម្យទម មិនវាយឫកពារ៍ខ្ពស់ មានចិត្តស្រឡាញ់ក្នុងពេលសន្ទនាជាមួយអ្នកដទៃ។

ពេលនិស្សិតរស់នៅវិទ្យាល័យ ការរស់នៅតាមវិន័យ មិនគ្រាន់តែជួយយ៉ាងខ្លាំងឲ្យគេរស់នៅជាមួយគ្នាយ៉ាងស្រួល និងឲ្យស្រឡាញ់គ្នាប៉ុណ្ណោះទេ តែត្រូវរាប់ការហ្វឹកហ្វឺនឲ្យរស់នៅតាមវិន័យនេះ ទុកជាមធ្យោបាយមួយដ៏សំខាន់ សម្រាប់

អប់រំគេក្នុងគ្រប់វិស័យ គឺថា នាំឲ្យគេចេះទប់ទល់ខ្លួនឯង ឲ្យមានចិត្តរម្យទម ឲ្យគេចាស់ចិត្តចាស់គំនិត និងមានលក្ខណៈផ្សេងៗទៀត។ ដូច្នេះ នៅពេលក្រោយ គេអាចបំពេញសកម្មភាព ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍យ៉ាងសមរម្យ និងយ៉ាងស័ក្តិសិទ្ធិ។ ប៉ុន្តែ ត្រូវហ្វឹកហ្វឺនតាមវិន័យទាំងនោះ ដើម្បីអប់រំចិត្តគំនិតរបស់គេឲ្យសុខចិត្តទទួលអំណាចរបស់អស់លោកជាអ្នកណែនាំ ដោយយល់ឃើញខ្លួនឯងថា គេស្តាប់បង្គាប់ដោយមានមនសិការ (រម ១៣, ៥) និងដោយនឹកគិតដល់ព្រះជាម្ចាស់។ ត្រូវអនុវត្តតាមក្បួនវិន័យ ស្របតាមអាយុរបស់និស្សិត។ ហេតុនេះ គេហាត់ខ្លួនបន្តិចម្តងៗ ឲ្យណែនាំខ្លួនដោយខ្លួនឯង ឲ្យធ្លាប់ប្រើសេរីភាពរបស់ខ្លួនដោយប្រាជ្ញា ហើយប្រតិបត្តិដោយគំនិតរបស់ខ្លួនផ្ទាល់ និងដោយចិត្តខ្នះខ្នែងទៀត ព្រមទាំងឲ្យធ្វើការរួមជាមួយបូជាចារ្យឯទៀតៗជាបងប្អូន និងជាមួយគ្រីស្តបរិស័ទធម្មតាទៀតផង។

ត្រូវឲ្យរបៀបរស់នៅក្នុងទេវវិទ្យាល័យ ណែនាំឲ្យគេចូលចិត្តគោរពប្រណិប័តន៍ព្រះជាម្ចាស់ និងចូលចិត្តនៅស្ងៀមស្ងាត់ ហើយឲ្យគេយកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក។ ត្រូវចាត់ទុករបៀបរស់នៅក្នុងទេវវិល័យ ទុកជាការហ្វឹកហ្វឺនឲ្យរស់នៅពេលអនាគត នៅពេលដែលគេទទួលអគ្គសញ្ញាតែងតាំងជាគង្វាលរួចហើយ។

១២-អស់លោកអភិបាលមានភារកិច្ចចាត់ចែងការហ្វឹកហ្វឺន ឲ្យរស់នៅតាមព្រះវិញ្ញាណយ៉ាងជ្រៅ ក្នុងរយៈពេលមួយដ៏សមគួរ។ ដូច្នេះ អស់លោកនឹងពង្រឹងការអប់រំឲ្យរស់នៅតាមព្រះវិញ្ញាណយ៉ាងមាំមួន ហើយនិស្សិតក៏អាចជ្រើសរើស និងតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគេ ដោយបានរិះគិតពិចារណាយ៉ាងសមរម្យជាយូរមកហើយ។ អស់លោកអភិបាលក៏មានភារកិច្ចសម្រេចថា តើគួរតែបញ្ឈប់ការសិក្សាមួយរយៈ ឬចាត់ចែងការហ្វឹកហ្វឺនម៉្យាងឲ្យនិស្សិតណែនាំគ្រីស្តបរិស័ទ ដើម្បីល្បងលមើលបេក្ខជន បម្រុងទៅជាបូជាចារ្យឲ្យបានច្បាស់ជាង។ អស់លោកអភិបាលក៏ត្រូវសម្រេចបន្ថយអាយុ ដែលមានកំណត់ទុកក្នុងក្បួនវិន័យរួមទូទៅនៃព្រះសហគមន៍ ឲ្យបានស្របតាមសភាពការណ៍ពិសេសនៃតំបន់នីមួយៗ។ ពេលនិស្សិតបញ្ចប់ការសិក្សានៅទេវវិទ្យា អស់លោកក៏មានភារកិច្ចរិះគិតអំពីការ សូមឲ្យនិស្សិតបំពេញមុខងារជាឧបដ្ឋាក អស់មួយរយៈពេលយ៉ាងសមគួរ មុនទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។

## ៥-អំពីការកែសម្រួលការសិក្សាវិជ្ជាពិសេសនៃព្រះសហគមន៍

១៣-និស្សិតទេវវិទ្យាល័យត្រូវទទួលការអប់រំតាមចំណេះមនុស្សលោកទូទៅ និងរៀនតាមវិទ្យាសាស្ត្រមុនសិក្សាវិទ្យាពិសេសនៃព្រះសហគមន៍។ គេត្រូវរៀនមុខវិជ្ជាទាំងប៉ុន្មានដែលយុវជនរួមជាតិត្រូវរៀនដើម្បីអាចចូលឧត្តមសិក្សាបាន។ លើសពីនេះទៅទៀត គេត្រូវរៀនភាសាឡាតាំង ជាភាសានាំឲ្យគេអាចយល់ និងចេះប្រើប្រាស់ឯកសារជាប្រភពនៃវិជ្ជាជាច្រើនរបស់ព្រះសហគមន៍បាន។ ត្រូវចាត់ចែងរៀនភាសាដែលគេប្រើក្នុងពិធីគោរពប្រណិប័តន៍នានា តាមរបៀបរបបផ្ទាល់របស់ខ្លួន ទុកជាសេចក្តីត្រូវការដ៏សំខាន់។ សូមផ្តែផ្តាំយ៉ាងខ្លាំងឲ្យនិស្សិតចេះភាសាដើមនៃព្រះគម្ពីរ និងភាសានៃការបញ្ជូនបន្តរបស់ព្រះសហគមន៍។

១៤-ពេលចាត់ចែងការសិក្សាវិជ្ជាពិសេសនៃព្រះសហគមន៍ ត្រូវមានគោលដៅធ្វើឲ្យទស្សនវិជ្ជា និងទេវវិទ្យាមានទំនាក់ទំនងគ្នាយ៉ាងស្រួល គឺវិជ្ជាទាំងពីរនោះសហការគ្នា ដើម្បីបើកចិត្តគំនិតនិស្សិតទេវវិទ្យាល័យឲ្យស្គាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្តកាន់តែច្បាស់ឡើងៗ។ គម្រោងការដ៏អស្ចារ្យនេះ ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រទាំងមូលនៃមនុស្សជាតិ និងនៅតែបន្តតទៅទៀតក្នុងព្រះសហគមន៍ជានិច្ចដែរ ហើយក៏បង្កើតផលជាពិសេស ដោយមុខងារបម្រើរបស់អស់លោកបូជាចារ្យ (ពន្លឺ ៧ និង ២៨)។

ហេតុនេះហើយ បានជាត្រូវចាប់ផ្តើមបង្រៀនវិជ្ជាពិសេសនៃព្រះសហគមន៍ ដោយបង្រៀនសេចក្តី ជាគ្រឹះអស់

រយៈពេលដ៏សមគួរ ដើម្បីឲ្យនិស្សិតមានទស្សនៈជាទូទៅ មុនចាប់ផ្ដើមទទួលការអប់រំ។ ក្នុងការបង្រៀនសេចក្ដីជាគ្រឹះទូទៅនេះ ត្រូវរៀបរាប់អំពីគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ដើម្បីឲ្យនិស្សិតយល់អំពីអត្ថន័យវិជ្ជាទាំងប៉ុន្មាន នៃព្រះសហគមន៍ និងឲ្យគេយល់អំពីលំដាប់លំដោយនៃវិជ្ជាទាំងនោះ ព្រមទាំងយល់អំពីគោលដៅនៃការសិក្សាវិជ្ជាទាំងនោះទៀត គឺណែនាំគ្រីស្តបរិស័ទតែម្ដង។ នៅពេលជាមួយគ្នានេះ មេរៀនខាងដើមដំបូងនេះ ត្រូវជួយឲ្យគេយកជំនឿធ្វើជាគ្រឹះនៃការរស់នៅទាំងមូលរបស់ខ្លួន គឺឲ្យជំនឿជ្រួតជ្រាបចិត្តគំនិតរបស់គេ។ ដូច្នេះ គេយល់កាន់តែរឹងប៉ឹងថា ព្រះជាម្ចាស់ត្រាស់ហៅគេមែន គេក៏ស្ម័គ្រចិត្តតបឆ្លើយនឹងព្រះអង្គដោយខ្លួនគេផ្ទាល់ គឺថ្វាយខ្លួនទាំងស្រុងទៅព្រះអង្គដោយចិត្តរីករាយ។

១៥-ត្រូវបង្រៀនទស្សនវិជ្ជា ក្នុងគោលបំណងចម្បងណែនាំនិស្សិត ឲ្យមានចំណេះចេះដឹងយ៉ាងមាំមួន ដែលពាក់ព័ន្ធគ្នាអំពីលក្ខណៈមនុស្ស និងអំពីលក្ខណៈពិភពលោក ហើយនិងអំពីព្រះជាម្ចាស់។ និស្សិតបានចំណេះចេះដឹងនោះដោយសម្អាងលើបេតិកភ័ណ្ឌនៃទស្សនវិជ្ជា ដែលមានតម្លៃដ៏ថ្លៃថ្នូររហូតតរៀងទៅ។ ប៉ុន្តែ ត្រូវគិតគូរដល់ការស្រាវជ្រាវទំនើបខាងទស្សនវិជ្ជា ជាពិសេសដល់ការស្រាវជ្រាវដែលមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងប្រទេសរបស់និស្សិត។ ត្រូវនឹកគិតដល់ការចម្រើនឡើងថ្មីៗនៃវិទ្យាសាស្ត្រទៀតផង។ ធ្វើដូច្នេះ ទើបនិស្សិតយល់ច្បាស់អំពីមតិមនុស្សនាសម័យបច្ចុប្បន្ន ហើយក៏រៀបចំខ្លួនដើម្បីនឹងនិយាយសន្ទនាជាមួយមនុស្សនាសម័យរបស់គេដែរ។

ត្រូវបង្រៀនប្រវត្តិសាស្ត្រនៃទស្សនវិជ្ជា ដើម្បីណែនាំឲ្យនិស្សិតស្គាល់គោលការណ៍ជាគ្រឹះនៃទស្សនវិទ្យានីមួយៗ។ ដូច្នេះ គេអាចយកអ្វីៗដែលទសន្សនវិជ្ជាបញ្ជាក់ថាត្រឹមត្រូវពិតប្រាកដនោះ ព្រមទាំងអាចរកឃើញឫសនៃសេចក្ដីមិនពិត និងអាចបដិសេធសេចក្ដីមិនពិតទាំងនោះបានផង។

វិធីបង្រៀនត្រូវលើកស្ទួយនិស្សិតឲ្យស្រឡាញ់សេចក្ដីពិត ដែលត្រូវតែស្វែងរក និងត្រូវពិនិត្យពិច័យ ហើយដែលត្រូវយកភ័ស្តុតាងមកបង្ហាញដោយគ្មានលម្អៀងថែមទៀត។ ប៉ុន្តែ ត្រូវមានចិត្តសុភាពរាបសាដោយដឹងខ្លួនថា ចំណេះចេះដឹងរបស់មនុស្សមានព្រំដែន។ សូមចាប់អារម្មណ៍យ៉ាងខ្លាំងថា ទស្សនវិជ្ជាក៏មានពាក់ព័ន្ធយ៉ាងស្អិតរមួតនឹងបញ្ហាដ៏ពិតប្រាកដនៃការរស់នៅ និងសំណួរផ្សេងៗដែលចោទឡើងក្នុងចិត្តគំនិតនិស្សិតដែរ។ ត្រូវជួយគេឲ្យឃើញថា ការរិះគិតតាមទស្សនវិជ្ជា ពិតជាទាក់ទិននឹងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ តែទេវវិទ្យាស្រាវជ្រាវគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះនោះ ដោយយកពន្លឺនៃជំនឿ ជាពន្លឺដ៏ខ្ពង់ខ្ពស់បំផុតមកបំភ្លឺចិត្តគំនិតគេ។

១៦-ត្រូវបង្រៀនទេវវិទ្យា ដោយយកពន្លឺចាំងពីជំនឿ មកបំភ្លឺចិត្តគំនិត ក្រោមការណែនាំនៃព្រះសហគមន៍ (ពន្លឺ ២៥)។ ដូច្នេះ និស្សិតមុខជាយោងលទ្ធិកាតូលិកចេញពីព្រះគម្ពីរ ជាសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់។ សូមឲ្យលទ្ធិនេះជ្រួតជ្រាបយ៉ាងជ្រៅក្នុងចិត្តគំនិតគេ និងយកធ្វើជាអាហារ សម្រាប់ជីវិតរបស់គេតាមព្រះវិញ្ញាណ។ នៅពេលក្រោយ កាលគេបំពេញមុខងារបម្រើព្រះសហគមន៍ក្នុងឋានៈជាបូជាចារ្យ គេក៏មានលទ្ធភាពអាចប្រកាស រៀបរាប់បកស្រាយ និងរក្សាការពារលទ្ធិនេះទៀតផង។

ត្រូវយកចិត្តទុកដាក់យ៉ាងពិសេស នឹងបង្រៀនព្រះគម្ពីរឲ្យនិស្សិតបានស្គាល់ គឺត្រូវរាប់គម្ពីរនេះ ទុកដូចជាដួងព្រលឹងនៃទេវវិទ្យាគ្រប់យ៉ាង។ ក្រោយពីបានបង្រៀនសេចក្ដីផ្ដើមយ៉ាងសមគួរ ត្រូវណែនាំនិស្សិតឲ្យស្គាល់វិធី វិភាគគម្ពីរយ៉ាងច្បាស់។ គេត្រូវរៀនគោលសំខាន់ៗនៃសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់។ ដោយអាន និងនឹកសញ្ជឹងគិតគម្ពីរជារៀងរាល់ថ្ងៃ គេក៏មានអាហារខាងព្រះវិញ្ញាណដែលលើកស្ទួយគេផងដែរ។

ត្រូវរៀបរាប់ពន្យល់គោលលទ្ធិនៃទេវវិទ្យាតាមលំដាប់លំដោយ គឺមុនដំបូងត្រូវបង្រៀនអំពីគោលសំខាន់ៗ នៃ

ព្រះគម្ពីរ។ ក្រោយមក ត្រូវបង្ហាញឲ្យនិស្សិតដឹងអំពីអ្វីៗ ដែលគ្រូបាធ្យាយទាំងនៅបូព៌ាប្រទេស ទាំងនៅបស្ចិមប្រទេស បានបញ្ជូនបន្តនិងរិះគិតយ៉ាងជ្រៅនិងយ៉ាងស្មោះត្រង់ អំពីសេចក្តីពិតនីមួយៗ ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ ត្រូវរៀបរាប់ប្រវត្តិនៃលទ្ធិគ្រីស្តសាសនាតាមរបៀបដដែល ទាំងនឹកគិតថាប្រវត្តិសាស្ត្រនៃលទ្ធិគ្រីស្តសាសនា ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រទូទៅនៃព្រះសហគមន៍ដែរ។ បន្ទាប់មក គេត្រូវហាត់ខ្លួនឲ្យរិះគិតអំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះកាន់តែជ្រៅទៅៗ និងយល់ថា ព្រឹត្តិការណ៍ទាំងនោះជាប់ទាក់ទងគ្នាយ៉ាងស្រួល ដោយយកសន្តះថូម៉ាស នៅអាឃីណូ ធ្វើជាគ្រូណែនាំក្នុងការរិះគិតនោះ។ ធ្វើដូច្នេះ ទើបគេអាចបង្ហាញព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការសង្គ្រោះ តាមតែមនុស្សអាចរិះគិតបាន។ ត្រូវបង្រៀនគេឲ្យទទួលថា ព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះ នៅស្ថិតស្ថេរ និងមានសកម្មភាពក្នុងពិធីគោរពប្រណិប័តន៍នានា (ពិធី ៧.១៦) ព្រមទាំងក្នុងការរស់នៅនៃព្រះសហគមន៍ទាំងមូលផង។ ត្រូវបង្ហាត់និស្សិតឲ្យដោះស្រាយបញ្ហាមនុស្សលោក តាមពន្លឺនៃសេចក្តី ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ គេក៏យកសេចក្តីពិតដែលនៅស្ថិតស្ថេរអស់កល្បជានិច្ចទាំងនោះ មកបំភ្លឺសភាពការណ៍របស់នមនុស្សលោកដែលតែងតែប្រែប្រួលជានិច្ច និងនាំយកសេចក្តីពិតទាំងនោះតាមរបៀបដែលមនុស្សលោកនាសម័យឥឡូវនេះអាចទទួល និងយល់បាន។

ត្រូវកែសម្រួលមុខវិជ្ជាឯទៀតៗនៃទេវវិទ្យាឲ្យបានថ្មី ដោយនិស្សិតមានទំនាក់ទំនងកាន់តែរស់រវើកជាមួយគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងជាមួយប្រវត្តិសាស្ត្រនៃការសង្គ្រោះ។ ត្រូវយកចិត្តទុកដាក់យ៉ាងពិសេស ធ្វើឲ្យទេវវិទ្យាសីលធម៌កាន់តែប្រសើរឡើងៗ គឺត្រូវរៀបរាប់ទេវវិទ្យាសីលធម៌នេះ តាមរបៀបវិទ្យាសាស្ត្រ ដោយសំអាងយ៉ាងច្រើនលើព្រះគម្ពីរ។ ត្រូវបង្ហាញបញ្ជាក់អំពីតម្លៃដ៏ថ្លៃថ្នូររបស់អស់អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យជឿ និងរួមក្នុងអង្គព្រះគ្រីស្ត ព្រមទាំងអំពីកាតព្វកិច្ចរបស់គេ ឲ្យបង្កបង្កើតផល ដោយសេចក្តីស្រឡាញ់ដើម្បីឲ្យមនុស្សលោកមានជីវិត។ ស្របជាមួយគ្នានេះ នៅពេលរៀបរាប់អំពីក្បួនច្បាប់ទូទៅនៃព្រះសហគមន៍ និងអំពីប្រវត្តិសាស្ត្រព្រះសហគមន៍ត្រូវនឹកគិតដល់គម្រោងការដ៏អស្ចារ្យនៃព្រះសហគមន៍ ឲ្យបានស្របនឹងធម្មនុញ្ញលទ្ធិ *"ពន្លឺបំភ្លឺពិភពលោក"* ដែលមហាសន្និបាតនេះ បានប្រកាសផ្សាយរួចហើយ។ ត្រូវបង្រៀនអំពីពិធីគោរពប្រណិប័តន៍ស្របតាមមាត្រាទី១៥ និង ១៦ នៃធម្មនុញ្ញពិធីគោរពប្រណិប័តន៍ ព្រោះត្រូវចាត់ពិធីគោរពប្រណិប័តន៍ទុកជាប្រភពទីមួយដែលត្រូវការជាងគេ ដើម្បីបង្កើតចិត្តគំនិតជាគ្រីស្តបរិស័ទសុទ្ធសាធ (ពិធី ១០.១៤.១៥.១៦)។

ដោយយល់ដល់សភាពការណ៍តាមតំបន់នីមួយៗ ត្រូវណែនាំនិស្សិតទេវវិទ្យាល័យ ឲ្យស្គាល់យ៉ាងច្បាស់អំពីសហគមន៍ និងក្រុមជំនុំដែលបែកចេញពីអាសនៈគ្រីស្តទូតសិលា។ ដូច្នេះ គេអាចជួយសហការឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាធ្លុងតែមួយ តាមការបញ្ជានៃមហាសន្និបាតនេះ (បង្រួប ១.៩.១០)។

ត្រូវណែនាំនិស្សិតឲ្យស្គាល់សាសនាឯទៀតៗ ជាពិសេសសាសនាដែលអ្នកស្រុកតែងតែគោរពក្នុងតំបន់នីមួយៗ ដូច្នេះ គេមុខជារកឃើញអ្វីៗដ៏ពិតប្រាកដនិងដ៏ល្អក្នុងសាសនាទាំងនោះ តាមតែព្រះជាម្ចាស់ចាត់ចែងឲ្យមាននោះ។ គេក៏នឹងហាត់ខ្លួនឲ្យឆ្លើយបដិសេធនឹងសេចក្តីមិនពិត ហើយគេអាចចែកចាយពន្លឺដ៏ពេញលេញនៃសេចក្តីពិត ជូនដល់អស់អ្នកដែលមិនស្គាល់សេចក្តីពិតនោះ។

១៧-ការបង្រៀនដ៏ពិតប្រាកដអំពីលទ្ធិគ្រីស្តសាសនា មានគោលដៅហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យយ៉ាងពិតប្រាកដ និងយ៉ាងជ្រៅ មិនគ្រាន់តែណែនាំគេឲ្យស្គាល់ទ្រឹស្តីប៉ុណ្ណោះទេ។ ហេតុនេះហើយបានជា ត្រូវប្រើវិធី តាមគរុកោសល្យ មកចាត់ចែងមេរៀន និងចាត់ចែងការសន្ទនា ហើយចាត់ចែងកិច្ចអនុវត្តន៍ផ្សេងៗ ដើម្បីលើកស្ទួយកិច្ចការ

របស់និស្សិត ដែលគេធ្វើខ្លួនឯង ឬតាមក្រុមតូចៗ។ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងឲ្យការបង្រៀនទាំងមូលស៊ីសង្វាក់គ្នា និងមាំមួនទៀត។ ត្រូវជៀសវាងកុំឲ្យមានមុខវិជ្ជា និងមេរៀនច្រើនពេក។ ហេតុនេះត្រូវលះបង់ប្រធានបទដែលឥតបានការ ឬប្រធានបទដែលត្រូវសិក្សានៅមហាវិទ្យាល័យ។

១៨-អស់លោកអភិបាលត្រូវយកចិត្តទុកដាក់ចាត់យុវជនដែលមានសមត្ថភាព គឺមានសម្បទា និងមានព្រហ្មវិហារធម៌ ហើយមានប្រាជ្ញាឲ្យទៅរៀននៅគ្រឹះស្ថានពិសេស នៅមហាវិទ្យាល័យ និងនៅសកលវិទ្យាល័យ។ ធ្វើដូច្នេះ អស់លោកគ្រោងទុកឲ្យមានគង្វាលខ្លះ ដែលបានទទួលការបង្រៀនយ៉ាងជ្រៅបែបវិទ្យាសាស្ត្រ អាចទប់ទល់នឹងសេចក្តីត្រូវការនៃកិច្ចការជាគ្រីស្តទូត។ លោកគង្វាលទាំងនោះអាចបង្រៀនវិជ្ជាព្រះសហគមន៍ និងវិជ្ជាផ្សេងៗទៀតបាន តាមអស់លោកអភិបាលយល់ឃើញថា គួរបង្រៀននោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវអប់រំគេឲ្យរស់នៅតាមព្រះវិញ្ញាណជាចាំបាច់ និងឲ្យចេះណែនាំគ្រីស្តបរិស័ទ ជាពិសេសប្រសិនបើនិស្សិត ដែលទៅរៀនវិទ្យាខ្ពស់ទាំងនោះ មិនទាន់ទទួលអគ្គសញ្ញាជាបូជាចារ្យនៅឡើយ។

## ៦-ការហ្វឹកហ្វឺនពិសេសខាងការណែនាំគ្រីស្តបរិស័ទ

១៩-ការហ្វឹកហ្វឺននិស្សិតទេវវិទ្យាល័យទាំងមូល មានគោលដៅតែមួយ គឺអប់រំគេឲ្យចេះណែនាំគ្រីស្តបរិស័ទ។ ហេតុនេះហើយ បានជាត្រូវបង្រៀននិស្សិតយ៉ាងហ្មត់ចត់អំពីសេចក្តីទាំងអស់ ដែលពាក់ព័ន្ធជាមួយមុខងារបម្រើព្រះសហគមន៍ គឺមានការអប់រំជំនឿនិងអត្ថាធិប្បាយគម្ពីរ មានការគោរពបម្រើព្រះជាម្ចាស់តាមពិធីគោរពប្រណិប័តន៍និង ធ្វើអគ្គសញ្ញានានាជូនគ្រីស្តបរិស័ទ មានសកម្មភាពមនុស្សធម៌ មានភារកិច្ចទាក់ទងជាមួយអ្នកដែលវង្វេងជំនឿ ឬដែលគ្មានជំនឿជាដើម ដោយមិនបំភ្លេចបន្ទុកណែនាំងទៀតៗផងដែរ។ ត្រូវបង្ហាត់គេយ៉ាងហ្មត់ចត់អំពីបច្ចេកទេសណែនាំគ្រីស្តបរិស័ទតាមព្រះវិញ្ញាណ ដើម្បីឲ្យគេអាចអប់រំបុត្រធីតានៃព្រះសហគមន៍ទាំងអស់ ឲ្យរស់នៅបែបជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ ទាំងដឹងខ្លួនយ៉ាងជាក់ច្បាស់ និងតាមបែបជាគ្រីស្តទូត ព្រមទាំងបំពេញភារកិច្ចផ្ទាល់ខ្លួន តាមរបៀបរស់នៅរបស់គេ។ សូមបង្ហាត់ខ្លួន ឲ្យចេះជួយណែនាំបព្វជិតបព្វជិតា ដោយយកចិត្តទុកដាក់បែបដដែលនោះឲ្យរស់នៅបន្តទៅមុខតាមព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដែលត្រាស់ហៅគាត់ និងឲ្យចម្រើនឡើងតាមគោលដៅនៃគ្រឹះស្ថានផ្សេងៗរបស់គាត់។

ជាទូទៅ ត្រូវបង្ហាត់និស្សិតទេវវិទ្យាល័យ ឲ្យមានសមត្ថភាពដ៏សំខាន់ជាងគេក្នុងការសន្ទនាជាមួយមនុស្សលោក គឺឲ្យចេះស្តាប់អ្នកដទៃ ឲ្យយល់អំពីលក្ខណៈផ្សេងៗរបស់មនុស្សជាតិ ដោយចិត្តស្រឡាញ់។

២០- នាសម័យយើងនេះ គរុកោសល្យ និងចិត្តសាស្ត្រ ហើយសង្គមសាស្ត្រ បានរកឃើញសេចក្តីថ្មីៗហើយ។ ត្រូវបង្ហាត់និស្សិតទេវវិទ្យាល័យ ឲ្យចេះសេចក្តីថ្មីៗទាំងនោះ យ៉ាងត្រឹមត្រូវនិងស្របតាមសេចក្តីណែនាំរបស់លោកអភិបាល។ ធ្វើដូច្នេះ ទើបអ្នកទទួលខុសត្រូវលើទេវវិទ្យាល័យ រៀបចំគេយ៉ាងហ្មត់ចត់ ឲ្យលើកស្ទួយនិងគាំទ្រកិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទធម្មតា (ពន្លឺ ៣៣) ព្រមទាំងឲ្យលើកស្ទួយរបៀបផ្សេងៗនិងកាន់តែស័ក្តិសិទ្ធ នៃកិច្ចការជាគ្រីស្តទូត។ មិនតែប៉ុណ្ណោះ ត្រូវឲ្យចិត្តគំនិតជាគ្រីស្តទូតយ៉ាងពិតប្រាកដ ជ្រួតជ្រាបចូលក្នុងខ្លួនគេ គឺចិត្តគំនិតជាគ្រីស្តទូតនោះនឹងនាំឲ្យគេធ្លាប់គិតហួសពីព្រំដែនភូមិភាគរបស់ខ្លួន ហួសពីព្រំដែនជាតិ និងហួសពីរបៀបរបបនៃពិធីរបស់ខ្លួនដែរ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការនៃព្រះសហគមន៍ទាំងមូល។ ត្រូវឲ្យគេត្រៀមខ្លួនយ៉ាងស្មោះអំពីចិត្ត ចេញទៅប្រកាសដំណឹងល្អរហូតដល់ទីដាច់ស្រយាលនៃពិភពលោក (ពន្លឺ ១៧)។

២១-និស្សិតទេវវិទ្យាល័យត្រូវទទួលការហ្វឹកហ្វឺន មិនគ្រាន់តែដោយរៀនទ្រឹស្ដីអំពីកិច្ចជាគ្រីស្ដទូតប៉ុណ្ណោះទេ តែត្រូវបង្ហាត់គេឲ្យប្រត្តិបតិតាមដែរ។ ត្រូវឲ្យគេអាចទទួលខុសត្រូវដោយផ្ទាល់ ក្នុងកិច្ចការដែលគេនឹងត្រូវបំពេញដោយសហការជាមួយអ្នកដទៃ។ ហេតុនេះ នៅពេលសិក្សានិងនៅពេលវិស្សមកាល ត្រូវអប់រំគេឲ្យបំពេញកិច្ចណែនាំគ្រីស្ដបរិស័ទ បង្កើតបទពិសោធន៍តាមសេចក្ដីត្រូវការ។ ត្រូវណែនាំគេឲ្យបំពេញកិច្ចការណែនាំគ្រីស្ដបរិស័ទ ដោយការហ្វឹកហ្វឺនស្របតាមសភាពការណ៍។ ត្រូវហ្វឹកហ្វឺនគេតាមវិធីប្រកបដោយរបៀបរៀបរយ ស្របតាមអាយុរបស់និស្សិត និងស្របតាមសភាពការណ៍តំបន់នីមួយៗ ព្រមទាំងស្របតាមការយល់ឃើញដ៏ប្រុងប្រយ័ត្នរបស់អស់លោកអភិបាល។ ត្រូវមានអ្នកជំនាញការខាងវិធីណែនាំចាត់ចែងការហ្វឹកហ្វឺននោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវរំឭកគេជានិច្ចថា មានតែមធ្យោបាយនៃលោកខាងមុខទេ ដែលសំខាន់ជាងគេ។

## ៧-ការអប់រំអចិន្ត្រៃយ៍ក្រោយការហ្វឹកហ្វឺននៅទេវវិទ្យាល័យ

២២-សូម្បីតែក្រោយពីបូជាចារ្យបានបញ្ចប់ការសិក្សានៅទេវវិទ្យាល័យក្ដី ក៏សភាពការណ៍នៃជីវភាពនៅក្នុងសង្គមទំនើបនេះ បង្ខំយ៉ាងខ្លាំងឲ្យបូជាចារ្យបន្តការអប់រំរបស់ខ្លួនឲ្យកាន់តែពេញលក្ខណៈ។ ហេតុនេះ ក្រុមអភិបាលតាមប្រទេសនីមួយៗ មានភារកិច្ចចាត់ចែងមធ្យោបាយដ៏សមរម្យជាងគេ ស្របតាមសភាពការណ៍ ដើម្បីអប់រំបូជាចារ្យតទៅទៀត។ ឧបមាថា ឲ្យ មានគ្រឹះស្ថានណែនាំ ដែលសហការនឹងព្រះសហគមន៍តាមភូមិនានាដែលគេបានជ្រើសរើសយ៉ាងហ្មត់ចត់ ឲ្យមានការប្រជុំតាមពេលកំណត់ ឲ្យចាត់ចែងការហ្វឹកហ្វឺនស្របតាមសភាពការណ៍ប្រទេស។ ល។ធ្វើដូច្នេះក្រុមបូជាចារ្យថ្មីៗ អាចចាប់ផ្ដើមរស់នៅក្នុងឋានៈជាបូជាចារ្យ និងចាប់ផ្ដើមបំពេញកិច្ចការជាគ្រីស្ដទូត ក្នុងវិស័យនៃការរស់នៅតាមព្រះវិញ្ញាណ ក្នុងវិស័យនៃចំណេះចេះដឹង និងក្នុងវិស័យនៃការណែនាំគ្រីស្ដបរិស័ទផង។ បន្តិចម្ដងៗ ក្រុមបូជាចារ្យថ្មីៗទាំងនោះ មុខជានឹងទទួលសមត្ថភាពប្រែកិច្ចការទាំងនោះឲ្យបានជាថ្មី និងធ្វើឲ្យកិច្ចការទាំងនោះចម្រើនឡើងទៀតផង។

# ពាក្យបញ្ចប់

អស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតនេះ បន្តកិច្ចការដែលមហាសន្និបាតក្រុងត្រែនតូចាប់ ផ្ដើមធ្វើហើយសូមផ្ញើទាំងទុកចិត្តឲ្យអស់លោកជាអ្នកណែនាំ និងឲ្យសាស្ត្រាចារ្យនៃទេវវិទ្យាល័យ នូវបន្ទុកហ្វឹកហ្វឺនបូជាចារ្យរបស់ព្រះគ្រីស្តសម្រាប់នៅពេលអនាគត។ សូមអស់លោកអប់រំបូជាចារ្យថ្មីទាំងនោះ ស្របតាមគោលគំនិតមហាសន្និបាតដែលមានបំណងលើកស្ទួយការកែសម្រួលព្រះសហគមន៍ឲ្យបានថ្មីនោះ។ នៅពេលជាមួយគ្នានេះ សូមដាស់តឿនយ៉ាងខ្លាំងជាទីបំផុត អស់អ្នកដែលត្រៀមខ្លួនទទួលមុខងារបម្រើក្នុងឋានៈជាបូជាចារ្យ ឲ្យដឹងច្បាស់ថា ព្រះសហគមន៍សង្ឃឹមលើអ្នកទាំងនោះ ដើម្បីសង្គ្រោះមនុស្សលោក។ សូមទទួលសេចក្ដីបញ្ញាក្នុងក្រឹត្យក្រមនេះ ដោយស្មោះអស់ពីចិត្ត ហើយសូមបង្កើតផលជាច្រើននៅស្ថិតស្ថេរជានិច្ចនិរន្តរ៍។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ ព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រមហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្ដីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈសិលា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# សេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ

**(អំពីការកែសម្រួលការរស់នៅជាបព្វជិតបព្វជិតា)**

## PERFECTAE CARITATIS

## ខ្ញុំ ប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសសេចក្តីនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

## សេចក្តីប្រកាស
## អំពីការកែសម្រួលការរស់នៅរបស់បព្វជិតបព្វជិតាតាមរបៀបថ្មី សមស្របតាមសម័យបច្ចុប្បន្ន

**១-បុព្វកថា**

ក្នុងធម្មនុញ្ញគោលលទ្ធិក្រោមចំណងជើងថា *"ព្រះសហគមន៍ជាពន្លឺបំភ្លឺពិភពលោក"* មហាសន្និបាតបានបង្ហាញថា ការស្វះស្វែងរកសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ដោយប្រព្រឹត្តតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ ហូរចេញមកពីលទ្ធិនិងពីគំរូរបស់ព្រះគ្រីស្តជាព្រះបរមគ្រូ ហើយពិតជាសញ្ញាសម្គាល់ដ៏ប្រសើរ សម្តែងយ៉ាងជាក់ច្បាស់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ឥឡូវនេះ មហាសន្និបាតមានបំណងចង់ចែងអំពីការរស់នៅ និងអំពីវិន័យរបស់គ្រឹះស្ថានទាំងប៉ុន្មាន ដែលមានសមាជិកធ្វើពិធីសច្ចាប្រណិធាន ថានឹងរស់នៅជាព្រហ្មចារី ជាអ្នកក្រីក្រ និងជាអ្នកស្តាប់បង្គាប់មេដឹកនាំ។ ធ្វើដូច្នេះ មហាសន្និបាតនឹងជួយផ្គត់ផ្គង់តាមតម្រូវការរបស់គេ ស្របតាមសម័យបច្ចុប្បន្នទាមទារនោះ។

តាំងពីដើមដំបូងនៃព្រះសហគមន៍រៀងមក មានបុរសនិងស្ត្រីខ្លះមានបំណងចង់តាមព្រះគ្រីស្តដោយមានសេរីភាពជាងគ្រីស្តបរិស័ទឯទៀតៗ និងយកតម្រាប់តាមព្រះអង្គយ៉ាងស្មោះស្ម័គ្រជាង ដោយប្រតិបត្តិតាមដំបូន្មានរបស់ព្រះគ្រីស្តដែលចែងក្នុងគម្ពីរដំណឹងល្អ គឺម្នាក់ៗបានញែកខ្លួនថ្វាយព្រះជាម្ចាស់តាមរបៀបរៀងៗខ្លួន។ ក្នុងចំណោមអ្នកទាំងនោះ ដោយព្រះវិញ្ញាណដ៏វិសុទ្ធជំរុញគេ មានគ្រីស្តបរិស័ទមួយចំនួនធំបានរស់នៅម្នាក់ឯង អ្នកខ្លះទៀតបង្កើតក្រុមគ្រួសារបព្វជិត បព្វជិតា។ ព្រះសហគមន៍ទទួលស្គាល់ក្រុមគ្រួសារទាំងនោះដោយរីករាយ និងយកអំណាចរបស់ខ្លួនមកធានារ៉ាប់រងទៀតផង។ តាំងពីពេលនោះមក ចំនួនក្រុមបព្វជិតបព្វជិតាប្លែកៗពីគ្នាមានកាន់តែច្រើនឡើងៗយ៉ាងអស្ចារ្យ តាមព្រះជាម្ចាស់គ្រោងទុកស្រាប់។ ក្រុមបព្វជិតទាំងនោះជួយព្រះសហគមន៍យ៉ាងសកម្ម មិនគ្រាន់តែឲ្យអាចប្រព្រឹត្តអំពើល្អ

គ្រប់យ៉ាង (២ធម ៣, ១៧) និងឲ្យប្រុងប្រៀបបំពេញមុខងារបម្រើរបស់ខ្លួន ដើម្បីកសាងព្រះកាយព្រះគ្រីស្តប៉ុណ្ណោះទេ (អភ ៤, ៣២) តែក្រុមទាំងនោះក៏ជួយឲ្យព្រះសហគមន៍បញ្ចេញសោភ័ណភាព តាមព្រះអំណោយទានផ្សេងៗនៃបុត្រធីតារបស់ខ្លួន ដូចព្រះមហេសីដែលតែងខ្លួនថ្វាយព្រះស្វាមី (វវ ២១, ២) ថែមទៀតផង។ ដូច្នេះ ព្រះសហគមន៍អាចសម្តែងព្រះប្រាជ្ញាញាណគ្រប់វិស័យរបស់ព្រះជាម្ចាស់បាន (អភ ៣, ១០)។

អស់អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យប្រតិបត្តិតាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ និងដែលសច្ចាប្រណិធានកាន់តាមយ៉ាងស្មោះ ក៏សម្តែងព្រះអំណោយទានម្យ៉ាងក្នុងចំណោមព្រះអំណោយទានទាំងនោះ គឺពួកគាត់ថ្វាយខ្លួនទៅព្រះអម្ចាស់យ៉ាងពិសេស សុខចិត្តដើរតាមគំរូព្រះគ្រីស្តដែលរស់នៅជាព្រហ្មចារី និងជាអ្នកក្រីក្រ (មថ ៨, ២០; លក ៩, ៥៨)។ ព្រះអង្គក៏ធ្វើតាមព្រះបញ្ជាព្រះបិតា រហូតដល់បូជាព្រះជន្មនៅលើឈើឆ្កាង (ភល ២, ៨) ទ្រង់បានរំដោះមនុស្សលោក និងប្រោសឲ្យគេបានវិសុទ្ធទៀតផង។ ព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរសេចក្តីស្រឡាញ់ក្នុងចិត្តគាត់ (រម ៥, ៥) ហើយសេចក្តីស្រឡាញ់នោះ ជំរុញពួកគាត់ឲ្យរស់នៅតាមមាគ៌ានេះ។ គាត់រស់នៅដោយថ្វាយខ្លួនទៅព្រះគ្រីស្តឲ្យកាន់តែខ្លាំងឡើងៗ និងដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ដែលជាព្រះកាយព្រះអង្គ (កូឡ ១, ២៤)។ ហេតុនេះហើយ បានជាគាត់រួមរស់ជាមួយព្រះគ្រីស្ត ដោយថ្វាយខ្លួនក្នុងគ្រប់វិស័យនៃការរស់នៅរបស់គេឲ្យកាន់តែជ្រាលជ្រៅឡើងៗយ៉ាងណា ព្រះសហគមន៍ក៏មានជីវិតរស់រវើក ហើយអាចបំពេញបេសកកម្មរបស់ខ្លួន ទាំងបង្កើតផលកាន់តែប្រសើរ និងច្រើនឡើងយ៉ាងនោះដែរ។

មហាសន្និបាតចាត់ចែងសេចក្តីដូចខាងក្រោមនេះ ដើម្បីឲ្យព្រះសហគមន៍នាបច្ចុប្បន្ន ទាញយកផលឲ្យកាន់តែច្រើនពីការរស់នៅដ៏ប្រសើររបស់បព្វជិត បព្វជិតា ដែលសច្ចាប្រណិធានកាន់តាមដំបូន្មាន ចែងក្នុងគម្ពីរដំណឹងល្អនោះ។ ព្រះសហគមន៍ពិតជាត្រូវការបព្វជិតបព្វជិតា។ សេចក្តីខាងក្រោមនេះ គ្រាន់តែជាគោលការណ៍ទូទៅសម្រាប់កែសម្រួលការរស់នៅនិងវិន័យគ្រឹះស្ថានរបស់បព្វជិតបព្វជិតាឲ្យបានជាថ្មីប៉ុណ្ណោះ។ គោលការណ៍ទូទៅទាំងនោះក៏ត្រូវយកមកកែសម្រួលដល់ការរស់នៅរបស់ក្រុមអ្នកដែលរស់នៅជាមួយគ្នា ដោយមិនធ្វើពីធីសច្ចាប្រណិធានដែរ ព្រមទាំងរបស់ក្រុមគ្រីស្តបរិស័ទដែលរស់នៅក្នុងសង្គម ស្របតាមលក្ខណៈរបស់ក្រុមនីមួយៗនោះដែរ។ ក្រោយពេលមហាសន្និបាតនេះ ចប់ទៅហើយ អាជ្ញាធរព្រះសហគមន៍ដែលមានសមត្ថកិច្ច ត្រូវចាត់ចែងសេចក្តីណែនាំផ្សេងៗ ដោយឡែក ដើម្បីបព្វជិតបព្វជិតាអនុវត្តតាមគោលការណ៍ទូទៅទាំងនោះយ៉ាងប្រាកដប្រជា។

## ២-គោលការណ៍ទូទៅសម្រាប់កែសម្រួលឲ្យបានជាថ្មីស្របតាមបច្ចុប្បន្ន

នៅពេលកែសម្រួលការរស់នៅរបស់បព្វជិតបព្វជិតាឲ្យបានជាថ្មី ស្របតាមបច្ចុប្បន្នកាល ម្យ៉ាងត្រូវនឹកគិតជានិច្ចដល់ប្រភពនៃការរស់នៅជាគ្រីស្តបរិស័ទទូទៅ ហើយក៏ត្រូវនឹកគិតដល់គោលគំនិតអ្នកបង្កើតគ្រឹះស្ថានបព្វជិតបព្វជិតាទាំងនោះដែរ។ ម្យ៉ាងទៀត ត្រូវគិតគូរធ្វើឲ្យគ្រឹះស្ថានបព្វជិតបព្វជិតាទាំងនោះបានស្របតាមសភាពការណ៍ថ្មីៗរបស់មនុស្សរស់នៅនាបច្ចុប្បន្នកាល។ ត្រូវកែសម្រួលការរស់នៅជាបព្វជិតបព្វជិតា ដោយព្រះវិញ្ញាណដ៏វិសុទ្ធជំរុញឲ្យកែសម្រួលផង និងដោយមានព្រះសហគមន៍ណែនាំផង តាមគោលការណ៍ដូចតទៅ៖

ក- បព្វជិតបព្វជិតាត្រូវកាន់តាមគោលការណ៍តែមួយដ៏សំខាន់បំផុត គឺដើរតាមព្រះគ្រីស្តស្របតាមសេចក្តីបង្រៀន ចែងក្នុងគម្ពីរដំណឹងល្អ។ គ្រឹះស្ថានបព្វជិតបព្វជិតាទាំងអស់ត្រូវចាត់គោលការណ៍នេះ ទុកជាគោលដ៏សំខាន់ជាងគេបំផុត។

ខ- គ្រឹះស្ថានបព្វជិតបព្វជិតា មានលក្ខណៈនិងមានមុខនាទីដោយឡែករៀងៗខ្លួន ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍។ ហេតុនេះហើយបានជា នៅពេលកែសម្រួល ត្រូវលាតត្រដាងគោលគំនិតអ្នកបង្កើតគ្រឹះស្ថានឲ្យបានជាក់ច្បាស់ និងត្រូវកាន់តាមគោលគំនិតគាត់ដោយចិត្តស្មោះ ត្រូវយល់អំពីបំណងប្រាថ្នាពិសេសរបស់អ្នកបង្កើតនោះ និងកាន់តាមប្រពៃណីដ៏វិសុទ្ធដែលជាបេតិកភ័ណ្ឌរបស់ក្រុមគ្រួសារនីមួយៗ។

គ-គ្រឹះស្ថានបព្វជិតបព្វជិតាទាំងអស់ ត្រូវរួបរួមក្នុងការរស់នៅរបស់ព្រះសហគមន៍យ៉ាងជិតស្និទ្ធ គឺត្រូវយកចិត្តទុកដាក់ទទួលយកនិងគាំទ្រគោលបំណង និងសេចក្ដីដែលព្រះសហគមន៍សម្រេចនឹងធ្វើ ដោយអស់ពីសមត្ថភាពក្នុងវិស័យព្រះគម្ពីរ ក្នុងវិស័យគោលលទ្ធិ វិស័យណែនាំគ្រីស្តបរិស័ទ បង្រួបបង្រួមគ្រីស្តបរិស័ទនិកាយផ្សេងៗ ក្នុងកិច្ចជាសាសនទូត និងសកម្មភាពក្នុងសង្គម តាមលក្ខណៈផ្ទាល់របស់គ្រឹះស្ថានបព្វជិតបព្វជិតាទាំងនោះ ។

ឃ-គ្រឹះស្ថានបព្វជិតបព្វជិតា ត្រូវខិតខំណែនាំឲ្យសមាជិករបស់ខ្លួនស្គាល់ជីវភាពមនុស្សនាបច្ចុប្បន្ន យ៉ាងគ្រប់គ្រាន់ និងស្គាល់តម្រូវការរបស់ព្រះសហគមន៍ដែរ។ ដូច្នេះគេអាចវិនិច្ឆ័យដោយប្រាជ្ញា ក្រោមពន្លឺនៃជំនឿ អំពីលក្ខណៈពិសេសនៃមនុស្សលោកនាសម័យបច្ចុប្បន្ននេះ។ គេមុខជានឹងមានចិត្តខ្នះខ្នែងយ៉ាងពេញទំហឹងបែបគ្រីស្តទូត នឹងមានសមត្ថភាពអាចនាំជំនួយដ៏ស័ក្តិសិទ្ធិជាង ដល់មនុស្សលោកទៀតផង។

ង- ការរស់នៅរបស់បព្វជិតបព្វជិតាតម្រង់ទៅរកគោលដៅចម្បងតែមួយ គឺនាំឲ្យអស់បព្វជិតបព្វជិតាដើរតាមព្រះគ្រីស្ត និងរួមរស់ជាមួយព្រះជាម្ចាស់ ដោយធ្វើពិធីសច្ចាប្រណិធានថា នឹងកាន់តាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ។ ហេតុនេះ ត្រូវយល់ឃើញយ៉ាងច្បាស់ថា ការកែសម្រួលដ៏ល្អជាងគេបំផុតឲ្យបានស្របតាមតម្រូវការនៃបច្ចុប្បន្នកាល នឹងបានលទ្ធផលល្អ លុះត្រាតែបព្វជិតបព្វជិតាប្រែចិត្តគំនិតតាមព្រះវិញ្ញាណ។ សូម្បីក្នុងការអភិវឌ្ឍន៍សកម្មភាពខាងក្រៅគ្រឹះស្ថាន ក៏ការប្រែចិត្តគំនិតតាមព្រះវិញ្ញាណមានសារៈសំខាន់ជាងគេដែរ។

## ៣-គោលការណ៍សម្រាប់កែសម្រួលគ្រឹះស្ថានតាមតម្រូវការនាបច្ចុប្បន្ន

ត្រូវចាត់ចែងការរស់នៅ ការអធិដ្ឋាន សកម្មភាពផ្សេងៗ ស្របតាមសុខភាពទាំងខាងរូបកាយ ទាំងខាងផ្លូវចិត្តរបស់បព្វជិតបព្វជិតានាបច្ចុប្បន្ន ព្រមទាំងស្របតាមតម្រូវការនៃកិច្ចជាគ្រីស្តទូត (ប្រសិនបើ លក្ខណៈផ្ទាល់របស់គ្រឹះស្ថាននីមួយៗត្រូវការ) សមស្របតាមអរិយធម៌ តាមសភាពការណ៍ក្នុងសង្គម និងតាមសភាពការណ៍សេដ្ឋកិច្ចដែរ។ ត្រូវអនុវត្តដូច្នេះនៅគ្រប់ទីកន្លែង ជាពិសេសនៅប្រទេសណាដែលមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។

ត្រូវរិះគិតពិចារណាអំពីរបៀបណែនាំគ្រឹះស្ថាននីមួយៗ តាមគោលការណ៍ទាំងនោះ។ ហេតុនេះ ត្រូវកែសម្រួលធម្មនុញ្ញ កែសម្រួលក្បួនប្រពៃណី ក្បួនទំនៀមទម្លាប់ សៀវភៅធម៌ ក្បួនពិធី និងសៀវភៅបែបដដែលនេះ។ ក្នុងសៀវភៅទាំងនោះ ត្រូវដកចេញអ្វីៗដែលហួសសម័យ ដោយគិតឲ្យបានស្របតាមឯកសារទាំងប៉ុន្មាននៃមហាសន្និបាតវិញ។

## ៤-អ្នកមានមុខនាទីកែសម្រួលឲ្យបានជាថ្មីសមស្របតាមសម័យ

សមាជិកទាំងអស់ក្នុងគ្រឹះស្ថាននីមួយៗត្រូវចូលរួមក្នុងការកែសម្រួលឲ្យបានជាថ្មីសមស្របតាមសម័យ ទើបការកែសម្រួលនោះបានស័ក្តិសិទ្ធិ និងល្អត្រឹមត្រូវ។ ប៉ុន្តែ មានតែអាជ្ញាធម៌ដែលមានសមត្ថកិច្ចទេ ជាពិសេសអង្គប្រជុំទូទៅ

ដែលអាចបញ្ជាក់សេចក្ដីណែនាំ តែងតាំងវិន័យនិងច្បាប់ថ្មី ព្រមទាំងមានសិទ្ធិទទួលយកបទពិសោធន៍ អស់រយៈពេលវែងល្មម ដែលគេប្រព្រឹត្តដោយប្រុងប្រយ័ត្នទៀតផង។ ប្រសិនបើត្រូវការស្របតាមក្បួនច្បាប់ទូទៅនៃព្រះសហគមន៍អាជ្ញាធរ ត្រូវទទួលការអនុញ្ញាតពីសន្ដអាសនៈឬពីអភិបាលភូមិភាគ។ អំពីករណីពាក់ព័ន្ធនឹងសមាជិកគ្រឹះស្ថានទាំងមូល ក្រុមមេដឹកនាំ ត្រូវសួរយោបល់របស់សមាជិកគ្រឹះស្ថាននោះយ៉ាងសមរម្យ តាមសេចក្ដីត្រូវការ ហើយត្រូវស្ដាប់តាមយោបល់របស់គេទៀតផង។

ចំពោះការកែសម្រួលការរស់នៅរបស់បព្វជិតាដែលរស់នៅក្នុងអារាម ត្រូវប្រមូលសំណូមពរ និងយោបល់អង្គប្រជុំនៃសហព័ន្ធអារាម និងអង្គប្រជុំឯទៀតៗដែលត្រូវកោះហៅយ៉ាងត្រឹមត្រូវតាមច្បាប់ព្រះសហគមន៍។ ប៉ុន្តែ ត្រូវនឹកចងចាំជានិច្ចថា ត្រូវតែកាន់តាមវិន័យ ឬតាមធម្មនុញ្ញរបស់ខ្លួន ដោយចិត្តកាន់តែស្មោះ ទើបមានសេចក្ដីសង្ឃឹមថានឹងកែសម្រួលឲ្យបានជាថ្មីយ៉ាងប្រសើរជាង កែសម្រួលដោយបង្កើតច្បាប់និងវិន័យជាច្រើនទៅវិញ។

## ៥-កត្តារួមក្នុងរបៀបរស់នៅរបស់បព្វជិតបព្វជិតា

បព្វជិតបព្វជិតាគ្រប់គ្រឹះស្ថាន ត្រូវនឹកចងចាំជាអាទិ៍ថា នៅពេលគេធ្វើពិធីសច្ចាប្រណិធាន កាន់តាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ គាត់បានតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគាត់។ ហេតុនេះហើយ បានជាគាត់មិនគ្រាន់តែលែងជំពាក់ជំពិននឹងអំពើបាបប៉ុណ្ណោះទេ (រម ៦, ១១) តែគាត់ក៏លះបង់លោកីយ៍ ហើយរស់នៅដោយញែកខ្លួនថ្វាយព្រះជាម្ចាស់តែមួយព្រះអង្គគត់ថែមទៀតផង។ គាត់បូជាកម្លាំងកាយកម្លាំងចិត្តថ្វាយខ្លួនបម្រើព្រះអង្គ។ ការញែកខ្លួនថ្វាយព្រះអង្គយ៉ាងពិសេសបែបនេះ ភ្ជាប់យ៉ាងជិតស្និទ្ធនឹងការញែកខ្លួនថ្វាយព្រះអង្គនៅពេលគាត់ទទួលអគ្គសញ្ញាជ្រមុជទឹក ដែលជាគ្រឹះ។ នៅពេលធ្វើពិធីសច្ចាប្រណិធាននោះ គាត់បញ្ជាក់ឲ្យបានច្បាស់យ៉ាងពេញលេញថា គាត់ញែកខ្លួនថ្វាយព្រះជាម្ចាស់ នៅពេលគាត់ទទួលអគ្គសញ្ញាជ្រមុជទឹកនោះរួចហើយ។

ដោយព្រះសហគមន៍ទទួលស្គាល់ថា គាត់ញែកខ្លួនថ្វាយព្រះជាម្ចាស់ដូច្នេះ បព្វជិតបព្វជិតាត្រូវដឹងថា ខ្លួនក៏ភ្ជាប់នឹងការបម្រើព្រះសហគមន៍ដែរ។

អ្នកបម្រើព្រះជាម្ចាស់បែបនេះ ត្រូវតែប្រតិបត្តិតាមគុណធម៌ ជាពិសេស សុខចិត្តដាក់ខ្លួន សុខចិត្តស្ដាប់បង្គាប់មេដឹកនាំមានកម្លាំងចិត្ត និងរស់នៅជាព្រហ្មចារី។ កិច្ចបម្រើព្រះអង្គបែបនេះ ក៏ជួយគាំទ្រគាត់ឲ្យមានគុណធម៌ទាំងនោះថែមទៀត។ គុណធម៌ទាំងនោះបណ្ដាយឲ្យបព្វជិតបព្វជិតារួមរស់ជាមួយព្រះគ្រីស្តដែលលះបង់ឋានៈរបស់ព្រះអង្គ (ភល ២, ៧-៨) ហើយនៅពេលជាមួយគ្នានេះ ធ្វើឲ្យគេរួមជាមួយព្រះគ្រីស្តដែលមានព្រះជន្មគង់នៅក្នុងព្រះវិញ្ញាណ (រម ៨, ១-១៣)។

ហេតុនេះ សូមឲ្យបព្វជិតបព្វជិតាកាន់តាមពិធីសច្ចាប្រណិធានរបស់ខ្លួនយ៉ាងស្មោះត្រង់ គឺសុខចិត្តលះបង់អ្វីៗទាំងអស់ព្រោះតែព្រះគ្រីស្ត (មក ១០, ២៨) សុខចិត្តដើរតាមព្រះអង្គទុកជា *"អ្វីដែលគាត់ត្រូវការដ៏ចាំបាច់តែមួយនោះ"* (លក ១០, ៤២; មថ ១ក៩, ២១) ស្ដាប់ព្រះបន្ទូលព្រះអង្គ (លក ១៩, ៣៩) ហើយខ្វល់ខ្វាយតែនឹងអ្វីៗ ដែលទាក់ទិនតែនឹងព្រះអង្គប៉ុណ្ណោះ (១ករ ៧, ៣២)។

ហេតុនេះហើយបានជា សមាជិកគ្រប់គ្រឹះស្ថានត្រូវស្វែងរកព្រះជាម្ចាស់តែមួយព្រះអង្គគត់ គឺស្មឹងស្មាធិ៍ភ្ជាប់ទាំងចិត្តគំនិត ទាំងវិញ្ញាណជាមួយព្រះអង្គ ហើយនៅពេលជាមួយគ្នានោះ មានចិត្តស្រឡាញ់ជំរុញគាត់ឲ្យទៅជាគ្រីស្តទូត

ផងដែរ។ គាត់ខិតខំរួមជាមួយព្រះគ្រីស្តដែលរំដោះមនុស្សលោក ហើយក៏យកចិត្តទុកដាក់លាតត្រដាងព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ។

## ៦-ការរស់នៅតាមព្រះវិញ្ញាណមានសារៈសំខាន់ជាងគេបំផុត

សូមឲ្យអស់លោកអ្នកដែលធ្វើពិធីសច្ចាប្រណិធាន កាន់តាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ ស្វះស្វែងរកព្រះជាម្ចាស់ និងស្រឡាញ់ព្រះអង្គលើសអ្វីៗទាំងអស់ គឺស្រឡាញ់ព្រះអង្គដែលស្រឡាញ់យើងជាមុន (១យហ ៤, ១០)។ ក្នុងគ្រប់កាលៈទេសៈ សូមឲ្យគាត់យកចិត្តទុកដាក់រួមរស់ជាមួយព្រះគ្រីស្ត ដែលមានព្រះជន្មកប់ទុកក្នុងព្រះជាម្ចាស់ (កឡ ៣, ៣)។ សេចក្តីស្រឡាញ់ចំពោះអ្នកដ៏ទៃ ហូរចេញពីជីវិតកប់ទុកក្នុងព្រះជាម្ចាស់នោះ ហើយជំរុញគាត់ឲ្យសង្គ្រោះមនុស្សលោក និងឲ្យកសាងព្រះសហគមន៍។ សេចក្តីស្រឡាញ់បញ្ចាបព្វជិតបព្វជិតាឲ្យប្រតិបត្តិតាមព្រះដំបូន្មានដែលចែងក្នុងគម្ពីរដំណឹងល្អយ៉ាងសកម្ម និងយ៉ាងរស់រវើកទៀតផង។

ហេតុនេះហើយ បព្វជិតបព្វជិតាត្រូវខិតខំឲ្យមានចិត្តគំនិតព្យាយាមចង់ស្ទឹងស្មាធិ៍ជានិច្ច ហើយក៏ស្ទឹងស្មាធិ៍ពិតមែនដែរ គឺគាត់ត្រូវយោងជីវិតខាងព្រះវិញ្ញាណបែបគ្រីស្តបរិស័ទពីប្រភពដ៏ពិតប្រាកដនេះ។ មុនដំបូង ជារៀងរាល់ថ្ងៃគាត់ត្រូវកាន់គម្ពីរ ដើម្បីស្រង់យកចំណេះ *"ដ៏ប្រសើរវិសេសវិសាលបំផុតអំពីព្រះយេស៊ូគ្រីស្ត"* (ភល ៣, ៨) ដោយអាន និងនឹកសញ្ជឹងគិតពីព្រះគម្ពីរនោះ។ បព្វជិតបព្វជិតាត្រូវធ្វើពិធីគោរពប្រណិប័តន៍ដ៏វិសុទ្ធរៀងរាល់ថ្ងៃ ជាពិសេសចូលរួមក្នុងគម្រោងការដ៏អស្ចារ្យនៃអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធបំផុត ពោលគឺក្នុងអភិបូជា។ គាត់ត្រូវអធិដ្ឋានស្របតាមគោលគំនិតរបស់ព្រះសហគមន៍ដោយចិត្តស្មោះ មិនគ្រាន់តែដោយទន្ទេញចាំសូត្រដោយរត់មាត់ប៉ុណ្ណោះទេ។ គាត់មុខជានឹងទទួលជីវិតតាមព្រះវិញ្ញាណពីប្រភពនេះដែលមិនចេះរីងស្ងួតឡើយ។

ក្រោយពីបព្វជិតបព្វជិតាទទួលទានអាហារពីតុ នៃព្រះគម្ពីររបស់ព្រះជាម្ចាស់ផង និងនៃយញ្ញដ៏សក្ការៈផងរួចហើយ គាត់ត្រូវស្រឡាញ់សរីរាង្គរបស់ព្រះគ្រីស្តទុកជាបងប្អូន ត្រូវគោរពនិងស្រឡាញ់អស់លោកគង្វាលព្រះសហគមន៍ដូចជាកូនស្រឡាញ់ឪពុកដូច្នោះដែរ។ គាត់បព្វជិតបព្វជិតា ត្រូវរស់នៅ និងនឹកគិតរួមជាមួយព្រះសហគមន៍កាន់តែជិតស្និទ្ធឡើងៗ និងបូជាកម្លាំងកាយកម្លាំងចិត្តបំពេញបេសកកម្មរបស់ព្រះសហគមន៍ទៀតផង។

## ៧-គ្រឹះស្ថានដែលមានទិសដៅស្ទឹងស្មាធិ៍ធ្វើសមាធិ

គ្រឹះស្ថានណាដែលមានទិសដៅតែស្ទឹងស្មាធិ៍ធ្វើសមាធិប៉ុណ្ណោះ ទោះបី មានតម្រូវការដ៏ចាំបាច់ជាបន្ទាន់ឲ្យបំពេញកិច្ចជាគ្រីស្តទូតយ៉ាងសកម្មយ៉ាងណាក្តី ក៏ត្រូវរក្សាទុកមុខងារពិសេសរបស់ខ្លួនក្នុងព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត គឺក្នុងព្រះកាយនោះ *"សរីរាង្គគ្មានមុខងារតែមួយដដែលទេ"* (រម ១២, ៤)។ បព្វជិតបព្វជិតាទាំងនោះគិតតែអំពីកិច្ចរបស់ព្រះជាម្ចាស់ជានិច្ចរស់នៅម្នាក់ឯង និងនៅស្ងៀមស្ងាត់ ព្យាយាមអធិដ្ឋាន និងធ្វើទុក្ករកិរិយាយ៉ាងសប្បាយរីករាយ។ បព្វជិតបព្វជិតាទាំងនេះ ថ្វាយសក្ការបូជាដ៏ប្រសើរឧត្តម គឺលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ។ គាត់ផ្តល់ឈ្មោះល្បីដល់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដោយបង្ហាញផលផ្លែដ៏វិសុទ្ធជាច្រើន គាត់នាំប្រជារាស្ត្រនោះ ឲ្យយកគម្រាប់តាម និងធ្វើឲ្យប្រជារាស្ត្រនោះចម្រើនចំនួនឡើង គឺគាត់បង្កើតជីវិតតាមរបៀបដ៏ស្ងាត់កំបាំង។ បព្វជិតបព្វជិតាទាំងនោះពិតជាកិត្តិយសរបស់ព្រះសហគមន៍ និងនាំព្រះជាម្ចាស់ប្រណីសន្តោសព្រះសហគមន៍ជាខ្លាំងផងដែរ។

ប៉ុន្តែ គួរឲ្យកែសម្រួលរបៀបរស់នៅរបស់គាត់ តាមគោលការណ៍ និងតាមលក្ខណៈដូចខាងលើ ឲ្យបានស្របតាមសម័យឥឡូវ។ ក៏ប៉ុន្តែ បព្វជិតបព្វជិតាទាំងនោះត្រូវរស់នៅដោយឡែកពីលោកីយ៍ជាដាច់ខាត និងត្រូវរក្សាទុកកិច្ចគោរពប្រណិប័តន៍ផ្សេងៗផ្ទាល់នៃការរស់នៅជាបព្វជិតបព្វជិតាដែលស្មឹងស្មាធ៏ធ្វើសមាធិនោះជានិច្ចដែរ។

## ៨-គ្រឹះស្ថានដែលមានទិសដៅបំពេញកិច្ចជាគ្រីស្តទូត

ក្នុងព្រះសហគមន៍មានគ្រឹះស្ថានជាច្រើន ដែលមានសមាជិកជាបូជាចារ្យ (អាចារ្យ) ឬជាគ្រីស្តបរិស័ទធម្មតាដែលបូជាកម្លាំងកាយ កម្លាំងចិត្ត បំពេញកិច្ចផ្សេងៗជាគ្រីស្តទូត។ ពួកគេទទួលព្រះអំណោយទានផ្សេងៗពីគ្នា តាមព្រះជាម្ចាស់ប្រណីសន្តោស គឺឲ្យអ្នកបម្រើចេះបម្រើ ឲ្យអ្នកបង្រៀនចេះបង្រៀន ឲ្យអ្នកដាស់តឿនចេះដាស់តឿន ឲ្យអ្នកចែកអំណោយមានចិត្តទូលាយ ឲ្យអ្នកមានចិត្តមេត្តាចែកទានដោយអំណររីករាយ (រម ១២, ៥-៨)។ "មានព្រះអំណោយទានផ្សេងៗពីគ្នា តែមានព្រះវិញ្ញាណតែមួយដែលបំពេញកិច្ចការទាំងអស់" (១ករ ១២, ៤)។ ក្នុងគ្រឹះស្ថានទាំងនោះ កិច្ចការជាគ្រីស្តទូត ឬកិច្ចការបង្ហាញមេត្តាករុណា ហាក់ដូចជាមុខងារបម្រើដ៏វិសុទ្ធរបស់គាត់ និងជាកិច្ចការពិសេសនៃមេត្តាករុណា ដែលព្រះសហគមន៍បានផ្ញើឲ្យគាត់បំពេញក្នុងនាមរបស់ខ្លួន តាមលក្ខណៈផ្ទាល់នៃការរស់នៅជាបព្វជិតបព្វជិតា។ ហេតុនេះហើយ បានជាចិត្តគំនិតជាគ្រីស្តទូតត្រូវជ្រួតជ្រាបចិត្តគំនិត និងការរស់នៅរបស់បព្វជិតបព្វជិតា ជាសមាជិកនៃគ្រឹះស្ថានទាំងនោះ ហើយចិត្តគំនិតជាបព្វជិតបព្វជិតា ក៏ត្រូវជ្រួតជ្រាបគ្រប់កិច្ចជាគ្រីស្តទូតរបស់គាត់ថែមទៀតដែរ។ អស់អ្នកដែលមានបំណងប្រាថ្នាចង់តបឆ្លើយនឹងព្រះគ្រីស្ត ដែលត្រាស់ហៅគេឲ្យដើរតាមព្រះអង្គ និងចង់បម្រើព្រះគ្រីស្តផ្ទាល់ដោយបម្រើសរីរាង្គនៃព្រះកាយព្រះអង្គ ត្រូវធ្វើសកម្មភាពជាគ្រីស្តទូតនោះ ដោយភ្ជាប់ចិត្តយ៉ាងជិតស្និទ្ធជាមួយព្រះគ្រីស្តទុកជាប្រភព។ ប្រសិនបើគាត់រួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះគ្រីស្តដូច្នេះ គាត់មុខជាស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកដទៃកាន់តែខ្លាំងឡើងៗពុំខាន។

ហេតុនេះហើយ បានជាគ្រឹះស្ថានទាំងនោះ ត្រូវកែសម្រួលវិន័យ និងប្រពៃណីរបស់ខ្លួនដោយសុភវិនិច្ឆ័យ តាមតម្រូវការនៃភារកិច្ចជាគ្រីស្តទូតរបស់គេផ្ទាល់។ ប៉ុន្តែ ដោយបព្វជិតបព្វជិតាបូជាកម្លាំងកាយកម្លាំងចិត្តបំពេញកិច្ចការជាគ្រីស្តទូតតាមបែបច្រើនប្លែកៗពីគ្នា នោះត្រូវកែសម្រួលការរស់នៅជាបព្វជិតបព្វជិតាឲ្យបានស្របតាមបែបផ្សេងៗទាំងនោះដែរ។ ក្នុងគ្រឹះស្ថានទាំងនោះ ត្រូវចាត់ចែង និងគាំទ្រការរស់នៅរបស់បព្វជិតបព្វជិតាដែលបម្រើព្រះគ្រីស្ត ដោយប្រើមធ្យោបាយរបស់គាត់ផ្ទាល់ និងស្របតាមរបៀបរស់នៅរបស់គាត់ដែរ។

## ៩-ត្រូវរក្សាទុកការរស់នៅរបស់បព្វជិតបព្វជិតាឲ្យរស់នៅក្នុងអារាម

សូមរក្សាទុកយ៉ាងស្មោះ នូវស្ថាប័នដ៏ប្រសើរគួរគោរពរបស់បព្វជិតបព្វជិតា ដែលមានគុណយ៉ាងលើសលប់ លើព្រះសហគមន៍ និងលើសង្គមមនុស្សតាំងពីដើមរៀងមក ទាំងនៅបស្ចិមប្រទេស ទាំងមជ្ឈិមប្រទេសដែរ។ សូមសម្តែងគោលគំនិតដ៏ពិតប្រាកដនៃរបៀបរស់នៅរបស់បព្វជិតបព្វជិតារស់នៅក្នុងអារាម។ អស់លោកអ្នកមានតួនាទីដ៏សំខាន់ជាងគេ គឺមុខងារដ៏សុភាពរាបសានិងឧត្តុង្គឧត្តម បម្រើព្រះជាម្ចាស់ដ៏ថ្កុំថ្កើង នៅក្នុងអារាមរបស់អស់លោកអ្នក ទោះបីអស់លោកអ្នកបូជាកម្លាំងកាយ កម្លាំងចិត្តទាំងស្រុង គោរពបម្រើព្រះជាម្ចាស់ដោយស្ងាត់ៗ លាក់កំបាំងក្នុងអារាមក្តី ឬទទួលខុសត្រូវយ៉ាងត្រឹមត្រូវលើកិច្ចការជាគ្រីស្តទូតមួយណាក្តី ឬធ្វើកិច្ចការមេត្តាករុណាមួយក្តី ក៏តួនាទីដ៏សំខាន់ជាងគេរបស់អស់លោកអ្នក គឺបម្រើព្រះជាម្ចាស់ដ៏ថ្កុំថ្កើងដែរ។ ហេតុនេះ បព្វជិតបព្វជិតាត្រូវរក្សាលក្ខណៈផ្ទាល់របស់អស់លោកអ្នក ប៉ុន្តែ ត្រូវកែសម្រួលប្រពៃណីពីបុរាណក្នុងកិច្ចការសម្តែងមេត្តាករុណា ឲ្យបានសមស្របតាមតម្រូវការរបស់មនុស្ស

លោកនាបច្ចុប្បន្ន។ ធ្វើដូច្នេះ អារាមអាចក្លាយទៅជាទីកន្លែងដ៏មានជីវិតរស់រវើក អប់រំណែនាំប្រជាជនគ្រីស្តបរិស័ទបាន។

យ៉ាងណាមិញ មានសហគមន៍បព្វជិតបព្វជិតាខ្លះ ភ្ជាប់ការរស់នៅជាគ្រីស្តទូតយ៉ាងជិតស្និទ្ធទៅនឹងកិច្ចការលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់រួមគ្នាក្នុងអារាម ហើយក៏ភ្ជាប់នឹងការកាន់តាមក្បួនវិន័យជាសង្ឃកាតូលិកដែរ ស្របតាមធម្មនុញ្ញ ឬតាមស្ថាប័នរបស់គាត់។ សហគមន៍ទាំងនោះត្រូវកែសម្រួលរបៀបរស់នៅរបស់ខ្លួនឲ្យបានស្របតាមតម្រូវការនៃកិច្ចការជាគ្រីស្តទូតយ៉ាងសមរម្យ ទាំងរក្សាទុកនូវរបៀបរស់នៅរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ផង។

## ១០-ការរស់នៅរបស់គ្រីស្តបរិស័ទធម្មតាដែលញែកខ្លួនថ្វាយព្រះជាម្ចាស់

គ្រីស្តបរិស័ទធម្មតាខ្លះ ទាំងបុរសទាំងស្ត្រី ញែកខ្លួនថ្វាយព្រះជាម្ចាស់។ ការរស់នៅរបស់គេមានលក្ខណៈពេញលេញជាអ្នកធ្វើពិធីសច្ចាប្រណិធានកាន់តាមដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ។ របៀបរស់នៅបែបនេះ មានសារៈសំខាន់គឺជួយព្រះសហគមន៍ឲ្យបំពេញបន្ទុកណែនាំរបស់ខ្លួន ក្នុងការអប់រំយុវជន ព្យាបាលអ្នកជំងឺ និងបំពេញមុខងារផ្សេងៗទៀតផង។ មហាសន្និបាតសូមគោរពរបៀបរស់នៅបែបនេះយ៉ាងខ្លាំង ហើយបញ្ជាក់គាំទ្រសមាជិកក្រុមទាំងនោះ ឲ្យដឹងថា ព្រះជាម្ចាស់ត្រាស់ហៅគេមែន ព្រមទាំងដាស់តឿនគេឲ្យកែសម្រួលរបៀបរស់នៅរបស់គេ ឲ្យបានស្របតាមតម្រូវការមនុស្សលោកនាបច្ចុប្បន្ន។

មហាសន្និបាតសូមប្រកាសថា គ្មានអ្វីអាចជំទាស់មិនឲ្យបងប្អូនបព្វជិតខ្លះ ដែលជាសមាជិកគ្រឹះស្ថានទាំងនោះទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ដើម្បីជួយផ្គត់ផ្គង់តម្រូវការខាងមុខងារបម្រើគ្រឹះស្ថានរបស់គេ។ អង្គប្រជុំទូទៅនៃគ្រឹះស្ថានអាចចាត់ចែងដូច្នេះបាន ក៏ប៉ុន្តែត្រូវរក្សាទុកនូវលក្ខណៈជាគ្រីស្តបរិស័ទធម្មតារបស់គ្រឹះស្ថានទាំង នោះជាដាច់ខាត។

## ១១-ក្រុមគ្រីស្តបរិស័ទរស់នៅក្នុងសង្គម

គ្រឹះស្ថានគ្រីស្តបរិស័ទរស់នៅក្នុងសង្គម ទោះបីមិនមែនជាគ្រឹះស្ថានបព្វជិតបព្វជិតាក្តី ក៏សមាជិកគ្រឹះស្ថានទាំងនោះធ្វើពិធីសច្ចាប្រណិធានយ៉ាងពិតប្រាកដ និងយ៉ាងពេញលេញដែរ។ គេរស់នៅក្នុងសង្គមទាំងកាន់តាមព្រះដំបូន្មានចែងទុកក្នុងគម្ពីរដំណឹងល្អ។ ពិធីសច្ចាប្រណិធាននោះ ញែកទាំងបុរស និងស្ត្រី ទាំងគ្រីស្តបរិស័ទធម្មតា ទាំងបូជាចារ្យ (អាចារ្យ) ដែលរស់នៅក្នុងសង្គម ឲ្យថ្វាយខ្លួនទៅព្រះជាម្ចាស់ពិតមែន។ ហេតុនេះ អ្នកទាំងនោះត្រូវយកចិត្តទុកដាក់តម្រង់ខ្លួនទាំងស្រុងថ្វាយព្រះអង្គ ដោយមានចិត្តស្រឡាញ់យ៉ាងពេញលក្ខណៈ ហើយត្រូវរក្សាទុកលក្ខណៈពិសេសនៃគ្រឹះស្ថានរបស់គេ ជាក្រុមអ្នករស់នៅក្នុងសង្គម។ ដូច្នេះពួកគេមានសមត្ថភាពអាចបំពេញមុខងាររបស់ខ្លួនជាគ្រីស្តទូតយ៉ាងស័ក្តិសិទ្ធិនៅគ្រប់កន្លែងក្នុងសង្គមបាន ដូចជានៅក្នុងផ្ទៃនៃសង្គម តាមគោលគំនិតអ្នកបង្កើតគ្រឹះស្ថានរបស់គេ។

សូមសមាជិកគ្រឹះស្ថានទាំងនោះជ្រាបឲ្យបានច្បាស់ថា គេអាចបំពេញបន្ទុករបស់ខ្លួនបាន លុះត្រាតែគេទទួលការអប់រំយ៉ាងមាំអំពីទេវវិទ្យា និងអំពីមនុស្សវិទ្យា ដើម្បីឲ្យគេទៅជាមេក្នុងចំណោមមនុស្សដូចមេក្នុងម្សៅ ព្រមទាំងធ្វើឲ្យព្រះកាយព្រះគ្រីស្តចម្រើនឡើង និងមានកម្លាំងកាន់តែមាំមួនឡើងផង។ ហេតុនេះហើយ បានជាសូមមេដឹកនាំគ្រឹះស្ថានទាំងនោះ យកចិត្តទុកដាក់យ៉ាងខ្លាំងឲ្យសមាជិកទទួលការអប់រំដ៏មាំនោះ ជាពិសេសឲ្យរស់នៅតាមព្រះវិញ្ញាណ ព្រមទាំងឲ្យគេទទួលការអប់រំបន្តបន្ទាប់តទៅទៀតផង។

## ១២-អំពីព្រហ្មចារិយធម៌

បព្វជិតបព្វជិតាធ្វើពិធីសច្ចាប្រណិធានរស់នៅជាព្រហ្មចារី *"ដោយយល់ឃើញដល់ព្រះរាជ្យ នៃស្ថានបរមសុខ"* (មថ ១៩, ១២)។ ត្រូវយល់ឃើញថា ការរស់នៅជាព្រហ្មចារី ពិតជាព្រះអំណោយទានដ៏ប្រសើររបស់ព្រះជាម្ចាស់ ដែលប្រណីសន្ដោសដល់គេ។ ការរស់នៅជាព្រហ្មចារីរំដោះមនុស្សឲ្យមានសេរីភាពតាមផ្លូវចិត្តយ៉ាងអស្ចារ្យ (១ករ ៧, ៣២-៣៥) ដើម្បីឲ្យគេអាចស្រឡាញ់ព្រះជាម្ចាស់ និងមនុស្សទាំងអស់ដោយអស់ពីសមត្ថភាព។ ហេតុនេះ ព្រហ្មចារីយធម៌ពិតជាសញ្ញាសម្គាល់អំពីសម្បត្តិនៃលោកខាងមុខ និងជាមធ្យោបាយមួយដ៏ស័ក្តិសិទ្ធណាស់ ជួយឲ្យបព្វជិតបព្វជិតា បូជាកម្លាំងកាយ កម្លាំងចិត្តទាំងស្រុងបម្រើព្រះជាម្ចាស់ និងបម្រើកិច្ចការនានាជាគ្រីស្តទូត។ គ្រីស្តបរិស័ទទាំងអស់ ដែលឃើញបព្វជិតបព្វជិតា អាចនឹកគិតដល់ព្រះសហគមន៍ដែលរួមរស់យ៉ាងអស្ចារ្យជាមួយព្រះគ្រីស្ត ជាស្វាមីតែមួយគត់ តាមព្រះជាម្ចាស់តែងតាំង និងដែលត្រូវលេចធ្លោឡើងយ៉ាងច្បាស់នៅលោកខាងមុខទៀតផង។

ហេតុនេះ សូមឲ្យបព្វជិតបព្វជិតាដែលយកចិត្តទុកដាក់ កាន់តាមពាក្យសច្ចាប្រណិធានរបស់ខ្លួនយ៉ាងស្មោះ សូមជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់ និងផ្ញើជីវិតលើព្រះជាម្ចាស់ដែលអាចជួយខ្លួនបាន។ កុំអួតអាងលើកម្លាំងរបស់ខ្លួនផ្ទាល់ឡើយ សូមធ្វើទុក្ករកិរិយា និងប្រយ័ត្នប្រយែងនឹងវិញ្ញាណទាំងប្រាំ។ កុំធ្វេសប្រហែសនឹងប្រើគ្រប់មធ្យោបាយ តាមធម្មជាតិ ដែលផ្តល់សុខភាពខាងផ្លូវចិត្ត និងខាងផ្លូវកាយ។ ធ្វើដូច្នេះ គេមិនរវើរវាយចិត្តស្ដាប់តាមទ្រឹស្តីក្លែងក្លាយ ដែលបង្រៀនថា មនុស្សគ្មានសមត្ថភាពរស់នៅជាព្រហ្មចារីយ៉ាងពេញលេញបានទេ ឬថាព្រហ្មចរិយធម៌រាំងមនុស្សមិនឲ្យចម្រើនឡើងបានដែរ។ បព្វជិតបព្វជិតាត្រូវលះបង់ចោលអ្វីៗទាំងអស់ ដែលប្រឆាំងនឹងព្រហ្មចរិយធម៌ឲ្យឆ្ងាយពីខ្លួន។ គាត់ត្រូវមានដួចសភាវគតិម៉្យាងខាងព្រះវិញ្ញាណ នៅក្នុងខ្លួនដែលជំរុញឲ្យគាត់លះបង់ចោលអ្វី ដែលប្រឆាំងនឹងព្រហ្មចារិយធម៌នោះ។ បព្វជិតបព្វជិតាទាំងអស់ ជាពិសេសមេដឹកនាំក្រុមគ្រួសារ ត្រូវនឹកចងចាំថា ខ្លួនអាចកាន់តាមព្រហ្មចរិយធម៌នេះបានយ៉ាងងាយស្រួល លុះត្រាតែបព្វជិតបព្វជិតាស្រឡាញ់គ្នាទៅវិញទៅមក រួមរស់នៅជាមួយគ្នាទុកជាបងប្អូនយ៉ាងពិតប្រាកដ។

ការរស់នៅជាព្រហ្មចារីយ៉ាងពេញលក្ខណៈ ជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសភាវគតិដ៏ជ្រៅបំផុតនៃលក្ខណៈរបស់មនុស្សយើង។ ហេតុនេះហើយ បានជាបេក្ខជនដែលមានបំណងប្រាថ្នា ចង់ធ្វើពិធីសច្ចាប្រណិធានរស់នៅជាព្រហ្មចារី ត្រូវសម្រេចចិត្តរស់តាមបែបនោះ ហើយមេដឹកនាំទទួលគេឲ្យធ្វើពិធីនោះបាន លុះត្រាតែគេត្រូវបានល្បងលមើលឲ្យរស់នៅជាព្រហ្មចារីអស់រយៈពេលជាយូរល្មមជាមុនសិន ហើយលុះត្រាតែគេជាមនុស្សពេញវ័យខាងផ្លូវចិត្ត គឺមានចិត្តធ្ងន់គ្រប់គ្រាន់។ មេដឹកនាំមិនគ្រាន់តែត្រូវជម្រាបគេជាមុនថា ការរស់នៅជាព្រហ្មចារីជាការពិបាកប៉ុណ្ណោះទេ តែត្រូវអប់រំគេឲ្យថ្វាយព្រហ្មចរិយធម៌របស់ខ្លួនទៅព្រះជាម្ចាស់ ទុកជាមធ្យោបាយមួយ ដែលជួយធ្វើឲ្យបុគ្គលិកលក្ខណៈរបស់ខ្លួនចម្រើនឡើង។

## ១៣-អំពីការរស់នៅបែបអ្នកក្រីក្រ

បព្វជិតបព្វជិតាស្ម័គ្រចិត្តរស់នៅបែបអ្នកក្រីក្រ ដើម្បីដើរតាមព្រះគ្រីស្ត។ មនុស្សនាបច្ចុប្បន្នចូលចិត្តសញ្ញាសម្គាល់ពិសេសនេះយ៉ាងខ្លាំង។ បព្វជិតបព្វជិតា ត្រូវយកចិត្តទុកដាក់កាន់តាម ពាក្យសច្ចាប្រណិធាននេះយ៉ាងស្មោះ ហើយប្រសិនបើមានតម្រូវការ ក៏ត្រូវរស់នៅក្នុងសភាពជាអ្នកក្រីក្រតាមរបៀបថ្មីដែរ។ បព្វជិតបព្វជិតាដែលស្ម័គ្រចិត្តរស់នៅក្នុងសភាពជាអ្នកក្រីក្រ ពិតជារួបរួមជាមួយព្រះគ្រីស្តដែលមានសម្បត្តិដ៏ច្រើន តែព្រះអង្គដាក់ខ្លួនមកធ្វើជាអ្នកក្រ ព្រោះ

តែយើង ដើម្បីឲ្យយើងបានទៅជាអ្នកមាន ដោយភាពក្រីក្ររបស់ព្រះអង្គ (២ករ ៨, ៩; មក ៨, ២០)។ បព្វជិតបព្វជិតាត្រូវរស់នៅក្នុងសភាពជាអ្នកក្រីក្រយ៉ាងពិតប្រាកដ មិនគ្រាន់តែសុំមេដឹកនាំអនុញ្ញាតឲ្យប្រើប្រាស់ទ្រព្យសម្បត្តិប៉ុណ្ណោះទេ តែត្រូវដាក់ចិត្តជាអ្នកក្រថែមទៀត ដោយនឹកថា ទ្រព្យសម្បត្តិរបស់គាត់នៅស្ថានបរមសុខ (មថ ៦, ២០)។ ធ្វើដូច្នេះ បព្វជិត បព្វជិតាពិតជាកាន់តាមពាក្យសច្ចារបស់ខ្លួនមែន។ សូមឲ្យបព្វជិតបព្វជិតាម្នាក់ៗ តាមការងាររៀងៗខ្លួន យល់ឃើញថា ខ្លួនត្រូវតែធ្វើការចិញ្ចឹមជីវិតដូចមនុស្សឯទៀតៗទាំងអស់។ គេធ្វើការឲ្យបានអ្វីៗដែលខ្លួនត្រូវការដើម្បីចិញ្ចឹមជីវិត និងដើម្បីប្រព្រឹត្តកិច្ចការរបស់ក្រុមគ្រួសារ។ ប៉ុន្តែ សូមបព្វជិតបព្វជិតា លះបង់ការខ្វល់ខ្វាយចង់បានអ្វីៗហួសហេតុ គឺសូមផ្ញើជីវិតលើព្រះជាម្ចាស់ដែលគង់នៅស្ថានបរមសុខ ជួយផ្គត់ផ្គង់ឲ្យផង (មថ ៦, ២៥)។

ក្រុមគ្រួសារអាចអនុញ្ញាតតាមធម្មនុញ្ញរបស់ខ្លួន ឲ្យសមាជិករបស់ខ្លួនលះបង់ទ្រព្យសម្បត្តិ ជាកេរមត៌កដែលគេបានទទួលរួចហើយ ឬដែលគេនឹងត្រូវទទួលនៅពេលអនាគតដែរ។

គ្រឹះស្ថានក៏ត្រូវខិតខំផ្ដល់សក្ខីភាព ហាក់ដូចជាសក្ខីភាពរួម អំពីការរស់នៅតាមសភាពជាអ្នកក្រីក្រ ស្របតាមកន្លែងផ្សេងៗដែលគេរស់នៅ។ គ្រឹះស្ថានទាំងនោះត្រូវស្ម័គ្រចិត្តយកទ្រព្យសម្បត្តិរបស់ខ្លួន ទៅផ្គត់ផ្គង់តម្រូវការឯទៀតៗរបស់ព្រះសហគមន៍ និងជួយ អ្នកក្រីក្រគោកយ៉ាក ដែលបព្វជិតបព្វជិតាទាំងអស់ត្រូវស្រឡាញ់ ដោយមានចិត្តអាណិតមេត្តា ដូចព្រះគ្រីស្តអាណិតមេត្តាដែរ (មថ ១៩, ២១; ២៥, ៣៤-៣៦; យក ២, ១៥-១៦; ១ យហ ៣, ១៧)។ ក្រុមគ្រួសារ និងគ្រឹះស្ថានតាមតំបន់នីមួយៗ ត្រូវចែកទ្រព្យសម្បត្តិជាមួយគ្នា គឺតំបន់មានច្រើនជាង ត្រូវជួយតំបន់ ដែលខ្វះខាតជាង។

ទោះបីគ្រឹះស្ថាននានាមានសិទ្ធិកាន់កាប់អ្វីៗ ដែលគេត្រូវការសម្រាប់ប្រើប្រាស់ និងសម្រាប់បំពេញកិច្ចការនៃគ្រឹះស្ថានក្តី (លើកលែងតែធម្មនុញ្ញ និងវិន័យផ្ទៃក្នុងមិនអនុញ្ញាត) ក៏គ្រឹះស្ថាននានាត្រូវជៀសវាងការប្រមែប្រមូល និងសន្សំទ្រព្យសម្បត្តិឲ្យមានហួសហេតុ ជៀសវាងការរស់នៅយ៉ាងស្រណុកសុខស្រួលហួសកម្រិតទៀតដែរ។

## ១៤-អំពីការស្ដាប់តាមបង្គាប់

បព្វជិតបព្វជិតាធ្វើពិធីសច្ចាប្រណិធានស្ដាប់តាមបង្គាប់មេដឹកនាំ ដោយលើកយកបំណងប្រាថ្នាផ្ទាល់ខ្លួន ទាំងស្រុង បូជាថ្វាយព្រះជាម្ចាស់។ ដោយការស្ដាប់បង្គាប់ គាត់រួបរួមយ៉ាងជិតស្និទ្ធ និងយ៉ាងពិតប្រាកដនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលសព្វព្រះហឫទ័យសង្គ្រោះមនុស្សលោក។ បព្វជិតបព្វជិតាយកតម្រាប់តាមព្រះគ្រីស្ត ដែលយាងមកធ្វើតាមព្រះហឫទ័យព្រះបិតា (យហ ៣, ៣៤; ៥, ៣០; ហប ១០, ៧; ទត ៣៩, ៩) ព្រះអង្គយក *"សភាពជាទាសករ"* (ភល ២, ៧) រៀនធ្វើតាមព្រះបញ្ជាដោយរងទុក្ខលំបាក (ហប ៥, ៨)។ តាមជំនឿរបស់ខ្លួន និងក្រោមការណែនាំនៃព្រះវិញ្ញាណ បព្វជិតបព្វជិតាត្រូវចុះចូលនឹងមេដឹកនាំរបស់ខ្លួន ដែលគាត់ត្រូវចាត់ទុកជាតំណាងរបស់ព្រះជាម្ចាស់។ គាត់ក៏ត្រូវចាត់ទុកថា មេដឹកនាំមុខជានឹងណែនាំគាត់ឲ្យបម្រើបងប្អូនទាំងអស់ក្នុងអង្គព្រះគ្រីស្ត ដូចព្រះគ្រីស្តផ្ទាល់ដាក់ខ្លួនជាអ្នកបម្រើបងប្អូនឯទៀតៗ ដោយព្រះអង្គសុខចិត្តចុះចូលនឹងព្រះបិតា ហើយបូជាព្រះជន្មដើម្បីរំដោះមនុស្សទាំងអស់ (មថ ២០, ២៨; យហ ១០, ១៤-១៨)។ ដូច្នេះ បព្វជិតបព្វជិតាជាប់ចិត្តយ៉ាងជិតស្និទ្ធិបម្រើព្រះសហគមន៍ និងខិតខំឲ្យរីកចម្រើនឡើងទៅជាមនុស្សពេញវ័យ គឺឡើងដល់កំពូលរបស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់ (អភ ៤,១៣)។

ហេតុនេះ សូមឲ្យបព្វជិតបព្វជិតាចុះចូលនឹងមេដឹកនាំ ដោយចិត្តគោរព និងដោយចិត្តសុភាពរាបសា តាមក្បួនវិន័យ និងតាមធម្មនុញ្ញរបស់គាត់ ដោយមានចិត្តជឿលើព្រះជាម្ចាស់ និងស្រឡាញ់ព្រះហឫទ័យព្រះអង្គ។ សូមឲ្យបព្វ

ជិតបព្វជិតាយកកម្លាំងប្រាជ្ញា និងកម្លាំងនៃឆន្ទៈរបស់ខ្លួន ព្រមទាំងយកគ្រប់អំណោយទានដែលខ្លួនបានទទួលពីធម្មជាតិ និងពីព្រះជាម្ចាស់ប្រណីសន្ដោសដល់គាត់ មកបំពេញកិច្ចការតាមបង្គាប់របស់មេដឹកនាំ ហើយសម្រេចកិច្ចការ ដែលមេដឹកនាំផ្ញើទុកឲ្យធ្វើ ដោយជឿជាក់ថា ខ្លួនជួយកសាងព្រះកាយព្រះគ្រីស្ដ តាមគម្រោងការរបស់ព្រះជាម្ចាស់។ ដូច្នេះ បព្វជិតបព្វជិតា ដែលធ្វើតាមបង្គាប់មេដឹកនាំ មិនបង្អាប់បង្អោនកិត្តិយសរបស់ខ្លួនជាមនុស្សដ៏មានតម្លៃទេ តែផ្ទុយទៅវិញ នាំខ្លួនឲ្យទៅជាមនុស្សពេញវ័យ ទាំងបណ្ដោយឲ្យសេរីភាពរបស់ខ្លួន ក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់រីកចម្រើនឡើងទៀតផង។

រីឯមេដឹកនាំវិញ អស់លោកអ្នកទទួលខុសត្រូវលើបព្វជិតបព្វជិតាដែលព្រះជាម្ចាស់ផ្ញើទុកឲ្យថែរក្សា (ហប ១៣, ១៧) ក្នុងការបំពេញមុខនាទីរបស់ខ្លួន អស់លោកអ្នកក៏ត្រូវស្ដាប់តាមព្រះហឫទ័យព្រះជាម្ចាស់ដែរ។ ត្រូវប្រើអំណាចរបស់ខ្លួនដោយមានបំណងចង់បម្រើបងប្អូន គឺមានបំណងចង់បង្ហាញព្រះហឫទ័យស្រឡាញ់របស់ព្រះអម្ចាស់ ចំពោះបងប្អូនទាំងនោះ។ សូមត្រួតត្រាអ្នកដែលចុះចូលក្រោមអំណាចរបស់ខ្លួន ទុកដូចជាបុត្រធីតារបស់ព្រះជាម្ចាស់ ដោយគោរពគាត់ទុកជាមនុស្សមានតម្លៃដ៏ថ្លៃថ្នូរ និងដាស់តឿនឲ្យគាត់ស្ម័គ្រចិត្តចង់ចុះចូលទៀតផង។ ត្រូវទុកសេរីភាពដ៏ត្រឹមត្រូវឲ្យគាត់ ជាពិសេសអំពីអគ្គសញ្ញាលើកលែងទោស និងអំពីការណែនាំជីវិតតាមព្រះវិញ្ញាណ។ មេដឹកនាំត្រូវអប់រំបព្វជិតបព្វជិតាឲ្យរួមសហការគ្នា ទាំងចេះស្ដាប់បង្គាប់ ដោយទទួលខុសត្រូវយ៉ាងសកម្មនៅពេលបំពេញមុខងាររបស់ខ្លួនផ្ទាល់ផង ហើយនៅពេលគាត់មានគំនិតចង់ចាប់ផ្ដើមធ្វើអ្វីមួយផងដែរ។ មេដឹកនាំត្រូវចូលចិត្តស្ដាប់គាត់ ដាស់តឿនគាត់ឲ្យខិតខំរួបរួមគ្នា ដើម្បីជាប្រយោជន៍ដល់គ្រឹះស្ថាន និងដល់ព្រះសហគមន៍។ ប៉ុន្តែ មេដឹកនាំក៏ត្រូវតែប្រើអំណាចរបស់ខ្លួននៅពេលត្រូវសម្រេចសេចក្ដីមួយ ឬបញ្ជាកិច្ចការណាមួយដែលត្រូវធ្វើពុំខាន។

អង្គប្រជុំ និងក្រុមប្រឹក្សានឹងបំពេញមុខនាទីរបស់ខ្លួនក្នុងការណែនាំគ្រឹះស្ថាន។ សូមឲ្យអង្គភាពទាំងនោះ តាមរបៀបរៀងៗខ្លួន ធ្វើឲ្យបព្វជិតបព្វជិតាទាំងអស់រួមបញ្ចេញយោបល់ និងយកចិត្តទុកដាក់នឹងប្រយោជន៍សហគមន៍ទាំងមូលទៀតដែរ។

## ១៥-អំពីការរស់នៅជាមួយគ្នា

ការរស់នៅជាមួយគ្នា នាំឲ្យបព្វជិតបព្វជិតាព្យាយាមអធិដ្ឋាន និងរួបរួមគ្នាមានចិត្តថ្លើមតែមួយ ដោយយកលទ្ធិនៃគម្ពីរដំណឹងល្អ យកពិធីបុណ្យដ៏សក្ការៈ ជាពិសេសយកអគ្គសញ្ញាអរព្រះគុណ ធ្វើជាអាហារផ្ដល់កម្លាំង (កក ២, ៤២) ដោយយកព្រះសហគមន៍ដើមដំបូងធ្វើគំរូ គឺមហាជនរបស់អ្នកជឿ មានចិត្តថ្លើមតែមួយ មានចិត្តគំនិតតែមួយដែរ (កក ២, ៣២)។ បព្វជិតបព្វជិតាជាសរីរាង្គនៃព្រះកាយព្រះគ្រីស្ដ។ ហេតុនេះ ត្រូវគោរពគ្នាទៅវិញទៅមកយ៉ាងស្និទ្ធស្នាល រស់នៅជាមួយគ្នាទុកជាបងប្អូន (រម ១២, ១០) ដោយជួយចែករំលែកសុខទុក្ខគ្នានឹងគ្នា (កឡ ៦, ២) ព្រោះព្រះជាម្ចាស់ចាក់បង្ហូរព្រះហឫទ័យស្រឡាញ់ក្នុងចិត្តគេ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ (រម ៥, ៥)។ សហគមន៍បព្វជិតបព្វជិតាប្រៀបដូចជាក្រុមគ្រួសារមួយ រួមក្នុងនាមព្រះអម្ចាស់ ព្រះអង្គក៏គង់នៅជាមួយសហគមន៍នោះដែរ (មថ ១៨, ២០)។ សេចក្ដីស្រឡាញ់ដែលធ្វើឲ្យធម្មវិន័យបានពេញលក្ខណៈ (រម ១៣, ១០) ក៏ជាចំណងធ្វើឲ្យគុណធម៌គ្រប់យ៉ាងបានពេញលក្ខណៈដែរ (កូឡ ៣, ១៤)។ យើងដឹងថា យើងឆ្លងពីសេចក្ដីស្លាប់ទៅកាន់ជីវិត ដោយសេចក្ដីស្រឡាញ់នោះ (១យហ ៣,១៤)។ ម្យ៉ាងទៀត បងប្អូនដែលរួបរួមគ្នា បង្ហាញបញ្ជាក់ថា ព្រះគ្រីស្ដយាងមកពិតមែនហើយ (យហ ១៣, ៣៥; ១៧, ២១)។ ការរួបរួមបែបនេះ ក៏ផ្ដល់កម្លាំងយ៉ាងខ្លាំងអស្ចារ្យ ដើម្បីបំពេញកិច្ចការជាគ្រីស្ដទូតថែមទៀតដែរ។

ត្រូវឲ្យអ្នកដែលមានឈ្មោះថា *"អ្នកជំនួយ"* ឬ *"សហការី"* ឬអ្នកគេហៅតាមឈ្មោះផ្សេងទៀតក៏បានរួមរស់ ជាប់យ៉ាងជិតស្និទ្ធក្នុងការរស់នៅ និងរួមក្នុងកិច្ចការរបស់សហគមន៍បព្វជិតបព្វជិតា ដើម្បីឲ្យចំណងភាតរភាពរវាងសមាជិកសហគមន៍ទាំងមូលកាន់តែស្និទ្ធស្នាលឡើងៗ។ យូរៗទៅ ក្នុងក្រុមគ្រួសារបព្វជិតា ត្រូវខិតខំធ្វើឲ្យមានឋានៈបព្វជិតាតែមួយគត់ លើកលែងតែមានសភាពការណ៍រារាំងយ៉ាងពិតប្រាកដឲ្យប្រព្រឹត្តតាមរបៀបផ្សេងទៀត។ ប្រសិនបើ នៅតែមានឋានៈផ្សេងៗ ត្រូវញែកបព្វជិតាចេញពីគ្នាតាមកិច្ចការផ្សេងៗដែលគេត្រូវបំពេញនោះ ស្របតាមព្រះជាម្ចាស់ត្រាស់ហៅគាត់យ៉ាងពិសេស ឬស្របតាមទេពកោសល្យពិសេសរបស់គាត់។

ចំពោះគ្រឹះស្ថាន ឬអារាមរបស់បុរសដែលមិនមែនសុទ្ធតែគ្រីស្តបរិស័ទធម្មតា គ្រឹះស្ថាននិងអារាមទាំងនោះ មានសិទ្ធិទទួលបូជាចារ្យ (អាចារ្យ) និងគ្រីស្តបរិស័ទធម្មតាដែរ ស្របតាមលក្ខណៈពិសេសរបស់គេ និងស្របតាម ធម្មនុញ្ញត្រូវបញ្ជាក់នៅពេលក្រោយ។ បូជាចារ្យ (អាចារ្យ) និងគ្រីស្តបរិស័ទធម្មតាមានសិទ្ធនិងភារកិច្ចស្មើគ្នា លើកលែងតែអំពីភារកិច្ចដែលហូរចេញមកពីអគ្គសញ្ញាតែងតាំងជាបូជាចារ្យប៉ុណ្ណោះ។

## ១៦-អំពីរបងឃាត់ឃាំងអ្នកក្រៅមិនឲ្យចូលក្នុងអារាម

ត្រូវរក្សាទុកយ៉ាងតឹងរ៉ឹងនូវវិន័យហាមមិនឲ្យអ្នកក្រៅចូលក្នុងអារាមបព្វជិតា ដែលមានមុខនាទីតែស៊ឹងស្មាធិ៍ប៉ុណ្ណោះ។ មានតែអភិបាលព្រះសហគមន៍ក្រុងរ៉ូមទេ មានសិទ្ធិដាក់ឬដករបងឃាំងអ្នកក្រៅមិនឲ្យចូលនោះបាន។ ត្រូវកែសម្រួលវិន័យនេះតាមកាលៈទេសៈ និងតាមកន្លែង ដោយលុបបំបាត់អ្វីៗហួសសម័យ ក្រោយពីបានសួរយោបល់របស់បព្វជិតាទាំងនោះរួចហើយ។

រីឯបព្វជិតាឯទៀតៗ ដែលមានមុខនាទីបំពេញកិច្ចការជាគ្រីស្តទូតនៅខាងក្រៅអារាម មិនត្រូវទុកវិន័យឃាត់ឃាំងអ្នកក្រៅមិនឲ្យចូលបានទេ ដើម្បីឲ្យគាត់អាចបំពេញមុខនាទីដែលព្រះសហគមន៍ផ្ញើទុកឲ្យគាត់យ៉ាងស្រួល។ ប៉ុន្តែ ត្រូវរក្សាវិន័យឃាត់ឃាំងម្យ៉ាងដូចមានកំណត់ទុកក្នុងធម្មនុញ្ញរបស់គេ។

## ១៧-អំពីសម្លៀកបំពាក់ជាបព្វជិតបព្វជិតា

សម្លៀកបំពាក់របស់បព្វជិតបព្វជិតាជាសញ្ញាសម្គាល់បង្ហាញបញ្ជាក់ថា មនុស្សម្នាក់ញែកខ្លួនថ្វាយព្រះជាម្ចាស់ហើយ។ ត្រូវពាក់សម្លៀកបំពាក់សាមញ្ញ និងសុភាពរាបសា ជាសម្លៀកបំពាក់របស់អ្នកក្រ ប៉ុន្តែត្រូវជាសម្លៀកបំពាក់សមរម្យស្របតាមតម្រូវការសុខភាព និងសមស្របតាមកាលៈទេសៈ និងទីកន្លែង ព្រមទាំងស្របតាមតម្រូវការនៃកិច្ចការជាគ្រីស្តទូត។ ត្រូវកែសម្រួលសម្លៀកបំពាក់បព្វជិត ឬបព្វជិតា ដែលមិនត្រូវតាមសេចក្តីណែនាំទាំងនោះ។

## ១៨-អំពីការអប់រំបព្វជិតបព្វជិតា

គ្រឹះស្ថាននានាអាចកែសម្រួលខ្លួនបាន លុះត្រាតែបព្វជិតបព្វជិតានៃគ្រឹះស្ថានទាំងនោះ ទទួលការអប់រំ។ ហេតុនេះហើយ បានជាមិនត្រូវចាត់បព្វជិតបព្វជិតាដែលមិនមែនជាបូជាចារ្យ (អាចារ្យ) ឲ្យបំពេញកិច្ចការជាគ្រីស្តទូតភ្លាមៗក្រោយពីគាត់បញ្ចប់ការអប់រំជាពន្លកថ្មីទេ។ ត្រូវអប់រំគាត់តទៅទៀតខាងជីវិតតាមព្រះវិញ្ញាណ ខាងកិច្ចការជាគ្រីស្តទូតខាងលទ្ធិគ្រីស្តសាសនា និងខាងបច្ចេកទេស នៅគេហដ្ឋានដែលមានបច្ចេកទេសខាងមុខវិជ្ជាទាំងនោះ ដោយគិតគូរផ្តល់សញ្ញាបត្រឲ្យគាត់ថែមទៀតផង។ ត្រូវអប់រំបព្វជិតបព្វជិតាតាមសមត្ថភាពរៀនសូត្ររៀងៗខ្លួន និងតាមចរិតលក្ខណៈផ្ទាល់របស់គាត់ ឲ្យគាត់ស្គាល់អំពីរបៀបរស់នៅ របៀបរិះគិត និងយោបល់មនុស្សម្នាក្នុងសង្គមនាបច្ចុប្បន្នយ៉ាង

គ្រប់គ្រាន់ ទើបការកែសម្រួលរបៀបរស់នៅរបស់បព្វជិតបព្វជិតា បានស្របតាមតម្រូវការនាសម័យបច្ចុប្បន្ន មិនគ្រាន់តែជាការកែសម្រួលសំបកខាងក្រៅប៉ុណ្ណោះទេ តែត្រូវឲ្យបព្វជិតបព្វជិតា ដែលបំពេញកិច្ចការខាងក្រៅអារាមអាចបំពេញមុខនាទីរបស់ខ្លួនបាន។ ត្រូវអប់រំបព្វជិតបព្វជិតាដោយយកកត្តាទាំងនេះ មកផ្សំគ្នាយ៉ាងសមរម្យ ទើបគាត់រស់នៅយ៉ាងសុខដុមរមនា។

បព្វជិតបព្វជិតាត្រូវយកចិត្តទុកដាក់ខិតខំបំពេញការអប់រំឲ្យរស់នៅតាមព្រះវិញ្ញាណ ឲ្យស្គាល់លទ្ធិគ្រីស្តសាសនាឲ្យមានបច្ចេកទេស តទៅទៀតអស់មួយជីវិត។ មេដឹកនាំក៏ត្រូវផ្តល់ឱកាស និងមធ្យោបាយ ព្រមទាំងពេលវេលា ដែលគាត់ត្រូវការឲ្យគាត់អាចអប់រំខ្លួនបាន ប្រសិនបើអាចធ្វើបាន។ យ៉ាងណាមិញ មេដឹកនាំមានភារកិច្ចជ្រើសរើសអ្នកណែនាំគ្រូអប់រំឲ្យរស់នៅតាមព្រះវិញ្ញាណ និងសាស្ត្រាចារ្យដ៏ប្រសើរជាងគេ។ តែអ្នកទាំងនោះ ត្រូវទទួលការអប់រំយ៉ាងល្អជាមុនសិន។

## ១៩-ការបង្កើតគ្រឹះស្ថានថ្មី

ត្រូវថ្លឹងថ្លែងឲ្យមែនទែន មុននឹងបង្កើតគ្រឹះស្ថានថ្មីមួយ គឺត្រូវរិះគិតថា តើត្រូវការគ្រឹះស្ថាននោះ ឬក៏អត់? យ៉ាងហោចណាស់ត្រូវរិះគិតថា តើគ្រឹះស្ថាននោះមានប្រយោជន៍ខ្លាំងអាចចម្រើនឡើងបានឬយ៉ាងណា?។ ត្រូវប្រុងប្រយ័ត្នដូច្នេះ ក្រែងលោមានសមាគមកើតឡើងដោយឥតបានការ ឬគ្មានកម្លាំងគ្រប់គ្រាន់ដែលត្រូវការឲ្យទៅមុខបាន។ ក្នុងព្រះសហគមន៍ថ្មីៗមានមូលហេតុពិសេសនឹងជួយលើកស្ទួយ ឬពង្រឹងរបៀបរស់នៅជាបព្វជិតបព្វជិតាស្រប តាមវប្បធម៌ និងអរិយធម៌ប្រជាជន ហើយត្រូវតាមជីវភាព និងតាមប្រពៃណីស្រុកនោះ។

## ២០-ការរក្សាទុក ការកែសម្រួល ឬការលះបង់កិច្ចការផ្ទាល់របស់គ្រឹះស្ថាន

គ្រឹះស្ថាននីមួយៗត្រូវរក្សាទុក និងបន្តបំពេញកិច្ចការរបស់ខ្លួនផ្ទាល់យ៉ាងស្មោះ ដោយនឹកគិតដល់ប្រយោជន៍ព្រះសហគមន៍សកល និងព្រះសហគមន៍ក្នុងភូមិភាគ។ តែត្រូវកែសម្រួលកិច្ចការទាំងនោះ ស្របតាមតម្រូវការនៃកាលៈទេសៈនៃទីកន្លែង ដោយប្រើមធ្យោបាយដែលសមស្របតាមសភាពការណ៍នោះ ឬបង្កើតមធ្យោបាយថ្មីៗក៏បាន ទាំងបោះបង់ចោលកិច្ចការដែលមិនស្របនឹងគោលគំនិត និងលក្ខណៈដ៏ពិតប្រាកដនៃគ្រឹះស្ថាននោះ។ ជាពិសេសត្រូវរក្សាទុកគំនិតជាសាសនទូត ក្នុងគ្រឹះស្ថានបព្វជិតបព្វជិតាជាចាំបាច់បំផុត និងកែសម្រួលគោលគំនិតស្របតាមលក្ខណៈគ្រឹះស្ថាននីមួយៗ និងស្របតាមសភាពការណ៍បច្ចុប្បន្ន ដើម្បីឲ្យគេប្រកាសដំណឹងល្អយ៉ាងសកម្មក្នុងចំណោមប្រជាជនទាំងឡាយ។

## ២១-គ្រឹះស្ថាន និងអារាមដែលអន់ថយ

តាមយោបល់អភិបាលភូមិភាគទាំងប៉ុន្មានក្នុងតំបន់ និងតាមការវិនិច្ឆ័យរបស់សន្តអាសនៈ មានគ្រឹះស្ថាន និងអារាមខ្លះគ្មានសង្ឃឹមយ៉ាងពិតប្រាកដថា នឹងចម្រើនឡើងទៀតបានសោះ។ ដូច្នេះត្រូវហាមមិនឲ្យគេទទួលចំណូលថ្មី។ ប្រសិនបើអាចធ្វើបាន ត្រូវបង្រួមគ្រឹះស្ថាន ឬអារាមទាំងនោះ ឲ្យរួមជាមួយគ្រឹះស្ថាននិងអារាមមួយផ្សេងទៀតដែលកំពុងលូតលាស់ ហើយដែលមានគោលដៅ និងគោលគំនិតស្រដៀងគ្នាដែរ។

## ២២-គ្រឹះស្ថាននានាត្រូវរួបរួមគ្នា

ប្រសិនបើគ្រឹះស្ថាន និងអារាមស្វយ័ត ជាប់នឹងក្រុមគ្រួសារបព្វជិតបព្វជិតាតែមួយដូចគ្នា ត្រូវគ្រឹះស្ថាន និងអារាម

ទាំងនោះរួបរួមគ្នាជាសហព័ន្ធ តាមតម្រូវការ និងដោយសន្តអាសនៈយល់ព្រមទៀតផង។ ប្រសិនបើគ្រឹះស្ថាននិងអារាម មានធម្មនុញ្ញ ទំនៀមទម្លាប់ និងគោលគំនិតស្រដៀងគ្នា ជាពិសេសប្រសិនបើគេខ្សោយពេក ក៏ត្រូវចូលរួបរួមគ្នាតែម្តង។ ប្រសិនបើគេបំពេញកិច្ចការខាងក្រៅអារាមដូចគ្នា ឬស្រដៀងគ្នា គេក៏ត្រូវរួមគ្នាជាសមាគមដែរ។

## ២៣-ក្រុមមេដឹកនាំដ៏ខ្ពង់ខ្ពស់

ត្រូវជួយលើកស្ទួយគាំទ្រក្រុម ឬក្រុមប្រឹក្សារបស់មេដឹកនាំដ៏ខ្ពង់ខ្ពស់ ដែលសន្តអាសនៈបានតែងតាំងមក។ ក្រុមទាំងនោះមានប្រយោជន៍ជាខ្លាំង ដើម្បីឲ្យគ្រឹះស្ថាននីមួយៗមានលទ្ធភាពអាចទៅកាន់គោលដៅរបស់ខ្លួនឲ្យកាន់តែល្អប្រសើរឡើង ព្រមទាំងឲ្យគ្រឹះស្ថានទាំងនោះសហការគ្នាកាន់តែសកម្ម ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍។ ដូច្នេះ ក្រុមទាំងនោះអាចចាត់ចែងអ្នកប្រកាសដំណឹងល្អក្នុងតំបន់មួយឲ្យបានត្រឹមត្រូវជាង និងមានសមត្ថភាពអាចសម្រេចបញ្ហាទូទៅរបស់បព្វជិតបាន។ ចំពោះកិច្ចការជាគ្រីស្តទូត ត្រូវចាត់ចែងដោយក្រុម ឬក្រុមប្រឹក្សារបស់មេដឹកនាំដ៏ខ្ពង់ខ្ពស់ ក៏ត្រូវមានទំនាក់ទំនងជាមួយគ្នា និងសហការយ៉ាងសមរម្យជាមួយនឹងក្រុមអភិបាលក្នុងប្រទេសនីមួយៗដែរ។

ក្រុមគ្រីស្តបរិស័ទធម្មតាដែលថ្វាយខ្លួនចំពោះព្រះជាម្ចាស់ ហើយរស់នៅក្នុងសង្គម ក៏អាចតែងតាំងក្រុមបែបនោះដែរ។

## ២៤-អំពីព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យទៅជាបព្វជិតបព្វជិតា

អស់លោកបូជាចារ្យ (អាចារ្យ) និងគ្រីស្តបរិស័ទដែលមានមុខនាទីអប់រំយុវជន ត្រូវយកចិត្តទុកដាក់ខិតខំយ៉ាងខ្លាំង ឲ្យមានអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅកាន់តែច្រើនឡើងៗ ស្របតាមតម្រូវការរបស់ព្រះសហគមន៍។ ត្រូវជ្រើសរើសអ្នកទាំងនោះ ដោយពិនិត្យពិចារណា។ សូម្បីតែក្នុងពេលអត្ថាធិប្បាយគម្ពីរជាធម្មតាក្តី ក៏ត្រូវនិយាយជារឿយៗ អំពីព្រះដំបូន្មានចែងក្នុងគម្ពីរដំណឹងល្អ និងអំពីការជ្រើសរើសរស់នៅជាបព្វជិតបព្វជិតាដែរ។ ឪពុកម្តាយក៏ត្រូវយកចិត្តទុកដាក់អប់រំកូនៗ តាមគ្រីស្តសាសនា ទាំងប្រាប់ឲ្យកូនៗដឹងថា ព្រះជាម្ចាស់ត្រាស់ហៅកូនៗខ្លះ ឲ្យទៅជាបព្វជិតបព្វជិតា ហើយក៏ត្រូវថែរក្សាការពារការត្រាស់ហៅនេះក្នុងចិត្តកូនៗផងដែរ។

គ្រឹះស្ថានទាំងឡាយមានសិទ្ធិបង្ហាញខ្លួនឲ្យគ្រីស្តបរិស័ទស្គាល់ ដើម្បីជួយឲ្យមានបេក្ខជនចង់ចូលជាបព្វជិតបព្វជិតាក្នុងគ្រឹះស្ថាននោះ តាមព្រះជាម្ចាស់ត្រាស់ហៅ។ ប៉ុន្តែ ត្រូវស្វែងរកបេក្ខជនដោយប្រុងប្រយ័ត្នជាធម្មតា ដោយគោរពសេចក្តីណែនាំរបស់សន្តអាសនៈ និងរបស់អភិបាលភូមិភាគចាត់ចែងទុកមក។ ប៉ុន្តែ បព្វជិតបព្វជិតាត្រូវនឹកចងចាំជានិច្ចថា ប្រសិនបើគាត់រស់នៅតាមបែបធ្វើជាគំរូ គាត់ពិតជាធានាជីវិតគ្រឹះស្ថានរបស់គាត់តាមរបៀបល្អជាងគេ ហើយគាត់ក៏អញ្ជើញគ្រីស្តបរិស័ទយ៉ាងសកម្ម ឲ្យទៅជាបព្វជិតបព្វជិតាដូចគាត់ដែរ។

## ២៥-ពាក្យបញ្ចប់

គ្រឹះស្ថាននានាត្រូវកែសម្រួលខ្លួនយ៉ាងសមរម្យ តាមសេចក្តីណែនាំទាំងនេះ គឺបព្វជិតបព្វជិតាគ្រឹះស្ថានទាំងនោះត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំង តបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគាត់ និងបំពេញមុខនាទីរបស់ខ្លួនក្នុងព្រះសហគមន៍នាបច្ចុប្បន្នកាល។ មហាសន្និបាតដ៏វិសុទ្ធយល់ឃើញថា របៀបរស់នៅជាព្រហ្មចារី ជាអ្នកក្រីក្រ និងជាអ្នកស្តាប់បង្គាប់មេដឹកនាំ ពិតជាមានតម្លៃខ្ពស់ណាស់ តាមព្រះគ្រីស្តផ្ទាល់ធ្វើជាគំរូស្រាប់។ មហាសន្និបាតសង្ឃឹមយ៉ាងមាំថា កិច្ចការ ដែលគ្រឹះស្ថានទាំងនោះនឹងប្រព្រឹត្ត ទោះជាកិច្ចការដ៏ស្ងាត់កំបាំងក្តី ឬជាកិច្ចការដែលមនុស្សលោកស្គាល់គ្រប់គ្នាក្តី មុខជាបានបង្កើតផលល្អពុំខាន។ ហេតុនេះ សូមបព្វជិតបព្វជិតាទាំងអស់ ផ្សព្វផ្សាយដំណឹងល្អស្តីអំពីព្រះគ្រីស្ត

ក្នុងពិភពលោកទាំងមូល ដោយកាន់ជំនឿឥតលម្អៀង ដោយមានចិត្តស្រឡាញ់ព្រះជាម្ចាស់និងអ្នកដទៃ ដោយស្រឡាញ់ឈើឆ្កាង និងដោយមានសេចក្ដីសង្ឃឹមថា នឹងបានទទួលសិរីរុងរឿងនៅលោកខាងមុខទៀតផង។ សូមឲ្យមនុស្សទាំងអស់ឃើញសក្ខីភាពរបស់គាត់ ហើយសូមឲ្យគេលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតាដែលគង់ស្ថានបរមសុខ (មថ ៥, ១៦)។ ដូច្នេះ ដោយមានព្រះនាងព្រហ្មចារិនីម៉ារី ជាមាតាព្រះអម្ចាស់ជួយអង្វរ គឺព្រះនាងដែល "បានរស់នៅ ទុកជាគំរូណែនាំការរស់នៅរបស់គាត់" សូមឲ្យបព្វជិតបព្វជិតាទាំងអស់រីកចម្រើននិងកើនចំនួនឡើងតៗទៅ និងបង្កើតផលកាន់តែច្រើនឡើង ដើម្បីសង្គ្រោះមនុស្សលោក។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ ព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្ដបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្ដទូត រួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្ដីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈសិលា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៦៥
ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក
(ហត្ថលេខារបស់អស់លោកអភិបាល)

# សកម្មភាពរបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូត

## APOSTOLICAM ACTUOSITATEM

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលនៃមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេចងចាំរហូតតរៀងទៅ។

## ក្រឹត្យក្រមស្តីអំពី
## សកម្មភាពរបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូត

**១-បុព្វកថា**

មហាសន្និបាតដ៏វិសុទ្ធ មានបំណងចង់ឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់ បំពេញសកម្មភាពជាគ្រីស្តទូតកាន់តែខ្លាំងឡើងៗ។ ដូច្នេះ មហាសន្និបាតបែរមករកគ្រីស្តបរិស័ទធម្មតា ដោយយកចិត្តទុកដាក់ជាទីបំផុត។ ក្នុងឯកសារផ្សេងៗ មហាសន្និបាតបានរំឭកគ្រីស្តបរិស័ទ អំពីតួនាទីផ្ទាល់ដ៏ចាំបាច់បំផុតរបស់ខ្លួន ក្នុងបេសកកម្មរបស់ព្រះសហគមន៍រួចហើយ (ពន្លឺ ៣៧ត; ពិធី ២៦-៤០; បង្រួប; អភិបាល១៦.១៧.១៨; ហ្វឹកហ្វឺន ៣.៥.៧)។ ព្រះសហគមន៍មិនអាចខ្វះគ្រីស្តបរិស័ទធម្មតា ដើម្បីបំពេញកិច្ចការជាគ្រីស្តទូតទេ ព្រោះកិច្ចការនេះ ពិតជាលទ្ធផលនៃការត្រាស់ហៅរបស់គេ ឲ្យទៅជាគ្រីស្តបរិស័ទ។ ព្រះគម្ពីរបង្ហាញយ៉ាងជាក់ច្បាស់ថា នៅខាងដើមដំបូងនៃព្រះសហគមន៍សកម្មភាព របស់គ្រីស្តបរិស័ទធម្មតាលេចឡើងដោយឯកឯង និងបានបង្កើតផលជាច្រើនអនេក។ (កក ១១,១៩-២១; ១៨, ២៦; រម ១៦, ១-១៦; ភីល ៤, ៣)។

នៅសម័យឥឡូវ គ្រីស្តបរិស័ទធម្មតាក៏ត្រូវយកចិត្តទុកដាក់ ខ្នះខ្នែងបំពេញកិច្ចការជាគ្រីស្តទូតនេះដែរ។ សភាពការណ៍នាបច្ចុប្បន្នកាល ទាមទារឲ្យគ្រីស្តបរិស័ទធម្មតា បំពេញកិច្ចការជាគ្រីស្តទូតកាន់តែខ្លាំងឡើងៗ និងកាន់តែទូលំទូលាយដែរ ព្រោះចំនួនមនុស្សកាន់តែកើនឡើង វិទ្យាសាស្ត្រនិងបច្ចេកទេសកាន់តែចម្រើនឡើង ហើយមនុស្សក៏រួមសាមគ្គីកាន់ តែជិតស្និទ្ធឡើងៗដែរ បណ្តាលឲ្យគ្រីស្តបរិស័ទធម្មតាមានសកម្មភាពក្នុងវិស័យនានាកាន់តែទូលាយ។ មានតែគ្រីស្តបរិស័ទធម្មតាទេ ដែលអាចបំពេញកិច្ចការទាំងនោះបាន។ សភាពការណ៍ថ្មីនោះ បណ្តាលឲ្យមានបញ្ហាថ្មីៗជាច្រើនកើតឡើង និងទាមទារឲ្យគេប្រុងប្រយ័ត្ន និងស្រាវជ្រាវយ៉ាងពិសេសអំពីបញ្ហាទាំងនោះ។ ដោយមនុស្សស្វ័យតយ៉ាងត្រឹមត្រូវក្នុងវិស័យជាច្រើននៃការរស់នៅរបស់ខ្លួន ក៏ប៉ុន្តែ ស្វ័យភាពនេះបណ្តាលឲ្យអ្នកខ្លះលះបង់សីលធម៌ និងសាសនាចោល ព្រមទាំងបណ្តាលឲ្យការរស់នៅក្នុងឋានៈជាគ្រីស្តបរិស័ទអន់ថយជាខ្លាំង។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទធម្មតាត្រូវតែបំពេញកិច្ចការជាគ្រីស្តទូតជាចាំបាច់។ ក្នុងតំបន់ជាច្រើន បូជាចារ្យមានចំនួនតិចណាស់ ឬគ្មាន

សេរីភាពបំពេញមុខងាររបស់ខ្លួនថែមទៀត។ ហេតុនេះហើយ បានជាបើគ្មានសកម្មភាពរបស់គ្រីស្តបរិស័ទធម្មតាទេ ព្រះសហគមន៍គ្មានវត្តមាននៅតំបន់ទាំងនោះ ហើយក៏មិនអាចបំពេញការងាររបស់ខ្លួនទៀតបានឡើយ។

សព្វថ្ងៃ ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រោសឲ្យគ្រីស្តបរិស័ទធម្មតាភ្ញាក់ស្មារតីរកាន់តែខ្លាំងឡើងៗ ឲ្យទទួលខុសត្រូវលើខ្លួនផ្ទាល់ ព្រះអង្គក៏ដាស់តឿនគេនៅគ្រប់ទីកន្លែង ឲ្យបម្រើព្រះគ្រីស្តនិងព្រះសហគមន៍។ ព្រះសហគមន៍ត្រូវការគ្រីស្តបរិស័ទធម្មតាក្នុងវិស័យជាច្រើនជាចាំបាច់បំផុតដូច្នេះ ពិតជាសញ្ញាសម្គាល់យ៉ាងជាក់ស្តែង អំពីសកម្មភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធនោះ។

ក្នុងក្រឹត្យក្រមនេះ មហាសន្និបាតមានបំណងចង់រៀបរាប់ពន្យល់អំពីលក្ខណៈនៃកិច្ចការរបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូត ព្រមទាំងចង់ពន្យល់អំពីសភាព និងអំពីកិច្ចការផ្សេងៗរបស់គ្រីស្តបរិស័ទទាំងនោះ។ មហាសន្និបាតក៏មានបំណងផ្តល់គោលការណ៍សំខាន់ៗជាគ្រឹះ ព្រមទាំងបញ្ចេញសេចក្តីណែនាំ ដើម្បីឲ្យគ្រីស្តបរិស័ទធម្មតា អាចបំពេញកិច្ចការនេះ តាមរបៀបកាន់តែសកម្មឡើងៗ។ ត្រូវកែសម្រួលក្បួនច្បាប់នៃព្រះសហគមន៍ អំពីគ្រីស្តបរិស័ទធម្មតា ដោយយកសេចក្តីណែនាំក្នុងក្រឹត្យក្រមនេះធ្វើជាគោល។

# ជំពូក ១

## ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាឲ្យបំពេញកិច្ចការជាគ្រីស្តទូត

### ២-គ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងបេសកកម្មរបស់ព្រះសហគមន៍

ព្រះគ្រីស្តបង្កើតព្រះសហគមន៍ ដើម្បីលាតសន្ធឹងព្រះរាជ្យព្រះអង្គនៅលើផែនដីទាំងមូល សម្រាប់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជាព្រះបិតា។ ដូច្នេះព្រះសហគមន៍នាំមនុស្សទាំងអស់ ឲ្យរួមចំណែកក្នុងការសង្គ្រោះរបស់ព្រះយេស៊ូគ្រីស្តដែលរំដោះមនុស្សលោក។ ដោយសារគ្រីស្តបរិស័ទ ព្រះសហគមន៍តម្រង់ពិភពលោកទាំងមូលទៅរកព្រះគ្រីស្ត។ យើងហៅគ្រប់សកម្មភាពនៃព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត ដែលមានគោលដៅនោះថា «កិច្ចការជាគ្រីស្តទូត»។ ព្រះសហគមន៍បំពេញកិច្ចការនេះ ដោយសារសមាជិកទាំងអស់របស់ខ្លួន តាមរបៀបផ្សេងៗពីគ្នា។ ព្រះជាម្ចាស់ដែលត្រាស់ហៅមនុស្សឲ្យទៅជាគ្រីស្តបរិស័ទ ក៏ត្រាស់ហៅគេឲ្យបំពេញកិច្ចការជាគ្រីស្តទូតដែរ ស្របតាមលក្ខណៈរបស់ខ្លួនជាគ្រីស្តបរិស័ទ។ សរីរាង្គនីមួយៗក្នុងរូបកាយមនុស្សម្នាក់ដែលមានជីវិត មិនគ្រាន់តែរស់នៅយ៉ាងអសកម្មប៉ុណ្ណោះទេ តែសរីរាង្គនីមួយៗរួមចំណែកក្នុងជីវិត និងក្នុងសកម្មភាពទូទៅនៃរូបកាយអ្នកនោះដែរ។ ក្នុងព្រះសហគមន៍ដែលជាព្រះកាយព្រះគ្រីស្ត ក៏ដូច្នេះដែរគឺ «ព្រះកាយនោះចម្រើន និងកសាងឡើងដោយសារសមត្ថភាពរបស់សរីរាង្គនីមួយៗ» (អភ ៤, ១៦)។ លើសពីនេះទៅទៀត សរីរាង្គនៃព្រះកាយព្រះគ្រីស្តរួបរួមគ្នា និងសាមគ្គីគ្នាយ៉ាងជិតស្និទ្ធបំផុត ហេតុនេះហើយ បានជាត្រូវរាប់សរីរាង្គណា ដែលមិនជួយតាមសមត្ថភាពរបស់ខ្លួនឲ្យរូបកាយទាំងមូលចម្រើនឡើង ទុកជាសរីរាង្គដែលគ្មានប្រយោជន៍សម្រាប់ព្រះសហគមន៍ និងសម្រាប់ខ្លួនឯងដែរ។

ក្នុងព្រះសហគមន៍មានមុខងារបម្រើផ្សេងៗពីគ្នា ប៉ុន្តែមានបេសកកម្មតែមួយ។ ព្រះគ្រីស្តបានផ្ញើឲ្យក្រុមគ្រីស្តទូត និងឲ្យក្រុមអ្នកបន្តមុខងារពីអស់លោកនូវបន្ទុកបង្រៀន បន្ទុកនាំឲ្យអ្នកជឿបានវិសុទ្ធ និងបន្ទុកគ្រប់គ្រងព្រះសហគមន៍ក្នុងនាមព្រះអង្គ និងដោយមានអំណាចរបស់ព្រះអង្គផង។ ប៉ុន្តែ ដោយគ្រីស្តបរិស័ទធម្មតាទទួលចំណែកក្នុងបន្ទុករបស់ព្រះគ្រីស្តជាមហាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ គេក៏បំពេញចំណែករបស់ខ្លួនក្នុងបេសកកម្មរបស់ប្រជារាស្ត្រព្រះជាម្ចាស់ទាំងមូល ក្នុងព្រះសហគមន៍និងក្នុងពិភពលោកទាំងមូល (ពន្លឺ ៣១)។ គេបំពេញកិច្ចការរបស់ខ្លួនជាគ្រីស្តទូត ដោយប្ដេជ្ញាចិត្តប្រកាសដំណឹងល្អនិងនាំមនុស្សឲ្យបានវិសុទ្ធ។ នៅពេលគេខិតខំនាំគោលគំនិតមកពីដំណឹងល្អឲ្យជ្រួតជ្រាបអ្វីៗក្នុងលោកីយ៍ ហើយនៅពេលគេយកចិត្តទុកដាក់ធ្វើឲ្យអ្វីៗខាងលោកីយ៍ចម្រើនឡើង គេក៏បំពេញមុខងាររបស់ខ្លួនជាគ្រីស្តទូតដែរ។ ក្នុងវិស័យទាំងនោះ ពួកគេត្រូវធ្វើកិច្ចការរបស់គេក្នុងលោកីយ៍នោះ តាមរបៀបដែលផ្តល់សក្ខីភាពយ៉ាងជាក់ស្តែងអំពីព្រះគ្រីស្ត និងដែលជួយសង្គ្រោះមនុស្សលោក។ គ្រីស្តបរិស័ទធម្មតាមានលក្ខណៈពិសេស គឺរស់នៅក្នុងចំណោមមនុស្សលោក និងក្នុងរឿងលោកីយ៍។ ដូច្នេះហើយ ព្រះជាម្ចាស់ត្រាស់ហៅគេឲ្យបំពេញមុខងារជាគ្រីស្តទូតក្នុងលោកីយ៍ តាមរបៀបខ្លួនជាមេក្នុងម្សៅ ដោយមានថាមពលនៃវិញ្ញាណរបស់ខ្លួនជាគ្រីស្តបរិស័ទ។

## ៣-គ្រឹះនៃមុខងាររបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូត

គ្រីស្តបរិស័ទធម្មតាទទួលភារកិច្ច និងសិទ្ធិជាគ្រីស្តទូត ដោយគេរួបរួមជាមួយព្រះគ្រីស្តជាព្រះសិរសា។ គេចូលរួមក្នុងរូបកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត ដោយអគ្គសញ្ញាជ្រមុជទឹក។ គេទទួលកម្លាំងពីឫទ្ធានុភាពនៃព្រះវិញ្ញាណ ដ៏វិសុទ្ធដោយអគ្គសញ្ញាលាបថ្ងាស គឺព្រះអម្ចាស់ផ្ទាល់ព្រះអង្គចាត់គេឲ្យទៅជាគ្រីស្តទូត។ ព្រះអង្គប្រសិទ្ធិគេឲ្យទៅជាបូជាចារ្យរបស់ព្រះមហាក្សត្រ និងទៅជាជាតិដ៏វិសុទ្ធ (១សល ២, ២-១០) ដើម្បីលើកកិច្ចការទាំងប៉ុន្មានរបស់គេថ្វាយព្រះជាម្ចាស់ទុកជាតង្វាយខាងវិញ្ញាណ និងដើម្បីផ្តល់សក្ខីភាពចំពោះព្រះគ្រីស្តនៅលើផែនដីទាំងមូល។ *"អគ្គសញ្ញាទាំងប៉ុន្មានជាពិសេសអគ្គសញ្ញាអរព្រះគុណដ៏វិសុទ្ធ សុទ្ធតែផ្តល់និងពង្រឹងសេចក្តីស្រឡាញ់របស់គេ គឺសេចក្តីស្រឡាញ់នេះ ជាកម្លាំងជំរុញគេឲ្យបំពេញបេសកកម្មគ្រប់យ៉ាងជាគ្រីស្តទូត"* (ពន្លឺ ៣៣.១០)។

ព្រះវិញ្ញាណដ៏វិសុទ្ធចាក់បង្ហូរជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ក្នុងចិត្តគ្រីស្តបរិស័ទទាំងអស់ក្នុងព្រះសហគមន៍។ គ្រីស្តបរិស័ទបំពេញមុខងារជាគ្រីស្តទូត ដោយផ្ញើជីវិតលើព្រះគ្រីស្ត ដោយមានសេចក្តីសង្ឃឹម និងដោយមានសេចក្តីស្រឡាញ់នោះ។ លើសពីនេះទៅទៀត វិន័យស្តីអំពីសេចក្តីស្រឡាញ់ ជាវិន័យដ៏ប្រសើរជាងគេរបស់ព្រះអម្ចាស់ជំរុញគ្រីស្តបរិស័ទទាំងអស់ឲ្យខិតខំធ្វើកិច្ចការ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយព្រះអង្គយាងមកគ្រងរាជ្យ និងប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គឲ្យមនុស្សទាំងអស់ គឺថា *"សូមឲ្យគេស្គាល់ព្រះជាម្ចាស់ដ៏ពិតតែមួយគត់ និងឲ្យគេស្គាល់ព្រះយេស៊ូគ្រីស្តដែលព្រះអង្គចាត់ឲ្យមកដែរ"* (យហ ១៧, ៣)។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទទាំងអស់ទទួលបន្ទុកដ៏ល្អប្រសើរបំផុត គឺខិតខំដោយឥតឈប់ឈរ ដើម្បីនាំឲ្យមនុស្សលោកនៅលើផែនដីទាំងមូល បានស្គាល់និងទទួលព្រះរាជសារស្តីអំពីការសង្គ្រោះ។

ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានវិសុទ្ធដោយសារអគ្គសញ្ញានានា និងដោយសារមុខងារបម្រើផ្សេងៗ ព្រះអង្គក៏ប្រទានព្រះអំណោយទានពិសេសដល់គ្រីស្តបរិស័ទ (១ករ ១២, ៧) «ប៉ុន្តែព្រះវិញ្ញាណចែកព្រះអំណោយទានទាំងនោះ ឲ្យម្នាក់ៗតាមព្រះហឫទ័យរបស់ព្រះអង្គ (១ករ ១២, ១១) ដើម្បីឲ្យក្រុមគ្រីស្តបរិស័ទទាំងអស់ និងគ្រីស្តបរិស័ទម្នាក់ៗបម្រើអ្នកឯទៀតៗ ស្របតាមព្រះអំណោយទានដែលខ្លួនបានទទួល ហើយទៅជាអ្នកចាត់ចែងដ៏ល្អ ដែលចែកចាយព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់ (១សល ៤, ១០) ដើម្បីកសាងព្រះកាយទាំងមូលក្នុងសេចក្តីស្រឡាញ់ (អភ ៤, ១៦)។ ដោយគ្រីស្តបរិស័ទម្នាក់ៗទទួលព្រះអំណោយទានទាំងនោះ សូម្បីតែព្រះអំណោយដ៏ទាបជាងគេក្តី ក៏ម្នាក់ៗដែលផ្ញើជីវិតលើព្រះគ្រីស្ត មានសិទ្ធិ និងភារកិច្ចប្រើព្រះអំណោយទាំងនេះ ក្នុងព្រះសហគមន៍និងក្នុងពិភពលោក ដើម្បីជាប្រយោជន៍ដល់មនុស្សលោក និងដើម្បីកសាងព្រះសហគមន៍។ គេមានសេរីភាពមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះអង្គផ្លុំទៅទិសណាក៏បាន តាមព្រះហឫទ័យព្រះអង្គ (យហ ៣, ៨)។ គេក៏រួបរួមជាមួយបងប្អូនក្នុងអង្គព្រះគ្រីស្ត ហើយជាពិសេសដោយរួមជាមួយអស់គង្វាលរបស់ខ្លួន គឺគង្វាលទាំងនោះហើយ ដែលមានភារកិច្ចរិះគិតពិចារណាអំពីព្រះអំណោយទានទាំងនោះដើម្បីឲ្យដឹងថា តើជាព្រះអំណោយទានពិតប្រាកដ ឬក៏អត់។ អស់លោកក៏ត្រូវរិះគិតពិចារណាអំពីរបៀបប្រើអំណោយទាននោះ យ៉ាងត្រឹមត្រូវទៀតផង។ អស់លោកមានភារកិច្ចពិចារណាមើលគ្រប់ការទាំងអស់ ហើយស្រង់យកការណាដែលល្អ មិនត្រូវរារាំងសកម្មភាពរបស់ព្រះវិញ្ញាណឡើយ (១ថស ៥, ១២.១៩-២១; ពន្លឺ ១២)។

## ៤-អំពីការរស់នៅតាមព្រះវិញ្ញាណក្នុងកិច្ចការជាគ្រីស្តទូត

ព្រះបិតាចាត់ព្រះបុត្រាឲ្យយាងមក។ ព្រះបុត្រាជាប្រភព និងជាដើមកំណើតនៃកិច្ចការជាគ្រីស្តទូតគ្រប់យ៉ាង

ក្នុងព្រះសហគមន៍។ ហេតុនេះសរឲ្យដឹងជាក់ច្បាស់ថា កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទធម្មតាបានផលផ្លែ លុះត្រាតែគេរួបរួមជាមួយព្រះគ្រីស្តជាប្រភពនៃជីវិត តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ថា «អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំស្ថិតនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ» (យហ ១៥, ៥)។ គ្រីស្តបរិស័ទរួមរស់យ៉ាងជិតស្និទ្ធជាមួយព្រះគ្រីស្តក្នុងព្រះសហគមន៍ ដោយទទួលទានអាហារផ្សេងៗខាងព្រះវិញ្ញាណ ជាអាហាររួមរបស់គ្រីស្តបរិស័ទទាំងអស់ ជាពិសេសដោយរួមចំណែកយ៉ាងសកម្មក្នុងពិធីគោរពប្រណិប័តន៍ (ពិធី ១១)។ ពេលគ្រីស្តបរិស័ទធម្មតា បំពេញការងារលោកីយ៍យ៉ាងត្រឹមត្រូវ តាមសភាពការណ៍នៃការរស់នៅរបស់គេ គេត្រូវប្រើអាហារទាំងនោះ ដើម្បីជៀសវាងមិនឲ្យបំបែកការរួបរួមជាមួយព្រះគ្រីស្តនោះ ពីការរស់នៅធម្មតារបស់គេឡើយ។ ផ្ទុយទៅវិញ គេត្រូវរួបរួមជាមួយព្រះអង្គកាន់តែជិតស្និទ្ធឡើងៗ ដោយប្រព្រឹត្តកិច្ចការរបស់ខ្លួនតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ធ្វើដូច្នេះ ទើបគ្រីស្តបរិស័ទធម្មតាកាន់តែវិសុទ្ធឡើងៗ ដោយចិត្តក្លៀវក្លានិងដោយមានអំណរសប្បាយ ទាំងខិតខំពុះពារការលំបាកប្រចាំថ្ងៃក្នុងជីវភាពរស់នៅ ជាការលំបាកដែលជៀសផុតមិនបាន ដោយប្រុងប្រយ័ត្ននិងដោយចិត្តព្យាយាមខន្តី (ពន្លឺ ៣២ និង ៤០-៤១)។ ទាំងកង្វល់ប្រចាំក្រុមគ្រួសារ ទាំងកិច្ចការខាងលោកីយ៍ ត្រូវភ្ជាប់នឹងជីវិតខាងព្រះវិញ្ញាណរបស់គេ ស្របតាមគ្រីស្តទូតប៉ូលដែលចែងថា «បងប្អូនធ្វើការអ្វីក៏ដោយ ទោះជាពាក្យសម្ដី ឬកិច្ចការក្ដី ត្រូវធ្វើទាំងអស់ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត ទាំងអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា ដោយសារព្រះអង្គផង» (កូឡ ៣.១៧)។

អ្នកចង់រស់នៅតាមបែបនេះ ត្រូវតែផ្ញើជីវិតលើព្រះគ្រីស្តជានិច្ច ត្រូវមានចិត្តសង្ឃឹម និងមានចិត្តស្រឡាញ់ជាដរាប។ មានតែពន្លឺនៃជំនឿ និងការនឹកសញ្ជឹងគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ដែលអាចនាំឲ្យមនុស្សទទួលស្គាល់ព្រះជាម្ចាស់ជានិច្ច និងនៅគ្រប់ទីកន្លែង «ដ្បិតយើងមានជីវិត មានចលនា និងមានភាវៈជាមនុស្ស ដោយសារព្រះអង្គ» (កក ១៧, ២៨)។ ដូច្នេះ យើងអាចស្វែងរកព្រះហឫទ័យរបស់ព្រះអង្គក្នុងគ្រប់កិច្ចការ ហើយក៏អាចរកឃើញព្រះគ្រីស្តក្នុងមនុស្សទាំងអស់ ទាំងនៅក្នុងអ្នកជិត ទាំងនៅក្នុងអ្នកឆ្ងាយដែរ។ យើងអាចវិនិច្ឆ័យពិចារណាយ៉ាងត្រឹមត្រូវអំពីអត្ថន័យដ៏ពិតប្រាកដ និងអំពីតម្លៃនៃកិច្ចការលោកីយ៍ ទាំងយល់គិតដល់ទិសដៅនៃជីវិតមនុស្សទៀតផង។

អស់អ្នកដែលមានជំនឿបែបនេះ ពិតជារស់នៅដោយមានចិត្តសង្ឃឹមថា នឹងបានឃើញព្រះជាម្ចាស់សម្ដែងសិរីរុងរឿងនៃបុត្រធីតារបស់ព្រះអង្គ ទាំងនឹកដល់ព្រះអម្ចាស់យេស៊ូសោយទិវង្គតនៅលើឈើឆ្កាង និងមានព្រះជន្មថ្មីដ៏រុងរឿង។

គ្រីស្តបរិស័ទរស់នៅក្នុងលោកនេះ ប្រៀបដូចជាធ្វើបូជនីយេសក៍ម្យ៉ាង។ គ្រីស្តបរិស័ទធម្មតារួមជាមួយព្រះគ្រីស្តលាក់ទុកក្នុងព្រះជាម្ចាស់ គេរួចពីការធ្វើទាសករនៃចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ តែខិតខំស្វះស្វែងរកសម្បត្តិសួគ៌ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច។ ដូច្នេះគ្រីស្តបរិស័ទធម្មតាមានចិត្តទូលំទូលាយ ខំប្រឹងប្រែងអស់ពីសមត្ថភាព លាតសន្ធឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺគេណែនាំកិច្ចការលោកីយ៍ និងធ្វើឲ្យកិច្ចការទាំងនោះបានពេញលក្ខណៈ តាមគោលគំនិតគ្រីស្តសាសនា។ ពេលគេប្រឈមមុខនឹងការលំបាកក្នុងការរស់នៅ គេយកសេចក្តីក្លាហានពីសេចក្តីសង្ឃឹម ដោយយល់ឃើញថា «ទុក្ខលំបាកនាបច្ចុប្បន្នកាល ពុំអាចប្រៀបផ្ទឹមនឹងសិរីរុងរឿងដែលព្រះជាម្ចាស់នឹងសម្ដែងឲ្យយើងឃើញនៅអនាគតកាលនោះបានឡើយ» (រម ៨, ១៨)។

គ្រីស្តបរិស័ទធម្មតាប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ ជាពិសេសចំពោះបងប្អូនរួមជំនឿ ដោយមានសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ជំរុញ (កាឡ ៦, ១០) គេ «លះបង់ការអាក្រក់គ្រប់យ៉ាងចេញ លះបង់ល្បិចកិច្ចកលទាំងប៉ុន្មាន ការលាក់ពុត ចិត្តច្រណែនឈ្នានីស និងការនិយាយដើមគេគ្រប់យ៉ាងនោះចោល» (១សល ២, ១)។ ធ្វើដូច្នេះ

គេមុខជាទាញមនុស្សទាំងអស់មករកព្រះគ្រីស្ត។ ប៉ុន្តែ «ព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង» (រម ៥, ៥)។ ព្រះហឫទ័យស្រឡាញ់នោះ ប្រោសឲ្យគ្រីស្តបរិស័ទធម្មតាអាចសម្ដែងគំនិតស្របតាមព្រះបន្ទូល ស្ដីអំពីសុភមង្គលដ៏ពិតប្រាកដក្នុងការរស់នៅរបស់គេ។ នៅពេលគេខ្វះខាត គេមិនធ្លាក់ទឹកចិត្តទេ ព្រោះគេដើរតាមព្រះយេស៊ូ ដែលដាក់ខ្លួនជាអ្នកក្រីក្រ ។ ពេលគេមានបរិបូរណ៍ហូរហៀរ គេមិនអួតខ្លួនទេ។ ដោយគេយកគម្រប់តាមព្រះគ្រីស្តជាមនុស្សសុភាពរាបសា គេមិនអួតបំប៉ោងយ៉ាងឥតបានការ (កាឡ ៥, ២៦)។ ផ្ទុយទៅវិញ គេខិតខំឲ្យបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ ជាជាងគាប់ចិត្តមនុស្សលោក គេប្រុងប្រៀបខ្លួនជានិច្ចនឹងលះបង់អ្វីៗទាំងអស់ ព្រោះតែព្រះគ្រីស្ត (លក ១៤, ២៦) និងសុខចិត្តទទួលការប្រៀតបៀន ព្រោះតែសេចក្ដីសុចរិត (មថ ៥, ១០) ទាំងនឹកចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់ថា «បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំ» (មថ ១៦, ២៤)។ គេមានចិត្តស្រឡាញ់រាប់អានគ្នាបែបគ្រីស្តបរិស័ទ គឺជួយគ្នាទៅវិញទៅមកតាមតម្រូវការនៅគ្រប់ពេលវេលា។

របៀបគ្រីស្តបរិស័ទធម្មតារស់នៅតាមព្រះវិញ្ញាណនេះ ត្រូវមានលក្ខណៈពិសេសតាមសភាពការណ៍នៃការរស់នៅរបស់គេម្នាក់ៗ គឺអ្នកខ្លះរស់នៅក្នុងឋានៈជាគូស្វាមីភរិយានិងមានក្រុមគ្រួសារ អ្នកខ្លះនៅលីវ ជាស្រីមេម៉ាយ ឬជាពោះម៉ាយ ជាអ្នកមានជំងឺ។ល។ របៀបគ្រីស្តបរិស័ទធម្មតារស់នៅតាមព្រះវិញ្ញាណក៏មានលក្ខណៈពិសេសតាមអាជីវកម្មរបស់គេម្នាក់ៗ និងតាមសកម្មភាពរបស់គេក្នុងសង្គមដែរ។ ម្នាក់ៗត្រូវតែធ្វើឲ្យទេពកោសល្យ និងព្រះអំណោយទានដែលខ្លួនបានទទួលចម្រើនឡើងជាលំដាប់ ជាពិសេសត្រូវពង្រឹងទេពកោសល្យ និងអំណោយទានដែលសម្របតាមសភាពការណ៍នៃការរស់នៅរបស់ខ្លួន ហើយក៏ត្រូវប្រើអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធរបស់ខ្លួនផ្ទាល់ទៀតផង។

មិនតែប៉ុណ្ណោះ មានគ្រីស្តបរិស័ទធម្មតាខ្លះ តបឆ្លើយនឹងព្រះជាម្ចាស់ត្រាស់ហៅគេយ៉ាងពិសេស ហើយចូលរួមក្នុងសមាគម ឬក្នុងគ្រឹះស្ថានដែលព្រះសហគមន៍ទទួលស្គាល់ជាផ្លូវការ។ គ្រីស្តបរិស័ទទាំងនោះ ត្រូវតែខិតខំប្រតិបត្តិតាមលក្ខណៈពិសេសនៃការរស់នៅ ស្របតាមការរស់នៅតាមព្រះវិញ្ញាណរបស់សមាគម ឬគ្រឹះស្ថានរបស់ខ្លួន។

សូមគ្រីស្តបរិស័ទធម្មតាចូលចិត្តជាខ្លាំងនូវសមត្ថភាពខាងអាជីវកម្ម គំនិតស្រឡាញ់ក្រុមគ្រួសារនិងសង្គម ព្រមទាំងស្រឡាញ់ព្រហ្មវិហារធម៌ ដែលពាក់ព័ន្ធនឹងការរស់នៅក្នុងសង្គម គឺមិនគៃបន្លំ មានបំណងចង់រកយុត្តិធម៌ មានចិត្តទៀងត្រង់ យោគយល់ដល់អ្នកដទៃ មានចិត្តក្លាហាននឹងន។ ប្រសិនបើគ្មានព្រហ្មវិហារធម៌ទាំងនោះទេ គ្មាននរណា អាចរស់នៅក្នុងឋានៈជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដបានឡើយ។

ព្រះនាងព្រហ្មចារិនីម៉ារី ជាព្រះមហាក្សត្រីយានីនៃក្រុមគ្រីស្តទូត ធ្វើជាគំរូដ៏ពេញលក្ខណៈអំពីការរស់នៅតាមព្រះវិញ្ញាណបែបនេះ និងពិតជាគំរូអំពីការរស់នៅជាគ្រីស្តទូតផងដែរ។ នៅពេលព្រះនាងរស់នៅលើផែនដីនេះ នាងរស់នៅតាមរបៀបរស់នៅរបស់មនុស្សទាំងអស់ គឺមានធ្វើការនៅផ្ទះ ធ្វើការនឿយហត់ក្នុងក្រុមគ្រួសារ តែនាងម៉ារីនៅតែរួបរួមយ៉ាងជិតស្និទ្ធជាមួយព្រះបុត្រាជានិច្ច។ នាងក៏រួមសហការក្នុងកិច្ចការរបស់ព្រះសង្គ្រោះ តាមរបៀបប្លែកពីគេទាំងអស់។ ឥឡូវព្រះនាងនៅស្ថានបរមសុខ។ «ដោយនាងមានចិត្តស្រឡាញ់ទុកជាម្ដាយ នាងចាប់អារម្មណ៍នឹងបងប្អូននៃព្រះបុត្រារបស់នាងដែលមិនទាន់ធ្វើដំណើរផុតពីផែនដីនេះនៅឡើយ ហើយដែលនៅតែប្រឈមមុខគ្រោះកាច និងទុក្ខលំបាកផ្សេងៗជាច្រើន ទម្រាំទៅដល់មាតុភូមិដ៏សែនសុខសាន្ត» (ពន្លឺ ៦២.៦៥)។ គ្រីស្តបរិស័ទទាំងអស់ ត្រូវគោរពនាងម៉ារីយ៉ាងពិតប្រាកដ និងធ្វើទាំងជីវិតគេ ទាំងមុខងាររបស់គេជាគ្រីស្តទូត ឲ្យនាងម៉ារីដែលស្រឡាញ់គេក្នុងឋានៈជាមាតា។

# ជំពូក ២

## គោលដៅនៃអ្នកបំពេញកិច្ចការជាគ្រីស្តទូត

### ៥-អារម្ភកថា

ព្រះគ្រីស្តសង្គ្រោះមនុស្សលោក។ ប៉ុន្តែ កិច្ចសង្គ្រោះនេះក៏សំដៅលើអ្វីៗទាំងអស់ដែលនៅក្នុងលោក ឲ្យបានប្រែជាថ្មីដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍មិនគ្រាន់តែទទួលបេសកកម្មនាំសាររបស់ព្រះគ្រីស្ត និងនាំព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គប៉ុណ្ណោះទេ តែព្រះសហគមន៍ទទួលបេសកកម្មនាំគំនិតស្របតាមដំណឹងល្អឲ្យជ្រាបចូលក្នុងអ្វីៗទាំងអស់ ដែលនៅក្នុងពិភពលោក និងធ្វើឲ្យអ្វីៗទាំងនោះបានពេញលក្ខណៈដែរ។ គ្រីស្តបរិស័ទធម្មតាបំពេញបេសកកម្មនៃព្រះសហគមន៍នេះ គឺពិតជាគ្រីស្តទូតនៅក្នុងព្រះសហគមន៍ផង និងនៅក្នុងពិភពលោកផង ទាំងខាងផ្លូវវិញ្ញាណផង ទាំងខាងផ្លូវលោកីយ៍ផងដែរ។ ទោះបីផ្លូវខាងវិញ្ញាណ និងផ្លូវលោកីយ៍ប្លែកពីគ្នាក្តី ក៏ផ្លូវទាំងពីរនោះ ភ្ជាប់ជាមួយគ្នាតាមគម្រោងការតែមួយគត់របស់ព្រះជាម្ចាស់ដែរ គឺព្រះអង្គសព្វព្រះហឫទ័យលើកយកពិភពលោកទាំងមូលសាជាថ្មីក្នុងអង្គព្រះគ្រីស្ត ដើម្បីឲ្យពិភពលោកនេះកើតជាថ្មី ចាប់តាំងពីពេលនៅលើផែនដីនេះទៅ ទម្រាំបានពេញលក្ខណៈនៅថ្ងៃចុងក្រោយបំផុត។ គ្រីស្តបរិស័ទធម្មតាជាសមាជិកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ផង និងជាសមាជិកនៃសង្គមមនុស្សផង តែមានមនសិការតែមួយ ជាមនសិការតាមជំនឿគ្រីស្តសាសនា។ មនសិការនេះ ត្រូវតែណែនាំគេក្នុងវិស័យទាំងពីរនេះជានិច្ច។

### ៦-មុខងារជាគ្រីស្តទូតមានគោលដៅនាំដំណឹងល្អ និងប្រោសមនុស្សឲ្យបានវិសុទ្ធ

ព្រះសហគមន៍ទទួលបេសកកម្មសង្គ្រោះមនុស្សលោក។ មនុស្សទទួលការសង្គ្រោះនេះដោយផ្ញើជីវិតលើព្រះគ្រីស្ត និងដោយព្រះអង្គប្រណីសន្ដោសដល់គេ។ ហេតុនេះ ព្រះសហគមន៍និងគ្រីស្តបរិស័ទទាំងអស់បំពេញមុខងារជាគ្រីស្តទូតមុនដំបូងត្រូវប្រកាសសាររបស់ព្រះគ្រីស្តឲ្យមនុស្សទាំងអស់ស្តាប់ឮ។ គេត្រូវប្រកាសសារនេះ ដោយពាក្យសម្តី និងដោយប្រព្រឹត្តកិច្ចការ គេក៏ត្រូវចែកប្រទានព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គឲ្យអ្នកដទៃទៀតផង។ គេបំពេញកិច្ចការនេះ ជាពិសេសដោយមុខងារបម្រើព្រះបន្ទូល និងដោយធ្វើអគ្គសញ្ញាជូនគេ។ ព្រះសហគមន៍បានផ្ញើមុខងារនេះយ៉ាងពិសេសទៅក្រុមគ្រីស្តបរិស័ទដែលទទួលអគ្គសញ្ញាតែងតាំង ក៏ប៉ុន្តែ គ្រីស្តបរិស័ទធម្មតា ក៏មានតួនាទីផ្ទាល់ដែលមានសារៈសំខាន់ជាទីបំផុត គឺតួនាទីនោះផ្តល់ឲ្យគេទៅជា «សហការីនៃសេចក្តីពិត» (៣ យហ ៨)។ តួនាទីរបស់អស់លោកដែលទទួលមុខងារឃ្វាលណែនាំព្រះសហគមន៍ និងតួនាទីរបស់គ្រីស្តបរិស័ទធម្មតាបង្គ្រប់គ្នាទៅវិញទៅមក យ៉ាងពិសេសក្នុងករណីនេះ។

គ្រីស្តបរិស័ទធម្មតាមានឱកាសជាច្រើនឥតគណនា អាចបំពេញកិច្ចការជាគ្រីស្តទូតដោយនាំដំណឹងល្អ និងប្រោសឲ្យមនុស្សបានវិសុទ្ធ។ គ្រីស្តបរិស័ទផ្តល់សក្ខីភាពតាមការរស់នៅបែបជាគ្រីស្តបរិស័ទ ហើយដោយកិច្ចការដែលគេប្រព្រឹត្ត

ទាំងមានចិត្តគំនិតអំពីលោកខាងលើ។ សក្ខីភាពទាំងពីរនោះ ពិតជាមានកម្លាំងយ៉ាងខ្លាំង អាចទាក់ទាញចិត្តមនុស្សមកកាន់ជំនឿ និងមករកព្រះជាម្ចាស់ ដ្បិតព្រះអម្ចាស់មានព្រះបន្ទូលថា៖ «ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបំភ្លឺមនុស្សទាំងឡាយ។ គេនឹងឃើញអំពើល្អដែលអ្នករាល់គ្នាប្រព្រឹត្ត ហើយលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នាដែល គង់នៅស្ថានបរមសុខ» (មថ ៥,១៦)។

គ្រីស្តបរិស័ទបំពេញកិច្ចការជាគ្រីស្តទូត មិនគ្រាន់តែដោយផ្តល់សក្ខីភាពប៉ុណ្ណោះទេ តែគ្រីស្តទូតដ៏ពិតប្រាកដឆ្លៀតយកគ្រប់ឱកាសសម្រាប់ប្រកាសអំពីព្រះគ្រីស្ត ដោយមានប្រសាសន៍ គឺមានប្រសាន៍ទៅកាន់អ្នកគ្មានជំនឿ ដើម្បីជួយគេឲ្យធ្វើដំណើរទៅកាន់ជំនឿ ព្រមទាំងមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទ ដើម្បីបង្រៀនគេ ពង្រឹងជំនឿរបស់គេដាស់តឿនគេឲ្យស្រឡាញ់ព្រះគ្រីស្តកាន់តែខ្លាំងឡើងៗផងដែរ «ដ្បិតព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជំរុញយើង» (២ករ ៥, ១៤)។ គ្រីស្តទូតប៉ូលមានប្រសាសន៍ថា «ប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អទេ សូមឲ្យខ្ញុំវេទនាទៅចុះ!» (១ករ ៩, ១៦)។ សេចក្តីនេះត្រូវលាន់ឮក្នុងចិត្តគំនិតរបស់គ្រីស្តបរិស័ទទាំងអស់។

នាសម័យបច្ចុប្បន្ន មានសំណួរថ្មីជាច្រើនចោទឡើង ហើយក៏មានការផ្សព្វផ្សាយសេចក្តីខុសជាទម្ងន់ ដែលមានទិសដៅចង់កម្ទេចបំផ្លាញសាសនាដល់ឫស ចង់បំផ្លាញរបៀបរៀបរយខាងសីលធម៌ ព្រមទាំងចង់បំផ្លាញសង្គមមនុស្សផងដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតសូមដាស់តឿនគ្រីស្តបរិស័ទធម្មតាយ៉ាងខ្លាំង សូមឲ្យម្នាក់ៗរួមចំណែកកាន់តែសកម្មក្នុងការរិះគិតយ៉ាងជ្រៅអំពីគោលការណ៍នៃគ្រីស្តសាសនា ឲ្យបានស្របតាមគោលគំនិតនៃព្រះសហគមន៍ គឺម្នាក់ៗត្រូវធ្វើតាមទេពកោសល្យ និងតាមការអប់រំរបស់ខ្លួនខាងលទ្ធិនៃគ្រីស្តសាសនា។ សូមឲ្យគេរួមការពារ គោលការណ៍ទាំងនោះ ព្រមទាំងអនុវត្តតាម ឲ្យបានសមស្របតាមបញ្ហានាសម័យឥឡូវ។

## ៧-ត្រូវប្រែមនុស្សលោកីយ៍ឲ្យបានថ្មីតាមគោលគំនិតគ្រីស្តបរិស័ទ

ព្រះជាម្ចាស់មានគម្រោងការអំពីពិភពលោកដូចតទៅ គឺព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សលោកសុខចិត្តរួមគ្នាកសាងពិភពលោក និងនាំឲ្យពិភពលោកកាន់តែប្រសើរឡើងៗ។ អ្វីៗដែលហៅថា «ពិភពលោក» មានដូចតទៅ គឺសម្បត្តិដែលពាក់ព័ន្ធនឹងជីវិតនិងក្រុមគ្រួសារ វប្បធម៌ កិច្ចការខាងសេដ្ឋកិច្ច អាជីវកម្ម និងមុខងារគ្រឹះស្ថាននៃសមាគមនយោបាយ ទំនាក់ទំនងអន្តរជាតិ និងកិច្ចការផ្សេងៗទៀតស្រដៀងគ្នា ការអភិវឌ្ឍន៍និងការចម្រើនឡើងនៃអ្វីៗទាំងនោះ។ អ្វីៗទាំងនោះមានតម្លៃដោយខ្លួនឯងផ្ទាល់ ព្រោះព្រះជាម្ចាស់បានដាក់តម្លៃនេះនៅក្នុងខ្លួនអ្វីៗទាំងនោះផ្ទាល់ មិនគ្រាន់តែមានតម្លៃទុកជាមធ្យោបាយ ដែលពាក់ព័ន្ធនឹងទិសដៅបំផុតរបស់មនុស្សប៉ុណ្ណោះទេ។ ទោះបីយើងរាប់អ្វីៗនីមួយៗផ្ទាល់ក្តី ឬរាប់អ្វីៗទាំងនោះទុកជាចំណែកក្នុងពិភពលោកទាំងមូលក្តី ក៏ «ព្រះជាម្ចាស់ទតឃើញអ្វីៗ ទាំងអស់ដែលព្រះអង្គបានប្រតិស្ឋានមក ទ្រង់ឈ្វេងយល់ថា ល្អប្រសើរបំផុតហើយ» (កណ ១, ៣១)។ អ្វីទាំងនោះ កើតមកល្អស្រាប់ហើយ តែអ្វីទាំងនោះទទួលតម្លៃដ៏ថ្លៃថ្នូរយ៉ាងពិសេស ដោយមានទំនាក់ទំនងជាមួយមនុស្ស គឺព្រះអង្គប្រតិស្ឋានអ្វីទាំងនោះ ដើម្បីបម្រើមនុស្ស។ ព្រះអង្គក៏សព្វព្រះហឫទ័យប្រមែប្រមូលអ្វីៗទាំងអស់ ទោះនៅក្នុងពិភពលោកក្តីទាំងអ្វីៗហួសពីពិភពលោកនេះក្តី ឲ្យរួបរួមជាអង្គភាពតែមួយក្នុងអង្គព្រះគ្រីស្ត «ដើម្បីឲ្យព្រះអង្គធ្វើជាប្រមុខ ក្នុងគ្រប់វិស័យទាំងអស់» (កូឡ ១, ១៨)។

ដោយព្រះជាម្ចាស់កំណត់ទិសដៅនេះ ព្រះអង្គមិនបណ្តោយឲ្យអ្វីៗទាំងអស់ក្នុងពិភពលោកបាត់បង់ស្វ័យភាពទេ ឬបាត់បង់ទិសដៅនិងបទដ្ឋានរបស់ខ្លួន ឬបាត់បង់មធ្យោបាយនិងសារៈសំខាន់របស់ខ្លួន ដើម្បីជាប្រយោជន៍ដល់មនុស្ស

លោកទេ តែផ្ទុយទៅវិញ ព្រះអង្គប្រោសឲ្យអ្វីៗទាំងនោះមានកម្លាំង និងមានតម្លៃផ្ទាល់កាន់តែខ្លាំង និងកាន់តែពេញលក្ខណៈឡើងៗ។ នៅពេលជាមួយគ្នានេះ ព្រះអង្គលើកអ្វីៗទាំងនោះឲ្យមានកម្រិតខ្ពស់ស្មើនឹងទិសដៅកំណត់ទាំងស្រុងរបស់មនុស្សនៅលើផែនដីនេះ។

តាមប្រវត្តិសាស្ត្រ របៀបមនុស្សប្រើប្រាស់អ្វីៗក្នុងលោកនេះ បណ្តាលឲ្យគេវង្វេងធ្វើផ្តេសផ្តាសជាទម្ងន់។ ដោយសារអំពើបាបខាងដើមដំបូង មនុស្សពិតជាវង្វេងលែងស្គាល់ព្រះជាម្ចាស់ដ៏ពិតប្រាកដ ជាញឹកញាប់គេក៏វង្វេងអំពីសភាពរបស់ខ្លួនជាមនុស្ស និងអំពីគោលការណ៍នៃសីលធម៌ជាច្រើនដង។ ហេតុនេះហើយ បានជាកិរិយាមារយាទនិងអ្វីៗដែលមនុស្សតែងតាំងត្រូវបាត់គុណភាព ហើយគេមើលងាយមើលបុគ្គលម្នាក់ៗទៀតដែរ។ នាសម័យឥឡូវ ក៏មានមនុស្សខ្លះសំអាងហួសហេតុ លើការចម្រើននៃវិទ្យាសាស្ត្រ និងលើការចម្រើននៃបច្ចេកទេស ក៏ដូចជាបណ្តោយខ្លួនទៅក្រាបថ្វាយបង្គំអ្វីៗក្នុងលោកនេះ ទុកជាព្រះរបស់ខ្លួន។ គេត្រឡប់ទៅជាទាសករនៃអ្វីៗក្នុងលោកនោះ គឺគេលែងធ្វើជាម្ចាស់លើអ្វីៗទាំងនោះទៀតហើយ។

ព្រះសហគមន៍ទាំងមូលមានភារកិច្ចជួយមនុស្សលោក ឲ្យមានសមត្ថភាពអាចកសាងពិភពលោក ដើម្បីឲ្យពិភពលោកនេះមានរបៀបរៀបរយយ៉ាងល្អ តម្រង់ទៅរកព្រះជាម្ចាស់ ដោយសារព្រះគ្រីស្ត។ អស់លោកគង្វាលមានភារកិច្ចពន្យល់យ៉ាងច្បាស់នូវគោលការណ៍ ស្តីអំពីទិសនៃសត្វលោកទាំងអស់ និងអំពីការប្រើប្រាស់អ្វីៗក្នុងលោកនេះ។ អស់លោកក៏នាំជំនួយខាងវិញ្ញាណ និងខាងសីលធម៌ ដើម្បីឲ្យព្រះគ្រីស្តប្រែអ្វីៗទាំងអស់ក្នុងពិភពលោកនេះឲ្យបានជាថ្មី។

គ្រីស្តបរិស័ទធម្មតាត្រូវចាត់ទុកថា ភារកិច្ចប្រែពិភពលោកឲ្យបានជាថ្មី ជាភារកិច្ចរបស់ខ្លួនគេផ្ទាល់។ ពួកគេត្រូវសម្រេចចិត្តយ៉ាងជាក់ច្បាស់បំពេញភារកិច្ចនោះ ដោយមានពន្លឺនៃដំណឹងល្អបំភ្លឺចិត្តគំនិត និងដោយមានគោលគំនិត នៃព្រះសហគមន៍ណែនាំ ព្រមទាំងដោយមានសេចក្តីស្រឡាញ់ជំរុញទៀតដែរ។ គ្រីស្តបរិស័ទធម្មតាក្នុងនាម ខ្លួនជាប្រជាពលរដ្ឋនៃលោកនេះ ត្រូវរួមសហការជាមួយប្រជាពលរដ្ឋឯទៀតៗ តាមសមត្ថភាពពិសេសរបស់ខ្លួនផ្ទាល់។ គេទទួលខុសត្រូវខ្លួនឯង និងស្វែងរកសេចក្តីសុចរិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការ និងនៅគ្រប់ទីកន្លែង។ ត្រូវប្រែរបៀបរៀបរយនៃពិភពលោកឲ្យបានជាថ្មី ដើម្បីឲ្យពិភពលោកនេះ កាន់តែស្របតាមគោលការណ៍ដ៏ខ្ពង់ខ្ពស់បំផុតនៃការរស់នៅជាគ្រីស្តបរិស័ទ និងឲ្យបានសម្របតាមការរស់នៅប្លែកៗពីគ្នាតាមស្រុកនីមួយៗ តាមកាលៈទេសៈ និងតាមប្រជាជាតិនានាផង។ ប៉ុន្តែ ត្រូវប្រែរបៀបរៀបរយនៃពិភពលោកដោយគោរពបទដ្ឋាន និងស្របតាមបទដ្ឋាននៃពិភពលោកនេះ។ ក្នុងចំណោមកិច្ចការជាគ្រីស្តទូតទាំងនោះ កិច្ចការខាងសង្គមកិច្ចតាមគ្រីស្តសាសនាសំខាន់ជាងគេ។ មហាសន្និបាតមានបំណងចង់ឲ្យគ្រីស្តបរិស័ទធម្មតា លាតសន្ធឹងកិច្ចការខាងសង្គមកិច្ចនេះ ក្នុងគ្រប់វិស័យនៃពិភពលោកដោយមិនបំភ្លេចវិស័យវប្បធម៌ទៀតផង។

## ៨-កិច្ចការមនុស្សធម៌ គឺជាកិច្ចការរបស់គ្រីស្តបរិស័ទជាគ្រីស្តទូត

សេចក្តីស្រឡាញ់ពិតជាប្រភពនិងជាកម្លាំងរបស់កិច្ចការជាគ្រីស្តទូតគ្រប់យ៉ាង។ ព្រះគ្រីស្តទ្រង់សព្វព្រះហឫទ័យឲ្យកិច្ចការខ្លះទៅជាសញ្ញាសម្គាល់បញ្ជាក់ អំពីបេសកកម្មរបស់ព្រះអង្គក្នុងឋានៈជាព្រះគ្រីស្ត (មថ ១១, ៤-៥) ព្រោះកិច្ចការខ្លះ បញ្ជាក់យ៉ាងជាក់ច្បាស់អំពីសេចក្តីស្រឡាញ់នោះ។

ក្នុងធម្មវិន័យទាំងមូល វិន័យដ៏សំខាន់ជាងគេមានចែងដូចតទៅ គឺត្រូវស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីចិត្តគំនិតនិងស្រឡាញ់អ្នកដទៃឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ (មថ ២២, ៣៧, ៤០)។ ព្រះគ្រីស្តបានលើកវិន័យ ស្តីអំពីសេចក្តី

ស្រឡាញ់ចំពោះអ្នកដទៃនោះ ទុកជាវិន័យផ្ទាល់របស់ព្រះអង្គ។ ព្រះអង្គក៏បានប្រទានឲ្យវិន័យនោះមានអត្ថន័យថ្មី ដោយព្រះអង្គជាមនុស្សពិតប្រាកដ ដូចមនុស្សឯទៀតជាបងប្អូន ទាំងមានព្រះបន្ទូលថា៖ «គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើអ្វី ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ» (មថ ២៥, ៤០)។ ដោយព្រះគ្រីស្តប្រសូតជាមនុស្ស ព្រះអង្គក៏រួបរួមជាមួយមនុស្សលោក ទាំងមូល ទាំងរួមសាមគ្គីជាមួយគេយ៉ាងអស្ចារ្យហួសពីសាមគ្គីធម្មតារវាងមនុស្សនិងមនុស្ស និងបង្រួបបង្រួមគេឲ្យទៅជាមហាគ្រួសារតែមួយ។ ព្រះអង្គក៏មានព្រះបន្ទូលលើកសេចក្តីស្រឡាញ់ ទុកជាលក្ខណៈផ្ទាល់របស់សាវ័កថា៖ «បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជានឹងដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន» (យហ ១៣, ៣៥)។

នៅខាងដើមដំបូង ព្រះសហគមន៍បានភ្ជាប់ «ពិធីជប់លៀងដោយសេចក្តីស្រឡាញ់» ជាមួយនឹងពិធីអរព្រះគុណ។ ដោយភ្ជាប់ពិធីទាំងពីរដូច្នេះ ព្រះសហគមន៍មានបំណងបញ្ជាក់ថា ព្រះសហគមន៍ទាំងមូលរួបរួមគ្នានៅជុំវិញព្រះគ្រីស្តដោយមានសេចក្តីស្រឡាញ់ជាចំណង។ យ៉ាងណាមិញ នៅគ្រប់សម័យព្រះសហគមន៍ក៏បង្ហាញខ្លួន ឲ្យមនុស្សលោកស្គាល់ ដោសារអត្តសញ្ញាអរព្រះគុណនោះ ជាសញ្ញានៃសេចក្តីស្រឡាញ់។ ទោះបីព្រះសហគមន៍មានអំណរ ដោយទទួលស្គាល់ថា អ្នកដទៃក៏ធ្វើអំពើល្អប្រកបដោយសេចក្តីស្រឡាញ់ដែរ ក៏ព្រះសហគមន៍រាប់ថា អំពើតាមមនុស្សធម៌ទុកជាផ្នែកមួយនៃបេសកកម្មរបស់ខ្លួនផ្ទាល់ និងចាត់ទុកការប្រព្រឹត្តអំពើតាមមនុស្សធម៌នោះ ជាសិទ្ធិរបស់ខ្លួន ដែលបំបាត់មិនបាន។ ហេតុនេះហើយ បានជាព្រះសហគមន៍តែងតែគោរពលើកតម្កើងយ៉ាងពិសេសបំផុត នូវកិច្ចការប្រកបដោយមេត្តាករុណាចំពោះជនក្រីក្រនិងជនទន់ខ្សោយ នូវគ្រប់កិច្ចការដែលហៅថា *"កិច្ចការប្រកបដោយសេចក្តីស្រឡាញ់"* និងការជួយគ្នាទៅវិញទៅមក ដើម្បីសម្រាលទុក្ខគ្រប់យ៉ាងរបស់មនុស្សលោកផង។

សព្វថ្ងៃ សកម្មភាពនិងកិច្ចការប្រកបដោយមនុស្សធម៌ទាំងនោះ ក៏កាន់តែមានសារៈសំខាន់។ យើងក៏ត្រូវចាប់អារម្មណ៍ដល់ពិភពលោកទាំងមូល ដ្បិតមធ្យោបាយទូរគមនាគមន៍កាន់តែស្រួលនិងកាន់តែលឿន ធ្វើឲ្យមនុស្សទាំងអស់ហាក់ដូចជាជិតគ្នា មនុស្សដែលរស់នៅក្នុងពិភពលោកទាំងមូល ក៏ដូចជាត្រឡប់ទៅជាក្រុមគ្រួសារតែមួយរួចហើយ។ កិច្ចការនៃសេចក្តីស្រឡាញ់អាច (នឹងត្រូវ) ទៅកាន់មនុស្សទាំងអស់ និងដល់អស់ជនរងគ្រោះ។ គ្រីស្តបរិស័ទ ដែលមានចិត្តស្រឡាញ់ ត្រូវស្វែងរក (និងរកឲ្យឃើញ) មនុស្សនៅគ្រប់ទីកន្លែងដែលរងទុក្ខដោយខ្វះស្បៀងអាហារ ខ្វះទឹកពិសា ខ្វះសម្លៀកបំពាក់ ខ្វះថ្នាំសង្កូវ ខ្វះការរៀនសូត្រ ខ្វះមធ្យោបាយរស់នៅឲ្យបានសមនឹងឋានៈរបស់ខ្លួនជាមនុស្ស។ គ្រីស្តបរិស័ទត្រូវស្វែងរក (និងរកឃើញ) អស់អ្នកដែលត្រូវគ្រោះកាចផ្សេងៗ អស់អ្នកដែលមានជំងឺ អស់អ្នកដែលត្រូវគេនិរទេស ឬត្រូវគេចាប់ឃុំឃាំង។ល។ ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តគេ និងជួយសម្រាលទុក្ខគេដោយផ្តល់ជំនួយស្របតាមទុក្ខរបស់គេ។ ជាដំបូងភារកិច្ចនេះ ជាភាកិច្ចរបស់មនុស្ស និងប្រជាជនដែលមានទ្រព្យសម្បត្តិច្រើនជាងគេ។

ត្រូវរាប់អ្នកដទៃទុកជារូបតំណាងរបស់ព្រះជាម្ចាស់ គឺព្រះអង្គបានប្រតិស្ឋានគេឲ្យបានដូចព្រះអង្គ ហើយត្រូវយល់ឃើញថា អ្នកដទៃនោះពិតជាព្រះគ្រីស្តជាអម្ចាស់នៃយើង។ តាមពិតអ្វីៗទាំងអស់ ដែលយើងជូនទៅអ្នកក្រីក្រ គឺយើងថ្វាយចំពោះព្រះគ្រីស្តជាអម្ចាស់នៃយើងដែរ។ ត្រូវគោរពសេរីភាព និងតម្លៃដ៏ថ្លៃថ្នូររបស់អ្នកដែលខ្លួនជួយនោះ ដោយចិត្តប្រុងប្រយ័ត្ន និងដោយរិះគិតពិចារណា។ ត្រូវមានចិត្តទៀងត្រង់ មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ឬមិនមានបំណងចង់ធ្វើជាម្ចាស់លើគេ។ ត្រូវបំពេញសេចក្តីត្រូវការតាមយុត្តិធម៌ជាមុនសិន ក្រែងលោយើងជូនអ្វីៗទុកជាអំណោយមកពីសេចក្តីស្រឡាញ់ តែតាមពិតជាអ្វីដែលគេត្រូវការឲ្យគេតាមយុត្តិធម៌។ សូមបំបាត់មូលហេតុដែលបណ្តាលឲ្យមាន ទុក្ខលំបាក កុំបំបាត់តែលទ្ធផលនៃមូលហេតុទាំងនោះប៉ុណ្ណោះ។ សូមចាត់ចែងជំនួយឲ្យមានរបៀបរៀបរយ ដើម្បីឲ្យអ្នក

ទទួលជំនួយទាំងនោះបានរួចផុតពីចំណងចំពោះអ្នកដទៃ និងមានលទ្ធភាពអាចទប់ទល់ ដោយខ្លួនឯងបាន។ ធ្វើដូច្នេះ ទើបគ្មាននរណាអាចរិះគន់ កិច្ចប្រព្រឹត្តតាមសេចក្តីស្រឡាញ់នោះទាល់តែសោះ និងគេយល់គ្រប់គ្នាថា កិច្ចការទាំងនោះ ពិតជាកើតមកពីសេចក្តីស្រឡាញ់។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទធម្មតាត្រូវរាប់រកកិច្ចការ ប្រកបដោយសេចក្តីស្រឡាញ់ទុកជាមានតម្លៃយ៉ាងខ្លាំង និងត្រូវជួយធ្វើកិច្ចការទាំងនោះតាមសមត្ថភាពរបស់ខ្លួន។ ត្រូវយកចិត្តទុកដាក់ជាខ្លាំងចំពោះកិច្ចការដែលគេចាប់ផ្តើមធ្វើសម្រាប់ជួយក្នុងសង្គម ទោះជាកិច្ចការរបស់បុគ្គលក្តី ឬជាកិច្ចការសាធារណៈក្តី ដោយមិនបំភ្លេចកិច្ចការអន្តរជាតិទេ។ ដោយជំនួយអន្តរជាតិទាំងនោះ គ្រីស្តបរិស័ទអាចជួយមនុស្ស និងប្រជាជនទាំងអស់ដែលកំពុងតែរងទុក្ខលំបាកយ៉ាងសកម្ម។ ក្នុងកិច្ចការទាំងនេះ សូមឲ្យគ្រីស្តបរិស័ទរួមសហការជាមួយអស់មនុស្សដែលមានឆន្ទៈល្អ។

# ជំពូក ៣

## វិស័យនានាសម្រាប់បំពេញកិច្ចការជាគ្រីស្តទូត

### ៩-អារម្ភកថា

គ្រីស្តបរិស័ទធម្មតាបំពេញកិច្ចការជាគ្រីស្តទូតរបស់ខ្លួន តាមបែបជាច្រើន ទាំងនៅក្នុងព្រះសហគមន៍ ទាំងនៅក្នុងពិភពលោក។ ក្នុងវិស័យទាំងពីរនោះ គេអាចបំពេញកិច្ចការជាគ្រីស្តទូតតាមរបៀបផ្សេងៗពីគ្នា។ ឥឡូវ យើងសូមរំឭកគ្រីស្តបរិស័ទអំពីវិស័យសំខាន់ៗដែលមានដូចតទៅ៖ សហគមន៍គ្រីស្តបរិស័ទ ក្រុមគ្រួសារ យុវជនយុវនារី ក្រុមតាមវណ្ណៈក្នុងសង្គម វិស័យជាតិនិងអន្តរជាតិ។ សព្វថ្ងៃស្ត្រីៗមានសកម្មភាពកាន់តែខ្លាំងឡើង ក្នុងគ្រប់វិស័យនៃការរស់នៅក្នុងសង្គម។ ហេតុនេះ ត្រូវឲ្យស្ត្រីៗទទួលចំណែកកាន់តែខ្លាំងឡើងៗ ក្នុងវិស័យទាំងអស់នៃកិច្ចការជាគ្រីស្តទូតរបស់ព្រះសហគមន៍។ ការរួមចំណែកនេះមានសារៈសំខាន់ខ្លាំងណាស់។

### ១០-វិស័យសហគមន៍របស់គ្រីស្តបរិស័ទ

គ្រីស្តបរិស័ទធម្មតា ទទួលចំណែកក្នុងមុខងាររបស់ព្រះគ្រីស្តជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ។ ហេតុនេះ គេបំពេញចំណែកមុខងារយ៉ាងសកម្មក្នុងការរស់នៅ និងក្នុងសកម្មភាពនៃព្រះសហគមន៍។ គេមានសកម្មភាពជាចាំបាច់ក្នុងសហគមន៍គ្រីស្តបរិស័ទ។ ប្រសិនបើគ្រីស្តបរិស័ទធម្មតាគ្មានសកម្មភាពទេ អស់លោកគង្វាលធ្វើកិច្ចការរបស់ខ្លួនក្នុងឋានៈជាគ្រីស្តទូត ដោយពុំបានលទ្ធផលយ៉ាងពេញលេញឡើយ។ កាលពីដើម មានបុរសនិងស្ត្រីតែងតែជួយគ្រីស្តទូតប៉ូលក្នុងកិច្ចប្រកាសដំណឹងល្អ (កក ១៨, ១៨-២៦; រម ១៦, ៣)។ យ៉ាងណាមិញ គ្រីស្តបរិស័ទធម្មតា ដែលមានឆន្ទៈជាគ្រីស្តទូតយ៉ាងពិតប្រាកដក៏ជួយបងប្អូន លើកទឹកចិត្តអស់លោកគង្វាល ទាំងសមាជិកឯទៀតៗ នៃប្រជារាស្ត្រដែលផ្ញើជីវិតលើព្រះជាម្ចាស់ (១ករ ១៦, ១៧-១៨)។ គ្រីស្តបរិស័ទធម្មតាចិញ្ចឹមជីវិតរបស់ខ្លួនតាមព្រះវិញ្ញាណ ដោយរួមយ៉ាងសកម្មក្នុងពិធីគោរពប្រណិប័តន៍នៃសហគមន៍របស់ខ្លួន។ គេយកចិត្តទុកដាក់ នឹងកិច្ចការជាគ្រីស្តទូតរបស់សហគមន៍នោះ។ គេក៏នាំផ្លូវមនុស្សដែលប្រហែលស្ថិតនៅឆ្ងាយពីព្រះសហគមន៍ ឲ្យមករកព្រះសហគមន៍វិញ។ គេយកចិត្តទុកដាក់រួមសហការយ៉ាងខ្លាំង ក្នុងការប្រកាសផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាពិសេសដោយអប់រំជំនឿក្មេងៗ។ គេយកសមត្ថភាពរបស់ខ្លួនមកធ្វើឲ្យមុខងារបម្រើព្រះសហគមន៍ និងការចាត់ចែងទ្រព្យសម្បត្តិរបស់ព្រះសហគមន៍កាន់តែមានប្រសិទ្ធភាពឡើងៗផង។

ភូមិគ្រីស្តបរិស័ទ ពិតជាឧទាហរណ៍មួយយ៉ាងអស្ចារ្យ អំពីកិច្ចការជាគ្រីស្តទូតរួម ដ្បិតក្នុងភូមិគ្រីស្តបរិស័ទនោះ មនុស្សប្លែកៗពីគ្នារួបរួមគ្នាជាផ្លូងតែមួយ និងចូលរួមក្នុងព្រះសហគមន៍សកល។ សូមឲ្យគ្រីស្តបរិស័ទធម្មតាមានទម្លាប់រួមសហការយ៉ាងជិតស្និទ្ធជាមួយអស់លោកគង្វាលរបស់ខ្លួន លើកយកបញ្ហារបស់ខ្លួនផ្ទាល់ និងបញ្ហារបស់មនុស្សលោក ព្រមទាំងសំណួរអំពីការសង្គ្រោះមនុស្សលោក នាំមកឲ្យព្រះសហគមន៍ពិនិត្យមើល និងរកដំណោះស្រាយ ទាំងគិតគូរដល់

យោបល់របស់គ្រីស្តបរិស័ទទាំងអស់។ គេរួមសហការតាមលទ្ធភាពរបស់គេ ក្នុងគ្រប់កិច្ចការជាគ្រីស្តទូត និងគ្រប់កិច្ចប្រកាសដំណឹងល្អរបស់ព្រះសហគមន៍ជាក្រុមគ្រួសាររបស់គេ។

គ្រីស្តបរិស័ទធម្មតា ត្រូវពង្រឹងចិត្តគំនិតស្រឡាញ់ភូមិភាគរបស់ខ្លួនឲ្យកាន់តែខ្លាំងឡើងៗ ព្រោះថា ព្រះសហគមន៍តាមភូមិនានាដូចជាកោសិការនៃភូមិភាគ។ គេប្រុងខ្លួនតបឆ្លើយនឹងអភិបាលរបស់ខ្លួន ឲ្យរួមសហការនឹងកិច្ចការ ដែលភូមិភាគចាត់ចែង។ ម្យ៉ាងទៀត គេត្រូវខិតខំតបឆ្លើយនឹងសេចក្តីត្រូវការរបស់ប្រជាជនដែលរស់នៅក្នុងទីក្រុង និងនៅតាមជនបទ ដោយមិនគ្រាន់តែរួមសហការត្រឹមតែភូមិ ឬភូមិភាគប៉ុណ្ណោះទេ តែខិតខំពង្រីកការរួមសហការរបស់គេទៅសហការអន្តរភូមិ អន្តរភូមិភាគ ហើយរហូតទៅដល់កម្រិតជាតិនិងអន្តរជាតិ។ សព្វថ្ងៃ ដោយប្រជាជនកាន់តែផ្លាស់ប្តូរទីលំនៅជានិច្ច មានចំណងនានាទៅវិញទៅមកកើតកាន់តែច្រើនឡើង ទូរគមនាគមន៍កាន់តែស្រួលទៅៗ មិនបណ្តោយឲ្យក្រុមមួយក្នុងសង្គមអាចរស់នៅដោយឯកឯង មិនគិតដល់ក្រុមឯទៀតៗបានទេ។ គ្រីស្តបរិស័ទធម្មតា ត្រូវយកចិត្តទុកដាក់នឹងសេចក្តីទាមទាររបស់ប្រជារាស្ត្រព្រះជាម្ចាស់ ដែលខ្ចាត់ខ្ចាយនៅលើផែនដីទាំងមូល ជាពិសេសគេយកចិត្តទុកដាក់នឹងកិច្ចជួយព្រះសហគមន៍នៅប្រទេសដែលមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត គឺជួយជាសម្ភារៈ ឬជាបុគ្គល។ គ្រីស្តបរិស័ទមានភារកិច្ចនិងកិត្តិយស សងព្រះជាម្ចាស់នូវទ្រព្យសម្បត្តិមួយចំណែកដែលគេបានទទួលពីព្រះអង្គ។

## ១១-ក្រុមគ្រួសារ

ព្រះអាទិករបានលើកសហគមន៍ នៃគូស្វាមីភរិយាធ្វើជាប្រភព និងជាគ្រឹះនៃសង្គមមនុស្ស។ ព្រះអង្គក៏ប្រោសប្រណីឲ្យគូស្វាមីភរិយាសម្តែងគម្រោងការដ៏អស្ចារ្យ ដែលមានអត្ថន័យជ្រៅបំផុតអំពីព្រះគ្រីស្ត និងអំពីព្រះសហគមន៍ (អភ ៥, ២២)។ ហេតុនេះ កិច្ចការជាគ្រីស្តទូតរបស់គូស្វាមីភរិយា និងរបស់ក្រុមគ្រួសារ មានសារៈសំខាន់យ៉ាងពិសេសសម្រាប់ព្រះសហគមន៍ និងសម្រាប់សង្គមទូទៅ។

គូស្វាមីភរិយាពិតជាសហការីរបស់ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្តោស និងជាសាក្សីអំពីជំនឿចំពោះគូរបស់ខ្លួនចំពោះកូន និងចំពោះសមាជិកឯទៀតៗក្នុងក្រុមគ្រួសាររបស់គេដែរ។ គេបញ្ជូនបន្តជំនឿដល់កូនរបស់ខ្លួនមុនគេ និងអប់រំជំនឿនេះឲ្យកូនមុនគេដែរ។ គេអប់រំកូនៗដោយបង្រៀន និងដោយធ្វើជាគំរូតាមការរស់នៅ បែបជាគ្រីស្តបរិស័ទ និងជាគ្រីស្តទូតដែរ។ ពេលកូនៗជ្រើសរើសរបៀបរស់នៅតាមព្រះជាម្ចាស់ត្រាស់ហៅ គេជួយទូន្មានកូនៗដោយប្រាជ្ញា។ ប្រសិនបើគេយល់ឃើញថា ព្រះជាម្ចាស់ត្រាស់ហៅ ឲ្យកូនទៅជាបូជាចារ្យ គេជួយកូនឲ្យថ្វាយខ្លួនជាបូជាចារ្យ ឬជាបព្វជិត។

តាំងពីដើមរៀងមក ហើយជាពិសេសសព្វថ្ងៃ គូស្វាមីភរិយាមានភារកិច្ចធ្វើជាគ្រីស្តទូតយ៉ាងសំខាន់ជាងគេ គឺបង្ហាញបញ្ជាក់ដោយការរស់នៅទាំងស្រុងរបស់គេថា គូស្វាមីភរិយាមិនអាចបំបាក់បំបែកគ្នាបានឡើយ ហើយចំណង នៃអាពាហ៍ពិពាហ៍រវាងគូស្វាមីភរិយាពិតជាចំណងដ៏វិសុទ្ធផង។ គេមានភារកិច្ចប្រកាសយ៉ាងខ្លាំងដាច់អហង្ការថា ឪពុកម្តាយ និងអាណាព្យាបាលមានសិទ្ធិនិងភារកិច្ចអប់រំកូនៗតាមបែបជាគ្រីស្តបរិស័ទ។ គេមានភារកិច្ចការពារតម្លៃដ៏ថ្លៃថ្នូរនិងស្វ័យភាពដ៏ត្រឹមត្រូវនៃក្រុមគ្រួសារ។ ហេតុនេះហើយបានជាគូស្វាមីភរិយា និងគ្រីស្តបរិស័ទទាំងអស់ ត្រូវតែរួមសហការជាមួយមនុស្សដែលមានឆន្ទៈល្អ ដើម្បីឲ្យច្បាប់សង្គមការពារសិទ្ធិទាំងនោះយ៉ាងពេញលេញ។ សូមរដ្ឋអំណាចដែលគ្រប់គ្រងប្រទេសនីមួយៗ ទទួលស្គាល់សេចក្តីទាមទាររបស់ក្រុមគ្រួសារអំពីសិទ្ធិឲ្យគេមានផ្ទះសម្បែង សិទ្ធិក្នុងការអប់រំកូន សិទ្ធិទាមទារសភាពការណ៍ការងារដ៏ល្អ សិទ្ធិទាមទារសុវត្ថិភាពក្នុងសង្គម និងសិទ្ធិពិនិត្យមើលការកំណត់

ពន្ធនាគារ តាមយុត្តិធម៌។ នៅពេលប្រជាជនផ្លាស់ប្តូរទីលំនៅ រដ្ឋអំណាចត្រូវគោរពយ៉ាងពេញលេញ នូវសិទ្ធឲ្យក្រុមគ្រួសាររួមរស់ជាមួយគ្នា។

ព្រះជាម្ចាស់បានប្រទានឲ្យក្រុមគ្រួសារមានបេសកកម្ម ឲ្យទៅជាកោសិកាដែលផ្តល់ជីវិតដើមដំបូងដល់សង្គម។ ក្រុមគ្រួសារអាចបំពេញបេសកកម្មនេះបាន លុះត្រាតែសមាជិកក្រុមគ្រួសារគោរពនិងស្រឡាញ់ព្រះជាម្ចាស់ រួមគ្នាអធិដ្ឋាន និងបង្ហាញខ្លួនទុកជាព្រះវិហាររបស់ព្រះសហគមន៍នៅក្នុងផ្ទះ។ ក្រុមគ្រួសារអាចបំពេញបេសកកម្មនេះបាន លុះត្រាតែសមាជិកក្រុមគ្រួសារទាំងអស់ចូលរួមក្នុងពិធីគោរពប្រណិប័តន៍នៃព្រះសហគមន៍។ នៅទីបញ្ចប់ ក្រុមគ្រួសារអាចបំពេញបេសកកម្មនេះបាន លុះត្រាតែក្រុមគ្រួសារទទួលភ្ញៀវយ៉ាងសកម្ម ហើយខិតខំរកយុត្តិធម៌ក្នុងសង្គម និងបម្រើបងប្អូនទាំងអស់ដែលខ្វះខាត។ ក្នុងចំណោមកិច្ចការជាគ្រីស្តទូតទាំងប៉ុន្មានរបស់ក្រុមគ្រួសារ ត្រូវកំណត់កិច្ចការពិសេសផ្សេងៗដូចតទៅ៖ ការទទួលកូនដែលត្រូវគេបោះបង់ចោល ការទទួលជនបរទេសដោយរាក់ទាក់ ការជួយធ្វើឲ្យសាលារៀន មានដំណើរការយ៉ាងស្រួល ការទូន្មាន និងជួយកូនជំទង់ ការជួយគូរដណ្តឹងឲ្យរៀបចំខ្លួនទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ ការអប់រំជំនឿក្មេងៗ ការលើកទឹកចិត្តគូស្វាមីភរិយា និងក្រុមគ្រួសារដែលជួបឧបសគ្គខាងសម្ភារៈ ឬខាងផ្លូវសីលធម៌ និងការជួយចាស់ជរាឲ្យទទួលផលដ៏ត្រឹមត្រូវនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺមនុស្សចាស់ជរាមិនគ្រាន់តែត្រូវមានអ្វីៗ ដែលខានមិនបានប៉ុណ្ណោះទេ តែគាត់ត្រូវទទួលផលដ៏ត្រឹមត្រូវនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចថែមទៀតផង។

ក្រុមគ្រួសារគ្រីស្តបរិស័ទត្រូវផ្តល់សក្ខីភាពយ៉ាងថ្លៃថ្នូរបំផុត អំពីព្រះគ្រីស្តនៅចំពោះមុខមនុស្សលោក ដោយភ្ជាប់ចិត្តនឹងព្រះសហគមន៍ក្នុងការរស់នៅទាំងស្រុងរបស់គេ និងដោយបង្ហាញក្រុមគ្រួសារគ្រីស្តបរិស័ទទុកជាគំរូ។ គេត្រូវផ្តល់សក្ខីភាពបែបនោះជានិច្ច និងនៅគ្រប់កន្លែង ជាពិសេសនៅតំបន់គេចាប់ផ្តើមផ្សព្វផ្សាយពូជដើមដំបូងនៃដំណឹងល្អ និងនៅតំបន់ព្រះសហគមន៍ចាប់ផ្តើមកើតឡើង ព្រមទាំងនៅតំបន់ព្រះសហគមន៍ជួបប្រទះឧបសគ្គដ៏ធ្ងន់ធ្ងរ។

ប្រហែលក្រុមគ្រួសារជាច្រើនត្រូវរួបរួមគ្នា បង្កើតជាសមាគម ដើម្បីជួយគ្នាឲ្យទៅដល់គោលដៅនៃកិច្ចការគ្រីស្តទូតរបស់ខ្លួន។

## ១២- យុវជនយុវនារី

យុវជនយុវនារីពិតជាកម្លាំងដ៏មានសារៈសំខាន់ក្នុងសង្គមទំនើបយើងនេះ។ សភាពការណ៍រស់នៅរបស់គេ ទំនៀមទម្លាប់រិះគិតរបស់គេ ទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ខ្លួន សុទ្ធតែប្រែប្រួលទាំងស្រុងរួចហើយ។ ជាញឹកញាប់ ពួកគេបានទទួលមុខងារថ្មីក្នុងសង្គម និងខាងសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ទោះបីពួកគេមានសារៈសំខាន់កាន់តែខ្លាំងឡើងៗជារៀងរាល់ថ្ងៃក្នុងសង្គមនិងខាងនយោបាយក្តី ក៏ពួកគេមិនសូវបានទទួលការអប់រំ ឲ្យផ្ទុកបន្ទុកថ្មីទាំងនោះយ៉ាងសមរម្យដែរ។

ដោយយុវជនយុវនារីមានសារៈសំខាន់កាន់តែខ្លាំងឡើងៗក្នុងសង្គម ដូច្នេះ យុវជនយុវនារីក៏ត្រូវមានសកម្មភាពជាគ្រីស្តទូតកាន់តែខ្លាំងឡើងៗដែរ។ ធម្មជាតិក៏ជំរុញយុវជនឲ្យធ្វើដូច្នេះដែរ។ នៅពេលគេដឹងខ្លួនអំពីបុគ្គលិកលក្ខណៈរបស់ខ្លួនផ្ទាល់ កម្លាំងនៃធម្មជាតិជំរុញគេឲ្យមានសកម្មភាពខ្លាំងហួសហេតុ ពេលនោះគេទទួលខុសត្រូវផ្ទាល់ ហើយចង់ទទួលចំណែកក្នុងជីវិតខាងសង្គមនិងខាងវប្បធម៌។ ប្រសិនបើ ព្រះវិញ្ញាណរបស់ព្រះគ្រីស្តជ្រួតជ្រាប ក្នុងកម្លាំងពុះកញ្ជ្រោលរបស់គេនោះ ហើយប្រសិនបើគេមានចិត្តចង់ស្តាប់បង្គាប់ព្រះសហគមន៍ និងស្រឡាញ់ព្រះសហគមន៍ផង គេមុខជានឹងអាចបង្កើតផលជាច្រើនដែលមានតម្លៃដ៏ថ្លៃថ្នូរ។ យុវជនយុវនារីត្រូវត្រឡប់ទៅជាគ្រីស្តទូត សម្រាប់យុវជន

យុវនារីឯទៀតៗមុនគេ ព្រោះគេមានទំនាក់ទំនងជាមួយយុវជនទាំងនោះ គេបំពេញកិច្ចការជាគ្រីស្តទូត ដោយខ្លួនគេ និងទៅវិញទៅមក ស្របតាមវណ្ណៈក្នុងសង្គមដែលគេរស់នៅ។

មនុស្សពេញវ័យត្រូវយកចិត្តទុកដាក់និយាយសន្ទនាយ៉ាងស្និទ្ធស្នាលជាមួយយុវជនយុវនារី។ ទោះបីមនុស្សពេញវ័យនិងយុវជនយុវនារីមានអាយុខុសប្លែកគ្នាក៏ដោយ ក៏ការសន្ទនាទាំងនោះ នាំឲ្យគេស្គាល់គ្នាទៅវិញទៅមក និងចែកចាយសម្បត្តិដ៏ថ្លៃថ្នូរខាងវិញ្ញាណរបស់ខ្លួនទៅវិញទៅមកដែរ។ មនុស្សពេញវ័យអាចជំរុញដាស់តឿនយុវជនយុវនារី ឲ្យទៅជាគ្រីស្តទូតបាន ជាពិសេសដោយធ្វើជាគំរូឲ្យគេ។ ជួនកាលមនុស្សពេញវ័យនឹងផ្តល់យោបល់ប្រកបដោយប្រាជ្ញា និងផ្តល់ជំនួយប្រកបដោយប្រសិទ្ធភាព។ ចំពោះយុវជនយុវនារីវិញ ត្រូវតែគោរពមនុស្សពេញវ័យ ត្រូវទុកចិត្តលើគាត់។ ទោះបីតាមធម្មជាតិយុវជនយុវនារីមានបំណងចង់ប្រែអ្វីៗទាំងអស់ឲ្យបានជាថ្មីក្តី ក៏យុវជនយុវនារីត្រូវចេះគោរពប្រពៃណីឲ្យបានសមរម្យតាមការគួរដែរ។

ក្មេងៗត្រូវបំពេញសកម្មភាពជាគ្រីស្តទូតផ្ទាល់ដែរ។ គេជាសាក្សីដែលមានជីវិតរស់រវើកអំពីព្រះគ្រីស្តនៅក្នុងចំណោមមិត្តសម្លាញ់ តាមសមត្ថភាពរបស់គេរៀងៗខ្លួន។

## ១៣- វណ្ណៈនៅក្នុងសង្គម

អ្នកបំពេញកិច្ចការជាគ្រីស្តទូតក្នុងវណ្ណៈនៅក្នុងសង្គម តែងយកចិត្តទុកដាក់ នាំគំនិតជាគ្រីស្តបរិស័ទឲ្យជ្រាបចូលក្នុងចិត្តគំនិត ក្នុងរបៀបរស់នៅក្នុងច្បាប់ និងក្នុងរចនាសម្ព័ន្ធសហគមន៍ដែលម្នាក់ៗរស់នៅ។ គ្មាននរណាអាចបំពេញកិច្ចការនេះឲ្យបានត្រឹមត្រូវជំនួសគ្រីស្តបរិស័ទធម្មតាទេ ព្រោះជាកិច្ចការរបស់គេផ្ទាល់តែម្តង។ គ្រីស្តបរិស័ទធម្មតាអាចបំពេញកិច្ចការនេះបាននៅកន្លែងគេរស់នៅ គឺម្នាក់ៗទៅជាគ្រីស្តទូតសម្រាប់ម្នាក់ៗទៀត។ គេបន្ថែមសក្ខីភាពនៃពាក្យសម្តីលើសក្ខីភាពនៃការរស់នៅ។ គេមានសមត្ថភាពអាចជួយបងប្អូនច្រើនជាងគេ នៅកន្លែងធ្វើការ នៅកន្លែងគេប្រកបអាជីវកម្ម នៅកន្លែងសិក្សា នៅកន្លែងគេមានទីលំនៅ នៅកន្លែងលេងលំហែកាយ ហើយនៅសហគមន៍ក្នុងភូមិទៀតផង។

គ្រីស្តបរិស័ទធម្មតាបំពេញបេសកកម្មនៃព្រះសហគមន៍ក្នុងលោកនេះ ជាពិសេសសម្តែងឲ្យមនុស្សលោកឃើញថា គេរស់នៅស្របនឹងជំនឿ គឺជំនឿលើព្រះគ្រីស្តនេះដែលផ្តល់ឲ្យគេទៅជាពន្លឺបំភ្លឺមនុស្សលោក។ ដោយគេរស់នៅតាមយុត្តិធម៌ក្នុងគ្រប់សកម្មភាព គេអាចដាស់មនុស្សម្នាក់ៗឲ្យមានចិត្តស្រឡាញ់ចំពោះអ្វីៗដ៏ពិតប្រាកដនិងអ្វីៗដ៏ល្អ។ ដូច្នេះគេក៏អាចជំរុញចិត្តមនុស្សឲ្យទៅកាន់ព្រះគ្រីស្ត និងឲ្យទៅកាន់ព្រះសហគមន៍នៅថ្ងៃណាមួយពុំខាន។ គេរស់នៅទាំងស្រឡាញ់អ្នកដទៃទុកជាបងប្អូន ជាហេតុបណ្តាលឲ្យគេចែករំលែកសភាពការណ៍រស់នៅ និងសភាពការណ៍ការងារ ចែករំលែកទុក្ខវេទនា និងសេចក្តីប៉ងប្រាថ្នារបស់បងប្អូនទាំងនោះ។ ធ្វើដូច្នេះ គេចាត់ចែងចិត្តគំនិតមនុស្ស បន្តិចម្តងៗ ឲ្យទទួលព្រះជាម្ចាស់ដែលប្រោសប្រណីសង្គ្រោះគេ។ នៅទីបញ្ចប់ ដោយគេដឹងខ្លួនយ៉ាងជាក់ច្បាស់ អំពីការខុសត្រូវរបស់ខ្លួនផ្ទាល់ក្នុងការរស់ក្នុងសង្គម គេខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងក្រុមគ្រួសារ ក្នុងសង្គម និង តាមអាជីវកម្មដោយចិត្តទូលំទូលាយបែបជាគ្រីស្តបរិស័ទ។ របៀបប្រព្រឹត្តនេះមុខជានឹងជ្រួតជ្រាបទៅដល់វណ្ណៈសង្គមគេរស់នៅ និងកន្លែងគេធ្វើការផង។

កិច្ចការជាគ្រីស្តទូតបែបនេះ សំដៅទៅលើមនុស្សទាំងអស់ ទោះជាមានចំនួនធំយ៉ាងណាក្តី។ គ្មាននរណាមានសិទ្ធិឃាត់មិនឲ្យមនុស្សណាទទួលសម្បត្តិខាងវិញ្ញាណ ឬខាងសម្ភារៈ ដែលគ្រីស្តទូតប្រគល់ឲ្យគេនោះឡើយ។ ប៉ុន្តែ អស់គ្រីស្តទូតដ៏ពិតប្រាកដមិនស្កប់ចិត្តដោយគ្រាន់តែបំពេញកិច្ចការនេះប៉ុណ្ណោះទេ គេត្រូវយកចិត្តទុកដាក់ប្រកាសព្រះគ្រីស្ត

ដោយនិយាយអំពីព្រះអង្គចំពោះអស់អ្នកដែលរស់នៅជុំវិញគេ។ មនុស្សជាច្រើនអាចទទួលដំណឹងល្អ និងអាចទទួលស្គាល់ព្រះគ្រីស្ត ដោយសារតែគ្រីស្តបរិស័ទធម្មតាដែលរស់នៅជាមួយគ្នាប៉ុណ្ណោះ។

## ១៤-វិស័យជាតិ និងអន្តរជាតិ

កិច្ចការជាគ្រីស្តទូតតាមវិស័យជាតិ និងអន្តរជាតិ ធំទូលំទូលាយណាស់ ជាកន្លែងគ្រីស្តបរិស័ទធម្មតាចាត់ចែងប្រាជ្ញានៃគ្រីស្តសាសនាយ៉ាងពិសេស។ គ្រីស្តបរិស័ទកាតូលិកត្រូវដឹងខ្លួនថា គេមានភារកិច្ចពង្រឹងនិងពង្រីកប្រយោជន៍រួមដ៏ពិតប្រាកដ ដោយសុខចិត្តបម្រើជាតិ និងដោយបំពេញភារកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋ។ ដូច្នេះគេអាចនាំរដ្ឋអំណាចឲ្យទទួលស្គាល់យោបល់របស់គេ និងប្រើអំណាចតាមយុត្តិធម៌ ហើយបង្កើតច្បាប់ស្របតាមសីលធម៌ទាមទារនោះ និងតាមប្រយោជន៍រួមដែរ។ គ្រីស្តបរិស័ទកាតូលិកដែលមានសមត្ថភាពអំពីនយោបាយ ហើយដែលមានជំនឿមាំមួន និងស្គាល់លទ្ធិនៃគ្រីស្តសាសនាយ៉ាងសមរម្យ កុំបដិសេធគ្រប់គ្រងកិច្ចការសាធារណៈឡើយ។ ដោយគ្រប់គ្រងកិច្ចការសាធារណៈយ៉ាងល្អ គេអាចរួមសហការក្នុងកិច្ចរកប្រយោជន៍រួម និងរៀបចំផ្លូវជូនដំណឹងល្អទៀតផង។

គ្រីស្តបរិស័ទកាតូលិកត្រូវយកចិត្តទុកដាក់ រួមសហការជាមួយមនុស្សទាំងអស់ដែលមានឆន្ទៈល្អ ដើម្បីលើកស្ទួយអ្វីៗដ៏ពិតប្រាកដ សុចរិត វិសុទ្ធ និងគួរឲ្យស្រឡាញ់ (ភល ៤, ៨)។ ត្រូវរួមសន្ទនាជាមួយអ្នកទាំងនោះ ទៅរកគេដោយប្រាជ្ញា និងដោយចិត្តធន់ទន់សុភាពរាបសា រកផ្លូវជួយកែច្នៃស្ថាប័នខាងសង្គម និងស្ថាប័នសាធារណៈឲ្យកាន់តែប្រសើរឡើងតាមគោលគំនិតនៃដំណឹងល្អ។

ក្នុងចំណោមសញ្ញាសម្គាល់នៃសម័យឥឡូវ ត្រូវកំណត់សម្គាល់យ៉ាងពិសេសថា ប្រជាជននានាមានគំនិតចង់រួមសាមគ្គីគ្នា ជាគំនិតកាន់តែខ្លាំងឡើងៗដែលជៀសមិនបាន។ គ្រីស្តបរិស័ទធម្មតាដែលបំពេញកិច្ចការជាគ្រីស្តទូត ត្រូវពង្រឹងគោលគំនិតនេះ និងជួយកែប្រែឲ្យទៅជាបំណងយ៉ាងស្មោះ និងយ៉ាងសកម្មទៅបង្កើតសង្គមដែលមនុស្សរាប់អានគ្នាជាបងប្អូនវិញ។ នៅទីបញ្ចប់ គ្រីស្តបរិស័ទធម្មតាត្រូវដឹងខ្លួនអំពីវិស័យអន្តរជាតិ អំពីសំណួរនិងដំណោះស្រាយខាងលទ្ធិនៃសាសនានានាដែលលេចឡើងថ្មីៗ ជាពិសេសត្រូវចាប់អារម្មណ៍ចំពោះប្រជាជននានា ដែលខិតខំឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ឡើង។

អស់អ្នកដែលធ្វើការនៅក្នុងចំណោមប្រជាជាតិបរទេស ឬដែលនាំជំនួយដល់ប្រជាជាតិទាំងនោះ ត្រូវនឹកចងចាំថាទំនាក់ទំនងរវាងប្រជាជននានា ដូចជាការដោះដូរដ៏ពិតប្រាកដ ត្រូវរាប់គ្នាទុកជាបងប្អូន គឺភាគីទាំងពីរផ្តល់អ្វីមួយ និងទទួលអ្វីមួយ ទៅវិញទៅមកផង។ អស់អ្នកដែលធ្វើដំណើរទៅបរទេស ទោះជាក្នុងមូលហេតុការងារក្តី ឬក្នុងមូលហេតុជាទេសចរក្តី ក៏ត្រូវនឹកចងចាំថា នៅគ្រប់កន្លែងគេកំពុងធ្វើដំណើរទៅ គេក៏ជាទូតរបស់ព្រះគ្រីស្តដែរ និងត្រូវមានកិរិយាមាយាទតាម ឋានៈជាទូតរបស់ព្រះអង្គនេះ។

# ជំពូក ៤

## របៀបផ្សេងៗធ្វើជាគ្រីស្តទូត

### ១៥-អារម្ភកថា

គ្រីស្តបរិស័ទធម្មតាអាចបំពេញកិច្ចការរបស់ខ្លួនជាគ្រីស្តទូតម្នាក់ៗក៏បាន ឬរួមក្នុងសហគមន៍ និងសមាគមផ្សេងៗក៏បានដែរ។

### ១៦-កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទម្នាក់ៗ មានសារៈសំខាន់ ហើយមានច្រើនបែប

គ្រីស្តបរិស័ទម្នាក់ៗត្រូវបំពេញកិច្ចការ ជាគ្រីស្តទូតដោយផ្ទាល់ខ្លួន គឺកិច្ចការនេះ សុទ្ធតែហូរមកពីការរស់នៅជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ (យហ ៤, ១៤)។ នេះជាដើមកំណើតនិងជាលក្ខណៈនៃគ្រប់កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទម្នាក់ៗ ឬនៃកិច្ចការរួមជាគ្រីស្តទូតរបស់ក្រុមគ្រីស្តបរិស័ទ។ គ្មានអ្វីអាចជំនួសគោលការណ៍នេះបានឡើយ។

កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទម្នាក់ៗ បានផលជានិច្ចហើយនៅគ្រប់ទីកន្លែង។ ជួនកាលក្នុងសភាពការណ៍ខ្លះ មានតែគ្រីស្តបរិស័ទម្នាក់ៗទេ ដែលអាចបំពេញកិច្ចការជាគ្រីស្តទូតនេះបាន។ ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទធម្មតាទាំងអស់ ទោះគេរស់នៅតាមរបៀបណាក្តី ទោះបីគេគ្មានលទ្ធភាពចូលរួមសហការក្នុងចលនាផ្សេងៗក្តី ក៏គេមានភារកិច្ចបំពេញកិច្ចការជាគ្រីស្តទូតនេះដែរ។

គ្រីស្តបរិស័ទធម្មតា អាចរួមចំណែកជាច្រើនបែបច្រើនយ៉ាងក្នុងកិច្ចសាងសង់ព្រះសហគមន៍ និងនាំឲ្យមនុស្សលោកបានវិសុទ្ធ ព្រមទាំងធ្វើឲ្យមនុស្សលោកមានជីវិតរស់រវើកក្នុងអង្គព្រះគ្រីស្ត។

គ្រីស្តបរិស័ទធម្មតាម្នាក់ៗបំពេញកិច្ចការជាគ្រីស្តទូតយ៉ាងពិសេស ដោយផ្តល់សក្ខីភាពតាមការរស់នៅរបស់ខ្លួននៅគ្រប់ពេលវេលា ដោយមានជំនឿ មានសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ណែនាំ។ សក្ខីភាពនេះពិតជាសញ្ញាសម្គាល់ស្របតាមសម័យយើងនេះ ហើយក៏សម្តែងព្រះគ្រីស្តដែលរស់នៅក្នុងអស់អ្នកផ្ញើជីវិតលើព្រះអង្គ។ ក្នុងសភាពការណ៍ខ្លះ គ្រីស្តបរិស័ទធម្មតាបំពេញកិច្ចការជាគ្រីស្តទូត ដោយប្រកាសអំពីព្រះគ្រីស្ត ការនេះពិតជាចាំបាច់បំផុត។ ម្នាក់ៗ ពន្យល់ និងផ្សព្វផ្សាយលទ្ធិរបស់ព្រះអង្គតាមសភាពការណ៍រស់នៅ និងតាមសមត្ថភាពរៀងៗខ្លួន ហើយប្រកាសលទ្ធិនេះដោយចិត្តស្មោះ។

លើសពីនេះទៅទៀត គ្រីស្តបរិស័ទធម្មតាក្នុងឋានៈខ្លួនជាពលរដ្ឋនៃពិភពលោកនេះ ក៏រួមសហការជាមួយអ្នកដទៃក្នុងករណីទាំងប៉ុន្មាន ដែលពាក់ព័ន្ធនឹងការសាងសង់និងការគ្រប់គ្រងពិភពលោក។ ដូច្នេះពួកគេត្រូវរិះគិតឲ្យកាន់តែជ្រៅអំពីមូលហេតុណែនាំឲ្យគេប្រព្រឹត្ត ក្នុងការរស់នៅជាក្រុមគ្រួសារ ក្នុងរបៀបប្រកបអាជីវកម្ម ក្នុងការរស់នៅតាមវប្បធម៌ និងក្នុងរបៀបរស់នៅក្នុងសង្គម តាមពន្លឺនៃជំនឿ។ ប្រសិនបើគេមានឱកាស គេក៏ត្រូវបង្ហាញឲ្យអ្នកឯទៀតៗដឹងអំពីមូល

ហេតុនៃការប្រព្រឹត្តរបស់ខ្លួន។ ដោយរិះគិតដូច្នេះ គេមុខជានឹងដឹងខ្លួនថា គេជាសហការីរបស់ព្រះជាម្ចាស់ ដែលប្រតិស្ឋានអ្វីៗទាំងអស់ ដែលព្រះអង្គរំដោះមនុស្សលោក និងដែលប្រោសឲ្យមនុស្សលោកបានវិសុទ្ធ។ គេក៏នឹងលើក តម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែរ។

នៅទីបញ្ចប់ គ្រីស្តបរិស័ទធម្មតានឹងរស់នៅដោយមានសេចក្តីស្រឡាញ់ណែនាំ ហើយបញ្ជាក់សេចក្តីស្រឡាញ់នេះ ដោយប្រព្រឹត្តកិច្ចការឲ្យបានច្បាស់តាមសមត្ថភាពរៀងៗខ្លួន។

គ្រីស្តបរិស័ទធម្មតាត្រូវនឹកចងចាំថា គេអាចមានទំនាក់ទំនងជាមួយមនុស្សទាំងអស់ និងរួមសហការក្នុងកិច្ចសង្គ្រោះមនុស្សលោកទាំងមូល ដោយចូលរួមក្នុងពិធីគោរពប្រណិប័តន៍ជាសាធារណៈ ដោយអធិដ្ឋានម្នាក់ឯង ដោយធ្វើតបធម៌ និងដោយសុខចិត្តទទួលកិច្ចការ និងទទួលទុក្ខលំបាកប្រចាំជីវិត ដែលធ្វើឲ្យគេបានដូចព្រះគ្រីស្តដែលរងទុក្ខលំបាក (២ករ ៤, ១០; កូឡ ១, ២៤)។

## ១៧-កិច្ចការជាគ្រីស្តទូតគ្រីស្តបរិស័ទម្នាក់ៗក្នុងសភាពការណ៍ខ្លះ

កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទម្នាក់ៗ ពិតជាការជាចាំបាច់ជាទីបំផុតនិងមានលក្ខណៈជាបន្ទាន់ នៅតំបន់ណាដែលព្រះសហគមន៍គ្មានសេរីភាព។ ក្នុងសភាពការណ៍ដ៏សែនលំបាកទាំងនោះ គ្រីស្តបរិស័ទធម្មតាធ្វើការជំនួសលោកគង្វាល តាមតែគេអាចធ្វើបាន។ ជួនកាលគេប្រថុយឲ្យគេចាប់ខ្លួន ឬប្រថុយជីវិតក៏មានដែរ ដោយបង្ហាត់បង្រៀនលទ្ធិនៃគ្រីស្តសាសនាឲ្យអ្នករស់នៅជុំវិញ អប់រំគេឲ្យកាន់គ្រីស្តសាសនា និងឲ្យមានចិត្តគំនិតកាតូលិក។ គេដាស់តឿនអ្នកដទៃឲ្យទទួលអគ្គសញ្ញាជាញឹកញាប់ ឲ្យគោរពថ្វាយបង្គំព្រះជាម្ចាស់ដោយចិត្តស្រឡាញ់ ជាពិសេសឲ្យទទួលអគ្គសញ្ញាអរព្រះគុណ។ មហាសន្និបាតអរព្រះគុណព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត ដែលព្រះអង្គនៅតែគាំទ្រគ្រីស្តបរិស័ទធម្មតាខ្លះ ដែលមានសេចក្តីក្លាហានទុកជាវីរបុរស នៅពេលគេបៀតបៀនធ្វើបាប។ មហាសន្និបាត សម្តែងនូវសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះគេ ដូចឪពុកស្រឡាញ់កូនដូច្នេះដែរ និងអរគុណគេថែមទៀតផង។

កិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទម្នាក់ៗ មានសារៈសំខាន់ជាខ្លាំងនៅកន្លែងណាមានគ្រីស្តបរិស័ទចំនួនតិច និងរស់នៅដាច់ពីគ្នា។ ក្នុងសភាពការណ៍នោះ គ្រីស្តបរិស័ទធម្មតាអាចបំពេញកិច្ចការជាគ្រីស្តទូតតែម្នាក់ៗ ដោយមានមូលហេតុដូចខាងលើ ឬដោយមូលហេតុពិសេសមកពីអាជីវកម្មរបស់គេដែរ។ គេក៏អាចជួបជុំគ្នាជាក្រុមតូចៗ ដោយគ្មានស្ថាប័នឬការចាត់ចែងរឹងប៉ឹងទេ ប៉ុន្តែក្រុមតូចៗទាំងនោះត្រូវជាសញ្ញាសម្គាល់សម្តែងអំពីព្រះសហគមន៍ដែលរួមគ្នា និងត្រូវសម្តែងឲ្យអ្នកដទៃឃើញជានិច្ចថា គេជាសក្ខីភាពអំពីសេចក្តីស្រឡាញ់ដ៏ពិតប្រាកដដែរ។

គ្រីស្តបរិស័ទធម្មតាជួយគ្នាទៅវិញទៅមកតាមផ្លូវវិញ្ញាណ ដោយស្រឡាញ់គ្នា និងដោយចែករំលែកបទពិសោធន៍របស់ខ្លួន។ ធ្វើដូច្នេះ ទើបគេរៀបចំខ្លួន ឲ្យមានសមត្ថភាពអាចពុះពារឧបសគ្គនានា បណ្តាលមកគេរស់នៅដាច់ឡែកពីគ្នា។ គេក៏រៀបចំខ្លួនឲ្យបង្កើតផលកាន់តែច្រើនតាមផ្លូវជាគ្រីស្តទូត។

## ១៨-សារៈសំខាន់នៃការចាត់ចែងកិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទឲ្យមានរបៀបរៀបរយ

ព្រះជាម្ចាស់ត្រាស់ហៅ គ្រីស្តបរិស័ទឲ្យបំពេញមុកិច្ចការជាគ្រីស្តទូតដោយផ្ទាល់ខ្លួន ស្របតាមសភាពការណ៍ផ្សេងៗនៃការរស់នៅរបស់គេ។ ប៉ុន្តែមិនត្រូវបំភ្លេចថា មនុស្សមានលក្ខណៈជាអ្នករស់នៅក្នុងសង្គម ព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យប្រមែប្រមូលអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ឲ្យទៅជាប្រជារាស្ត្ររបស់ព្រះអង្គ (១សល ២.៥-១០) និង

បង្រួបបង្រួមគេឲ្យទៅជាព្រះកាយតែមួយ (១ករ ១២, ១២)។ ហេតុនេះ ការចាត់ចែងកិច្ចការជាគ្រីស្តទូត ឲ្យមានរបៀបរៀបរយ ពិតជាស្របតាមលក្ខណៈរបស់មនុស្ស និងតាមលក្ខណៈរបស់គ្រីស្តបរិស័ទទៀតផង។ ការចាត់ចែងកិច្ចការជាគ្រីស្តទូតឲ្យមានរបៀបរៀបរយនេះ ក៏បង្ហាញសញ្ញាសម្គាល់បញ្ជាក់ថា ព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយក្នុងអង្គព្រះគ្រីស្ត ដែលមានព្រះបន្ទូលថា «នៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះជាមួយគេដែរ» (មថ ១៨, ២០)។

ហេតុនេះហើយបានជាគ្រីស្តបរិស័ទ ត្រូវបំពេញកិច្ចការរបស់ខ្លួនជាគ្រីស្តទូត ដោយព្រមគ្នារកទិសដៅតែមួយ។ សូមឲ្យគេបំពេញកិច្ចការរបស់ខ្លួនជាគ្រីស្តទូតនៅក្រុមគ្រួសារ នៅក្នុងព្រះសហគមន៍ក្នុងភូមិនិងក្នុងភូមិភាគ ដែលជាកន្លែងបង្ហាញលក្ខណៈរួមនៃកិច្ចការជាគ្រីស្តទូត។ សូមឲ្យគេបំពេញកិច្ចការជាគ្រីស្តទូត ក្នុងក្រុមដែលគេបានជ្រើសរើសរួមគ្នាដោយសេរី។

កិច្ចការជាគ្រីស្តទូតចាត់ចែងឲ្យមានរបៀបរៀបរយ មានសារៈសំខាន់ណាស់ ព្រោះថា ក្នុងក្រុមនៃព្រះសហគមន៍ ឬក្នុងក្រុមតាមវណ្ណៈផ្សេងៗក្នុងសង្គម អ្នកបំពេញកិច្ចការជាគ្រីស្តទូត ត្រូវតែធ្វើការរួម។ ក្រុមដែលកើតមក ដើម្បីបំពេញកិច្ចការជាគ្រីស្តទូតរួម ក៏តែងគាំទ្រសមាជិករបស់គេ អប់រំគេឲ្យបំពេញកិច្ចការរួមនេះបាន ហើយចាត់ចែង និងណែនាំកិច្ចការរបស់គេថែមទៀតផង។ ហេតុនេះ ដោយគេធ្វើកិច្ចការរួមជាមួយគ្នា យើងសង្ឃឹមថា គេនឹងបានលទ្ធផលច្រើនជាងម្នាក់ៗដែលបំពេញកិច្ចការដោយដាច់ឡែកពីគ្នា។

ក្នុងសភាពការណ៍នាបច្ចុប្បន្នកាល នៅកន្លែងណាគ្រីស្តបរិស័ទធម្មតាបំពេញសកម្មភាព ត្រូវចាត់ចែងកិច្ចការជាគ្រីស្តទូតរួម និងឲ្យមានរបៀបរៀបរយជាចាំបាច់។ បើគេខិតខំប្រឹងប្រែងរួបរួមគ្នាយ៉ាងស្អិតរមួត ទើបគេអាចបានផលតាមទិសដៅទាំងប៉ុន្មាននៃកិច្ចការជាគ្រីស្តទូត។ បើគេប្រឹងប្រែងរួមគ្នា ទើបគេអាចការពារផលទាំងនោះយ៉ាងសកម្មបាន។ បើយល់ឃើញដូច្នេះ នោះកិច្ចការជាគ្រីស្តទូតមុខជាជ្រួតជ្រាបក្នុងចិត្តគំនិតរួមនៃក្រុមណាមួយ និងនាំឲ្យប្រែសភាពការណ៍នៃការរស់នៅរបស់ក្រុមនោះ ដែលគ្រីស្តទូតមានបំណងទាក់ទងជាមួយ។ បើមិនធ្វើដូច្នេះទេ អ្នកទាំងនោះគ្មានលទ្ធភាពអាចតស៊ូប្រឆាំងនឹងមតិសាធារណៈ ឬស្ថាប័នដែលតែងតែគាបសង្កត់គេនោះឡើយ។

## ១៩ កិច្ចការជាគ្រីស្តទូតចាត់ចែងឲ្យមានរបៀបរៀបរយ

សមាគមបំពេញកិច្ចការជាគ្រីស្តទូត មានច្រើនបែបណាស់។ មានសមាគមខ្លះ មានបំណងចង់ទៅកាន់ទិសដៅនៃកិច្ចការជាគ្រីស្តទូតទូទៅនៃព្រះសហគមន៍។ មានសមាគមខ្លះ មានគោលបំណងចង់ប្រកាសដំណឹងល្អ និងចង់ណែនាំមនុស្សលោកឲ្យបានវិសុទ្ធ តាមទស្សនៈពិសេសម៉្យាងរបស់គេ។ មានសមាគមខ្លះ មានគោលបំណង ចង់ឲ្យអ្វីៗក្នុងពិភពលោកនេះ មានជីវិតរស់រវើកតាមគំនិតនៃគ្រីស្តសាសនា។ មានសមាគមខ្លះទៀត មានគោលបំណងចង់ផ្តល់សក្ខីភាពអំពីព្រះគ្រីស្ត ជាពិសេសដោយធ្វើកិច្ចការបង្ហាញធម៌មេត្តាករុណា និងសេចក្តីស្រឡាញ់។

ក្នុងចំណោមក្រុមទាំងនោះ ត្រូវចាប់អារម្មណ៍មុនគេនឹងសមាគម ដែលជួយសមាជិកក្រុមនោះឲ្យរស់នៅ កាន់តែស្របនឹងជំនឿរបស់គេ។ សមាគមទាំងនោះក៏លើកតម្កើងការរស់នៅជាធម្មតារបស់គេឲ្យបានស្របតាមជំនឿ។ ក្រុមទាំងប៉ុន្មាន មានគោលដៅបម្រើបេសកកម្មរបស់ព្រះសហគមន៍ចំពោះមនុស្សលោក មិនមែនមានគោលដៅឲ្យក្រុមរបស់ខ្លួនចម្រើនឡើងទេ។ ក្រុមមួយមានតម្លៃចំពោះកិច្ចការជាគ្រីស្តទូត លុះត្រាតែក្រុមនោះប្រព្រឹត្តកិច្ចការស្របតាមគោលដៅនៃព្រះសហគមន៍ លុះត្រាតែក្រុមនោះផ្តល់សក្ខីភាព ដែលមានលក្ខណៈគ្រីស្តបរិស័ទសុទ្ធសាធ និងលុះត្រាតែសមាជិក

ម្នាក់ៗ និងសមាគមទាំងមូលរស់នៅតាមគោលគំនិតនៃដំណឹងល្អ។

ដោយយល់ឃើញថា សង្គមនាបច្ចុប្បន្នកាលរីកចំរើនឡើង និងចាត់ចែងរចនាសម្ព័ន្ធជាលំដាប់លំដោយបេសកកម្មសកលរបស់ព្រះសហគមន៍ ទាមទារឲ្យសមាគមជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទកាតូលិក កាន់តែចម្រើនឡើង នៅតាមវិស័យអន្តរជាតិ។ ប្រសិនបើក្រុម និងសមាជិកដែលចូលរួមក្នុងអង្គការអន្តរជាតិកាតូលិកទាំងនោះ រួមគ្នាកាន់តែជិតស្និទ្ធឡើងៗ អង្គការទាំងនោះ មុខជាបានលទ្ធផលតាមទិសដៅរបស់ខ្លួនឲ្យកាន់តែស្រួល។

គ្រីស្តបរិស័ទធម្មតាមានសិទ្ធិបង្កើតសមាគម មានសិទ្ធិណែនាំសមាគម និងមានសិទ្ធិចូលរួមក្នុងសមាគម ដែលកើតរួចហើយ ប៉ុន្តែ ត្រូវតែរក្សាចំណងទំនាក់ទំនងជាមួយអំណាចនៃព្រះសហគមន៍ជានិច្ច។ ក៏ប៉ុន្តែ ត្រូវប្រយ័ត្នកុំឲ្យបែកខ្ញែកកម្លាំងឡើយ។ ប្រសិនបើមានបង្កើតសមាគមថ្មីៗ និងកិច្ចការផ្សេងៗដោយគ្មានមូលហេតុគ្រប់គ្រាន់ទេនោះ ឬប្រសិនបើមានរក្សាទុកសមាគមទាំងប៉ុន្មានដែលលែងមានប្រយោជន៍ហើយ ឬមួយទៀត ប្រសិនបើមានប្រព្រឹត្តតាមវិធីហួសសម័យ មុខជាកម្លាំងបែកខ្ញែកគ្នាពុំខាន។ នៅទីបញ្ចប់ ប្រហែលមិនគួរយករបៀបមុខងារជាគ្រីស្តទូតពីប្រទេសមួយមកអនុវត្តក្នុងប្រទេសមួយទៀត ដោយមិនបានរិះគិតពិចារណាជាមុនទេ។

## ២០-កិច្ចការកាតូលិក

តាំងពីប៉ុន្មានឆ្នាំកន្លងមក ក្នុងប្រទេសជាច្រើន មានចំនួនគ្រីស្តបរិស័ទធម្មតាបំពេញកិច្ចការជាគ្រីស្តទូត កាន់តែច្រើនឡើងៗ ហើយរួមគ្នាជាក្រុមៗ តាមរបៀបផ្សេងៗនៃកិច្ចការរបស់គេ និងតាមសមាគមប្លែកៗពីគ្នាផង។ ក្រុម និងសមាគមទាំងនោះ បានបំពេញ (និងនៅតែបំពេញ) កិច្ចការដែលច្បាស់ជាកិច្ចរបស់គ្រីស្តទូតមែន ដោយរួមយ៉ាងជិតស្និទ្ធជាមួយអស់លោកអភិបាល។ ក្នុងចំណោមក្រុម និងសមាគមទាំងនោះ និងក្រុមស្រដៀងគ្នានិងបុរាណជាងគេ ត្រូវកំណត់សម្គាល់មុនគេ ក្រុមទាំងប៉ុន្មានដែលបង្កើតផលជាច្រើនថ្វាយព្រះគ្រីស្តយាងមកគ្រងរាជ្យ ដោយប្រើវិធីផ្សេងៗ។ អភិបាលព្រះសហគមន៍ក្រុងរ៉ូម និងអភិបាលឯទៀតៗជាច្រើន នាំគ្នាជួយនិងសរសើរក្រុមយ៉ាងត្រឹមត្រូវ ហើយដាក់ឈ្មោះក្រុម និងសមាគមទាំងនោះថា «កិច្ចការកាតូលិក»។ ធម្មតាគេរាប់ក្រុមទាំងនោះទុកជាគ្រីស្តបរិស័ទធម្មតាដែលរួមសហការជាមួយអស់លោកអភិបាលក្នុងឋានៈអស់លោកបំពេញកិច្ចការជាគ្រីស្តទូត។

របៀបបំពេញកិច្ចការជាគ្រីស្តទូតបែបនេះ ទោះជាមានឈ្មោះថា «កិច្ចការកាតូលិក» ក្តី ឬគ្មានឈ្មោះនេះក្តី ក៏បំពេញកិច្ចការជាគ្រីស្តទូត ដែលមានតម្លៃយ៉ាងប្រសើរ។

- ក្រុមទាំងនោះតែងតាំងឡើងដោយមានលក្ខណៈដូចតទៅ៖

  ក) ក្រុមទាំងនោះ មានគោលដៅផ្ទាល់ គឺទិសដៅរបស់ព្រះសហគមន៍ ដែលបំពេញកិច្ចការជាគ្រីស្តទូតពោលគឺចង់ប្រកាសដំណឹងល្អ នាំមនុស្សលោកឲ្យបានវិសុទ្ធ ហើយអប់រំមនសិការរបស់គេតាមមាគ៌ានៃគ្រីស្តសាសនា ដើម្បីឲ្យគេមានសមត្ថភាពអាចនាំគោលគំនិតនៃដំណឹងល្អ ឲ្យជ្រួតជ្រាបក្នុងសហគមន៍ និងក្នុងវណ្ណៈផ្សេងៗក្នុងសង្គម។

  ខ) គ្រីស្តបរិស័ទធម្មតារួមសហការជាមួយក្រុមអភិបាលតាមរបៀបផ្ទាល់របស់គេ នាំបទពិសោធន៍របស់គេព្រមទាំងទទួលខុសត្រូវក្នុងការណែនាំក្រុមទាំងនោះ និងក្នុងការស្វែងរករបៀបអនុវត្តតាមការណែនាំរបស់ព្រះសហគមន៍ ហើយក៏ទទួលខុសត្រូវក្នុងការបង្កើតកម្មវិធីអនុវត្ត និងក្នុងការពិនិត្យការអនុវត្តន៍នោះតទៅទៀតផង។

គ) គ្រីស្តបរិស័ទធម្មតាទាំងនោះ ប្រព្រឹត្តកិច្ចការរួមគ្នាដូចជា រូបកាយដែលមានរបៀបរៀបរយ។ ការរួមនេះសម្តែង យ៉ាងច្បាស់អំពីព្រះសហគមន៍ដែលរួមគ្នា និងធ្វើឲ្យកិច្ចការជាគ្រីស្តទូតបានលទ្ធផលច្រើនជាង។

ឃ) ទោះជាគ្រីស្តបរិស័ទធម្មតាទាំងនោះ ចាប់ផ្តើមបំពេញកិច្ចការជាគ្រីស្តទូតដោយខ្លួនឯងក្តី ឬតបឆ្លើយនឹងលោកអភិបាលដែលអញ្ជើញឲ្យគេធ្វើការ និងរួមសហការជាមួយអស់លោកអភិបាល ក្នុងកិច្ចការជាគ្រីស្តទូតក្តី ក៏គេធ្វើការក្រោមការណែនាំដ៏ខ្ពង់ខ្ពស់ របស់អស់លោកអភិបាល ដែលអាចបញ្ជាក់ពីការរួមសហការនោះ ដោយចាត់គេឲ្យធ្វើយ៉ាងច្បាស់។

ក្រុមដែលមានលក្ខណៈទាំងនោះ តាមការយល់ឃើញរបស់អស់លោកអភិបាលត្រូវចាត់ទុកជា «កិច្ចការកាតូលិក» ទោះបីគេមានរចនាសម្ព័ន្ធ និងឈ្មោះផ្សេងៗ តាមទីកន្លែង និងតាមប្រជាជាតិទាមទារក្តី។

មហាសន្និបាតដ៏វិសុទ្ធសូមធានាដល់ក្រុមទាំងនោះយ៉ាងខ្លាំង ដែលច្បាស់ជាតបឆ្លើយនឹងសេចក្តីត្រូវការនៃកិច្ចការជាគ្រីស្តទូតរបស់ព្រះសហគមន៍ក្នុងប្រទេសជាច្រើន។ មហាសន្និបាតក៏អញ្ជើញអស់លោកគង្វាលនិងគ្រីស្តបរិស័ទធម្មតាដែលធ្វើការក្នុងក្រុមទាំងនោះ ឲ្យណែនាំក្រុមទាំងនោះយ៉ាងត្រឹមត្រូវតាមលក្ខណៈ ចែងខាងលើកាន់តែល្អឡើងៗ និងឲ្យរួមសហការក្នុងព្រះសហគមន៍ដូចបងប្អូន ជាមួយអស់អ្នកដែលបំពេញកិច្ចការជាគ្រីស្តទូតតាមរបៀបផ្សេងៗទៀត។

## ២១-ត្រូវយកចិត្តទុកដាក់ចំពោះក្រុមដែលបំពេញកិច្ចជាគ្រីស្តទូត

ត្រូវគោរពក្រុមទាំងប៉ុន្មានដែលបំពេញកិច្ចការជាគ្រីស្តទូតតាមសមគួរ ក៏ប៉ុន្តែ អស់លោកអភិបាលសរសើរ គាំទ្រ និងបង្កើតក្រុមខ្លះទុកជាមានលក្ខណៈបន្ទាន់ជាងគេ តាមតម្រូវការនៃពេលវេលានិងនៃទីកន្លែង។ អស់លោកគង្វាល បព្វជិត បព្វជិតា និងគ្រីស្តបរិស័ទធម្មតា ត្រូវចាត់ទុកក្រុមទាំងនោះទុកជាសំខាន់ជាងគេ ហើយម្នាក់ៗ ត្រូវពង្រីកក្រុមទាំងនោះតាមបេសកកម្មរៀងៗខ្លួន។ ក្នុងចំណោមក្រុមទាំងនោះ ត្រូវកត់សម្គាល់យ៉ាងពិសេស សមាគម ឬក្រុមអន្តរជាតិរបស់គ្រីស្តបរិស័ទកាតូលិក។

## ២២-គ្រីស្តបរិស័ទធម្មតា ដែលបម្រើព្រះសហគមន៍យ៉ាងពិសេស

ក្នុងព្រះសហគមន៍ ត្រូវគោរព និងយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះគ្រីស្តបរិស័ទធម្មតានៅលីវក្តី មានគ្រួសារក្តី ដែលសុខចិត្តប្តេជ្ញាចិត្តយកកម្លាំងកាយកម្លាំងចិត្ត យកសមត្ថភាពនៃអាជីវកម្មរបស់គេ មកបម្រើស្ថាប័ននិងសកម្មភាពនានានៃព្រះសហគមន៍ អស់មួយរយៈពេលក្តី ឬរហូតអស់មួយជីវិតក្តី។ យើងមានអំណរសប្បាយជាខ្លាំងដោយឃើញថាមានចំនួនគ្រីស្តបរិស័ទធម្មតាកាន់តែច្រើនឡើងជារៀងរាល់ថ្ងៃ ស្ម័គ្រចិត្តបម្រើសមាគមនានានិងកិច្ចការជាគ្រីស្តទូត ទាំងនៅក្នុងប្រទេសរបស់ខ្លួន ទាំងក្នុងវិស័យអន្តរជាតិ ជាពិសេសក្នុងព្រះសហគន៍កាតូលិកនៅប្រទេសដែលមានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត និងក្នុងព្រះសហគមន៍កំពុងកើតឡើង។

អស់លោកគង្វាលត្រូវទទួលគ្រីស្តបរិស័ទធម្មតាទាំងនោះដោយអំណរសប្បាយទាំងអរព្រះគុណព្រះជាម្ចាស់ផង។ អស់លោកត្រូវយកចិត្តទុកដាក់ឲ្យគេរស់នៅតាមសភាពការណ៍ត្រឹមត្រូវតាមយុត្តិធម៌ តាមសមធម៌ និងតាមសេចក្តីស្រឡាញ់តាមអស់លោកអាចធ្វើបាន។ ជាពិសេស ត្រូវផ្គត់ផ្គង់ជីវភាពគេ និងក្រុមគ្រួសាររបស់គេឲ្យបានគ្រប់គ្រាន់។ អស់លោកត្រូវចាត់ចែងឲ្យគេមានមធ្យោបាយគ្រប់គ្រាន់សម្រាប់អប់រំគេ គាំទ្រគេ និងជួយដាស់តឿនគេតាមព្រះវិញ្ញាណផង។

# ជំពូក ៥

## សេចក្តីចាត់ចែងដែលត្រូវអនុវត្តតាម

### ២៣-សារម្ភកថា

អ្នកបំពេញកិច្ចការជាគ្រីស្តទូត ម្នាក់ឯងក្តី ឬក្នុងក្រុមក្តី ក៏ត្រូវចូលរួមក្នុងកិច្ចការជាគ្រីស្តទូតរបស់ព្រះសហគមន៍ តាមមុខតំណែងដ៏ពិតប្រាកដរបស់ខ្លួន។ លើសពីនេះទៅទៀត អ្នកទាំងនោះត្រូវរក្សាចំណងទាក់ទងជាមួយអស់លោកអភិបាលដែលព្រះវិញ្ញាណបានតែងតាំងឲ្យឃ្វាលព្រះសហគមន៍របស់ព្រះជាម្ចាស់ (កក ២០,២៨)។ ការណ៍នេះសំខាន់ក្នុងកិច្ចការរបស់ខ្លួនជាគ្រីស្តទូតតាមបែបគ្រីស្តបរិស័ទ។ អស់អ្នកដែលផ្តើមកិច្ចការផ្សេងៗក្នុងឋានៈជាគ្រីស្តទូត ក៏ត្រូវរួមសហការគ្នាជាចាំបាច់ដែរ។ អស់លោកអភិបាលមានភារកិច្ចចាត់ចែងឲ្យអ្នកទាំងនោះរួមសហការគ្នាយ៉ាងស្រួល។

អស់អ្នកដែលបំពេញកិច្ចការជាគ្រីស្តទូត តាមបែបប្លែកៗពីគ្នាៗក្នុងព្រះសហគមន៍ ត្រូវគោរពគ្នាទៅវិញទៅមក និងរួមសហការគ្នា ទោះបីត្រូវគោរពលក្ខណៈផ្ទាល់នៃបែបនីមួយៗទាំងនោះក្តី។ ការណ៍នេះពិតជាចាំបាច់បំផុត ដើម្បីលើកស្ទួយគំនិតឲ្យរួមគ្នាជាធ្លុងតែមួយ បណ្តាលឲ្យសេចក្តីស្រឡាញ់លេចធ្លោឡើង ក្នុងគ្រប់កិច្ចការជាគ្រីស្តទូតនៃព្រះសហគមន៍។ បើអ្នកទាំងនោះរួមសហការជាមួយគ្នាមែន ពិតជាគេបានលទ្ធផលតាមគោលដៅរួម និងគេជៀសវាងមិនឲ្យមានការប្រជែងប្រឆាំងគ្នា បណ្តាលឲ្យខូចប្រយោជន៍ព្រះសហគមន៍ឡើង។

ការរួមគ្នានេះចាំបាច់ ជាពិសេស នៅពេលមានកិច្ចការមួយ ក្នុងព្រះសហគមន៍ទាមទារឲ្យលោកគង្វាលក្នុងភូមិភាគ និងគង្វាលជាបព្វជិត ព្រមទាំងក្រុមបព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតា ត្រូវរួមសហការគ្នាឲ្យមានរបៀបរៀបរយយ៉ាងស្រួល។

### ២៤-ចំណងទំនាក់ទំនងជាមួយអស់លោកអភិបាល

អស់លោកអភិបាលមានភារកិច្ចជួយគ្រីស្តបរិស័ទធម្មតា ឲ្យបំពេញកិច្ចការជាគ្រីស្តទូត ព្រមទាំងផ្តល់គោលការណ៍ឲ្យគេ និងជួយគាំទ្រគេខាងផ្លូវវិញ្ញាណ។ អស់លោកចាត់ចែងកិច្ចការនោះ ដើម្បីជាប្រយោជន៍រួមនៃព្រះសហគមន៍ ហើយយកចិត្តទុកដាក់ឲ្យគេកាន់តាមលទ្ធិនៃគ្រីស្តសាសនា និងគោរពតាមសេចក្តីចាត់ចែងជាគ្រឹះ។

អស់អ្នកដែលបំពេញកិច្ចការជាគ្រីស្តទូត មានចំណងទាក់ទងជាមួយអស់លោកអភិបាលតាមបែបផ្សេងៗ ស្របតាមរបៀប និងតាមគោលដៅប្លែកៗពីគ្នានៃកិច្ចការជាគ្រីស្តទូតនោះ។

ក្នុងព្រះសហគមន៍ មានគ្រីស្តបរិស័ទធម្មតាផ្តើមកិច្ចការជាគ្រីស្តទូតមួយចំនួន ពួកគេបានសម្រេចចិត្តធ្វើកិច្ចការទាំងនោះ ដែលគេជ្រើសរើសដោយសេរី។ ពួកគេមានសិទ្ធិគ្រប់គ្រងកិច្ចការទាំងនោះ តាមការវិនិច្ឆ័យដ៏ឈ្លាសវៃរបស់ខ្លួន។ ក្នុងសភាពការណ៍ខ្លះ កិច្ចការទាំងនោះជួយឲ្យព្រះសហគន៍អាចបំពេញបេសកកម្មរបស់ខ្លួនបានយ៉ាងល្អ។ ហេតុ

នេះហើយ បានជាអស់លោកអភិបាលតែងតែសរសើរ និងធានាកិច្ចការទាំងអស់នោះជាញឹកញាប់។ ក៏ប៉ុន្តែ អ្នកណាអួតថា កិច្ចការរបស់ខ្លួនមានឈ្មោះថា «កាតូលិក» លុះត្រាអស់លោកអភិបាលដែលត្រូវបានតែងតាំងយ៉ាងត្រឹមត្រូវ យល់ស្របនឹងកិច្ចការនោះ។

អស់លោកអភិបាលទទួលស្គាល់យ៉ាងច្បាស់ថា របៀបធ្វើកិច្ចការជាគ្រីស្តទូតខ្លះពិតជារបៀបព្រះសហគមន៍។

លើសពីនេះទៅទៀត តាមតម្រូវការនៃប្រយោជន៍រួមរបស់ព្រះសហគមន៍ អស់លោកអភិបាលអាចជ្រើសរើស និងជួយលើកស្ទួយយ៉ាងពិសេស សមាគមនិងស្ថាប័នដែលបំពេញកិច្ចការជាគ្រីស្តទូតខ្លះ គឺសមាគម និងស្ថាប័ន ដែលមានគោលដៅចំខាងវិញ្ញាណ។ អស់លោកក៏ត្រូវទទួលខុសត្រូវយ៉ាងពិសេសចំពោះសមាគមនិងស្ថាប័នទាំងនោះ។ ដោយអស់លោកអភិបាលចាត់ចែងកិច្ចការជាគ្រីស្តទូតដូច្នេះតាមរបៀបផ្សេងៗនោះ ស្របតាមកាលៈទេសៈដូច្នេះ អស់លោកភ្ជាប់កិច្ចការជាគ្រីស្តទូតតាមបែបណាមួយ ទៅនឹងបន្ទុកផ្ទាល់របស់អស់លោកជាគ្រីស្តទូត។ ទោះបីអស់លោកធ្វើដូច្នេះក្តី ក៏អស់លោកមិនប្រែលក្ខណៈជាគ្រីស្តទូតរបស់អស់លោក ហើយក៏មិនលាយឡំបន្ទុករបស់អស់លោក និងកិច្ចការរបស់គ្រីស្តបរិស័ទទេ។ ហេតុនេះ អស់លោកមិនដកសមត្ថភាពដែលគ្រីស្តបរិស័ទធម្មតា ត្រូវការជាចាំបាច់ ក្នុងការចាប់ផ្តើមកិច្ចការដោយខ្លួនផ្ទាល់បានឡើយ។ ក្នុងឯកសារផ្សេងៗនៃព្រះសហគមន៍ មានហៅកិច្ចរបស់លោកអភិបាលបែបនេះថា «ការផ្ញើទុក»។

នៅទីបញ្ចប់ ជួនកាលអស់លោកអភិបាលផ្ញើបន្ទុកខ្លះ ឲ្យគ្រីស្តបរិស័ទធម្មតាបំពេញ ជាបន្ទុកដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងភារកិច្ចរបស់អស់លោកក្នុងឋានៈជាគង្វាល ឧបមាថា អស់លោកផ្ញើបន្ទុកខ្លះក្នុងការបង្រៀនលទ្ធិនៃគ្រីស្តសាសនា ក្នុងការធ្វើពិធីគោរពប្រណិប័តន៍ខ្លះ ក្នុងការណែនាំគ្រីស្តបរិស័ទ។ តាមបេសកកម្មនោះ គ្រីស្តបរិស័ទធម្មតាបំពេញបន្ទុកទាំងនេះ ដោយស្តាប់តាមបង្គាប់ទាំងស្រុងរបស់អ្នកទទួលខុសត្រូវក្នុងនាមលោកអភិបាល។

ចំពោះកិច្ចការ និងស្ថាប័នខាងលោកីយ៍ អស់លោកអភិបាលមានតួនាទីបង្រៀន និងបកស្រាយយ៉ាងពិតប្រាកដនូវគោលការណ៍ខាងសីលធម៌ដែលត្រូវអនុវត្តក្នុងវិស័យទាំងនោះ។ ក្រោយពីបានរិះគិតពិចារណាយ៉ាងយូរ និងដោយបានប្រមូលយោបល់អ្នកដែលមានសមត្ថភាព អស់លោកក៏អាចវិនិច្ឆ័យថា កិច្ចការឬស្ថាប័នទាំងនោះ ស្របតាមគោលការណ៍នៃសីលធម៌ឬក៏អត់ និងប្រកាសអំពីអ្វីៗដែលត្រូវធ្វើជាចាំបាច់អំពីកិច្ចការទាំងនោះ ដើម្បីថែរក្សាការពារ និងលើកស្ទួយសម្បត្តិខាងវិញ្ញាណ ដែលហួសពីសម្បត្តិក្នុងលោកីយ៍នេះ។

## ២៥-ក្រុមលោកគង្វាលជួយគ្រីស្តបរិស័ទធម្មតាឲ្យបំពេញកិច្ចការជាគ្រីស្តទូត

អស់លោកអភិបាល អស់លោកគង្វាលទទួលបន្ទុកថែរក្សាគ្រីស្តបរិស័ទក្នុងភូមិ ក្រុមគង្វាលនៃភូមិភាគ និងក្រុមគង្វាលជាបព្វជិតត្រូវនឹកថា អស់អ្នកផ្ញើជីវិតលើព្រះគ្រីស្តទាំងប៉ុន្មាន ទោះជាគ្រីស្តបរិស័ទទទួលអគ្គសញ្ញាតែងតាំងក្តី ទោះជាគ្រីស្តបរិស័ទធម្មតាក្តី ក៏សុទ្ធតែមានសិទ្ធិនិងភារកិច្ចរួម បំពេញកិច្ចការជាគ្រីស្តទូត។ គ្រីស្តបរិស័ទធម្មតាក៏មានភារកិច្ចផ្ទាល់ពិសេសម្យ៉ាង ក្នុងការសាងសង់ព្រះសហគមន៍ដែរ។ ហេតុនេះហើយ បានជាអស់លោកគង្វាលត្រូវធ្វើការរួមជាមួយគ្រីស្តបរិស័ទធម្មតាក្នុងឋានៈជាបងប្អូនក្នុងព្រះសហគមន៍ និងដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍។ អស់លោកក៏នឹងយកចិត្តទុកដាក់គាំទ្រគ្រីស្តបរិស័ទធម្មតាក្នុងកិច្ចការជាគ្រីស្តទូតរបស់គេ(ពន្លឺ ៣៧)។

អស់លោកអភិបាលត្រូវជ្រើសរើសលោកគង្វាលដោយប្រុងប្រយ័ត្ន ជាគង្វាលដែលមានសមត្ថភាព និងដែលដឹងសេចក្តីពាក់ព័ន្ធនឹងគ្រីស្តបរិស័ទធម្មតា ដើម្បីជួយណែនាំក្រុមគ្រីស្តបរិស័ទឲ្យបំពេញកិច្ចជាការគ្រីស្តទូត តាមរបៀប

ពិសេសប្លែកៗពីគ្នា។ ដោយអស់លោកគង្វាលទទួលបេសកកម្មពីលោកអភិបាល អស់លោកបំពេញមុខងារបម្រើគ្រីស្តបរិស័ទបែបនេះ ទុកជាតំណាងរបស់លោកអភិបាល។ អស់លោកគង្វាលត្រូវភ្ជាប់ចិត្តយ៉ាងស្មោះនឹងគោលគំនិត និងលទ្ធិនៃព្រះសហគមន៍ ហើយត្រូវជួយឲ្យគ្រីស្តបរិស័ទធម្មតា និងលោកអភិបាលមានទំនាក់ទំនងជាមួយគ្នាតាមសមរម្យ។ អស់លោកត្រូវយកចិត្តទុកដាក់ ខិតខំចិញ្ចឹមជីវិតខាងវិញ្ញាណរបស់គ្រីស្តបរិស័ទ ឲ្យមានគំនិតជាគ្រីស្តទូត ក្នុងសមាគមកាតូលិកដែលលោកអភិបាលផ្ញើទុកមកនោះ។ អស់លោកត្រូវរួមធ្វើកិច្ចការជាគ្រីស្តទូតជាមួយគ្រីស្តបរិស័ទធម្មតា ដោយផ្តល់យោបល់ប្រកបដោយប្រាជ្ញា និងដោយជួយឲ្យគេបំពេញគម្រោងការរបស់គេ។ ដោយនិយាយសន្ទនាជានិច្ចជាមួយគ្រីស្តបរិស័ទធម្មតា អស់លោកស្វែងរកដោយពិនិត្យពិច្ច័យនូវរបៀប ដែលអាចផ្តល់ឲ្យកិច្ចការជាគ្រីស្តទូតរបស់គេ បានលទ្ធផលកាន់តែច្រើនឡើងៗ។ អស់លោកត្រូវជួយសមាជិកឲ្យមានគំនិត រួបរួមគ្នាក្នុងសមាគម និងឲ្យសមាគមរួបរួមជាមួយសមាគមឯទៀតៗដែរ (បព្វជិត ៨)។

នៅទីបញ្ចប់ បព្វជិតបព្វជិតាត្រូវរាប់ទុកថា គ្រីស្តបរិស័ទធម្មតាបំពេញកិច្ចការជាគ្រីស្តទូតគួរឲ្យសរសើរ។ គេត្រូវស្ម័គ្រចិត្ត ពង្រីងកិច្ចការនេះឲ្យបានទូលំទូលាយ ស្របតាមគោលដៅនៃក្បួនវិន័យគ្រឹះស្ថានរបស់ខ្លួន។ គេត្រូវខិតខំគាំទ្រ និងជួយ ហើយបង្គ្រប់កិច្ចការរបស់អស់លោកគង្វាលទៀត។

## ២៦-មធ្យោបាយដែលអាចជួយឲ្យរួមសហការគ្នា

ប្រសិនបើអាចធ្វើបាន ត្រូវមានក្រុមប្រឹក្សាផ្សេងៗតាមភូមិភាគដែលគាំទ្រកិច្ចការជាគ្រីស្តទូតរបស់ព្រះសហគមន៍ក្នុងវិស័យប្រកាសដំណឹងល្អផង ក្នុងវិស័យនាំឲ្យគ្រីស្តបរិស័ទបានវិសុទ្ធ ក្នុងវិស័យសប្បុរសធម៌ ក្នុងវិស័យសង្គមកិច្ច និងក្នុងវិស័យឯទៀតៗដែរ។ ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង និងក្រុមបព្វជិតបព្វជិតា ត្រូវរួមសហការជាមួយគ្រីស្តបរិស័ទធម្មតាក្នុងក្រុមប្រឹក្សាទាំងនោះ តាមតម្រូវការនិងយ៉ាងសមរម្យ។ ក្រុមប្រឹក្សាទាំងនោះ អាចជួយឲ្យសមាគម និងគ្រីស្តបរិស័ទធម្មតាដែលចាប់ផ្តើមកិច្ចការផ្សេងៗ ឲ្យរួមសហការគ្នាទៅវិញទៅមក ទាំងគោរពលក្ខណៈផ្ទាល់របស់ខ្លួន ហើយស្វ័យភាពនៃសមាគម និងក្រុមទាំងនោះ។

ប្រសិនបើអាចធ្វើបាន ត្រូវមានក្រុមប្រឹក្សាផ្សេងៗបែបដដែលនោះ នៅតាមសហគមន៍ក្នុងភូមិ តាមកម្រិតអន្តរភូមិ អន្តរភូមិភាគ ហើយប្រហែលតាមកម្រិតជាតិ និងអន្តរជាតិ។

នៅក្បែរសន្តអាសនៈត្រូវតែងតាំងការិយាល័យពិសេសមួយសម្រាប់បម្រើ និងលើកស្ទួយកិច្ចការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទធម្មតា។ ការិយាល័យនោះ ហាក់ដូចជាមណ្ឌលមួយប្រកបដោយមធ្យោបាយតាមសមរម្យ ដើម្បីផ្តល់ព័ត៌មានអំពីកិច្ចការផ្សេងៗដែលគ្រីស្តបរិស័ទធម្មតាផ្តើមធ្វើ។ ការិយាល័យនោះនឹងខិតខំស្រាវជ្រាវ និងសិក្សាអំពីបញ្ហាទាំងប៉ុន្មាន ដែលចោទឡើងសព្វថ្ងៃក្នុងវិស័យទាំងនេះ និងជួយទាំងក្រុមអភិបាល ទាំងគ្រីស្តបរិស័ទធម្មតាក្នុងកិច្ចការជាគ្រីស្តទូត។ ក្រុមចលនាផ្សេងៗ និងអង្គការជាគ្រីស្តទូតរបស់គ្រីស្តបរិស័ទធម្មតាក្នុងពិភពលោកទាំងមូល ក៏ត្រូវចូលរួមយ៉ាងសកម្មក្នុងការិយាល័យនោះ ជាកន្លែងក្រុមនិងអង្គការទាំងនោះអាចជួបជុំគ្នាបាន ដើម្បីរួមសហការជាមួយគ្រីស្តបរិស័ទធម្មតា ជាមួយក្រុមអ្នកខ្លះ ដែលទទួលអគ្គសញ្ញាតែងតាំង និងជាមួយក្រុមបព្វជិតបព្វជិតាខ្លះដែរ។

## ២៧-ការរួមសហការជាមួយគ្រីស្តបរិស័ទឯទៀតៗ និងជាមួយអ្នកដែលមិនកាន់គ្រីស្តសាសនា

បេតិកភ័ណ្ឌរួមនៃដំណឹងល្អ និងភារកិច្ចរួមហូរមកពីបេតិកភ័ណ្ឌនោះដាស់តឿន និងទាមទារឲ្យគ្រីស្តបរិស័ទ

កាតូលិក និងគ្រីស្តបរិស័ទឯទៀតៗរួមសហការគ្នា។ បុគ្គល ឬក្រុមព្រះសហគមន៍ អាចរួមសហការគ្នាក្នុងសកម្មភាពផ្សេងៗ ក៏បាន ឬរួមសហការគ្នាក្នុងសមាគមរួមក៏បាន នៅតាមកម្រិតជាតិ ឬអន្តរជាតិក៏បាន (បង្រួប ១២)។

គ្រីស្តបរិស័ទទាំងអស់កាន់តាមតម្លៃដ៏ថ្លៃថ្នូររួម។ ហេតុនេះ អស់គ្រីស្តបរិស័ទដែលមានគោលបំណងបំពេញកិច្ចការជាគ្រីស្តទូត ត្រូវរួមសហការបែបនេះជាមួយអស់អ្នកដែលមិនកាន់គ្រីស្តសាសនា តែទទួលស្គាល់តម្លៃដ៏ថ្លៃថ្នូរនៃគ្រីស្តសាសនាទាំងនោះ។ ប្រសិនបើគ្រីស្តបរិស័ទធម្មតារួមសហការយ៉ាងសកម្ម និងដោយប្រុងប្រយ័ត្នបែបនេះ (បង្រួប ១២; ពន្លឺ ៣៧) ជាពិសេសក្នុងសកម្មភាពលោកីយ៍ គេមុខជាផ្តល់សក្ខីភាព អំពីព្រះគ្រីស្តជាព្រះសង្គ្រោះរបស់មនុស្សលោក និងអំពីក្រុមគ្រួសាររបស់មនុស្សលោកដែលរួបរួមគ្នាជាធ្លុងតែមួយផង។

# ជំពូក ៦

## ការអប់រំឲ្យបំពេញកិច្ចការជាគ្រីស្តទូត

### ២៨-គ្រីស្តបរិស័ទត្រូវទទួលការអប់រំឲ្យបំពេញកិច្ចការជាគ្រីស្តទូត

ជីវិតតាមព្រះវិញ្ញាណរបស់គ្រីស្តបរិស័ទធម្មតាត្រូវតែចម្រើនឡើង ហើយគេក៏ត្រូវស្គាល់លទ្ធិនៃគ្រីស្តសាសនាកាន់តែច្បាស់ដែរ។ គេត្រូវតែសម្របខ្លួនតាមសភាពការណ៍ថ្មីៗ តាមព្រឹត្តិការណ៍ តាមបុគ្គលម្នាក់ៗនិងតាមកាតព្វកិច្ចផ្សេងៗដែរ។ ហេតុនេះហើយបានជាគ្រីស្តបរិស័ទដែលបំពេញកិច្ចការជាគ្រីស្តទូត ត្រូវទទួលការអប់រំយ៉ាងពេញលេញនិងប្លែកៗពីគេ ទើបគេអាចបំពេញកិច្ចការនេះយ៉ាងស័ក្តិសិទ្ធនិងប្រសើរបាន។ គេត្រូវទទួលការអប់រំជាអចិន្ត្រៃយ៍ជាចាំបាច់។ មហាសន្និបាតបានផ្តល់យោបល់ និងប្រកាសសេចក្តីផ្សេងៗទុកជាគ្រឹះនៃការអប់រំក្នុងកិច្ចការជាគ្រីស្តទូតនេះរួចទៅហើយ (ពន្លឺ ជំពូក ២.៤.៥ ; បង្រួប ៤.៦.៧.១២)។ មានកិច្ចជាគ្រីស្តទូតបែបខ្លះ ទាមទារឲ្យគេទទួលការអប់រំពិសេសដោយឡែកពីគេ លើសពីការអប់រំរបស់គ្រីស្តបរិស័ទទូទៅទៅទៀត ព្រោះមនុស្សតែងតែប្លែកៗពីគ្នា ហើយក៏រស់នៅតាមសភាពការណ៍ប្លែកៗពីគ្នាដែរ។

### ២៩-គោលការណ៍សម្រាប់អប់រំគ្រីស្តបរិស័ទធម្មតាឲ្យបំពេញកិច្ចការជាគ្រីស្តទូត

គ្រីស្តបរិស័ទធម្មតា រួមចំណែកក្នុងបេសកកម្មរបស់ព្រះសហគមន៍ តាមរបៀបផ្ទាល់របស់គេ។ ហេតុនេះ ការអប់រំគេឲ្យបំពេញកិច្ចការជាគ្រីស្តទូត ត្រូវស្របតាមលក្ខណៈពិសេសរបស់គ្រីស្តបរិស័ទធម្មតាជាអ្នករស់នៅក្នុងសង្គម និងស្របតាមជីវិតខាងវិញ្ញាណសមនឹងការរស់នៅរបស់គេដែរ។

មុននឹងគ្រីស្តបរិស័ទធម្មតាទទួលការអប់រំឲ្យបំពេញកិច្ចការជាគ្រីស្តទូត គេត្រូវទទួលការអប់រំក្នុងឋានៈជាមនុស្សជាមុនសិន គឺស្របតាមបុគ្គលិកលក្ខណៈ និងតាមសភាពការណ៍រស់នៅរបស់គេម្នាក់ៗ។ គ្រីស្តបរិស័ទធម្មតា ត្រូវស្គាល់សភាពការណ៍នៃពិភពលោកនាបច្ចុប្បន្នកាលយ៉ាងច្បាស់ និងត្រូវចូលរួមយ៉ាងស្រួលក្នុងក្រុមរបស់ខ្លួនក្នុងសង្គម និងក្នុងអរិយធម៌របស់ខ្លួនដែរ។

ជាបឋម គ្រីស្តបរិស័ទធម្មតាត្រូវទទួលការអប់រំឲ្យបំពេញបេសកកម្មរបស់ព្រះគ្រីស្ត និងរបស់ព្រះសហគមន៍ដោយខ្លួនមានជំនឿ គឺរស់នៅស្របតាមគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលប្រតិស្ឋាន និងសង្គ្រោះមនុស្សលោកក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រោសឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានជីវិតរស់រវើក។ ព្រះវិញ្ញាណដាស់តឿនមនុស្សទាំងអស់ឲ្យស្រឡាញ់ព្រះជាម្ចាស់ទុកជាព្រះបិតា និងឲ្យស្រឡាញ់ពិភពលោក និងមនុស្សលោក រួមជាមួយព្រះអង្គដែរ។ ត្រូវចាត់ការអប់រំនេះទុកជាគ្រឹះ និងទុកជាលក្ខ័ណ្ឌដែលខានមិនបាន នាំឲ្យគ្រីស្តបរិស័ទធម្មតាអាចបំពេញកិច្ចការជាគ្រីស្តទូតគ្រប់យ៉ាង និងបង្កើតផលបាន។

លើសពីការអប់រំខាងវិញ្ញាណ គេក៏ត្រូវមានចំណេះយ៉ាងជ្រាលជ្រៅអំពីទេវវិទ្យា អំពីសីលធម៌ និងអំពីទស្សនវិទ្យាដែរ។ ចំណេះបែបនេះក៏ត្រូវសមស្របតាមអាយុ ស្របនឹងសភាពការណ៍រស់នៅ និងស្របតាមទេពកោសល្យរបស់គេម្នាក់ៗ។ លើសពីនេះទៅទៀត សូមកុំភ្លេចថា គេត្រូវស្គាល់វប្បធម៌ទូទៅយ៉ាងសមរម្យ ភ្ជាប់នឹងការអប់រំ ឲ្យចេះប្រើប្រាស់ចំណេះរបស់ខ្លួន និងឲ្យទទួលការអប់រំខាងបច្ចេកទេសទៀតផង។

ក្នុងការអប់រំគ្រីស្តបរិស័ទធម្មតា ត្រូវជួយលើកស្ទួយអ្វីជាតម្លៃដ៏ពិតប្រាកដក្នុងឋានៈជាមនុស្ស ជាពិសេសឲ្យគេចេះរស់នៅរួមគ្នាទុកជាបងប្អូនបង្កើត ចេះរួមសហការគ្នា និងចេះសន្ទនាជាមួយអ្នកដទៃទៀតផង។ ដូច្នេះការអប់រំនេះជួយឲ្យគេមានទំនាក់ទំនងជាមួយមនុស្សដទៃទៀត ឲ្យកាន់តែស្រួលឡើង។

ការអប់រំឲ្យបំពេញកិច្ចការជាគ្រីស្តទូតមិនគ្រាន់តែស្រេចលើការរៀនសូត្រទ្រឹស្តីប៉ុណ្ណោះទេ តែតាំងពីដើមរៀងមកត្រូវបង្ហាត់គេបន្តិចម្តងៗ និងដោយប្រុងប្រយ័ត្ន ឲ្យយល់ឃើញអំពីអ្វីៗទាំងអស់តាមពន្លឺនៃជំនឿ ឲ្យចេះរិះគិតពិចារណាថ្លឹងថ្លែងអ្វីៗនោះ និងឲ្យប្រព្រឹត្តការទាំងអស់តាមពន្លឺនៃជំនឿដែរ។ ត្រូវបង្ហាត់គេឲ្យយកការប្រត្តិបត្តិរបស់ខ្លួន ទុកជាមធ្យោបាយសម្រាប់អប់រំខ្លួនឯង និងចម្រើនឡើង រួមជាមួយអ្នកដទៃ។ ដូច្នេះគេចូលបម្រើព្រះសហគមន៍យ៉ាងសកម្ម។ ត្រូវអប់រំបែបនេះតទៅឲ្យកាន់តែប្រសើរឡើងជានិច្ច ព្រោះបុគ្គលិកលក្ខណៈមនុស្សម្នាក់ៗចេះតែចម្រើនឡើងជាលំដាប់ ហើយបញ្ហានានាក៏តែងតែប្រែប្រួលជានិច្ចដែរ។ ត្រូវមានចំណេះកាន់តែជ្រៅទៅៗ និងធ្វើកិច្ចការសម្របតាមសភាពការណ៍ និងបញ្ហាដែលតែងតែប្រែប្រួលទាំងនោះដែរ។ ត្រូវយកចិត្តទុកដាក់ គោរពបុគ្គលិកលក្ខណៈទាំងមូលរបស់គេម្នាក់ៗ ទាំងខិតខំតបឆ្លើយនិងសេចក្តីទាមទារជាច្រើនរបស់គេ។ ការអប់រំបែបនេះ មុខជានឹងរក្សាការពារបុគ្គលិកលក្ខណៈ របស់គេឲ្យនៅគង់វង្ស និងឲ្យគេបានសុខដុមរមនាកាន់តែខ្លាំងឡើងៗ។

ធ្វើដូច្នេះ គ្រីស្តបរិស័ទធម្មតាអាចចូលខាងលោកីយ៍ឲ្យកាន់តែជ្រៅ និងកាន់តែសកម្មបាន គឺគេអាចរួមចំណែកក្នុងដំណើរនៃព្រឹត្តិការណ៍ដែលតែងតែកន្លងផុតទៅ។ នៅពេលជាមួយគ្នានេះ ក្នុងឋានៈខ្លួនជាសមាជិក ដែលមានជីវិត និងជាសាក្សីអំពីព្រះសហគមន៍ គេធ្វើឲ្យព្រះសហគមន៍មានវត្តមាន និងមានសកម្មភាពនៅក្នុងលោកីយ៍( ពន្លឺ ៣៣ )។

## ៣០-អ្នកអប់រំគ្រីស្តបរិស័ទឲ្យបំពេញកិច្ចការជាគ្រីស្តទូត

ត្រូវចាប់ផ្តើមអប់រំកូនក្មេងតាំងពីតូចមក ឲ្យធ្វើជាគ្រីស្តទូត ជាពិសេសត្រូវអប់រំកូនជំទង់ និងយុវជនយុវនារី ឲ្យចាប់ផ្តើមបំពេញកិច្ចការជាគ្រីស្តទូត និងឲ្យមានគំនិតជាគ្រីស្តទូត។ ត្រូវអប់រំគ្រីស្តបរិស័ទអស់មួយជីវិត ស្របតាមការងារថ្មីៗរបស់ខ្លួនទាមទារ។ អស់អ្នកដែលទទួលបន្ទុកអប់រំតាមគ្រីស្តសាសនា ច្បាស់ជាត្រូវយកចិត្តទុកដាក់នឹងអប់រំគ្រីស្តបរិស័ទឲ្យបំពេញកិច្ចការជាគ្រីស្តទូតនេះ។

ឪពុកម្តាយមានភារកិច្ចក្នុងរង្វង់គ្រួសារ គឺគាត់រៀបចំចិត្តគំនិតកូនៗតាំងពីវ័យតូចមក ឲ្យទទួលស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់។ គាត់ត្រូវអប់រំកូនៗបន្តិចម្តងៗ ជាពិសេសដោយធ្វើគំរូឲ្យកូន យកចិត្តទុកដាក់នឹងសេចក្តីត្រូវការរបស់អ្នកដទៃ ទាំងខាងសម្ភារៈ ទាំងខាងវិញ្ញាណ។ ក្រុមគ្រួសារទាំងមូល ដែលជាសហគមន៍រស់នៅជាមួយគ្នា ត្រូវអប់រំសមាជិកឲ្យបំពេញកិច្ចការគ្រីស្តទូតដើមដំបូង។

ប៉ុន្តែត្រូវអប់រំកូនក្មេងជាចាំបាច់ ឲ្យចេះគិតគូរដល់មនុស្សនៅខាងក្រៅក្រុមគ្រួសាររបស់ខ្លួន និងឲ្យបែរទៅស្គាល់ការរស់នៅរបស់សហគមន៍នានា ទាំងក្រុមក្នុងព្រះសហគមន៍ ទាំងក្រុមក្នុងលោកដែរ។ ត្រូវណែនាំក្មេងៗ ឲ្យចូលរួមក្នុងព្រះសហគមន៍ក្នុងភូមិ តាមបែបឲ្យគេភ្ញាក់ស្មារតីថា គេជាសមាជិកនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលមានជីវិតរស់រវើក

និងមានសកម្មភាពទៀតផង។ ហេតុនេះ អស់លោកគង្វាលត្រូវយកចិត្តទុកដាក់ជានិច្ចនឹងអប់រំគេឲ្យបំពេញកិច្ចការជាគ្រីស្តទូតនេះ ទោះជាក្នុងពេលអប់រំជំនឿក្តី ក្នុងពេលធ្វើពិធីអត្ថាធិប្បាយព្រះគម្ពីរក្តី ក្នុងការណែនាំខាងវិញ្ញាណក្តី និងក្នុងកិច្ចការផ្សេងៗទៀត នៃមុខងារបម្រើរបស់អស់លោកក្តី។

សាលារៀន វិទ្យាល័យ និងស្ថាប័នទាំងប៉ុន្មានដែលមានគោលដៅអប់រំ ក៏ត្រូវជួយលើកស្ទួយគំនិតជាគ្រីស្តបរិស័ទកាតូលិក និងកិច្ចការជាគ្រីស្តទូត ក្នុងចិត្តគំនិតយុវជនយុវនារីដែរ។ ប្រសិនបើគ្មានសាលា គ្មានវិទ្យាល័យ និងគ្មានស្ថាប័នទាំងនោះ ឬប្រសិនបើយុវជនយុវនារីមិនរៀននៅសាលាទាំងនោះ ឬប្រសិនបើមានមូលហេតុផ្សេងៗទៀត សូមឲ្យឪពុកម្តាយ និងអស់លោកគង្វាល ព្រមទាំងក្រុមចលនាដែលបំពេញកិច្ចការជាគ្រីស្តទូត យកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ឲ្យអប់រំគេជំនួស។ រីឯគ្រូនិងអ្នកអប់រំដែលបំពេញកិច្ចការជាគ្រីស្តទូតយ៉ាងល្អប្រសើរ ដោយព្រះជាម្ចាស់ត្រាស់ហៅគាត់ ឬដោយគាត់ទទួលភារកិច្ចនេះឲ្យបំពេញ ក៏សូមឲ្យលទ្ធិ នៃជំនឿនិងគុណកោសល្យ ជ្រួតជ្រាបក្នុងចិត្តគេ ដើម្បីបញ្ចូនបន្តការអប់រំនេះឲ្យបានប្រសិទ្ធភាព។

ក្រុមនិងសមាគមផ្សេងៗរបស់គ្រីស្តបរិស័ទធម្មតា ដែលបំពេញកិច្ចការជាគ្រីស្តទូត ឬដែលមានគោលដៅមួយផ្សេងទៀតខាងវិញ្ញាណ ក៏ត្រូវយកចិត្តទុកដាក់ជួយអប់រំគេឲ្យបំពេញកិច្ចការជាគ្រីស្តទូតនេះ ស្របតាមគោលដៅ និងតាមរបៀបរបស់ខ្លួន។ ជាញឹកញាប់ ក្រុមនិងសមាគមទាំងនោះ ជាផ្លូវធម្មតាសម្រាប់អប់រំគ្រីស្តបរិស័ទឲ្យបំពេញកិច្ចការជាគ្រីស្តទូត។ ក្នុងក្រុមនិងសមាគមទាំងនោះមានការអប់រំខាងលទ្ធិនៃគ្រីស្តសាសនា មានអប់រំខាងវិញ្ញាណ និងមានអប់រំឲ្យប្រតិបត្តិតាម។ សមាជិកក្រុមនិងសមាគមទាំងនោះតែងតែជួបជុំគ្នាជាក្រុមតូចៗជាមួយអ្នករស់នៅជាមួយ និងជាមួយមិត្តសម្លាញ់ មកពិនិត្យវិធីនិងលទ្ធផលនៃកិច្ចការជាគ្រីស្តទូតរបស់គេ ហើយក៏រួមគ្នាវាយតម្លៃការរស់នៅរបស់ខ្លួនជារៀងរាល់ថ្ងៃ តាមដំណឹងល្អ។

ត្រូវបន្តការអប់រំនេះ ដោយនឹកគិតដល់កិច្ចការជាគ្រីស្តទូតទាំងមូល ដែលជាភារកិច្ចរបស់គ្រីស្តបរិស័ទធម្មតា ទាំងអស់ ដ្បិតគេត្រូវប្រព្រឹត្តកិច្ចការនេះក្នុងគ្រប់សភាពការណ៍ប្រចាំការរស់នៅរបស់គេ ជាពិសេសនៅពេលបំពេញអាជីវកម្ម និងក្នុងការរស់នៅក្នុងសង្គម មិនគ្រាន់តែនៅខាងក្នុងក្រុម និងសមាគមរបស់ខ្លួនប៉ុណ្ណោះទេ។ លើសពីនេះទៅទៀត គ្រីស្តបរិស័ទធម្មតាម្នាក់ៗ ជាពិសេសគ្រីស្តបរិស័ទពេញវ័យ ត្រូវត្រៀមខ្លួនយ៉ាងសកម្មឲ្យបំពេញកិច្ចការជាគ្រីស្តទូតដែរ។ ពេលមនុស្សចម្រើនវ័យឡើង ប្រាជ្ញារបស់គេក៏កាន់តែទូលាយដែរ។ ដូច្នេះម្នាក់ៗកាន់តែអាចទទួលស្គាល់ទេពកោសល្យដែលព្រះជាម្ចាស់បានប្រទានឲ្យ គេក៏អាចប្រព្រឹត្តតាមព្រះអំណោយទាន ដែលព្រះវិញ្ញាណប្រទានឲ្យដែរ ដើម្បីជាប្រយោជន៍ដល់បងប្អូនទាំងអស់។

## ៣១-ការអប់រំត្រូវស្របតាមបែបផ្សេងៗនៃកិច្ចការជាគ្រីស្តទូត

គ្រីស្តបរិស័ទប្រព្រឹត្តកិច្ចការជាគ្រីស្តទូតតាមបែបផ្សេងៗ ត្រូវតែទទួលការអប់រំស្របតាមបែបនោះ។

ក) ចំពោះកិច្ចការប្រកាសដំណឹងល្អ និងនាំឲ្យមនុស្សបានវិសុទ្ធ៖ គ្រីស្តបរិស័ទធម្មតាត្រូវរៀបចំខ្លួនយ៉ាងពិសេស ឲ្យចេះចាប់ផ្តើមសន្ទនាជាមួយអ្នកដទៃ ទោះជាអ្នកផ្ញើជីវិតលើព្រះគ្រីស្តក្តី មិនផ្ញើជីវិតលើព្រះគ្រីស្តក្តី ដើម្បីសម្តែងសាររបស់ព្រះគ្រីស្តឲ្យមនុស្សទាំងអស់។

ប៉ុន្តែ ក្នុងសម័យយើងនេះ លទ្ធិសម្ភារៈនិយមផ្សព្វផ្សាយស្ទើរតែគ្រប់កន្លែង សូម្បីតែក្នុងចំណោមគ្រីស្តបរិស័ទកាតូលិកដែរ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទធម្មតា មិនគ្រាន់តែត្រូវសិក្សាលទ្ធិនៃគ្រីស្តសាសនាដោយយកចិត្ត

ទុកដាក់ជាពិសេសត្រង់ប្រការដែលគេចោទប្រកាន់ប៉ុណ្ណោះទេ គេក៏ត្រូវផ្តល់សក្ខីភាព ដោយការរស់នៅស្របតាមដំណឹងល្អ នៅចំពោះមនុស្សកាន់តាមលទ្ធិសម្ភារៈនិយមគ្រប់ប្រភេទថែមទៀត។

ខ) ចំពោះកិច្ចប្រែអ្វីៗក្នុងលោកនេះតាមរបៀបគ្រីស្តសាសនា៖ គ្រីស្តបរិស័ទធម្មតាត្រូវទទួលការអប់រំអំពីអត្ថន័យ ដ៏ពិតប្រាកដ និងអំពីតម្លៃនៃសម្បត្តិទាំងប៉ុន្មានក្នុងលោកនេះ ព្រមទាំងអំពីទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះនឹងទិសដៅកំណត់ទាំងអស់របស់មនុស្ស។ តែត្រូវហាត់ខ្លួនឲ្យចេះប្រើប្រាស់អ្វីៗទាំងអស់ និងទទួលបទពិសោធន៍ អំពីការចាត់ចែងស្ថាប័ន ទាំងយកចិត្តទុកដាក់នឹងប្រយោជន៍រួម តាមគោលការណ៍នៃលទ្ធិរបស់ព្រះសហគមន៍អំពីសីលធម៌ និងអំពីសង្គមផង។ គ្រីស្តបរិស័ទធម្មតាត្រូវយល់ឲ្យបានច្បាស់ជាពិសេសអំពីគោលការណ៍និងសេចក្តីបញ្ជាក់នៃលទ្ធិខាងសង្គមនេះ ដើម្បីឲ្យគេមានសមត្ថភាពអាចជួយឲ្យលទ្ធិនេះចម្រើនឡើងតាមចំណែករបស់ខ្លួន និងឲ្យគេអនុវត្តន៍តាមករណីនីមួយៗយ៉ាងត្រឹមត្រូវផងដែរ។

គ) កិច្ចបង្ហាញសេចក្តីស្រឡាញ់ និងកិច្ចការមនុស្សធម៌ពិតជាផ្តល់សក្ខីភាពដ៏ប្រសើរបំផុត អំពីការរស់នៅបែបគ្រីស្តបរិស័ទ។ ហេតុនេះហើយ បានជាក្នុងការអប់រំឲ្យបំពេញកិច្ចការជាគ្រីស្តទូត ត្រូវណែនាំគេឲ្យចេះបំពេញកិច្ចបង្ហាញសេចក្តីស្រឡាញ់ និងធ្វើកិច្ចការមនុស្សធម៌ទាំងនោះ។ ដូច្នេះតាំងពីវ័យកុមារមក សាវ័ករបស់ព្រះគ្រីស្តត្រូវហាត់ខ្លួន ឲ្យចេះចែករំលែកទុក្ខលំបាករបស់បងប្អូន និងផ្គត់ផ្គង់សេចក្តីត្រូវការរបស់បងប្អូនទាំងនោះដោយចិត្តទូលំទូលាយ។

## ៣២-មធ្យោបាយដែលត្រូវអនុវត្តតាម

គ្រីស្តបរិស័ទធម្មតា ដែលបំពេញកិច្ចការជាគ្រីស្តទូតមានមធ្យោបាយជាច្រើន ដើម្បីទទួលការអប់រំនោះ គឺមានសិក្ខាសាលា សន្និបាត សំណាក់ធម៌ ការប្រជុំជាញឹកញាប់ សៀវភៅ និងសេចក្តីអត្ថាធិប្បាយណែនាំឲ្យគេស្គាល់ព្រះគម្ពីរកាន់តែជ្រៅទៅៗ និងឲ្យចម្រើនឡើងតាមផ្លូវវិញ្ញាណ។ មធ្យោបាយទាំងនោះក៏នាំឲ្យស្គាល់ជីវភាព និងសភាពការណ៍លោកនេះ ឲ្យរកឃើញនិងប្រើវិធីកាន់តែសមស្របតាមកិច្ចការជាគ្រីស្តទូតដែរ។

មធ្យោបាយសម្រាប់អប់រំទាំងនោះ ស្របតាមរបៀបបំពេញកិច្ចការជាគ្រីស្តទូតនីមួយៗ តាមតែវណ្ណៈក្នុងសង្គមជាកន្លែង ដែលគេមានបំណងបំពេញកិច្ចការជាគ្រីស្តទូត។

មានបង្កើតមណ្ឌលសិក្សា និងគ្រឹះស្ថានដ៏ខ្ពង់ខ្ពស់ផ្សេងៗ ដើម្បីអប់រំតាមបែបនេះ។ មណ្ឌល និងគ្រឹះស្ថានទាំងនោះបានផ្តល់លទ្ធផលដ៏ប្រសើររួចទៅហើយ។ មហាសន្និបាត មានអំណរសប្បាយដោយគ្រីស្តបរិស័ទផ្តើមកិច្ចការទាំងនោះ ហើយដោយមានផ្សព្វផ្សាយឥទ្ធិពលនៃការដែលគេផ្តើមនោះ ឲ្យរីកសាយក្នុងប្រទេសខ្លះ ទាំងផ្តល់លទ្ធផលជាច្រើនរួចទៅហើយ។ មហាសន្និបាតក៏សូមឲ្យបង្កើតកិច្ចការទាំងនោះនៅកន្លែងផ្សេងៗ ទៀតតាមសេចក្តីត្រូវការ។

លើសពីនោះទៅទៀត មហាសន្និបាតទូន្មានឲ្យបង្កើតមណ្ឌលឯកសារ និងមណ្ឌលសិក្សា មិនគ្រាន់តែក្នុងវិស័យទេវវិទ្យាប៉ុណ្ណោះទេ តែក្នុងវិស័យមនុស្សវិទ្យា ចិត្តសាស្រ្ត សង្គមវិទ្យា វិធីសាស្រ្ត ដើម្បីពង្រឹងសមត្ថភាពរបស់គ្រីស្តបរិស័ទធម្មតា ទាំងបុរសទាំងស្រ្តី ទាំងយុវជនទាំងមនុស្សពេញវ័យ នៅក្នុងគ្រប់វិស័យនៃកិច្ចការជាគ្រីស្តទូតផង។

## ៣៣-ពាក្យដាស់តឿន

មហាសន្និបាតដ៏វិសុទ្ធសូមទទូចអង្វរគ្រីស្តបរិស័ទធម្មតាទាំងអស់ ក្នុងនាមព្រះអម្ចាស់ សូមតបឆ្លើយដោយចិត្ត

ទូលំទូលាយនឹងព្រះគ្រីស្ត ដែលត្រាស់ហៅបងប្អូននៅពេលនេះ ដោយមានព្រះវិញ្ញាណដែលជំរុញផង។ សូមយុវជនយុវនារីយល់យ៉ាងច្បាស់ថា ព្រះគ្រីស្តត្រាស់ហៅគេយ៉ាងពិសេស សូមទទួលសេចក្ដីអញ្ជើញនេះដោយរីករាយ និងដោយចិត្តស្មោះ។ គឺព្រះអម្ចាស់ផ្ទាល់ព្រះអង្គតឿនគ្រីស្តបរិស័ទធម្មតា ជាថ្មីម្តងទៀត ដោយសារមហាសន្និបាត សូមឲ្យគ្រីស្តបរិស័ទធម្មតារួបរួមជាមួយព្រះអង្គ ឲ្យកាន់តែជិតស្និទ្ធឡើងៗជារៀងរាល់ថ្ងៃ ឲ្យយកចិត្តទុកដាក់ និងគិតដល់ប្រយោជន៍ព្រះអង្គ ហាក់ដូចជាគិតដល់ប្រយោជន៍ផ្ទាល់ខ្លួនដែរ (ភល ២, ៤)។ សូមរួមចំណែកក្នុងបេសកកម្មរបស់ព្រះអង្គ។ ព្រះអម្ចាស់ចាត់បងប្អូនម្តងទៀតឲ្យទៅតាមភូមិ តាមស្រុកនានា ដែលព្រះអង្គបម្រុងនឹងយាងទៅ (លក ១០, ១)។ ដូច្នេះ គ្រីស្តបរិស័ទធម្មតាពិតជាត្រូវបង្ហាញខ្លួនថា ខ្លួនជាសហការីរបស់ព្រះអង្គ តាមរបៀបប្លែកៗពីគ្នា និងដោយប្រើមធ្យោបាយផ្សេងៗ បំពេញកិច្ចការជាគ្រីស្តទូតតែមួយដដែលរបស់ព្រះសហគមន៍។ បងប្អូនក៏ស្គាល់សេចក្តីទាមទារនៅសម័យឥឡូវ ខិតខំប្រឹងប្រែងបម្រើព្រះអម្ចាស់ទាំងដឹងថា កិច្ចការដែលខ្លួនធ្វើទាំងនឿយហត់ ដោយរួមជាមួយព្រះអង្គនោះ មិនមែនអសារឥតការឡើយ (១ករ ១៥, ៥៨)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ នឹងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តី ដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្ត: សិលា ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ព្រះអម្ចាស់ចាត់ព្រះសហគមន៍ឲ្យទៅកាន់សាសន៍ដទៃ

(អំពីសកម្មភាពរបស់ព្រះសហគមន៍ជាសាសនទូត)

## Ad Gentes

## ខ្ញុំឈ្មោះប៉ូល ជាអភិបាល និងជាអ្នកបម្រើអស់អ្នកដែលបម្រើព្រះជាម្ចាស់។ រួមជាមួយអស់លោកអភិបាលដែលប្រជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធ សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេនឹកចងចាំជានិច្ច ។

## ក្រឹត្យក្រម អំពីសកម្មភាពរបស់ព្រះសហគមន៍ ដែលទទួលបេសកកម្មជាសាសនទូត

### បុព្វកថា

១-ព្រះជាម្ចាស់ចាត់ព្រះសហគមន៍ឲ្យទៅកាន់សាសន៍ដទៃ ដើម្បីទៅជា *"អគ្គសញ្ញានៃការសង្គ្រោះរបស់មនុស្សទាំងអស់"* (ពន្លឺ ៤៨)។ ហេតុនេះហើយ បានជាព្រះសហគមន៍ខិតខំអស់ពីសមត្ថភាព ប្រកាសដំណឹងល្អឲ្យមនុស្សទាំងអស់ស្របតាមការទាមទារនៃលក្ខណៈរបស់ខ្លួនផ្ទាល់ ជាព្រះសហគមន៍សកល និងតាមព្រះបញ្ជារបស់ព្រះយេស៊ូ ដែលបានបង្កើត ព្រះសហគមន៍នោះដែរ (មក ១៦, ១៦)។ ក្រុមគ្រីស្តទូតដែលជាគ្រឹះនៃព្រះសហគមន៍ បានយកតម្រាប់តាមព្រះគ្រីស្ត គឺអស់លោក *"បានប្រកាសព្រះបន្ទូលនៃសេចក្តីពិត និងបង្កើតព្រះសហគមន៍នានា"* (សន្តះអូគូស្តាំង)។ អស់លោកដែលបន្តមុខងារពីក្រុមគ្រីស្តទូត ក៏មានភារកិច្ចបន្តកិច្ចការនេះដែរ ដើម្បីឲ្យ *"ព្រះបន្ទូលរបស់ព្រះអម្ចាស់បានផ្សព្វផ្សាយ និងបានរុងរឿង"* (២ថស ៣, ១)។ អស់លោកក៏មានភារកិច្ចប្រកាសដំណឹងល្អ អំពីព្រះជាម្ចាស់គ្រងរាជ្យ និងតែងតាំងព្រះរាជ្យនោះលើពិភពលោកទាំងមូលផងដែរ។

ប៉ុន្តែ តាមសភាពការណ៍របស់មនុស្សលោកនាបច្ចុប្បន្នកាល ព្រះជាម្ចាស់ត្រាស់ហៅព្រះសហគមន៍ដែលជាអំបិលសម្រាប់ផែនដី និងជាពន្លឺបំភ្លឺពិភពលោក (មថ ៥, ១៣-១៤) ជាបន្ទាន់ឲ្យសង្គ្រោះ និងកែទម្រង់សត្វលោកទាំងអស់ឲ្យបានជាថ្មី ដើម្បីឲ្យអ្វីៗកើតជាថ្មីក្នុងអង្គព្រះគ្រីស្ត ហើយដើម្បីតែងតាំងមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាមហាគ្រួសារតែមួយក្នុងអង្គព្រះគ្រីស្ត និងឲ្យធ្វើជាប្រជារាស្ត្រតែមួយរបស់ព្រះជាម្ចាស់ទៀតផង។

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធអរព្រះគុណព្រះជាម្ចាស់ ចំពោះកិច្ចការដ៏ប្រសើរអស្ចារ្យ ដែលព្រះសហគមន៍ទាំងមូលបានខ្នះខ្នែងសម្រេចដោយចិត្តទូលំទូលាយ។ មហាសន្និបាតក៏ប្រាថ្នាចង់គូសបញ្ជាក់គោលការណ៍

ដ៏សំខាន់ៗនៃសកម្មភាពរបស់ព្រះសហគមន៍ ដែលបំពេញបេសកកម្មជាសាសនទូតដែរ។ មហាសន្និបាតក៏មានបំណង ប្រមែប្រមូលកម្លាំងគ្រីស្តបរិស័ទទាំងអស់ ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដើរទៅមុខ តាមទ្វារចង្អៀតនៃឈើឆ្កាង និងលាតសន្ធឹងព្រះរាជ្យរបស់ព្រះគ្រីស្តជាអម្ចាស់ ដែលទតមើលសតវត្សទាំងប៉ុន្មាននៅពេលតែមួយ (បស ៣៦, ១៩) ព្រមទាំងរៀបចំមាគ៌ាថ្វាយព្រះអង្គយាងមកយ៉ាងរុងរឿង។

# ជំពូក ១

## គោលការណ៍តាមលទ្ធិនៃគ្រីស្តសាសនា

### ២-គម្រោងការរបស់ព្រះបិតា

នៅពេលព្រះសហគមន៍ធ្វើដំណើរក្នុងលោកនេះ ព្រះសហគមន៍មានលក្ខណៈជាសាសនទូត ព្រោះព្រះសហគមន៍កើតមក ដោយព្រះជាម្ចាស់ជាព្រះបិតាចាត់ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមក តាមព្រះអង្គគ្រោងទុក (ពន្លឺ ១)។

គម្រោងការនេះហូរចេញមកពីព្រះហឫទ័យរបស់ព្រះបិតា ជាប្រភពនៃសេចក្តីស្រឡាញ់ គឺព្រះបិតាជាដើមកំណើតនៃអ្វីៗទាំងអស់ ព្រះអង្គប្រទានព្រះជន្មឲ្យព្រះបុត្រា ហើយព្រះវិញ្ញាណក៏ហូរចេញមកពីព្រះបិតា ដោយសារព្រះបុត្រា។ ព្រះបិតាបានប្រតិស្ឋានមនុស្សយើង ដោយព្រះអង្គមានសេរីភាពពេញលេញ មកពីព្រះអង្គមានព្រះហឫទ័យសប្បុរស និងមេត្តាករុណាយ៉ាងក្រៃលែងហួសពីការស្មាន។ ព្រះអង្គក៏ត្រាស់ហៅមនុស្សយើង ឲ្យទទួលចំណែកក្នុងព្រះជន្ម និងសិរីរុងរឿងផ្ទាល់របស់ព្រះអង្គថែមទៀត។ ព្រះអង្គបានចាក់បង្ហូរព្រះហឫទ័យ មេត្តាករុណារបស់ព្រះអង្គលើយើងដោយឥតសំចៃ ហើយទ្រង់នៅតែចាក់បង្ហូរព្រះហឫទ័យមេត្តាករុណានេះ តទៅឥតឈប់ឈរដែរ។ ហេតុនេះហើយ បានជាព្រះអង្គពិតជាព្រះអាទិករនៃសត្វលោកទាំងឡាយ ដើម្បីឲ្យព្រះអង្គ *"គ្រងរាជ្យលើអ្វីទាំងអស់ក្នុងគ្រប់ប្រការទាំងអស់"* (១ករ ១៥, ២៨) ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គផង និងប្រទានសុភមង្គលឲ្យមនុស្សយើងផងដែរ។ ព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅមនុស្សលោក ឲ្យទទួលចំណែកក្នុងព្រះជន្មផ្ទាល់របស់ព្រះអង្គ មិនគ្រាន់តែចែកឲ្យបុគ្គលម្នាក់ៗ ដែលគ្មានចំណងជាប់ទាក់ទងជាមួយអ្នកដទៃប៉ុណ្ណោះទេ តែព្រះអង្គសព្វព្រះហឫទ័យតែងតាំងប្រជារាស្ត្រមួយឲ្យប្រមែប្រមូលបុត្រធីតារបស់ព្រះអង្គដែលខ្ចាត់ខ្ចាយទៅ ឲ្យចូលរួបរួមគ្នាជាធ្លុងតែមួយថែមទៀតផង (យហ ១១, ៥២ )។

### ៣-បេសកកម្មរបស់ព្រះបុត្រា

ព្រះជាម្ចាស់សម្រេចគម្រោងការសង្គ្រោះមនុស្សជាតិទាំងមូល តែព្រះអង្គមិនសង្គ្រោះគេដោយស្ងាត់ៗក្នុងចិត្តគំនិតគេប៉ុណ្ណោះទេ ព្រះអង្គក៏មិនសង្គ្រោះគេ តាមរយៈអ្នកខ្លះ ដែលខិតខំស្វែងរកព្រះអង្គតាមរបៀបផ្សេងៗជាច្រើនដែរ សូម្បីតែតាមរយៈសាសនាផ្សេងៗក៏ដោយ។ អ្នកខ្លះខ្នះខ្នែងស្វែងរកព្រះអង្គទាំងមានបំណងទៅកាន់ព្រះអង្គ ប្រសិនបើពួកគេអាចធ្វើដូច្នេះបាននោះ គេក៏មានបំណងចង់ឃើញព្រះអង្គថែមទៀត។ តាមពិត ព្រះអង្គគង់មិននៅឆ្ងាយពីយើងម្នាក់ៗទេ (កក ១៧, ២៧)។ ជួនកាលយើងអាចចាត់ទុកថា ការខិតខំទាំងនោះមកពីមនុស្សតម្រង់ខ្លួនទៅរកព្រះដ៏ពិតប្រាកដ ឬជាការរៀបចំខ្លួនឲ្យទទួលដំណឹងល្អ (ពន្លឺ ១៦) តាមគម្រោងការដ៏សប្បុរសរបស់ព្រះជាម្ចាស់ ដែលថែរក្សាមនុស្សលោកដែរ។ ក៏ប៉ុន្តែ ត្រូវតែបំភ្លឺ និងតម្រង់ការខិតខំទាំងនោះដែរ។ ព្រះជាម្ចាស់សម្រេចព្រះហឫទ័យយាងចូលក្នុងប្រវត្តិសាស្ត្រមនុស្សលោក តាមរបៀបថ្មីជាស្ថាពរ គឺព្រះអង្គចាត់ព្រះបុត្រាឲ្យប្រសូតជាមនុស្សដូចយើង ដើម្បីដកមនុស្ស

លោកឲ្យរួចពីអំណាចនៃភាពងងឹត និងពីមារសាតាំង (កូឡ ១, ១៣; កក ១០, ៣៨) និងសម្រុះសម្រួលមនុស្សលោកឲ្យជាមួយព្រះអង្គក្នុងព្រះបុត្រានោះដែរ (២ ករ ៥, ១៩)។ ដោយប្រព្រឹត្តដូច្នេះ ព្រះអង្គពង្រឹងសេចក្ដីសុខសាន្ត គឺធ្វើឲ្យមនុស្សលោកដែលសុទ្ធតែជាអ្នកបាប រួបរួមជាមួយព្រះអង្គ និងរួមរស់ជាមួយគ្នាទុកជាបងប្អូន។ ព្រះអង្គប្រតិស្ឋានអ្វីៗទាំងអស់ដោយសារព្រះបុត្រា (ហប ១, ២; យហ ១, ៣; ១០, ១; ករ ៨, ៦; កូឡ ១, ១៦) និងតែងតាំងព្រះបុត្រានេះឲ្យទទួលអ្វីៗទាំងអស់ទុកជាមរតក និងប្រមូលអ្វីៗទាំងអស់ក្នុងអង្គព្រះបុត្រា (អភ ១, ១០ )។

ព្រះជាម្ចាស់ចាត់ព្រះគ្រីស្តយេស៊ូឲ្យយាងមកក្នុងពិភពលោក ធ្វើជាស្ពានមេត្រីដ៏ពិតប្រាកដរវាងព្រះអង្គ និងមនុស្សលោក។ ដោយព្រះបុត្រាពិតជាព្រះជាម្ចាស់មែន *"គ្រប់លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់ ស្ថិតនៅយ៉ាងពេញលេញ ក្នុងរូបកាយរបស់ព្រះគ្រីស្ត"* (កូឡ ២,៩)។ ព្រះបុត្រាជាលោកអដាំថ្មី ព្រោះព្រះអង្គពិតជាមនុស្ស។ ព្រះបិតាតែងតាំងព្រះអង្គធ្វើជាមេដឹកនាំមនុស្សលោកដែលកើតជាថ្មី ព្រះអង្គពោរពេញដោយ *"ព្រះហឫទ័យប្រណីសន្ដោស និងដោយសេចក្ដីពិត"* (យហ ១, ១៤)។ ហេតុនេះហើយ បានជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលប្រសូតជាមនុស្សយ៉ាងពិតប្រាកដ ព្រះអង្គយាងមកចែករំលែកព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ឲ្យមនុស្សលោក។ «ព្រះអង្គដែលមានសម្បត្តិដ៏ច្រើន បានដាក់ខ្លួនមកជាអ្នកក្រ ដើម្បីឲ្យយើងទៅជាអ្នកមានដោយភាពក្រីក្ររបស់ព្រះអង្គ» (២ករ ៨, ៩)។ «បុត្រមនុស្សយាងមកក្នុងលោកនេះ មិនមែនដើម្បីឲ្យគេបម្រើលោកទេ គឺដើម្បីបម្រើមនុស្សលោក និងបូជាជីវិតសម្រាប់រំដោះមនុស្សទាំងអស់វិញ» (មក ១០, ៤៥)។ អស់គ្រូបាធ្យាយដ៏វិសុទ្ធនៃព្រះសហគមន៍តែងតែប្រកាសថា ព្រះគ្រីស្តលើកយកអ្វីណាមួយក្នុងរូបកាយព្រះអង្គ ព្រះអង្គក៏ប្រោសអ្វីមួយនោះឲ្យបានជាសះស្បើយ។ ប៉ុន្តែ ព្រះបុត្រាបានលើកយកសភាពជាមនុស្សគ្រប់យ៉ាង ដូចយើងទាំងអស់គ្នា ជាអ្នកកើតទុក្ខ និងជាអ្នកក្រីក្រ តែព្រះអង្គមិនដែលប្រព្រឹត្តអំពើបាបណាមួយសោះឡើយ (ហប ៤, ១៥; ៩, ២៨)។ ព្រះបិតាបានញែកព្រះគ្រីស្តប្រសិទ្ធិឲ្យបានវិសុទ្ធ និងចាត់ព្រះអង្គឲ្យយាងមកក្នុងពិភពលោក (យហ ១០, ៣៦)។ ព្រះគ្រីស្តមានព្រះបន្ទូល អំពីព្រះអង្គផ្ទាល់ថា៖ *"ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គចាត់ខ្ញុំឲ្យមកប្រាប់មនុស្សជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថា គេមើលឃើញវិញ"* (លក ៤, ១៨)។ ព្រះអង្គមានព្រះបន្ទូលទៀតថា៖ *"បុត្រមនុស្សបានមកដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់"* (លក ១៩, ១០)។

ត្រូវប្រកាសសេចក្ដីដែលព្រះអម្ចាស់បានថ្លែងកាលពីមុន និងអ្វីៗដែលព្រះជាម្ចាស់បានប្រព្រឹត្ត ក្នុងអង្គព្រះគ្រីស្ត ដើម្បីសង្គ្រោះមនុស្សលោក គឺត្រូវប្រកាស និងផ្សព្វផ្សាយរហូតដល់ទីដាច់ស្រយាលនៃផែនដី (កក ១, ៨) ចាប់តាំងពីក្រុងយេរូសាឡឹមតទៅ (លក ២៤, ៤៧) ដើម្បីឲ្យអ្វីដែលព្រះជាម្ចាស់បានសម្រេចម្ដងជាស្រេចនោះក្នុងគោលបំណងសង្គ្រោះមនុស្សទាំងអស់ បានលទ្ធផលក្នុងមនុស្សទាំងអស់ នៅគ្រប់ជំនាន់តរៀងទៅ។

## ៤-បេសកម្មនៃព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះគ្រីស្តចាត់ព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះបិតាមក ដើម្បីបំពេញគម្រោងការរបស់ព្រះអង្គយ៉ាងពេញលេញ គឺព្រះវិញ្ញាណប្រោសឲ្យព្រះរាជកិច្ចរបស់ព្រះគ្រីស្ត ដែលសង្គ្រោះមនុស្សលោក បានសម្រេចក្នុងចិត្តគំនិតរបស់មនុស្សលោក។ ព្រះវិញ្ញាណក៏ជំរុញព្រះសហគមន៍ឲ្យលាតត្រដាងនៅគ្រប់កន្លែងដែរ។ ច្បាស់ជាព្រះវិញ្ញាណមានសកម្មភាពមុនព្រះគ្រីស្តទទួលសិរីរុងរឿងពិតមែនហើយ ត្រង់នេះមិនត្រូវសង្ស័យឡើយ។ ក៏ប៉ុន្តែ នៅបុណ្យថ្ងៃទីហាសិបព្រះវិញ្ញាណ យាងមកសណ្ឋិតនៅលើក្រុមសាវ័ក ដើម្បីស្ថិតនៅជាមួយគេ រហូតជានិច្ចនិរន្តរ៍តរៀងទៅ (យហ ១៤, ១៦)។ ពេលនោះ ព្រះសហគមន៍បង្ហាញខ្លួននៅចំពោះមុខមនុស្សទាំងអស់ជាសាធារណៈ ហើយក្រុមសាវ័កចាប់ផ្ដើមប្រកាស

ដំណឹងល្អទៀតផង។ នៅពេលដដែលនោះ ព្រះសហគមន៍នៃសម្ពន្ធមេត្រីថ្មីដែលនិយាយគ្រប់ភាសាយល់ និងស្រឡាញ់គ្រប់ភាសាដូចគ្នា ក៏ផ្តល់សញ្ញាសម្គាល់ទុកជាមុន អំពីប្រជាជនទាំងអស់រួបរួមគ្នាក្នុងជំនឿសកលតែមួយដែរ។ ព្រះសហគមន៍ក៏ប្រមែប្រមូលមនុស្សដែលខ្ចាត់ខ្ចាយដែរ (តាមអត្ថបទស្តីពីប្រាសាទនៅបាបិល កណ ១១, ១-៩)។ នៅថ្ងៃបុណ្យទីហាសិប *"កិច្ចការរបស់គ្រីស្តទូត"* ចាប់ផ្តើមហើយដូចនៅពេលព្រះវិញ្ញាណយាងមកលើព្រះនាងព្រហ្មចារិនីម៉ារី នៅពេលព្រះគ្រីស្តចាប់ផ្ទៃ ឬដូចនៅពេលព្រះវិញ្ញាណដ៏វិសុទ្ធដដែលនោះយាងមកលើព្រះគ្រីស្ត ពេលព្រះអង្គអធិដ្ឋានដូច្នោះដែរ ហើយជំរុញព្រះគ្រីស្តឲ្យចាប់ផ្តើមព្រះរាជកិច្ចបម្រើមនុស្សលោក (លក ៣, ២២; ៤, ១; កក ១០, ៣៨)។ មុនពេលព្រះគ្រីស្តយេស៊ូបូជាព្រះជន្មសម្រាប់មនុស្សលោក ដោយគ្មាននរណាបង្ខំ ព្រះអង្គចាត់ចែងមុខងារបម្រើរបស់ក្រុមគ្រីស្តទូត ហើយមានព្រះបន្ទូលសន្យាថា និងចាត់ព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកដែរ។ ហេតុនេះហើយ បានជាមុខងារបម្រើ និងបេសកម្មក្រុមគ្រីស្តទូតនោះជាប់ជាមួយគ្នា ដើម្បីបំពេញព្រះរាជកិច្ចនៃការសង្គ្រោះនៅគ្រប់កន្លែង ហើយរហូតតរៀងទៅ។ នៅគ្រប់សម័យ ព្រះវិញ្ញាណ «បង្រួបបង្រួមព្រះសហគមន៍ទាំងមូល ឲ្យរួបរួមគ្នាជាធ្លុងតែមួយ និងឲ្យមានមុខងារបម្រើផ្សេងៗ។ ព្រះអង្គក៏ប្រទានព្រះអំណោយទានផ្សេងៗ ដែលចាត់ចែងព្រះសហគមន៍ឲ្យមានរចនាសម្ពន្ធតាមលំដាប់លំដោយ និងឲ្យសម្តែងសកម្មភាពរបស់ព្រះអង្គផ្ទាល់ដែរ» (ពន្លឺ ៤)។ ព្រះវិញ្ញាណផ្តល់ឲ្យរចនាសម្ពន្ធនៃព្រះសហគមន៍មានជីវិតរស់រវើក និងប្រោសឲ្យគ្រីស្តបរិស័ទមានចិត្តជាសាសនទូត ដូចព្រះអង្គជំរុញព្រះគ្រីស្ត កាលពីដើមដូច្នោះដែរ។ ជួនកាលព្រះវិញ្ញាណបំពេញសកម្មភាពយ៉ាងច្បាស់ មុនពេលគ្រីស្តទូតមកបំពេញការងាររបស់ខ្លួន (កក ១០, ៤៤-៤៧; ១១, ១៥; ១៥, ៨) ព្រះអង្គក៏នៅតែណែនាំ និងគាំទ្រសកម្មភាពក្រុមគ្រីស្តទូតទាំងនោះ ដោយគ្រប់បែបយ៉ាងតទៅទៀតដែរ (កក ៤, ៨; ៥, ៣២; ៨, ២៦.២៩.៣៩; ៩, ៣១; ១០; ១១, ២៤.២៨; ១៣, ២.៤.៩; ១៦, ៦-៧; ២០, ២២-២៣ ; ២១, ១១ )។

## ៥-បេសកកម្មរបស់ព្រះសហគមន៍

នៅពេលព្រះអម្ចាស់យេស៊ូចាប់ផ្តើមព្រះរាជកិច្ចព្រះអង្គ *"ត្រាស់ហៅ អស់អ្នកដែលទ្រង់សព្វព្រះហឫទ័យជ្រើសរើស និងតែងតាំងសាវ័កដប់ពីរនាក់ឲ្យនៅជាមួយព្រះអង្គ ដើម្បីចាត់គេឲ្យទៅប្រកាសដំណឹងល្អ"* (មក ៣, ១៣; តាម មថ ១០, ១-៤២)។ ដូច្នេះ ក្រុមគ្រីស្តទូតទៅជាពន្លកដើមដំបូងនៃប្រជាជនអ៊ីស្រាអែលថ្មី និងជាដើមកំណើតនៃក្រុមអភិបាល។ បន្ទាប់មកកាលព្រះអម្ចាស់បង្ហើយគម្រោងការដ៏អស្ចារ្យអំពីការសង្គ្រោះ និងអំពីការកែទម្រង់ពិភពលោកឲ្យបានជាថ្មីនោះ។ ដោយព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ថ្មីដ៏រុងរឿង ព្រះអង្គទទួលគ្រប់អំណាចនៅលើមេឃ និងនៅលើផែនដី (មថ ២៨, ១៨) ទ្រង់តែងតាំងព្រះសហគមន៍ទុកជាអគ្គសញ្ញានៃការសង្គ្រោះមុនពេលព្រះជាម្ចាស់លើកព្រះអង្គទៅលើ (កក ១, ១១)។ ព្រះបិតាចាត់ព្រះបុត្រាឲ្យយាងមកយ៉ាងណា (យហ ២០, ២១) ព្រះអម្ចាស់យេស៊ូ ក៏ចាត់ក្រុមគ្រីស្តទូតឲ្យទៅក្នុងពិភពលោកទាំងមូលយ៉ាងនោះដែរ ទាំងបញ្ជាថា *"ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្រៀនដល់អ្នករាល់គ្នា"* (មថ ២៨, ១៩ត)។ *"ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់ចុះ។ អ្នកណាជឿ និងទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកមិនព្រមជឿវិញនឹងត្រូវទទួលទោស"* (មក ១៦, ១៥ត)។ តាមព្រះបន្ទូលទាំងនោះ ព្រះសហគមន៍មានភារកិច្ចផ្សព្វផ្សាយជំនឿ និងការសង្គ្រោះដែលព្រះគ្រីស្តនាំមក។ ម៉្យាងទៀត ក្រុមអភិបាលព្រះសហគមន៍ទទួលភារកិច្ចនេះទុកជាកេរមរតកបន្តពីក្រុមគ្រីស្តទូតដែរ ដោយមានក្រុមលោកគង្វាលជួយផង ទាំងរួបរួម

ជាមួយអភិបាលក្រុងរ៉ូមដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ជាគង្វាលដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះសហគមន៍។ ម្យ៉ាងទៀត ព្រះគ្រីស្តក៏ប្រទានឲ្យគ្រីស្តបរិស័ទគ្រប់ៗរូបក្នុងព្រះសហគមន៍ ទទួលជីវិតពីព្រះអង្គដែរ គឺ *"ព្រះអង្គហើយ ដែលធ្វើឲ្យព្រះកាយទាំងមូលរួបរួមផ្គុំគ្នា និងភ្ជាប់ឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មានដែលបម្រើព្រះកាយ តាមកម្រិតសមត្ថភាពរបស់សរីរាង្គនីមួយៗ ដើម្បីឲ្យព្រះកាយនោះចម្រើននិងកសាងឡើងក្នុងសេចក្តីស្រឡាញ់។"* (អភ ៤, ១៦)។ ព្រះសហគមន៍បំពេញបេសកម្មរបស់ខ្លួន ដោយប្រព្រឹត្តតាមព្រះបញ្ជារបស់ព្រះគ្រីស្ត និងដោយព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យព្រះសហគមន៍ មានចលនារស់រវើកនឹងសេចក្តីស្រឡាញ់។ ដូច្នេះព្រះសហគមន៍មានវត្តមានយ៉ាងពិតប្រាកដនៅក្បែរមនុស្សលោកគ្រប់ៗរូប និងនៅក្បែរប្រជាជនទាំងអស់។ ព្រះសហគមន៍ក៏នាំគេឲ្យផ្ញើជីវិតលើព្រះអង្គ ឲ្យគេមានសេរីភាព និងឲ្យគេបានសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត។ ដោយគ្រីស្តបរិស័ទរស់នៅបែបជាគំរូដល់គេ ដោយប្រកាសដំណឹងល្អ ដោយចែងអគ្គសញ្ញានានា និងដោយប្រើមធ្យោបាយផ្សេងៗ ព្រះសហគមន៍នាំព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់មកគេទៀតផងដែរ។ ធ្វើដូច្នេះ ព្រះសហគមន៍ក៏បើកផ្លូវយ៉ាងពិតប្រាកដឲ្យគេអាចចូលរួមយ៉ាងពេញលេញក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត។ បេសកម្មរបស់ព្រះសហគមន៍នេះបន្ត និងពង្រីងបេសកម្មរបស់ព្រះគ្រីស្តផ្ទាល់ តាមដំណើរនៃប្រវត្តិសាស្ត្រ គឺបេសកកម្មរបស់ព្រះគ្រីស្តដែលព្រះ បិតាចាត់ឲ្យយាងមកប្រកាសដំណឹងល្អដល់ជនក្រីក្រ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្តក៏ជំរុញព្រះសហគមន៍ឲ្យទៅតាមផ្លូវរបស់ព្រះគ្រីស្តនោះ គឺព្រះសហគមន៍ក៏ត្រូវរស់នៅក្នុងឋានៈជាជនក្រីក្រ ធ្វើតាមបញ្ជា សុខចិត្តបម្រើគេ និងសុខចិត្តបូជាជីវិតរហូតដល់បាត់បង់ជីវិតផង។ ប៉ុន្តែ ព្រះគ្រីស្តមានជ័យជម្នះលើសេចក្តីស្លាប់នេះ ដោយទ្រង់ទទួលព្រះជន្មថ្មីដ៏រុងរឿង។ ក្រុមគ្រីស្តទូតទាំងអស់បានដើរតាមផ្លូវដដែលនោះទាំងមានចិត្តសង្ឃឹម អស់លោកក៏រងទុក្ខវេទនា និងឈឺចុកចាប់ជាច្រើនយ៉ាង គឺអស់លោក *"ជួយបំពេញទុក្ខលំបាករបស់ព្រះគ្រីស្ត សម្រាប់ព្រះកាយព្រះអង្គជាព្រះសហគមន៍"* (កូឡ ១, ២៤)។ គ្រីស្តបរិស័ទបានបង្ហូរឈាមរបស់ខ្លួនជារឿយៗ ទុកជាពូជបង្កើតគ្រីស្តបរិស័ទឯទៀតៗដែរ (លោកទែរទូស៊ីយាំង)។

## ៦-សកម្មភាពជាសាសនទូត

ក្រុមអភិបាល ដែលមានអភិបាលក្រុងរ៉ូម ជាអ្នកបន្តមុខតំណែងរបស់គ្រីស្តទូតសិលាមកធ្វើជាប្រធាន មានភារកិច្ចបំពេញបេសកម្មនោះ ដោយមានព្រះសហគមន៍ទាំងមូលជួយអធិដ្ឋាន និងសហការផងដែរ។ ទោះបីអស់លោកអភិបាលបំពេញបេសកម្មនេះតាមរបៀបផ្សេងៗពីគ្នា ត្រូវតាមសភាពការណ៍ផ្សេងៗក្តី ក៏បេសកម្មនោះមានតែមួយគត់ និងដដែលនៅគ្រប់ទីកន្លែង ក្នុងគ្រប់កាលៈទេសៈ។ ហេតុហើយបានជាត្រូវទទួលស្គាល់ថា សកម្មភាពផ្សេងៗរបស់ព្រះសហគមន៍ មិនមែនមកពីលក្ខណៈផ្ទាល់របស់បេសកម្មទេ តែហូរមកពីសភាពការណ៍ផ្សេងៗរបស់គ្រីស្តរិស័ទ ដែលបំពេញបេសកកម្មនោះ។

ជួនកាលសភាពការណ៍ប្លែកៗ មកពីព្រះសហគមន៍ ជួនកាលមកពីប្រជាជននានា ជួនកាលមកពីក្រុមមនុស្សដែលប្លែកពីគ្នា ឬជួនកាលមកពីមនុស្ស ដែលព្រះសហគមន៍ទាក់ទងជាមួយ នៅពេលបំពេញបេសកកម្មនោះតែម្តង។ ទោះបីព្រះសហគមន៍មានមធ្យោបាយសព្វគ្រប់ ដើម្បីនាំការសង្គ្រោះក្តី ក៏ព្រះសហគមន៍មិនប្រព្រឹត្តហើយក៏មិនអាចប្រព្រឹត្តភ្លាមៗ និងចំៗ តាមគ្រប់មធ្យោបាយរបស់ខ្លួនជានិច្ចបានទេ។ ជួនកាលព្រះសហគមន៍ចាប់ផ្តើមបំពេញសកម្មភាពតាមកម្រិត ដើម្បីខិតខំធ្វើគម្រោងការរបស់ព្រះជាម្ចាស់ឲ្យបានសម្រេច។ ជួនកាលព្រះសហគមន៍ចាប់ផ្តើមបំពេញសកម្មភាពយ៉ាងស្រួល តែក្រោយមកត្រូវអន់ថយទៅវិញ ឬស្ថិតនៅដដែលដូចជាឃាំងស្ទាក់ មិនអាចទៅមុខទៀតបាន។ ចំពោះមនុស្សវិញ ព្រះសហគមន៍ទាក់ទងជាមួយក្រុមមនុស្សខ្លះ និងប្រជាជនខ្លះ តែបន្តិចម្តងៗប៉ុណ្ណោះទេ ហើយ

ក៏ជ្រួតជ្រាបក្នុងចិត្តគំនិតគេតែបន្តិចម្ដងៗដែរ។ យូរៗទៅព្រះសហគមន៍ក៏លើកយកអ្នកទាំងនោះ ឲ្យចូលក្នុងសេចក្ដីដ៏ពេញលក្ខណៈរបស់ព្រះសហគមន៍សកលដែរ។ តែត្រូវឲ្យសកម្មភាពរបស់ព្រះសហគមន៍ និងមធ្យោបាយផ្សេងៗដែលព្រះសហគមន៍ប្រើនោះ បានស្របតាមសភាពការណ៍នីមួយៗនិងតាមរបៀបរស់នៅរបស់គេ។

តាមធម្មតាគេហៅ *"បេសកកម្ម"* គឺកិច្ចការផ្សេងៗរបស់អ្នក ដែលព្រះសហគមន៍ចាត់ឲ្យទៅក្នុងពិភពលោកទាំងមូល ដើម្បីប្រកាសដំណឹងល្អ និងតែងតាំងព្រះសហគមន៍ក្នុងប្រជាជនមួយ និងក្នុងក្រុមមនុស្សដែលមិនទាន់ជឿលើព្រះគ្រីស្តនៅឡើយ។ ធម្មតា "បេសកជន" ឬ «សាសនទូត» ទាំងនោះបំពេញសកម្មភាពផ្សេងៗក្នុងតំបន់ ដែលសន្តអាសនៈបានកំណត់ទុក និងទទួលស្គាល់ហើយ។ សកម្មភាពរបស់សាសនទូតទាំងនោះមានគោលដៅតែមួយ គឺនាំដំណឹងល្អដល់ប្រជាជន និងតែងតាំងព្រះសហគមន៍នៅក្នុងប្រជាជន ឬនៅក្នុងក្រុមមនុស្សដែលព្រះសហគមន៍មិនទាន់ចាក់ឫសនៅឡើយ។ ត្រូវឲ្យព្រះសហគមន៍ថ្មីៗដោយឡែក កើតឡើងដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចម្រើនឡើងនៅគ្រប់កន្លែងក្នុងពិភពលោកទាំងមូល។ ត្រូវតែងតាំងព្រះសហគមន៍ទាំងនោះ ឲ្យមានសមត្ថភាពអាចរស់នៅដោយខ្លួនឯងបាន និងមានកម្លាំងមាំមួនគ្រប់គ្រាន់ ហើយមានធនធានផ្ទាល់ គឺមានកម្លាំងដូចជាមានអាយុពេញវ័យ។ ត្រូវឲ្យព្រះសហគមន៍ថ្មីៗ មានក្រុមអភិបាលដែលកើតមកពីប្រជាជននោះ រួមជាមួយប្រជាជនគ្រីស្តបរិស័ទ និងមានមធ្យោបាយគ្រប់គ្រាន់ដែលគេត្រូវការ សមស្របតាមទេពកោសល្យនិងអរិយធម៌របស់គេ។ ធ្វើដូច្នេះ ទើបព្រះសហគមន៍ថ្មីៗទាំងនោះ អាចរស់នៅក្នុងឋានៈជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ ហើយអាចជួយជាប្រយោជន៍ ដល់ព្រះសហគមន៍ទាំងមូលផងដែរ។ មានតែការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្តប៉ុណ្ណោះទេ ដែលជាមធ្យោបាយចម្បងសម្រាប់តែងតាំងព្រះសហគមន៍បែបនោះ។ ព្រះអម្ចាស់ចាត់ក្រុមសាវ័កក្នុងពិភពលោកទាំងមូល ដើម្បីឲ្យគេប្រកាសដំណឹងល្អ និងដើម្បីឲ្យមនុស្សដែលកើតជាថ្មី ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះ (១សល ១, ២៣) អាចចូលរួមក្នុងព្រះសហគមន៍ ដោយអគ្គសញ្ញាជ្រមុជទឹកទៀតផង។ ព្រះសហគមន៍ជាព្រះកាយរបស់ព្រះគ្រីស្ត ដែលជាព្រះបន្ទូលប្រសូតជាមនុស្ស។ ព្រះសហគមន៍ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទុកជាអាហារដែលផ្ដល់ជីវិត និងទទួលនំប៉័ងនៃអគ្គសញ្ញាអរព្រះគុណទៀតដែរ (កក ២, ៤២ )។

នៅពេលព្រះសហគមន៍បំពេញបេសកកម្មជាសាសនទូតនេះ ព្រះសហគមន៍ជួបប្រទះសភាពការណ៍ប្លែកៗពីគ្នា។ ជួនកាលសភាពការណ៍ទាំងនោះលាយឡំគ្នា គឺមុនដំបូងព្រះសហគមន៍ចាប់ផ្ដើមចាក់ឫស រួចចម្រើនឡើងដូចជានៅថ្មីខ្ចី ក្រោយមកគេដូចជានៅយុវវ័យ។ កាលណាព្រះសហមន៍ឆ្លងដំណាក់កាលទាំងនោះ ព្រះសហគមន៍នៅតែប្រកាសដំណឹងល្អតទៅទៀត គឺព្រះសហគមន៍តែងតាំងថ្មីទាំងនោះ នៅតែមានភារកិច្ចបន្តបេសកកម្មនេះតទៅទៀត គឺប្រកាសដំណឹងល្អដល់អស់អ្នកដែលនៅខាងក្រៅនៅឡើយ។ លើសពីនេះទៅទៀត ជួនកាលព្រះសហគមន៍ស្ថិតនៅក្នុងក្រុមមនុស្សខ្លះរួចហើយ តែក្រុមទាំងនោះត្រូវប្រែប្រួលទាំងស្រុងដោយមានមូលហេតុផ្សេងៗ បណ្ដាលឲ្យសភាពការណ៍ថ្មីៗកើតឡើង។ ពេលនោះ ព្រះសហគមន៍ត្រូវពិនិត្យពិចារណាថា តើត្រូវបង្កើតសកម្មភាពប្រកាសដំណឹងល្អសារជាថ្មីព្រោះសភាពការណ៍ទាំងនោះឬយ៉ាងណា?។ ម្យ៉ាងទៀត ក្នុងសភាពការណ៍ខ្លះ ព្រះសហគមន៍គ្មានលទ្ធភាពអាចប្រកាសដំណឹងល្អចំៗភ្លាមបានទេ យ៉ាងហោចណាស់ក្នុងរយៈពេលមួយ។ ពេលនោះ សាសនទូតអាច និងត្រូវផ្ដល់សក្ខីភាពអំពីព្រះហឫទ័យស្រឡាញ់ និងមេត្តាករុណារបស់ព្រះគ្រីស្ត ដោយចិត្តអត់ធ្មត់ខន្តី និងប្រុងប្រយ័ត្ន ទាំងផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់។ ធ្វើដូច្នេះ សាសនទូតរៀបចំមាគ៌ាថ្វាយព្រះអម្ចាស់ និងធ្វើឲ្យព្រះអង្គមានវត្តមានម្យ៉ាងនៅក្នុងប្រជាជននោះ។ ហេតុនេះហើយ បានជាសកម្មភាពជាសាសនទូតច្បាស់ជាហូរចេញមកយ៉ាងជ្រៅពីលក្ខណៈផ្ទាល់របស់ព្រះសហ

គមន៍មែន។ សកម្មភាពជាសាសនទូតនេះផ្សព្វផ្សាយជំនឿដែលសង្គ្រោះមនុស្សលោក និងលាតសន្ធឹងព្រះសហគមន៍។ សកម្មភាពនេះ ក៏ធ្វើឲ្យលក្ខណៈសកលរបស់ព្រះសហគម៍កើតជារូបរាងដែរ។ លក្ខណៈរបស់ព្រះសហគមន៍ដែលមានក្រុមគ្រីស្តទូតជាគ្រឹះ ក៏ពង្រឹងសកម្មភាពជាសាសនទូតឲ្យមានកម្លាំងឡើង និងនាំឲ្យក្រុមអភិបាលមានអារម្មណ៍ទទួលខុសត្រូវរួមជាមួយគ្នា។ សកម្មភាពជាសាសនទូតនោះក៏បញ្ជាក់ និងផ្សព្វផ្សាយ ព្រមទាំងណែនាំមនុស្សឲ្យបានវិសុទ្ធថែមទៀតផង។ ហេតុនេះហើយ បានជាសកម្មភាពជាសាសនទូតក្នុងចំណោមសាសន៍ដទៃ ប្លែកពីសកម្មភាពរបស់ព្រះសហសគមន៍ដែលឃ្វាលណែនាំគ្រីស្តបរិស័ទ ហើយប្លែកពីកិច្ចការផ្សេងៗ ដែលត្រូវចាប់ផ្តើមធ្វើដើម្បីបង្រួបបង្រួមគ្រីស្តបរិស័ទទាំងអស់ឲ្យរួមគ្នាជាធ្លុងតែមួយដែរ។ ប៉ុន្តែ សកម្មភាពទាំងពីរនោះ ក៏ភ្ជាប់យ៉ាងជិតស្និទ្ធនឹងសកម្មភាពជាសាសនទូតរបស់ព្រះសហគមន៍ដែរ ព្រោះថា គ្រីស្តបរិស័ទបាក់បែកគ្នាដូច្នេះ បណ្តាលឲ្យកើតមានឧបសគ្គរាំង ការប្រកាសដំណឹងល្អដល់សត្វលោកទាំងឡាយ ដែលជាកិច្ចការដ៏វិសុទ្ធជាងគេបំផុត (បង្រួប ១) ហើយក៏បិទផ្លូវមិនឲ្យមនុស្សជាច្រើនមានជំនឿទៀតដែរ។ ហេតុនេះហើយ បានជាព្រះជាម្ចាស់ត្រាស់ហៅ អស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹកឲ្យរួបរួមគ្នាជាមហាគ្រួសារតែមួយ។ ដូច្នេះ គេអាចព្រមគ្នាផ្តល់សក្ខីភាពតែមួយអំពីព្រះគ្រីស្តជាព្រះអម្ចាស់របស់គេ នៅចំពោះមុខជាតិសាសន៍ទាំងឡាយ។ នេះពិតជាភារកិច្ចដ៏ចាំបាច់នៃបេសកកម្មជាសាសនទូតមែន។ ប្រសិនបើគ្រីស្តបរិស័ទមិនទាន់មានសមត្ថភាពអាចផ្តល់សក្ខីភាពអំពីជំនឿតែមួយនៅឡើយ ក៏យ៉ាងហោចណាស់ គេត្រូវស្រឡាញ់គ្នា និងរាប់អានគ្នាទៅវិញទៅមកដែរ។

## ៧-មូលហេតុ និងសេចក្តីត្រូវការនៃសកម្មភាពជាសាសនទូត

*"ព្រះជាម្ចាស់សព្វព្រះហឫទ័យសង្គ្រោះមនុស្សទាំងអស់ និងឲ្យបានស្គាល់សេចក្តីពិត ដ្បិតមានព្រះជាម្ចាស់តែមួយព្រះអង្គ ជាស្ពានមេត្រីតែមួយរវាងព្រះជាម្ចាស់និងមនុស្សលោក គឺព្រះយេស៊ូគ្រីស្តជាមនុស្សម្នាក់ដែលបានបូជាព្រះជន្មដើម្បីរំដោះមនុស្សទាំងអស់"* (១ធម ២, ៤-៥)។ *"គ្មាននរណាផ្សេងទៀត អាចសង្គ្រោះមនុស្សលោកបានឡើយ"* (កក ៤, ១២)។ ព្រះសហគមន៍បំពេញសកម្មភាពជាសាសនទូតនេះ មកពីព្រះជាម្ចាស់សព្វព្រះហឫទ័យដូច្នេះ។ ហេតុនេះហើយ បានជាត្រូវឲ្យមនុស្សទាំងអស់ប្រែចិត្តទៅរកព្រះគ្រីស្ត ដែលគេបានស្គាល់ដោយព្រះសហគមន៍ប្រកាសដំណឹងល្អ។ គេក៏ត្រូវចូលរួមក្នុងអង្គព្រះគ្រីស្ត និងក្នុងព្រះសហគមន៍ដែលជាព្រះកាយព្រះអង្គ ដោយសារអគ្គសញ្ញាជ្រមុជទឹក។ *"ព្រះគ្រីស្តផ្ទាល់បង្រៀនយ៉ាងជាក់ច្បាស់ថា មនុស្សត្រូវតែផ្ញើជីវិតលើព្រះអង្គ និងទទួលអគ្គសញ្ញាជ្រមុជទឹកជាចាំបាច់ (មក ១៦, ១៦; យហ ៣, ៥)។ នៅពេលជាមួយគ្នានោះ ព្រះអង្គក៏បញ្ជាក់ថាត្រូវតែមានព្រះសហគមន៍ជាចាំបាច់ដែរ។ មនុស្សចូលក្នុងព្រះសហគមន៍ដោយអគ្គសញ្ញាជ្រមុជទឹកដែលជាទ្វារ។ ហេតុនេះហើយ បានជាអស់អ្នកដែលដឹងថាព្រះជាម្ចាស់បានតែងតាំងព្រះសហគមន៍កាតូលិក ដោយសារព្រះយេស៊ូគ្រីស្ត ទុកជាមធ្យោបាយដ៏ចាំបាច់ដើម្បីទទួលការសង្គ្រោះ ប៉ុន្តែ បដិសេធមិនព្រមចូលព្រះសហគមន៍កាតូលិក ឬបដិសេធមិនព្រមព្យាយាមស្ថិតនៅជាប់នឹងព្រះសហគមន៍នោះ ពុំអាចទទួលការសង្គ្រោះបានឡើយ"* (ពន្លឺ ១៤)។ ប៉ុន្តែ ព្រះជាម្ចាស់អាចណែនាំមនុស្សដែលមិនស្គាល់ដំណឹងល្អ (ដោយគ្មានកំហុសផ្ទាល់ខ្លួនទេ) ឲ្យផ្ញើជីវិតលើព្រះអង្គតាមមាគ៌ាផ្សេងៗបាន ជាមាគ៌ាដែលមានតែព្រះអង្គទេដែលស្គាល់។ មានតែការផ្ញើជីវិតលើព្រះអង្គប៉ុណ្ណោះទេ ដែលអាចធ្វើឲ្យមនុស្សបានគាប់ព្រះហឫទ័យព្រះជាម្ចាស់បាន (ហប ១១, ៦)។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍មានកាតព្វកិច្ចប្រកាសដំណឹងល្អ (១ករ ៩, ១៦) ហើយក៏មានសិទ្ធិដ៏សក្ការៈប្រកាសដំណឹងល្អនេះថែមទៀតផង។ ហេតុនេះហើយ បានជាព្រះសហគមន៍ត្រូវតែមានសកម្មភាពជាសាសនទូតយ៉ាងខ្លាំង និងជាចាំបាច់ យ៉ាងពេញលេញ នៅសម័យបច្ចុប្បន្នក៏ដូចនៅគ្រប់សម័យដែរ។

ដោយការប្រកាសដំណឹងល្អនេះ ព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តប្រមែប្រមូល និងចាត់ចែងកម្លាំងរបស់ខ្លួនឥតឈប់ឈរ ដើម្បីចម្រើនឡើង (អភ ៤, ១១-១៦)។ សេចក្តីស្រឡាញ់របស់សមាជិកនៃព្រះសហគមន៍ ចំពោះព្រះជាម្ចាស់ជំរុញឲ្យគេបំពេញសកម្មភាពជាសាសនទូតនេះ ហើយក៏ជំរុញឲ្យគេមានបំណងចង់ចែករំលែកសម្បត្តិ ខាងព្រះវិញ្ញាណនៃជីវិតនៅលោកខាងមុខ ឲ្យមនុស្សទាំងអស់ ដូចគេចែករំលែកសម្បត្តិនៅនាលោកនេះឲ្យគេដែរ។

ដោយព្រះសហគមន៍មានសកម្មភាពជាសាសនទូតដូច្នេះ មនុស្សលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់យ៉ាងពេញលេញទៀត ព្រោះគេទទួលស្គាល់ ទាំងដឹងខ្លួន និងយ៉ាងពេញលេញ នូវព្រះរាជកិច្ចដែលព្រះអង្គបានសម្រេចក្នុងអង្គព្រះគ្រីស្ត ដើម្បីសង្គ្រោះគេ។ ដោយព្រះសហគមន៍ប្រកាសដំណឹងល្អដូច្នេះ ព្រះជាម្ចាស់ក៏សម្រេចគម្រោងការរបស់ព្រះអង្គ ជាគម្រោងការដែលព្រះគ្រីស្តបានបម្រើ ដោយទ្រង់បានស្តាប់តាមព្រះបញ្ជា និងដោយព្រះហឫទ័យស្រឡាញ់ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះបិតា ដែលចាត់ព្រះអង្គឲ្យយាងមក (យហ ៧, ១៨; ៨, ៣០.៤០.៥០; ១៧, ១)។ គម្រោងការនេះមានដូចតទៅ គឺនាំឲ្យមនុស្សលោកទាំងមូលរួបរួមគ្នាជាប្រជារាស្ត្រតែមួយរបស់ព្រះជាម្ចាស់ និងជួបជុំគ្នាក្នុងព្រះកាយតែមួយរបស់ព្រះគ្រីស្ត ហើយកសាងឡើងជាព្រះវិហារតែមួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធទៀតផង។ គម្រោងការរបស់ព្រះជាម្ចាស់នោះ មានគោលដៅបង្រួបបង្រួមមនុស្សឲ្យរួបរួមគ្នា ក្នុងសេចក្តីសុខសាន្តទុកជាបងប្អូន ក៏ស្របតាមបំណងប្រាថ្នាកប់ជ្រៅក្នុងចិត្តរបស់មនុស្សទាំងអស់ដែរ។ មនុស្សទាំងអស់មានសភាពជាមនុស្សតែមួយដូចគ្នា ពេលណាគេទទួលជីវិតថ្មី ក្នុងអង្គព្រះគ្រីស្តដោយសារព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់គ្នា និងរួមគ្នាបញ្ចាំងសិរីរុងរឿងរបស់ព្រះជាម្ចាស់ (២ករ ៣, ១៨) ដោយរួមគ្នាប្រកាសថា «ឱ! ព្រះបិតាយើងខ្ញុំ» នៅពេលនោះ ព្រះអាទិករនឹងសម្រេចគម្រោងការរបស់ព្រះអង្គយ៉ាងពេញលេញជាស្ថាពរ គឺព្រះអង្គដែលបានប្រតិស្ឋានមនុស្ស ឲ្យជារូបតំណាងរបស់ព្រះអង្គ និងឲ្យមានលក្ខណៈដូចព្រះអង្គ។

## ៨-សកម្មភាពជាសាសនទូត ក្នុងប្រវត្តិសាស្ត្រមនុស្សលោក

សកម្មភាពជាសាសនទូត ភ្ជាប់យ៉ាងជិតស្និទ្ធជាមួយសភាពនឹងសេចក្តីប៉ងប្រាថ្នារបស់មនុស្សជាតិ។ ពេលព្រះសហគមន៍សម្តែងព្រះគ្រីស្តឲ្យមនុស្សលោកស្គាល់ ព្រះសហគមន៍ក៏សម្តែងសេចក្តីពិតប្រាកដ អំពីតម្លៃនៃជីវិតមនុស្ស និងអំពីឧបនិស្ស័យទាំងមូលរបស់គេ តាមព្រះជាម្ចាស់ត្រាស់ហៅគេ ព្រោះព្រះគ្រីស្តជាប្រភព និងជាគំរូរបស់មនុស្សលោកដែលកើតជាថ្មី ពោរពេញដោយសេចក្តីស្រឡាញ់ទុកជាបងប្អូន ពោរពេញដោយសេចក្តីស្មោះត្រង់ និងពោរពេញដោយចិត្តគំនិតចង់បានសន្តិភាព សមស្របតាមបំណងប្រាថ្នាមនុស្សលោកចង់បាននោះ។ ព្រះសហគមន៍ផ្តល់សក្ខីភាពថ្វាយព្រះគ្រីស្តដោយប្រកាសដំណឹងល្អ។ ព្រះគ្រីស្តនិងព្រះសហគមន៍មិនភ្ជាប់នឹងគំនិតជាតិនិយមទេ ហើយក៏មិនប្រកាន់ពណ៌សម្បុរដែរ។ ហេតុនេះ នៅកន្លែងណាក៏ដោយ ហើយនរណាក៏ដោយ ក៏មនុស្សមិនអាចចាត់ព្រះគ្រីស្ត និងព្រះសហគមន៍ទុកជាជនបរទេស គ្មានទំនាក់ទំនងជាមួយខ្លួនបានឡើយ។ ព្រះគ្រីស្តផ្ទាល់ជាសេចក្តីពិត និងជាមាគ៌ាដែលព្រះសហគមន៍សម្តែងឲ្យមនុស្សទាំងអស់ស្គាល់ ដោយប្រកាសដំណឹងល្អ គឺនាំព្រះបន្ទូលរបស់ព្រះគ្រីស្តនោះថា *"ចូរប្រែចិត្តគំនិត និងជឿដំណឹងល្អចុះ"* (មក ១, ១៥)។ អ្នកមិនព្រមផ្ញើជីវិតលើព្រះអង្គ ក៏ទទួលទោសរួចហើយ (យហ ៣, ១៨)។ ហេតុនេះហើយ បានជាព្រះបន្ទូលរបស់ព្រះគ្រីស្តសម្តែងព្រះហឫទ័យប្រណីសន្តោសផង ហើយក៏សម្តែងការវិនិច្ឆ័យដាក់ទោសផង ជាព្រះបន្ទូលដែលផ្តល់ជីវិតផង ហើយក៏នាំសេចក្តីស្លាប់ផងដែរ។ យើងត្រូវតែសម្លាប់អ្វីៗក្នុងខ្លួនដែលចាស់ទៅហើយនោះ ទើបយើងអាចទៅដល់ជីវិតថ្មីបាន។ សេចក្តីនេះ មានអត្ថន័យមុនដំបូងសម្រាប់មនុស្ស តែសេចក្តីនេះ ក៏មានអត្ថន័យសម្រាប់សម្បត្តិផ្សេងៗនៅក្នុងលោកនេះដែរ គឺអ្វីៗទាំងអស់ភ្ជាប់នឹងបាបរបស់មនុស្សផង

ហើយក៏ភ្ជាប់នឹងព្រះពររបស់ព្រះជាម្ចាស់ផងដែរ ដ្បិតមនុស្ស *"គ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយបាត់បង់សិរីរុងរឿងរបស់ព្រះជាម្ចាស់"* (រម ៣, ២៣)។ គ្មាននរណារួចពីបាប ដោយខ្លួនឯងបានទេ ឬដោយការខិតខំរបស់ខ្លួនឡើយ គ្មាននរណាម្នាក់រួចផុតទាំងស្រុងពីភាពទន់ខ្សោយរបស់ខ្លួន និងពីភាពឯកោរបស់ខ្លួន ហើយពីឋានៈជាទាសករបានទេ គឺមនុស្សគ្រប់ៗគ្នាត្រូវការព្រះគ្រីស្តជាគំរូ ជាព្រះបរមគ្រូ ជាអ្នករំដោះ ជាព្រះសង្គ្រោះ និងជាអ្នកផ្តល់ជីវិត។ ពិតមែនហើយ តាមប្រវត្តិសាស្ត្ររបស់មនុស្សលោក សូម្បីតែតាមផ្លូវលោកីយ៍ក៏ដោយ ក៏ដំណឹងល្អរបស់ព្រះគ្រីស្តបាននាំសេរីភាព និងនាំឲ្យសង្គមជឿនលឿន ដូចជាមេដែលធ្វើឲ្យម្សៅដោរឡើងដូច្នោះដែរ។ សព្វថ្ងៃក៏ដូចពីមុនដែរ ដំណឹងល្អក៏បង្ហាញខ្លួនជានិច្ចទុកជាមេក្នុងម្សៅ គឺនាំឲ្យមនុស្សស្រឡាញ់គ្នាទៅវិញទៅមកទុកជាបងប្អូន និងនាំឲ្យមនុស្សរួបរួមគ្នាជាធ្លុងតែមួយ ហើយក៏នាំសន្តិភាពថែមទៀតដែរ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទនាំគ្នាគោរពព្រះ គ្រីស្តយ៉ាងត្រឹមត្រូវទុកជា *"ព្រះដែលប្រជាជាតិនានារង់ចាំ និងជាព្រះសង្គ្រោះរបស់គេផង"* (សន្តះអ៊ីរេណេ)។

## ៩-សកម្មភាពជាសាសនទូត បង្ហាញអំពីគ្រាចុងក្រោយបំផុត

ព្រះសហគមន៍បំពេញសកម្មភាពជាសាសនទូត នៅក្នុងចន្លោះពេលព្រះអម្ចាស់យាងមកលើកដំបូង និងពេលព្រះអង្គនឹងយាងមកលើកទីពីរ។ នៅពេលចុងក្រោយនោះ ព្រះអង្គនឹងប្រមែប្រមូលព្រះសហគមន៍ពីគ្រប់ទិសទី ដូចអ្នកស្រែប្រមូលស្រូវដែលគេច្រូត ឲ្យចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ (មថ ២៤, ៣១)។ ប៉ុន្តែ មុនព្រះអម្ចាស់យាងមកនោះ *"ត្រូវប្រកាសដំណឹងល្អឲ្យមនុស្សគ្រប់ជាតិសាសន៍"* (មក ១៣, ១០)។

សកម្មភាពជាសាសនទូត ពិតជាសម្តែងអំពីគម្រោងការរបស់ព្រះជាម្ចាស់ដែលកើតជារូបរាង គឺសកម្មភាពជាសាសនទូតនេះពិតជាគ្មានអត្ថន័យប្លែកពីការសម្តែងគម្រោងការនេះទេ។ ព្រះជាម្ចាស់សម្តែង និងបំពេញគម្រោងការនោះក្នុងពិភពលោក និងតាមប្រវត្តិសាស្ត្ររបស់មនុស្សលោក គឺព្រះអង្គច្បាស់ជាណែនាំប្រវត្តិសាស្ត្រនៃការសង្គ្រោះទៅកាន់ទិសដៅរបស់ខ្លួន។ ដោយព្រះសហគមន៍ប្រកាសព្រះបន្ទូល និងធ្វើអគ្គសញ្ញានានា ដែលមានអគ្គសញ្ញាអរព្រះគុណជាស្នូលនិងជាកំពូល ព្រះសហគមន៍ធ្វើឲ្យព្រះគ្រីស្តមានវត្តមានក្នុងពិភពលោកនេះហើយ គឺព្រះគ្រីស្តដែលសម្រេចការសង្គ្រោះ។ ព្រះជាម្ចាស់បានសាបព្រោះអ្វីៗដ៏ពិតប្រាកដ និងអ្វីៗដែលសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ កប់ទុកក្នុងចំណោមសាសន៍ដទៃ ហាក់ដូចជាវត្តមានម៉្យាងដ៏ស្ងាត់កំបាំងរបស់ព្រះអង្គក្នុងសាសន៍ទាំងនោះ។ បើព្រះសហគមន៍រកឃើញ ព្រះសហគមន៍រំដោះអ្វីទាំងនោះឲ្យរួចពីចំណងអាក្រក់ និងលើកទៅថ្វាយសងព្រះគ្រីស្ត ដែលបានបង្កើតអ្វីៗទាំងនោះវិញ។ ព្រះគ្រីស្តបំផ្លាញអំណាចរបស់មារ និងកម្ទេចសេចក្តីអាក្រក់ដ៏មានមុខជាច្រើនអនេកនៃអំពើបាបផង។ *"ប្រសិនបើព្រះសហគមន៍រកឃើញពូជដ៏ល្អសាបព្រោះក្នុងចិត្តគំនិតរបស់មនុស្សលោក ឬក្នុងពិធីបុណ្យរបស់គេ និងក្នុងអរិយធម៌ប្រជាជាតិនានា ព្រះសហគមន៍មិនគ្រាន់តែរក្សាទុកឲ្យនៅគង់វង្ស មិនឲ្យវិនាសបាត់បង់ប៉ុណ្ណោះទេ តែព្រះសហគមន៍ព្យាបាលពូជទាំងនោះឲ្យបានជា និងនាំឲ្យបានពេញលក្ខណៈ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ កិច្ចការនោះបណ្តាលឲ្យមារត្រូវអាម៉ាស់ ហើយក៏នាំឲ្យមនុស្សលោកបានសុភមង្គលទៀតផង"* (ពន្លឺ ១៧)។ ដូច្នេះហើយ សកម្មភាពជាសាសនទូត តម្រង់ឲ្យមនុស្សលោកបានពេញលក្ខណៈនៅពេលចុងក្រោយបំផុត។ ដោយសកម្មភាពជាសាសនទូតនេះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់រីកចម្រើនឡើងរហូតដល់បានពេញកម្រិត និងរហូតដល់ពេលវេលាដែលព្រះបិតាបានកំណត់ទុក ដោយអំណាចរបស់ព្រះអង្គ (កក ១, ៧)។ ព្យាការីអេសាយបានថ្លែងអំពីព្រឹត្តការណ៍នេះទុកជាមុនថា *"ចូរពង្រីកជំរំរបស់អ្នកឲ្យបានទូលាយឡើង ចូរលាតដំបូលក្រណាត់នៃលំនៅរបស់អ្នកឲ្យវែងកុំសំចៃឡើយ"* (អស ៥៤, ២)។ សកម្មភាពជាសាសនទូត ធ្វើឲ្យព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តរីកចម្រើនឡើង

រហូតដល់ *"ទៅជាមនុស្សពេញវ័យ ឡើងដល់កំពូលរបស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់"* (អភ ៤, ១៣) គឺរហូតដល់ព្រះវិហារខាងព្រះវិញ្ញាណ ជាកន្លែងថ្វាយបង្គំព្រះជាម្ចាស់តាមព្រះវិញ្ញាណ និងតាមសេចក្តីពិត (យហ ៤, ២៣) ចម្រើនហើយសាងសង់ឡើងលើក្រុមគ្រីស្តទូតនិងព្យាការីនានាជាគ្រឹះ ដោយមានព្រះគ្រីស្តផ្ទាល់ជាសរសរទ្រូងដ៏សំខាន់ (អភ ២, ២០)។

# ជំពូក ២

## សកម្មភាពជាសាសនទូត

### ១០-សេចក្ដីផ្ដើម

ព្រះគ្រីស្តចាត់ព្រះសហគមន៍ដើម្បីសម្ដែង និងចែករំលែកព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ឲ្យមនុស្ស ទាំងអស់ និងឲ្យគ្រប់ជាតិសាសន៍បានស្គាល់។ ព្រះសហគមន៍យល់ឃើញថា បេសកកម្មជាសាសនទូតដែលខ្លួនត្រូវបំពេញនោះ នៅតែធំសម្បើមណាស់នៅឡើយ។ មានមនុស្សចំនួនរាប់កោដិនាក់មិនទាន់បានឮដំណឹងល្អ ឬបានឮមិនច្បាស់។ ចំនួននេះនៅតែកើនឡើងជាលំដាប់។ មនុស្សទាំងនោះជួបជុំគ្នាជាក្រុមធំៗ កំណត់ដោយទំនាក់ទំនងជាមួយគ្នាយ៉ាងស្អិតស្អែរតាមវប្បធម៌ ឬដោយប្រពៃណីសាសនាពីបុរាណ ឬដោយចំណងដ៏មាំមួននានាក្នុងសង្គម។ មនុស្សខ្លះកាន់សាសនាមួយដ៏សំខាន់ មនុស្សខ្លះមិនស្គាល់ព្រះជាម្ចាស់ទាល់តែសោះ មនុស្សខ្លះទៀតបដិសេធថា គ្មានព្រះជាម្ចាស់ទេ ឬជួនកាលជំទាស់ប្រឆាំងនឹងព្រះអង្គក៏មានដែរ។ ព្រះសហគមន៍ត្រូវចូលរួមក្នុងគ្រប់ក្រុមមនុស្ស ទាំងនោះ ដូចព្រះគ្រីស្តផ្ទាល់ដែលកើតជាមនុស្ស យាងចូលរួមក្នុងសភាពការណ៍សង្គមមួយ ក្នុងសភាពការណ៍វប្បធម៌ប្រជាជនមួយ។ នៅសម័យព្រះអង្គរស់នៅក្នុងលោកនេះ ព្រះអង្គរស់នៅក្នុងក្រុមមនុស្សដែលមានអរិយធម៌ផ្ទាល់ខ្លួន។ បើធ្វើដូច្នេះ ទើបព្រះសហគមន៍អាចបង្ហាញគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះឲ្យមនុស្សទាំងអស់បានស្គាល់ និងអាចជូនជីវិត ដែលព្រះជាម្ចាស់ប្រទានឲ្យទៀតផង។

### ១-សក្ខីភាពរបស់គ្រីស្តបរិស័ទ

### ១១-គ្រីស្តបរិស័ទផ្ដល់សក្ខីភាពតាមការរស់នៅរបស់ខ្លួន និងសន្ទនាជាមួយអ្នកដទៃ

ព្រះសហគមន៍ត្រូវមានវត្តមាននៅក្នុងគ្រប់ក្រុមមនុស្ស ដោយមានគ្រីស្តបរិស័ទរស់នៅក្នុងក្រុមទាំងនោះស្រាប់ ឬដោយព្រះសហគមន៍ចាត់គ្រីស្តបរិស័ទខ្លះឲ្យទៅរស់នៅក្នុងក្រុមទាំងនោះដែរ។ កន្លែងណាគ្រីស្តបរិស័ទរស់នៅ គេមានភារកិច្ចបង្ហាញបញ្ជាក់ថា គេបានកើតជាថ្មីដោយរួបរួមជាមួយព្រះគ្រីស្ត នៅពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក។ គេក៏បានទទួលកម្លាំងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលគេបានទទួលអគ្គសញ្ញាលាបថ្ងាសដែរ។ គេផ្ដល់សក្ខីភាពនេះ ដោយរស់នៅតាមរបៀបល្អធ្វើជាគំរូឲ្យអ្នកដទៃ និងដោយនិយាយជាមួយដែរ។ ដូច្នេះ អ្នកដទៃមុខជានឹងឃើញអំពើ ល្អដែលគ្រីស្តបរិស័ទប្រព្រឹត្ត ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងព្រះបិតា (មថ ៥, ១៦) ព្រមទាំងយល់អត្ថន័យជីវិតមនុស្សឲ្យកាន់តែច្បាស់ និងកាន់តែពិតប្រាកដឡើង ព្រមទាំងយល់ឃើញកាន់តែច្បាស់ថា មនុស្សទូទាំងសកលលោករួបរួមគ្នាជាធ្លុងតែមួយផងដែរ។

គ្រីស្តបរិស័ទអាចធ្វើជាសាក្សីអំពីព្រះគ្រីស្តបែបនេះនិងបានផល លុះត្រាតែគេរួមរស់ជាមួយអ្នកដទៃ ហើយរាប់អានគេ និងស្រឡាញ់គេដោយចិត្តស្មោះ។ គ្រីស្តបរិស័ទត្រូវចាត់ខ្លួនទុកជាសមាជិកនៃក្រុមដែលខ្លួនរស់នៅ គឺត្រូវរួម

ចំណែកក្នុងសកម្មភាពនានាខាងវប្បធម៌ និងក្នុងសង្គម ដោយចែកចាយអ្វីៗក្នុងកិច្ចការផ្សេងៗប្រចាំជីវិតមនុស្សថែមទៀតផង។ គ្រីស្តបរិស័ទក៏ត្រូវស្គាល់ប្រពៃណីជាតិ និងប្រពៃណីសាសនារបស់គេ ទាំងទទួលស្គាល់ និងគោរពដោយរីករាយនូវ *"ពូជនៃព្រះបន្ទូល"* កប់ទុកក្នុងប្រពៃណី និងក្នុងសាសនាទាំងនោះស្រាប់។ នៅពេលជាមួយគ្នានោះ គ្រីស្តបរិស័ទត្រូវយកចិត្តទុកដាក់ នឹងការផ្លាស់ប្រែយ៉ាងជ្រៅដែលកើតឡើងក្នុងប្រជាជាតិទាំងនោះ។ មនុស្សសម័យទំនើបតែងតែចាប់អារម្មណ៍យ៉ាងហួសទៅលើវិទ្យាសាស្ត្រ និងទៅលើបច្ចេកទេស។ គ្រីស្តបរិស័ទត្រូវតែខិតខំណែនាំគេ កុំឲ្យងាកបែរចេញពីអ្វីៗ ដែលពាក់ព័ន្ធនឹងព្រះជាម្ចាស់ឡើយ ត្រូវដាស់តឿនពួកគេ ឲ្យមានបំណងប្រាថ្នាចង់រកសេចក្តីពិតឲ្យកាន់តែខ្លាំងឡើងៗ និងចង់បានសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ កាលពីដើមព្រះគ្រីស្តផ្ទាល់បានស្ទង់ចិត្តមនុស្សលោក ហើយបានណែនាំគេទៅកាន់ពន្លឺរបស់ព្រះជាម្ចាស់ ដោយនិយាយសន្ទនាជាមួយគេតាមរបៀបមនុស្សធម្មតា។ ក្រុមសាវ័ករបស់ព្រះអង្គ ដែលមានព្រះវិញ្ញាណរបស់ព្រះគ្រីស្តជ្រួតជ្រាបពេញខ្លួនក៏ត្រូវស្គាល់មនុស្សដែលរស់នៅជាមួយ ត្រូវអត់ធ្មត់ព្យាយាមនិយាយសន្ទនាជាមួយគេដោយចិត្តស្មោះ ដើម្បីឲ្យខ្លួនស្គាល់អ្វីៗដ៏ថ្លៃថ្នូរបំផុត ដែលជាព្រះអំណោយទានដែលព្រះជាម្ចាស់បានប្រោសប្រទានឲ្យជនជាតិទាំងឡាយ តាមព្រះហឫទ័យទូលាយដ៏អស្ចារ្យរបស់ព្រះអង្គ។ នៅពេលជាមួយគ្នានោះ គ្រីស្តបរិស័ទក៏ត្រូវយកចិត្តទុកដាក់នាំពន្លឺនៃដំណឹងល្អមកបំភ្លឺអ្វីៗដ៏ថ្លៃថ្នូរបំផុតទាំងនោះ និងរំដោះអ្វីទាំងនោះ ហើយណែនាំឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់ជាព្រះសង្គ្រោះទៀតផង។

## ១២-អំពីមេត្តាករុណារបស់គ្រីស្តបរិស័ទ

គ្រីស្តបរិស័ទដែលរស់នៅក្នុងក្រុមនានារបស់មនុស្ស ត្រូវមានចិត្តស្រឡាញ់ក្នុងខ្លួន ដូចព្រះជាម្ចាស់បានស្រឡាញ់យើងដូច្នោះដែរ គឺព្រះអង្គសព្វព្រះហឫទ័យឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ដោយព្រះហឫទ័យ ស្រឡាញ់នោះឯង (១យហ ៤, ១១)។ គ្រីស្តបរិស័ទស្រឡាញ់មនុស្សគ្រប់ប្រភេទយ៉ាងពិតប្រាកដ ដោយមិនប្រកាន់ឋានៈ វណ្ណៈ ជាតិ ឬសាសនាណាឡើយ។ គ្រីស្តបរិស័ទស្រឡាញ់អ្នកដទៃ ដោយមិនចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន ឬឲ្យគេតបស្នងសងគុណនោះទេ។ ព្រះជាម្ចាស់ស្រឡាញ់យើងដោយមិនចង់បានប្រយោជន៍ពីយើងទេ។ យ៉ាងណាមិញ គ្រីស្តបរិស័ទដែលស្រឡាញ់គេ ត្រូវយកចិត្តទុកដាក់នឹងបុគ្គលម្នាក់ៗក្នុងឋានៈគេជាមនុស្ស គឺត្រូវស្រឡាញ់គេតាមរបៀបដែលព្រះជាម្ចាស់យាងមករកយើងដូច្នេះដែរ។ កាលពីដើម ព្រះគ្រីស្តយាងចុះយាងឡើងគ្រប់ក្រុងគ្រប់ភូមិ ទាំងព្យាបាលមនុស្ស ដែលមានជំងឺរោគាព្យាធិគ្រប់ប្រភេទ ទុកជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ (មថ ៩, ៣៥ត; កក ១០-៣៨)។ យ៉ាងណាមិញ ដោយសារគ្រីស្តបរិស័ទជាបុត្រធីតា ព្រះសហគមន៍ក៏មានទំនាក់ទំនងជាមួយមនុស្សទាំងអស់ ទោះជាមានឋានៈ វណ្ណៈយ៉ាងណាក៏ដោយ គឺព្រះសហគមន៍មានទំនាក់ទំនងយ៉ាងពិសេសជាមួយអ្នកក្រីក្រ និងអ្នកកើតទុក្ខលំបាក ហើយក៏ស្ម័គ្រចិត្ត «ចំណាយខ្លួន ដើម្បីជាប្រយោជន៍ដល់គេ» ថែមទៀត (២ករ ១២, ១៥)។ ព្រះសហគមន៍តែងរំលែកអំណរសប្បាយ និងទុកព្រួយរបស់គេ ស្គាល់បំណងប្រាថ្នានិងបញ្ហាជីវិតរបស់គេ ព្រមទាំងតែងរំលែកទុក្ខព្រួយ និងតប់ប្រមល់នៅពេលគេស្លាប់។ ចំពោះអស់អ្នកដែលស្វែងរកសន្តិភាព ព្រះសហគមន៍ប៉ងប្រាថ្នាចង់សន្ទនាជាមួយគេ ដូចសន្ទនាជាមួយបងប្អូនដែរ ទាំងនាំសន្តិភាព និងពន្លឺដែលហូរមកពីដំណឹងល្អជូនគេផង។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទត្រូវរួមសហការជាមួយមនុស្សឯទៀតៗទាំងអស់ ដើម្បីចាត់ចែងសេដ្ឋកិច្ចនិងសង្គមឲ្យបានទៀងត្រង់ល្អត្រឹមត្រូវ។ គ្រីស្តបរិស័ទត្រូវយកចិត្តទុកដាក់ ប្រើកម្លាំងកាយកម្លាំងចិត្តយ៉ាងពិសេស ក្នុងការអប់រំក្មេងៗ និងកូនជំទង់ ដោយចាត់ចែងឲ្យមានសាលារៀនគ្រប់មុខ។ ត្រូវចាត់សាលារៀនទាំងនោះទុកជា

មធ្យោបាយពិសេស មិនគ្រាន់តែសម្រាប់អប់រំ និងលើកស្ទួយយុវជនគ្រីស្តបរិស័ទប៉ុណ្ណោះទេ តែនៅពេលជាមួយគ្នានោះសម្រាប់បម្រើមនុស្សទាំងអស់តាមរបៀបដ៏មានតម្លៃថ្លៃថ្នូរបំផុត។ ជាពិសេសនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍ឡើង សាលារៀនទាំងនោះក៏លើកស្ទួយតម្លៃដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ និងរៀបចំឲ្យមនុស្សអាចរស់នៅស្របតាមលក្ខណៈជាមនុស្សកាន់តែប្រសើរឡើងៗ។ ម្យ៉ាងទៀត គ្រីស្តបរិស័ទក៏ត្រូវរួមជាមួយជនរួមជាតិទាំងអស់ ដែលខិតខំខ្នះខ្នែងបំបាត់ការអត់ឃ្លាន បំបាត់ភាពល្ងង់ខ្លៅ និងបំបាត់ជំងឺ។ ធ្វើដូច្នេះ ទើបគេយកចិត្តទុកដាក់ឲ្យជីវភាពប្រជាជនចម្រើនឡើង ព្រមទាំងពង្រឹងសន្តិភាពក្នុងពិភពលោកទាំងមូល។ ក្នុងសកម្មភាពនេះ គ្រីស្តបរិស័ទក៏ត្រូវមានបំណងប្រាថ្នាយ៉ាងខ្លាំងទាំងប្រុងប្រយ័ត្ន ចង់រួមសហការជាមួយអង្គការនានា ជាអង្គការឯកជនក្តី សាធារណៈក្តី ជាមួយរដ្ឋាភិបាលនានា ជាមួយអង្គការអន្តរជាតិ ជាមួយក្រុមគ្រីស្តបរិស័ទផ្សេងៗ និងជាមួយក្រុមបរិស័ទសាសនាឯទៀតៗដែរ។

ប៉ុន្តែ ព្រះសហគមន៍គ្មានបំណងចង់ចូលឈ្លានពាន ក្នុងការដឹកនាំប្រទេសក្នុងលោកនេះជាដាច់ខាត។ ព្រះសហគមន៍ទាមទារសេចក្តីតែមួយ គឺបម្រើមនុស្សលោកយ៉ាងស្មោះ ទាំងបង្ហាញសេចក្តីស្រឡាញ់ដល់គេ ដោយព្រះជាម្ចាស់ជួយឧបត្ថម្ភផង (មថ ២០, ២៦; ២៣, ១១)។

សាវ័ករបស់ព្រះគ្រីស្តរួមយ៉ាងជិតស្និទ្ធជាមួយមនុស្សឯទៀតៗ ដោយរស់នៅ និងប្រព្រឹត្តកិច្ចការនានា។ ទោះបីនៅកន្លែងណាដែលគេគ្មានលទ្ធភាព ប្រកាសអំពីព្រះគ្រីស្តយ៉ាងច្បាស់ក្តី ក៏គេសង្ឃឹមថានឹងបង្ហាញសក្ខីភាពដ៏ពិតប្រាកដអំពីព្រះគ្រីស្តឲ្យមនុស្សលោកឃើញ និងខិតខំជួយមនុស្សលោកឲ្យទទួលការសង្គ្រោះថែមទៀត។ គ្រីស្តបរិស័ទមិនស្វែងរកឲ្យមនុស្សចម្រើនឡើង និងជឿនលឿនតែផ្នែកខាងសម្ភារៈប៉ុណ្ណោះទេ តែមានបំណងចង់ពង្រីកកិត្តិយសដ៏ថ្លៃថ្នូររបស់គេ ព្រមទាំងចង់ឲ្យមនុស្សប្រួបរួមគ្នាជាធ្លុងតែមួយក្នុងឋានៈជាបងប្អូន ដោយបង្រៀនសេចក្តីពិតខាងសាសនា និងខាងសីលធម៌ តាមព្រះគ្រីស្តបំភ្លឺឲ្យយល់នោះ។ ធ្វើដូច្នេះ គ្រីស្តបរិស័ទត្រួសត្រាយផ្លូវកាន់តែប្រសើរឡើងៗនាំមនុស្សឆ្ពោះទៅកាន់ព្រះជាម្ចាស់បន្តិចម្តងៗ។ គ្រីស្តបរិស័ទជួយមនុស្សឲ្យទទួលការសង្គ្រោះ ដោយស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់អ្នកដទៃ។ ធ្វើដូច្នេះ *"គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត"* ចាប់ផ្តើមលេចធ្លោឡើង គឺមនុស្សថ្មីកើតមក ស្របតាមព្រះហឫទ័យព្រះជាម្ចាស់ លេចមកក្នុងអង្គព្រះគ្រីស្ត (អភ ៤, ២៤) ហើយព្រះជាម្ចាស់ក៏សម្តែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ក្នុងអង្គព្រះគ្រីស្តនោះដែរ។

## ២-ការប្រកាសដំណឹងល្អនិងការប្រមូលប្រជារាស្ត្ររបស់ព្រះជាម្ចាស់

### ១៣-ការប្រកាសដំណឹងល្អ និងការប្រែចិត្តគំនិត

ត្រូវប្រកាសគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត (១ករ ៩, ១៦; រម ១០, ១៤) ឲ្យមនុស្សទាំងអស់ (មក ១៦, ១៥) ដោយចិត្តអង់អាច និងដោយចិត្តព្យាយាមខន្តី (កក ៤, ១៣.២៩.៣១; ៩, ២៧- ២៨; ១៣, ៤៦; ១៤, ៣; ១៩, ៨; ២៦, ២៦; ២៨, ៣១; ១ថស ២, ២; ២ករ ៣, ១២ ; ៧, ៤ ; ភល ១, ២០; អភ ៣, ១២; ៦, ១៩-២០) នៅគ្រប់ទីកន្លែងដែលព្រះជាម្ចាស់ *"បើកទ្វារចំហ"* (កូឡ ៤, ៣) គឺត្រូវប្រកាសអំពីព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ និងអំពីព្រះយេស៊ូគ្រីស្ត ដែលព្រះជាម្ចាស់ចាត់ឲ្យយាងមកសង្គ្រោះមនុស្សលោកទាំងអស់ (១ថស ១, ៩-១០; ១ករ ១, ១៨-២១; កាឡ ១, ៣១; កក ១៤, ១៥-១៧; ១៧, ២២-៣១) ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបើកចិត្តគំនិតអ្នក ដែលមិនកាន់គ្រីស្តសាសនា (កក ១៦-១៤) ឲ្យគេប្រែចិត្តគំនិតដោយសេរី ទៅរកព្រះអម្ចាស់ និងផ្ញើជីវិតលើព្រះអង្គផង។ គេក៏ផ្ចង់ចិត្តនឹងព្រះអង្គយ៉ាងស្មោះ គឺលើព្រះអង្គដែល «ជាមាគ៌ា ជាសេចក្តីពិត និងជាជីវិត» (យហ ១៤, ៦)។ព្រះអង្គបំពេញ

សេចក្តី ដែលមនុស្សលោកទន្ទឹងរង់ចាំប៉ងប្រាថ្នាចង់បានខាងផ្លូវវិញ្ញាណ។ ព្រះអង្គក៏នឹងប្រទានហួសពីសេចក្តីប៉ងប្រាថ្នាទាំងនោះទៅទៀត។

តាមពិត ត្រូវយល់ឃើញថា មនុស្សប្រែចិត្តគំនិតដូច្នេះ គឺគ្រាន់តែប្រែចិត្តគំនិតខាងដើមដំបូងប៉ុណ្ណោះ។ ដោយគេប្រែចិត្តគំនិតដើមដំបូងដូច្នេះ ទើបធ្វើឲ្យគេដឹងខ្លួនថា គេងាកចេញពីអំពើបាប ហើយចូលក្នុងគម្រោងការដ៏អស្ចារ្យនៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ គឺព្រះអង្គសព្វព្រះហឫទ័យត្រាស់ហៅគេ ឲ្យប្រាស្រ័យទាក់ទងជាមួយព្រះអង្គ ក្នុងអង្គព្រះគ្រីស្ត។ អ្នកប្រែចិត្តគំនិតថ្មីនោះ ចាប់ផ្តើមធ្វើដំណើរតាមព្រះវិញ្ញាណ ដោយព្រះជាម្ចាស់ប្រោសប្រណីជួយគេផង។ ពេលធ្វើដំណើរនេះដោយសារជំនឿ គេរួបរួមក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែលសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង។ គេលះបង់របៀបរស់នៅបែបចាស់ចោល ឆ្លងទៅរស់នៅតាមរបៀបថ្មី គឺទៅជាមនុស្សថ្មីដ៏ពេញលក្ខណៈក្នុងអង្គព្រះគ្រីស្ត (កូឡ ៣, ៥-១០; អភ ៤, ២០-២៤)។ ដំណើរឆ្លងដូច្នេះ នាំឲ្យគេប្រែចិត្តគំនិត និងប្រែរបៀបរស់នៅបន្តិចម្តងៗតាមលំដាប់លំដោយ។ ការប្រែចិត្តគំនិតនេះ ក៏ត្រូវលេចធ្លោឡើងតាមរបៀបរស់នៅក្នុងសង្គមមនុស្ស បន្តិចម្តងៗកាន់តែជ្រៅទៅៗ អស់រយៈពេលដែលគេទទួលការអប់រំជំនឿ។ គេផ្ញើជីវិតលើព្រះអម្ចាស់ គឺលើព្រះអង្គដែលជាសញ្ញាសម្គាល់នាំឲ្យមនុស្សខ្វែងគំនិត និងញែកចេញពីគ្នាយ៉ាងណា (លក ២, ៣៤; មថ ១០, ៣៤-៣៩) អ្នកប្រែចិត្តគំនិតថ្មី ក៏ធ្លាប់មានបទពិសោធន៍ថា ខ្លួនត្រូវញែកចេញពីក្រុមគ្រួសារ បាក់បែកពីគេយ៉ាងនោះដែរ។ ប៉ុន្តែ គេក៏បានអំណរសប្បាយដោយព្រះជាម្ចាស់ ប្រោសប្រទានព្រះអំណោយទានដល់គេហួសកម្រិតដែរ (១ថស ១, ៦)។

ព្រះសហគមន៍ហាមផ្តាច់មិនឲ្យបង្ខំនរណាម្នាក់ចូលគ្រីស្តសាសនាជាដាច់ខាត និងមិនឲ្យណែនាំគេ ឬទាក់ទាញចិត្តគេ ដោយប្រើឧបាយកលមិនគួរគប្បីឡើយ ក៏ដូចព្រះសហគមន៍ទាមទារដាច់អហង្ការនូវសិទ្ធិសេរីភាពរបស់ខ្លួន កុំឲ្យគេបង្ខំនរណាម្នាក់ឲ្យលះបង់ជំនឿរបស់ខ្លួន ដោយធ្វើទុក្ខបុកម្នេញដល់គេយ៉ាងថោកទាបដូច្នោះដែរ (សេរីភាព ២.៤. ១០; អំណរ ២១)។ តាមប្រពៃណីពីបុរាណដ៏យូរអង្វែងរបស់ព្រះសហគមន៍មក ត្រូវពិនិត្យពិច័យយ៉ាងម៉ត់ចត់នូវមូលហេតុ ដែលនាំឲ្យមនុស្សម្នាក់ប្រែចិត្តគំនិត។ ប្រសិនបើជាត្រូវការ ត្រូវជម្រះមូលហេតុទាំងនោះឲ្យបានទៀងត្រង់ផង។

## ១៤-ក្រុមអ្នកស្តាប់ព្រះសូរសៀងព្រះជាម្ចាស់លាន់ឮឡើង

អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ទុកជាអំណោយទានរបស់ព្រះជាម្ចាស់តាមរយៈព្រះសហគមន៍ (ពន្លឺ ១៧) ត្រូវចូលក្នុងក្រុមអ្នកទទួលការអប់រំជំនឿដោយសារពិធីផ្សេងៗ។ ការអប់រំជំនឿនោះ មិនគ្រាន់តែអាស្រ័យទៅលើការរៀបរាប់អំពីគោលលទ្ធិដ៏សំខាន់ៗនៃជំនឿ និងនៃធម៌វិន័យប៉ុណ្ណោះទេ តែជាការហ្វឹកហ្វឺនឲ្យគេរស់នៅបែបជាគ្រីស្តបរិស័ទក្នុងគ្រប់វិស័យប្រចាំជីវិត ព្រមទាំងបង្ហាត់គេយ៉ាងសមរម្យ។ សាវ័ករបស់ព្រះគ្រីស្តរួបរួមជាមួយព្រះបរមគ្រូរបស់គេ ដោយទទួលការអប់រំ និងហ្វឹកហ្វឺនផង។ ហេតុនេះហើយ បានជាត្រូវណែនាំអ្នកទទួលការអប់រំជំនឿទាំងនោះ ឲ្យចូលក្នុងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះយ៉ាងសមរម្យ និងត្រូវបង្ហាត់គេឲ្យរស់នៅស្របតាមបែបដំណឹងល្អទៀត។ ត្រូវណែនាំគេដោយពិធីផ្សេងៗ តាមពេលវេលាជាលំដាប់លំដោយ (ពិធី ៦៤-៦៥) ឲ្យចូលរួម ក្នុងរបៀបរស់នៅតាមជំនឿ ឲ្យចូលរួមក្នុងពិធីនានានៃព្រះសហគមន៍ ព្រមទាំងឲ្យគេមានចិត្តស្រឡាញ់ ស្របតាមប្រជារាស្ត្ររបស់ព្រះជាម្ចាស់។

បន្ទាប់មក អ្នកស្តាប់ព្រះសូរសៀងព្រះជាម្ចាស់លាន់ឮឡើង បាន *"រួចផុតពីអំណាចនៃភាពងងឹត"* (កូឡ ១, ១៣) រួចហើយ ដោយអគ្គសញ្ញាទាំងបីដែលបញ្ចូលគេក្នុងព្រះសហគមន៍ គេរួមស្លាប់ជាមួយព្រះគ្រីស្ត បានចុះក្នុងផ្នូររួមជាមួយព្រះអង្គ ហើយក៏បានទទួលជីវិតថ្មីដ៏រុងរឿងរួមជាមួយព្រះអង្គដែរ (រម ៦, ៤-១១; កូឡ ២, ១២- ១៣; ១ សល ៣,

២១-២២; មក ១៦, ១៦)។ គេទទួលព្រះវិញ្ញាណ ដែលប្រោសឲ្យគេទៅជាបុត្រធីតារបស់ព្រះបិតា (១ថស ៣, ១៥-៧; កក ៨, ១៤-១៧) ហើយនាំគ្នាធ្វើពិធីនឹករឭកព្រះអម្ចាស់សោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង រួមជាមួយប្រជារាស្ត្រទាំងមូលរបស់ព្រះជាម្ចាស់។

មហាសន្និបាត ប្រាថ្នាចង់ប្រែសម្រួលពិធីបុណ្យនានាក្នុងរដូវអប់រំពិសេស និងក្នុងរដូវបុណ្យចម្លង ដើម្បីរៀបចំចិត្តគំនិតអ្នកស្ដាប់ព្រះសូរសៀងព្រះជាម្ចាស់លាន់ឮឡើង ឲ្យលើកតម្កើងព្រឹត្តិការណ៍ដ៏អស្ចារ្យនៃបុណ្យចម្លង ព្រោះក្នុងពិធីបុណ្យចម្លងដ៏ឱឡារិកនោះ គេកើតជាថ្មីក្នុងអង្គព្រះគ្រីស្ត ដោយទទួលអគ្គសញ្ញាជ្រមុជទឹក។

មិនគ្រាន់តែអស់អ្នកណែនាំ ឬអស់លោកបូជាចារ្យ (អាចារ្យ) ប៉ុណ្ណោះទេ មានភារកិច្ចហ្វឹកហ្វឺនអ្នកអប់រំជំនឿឲ្យទៅជាគ្រីស្តបរិស័ទ តែសហគមន៍គ្រីស្តបរិស័ទទាំងមូលឯណោះវិញ ទទួលភារកិច្ចហ្វឹកហ្វឺននោះ ជាពិសេសសហគមន៍ឪពុកម្ដាយធម៌ឬបងធម៌។ ធ្វើដូច្នោះ ទើបអ្នកទទួលការអប់រំជំនឿដឹងខ្លួនតាំងពីដើមដំបូងមកថា គេមានទំនាក់ទំនងជាមួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់ហើយ។ ដោយព្រះសហគមន៍មានលក្ខណៈជាគ្រីស្តទូត អ្នកកំពុងទទួលការអប់រំជំនឿ ក៏ត្រូវហាត់ខ្លួនឲ្យរួមយ៉ាងសកម្មក្នុងកិច្ចប្រកាសដំណឹងល្អ និងក្នុងកិច្ចសាងសង់ព្រះសហគមន៍ ដោយផ្ដល់សក្ខីភាពអំពីការរស់នៅតាមបែបថ្មី និងដោយប្រកាសជំនឿរបស់ខ្លួន។ ត្រូវបញ្ជាក់លក្ខន្តិកៈរបស់អ្នកទទួលការអប់រំជំនឿទាំងនេះឲ្យបានច្បាស់ ក្នុងក្បួនច្បាប់ថ្មីជាទូទៅរបស់ព្រះសហគមន៍ ព្រោះគេរួបរួមជាមួយព្រះសហគមន៍រួចហើយ (ពន្លឺ ១៤) គេក៏នៅក្នុងព្រះដំណាក់ព្រះគ្រីស្តរួចហើយដែរ។ តាមធម្មតា គេរស់នៅដោយមានជំនឿ មានចិត្តសង្ឃឹម និងមានចិត្តស្រឡាញ់ផង។

## ៣-ការអប់រំសហគមន៍គ្រីស្តបរិស័ទ

### ១៥-ការអប់រំសហគមន៍គ្រីស្តបរិស័ទ

ព្រះវិញ្ញាណត្រាស់ហៅមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ត ដោយព្រះអង្គសាបព្រោះពូជនៃព្រះបន្ទូលក្នុងចិត្តមនុស្សគ្រប់ៗរូប និងដោយព្រះអង្គចាត់ឲ្យគ្រីស្តបរិស័ទប្រកាសដំណឹងល្អផង។ ព្រះវិញ្ញាណនាំមនុស្សឲ្យសុខចិត្តគោរពតាមបង្គាប់នៃជំនឿ ហើយក៏ប្រោសឲ្យអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តមានជីវិតថ្មីដោយអគ្គសញ្ញាជ្រមុជទឹកដែរ។ ព្រះអង្គប្រមូលគេឲ្យចូលរួមក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់តែមួយ *"ជាពូជសាសន៍ដែលព្រះអង្គបានជ្រើសរើស ជាក្រុមបូជាចារ្យរបស់ព្រះមហាក្សត្រ ជាប្រជាជាតិដ៏វិសុទ្ធ ជាប្រជារាស្ត្រដែលព្រះជាម្ចាស់បានយកមកធ្វើជាកម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ"* (១សល ២, ៩; ពន្លឺ ៩)។

ហេតុនេះហើយ បានជាសាសនទូតទាំងអស់ដែលជាសហការីរបស់ព្រះជាម្ចាស់ (១ករ ៣, ៩) ត្រូវបង្កើតសហគមន៍របស់អ្នកជឿ។ សហគមន៍ទាំងនោះ ត្រូវរស់នៅយ៉ាងសមរម្យ ស្របតាមព្រះជាម្ចាស់ដែលត្រាស់ហៅគេ (អភ ៤, ១) ហើយត្រូវមានសមត្ថភាពអាចបំពេញបន្ទុកដែលព្រះអង្គបានផ្ញើទុកឲ្យគេ គឺបំពេញបន្ទុកជាបូជាចារ្យ ជាព្យាការី និងជាព្រះមហាក្សត្រ។ ដូច្នេះ សហគមន៍គ្រីស្តបរិស័ទក្លាយទៅជាសញ្ញាសម្គាល់ អំពីវត្តមានរបស់ព្រះជាម្ចាស់ក្នុងពិភពលោក លុះត្រាតែសហគមន៍បំពេញបន្ទុកទាំងបីនោះ។ ដោយថ្វាយអភិបូជា សហគមន៍នេះរួមជាមួយព្រះគ្រីស្តឆ្លងទៅកាន់ព្រះបិតាដោយឥតឈប់ឈរ (ពន្លឺ ១០.១១.៣៤)។ ដោយផ្ចិតផ្ចង់ទទួលព្រះបន្ទូលទុកជាអាហារ (បន្ទូល ២១) សហគមន៍នេះបង្ហាញសក្ខីភាពអំពីព្រះគ្រីស្ត (ពន្លឺ ១២.៣៥)។ សហគមន៍នេះក៏មានចិត្តមេត្តាករុណា ហើយមានចិត្តឧស្សាហ៍បំពេញកិច្ចការជាគ្រីស្តទូតថែមទៀត (ពន្លឺ ២៣.២៦)។

តាំងពីដើមដំបូងរៀងមក ត្រូវចាត់ចែងសហគមន៍គ្រីស្តបរិស័ទ ឲ្យមានសមត្ថភាពអាចផ្គត់ផ្គង់តម្រូវការរបស់ខ្លួន ដោយខ្លួនឯង ប្រសិនបើអាចធ្វើបាន។

ព្រះជាម្ចាស់បានប្រទានឲ្យគ្រីស្តបរិស័ទដែលប្រជុំគ្នានោះ មានអរិយធម៌ជាទ្រព្យដ៏ថ្លៃថ្នូរនៃជាតិរបស់ខ្លួន។ ហេតុនេះហើយ សហគមន៍នោះត្រូវចាក់ឫសយ៉ាងជ្រៅក្នុងប្រជាជនរបស់ខ្លួនដែរ។ ក្រុមគ្រួសារគ្រីស្តបរិស័ទត្រូវមានលទ្ធភាពនឹងចម្រើនឡើងបាន ដោយមានគោលគំនិតស្របតាមដំណឹងល្អ ជ្រួតជ្រាបចិត្តគំនិតគេ (ពន្លឺ ១១.៣៥.៤១)។ គេត្រូវមានសាលារៀនយ៉ាងសមរម្យ សម្រាប់ជួយអប់រំក្មេងៗ។ ត្រូវចាត់ចែងឲ្យមានសមាគម និងក្រុមផ្សេងៗក្នុងសហគមន៍ទាំងនោះ ដើម្បីឲ្យគ្រីស្តបរិស័ទអាចបំពេញកិច្ចការជាគ្រីស្តទូត គឺនាំគំនិតស្របតាមដំណឹងល្អឲ្យចូលជ្រួតជ្រាបក្នុងសង្គមទាំងមូល។ គ្រីស្តបរិស័ទកាតូលិកដែលតែងកាន់តាមរបៀបរបបពិធីប្លែកៗពីគ្នា ក៏ត្រូវសម្តែងចិត្តស្រឡាញ់គ្នា ឲ្យអ្នកដទៃឃើញយ៉ាងច្បាស់ដែរ (ប្ស៣ ៣០)។

ត្រូវអប់រំពន្លកថ្មីឲ្យមានចិត្តចង់បង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួមគ្នាជាធ្លុងតែមួយ គឺគេត្រូវយល់ឲ្យបានច្បាស់ថា បងប្អូនទាំងអស់ដែលផ្ញើជីវិតលើព្រះគ្រីស្ត ក៏ជាសាវ័ករបស់ព្រះគ្រីស្តដូចខ្លួនដែរ គេបានទទួលជីវិតថ្មីដោយអគ្គសញ្ញាជ្រមុជទឹក ហើយក៏ទទួលចំណែកនៃព្រះអំណោយទានជាច្រើនរបស់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដូចខ្លួនដែរ។ ប្រសិនបើអាចធ្វើបានស្របតាមសភាពការណ៍ខាងសាសនា គ្រីស្តបរិស័ទកាតូលិក ត្រូវរួមសហការជាមួយបងប្អូននិកាយឯទៀតៗ គឺរួមគ្នាប្រកាសជំនឿតែមួយទៅលើព្រះជាម្ចាស់ និងទៅលើព្រះយេស៊ូគ្រីស្តនៅចំពោះមុខប្រជាជាតិទាំងឡាយ ស្របតាមក្រឹត្យក្រមស្តីអំពីការបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួមគ្នាជាធ្លុងតែមួយ។ ក៏ប៉ុន្តែ ត្រូវប្រយ័ត្នកុំនឹកស្មានថា គ្រប់និកាយដូចគ្នាទាំងអស់ ឬនិកាយណាក៏ដូចនិកាយណាដែរនោះ។ ទោះបីត្រូវប្រយ័ត្នមិនឲ្យលាយឡំជំនឿក្តី ប៉ុន្តែ មិនត្រូវប្រកួតប្រជែងគ្នាជាដាច់ខាត។ ប្រសិនបើអាចធ្វើបាន សូមឲ្យគ្រីស្តបរិស័ទកាតូលិករួមសហការជាមួយគ្រីស្តបរិស័ទនិកាយផ្សេងៗ ដោះស្រាយបញ្ហាសង្គមកិច្ច បច្ចេកទេស វប្បធម៌ និងសាសនាផង។ សូមរួមសហការគ្នា ជាពិសេសដោយយល់ដល់ព្រះគ្រីស្តដែលជាព្រះអម្ចាស់តែមួយព្រះអង្គ គឺជាព្រះអម្ចាស់របស់គេ និងជាព្រះអម្ចាស់របស់យើងដែរ។ សូមព្រះនាមព្រះអង្គបង្រួបបង្រួមគ្រីស្តបរិស័ទគ្រប់និកាយឲ្យរួមគ្នាជាធ្លុងតែមួយផង។ ត្រូវរួមសហការគ្នា មិនត្រឹមតែក្នុងឋានៈជាបុគ្គលម្នាក់ៗប៉ុណ្ណោះទេ តែក្នុងក្នុងឋានៈជាសហគមន៍ ជាក្រុមជំនុំ និងតាមកិច្ចការដែលគេធ្វើរួមជាមួយគ្នាតាមការយល់ឃើញរបស់អភិបាលភូមិភាគ។

គ្រីស្តបរិស័ទដែលមកពីគ្រប់ប្រជាជាតិ ហើយដែលរួមប្រជុំគ្នាក្នុងព្រះសហគមន៍ *"មិនប្លែកពីមនុស្សឯទៀតៗទេ គេគ្មានប្រទេសប្លែកពីគេទេ គេមិនប្រើភាសាប្លែកពីគេដែរ។ ក្នុងសង្គម គេក៏មិនរស់នៅតាមរបៀបប្លែកពីគេដែរ"* (លិខិតទៅលោកឌីយ៉ូង៉ែត ៥; ពន្លឺ ៣៨)។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទត្រូវតែរស់នៅ ទាំងថ្វាយខ្លួនចំពោះព្រះជាម្ចាស់ និងចំពោះព្រះគ្រីស្ត តាមប្រពៃណីនិងតាមទំនៀមទម្លាប់ស្រុករបស់ខ្លួន គឺត្រូវមានចិត្តស្រឡាញ់មាតុភូមិយ៉ាងពិតប្រាកដ និងយ៉ាងសកម្មក្នុងឋានៈជាប្រជាពលរដ្ឋដ៏ល្អត្រឹមត្រូវ។ ប៉ុន្តែ ត្រូវជៀសវាងកុំឲ្យប្រកាន់ពូជសាសន៍ជាដាច់ខាត កុំកាន់លទ្ធិជាតិនិយមជ្រុលហួស ត្រូវខិតខំណែនាំគេឲ្យចេះស្រឡាញ់មនុស្សលោកទូទៅ។ គ្រីស្តបរិស័ទធម្មតា ជាអ្នកដែលចូលរួមក្នុងព្រះកាយព្រះគ្រីស្ត ដោយអគ្គសញ្ញាជ្រមុជទឹក ហើយរស់នៅក្នុងលោកនេះ មានសារៈសំខាន់ណាស់ ដើម្បីឲ្យព្រះសហគមន៍បានលទ្ធផលទាំងនោះបាន គួរឲ្យគោរពគេយ៉ាងពិសេស។ គ្រីស្តបរិស័ទធម្មតាមានតួនាទីពិសេសដោយឡែកមួយ គឺដោយព្រះវិញ្ញាណរបស់ព្រះគ្រីស្តជ្រួតជ្រាបចិត្តគំនិតគេ ផ្តល់ជីវិតរស់រវើកដល់អ្វីៗក្នុងលោកីយ៍នេះ គេដូចជាមេក្នុងម្សៅ គឺចាត់ចែងអ្វីៗទាំងនោះពីខាងក្នុង ឲ្យបានស្របតាមព្រះគ្រីស្តជានិច្ច (ពន្លឺ ៣២)។

ប៉ុន្តែ ប្រសិនបើគ្រីស្តបរិស័ទរស់នៅ ហើយចាត់ចែងគ្នាជាព្រះសហគមន៍ក្នុងប្រទេសណាមួយ ក៏មិនទាន់គ្រប់គ្រាន់ទេ។ ប្រសិនបើ គ្រីស្តបរិស័ទបំពេញកិច្ចការជាគ្រីស្តទូត ដោយគ្រាន់តែធ្វើជាគំរូឲ្យអ្នកដទៃ ក៏មិនទាន់គ្រប់គ្រាន់ដែរ។ ព្រះជាម្ចាស់តែងតាំងប្រជារាស្ត្ររបស់ព្រះអង្គឲ្យរស់នៅក្នុងប្រទេសនីមួយៗ ដើម្បីឲ្យគេប្រកាសដំណឹងអំពីព្រះគ្រីស្តដល់ជនរួមជាតិក្នុងប្រទេសនោះ ដោយនិយាយអំពីព្រះអង្គផង និងដោយធ្វើកិច្ចការផង គឺជួយជនរួមជាតិនោះឲ្យទទួលព្រះគ្រីស្តយ៉ាងពេញលេញ។

មិនតែប៉ុណ្ណោះសោត ត្រូវតែងតាំងមុខងារបម្រើផ្សេងៗក្នុងព្រះសហគមន៍ជាចាំបាច់ ដើម្បីឲ្យព្រះសហគមន៍ចាក់ឫសយ៉ាងមាំ និងចម្រើនឡើងបាន។ ព្រះជាម្ចាស់ត្រាស់ហៅអ្នកខ្លះពីក្នុងផ្ទៃអង្គប្រជុំនៃគ្រីស្តបរិស័ទនោះឲ្យបំពេញមុខងារបម្រើទាំងនោះ។ គ្រីស្តបរិស័ទទាំងអស់ក៏ត្រូវគោរពអ្នកទាំងនោះ និងគាំទ្រលើកទឹកចិត្តគេយ៉ាងខ្លាំង។ ក្នុងចំណោមមុខងារបម្រើទាំងនោះ មានមុខងារជាបូជាចារ្យ ជាឧបដ្ឋាក ជាអ្នកអប់រំជំនឿ ជាអ្នកបំពេញសកម្មភាពកាតូលិកក្នុងសង្គមជាដើម។ ម៉្យាងទៀត បព្វជិតបព្វជិតា ក៏បំពេញភារកិច្ចមួយដ៏ចាំបាច់ខានពុំបាន គឺជួយធ្វើឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់ចាក់ឫសក្នុងចិត្តមនុស្ស ព្រមទាំងពង្រឹងនិងលាតសន្ធឹងព្រះរាជ្យនោះយ៉ាងឆ្ងាយ ដោយអង្វរព្រះជាម្ចាស់ ឬដោយប្រព្រឹត្តកិច្ចការផ្សេងៗយ៉ាងសកម្មទៀតដែរ។

## ១៦-ការតែងតាំងក្រុមបូជាចារ្យដែលកើតក្នុងស្រុក

ព្រះសហមន៍មានអំណរសប្បាយជាខ្លាំង ហើយសូមអរព្រះគុណព្រះជាម្ចាស់ ដែលទ្រង់ត្រាស់ហៅយុវជនជាច្រើនក្នុងចំណោមប្រជាជនទាំងប៉ុន្មាន ដែលទើបនឹងប្រែចិត្តមករកព្រះគ្រីស្ត ឲ្យទៅជាបូជាចារ្យ។ ការនេះ ពិតជាព្រះអំណោយទានដ៏ថ្លៃថ្លារកថ្លែងពុំបានមកពីព្រះជាម្ចាស់។ ពេលព្រះសហគមន៍ស្ថិតនៅក្នុងក្រុមមនុស្សណាមួយ មានអ្នកបម្រើមុខងារនៃការសង្គ្រោះកើតចេញមកពីខ្លួនផ្ទាល់ គឺមានក្រុមអភិបាល ក្រុមលោកគង្វាល និងក្រុមឧបដ្ឋាក ពេលនោះ ព្រះសហគមន៍ពិតជាចាក់ឫសយ៉ាងមាំក្នុងក្រុមមនុស្សនោះ។ អស់លោកបម្រើបងប្អូនរួមជាតិ ហើយបន្តិចម្តងៗ ព្រះសហគមន៍គ្រីស្តបរិស័ទថ្មីនោះ ក៏មានរចនាសម្ព័ន្ធជាភូមិភាគ ដោយមានក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំងផ្ទាល់ដែរ។

ចាប់តាំងពីពេលព្រះសហគមន៍ណាមួយចាប់ផ្តើមចាក់ឫសមក ហើយនៅក្នុងព្រះសហគមន៍ថ្មីៗ ត្រូវអនុវត្តតាមគោលការណ៍ដ៏សំខាន់ៗស្តីអំពីការអប់រំគ្រីស្តបរិស័ទដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យទៅជាបូជាចារ្យ តាមមហាសន្និបាតបានសម្រេចនោះ។ ត្រូវចាប់អារម្មណ៍ជាទីបំផុតអំពីការអប់រំគេឲ្យរស់នៅតាមព្រះវិញ្ញាណ។ ការអប់រំនេះត្រូវភ្ជាប់យ៉ាងជិតស្និទ្ធ ជាមួយនិងការបង្រៀនអំពីលទ្ធិនៃគ្រីស្តសាសនា និងការហ្វឹកហ្វឺនឲ្យចេះឃ្វាលណែនាំគ្រីស្តបរិស័ទ។ ត្រូវបង្ហាត់គេអំពីរបៀបរស់នៅស្របតាមបែបដំណឹងល្អ ដោយមិនគិតគូរដល់ប្រយោជន៍ផ្ទាល់ខ្លួន និងដល់ប្រយោជន៍របស់បងប្អូនញាតិសន្តានឡើយ។ ត្រូវអប់រំគេយ៉ាងជ្រៅអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍ ដែលគេត្រូវយកចិត្តទុកដាក់ពង្រីកនោះ។ ដូច្នេះ និស្សិតទេវវិទ្យាល័យទាំងនោះនឹងទទួលការអប់រំយ៉ាងអស្ចារ្យឲ្យបូជាកម្លាំងកាយកម្លាំងចិត្ត បម្រើព្រះកាយព្រះគ្រីស្ត និងបម្រើដំណឹងល្អ។ គេក៏ភ្ជាប់ចិត្តភ្ជាប់គំនិតនិងអភិបាលរបស់ខ្លួន ក្នុងឋានៈជាសហការីដ៏ទៀងត្រង់ ព្រមទាំងជួយបូជាចារ្យឯទៀតៗជាបងប្អូន ដោយចិត្តស្មោះសរផងដែរ (ហ្វិក ៤.៨.៩)។ ត្រូវអប់រំនិស្សិតទាំងនោះឲ្យបានស្របតាមពន្លឺនៃគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ ដូចមានចែងទុកក្នុងគម្ពីរស្រាប់។ ត្រូវឲ្យគេស្គាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះរបស់មនុស្សលោក ដែលមានលាតត្រដាងនៅតាមពិធីគោរពបម្រើព្រះជាម្ចាស់ (ពិធី ១៧) ហើយគេក៏ត្រូវរស់នៅតាមគម្រោងការនោះទៀតផង។

ចំពោះគោលការណ៍ដែលត្រូវតែកាន់ជាទូទៅ ក្នុងការអប់រំនិស្សិតទេវវិទ្យាល័យ សូម្បីតែក្នុងការហ្វឹកហ្វឺន ឲ្យចេះឃ្វាលណែនាំគ្រីស្តបរិស័ទ និងការអនុវត្ត ត្រូវប្រតិបត្តិតាមសេចក្តីចាត់ចែងនៃមហាសន្និបាតដែរ (ហ្វឹក ១)។ ក៏ប៉ុន្តែត្រូវភ្ជាប់ការហ្វឹកហ្វឺននេះនិងការអប់រំឲ្យមានចិត្តព្យាយាមខ្នះខ្នែងចង់ស្គាល់របៀបរិះគិត និងរបៀបប្រព្រឹត្តនៃជាតិរបស់ខ្លួនផ្ទាល់ថែមទៀតផង។ ត្រូវបើកចិត្តគំនិតនិសិត្សទាំងនោះឲ្យចេះពិចារណាយ៉ាងជ្រៅ ដើម្បីឲ្យគេស្គាល់អរិយធម៌ជាតិរបស់ខ្លួនយ៉ាងច្បាស់ និងចេះវិនិច្ឆ័យថ្លឹងថ្លែងអំពីអ្វីៗដ៏ល្អ និងអ្វីៗដ៏អាក្រក់បង្កប់ទុកនៅក្នុងអរិយធម៌ជាតិនោះ។ ពេលបង្រៀនទស្សនវិទ្យានិងទេវវិទ្យា ត្រូវអប់រំគេឲ្យយល់ច្បាស់អំពីបុព្វហេតុបណ្តាលឲ្យប្រពៃណី និងសាសនាជាតិ មិនស្របនឹងគ្រីស្តសាសនា។ យ៉ាងណាមិញ ពេលហ្វឹកហ្វឺននិស្សិតឲ្យទៅជាបូជាចារ្យ ត្រូវនឹកគិតដល់តម្រូវការក្នុងកិច្ចឃ្វាលណែនាំគ្រីស្តបរិស័ទនៅតាមតំបន់នោះ។ ជាពិសេសនិសិត្សត្រូវរៀនឲ្យស្គាល់ប្រវត្តិសាស្ត្រ ស្គាល់គោលដៅ និងរប្រៀបអស់សាសនទូត នៅសម័យមុនៗ បានប្រកាសដំណឹងល្អក្នុងស្រុកនោះ។ មិនតែប៉ុណ្ណោះត្រូវអប់រំគេឲ្យស្គាល់សភាពការណ៍ពិសេសនៃសង្គម សភាពការណ៍ពិសេសនៃសេដ្ឋកិច្ច និងសភាពការណ៍ពិសេស នៃវប្បធម៌របស់ប្រជាជនរបស់ខ្លួនគេផ្ទាល់។ គេក៏ត្រូវទទួលការអប់រំឲ្យចង់បង្រួបបង្រួមគ្រីស្តបរិស័ទគ្រប់និកាយឲ្យ រួបរួមគ្នាជាធ្លុងតែមួយ (បង្រួប ៤) និងហាត់ខ្លួនឲ្យចេះនិយាយសន្ទនាយ៉ាងស្និទ្ធស្នាលជាមួយអ្នកកាន់សាសនាដទៃ ដូចជាសន្ទនាជាមួយបងប្អូនដែរ។ យោងតាមមូលហេតុទាំងនេះ ប្រសិនបើអាចធ្វើបាន ត្រូវបង្រៀននិស្សិតដែលនឹងទៅជាបូជាចារ្យ ឲ្យជាប់ទាក់ទងជានិច្ចនឹងស្រុកកំណើតរបស់ខ្លួន ហើយក៏រស់នៅស្របតាមរបៀបរស់នៅនៃប្រជាជនក្នុងស្រុករបស់ខ្លួនដែរ។ ត្រូវអប់រំគេខាងរដ្ឋបាលព្រះសហគមន៍ គឺឲ្យចេះបំពេញក្រដាសស្នាមយ៉ាងត្រឹមត្រូវតាមការចាត់ចែងនៃព្រះសហគមន៍ និងអប់រំគេឲ្យចេះត្រួតត្រាធនធានព្រះសហគមន៍ថែមទៀតផង។

ក្នុងចំណោមបូជាចារ្យដែលធ្លាប់ឃ្វាលណែនាំគ្រីស្តបរិស័ទ តាមសហគមន៍ជាយូរឆ្នាំល្មមហើយនោះ ត្រូវជ្រើសរើសបូជាចារ្យខ្លះ ដែលមានសមត្ថភាពអាចបន្តឧត្តមសិក្សាកម្រិតខ្ពស់ដោយជោគជ័យ បាននៅសកលវិទ្យាល័យក្នុងប្រទេស ឬនៅសកលវិទ្យាល័យខាងក្រៅប្រទេស ជាពិសេសនៅក្រុងរ៉ូម ឬនៅក្នុងគ្រឹះស្ថានវិទ្យាសាស្ត្រផ្សេងទៀតផង។ ធ្វើដូច្នេះ ទើបព្រះសហគមន៍ថ្មីៗ មានលោកខ្លះពីក្រុមបូជាចារ្យដែលកើតក្នុងស្រុកនោះ ប្រកបដោយចំណេះវិជ្ជា និងដោយបទពិសោធន៍សមរម្យ អាចបំពេញមុខងារដ៏ពិបាកជាងគេក្នុងព្រះសហគមន៍នោះបាន។

ប្រសិនបើក្រុមអភិបាលក្នុងប្រទេសមួយយល់ឃើញថាល្អគួរ ត្រូវតែងតាំងក្រុមឧបដ្ឋាកដូចកាលពីដើម ទុកជាក្រុមមួយដែលមានរបៀបរស់នៅជាអចិន្ត្រៃយ៍ ស្របតាមធម្មនុញ្ញគោលលទ្ធិអំពីព្រះសហគមន៍ (ពន្លឺ ២៩)។ ត្រូវមានបុរសបំពេញមុខងារបម្រើជាឧបដ្ឋាកយ៉ាងពិតប្រាកដ គឺប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬគ្រប់គ្រងសហគមន៍គ្រីស្តបរិស័ទដែលនៅឆ្ងាយ ក្នុងនាមបូជាចារ្យទទួលខុសត្រូវសហគមន៍នោះ ឬក្នុងនាមលោកអភិបាល។ អស់លោកឧបដ្ឋាកក៏សម្តែងមេត្តាករុណាធម៌ តាមសង្គមកិច្ច ឬតាមអង្គការមនុស្សធម៌ផ្សេងៗ។ ត្រូវពង្រឹងកម្លាំងបុរសទាំងនោះ ដោយធ្វើពិធីទ្រាបដៃលើគេ ជាពិធីដែលក្រុមគ្រីស្តទូតបានបញ្ជូនបន្តមក។ អស់លោកក៏ត្រូវរួបរួមយ៉ាងជិតស្និទ្ធនឹងតុសក្ការៈពោលគឺ ចូលរួមក្នុងអភិបូជា ដើម្បីឲ្យអស់លោកអាចបំពេញមុខងារបម្រើរបស់ខ្លួនយ៉ាងសកម្មបាន តាមព្រះជាម្ចាស់ប្រណីសន្តោស ដោយសារអគ្គសញ្ញាតែងតាំងជាឧបដ្ឋាក។

## ១៧-ការបង្ហាត់បង្រៀនអ្នកអប់រំជំនឿ

គួរឲ្យសរសើរកងទ័ពដ៏ប្រសើររបស់អ្នកអប់រំជំនឿ ដែលមានគុណយ៉ាងខ្លាំងក្នុងកិច្ចបំពេញបេសកកម្ម ជាសាសនទូតទៅកាន់សាសនាដទៃ។ អ្នកអប់រំជំនឿទាំងបុរសទាំងស្ត្រីនោះ ពិតជាមានចិត្តគំនិតជាគ្រីស្តទូតមែន។ គេធ្វើការ

យ៉ាងខ្លាំងអស្ចារ្យ គឺជួយព្រះសហគមន៍យ៉ាងពិសេស ជាជំនួយដ៏ចាំបាច់ជាទីបំផុត ក្នុងកិច្ចផ្សព្វផ្សាយជំនឿ និងពង្រីកព្រះសហគមន៍។ សព្វថ្ងៃ ដោយចំនួនបូជាចារ្យមានតិចពេក ដើម្បីនាំដំណឹងល្អដល់មនុស្សច្រើនអនេកផង និងដើម្បីឃ្វាលណែនាំគ្រីស្តបរិស័ទផង តួនាទីរបស់អ្នកអប់រំជំនឿមានសារៈសំខាន់ខ្លាំងណាស់។ ត្រូវអប់រំពួកគេយ៉ាងសមរម្យស្របតាមការចម្រើននៃវប្បធម៌ស្រុកគេ ដើម្បីឲ្យគេអាចធ្វើជាសហការីសកម្មរបស់ក្រុមបូជាចារ្យ។ សព្វថ្ងៃពួកគេទទួលបន្ទុកកាន់តែថ្មី និងកាន់តែធ្ងន់និងទូលំទូលាយទៀតផង។

ហេតុនេះហើយ បានជាត្រូវបង្កើនចំនួនសាលាតាមភូមិភាគ និងតាមតំបន់ ដើម្បីហ្វឹកហ្វឺនអ្នកអប់រំជំនឿ។ ក្នុងសាលាទាំងនោះ ត្រូវយកចិត្តទុកដាក់បង្ហាត់បង្រៀន អ្នកដែលនឹងអប់រំជំនឿនៅពេលអនាគត ឲ្យស្គាល់គោលលទ្ធិកាតូលិក ជាពិសេសបង្រៀនគម្ពីរ និងពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ ព្រមទាំងឲ្យគេស្គាល់គរុកោសល្យអប់រំជំនឿ និងកិច្ចឃ្វាលណែនាំគ្រីស្តបរិស័ទ។ ក្នុងសាលាទាំងនោះ គេត្រូវហ្វឹកហ្វឺនឲ្យកាន់តាមសីលធម៌គ្រីស្តបរិស័ទ ទាំងយកចិត្តទុកដាក់គោរពប្រណិប័តន៍ព្រះជាម្ចាស់ និងរស់នៅយ៉ាងវិសុទ្ធជានិច្ច។ លើសពីនេះទៅទៀត ត្រូវចាត់ចែងសិក្ខាសាលា ឬត្រូវបង្រៀនគេតាមពេលកំណត់ ដើម្បីផ្តល់ឱកាសឲ្យអ្នកអប់រំជំនឿទទួលចំណេះវិទ្យាទំនើប ខាងវិស័យសិក្សា និងខាងបច្ចេកទេស ដែលមានប្រយោជន៍សម្រាប់បំពេញមុខងាររបស់ខ្លួន ព្រមទាំងសម្រាប់ចិញ្ចឹម និងពង្រឹងជីវិតរបស់គេតាមព្រះវិញ្ញាណ។ មិនតែប៉ុណ្ណោះសោត ព្រះសហគមន៍ត្រូវផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ តាមយុត្តិធម៌ឲ្យអស់អ្នក ដែលបូជាកម្លាំងចិត្តទាំងស្រុងបំពេញបន្ទុកនេះ។ ព្រះសហគមន៍ក៏ត្រូវធានាឲ្យគេអាចរស់នៅបែបសមរម្យ និងផ្តល់ប្រាក់សម្រាប់សុខភាពដែរ។ មហាសន្និបាតសំណូមពរឲ្យក្រសួងប្រកាសដំណឹងល្អ ក្នុងចំណោមប្រជាជាតិនានា បង្កើតមូលនិធិពិសេសមួយ ដើម្បីជួយអប់រំ និងផ្គត់ផ្គង់អ្នកអប់រំជំនឿយ៉ាងសមរម្យ។ ប្រសិនបើអស់លោកអភិបាល យល់ឃើញថាមានប្រយោជន៍ និងត្រូវការ សូមបង្កើតក្រុមប្រមូលប្រាក់សម្រាប់អ្នកអប់រំជំនឿ។ ម្យ៉ាងទៀត ព្រះសហគមន៍នានាត្រូវទទួលស្គាល់កិច្ចការរបស់អ្នកជួយអប់រំជំនឿទៀត ពួកគេបានប្រព្រឹត្តកិច្ចការទាំងនោះដោយចិត្តទូលាយ ត្រូវគោរព និងអរគុណគេដែរ។ ព្រះសហគមន៍ត្រូវការអ្នកជំនួយទាំងនោះជាចាំបាច់។ អ្នកជំនួយទាំងនោះ ធ្វើជាអធិបតីក្នុងពេលសហគមន៍របស់ខ្លួនអធិដ្ឋាន ហើយបង្រៀនលទ្ធិនៃគ្រីស្តសាសនា។ ហេតុនេះហើយ បានជាត្រូវយកចិត្តទុកដាក់អប់រំគេឲ្យស្គាល់លទ្ធិនៃគ្រីស្តសាសនា ទាំងអប់រំគេខាងផ្លូវជីវិតតាមព្រះវិញ្ញាណ។ មិនតែប៉ុណ្ណោះ ប្រសិនបើលោកអភិបាលយល់ឃើញថាសមគួរ ត្រូវផ្ញើបេសកកម្មជាផ្លូវការតាមក្បួនច្បាប់ ឲ្យអ្នកអប់រំជំនឿដែលទទួលការអប់រំគ្រប់គ្រាន់ ដោយធ្វើពិធីមួយជាសាធារណៈ ដើម្បីឲ្យគេអាចបម្រើជំនឿប្រជាជនប្រកបដោយអំណាច។

## ១៨-ត្រូវលើកស្ទួយឲ្យមានបព្វជិតបព្វជិតា

ចាប់តាំងពីពេលតែងតាំងព្រះសហគមន៍មួយមក ត្រូវយកចិត្តទុកដាក់លើកស្ទួយឲ្យមានបព្វជិតបព្វជិតា។ បព្វជិតបព្វជិតាមិនគ្រាន់តែជួយយ៉ាងសកម្ម និងយ៉ាងចាំបាច់បំផុតក្នុងការប្រកាសដំណឹងល្អប៉ុណ្ណោះទេ តែដោយបព្វជិតបព្វជិតាញែកខ្លួនថ្វាយព្រះជាម្ចាស់យ៉ាងស្និទ្ធស្នាល ក្នុងព្រះសហគមន៍ដូច្នេះ (ពន្លឺ ៣១.៤៤) អស់លោកអ្នកក៏បង្ហាញបញ្ជាក់យ៉ាងច្បាស់ ឲ្យគ្រីស្តបរិស័ទយល់អត្ថន័យនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យទៅជាគ្រីស្តបរិស័ទថែមទៀត។

បព្វជិតបព្វជិតានៃគ្រឹះស្ថាន ដែលជួយតែងតាំងព្រះសហគមន៍ ត្រូវរួមរស់យ៉ាងស្និទ្ធស្នាលជាមួយព្រះគ្រីស្តជ្រួតជ្រាបក្នុងចិត្តយ៉ាងជ្រៅ។ ការរស់នៅបែបនេះ ពិតជាទ្រព្យសម្បត្តិដ៏ថ្លៃថ្នូរ និងជាសិរីរុងរឿងនៃប្រពៃណីសាសនារបស់ព្រះសហគមន៍។ គេត្រូវខិតខំបង្ហាញនិងបញ្ជូនបន្តប្រពៃណីដ៏ថ្លៃថ្នូរនេះ ស្របតាមទេពកោសល្យ និងតាមលក្ខណៈប្រជាជាតិនីមួយ។ ជួនកាលប្រជាជនទាំងនោះ មានប្រពៃណីបួសធ្វើតបធម៌ និងប្រពៃណីស្មឹងស្មាធ៌ធ្វើសមាធិ មុនពេល

ព្រះគ្រីស្ដប្រកាសដំណឹងល្អទៅទៀត តាមព្រះជាម្ចាស់សព្វព្រះហឫទ័យផ្សព្វផ្សាយពូជទាំងនោះក្នុងអរិយធម៌បុរាណ។ គ្រឹះស្ថានបព្វជិតបព្វជិតាត្រូវរិះគិតពិចារណា អំពីរបៀបលើកយកប្រពៃណីតបធម៌ និងប្រពៃណីស្ញឹងស្ញាធ៍ទាំងនោះ ឲ្យចូលក្នុងការរស់នៅជាបព្វជិតបព្វជិតានៃគ្រីស្ដសាសនាផង។

ក្នុងព្រះសហគមន៍ថ្មីៗ ត្រូវយកចិត្តទុកដាក់លើកស្ទួយរបៀបរស់នៅផ្សេងៗជាបព្វជិតបព្វជិតា ដើម្បីបង្ហាញមុខផ្សេងៗនៃបេសកកម្មរបស់ព្រះគ្រីស្ដ និងនៃការរស់នៅរបស់ព្រះសហគមន៍។ ក្រុមបព្វជិតបព្វជិតាទាំងនោះត្រូវបូជាកម្លាំងកាយ កម្លាំងចិត្តបំពេញសកម្មភាពផ្សេងៗ ក្នុងការឃ្វាលណែនាំគ្រីស្ដបរិស័ទ និងអប់រំសមាជិករបស់ខ្លួនយ៉ាងសមរម្យឲ្យអាចបំពេញសកម្មភាពទាំងនោះបាន។ ប៉ុន្តែ ក្រុមអភិបាលក្នុងប្រទេសនីមួយៗ ត្រូវប្រយ័ត្នប្រយែងកុំឲ្យមានក្រុមគ្រួសារដែលមានគោលដៅជាគ្រីស្ដទូតប្រហែលគ្នាចម្រើនចំនួនឡើង ក្រែងលបណ្ដាលឲ្យមានផលវិបាកកើតដល់ការរស់នៅជាបព្វជិតបព្វជិតាផង និងដល់កិច្ចការជាគ្រីស្ដទូតរបស់ព្រះសហគមន៍ទៀតផង។

គួរឲ្យកត់សម្គាល់យ៉ាងពិសេសថា បព្វជិតបព្វជិតាខ្លះខិតខំចាប់ផ្ដើម ធ្វើឲ្យរបៀបរស់នៅដោយស្ញឹងស្ញាធ៍ធ្វើសមាធិ ចាក់ឫសនៅក្នុងព្រះសហគមន៍ថ្មីៗ។ គ្រឹះស្ថានខ្លះរក្សាទុកតែកត្តាខ្លះដ៏សំខាន់ៗនៃការរស់នៅបែបលោកសង្ឃ ហើយខិតខំតែងតាំងប្រពៃណីដ៏ប្រសើរបំផុតនៃក្រុមគ្រួសាររបស់ខ្លួន។ គ្រឹះស្ថានខ្លះទៀត ត្រឡប់មកកាន់តាមរបៀបរស់នៅរបស់លោកសង្ឃគ្រីស្ដបរិស័ទពីជំនាន់ដើម។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏អស់លោកអ្នកទាំងនោះ ត្រូវស្វែងរកឲ្យការរស់នៅរបស់អស់លោកអ្នក បានសមស្របតាមសភាពការណ៍ស្រុកនោះយ៉ាងពិតប្រាកដ។ ត្រូវតែងតាំងក្រុមបព្វជិតបព្វជិតាស្ញឹងស្ញាធ៍ធ្វើសមាធិ នៅគ្រប់កន្លែងក្នុងគ្រប់ព្រះសហគមន៍ថ្មីៗ ព្រោះការរស់នៅបែបនេះ ពិតជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះសហគមន៍ចម្រើនឡើង យ៉ាងពេញលក្ខណៈប្រាកដមែន។

# ជំពូក ៣

## ព្រះសហគមន៍ដោយឡែក

### ១៩-ព្រះសហគមន៍ថ្មីៗចម្រើនឡើង

កាលក្រុមគ្រីស្តបរិស័ទចាក់ឫសក្នុងការរស់នៅនៃសង្គមមួយរួចហើយ និងរស់នៅសមស្របតាមអរិយធម៌ស្រុកនោះខ្លះៗ ព្រមទាំងស្ថិតស្ថេរនៅយ៉ាងមាំមួនផងនោះ កិច្ចតែងតាំងព្រះសហគមន៍ក្នុងក្រុមមនុស្សនោះ បានដល់ទិសដៅម្យ៉ាងហើយ។ ពេលនោះព្រះសហគមន៍ត្រូវមានធនធានមនុស្សផ្ទាល់ ទោះបីមិនគ្រប់គ្រាន់ក្តី គឺមានក្រុមបូជាចារ្យ ដែលកើតក្នុងស្រុក មានបព្វជិតបព្វជិតាជាតិនោះ មានគ្រីស្តបរិស័ទធម្មតា ហើយក៏មានមុខងារបម្រើ និងស្ថាប័នផ្សេងៗ ដែលព្រះសហគមន៍ត្រូវការសម្រាប់ណែនាំការរស់នៅនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឲ្យចម្រើនឡើង ក្រោមការណែនាំរបស់លោកអភិបាល។

ប៉ុន្តែ ត្រូវឲ្យការរស់នៅរបស់ប្រជារាស្ត្រព្រះជាម្ចាស់ក្នុងព្រះសហគមន៍ថ្មីទាំងនោះ មានលក្ខណៈពេញវ័យក្នុងគ្រប់វិស័យនៃការរស់នៅជាគ្រីស្តបរិស័ទ។ ត្រូវសម្រួលរបៀបរស់នៅជាគ្រីស្តបរិស័ទនោះ តាមសេចក្តីចាត់ចែងរបស់មហាសន្និបាត។ ត្រូវឲ្យអង្គប្រជុំរបស់គ្រីស្តបរិស័ទដឹងខ្លួនបន្តិចម្តងៗ ពីមួយថ្ងៃទៅមួយថ្ងៃថា គេពិតជាសហគមន៍រួមជំនឿ ជាសហគមន៍ធ្វើពិធីគោរពប្រណិប័តន៍រួមគ្នា ជាសហគមន៍ដែលមានសេចក្តីស្រឡាញ់រួមដែរ។ គ្រីស្តបរិស័ទធម្មតាដែលមានសកម្មភាពក្នុងសង្គម និងមានសកម្មភាពជាគ្រីស្តទូត ក៏ខិតខំបង្កើតសង្គមប្រកបដោយសេចក្តីស្រឡាញ់ និងដោយយុត្តិធម៌។ ត្រូវប្រើមធ្យោបាយទូរគមនាគមន៍នានាក្នុងសង្គមតាមតម្រូវការ និងដោយប្រុងប្រយ័ត្ន។ ដោយក្រុមគ្រួសារគ្រីស្តបរិស័ទនីមួយៗរស់នៅតាមបែបជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ ក្រុមគ្រួសារទាំងនោះក្លាយទៅជាកន្លែងអប់រំយុវជនឲ្យយកចិត្តទុកដាក់និងកិច្ចការជាគ្រីស្តទូត ហើយក៏ជាកន្លែងព្រះជាម្ចាស់ត្រាស់ហៅគេឲ្យធ្វើជាបូជាចារ្យ និងធ្វើជាបព្វជិតបព្វជិតាផង។ ព្រះសហគមន៍នេះអប់រំជំនឿតាមរបៀបសមរម្យ ហើយក៏លើកតម្កើងជំនឿនេះតាមពិធីគោរពប្រណិប័តន៍ស្របតាមទេពកោសល្យនៃប្រជាជននោះ។ ជំនឿនេះក៏ជ្រាបចូលក្នុងស្ថាប័នគួរគោរព និងក្នុងទំនៀមទម្លាប់ស្រុកនោះតាមរយៈច្បាប់ដ៏សមរម្យរបស់ព្រះសហគមន៍ទៀតផង។

អភិបាលម្នាក់ៗ រួមជាមួយក្រុមលោកគង្វាលរបស់ខ្លួន ត្រូវរួមចិត្តគំនិតកាន់តែជិតស្និទ្ធជាមួយព្រះគ្រីស្ត និងជាមួយព្រះសហគមន៍ គឺគិតគូរនិងរស់នៅរួបរួមជាមួយព្រះសហគមន៍សកល គឺព្រះសហគមន៍ថ្មីៗទាំងប៉ុន្មានត្រូវរួបរួមជាមួយព្រះសហគមន៍ទាំងមូល។ ព្រះសហគមន៍ថ្មីៗទាំងនោះ ត្រូវយកសេចក្តីខ្លះពីប្រពៃណីនៃអរិយធម៌ប្រទេសរបស់ខ្លួន មកផ្សំជាមួយប្រពៃណីព្រះសហគមន៍សកល ដើម្បីពង្រីកព្រះជន្មនៃព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត ដោយជួយចែកចាយសេចក្តីខ្លះពីប្រពៃណីនៃអរិយធម៌របស់ខ្លួនឲ្យគ្នាទៅវិញទៅមក។ ហេតុនេះហើយ បានជាត្រូវយកចិត្តទុកដាក់លើកស្ទួយសេចក្តីខ្លះតាមទេវវិទ្យា តាមចិត្តសាស្ត្រ និងតាមមនុស្សវិជ្ជា ដែលអាចជួយឲ្យព្រះសហគមន៍ថ្មីទាំងនោះយល់ឃើញថា គេរួបរួមជាមួយព្រះសហគមន៍សកលកាន់តែខ្លាំងឡើងៗ។

ព្រះសហគមន៍ថ្មីៗជាច្រើន ស្ថិតនៅតំបន់ក្រជាងគេក្នុងពិភពលោក។ តាមធម្មតាព្រះសហគមន៍ទាំងនោះ នៅតែខ្វះបូជាចារ្យយ៉ាងខ្លាំង។ គេក៏ខ្វះធនធានសម្ភារៈដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍ទាំងនោះត្រូវការឲ្យព្រះសហគមន៍ទាំងមូលបន្តបេសកកម្មជាសាសនទូត និងបន្តការជួយផ្គត់ផ្គង់ជំនួយតទៅទៀត។ ត្រូវប្រើជំនួយទាំងនោះជាអាទិ៍ ឲ្យព្រះសហគមន៍ទាំងនោះចម្រើនឡើង និងឲ្យគ្រីស្តបរិស័ទរស់នៅក្នុងឋានៈជាគ្រីស្តបរិស័ទពេញវ័យ។ ព្រះសហគមន៍សាកលក៏ត្រូវជួយបន្តបេសកកម្មជាសាសនទូត ឲ្យព្រះសហគមន៍ដែលតែងតាំងជាយូរមកហើយដែរ តែកំពុងអន់ថយ និងទន់ខ្សោយ។

ប៉ុន្តែ ព្រះសហគមន៍ថ្មីៗទាំងនោះ ត្រូវយកចិត្តទុកដាក់ខ្នះខ្នែងណែនាំគ្រីស្តបរិស័ទជាទូទៅ និងចាត់ចែងសកម្មភាពស្របតាមសភាពការណ៍ ដើម្បីឲ្យអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យធ្វើជាបូជាចារ្យក្នុងភូមិភាគ និងគ្រឹះស្ថានបព្វជិតបព្វជិតាចម្រើនចំនួនឡើងៗ។ ប៉ុន្តែ ត្រូវពិនិត្យពិច័យនិងលើកស្ទួយអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅ និងគ្រឹះស្ថានទាំងនោះ ឲ្យកាន់តែច្បាស់និងកាន់តែសកម្ម (បូជាចារ្យ ១១; ហ្វឹកហ្វឺន ២)។ ធ្វើដូច្នេះ ទើបព្រះសហគមន៍ថ្មីៗទាំងនោះអាចផ្គត់ផ្គង់តម្រូវការរបស់ខ្លួនបន្តិចម្ដងៗ ព្រមទាំងអាចជួយព្រះសហគមន៍ដទៃទៀតផង។

## ២០-សកម្មភាពជាសាសនទូតរបស់ព្រះសហគមន៍តាមភូមិភាគ

ព្រះសហគមន៍ភូមិភាគ មានភារកិច្ចធ្វើជាតំណាងព្រះសហគមន៍សកលឲ្យកាន់តែប្រសើរឡើងៗ។ ហេតុនេះព្រះសហគមន៍ភូមិភាគត្រូវដឹងច្បាស់ថា ព្រះជាម្ចាស់ចាត់ខ្លួនឲ្យទៅកាន់អស់អ្នកដែលរស់នៅក្នុងតំបន់ជាមួយគ្នា តែមិនជឿលើព្រះគ្រីស្ត។ ព្រះសហគមន៍ត្រូវធ្វើជាសញ្ញាសម្គាល់បង្ហាញព្រះគ្រីស្តឲ្យពួកគេស្គាល់ ដោយគ្រីស្តបរិស័ទម្នាក់ៗ និងព្រះសហគមន៍ទាំងមូលផ្ដល់សក្ខីភាពដោយសារមការរស់នៅរបស់គេ។

ម្យ៉ាងទៀត ត្រូវមានអ្នកមានមុខងារបម្រើព្រះ បន្ទូលជាចាំបាច់ ដើម្បីឲ្យដំណឹងល្អទៅដល់មនុស្សទាំងអស់។ ហេតុនេះហើយ ជាអាទិ៍លោកអភិបាលត្រូវប្រកាសជំនឿ នាំឲ្យមានសាវ័កថ្មីមករកព្រះគ្រីស្ត (ពន្លឺ ២៥)។ លោកអភិបាលត្រូវស្គាល់សភាពការណ៍នៃហ្វូងចៀមរបស់ខ្លួនឲ្យបានច្បាស់ ហើយក៏ត្រូវស្គាល់គំនិតដ៏ជ្រៅកប់ក្នុងចិត្តរបស់ជនរួមជាតិនោះអំពីព្រះជាម្ចាស់ ទាំងនឹកគិតយ៉ាងហ្មត់ចត់អំពីការប្រែប្រួល ដែលបណ្ដាលមកពីមនុស្សទៅរស់នៅក្នុងទីក្រុង មនុស្សផ្លាស់ប្ដូរកន្លែងទៅរកការធ្វើ និងមនុស្សមិនយកចិត្តទុកដាក់នឹងសាសនាណាសោះទៀតផង។ បើលោកស្គាល់ដូច្នេះ ទើបលោកអាចបំពេញបន្ទុកដ៏ប្រសើរនេះបាន។

ក្នុងព្រះសហគមន៍ថ្មីៗ លោកគង្វាលដែលកើតក្នុងស្រុក ត្រូវខ្នះខ្នែងប្រកាសដំណឹងល្អ ដោយចាត់ចែងសកម្មភាពរួមជាមួយសាសនទូតមកពីបរទេស។ ទាំងអស់លោកគង្វាលកើតក្នុងស្រុក ទាំងលោកគង្វាលមកពីបរទេស ក៏ត្រូវរួបរួមយ៉ាងជិតស្និទ្ធ ជាក្រុមគង្វាលតែមួយ ក្រោមអំណាចរបស់លោកអភិបាល។ អស់លោកមិនគ្រាន់តែឃ្វាលថែរក្សាគ្រីស្តបរិស័ទ និងធ្វើពិធីគោរពបម្រើព្រះជាម្ចាស់ប៉ុណ្ណោះទេ តែអស់លោកត្រូវប្រកាសដំណឹងល្អដល់មនុស្សនៅខាងក្រៅព្រះសហគម៍ទៀតផង។ ប្រសិនបើមានឱកាសផ្ដល់ឲ្យ ត្រូវប្រុងខ្លួនដោយចិត្តមុះមុត ជូនខ្លួនទៅលោកអភិបាលឲ្យលោកចាត់ទៅចាប់ផ្ដើមកិច្ចការជាសាសនទូតនៅស្រុកដាច់ស្រយាល ឬនៅតំបន់ណាដែលគ្មាននរណាអើពើ ក្នុងភូមិភាគរបស់ខ្លួនក្ដី ឬក្នុងភូមិភាគឯទៀតៗដែរ។

បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតា ក៏ត្រូវខ្នះខ្នែងចំពោះជនរួមជាតិដូច្នេះដែរ ជាពិសេសចំពោះអ្នកក្រីក្រជាងគេ។

ក្រុមអភិបាលត្រូវយកចិត្តទុកដាក់ចាត់ចែងសិក្ខាសាលាតាមពេលកំណត់ ដើម្បីបង្រៀនគម្ពីរ បង្រៀនទេវវិជ្ជា បង្ហាត់ជីវិតតាមព្រះវិញ្ញាណ និងបង្ហាត់អំពីការណែនាំគ្រីស្តបរិស័ទតាមរបៀបទំនើបទាន់សម័យ។ ត្រូវចាត់ចែងដូច្នេះ ដោយមានបំណងឲ្យអស់លោកគង្វាល បានចំណេះអំពីទេវវិទ្យា និងអំពីវិធីណែនាំគ្រីស្តបរិស័ទកាន់តែច្បាស់ នៅពេលពិភពលោកដ៏មិនទៀងទាត់នេះប្រែប្រួលគ្រប់យ៉ាង។

សូមអនុវត្តតាមសេចក្តីទាំងប៉ុន្មាន ដែលមហាសន្និបាតបានសម្រេច ដោយមានចិត្តគំនិតចង់គោរពសាសនាជាពិសេសក្នុងក្រឹត្យក្រមស្តីអំពីមុខងារ និងការរស់នៅរបស់អស់លោកគង្វាល។ ត្រូវឲ្យព្រះសហគមន៍ភូមិភាគតែងតាំងអ្នកមានមុខងារបម្រើ ដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឲ្យព្រះសហគមន៍នេះអាចបំពេញសកម្មភាពជាសាសនទូតរបស់ខ្លួនដោយជោគជ័យបាន។ ហេតុនេះហើយ បានជាត្រូវអប់រំអ្នកទទួលមុខងារបម្រើទាំងនោះឲ្យទាន់ពេលវេលាស្របតាមសភាពការណ៍ព្រះសហគមន៍នីមួយៗ។ ដោយមនុស្សនាបច្ចុប្បន្ន ចូលចិត្តរួមគ្នាជាក្រុមកាន់តែច្រើនឡើងៗ ត្រូវឲ្យក្រុមអភិបាលក្នុងប្រទេស ចែកចាយយោបល់គ្នាទៅវិញទៅមកអំពីរបៀបសន្ទនាទាក់ទងជាមួយក្រុមទាំងនោះ។ នៅតំបន់ខ្លះ មានក្រុមមនុស្សខ្លះ មិនអាចទទួលជំនឿរបស់ព្រះសហគមន៍កាតូលិកបានទេ ព្រោះគេមិនអាចសម្របខ្លួនតាមបែបបទរបស់ព្រះសហគមន៍នៅស្រុកដែលគេរស់នៅនោះ។ ក្នុងករណីនេះ គួរឲ្យរកដំណោះស្រាយតាមរបៀបពិសេស រហូតដល់ពេលគ្រីស្តបរិស័ទទាំងអស់អាចជួបជុំគ្នាក្នុងសហគមន៍តែមួយបានផង (គង្វាល ១០)។ អភិបាលម្នាក់ៗ ត្រូវត្រាស់ហៅសាសនទូត ឬសុខចិត្តទទួលសាសនទូត ឲ្យមករស់នៅក្នុងភូមិភាគរបស់ខ្លួន គឺសាសនទូត ដែលសន្តះអាសនៈបានចាត់ចែងឲ្យទៅក្នុងគោលបំណងនេះ។ លោកអភិបាលក៏ត្រូវជួយលើកស្ទួយសាសនទូតទាំងនោះយ៉ាងសកម្ម ក្នុងកិច្ចដែលអស់លោកមានបំណងចង់ធ្វើទៀតដែរ។

គួរណាស់ឲ្យព្រះសហគមន៍ថ្មីៗ ចូលរួមយ៉ាងសកម្ម ក្នុងបេសកកម្មសកលរបស់ព្រះសហគមន៍ដែរ។ ទោះបីខ្លួនខ្វះគង្វាលក្តី ព្រះសហគមន៍ថ្មីៗទាំងនោះ គួរណាស់ចាត់សាសនាទូតដែលអាចទៅប្រកាសដំណឹងល្អនៅលើផែនដីទាំងមូលដែរ។ ធ្វើដូច្នេះ ទើបក្រុមគង្វាលជាបងប្អូនរួមជាតិចាប់ផ្តើមមានចិត្តខ្នះខ្នែង ធ្វើសាសនទូតចំពោះអ្នកដទៃ។ ពេលណាព្រះសហគមន៍ថ្មីៗ រួមយ៉ាងសកម្មក្នុងកិច្ចប្រកាសដំណឹងល្អចំពោះសាសន៍ដទៃទៀត គឺពេលនោះព្រះសហគមន៍ថ្មីៗទាំងនោះ ពិតជារួបរួមជាមួយព្រះសហគមន៍សកលជាពុំខានឡើយ។

## ២១-ត្រូវលើកស្ទួយគ្រីស្តបរិស័ទធម្មតាឲ្យទៅជាគ្រីស្តទូត

ព្រះសហគមន៍ចាក់គ្រឹះបានមាំមួន និងមានជីវិតរស់រវើកយ៉ាងពេញលេញ ព្រមទាំងធ្វើជាសញ្ញាសម្គាល់ដ៏ ពេញលក្ខណៈអំពីព្រះគ្រីស្តក្នុងចំណោមមនុស្សលោក លុះត្រាតែមានក្រុមគ្រីស្តបរិស័ទធម្មតាដ៏ពិតប្រាកដ ធ្វើការរួមជាមួយក្រុមអភិបាល។ ដំណឹងល្អអាចជ្រួតជ្រាបយ៉ាងជ្រៅក្នុងចិត្តគំនិត ក្នុងការរស់នៅ និងក្នុងកិច្ចការរបស់ប្រជាជនណាមួយបាន លុះត្រាតែមានគ្រីស្តបរិស័ទធម្មតាបញ្ចេញសកម្មភាព។ ហេតុនេះហើយបានជាតាំងពីពេលចាក់ គ្រឹះព្រះសហគមន៍ណាមួយមក ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតតែងតាំងក្រុមគ្រីស្តបរិស័ទធម្មតា ដែលប្រៀបបានទៅនឹងមនុស្សពេញវ័យ។

គ្រីស្តបរិស័ទធម្មតាជាសមាជិកនៃប្រជារាស្ត្រព្រះជាម្ចាស់យ៉ាងពេញលេញហើយ ក៏ជាសមាជិកនៃសង្គមមនុស្សយ៉ាងពេញលេញផងដែរ។ ពួកគេក៏ជាសមាជិកនៃជាតិរបស់គេដែរ គេកើតក្នុងស្រុកនោះ ពេលគេរៀនសូត្រ គេចាប់ផ្តើមស្គាល់ទ្រព្យសម្បត្តិដ៏មានតម្លៃនៃវប្បធម៌ជាតិរបស់គេ។ គេភ្ជាប់នឹងការរស់នៅតាមលក្ខណៈជាតិនោះ ដោយមានចំណង

ពាក់ព័ន្ធបែបជាច្រើនក្នុងសង្គម គេរិះគិត និងយល់ឃើញអំពីបញ្ហារួមរបស់ជាតិ ហាក់ដូចជាបញ្ហារបស់ខ្លួនផ្ទាល់ ហើយគេក៏ខិតខំរកដំណោះស្រាយបញ្ហាទាំងនោះទៀតផងដែរ។ គ្រីស្តបរិស័ទធម្មតាក៏ជាកម្មសិទ្ធរបស់ព្រះគ្រីស្ត ព្រោះគេបានកើតជាថ្មីក្នុងព្រះសហគមន៍ដោយសារជំនឿ និងដោយអគ្គសញ្ញាជ្រមុជទឹក គេរួមជាប់ជាមួយព្រះគ្រីស្ត (១ករ ១៥, ២៣) ដោយរស់នៅតាមរបៀបថ្មី និងដោយប្រព្រឹត្តកិច្ចការតាមរបៀបថ្មីដែរ ដើម្បីឲ្យអ្វីៗទាំងអស់ចុះចូលក្រោមអំណាចរបស់ព្រះជាម្ចាស់ ដោយរួមក្នុងអង្គព្រះគ្រីស្ត និងដើម្បីឲ្យព្រះជាម្ចាស់បំពេញអ្វីៗទាំងអស់ក្នុងមនុស្សទាំងអស់ (១ករ ១៥, ២៨)។

គ្រីស្តបរិស័ទធម្មតា ទាំងបុរស ទាំងស្ត្រី មានភារកិច្ចដ៏សំខាន់ជាងគេ គឺធ្វើជាសាក្សីអំពីព្រះគ្រីស្តដោយរបៀបរស់នៅរបស់ខ្លួន និងដោយពាក្យសម្ដីដែលគេនិយាយអំពីព្រះអង្គ ក្នុងរង្វង់គ្រួសារ ក្នុងសង្គម និងនៅកន្លែងប្រកបការងារ។ ហេតុនេះ *"និស្ស័យមនុស្សថ្មីដែលព្រះជាម្ចាស់បានបង្កើតមក តាមសេចក្ដីសុចរិត ដើម្បីឲ្យបានវិសុទ្ធយ៉ាងពិតប្រាកដ"* (អភ ៤, ២៤) ត្រូវលេចធ្លោឡើងក្នុងរូបគេ។ គេក៏ត្រូវបង្ហាញបញ្ចេញជីវិតតាមរបៀបថ្មី នៅក្នុងសង្គមមនុស្ស នៅក្នុងអរិយធម៌ជាតិ និងតាមប្រពៃណីជាតិដែរ។ គ្រីស្តបរិស័ទធម្មតាត្រូវស្គាល់អរិយធម៌ជាតិ ព្យាបាលអរិយធម៌នេះ ថែរក្សា និងពង្រីកអរិយធម៌នេះតាមសភាពការណ៍ថ្មីៗ ហើយនាំឲ្យអរិយធម៌នេះបានពេញ លក្ខណៈក្នុងអង្គព្រះគ្រីស្ត។ ធ្វើដូច្នេះ ជំនឿលើព្រះគ្រីស្ត និងការរស់នៅរបស់ព្រះសហគមន៍ លែងមានលក្ខណៈ ក្រៅពីសង្គមជាកន្លែងដែលគេរស់នៅទៀតហើយ។ គេក៏ចាប់ផ្ដើមធ្វើឲ្យជំនឿជ្រួតជ្រាបក្នុងសង្គមនោះ ព្រមទាំងចាប់ផ្ដើមប្រែទម្រង់សង្គមនោះទៀតផង។ គ្រីស្តបរិស័ទធម្មតាត្រូវសហការជាមួយជនរួមជាតិរបស់ខ្លួនដោយចិត្តស្មោះ ដើម្បីបង្ហាញតាមរបៀបរស់នៅរបស់គេថា មានចំណងទាក់ទងថ្មី បង្រួបបង្រួមមនុស្ស និងមានចំណងសាមគ្គីសាកលថ្មី ដែលហូរចេញមកពីគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត។ គេក៏ត្រូវផ្សព្វផ្សាយជំនឿលើព្រះគ្រីស្ត ក្នុងចំណោមអស់អ្នកដែលរស់នៅជាមួយ និងធ្វើការជាមួយដែរ។ គេមានកាតព្វកិច្ចផ្សព្វផ្សាយជំនឿដូច្នេះជាចាំបាច់ ព្រោះមនុស្សភាគច្រើនអាចស្ដាប់ព្រះដំណឹងល្អ និងស្គាល់ព្រះគ្រីស្តបានដោយសារតែគ្រីស្តបរិស័ទធម្មតារស់នៅក្បែរគេប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅកន្លែងដែលអាចធ្វើបានគ្រីស្តបរិស័ទធម្មតាក៏ត្រូវប្រុងខ្លួនបំពេញបេសកកម្មពិសេសមួយ ដើម្បីប្រកាសដំណឹងល្អ និងបង្រៀនលទ្ធិនៃគ្រីស្តសាសនា ទាំងរួមសហការយ៉ាងជិតស្និទ្ធជាមួយក្រុមអភិបាល។ ដូច្នេះ គេផ្ដល់ឲ្យព្រះសហគមន៍ទើបកើតនោះ មានកម្លាំងមាំមួន។ អស់លោកដែលមានមុខងារបម្រើព្រះសហគមន៍ ត្រូវទទួលស្គាល់តម្លៃនៃកិច្ចការដ៏សែនពិបាករបស់គ្រីស្តបរិស័ទធម្មតា ក្នុងឋានៈជាគ្រីស្តទូត។ អស់លោកត្រូវអប់រំគ្រីស្តបរិស័ទធម្មតាទាំងនោះឲ្យដឹងខ្លួនថា ដោយគេជាសរីរាង្គនៃព្រះកាយព្រះគ្រីស្ត គេក៏ទទួលខុសត្រូវលើមនុស្សឯទៀតទាំងអស់ដែរ។ អស់លោកត្រូវបង្រៀនគេឲ្យជ្រាបយ៉ាងជ្រៅអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត និងបង្ហាត់គេឲ្យចេះប្រើវិជ្ជាថ្មីៗទៀតផង។ អស់លោកត្រូវនៅជាមួយគេ នៅគ្រាលំបាក ស្របតាមគំនិតនៃធម្មនុញ្ញគោលលទ្ធិ *"ព្រះគ្រីស្តជាពន្លឺបំភ្លឺប្រជាជាតិនានា"* និងក្រឹត្យក្រម *"សកម្មភាពជាគ្រីស្តទូត"*។ ធ្វើដូច្នេះ ព្រះសហគមន៍ថ្មីទាំងមូលត្រូវផ្ដល់សក្ខីភាពតែមួយយ៉ាងរស់រវើក និងមាំមួនអំពីព្រះគ្រីស្ត ដើម្បីឲ្យព្រះសហគមន៍ ទៅជាសញ្ញាសម្គាល់យ៉ាងច្បាស់អំពីការសង្គ្រោះ ដែលមកដល់យើងដោយសារព្រះគ្រីស្ត។ ប៉ុន្តែ គ្រីស្តបរិស័ទធម្មតាត្រូវគោរពមុខងារ និងភារកិច្ចផ្ទាល់របស់អស់លោកជាគង្វាលព្រះសហគមន៍។

## ២២-គ្រីស្តបរិស័ទរស់នៅតាមរបៀបប្លែកៗពីគ្នាក្នុងព្រះសហគមន៍តែមួយ

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រៀបបាននឹងពូជ។ កាលពូជនោះចាក់ឫសក្នុងដីដែលមានជីជាតិល្អ ហើយមានទឹកសន្សើមរបស់ព្រះជាម្ចាស់ស្រោចស្រពទៀតផងនោះ វាស្រូបជីជាតិពីដី និងយកជីជាតិនោះមកប្រែធ្វើជាកម្លាំង និងជា

ជីវិតផ្ទាល់ខ្លួន ដើម្បីឲ្យបានផ្លែយ៉ាងបរិបូណ៌។ យ៉ាងណាមិញ ព្រះសហគមន៍ថ្មីៗ ដែលចាក់ឫសក្នុងអង្គព្រះគ្រីស្ត និងសាងសង់លើគ្រីស្តទូតជាគ្រឹះ ក៏ទទួលយកអរិយធម៌ដ៏ថ្លៃថ្នូរនៃប្រជាជាតិនានា មកស្រូបយកជីជាតិ ធ្វើជាកម្លាំង និងជាជីវិតរបស់ខ្លួនផ្ទាល់យ៉ាងនោះដែរ។ ព្រះគ្រីស្តបានទទួលប្រជាជាតិទាំងអស់ទុកជាមរតក (ទន ២, ៨)។ ព្រះសហគមន៍ថ្មីៗ និងប្រជាជាតិទាំងនោះចែកចាយអ្វីដ៏មានតម្លៃរបស់ខ្លួន ជូនទៅវិញទៅមកយ៉ាងអស្ចារ្យ។ ព្រះជាម្ចាស់ចាត់ចែងអំពីព្រះបុត្រាប្រសូតជាមនុស្សដូច្នោះដែរ។ ព្រះសហគមន៍ថ្មីៗទាំងនោះ លើកយកទំនៀមទម្លាប់និងប្រពៃណី លើកយកប្រាជ្ញាញាណរបស់គេ ហើយក៏លើកយកចំណេះវិជ្ជា សិល្បៈ និងវិន័យរបស់ប្រជាជាតិទាំងនោះ គឺលើកយកអ្វីៗទាំងអស់មកជួយប្រកាសសិរីរុងរឿងរបស់ព្រះអាទិករ។ ព្រះសហគមន៍លើកយកអ្វីៗទាំងអស់ មកជួយធ្វើឲ្យព្រះហឫទ័យប្រណីសន្តោសរបស់ព្រះសង្គ្រោះលេចធ្លោឡើង ព្រមទាំងជួយចាត់ចែងរបៀបរស់នៅរបស់គ្រីស្តបរិស័ទ ឲ្យបានត្រឹមត្រូវល្អទៀតផង (ពន្លឺ ១៣)។

ក្នុងតំបន់ធំៗដែលមានបណ្តាប្រទេសមានអារ្យធម៌ស្រដៀងគ្នា ត្រូវដាស់តឿនឲ្យគេរិះគិតរួមគ្នាតាមផ្លូវទេវវិទ្យាអំពីសេចក្តីទាំងនោះ ដើម្បីឲ្យព្រះសហគមន៍ទទួលលទ្ធផលខាងលើនេះ។ ត្រូវតែពិនិត្យពិច័យព្រះរាជកិច្ច និងព្រះបន្ទូលដែលព្រះជាម្ចាស់បានសម្តែង ដែលមានចែងកត់ទុកក្នុងគម្ពីរ តាមអស់បុព្វបុរសនៃព្រះសហគមន៍ និងក្រុមណែនាំព្រះសហគមន៍បានពន្យល់ហើយស្រាប់។ ត្រូវរិះគិតពិនិត្យពិច័យសាជាថ្មី ក្រោមពន្លឺរបស់ព្រះសហគមន៍សកល ដែលបញ្ជូនបន្តជំនឿតៗរៀងមកដែរ។ ដោយរិះគិតដូច្នេះ គ្រីស្តបរិស័ទមុខជានឹងយល់កាន់តែច្បាស់អំពីរបៀបដែលប្រាជ្ញាមនុស្សអាចពន្យល់លទ្ធិជំនឿបាន ស្របតាមទស្សនវិទ្យា និងតាមប្រាជ្ញាញាណរបស់ប្រជាជាតិនានា។ គេក៏អាចយល់កាន់តែច្បាស់ថា ប្រពៃណី អត្ថន័យនៃជីវិត របៀបចាត់ចែងសង្គមនៃជនជាតិរបស់ខ្លួន អាចស្របតាមរបៀបរស់នៅដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ ដោយរិះគិតដូច្នេះ គេមុខជានឹងរកឃើញមាគ៌ាឲ្យខ្លួនរស់នៅសមស្របយ៉ាងជ្រៅតាមអរិយធម៌ប្រជាជាតិនានា ក្នុងគ្រប់វិស័យនៃការរស់នៅជាគ្រីស្តបរិស័ទ។ គេក៏ចៀសវាងមិនយកសាសនាផ្សេងៗមកលាយឡំនឹងសាសនារបស់ខ្លួន ហើយក៏លះបង់ការប្រកាន់សាសនាថាគ្រីស្តសាសនាតាមបែបរបស់ខ្លួនថា ល្អជាងគេ។ ការរស់នៅជាគ្រីស្តបរិស័ទមុខជានឹងបានសមស្របតាមទេពកោសល្យ និងតាមលក្ខណៈនៃអរិយធម៌ប្រទេសនោះ។ ព្រះសហគមន៍ត្រូវលើកយកប្រពៃណីដែលមានគុណសម្បត្តិនៃគ្រប់ប្រជាជាតិ មកថ្លឹងថ្លែងតាមពន្លឺនៃដំណឹង ល្អបំភ្លឺផងនោះ ឲ្យរួបរួមជាធ្លុងតែមួយក្នុងព្រះសហគមន៍សកល។ ព្រះសហគមន៍ថ្មីៗតាមតំបន់ទាំងនោះ ដែលលើកយកប្រពៃណីដ៏ថ្លៃថ្នូរប្រទេសរបស់ខ្លួនធ្វើជាសម្បត្តិផ្ទាល់ខ្លួននោះ ក៏ចូលរួបរួមក្នុងព្រះសហគមន៍សកល ទាំងគោរពអាសនៈគ្រីស្តទូតសិលា ដែលជា «អធិបតីនាំមុខ គ្រប់សហគមន៍ប្រកបដោយមេត្តាករុណាធម៌» (ពន្លឺ ១៣)។

ហេតុនេះហើយ បានជាមហាសន្និបាតមានសំណូមពរលើសពីនេះទៅទៀត (តាមពិតត្រូវតែធ្វើតាម) សូមឲ្យក្រុមអភិបាលព្រះសហគមន៍ក្នុងប្រទេសនានា តាមតំបន់ធំៗដែលមានអរិយធម៌ស្រដៀងគ្នា រួមគ្នាចែករំលែកយោបល់គ្នាព្រមព្រៀងគ្នាយ៉ាងពិតប្រាកដ បន្តកិច្ចសម្រួលព្រះសហគមន៍ឲ្យបានសមស្របតាមអរិយធម៌នោះ។

# ជំពូក ៤

## ក្រុមសាសនទូត

### ២៣-ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យធ្វើជាសាសនទូត

សាវ័ករបស់ព្រះគ្រីស្តគ្រប់ៗគ្នា មានភារកិច្ចផ្សព្វផ្សាយជំនឿតាមចំណែករៀងៗខ្លួន (ពន្លឺ ១៧)។ ប៉ុន្តែក្នុងចំណោមសាវ័កទាំងប៉ុន្មាន ព្រះគ្រីស្តជាអម្ចាស់នៅតែត្រាស់ហៅអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យ ដើម្បីឲ្យគេនៅជាមួយព្រះអង្គ និងចាត់គេឲ្យទៅប្រកាសដំណឹងល្អដល់សាសន៍ដទៃ (មក ៣, ១៣ត)។ ហេតុនេះហើយ បានជាព្រះអង្គប្រទានឲ្យគ្រីស្តបរិស័ទខ្លះមានចិត្តគំនិតចង់ធ្វើជាសាសនទូត ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធដែលចែករំលែកព្រះអំណោយទានតាមព្រះហឫទ័យព្រះអង្គ (១ករ ១២, ១១) ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍។ ព្រះគ្រីស្តជាអម្ចាស់ក៏ធ្វើឲ្យកើតគ្រឹះស្ថាន ដែលទទួលបេសកកម្មប្រកាសដំណឹងល្អទុកជាភារកិច្ចផ្ទាល់ ទោះជាភារកិច្ចរបស់ព្រះសហគមន៍ទាំងមូល។

ព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទខ្លះយ៉ាងពិសេស ឲ្យសុខចិត្តទទួលភារកិច្ចជាសាសនទូត។ អ្នកទាំងនោះជាជនបរទេស ឬជាអ្នកកើតក្នុងស្រុក ជាបូជាចារ្យ (អាចារ្យ) ឬជាបព្វជិតបព្វជិតា ឬជាគ្រីស្តបរិស័ទធម្មតា មានទេពកោសល្យ មានគុណសម្បត្តិ និងមានប្រាជ្ញាល្មមឲ្យអាចបំពេញបេសកកម្មពិសេសជាសាសនទូតនេះ។ អ្នកកាន់អំណាចដ៏ត្រឹមត្រូវក្នុងព្រះសហគមន៍ ចាត់គេឲ្យទៅកាន់អ្នកដែលនៅឆ្ងាយពីព្រះគ្រីស្ត។ គេក៏ទៅដោយមានជំនឿ និងស្តាប់បង្គាប់ទៀតផង។ ព្រះគ្រីស្តជ្រើសរើសញែកគេដើម្បីឲ្យបំពេញកិច្ចដែលព្រះអង្គដាក់ឲ្យគេបំពេញនោះ (កក ១៣, ២) ក្នុងឋានៈជាអ្នកមានមុខងារបម្រើដំណឹងល្អ *"ដើម្បីនាំសាសន៍ដទៃមកថ្វាយខ្លួន ជាតង្វាយដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាតង្វាយដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រោសឲ្យបានវិសុទ្ធ"* (រម ១៥, ១៦)។

### ២៤-ចិត្តគំនិតតាមព្រះវិញ្ញាណជាសាសនទូត

មនុស្សត្រូវតបឆ្លើយនឹងព្រះជាម្ចាស់ដ៏ពិតប្រាកដដែលត្រាស់ហៅគេធ្វើជាសានាទូត ដោយ *"មិនសួរយោបល់ ពីមនុស្សណាម្នាក់ឡើយ"* (កាឡ ១, ១៦) គេក៏ភ្ជាប់ចិត្តទាំងស្រុងនឹងកិច្ចប្រកាសដំណឹងល្អដែរ។ ប៉ុន្តែ អ្នកនោះអាចឆ្លើយបែបនេះបាន លុះត្រាតែព្រះវិញ្ញាណអញ្ជើញគេ និងប្រទានឫទ្ធានុភាពរបស់ព្រះអង្គឲ្យគេ ដ្បិតអ្នកដែលព្រះគ្រីស្តចាត់ឲ្យទៅរួមរស់ និងរួមបំពេញបេសកកម្មរបស់ព្រះអង្គដែល *"លះបង់អ្វីទាំងអស់មកយកឋានៈជាទាសករ"* (ភល ២, ៧)។ គេត្រូវប្រុងខ្លួនបន្តបេសកកម្មនេះអស់មួយជីវិត គឺសុខចិត្តលះបង់ខ្លួន និងលះបង់អ្វីៗទាំងអស់ដែលគេមាន រហូតដល់ពេលនោះ ព្រមទាំងធ្វើឲ្យខ្លួន *"បានដូចមនុស្សទាំងអស់"* (១ករ ៩, ២២)។

ពេលសាសនទូតប្រកាសដំណឹងល្អក្នុងចំណោមសាសន៍ដទៃ គាត់នាំគេឲ្យស្គាល់គម្រោងការដ៏អស្ចារ្យ របស់ព្រះគ្រីស្ត។ គាត់ត្រូវមានចិត្តសង្ឃឹម ព្រោះគាត់ជាទូតរបស់ព្រះអង្គ។ ដោយរួមក្នុងអង្គព្រះគ្រីស្ត គាត់ហ៊ាននិយាយពាក្យ

ត្រឹមត្រូវតាមដែលគាត់ត្រូវនិយាយ (អភ ៦, ១៩ត; កក ៤, ៣១)។ គាត់មិនត្រូវខ្មាសនឹងនិយាយអំពីឈើឆ្កាង ដែល *"រារាំងមនុស្សមិនឲ្យជឿ"* ទេ (១ករ ១, ២៣)។ សាសនទូតដើរតាមដានព្រះបរមគ្រូដែល *"ស្លូតនិងមានចិត្តសុភាព"* ហើយត្រូវបង្ហាញថា នឹមរបស់ព្រះអង្គស្រួល ហើយបន្ទុកដែលព្រះអង្គដាក់លើគេក៏ស្រាលដែរ (មថ ១១, ២៩ត)។ គាត់ត្រូវផ្តល់សក្ខីភាពអំពីព្រះអម្ចាស់របស់ខ្លួន ដោយរស់នៅត្រឹមត្រូវតាមដំណឹងល្អ ដោយមានចិត្តស៊ូទ្រាំ មានចិត្តអត់ធ្មត់យ៉ាងខ្លាំង មានចិត្តស្លូតបូត និងមានចិត្តស្រឡាញ់ឥតពុតត្បុត (២ករ ៦, ៤ត)។ ប្រសិនបើត្រូវការ គាត់ក៏ត្រូវផ្តល់សក្ខីភាពថ្វាយព្រះអម្ចាស់របស់ខ្លួន រហូតដល់បូជាជីវិតទៀតផង។ គាត់ត្រូវអង្វរព្រះអង្គប្រទានឲ្យគាត់មានចិត្តក្លាហាន និងមានកម្លាំង ដើម្បីទទួលស្គាល់ថា ទោះបីគាត់ជួបប្រទះទុក្ខលំបាកជាច្រើន និងរស់នៅក្នុងឋានៈជាអ្នកក្រតោកយ៉ាកបំផុតយ៉ាងណាក្តី ក៏គាត់មានអំណរខ្លាំងក្រៃលែងដែរ (២ករ ៨, ២)។ គាត់ត្រូវជឿជាក់ថាអ្នកបម្រើព្រះគ្រីស្តត្រូវស្តាប់តាមបង្គាប់ ព្រោះការស្តាប់តាមបង្គាប់នេះ ជាគុណធម៌ពិសេសនៃអ្នកបម្រើរបស់ព្រះគ្រីស្ត ដែលព្រះអង្គបានរំដោះមនុស្សលោក ដោយស្តាប់តាមព្រះបញ្ជារបស់ព្រះបិតាដែរ។

អស់អ្នកប្រកាសដំណឹងល្អ ត្រូវចៀសវាងកុំធ្វេសប្រហែសនឹងព្រះអំណោយទាន ដែលស្ថិតនៅក្នុងខ្លួនឡើយ ហើយក៏ត្រូវប្រែចិត្តគំនិតឲ្យបានជាថ្មីជារៀងរាល់ថ្ងៃដែរ (១ធម ៤, ១៤; អភ ៤, ២៣; ២ករ ៤, ១៦)។ អស់លោកអភិបាល និងអស់មេដឹកនាំក្រុមគ្រួសារនានា ត្រូវប្រជុំសាសនទូតទាំងអស់ឲ្យជួបជុំគ្នាតាមពេលកំណត់ ដើម្បីពង្រឹងសេចក្តីសង្ឃឹមរបស់គេលើព្រះជាម្ចាស់ ដែលត្រាស់ហៅគេ និងដើម្បីឲ្យគេមានចិត្តគំនិតថ្មី ក្នុងមុខងាររបស់ខ្លួនជាគ្រីស្តទូត។ ត្រូវចាត់ចែងឲ្យមានគេហដ្ឋានសម្រាប់ប្រជុំទាំងនោះ។

### ២៥-ការបង្ហាត់សាសនទូតឲ្យរស់តាមព្រះវិញ្ញាណ និងតាមសីលធម៌

អ្នកដែលត្រូវជាសាសនទូតនៅពេលអនាគត ត្រូវរៀបចំចិត្តគំនិតយ៉ាងពិសេសឲ្យបំពេញមុខងារដ៏ប្រសើរនេះ ដោយបង្ហាត់ខ្លួនឲ្យរស់តាមព្រះវិញ្ញាណ និងតាមសីលធម៌។ សាសនទូតត្រូវប្រុងខ្លួនចាប់ផ្តើមកិច្ចការផ្សេងៗ ដោយគំនិតផ្ទាល់ ត្រូវមានចិត្តនឹងរតស៊ូដើម្បីសម្រេចកិច្ចដែលគាត់បានចាប់ផ្តើមនោះ នៅពេលជួបប្រទះការលំបាកនានា គាត់ត្រូវមានចិត្តព្យាយាម។ សាសនទូតត្រូវស៊ូទ្រាំរស់នៅម្នាក់ឯង ស៊ូទ្រាំអស់កម្លាំងកាយកម្លាំងចិត្ត ស៊ូទ្រាំធ្វើការដោយគ្មានលទ្ធផល ទាំងមានចិត្តក្លាហាន និងចិត្តអត់ធ្មត់ខន្តី។ គាត់ត្រូវទៅជួបមនុស្សទាំងឡាយដោយចិត្តគំនិតទូលំទូលាយ និងចិត្តបើកចំហទៀតផង។ សាសនទូតត្រូវបំពេញកិច្ចការដែលព្រះសហគមន៍ផ្ញើឲ្យគាត់ធ្វើដោយចិត្តទូលាយ។ គាត់ត្រូវសុខចិត្តសម្របខ្លួនតាមរបៀបរស់របស់ជនជាតិដទៃ និងសម្របខ្លួនតាមសភាពការណ៍ដែលតែងតែប្រែប្រួលទៀតផង។ គាត់ត្រូវជួយសាសនទូតឯទៀតៗជាបងប្អូន និងអស់អ្នកដែលយកកម្លាំងកាយកម្លាំងចិត្តរួមធ្វើកិច្ចការតែមួយដូចគ្នា ដោយធ្វើការរួមចិត្តគំនិតជាមួយគេ និងដោយចិត្តស្រឡាញ់គ្នាទៅវិញទៅមកផង។ ដូច្នេះ អ្នកទាំងនោះមានចិត្តថ្លើមតែមួយ ដោយយកសហគមន៍នៅជំនាន់គ្រីស្តទូតជាគំរូ (កក ២, ៤២; ៤, ៣២)។

ពេលសាសនទូតទទួលការអប់រំ ត្រូវបង្ហាត់គេឲ្យរៀបចំចិត្តគំនិតតាមរបៀបនេះ ត្រូវឲ្យជីវិតខាងព្រះវិញ្ញាណ ថែទាំលើកឡើង និងគាំទ្រចិត្តគំនិតបែបនេះឲ្យកាន់តែមាំមួនឡើង។ សាសនទូតត្រូវមានជំនឿមោះមុត និងមានសេចក្តីសង្ឃឹមដែលមិនចេះរង្គោះរង្គើឡើយ ហើយក៏ត្រូវជាមនុស្សចូលចិត្តអធិដ្ឋាន។ គាត់ត្រូវមានចិត្តអង់អាច មានចិត្តស្រឡាញ់ និងចិត្តធ្ងន់ (២ធម ១, ៧)។ គាត់ *"ត្រូវរៀនឲ្យចេះស្កប់ចិត្តក្នុងគ្រប់កាលៈទេសៈ"* (ភល ៤, ១១)។ ដោយគាត់សុខចិត្តបូជាជីវិត គាត់ត្រូវផ្ទុកក្នុងរូបកាយរបស់គាត់នូវសេចក្តីឈឺចុកចាប់របស់ព្រះយេស៊ូជានិច្ច ដើម្បីឲ្យព្រះជន្មរបស់ព្រះអង្គមានឥទ្ធិពលយ៉ាងសកម្ម នៅក្នុងរូបកាយរបស់អស់អ្នកដែលគេចាត់គាត់ទៅជួប (២ករ ៤, ១០ត)។ ដោយ

គាត់មានចិត្តខ្នះខ្នែងចង់នាំការសង្គ្រោះដល់អ្នកដទៃ គាត់ត្រូវសុខចិត្តចំណាយអ្វីៗទាំងអស់ដែលគាត់មាន ហើយក៏ចំណាយខ្លួនឯងថែមទៀត ដើម្បីជាប្រយោជន៍ដល់គេដែរ (២ករ ១២, ១៥ត) រហូតដល់ *"ស្រឡាញ់ព្រះជាម្ចាស់នឹងស្រឡាញ់មនុស្សឯទៀតៗកាន់តែខ្លាំងឡើង ដោយបំពេញកិច្ចការរបស់ខ្លួនជារៀងរាល់ថ្ងៃ"* (ពន្លឺ ៤១)។ ដូច្នេះ ដោយគាត់រួមជាមួយព្រះគ្រីស្តដែលធ្វើតាមព្រះហឫទ័យព្រះបិតា គាត់នឹងបន្តបេសកកម្មរបស់ព្រះគ្រីស្ត ក្រោមអំណាចរបស់លោកអភិបាល និងរួមសហការក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ដែលសង្គ្រោះមនុស្សលោក។

## ២៦-ការអប់រំខាងលទ្ធិនៃគ្រីស្តសាសនា និងខាងកិច្ចការជាគ្រីស្តទូត

អស់អ្នកដែលព្រះសហគមន៍ចាត់ឲ្យទៅកាន់សាសន៍ដទៃៗទាំងនោះ ត្រូវទទួល *"ការអប់រំអំពីជំនឿ និងអំពីគោលលទ្ធិដ៏ត្រឹមត្រូវ"* (១ធម ៤, ៦) ដើម្បីឲ្យគេទៅជាអ្នកបម្រើព្រះគ្រីស្តយ៉ាងល្អប្រសើរ។ គេត្រូវរៀនអំពីគោលលទ្ធិដ៏ត្រឹមត្រូវនេះ ជាពិសេសដោយយោងសេចក្តីពីព្រះគម្ពីរ ហើយត្រូវរិះគិតយ៉ាងជ្រៅអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ត ដែលគេនឹងត្រូវប្រកាសនិងធ្វើជាសាក្សីនោះ។

ហេតុនេះហើយ បានជាត្រូវរៀបចំ និងអប់រំសាសនទូតទាំងអស់ គឺទាំងបូជាចារ្យ ទាំងបព្វជិតបព្វជិតា ទាំងគ្រីស្តបរិស័ទធម្មតា តាមសភាពការណ៍រៀងៗខ្លួន កុំឲ្យគេអន់ក្នុងភារកិច្ចរបស់ខ្លួននៅពេលអនាគត។ តាំងពីដើមដំបូងនៃការអប់រំនោះ ត្រូវចាត់ចែងការបង្រៀនអំពីលទ្ធិនៃគ្រីស្តសាសនា ដោយនឹកគិតដល់លក្ខណៈសកលរបស់ព្រះសហគមន៍ និងនឹកគិតដល់លក្ខណៈប្លែកៗនៃប្រជាជាតិនានា។ ត្រូវបង្រៀនមុខវិទ្យាទាំងប៉ុន្មានឯទៀតៗ ដោយមានគោលគំនិតបែបនេះដែរ គឺវិជ្ជាទាំងប៉ុន្មានដែលគេរៀននោះ មុខជានឹងជួយអប់រំឲ្យគេអាចបំពេញមុខងារបម្រើរបស់ខ្លួន។ ត្រូវឲ្យគេរៀនអំពីចំណេះដែលមានប្រយោជន៍ គឺចំណេះទូទៅអំពីប្រជាជននានា អំពីអរិយធម៌ និងអំពីសាសនានានាផង។ ត្រូវរៀនដូច្នេះ ដោយមិនគ្រាន់តែបែរទៅកាន់អតីតកាលប៉ុណ្ណោះទេ តែត្រូវបែរខ្លួនទៅរកបច្ចុប្បន្នកាលទៀតផង។ អ្នកដែលត្រូវជួបជាមួយប្រជាជនណាមួយប្លែកពីប្រជាជនរបស់ខ្លួន ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងនឹងបេតិកភ័ណ្ឌ ភាសា និងរបៀបរស់នៅរបស់ប្រជាជននោះ។ ហេតុនេះហើយ បានជាសាសនទូតត្រូវរៀនអំពីមុខវិជ្ជាសាសនទូតជាចាំបាច់បំផុត ពោលគឺរៀនឲ្យស្គាល់លទ្ធិ និងសេចក្តីណែនាំរបស់ព្រះសហគមន៍អំពីកិច្ចប្រកាសដំណឹងល្អ និងស្គាល់របៀបអ្នកនាំដំណឹងល្អបានប្រព្រឹត្តតាមសតវត្សមុនៗដែរ។ គេក៏ត្រូវស្គាល់សភាពការណ៍បច្ចុប្បន្ននៃព្រះសហគមន៍ក្នុងប្រទេស ដែលមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។ នៅពេលជាមួយគ្នានេះ គេត្រូវស្គាល់វិធីដែលស័ក្តិសិទ្ធិជាងគេសព្វថ្ងៃ តាមការយល់ឃើញរបស់សាសនទូត។

ទោះបីក្នុងការអប់រំដែលមានលក្ខណៈសព្វគ្រប់បែបនេះ សាសនទូតត្រូវយកកចិត្តទុកដាក់ នឹងការណែនាំគ្រីស្តបរិស័ទក្តី ក៏គាត់ត្រូវទទួលការអប់រំយ៉ាងពិសេស និងចាត់ចែងយ៉ាងត្រឹមត្រូវ អំពីកិច្ចការជាគ្រីស្តទូត ដោយមានគេបង្រៀនផង និងដោយគាត់ធ្វើការអនុវត្តន៍ផងដែរ (ហ្វឹកហ្វឺន ១៩-២១)។

ត្រូវឲ្យបព្វជិតបព្វជិតាមួយចំនួនធំ តាមលទ្ធភាពអាចធ្វើបាន ទទួលការអប់រំយ៉ាងសមរម្យអំពីវិធីអប់រំជំនឿ ដើម្បីឲ្យគេអាចរួមសហការកាន់តែខ្លាំងឡើងៗក្នុងកិច្ចការជាគ្រីស្តទូត។ សូម្បីតែអស់អ្នកដែលបំពេញតួនា ទីមួយផ្នែកក្នុងសកម្មភាពជាសាសនទូតតែមួយរយៈពេលប៉ុណ្ណោះ ក៏ត្រូវទទួលការអប់រំស្របតាមសភាពការណ៍របស់ខ្លួនដែរ។

លើសពីការអប់រំគ្រប់យ៉ាងនោះ កាលសាសនទូតរស់នៅក្នុងប្រទេសដែលព្រះសហគមន៍ចាត់ឲ្យទៅនោះ ក៏ត្រូវទទួលការអប់រំបន្ថែម ពោលគឺ ត្រូវឲ្យសាសនទូតស្គាល់ប្រវត្តិសាស្ត្រកាន់តែច្បាស់ ស្គាល់រចនាសម្ពន្ធក្នុងសង្គម និង

ប្រពៃណីប្រជាជនទាំងនោះ។ ត្រូវឲ្យសាសនទូតយល់សីលធម៌ និងវិន័យខាងសាសនារបស់ប្រជាជននោះ ព្រមទាំងស្គាល់គោលគំនិតកប់ក្នុងចិត្តតាមប្រពៃណីដ៏សក្ការៈរបស់គេ អំពីព្រះជាម្ចាស់ អំពីពិភពលោក និងអំពីមនុស្សដែរ។ ត្រូវឲ្យសាសនទូតរៀនភាសាប្រជាជននោះ រហូតដល់អាចនិយាយយ៉ាងស្រួល និងត្រឹមត្រូវ ដើម្បីឲ្យគេមានផ្លូវចាប់ចិត្តនិងគំនិតរបស់គេ។ លើសពីនេះទៅទៀត ត្រូវណែនាំឲ្យសាសនទូតស្គាល់តម្រូវការពិសេសក្នុងកិច្ចណែនាំគ្រីស្តបរិស័ទ ក្នុងប្រទេសនោះ។

ត្រូវអប់រំសាសនទូតខ្លះឲ្យបានជ្រៅ នៅគ្រឹះស្ថានសម្រាប់បង្រៀនមុខវិជ្ជាជាសាសនទូត ឬនៅមហាវិទ្យាល័យ ឬនៅសកលវិទ្យាល័យផ្សេងៗ ដើម្បីឲ្យគេអាចបំពេញមុខងារពិសេសយ៉ាងសកម្ម។ ដោយគេមានចំណេះវិជ្ជាខ្ពស់ដូច្នេះ គេមានសមត្ថភាពអាចជួយសាសនទូតឯទៀតៗក្នុងសកម្មភាពជាសាសនទូតរបស់អស់លោកដែលកាន់តែចាំបាច់ ប៉ុន្តែកាន់តែពិបាកក្នុងពិភពលោកនាបច្ចុប្បន្ន។ ម្យ៉ាងទៀត គួរឲ្យក្រុមអភិបាលតាមតំបន់ មានអ្នកជំនាញការបែបនេះ កាន់តែច្រើនឡើង ដើម្បីយកចំណេះវិជ្ជា និងបទពិសោធន៍របស់គេមកប្រើ ដើម្បីរកដំណោះស្រាយបញ្ហាដ៏ពិបាក ដែលអស់លោកជួបប្រទះក្នុងការបំពេញបន្ទុករបស់អស់លោក។ ត្រូវមានមនុស្សដែលចេះប្រើគ្រឿងបច្ចេកទេស និងមធ្យោបាយទូរគមនាគមន៍ក្នុងសង្គម ដែលអស់លោកត្រូវយល់ថា មានសារៈសំខាន់យ៉ាងខ្លាំងក្នុងកិច្ចបំពេញបេសកកម្មរបស់អស់លោក។

## ២៧-គ្រឹះស្ថានដែលបំពេញសកម្មភាពក្នុងប្រទេសមានមនុស្សភាគច្រើនដែលមិនស្គាល់ព្រះគ្រីស្ត

ទោះបីអ្នកដែលត្រូវគេចាត់ឲ្យទៅប្រកាសដំណឹងល្អដល់សាសន៍ដទៃ ត្រូវការការអប់រំទាំងប៉ុន្មានខាងលើនេះជាចាំបាច់បំផុតក្តី ក៏បុគ្គលម្នាក់ៗដូចជាពិបាកសម្រេចដោយខ្លួនឯងឲ្យមានប្រសិទ្ធភាពយ៉ាងពិតប្រាកដ។ តាមបទពិសោធន៍ ក៏គ្មាននរណាម្នាក់អាចបំពេញកិច្ចការជាសាសនទូត ដោយម្នាក់ឯងដាច់ពីគេបានដែរ។ ហេតុនេះហើយ បានជាព្រះជាម្ចាស់ ត្រាស់ហៅមនុស្សខ្លះឲ្យចូលរួមក្នុងគ្រឹះស្ថានផ្សេងៗ។ ដោយអ្នកទាំងនោះរួមកម្លាំងគ្នា គេអាចទទួលការអប់រំត្រឹមត្រូវស្របតាមតម្រូវការ ហើយក៏អាចបំពេញបេសកកម្មនេះក្នុងនាមព្រះសហគមន៍បាន និងតាមបំណងប្រាថ្នាក្រុមអភិបាលផងដែរ។ តាំងពីយូរសតវត្សមក សមាជិកគ្រឹះស្ថានទាំងនោះនឿយហត់ហាលថ្ងៃហាលក្តៅ ឬជាកម្លាំងកាយ កម្លាំងចិត្តទាំងស្រុង បម្រើកិច្ចប្រកាសដំណឹងល្អ ឬក៏បម្រើកិច្ចការនេះតែមួយផ្នែកដែរ។ ជួនកាលសន្តះអាសនៈផ្ញើតំបន់ដ៏ធំសម្បើមឲ្យគ្រឹះស្ថានទាំងនោះប្រកាសដំណឹងល្អ។ សមាជិកគ្រឹះស្ថានទាំងនោះ បានប្រមូលប្រជារាស្ត្រថ្មីថ្វាយព្រះជាម្ចាស់ ពោលគឺព្រះសហគមន៍តាមតំបន់នោះ ដែលសព្វថ្ងៃ ភ្ជាប់ចិត្តនឹងគង្វាលទាំងប៉ុន្មានរបស់ខ្លួន។ គេតែងតាំងព្រះសហគមន៍ផ្សេងៗដោយបែកញើសហូរញើស ហើយលើសពីនេះទៅទៀត ដោយបានបូជាជីវិតដែរ។ សព្វថ្ងៃ គេយកបទពិសោធន៍របស់គេមកបម្រើព្រះសហគមន៍ទាំងនោះ ទាំងខ្នះខ្នែងរួមសហការជាមួយព្រះសហគមន៍តាមតំបន់ដូចបងប្អូន ឬទទួលខុសត្រូវណែនាំគ្រីស្តបរិស័ទឬបំពេញបន្ទុកពិសេសដើម្បីជាប្រយោជន៍រួម។

ជួនកាលសមាជិកគ្រឹះស្ថានទាំងនោះទទួលខុសត្រូវបំពេញកិច្ចការខ្លះដ៏បន្ទាន់បំផុត សម្រាប់តំបន់មួយទាំងមូល ឧបមាថា ការប្រកាសដំណឹងល្អដល់ក្រុមមនុស្សពិសេសមួយ ឬដល់ប្រជាជនមួយដែលមិនទាន់ទទួលដំណឹងល្អ ដោយមូលហេតុផ្សេងៗ ឬដែលជំទាស់នឹងដំណឹងល្អនេះ តាំងពីដើមរៀងមក (គង្វាល ១០)។

ប្រសិនមានតម្រូវការ សមាជិកគ្រឹះស្ថានទាំងនោះ ត្រូវប្រុងខ្លួនសុខចិត្តជួយអប់រំអស់អ្នកដែលស្ម័គ្រចិត្តបំពេញសកម្មភាពជាសាសនទូតតែមួយរយៈពេល ដោយចែករំលែកបទពិសោធន៍របស់ខ្លួនឲ្យគេ។

ដោយមូលហេតុទាំងអស់ខាងលើនេះ និងដោយមានប្រជាជនជាច្រើនទៀត ដែលត្រូវនាំមករកព្រះគ្រីស្ត ព្រះសហគមន៍នៅតែត្រូវការគ្រឹះស្ថានទាំងនោះជាចាំបាច់បំផុត។

# ជំពូក ៥

## ការចាត់ចែងសកម្មភាពជាសាសនទូត

### សេចក្ដីផ្ដើម

២៨-គ្រីស្ដបរិស័ទទទួលព្រះអំណោយទានផ្សេងៗពីគ្នា (រម ១២, ៦)។ ហេតុនេះហើយ បានជាគេត្រូវរួមសហការគ្នាក្នុងកិច្ចប្រកាសដំណឹងល្អ គឺម្នាក់ៗតាមលទ្ធភាព តាមធនធាន តាមព្រះអំណោយទាន និងតាមមុខងារបម្រើរៀងៗខ្លួន (១ករ ៣, ១០)។ គ្រីស្ដបរិស័ទទាំងអស់ គឺទាំងអ្នកសាបព្រោះ ទាំងអ្នកច្រូតកាត់ (យហ ៤, ៣៧) ទាំងអ្នកដាំ ទាំងអ្នកស្រោចទឹក ត្រូវរួបរួមគ្នាជាធ្លុងតែមួយ (១ករ ៣, ៨) ដើម្បី *"ខិតខំរួមគ្នាដោយស្ម័គ្រចិត្ត និងដោយមានសណ្ដាប់ធ្នាប់ទៅរកទិសដៅតែមួយ"* (ពន្លឺ ១៨)។ គេក៏ត្រូវមានចិត្តថ្លើមតែមួយ ចំណាយកម្លាំងរបស់ខ្លួនកសាងព្រះសហគមន៍ដែរ។

ហេតុនេះហើយ បានជាត្រូវតម្រែតម្រង់កិច្ចការរបស់អ្នកប្រកាសដំណឹងល្អ និងជំនួយគ្រីស្ដបរិស័ទឯទៀតៗ ឲ្យភ្ជាប់រួមជាមួយគ្នា ដើម្បីឲ្យ *"គេធ្វើការទាំងអស់នោះ ដោយមានសណ្ដាប់ធ្នាប់"* (១ករ ១៤, ៤០) និងឲ្យរួមសហការគ្នាក្នុងគ្រប់វិស័យនៃសកម្មភាពជាសាសនទូតផង។

### ២៩-ការចាត់ចែងជាទូទៅ

ក្រុមអភិបាលទាំងមូលទទួលភារកិច្ចប្រកាសដំណឹងល្អនៅលើផែនដីទាំងមូល (ពន្លឺ ២៣)។ ហេតុនេះហើយ បានជាសន្និបាតរបស់អស់លោកអភិបាល ឬ *"ក្រុមប្រឹក្សាអចិន្ត្រៃយ៍របស់អភិបាលនៃព្រះសហគមន៍សកល"* ក្នុងចំណោមកិច្ចទូទៅរបស់អស់លោក ត្រូវយកចិត្តទុកដាក់យ៉ាងពិសេស នឹងសកម្មភាពជាសាសនទូតទុកជាភារកិច្ចមួយដ៏សំខាន់បំផុត និងជាភារកិច្ចដ៏សក្ការៈបំផុតរបស់ព្រះសហគមន៍។

ត្រូវឲ្យមានក្រសួងតែមួយ ដែលមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងតំបន់ទាំងប៉ុន្មាន ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ដ និងសម្រាប់ណែនាំសកម្មភាពជាសាសនទូតគ្រប់យ៉ាងគឺ *"ក្រសួងផ្សព្វផ្សាយជំនឿ"*។ ក្រសួងនោះត្រូវណែនាំ និងចាត់ចែងកិច្ច និងសកម្មភាពជាសាសនទូតទាំងនោះនៅលើផែនដីទាំងមូល ឲ្យរួមសហការគ្នា។ ក៏ប៉ុន្តែ ត្រូវគោរពសិទ្ធិព្រះសហគមន៍នៅមជ្ឈិមបូព៌ាទុកដោយឡែក។

ព្រះវិញ្ញាណដាស់តឿនគ្រីស្ដបរិស័ទ តាមរបៀបផ្សេងៗពីគ្នាក្នុងព្រះសហគមន៍របស់ព្រះជាម្ចាស់ ឲ្យគេមានគំនិតជាសាសនទូត។ ជារឿយៗព្រះវិញ្ញាណតែងតែមានសកម្មភាព មុនអស់លោកដែលមានមុខងារណែនាំការរស់នៅរបស់ព្រះសហគមន៍ទៅទៀត។ ក៏ប៉ុន្តែ តាមតែខ្លួនអាចធ្វើបាន ក្រសួងនោះត្រូវខិតខំជួយឲ្យមានគ្រីស្ដបរិស័ទខ្លះតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគេឲ្យទៅជាសាសនទូត និងផ្សព្វផ្សាយចិត្តគំនិតជាសាសនទូតផងដែរ។ ក្រសួងនោះត្រូវខិតខំនាំឲ្យគ្រីស្ដបរិស័ទមានចិត្តខ្នះខ្នែង និងអង្វរព្រះជាម្ចាស់សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍នៅតំបន់ ដែល

មានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។ ត្រូវបោះពុម្ពផ្សាយដំណឹងផ្សេងៗដ៏ពិតប្រាកដ ហើយដែលមានសារៈសំខាន់អំពីព្រះសហគមន៍ទាំងនោះទៀតដែរ។ ក្រសួងនោះ ត្រូវដាស់តឿនឲ្យមានសាសនទូតច្រើន ព្រមទាំងចែកសាសនទូតទាំងនោះតាមតម្រូវការដ៏សំខាន់ជាងគេនៃតំបន់នានា។ ក្រសួងនេះ ត្រូវចាត់ចែងផែនការណ៍ប្រកបដោយប្រាជ្ញា ដើម្បីឲ្យសាសនទូតប្រព្រឹត្តសកម្មភាព។ ក្រសួងនោះ ត្រូវបញ្ចេញសេចក្ដីណែនាំ និងគោលការណ៍សម្រាប់ការប្រកាសដំណឹងល្អ ឲ្យបានសមស្របតាមសភាពការណ៍ ព្រមទាំងត្រូវជំរុញគ្រីស្តបរិស័ទក្នុងកិច្ចប្រកាសដំណឹងល្អនោះ។ ក្រសួងនោះត្រូវចាត់ចែងការរៃប្រាក់យ៉ាងសកម្ម និងដោយរួមសហការគ្នា ព្រមទាំងចែករំលែកធនធានទាំងនោះតាមសេចក្ដីត្រូវការ តាមប្រយោជន៍ និងតាមទំហំតំបន់ទាំងនោះ ស្របតាមចំនួនគ្រីស្តបរិស័ទ និងចំនួនអ្នកកាន់សាសនាដទៃ តាមកិច្ចការផ្សេងៗ តាមគ្រឹះស្ថាន តាមចំនួនអ្នកបម្រើព្រះសហគមន៍ និងតាមចំនួនសាសនទូតដែរ។

ក្រសួងផ្សព្វផ្សាយជំនឿនេះ ត្រូវរួមសហការជាមួយក្រសួងបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាផ្លូងតែមួយ ដើម្បីជួយរកផ្លូវ និងមធ្យោបាយចាត់ចែងការសហការជាមួយគ្រីស្តបរិស័ទនិកាយផ្សេងៗទុកជាបងប្អូន។ ត្រូវរួបរួមជាមួយក្រុមជំនុំគ្រីស្តបរិស័ទផ្សេងៗ ដែលបង្កើតសកម្មភាពជាសាសនទូត មិនត្រូវទាស់ទែងគ្នា ក្នុងគោលបំណងផ្សះផ្សាគ្នា ប្រសិនបើអាចធ្វើបាន ព្រោះការបែបបាក់គ្នានេះជាមូលហេតុរាំងមិនឲ្យមនុស្សជឿលើព្រះគ្រីស្តបាន។

ហេតុនេះហើយ បានជាក្រសួងនោះត្រូវជាអង្គភាពរដ្ឋបាលផង និងត្រូវជាអង្គភាពចាត់ចែងដែលមានជីវិតរស់រវើកផង។ ត្រូវប្រើវិធីបែបវិទ្យាសាស្ត្រ និងប្រើមធ្យោបាយស្របតាមសភាពការណ៍នាបច្ចុប្បន្នកាលយើងនេះ គឺថា ត្រូវគិតគូរដល់អ្នកសិក្សាស្វែងរកតាមទេវវិទ្យា តាមវិជ្ជាចាត់ចែងវិធី និងតាមវិជ្ជាណែនាំគ្រីស្តបរិស័ទឲ្យទៅជាសាសនទូតផងដែរ។

អស់លោកដែលរួមសហការក្នុងកិច្ចការជាសាសនទូត ត្រូវជ្រើសរើសតំណាងឲ្យចូលក្នុងអង្គភាពណែនាំក្រសួងនោះ គឺអភិបាលជាតំណាងមកពីសកលលោកទាំងមូល ដើម្បីឲ្យក្រសួងស្ដាប់យោបល់ក្រុមអភិបាលតាមប្រទេសនានា។ ត្រូវមានមេដឹកនាំខ្លះនៃគ្រឹះស្ថាននានា ព្រមទាំងមេដឹកនាំនៃក្រុម «កិច្ចការសាសនទូតរបស់អភិបាលក្រុងរ៉ូម»។ តំណាងទាំងនោះ ត្រូវរួមចំណែកក្នុងការណែនាំក្រសួងយ៉ាងសកម្ម ដោយមានសម្លេងអាចសម្រេចសេចក្ដីបានផង។ ត្រូវជ្រើសរើសតំណាងទាំងនោះតាមរបៀប និងតាមវិធីអភិបាលព្រះសហគមន៍ក្រុងរ៉ូមនឹងចាត់ចែងនៅពេលខាងមុខ។ ត្រូវកោះហៅតំណាងទាំងនោះឲ្យជួបជុំគ្នាតាមពេលកំណត់។ តំណាងទាំងនោះត្រូវចាត់ចែងខាងលើបំផុត នូវកិច្ចជាសាសនទូតទាំងមូល ក្រោមអំណាចអភិបាលព្រះសហគមន៍ក្រុងរ៉ូម។

ក្រសួងនេះ ត្រូវតែមានក្រុមអចិន្ត្រៃយ៍របស់អ្នកជំនាញការផ្ដល់យោបល់ ជាអ្នកមានចំណេះជ្រៅជ្រះ និងមានបទពិសោធន៍ជាខ្លាំង។ ក្នុងចំណោមកិច្ចការឯទៀតៗ ក្រុមនោះមានតួនាទីប្រមូលពត៌មានសមរម្យ អំពីសភាពការណ៍ តាមតំបន់នីមួយៗ និងតាមមតិរបស់ក្រុមមនុស្សផ្សេងៗអំពីវិធីប្រកាសដំណឹងល្អដែលត្រូវប្រើទៀតដែរ។ ក្រុមនោះត្រូវផ្ដល់សេចក្ដី សន្និដ្ឋានបែបវិទ្យាសាស្ត្រ សម្រាប់ធ្វើកិច្ចការជាសាសនទូត និងឲ្យមានការរួមសហការគ្នាក្នុងកិច្ចការនោះ។ ត្រូវមានតំណាងគ្រឹះស្ថានបព្វជិតា តំណាងក្រុមនានាតាមតំបន់ដែលជួយព្រះសហគមន៍នៅប្រទេស ដែលមានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត និងតំណាងអង្គការគ្រីស្តបរិស័ទធម្មតា ជាពិសេសតំណាងអង្គការអន្តរជាតិចូលរួមក្នុងក្រសួងនេះតាមការគួរ។

## ៣០-ការចាត់ចែងតាមតំបន់មនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត

អស់អ្នកដែលចូលរួមក្នុងកិច្ចបំពេញសកម្មភាពជាសាសនទូត ត្រូវមាន *"ចិត្តថ្លើមតែមួយ"* (កក ៤, ៣២) ដើម្បី

ឲ្យកិច្ចប្រកាសដំណឹងល្អនោះ បានលទ្ធផលតាមគោលដៅ។ អភិបាលជាមេដឹកនាំ និងជាអ្នកធ្វើឲ្យកិច្ចការជាគ្រីស្តទូតទាំងអស់ក្នុងភូមិភាគរួមសហការគ្នា។ លោកមានភារកិច្ចជំរុញសកម្មភាពជាសាសនទូត និងណែនាំសកម្មភាពនោះ ហើយចាត់ចែងឲ្យមានការរួមសហការគ្នា។ ក៏ប៉ុន្តែលោកត្រូវរក្សាទុក និងលើកទឹកចិត្តរបស់អ្នកដែលមានគំនិតផុសឡើងថ្មីដោយខ្លួនឯង ក្នុងកិច្ចការនេះដែរ។ អស់សាសនទូត សូម្បីតែបព្វជិតបព្វជិតាដែលមិនស្ថិតនៅក្រោមអំណាចរបស់អភិបាល ក៏ត្រូវសុខចិត្តធ្វើតាមបង្គាប់របស់លោក ក្នុងកិច្ចការទាំងប៉ុន្មានដែលពាក់ព័ន្ធនឹងមុខងារដ៏សក្ការៈជាគ្រីស្តទូតដែរ (អភិបាល ៣៥.៤)។ លោកអភិបាលត្រូវចាត់ចែងឲ្យមានក្រុមប្រឹក្សាណែនាំមួយ ដើម្បីពង្រឹងការរួមសហការនោះ ដោយមានតំណាងរបស់ក្រុមគង្វាល តំណាងរបស់បព្វជិតបព្វជិតា និងតំណាងរបស់គ្រីស្តបរិស័ទធម្មតាចូលរួមផង ដើម្បីឲ្យការរួមសហការកាន់តែល្អឡើងៗ។ លោកអភិបាលត្រូវយកចិត្តទុកដាក់ចាត់ចែងកិច្ចប្រកាសដំណឹងល្អ មិនគ្រាន់តែសំដៅចំពោះអ្នកដែលប្រែចិត្តគំនិតជឿលើព្រះគ្រីស្តប៉ុណ្ណោះទេ តែត្រូវចែករំលែកចំនួនអ្នកប្រកាសដំណឹងល្អ និងចែករំលែកចំនួនធនធានស្មើភាគគ្នាសម្រាប់បំពេញកិច្ចប្រកាសដំណឹងល្អដល់អ្នកមិនកាន់គ្រីស្តសាសនាដែរ។

## ៣១-ការរួមសហការតាមតំបន់

ក្រុមអភិបាលក្នុងប្រទេសនានា ត្រូវតែសម្រេចបញ្ហាដ៏ធ្ងន់ធ្ងរនិងបញ្ហាបន្ទាន់ជាងគេ ដោយរិះគិតរួមគ្នា និងព្រមព្រៀងគ្នា ក៏ប៉ុន្តែមិនត្រូវបំភ្លេចថា ភូមិភាគមានសភាពការណ៍ប្លែកៗពីគ្នាដែរ (អភិបាល ៣៦-៣៨)។ មហាសន្និបាតទូន្មានឲ្យក្រុមអភិបាលរួមកម្លាំង បង្កើតកិច្ចការផ្សេងៗដើម្បីជាប្រយោជន៍រួម ពោលគឺ ត្រូវមានទេវវិទ្យាល័យ សាលារៀនកម្រិតឧត្តម និងសាលាបច្ចេកទេស មជ្ឈមណ្ឌលណែនាំគ្រីស្តបរិស័ទ មជ្ឈមណ្ឌលបង្រៀនអ្នកអប់រំជំនឿ មជ្ឈមណ្ឌលអប់រំអំពីធិគោរពប្រណិប័តន៍ ព្រមទាំងមជ្ឈមណ្ឌលមធ្យោបាយទូរគមនាគមន៍ក្នុងសង្គម។ ធ្វើដូច្នេះ អស់លោកជៀសវាងការប្រើធនធានមនុស្ស និងធនធានសម្ភារៈដែលមានមិនគ្រប់គ្រាន់ផង ដោយខ្ជះខ្ជាយ ហើយក៏ជៀសវាងការបង្កើតអ្វីៗដែលមិនសូវត្រូវការប៉ុន្មាន។

ត្រូវចាត់ចែងការសហការបែបនេះយ៉ាងសមគួរតាមសេចក្តីត្រូវការ សូម្បីតែក្រុមអភិបាលព្រះសហគមន៍ ក្នុងប្រទេសនានា ក៏ត្រូវរួមសហការរបៀបនេះដែរ។

## ៣២-ការចាត់ចែង និងសកម្មភាពគ្រឹះស្ថានរបស់សាសនទូត

ត្រូវចាត់ចែងសកម្មភាពដែលគ្រឹះស្ថាន និងសមាគមនានាខាងព្រះសហគមន៍បំពេញនោះ ឲ្យរួមសហការគ្នា។ ការសហការដូច្នេះពិតជាមានប្រយោជន៍មែន។ ទោះជាគ្រឹះស្ថាននិងសមាគមទាំងនោះ ជាគ្រឹះស្ថាននិងជាសមាគមបែបណាក៏ដោយ ក៏ត្រូវធ្វើតាមបង្គាប់អភិបាលភូមិភាគគ្រប់ៗគ្នា ក្នុងគ្រប់ករណីដែលពាក់ព័ន្ធនឹងកិច្ចប្រកាសដំណឹងល្អ។ ហេតុនេះ អភិបាលនិងមេដឹកនាំគ្រឹះស្ថាននីមួយៗ ត្រូវចាត់ចែងការព្រមព្រៀងដោយឡែក សម្រាប់ណែនាំទំនាក់ទំនងជាមួយគ្នា។

ប្រសិនបើសន្តះអាសនៈផ្ញើតំបន់មួយឲ្យគ្រឹះស្ថានណាមួយ មេដឹកនាំព្រះសហគមន៍ក្នុងតំបន់នោះ និងគ្រឹះស្ថាននោះ ត្រូវយកចិត្តទុកដាក់ចាត់ចែងអ្វីៗទាំងអស់ឲ្យតម្រែតម្រង់ទៅរកគោលដៅតែមួយ គឺជួយឲ្យ សហគមន៍គ្រីស្តបរិស័ទថ្មីនោះចម្រើនឡើង និងក្លាយទៅជាព្រះសហគមន៍តាមតំបន់ នៅពេលក្រោយដែលមានអភិបាលកើតពីប្រជាជននោះណែនាំ តាមរការសមរម្យ ដោយមានក្រុមគង្វាលរបស់លោកជាសហការីផង។

ពេលគ្រឹះស្ថានណាផុតអាណត្តិប្រកាសដំណឹងល្អនៅតំបន់មួយ សភាពការណ៍ថ្មីមួយកើតឡើង ពេលនោះក្រុមអភិបាល និងគ្រឹះស្ថាននានាត្រូវពិគ្រោះគ្នា និងចាត់ចែងសេចក្តីណែនាំក្នុងទំនាក់ទំនងរវាងអភិបាលភូមិភាគ និងគ្រឹះស្ថានទាំងនោះ (អភិបាល ៣៥, ៥-៦)។ សន្តះអាសនៈត្រូវគ្រោងទុកគោលការណ៍ទូទៅសម្រាប់ឲ្យក្រុមអភិបាល និងគ្រឹះស្ថាននានាធ្វើការព្រមព្រៀងគ្នាតាមតំបន់ ឬការព្រមព្រៀងដោយឡែកផង។

ទោះបីគ្រឹះស្ថាននានា ប្រុងខ្លួនបន្តកិច្ចការដែលគេចាប់ផ្តើមធ្វើនោះ ដោយរួមសហការក្នុងកិច្ចបំពេញមុខងារបម្រើគ្រីស្តបរិស័ទជាធម្មតាក្តី ក៏នៅពេលក្រុមគង្វាលដែលកើតក្នុងប្រទេសនោះបានចម្រើនចំនួនឡើងហើយ គ្រឹះស្ថាននានាត្រូវតែស្ថិតនៅក្នុងភូមិភាគនោះដដែលដោយចិត្តទូលាយ ទាំងបំពេញកិច្ចពិសេស ឬណែនាំតំបន់ខ្លះៗ ប្រសិនបើគេអាចធ្វើបាន ស្របតាមគោលដៅរបស់គ្រឹះស្ថានទាំងនោះ។

## ៣៣-គ្រឹះស្ថាននានាត្រូវរួមសហការគ្នា

គ្រឹះស្ថាននានាដែលបំពេញសកម្មភាពជាសាសនទូតក្នុងតំបន់តែមួយ ត្រូវរកមធ្យោបាយនិងវិធីឲ្យគេបំពេញសកម្មភាពដោយរួមសហការគ្នា។ ហេតុនេះហើយបានជាក្រុមបព្វជិត និងសហព័ន្ធបព្វជិតាដែលមានគ្រឹះស្ថានទាំងអស់ក្នុងប្រទេសមួយ ឬក្នុងតំបន់មួយចូលរួម មានប្រយោជន៍ខ្លាំងណាស់។ ក្រុមទាំងនោះ ត្រូវស្វែងរកកិច្ចដែលគេអាចធ្វើបាន ដោយរួមកម្លាំងគ្នា ហើយក៏ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមអភិបាលប្រទេសនោះផងដែរ។ ដោយមូលហេតុដូចខាងលើ ត្រូវចាត់ចែងឲ្យគ្រឹះស្ថានរបស់សាសនទូត រួមសហការគ្នាក្នុងស្រុកកំណើតរបស់គេ តាមបែបដដែលនេះ។ ដូច្នេះ គេអាចដោះស្រាយបញ្ហានិងកិច្ចការដែលគេផ្តើមគំនិតធ្វើរួមគ្នា ឲ្យបានងាយស្រួល និងដោយសន្សំកម្លាំង ពោលគឺ ការអប់រំសាសនទូតខាងគោលលិទ្ធិនៃគ្រីស្តសាសនា ការចាត់ចែងសិក្ខាសាលាសម្រាប់សាសនទូត និងសេចក្តីរាយការណ៍ដែលត្រូវផ្ញើដល់រដ្ឋអំណាច ឬដល់អង្គការអន្តរជាតិជាដើម។

## ៣៤-គ្រឹះស្ថានវិទ្យាសាស្រ្តត្រូវរួមសហការគ្នា

ត្រូវតែអប់រំសាសនទូតតាមបែបវិទ្យាសាស្រ្ត ដើម្បីឲ្យគេអាចបំពេញបេសកកម្មរបស់ខ្លួនបាន តាមរបៀបជាធម្មតា និងមានសណ្តាប់ធ្នាប់។ ជាពិសេសត្រូវហ្វឹកហ្វឺនសាសនទូត ឲ្យគេចេះរិះគិតអំពីទំនាក់ទំនងគ្រីស្តសាសនានឹងសាសនាដទៃ ហើយជាមួយអរិយធម៌ឯទៀតៗ ហើយក៏ត្រូវជួយគេយ៉ាងសកម្មក្នុងពេលគេទាក់ទងជាមួយសាសនា និងអរិយធម៌ទាំងនោះដែរ។ មហាសន្និបាតសំណូមពរឲ្យ គ្រឹះស្ថាននានាដែលសិក្សាវិជ្ជាជាសាសនទូត និងមុខវិជ្ជាផ្សេងទៀត ឬបច្ចេកទេសដែលមានប្រយោជន៍សម្រាប់ប្រទេសដែលមានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត រួមសហការក្នុងការហ្វឹកហ្វឺនអំពីការសិក្សាខាងជាតិសាសន៍ ភាសាវិទ្យា ប្រវត្តិវិទ្យា សង្គមវិទ្យា វិជ្ជាណែនាំគ្រីស្តបរិស័ទ និងវិទ្យាផ្សេងៗទៀតដែលស្រដៀងគ្នា។ ដោយគ្រឹះស្ថានទាំងនោះរួមសហការគ្នាដូច្នេះ ទើបគេអាចជួយសាសនទូតឲ្យបំពេញបេសកកម្មរបស់ខ្លួន និងជួយព្រះសហគមន៍ក្នុងតំបន់ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្តដែរ។

# ជំពូក ៦

# សហប្រតិបត្តិការ

## ៣៥-សេចក្ដីផ្ដើម

ព្រះសហគមន៍ទាំងមូលមានលក្ខណៈជាសាសនទូត។ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក៏មានភារកិច្ចចម្បង គឺប្រកាសដំណឹងល្អដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធ អញ្ជើញគ្រីស្តបរិស័ទទាំងអស់ឲ្យប្រែចិត្តគំនិតទាំងស្រុង សូមភ្ញាក់ស្មារតីឡើងដឹងខ្លួនឲ្យច្បាស់ថា ខ្លួនត្រូវទទួលខុសត្រូវក្នុងកិច្ចផ្សព្វផ្សាយដំណឹងល្អ។ ខ្លួនក៏ត្រូវបំពេញមុខងារមួយផ្នែករបស់ខ្លួនផ្ទាល់ ក្នុងកិច្ចការជាសាសនទូតនៅចំពោះអ្នកដែលមិនកាន់គ្រីស្តសាសនាដែរ។

## ៣៦-ប្រជារាស្ត្រព្រះជាម្ចាស់ទាំងមូលមានភារកិច្ចជាសាសនទូត

គ្រីស្តបរិស័ទក្នុងឋានៈជាសិរីរាង្គរបស់ព្រះគ្រីស្តដែលមានព្រះជន្មគង់នៅ បានចូលរួមក្នុងព្រះកាយព្រះគ្រីស្តនោះ និងបានដូចព្រះអង្គ ដោយទទួលអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស និងអគ្គសញ្ញាអរព្រះគុណ។ ហេតុនេះហើយ បានជាគ្រីស្តបរិស័ទទាំងអស់ មានភារកិច្ចរួមសហការលាតសន្ធឹងព្រះកាយព្រះគ្រីស្តឲ្យចម្រើនឡើង ដើម្បីធ្វើឲ្យព្រះកាយនោះបានបំពេញអ្វីៗទាំងអស់នៅពេលឆាប់ៗ (អភ ៤, ១៣)។

ហេតុនេះហើយ បានជាគ្រីស្តបរិស័ទទាំងអស់ ត្រូវភ្ញាក់ស្មារតីឡើងដឹងខ្លួនយ៉ាងច្បាស់ថា គេត្រូវទទួលខុសត្រូវចំពោះមនុស្សលោក។ គេត្រូវពង្រឹងចិត្តគំនិតជាកាតូលិក គឺចិត្ត *"សកល"* យ៉ាងពិតប្រាកដ យកចិត្តទុកដាក់នឹងមនុស្សទាំងអស់ក្នុងសកលលោក និងចំណាយកម្លាំងរបស់ខ្លួនក្នុងកិច្ចប្រកាសដំណឹងល្អ។ ប៉ុន្តែ គេត្រូវដឹងទាំងអស់គ្នាថា ភារកិច្ចចម្បងដ៏សំខាន់ជាងគេបំផុតក្នុងកិច្ចផ្សព្វផ្សាយជំនឿ គឺឲ្យគេរស់នៅបែបល្អប្រសើរជាគ្រីស្តបរិស័ទ។ ប្រសិនបើគេយកចិត្តទុកដាក់បម្រើព្រះជាម្ចាស់យ៉ាងខ្លាំង និងមានចិត្តស្រឡាញ់អ្នកដទៃ គេមុខជានឹងនាំកម្លាំងខាងព្រះវិញ្ញាណមកព្រះសហគមន៍ទាំងមូលពុំខាន។ ពេលនោះ ព្រះសហគមន៍ក៏នឹងលេចធ្លោឡើង ទុកជាទង់ជាសញ្ញាសម្គាល់មួយក្នុងចំណោមប្រជាជាតិទាំងឡាយ (អស ១១, ១២) និងជា *"ពន្លឺសម្រាប់បំភ្លឺមនុស្សលោក"* (មថ ៥, ១៤) ហើយ *"ជាអំបិលសម្រាប់មនុស្សលោក"* (មថ ៥, ១៣)។ ប្រសិនបើ គ្រីស្តបរិស័ទផ្តល់សក្ខីភាពដោយរស់នៅបែបនោះ រួមជាមួយក្រុមគ្រីស្តបរិស័ទនិកាយផ្សេងៗ ស្របតាមក្រឹត្យក្រមស្តីអំពីការបង្រួបបង្រួម គ្រីស្តបរិស័ទឲ្យរួមគ្នាជាធ្លុងតែមួយ (បង្រួប ១២)។ សក្ខីភាពរបស់គ្រីស្តបរិស័ទដែលរស់បែបនោះ ក៏រឹតតែបានលទ្ធផលល្អទៅទៀតផង។

គ្រីស្តបរិស័ទដែលប្រែចិត្តគំនិតជាថ្មីបែបនោះ មុខជានឹងពោលពាក្យអង្វរព្រះជាម្ចាស់ ដែលផុសឡើងឯកឯងពីក្នុងចិត្ត និងនាំឲ្យគេធ្វើកិច្ចតបធម៌ផ្សេងៗថ្វាយព្រះអង្គ សូមទ្រង់ប្រណីសន្ដោសឲ្យកិច្ចការរបស់សាសនទូតបានផលជាច្រើន។ ចិត្តគំនិតថ្មីនោះ ក៏មុខជានឹងបណ្តាលឲ្យព្រះជាម្ចាស់ត្រាស់ហៅគ្រីស្តបរិស័ទឲ្យធ្វើជាសាសនទូត និងឲ្យព្រះសហគមន៍ដែលនៅប្រទេសដែលមានមនុស្សភាគច្រើន មិនស្គាល់ព្រះគ្រីស្តបានធនធានសាសនទូតតាមតម្រូវការ។

ត្រូវប្រើមធ្យោបាយទំនើបខាងទូរគមនាគមន៍ក្នុងសង្គម ដើម្បីផ្សព្វផ្សាយពត៌មានអំពីកិច្ចការជាសាសនទូត ដើម្បីឲ្យគ្រីស្តបរិស័ទម្នាក់ៗ និងគ្រីស្តបរិស័ទទាំងអស់ ស្គាល់សភាពការណ៍បច្ចុប្បន្ននៃព្រះសហគមន៍ក្នុងពិភពលោកទាំងមូលយ៉ាងច្បាស់។ ពេលនោះ គេមុខជានឹងបានឮសម្លេងរបស់មនុស្សច្រើនអនេកស្រែកឡើងថា *"សូមមកជួយយើងផង!"* (កក ១៦, ៩) ហើយភ្ញាក់ស្មារតីថា សកម្មភាពជាសាសនទូតក៏ពិតជាសកម្មភាពរបស់ខ្លួនផ្ទាល់។ នៅពេលនោះ គេមុខជានឹងមានចិត្តទូលាយ សុខចិត្តជួយតាមតម្រូវការដ៏សម្បើមរបស់មនុស្សលោក ហើយនាំគ្នាជួយគេផងដែរ។

ត្រូវរួមសហការគ្នាក្នុងការប្រមូលពត៌មាន និងឲ្យអង្គការជាតិនិងអន្តរជាតិរួមសហការគ្នាទៀតផង។

## ៣៧-សហគមន៍គ្រីស្តបរិស័ទមានភារកិច្ចនៅជាសាសនទូត

ប្រជារាស្ត្ររបស់ព្រះជាម្ចាស់រស់នៅជាព្រះសហគមន៍ៗ ជាពិសេស គឺមានព្រះសហកមន៍ភូមិភាគ និងព្រះសហគមន៍ភូមិ។ មនុស្សលោកឃើញប្រជារាស្ត្រនេះនៅតាមសហគមន៍ទាំងនោះ។ ហេតុនេះហើយ បានជាសហគមន៍ទាំងនោះមានភារកិច្ចផ្តល់សក្ខីភាពអំពីព្រះគ្រីស្តនៅចំពោះមុខសាសន៍ដទៃ។ ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលប្រោសឲ្យសហគមន៍ទាំងនោះប្រែជាថ្មីកាន់តែខ្លាំងឡើងៗ អាចចម្រើនឡើងបានក្នុងសហគមន៍ទាំងនោះ លុះត្រាតែសហគមន៍នីមួយៗលាតសន្ធឹងសេចក្តីស្រឡាញ់របស់ខ្លួន រហូតដល់ទីដាច់ស្រយាលនៃផែនដី។ សហគមន៍ទាំងនោះក៏ត្រូវយកចិត្តទុកដាក់នឹងអ្នកដែលនៅឆ្ងាយ ដូចគេយកចិត្តទុកដាក់នឹងសមាជិករបស់ខ្លួនផ្ទាល់ដូច្នោះដែរ។

ធ្វើដូច្នេះ សហគមន៍ទាំងមូលអធិដ្ឋាន រួមសហការជាមួយគេ មានសកម្មភាពក្នុងចំណោមប្រជាជនរបស់អ្នកដែលមិនកាន់គ្រីស្តសាសនា តាមរយៈបុត្រធីតាដែលព្រះជាម្ចាស់បានជ្រើសរើស ឲ្យបំពេញបន្ទុកជាសាសនទូត ជាបន្ទុកដ៏ប្រសើរអស្ចារ្យ។

សមាគមត្រូវនៅតែមានទំនាក់ទំនងជាមួយសាសនទូតទាំងប៉ុន្មាន ដែលចេញពីសហគមន៍នោះ ឬឲ្យមានទំនាក់ទំនងជាមួយសហគមន៍មួយថ្មី និងជាមួយភូមិភាគក្នុងប្រទេសដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត ដើម្បីបង្ហាញបញ្ជាក់ថា សហគមន៍នោះទៅជាចំណងដែលគេមើលឃើញបានអំពីព្រះសហគមន៍នានារួបរួមគ្នា និងដើម្បីកសាងគ្នាទៅវិញទៅមកផង។ តែត្រូវប្រយ័ត្នកុំឲ្យសហការបែបនោះ នាំឲ្យធ្វេសប្រហែសនឹងកិច្ចការជាសាសនទូតសកលឡើយ។

## ៣៨-ភារកិច្ចរបស់អភិបាលក្នុងកិច្ចការជាសាសនទូត

អស់លោកអភិបាល ក្នុងឋានៈអស់លោកជាសមាជិកនៃក្រុមអភិបាលដែលបន្តពីក្រុមគ្រីស្តទូតមក ក៏ទទួលអគ្គសញ្ញាតែងតាំងជាអភិបាល មិនគ្រាន់តែដើម្បីណែនាំភូមិភាគមួយប៉ុណ្ណោះទេ តែដើម្បីជួយសង្គ្រោះមនុស្សលោកទាំងមូលផង។ ព្រះគ្រីស្តមានព្រះបញ្ជាឲ្យគ្រីស្តទូតប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ (មក ១៦, ១៥)។ ព្រះបញ្ជានោះសំដៅមកចំៗលើអស់លោកផ្ទាល់មុនគេ រួមជាមួយគ្រីស្តទូតសិលា ហើយក៏ក្រោមការណែនាំរបស់គ្រីស្តទូតសិលាដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍ទាំងប៉ុន្មានរួបរួមគ្នា និងសហការគ្នាជាចាំបាច់បំផុតនាបច្ចុប្បន្នកាលនេះ ដើម្បីបន្តកិច្ចប្រកាសដំណឹងល្អ។ ដោយព្រះសហគមន៍រួបរួមគ្នាដូច្នេះ ព្រះសហគមន៍នីមួយៗយកចិត្តទុកដាក់នឹងព្រះសហគមន៍ឯទៀតៗទាំងអស់។ ព្រះសហគមន៍នីមួយៗជម្រាបសេចក្តីត្រូវការរបស់ខ្លួនឲ្យគ្នាទៅវិញទៅមក និងចែករំលែកធនធានគ្នា ដ្បិតក្រុមអភិបាលទាំងមូលមានភារកិច្ចធ្វើឲ្យព្រះកាយព្រះគ្រីស្តចម្រើនឡើង (ពន្លឺ ២៣-២៤)។

អភិបាលម្នាក់ៗ រួមជាអង្គតែមួយនឹងភូមិភាគរបស់ខ្លួន។ ពេលណាលោកធ្វើឲ្យកិច្ចការជាសាសនទូត ក្នុងភូមិភាគរបស់លោកមានជីវិតរស់រវើក ពេលលោកជំរុញកិច្ចការនោះទៅមុខ ឬណែនាំកិច្ចការជាគ្រីស្តទូត ពេលនោះលោកហាក់ដូចជាបង្ហាញចិត្តគំនិតខ្នះខ្នែងរបស់ប្រជារាស្ត្រព្រះជាម្ចាស់ ដែលបំពេញកិច្ចការជាសាសនទូតឲ្យគេឃើញ។ ធ្វើដូច្នេះ លោកណែនាំឲ្យគ្រីស្តបរិស័ទទាំងអស់ក្នុងភូមិភាគទាំងមូលទៅជាសាសនទូតដែរ។

លោកអភិបាលត្រូវយកចិត្តទុកដាក់ ធ្វើឲ្យមានគ្រីស្តបរិស័ទក្នុងប្រជាជនរបស់លោក ជាពិសេសក្នុងចំណោមជនពិការ និងជនដែលកើតទុក្ខ អង្វរព្រះជាម្ចាស់ និងថ្វាយតបធម៌ទៅព្រះអង្គអស់ពីដួងចិត្ត ដើម្បីឲ្យមនុស្សលោកទទួលដំណឹងល្អ។ លោកត្រូវលើកទឹកចិត្តយុវជន និងគង្វាល ឲ្យចូលគ្រឹះស្ថានសាសនទូត ឲ្យសុខចិត្ត ទាំងអរព្រះគុណព្រះជាម្ចាស់ ដោយព្រះអង្គជ្រើសរើសអ្នកខ្លះឲ្យចូលក្នុងសកម្មភាពជាសាសនទូតរបស់ព្រះសហគមន៍សកល។ លោកត្រូវដាស់តឿន និងជួយក្រុមគ្រួសារបព្វជិតបព្វជិតាក្នុងភូមិភាគ ឲ្យបំពេញផ្នែករបស់ខ្លួនក្នុងកិច្ចការជាសាសនទូត។ លោកត្រូវណែនាំឲ្យគ្រីស្តបរិស័ទ ជួយកិច្ចការរបស់គ្រឹះស្ថានសាសនទូត ជាពិសេស «កិច្ចការសានទូតរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម»។ គួរលើកតម្កើងកិច្ចការទាំងនោះយ៉ាងខ្លាំង ព្រោះកិច្ចការទាំងនោះជាមធ្យោបាយ ធ្វើឲ្យគ្រីស្តបរិស័ទមានចិត្តគំនិតសកល និងជាសាសនទូតទៀតផង តាំងពីក្មេងមក។ «កិច្ចការជាសាសនទូតរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូម» គឺជាមធ្យោបាយប្រកបដោយប្រសិទ្ធិភាពសម្រាប់ប្រមែប្រមូលធនធាន ដើម្បីជាប្រយោជន៍ ដល់ព្រះសហគមន៍នៅតំបន់ទាំងប៉ុន្មាន ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត តាមសេចក្តីត្រូវការព្រះសហគមន៍នីមួយៗនោះ។

ត្រូវការចំនួនកម្មករធ្វើការក្នុងចម្ការរបស់ព្រះអម្ចាស់ ឲ្យកាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃ។ ម្យ៉ាងទៀត ក្នុងភូមិភាគនីមួយៗ ក៏មានបូជាចារ្យភូមិភាដែលគមានបំណងប្រាថ្នា ចង់បំពេញមុខងារក្នុងកិច្ចប្រកាសដំណឹងល្អក្នុងពិភពលោកទាំងមូលកាន់តែខ្លាំងឡើងៗដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតដាស់តឿនអស់លោកអភិបាលឲ្យរិះគិតថា ការខ្វះចំនួនបូជាចារ្យខ្លាំងពេក ជាហេតុរាំងកិច្ចប្រកាសដំណឹងល្អក្នុងតំបន់ជាច្រើន។ សូមអស់លោកសុខចិត្តចាត់បូជាចារ្យដ៏ល្អប្រសើរជាងគេពីភូមិភាគរបស់ខ្លួន ដែលសូមទៅបំពេញកិច្ចការជាសាសនទូតនោះ ឲ្យទៅក្នុងភូមិភាគដែលខ្វះគង្វាល។ ប៉ុន្តែ បូជាចារ្យទាំងនោះ ត្រូវទទួលការអប់រំតាមសេចក្តីត្រូវការជាមុនសិន។ បូជាចារ្យទាំងនោះនឹងត្រូវបំពេញមុខងារបម្រើជាសាសនទូតក្នុងតំបន់ ដែលមានមនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត យ៉ាងហោចណាស់បានមួយរយៈពេល។

ក្រុមអភិបាលក្នុងប្រទេសនីមួយៗ ត្រូវចាត់ចែងការរួមសហការឲ្យមានរបៀបរៀបរយក្នុងតំបន់របស់អស់លោក ដើម្បីឲ្យអស់លោកអាចបំពេញសកម្មភាពជាកិច្ចជាសាសនទូតយ៉ាងសកម្ម ដើម្បីជាប្រយោជន៍ដល់ព្រះសហគមន៍ទាំងមូល។

ពេលអស់លោកអភិបាលប្រជុំគ្នាជាក្រុមអភិបាល សូមចាត់ចែងអំពីបូជាចារ្យពីក្រុមគង្វាលក្នុងភូមិភាគ ដែលត្រូវចាត់ឲ្យទៅបម្រើកិច្ចប្រកាសដំណឹងល្អដល់ប្រជាជាតិទាំងឡាយ។ សូមឲ្យលោកសម្រេចចំនួនប្រាក់ ដែលភូមិភាគនីមួយៗ ត្រូវតែប្រគល់ជារៀងរាល់ឆ្នាំសម្រាប់កិច្ចការជាសាសនទូតនោះ គឺស្របតាមប្រាក់ចំណូលនៃភូមិភាគរបស់ខ្លួន (អភិបាល ៦)។ សូមសម្រេចអំពីគោលដៅ អំពីរបៀបចាត់ចែងធនធាន សម្រាប់ជួយព្រះសហគមន៍ក្នុងប្រទេសដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត។ សូមសម្រេចអំពីជំនួយសម្រាប់គ្រឹះស្ថានសាសនទូត និងសម្រាប់ទេវវិទ្យាល័យភូមិភាគនៃព្រះសហគមន៍ក្នុងប្រទេសមនុស្សភាគច្រើន មិនជឿលើព្រះគ្រីស្ត ហើយប្រសិនបើត្រូវការ ត្រូវ

សម្រេចបង្កើតទេវវិទ្យាល័យក្នុងតំបន់នោះទៀតផង។ សូមសម្រេចពង្រីក និងពង្រឹងចំណងទាក់ទងរវាងគ្រឹះស្ថានសាសនទូតជាមួយភូមិភាគនានា ឲ្យកាន់តែជិតស្និទ្ធឡើងៗ។

ក្រុមអភិបាលក៏មានភារកិច្ចតែងតាំង និងពង្រឹងកិច្ចការផ្សេងៗសម្រាប់ទទួលអស់ជនដែលចាកចេញពីតំបន់ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត មករស់នៅក្នុងភូមិភាគរបស់អស់លោក។ អ្នកទាំងនោះចេញពីប្រទេសរបស់ខ្លួនដោយមានមូលហេតុផ្សេងៗ ឧទាហរណ៍ មករកការងារធ្វើ ឬមកសិក្សានៅឯបរទេសជាដើម។ ត្រូវទទួលអ្នកទាំងនោះយ៉ាងរាក់ទាក់ទុកជាបងប្អូន ហើយយកចិត្តទុកដាក់នឹងណែនាំគេយ៉ាងសមរម្យខាងសាសនា។ ដោយជនទាំងនោះ ចូលមករស់នៅក្នុងប្រទេសរបស់អស់លោក ប្រជាជនទាំងឡាយដែលនៅឆ្ងាយ ក៏ដូចជាមករស់នៅក្បែរអស់លោកហើយ។ ម្យ៉ាងទៀត ជនបរទេសចូលមករស់នៅ ក្នុងស្រុកអស់លោក ក៏ផ្តល់ឱកាសឲ្យព្រះសហគមន៍ ដែលមានគ្រីស្តបរិស័ទជាយូរមកហើយ អាចចាប់ផ្តើមមានទំនាក់ទំនងជាមួយប្រជាជាតិដែលមិនទាន់បានឮដំណឹងល្អដែរ។ សហគមន៍គ្រីស្តបរិស័ទទាំងនោះ ក៏អាចបង្ហាញឲ្យគេឃើញព្រះភ័ក្ត្រដ៏ពិតប្រាកដរបស់ព្រះគ្រីស្ត ដោយគ្រីស្តបរិស័ទបម្រើគេ ទាំងមានចិត្តស្រឡាញ់ និងជួយគេផង។

## ៣៩-ក្រុមគង្វាល មានភារកិច្ចធ្វើជាសាសនទូត

លោកគង្វាលជារូបតំណាងរបស់ព្រះគ្រីស្ត និងជាសហការីរបស់ក្រុមអភិបាលក្នុងមុខងារដ៏សក្ការៈទាំងបី ដែលមានលក្ខណៈភ្ជាប់នឹងបេសកកម្មរបស់ព្រះសហគមន៍ (ពន្លឺ ២៨)។ ហេតុនេះហើយ បានជាលោកគង្វាលត្រូវយល់យ៉ាងជាក់ច្បាស់ថា អស់លោកញែកខ្លួនថ្វាយព្រះជាម្ចាស់ ដើម្បីបម្រើកិច្ចការជាសាសនទូតដែរ។ អស់លោកមានមុខងារបម្រើផ្ទាល់មួយដ៏ពិសេស គឺថ្វាយអភិបូជាជាដើម ដែលធ្វើឲ្យព្រះសហគមន៍បានពេញលក្ខណៈ។ អស់លោករួបរួមជាមួយព្រះគ្រីស្តជាព្រះសិរសា ហើយនាំអ្នកដទៃឲ្យរួបរួមជាមួយព្រះអង្គដែរ។ ដូច្នេះ អស់លោកគង់តែដឹងខ្លួនថា ព្រះកាយព្រះគ្រីស្តនៅតែខ្វះសមាជិកជាច្រើន គឺព្រះកាយមិនទាន់ពេញលេញនៅឡើយ។ អស់លោកក៏គង់តែដឹងថា ខ្លួនត្រូវខិតខំធ្វើអ្វីដើម្បីឲ្យព្រះកាយនោះចម្រើនឡើងជារៀងរាល់ថ្ងៃ។ ហេតុនេះហើយ បានជាអស់លោកមុខជានឹងចាត់ចែងកិច្ចណែនាំគ្រីស្តបរិស័ទ ដើម្បីឲ្យមានប្រយោជន៍ដល់កិច្ចការផ្សព្វផ្សាយដំណឹងល្អ ក្នុងចំណោមសាសន៍ដទៃ។

ពេលអស់លោកង្វាលបំពេញមុខងារណែនាំគ្រីស្តបរិស័ទ អស់លោកត្រូវដាស់តឿនគេឲ្យមានចិត្តខ្នះខ្នែងក្នុងកិច្ចប្រកាសដំណឹងល្អក្នុងពិភពលោកទាំងមូល។ ដោយអប់រំជំនឿរបស់គេ និងធ្វើពិធីអត្ថាធិប្បាយគម្ពីរ អស់លោកបង្រៀនអំពីព្រះសហគមន៍មានបេសកកម្មប្រកាសព្រះគ្រីស្តដល់សាសន៍ដទៃ។ អស់លោកត្រូវបង្រៀនក្រុមគ្រួសារគ្រីស្តបរិស័ទឲ្យដឹងអំពីការចាំបាច់និងកិត្តិយសដោយមានកូនទៅជាសាសនទូត ប្រសិនព្រះជាម្ចាស់ត្រាស់ហៅកូនប្រុសកូនស្រីរបស់ខ្លួនឲ្យទៅជាសាសនទូត ត្រូវជួយកូនៗឲ្យតបឆ្លើយនឹងព្រះអង្គ។ អស់លោកត្រូវលើកទឹកចិត្តយុវជនយុវនារីតាមសាលារៀន ឬតាមសមាគមគ្រីស្តបរិស័ទ ឲ្យមានចិត្តខ្នះខ្នែងនឹងកិច្ចការជាសាសនទូត។ ធ្វើដូច្នេះ មុខជានឹងមានអ្នកចេញមកពីចំណោមរបស់គេទៅប្រកាសដំណឹងល្អពុំខាន។ អស់លោកគង្វាលត្រូវបង្ហាត់គ្រីស្តបរិស័ទឲ្យអង្វរព្រះជាម្ចាស់សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍ក្នុងប្រទេស ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត។ កុំខ្មាស់នឹងសុំទានសម្រាប់ជួយព្រះសហគមន៍ទាំងនោះឡើយ ព្រោះអស់លោកក្លាយទៅជាអ្នកសុំទានសម្រាប់ព្រះគ្រីស្ត និងដើម្បីសង្គ្រោះមនុស្សលោក។

សាស្ត្រាចារ្យនៃទេវវិទ្យាល័យ និងសកលវិទ្យាល័យ ត្រូវបង្រៀនយុវជនឲ្យស្គាល់សភាពការណ៍ដ៏ពិតប្រាកដ នៃ

ពិភពលោកផង និងសភាពការណ៍របស់ព្រះសហគមន៍ផង។ ធ្វើដូច្នេះ យុវជនទាំងនោះ មុខជានឹងយល់កាន់តែច្បាស់អំពីការចាំបាច់នៃកិច្ចប្រកាសដំណឹងល្អដល់សាសន៍ដទៃ ហើយយុវជនទាំងនោះ មុខជានឹងមានចិត្តខ្នះខ្នែងជួយព្រះសហគមន៍ទាំងនោះជាពុំខាន។ ពេលសាស្ត្រាចារ្យបង្រៀនគោលលទ្ធិនៃគ្រីស្តសាសនា ឬបង្រៀនគម្ពីរ ឬបង្រៀនសីលធម៌ និងប្រវត្តិសាស្ត្រ អស់លោកត្រូវបង្ហាញឲ្យបានច្បាស់អំពីសេចក្ដីដែលពាក់ព័ន្ធនឹងកិច្ចការជាសាសនទូត ដែលកប់ទុកក្នុងមុខវិជ្ជាទាំងនោះ ដើម្បីឲ្យយុវជនដែលទទួលការអប់រំឲ្យទៅជាបូជាចារ្យ (អាចារ្យ) នៅពេលអនាគតភ្ញាក់ស្មារតី ជាសាសនទូត។

## ៤០-គ្រឹះស្ថានបព្វជិតបព្វជិតាដែលមានទិសដៅឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ មានភារកិច្ចជាសាសនទូត

តាំងពីដើមរៀងមក ហើយក៏ដូចនៅសព្វថ្ងៃដែរ គ្រឹះស្ថានបព្វជិតបព្វជិតា ទាំងគ្រឹះស្ថានបព្វជិតពួជិតា ដែលមានគោលដៅស្ញឹងស្មាធ៌ធ្វើសមាធិ ទាំងគ្រឹះស្ថានបព្វជិតបព្វជិតាដែលតែងតែមានសកម្មភាពក្នុងសង្គម ទទួលចំណែកដ៏សំខាន់យ៉ាងខ្លាំង ក្នុងកិច្ចប្រកាសដំណឹងល្អដល់មនុស្សលោក។ មហាសន្និបាតពេញចិត្តទទួលស្គាល់គុណសម្បត្តិរបស់បព្វជិតបព្វជិតាទាំងនោះ និងសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះអស់លោកដែលបានបូជាកម្លាំងកាយកម្លាំងចិត្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងបម្រើមនុស្សលោក។ មហាសន្និបាតក៏ដាស់តឿនបព្វជិតបព្វជិតានៃគ្រឹះស្ថានទាំងនោះ ឲ្យព្យាយាមបន្តកិច្ចការដែលអស់លោកអ្នកបានចាប់ផ្តើមធ្វើ ដោយមិនអាក់ខានឡើយ។ អស់លោកអ្នកដឹងច្បាស់ថា ត្រូវតែប្រតិបត្តិតាមសេចក្តីស្រឡាញ់ ជាគុណធម៌ដែលអស់លោកអ្នកចង់កាន់តាមរបៀបកាន់តែពេញលក្ខណៈ ស្របតាមព្រះជាម្ចាស់ត្រាស់ហៅអស់លោកអ្នក។ សេចក្តីស្រឡាញ់នោះជំរុញនិងបង្ខំអស់លោកអ្នកឲ្យមានចិត្តគំនិតចង់បំពេញកិច្ចការដែលពិតជាមានលក្ខណៈកាតូលិកមែន (ពន្លឺ ៤៤)។

បព្វជិតបព្វជិតាដែលស្ញឹងស្មាធ៌ធ្វើសមាធិ ក៏មានសារៈសំខាន់ជាខ្លាំងក្នុងកិច្ចណែនាំឲ្យមនុស្សប្រែចិត្តគំនិត មករកព្រះគ្រីស្ត ព្រោះថា ដោយអស់លោកអ្នកអធិដ្ឋាន ធ្វើតបធម៌ និងឆ្លងកាត់ការលំបាកផ្សេងៗ ទើបព្រះជាម្ចាស់ចាត់អ្នកច្រូតទៅក្នុងស្រែរបស់ព្រះអង្គ (មថ ៩, ៣៨) តាមពាក្យអង្វររបស់យើង ព្រះអង្គបើកចិត្តគំនិតអ្នកមិនកាន់គ្រីស្តសាសនាឲ្យស្តាប់ដំណឹងល្អបាន (កក ១៦, ១៤) ព្រះអង្គក៏ប្រោសឲ្យព្រះបន្ទូលស្តីអំពីការសង្គ្រោះដុះឡើងដែរ (១ករ ៣, ៧)។ លើសពីនេះទៅទៀត មហាសន្និបាតអញ្ជើញគ្រឹះស្ថានទាំងនោះ ឲ្យបង្កើតក្រុមថ្មីក្នុងតំបន់មានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត ដូចមានគ្រឹះស្ថានខ្លះបានបង្កើតរួចមកហើយដែរ។ ដោយអស់លោកអ្នករស់នៅក្នុងឋានៈជាបព្វជិតបព្វជិតា ស្របតាមប្រពៃណីដ៏ពិតប្រាកដនៃសាសនាប្រជាជនទាំងនោះ អស់លោកអ្នកផ្តល់សក្ខីភាពដ៏ល្អប្រសើរក្នុងចំណោមសាសន៍ដទៃ អំពីព្រះជាម្ចាស់ដ៏ឧត្តុងឧត្តមដែលមានព្រះហឫទ័យស្រឡាញ់ចំពោះប្រជាជននោះ ព្រមទាំងផ្តល់សក្ខីភាពថា មនុស្សលោករួបរួមគ្នាក្នុងអង្គព្រះគ្រីស្តទៀតផង។

គ្រឹះស្ថានបព្វជិតបព្វជិតាដែលបំពេញសកម្មភាពផ្សេងៗ ទោះបីមានគោលដៅប្រកាសដំណឹងល្អយ៉ាងច្បាស់ជាគោលដៅតែមួយរបស់គេក្តី ឬគ្មានគោលដៅនេះយ៉ាងច្បាស់ក្តី ក៏ត្រូវសួរខ្លួនឯងដោយចិត្តស្មោះនៅចំពោះព្រះជាម្ចាស់ថា តើគ្រឹះស្ថានរបស់ខ្លួនអាចលាតសន្ធឹងសកម្មភាពក្នុងចំណោមសាសន៍ដទៃ ដើម្បីលាតត្រដាងព្រះរាជ្យរបស់ព្រះជាម្ចាស់បាន ឬយ៉ាងណា?។ តើគេអាចផ្ញើមុខងារបម្រើរបស់ខ្លួនខ្លះទុកឲ្យអ្នកដទៃបំពេញ ដើម្បីចំណាយកម្លាំងរបស់ខ្លួនទៅប្រកាសដំណឹងល្អបាន ឬយ៉ាងណា? តើគេអាចចាប់ផ្តើមសកម្មភាពរបស់ខ្លួនក្នុងតំបន់ ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត ដោយកែសម្រួលធម្មនុញ្ញរបស់គ្រឹះស្ថានរបស់ខ្លួន ប្រសិនបើត្រូវការកែសម្រួល ឲ្យបានសមស្រប

តាមសកម្មភាពថ្មីនោះបានឬយ៉ាងណា? (ប៉ុន្តែ ត្រូវកែសម្រួលធម្មនុញ្ញរបស់គេ ឲ្យបានស្របតាមគោលគំនិតអ្នកបង្កើតគ្រឹះស្ថាននោះ)។ តើបព្វជិតបព្វជិតានៃគ្រឹះស្ថានទាំងនោះ ទទួលចំណែកក្នុងកិច្ចការជាសាសនទូត តាមកម្លាំងរបស់ខ្លួនឬយ៉ាងណា? តើរបៀបអស់លោកអ្នករស់នៅ ពិតជាផ្តល់សក្ខីភាពអំពីដំណឹងល្អ ហើយពិតជាស្របតាមទេពកោសល្យ និងស្របតាមសភាពការណ៍ប្រជាជន ឬយ៉ាងណា?

ក្នុងព្រះសហគមន៍មានគ្រឹះស្ថានគ្រីស្តបរិស័ទរស់នៅក្នុងសង្គម ទាំងថ្វាយខ្លួនទៅព្រះជាម្ចាស់ កាន់តែច្រើនឡើងៗជារៀងរាល់ថ្ងៃជាលំដាប់ ដោយព្រះវិញ្ញាណដ៏វិសុទ្ធជួយបំភ្លឺផង។ គ្រឹះស្ថានទាំងនោះ អាចជួយព្រះសហគមន៍ក្នុងតំបន់មានមនុស្សភាគច្រើនដែលមិនជឿលើព្រះគ្រីស្ត តាមរបៀបផ្សេងៗ ក្រោមអំណាចរបស់លោកអភិបាល។ ត្រូវរាប់គ្រឹះស្ថានទាំងនោះទុកជាសញ្ញាសម្គាល់បញ្ជាក់ថា គេថ្វាយខ្លួនទាំងស្រុងចំពោះព្រះជាម្ចាស់ ដើម្បីប្រកាសដំណឹងល្អដល់មនុស្សលោកទាំងមូល។

## ៤១-នាទីកិច្ចរបស់គ្រីស្តបរិស័ទធម្មតាក្នុងកិច្ចការជាសាសនទូត

គ្រីស្តបរិស័ទធម្មតារួមសហការក្នុងកិច្ចប្រកាសដំណឹងល្អរបស់ព្រះសហគមន៍ ក្នុងឋានៈជាសាក្សី ហើយក៏រួមយ៉ាងសកម្មក្នុងបេសកកម្មរបស់ព្រះសហគមន៍ ពោលគឺនាំការសង្គ្រោះដល់មនុស្សលោក (ពន្លឺ ៣៣.៣៥) ជាពិសេសប្រសិនបើ ព្រះជាម្ចាស់ត្រាស់ហៅគេ ហើយក្រុមអភិបាលបញ្ជាឲ្យគេបំពេញការងារនេះ។

ក្នុងដែនដីដែលមានគ្រីស្តបរិស័ទជាច្រើន ហើយគ្រីស្តបរិស័ទធម្មតារួមសហការក្នុងកិច្ចប្រកាសដំណឹងល្អ ដោយធ្វើឲ្យទាំងខ្លួនគេ ទាំងអ្នកដទៃស្គាល់ និងស្រឡាញ់ព្រះសហគមន៍ក្នុងតំបន់ ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត។ គេក៏រួមសហការដោយនាំឲ្យមានអ្នកខ្លះក្នុងក្រុមគ្រួសាររបស់ខ្លួន ក្នុងគ្រឹះស្ថាន និងក្នុងសមាគមកាតូលិកនានា និងក្នុងសាលារៀន សុខចិត្តតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅអ្នកខ្លះឲ្យធ្វើជាសាសនទូត។ គេក៏រួមសហការដោយប្រមូលធនធានគ្រប់យ៉ាង ដើម្បីឲ្យអ្នកដទៃអាចទទួលព្រះអំណោយ ទាននៃជំនឿដែលខ្លួនបានទទួល ដោយឥតបង់ថ្លៃដែរ។

ក្នុងតំបន់ដែលមានមនុស្សភាគច្រើនមិនជឿលើព្រះគ្រីស្ត គ្រីស្តបរិស័ទធម្មតាជាជនជាតិបរទេសក្តី ជាជនជាតិកើតនៅស្រុកនោះក្តី ក៏ត្រូវបង្រៀនតាមសាលារៀន ឬត្រួតត្រាសម្ភារៈលោកីយ៍ ឬរួមសហការក្នុងសកម្មភាពនៃព្រះសហគមន៍ភូមិ និងព្រះសហគមន៍នៃភូមិភាគ។ គេត្រូវតែងតាំងនិងពង្រីកកិច្ចការរបស់គ្រីស្តបរិស័ទធម្មតាជាគ្រីស្តទូតគ្រប់យ៉ាង ដើម្បីឲ្យគ្រីស្តបរិស័ទរបស់ព្រះសហគមន៍ថ្មីៗទាំងនោះ អាចទទួលខុសត្រូវលើការរស់នៅរបស់ព្រះសហគមន៍របស់គេផ្ទាល់នៅពេលឆាប់ៗ។

គ្រីស្តបរិស័ទធម្មតាត្រូវសហការដោយចិត្តទូលាយខាងសេដ្ឋកិច្ច និងខាងសង្គមជាមួយប្រជាជនទាំងឡាយ ដែលកំពុងតែចម្រើនឡើង។ គួរឲ្យសរសើរកិច្ចរួមសហការនោះ ព្រោះមានគោលដៅតែងតាំងស្ថាប័ន ដែលអាចប្រែរូបនាសម្ពន្ធសង្គម ឬដែលមានគោលដៅអប់រំអ្នកដែលទទួលខុសត្រូវលើកិច្ចការណែនាំប្រទេសទៀតដែរ។

គួរសរសើរយ៉ាងពិសេសអស់លោកអ្នក ដែលជួយឲ្យមនុស្សលោកស្គាល់អរិយធម៌ប្រជាជននានា និងស្គាល់សាសនានានាផងដែរ ដោយស្វែងរកតាមប្រវត្តិសាស្ត្រ ឬតាមសង្គមវិទ្យា ឬតាមសាសនាវិទ្យាក្នុងសកលវិទ្យាល័យ ឬតាមគ្រឹះស្ថានវិទ្យាសាស្ត្រផ្សេងៗ។ ធ្វើដូច្នេះ អស់លោកជួយអ្នកប្រកាសដំណឹងល្អ និងរៀបចំផ្លូវសម្រាប់ទាក់ទងសន្ទនាជាមួយអ្នកកាន់សាសនាដទៃ។

គ្រីស្តបរិស័ទធម្មតាត្រូវរួមសហការជាមួយគ្រីស្តបរិស័ទនិកាយឯទៀតៗ និងរួមជាមួយអ្នកកាន់សាសនាដទៃ ហើយជាពិសេសជាមួយសមាជិកនៃអង្គការអន្តរជាតិដែរ។ ត្រូវរួមសហការជាមួយគេដូចបងប្អូនដោយនឹកគិតជានិច្ចថា *"ត្រូវសាងសង់បុរីនៅលើផែនដី ដោយយកព្រះ អម្ចាស់ធ្វើជាគ្រឹះ ហើយក៏តម្រង់បុរីនេះទៅរកព្រះអង្គដែរ"* (ពន្លឺ ៤៦)។

គ្រីស្តបរិស័ទធម្មតាត្រូវទទួលការអប់រំខាងបច្ចេកទេស និងខាងជីវិតខាងព្រះវិញ្ញាណជាចាំបាច់ខានមិនបាន ដើម្បីឲ្យគេអាចបំពេញបន្ទុកទាំងនោះ។ គ្រឹះស្ថានដែលមានបច្ចេកទេសពិសេស ត្រូវជួយអប់រំគេដើម្បីឲ្យការរស់នៅរបស់គេទៅជាសក្ខីភាពអំពីព្រះគ្រីស្ត ក្នុងចំណោមសាសន៍ដទៃ តាមពាក្យរបស់គ្រីស្តទូតប៉ូលថា៖ *"សូមបងប្អូនកុំធ្វើឲ្យសាសន៍យូដា សាសន៍ក្រិក ឬព្រះសហគមន៍របស់ព្រះជាម្ចាស់ជំពប់ចិត្តឡើយ។ រីឯខ្ញុំវិញ ខ្ញុំខំប្រឹងផ្គាប់ចិត្តមនុស្សទាំងអស់ក្នុងគ្រប់កិច្ចការ ខ្ញុំមិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនទេ គឺស្វែងរកប្រយោជន៍សម្រាប់មនុស្សទាំងអស់ ដើម្បីឲ្យគេទទួលការសង្គ្រោះ"* (១ ករ ១០, ៣២-៣៣)។

# ពាក្យបញ្ចប់

អស់លោកអភិបាលដែលប្រជុំគ្នាក្នុងមហាសន្និបាត រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម យល់ឃើញយ៉ាងជ្រៅបំផុតអំពីភារកិច្ចលាតសន្ធឹងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅគ្រប់ទីកន្លែង សូមសរសើរដោយចិត្តស្រឡាញ់ អស់លោកអ្នកដែលប្រកាសដំណឹងល្អ ជាពិសេសអស់លោកអ្នកដែលត្រូវគេបៀតបៀន ព្រោះតែព្រះគ្រីស្តហើយ ក៏សូមរំលែកទុក្ខគេផង។

អស់លោកអភិបាលក៏មានចិត្តស្រឡាញ់គេយ៉ាងខ្លាំងដែរ ដូចព្រះគ្រីស្តមានព្រះហឫទ័យស្រឡាញ់យ៉ាងខ្លាំងចំពោះមនុស្សលោកដូច្នោះដែរ។ អស់លោកអភិបាលដឹងច្បាស់ថា មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ដែលប្រោសឲ្យព្រះរាជ្យព្រះអង្គមកដល់នៅលើផែនដីបាន។ ហេតុនេះ អស់លោករួមជាមួយគ្រីស្តបរិស័ទទាំងអស់ ក៏សូមអង្វរព្រះជាម្ចាស់ និងដោយមានព្រះនាងព្រហ្មចារីម៉ារី ជាព្រះមហាក្សត្រីយានីរបស់គ្រីស្តទូតទាំងឡាយជួយអង្វរផង សូមឲ្យប្រជាជាតិនានាស្គាល់សេចក្តីពិតនៅពេលឆាប់ៗ (១ធម ២, ៤)។ សូមឲ្យសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែលចាំងលើព្រះភ័ក្ត្ររបស់ព្រះគ្រីស្ត ចាប់ផ្តើមបំភ្លឺមនុស្សទាំងអស់ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធផង (២ករ ៤, ៦)។

អស់លោកអភិបាល ដែលចូលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងឯកសារទាំងមូលនេះហើយនឹងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចជាគ្រីស្តទូតដែលព្រះគ្រីស្តបានប្រគល់ឲ្យ រួមជាមួយអស់លោកអភិបាល យើងក៏យល់ព្រមសម្រេចនឹងប្រកាសចេញជាក្រឹតក្រមដែរ ដោយមានព្រះវិញ្ញាណចូលរួមជាមួយផង។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈសិលា ថ្ងៃទី៧ ខែធ្នូ ឆ្នាំ ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់អស់លោកអភិបាល)

# គ្រីស្តបរិស័ទត្រូវរួបរួមគ្នាជាធ្លុងតែមួយ

**(អំពីការបង្រួបបង្រួមគ្រីស្តបរិស័ទ)**

## UNITATIS REDINTEGRATIO

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយ
## អស់លោកអភិបាលជួបជុំក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ
## សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ

## ក្រឹត្យក្រមអំពី
## ការបង្រួបបង្រួមគ្រីស្តបរិស័ទគ្រប់និកាយ ឲ្យរួបរួមគ្នាជាធ្លុងតែមួយ

១-ក្នុងចំណោមគោលដៅនៃមហាសន្និបាតសកល វ៉ាទីកង់ ទី២ ដ៏វិសុទ្ធ ការលើកស្ទួយគ្រីស្តបរិស័ទគ្រប់និកាយឲ្យរួបរួមគ្នាជាធ្លុងតែមួយ ពិតជាគោលដៅមួយដ៏សំខាន់។ ព្រះគ្រីស្តជាព្រះអម្ចាស់តែងតាំងព្រះសហគមន៍តែមួយគត់។ ក៏ប៉ុន្តែ មានសហគមន៍គ្រីស្តបរិស័ទជាច្រើនអះអាងនៅចំពោះមនុស្សលោកថា មានតែគ្នាគេទេដែលទទួលមត៌កដ៏ពិតប្រាកដរបស់ព្រះយេស៊ូគ្រីស្ត។ ទោះបីគ្រីស្តបរិស័ទទាំងអស់ប្រកាសជំនឿថា គេជាសាវ័ករបស់ព្រះអម្ចាស់ក្តី ក៏គេកាន់ឥរិយាបថផ្សេង ៗពីគ្នា និងដើរតាមមាគ៌ាប្លែក ៗពីគ្នាដែរ ហាក់ដូចជាព្រះគ្រីស្តបែងចែកជាច្រើនភាគ (១ករ ១, ១៣)។ ការបែងចែកគ្នាដូច្នេះ ច្បាស់ជាទាស់នឹងព្រះហឫទ័យរបស់ព្រះគ្រីស្តមែន ហើយក៏បណ្តាលឲ្យមនុស្សលោកឃ្លាតឆ្ងាយពីជំនឿ ព្រមទាំងជាឧបសគ្គរាំងការប្រកាសដំណឹងល្អឲ្យមនុស្សគ្រប់ ៗគ្នា ដែលជាកិច្ចដ៏វិសុទ្ធបំផុត។

ប៉ុន្តែ ព្រះអម្ចាស់នៃពេលវេលា នៅតែសម្រេចគម្រោងការរបស់ព្រះអង្គតាមព្រះហឫទ័យប្រោសប្រណីចំពោះយើងជាអ្នកបាប ដោយព្រះប្រាជ្ញាញាណនិងដោយព្រះហឫទ័យអត់ធ្មត់ខន្តីដែរ។ នៅសម័យថ្មី ៗនេះ ព្រះអង្គចាប់ផ្តើមបំភ្លឺចិត្តគំនិតគ្រីស្តបរិស័ទដែលបែងចែកគ្នានោះ ឲ្យមានចំនួនកាន់តែច្រើនឡើង ៗនឹកស្តាយដោយបែងចែកគ្នាដូច្នេះ និងក៏មានបំណងប្រាថ្នាចង់រួបរួមគ្នាជាធ្លុងតែមួយដែរ។ នៅគ្រប់ទីកន្លែង ព្រះជាម្ចាស់ប្រណីសន្តោសមនុស្សជាច្រើន ហើយមានចលនាមួយកាន់តែខ្លាំងឡើងជារៀងរាល់ថ្ងៃកើតឡើង ក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ សូម្បីតែក្នុងចំណោមបងប្អូនដែលបែកចេញពីយើងក្តី ក៏កើតចលនានោះដែរ ក្នុងគោលបំណងបង្រួបបង្រួមគ្រីស្តបរិស័ទទាំងអស់ឲ្យរួបរួមគ្នាជាធ្លុងតែមួយ។

គេតែងហៅចលនានោះថា «ចលនាបង្រួបបង្រួមគ្រីស្តបរិស័ទគ្រប់និកាយឲ្យរួបរួមគ្នាជាធ្លុងតែមួយ»។ អស់អ្នកដែលតែងតែអង្វរព្រះជាម្ចាស់ជាព្រះត្រៃឯក និងដែលប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់និងពិតជាព្រះសង្គ្រោះ

ក៏ចូលរួមក្នុងចលនានោះដែរ។ មិនគ្រាន់តែគ្រីស្តបរិស័ទក្នុងឋានៈជាបុគ្គលម្នាក់ៗប៉ុណ្ណោះទេ ចូលចលនានោះ តែគ្រីស្តបរិស័ទដែលរួមគ្នា ក្នុងឋានៈជាសហគមន៍ក៏ចូលដែរ គេបានស្តាប់ដំណឹងល្អក្នុងសហគមន៍ទាំងនោះ ដែលគេហៅថា «ព្រះសហគមន៍របស់គេ» (ឬ "ក្រុមជំនុំរបស់គេ") និង «ព្រះសហគមន៍ (ឬ *"ក្រុមជំនុំ"*) របស់ព្រះជាម្ចាស់»។ ក៏ប៉ុន្តែគ្រីស្តបរិស័ទស្ទើរតែទាំងអស់នោះ មានបំណងសង្វាតចង់ឲ្យមានព្រះសហគមន៍ (ឬ *"ក្រុមជំនុំ"*) របស់ព្រះជាម្ចាស់តែមួយគត់ ដែលមនុស្សអាចមើលឃើញបាន ជាព្រះសហគមន៍ (ឬ *"ក្រុមជំនុំ"*) សកលយ៉ាងពិតប្រាកដ ដែលព្រះជាម្ចាស់ចាត់មក ក្នុងពិភពលោកទាំងមូល ដើម្បីឲ្យមនុស្សលោកប្រែចិត្តគំនិតទទួលដំណឹងល្អ និងទទួលការសង្គ្រោះ ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធមានអំណរសប្បាយដោយឃើញការណ៍ទាំងនោះ។ ក្រោយពីបានប្រកាសបញ្ជាក់លទ្ធិអំពីព្រះសហគមន៍រួចហើយ និងដោយមានបំណងចង់បង្រួបបង្រួមសាវ័កទាំងប៉ុន្មានរបស់ព្រះគ្រីស្តឲ្យរួបរួមគ្នាឡើងវិញ មហាសន្និបាតក៏សូមផ្តល់ឲ្យគ្រីស្តបរិស័ទកាតូលិកទាំងអស់នូវជំនួយ និងគោលការណ៍ ព្រមទាំងមធ្យោបាយដែលអាចជួយគេឲ្យតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគេឲ្យរួបរួមគ្នា និងតបឆ្លើយនឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គផង។

# ជំពូក ១

## គោលការណ៍កាតូលិក
## អំពីការបង្រួបបង្រួមគ្រីស្តបរិស័ទទាំងអស់ឲ្យរួបរួមជាធ្លុងតែមួយ

២-ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យសប្បុរសចំពោះមនុស្សយើងដូចតទៅ គឺព្រះបិតាចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គ ឲ្យយាងមកក្នុងពិភពលោក។ ដោយព្រះបុត្រាប្រសូតជាមនុស្ស ព្រះអង្គបានប្រោសមនុស្សជាតិទាំងមូលឲ្យមានជីវិតថ្មី ទាំងរំដោះគេ និងបង្រួបបង្រួមគេជាអង្គតែមួយដែរ (១យហ ៤, ៩; កូឡ ១, ១៨-២០; យហ ១១, ៥២)។ មុនពេលព្រះបុត្រាបូជាព្រះជន្មនៅលើឈើឆ្កាងទុកជាតង្វាយដ៏និមល ព្រះអង្គអង្វរព្រះបិតាសូមព្រះអង្គប្រណីសន្តោសអស់អ្នកដែលនឹងផ្ញើជីវិតលើព្រះអង្គនៅពេលក្រោយៗទៀតថា «បពិត្រព្រះបិតា! សូមឲ្យគេទាំងអស់គ្នារួមជាអង្គតែមួយនៅក្នុងយើង ដូចព្រះអង្គស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំស្ថិតនៅជាប់នឹងព្រះអង្គដូច្នោះដែរ ដើម្បីឲ្យមនុស្សលោកជឿថា ព្រះអង្គពិតជាបានចាត់ខ្ញុំមកមែន» (យហ ១៧, ២១)។ ព្រះអង្គក៏តែងតាំងអគ្គសញ្ញាដ៏ប្រសើរឧត្តមមួយក្នុងព្រះសហគមន៍ និងក្នុងក្រុមជំនុំ គឺអគ្គសញ្ញាអរព្រះគុណ ដែលបង្ហាញបញ្ជាក់ថា ព្រះសហគមន៍រួបរួមជាធ្លុងតែមួយ ហើយនិងធ្វើឲ្យព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយទៀតដែរ។ ព្រះអង្គក៏ប្រទានវិន័យថ្មីឲ្យក្រុមសាវ័ករបស់ព្រះអង្គ គឺឲ្យគេស្រឡាញ់គ្នាទៅវិញទៅមក (យហ ១៣, ៣៤)។ ព្រះអង្គក៏សន្យាថា នឹងចាត់ព្រះវិញ្ញាណ ជាវិញ្ញាណដែលជួយការពារ (យហ ១៦, ៧) ជាព្រះអម្ចាស់ដែលផ្តល់ជីវិត ឲ្យគង់នៅជាមួយគេជាដរាបតរៀងមក។

ក្រោយពីពេលគេលើកព្រះអង្គនៅលើឈើឆ្កាង និងក្រោយពីពេលព្រះអង្គយាងចូលក្នុងសិរីរុងរឿង ព្រះអម្ចាស់យេស៊ូចាក់បង្ហូរព្រះវិញ្ញាណតាមព្រះបន្ទូលសន្យា។ ដោយព្រះវិញ្ញាណនេះ ព្រះអង្គក៏ត្រាស់ហៅ និងប្រមែប្រមូលព្រះសហគមន៍ (ក្រុមជំនុំ) ដែលជាប្រជារាស្ត្រនៃសម្ពន្ធមេត្រីថ្មី ឲ្យមានជំនឿតែមួយ មានសេចក្តីសង្ឃឹមតែមួយ និងមានចិត្តស្រឡាញ់តែមួយដែរ តាមសេចក្តីដែលគ្រីស្តទូតប៉ូលបង្រៀនថា «ព្រះកាយមានតែមួយ ព្រះវិញ្ញាណមានតែមួយ សេចក្តីសង្ឃឹមមានតែមួយ តាមព្រះជាម្ចាស់ត្រាស់ហៅបងប្អូន។ ព្រះអម្ចាស់មានតែមួយ ជំនឿមានតែមួយ ពិធីជ្រមុជទឹកមានតែមួយ» (អភ ៤, ៤-៥)។ «បងប្អូនទាំងអស់ដែលបានទទួលពិធីជ្រមុជទឹកក្នុងអង្គព្រះគ្រីស្តរួច បងប្អូនរួបរួមយ៉ាងជិតស្និទ្ធនឹងព្រះគ្រីស្ត ដូចជាយកព្រះអង្គមកបំពាក់លើខ្លួន... គឺបងប្អូនរួបរួមគ្នាជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ» (កាឡ ៣, ២៧-២៨)។ ព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតក្នុងអ្នកជឿ ព្រះអង្គបំពេញព្រះសហគមន៍ទាំងមូល ហើយត្រួតត្រាព្រះសហគមន៍ទៀតផង។ ព្រះវិញ្ញាណធ្វើឲ្យអ្នកជឿទាំងប៉ុន្មានរួបរួមចិត្តគំនិតគ្នាយ៉ាងអស្ចារ្យ គឺប្រោសឲ្យគេរួបរួមគ្នាយ៉ាងជិតស្និទ្ធបំផុតក្នុងអង្គព្រះគ្រីស្ត ព្រោះព្រះវិញ្ញាណជាដើមកំណើតប្រោសឲ្យព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយនោះ។ ព្រះវិញ្ញាណនេះហើយដែលចែកប្រទានព្រះអំណោយទានប្លែកៗពីគ្នា និងមុខងារបម្រើផ្សេងៗ (១ករ ១២, ៤-១១) ព្រះអង្គក៏ចែកប្រទានតួនាទីផ្សេងៗក្នុងព្រះសហគមន៍របស់ព្រះយេស៊ូគ្រីស្តទៀតផង ព្រះអង្គ *"ចាត់ចែងប្រជារាស្ត្រដ៏វិសុទ្ធដូច្នេះ ឲ្យបំពេញមុខងារបម្រើ ដើម្បីសាងសង់ព្រះកាយព្រះគ្រីស្ត"* (អភ ៤, ១២)។

ក៏ប៉ុន្តែ ព្រះគ្រីស្តបានផ្ញើមុខងារបង្រៀន មុខងារត្រួតត្រា និងមុខងារនាំមនុស្សឲ្យបានវិសុទ្ធ ទៅនឹងក្រុមគ្រីស្តទូតទាំងដប់ពីរនាក់ (មថ ២៨, ១៨-២០ ភ្ជាប់នឹង យហ ២០, ២១-២៣) ដើម្បីតែងតាំងព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះអង្គនៅគ្រប់ទីកន្លែង រហូតដល់អវសានកាលនៃពិភពលោក។ ក្នុងចំណោមគ្រីស្តទូតទាំងដប់ពីរនាក់នោះ ព្រះអង្គជ្រើសរើសលោកសិលា។ ក្រោយពីលោកសិលានោះបានប្រកាសជំនឿ ព្រះអង្គសម្រេចព្រះហឫទ័យសាងព្រះសហគមន៍របស់ព្រះអង្គលើលោកសិលានេះទុកជាគ្រឹះ។ ព្រះអង្គមានព្រះបន្ទូលសន្យាថា នឹងប្រគល់ *"កូនសោរនៃព្រះរាជ្យ"* ទុកមកលោក (មថ ១៦, ១៩ ភ្ជាប់នឹង ១៨, ១៨)។ ក្រោយពីលោកប្រកាសបញ្ជាក់ថា លោកស្រឡាញ់ព្រះអង្គពិតមែនហើយ ព្រះអង្គក៏ផ្ញើហ្វូងចៀមព្រះអង្គឲ្យលោកពង្រឹងជំនឿរបស់គេ (លក ២២, ៣២) និងឃ្វាលណែនាំគេឲ្យរួបរួមគ្នាជាធ្លុងតែមួយយ៉ាងពេញលក្ខណៈ (យហ ២១, ១៥-១៧)។ ក៏ប៉ុន្តែ ព្រះយេស៊ូគ្រីស្តនៅតែជាគ្រឹះដ៏សំខាន់បំផុត ដែលស្ថិតស្ថេរនៅអស់កល្បជានិច្ច (អភ ២, ២០) និងជា *"គង្វាលនៃជីវិតរបស់យើង"* (១សល ២, ២៥)។

ព្រះយេស៊ូគ្រីស្ត សព្វព្រះហឫទ័យឲ្យប្រជារាស្ត្ររបស់ព្រះអង្គចម្រើនចំនួនឡើង ដោយគ្រីស្តទូត និងអស់លោកដែលបន្តមុខងារពីក្រុមគ្រីស្តទូត ប្រកាសដំណឹងល្អយ៉ាងស្មោះត្រឹមត្រូវ។ អស់លោកអភិបាលបន្តមុខងារពីក្រុម គ្រីស្តទូតរួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូម ដែលបន្តមុខងារពីគ្រីស្តទូតសិលាមក ក្នុងឋានៈជាមេដឹកនាំ។ ព្រះយេស៊ូគ្រីស្តក៏សព្វព្រះហឫទ័យឲ្យប្រជារាស្ត្ររបស់ព្រះអង្គចម្រើនឡើង ដោយអស់លោកធ្វើអគ្គសញ្ញាជូនគ្រីស្តបរិស័ទ និងគ្រប់គ្រងគេដោយសេចក្តីស្រឡាញ់ ក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធដែរ។ ព្រះអង្គក៏បង្រួបបង្រួមប្រជារាស្ត្រព្រះអង្គឲ្យរួបរួមគ្នាជាធ្លុងតែមួយ ដោយគេប្រកាសជំនឿតែមួយ ដោយរួបរួមគ្នាគោរពបម្រើព្រះជាម្ចាស់ និងដោយគេរួបរួមគ្នាទុកគ្នា ជាបងប្អូនយ៉ាងសុខសាន្ត ក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់។

ដូច្នេះ ព្រះសហគមន៍ដែលជាហ្វូងចៀមតែមួយគត់របស់ព្រះជាម្ចាស់ ប្រៀបដូចទង់មួយជាសញ្ញាលើកឡើងឲ្យមនុស្សគ្រប់ជាតិសាសន៍ឃើញ (អស ១១, ១០-១២) ព្រះសហគមន៍យកដំណឹងល្អស្តីអំពីសេចក្តីសុខសាន្តមកបម្រើមនុស្សលោកទាំងមូល (អភ ២, ១៧-១៨ ភ្ជាប់នឹង មក ១៦-១៥)។ ព្រះសហគមន៍នៅតែធ្វើបូជនីយសចរទាំងមានសេចក្តីសង្ឃឹម ឆ្ពោះទៅកាន់មាតុភូមិនៃលោកខាងមុខ ជាទិសដៅរបស់ខ្លួន (១សល ៣-៩)។

នេះជាគម្រោងការដ៏សក្ការៈរបស់ព្រះសហគមន៍ដែលរួបរួមគ្នាជាធ្លុងតែមួយក្នុងអង្គព្រះគ្រីស្ត ដោយសារព្រះគ្រីស្ត និងក្រោមការណែនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលចែកប្រទានមុខងារបម្រើប្លែកៗពីគ្នាក្នុងព្រះសហគមន៍នោះ។ ព្រះត្រៃឯក គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណ ដែលរួបរួមគ្នាជាអង្គតែមួយ ពិតជាគំរូដ៏ខ្ពង់ខ្ពស់បំផុតនិងជាដើមកំណើតនៃគម្រោងការរបស់ព្រះសហគមន៍ដែលរួបរួមជាធ្លុងតែមួយ។

## ៣-ទំនាក់ទំនងជាមួយបងប្អូនដែលបែកចេញពីព្រះសហគមន៍កាតូលិក

តាំងពីដើមរៀងមក ក្នុងព្រះសហគមន៍តែមួយគត់របស់ព្រះជាម្ចាស់ កើតការបែកបាក់គ្នាខ្លះ (១ករ ១១, ១៨-១៩; កាឡ ១, ៦-៩; ១យហ ២, ១៨-១៩)។ គ្រីស្តទូតប៉ូលស្តីបន្ទោសយ៉ាងខ្លាំងអ្នកធ្វើឲ្យព្រះសហគមន៍បែកបាក់ (១ករ ១១; ១១, ២២)។ នៅសតវត្សក្រោយៗមកទៀត គ្រីស្តបរិស័ទក៏ខ្វែងគំនិតគ្នារឹតតែធ្ងន់ធ្ងរឡើងទៀត មានសហគមន៍ធំៗជាច្រើនបែកចេញពីការរួបរួមគ្នាយ៉ាងពេញលេញនៃព្រះសហគមន៍កាតូលិក។ ជួនកាលកំហុសមកពីមនុស្សក្នុងភាគីទាំងសងខាង។ បងប្អូនដែលកើតសព្វថ្ងៃក្នុងសហគមន៍ដែលបែកចេញទាំងនោះ ហើយដែលផ្ញើជីវិតលើព្រះគ្រីស្ត មិនត្រូវចោទថា គេមានកំហុសដោយបាក់បែកនោះទេ។ ព្រះសហគមន៍កាតូលិកគោរព និងស្រឡាញ់គេ

ក្នុងឋានៈជាបងប្អូន ដ្បិតអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ត ហើយបានទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងត្រឹមត្រូវ ទោះបីគេមិនរួបរួមយ៉ាងពេញលក្ខណៈជាមួយព្រះសហគមន៍កាតូលិកក្តី ក៏គេរួបរួមម៉្យាងជាមួយដែរ។ តាមពិតក្រុមគេ និងព្រះសហគមន៍កាតូលិកខ្វែងគំនិតគ្នា អំពីប្រការផ្សេងៗត្រង់លទ្ធិនៃជំនឿ ជួនកាលគេខ្វែងគំនិតគ្នាអំពីវិន័យ ជួនកាលគេខ្វែងគំនិតគ្នា អំពីរចនាសម្ព័ន្ធនៃព្រះសហគមន៍។ ការខ្វែងគំនិតទាំងនោះបង្កើតឧបសគ្គជាច្រើន ជួនកាលក្លាយជាឧកសគ្គធ្ងន់ធ្ងរ រារាំងមិនឲ្យគ្រីស្តបរិស័ទរួបរួមគ្នាយ៉ាងពេញលេញបាន។ ចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ មានគោលដៅពុះពារឧបសគ្គទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏បងប្អូនទាំងនោះ ពិតជាមនុស្សសុចរិតដោយគេផ្ញើជីវិតលើព្រះគ្រីស្តនិងទទួលអគ្គសញ្ញាជ្រមុជទឹក គេចូលរួមក្នុងព្រះកាយព្រះគ្រីស្ត គេក៏ពិតជាមានឈ្មោះថាជាគ្រីស្តបរិស័ទដែរ។ សមាជិកនៃព្រះសហគមន៍កាតូលិក ទទួលស្គាល់គេយ៉ាងត្រឹមត្រូវទុកជាបងប្អូនក្នុងព្រះអម្ចាស់។

មិនតែប៉ុណ្ណោះសោត ព្រះសហគមន៍ (ក្រុមជំនុំ) សាងឡើងនិងមានជីវិតរស់រវើក ដោយកត្តានិងគុណធម៌ផ្សេងៗភ្ជាប់គ្នា។ មានកត្តានិងគុណសម្បត្តិដ៏សំខាន់ៗបំផុតជាច្រើន ស្ថិតនៅខាងក្រៅព្រះសហគមន៍កាតូលិកដែលមនុស្សមើលឃើញ គឺមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែងជាលាយលក្ខណ៍អក្សរ មានជីវិតតាមព្រះហឫទ័យប្រណីសន្ដោសនៃព្រះជាម្ចាស់ មានជំនឿ មានសេចក្តីសង្ឃឹម មានសេចក្តីស្រឡាញ់ មានព្រះអំណោយទានផ្សេងៗរបស់ព្រះវិញ្ញាណនៅក្នុងចិត្តគេ ព្រមទាំងមានកត្តាជាច្រើនឯទៀតៗ ដែលមនុស្សមើលឃើញបានផង។ គុណសម្បត្តិទាំងនេះសុទ្ធតែមកពីព្រះគ្រីស្ត និងណែនាំឲ្យទៅកាន់ព្រះអង្គ ហើយក៏ពិតជាគុណសម្បត្តិនៃព្រះសហគមន៍តែមួយគត់របស់ព្រះគ្រីស្តត្រឹមត្រូវតាមច្បាប់។

ក្នុងចំណោមបងប្អូនដែលបែកចេញពីយើង ក៏គេតែងតែធ្វើពិធីជាច្រើនតាមគ្រីស្តសាសនា។ គេនាំគ្នាធ្វើពិធីទាំងនោះតាមរបៀបផ្សេងៗ ស្របតាមសភាពការណ៍ប្លែកៗរបស់ព្រះសហគមន៍ ឬសហគមន៍ (ក្រុមជំនុំ) នីមួយៗ។ ពិធីទាំងនោះ ពិតជាអាចផ្តល់ជីវិតតាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ដែរ។ យើងត្រូវទទួលស្គាល់ថាពិធីទាំងនោះអាចនាំឲ្យគេចូលរួបរួមក្នុងការសង្គ្រោះផងដែរ។

ហេតុនេះហើយ ទោះបីយើងជឿថា ព្រះសហគមន៍និងក្រុមជំនុំទាំងនោះដែលបាក់បែកចេញពីយើង ខ្វះសេចក្តីខ្លះក៏ដោយ ក៏យើងចាត់ទុកថា ព្រះសហគមន៍និងក្រុមជំនុំទាំងនោះមានអត្ថន័យ និងមានប្រយោជន៍តាមគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះដែរ។ ព្រះវិញ្ញាណរបស់ព្រះគ្រីស្តសព្វព្រះហឫទ័យប្រើព្រះសហគមន៍និងក្រុមជំនុំទាំងនោះទុកជាមធ្យោបាយនាំការសង្គ្រោះដល់មនុស្សលោក។ អានុភាពនៃការសង្គ្រោះនេះ ហូរចេញមកពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់និងសេចក្តីពិតដ៏ពេញលេញ ដែលព្រះគ្រីស្តបានផ្ញើទុកឲ្យព្រះសហគមន៍កាតូលិក។

ក៏ប៉ុន្តែ បងប្អូនដែលបែកចេញពីយើងទាំងនេះ ទោះម្នាក់ៗក្តី ទោះជាក្រុមជំនុំឬព្រះសហគមន៍របស់គេក្តី ក៏គេមិនប្រកបដោយការរួបរួមដែលព្រះគ្រីស្តសព្វព្រះហឫទ័យចែកប្រទានឲ្យអស់អ្នកដែលព្រះអង្គបានបង្កើតជាថ្មីដែរ។ ព្រះអង្គបានផ្តល់ជីវិតឲ្យគេ ដើម្បីឲ្យគេទៅជាព្រះកាយតែមួយ ហើយបម្រុងនឹងបានជីវិតថ្មី តាមព្រះគម្ពីរនិងការបញ្ជូនបន្តនៃព្រះសហគមន៍បញ្ជាក់ស្រាប់។ មនុស្សលោកមានគ្រប់មធ្យោបាយ ដើម្បីទទួលការសង្គ្រោះ ដោយសារតែព្រះសហគមន៍កាតូលិករបស់ព្រះគ្រីស្តមួយគត់ គឺព្រះសហគមន៍ដែលជា "មធ្យោបាយសកលនៃការសង្គ្រោះ"។ យើងជឿថា ព្រះអម្ចាស់បានផ្ញើទុកគុណសម្បត្តិដ៏បរិបូរណ៍លើសលុបនៃសម្ពន្ធមេត្រីថ្មី ទៅក្រុមគ្រីស្តទូតតែមួយគត់ ដែលមានគ្រីស្តទូតសិលាជាប្រធាន ដើម្បីតែងតាំងព្រះកាយតែមួយគត់របស់ព្រះគ្រីស្តនៅលើផែនដីនេះ។ អស់អ្នកដែលភ្ជាប់នឹងប្រជារាស្ត្ររបស់ព្រះជាម្ចាស់តាមរបៀបម៉្យាងរួចហើយ ក៏ត្រូវរួបរួមក្នុងព្រះកាយនេះយ៉ាងពេញលេញដែរ។ ពេលប្រជារាស្ត្រនេះកំពុងតែ

ធ្វើបូជនីយសេចរនៅលើផែនដីនេះ ទោះបីសមាជិកតែងតែប្រព្រឹត្តអំពើបាបក៏ដោយ ក៏ប្រជារាស្ត្រនៅតែចម្រើនឡើងក្នុងអង្គព្រះគ្រីស្តដែរ ដោយមានព្រះជាម្ចាស់ណែនាំយ៉ាងទន់ភ្លន់ តាមព្រះអង្គគ្រោងទុកយ៉ាងអាថ៌កំបាំង រហូតដល់ពេលគេទទួលសិរីរុងរឿងយ៉ាងពេញលេញអស់កល្បជានិច្ច នៅក្នុងយេរូសាឡឹមនៃលោកខាងមុខ។

## ៤-អំពីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ

សព្វថ្ងៃ នៅច្រើនកន្លែងក្នុងពិភពលោក ដោយមានព្រះវិញ្ញាណដ៏វិសុទ្ធប្រណីសន្តោស គ្រីស្តបរិស័ទមួយចំនួនធំខិតខំអធិដ្ឋាន និយាយសន្ទនាគ្នា និងធ្វើការរួមជាមួយគ្នា ដើម្បីឲ្យរួបរួមគ្នាយ៉ាងពេញលក្ខណៈតាមព្រះហឫទ័យព្រះយេស៊ូគ្រីស្ត។ ហេតុនេះហើយ បានជាមហាសន្និបាត ដាស់តឿនគ្រីស្តបរិស័ទកាតូលិកទាំងអស់ឲ្យទទួលស្គាល់សញ្ញាសម្គាល់នៃកាលៈទេសៈ និងឲ្យចូលរួមយ៉ាងសកម្មក្នុងការខិតខំបង្រួបបង្រួមគ្រីស្តបរិស័ទជាធ្លុងតែមួយនេះ។

ពេលយើងនិយាយថា *"ចលនាបង្រួបបង្រួម"* នេះ យើងយល់ដល់កិច្ចការទាំងប៉ុន្មានដែលគ្រីស្តបរិស័ទចាប់ផ្តើមធ្វើដោយមានគំនិតផ្ទាល់ ឬការដែលព្រះសហគមន៍ ឬក្រុមជំនុំនានាចាត់ចែង ដើម្បីជួយឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ ស្របតាមសេចក្តីត្រូវការប្លែកៗនៃព្រះសហគមន៍ និងតាមសភាពការណ៍នៃកាលៈទេសៈផងដែរ។ ដូច្នេះ មុនដំបូងត្រូវខិតខំបំបាត់ចោលនូវពាក្យសម្តី នូវការវិនិច្ឆ័យនិងយោបល់ ព្រមទាំងនូវកិច្ចការដែលមិនត្រឹមត្រូវតាមសភាពការណ៍របស់បងប្អូនដែលបែកបាក់ទាំងនោះ គឺមិនស្របតាមសេចក្តីពិត និងមិនស្របតាមយុត្តិធម៌ដែរ។ ពាក្យសម្តី ការវិនិច្ឆ័យនិងយោបល់ កិច្ចការទាំងនោះ បណ្តាលឲ្យការទាក់ទងជាមួយបងប្អូនរឹតតែពិបាក។ បន្ទាប់មក នៅពេលគ្រីស្តបរិស័ទរបស់ព្រះសហគមន៍និងក្រុមជំនុំនានា ចាត់ចែងការប្រជុំតាមគោលគំនិតចង់គោរពព្រះជាម្ចាស់ត្រូវមាន *"អ្នកជំនាញការ"* ដែលស្គាល់សេចក្តីទាំងនេះយ៉ាងល្អិតល្អន់ ណែនាំការសន្ទនាគ្នា គឺម្នាក់ៗរៀបរាប់យ៉ាងក្បោះក្បាយនូវលទ្ធិសហគមន៍ ឬក្រុមជំនុំរបស់ខ្លួន ព្រមទាំងបញ្ជាក់លក្ខណៈ ផ្ទាល់របស់សហគមន៍ ឬក្រុមជំនុំរបស់ខ្លួននោះទៀតផង។ ដោយមានការសន្ទនាបែបនេះ គ្រីស្តបរិស័ទទាំងអស់មុខជានឹងស្គាល់សេចក្តីដែលនិកាយនីមួយៗបង្រៀន និងរបៀបរស់នៅរបស់គេឲ្យបានច្បាស់ ព្រមទាំងវាយតម្លៃ ឲ្យបានត្រឹមត្រូវជាងមុនទៅទៀត។ និកាយនីមួយៗ ក៏នាំគ្នារួមសហការកាន់តែច្រើនឡើងៗក្នុងគ្រប់វិស័យ តាមមនសិការគ្រីស្តបរិស័ទទាមទារ ដើម្បីជាប្រយោជន៍រួម។ ជួនកាលគ្រីស្តបរិស័ទក៏អាចរួមគ្នាអធិដ្ឋានដោយមានចិត្តថ្លើមតែមួយដែរ។ មិនតែប៉ុណ្ណោះសោត គ្រីស្តបរិស័ទទាំងអស់ ត្រូវពិនិត្យពិច័យខ្លួនឯង អំពីសេចក្តីស្មោះត្រង់របស់ខ្លួនចំពោះព្រះហឫទ័យរបស់ព្រះគ្រីស្ត និងចំពោះព្រះសហគមន៍។ គេក៏ត្រូវខិតខំកែតម្រង់និកាយរបស់ខ្លួនឲ្យកាន់តែប្រសើរឡើងៗ ដោយឥតឈប់ឈរតាមសេចក្តីត្រូវការ។

ប្រសិនបើ គ្រីស្តបរិស័ទកាតូលិកប្រព្រឹត្តការទាំងនោះ ដោយប្រុងប្រយ័ត្ននិងដោយចិត្តអត់ធ្មត់ ក្រោមការណែនាំរបស់គង្វាលរបស់ខ្លួន គេមុខជានឹងជួយឲ្យយុត្តិធម៌និងសេចក្តីពិតចម្រើនឡើង ជួយឲ្យគ្រីស្តបរិស័ទស្រុះស្រួលគ្នា និងសហការគ្នា ព្រមទាំងជួយឲ្យគេស្រឡាញ់គ្នាទុកជាបងប្អូន និងរួបរួមគ្នាទៀតផង។ បន្តិចម្តងៗ ដោយប្រព្រឹត្តតាមវិធីនេះ គ្រីស្តបរិស័ទនឹងអាចពុះពារឈ្នះឧបសគ្គនានាដែល រារាំងមិនឲ្យរួបរួមគ្នាយ៉ាងពេញលេក្ខណៈជាសហគមន៍បាន។ ក្រោយមកគ្រីស្តបរិស័ទទាំងអស់ មុខជានឹងរួបរួមគ្នាធ្វើពិធីអរព្រះគុណតែមួយគត់ ដោយរួមគ្នាជាព្រះសហគមន៍តែមួយគត់ពុំខាន។ ព្រះគ្រីស្តបានប្រទានការរួបរួមគ្នាបែបនេះឲ្យព្រះសហគមន៍របស់ព្រះអង្គ តាំងពីដើមរៀងមក។ យើងជឿថា ការរួបរួមគ្នានេះស្ថិតនៅក្នុងព្រះសហគមន៍កាតូលិក មិនអាចបាត់បង់បានឡើយ។ យើងក៏សង្ឃឹមថា ការរួបរួមគ្នានេះមុខជាចម្រើនឡើងជារៀងរាល់ថ្ងៃជាលំដាប់ រហូតដល់អវសានកាលនៃពិភពលោក។

ការរៀបចំ និងការសម្រុះសម្រួលបុគ្គលម្នាក់ៗ ដែលចង់រួបរួមយ៉ាងពេញលេញជាមួយព្រះសហគមន៍កាតូលិក ជាក់ច្បាស់មានលក្ខណៈប្លែកពីចលនាបង្រួបបង្រួមនិកាយនានា ឲ្យរួបរួមគ្នាជាធ្លុងតែមួយ។ ប៉ុន្តែ កិច្ចការទាំងពីរនោះ មិនទាស់គ្នាទេ ព្រោះកិច្ចការទាំងពីរ មកពីព្រះជាម្ចាស់ចាត់ចែងតាមរបៀបគួរឲ្យសរសើរ។

ក្នុងកិច្ចការបង្រួបបង្រួមគ្រីស្តបរិស័ទ ឲ្យរួបរួមគ្នាជាធ្លុងតែមួយនោះ គ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិក ត្រូវតែស្រឡាញ់បងប្អូនដែលបែកបាក់ទាំងនោះ ដោយមិនរួញរាឡើយ។ ត្រូវតែអង្វរព្រះជាម្ចាស់ឲ្យគេ និយាយជាមួយគេអំពីសេចក្ដីផ្សេងៗដែលពាក់ព័ន្ធនឹងព្រះសហគមន៍។ ត្រូវសុខចិត្តទៅរកគេ មុនពួកគេមករកយើង។ ជាពិសេសត្រូវយកចិត្តទុកដាក់ចាប់អារម្មណ៍ ដោយចិត្តស្មោះអំពីអ្វីៗទាំងអស់ដែលត្រូវកែតម្រង់ឲ្យបានថ្មី ក្នុងមហាគ្រួសារកាតូលិកផ្ទាល់ ដើម្បីឲ្យរបៀបរស់នៅរបស់ព្រះសហគមន៍ ផ្ដល់សក្ខីភាពកាន់តែត្រឹមត្រូវ និងកាន់តែច្បាស់អំពីលទ្ធិ និងអំពីរចនាសម្ព័ន្ធ ដែលព្រះគ្រីស្តបានបញ្ជូនបន្តមកតាមរយៈក្រុមគ្រីស្តទូត។

ទោះបីព្រះសហគមន៍កាតូលិកបានទទួលសេចក្ដីពិត ដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់ក្ដី ហើយទោះបីព្រះសហគមន៍កាតូលិកបានទទួលគ្រប់មធ្យោបាយនៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ក្ដី ក៏សមាជិកនៃព្រះសហគមន៍មិនរស់នៅ ដោយមានចិត្តស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំងទាំងអស់គ្នា ដូចគេត្រូវស្រឡាញ់នោះទេ។ ហេតុនេះហើយ បានជាមុខនៃព្រះសហគមន៍មិនចាំងពន្លឺឲ្យបានច្បាស់នៅលើបងប្អូនដែលបែកបាក់នោះ និងនៅលើមនុស្សលោកទាំងមូលទេ។ គេក៏រារាំងព្រះរាជ្យព្រះជាម្ចាស់មិនឲ្យចម្រើនឡើងដែរ។ ហេតុនេះ គ្រីស្តបរិស័ទកាតូលិកទាំងអស់ ត្រូវខិតខំតម្រង់ខ្លួនឲ្យទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ (យក ១, ៤; រម ១២, ១-២)។ ក្នុងរូបកាយរបស់ខ្លួន ព្រះសហគមន៍រួមជាមួយព្រះគ្រីស្តជាមនុស្សសុភាពរាបសាដែលតែងតែស្លាប់ (២ករ ៤, ១០; ភល ២, ៥-៨)។ ហេតុនេះ ម្នាក់ៗតាមកន្លែងរបស់ខ្លួន ត្រូវខិតខំនាំឲ្យព្រះសហគមន៍ជម្រះខ្លួន និងប្រែឲ្យបានជាថ្មីជារៀងរាល់ថ្ងៃ ទម្រាំដល់ពេលព្រះគ្រីស្តលើកព្រះសហគមន៍នេះ ប្រកបដោយសិរីរុងរឿង ឥតសៅហ្មង ឥតមានជ្រួញ មកថ្វាយព្រះអង្គ (អភ ៥, ២៧)។

គ្រីស្តបរិស័ទទាំងអស់ក្នុងព្រះសហគមន៍ ត្រូវរក្សាទុកការរួបរួមគ្នាត្រង់សេចក្ដីទាំងប៉ុន្មានដ៏ចាំបាច់ គឺម្នាក់ៗតាមមុខងាររៀងៗខ្លួន។ ប៉ុន្តែគ្រីស្តបរិស័ទទាំងអស់ក៏ត្រូវរក្សាទុកសិទ្ធិសេរីភាពដ៏ត្រឹមត្រូវ ចំពោះរបៀបរស់នៅប្លែកៗពីគ្នាតាមព្រះវិញ្ញាណនិងតាមក្បួនវិន័យរបស់គេ ចំពោះរបៀបធ្វើពិធីបុណ្យប្លែកៗពីគ្នា សូម្បីតែចំពោះការកសាងទេវវិទ្យាដោយរិះគិតអំពីសេចក្ដីពិតដែលព្រះជាម្ចាស់បានសម្ដែងមក ក៏ត្រូវទុកសេរីភាពឲ្យគេដែរ។ ប៉ុន្តែ ត្រូវមានចិត្តស្រឡាញ់ក្នុងគ្រប់កិច្ចការទាំងអស់។ ធ្វើដូច្នេះ គ្រីស្តបរិស័ទទាំងអស់នឹងបង្ហាញឲ្យកាន់តែច្បាស់ឡើងៗ នូវលក្ខណៈ *"កាតូលិក"* (គឺ *"សកល"*) និងស្របតាមជំនឿរបស់ក្រុមគ្រីស្តទូតរបស់ព្រះសហគមន៍។

ម្យ៉ាងវិញទៀត គ្រីស្តបរិស័ទកាតូលិកត្រូវតែអរសប្បាយជាចាំបាច់ដោយទទួលស្គាល់ និងរាប់រកសេចក្ដីដ៏ល្អត្រឹមត្រូវដែលមានលក្ខណៈគ្រីស្តសាសនា ហូរមកពីបេតិកភ័ណ្ឌរួម ហើយដែលបងប្អូនបែកចេញពីយើងធ្លាប់កាន់តាមនោះ។ ត្រូវតែទទួលស្គាល់គុណសម្បត្តិរបស់ព្រះគ្រីស្ត និងឫទ្ធានុភាពរបស់ព្រះអង្គកំពុងមានសកម្មភាពក្នុងការរស់នៅរបស់អស់អ្នកដែលផ្ដល់សក្ខីភាពថ្វាយព្រះគ្រីស្ត ជួនកាលរហូតដល់បូជាជីវិតទៀតផង។ ការទទួលស្គាល់សេចក្ដីទាំងនោះពិតជាត្រឹមត្រូវហើយនាំការសង្គ្រោះទៀតផង ដ្បិតមនុស្សត្រូវតែស្ញប់ស្ញែងចំពោះព្រះជាម្ចាស់ជានិច្ច គឺត្រូវស្ញប់ស្ញែងព្រះអង្គ ដោយឃើញស្នាព្រះហស្ដរបស់ព្រះអង្គដែរ។

យើងក៏មិនត្រូវបំភ្លេចថា អ្វីៗដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រណីសន្ដោស សម្រេចក្នុងបងប្អូនដែលបែកចេញពីយើង ក៏អាចជួយអប់រំកសាងយើងដែរ។ អ្វីៗដែលពិតជាមានលក្ខណៈតាមគ្រីស្ដសាសនា មិនដែលជំទាស់នឹងតម្លៃដ៏ថ្លៃថ្នូរ និងដ៏ពិតប្រាកដនៃជំនឿទេ ដ្បិតអ្វីៗទាំងនោះអាចជួយឲ្យយើងទៅដល់គម្រោងការដ៏អស្ចារ្យរបស់ព្រះគ្រីស្ដ និងរបស់ព្រះសហគមន៍ឲ្យបានកាន់តែពេញលេញឡើង។

ក៏ប៉ុន្ដែ ដោយគ្រីស្ដបរិស័ទបែកបាក់គ្នាដូច្នេះ គេរារាំងព្រះសហគមន៍មិនឲ្យមានលក្ខណៈកាតូលិក ជាលក្ខណៈរបស់ខ្លួនផ្ទាល់ឲ្យបានពេញលេញ ក្នុងអស់អ្នកដែលជាកូនចៅរបស់ខ្លួនដោយសារអគ្គសញ្ញាជ្រមុជទឹក តែដែលបែកចេញពីការរួបរួមដ៏ពេញលេញទៅហើយ។ មិនតែប៉ុណ្ណោះសោត ព្រះសហគមន៍ផ្ទាល់ក៏ពិបាកបង្ហាញគ្រប់វិស័យនៃលក្ខណៈកាតូលិករបស់ខ្លួនយ៉ាងពេញលេញបាន ក្នុងការរស់នៅរបស់មនុស្សលោកដែរ។

មហាសន្និបាតមានអំណរសប្បាយដោយកត់សម្គាល់ថា មានគ្រីស្ដបរិស័ទកាតូលិកកាន់តែច្រើនឡើងៗ ចូលរួមក្នុងចលនាបង្រួបបង្រួមគ្រីស្ដបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ។ មហាសន្និបាតក៏សូមផ្ញើចលនានោះឲ្យអស់លោកអភិបាលនៅលើផែនដីទាំងមូល សូមអស់លោកយកចិត្តទុកដាក់លើកស្ទួយចលនានេះ ព្រមទាំងណែនាំចលនានោះដោយត្រិះរិះពិចារណាផង។

# ជំពូក ២

## ការប្រតិបត្តិតាមចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ

៥-ព្រះសហគមន៍ទាំងមូល ទាំងគង្វាល ទាំងគ្រីស្តបរិស័ទធម្មតា ត្រូវតែយកចិត្តទុកដាក់នាំឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាធ្លុងតែមួយ ដោយការរស់នៅជារៀងរាល់ថ្ងៃ ឬដោយស្រាវជ្រាវទេវវិទ្យានិងប្រវត្តិសាស្រ្ត គឺម្នាក់ៗតាមសមត្ថភាពរៀងៗខ្លួន។ ការយកចិត្តទុកដាក់បែបនេះបង្ហាញចំណងម៉្យាងរបស់គ្រីស្តបរិស័ទជាបងប្អូនហើយអាចបណ្តោយឲ្យគេរួបរួមគ្នាយ៉ាងពេញលេញនិងពេញលេក្ខណៈ តាមព្រះជាម្ចាស់អាណិតមេត្តា។

### ៦-ការកែសម្រួលព្រះសហគមន៍ឲ្យបានជាថ្មី

ព្រះសហគមន៍កែសម្រួលជាថ្មី មានអត្តន័យជាអាទិ៍ថា ព្រះសហគមន៍ត្រូវតែស្មោះនឹងព្រះជាម្ចាស់ដែលត្រាស់ហៅគេ។ កម្លាំងនៃចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ អាស្រ័យតែលើការកែសម្រួលបែបនោះ។ នៅពេលសហគមន៍ធ្វើបូជនិយេសចររបស់ខ្លួននៅលើផែនដីនេះ ព្រះគ្រីស្តត្រាស់ហៅព្រះសហគមន៍ឲ្យកែសម្រួលជាថ្មីជាអចិន្រ្តៃយ៍ ពីព្រោះព្រះសហគមន៍ជាស្ថាប័នដែលមានលក្ខណៈជាមនុស្សលោកីយ៍។ ហេតុនេះហើយបានជាតាមកាលៈទេសៈ ប្រហែលព្រះសហគមន៍មិនសូវបានប្រយ័ត្នប្រយែងត្រង់ប្រការខ្លះៗ អំពីសីលធម៌ អំពីក្បួនវិន័យក្រុមបូជាចារ្យ សូម្បីតែអំពីរបៀបចែងលទ្ធិនៃគ្រីស្តសាសនា (ដែលប្លែកពីបញ្ញើនៃជំនឿដែលព្រះគ្រីស្តផ្ញើទុកនោះ) ត្រូវកែសម្រួលឲ្យបានល្អ ក្នុងរយៈពេលនិងតាមរបៀបដ៏សមរម្យដែរ។

ហេតុនេះ ការកែព្រះសហគមន៍ជាថ្មីនោះ ពិតជាមានប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតក្នុងចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយ។ ព្រះសហគមន៍កំពុងតែកែសម្រួលជាថ្មីបែបនេះតាមវិស័យផ្សេងៗនៃការរស់នៅរបស់ខ្លួន គឺតាមចលនាសិក្សាព្រះគម្ពីរនិងពិធីគោរពប្រណិប័តន៍ តាមរបៀបធ្វើពិធីអត្ថាធិប្បាយគម្ពីរ តាមរបៀបអប់រំជំនឿ តាមរបៀបគ្រីស្តបរិស័ទបំពេញកិច្ចការជាគ្រីស្តទូត តាមរបៀបបព្វជិតបព្វជិតារស់នៅជាថ្មីជាច្រើនយ៉ាង តាមរបៀបគូស្វាមីភរិយារស់នៅស្របតាមព្រះវិញ្ញាណ តាមលទ្ធិនិងសកម្មភាពរបស់ព្រះសហគមន៍អំពីសង្គមកិច្ច។ល។ ត្រូវរាប់ការកែសម្រួលទាំងនោះ ទុកជាសក្ខីភាពនិងទុកជាសញ្ញាសម្គាល់ផ្តល់ដំណឹងថា ចលនាបង្រួបបង្រួមគ្រីស្តបរិស័ទមុខជានឹងចម្រើនឡើងជាលំដាប់លំដោយនៅពេលអនាគតពុំខាន។

### ៧-ត្រូវប្រែចិត្តគំនិត

មានចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ ឲ្យរួបរួមគ្នាជាធ្លុងតែមួយយ៉ាងពិតប្រាកដ លុះត្រាតែគ្រីស្តបរិស័ទប្រែចិត្តគំនិត។ បំណងប្រាថ្នាចង់ឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ ហូរមក និងចម្រើនឡើងពីគ្រីស្តបរិស័ទប្រែចិត្តគំនិតសុខចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួន បង្ហាញសេចក្តីស្រឡាញ់ដោយសេរី។ ហេតុនេះ ត្រូវតែអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ សូមព្រះអង្គប្រណីសន្តោសឲ្យយើងលះបង់ខ្លួនឯងយ៉ាងស្មោះ មានចិត្តសុភាពរាបសា បម្រើអ្នកដទៃដោយចិត្តស្លូតបូត មាន

ចិត្តទូលំទូលាយចំពោះអ្នកដទៃដូចជាចំពោះបងប្អូន។ គ្រីស្តទូតប៉ូលជាសាសនទូត ដែលបានប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍ចែងថា៖ *"ខ្ញុំដែលជាប់ឃុំឃាំង សូមដាស់តឿនបងប្អូនក្នុងព្រះនាមព្រះអម្ចាស់ថា ដោយព្រះជាម្ចាស់បានត្រាស់ហៅបងប្អូន ចូររស់នៅឲ្យបានសមរម្យនឹងការត្រាស់ហៅនោះទៅ។ ចូរបន្ទាបខ្លួន ចូរមានចិត្តស្លូតបូតនិងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់។ ចូរយកចិត្តទុកដាក់រក្សាការរួបរួមគ្នា ដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្តីសុខសាន្តធ្វើជាចំណងប្រាស្រ័យទាក់ទងគ្នា" (អភ ៤, ១-៣)។ ពាក្យដាស់តឿននេះសំដៅយ៉ាងពិសេសចំពោះអស់អ្នក ដែលទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ ដោយមានគោលបំណងបន្តបេសកកម្មរបស់ព្រះគ្រីស្ត គឺរបស់ព្រះអង្គដែលយាងមកក្នុងលោកនេះ "មិនមែនដើម្បីឲ្យគេបម្រើលោកទេ គឺមកបម្រើគេវិញ"* (មថ ២០, ២៨)។

ពេលយើងគិតពីអំពើបាបនៃការបាក់បែកគ្នា យើងអាចនឹកដល់សក្ខីភាពរបស់គ្រីសទូតយ៉ូហានដែលមានប្រសាសន៍ថា៖ *"ប្រសិនបើយើងពោលថា យើងគ្មានបាបសោះនោះ ដូចជាយើងចោទថា ព្រះជាម្ចាស់កុហកទៅវិញ ហើយព្រះបន្ទូលរបស់ព្រះអង្គមិនស្ថិតនៅក្នុងខ្លួនយើងទេ"* (១យហ ១, ១០)។ ហេតុនេះ យើងត្រូវទូលអង្វរដោយចិត្តសុភាពរាបសា សូមព្រះជាម្ចាស់និងបងប្អូនដែលបែកចេញពីយើង អត់ទោសឲ្យយើង ដូចយើងអត់ទោសឲ្យអស់អ្នកដែលប្រព្រឹត្តខុសនឹងយើងដូច្នោះដែរ។

សូមគ្រីស្តបរិស័ទទាំងអស់នឹកចាំថា ប្រសិនបើគេយកចិត្តទុកដាក់ ខិតខំរស់នៅតាមដំណឹងល្អកាន់តែបរិសុទ្ធឡើងៗ គេមុខជានឹងជួយ ហើយក៏ធ្វើឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយ។ គេរួបរួមគ្នាជាមួយព្រះបិតា ជាមួយព្រះបន្ទូល និងជាមួយព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងជិតស្និទ្ធឡើងយ៉ាងណា គេក៏មុខជានឹងអាចនាំឲ្យគ្រីស្តបរិស័ទរស់នៅដូចបងប្អូនយ៉ាងជិតស្និទ្ធនិងស្រួលយ៉ាងនោះដែរ។

## ៨-ត្រូវរួមគ្នាអធិដ្ឋាន

ត្រូវចាត់ទុកថា ការប្រែចិត្តគំនិត និងការរស់នៅបែបវិសុទ្ធយ៉ាងនេះ រួមជាមួយពិធីអធិដ្ឋានជាសាធារណៈ និងពាក្យអធិដ្ឋានម្នាក់ៗ ពិតជាដួងព្រលឹងនៃចលនាបង្រួបបង្រួមគ្រីស្តបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយមែន។ យើងក៏អាចហៅការទាំងនោះយ៉ាងត្រឹមត្រូវថា ជាចលនាបង្រួបបង្រួមគ្រីស្តបរិស័ទខាងព្រះវិញ្ញាណ។

គ្រីស្តបរិស័ទកាតូលិកចូលចិត្តជួបជុំគ្នាជាញឹក អង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសឲ្យព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយ គឺអង្វរព្រះអង្គសាជាថ្មីតាមរបៀបព្រះអម្ចាស់ទទូចអង្វរព្រះបិតានៅថ្ងៃមុនចូលទិវង្គតថា៖ *"សូមឲ្យគេទាំងអស់គ្នា រួមជាអង្គតែមួយ"* (យហ ១៧, ២១)។

ក្នុងសភាពការណ៍ពិសេសខ្លះ ឧប. ក្នុងឱកាសពិធីអធិដ្ឋានចាត់ចែង *"សម្រាប់ឲ្យគ្រីស្តបរិស័ទរួបរួមគ្នា"* និងក្នុងឱកាសអង្គប្រជុំចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ គ្រីស្តបរិស័ទកាតូលិកមានសិទ្ធិ ហើយក៏ត្រូវអង្វរព្រះជាម្ចាស់រួមជាមួយបងប្អូនដែលបែកចេញទៅ។ ពិធីទទូចអង្វររួមបែបនេះពិតជាមធ្យោបាយដ៏ស័ក្តិសិទ្ធ សូមព្រះជាម្ចាស់ប្រណីសន្តោសឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយមែន។ ម៉្យាងវិញទៀត ពិធីអង្វររួមទាំងនោះ បង្ហាញយ៉ាងជាក់ច្បាស់ នូវចំណងនានារបស់គ្រីស្តបរិស័ទកាតូលិក ដែលនៅតែរួមជាមួយបងប្អូនដែលបែកចេញទៅ *"ដ្បិតនៅទីណាមានពីរ ឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះជាមួយគេដែរ"* (មថ ១៨, ២០)។

ប៉ុន្តែ គ្រីស្តបរិស័ទកាតូលិកគ្មានសិទ្ធិចាត់ *"ការរួបរួមធ្វើពិធីដ៏សក្ការៈជាមួយគ្នា"* ទុកជាមធ្យោបាយអាចប្រើបាន ដោយគ្មានរិះគិតពិចារណា ដើម្បីឲ្យគ្រីស្តបរិស័ទរួបរួមគ្នាជាធ្លុងតែមួយឡើងវិញបានទេ។ មានគោលការណ៍ពីរយ៉ាង ណែនាំ *"ការរួបរួមធ្វើពិធីដ៏សក្ការៈជាមួយគ្នា"* នោះ គឺការរួបរួមធ្វើពិធីនោះត្រូវសម្តែងថា ព្រះសហគមន៍រួបរួមជាធ្លុងតែមួយមែន។ គោលការណ៍ទីពីរ គឺណែនាំអ្នកចូលរួម ឲ្យទទួលចំណែកនៃមធ្យោបាយព្រះជាម្ចាស់ប្រណីសន្តោសមនុស្សលោក។ តាមធម្មតា *"ការរួបរួមធ្វើពិធីដ៏សក្ការៈជាមួយគ្នា"* មិនអាចធ្វើបាន ព្រោះពិធីនោះ មិនបង្ហាញការរួបរួមជាធ្លុងតែមួយទេ។ តែជួនកាល បើគិតពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ត្រូវរួបរួមធ្វើពិធីដ៏សក្ការៈវិញ។ ចំពោះរបៀបប្រតិបត្តិយ៉ាងជាក់ច្បាស់ ត្រូវនឹកគិតដល់សភាពការណ៍នៃទីកន្លែងនៃកាលៈទេសៈ និងនៃបុគ្គលនានា។ លោកអភិបាលភូមិភាគ ត្រូវផ្តល់សេចក្តីណែនាំដោយប្រុងប្រយ័ត្នសម្រាប់ចាត់ចែងពិធីនោះ លើកលែងតែក្រុមអភិបាលក្នុងប្រទេសចាត់ចែងតាមរបៀបផ្សេង ស្របតាមលក្ខន្តិកៈក្រុមនោះផ្ទាល់ ឬតាមសន្តះអាសនៈចាត់ចែងដែរ។

## ៩- គ្រីស្តបរិស័ទគ្រប់និកាយត្រូវស្គាល់គ្នាទៅវិញទៅមក

ត្រូវស្គាល់ចិត្តគំនិតរបស់បងប្អូនដែលបែកចេញពីយើង។ ហេតុនេះ ត្រូវសិក្សាដើម្បីស្គាល់ចិត្តគំនិតគេ ប៉ុន្តែ ត្រូវសិក្សាដោយចិត្តស្មោះ និងដោយចិត្តមេត្តាករុណា។ គ្រីស្តបរិស័ទកាតូលិកខ្លះ ត្រូវរៀបចំខ្លួនយ៉ាងសមរម្យជាមុនសិន ទើបសិក្សាឲ្យមានចំណេះចេះដឹងកាន់តែច្បាស់ អំពីលទ្ធិនិងអំពីប្រវត្តិសាស្ត្រនិកាយនីមួយៗ អំពីការរស់នៅតាមព្រះវិញ្ញាណ និងអំពីវប្បធម៌របស់គេអំពីមតិខាងសាសនា និងអំពីវប្បធម៌ផ្ទាល់របស់បងប្អូនទាំងនោះ។ គ្រីស្តបរិស័ទក៏អាចជួយឲ្យមានចំណេះចេះដឹងបែបនេះ ដោយចាត់ចែងប្រជុំចម្រុះគ្នាបានដែរ។ អ្នកចូលរួមត្រូវមានសមត្ថភាពយ៉ាងពិតប្រាកដ ហើយត្រូវរិះគិតជាពិសេសអំពីបញ្ហាទេវវិទ្យា ដោយភាគីទាំងអស់មានសិទ្ធិស្មើគ្នា ក្រោមការប្រុងប្រយ័ត្នរបស់អភិបាលទាំងឡាយ។ ការសន្ទនាបែបនោះ មុខជាបណ្តោយឲ្យគោលជំហរដ៏ពិតប្រាកដរបស់ព្រះសហគមន៍កាតូលិកលេចធ្លោភ្លឺកាន់តែច្បាស់ឡើងៗ។ តាមរបៀបនេះ យើងក៏ស្គាល់គោលគំនិតបងប្អូនដែលបែកចេញកាន់តែច្បាស់ ហើយយើងក៏អាចបង្ហាញលទ្ធិជំនឿរបស់យើងកាន់តែសមរម្យដែរ។

## ១០-ការអប់រំអំពីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ

ត្រូវបង្រៀនទេវវិទ្យានិងវិទ្យាឯទៀតៗ ជាពិសេសប្រវត្តិសាស្ត្រ ស្របតាមតាមគំនិតនៃចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ ដើម្បីឲ្យតបឆ្លើយយ៉ាងត្រឹមត្រូវស្របតាមសេចក្តីពិត។

អស់លោកដែលត្រៀមខ្លួនទៅជាអភិបាលនិងជាបូជាចារ្យ ត្រូវយល់ច្បាស់អំពីទេវវិទ្យា ដែលបានរិះគិតតាមបែបនោះជាចាំបាច់បំផុត ជាពិសេសត្រូវសិក្សាអំពីបញ្ហា ដែលមានពាក់ព័ន្ធនឹងទំនាក់ទំនងរវាងបងប្អូនដែលបែកចេញជាមួយព្រះសហគមន៍កាតូលិក។ ប៉ុន្តែ ត្រូវសិក្សាមិនមែនតាមបែបជជែកដេញដោលគ្នាសោះឡើយ។

គ្រីស្តបរិស័ទធម្មតានិងបព្វជិតបព្វជិតា ទទួលការបង្រៀន និងការអប់រំឲ្យរស់នៅតាមព្រះវិញ្ញាណ ពិតជាការដ៏ចាំបាច់។ តែការបង្រៀននិងអប់រំនោះ អាស្រ័យយ៉ាងពិសេសទៅលើការអប់រំរបស់អស់បូជាចារ្យ។

គ្រីស្តបរិស័ទជាសាសនទូត ធ្វើការនៅប្រទេសដែលមានគ្រីស្តបរិស័ទនិកាយផ្សេងៗធ្វើការដែរ ក៏ត្រូវស្គាល់បញ្ហាចោទឡើងដោយចលនាបង្រួបបង្រួម ក្នុងកិច្ចការរបស់ខ្លួនជាគ្រីស្តទូត ជាពិសេសសព្វថ្ងៃ និងអំពីលទ្ធផលរបស់ចលនានោះទៀតផងដែរ។

## ១១-របៀបសម្ដែងនិងការបរិយាយលទ្ធិនៃជំនឿ

វិធីនិងរបៀបរៀបរាប់លទ្ធិកាតូលិក មិនត្រូវរារាំងការសន្ទនាជាមួយបងប្អូនទាំងនោះទេ។ ត្រូវរៀបរាប់លទ្ធិទាំងស្រុងយ៉ាងច្បាស់ ដោយមិនលាក់លៀមអ្វីជាដាច់ខាត។ អ្នកលាក់លៀមបញ្ហាដែលចោទឡើង ដើម្បីបានសេចក្ដីសុខសាន្តក្លែងក្លាយ ពិតជាខុសទាំងស្រុងនឹងចលនាបង្រួបបង្រួមគ្រីស្តបរិស័ទ ព្រោះរបៀបនោះបង្ខូចលទ្ធិកាតូលិក និងបណ្ដាលឲ្យគេមិនអាចយល់អត្ថន័យដ៏ពិតប្រាកដដែលប្រកែកមិនបាននៃលទ្ធិនោះ។

នៅពេលជាមួយគ្នានេះត្រូវពន្យល់លទ្ធិកាតូលិកឲ្យកាន់តែជ្រៅទៅៗ និងកាន់តែទៀងត្រង់ ដោយយករបៀបនិយាយ និងពាក្យពេចន៍ដែលមនុស្សទូទៅធ្លាប់ប្រើ សូម្បីតែបងប្អូនដែលបែកចេញនោះ អាចស្ដាប់បានដែរ។

លើសពីនេះទៅទៀត ទេវវិទូកាតូលិក ដែលកាន់តាមលទ្ធិកាតូលិកយ៉ាងស្មោះ នៅពេលអស់លោកសន្ទនាជាមួយបងប្អូនដែលបែកចេញ ក៏ត្រូវស្រាវជ្រាវអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ រួមជាមួយបងប្អូនទាំងនោះដែរ។ ប៉ុន្តែអស់លោកត្រូវរិះគិតដោយចិត្តចង់រកសេចក្ដីពិត ទាំងមានចិត្តស្រឡាញ់និងចិត្តសុភាព។ ពេលរៀបរាប់លទ្ធិកាតូលិក អស់លោកត្រូវនឹកចាំថា ប្រការនីមួយៗក្នុងលទ្ធិកាតូលិកទាំងមូល មិនស្មើទាំងអស់ទេ តែមានសារៈសំខាន់ប្លែកៗគ្នា តាមលំដាប់លំដោយវិញ គឺស្រេចតាមទំនាក់ទំនងនឹងគ្រឹះនៃលទ្ធិ។ ហេតុនេះហើយ បានជាមានមាគ៌ាមួយ ដាស់តឿនទេវវិទូទាំងអស់ឲ្យប្រណាំងប្រជែង រកចំណេះចេះដឹងកាន់តែជ្រៅទៅៗ និងឲ្យសម្ដែងអំពី *"ព្រះជន្មដ៏បរិបូណ៌បំផុតរបស់ព្រះគ្រីស្ត ដែលមនុស្សលោកគិតមិនដល់នោះ"* (អភ ៣, ៨) ឲ្យកាន់តែច្បាស់ឡើងៗដែរ។

## ១២-អំពីការរួមសហការជាមួយបងប្អូនដែលបែកចេញទៅហើយ

សូមឲ្យគ្រីស្តបរិស័ទទាំងអស់ នាំគ្នាប្រកាសជំនឿរបស់ខ្លួនទៅលើព្រះជាម្ចាស់តែមួយព្រះអង្គ ជាព្រះត្រៃឯក ទៅលើព្រះបុត្រារបស់ព្រះជាម្ចាស់ដែលប្រសូតជាមនុស្ស ជាព្រះសង្គ្រោះដែលបានរំដោះយើង និងជាព្រះអម្ចាស់ នៅចំពោះមុខមនុស្សគ្រប់ជាតិសាសន៍ផង។ សូមឲ្យគ្រីស្តបរិស័ទទាំងអស់ខិតខំរួមគ្នា គោរពរាប់អានគ្នាទៅវិញទៅមក នាំគ្នាផ្ដល់សក្ខីភាពអំពីសេចក្ដីសង្ឃឹមរបស់យើង ជាសេចក្ដីសង្ឃឹមដែលមិននាំឲ្យខកចិត្តឡើយ។ សព្វថ្ងៃមនុស្សនាំគ្នាតែងតែសហការគ្នាជាទូទៅផ្នែកសង្គម។ ដូច្នេះ មនុស្សទាំងអស់ត្រូវតែបម្រើកិច្ចរួមនេះ ដោយគ្មាននរណាម្នាក់អាក់ខានបានឡើយ ជាពិសេសអ្នកដែលផ្ញើជីវិតលើព្រះជាម្ចាស់ មានគ្រីស្តបរិស័ទទាំងអស់មុនគេបង្អស់ ព្រោះគេពាក់ឈ្មោះរបស់ព្រះគ្រីស្តជាកិត្តិយសរបស់គេ។ គ្រីស្តបរិស័ទទាំងអស់ដែលសហការគ្នាបង្ហាញបញ្ជាក់យ៉ាងច្បាស់ថា ព្រះសហគមន៍រួបរួមគ្នាជាធ្លុងតែមួយខ្លះៗរួចហើយ។ គេក៏សម្ដែងព្រះភ័ក្ត្រព្រះគ្រីស្តក្នុងឋានៈព្រះអង្គជាអ្នកបម្រើ ឲ្យភ្លឺកាន់តែច្បាស់ឡើងៗដែរ។ គ្រីស្តបរិស័ទសហការបែបនេះ ក្នុងប្រទេសជាច្រើនរួចហើយ តែត្រូវសហការគ្នាឲ្យកាន់តែខ្លាំងឡើងៗទៀតផង ជាពិសេសនៅប្រទេសមានសង្គមកំពុងលូតលាស់ ឬមានបច្ចេកទេសកំពុងចម្រើនឡើង។ ក្នុងប្រទេសទាំងនោះ គ្រីស្តបរិស័ទត្រូវសហការគ្នាដោយនាំឲ្យគេគោរពតម្លៃដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ ត្រូវសហការគ្នាជួយកសាងសន្តិភាព ត្រូវសហការគ្នាក្នុងកិច្ចបន្តការអនុវត្តន៍តាមដំណឹងល្អផ្នែកសង្គម។ ត្រូវសហការគ្នាឲ្យវិទ្យាសាស្ត្រ និងសិល្បៈលូតលាស់ឡើងក្នុងបរិយាកាសស្របតាមគ្រីស្តសាសនា។ ម្យ៉ាងវិញទៀត ត្រូវសហការគ្នាជួយព្យាបាលទុក្ខគ្រប់យ៉ាងរបស់មនុស្សលោកនាសម័យបច្ចុប្បន្ន មានទុរ្ភិក្ស មហន្តរាយ ភាពល្ងង់ខ្លៅ ភាពក្រីក្រ គ្មានផ្ទះនៅ ការចែកធនធានមិន ស្មើគ្នាជាដើម។ បើអស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្តរួមសហការបែបនេះ គេមុខជានឹងអាចរៀនយ៉ាងស្រួលអំពីរបៀបមនុស្សអាចស្គាល់គ្នាទៅវិញទៅមកបាន គោរពរាប់អានគ្នា និងរៀបចំផ្លូវឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាធ្លុងតែមួយផង។

# ជំពូក ៣

## ព្រះសហគមន៍និងក្រុមជំនុំ ដែលបែកចេញពីអាសនៈគ្រីស្តទូតនៅក្រុងរ៉ូម

១៣-ឥឡូវយើងសូមពិនិត្យមើលការបែកបាក់ដ៏ធំជាងគេ ដែលបណ្តាលឲ្យអាវវែងឥតថ្នេររបស់ព្រះគ្រីស្ត ត្រូវរហែក។ ព្រះសហគមន៍បែកបាក់មុនគេនៅបូព៌ាប្រទេស គឺមានគ្រីស្តបរិស័ទខ្លះប្រកែកតវ៉ាមិនព្រមទទួលស្គាល់សេចក្តីបញ្ជាក់លទ្ធិនៃជំនឿនៃមហាសន្និបាតអេភេសូ និងកាលសេដូន។ នៅពេលក្រោយ អភិបាលដ៏ប្រសើរឧត្តមនៅបូព៌ាប្រទេស និងអាសនៈក្រុងរ៉ូម ក៏ផ្តាច់ការរួបរួមគ្នាក្នុងព្រះសហគមន៍ដែរ។

ជាងបួនសតវត្សក្រោយមកទៀត ព្រះសហគមន៍បែកបាក់ជាច្រើននិកាយនៅបស្ចិមប្រទេស បណ្តាលមកពីព្រឹត្តិការណ៍ដែលគេតែងហៅថា *"ការកែទម្រង់"*។ មានក្រុមជំនុំជាច្រើនកើតឡើង តាមជាតិ ឬតាមជំនឿរបស់គេ ហើយបែកចេញពីអាសនៈក្រុងរ៉ូម។ ក្នុងចំណោមក្រុមសហគមន៍ឬក្រុមជំនុំដែលនៅតែរក្សាប្រពៃណី និងរចនាសម្ព័ន្ធកាតូលិកខ្លះ មានសហគមន៍អង់គ្លីកង់ ដោយឡែកពីគេ។

ប៉ុន្តែ ការបែកបាក់គ្នាទាំងនោះប្លែកៗពីគ្នាយ៉ាងខ្លាំង គឺមិនគ្រាន់តែប្លែកពីគ្នាដោយកំណើត ឬដោយសភាពការណ៍តាមកាលៈទេសៈ និងតាមទីកន្លែងរបស់គេប៉ុណ្ណោះទេ តែប្លែកពីគ្នាជាពិសេសដោយលក្ខណៈ បញ្ហាដ៏ធ្ងន់ធ្ងរអំពីលទ្ធិនៃជំនឿ និងអំពីរចនាសម្ព័ន្ធរបស់ព្រះសហគមន៍។

ហេតុនេះហើយ បានជាមហាសន្និបាតយល់ឃើញថា គួរផ្តល់យោបល់ដូចខាងក្រោមនេះ ដើម្បីជួយបង្រួបបង្រួមគ្រីស្តបរិស័ទដោយរិះគិតពិចារណា។ ប៉ុន្តែ ត្រូវវាយតម្លៃសភាពការណ៍ប្លែកៗនៃសង្គមគ្រីស្តបរិស័ទផ្សេងៗ ឲ្យបានត្រឹមត្រូវ ហើយទោះបីគេបែកបាក់គ្នាឯងក្តី ក៏ត្រូវបង្ហាញចំណងដែលនៅស្ថិតស្ថេររវាងក្រុមគ្រីស្តបរិស័ទទាំងនោះដែរ។

### ១-យោបល់អំពីព្រះសហគមន៍នៅបូព៌ាប្រទេស

#### ១៤-មតិនិងប្រវត្តិផ្ទាល់របស់បងប្អូនគ្រីស្តបរិស័ទនៅបូព៌ាប្រទេស

អស់រយៈប៉ុន្មានសតវត្សខាងដើមដំបូង ព្រះសហគមន៍នៅបូព៌ាប្រទេស និងព្រះសហគមន៍នៅបស្ចិមប្រទេស តែងតែដើរតាមមាគ៌ារៀងៗខ្លួន តែរួបរួមគ្នាទុកជាបងប្អូនត្រង់លទ្ធិនៃជំនឿនិងត្រង់របៀបធ្វើអគ្គសញ្ញា។ នៅពេលគេខ្វែងគំនិតគ្នាអំពីលទ្ធិនៃជំនឿ ឬអំពីក្បួនវិន័យ ព្រះសហគមន៍ទាំងសងខាងយល់ព្រមជាមួយគ្នាឲ្យអាសនៈក្រុងរ៉ូម ធ្វើអន្តរាគមន៍។ ក្នុងចំណោមសេចក្តីដ៏សំខាន់ៗ មហាសន្និបាតចូលចិត្តរំឭកបងប្អូនទាំងអស់ថា នៅបូព៌ាប្រទេសមានព្រះសហគមន៍ជាច្រើនដោយឡែក ឬតាមភូមិភាគ មានព្រះសហគមន៍ដែលអភិបាលដ៏ប្រសើរឧត្តមណែនាំជាដើម តែងអះអាងថា ក្រុមគ្រីស្តទូតបានតែងតាំង។ ហេតុនេះហើយ បានជាក្នុងចំណោមគ្រីស្តបរិស័ទនៅបូព៌ាប្រទេសពីដើម គេមានអាទិភាព (ហើយសព្វថ្ងៃគេក៏នៅតែមានអាទិភាពដដែលដែរ) គឺគេយកចិត្តទុកដាក់យ៉ាងពិសេស រក្សាទំនាក់ទំនងដែលត្រូវតែមានរវាងព្រះសហគមន៍ភូមិភាគនីមួយៗទុកជាប្អូនស្រី ដោយរួបរួមគ្នាតាមលទ្ធិនៃជំនឿ និងសេចក្តីស្រឡាញ់។

យើងមិនត្រូវបំភ្លេចទៀតថា ព្រះសហគមន៍នៅបូព៌ាប្រទេស មានគុណសម្បត្តិដ៏ថ្លៃថ្នូរតាំងពីដើមរៀងមក។ ព្រះសហគមន៍នៅបស្ចិមប្រទេស បានយោងកត្តាជាច្រើនពីគុណសម្បត្តិដ៏ថ្លៃថ្នូរនេះ គឺកត្តាខាងពិធីគោរពប្រណិប័តន៍ ខាងរបៀបរស់នៅតាមព្រះវិញ្ញាណជាប្រពៃណីបញ្ជូនបន្តមក និងខាងច្បាប់វិន័យ។ យើងក៏ត្រូវដឹងថា មហាសន្និបាតសកលជាច្រើនដែលជួបជុំគ្នានៅបូព៌ាប្រទេស បានប្រកាសបញ្ជាក់គោលលទ្ធិសំខាន់ៗជាគ្រឹះនៃលទ្ធិនៃ ជំនឿគ្រិស្តសាសនា គឺគោលលទ្ធិអំពីព្រះត្រៃឯក អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលប្រសូតជាមនុស្សដោយសារ ព្រះនាងព្រហ្មចារិនីម៉ារី។ យើងត្រូវចាត់ទុកថា ព្រឹត្តិការណ៍ទាំងនេះមានតម្លៃដ៏ថ្លៃប្រសើរ។ ព្រះសហគមន៍ទាំងនោះក៏បានរងទុក្ខវេទនាជាទម្ងន់ ដើម្បីរក្សាទុកជំនឿរបស់ខ្លួន ហើយសព្វថ្ងៃ គេក៏នៅតែរងទុក្ខវេទនានៅឡើយដែរ។

តាំងពីដើមដំបូងនៃព្រះសហគមន៍ គ្រីស្តបរិស័ទទទួលសេចក្តីដែលបញ្ជូនបន្តពីក្រុមគ្រីស្តទូតមក តាមរបៀបប្លែកៗពីគ្នា គេក៏ពន្យល់បេតិកភ័ណ្ឌនោះតាមរបៀបប្លែកៗពីគ្នាដែរ ស្របតាមទេពកោសល្យ និងតាមសភាពការណ៍ជីវភាពប្លែកៗពីគ្នា។ មូលហេតុទាំងនោះ និងមូលហេតុផ្សេងៗទៀតខាងក្រៅព្រះសហគមន៍ ជាឱកាសបណ្តាលឲ្យព្រះសហគមន៍បាក់បែកគ្នា។ គ្រីស្តបរិស័ទទាំងសងខាងស្តាប់គ្នាមិនបាន មិនយល់ចិត្តគំនិតគ្នា ហើយក៏ខ្វះសេចក្តីស្រឡាញ់ ពិតជាមូលហេតុបណ្តាលឲ្យបែកបាក់គ្នាថែមទៀត។

ហេតុនេះហើយ បានជាមហាសន្និបាតដាស់តឿនគ្រីស្តបរិស័ទទាំងអស់ ជាពិសេសអស់អ្នកដែលមានបំណងជួយធ្វើឲ្យព្រះសហគមន៍នៅបូព៌ាប្រទេស និងព្រះសហគមន៍នៅបស្ចិមប្រទេសរួបរួមគ្នាយ៉ាងពេញលេញ តាមបំណងប្រាថ្នាព្រះសហគមន៍ទាំងពីរ សូមរិះគិតពិចារណាយ៉ាងច្បាស់ អំពីសភាពការណ៍ពិសេសរបស់ព្រះសហគមន៍នៅបូព៌ាប្រទេស អំពីសម័យព្រះសហគមន៍ទាំងនោះកើតនិងចម្រើនឡើង អំពីលក្ខណៈនៃទំនាក់ទំនងព្រះសហគមន៍ទាំងនោះ ជាមួយគ្នាផង និងជាមួយអាសនៈក្រុងរ៉ូមផង មុនពេលព្រះសហគមន៍ទាំងពីរបាក់បែកគ្នា។ សូមឲ្យគ្រីស្តបរិស័ទវាយតម្លៃយ៉ាងត្រឹមត្រូវ តាមយុត្តិធម៌អំពីសេចក្តីទាំងនោះ។ បើអស់អ្នកកាន់តាមគោលការណ៍ទាំងនេះឲ្យបានល្អ គោលការណ៍ទាំងនេះមុខជាអាចជួយយ៉ាងខ្លាំងក្នុងការសន្ទនាជាមួយគ្នា តាមគោលបំណងរបស់ខ្លួន។

## ១៥-ប្រពៃណីខាងពិធីគោរពប្រណិប័តន៍និងខាងការរស់នៅតាមព្រះវិញ្ញាណ

យើងម្នាក់ៗដឹងច្បាស់ថា គ្រីស្តបរិស័ទនៅបូព៌ាប្រទេសតែងតែធ្វើពិធីគោរពប្រណិប័តន៍ដោយចិ ត្តស្រឡាញ់យ៉ាងខ្លាំង ជាពិសេសរបៀបគេថ្វាយពិធីអរព្រះគុណ។ ពិធីគោរពប្រណិប័តន៍ទាំងនោះពិតជាប្រភពនៃជីវិតសម្រាប់ព្រះសហគមន៍ និងជាប្រផ្នូលបញ្ជាក់ចិត្តថា គេនឹងទទួលសិរីរុងរឿងនៃលោកខាងមុខទៀតផង។ ដោយពិធីគោរពប្រណិប័តន៍ទាំងនោះ គ្រីស្តបរិស័ទរួមជាមួយអភិបាល មានផ្លូវទៅកាន់ព្រះជាម្ចាស់ជាព្រះបិតា ដោយសារព្រះបុត្រា ជាព្រះបន្ទូលប្រសូតជាមនុស្ស ដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង ក្នុងព្រះវិញ្ញាណដែលព្រះអង្គចាក់បង្ហូរនោះ។ គេចូលរួបរួមជាមួយព្រះត្រៃឯកដ៏វិសុទ្ធបំផុត និង *"មានលក្ខណៈជាព្រះជាម្ចាស់"* (២សល ១, ៤)។ ដូច្នេះ ព្រះសហគមន៍របស់ព្រះជាម្ចាស់សាងសង់និងចម្រើនឡើង ដោយគេថ្វាយពិធីអរព្រះគុណព្រះអម្ចាស់ តាមព្រះសហគមន៍ដោយឡែកពីគ្នា។ ដោយអស់បូជាចារ្យថ្វាយពិធីអរព្រះគុណរួមគ្នា អស់លោកក៏សម្តែងឲ្យឃើញថា ព្រះសហគមន៍ទាំងនោះរួបរួមគ្នាទៀតដែរ។

ក្នុងពិធីគោរពប្រណិប័តន៍ទាំងនោះ គ្រីស្តបរិស័ទនៅបូព៌ាប្រទេសតែងតែលើកតម្កើងព្រះនាងម៉ារី ព្រហ្មចារិនីជាដរាប ដោយសូត្របទជាច្រើនដ៏សែនពិរោះ។ មហាសន្និបាតសកលក្រុងអេភេសូ បានប្រកាសយ៉ាងឱឡារិកថា

ព្រះនាងម៉ារីជាព្រះមាតាដ៏វិសុទ្ធបំផុតរបស់ព្រះជាម្ចាស់ ដើម្បីឲ្យគ្រីស្តបរិស័ទទទួលស្គាល់ថា ព្រះគ្រីស្តពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយក៏ពិតជាបុត្រមនុស្សផង ស្របតាមព្រះគម្ពីរ។

សន្តបុគ្គលជាច្រើនក៏ទទួលគារវៈកិច្ចយ៉ាងខ្លាំងដូច្នេះដែរ។ ក្នុងចំណោមសន្តបុគ្គលទាំងនោះ មានគ្រូបាធ្យាយនៃព្រះសហគមន៍សកលមួយចំនួនធំ។

ទោះបីព្រះសហគមន៍ទាំងនោះបែកចេញពីយើងក្តី ក៏យើងអាចរួបរួមធ្វើពិធីដ៏សក្ការៈខ្លះជាមួយគ្នាបាន តាមសភាពការណ៍អនុគ្រោះ និងដោយអភិបាលព្រះសហគមន៍អនុញ្ញាតឲ្យដែរ។ គ្រីស្តបរិស័ទកាតូលិកមិនគ្រាន់តែអាចចូលរួមបានប៉ុណ្ណោះទេ តែត្រូវទូន្មានឲ្យគេចូលរួមថែមទៀតផង ព្រោះថា ព្រះសហគមន៍ទាំងនោះមានអគ្គសញ្ញាដ៏ពិតប្រាកដ ហើយជាពិសេស ដោយមានអភិបាលតៗគ្នាតាំងពីក្រុមគ្រីស្តទូតរៀងមក នៅព្រះសហគមន៍ទាំងនោះមានមុខងារជាបូជាចារ្យ និងពិធីអរព្រះគុណទៀតផង។ ការណ៍ទាំងនោះធ្វើឲ្យព្រះសហគមន៍ទាំងនោះរួបរួមយ៉ាងជិតស្និទ្ធជាមួយយើង។

នៅបូព៌ាប្រទេស ក៏មានប្រពៃណីដ៏ថ្លៃថ្នូរអំពីការរស់នៅតាមព្រះវិញ្ញាណ ដែលចេញមុខជាពិសេសដោយមានក្រុមលោកសង្ឃជាច្រើន។ នៅតំបន់ទាំងនោះ តាំងពីសម័យដ៏រុងរឿងនៃគ្រូបាធ្យាយដ៏វិសុទ្ធមក គោលគំនិតរស់នៅតាមព្រះវិញ្ញាណរីកដុះឡើង និងផ្សព្វផ្សាយនៅបស្ចិមប្រទេសតាមក្រោយ ហើយត្រឡប់ដូចជាប្រភពនៃការចាត់ចែងការរស់នៅរបស់បព្វជិតបព្វជិតាឡាតាំង។ របៀបរស់នៅរបស់គេ ក៏ផ្តល់ឲ្យការរស់នៅជាបព្វជិតបព្វជិតាឡាតាំងទាំងនោះទទួលកម្លាំងថ្មីទៀតដែរ។ ហេតុនេះហើយ បានជាយើងសូមផ្តែផ្តាំគ្រីស្តបរិស័ទកាតូលិកយ៉ាងខ្លាំង ឲ្យក្រេបជញ្ជក់នូវគុណសម្បត្តិដ៏ថ្លៃថ្នូរនៃជីវិតតាមព្រះវិញ្ញាណរបស់គ្រូបាធ្យាយបូព៌ាប្រទេស។ គុណសម្បត្តិដ៏ថ្លៃថ្នូរនៃជីវិតតាមព្រះវិញ្ញាណនោះ លើកមនុស្សទាំងស្រុងឲ្យបែរខ្លួនទៅស្ញឹងស្ញប់អំពីការអាថ៌កំបាំងដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

មនុស្សទាំងអស់ត្រូវដឹងថា ត្រូវស្គាល់ គោរព ថែរក្សា និងពង្រីកបេតិកភ័ណ្ឌដ៏ប្រសើរខាងពិធីបុណ្យ និងខាងជីវិតតាមព្រះវិញ្ញាណរបស់ព្រះសហគមន៍នៅបូព៌ាប្រទេស។ ភារកិច្ចនេះពិតជាការដ៏ចាំបាច់បំផុត ដើម្បីរក្សាប្រពៃណីទាំងស្រុងនៃគ្រីស្តសាសនាយ៉ាងស្មោះ។ ការគោរព ថែរក្សា និងការពង្រីកបេតិកភ័ណ្ឌនេះមុខជានឹងសម្រុះសម្រួលគ្រីស្តបរិស័ទបូព៌ាប្រទេសនិងគ្រីស្តបរិស័ទបស្ចិមប្រទេសជាពុំខាន។

## ១៦-ក្បួនវិន័យរបស់គ្រីស្តបរិស័ទនៅបូព៌ាប្រទេស

លើសពីនេះទៅទៀត តាំងពីដើមរៀងមក ព្រះសហគមន៍នៅបូព៌ាប្រទេសតែងតែអនុវត្តតាមក្បួនវិន័យផ្ទាល់ តាមការយល់ស្របរបស់អស់គ្រូបាធ្យាយ និងមហាសន្និបាតនានា។ ជួនកាលមហាសន្និបាតសកលយល់ស្របដែរ។ របៀបគោរព និងប្រពៃណីប្លែកៗពីគ្នា មិនទាស់នឹងព្រះសហគមន៍រួបរួមជាធ្លុងតែមួយទាល់តែសោះ ដូចមានចែងខាងលើ។ ដោយមានប្រពៃណី និងរបៀបរស់នៅប្លែកពីគ្នាដូច្នេះ ព្រះសហគមន៍មុខជាមានសោភ័ណភាពឆើតឆាយថែមទៀត ហើយក៏យកមកធ្វើជាជំនួយដ៏មានតម្លៃសម្រាប់បំពេញបេសកកម្មរបស់ខ្លួនដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតសូមប្រកាសថា ព្រះសហគមន៍នៅបូព៌ាប្រទេសដឹងខ្លួនថា ទោះបីព្រះសហគមន៍ទាំងមូលត្រូវរួបរួមគ្នាជាធ្លុងតែមួយ ជាចាំបាច់ក្តី ក៏ព្រះសហគមន៍ទាំងនោះមានសិទ្ធិសេរីភាពត្រួតត្រាខ្លួនឯង តាមក្បួនវិន័យរបស់គេដែរ ព្រោះក្បួនវិន័យទាំងនោះសមស្របតាមបុគ្គលិកលក្ខណៈគ្រីស្តបរិស័ទរបស់គេ និងអាចជួយលើកស្ទួយប្រយោជន៍របស់គេខាងវិញ្ញាណទៀតផង។ សូមកុំឲ្យមាននរណាមានមន្ទិលសង្ស័យអំពីសេចក្តីនេះឲ្យសោះ។ ត្រូវអនុវត្តតាមគោលការណ៍នេះយ៉ាងពេញ

លេញ ព្រោះជាគោលការណ៍តាមប្រពៃណីព្រះសហគមន៍។ តាមពិត តាមប្រវត្តិសាស្ត្រ គេមិនបានគោរពតាមគោលការណ៍នេះរហូតទេ តែគោលការណ៍នេះជាលក្ខ័ណ្ឌដ៏ចាំបាច់បំផុតមុនគេ ដើម្បីឲ្យគ្រីស្តបរិស័ទអាចរួបរួមគ្នាវិញបាន។

## ១៧-លក្ខណៈពិសេសរបស់គ្រីស្តបរិស័ទនៅបូព៌ាប្រទេសអំពីបញ្ហាលទ្ធិនៃជំនឿ

សេចក្តីចែងនៅខាងលើអំពីពិធីគោរពប្រណិប័តន៍ និងអំពីក្បួនវិន័យដែលប្លែកៗពីគ្នាយ៉ាងត្រឹមត្រូវ ក៏ត្រូវអនុវត្តតាម អំពីរបៀបពន្យល់បញ្ជាក់ទេវវិទ្យានៃលទ្ធិនៃជំនឿដែរ។ តាមពិតពេលគ្រីស្តបរិស័ទខិតខំរិះគិត ដើម្បីឲ្យយល់កាន់តែជ្រៅទៅៗ អំពីសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងមក គ្រីស្តបរិស័ទនៅបូព៌ាប្រទេសនិងនៅបស្ចិមប្រទេស បានប្រើវិធីនិងមធ្យោបាយប្លែកៗពីគ្នា ដើម្បីរកនិងពន្យល់បញ្ជាក់សេចក្តីអំពីព្រះជាម្ចាស់។ ហេតុនេះហើយកុំឆ្ងល់ថា គ្រីស្តបរិស័ទភាគីមួយ យល់និងពន្យល់បញ្ជាចាក់ទិដ្ឋភាពខ្លះ អំពីគម្រោងការដ៏អស្ចារ្យដែលព្រះជាម្ចាស់បានសម្តែងមកនោះយ៉ាងច្បាស់ជាងគ្រីស្តបរិស័ទភាគីមួយទៀត។ ដូច្នេះ ត្រូវរាប់ជាញឹកថា សេចក្តីពន្យល់បញ្ជាក់ទេវវិទ្យាប្លែកៗពីគ្នាទាំងនោះហាក់ដូចជាបន្ថែមអត្ថន័យឲ្យគ្នា ជាជាងទាស់ទែងគ្នាវិញ។ រីឯប្រពៃណីដ៏ពិតប្រាកដរបស់គ្រីស្តបរិស័ទនៅបូព៌ាប្រទេសយើងត្រូវទទួលស្គាល់ថា បានចាក់ឫសយ៉ាងល្អបំផុតក្នុងព្រះគម្ពីរ។ ពីធីគោរពប្រណិប័តន៍តែងតែបកស្រាយ និងពន្យល់រៀបរាប់ប្រពៃណីទាំងនោះ ក៏ទទួលជីវិតពីការបញ្ជូនបន្តដ៏រស់រវើកពីក្រុមគ្រីស្តទូតមក និងពីសំណេររបស់គ្រូបាធ្យាយនៅបូព៌ាប្រទេស ព្រមទាំងពីអ្នកនិពន្ធអំពីជីវិតខាងព្រះវិញ្ញាណទៀតផង។ ប្រពៃណីទាំងនោះ ក៏ណែនាំឲ្យគ្រីស្តបរិស័ទរស់នៅយ៉ាងត្រឹមត្រូវ រហូតដល់ណែនាំគេឲ្យសញ្ជឹងគិតយ៉ាងពេញលក្ខណៈអំពីសេចក្តីពិតនៃគ្រីស្តសាសនា។

មហាសន្និបាតដ៏វិសុទ្ធ សូមអរព្រះគុណព្រះជាម្ចាស់ ដោយដឹងថា គ្រីស្តបរិស័ទនៅបូព៌ាប្រទេសជាច្រើន ដែលជាកូនចៅរបស់ព្រះសហគមន៍កាតូលិក នៅតែថែរក្សាបេតិកភ័ណ្ឌនេះ ហើយមានបំណងចង់រស់នៅតាមបេតិកភ័ណ្ឌនេះឲ្យកាន់តែបរិសុទ្ធ និងកាន់តែពេញលេញ។ គេរស់នៅរួបរួមយ៉ាងពេញលក្ខណៈជាមួយបងប្អូនរបស់គេ ដែលកាន់តាមប្រពៃណីបស្ចិមប្រទេស។ មហាសន្និបាតប្រកាសថា បេតិកភ័ណ្ឌទាំងមូលនេះ ទាំងខាងជីវិតតាមព្រះវិញ្ញាណ ទាំងខាងពិធីគោរពប្រណិប័តន៍ ទាំងខាងក្បួនវិន័យនិងខាងទេវវិទ្យា តាមប្រពៃណីផ្សេងៗតាមការបញ្ជូនបន្តមក ក៏ពិតជាចំណែកនៃលក្ខណៈកាតូលិកយ៉ាងពេញលេញមែន ហើយក៏ពិតជាមានលក្ខណៈបន្តពីក្រុមគ្រីស្តទូត របស់ព្រះសហគមន៍ដែរ។

## ១៨-ពាក្យបញ្ចប់

ក្រោយពីបានពិនិត្យមើលសេចក្តីទាំងនេះយ៉ាងច្បាស់រួចហើយ មហាសន្និបាតសូមប្រកាសសាជាថ្មីនូវសេចក្តីដែលមហាសន្និបាតពីសម័យមុនៗ និងដែលអភិបាលព្រះសហគមន៍ក្រុងរ៉ូមនានាបានប្រកាសថា *"មិនគួរយកវិន័យណាផ្សេងទៀតដែលមិនចាំបាច់ មកបង្ខំបងប្អូនឲ្យប្រតិបត្តិតាមឡើយ"* (កក ១៥, ២៨) ដើម្បីបង្រួបបង្រួមគ្រីស្តបរិស័ទវិញ ឬដើម្បីរក្សាគេឲ្យរួបរួមជាមួយគ្នាជាធ្លុងតែមួយដែរ។ មហាសន្និបាតប្រាថ្នាចង់យ៉ាងខ្លាំងឲ្យគ្រីស្តបរិស័ទទាំងអស់ តាំងពីពេលនេះតទៅ ខិតខំធ្វើឲ្យព្រះសហគមន៍រួបរួមគ្នាបន្តិចម្តងៗ តាមកម្រិតផ្សេងៗ និងតាមរបៀបរស់នៅផ្សេងៗរបស់ព្រះសហគមន៍ ជាពិសេសដោយអធិដ្ឋាន និងសន្ទនាជាមួយគ្នាដូចបងប្អូន អំពីលទ្ធិជំនឿ និងអំពីតម្រូវការដ៏សំខាន់ៗជាបន្ទាន់ក្នុងមុខងារណែនាំនាសម័យយើងនេះ។ តាមរបៀបដដែលនេះ មហាសន្និបាតក៏ផ្តែផ្តាំអស់លោកគង្វាល និងគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិក ឲ្យមានទំនាក់ទំនងជាមួយនឹងគ្រីស្តបរិស័ទបូព៌ាប្រទេស ដែលមិនរស់នៅបូព៌ាទៀតទេ តែទៅរស់នៅឆ្ងាយពីមាតុភូមិរបស់គេ។ ដូច្នេះ គេពិតជាសហការជាមួយគ្នាដូចបងប្អូនកាន់តែខ្លាំងឡើងៗ គឺគំនិតវិញ្ញាណនៃសេចក្តីស្រឡាញ់មុខជានឹងបំបាត់ការប្រកួតប្រជែងគ្រប់យ៉ាង។ ប្រសិនបើ គ្រីស្តបរិស័ទខិតខំបំពេញកិច្ច

នេះដោយអស់ពីក្នុងចិត្ត មហាសន្និបាតមានសង្ឃឹមថា របងដែលញែកព្រះសហគមន៍នៅបូព៌ាប្រទេស ពីព្រះសហគមន៍នៅបស្ចិមប្រទេស មុខជាត្រូវរលំ ដើម្បីឲ្យមានព្រះដំណាក់តែមួយ សាងសង់យ៉ាងមាំលើថ្មគ្រឹះដ៏សំខាន់ គឺព្រះគ្រីស្តយេស៊ូ ដែលនឹងបង្រួបបង្រួម ព្រះសហគមន៍ទាំងពីរឲ្យរួបរួមគ្នាជាធ្លុងតែមួយផង។

## ២-ព្រះសហគមន៍ និងក្រុមជំនុំនៅបស្ចិមប្រទេសដែលបែកចេញទៅហើយ

### ១៩-សភាពការណ៍ពិសេសរបស់សហគមន៍ទាំងនោះ

នៅសម័យកើតវិបត្តិដ៏ធំធេង ដែលចាប់ផ្តើមនៅបស្ចិមប្រទេសនាចុងយុគកណ្តាល ហើយនៅពេលក្រោយៗទៀត មានព្រះសហគមន៍និងក្រុមជំនុំបែកចេញពីអាសនៈរបស់គ្រីស្តទូតនៅក្រុងរ៉ូម។ សព្វថ្ងៃព្រះសហគមន៍ និងក្រុមជំនុំទាំងនោះ ក៏នៅតែរួមជាមួយព្រះសហគមន៍កាតូលិក ដោយត្រូវរ៉ូវគ្នាយ៉ាងពិសេសម្យ៉ាង និងដោយសារទំនាក់ទំនងដ៏យូរអង្វែង មកពីប្រជាជនគ្រីស្តបរិស័ទ បានរស់នៅរួបរួមគ្នាជាសហគមន៍តែមួយ តាមដំណើរដ៏យូរលង់នៃសតវត្សពីមុនៗមក។ ព្រះសហគមន៍ និងក្រុមជំនុំទាំងនោះ មានលក្ខណៈប្លែកៗពីគ្នា ដោយមានកំណើតប្លែកពីគ្នា មានលទ្ធិជំនឿប្លែកពីគ្នា និងមានការរស់នៅតាមព្រះវិញ្ញាណប្លែកពីគ្នាដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍និងក្រុមជំនុំទាំងនោះ មិនគ្រាន់តែប្លែកពីព្រះសហគមន៍កាតូលិកយើងយ៉ាងក្រៃលែងប៉ុណ្ណោះទេ តែប្លែកពីគ្នាឯងថែមទៀតផង។ ហេតុនេះ ពិបាករៀបរាប់បញ្ជាក់អំពីពួកគេយ៉ាងច្បាស់លាស់។ យើងក៏គ្មានបំណងរៀបរាប់បញ្ជាក់អំពីពួកគេដូច្នោះដែរ។

ទោះបីចលនាបង្រួបបង្រួមគ្រីស្តបរិស័ទមិនទាន់កើតនៅគ្រប់កន្លែងនៅឡើយក្តី ទោះបីមានព្រះសហគមន៍និងក្រុមជំនុំខ្លះ មិនទាន់មានបំណងចង់រស់នៅជាមួយព្រះសហគមន៍កាតូលិកដោយសន្តិភាពគ្រប់គ្នាក្តី ក៏យើងនៅ តែមានសង្ឃឹមថា គង់តែថ្ងៃណាមួយ គេនឹងមានគំនិតតាមចលនាបង្រួបបង្រួមគ្នានេះ ហើយមុខជាយើងនឹង គោរពរាប់អានគ្នាទៅវិញទៅមកកាន់តែខ្លាំងឡើងៗទៀតផង។

ក៏ប៉ុន្តែ ត្រូវទទួលស្គាល់ថា ព្រះសហគមន៍និងក្រុមជំនុំទាំងនោះ ប្លែកពីព្រះសហគមន៍កាតូលិកយើងជាសន្ធឹក មិនគ្រាន់តែប្លែកពីគ្នាត្រង់ប្រវត្តិសាស្ត្រ សង្គមសាស្ត្រ ចិត្តសាស្ត្រ ឬត្រង់វប្បធម៌ប៉ុណ្ណោះទេ តែជាពិសេស ប្លែកពីគ្នាត្រង់របៀបបកស្រាយគម្ពីរ ដែលជាសេចក្តីពិតដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ ទោះបីព្រះសហគមន៍ និងក្រុមជំនុំទាំងនោះ ប្លែកពីព្រះសហគមន៍កាតូលិកក្តី ក៏យើងចង់គូសសង្កត់សេចក្តីខ្លះ ដែលអាចទៅជានិងត្រូវជាមូលដ្ឋាន និងដើមកំណើត ដើម្បីបង្កើតការសន្ទនាគ្នា និងនាំឲ្យការសន្ទនានេះកាន់តែស្រួលឡើងៗទៀតដែរ។

### ២០-អំពីជំនឿផ្ញើជីវិតលើព្រះគ្រីស្ត

យើងនឹកគិតជាពិសេសដល់គ្រីស្តបរិស័ទដែលប្រកាសយ៉ាងជាក់ច្បាស់ថា ព្រះយេស៊ូគ្រីស្តពិតជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់របស់ខ្លួន ជាស្ពានមេត្រីតែមួយគត់រវាងព្រះជាម្ចាស់និងមនុស្សលោក ដើម្បីលើកតម្កើង សិរីរុងរឿងរបស់ព្រះជាម្ចាស់តែមួយព្រះអង្គ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងដឹងច្បាស់ថា ព្រះសហគមន៍ និងក្រុមជំនុំទាំងនោះ កាន់ជំនឿប្លែកពីលទ្ធិកាតូលិកយ៉ាងក្រៃល សូម្បីតែអំពីលទ្ធិព្រះគ្រីស្តជាព្រះបន្ទូលប្រសូតជាមនុស្ស និងអំពីការសង្គ្រោះ គេក៏ប្លែកពីព្រះសហគមន៍កាតូលិកដែរ ជាហេតុបណ្តាលឲ្យមានជំនឿប្លែកពីគ្នាត្រង់គម្រោងការដ៏អស្ចារ្យរបស់ព្រះសហគមន៍ និងអំពីមុខងារបម្រើរបស់ព្រះសហគមន៍ ព្រមទាំងអំពីតួនាទីរបស់នាងម៉ារីក្នុងការសង្គ្រោះ។ ក៏ប៉ុន្តែ យើងមានអំណរដោយឃើញបងប្អូនដែលបែកចេញទៅហើយនោះ បែរទៅរកព្រះគ្រីស្តទុកជាប្រភពនិងបំពេញតួនាទី

ដ៏សំខាន់ជាងគេ ក្នុងការរួបរួមគ្នាជាសហគមន៍តែមួយ។ គេមានបំណងរួបរួមជាមួយព្រះគ្រីស្ត និងស្វែងរកការរួបរួមគ្នា ហើយផ្តល់សក្ខីភាពនៃជំនឿរបស់គេនៅគ្រប់កន្លែងក្នុងចំណោមជាតិសាសន៍ទាំងឡាយ។

## ២១-ការសិក្សាព្រះគម្ពីរ

បងប្អូនទាំងនោះ តែងស្រឡាញ់និងគោរព (ហាក់ដូចជានមស្ការថ្វាយបង្គំព្រះគម្ពីរម៉្យាង) ជាមូលហេតុជំរុញគេឲ្យសិក្សាគម្ពីរដោយឥតឈប់ឈរ និងពិនិត្យពិច័យអក្សរដោយយកចិត្តទុកដាក់ *"ព្រោះដំណឹងល្អជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់សម្រាប់សង្គ្រោះអស់អ្នកដែលជឿ គឺមុនដំបូងសាសន៍យូដា បន្ទាប់មកសាសន៍ក្រិក"* (រម ១, ១៦)។

គេតែងអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ ហើយស្វែងរកព្រះជាម្ចាស់ក្នុងព្រះគម្ពីរ ដោយយល់ថាព្រះអង្គដែលមានព្រះបន្ទូលមកគេដោយសារព្រះគ្រីស្ត តាមអស់លោកព្យាការីបានថ្លែងទុកជាមុន។ ព្រះអង្គជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីជាប្រយោជន៍ដល់មនុស្សលោក។ គេនឹកសញ្ជឹងគិតអំពីជីវប្រវត្តិព្រះគ្រីស្ត អំពីការប្រៀនប្រដៅ និងអំពីព្រះរាជកិច្ចរបស់ព្រះបរមគ្រូ ដើម្បីសង្គ្រោះមនុស្សលោក ជាពិសេសអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង។

ទោះបីគ្រីស្តបរិស័ទដែលបែកចេញពីយើង តែងប្រកាសថា គម្ពីរពិតជាមានអំណាចរបស់ព្រះជាម្ចាស់ផ្ទាល់ក្តី ក៏គេមានយោបល់ផ្សេងពីយើង (គេក៏មានយោបល់ប្លែកពីគ្នាឯងដែរ) អំពីទំនាក់ទំនងរវាងព្រះគម្ពីរនិងព្រះសហគមន៍។ តាមលទ្ធិនៃជំនឿកាតូលិក ក្រុមអភិបាលមានមុខងារបង្រៀនព្រះសហគមន៍យ៉ាងពិតប្រាកដ មានមុខងារពិសេសក្នុងការបកស្រាយ និងក្នុងការអត្ថាធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែងជាលាយល័ក្ខអក្សរ។

ប៉ុន្តែ ជាពិសេសនៅពេលសន្ទនាគ្នា ព្រះបន្ទូលពិតជាឧបករណ៍ដ៏ប្រសើរបំផុតក្នុងព្រះហស្តរបស់ព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សទាំងអស់រួបរួមគ្នាជាផ្លូងតែមួយ តាមតែព្រះសង្គ្រោះប្រទានឲ្យមនុស្សលោក។

## ២២-អំពីអគ្គសញ្ញា

គ្រប់ពេលមនុស្សទទួលអគ្គសញ្ញាជ្រមុជទឹកយ៉ាងត្រឹមត្រូវតាមព្រះអម្ចាស់ចាត់ចែងទុកនោះ និងទទួលដោយចិត្តគំនិតយ៉ាងសមរម្យតាមតម្រូវការ មនុស្សរួបរួមក្នុងព្រះកាយព្រះគ្រីស្តដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង គេកើតជាថ្មីដើម្បីទទួលចំណែកនៃព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ តាមគ្រីស្តទូតប៉ូលចែងថា៖ *"ដោយបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយបងប្អូនក៏ទទួលជីវិតថ្មីរួមជាមួយព្រះអង្គដែរ ព្រោះបងប្អូនបានជឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលបានប្រោសព្រះគ្រីស្តឲ្យមានព្រះជន្មថ្មីដ៏រុងរឿង"* (កូឡ ២, ១២)។

ហេតុនេះហើយ បានជាពិធីជ្រមុជទឹកពិតជាចំណងតាមអគ្គសញ្ញា ចងអស់អ្នកដែលកើតជាថ្មីដោយសាពិធីនោះ។ ប៉ុន្តែអគ្គសញ្ញាជ្រមុជទឹកគ្រាន់តែជាដើម និងជាពេលចាប់ផ្តើមដំណើរប៉ុណ្ណោះ ដ្បិតអគ្គសញ្ញាជ្រមុជទឹកនេះតម្រង់មនុស្សទៅទទួលព្រះជន្មរបស់ព្រះគ្រីស្តយ៉ាងពេញបរិបូរណ៍។ ហេតុនេះអគ្គសញ្ញាជ្រមុជទឹក តម្រង់ទៅប្រកាសជំនឿយ៉ាងពេញលេញ និងតម្រង់ឲ្យគេចូលរួមទាំងស្រុងក្នុងការចាត់ចែងនៃការសង្គ្រោះ តាមព្រះគ្រីស្តសព្វព្រះហឫទ័យចាត់ចែងនោះ។ នៅទីបញ្ចប់ អគ្គសញ្ញាជ្រមុជទឹកក៏តម្រង់ឲ្យចូលរួមយ៉ាងពេញលេញក្នុងសហគមន៍ដែលអរព្រះគុណ។

ទោះបីព្រះសហគមន៍ និងក្រុមជំនុំទាំងនោះមិនរួបរួមជាមួយយើងយ៉ាងពេញលក្ខណៈក្តី (អគ្គសញ្ញាជ្រមុជទឹកជាប្រភពនៃការរួបរួមនោះ) ទោះបីយើងជឿថា គេមិនរក្សាទុកសភាពទាំងស្រុងដ៏ពិតប្រាកដនៃគម្រោងការដ៏អស្ចារ្យរបស់

ពិធីអរព្រះគុណក្ដី ជាពិសេសព្រោះគេគ្មានអគ្គសញ្ញាតែងតាំង ក៏ប៉ុន្ដែ ពេលព្រះសហគមន៍និងក្រុមជំនុំដែលបែកចេញពីយើងទាំងនោះ ធ្វើពិធីលៀងព្រះអម្ចាស់ ជាពិធីរំឭកគេអំពីព្រះអម្ចាស់សោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង គេក៏ប្រកាសថា ជីវិតដ៏ពិតប្រាកដមានន័យថា រួមរស់ជាមួយព្រះគ្រីស្ដ ហើយគេរង់ចាំព្រះអង្គយាងមកយ៉ាងរុងរឿងដែរ។ ហេតុនេះ ត្រូវសន្ទនាគ្នាអំពីលទ្ធិស្ដីពីពិធីលៀងព្រះអម្ចាស់ និងអំពីអគ្គសញ្ញាឯទៀតៗ អំពីពិធីបុណ្យនានា និងអំពីមុខងារបម្រើព្រះសហគមន៍។

## ២៣-ការរស់នៅក្នុងអង្គព្រះគ្រីស្ដ

បងប្អូនទាំងនោះ រស់នៅតាមឋានៈជាគ្រីស្ដបរិស័ទ មកពីគេផ្ញើជីវិតលើព្រះគ្រីស្ដ។ ព្រះជាម្ចាស់ក៏ប្រណី សន្ដោសគេ ដោយគេទទួលពិធីជ្រមុជទឹក និងដោយគេស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គផង។ គេបង្ហាញថា គេរស់នៅក្នុងឋានៈជាគ្រីស្ដបរិស័ទដោយម្នាក់ៗអធិដ្ឋាន ដោយនឹកសញ្ជឹងគិតអំពីព្រះគម្ពីរ ដោយរស់នៅក្នុងគ្រួសារបែបជាគ្រីស្ដបរិស័ទ ដោយសហគមន៍គេតែងតែជួបជុំគ្នាលើកតម្កើងព្រះជាម្ចាស់។ ម្យ៉ាងវិញទៀត ក្នុងពិធីគោរពប្រណិប័តន៍របស់គេជួនកាល គេរក្សាទុកកត្តារួមជាច្រើនគួរឲ្យសរសើរនៃពិធីគោរពបម្រើព្រះជាម្ចាស់ពីបុរាណមក រួមជាមួយយើងដែរ។

ជំនឿលើព្រះគ្រីស្ដបង្កើតផល គឺគេលើកតម្កើងនិងអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានព្រះអំណោយទានដល់គេ។ គេក៏យកចិត្តទុកដាក់យ៉ាងខ្លាំងនឹងយុត្តិធម៌ថែមទៀត និងស្រឡាញ់អ្នកដទៃដោយចិត្តស្មោះ។ ដោយសារជំនឿជំរុញគេឲ្យប្រព្រឹត្តអំពើល្អបែបនេះ គេបង្កើតកិច្ចការនិងស្ថាប័នជាច្រើនដើម្បីជួយសម្រាលទុក្ខមនុស្សលោក ទាំងខាងវិញ្ញាណ ទាំងខាងរូបកាយ ដើម្បីអប់រំយុវជនយុវនារី ដើម្បីជួយស្ដាជីវភាពក្នុងសង្គម និងដើម្បីតែងតាំងសន្ដិភាពឲ្យនៅស្ថិតស្ថេរនៅគ្រប់ទីកន្លែង។

ទោះបីក្នុងចំណោមគ្រីស្ដបរិស័ទទាំងនោះ មានគ្នាជាច្រើនមិនយល់អត្ថន័យនៃដំណឹងល្អតាមបែបកាតូលិក ក្នុងវិស័យសីលធម៌ក្ដី ហើយក៏មិនយល់ស្របនឹងដំណោះស្រាយក្នុងបញ្ហាដ៏សែនពិបាក នាសង្គមនៅបច្ចុប្បន្នកាលនេះក្ដី ក៏ប៉ុន្ដែ គេចង់ភ្ជាប់ចិត្តនឹងព្រះបន្ទូលរបស់ព្រះគ្រីស្ដដូចយើងដែរ ទុកជាប្រភពនៃកម្លាំងរបស់គ្រីស្ដបរិស័ទ។ គេក៏ចង់ធ្វើតាមបញ្ញារបស់គ្រីស្ដទូតប៉ូលថា *"ការអ្វីក៏ដោយ ដែលបងប្អូនធ្វើ ទោះជាពាក្យសម្ដី ឬកាយវិការក្ដី ត្រូវធ្វើក្នុងព្រះនាមព្រះអម្ចាស់យេស៊ូទាំងអស់ ទាំងអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា តាមរយៈព្រះគ្រីស្ដផង"* (កូឡ ៣, ១៧)។ ការសន្ទនាតាមចលនាបង្រួបបង្រួមគ្នា អំពីការប្រព្រឹត្តតាមសីលធម៌ស្របតាមដំណឹងល្អ អាចចាប់ផ្ដើមបាន ដោយនឹកអំពីព្រះបន្ទូលនោះ។

## ២៤-ពាក្យបញ្ចប់

ក្រោយពីបានរៀបរាប់យ៉ាងខ្លីអំពីលក្ខខ័ណ្ឌនៃកិច្ចការបង្រួបបង្រួមគ្រីស្ដបរិស័ទ ឲ្យរួបរួមគ្នាជាធ្លុងតែមួយរួចហើយ ក្រោយពីបានបង្ហាញបញ្ជាក់គោលការណ៍ណែនាំកិច្ចការបង្រួបបង្រួមនេះ យើងបែរមុខទៅរកអនាគតទាំងទុកចិត្តលើព្រះជាម្ចាស់។ មហាសន្និបាតដាស់តឿនគ្រីស្ដបរិស័ទឲ្យជៀសវាងប្រព្រឹត្តអំពើដោយមិនគិតជាមុន កុំខ្នះខ្នែងដោយមិនប្រុងប្រយ័ត្ន ដែលសុទ្ធតែជាអំពើអាចបង្ខូចចលនារួបរួមគ្នាមិនឲ្យចម្រើនបាន។ កិច្ចការបង្រួបបង្រួមរបស់គេ សុទ្ធតែមានន័យថា *"កាតូលិក"* យ៉ាងពេញលេញនិងដោយចិត្តស្មោះ គឺស្មោះត្រង់នឹងសេចក្ដីដ៏ពិតដែលយើងទទួលពីក្រុមគ្រីស្ដទូត និងពីគ្រូបាធ្យាយមក ហើយក៏ស្របតាមលទ្ធិជំនឿព្រះសហគមន៍បានប្រកាសជានិច្ចតាំងពីដើមរៀងមក។ កិច្ចការបង្រួបបង្រួមនេះ តម្រង់ទៅកាន់សេចក្ដីបរិបូណ៍ដ៏ពេញលក្ខណៈ គឺព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យព្រះកាយព្រះអង្គ

ចម្រើនឡើងក្នុងសេចក្តីពេញបរិបូរណ៍ ដ៏ពេញលក្ខណៈនេះតាមដំណើរនៃសតវត្សកន្លងទៅ។

មហាសន្និបាតប្រាថ្នាយ៉ាងខ្លាំង សូមឲ្យកិច្ចការដែលបុត្រធីតាព្រះសហគមន៍កាតូលិកចាប់ផ្តើមធ្វើ បានចម្រើនឡើង រួមនឹងកិច្ចការរបស់បងប្អូនដែលបែកចេញពីយើង។ សូមកុំយកអ្វីមករារាំងមាគ៌ារបស់ព្រះអង្គ ដែលណែនាំ និងថែរក្សាមនុស្សលោកដោយព្រះហឫទ័យស្រឡាញ់។ កុំស្រមៃឃើញអំពីព្រះវិញ្ញាណនឹងជំរុញគ្រីស្តបរិស័ទយ៉ាងណា នៅពេលខាងមុខឡើយ។ លើសពីនេះទៅទៀត មហាសន្និបាតដឹងខ្លួនហើយប្រកាសថា ការសម្រុះសម្រួលគ្រីស្តបរិស័ទទាំងអស់ឲ្យរួបរួមគ្នាក្នុងព្រះសហគមន៍ តែមួយគត់របស់ព្រះគ្រីស្ត ពិតជាគម្រោងការរបស់ព្រះជាម្ចាស់មែន គឺហួសពីកម្លាំង និងពីសមត្ថភាពរបស់មនុស្ស។ ហេតុនេះហើយ បានជាមហាសន្និបាតសង្ឃឹមទាំងស្រុង ទៅលើពាក្យអង្វររបស់ព្រះគ្រីស្តសម្រាប់ព្រះសហគមន៍ និងសង្ឃឹមទៅលើព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាចំពោះយើង ព្រមទាំងសង្ឃឹមទៅលើឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ *"សេចក្តីសង្ឃឹមមិនធ្វើឲ្យយើងខកចិត្តឡើយ ព្រោះព្រះជាម្ចាស់បានចាក់បង្ហូរព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គមកក្នុងចិត្តយើង ដោយប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកយើង"* (រម ៥, ៥)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ នឹងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្ត បានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូតរួមជាមួយអស់លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលា ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៦៤

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ព្រះសហគមន៍នៅបូព៌ាប្រទេស

## ORIENTALIUM ECCLESIARUM

## ខ្ញុំប៉ូល ជាអភិបាល
## ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់
## រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាត
## ដ៏វិសុទ្ធនេះ សូមប្រកាសក្រឹត្យក្រមនេះ
## ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

## ក្រឹត្យក្រមអំពីព្រះសហគមន៍កាតូលិកនៅបូព៌ាប្រទេស

### ១-បុព្វកថា

ព្រះសហគមន៍កាតូលិកគោរពយ៉ាងខ្លាំងនូវស្ថាប័ន ក្បួនពិធីគោរពប្រណិប័តន៍ និងប្រពៃណីព្រះសហគមន៍ ហើយវិន័យណែនាំការរស់នៅតាមគ្រីស្តសាសនារបស់ព្រះសហគមន៍នៅបូព៌ាប្រទេស។ ព្រះសហគមន៍ទាំងនោះមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ព្រោះព្រះសហគមន៍ទាំងនោះកើតជាយូរយារណាស់មកហើយ។ ការបញ្ជូនបន្តមកពីក្រុមគ្រីស្តទូតដោយសារគ្រូបាធ្យាយ ក៏លេចភ្លឺចិញ្ចាចចិញ្ចែងក្នុងព្រះសហគមន៍ទាំងនោះដែរ។ ការបញ្ជូនបន្តនេះ ពិតជាបេតិកភ័ណ្ឌរួមរបស់ព្រះសហគមន៍ទាំងមូល ជាបេតិកភ័ណ្ឌដែលបែកគ្នាមិនបាន ដែលព្រះជាម្ចាស់បានសម្តែងឲ្យមនុស្សលោកស្គាល់។ ព្រះសហគមន៍ទាំងនោះពិតជាសាក្សី ដែលមានជីវិតអំពីការបញ្ជូនបន្តនោះ។ មហាសន្និបាតប្រាថ្នាចង់ឲ្យព្រះសហគមន៍ទាំងនោះ លូតលាស់ឡើង និងបំពេញបេសកកម្មរបស់ខ្លួនដោយមានកម្លាំងរស់រវើកជាថ្មី។ ហេតុនេះហើយ បានជាលើសពីសេចក្តីសម្រេច អំពីព្រះសហគមន៍សកល មហាសន្និបាតសម្រេចតែងតាំងគោលការណ៍ដ៏សំខាន់ៗខ្លះ ទាំងផ្ញើបញ្ហាងទៀតៗឲ្យសន្និបាតព្រះសហគមន៍នៅបូព៌ាប្រទេស និងឲ្យអាសនៈគ្រីស្តទូតសិលាសម្រេចដោយប្រុងប្រយ័ត្ន។

### ព្រះសហសហគមន៍ដែលកាន់តាមរបៀបរបបពិធីពិសេសដោយឡែក

២-ព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ ជាព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្ត គឺមានគ្រីស្តបរិស័ទរួមភ្ជាប់ជាមួយគ្នាដូចជារូបកាយមួយក្នុងព្រះវិញ្ញាណ ដោយមានជំនឿតែមួយ អគ្គសញ្ញាដដែលដូចគ្នា និងមានការណែនាំគ្រប់គ្រងតែមួយដូចគ្នា។ គ្រីស្តបរិស័ទក៏តែងតាំងសហគមន៍ផ្សេងៗ ដែលមានអំណាចមកពីព្រះជាម្ចាស់តាមលំដាប់លំដោយ បង្រួប

បង្រួមគេឲ្យភ្ជាប់ជាមួយគ្នា ពិតជាព្រះសហគមន៍ដោយឡែក ឬជាព្រះសហគមន៍ដែលមានរបៀបរបបពិធីផ្ទាល់។ ព្រះសហគមន៍ទាំងនោះ រួបរួមគ្នាយ៉ាងល្អគួរឲ្យសរសើរ ដូច្នេះទោះបីក្នុងព្រះសហគមន៍តែមួយ មានសេចក្ដីប្លែកៗពីគ្នាក៏ដោយ ក៏សេចក្ដីទាំងនោះមិនបង្ខូចការរួបរួមគ្នាជាធ្លុងតែមួយទេ ផ្ទុយទៅវិញ សេចក្ដីប្លែកៗពីគ្នាទាំងប៉ុន្មានលើកតម្កើងការរួបរួមគ្នានោះ។ ព្រះសហគមន៍កាតូលិកមានគោលបំណងថែរក្សាប្រពៃណីព្រះសហគមន៍ដោយឡែកនីមួយៗ ឬព្រះសហគមន៍ដែលមានរបៀបរបបពិធីផ្ទាល់ ឲ្យនៅគង់វង្សទាំងស្រុង។ ព្រះសហគមន៍ ក៏មានបំណងសម្របរបៀបរស់នៅរបស់ខ្លួនតាមតម្រូវការផ្សេងៗ គឺតាមកាលៈទេសៈ និងទីកន្លែងទៀតផង។

៣-ព្រះសហគមន៍ដោយឡែកទាំងនោះ ទោះជានៅបូព៌ាប្រទេសក្ដី នៅបស្ចិមប្រទេសក្ដី ក៏ប្លែកពីគ្នាដោយមានក្បួន ពិធីប្លែកពីគ្នា គឺថា គេគោរពប្រណិប័តន៍ព្រះជាម្ចាស់តាមរបៀបផ្សេងៗគ្នា មានក្បួនវិន័យប្លែកពីគ្នាសម្រាប់ក្រុមបូជាចារ្យ (អាចារ្យ) ហើយក៏មានបេតិកភ័ណ្ឌខាងព្រះវិញ្ញាណប្លែកពីគ្នាដែរ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះជាម្ចាស់បានផ្ញើព្រះសហគមន៍ទាំងនោះ ទៅលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមគ្រប់គ្រងណែនាំ តាមរបៀបដដែល។ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ អភិបាលព្រះសហគមន៍ក្រុងរ៉ូមនេះ បន្តមុខងារពីគ្រីស្ដទូតសិលាមក ក្នុងឋានៈលោកជាប្រធានលើព្រះសហគមន៍សកល។ ហេតុនេះ ព្រះសហគមន៍ទាំងប៉ុន្មានមានកិត្តិយសដ៏ថ្លៃថ្នូរស្មើគ្នាទាំងអស់ គ្មានព្រះសហគមន៍ណាមួយលើសព្រះសហគមន៍ឯទៀតៗ ដោយអះអាងលើរបៀបរបបពិធីរបស់ខ្លួនឡើយ។ ព្រះសហគមន៍ទាំងនោះមានសិទ្ធិស្មើគ្នា ហើយក៏ត្រូវតែបំពេញកាតព្វកិច្ចដូចគ្នា គឺមានភារកិច្ចប្រកាសដំណឹងល្អក្នុងពិភពលោកទាំងមូល (មក ១៦, ១៥) ក្រោមការណែនាំរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូមដូចគ្នាដែរ។

៤- ហេតុនេះហើយ បានជាត្រូវផ្គត់ផ្គង់ព្រះសហគមន៍ដោយឡែកទាំងនោះ ឲ្យនៅស្ថិតស្ថេរ និងឲ្យចម្រើនឡើងទៀតផង។ ត្រូវតែងតាំងសហគមន៍គ្រីស្ដបរិស័ទ និងអំណាចដ៏សក្ការៈតាមលំដាប់លំដោយ នៅកន្លែងណាដែលផលប្រយោជន៍ខាងព្រះវិញ្ញាណរបស់គ្រីស្ដបរិស័ទទាមទារឲ្យមាន។ ក៏ប៉ុន្តែ អំណាចដ៏សក្ការៈតាមលំដាប់លំដោយនៃព្រះសហគមន៍ដោយឡែកទាំងនោះ ដែលស្ថិតនៅក្នុងតំបន់តែមួយ ត្រូវយកចិត្តទុកដាក់ពិគ្រោះគ្នា ដោយចាត់ចែងការប្រជុំតាមពេលកំណត់ ដើម្បីលើកស្ទួយឲ្យមានសកម្មភាពរួម និងព្រួតកម្លាំងគ្នាគាំទ្រកិច្ចការរួម ទើបអស់លោកបណ្ដោយឲ្យប្រយោជន៍សាសនាចម្រើនឡើងឲ្យបានស្រួល ហើយក៏ការពារវិន័យរបស់ក្រុមបូជាចារ្យយ៉ាងសកម្មដែរ។ ត្រូវបង្រៀនអស់អ្នកដែលទទួលអគ្គសញ្ញាតែងតាំង និងបេក្ខជនដែលត្រូវទទួលអគ្គសញ្ញានោះ ឲ្យដឹងច្បាស់អំពីរបៀបរបបពិធីគោរពប្រណិប័តន៍ផ្សេងៗ ជាពិសេសដឹងអំពីសេចក្ដីណែនាំក្នុងករណីអន្តររបៀបរបបពិធី។ នៅពេលអប់រំជំនឿ គ្រីស្ដបរិស័ទធម្មតាក៏ត្រូវទទួលការអប់រំអំពីរបៀបរបបពិធីផ្សេងៗ និងអំពីសេចក្ដីណែនាំក្នុងករណីអន្តររបៀបរបបពិធីនោះដែរ។ មិនតែប៉ុណ្ណោះសោត គ្រីស្ដបរិស័ទម្នាក់ៗ និងគ្រីស្ដបរិស័ទទាំងអស់ ព្រមទាំងអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជ ទឹកក្នុងព្រះសហគមន៍ ឬក្នុងសហគមន៍មិនមែនកាតូលិក ហើយដែលមករួបរួមយ៉ាងពេញលក្ខណៈក្នុងព្រះសហគមន៍កាតូលិកយើង ត្រូវតែរក្សាទុករបៀបរបបពិធីរបស់ខ្លួនផ្ទាល់នៅគ្រប់កន្លែង។ គេក៏ត្រូវប្រតិបត្តិតាមនិងកាន់ តាមតែគេអាចធ្វើបានដែរ។ ក្នុងករណីពិសេស ដែលចោទឡើងអំពីបុគ្គលម្នាក់ៗ អំពីសហគមន៍នានា ឬអំពីតំបន់ផ្សេងៗ គេមានសិទ្ធិឡើងសំណុំរឿងទៅអាសនៈរបស់គ្រីស្ដទូតសិលា។ អភិបាលព្រះសហគមន៍ក្រុងរ៉ូមនេះ ក្នុងឋានៈលោកជាអាជ្ញាកណ្ដាលដ៏ខ្ពង់ខ្ពស់បំផុតក្នុងទំនាក់ទំនងរវាងព្រះសហគមន៍នានា លោកនឹងផ្គត់ផ្គង់តាមតម្រូវការរបស់គេ ដោយមានចិត្តគំនិតចង់បង្រួបបង្រួមគ្រីស្ដបរិស័ទឲ្យរួបរួមគ្នាជាធ្លុងតែមួយផង។ លោកនឹងសម្រេចដោយខ្លួនលោកផ្ទាល់ក៏បាន ឬដោយផ្ញើឲ្យអំណាចផ្សេងៗសម្រេចក៏បាន ទាំងផ្ដល់សេចក្ដីណែនាំ ក្រឹត្យក្រម និងបញ្ញាតាមសេចក្ដីត្រូវការ។

## ត្រូវថែរក្សាបេតិកភ័ណ្ឌនៃព្រះសហគមន៍នាបូព៌ាប្រទេស

៥-ប្រវត្តិសាស្ត្រ ប្រពៃណីនានា និងស្ថាប័នជាច្រើននៃព្រះសហគមន៍ តែងបញ្ជាក់យ៉ាងច្បាស់ថា ព្រះសហគមន៍នៅបូព៌ាប្រទេសមានគុណជាច្រើនទៅលើព្រះសហគមន៍សកល។ ហេតុនេះហើយ បានជាមហាសន្និបាតសូមលើកតម្កើង និងរាប់បេតិកភ័ណ្ឌខាងព្រះសហគមន៍ និងខាងការរស់នៅតាមព្រះវិញ្ញាណរបស់គេ។ លើសពីនេះទៅទៀត មហាសន្និបាតទទួលស្គាល់យ៉ាងម៉ឺងម៉ាត់ថា បេតិកភ័ណ្ឌនោះ ពិតជាបេតិកភ័ណ្ឌរបស់ព្រះសហគមន៍ទាំងមូលរបស់ព្រះគ្រីស្ត។ ហេតុនេះហើយ បានជាមហាសន្និបាតសូមប្រកាសយ៉ាងឱឡារិកថា ព្រះសហគមន៍នៅបូព៌ាប្រទេស ក៏ដូចព្រះសហគមន៍នៅបស្ចិមប្រទេស មានសិទ្ធិនិងភារកិច្ចគ្រប់គ្រងខ្លួនឯង ដោយខ្លួនឯងបានតាមក្បួនវិន័យដោយឡែករបស់គេ។ គួរឲ្យគោរព និងប្រតិបត្តិតាមក្បួនវិន័យទាំងនោះ ព្រោះក្បួនវិន័យទាំងនោះ មកពីបរមបុរាណ និងស្របតាមទំនៀមទម្លាប់គ្រីស្តបរិស័ទរបស់គេ ហើយក៏ស្រួលនាំផលប្រយោជន៍ដល់គេ។

៦-សូមឲ្យគ្រីស្តបរិស័ទនៅបូព៌ាប្រទេសទាំងអស់ដឹងយ៉ាងជាក់ច្បាស់ថា គេមានសិទ្ធិអាចនិងត្រូវរក្សាទុកក្បួនពិធីគោរពប្រណិប័តន៍ដ៏ត្រឹមត្រូវរបស់ខ្លួន និងរក្សាទុកក្បួនវិន័យរបស់គេទៀតផង។ ប្រសិនត្រូវកែសម្រួលក្បួនទាំងនោះ ត្រូវកែសម្រួលតែក្នុងគោលបំណងធ្វើឲ្យពិធី និងក្បួនវិន័យទាំងនោះចម្រើនឡើង និងត្រូវកែសម្រួលពីផ្ទៃក្នុងព្រះសហគមន៍ដោយឡែកទាំងនោះទៀត។ គ្រីស្តបរិស័ទនៅបូព៌ាប្រទេស ត្រូវកាន់តាមសេចក្តីទាំងនោះដោយចិត្តស្មោះយ៉ាងខ្លាំង។ គេត្រូវស្គាល់ពិធីនិងក្បួនវិន័យទាំងនោះ ឲ្យកាន់តែច្បាស់ឡើងៗ និងអនុវត្តតាមឲ្យកាន់តែប្រសើរឡើងៗដែរ។ ប្រសិនបើ មានមូលហេតុបណ្តាលឲ្យគេឃ្លាតឆ្ងាយ នោះគឺមកសភាពការណ៍ផ្សេងៗតាមកាលៈទេសៈ ឬមកតែបុគ្គល នោះសូមឲ្យគេខិតខំត្រឡប់មករកប្រពៃណីដូនតាគេវិញ។ ចំពោះអស់អ្នកដែលធ្លាប់មានទំនាក់ទំនងជាញឹកញាប់ជាមួយព្រះសហគមន៍នៅបូព៌ាប្រទេស ឬជាមួយគ្រីស្តបរិស័ទនៅបូព៌ាប្រទេស តាមបន្ទុករបស់ខ្លួនផ្ទាល់ ឬតាមមុខងារបម្រើរបស់គេក្នុងឋានៈជាគ្រីស្តទូត សូមរៀនយ៉ាងហ្មត់ចត់ដើម្បីឲ្យស្គាល់ និងឲ្យស្រឡាញ់របៀបរបបពិធី ក្បួនវិន័យ លទ្ធិនៃជំនឿ និងលក្ខណៈពិសេសរបស់គ្រីស្តបរិស័ទនៅបូព៌ាប្រទេស។ មហាសន្និបាតផ្តែផ្តាំយ៉ាងផ្ចង់ផ្ចាច់ថា សូមគ្រឹះស្ថាន និងសហគមន៍ដែលកាន់របៀបរបបពិធីឡាតាំង ហើយដែលធ្វើការនៅបូព៌ាប្រទេស ឬជាមួយគ្រីស្តបរិស័ទនៅបូព៌ាប្រទេស សូមបង្កើតគេហដ្ឋាន និងតំបន់ក្រុមគ្រួសារបព្វជិតដែលកាន់តាមរបៀបរបបពិធីបូព៌ាប្រទេស ប្រសិនបើអាចធ្វើបាន ដើម្បីឲ្យគេបំពេញកិច្ចការជាគ្រីស្តទូតឲ្យបានប្រសិទ្ធភាព។

## អភិបាលដ៏ប្រសើរឧត្តមនៅបូព៌ាប្រទេស

៧-មានតែងតាំងអភិបាលដ៏ប្រសើរឧត្តមក្នុងព្រះសហគមន៍តាំងពីបរមបុរាណមក ហើយមហាសន្និបាតសកលដើមដំបូង ក៏តែងតែទទួលស្គាល់អភិបាលដ៏ប្រសើរឧត្តមទាំងនោះដែរ។

*"អភិបាលដ៏ប្រសើរឧត្តមនៃព្រះសហគមន៍នៅបូព៌ាប្រទេស"* មានន័យថា អភិបាលដែលគ្រប់គ្រងលើអភិបាលឯទៀតៗទាំងអស់ សូម្បីតែលើអភិបាលព្រះសហគមន៍នៃក្រុងធំៗក្តី ក៏អស់លោកគ្រប់គ្រងដែរ។ អស់លោកក៏គ្រប់គ្រងលើក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំងជាអ្នកបម្រើព្រះសហគមន៍ និងលើគ្រីស្តបរិស័ទដែលរស់នៅក្នុងតំបន់របស់លោក ឬលើគ្រីស្តបរិស័ទដែលកាន់តាមរបៀបរបបពិធីរបស់លោក។ លោកគ្រប់គ្រងដូច្នេះតាមសេចក្តីណែនាំនៃច្បាប់វិន័យ ទាំងទទួលស្គាល់អភិបាលព្រះសហគមន៍ក្រុងរ៉ូមទុកជាប្រធានផង។

នៅគ្រប់កន្លែងដែលគេតែងតាំងអ្នកកាន់អំណាចដ៏សក្ការៈម្នាក់នៃរបៀបរបបពិធីណាមួយ ក្រៅពីព្រំដែនតំបន់អភិបាលដ៏ប្រសើរឧត្តមនោះ ក៏អ្នកកាន់អំណាចដ៏សក្ការៈថ្មីនោះ (គឺអំណាចដែលមកពីព្រះជាម្ចាស់) នៅតែភ្ជាប់ចំណងជាមួយក្រុមអភិបាលដែលមានអំណាចតាមលំដាប់លំដោយនៅក្នុងតំបន់ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលដ៏ប្រសើរឧត្តមនៃរបៀបរបបពិធីនោះ តាមសេចក្តីណែនាំនៃច្បាប់វិន័យដែរ។

៨-អភិបាលដ៏ប្រសើរឧត្តមនៃព្រះសហគមន៍នៅបូព៌ាប្រទេស ទោះបីមានអភិបាលដ៏ប្រសើរឧត្តមខ្លះកើតក្រោយពីអភិបាលដ៏ប្រសើរឧត្តមឯទៀតៗ ក៏អស់លោកមានកិត្តិយសស្មើគ្នាទាំងអស់ ក្នុងឋានៈអស់លោកជាអភិបាលដ៏ប្រសើរឧត្តមដូចគ្នា តែត្រូវរក្សាទុកឋានន្តរស័ក្តិកិត្តិយស ដែលគេតែងតាំងយ៉ាងត្រឹមត្រូវរួចមកហើយ។

៩-តាមប្រពៃណីពីបរមបុរាណនៃព្រះសហគមន៍តរៀងមក ត្រូវគោរពយ៉ាងពិសេសចំពោះអភិបាលដ៏ប្រសើរឧត្តមទាំងប៉ុន្មាននៃព្រះសហគមន៍នៅបូព៌ាប្រទេស ដ្បិតអស់លោកជាប្រធានក្នុងតំបន់រៀងៗខ្លួនក្នុងឋានៈជាឪពុក និងជាមេដឹកនាំ។ ហេតុនេះហើយ បានជាមហាសន្និបាតសម្រេចថា ត្រូវតែងតាំងសិទ្ធិនិងឯកសិទ្ធិរបស់អស់លោកឡើងវិញស្របតាមប្រពៃណីពីបុរាណរបស់ព្រះសហគមន៍នីមួយៗ និងស្របតាមក្រឹត្យក្រមនៃមហាសន្និបាតសកលទាំងប៉ុន្មានពីមុនៗមក។

ទោះបីត្រូវកែសម្រួលសិទ្ធិ និងឯកសិទ្ធិទាំងនោះបន្តិច ឲ្យបានស្របតាមសភាពការណ៍នាបច្ចុប្បន្នក្តី ក៏សិទ្ធិ និងឯកសិទ្ធិទាំងនោះ ពិតជាសិទ្ធិនិងឯកសិទ្ធិរបស់អស់លោកអភិបាលដ៏ប្រសើរឧត្តមតែងតែមាន នៅសម័យព្រះសហគមន៍នៅបូព៌ាប្រទេស និងនៅបស្ចិមប្រទេសរួបរួមគ្នានៅឡើយ។

អស់លោកអភិបាលដ៏ប្រសើរឧត្តមនិងសន្និបាតរបស់អស់លោក ជាស្ថាប័នដ៏ខ្ពង់ខ្ពស់បំផុតដែលអាចដោះស្រាយបញ្ហាទាំងប៉ុន្មានក្នុងតំបន់របស់លោកអភិបាលដ៏ប្រសើរឧត្តម។ ស្ថាប័នដ៏ខ្ពង់ខ្ពស់បំផុតនេះ ក៏មានសិទ្ធិតែងតាំងមេដឹកនាំថ្មី និងតែងតាំងអភិបាលតាមរបៀបរបបពិធីរបស់អស់លោក ក្នុងព្រំដែនតំបន់របស់លោកអភិបាលដ៏ប្រសើរឧត្តមដែរ។ ក៏ប៉ុន្តែ អភិបាលព្រះសហគមន៍ក្រុងរ៉ូម នៅតែមានសិទ្ធិដែលដកមិនបាន អាចធ្វើអន្តរាគមន៍ក្នុងករណីនីមួយៗទាំងនេះបានផងដែរ។

១០-សេចក្តីថ្លែងអំពីអភិបាលដ៏ប្រសើរឧត្តមទាំងនោះ ក៏ត្រូវរាប់ទុកជាបានការចំពោះអគ្គអភិបាលដ៏ប្រសើរ ដែលជាមេដឹកនាំព្រះសហគមន៍ដោយឡែកទាំងមូលមួយ ឬដែលជាមេដឹកនាំរបៀបរបបពីធីមួយ ស្របតាមសេចក្តីណែនាំនៃច្បាប់វិន័យ ដែរ។

១១-អភិបាលដ៏ប្រសើរឧត្តមទាំងប៉ុន្មាន ជាស្ថាប័នគ្រប់គ្រងព្រះសហគមន៍ទាំងប៉ុន្មាននៅបូព៌ាប្រទេស តាមប្រពៃណី។ ហេតុនេះហើយបានជា ពេលណាត្រូវតែងតាំងតំបន់ថ្មីក្រោមអំណាចអភិបាលដ៏ប្រសើរឧត្តមម្នាក់ តាមតម្រូវការ មហាសន្និបាតសកលយើងនេះ ប្រាថ្នាចង់ឲ្យមានតែមហាសន្និបាតសកល ឬអភិបាលព្រះសហគមន៍ក្រុងរ៉ូមប៉ុណ្ណោះ តែងតាំងតំបន់ថ្មីនោះ។

## វិន័យអំពីអគ្គសញ្ញា

១២-មហាសន្និបាតសកលដ៏វិសុទ្ធបញ្ជាក់ និងយល់ស្របតាមក្បួនវិន័យពីបុរាណ អំពីរបៀបធ្វើអគ្គសញ្ញាជូនគ្រីស្តបរិស័ទ ដែលព្រះសហគមន៍ទាំងប៉ុន្មាននៅបូព៌ាប្រទេសធ្លាប់អនុវត្តតាម។ មហាសន្និបាតក៏ប្រាថ្នាចង់ឲ្យគេតែងតាំងរបៀបបុរាណធ្វើអគ្គសញ្ញាឡើងវិញថែមទៀត ប្រសិនបើត្រូវការ។

១៣-ចំពោះក្បួនវិន័យអំពីអ្នកបម្រើ ប្រេងគ្រីស្មាដ៏វិសុទ្ធដែលគ្រីស្តបរិស័ទនៅបូព៌ាប្រទេសតែងអនុវត្តតាមតាំងពីបរមបុរាណមក សូមតែងតាំងឡើងវិញយ៉ាងពេញលេញ។ ហេតុនេះហើយបានជាអស់លោកគង្វាល មានសិទ្ធិអាចធ្វើអគ្គសញ្ញានេះ ជូនគ្រីស្តបរិស័ទបាន ដោយប្រើប្រេងគ្រីស្មាដែលអភិបាលដ៏ប្រសើរឧត្ដម ឬអភិបាលបានប្រសិទ្ធិពររួចមកហើយ។

១៤-អស់លោកគង្វាល នៃព្រះសហគមន៍បូព៌ាប្រទេស មានសិទ្ធិអាចធ្វើអគ្គសញ្ញាលាបថ្ងាសនេះ ដែលអាចចាត់ទុកជាបានការ ទោះជានៅពេលធ្វើអគ្គសញ្ញាជ្រមុជទឹក ឬនៅពេលផ្សេងទៀតក្ដី ទោះជាគ្រីស្តបរិស័ទដែលទទួលនោះកាន់តាមរបៀបរបបពិធីណាក៏ដោយ សូម្បីតែគ្រីស្តបរិស័ទកាន់តាមរបៀបរបបពិធីឡាតាំងក្ដី ក៏លោកគង្វាលមានសិទ្ធិអាចធ្វើអគ្គសញ្ញានេះជូនគេបានដែរ។ ប៉ុន្តែអស់លោកត្រូវកាន់តាមបញ្ញត្តិនៃច្បាប់រួម និងតាមបញ្ញត្តិព្រះសហគមន៍ដោយឡែក ដើម្បីឲ្យបានត្រឹមត្រូវតាមច្បាប់។ ចំពោះគង្វាល ដែលកាន់តាមរបៀបរបបពិធីឡាតាំង ក៏មានសិទ្ធិអាចធ្វើអគ្គសញ្ញានេះជូនគ្រីស្តបរិស័ទនៃព្រះសហគមន៍បូព៌ាប្រទេសបានដែរ លុះត្រាតែលោកមានសិទ្ធិក្នុងការធ្វើអគ្គសញ្ញាលាបថ្ងាសនេះក្នុងព្រះសហគមន៍របស់ខ្លួន។ ធ្វើដូច្នេះលោកគង្វាលមិនបង្ខូចប្រយោជន៍របៀបរបបពិធីផ្ទាល់របស់គ្រីស្តបរិស័ទទាំងនោះ។ ប៉ុន្តែអស់លោក ត្រូវកាន់តាមបញ្ញត្តិនៃច្បាប់រួម និងតាមបញ្ញត្តិព្រះសហគមន៍ដោយឡែក ដើម្បីឲ្យបានត្រឹមត្រូវតាមច្បាប់។

១៥-គ្រីស្តបរិស័ទមានកាតព្វកិច្ចចូលរួមក្នុងពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់ រៀងរាល់ថ្ងៃអាទិត្យ និងនៅថ្ងៃបុណ្យធំៗ។ គេក៏មានកាតព្វកិច្ចចូលរួមក្នុងពិធីលើកតម្កើងព្រះជាម្ចាស់ តាមវិន័យ ឬតាមទម្លាប់នៃរបៀបរបបពិធីរបស់គេផ្ទាល់ដែរ។ មានកំណត់ពេលសម្រាប់បំពេញកាតព្វកិច្ចនោះ គឺតាំងពីពិធីលើកតម្កើងព្រះជាម្ចាស់ល្ងាចថ្ងៃសៅរ៍ រហូតដល់ល្ងាចថ្ងៃអាទិត្យ ឬល្ងាចថ្ងៃបុណ្យធំៗនោះ។ មានចាត់ចែងដូច្នេះ ដើម្បីឲ្យគ្រីស្តបរិស័ទស្រួលបំពេញកាតព្វកិច្ចនោះ។ យើងទូន្មានគ្រីស្តបរិស័ទយ៉ាងខ្លាំង ឲ្យទទួលព្រះកាយនៅថ្ងៃទាំងនោះ ឬជាញឹកញាប់ជាង រហូតដល់ទទួលរៀងរាល់ថ្ងៃក៏បានដែរ។

១៦-គ្រីស្តបរិស័ទនៃព្រះសហគមន៍ទាំងប៉ុន្មានដោយឡែក ដែលរស់នៅក្នុងតំបន់ឬក្នុងភូមិភាគព្រះសហគមន៍បូព៌ាតែមួយ តែងតែរស់នៅលាយឡំគ្នាជានិច្ច។ ហេតុនេះ មេដឹកនាំដែលកាន់អំណាចដ៏សក្ការៈត្រូវផ្ដល់ឲ្យគង្វាលរបស់ខ្លួនមានសិទ្ធិជាធម្មតា និងដោយគ្មានលក្ខខ័ណ្ឌណារារាំង ធ្វើអគ្គសញ្ញាលើកលែងទោសជូនគ្រីស្តបរិស័ទ ទោះជាគង្វាលនេះកាន់របៀបរបបពីធីណាក៏ដោយ។ សិទ្ធិនោះអាចប្រើបាននៅតំបន់ទាំងមូល ដែលស្ថិតនៅក្រោមអំណាចអភិបាលដែលផ្ដល់សិទ្ធិនោះ ព្រមទាំងប្រើបាននៅកន្លែងដែលគ្រីស្តបរិស័ទរស់នៅ និងសម្រាប់គ្រីស្តបរិស័ទទាំងអស់ដែលរស់នៅក្នុងតំបន់នោះ ទោះបីគេកាន់តាមរបៀបរបបពិធីណាក៏ដោយ លើកលែងតែអ្នកកាន់អំណាចដ៏សក្ការៈក្នុងតំបន់នោះបានបដិសេធយ៉ាងច្បាស់ ចំពោះកន្លែងដែលគ្រីស្តបរិស័ទកាន់តាមរបៀបរបបពិធីរបស់លោករួចហើយ។

១៧-មហាសន្និបាតប្រាថ្នាចង់ឲ្យតែងតាំងឧបដ្ឋាកអចិន្ត្រៃយ៍ឡើងវិញ នៅកន្លែងណាដែលគេលែងមាន ដើម្បីអនុវត្តតាមក្បួនវិន័យបុរាណនៃព្រះសហគមន៍បូព៌ាប្រទេស អំពីអគ្គសញ្ញាតែងតាំងជាអ្នកបម្រើ។ ចំពោះមុខងារជាអនុឧបដ្ឋាក និងមុខងារបម្រើតូចជាងគេ ព្រមទាំងអំពីសិទ្ធិនិងកាតព្វកិច្ចភ្ជាប់នឹងមុខងារទាំងនោះ អំណាចដែលមានសមត្ថកិច្ច បញ្ចេញច្បាប់វិន័យក្នុងព្រះសហគមន៍ដោយឡែកនីមួយៗ ត្រូវចាត់វិធានការតាមសេចក្ដីត្រូវការ។

១៨-ចំពោះគ្រីស្តបរិស័ទកាតូលិកនៃព្រះសហគមន៍បូព៌ាប្រទេស ដែលរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក តែមិនមែនជាគ្រីស្តបរិស័ទកាតូលិកបូព៌ាទេ មហាសន្និបាតសម្រេចថា ត្រូវតែរៀបអាពាហ៍ពិពាហ៍

តាមក្បួនច្បាប់ ដើម្បីឲ្យអាពាហ៍ពិពាហ៍នោះត្រឹមត្រូវតាមច្បាប់ គឺគ្រាន់តែឲ្យមានវត្តមានរបស់លោកគង្វាលម្នាក់ជាចាំបាច់ និងឲ្យគោរពតាមក្បួនវិន័យឯទៀតៗតាមសេចក្ដីណែនាំនៃច្បាប់ ទើបអាពាហ៍ពិពាហ៍នោះទុកជាបានការ។ មហាសន្និបាតសម្រេចដូច្នេះ ដើម្បីឲ្យអាពាហ៍ពិពាហ៍ទាំងនោះអាចយកជាការបាន និងដើម្បីឲ្យគូស្វាមីភរិយានៅជាប់ស្ថិតស្ថេរ ហើយបានវិសុទ្ធ ព្រមទាំងរស់នៅជាមួយគ្នាដោយសេចក្ដីសុខសាន្តទៀតផង។

## ពិធីគោរពបម្រើព្រះជាម្ចាស់

១៩-តាំងពីពេលនេះតទៅ មានតែមហាសន្និបាតសកល និងសន្តះអាសនៈនៃគ្រីស្តទូតសិលាប៉ុណ្ណោះទេ ដែលមាន សិទ្ធិផ្លាស់ប្តូរថ្ងៃបុណ្យរួមរបស់ព្រះសហគមន៍បូព៌ាប្រទេសទាំងឡាយ ឬលុបបំបាត់ថ្ងៃបុណ្យទាំងនោះបាន។ ចំពោះថ្ងៃបុណ្យរបស់ព្រះសហគមន៍ដោយឡែក សន្និបាតរបស់អភិបាលដ៏ប្រសើរឧត្តម ឬសន្និបាតរបស់អគ្គអភិបាល ក៏មានសិទ្ធិតែងតាំង និងផ្លាស់ប្តូរ ឬលុបបំបាត់ថ្ងៃបុណ្យនានា ដូចអាសនៈគ្រីស្តទូតសិលាដែរ។ ក៏ប៉ុន្តែ ត្រូវនឹកគិតដល់តំបន់ទាំងមូល និងដល់ព្រះសហគមន៍ដោយឡែកឯទៀតៗដែរ។

២០-មហាសន្និបាតប្រាថ្នាចង់ឲ្យគ្រីស្តបរិស័ទទាំងអស់ ព្រមព្រៀងគ្នាធ្វើបុណ្យចម្លងនៅថ្ងៃតែមួយដូចគ្នា។ ទម្រាំពេលនោះ សូមអស់លោកអភិបាលដ៏ប្រសើរឧត្តម និងអ្នកកាន់អំណាចយ៉ាងខ្ពង់ខ្ពស់ក្នុងព្រះសហគមន៍ក្នុងតំបន់ រួមមតិគ្នាធ្វើបុណ្យចម្លងនៅថ្ងៃអាទិត្យដដែលតែមួយដូចគ្នា ដោយព្រមគ្នាជាឯកច្ឆ័ន្ទ និងដោយបានពិគ្រោះជាមួយអស់អ្នកដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ធ្វើដូច្នេះ មុខជាអស់លោកនឹងជួយឲ្យគ្រីស្តបរិស័ទទាំងអស់ដែលរស់នៅក្នុងតំបន់ ឬក្នុងប្រទេសតែមួយ រួបរួមគ្នាជាធ្លុងតែមួយពុំខាន។

២១- ចំពោះកាលបរិច្ឆេទធ្វើពិធីគោរពប្រណិប័តន៍ គ្រីស្តបរិស័ទទាំងអស់ដែលរស់នៅក្រៅតំបន់ ឬក្រៅកន្លែងដែលគេកាន់តាមរបៀបរបបពិធីរបស់ខ្លួន មានសិទ្ធិសម្របខ្លួនទាំងស្រុងតាមវិន័យដែលតែងអនុវត្តនៅកន្លែងគេរស់នៅ។ ចំពោះក្រុមគ្រួសារដែលមានគូស្វាមីភរិយាជាគ្រីស្តបរិស័ទ កាន់តាមរបៀបរបបពិធីផ្សេងពីគ្នា គេមានសិទ្ធិតាមច្បាប់ដដែលនេះ គឺកាន់តាមរបៀបរបបពិធីតែមួយគត់។

២២-ក្រុមអ្នកទទួលអគ្គសញ្ញាតែងតាំង និងបព្វជិតបព្វជិតានៃព្រះសហគមន៍នៅបូព៌ាប្រទេស ត្រូវធ្វើពិធីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមវិន័យ និងតាមប្រពៃណីនៃក្បួនច្បាប់ក្រុមគ្រួសាររបស់គេ។ តាំងពីបរមបុរាណមកព្រះសហគមន៍នៅបូព៌ាប្រទេស តែងតែពេញចិត្តយ៉ាងខ្លាំង និងធ្លាប់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដូច្នេះ។ គ្រីស្តបរិស័ទក៏ត្រូវធ្វើតាមគំរូដូនតារបស់ខ្លួន គឺត្រូវចូលរួមក្នុងពិធីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នោះដែរ ដោយគោរពប្រណិប័តន៍តាមសមត្ថភាពរៀងៗខ្លួន។

២៣-មានតែអភិបាលដ៏ប្រសើរឧត្តមរួមជាមួយសន្និបាតរបស់លោក ឬអ្នកកាន់អំណាចដ៏ខ្ពង់ខ្ពស់ក្នុង ព្រះសហគមន៍នីមួយៗ ដោយមានក្រុមប្រឹក្សាអ្នកកាន់អំណាចដ៏សក្ការៈប៉ុណ្ណោះទេ ដែលមានសិទ្ធិចាត់ចែងឲ្យគេប្រើភាសាណាមួយ ក្នុងពិធីគោរពប្រណិប័តន៍ព្រះជាម្ចាស់។ ក្រោយពីបានរាយការណ៍ទៅអាសនៈគ្រីស្តទូតសិលាមក អស់លោក ក៏មានសិទ្ធិយល់ព្រមអនុម័តឲ្យយកអត្ថបទដែលគេបកប្រែតាមភាសាប្រជាជនរស់នៅក្នុងប្រទេសមកប្រើជាផ្លូវការបាន។

## ទំនាក់ទំនងជាមួយបងប្អូនក្នុងព្រះសហគមន៍ដែលបែកចេញពីយើង

២៤-ព្រះសហគមន៍នៅបូព៌ាប្រទេស ដែលរួបរួមជាមួយអាសនៈគ្រីស្តទូតសិលានៅក្រុងរ៉ូម មានភារកិច្ចពិសេស

លើកស្ទួយឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាធ្លុងតែមួយ ជាពិសេសគ្រីស្តបរិស័ទនៅបូព៌ាប្រទេសស្របតាមគោលការណ៍មហាសន្និបាតនេះ ស្តីអំពីការបង្រួបបង្រួមជាធ្លុងតែមួយ។ គេជួយឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាធ្លុង តែមួយមុនដំបូងដោយអធិដ្ឋាន បន្ទាប់មកដោយធ្វើជាគំរូតាមរបៀបរស់នៅរបស់គេ ដោយគោរពប្រពៃណីបុរាណនៅបូព៌ាប្រទេសយ៉ាងស្មោះបែបសាសនា ដោយស្គាល់គ្នាទៅវិញទៅមកឲ្យកាន់តែច្បាស់ឡើងៗ ដោយរួមសហការគ្នា និងដោយរាប់អានគ្នាទៅវិញទៅមកទុកជាបងប្អូន ព្រមទាំងរាប់រកអ្វីទាំងអស់របស់គេទុកជាគួរឲ្យស្រឡាញ់។

២៥- ប្រសិនបើមានគ្រីស្តបរិស័ទនៅបូព៌ាប្រទេសដែលបែកចេញពីយើង ចូលរួបរួមក្នុងព្រះសហគមន៍កាតូលិកតែមួយ ដោយព្រះហឫទ័យប្រោសប្រណីរបស់ព្រះវិញ្ញាណជួយបំភ្លឺចិត្តគំនិតគេផង កុំទាមទារអ្វីលើសពីសេចក្តីប្រកាសជំនឿកាតូលិកឡើយ។ ដោយព្រះសហគមន៍របស់គេបានរក្សាទុកមុខងារជាបូជាចារ្យឲ្យប្រើជាការបាន អស់លោកដែលទទួលអគ្គសញ្ញាតែងតាំងបម្រើព្រះសហគមន៍នៅបូព៌ាប្រទេស ហើយដែលចូលរួបរួមក្នុងព្រះសហគមន៍កាតូលិកតែមួយនោះ មានសិទ្ធិបំពេញមុខងាររបស់ខ្លួនផ្ទាល់តទៅទៀតបាន តាមវិន័យដែលអំណាចមានសមត្ថកិច្ចតែងតាំងរួចហើយ។

២៦-ធម៌វិន័យរបស់ព្រះជាម្ចាស់ ហាមមិនឲ្យគ្រីស្តបរិស័ទចូលរួបរួមក្នុងពិធីដ៏សក្ការៈប្លែកពីពិធីនៃគ្រីស្តសាសនាជាដាច់ខាត។ ការចូលរួបរួមក្នុងពិធីដ៏សក្ការៈបែបនេះ បណ្តាលឲ្យព្រះសហគមន៍បាក់បែកគ្នា និងនាំឲ្យប្រកាសយ៉ាងជាក់ច្បាស់ថា ខ្លួនភ្ជាប់ចិត្តជឿសេចក្តីមិនពិត ឬប្រកាសសេចក្តីដែលបណ្តាលឲ្យវង្វេងជំនឿ និងរារាំងអ្នកដទៃមិនឲ្យជឿទៀត។ ការចូលរួបរួមក្នុងពិធីដ៏សក្ការៈបែបនេះក៏បណ្តាលឲ្យខ្លួនមិនអើពើនឹងជំនឿដោយគិតថា សាសនាណា ក៏ដូចសាសនាណាដែរ។

ប៉ុន្តែ ចំពោះបងប្អូនគ្រីស្តបរិស័ទនៅបូព៌ាប្រទេសវិញ មិនមែនដូច្នោះទេ។ បទពិសោធន៍ក្នុងការឃ្វាលណែនាំបង្ហាញឲ្យឃើញថា នៅពេលណាគ្មានការប៉ះពាល់នឹងការរួបរួមរបស់ព្រះសហគមន៍ ហើយមិនបណ្តាលឲ្យខ្លាចអ្វីដែលត្រូវជៀសវាងនោះ យើងអាច (ហើយក៏ត្រូវ) ចាប់អារម្មណ៍នឹងសភាពការណ៍ផ្សេងៗរបស់បុគ្គលម្នាក់ៗ គឺយើងត្រូវចាប់អារម្មណ៍នឹងតម្រូវការរបស់គេ ដែលត្រូវទទួលការសង្គ្រោះនិងផលប្រយោជន៍ខាងវិញ្ញាណវិញ។ ហេតុនេះហើយ បានជាកាលពីដើមហើយសព្វថ្ងៃដែរ ព្រះសហគមន៍កាតូលិកអនុញ្ញាតឲ្យអនុវត្តតាមគោលការណ៍មិនសូវតឹងរឹងទេ ដោយយល់ឃើញដល់សភាពការណ៍នៃកាលៈទេសៈនៃទីកន្លែង និងនៃបុគ្គលម្នាក់ៗ។ ព្រះសហគមន៍មានគោលបំណងជូនគ្រប់មធ្យោបាយនៃការសង្គ្រោះឲ្យគេ ព្រមទាំងផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់របស់គ្រីស្តបរិស័ទចំពោះគ្នាទៅវិញទៅមក។ ហេតុនេះហើយ បានជាព្រះសហគមន៍កាតូលិកអនុញ្ញាតឲ្យគ្រីស្តបរិស័ទទទួលអគ្គសញ្ញានានា និងចូលរួមក្នុងពិធីឯទៀតៗ និងក្នុងអ្វីៗដ៏សក្ការៈដែរ។

មហាសន្និបាតយល់ឃើញដូច្នេះ *"កុំឲ្យយើងទៅជាឧបសគ្គចំពោះអ្នកដែលទទួលការសង្គ្រោះ ដោយយើងដាក់ទោសគេធ្ងន់ពេក"* ក្នុងគោលបំណង ជួយព្រះសហគមន៍នានានៅបូព៌ាប្រទេស ដែលបែកចេញពីយើងឲ្យរួបរួមជាមួយយើង ចែងរបៀបប្រព្រឹត្តិដូចតទៅ៖

២៧-ទោះបីត្រូវនឹកគិតដល់គោលការណ៍ចែងនៅខាងលើក៏ដោយ ក៏យើងអាចធ្វើអគ្គសញ្ញាលើកលែងទោស អគ្គសញ្ញាអរព្រះគុណ និងអគ្គសញ្ញាលាបប្រេងអ្នកជំងឺ ជូនគ្រីស្តបរិស័ទនៅបូព៌ាប្រទេសដែលបែកចេញពីព្រះសហគមន៍កាតូលិកយើងដោយមិនដឹងខ្លួនបាន លុះត្រាតែគេសូមទទួលអគ្គសញ្ញាទាំងនោះដោយខ្លួនគេផ្ទាល់ និងបានរៀបចំខ្លួនទទួលយ៉ាងសមរម្យ។ លើសពីនេះទៅទៀត គ្រីស្តបរិស័ទកាតូលិកមានសិទ្ធិសូមលោកដែលទទួលមុខងារបម្រើ ដែលមិនមែនជាគ្រីស្តបរិស័ទកាតូលិក ធ្វើអគ្គសញ្ញាទាំងនោះជូនខ្លួនបាន លុះត្រាតែគេទទួលអគ្គសញ្ញាទាំងនោះក្នុង

ព្រះសហគមន៍ដែលទទួលស្គាល់ថា អគ្គសញ្ញាទាំងនោះយកជាការបាន។ គ្រីស្តបរិស័ទកាតូលិកមានសិទ្ធិសុំដូច្នេះ គ្រប់ពេលណាគេត្រូវការ ឬគ្រប់ពេលណាគេយល់ឃើញថា មានប្រយោជន៍យ៉ាងពិតប្រាកដខាងព្រះវិញ្ញាណ ឬប្រសិនបើគេមានឧបសគ្គខាងផ្លូវកាយ ឬខាងផ្លូវចិត្ត មិនអាចទៅសូមគង្វាល កាតូលិកបាន។

២៨-លើសពីនេះទៅទៀត ទោះបីត្រូវនឹកគិតដល់គោលការណ៍ដូចមានចែងនៅខាងលើក៏ដោយ ក៏មានការអនុញ្ញាតឲ្យគ្រីស្តបរិស័ទកាតូលិកនិងបងប្អូនគ្រីស្តបរិស័ទខាងបូព៌ាប្រទេសដែលបែកចេញពីយើង ចូលរួបរួមធ្វើពិធីដ៏សក្ការៈជាមួយគ្នាបាន ព្រមទាំងចែកចាយអ្វីៗដ៏សក្ការៈក្នុងពិធីគោរពប្រណិប័តន៍និងនៅទីកន្លែងដ៏សក្ការៈដែរ ប៉ុន្តែត្រូវមានមូលហេតុដ៏ត្រឹមត្រូវ។

សេចក្តីណែនាំ អំពីការចូលរួបរួមធ្វើពិធីដ៏សក្ការៈជាមួយបងប្អូននៃព្រះសហគមន៍នៅបូព៌ាប្រទេស ដែលបែកចេញពីយើង ពិតជាស្រួលជាងគោលការណ៍ចែងនៅខាងលើមែន។ មហាសន្និបាតផ្ញើសេចក្តីណែនាំទាំងនេះឲ្យអស់លោកកាន់អំណាចដ៏សក្ការៈដែលគ្រប់គ្រងតំបន់ទាំងនោះ អនុវត្តតាមដោយប្រុងប្រយ័ត្ន។ សូមអស់លោកពិគ្រោះគ្នា ហើយប្រសិនបើត្រូវការ សូមពិគ្រោះជាមួយអស់លោកដែលមានអំណាចដ៏សក្ការៈនៃព្រះសហគមន៍ ដែលបែកចេញពីព្រះសហគមន៍កាតូលិកដែរ រួចត្រូវដោះស្រាយទំនាក់ទំនងរបស់គ្រីស្តបរិស័ទទាំងឡាយ តាមសេចក្តីសម្រេចនិងតាមសេចក្តីណែនាំដ៏ស័ក្តិសិទ្ធិតាមតម្រូវការ។

# ពាក្យបញ្ចប់

មហាសន្និបាតមានអំណរសប្បាយរីករាយ ដោយព្រះសហគមន៍កាតូលិកនៅបូព៌ាប្រទេស និងនៅបស្ចិមប្រទេស រួមសហការគ្នាយ៉ាងសកម្ម។ ការសហការនេះមុខជានឹងបង្កើតផលល្អពុំខាន។ នៅពេលជាមួយគ្នានេះ មហាសន្និបាតប្រកាសសេចក្តីដូចតទៅ៖ មហាសន្និបាតបានចាត់ចែងសេចក្តីខាងច្បាប់ទាំងនោះ ដោយយល់ដល់សភាពការណ៍បច្ចុប្បន្ន ទម្រាំដល់ពេលព្រះសហគមន៍កាតូលិក និងព្រះសហគមន៍នៅបូព៌ាប្រទេសដែលបែកចេញនោះរួបរួមគ្នាយ៉ាងពេញលក្ខណៈ។ ទម្រាំពេលនោះ មហាសន្និបាតអញ្ជើញគ្រីស្តបរិស័ទទាំងអស់ ទាំងនៅបូព៌ាប្រទេស ទាំងនៅបស្ចិមប្រទេស ឲ្យព្យាយាមទទូចអង្វរព្រះជាម្ចាស់រៀងរាល់ថ្ងៃ សូមឲ្យគ្រីស្តបរិស័ទទាំងអស់រួបរួមគ្នាជាអង្គតែមួយ ដោយព្រះមាតារបស់ព្រះអម្ចាស់ដ៏វិសុទ្ធបំផុតជួយឧបត្ថម្ភផង។ សូមគ្រីស្តបរិស័ទទាំងអស់ទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រណីដល់គ្រីស្តបរិស័ទជាច្រើនអនេក នៃព្រះសហគមន៍នីមួយៗ ដែលប្រកាសព្រះនាមព្រះគ្រីស្តដោយចិត្តក្លាហាន ហើយដែលកំពុងរងទុក្ខលំបាកវេទនាព្រោះតែមូលហេតុនេះ។ សូមព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រណីសម្រាលទុក្ខគេ និងលើកទឹកចិត្តគេយ៉ាងពេញលេញទៀតផង។

«យើងត្រូវស្រឡាញ់រាប់អានគ្នាទៅវិញទៅមកទុកដូចជាបងប្អូន។ ត្រូវលើកកិត្តិយសគ្នាទៅវិញទៅមក ដោយចិត្តគោរព» (រម ១២, ១០)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ ព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផងក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលា ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៦៤

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# ក្នុងចំណោមការអស្ចារ្យ

(អំពីមធ្យោបាយទូរគមនាគមន៍)

# INTER MIRIFICA

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសក្រឹត្យក្រមនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។ ក្រឹត្យក្រមអំពីសារទូរគមនាគមន៍ក្នុងសង្គម

### ១-អត្ថន័យពាក្យ

មនុស្សប្រកបដោយប្រាជ្ញាដ៏ប៉ិនប្រសប់ បានរកឃើញបច្ចេកទេសដ៏អស្ចារ្យវិសេសវិសាល ដោយពិនិត្យមើល ពីពិភពលោកដែលព្រះជាម្ចាស់ប្រតិស្ឋានមក ជាពិសេសនៅសម័យយើងនេះ ដោយព្រះអង្គជួយឧបត្ថម្ភផង។ ក្នុងចំណោមការអស្ចារ្យទាំងប៉ុន្មានដែលមនុស្សបានរកឃើញនោះ ព្រះសហគមន៍ទទួលស្គាល់ និងតាមមើលយ៉ាងពិសេសនូវការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងគុណសម្បត្តិខាងវិញ្ញាណរបស់មនុស្ស។ ការដែលគេរកឃើញទាំងនោះ ផ្ដល់ឲ្យមនុស្សមានសមត្ថភាពកាន់តែទូលំទូលាយ អាចផ្សព្វផ្សាយដំណឹងគ្រប់យ៉ាង ផ្សព្វផ្សាយគំនិត និងយោបល់ផ្សេងៗ ព្រមទាំងសេចក្ដីណែនាំកាន់តែស្រួលឡើងៗ ព្រះសហគមន៍យកចិត្តទុកដាក់ជាទីបំផុតនឹងការអស្ចារ្យដែលមនុស្សរកឃើញទាំងនោះ ដូចម្ដាយយកចិត្តទុកដាក់នឹងកូនដូច្នោះដែរ។ ក្នុងចំណោមបច្ចេកទេសដែលមនុស្សរកឃើញទាំងនោះ យើងត្រូវកត់សម្គាល់យ៉ាងពិសេស នូវមធ្យោបាយដែលមានលក្ខណៈជួយឲ្យមានទំនាក់ទំនងជាមួយមនុស្សទាំងអស់។ បច្ចេកទេសទាំងនោះ មានឥទ្ធិពលមិនត្រឹមតែលើបុគ្គលម្នាក់ៗប៉ុណ្ណោះទេ តែមានឥទ្ធិពលលើមនុស្សទាំងក្រុមៗ រហូតមានឥទ្ធិពលដល់មនុស្សជាតិទាំងមូលថែមទៀតផង។ ក្នុងចំណោមបច្ចេកទេសទាំងនោះ មានការសែតផ្សព្វផ្សាយពត៌មាន មានខ្សែភាពយន្ត វិទ្យុ ទូរទស្សន៍ និងបច្ចេកទេសដទៃទៀតដែលមានលក្ខណៈដូចគ្នា។ ហេតុនេះហើយ បានជាយើងអាចហៅបច្ចេកទេសទាំងនោះយ៉ាងត្រឹមត្រូវថា «មធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម»។

### ២-ហេតុអ្វីមហាសន្និបាតយកចិត្តទុកដាក់អំពីបញ្ហានេះ?

ព្រះសហគមន៍ជាមាតារបស់យើងដឹងច្បាស់ថា ប្រសិនបើមនុស្សប្រើឧបករណ៍ទាំងនោះយ៉ាងត្រឹមត្រូវ គ្រឿងឧបករណ៍ទាំងនោះ អាចជួយបម្រើមនុស្សជាតិយ៉ាងខ្លាំងក្លា គឺជួយឲ្យមនុស្សលំហែកាយ ហើយជួយឲ្យវប្បធម៌ និងប្រាជ្ញាញាណរបស់ខ្លួនចម្រើនឡើង ព្រមទាំងលាតសន្ធឹងអំណាចរបស់ព្រះជាម្ចាស់ ដែលគ្រងរាជ្យលើមនុស្សលោក ឲ្យ

កាន់តែរឹងប៉ឹងឡើងៗ។ ប៉ុន្តែ ព្រះសហគមន៍ក៏ដឹងទៀតថា មនុស្សអាចប្រើឧបករណ៍ទាំងនោះ ប្រឆាំងនឹងគម្រោងការរបស់ព្រះអាទិករបានដែរ ហើយនាំមនុស្សលោកទៅរកអន្តរាយទៀតផង។ ព្រះសហគមន៍ក្នុងឋានៈជាមាតា ព្រួយបារម្ភដោយឃើញថា មធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម បណ្តាលឲ្យមនុស្សជាតិបង់ខាតប្រយោជន៍របស់ខ្លួនជាញឹករួចហើយ មកពីគេប្រើប្រាស់ឧបករណ៍ទាំងនោះបែបមិនត្រឹមត្រូវ។

ហេតុនេះហើយ បានជាមហាសន្និបាតសកល រួមជាមួយអភិបាលព្រះសហគមន៍ក្រុងរ៉ូមត ៗមក និងជាមួយអភិបាលនានាដែលខ្វល់ខ្វាយ និងគិតគូរអំពីបញ្ហាដ៏ធ្ងន់ធ្ងរនេះយល់ឃើញថា ខ្លួនមានភារកិច្ចរិះគិតអំពីបញ្ហាសំខាន់ៗជាងគេដែលចោទឡើង អំពីមធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម។ មហាសន្និបាតក៏សង្ឃឹមទៀតថា លទ្ធិនិងក្បួនវិន័យ ដែលខ្លួនផ្តល់ជូននេះ មុខជានឹងមានប្រយោជន៍ មិនគ្រាន់តែសម្រាប់សង្គ្រោះគ្រីស្តបរិស័ទប៉ុណ្ណោះទេ តែមានប្រយោជន៍សម្រាប់ឲ្យមនុស្សជាតិទាំងមូលចម្រើនឡើងទៀតដែរ។

# ជំពូក ១

## លទ្ធិនៃព្រះសហគមន៍

### ៣-បន្ទុករបស់ព្រះសហគមន៍

ព្រះគ្រីស្តជាព្រះអម្ចាស់នៃយើង បានតែងតាំងព្រះសហគមន៍ដើម្បីនាំការសង្គ្រោះដល់មនុស្សទាំងអស់។ ហេតុនេះហើយ បានជាព្រះសហគមន៍យល់ឃើញថា ខ្លួនមានភារកិច្ចប្រកាសដំណឹងល្អ។ ព្រះសហគមន៍កាតូលិកក៏យល់ឃើញទៀតថា ខ្លួនមានភារកិច្ចប្រើឧបករណ៍នាំសារក្នុងសង្គម ដើម្បីប្រកាសសារអំពីការសង្គ្រោះដែរ។ ម៉្យាងទៀត ព្រះសហគមន៍ក៏មានភារកិច្ចបង្រៀនមនុស្ស ឲ្យចេះប្រើប្រាស់ឧបករណ៍ទាំងនោះយ៉ាងល្អត្រឹមត្រូវដែរ។

ហេតុនេះតាំងពីកំណើតមក ព្រះសហគមន៍មានសិទ្ធិកាន់កាប់ហើយប្រើប្រាស់មធ្យោបាយទាំងនោះ ដោយមិនចោលមធ្យោបាយណាមួយឡើយ តាមតែខ្លួនត្រូវការ ឬតាមតែមធ្យោបាយទាំងនោះ មានប្រយោជន៍សម្រាប់អប់រំគ្រីស្តបរិស័ទ និងសម្រាប់កិច្ចការណែនាំឯទៀតៗផង។ អស់លោកអភិបាលមានភារកិច្ចបង្រៀន និងណែនាំគ្រីស្តបរិស័ទ ឲ្យប្រើមធ្យោបាយសារទូរគមនាគមន៍ទាំងនោះសម្រាប់សង្គ្រោះខ្លួនគេ និងសង្គ្រោះមនុស្សជាតិទាំងមូល ហើយឲ្យគេ និងមនុស្សជាតិបានពេញលក្ខណៈទៀតដែរ។

លើសពីនេះទៅទៀត គ្រីស្តបរិស័ទធម្មតាទាំងឡាយ មានភារកិច្ចប្រើមធ្យោបាយទាំងនោះ ស្របតាមតម្លៃដ៏ថ្លៃថ្នូររបស់គ្រីស្តសាសនា និងស្របតាមលក្ខណៈរបស់មនុស្ស។ ដូច្នេះ មធ្យោបាយទាំងនោះអាចតបឆ្លើយនឹងសេចក្តីប៉ងប្រាថ្នាដ៏ខ្លាំងក្លារបស់មនុស្សជាតិ និងស្របតាមគម្រោងការរបស់ព្រះជាម្ចាស់ដែរ។

### ៤-វិន័យនិងសីលធម៌

អស់អ្នកដែលប្រើប្រាស់មធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម ត្រូវតែស្គាល់គោលការណ៍នៃសីលធម៌ និងអនុវត្តតាមយ៉ាងស្មោះត្រង់ជាចាំបាច់ ដើម្បីឲ្យគេអាចប្រើប្រាស់មធ្យោបាយទាំងនោះយ៉ាងត្រឹមត្រូវ។ មុនដំបូងគេពិតជាត្រូវយកចិត្តទុកដាក់នឹងកម្មវត្ថុ គឺពីសេចក្តីដែលគេផ្សព្វផ្សាយនោះ ស្របតាមលក្ខណៈផ្ទាល់នៃឧបករណ៍នីមួយៗ។ គេក៏ត្រូវយកចិត្តទុកដាក់នឹងបរិបទនៃការផ្សព្វផ្សាយទៀតដែរ ឧបមាត្រូវគិតអំពីគោលដៅ អំពីអ្នកដែលទទួល ឬស្តាប់ពត៌មាន អំពីទីកន្លែង អំពីពេលវេលា។ល។ បរិបទនោះ អាចបណ្តោយឲ្យផ្លាស់ប្តូរ ឬឲ្យប្រែសីលធម៌ទាំងស្រុង។ យើងត្រូវកត់សម្គាល់អំពីរបៀបមធ្យោបាយនីមួយៗមានសកម្មភាពគឺថា អំពីកម្លាំងដ៏ខ្លាំងក្លានៃមធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម ដែលប៉ះលើចិត្តគំនិតអ្នកស្តាប់។ អ្នកស្តាប់ ជាពិសេសអ្នកដែលមិនសូវបានទទួលការអប់រំយ៉ាងសមរម្យជាមុន

មិនអាចដឹងអំពីឥទ្ធិពលនៃទូរគមនាគមន៍នោះប៉ះទង្គិច គេក៏មិនអាចធ្វើជាម្ចាស់លើឥទ្ធិពលនោះបានដែរ ហើយប្រសិនបើត្រូវលះបង់ចោលឥទ្ធិពលនោះ គេមិនអាចលះបង់ចោលបានឡើយ។

៥-អស់អ្នកដែលចាប់អារម្មណ៍នឹងមធ្យោបាយសារទូរគមនាគមន៍ក្នុងសង្គម ត្រូវតែអប់រំជាចាំបាច់បំផុត ឲ្យមនសិការរបស់ខ្លួនបានទៀងត្រង់ ចំពោះការប្រើប្រាស់ឧបករណ៍ទាំងនោះ ជាពិសេសចំពោះបញ្ហាជាច្រើន ដែលអ្នកឯកទេសកំពុងជជែកវែកញែកយ៉ាងខ្លាំងនៅសម័យឥឡូវ។

## សិទ្ធិទទួលពត៌មាន

បញ្ហាទីមួយ គឺអំពីពត៌មាន។ ពត៌មាន មានន័យថា ការប្រមូលនិងផ្សព្វផ្សាយដំណឹងផ្សេងៗ។ សង្គមទំនើបតែងតែចម្រើនឡើងជាលំដាប់ ហើយសមាជិកក្នុងសង្គម ក៏មានចំណងទាក់ទងគ្នាទៅវិញទៅមកកាន់តែជិតស្និទ្ធឡើងៗដែរ។ ហេតុនេះ ពត៌មានមានប្រយោជន៍យ៉ាងខ្លាំង ហើយយ៉ាងចាំបាច់បំផុតទៀតផង។ សេចក្ដីនេះជាក់ច្បាស់ហើយ។ ដោយមានគេផ្សព្វផ្សាយដំណឹងជាសាធារណៈ តាមពេលមនុស្សត្រូវការ ពីអំពើដែលមនុស្សបានធ្វើ និងអំពីព្រឹត្តិការណ៍ដែលកើតឡើង គេផ្ដល់ឲ្យមនុស្សម្នាក់ៗស្គាល់អំពើ និងព្រឹត្តិការណ៍ទាំងនោះយ៉ាងពេញលេញសព្វគ្រប់ជាអចិន្ត្រៃយ៍។ ដោយស្គាល់ពត៌មានបែបនេះ មនុស្សម្នាក់ៗតាមចំណែករៀងៗខ្លួន អាចសហការយ៉ាងស័ក្ដិសិទ្ធិ និងកាន់តែស្រួល ធ្វើឲ្យសង្គមទាំងមូលលូតលាស់និងចម្រើនឡើងបានផង។ ហេតុនេះត្រូវយល់ថា សង្គមមនុស្សមានសិទ្ធិទទួលពត៌មាន អំពីប្រធានបទដែលពាក់ព័ន្ធនឹងមនុស្សទាំងអស់ ទោះជាបុគ្គលម្នាក់ៗក្ដី ទោះជាសមាជិកក្នុងសង្គមមួយក្ដី តាមសភាពការណ៍រៀងៗខ្លួន។ ប៉ុន្តែ គេអាចប្រើសិទ្ធិនេះបាន លុះត្រាតែមានផ្សព្វផ្សាយតែពត៌មានពិតប្រាកដជានិច្ច និងពត៌មានដ៏ពេញលេញសព្វគ្រប់ ទាំងគោរពយុត្តិធម៌និងសេចក្ដីស្រឡាញ់ទៀតផង។ សូមរកនិងផ្សព្វផ្សាយពត៌មានតាមរបៀបសមរម្យ និងប្រកបដោយគុណធម៌ គឺថា ត្រូវគោរពតាមវិន័យនៃសីលធម៌យ៉ាងហ្មត់ចត់ជាចាំបាច់ ហើយក៏ត្រូវគោរពសិទ្ធិនិងកិត្តិយសរបស់បុគ្គលម្នាក់ៗ ដ្បិត «ចំណេះចេះដឹងគ្រប់យ៉ាងមិនមានប្រយោជន៍ទាំងអស់ទេ រីឯសេចក្ដីស្រឡាញ់រមែងតែងតែជួយកសាងវិញ» (១ករ ៨, ១)។

### ៦-សិល្បៈ និងសីលធម៌

បញ្ហាទីពីរ គឺរបៀបសិល្បៈ (គឺការផ្សព្វផ្សាយពត៌មានតាមពាក្យដែលគេនិយមនិយាយទូទៅ) និងសីលធម៌ពាក់ព័ន្ធគ្នាទៅវិញទៅមក។ សព្វថ្ងៃ គេតែងតែជជែកវែកញែកកាន់តែច្រើនឡើងអំពីបញ្ហានេះ មកពីគេកាន់លទ្ធិភាន់ច្រឡំអំពីសីលធម៌និងអំពីសិល្បៈ។ ហេតុនេះហើយ បានជាមហាសន្និបាតប្រកាសថា មនុស្សទាំងអស់ត្រូវតែអនុវត្តតាមសីលធម៌ដ៏ពិតប្រាកដមកពីកំណើត។ មានតែសីលធម៌បែបនេះទេ ដែលហួសពីសកម្មភាពគ្រប់យ៉ាងរបស់មនុស្ស ហើយដែលធ្វើឲ្យគ្រប់សកម្មភាពទាំងនោះស៊ីចង្វាក់គ្នា ទោះបីសកម្មភាពទាំងនោះល្អប្រសើរយ៉ាងណាក៏ដោយ។ ក្នុងចំណោមសកម្មភាពទាំងនោះ មានសិល្បៈជាដើម។ សីលធម៌បែបនេះ ក៏គ្រប់គ្រងមនុស្សទាំងស្រុង ក្នុងឋានៈជាអ្នកទទួលប្រាជ្ញាពីព្រះជាម្ចាស់ ដែលព្រះអង្គត្រាស់ហៅឲ្យគេមានទិដៅហួសពីលោកីយ៍នេះទៀតផង។ ម្យ៉ាងទៀត មនុស្សបានពេញលក្ខណៈ និងបានសុភមង្គល ដោយគោរពតាមសីលធម៌ទាំងស្រុងនេះដោយចិត្តស្មោះ។

### ៧-អំពីសេចក្តីអាក្រក់

បញ្ហាទីបី គឺបញ្ហានិទានរឿង ឬការរៀបរាប់ ឬការសម្តែងសេចក្តីអាក្រក់របស់មនុស្ស តាមរយៈសារទូរគមនាគមន៍

ក្នុងសង្គម ពិតជាអាចជួយណែនាំឲ្យមនុស្សស្គាល់ និងចេះវិភាគរិះគិតយ៉ាងជ្រៅអំពីលក្ខណៈមនុស្សយើងបាន។ ប្រសិនបើ គេចេះប្រើរបៀបសិល្បៈយ៉ាងស្វាហាប់ គេបណ្ដោយឲ្យរំភើបចិត្ត ទើបការរៀបរាប់សេចក្ដីអាក្រក់នោះ អាចបង្ហាញ និងលើកតម្កើងសេក្ដីពិតនិងអ្វីដ៏ល្អប្រសើរ ឲ្យភ្លឺឡើងយ៉ាងជាក់ច្បាស់បាន។ ក៏ប៉ុន្តែ ការបង្ហាញសេចក្ដីអាក្រក់នោះ ក៏អាចបង្ខូចសតិមនុស្សបានដែរ។ ប្រសិនបើ យើងចង់ឲ្យសិល្បៈមានប្រយោជន៍ដល់មនុស្សវិញ ត្រូវតែអនុវត្តតាមសីលធម៌យ៉ាងហ្មត់ចត់ ជាពិសេសចំពោះប្រធានបទដែលងាយស្រួលបង្កបង្កើតបំណងអាក្រក់ តាមតណ្ហាដែលយើងមានក្នុងខ្លួន។

## ៨-មតិសាធារណៈ

មតិសាធារណៈសព្វថ្ងៃ មានឥទ្ធិពលយ៉ាងខ្លាំងសម្បើម ទៅលើការរស់នៅរបស់មនុស្សម្នាក់ៗ និងទៅលើការរស់នៅជាសាធារណៈរបស់ប្រជាពលរដ្ឋទូទៅ ទោះបីគេមានឋានៈវណ្ណៈណាក៏ដោយ។ ហេតុនេះហើយ បានជាត្រូវឲ្យសមាជិកទាំងអស់ក្នុងសង្គម បំពេញភារកិច្ចរបស់ខ្លួនអំពីយុត្តិធម៌ និងអំពីសេចក្ដីពិតក្នុងករណីនេះដែរ។ គេត្រូវប្រើសារទូរគមនាគមន៍ក្នុងសង្គម ដើម្បីសហការបង្កើតមតិសាធារណៈយ៉ាងល្អត្រឹមត្រូវ និងផ្សព្វផ្សាយមតិទាំងនោះ។

## ៩-ភារកិច្ចរបស់អ្នកប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម

អស់អ្នកប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម គឺអ្នកអានកាសែត អ្នកទស្សនាទូរទស្សន៍ និងអ្នកស្ដាប់វិទ្យុទទួលពត៌មានទាំងនោះ តាមជម្រើសរបស់ខ្លួនដោយសេរី ក្នុងចំណោមដំណឹងទាំងប៉ុន្មានដែលមានផ្សព្វផ្សាយតាមរយៈមធ្យោបាយទាំងនោះ។ ហេតុនេះ អ្នកអានកាសែត អ្នកទស្សនាទូរទស្សន៍ និងអ្នកស្ដាប់វិទ្យុ មានភារកិច្ចពិសេស គឺជម្រើសរបស់គេ ច្បាស់ជាគាំទ្រនូវអ្វីៗដែលមានតម្លៃដ៏ពិតប្រាកដតាមសីលធម៌ តាមវប្បធម៌ និងតាមសិល្បៈ។ គេត្រូវជៀសវាងអ្វីៗដែលជាឱកាស ឬជាមូលហេតុបណ្ដាលឲ្យខ្លួនខូចខាតខាងវិញ្ញាណ។ គេជៀសវាងអ្វីៗដែលបណ្ដាលឲ្យអ្នកដទៃវង្វេងពីជំនឿដោយគេធ្វើគំរូអាក្រក់ដាក់ឲ្យអ្នកទាំងនោះ។ គេក៏មិនត្រូវបង្កើតឧបសគ្គដល់ទូរគមនាគមន៍ល្អ និងបែរជាគាំទ្រទូរគមនាគមន៍អាក្រក់ទៅវិញ។ រឿងនេះ តែងកើតឡើងនៅពេលយើងយកប្រាក់មកគាំទ្រអ្នកដែលប្រើសារទូគមនាគមន៍ក្នុងសង្គម ដោយគិតតែពីចង់បានកម្រៃប៉ុណ្ណោះ។

អ្នកប្រើប្រាស់សារទូគមនាគមន៍ក្នុងសង្គម មិនត្រូវធ្វេសប្រហែសនឹងភារកិច្ចរបស់ខ្លួនឡើយ គឺត្រូវស្វែងរកឲ្យបានដឹងទាន់ពេល អំពីគោលជំហរនៃអំណាចដែលមានសមត្ថកិច្ចក្នុងព្រះសហគមន៍អំពីរឿងទាំងនោះ និងអនុវត្តតាមមនសិការទៀងត្រង់របស់ខ្លួនណែនាំទៀតផង ដើម្បីឲ្យកិរិយារបស់ខ្លួនបានស្របតាមសីលធម៌។ លើសពីនេះទៅទៀត គេត្រូវយកចិត្តទុកដាក់អប់រំមនសិការរបស់ ខ្លួនឲ្យបានភ្លឺថ្លានិងទៀងត្រង់ ដោយប្រើជំនួយសមរម្យតាមតម្រូវការ ដើម្បីងាយស្រួលទប់ទល់នឹងឥទ្ធិពលដែលមិនល្អ និងតាមឥទ្ធិពលដ៏ល្អវិញ។

## ១០-ភារកិច្ចរបស់យុវជនយុវនារីនិងភារកិច្ចរបស់ឪពុកម្ដាយ

អ្នកប្រើប្រាស់សារទូគមនាគមន៍ក្នុងសង្គម ជាពិសេសយុវជនយុវនារី ត្រូវហ្វឹកហ្វឺនហាត់ខ្លួនឲ្យចេះប្រមាណ និងប្រើប្រាស់មធ្យោបាយទាំងនោះដោយអនុវត្តតាមវិន័យ។ គេក៏ត្រូវស្វែងរកឲ្យយល់អ្វីៗដែលគេឃើញ ស្ដាប់ឮ និងអានឲ្យកាន់តែច្បាស់ឡើងៗ។ គេត្រូវជជែកវែកញែកជាមួយអ្នកអប់រំរបស់គេ ឬជាមួយអ្នកជំនាញការអំពីរឿងដែលគេបានឃើញ ស្ដាប់ឮ និងបានអាននោះ។ ធ្វើដូច្នេះ ទើបគេហាត់ខ្លួនឲ្យចេះវិនិច្ឆ័យយ៉ាងត្រឹមត្រូវ។ រីឯឪពុកម្ដាយវិញ ត្រូវនឹកចាំថា គាត់មានភារកិច្ចប្រយ័ត្នប្រយែងយ៉ាងហ្មត់ចត់ កុំឲ្យអ្វីអាក្រក់ដែលមានផ្សាយតាមខ្សែភាពយន្ត និងតាមទូរទស្សន៍ ឬតាមកាសែត ហើយដែលផ្ទុយនឹងជំនឿឬនឹងសីលធម៌ ចូលក្នុងផ្ទះឲ្យសោះ។ គាត់ក៏ត្រូវការពារកូនៗមិនឲ្យទស្សនា និងអានសេចក្ដីអាក្រក់ទាំងនោះនៅកន្លែងផ្សេងទៀតដែរ។

## ១១-ភារកិច្ចរបស់អ្នកផលិត

អ្នកកាសែត អ្នកនិពន្ធសៀវភៅ តួល្ខោន អ្នកចាត់ចែងខ្សែភាពយន្ត អ្នកផលិត អ្នកធ្វើកម្មវិធីខ្សែភាពយន្ត អ្នកផ្សព្វផ្សាយខ្សែភាពយន្ត អ្នកសរសេរសេចក្តីវាយតម្លៃ សរុបសេចក្តីមក អស់អ្នកដែលចូលរួមក្នុងការផលិត និងការផ្សព្វផ្សាយសេចក្តីតាមរយៈសារទូរគមនាគមន៍ក្នុងសង្គម មានភារកិច្ចពិសេសក្នុងការប្រើប្រាស់មធ្យោបាយទាំងនោះ។ ក្នុងពិភពលោកយើងនេះ អ្នកទាំងនោះពិតជាទទួលខុសត្រូវជាទម្ងន់ ព្រោះថា ដោយគេផ្សព្វផ្សាយពត៌មាន និងដោយគេសង្កត់លើមតិសាធារណៈ គេអាចណែនាំមនុស្សជាតិតាមផ្លូវល្អក៏បាន ឬតាមផ្លូវអាក្រក់ក៏បានដែរ។

ហេតុនេះ គេមិនត្រូវគិតតែអំពីផលប្រយោជន៍សេដ្ឋកិច្ច ឬអំពីផលប្រយោជន៍នយោបាយ ឬអំពីសិល្បៈប៉ុណ្ណោះទេ ហើយក៏កុំឲ្យសេដ្ឋកិច្ច នយោបាយ និងសិល្បៈទាស់ទែងប្រឆាំងនឹងប្រយោជន៍រួមជាដាច់ខាត។ គួរឲ្យពួកគេរួមជាសមាគមអាជីវកម្ម ដែលមានសមត្ថភាពអាចបង្ខំសមាជិករបស់ខ្លួន ឲ្យគោរពសីលធម៌ក្នុងពេលដោះស្រាយបញ្ហា និងបំពេញសកម្មភាពអាជីវកម្មរបស់គេនោះ។ ធ្វើដូច្នេះ គេមុខជានឹងបានលទ្ធផលល្អយ៉ាងស្រួលជាងនៅម្នាក់ឯងជាពុំខាន។ ប្រសិនបើត្រូវការសមាគមរបស់គេ អាចសុំឲ្យសមាជិកសន្យាយ៉ាងជាក់លាក់ថា គេស្ម័គ្រចិត្តគោរពតាមក្បួនសីលធម៌ថែមទៀតផង។

អ្នកទាំងនោះត្រូវនឹកចងចាំជានិច្ចថា អ្នកអាននិងអ្នកទស្សនា ភាគច្រើនជាយុវជនយុវនារី ដែលត្រូវការកាសែតនិងខ្សែភាពយន្តដើម្បីលំហែកាយ និងលំហែចិត្តយ៉ាងសមរម្យ ហើយដែលលើកចិត្តគំនិតគេឲ្យ ទៅរកឧត្តមគតិយ៉ាងខ្ពស់។ អ្នកទាំងនោះ ក៏ត្រូវយកចិត្តទុកដាក់ធ្វើឲ្យសហការីដែលមានសមត្ថភាពប្រាកដប្រជា ចាត់ចែងប្រធានបទអំពីសាសនា ដើម្បីរៀបរាប់ដោយក្តីគោរពនិងសមគួរនឹងរឿងសាសនា។

## ១២-ភារកិច្ចរបស់រដ្ឋអំណាច

រដ្ឋអំណាចមានភារកិច្ចពិសេសដោយឡែក ក្នុងវិស័យនោះ ដោយនឹកគិតដល់ប្រយោជន៍រួម ព្រោះសារទូរគមនាគមន៍ក្នុងសង្គម មានទិសដៅបម្រើប្រយោជន៍រួមនោះតែម្តង។ រដ្ឋអំណាចមានបន្ទុកថែរក្សានិងការពារសេរីភាពដ៏ពិតប្រាកដ និងដ៏ត្រឹមត្រូវ ជាពិសេសក្នុងការចែកចាយពត៌មាន ជាសេរីភាពដែលសង្គមសម័យទំនើបត្រូវការជាចាំបាច់បំផុតដើម្បីចម្រើនឡើង។ រដ្ឋអំណាចក៏មានភារកិច្ចជួយលើកស្ទួយអ្វីៗដ៏ថ្លៃថ្នូរតាមសាសនា តាមវប្បធម៌ និងតាមសិល្បៈដែរ។ រដ្ឋអំណាចមានភារកិច្ចធានាឲ្យអ្នកប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម អាចប្រើសិទ្ធិសេរីភាពដ៏ត្រឹមត្រូវរបស់ខ្លួនបាន។ រដ្ឋអំណាចក៏មានភារកិច្ច គាំទ្រកិច្ចការណាដែលមនុស្សចាប់ផ្តើមធ្វើជាកិច្ច ដែលមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់យុវជនយុវនារី តែបើរដ្ឋអំណាចមិនជួយគាំទ្រគេទេ គេគ្មានសមត្ថភាពអាចសម្រេចបានឡើយ។

មិនតែប៉ុណ្ណោះ រដ្ឋអំណាចដែលតែងតែរកសេចក្តីសុខសាន្តជូនប្រជាពលដ្ឋ ក៏មានភារកិច្ចធានាថា កុំឲ្យការប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គមដោយមិនត្រឹមត្រូវ បណ្តាលឲ្យកើតឧបសគ្គយ៉ាងធ្ងន់ធ្ងរចំពោះសីលធម៌ សាធារណៈ និងរារាំងសង្គមមិនឲ្យចម្រើនឡើងបាន។ រដ្ឋអំណាចអាចធានាដូច្នេះតាមប្រាជ្ញាមោះមុត និងតាមយុត្តិធម៌ ដោយបង្កើតច្បាប់ និងដោយណែនាំប្រជាពលរដ្ឋយ៉ាងស័ក្តិសិទ្ធិ ឲ្យអនុវត្តតាមច្បាប់ទាំងនោះទៀតផង។ ដោយប្រព្រឹត្តដូច្នេះ រដ្ឋអំណាចមិនប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ និងរបស់ក្រុមនានានោះទេ ជាពិសេសក្នុងករណីដែលមានអាជីវកម្មប្រើមធ្យោបាយទំនាក់ទំនងទាំងនោះ គ្មានមនសិការមធ្យ័តប្រាកដប្រជាទេ។

ត្រូវចាត់វិធានការពិសេស ដើម្បីជួយការពារកូនជំទង់ៗ កុំឲ្យអានកាសែត និងទស្សនាខ្សែភាពយន្ត ដែលបណ្តាលឲ្យគេរបួសចិត្តគំនិត ក្នុងវ័យទន់ខ្សោយរបស់គេនោះ។

# ជំពូក ២

## ការណែនាំរបស់ព្រះសហគមន៍

### ១៣-សកម្មភាពរបស់អស់លោកអភិបាលនិងគ្រីស្តបរិស័ទធម្មតា

សមាជិកទាំងអស់របស់ព្រះសហគមន៍ ត្រូវរួមគ្នាខិតខំដោយរីករាយ ដើម្បីប្រើសារទូរគមនាគមន៍ក្នុងសង្គមទាំងនោះ ឲ្យបម្រើកិច្ចការជាគ្រីស្តទូតតាមរបៀបផ្សេងៗរបស់ព្រះសហគមន៍យ៉ាងស័ក្តិសិទ្ធិ ដោយមិនបង្អង់ឡើយ និងដោយយកចិត្តទុកដាក់យ៉ាងខ្លាំងទៀតផង។ តែត្រូវគិតដល់កាលៈទេសៈ និងដល់ទីកន្លែង។ គេក៏ត្រូវយកចិត្តទុកដាក់ជាមុនឲ្យបំបាត់កិច្ចការដ៏អាក្រក់ គេត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ ជាពិសេសក្នុងករណីសីលធម៌និងសាសនាមានការប្រែប្រួលដូច្នេះ។

ហេតុនេះហើយ បានជាអស់លោកអភិបាលជាគង្វាលត្រូវតែយកចិត្តទុកដាក់បំពេញភារកិច្ចរបស់ខ្លួនក្នុងវិស័យនេះ ដែលជាប់នឹងបន្ទុករបស់អស់លោក ជាអ្នកប្រកាសដំណឹងល្អ។

គ្រីស្តបរិស័ទធម្មតាដែលប្រកបអាជីវកម្មផលិតអ្វីៗតាមមធ្យោបាយទំនាក់ទំនងទាំងនោះ ត្រូវខិតខំផ្តល់សក្ខីភាពថ្វាយព្រះយេស៊ូគ្រីស្ត។ មុនដំបូង ត្រូវផ្តល់សក្ខីភាពដោយបំពេញអាជីវកម្មរបស់ខ្លួន ដោយមានសមត្ថភាពគ្រប់គ្រាន់ និងដោយមានចិត្តគំនិតជាគ្រីស្តទូត។ បន្ទាប់មក គេត្រូវផ្តល់សក្ខីភាព ដោយរួមសហការចំៗជាមួយសកម្មភាពណែនាំរបស់ព្រះសហគមន៍ ដោយជូនវិភាគទានជាបច្ចេកទេស ជាប្រាក់ចំណាយ ជាវប្បធម៌ និងជាសិល្បៈ តាមសមត្ថភាពរៀងៗខ្លួន។

### ១៤-សកម្មភាពគ្រីស្តបរិស័ទកាតូលិក អាចផ្តើមប្រព្រឹត្តបាន

មុនដំបូង គ្រីស្តបរិស័ទកាតូលិកត្រូវជួយគាំទ្រកាសែតល្អៗនានា។ ប្រសិនបើយើងមានបំណងចង់ឲ្យគោលគំនិតរបស់ព្រះគ្រីស្តជ្រួតជ្រាបចិត្តអ្នកអាន ត្រូវលើកស្ទួយនិងពង្រីកកាសែតនានាតាមគ្រីស្តសាសនាសុទ្ធសាធ គឺកាសែតដែលមានគោលបំណងជាក់ច្បាស់ អប់រំ ពង្រឹង និងលើកស្ទួយមតិសាធារណៈស្របតាមសិទ្ធិមនុស្ស ហើយស្របតាមលទ្ធិ និងក្បួនវិន័យកាតូលិក ព្រមទាំងផ្សព្វផ្សាយនិងបកស្រាយដំណឹងអំពីការរស់នៅរបស់ព្រះសហគមន៍។ អភិបាល ឬគ្រីស្តបរិស័ទធម្មតា អាចធ្វើជាអ្នកចាប់ផ្តើម និងធ្វើជាប្រធានកិច្ចការនេះបាន។ ត្រូវទូន្មានគ្រីស្តបរិស័ទ ឲ្យអាន និងឲ្យផ្សព្វផ្សាយកាសែតកាតូលិកជាចាំបាច់ ដើម្បីឲ្យគេចេះថ្លឹងថ្លែងអត្ថន័យព្រឹត្តិការណ៍ទាំងអស់ដែលកើតឡើងបាន។

ត្រូវជួយគាំទ្រនិងពង្រឹងយ៉ាងស័ក្តិសិទ្ធិ ហើយត្រូវប្រើគ្រប់មធ្យោបាយ នូវការផលិតនិងការផ្សព្វផ្សាយខ្សែភាពយន្តសម្រាប់លំហែកាយយ៉ាងសមរម្យ ដែលជួយពង្រីកវប្បធម៌ និងជួយសិល្បៈ ជាពិសេសខ្សែភាពយន្តសម្រាប់យុវវ័យ។ ជាចម្បង ត្រូវជួយគាំទ្រនិងសម្រួលការផលិតភាពយន្តឲ្យសហការគ្នា ហើយជួយគាំទ្រអ្នកផ្សព្វផ្សាយខ្សែភាពយន្ត ដែលប្រកបដោយគុណធម៌។ ត្រូវជួយគាំទ្រផ្សព្វផ្សាយខ្សែភាពយន្តមានគុណភាពល្អ ដោយសរសេរសេចក្តី

វាយការណ៍ថ្លឹងថ្លែងយ៉ាងល្អ និងដោយចែករំលែកនាងដែរ។ ត្រូវណែនាំគ្រីស្តបរិស័ទប្រកបដោយគុណធម៌ ដែលជាម្ចាស់រង្គសាលបញ្ចាំងខ្សែភាពយន្ត ឲ្យសហការជាមួយគ្នា។

ត្រូវជួយគាំទ្រយ៉ាងស័ក្តិសិទ្ធិ នូវការផ្សព្វផ្សាយតាមវិទ្យុ និងតាមទូរទស្សន៍ ដែលស្របតាមសីលធម៌ល្អ ជាពិសេសការផ្សព្វផ្សាយសម្រាប់ក្រុមគ្រួសារ។ ត្រូវជួយជំរុញយ៉ាងខ្លាំងឲ្យមានការផ្សព្វផ្សាយវិទ្យុកាតូលិក ដ្បិតការផ្សព្វផ្សាយទាំងនោះ ដាស់តឿនអ្នកស្តាប់ និងទស្សនិកជនឲ្យចូលរួមយ៉ាងសកម្មក្នុងការរស់នៅរបស់ព្រះសហគមន៍ ហើយក៏ជួយឲ្យគេបានស្គាល់លទ្ធិគ្រីស្តសាសនា។ ត្រូវបង្កើតស្ថានីយ៍កាតូលិក នៅកន្លែងណាដែលគួរឲ្យបង្កើត។ ក៏ប៉ុន្តែ ត្រូវធានាឲ្យការផ្សព្វផ្សាយតាមវិទ្យុទាំងនោះ មានគុណភាពល្អ និងស័ក្តិសិទ្ធិទៀតផង។

លើសពីនេះទៅទៀត ត្រូវគិតគូរអំពីល្ខោនជាសិល្បៈដ៏ប្រសើរ និងបុរាណ ដែលគេផ្សព្វផ្សាយសព្វថ្ងៃ ជាទូទៅដោយសារទូរគមនាគមន៍ក្នុងសង្គម ហើយដែលជួយអប់រំទស្សនិកជន ក្នុងលក្ខណៈខ្លួនជាមនុស្ស និងស្របតាមសីលធម៌ផង។

## ១៥-ការហ្វឹកហ្វឺនរបស់អ្នកផលិត

ត្រូវហ្វឹកហ្វឺនបូជាចារ្យ (អាចារ្យ) បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតា ដោយមិនបង្អង់ឡើយ ដើម្បីតបឆ្លើយនឹងសេចក្តីត្រូវការទាំងប៉ុន្មានដែលមានរៀបរាប់ខាងលើនេះ។ ត្រូវឲ្យអ្នកទាំងនោះ មានសមត្ថភាពយ៉ាងពិតប្រាកដ ដើម្បីឲ្យចេះប្រើគ្រឿងឧបករណ៍ទាំងនោះ ក្នុងគោលបំណងជាគ្រីស្តទូត។

ត្រូវហ្វឹកហ្វឺនគ្រីស្តបរិស័ទធម្មតាឲ្យបំពេញអាជីវកម្មនេះ គឺអប់រំគេឲ្យចេះបច្ចេកទេស ឲ្យស្គាល់លទ្ធិគ្រីស្តសាសនា និងស្គាល់សីលធម៌ស្របតាមអាជីវកម្មនេះដែរ។ ការហ្វឹកហ្វឺនដូច្នេះ ពិតជាកាតព្វកិច្ចមួយដ៏សំខាន់មែន។ ហេតុនេះហើយ បានជាត្រូវបង្កើតសាលារៀន មហាវិទ្យាល័យ គ្រឹះស្ថាន ជាកន្លែងអ្នកកាសែត អ្នកផលិតខ្សែភាពយន្ត និងអ្នកផ្សព្វផ្សាយតាមវិទ្យុ និងតាមទូរទស្សន៍ និងអ្នកឯទៀតៗដែលទាក់ទិន នឹងមធ្យោបាយទាំងនោះ អាចទទួលការអប់រំសព្វគ្រប់ និងមានចិត្តគំនិតជ្រួតជ្រាបដោយគោលៗតាមគ្រីស្តសាសនា ជាពិសេសដោយលទ្ធិខាងសង្គមនៃព្រះសហគមន៍។ ត្រូវអប់រំ និងជួយគាំទ្រអ្នកល្ខោន ដើម្បីឲ្យគេបម្រើសង្គមដោយសិល្បៈរបស់គេ និងតាមរបៀបរបស់គេ។ លើសពីនេះទៅទៀត ត្រូវបង្រៀនយ៉ាងហ្មត់ចត់អ្នកវាយតម្លៃសៀវភៅ និងការផ្សព្វផ្សាយតាមវិទ្យុ តាមទូរទស្សន៍។ល។ គេត្រូវទទួលសមត្ថភាពយ៉ាងពិតប្រាកដក្នុងករណីយកិច្ចរបស់គេ។ ត្រូវហ្វឹកហ្វឺនគេ និងលើកទឹកចិត្តគេ ឲ្យចេះថ្លឹងថ្លែង វាយតម្លៃដោយនឹកដល់សីលធម៌តាមសមគួរ។

## ១៦-ការអប់រំអ្នកប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម

អ្នកប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម ត្រូវទទួលការអប់រំឲ្យចេះប្រើមធ្យោបាយទាំងនោះយ៉ាងត្រឹមត្រូវ ស្របតាមអាយុនិងតាមកម្រិតវប្បធម៌របស់គេ។ ត្រូវបង្រៀនគេអំពីទ្រឹស្តី និងដោយមានការអនុវត្តន៍ ស្របតាមសភាពការណ៍របស់អ្នកប្រើប្រាស់ និងស្របតាមគ្រឿងឧបករណ៍នៃទំនាក់ទំនងនោះ។ ហេតុនេះ ត្រូវជំរុញឲ្យមានសមិទ្ធិផលដែលមានគោលដៅអប់រំ ឲ្យកាន់តែច្រើនឡើងៗ ជាពិសេសសមិទ្ធិផលសម្រាប់អប់រំយុវជនយុវនារីក្នុងសាលារៀនកាតូលិក គ្រប់ថ្នាក់ ក្នុងទេវវិទ្យាល័យ និងក្នុងគ្រប់ក្រុមគ្រីស្តបរិស័ទធម្មតា ដែលបំពេញកិច្ចការជាគ្រីស្តទូត។ ត្រូវណែនាំការអប់រំនោះឲ្យស្របតាមគោលការណ៍នៃសីលធម៌គ្រីស្តសាសនា។ ពេលអប់រំជំនឿ ត្រូវរៀបរាប់និងពន្យល់លទ្ធិនិងក្បួនវិន័យរបស់ព្រះសហគមន៍អំពីករណីនេះ។

## ១៧-មធ្យោបាយខាងបច្ចេកទេស និងខាងសេដ្ឋកិច្ច

ប្រសិនបើ គ្រីស្តបរិស័ទខ្វិលច្រអូសសុខចិត្តឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប់ចំណង ឬត្រូវបរាជ័យ ដោយជួបឧបសគ្គខាងបច្ចេកទេស ឬដោយខ្វះធនធានដែលត្រូវចាយវាយយ៉ាងសម្បើម សម្រាប់តែងតាំងសារទូរគមនាគមន៍ក្នុងសង្គមនោះ គេពិតជាបង្អាប់កិត្តិយសរបស់ខ្លួនជាគ្រីស្តបរិស័ទមែន។ ហេតុនេះហើយ បានជាមហាសន្និបាតរំឭកគ្រីស្តបរិស័ទទាំងអស់ថា ខ្លួនមានភារកិច្ចជួយគាំទ្រកាសែត ព្រឹត្តិប័ត្រ ខ្សែភាពយន្ត ស្ថានីយ៍និងការផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍ ព្រោះមធ្យោបាយទាំងនោះមានគោលសំខាន់ជាងគេ គឺផ្សព្វផ្សាយនិងការពារសេចក្ដីពិត ហើយណែនាំសង្គមឲ្យមានជីវិតរស់រវើកតាមគ្រីស្តសាសនា។ នៅពេលជាមួយគ្នានេះ មហាសន្និបាតទទូចអញ្ជើញក្រុមផ្សេងៗ និងមនុស្សទាំងឡាយដែលមានមុខងារសំខាន់ៗតាមសេដ្ឋកិច្ច និងតាមបច្ចេកទេស ឲ្យសុខចិត្តយកធនធានរបស់ខ្លួនដោយសទ្ធាជ្រះថ្លា មកជួយគាំទ្រសារទូរគមនាគមន៍ក្នុងសង្គម និងផ្តល់ជំនូន្មានឲ្យគេ ព្រោះមធ្យោបាយទាំងនោះ បម្រើវប្បធម៌និងកិច្ចការជាគ្រីស្តទូតដ៏ពិតប្រាកដ។

## ១៨-ទិវាប្រចាំឆ្នាំ

រៀងរាល់ឆ្នាំ ត្រូវចាត់ចែងទិវាមួយក្នុងភូមិភាគនីមួយៗ តាមតែអស់លោកអភិបាលយល់ឃើញថា ត្រូវចាត់ចែងនោះ។ ក្នុងទិវានោះ ត្រូវបង្រៀនគ្រីស្តបរិស័ទអំពីភារកិច្ចរបស់ខ្លួនក្នុងករណីនេះ និងអញ្ជើញគេឲ្យចូលបដិភាគ និងអង្វរព្រះជាម្ចាស់ថែមទៀតផង។ ត្រូវយកអំណោយទាំងនោះយ៉ាងទៀងទាត់សម្រាប់ទ្រទ្រង់ និងពង្រីកកិច្ចការ ដែលព្រះសហគមន៍បានបង្កើតនោះ ទាំងនឹកដល់សេចក្ដីត្រូវការនៃព្រះសហគមន៍ទាំងមូលទៀតផង។ ធ្វើដូច្នេះ ទើបព្រះសហគមន៍បំពេញកិច្ចការជាគ្រីស្តទូតដែលមានច្រើនមុខ ក្នុងវិស័យសារទូរគមនាគមន៍ក្នុងសង្គម។

## ១៩-គណៈកម្មាធិការនៃសន្ធៈអាសនៈ

អភិបាលព្រះសហគមន៍ក្រុងរ៉ូមអាចប្រើគណៈកម្មាធិការពិសេសនៃសន្ធៈអាសនៈ ដើម្បីជួយបំពេញមុខងារណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់លោក ក្នុងវិស័យសារទូរគមនាគមន៍ក្នុងសង្គម។

## ២០-មុខងារអស់លោកអភិបាល

អស់លោកអភិបាលមានភារកិច្ចយកចិត្តទុកដាក់យ៉ាងពិសេស នឹងអ្វីៗដែលគ្រីស្តបរិស័ទចង់ផ្តើមធ្វើក្នុងវិស័យសារទូរគមនាគមន៍ក្នុងសង្គម។ អស់លោកត្រូវលើកស្ទួយកិច្ចការទាំងនោះ ក្នុងភូមិភាគរៀងៗខ្លួន តាមតែកិច្ចការទាំងនោះ មានពាក់ព័ន្ធនឹងកិច្ចការជាគ្រីស្តទូតយ៉ាងសាធារណៈ។ អស់លោកមានភារកិច្ចណែនាំអ្នកផ្តើមកិច្ចការទាំងនោះឲ្យរួមសហការគ្នា សូម្បីតែកិច្ចការទាំងនោះ នៅក្នុងក្រុមគ្រួសារបព្វជិតដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់លោកអភិបាល ក៏ត្រូវរួមសហការក្នុងកិច្ចការទាំងនេះដែរ។

## ២១-គណៈកម្មការជាតិ

តាមប្រទេសនីមួយៗ កិច្ចការជាគ្រីស្តទូតបានប្រសិទ្ធភាព លុះត្រាតែមានគោលដៅរួមសម្រាប់ជាតិទាំងមូល និងឲ្យគេខិតខំរួមគ្នាដែរ។ ហេតុនេះហើយបានជាមហាសន្និបាតសម្រេចនិងបញ្ជាក់ថា សូមបង្កើតគណៈកម្មការជាតិនៅគ្រប់ទីកន្លែង សម្រាប់កាសែត ខ្សែភាពយន្ត វិទ្យុ និងទូរទស្សន៍។ សូមចាត់ចែងឲ្យគ្រីស្តបរិស័ទជួយគណៈកម្មការជាតិ

ទាំងនោះយ៉ាងស័ក្ដិសិទ្ធិ។ គណៈកម្មការទាំងនោះមានមុខងារយ៉ាងពិសេសអប់រំមនសិការរបស់គ្រីស្ដបរិស័ទយ៉ាងល្អក្នុងការប្រើប្រាស់សារទូរគមនាគមន៍ក្នុងសង្គម។ គណៈកម្មការទាំងនោះក៏ត្រូវលើកទឹកចិត្តគ្រីស្ដបរិស័ទ ដែលចាប់ផ្ដើមធ្វើកិច្ចការមួយក្នុងវិស័យនោះ ព្រមទាំងសម្រួលកិច្ចការទាំងប៉ុន្មានឲ្យសហការគ្នាផង។

ក្នុងប្រទេសនីមួយៗ ត្រូវធ្វើឲ្យគណៈកម្មាធិការរបស់អស់លោកអភិបាល ឬអភិបាលម្នាក់ដែលជាតំណាងអភិបាល ឯទៀតៗ ណែនាំគណៈកម្មការជាតិនោះ។ ត្រូវឲ្យមានគ្រីស្ដបរិស័ទដែលមានសមត្ថភាពខាងលទ្ធិគ្រីស្ដសាសនា និងខាងបច្ចេកទេស ចូល រួមក្នុងគណៈកម្មការទាំងនោះ។

## ២២-អង្គការអន្តរជាតិ

លើសពីនេះទៅទៀត សារទូរគមនាគមន៍ក្នុងសង្គមមានឥទ្ធិពលហួសពីព្រំប្រទល់ប្រទេសនីមួយៗ ហើយបណ្ដោយឲ្យមនុស្សម្នាក់ៗត្រឡប់ទៅជាប្រជាពលរដ្ឋនៃពិភពលោកទាំងមូលរួចហើយ។ ហេតុនេះហើយ បានជាត្រូវឲ្យកិច្ចការក្នុងជាតិនីមួយៗ រួមសហការក្នុងកម្រិតអន្តរជាតិ។ គណៈកម្មការជាតិនីមួយៗត្រូវសហការយ៉ាងស័ក្ដិសិទ្ធិជាមួយអង្គការអន្តរជាតិកាតូលិកតាមមាត្រាលេខ ២០។ មានតែសន្តះអាសនៈមួយគត់ទេ យល់ស្របទទួលស្គាល់អង្គការអន្តជាតិកាតូលិកឲ្យបានត្រឹមត្រូវតាមច្បាប់ ហើយសន្តះអាសនៈក៏គ្រប់គ្រងអង្គការអន្តរជាតិកាតូលិកដែរ។

# ពាក្យបញ្ចប់

## ២៣-ពាក្យណែនាំ

គណៈកម្មាធិការពិសេសនៃសន្តៈអាសនៈ ដែលមានចែងនៅលេខ១៩ និងបោះពុម្ពផ្សាយពាក្យណែនាំពិសេសអំពីសេចក្តីផ្តែផ្តាំនៃមហាសន្និបាត ដើម្បីឲ្យគេអនុវត្តតាមគោលការណ៍និងតាមក្បួនវិន័យទាំងអស់ស្តីអំពីសារទូរគមនាគមន៍ក្នុងសង្គម។ ត្រូវមានអ្នកជំនាញការពីគ្រប់ប្រទេសជួយគណៈកម្មាធិការពិសេសនៃសន្តៈអាសនៈនោះផង។

## ២៤-ពាក្យដាស់តឿនចុងក្រោយ

មហាសន្និបាតជឿទាំងទុកចិត្តថា បុត្រធីតានៃព្រះសហគមន៍ មុខជានឹងទទួលគោលការណ៍ និងក្បួនវិន័យ ចែងក្នុងក្រឹត្យក្រមនេះដោយចិត្តរីករាយ និងប្រតិបត្តិតាមដោយចិត្តស្មោះទៀតផង។ ហេតុនេះហើយ កាលគ្រីស្តបរិស័ទប្រើមធ្យោបាយទាំងនោះ គេមិនត្រូវខូចខាតប្រយោជន៍ឡើយ ផ្ទុយទៅវិញ គេមុខជានឹងទៅជាដូចអំបិលនិងពន្លឺ គឺគេផ្តល់ឱជារសដល់ជីវិតមនុស្សលោក និងបំភ្លឺចិត្តគំនិតគេទៀតផង។ មហាសន្និបាតក៏បែរទៅរកអស់មនុស្ស ដែលមានឆន្ទៈល្អ ជាពិសេសបែរទៅរកអស់អ្នកដែលកាន់កាប់សារទូរគមនាគមន៍ក្នុងសង្គម សូមអញ្ជើញអស់លោកអ្នកឲ្យប្រើមធ្យោយោបាយទាំងនោះ ដើម្បីរកតែប្រយោជន៍មនុស្សជាតិប៉ុណ្ណោះ ព្រោះវាសនាមនុស្សជាតិពឹងផ្អែកលើការប្រើប្រាស់មធ្យោយោបាយទាំងនោះ កាន់តែខ្លាំងឡើងៗជារៀងរាល់ថ្ងៃ។ ដូច្នេះ សូមលើកតម្កើងព្រះនាមព្រះអម្ចាស់ ដោយសារការអស្ចារ្យដែលមនុស្សលោករកឃើញនៅសម័យទំនើបនេះ ក៏ដូចមនុស្សតែងតែ លើកតម្កើងព្រះអង្គ ដោយស្នាដៃខាងសិល្បៈកាលពីដើមដូច្នោះដែរ តាមពាក្យរបស់គ្រីស្តទូតដែលចែងថា «ព្រះយេស៊ូគ្រីស្តមិនប្រែប្រួលឡើយ ពីដើមសព្វថ្ងៃ និងរហូតដល់អស់កល្បជានិច្ច ព្រះអង្គនៅតែដដែល» (ហប ១៣, ៨)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងក្រឹត្យក្រមទាំងមូលនេះ និងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើង ក្នុងឋានៈជាគ្រីស្តទូតរួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចថាចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលា ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៦៣

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# តម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស

## DIGNITATIS HUMANAE

### ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយ អស់លោកអភិបាល ដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសសេចក្ដីនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

### ពិធីអត្ថាធិប្បាយ សេចក្ដីប្រកាស អំពីសេរីភាពខាងសាសនា ទាំងបុគ្គលម្នាក់ៗ ទាំងសហគមន៍នានា មានសេរីភាពខាងសាសនា នៅក្នុងសង្គម និងតាមច្បាប់រដ្ឋ

១-មនុស្សសម័យឥឡូវ យល់អំពីកិត្តិយសដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗកាន់តែច្បាស់ឡើងៗ ហើយក៏មានចំនួនមនុស្សកាន់តែច្រើនឡើងៗ ដែលទាមទារឲ្យម្នាក់ៗមានសមត្ថភាពប្រតិបត្តិស្របតាមជម្រើសរបស់ខ្លួនផ្ទាល់ និងទទួលខុសត្រូវលើជម្រើសនោះ ដោយមានសេរីភាពពេញលេញដែរ។ គេមិនចង់ឲ្យនរណាបង្ខំទេតែចង់ឲ្យមនសិការរបស់ខ្លួនណែនាំគេឲ្យបំពេញភារកិច្ចរបស់ខ្លួនតែម្ដង។ គេក៏សូមឲ្យមានច្បាប់ដែលកំណត់ព្រំដែនរដ្ឋអំណាច កុំឲ្យរដ្ឋអំណាចនេះ ហាមយ៉ាងតឹងតែងពេក មិនឲ្យបុគ្គលម្នាក់ៗ និងសមាគមនានាប្រើសេរីភាពដ៏ពេញលេញរបស់ខ្លួនក្នុងវិស័យមួយចំនួន។ មនុស្សទាមទារសេរីភាពក្នុងសង្គម ជាពិសេសចំពោះអ្វីៗដែលពាក់ព័ន្ធនឹងវិញ្ញាណ មានសេរីភាពប្រតិបត្តិតាមសាសនាក្នុងសង្គមជាដើម។

មហាសន្និបាតវ៉ាទីកង់យើងនេះ យកចិត្តទុកដាក់ទទួលស្គាល់សេចក្ដីប៉ងប្រាថ្នាទាំងនោះ ទាំងពិនិត្យពិច័យការបញ្ជូនបន្តដ៏សក្ការៈ និងពិនិត្យពិច័យលទ្ធិដ៏វិសុទ្ធរបស់ព្រះសហគមន៍។ ការបញ្ជូនបន្តនិងលទ្ធិនោះជាប្រភពសម្រាប់បង្រៀនសេចក្ដីថ្មី ដែលត្រូវតាមសេចក្ដីចាស់ជានិច្ច។ មហាសន្និបាតមានគោលបំណងប្រកាសថា សេចក្ដីប៉ងប្រាថ្នាទាំងនោះ ត្រូវតាមសេចក្ដីពិតនិងតាមយុត្តិធម៌ដែរ។

ហេតុនេះហើយ បានជាមុនដំបូងមហាសន្និបាតប្រកាសថា ព្រះជាម្ចាស់ផ្ទាល់ព្រះអង្គបានសម្ដែងឲ្យមនុស្សជាតិស្គាល់មាគ៌ា ដែលណែនាំឲ្យគេអាចទទួលការសង្គ្រោះក្នុងអង្គព្រះគ្រីស្តបាន និងអាចទៅដល់សុភមង្គលបានដោយបម្រើព្រះអង្គ។ យើងជឿថា សាសនាដ៏ពិតប្រាកដតែមួយគត់នេះ ស្ថិតនៅក្នុងព្រះសហគមន៍កាតូលិក ដែលកាន់តាមជំនឿរបស់ក្រុមគ្រីស្តទូតជាគ្រឹះ។ ព្រះយេស៊ូបានផ្ញើបន្ទុកឲ្យក្រុមគ្រីស្តទូតផ្សព្វផ្សាយសាសនានេះ ឲ្យមនុស្សលោកទាំងអស់ស្គាល់ ដោយមានព្រះបន្ទូលប្រាប់គេថា៖ «ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេមានទំនាក់ទំនងជាមួយព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវ

បង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា» (មថ ២៨, ១៩-២០)។ ម្យ៉ាងទៀត មនុស្សទាំងអស់ត្រូវតែស្វែងរកសេចក្តីពិត ជាពិសេសសេចក្តីពិតអំពីព្រះជាម្ចាស់ និងអំពីព្រះសហគមន៍របស់ព្រះអង្គ។ លុះមនុស្សស្គាល់សេចក្តីពិតនេះរួចហើយ គេត្រូវតែទទួល និងកាន់សាសនានេះដោយចិត្តស្មោះ។

តាមរបៀបដដែល មហាសន្និបាតដ៏វិសុទ្ធប្រកាសថា មនុស្សត្រូវបំពេញការងារទាំងពីរនោះ តាមមនសិការរបស់ខ្លួន តែសេចក្តីពិតបង្ខំចិត្តគេ ដោយសារតែកម្លាំងនៃសេចក្តីពិតនេះផ្ទាល់ ដែលចូលជ្រាបក្នុងវិញ្ញាណបែបទន់ភ្លន់ផ្អែមល្ហែម។ មនុស្សទាមទារសិទ្ធិសេរីភាពខាងសាសនានេះ ដើម្បីឲ្យគេអាចបំពេញការងាររបស់ខ្លួនបាន គឺឲ្យគេអាចគោរពបម្រើព្រះជាម្ចាស់ ដោយសង្គមស៊ីវិលមិនបង្ខំគេតាមបែបណាឡើយ។ ដូច្នេះ សិទ្ធិសេរីភាពនេះ មិនទាស់នឹងលទ្ធិជំនឿកាតូលិកតាំងពីដើមរៀងមក ស្តីអំពីភារកិច្ចខាងវិញ្ញាណរបស់មនុស្ស និងរបស់សហគមន៍នានាចំពោះសាសនាដ៏ពិតប្រាកដ និងចំពោះព្រះសហគមន៍តែមួយគត់របស់ព្រះគ្រីស្ត។ លើសពីនេះទៅទៀត ដោយរិះគិតវែកញែកអំពីសេរីភាពខាងសាសនានេះ មហាសន្និបាតដ៏វិសុទ្ធមានបំណងចង់លាតត្រដាងលទ្ធិរបស់អភិបាលព្រះសហគមន៍ក្រុងរ៉ូមថ្មីៗនានា អំពីសិទ្ធិបុគ្គលម្នាក់ៗដែលគ្មាននរណាអាចរំលោភបាន និងអំពីរបៀបរៀបរយនៃសង្គមតាមច្បាប់ គឺអំពីនិតិរដ្ឋ។

## ១-លទ្ធិទូទៅអំពីសេរីភាពខាងសាសនា

## ២-គ្រឹះនៃសេរីភាពខាងសាសនា

មហាសន្និបាតវ៉ាទីកង់ប្រកាសថា បុគ្គលម្នាក់ៗមានសិទ្ធិសេរីភាពខាងសាសនា។ សិទ្ធិសេរីភាពនេះ មានន័យថា គ្មានបុគ្គលមួយណា ឬក្រុមផ្សេងៗក្នុងសង្គម ឬអំណាចរបស់មនុស្សលោកណា មានសិទ្ធិគាបសង្កត់មនុស្សទាំងអស់ ទោះជាតាមរបៀបណាក៏ដោយ។ ហេតុនេះអំពីរឿងសាសនា មិនត្រូវបង្ខំនរណាម្នាក់ឲ្យប្រព្រឹត្តផ្ទុយនឹងមនសិការរបស់ខ្លួន ហើយក៏មិនត្រូវឃាត់គេមិនឲ្យប្រព្រឹត្តតាមមនសិការរបស់ខ្លួនបានដែរ ទាំងនៅកន្លែងឯកជនទាំងនៅកន្លែងសាធារណៈក្តី ទាំងម្នាក់ឯងទាំងរួមជាមួយអ្នកដទៃក្តី។ ប៉ុន្តែ គេត្រូវប្រព្រឹត្តតាមព្រំដែនដ៏ត្រឹមត្រូវ។ មហាសន្និបាតប្រកាសទៀតថា សិទ្ធិសេរីភាពខាងសាសនា ចាក់គ្រឹះនៅលើកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ តាមតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងប្រាជ្ញារបស់មនុស្ស បានសម្តែងឲ្យស្គាល់នោះ។ ត្រូវទទួលស្គាល់សិទ្ធិសេរីភាពខាងសាសនារបស់បុគ្គលម្នាក់ៗ តាមក្បួនច្បាប់ ដើម្បីឲ្យទៅជាសិទ្ធិក្នុងសង្គមទៀតដែរ។

ដោយមនុស្សទាំងអស់មានកិត្តិយសដ៏ថ្លៃថ្នូរ ម្នាក់ៗសុទ្ធតែជាបុគ្គលប្រកបដោយប្រាជ្ញានិងឆន្ទៈសេរី ហើយក៏អាចទទួលខុសត្រូវដោយខ្លួនឯងបានដែរ។ ហេតុនេះ តាមលក្ខណៈរបស់ខ្លួនជាមនុស្ស បុគ្គលម្នាក់ៗមានភារកិច្ចខាងវិញ្ញាណ គឺត្រូវស្វែងរកសេចក្តីពិត ជាពិសេសស្វែងរកសេចក្តីពិតដែលពាក់ព័ន្ធនឹងសាសនា។ ពេលគេស្គាល់សេចក្តីពិត គេក៏ត្រូវតែភ្ជាប់ចិត្តនឹងសេចក្តីពិតនោះ ហើយក៏ត្រូវចាត់ចែងការរស់នៅរបស់ខ្លួន តាមសេចក្តីពិតនោះទាមទារឲ្យគេប្រព្រឹត្តទៀតផង។ ប៉ុន្តែ មនុស្សអាចបំពេញភារកិច្ចនេះ តាមលក្ខណៈរបស់ខ្លួនជាមនុស្សបាន លុះត្រាតែគេមានសេរីភាពខាងចិត្តគំនិត និងរួចផុតពីការគាបសង្កត់គ្រប់យ៉ាងពីខាងក្រៅខ្លួនដែរ។ ហេតុនេះហើយ បានជាសិទ្ធិសេរីភាពខាងសាសនាមិនសំអាងទៅលើការចូលចិត្តរបស់បុគ្គលផ្ទាល់ទេ តែសំអាងទៅលើលក្ខណៈដ៏ថ្លៃថ្នូររបស់មនុស្សតែម្តង។ ហេតុនេះ សិទ្ធិសេរីភាពស្ថិតនៅក្នុងមនុស្សទាំងអស់ ដែលទាមទារឲ្យមនុស្សរួចផុតពីការគាប

សង្កត់គ្រប់បែបយ៉ាង។ សិទ្ធិសេរីភាពនោះស្ថិតនៅក្នុងគេ ទោះបីគេមិនអនុវត្តតាមភារកិច្ចស្វែងរកសេចក្តីពិត និងមិនភ្ជាប់ចិត្តនឹងសេចក្តីពិតនោះក៏ដោយ។ ប្រសិនបើមានរបៀបរៀបរយដ៏ត្រឹមត្រូវក្នុងសង្គម គ្មាននរណាអាចរារាំងសិទ្ធិសេរីភាពនោះបានឡើយ។

## ៣-សិទ្ធិសេរីភាពខាងសាសនានិងទំនាក់ទំនងរបស់មនុស្សនឹងព្រះជាម្ចាស់

ប្រសិនបើយើងយល់ឃើញថា ធម៌របស់ព្រះជាម្ចាស់ពិតជាក្បួនវិន័យដ៏ខ្ពង់ខ្ពស់បំផុត ដែលណែនាំការរស់នៅរបស់មនុស្សលោក សេចក្តីទាំងនេះក៏រឹតតែច្បាស់ទៅទៀត ព្រោះធម៌វិន័យរបស់ព្រះអង្គនេះ ជាធម៌ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច ជាធម៌ពិតប្រាកដដែលទ្រទ្រង់សត្វលោកទាំងឡាយ ហើយក៏ជាធម៌សកលទៀតផង។ ព្រះជាម្ចាស់ចាត់ចែងណែនាំ និងគ្រប់គ្រងពិភពលោកទាំងមូល និងប្រវត្តិសាស្ត្ររបស់សហគមន៍មនុស្ស ក៏ដោយសារធម៌នោះដែរ ស្របតាមគម្រោងការប្រកបដោយព្រះប្រាជ្ញាញាណ និងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។ ព្រះជាម្ចាស់ប្រោសឲ្យមនុស្សទទួលចំណែកក្នុងការទ្រទ្រង់អ្វីៗទាំងអស់តាមធម៌នេះ ជាធម៌របស់ព្រះអង្គផ្ទាល់។ ហេតុនេះ បានជាមនុស្សអាចទៅដល់សេចក្តីពិតកាន់តែច្បាស់ឡើងៗ ជាសេចក្តីពិតដែលមិនប្រែប្រួលឡើយ។ ព្រះអង្គដែលថែរក្សាណែនាំមនុស្សលោកដោយព្រះហឫទ័យស្រឡាញ់ចាត់ចែងដូច្នេះ។ ហេតុនេះហើយបានជាមនុស្សម្នាក់ៗមានភារកិច្ច ហើយក៏មានសិទ្ធិនឹងស្វែងរកសេចក្តីពិតខាងសាសនាដែរ ដើម្បីឲ្យគេអាចវិនិច្ឆ័យតាមមនសិការទៀងត្រង់ និងពិតប្រាកដ ដោយប្រុងប្រយ័ត្ន ដោយប្រើមធ្យោបាយយ៉ាងសមគួរ។

ប៉ុន្តែ មនុស្សត្រូវស្វែងរកសេចក្តីពិត ស្របតាមតម្លៃដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ និងស្របតាមលក្ខណៈរបស់ខ្លួនជាអ្នករស់នៅក្នុងសង្គមដែរ គឺថា ឲ្យគេស្វែងរកសេចក្តីពិតដោយសេរី ដោយទទួលការបង្រៀននិងការអប់រំដោយចែកយោបល់ និងដោយនិយាយសន្ទនាជាមួយអ្នកដទៃ។ មួយក្រុមរៀបរាប់ដល់ក្រុមឯទៀតៗអំពីសេចក្តីពិតដែលគេបានរកឃើញរួចហើយ ឬដែលគេស្មានថាបានរកឃើញហើយនោះ ដើម្បីជួយគ្នាទៅវិញទៅមកក្នុងការស្វែងរកសេចក្តីពិតនោះ។ ពេលគេរកឃើញសេចក្តីពិតរួចហើយ គេត្រូវភ្ជាប់ចិត្តនឹងសេចក្តីពិតនោះយ៉ាងមាំ ដោយខ្លួនឯងផ្ទាល់។

ដោយសារមនសិការរបស់ខ្លួន មនុស្សដឹងហើយទទួលស្គាល់សេចក្តី ដែលធម្មវិន័យរបស់ព្រះជាម្ចាស់បានបញ្ញា។ គេក៏ត្រូវស្តាប់តាមមនសិការនេះយ៉ាងស្មោះ ក្នុងគ្រប់កិច្ចការដែលខ្លួនប្រព្រឹត្ត ដើម្បីឈានទៅដល់ទិសដៅនៃជីវិតរបស់ខ្លួន គឺឈានទៅព្រះជាម្ចាស់តែម្តង។ ហេតុនេះហើយ មិនត្រូវបង្ខំមនុស្សឲ្យប្រព្រឹត្តខុសនឹងមនសិការរបស់ខ្លួនឡើយ។ ប៉ុន្តែ ក៏មិនត្រូវឃាត់ឃាំងបង្ខំគេ មិនឲ្យប្រព្រឹត្តតាមមនសិការរបស់ខ្លួននោះដែរ ជាពិសេសអំពីរឿងសាសនា។ តាមលក្ខណៈសាសនា អ្នកកាន់សាសនាតែងតែប្រព្រឹត្តកិច្ចការនៅក្នុងចិត្តគំនិតជាដើម ជាកិច្ចការដែលខ្លួនប្រាថ្នាចង់ប្រព្រឹត្តដោយសេរី ជាកិច្ចការដែលណែនាំគេឲ្យតម្រង់ខ្លួនបែរទៅរកព្រះជាម្ចាស់។ អំណាចមនុស្សលោកសុទ្ធសាធ មិនអាចបង្ខំឲ្យធ្វើ ឬឃាត់មិនឲ្យធ្វើអ្វី ខាងសាសនាបានឡើយ។ ប៉ុន្តែ ដោយមនុស្សមានលក្ខណៈជាអ្នករស់នៅក្នុងសង្គម គេត្រូវបង្ហាញកិច្ចការខាងសាសនាដែលខ្លួនប្រព្រឹត្តនៅខាងក្នុងចិត្តគំនិតទាំងនោះឲ្យអ្នកដទៃមើលឃើញនៅខាងក្រៅដែរ។ តាមលក្ខណៈជាអ្នករស់នៅក្នុងសង្គមដដែលនេះ មនុស្សមានសិទ្ធិអាចផ្លាស់ប្តូរយោបល់ជាមួយអ្នកដទៃអំពីសាសនាបាន និងឲ្យប្រកាសសាសនារបស់ខ្លួនតាមរបៀបជាសហគមន៍ផងដែរ។

ហេតុនេះហើយ បានជាអ្នកណា ឬរដ្ឋអំណាចណា ដែលបដិសេធមិនព្រមឲ្យមនុស្សកាន់សាសនារបស់ខ្លួន

ដោយសេរីនៅក្នុងសង្គម អ្នកនោះឬរដ្ឋអំណាចនោះ ប្រមាថមើលងាយលក្ខណៈរបស់មនុស្ស និងមើលងាយរបៀបរៀបរយដែលព្រះជាម្ចាស់បានតែងតាំងសម្រាប់មនុស្សលោកទាំងអស់។ ប៉ុន្តែ អ្នកកាន់សាសនាត្រូវតែរក្សាទុកសណ្ដាប់ធ្នាប់សាធារណៈដ៏ត្រឹមត្រូវ។

លើសពីនេះទៅទៀត តាមលក្ខណៈកិច្ចការខាងសាសនា កិច្ចការទាំងនោះហួសពីលោកីយ៍នេះ ដែលតែងតែកន្លងផុតទៅតាមកាលៈទេសៈ។ ពេលមនុស្សប្រព្រឹត្តកិច្ចការទាំងនោះ ទោះម្នាក់ឯងក្ដី ឬយ៉ាងសាធារណៈក្ដី គេក៏សម្រេចចិត្តដោយខ្លួនឯង តម្រង់ខ្លួនបែរទៅរកព្រះជាម្ចាស់។ រីឯរដ្ឋអំណាចវិញ មានទិសដៅគិតគូរដល់ប្រយោជន៍រួមក្នុងលោកនេះ។ ហេតុនេះហើយ បានជារដ្ឋអំណាច ពិតជាត្រូវទទួលស្គាល់ការរស់នៅរបស់ប្រជាពលរដ្ឋខាងផ្លូវសាសនា និងត្រូវគាំទ្រការរស់នៅខាងសាសនានោះទៀតផងដែរ។ ប៉ុន្តែ ប្រសិនបើរដ្ឋអំណាចលួចយកសិទ្ធិណែនាំ ឬឃាត់មនុស្សមិនឲ្យប្រព្រឹត្តកិច្ចការខាងសាសនា យើងត្រូវនិយាយថា រដ្ឋអំណាចប្រព្រឹត្ត ហួសពីព្រំដែនរបស់ខ្លួនហើយ។

## ៤-សេរីភាពក្រុមអ្នកកាន់សាសនាផ្សេងៗ

បុគ្គលម្នាក់ៗមានសេរីភាព និងឯកសិទ្ធិមិនឲ្យគេបង្ខិតបង្ខំក្នុងរឿងសាសនា។ ក៏ប៉ុន្តែ ត្រូវទទួលស្គាល់សិទ្ធិសេរីភាព និងឯកសិទ្ធិនោះ នៅពេលមនុស្សរួមគ្នាប្រព្រឹត្តកិច្ចការខាងសាសនាដែរ។ ដោយលក្ខណៈរបស់មនុស្សជាអ្នករស់នៅក្នុងសង្គម ហើយដោយលក្ខណៈសាសនាផ្ទាល់ជាកិច្ចការខាងសង្គមដែរ ត្រូវតែមានក្រុមរបស់អ្នកកាន់សាសនាផ្សេងៗដែរ។

ក្រុមទាំងនោះ មានឯកសិទ្ធិមិនត្រូវឲ្យគេបង្ខិតបង្ខំ គឺមានសិទ្ធិអាចចាត់ចែងខ្លួនឯងតាមវិន័យរបស់គេផ្ទាល់ ឲ្យគោរពថ្វាយបង្គំព្រះដ៏ខ្ពង់ខ្ពស់ជាសាធារណៈ ឲ្យជួយសមាជិករបស់ខ្លួនប្រព្រឹត្តតាមសាសនានោះ ព្រមទាំងឲ្យអប់រំ និងបង្រៀនគេ។ ក្រុមទាំងនោះក៏មានសិទ្ធិលើកស្ទួយស្ថាប័ន សម្រាប់ឲ្យសមាជិកគេសហការគ្នា តម្រែតម្រង់ការរស់នៅរបស់ខ្លួនតាមគោលការណ៍ខាងសាសនារបស់គេទៀតផង។ ប៉ុន្តែ ក្រុមកាន់សាសនាទាំងនោះ មិនត្រូវរំលោភសេចក្ដីទាមទារដ៏ត្រឹមត្រូវ ដែលណែនាំឲ្យមានសណ្ដាប់ធ្នាប់សាធារណៈក្នុងសង្គមឡើយ។

ក្រុមអ្នកកាន់សាសនាទាំងនោះ ក៏មានសិទ្ធិជ្រើសរើសអ្នកបំពេញមុខងារបម្រើក្រុមរបស់គេ មានសិទ្ធិអប់រំអ្នកទាំងនោះ មានសិទ្ធិចាត់ចែងគេឲ្យបំពេញមុខងារផ្សេងៗ និងផ្លាស់ប្ដូរកន្លែងអ្នកទាំងនោះធ្វើការ។ អ្នកទាំងនោះក៏មានសិទ្ធិទាក់ទងជាមួយមេដឹកនាំ ឬជាមួយសហគមន៍សាសនានៅក្រៅប្រទេស និងមានសិទ្ធិសាងសង់គេហដ្ឋានសាសនា ព្រមទាំងមានសិទ្ធិកាន់កាប់កម្មសិទ្ធិ និងត្រួតត្រាទ្រព្យសម្បត្តិដែលគេត្រូវការទៀតដែរ។ ក្នុងករណីទាំងនោះ រដ្ឋអំណាចគ្មានសិទ្ធិឃាត់ក្រុមអ្នកកាន់សាសនា ដោយបញ្ចេញច្បាប់ ឬដោយប្រើវិធីតាមរដ្ឋការណាឡើយ។

ក្រុមអ្នកកាន់សាសនាទាំងនោះ ក៏មានសិទ្ធិបង្រៀន ឬសម្ដែងជំនឿរបស់គេជាសាធារណៈ ដោយប្រើសម្លេង ឬដោយចែកសំណេរជាលាយលក្ខណ៍អក្សរ។ រដ្ឋអំណាចគ្មានសិទ្ធិឃាត់គេឡើយ។ ប៉ុន្តែ នៅពេលក្រុមអ្នកកាន់សាសនាទាំងនោះ ផ្សព្វផ្សាយជំនឿរបស់ខ្លួនជាសាធារណៈ ឬនៅពេលគេនាំប្រជាជនឲ្យប្រតិបត្តិតាមសាសនារបស់ខ្លួន ក្រុមអ្នកកាន់សាសនាទាំងនោះ ត្រូវប្រយ័ត្នជានិច្ច កុំបង្ខំប្រជាជន ឬបញ្ចុះបញ្ចូលគេបែបមិនសមរម្យ ឬដោយប្រើវិធីមិនសូវស្មោះត្រង់នោះឡើយ ជាពិសេសពេលក្រុមអ្នកកាន់សាសនាទាំងនោះផ្សព្វផ្សាយជំនឿដល់អ្នក ដែល

មានវប្បធម៌ទាប និងដល់អ្នកក្រីក្រ។ ត្រូវយល់ថា អ្នកផ្សព្វផ្សាយជំនឿតាមរបៀបនេះ គឺប្រព្រឹត្តកិច្ចការហួសពីសិទ្ធិសេរីភាពរបស់ខ្លួន ហើយក៏បំពានសិទ្ធិសេរីភាពរបស់អ្នកដទៃទៀតផង។

លើសពីនេះទៅទៀត តាមសិទ្ធិសេរីភាពខាងសាសនា មិនត្រូវឃាត់ក្រុមអ្នកកាន់សាសនានានា មិនឲ្យបង្ហាញដោយសេរី នូវអានុភាពពិសេសនៃលទ្ធិជំនឿរបស់គេ ក្នុងកិច្ចចាត់ចែងសង្គមឲ្យមានរបៀបរៀបរយ និងអាចធ្វើឲ្យសកម្មភាពទាំងមូលរបស់មនុស្សលោកមានជីវិតរស់រវើកដែរ។ ដោយមនុស្សមានលក្ខណៈជាអ្នករស់នៅក្នុងសង្គម និងដោយមានលក្ខណៈផ្ទាល់របស់សាសនា មនុស្សដែលមានមនោសញ្ចេតនាស្រឡាញ់សាសនា ក៏មានសិទ្ធិជួបជុំគ្នាដោយសេរី និងតែងតាំងសមាគមអប់រំ តែងតាំងសមាគមវប្បធម៌ សមាគមមេត្តាករុណា និងសមាគមសង្គមកិច្ចទៀតផង។

## ៥-សេរីភាពសាសនានិងក្រុមគ្រួសារ

ក្រុមគ្រួសារនីមួយៗ ក្នុងឋានៈជាសង្គមតូចមួយដែលមានសិទ្ធិផ្ទាល់ ជាគ្រឹះនៃសង្គមមុនគេ ក៏មានសិទ្ធិចាត់ចែងការរស់នៅរបស់ខ្លួនខាងសាសនា ក្រោមការដឹកនាំរបស់ឪពុកម្ដាយ។ មាតាបិតាមានសិទ្ធិសម្រេចអប់រំកូនៗតាមជំនឿរបស់ខ្លួន។ ហេតុនេះហើយបានជារដ្ឋអំណាចត្រូវទទួលស្គាល់សិទ្ធិរបស់គាត់ ឲ្យជ្រើសរើសសាលារៀន ឬមធ្យោបាយអប់រំផ្សេងៗទៀត ដោយមានសេរីភាពពេញទី។ រដ្ឋអំណាចមិនត្រូវយកសេរីភាពក្នុងការជ្រើសរើសនេះធ្វើជាលេស ដើម្បីដាក់បន្ទុកចំៗដោយអយុត្តិធម៌ ឬដោយបញ្ឆិតបញ្ឆៀងលើមាតាបិតា។ ប្រសិនបើមានគេបង្ខំឲ្យកូនៗរៀនមេរៀនដែលទាស់នឹងជំនឿរបស់ឪពុកម្ដាយ ឬប្រសិនបើមានគេបង្ខំឲ្យអប់រំកូន ដោយគ្មានការអប់រំអំពីសាសនាទាល់តែសោះ ពេលនោះគេពិតជារំលោភសិទ្ធិរបស់ឪពុកម្ដាយមែន។

## ៦-ត្រូវមានទំនួលខុសត្រូវលើសិទ្ធិសេរីភាពខាងសាសនា

ប្រយោជន៍រួមមានន័យថា គ្រប់សភាពការណ៍ជីវភាពក្នុងសង្គម ដែលណែនាំឲ្យម្នាក់ៗអាចទៅជាមនុស្សពេញលក្ខណៈយ៉ាងស្រួល និងយ៉ាងពេញលេញ។ ជាបឋម ប្រយោជន៍រួមមានន័យថា ការរក្សាទុកនូវសិទ្ធិ និងភារកិច្ចរបស់បុគ្គលម្នាក់ៗ។ ទាំងប្រជាពលរដ្ឋ ទាំងក្រុមក្នុងសង្គម ទាំងរដ្ឋអំណាច ទាំងព្រះសហគមន៍ និងសហគមន៍សាសនាឯទៀតៗ ត្រូវយកចិត្តទុកដាក់រក្សាទុកសេរីភាពខាងសាសនា តាមរបៀបរៀងៗខ្លួន ស្រេចតែភារកិច្ចរបស់ខ្លួនចំពោះប្រយោជន៍រួមនោះ។

គ្រប់រដ្ឋអំណាចមានភារកិច្ចចម្បង ការពារនិងលើកស្ទួយសិទ្ធិមនុស្សដែលមិនអាចរំលោភបាន។ ហេតុនេះហើយ បានជារដ្ឋអំណាចត្រូវបង្កើតច្បាប់ដ៏ត្រឹមត្រូវ និងតែងតាំងមធ្យោបាយផ្សេងៗទៀត សមស្របតាមសភាពការណ៍ ដើម្បីទទួលស្គាល់សិទ្ធិសេរីភាពខាងសាសនារបស់ប្រជាពលរដ្ឋទាំងអស់យ៉ាងស័ក្តិសិទ្ធ និងដើម្បីបង្កើតសភាពការណ៍ ដែលផ្តល់ឲ្យការរស់នៅតាមសាសនា អាចលូតលាស់ចម្រើនឡើងបានដែរ។ ដូច្នេះ ប្រជាពលរដ្ឋអាចប្រើសិទ្ធិរបស់ខ្លួនបានយ៉ាងពេញលេញ ហើយក៏អាចបំពេញភារកិច្ចរបស់ខ្លួនខាងសាសនាដែរ។ ម្ល៉ោះហើយ សង្គមមុខជានឹងទទួលផលនៃយុត្តិធម៌ និងសន្តិភាពដែលកើតមកពីមនុស្សស្មោះត្រង់ចំពោះព្រះជាម្ចាស់ និងចំពោះព្រះហឫទ័យដ៏វិសុទ្ធរបស់ព្រះអង្គផង។

ប្រសិនបើ ប្រជាជនរស់នៅតាមសភាពការណ៍ដោយឡែក រដ្ឋអំណាចទទួលស្គាល់សហគមន៍សាសនាតែមួយយ៉ាងពិសេសតាមច្បាប់ នៅពេលជាមួយគ្នានេះ រដ្ឋអំណាចក៏ត្រូវទទួលស្គាល់ និងគោរពសិទ្ធិសេរីភាពខាងសាសនារបស់ប្រជាពលរដ្ឋទាំងអស់ និងរបស់គ្រប់សហគមន៍សាសនាផងដែរ។

មិនតែប៉ុណ្ណោះសោត រដ្ឋអំណាចត្រូវយកចិត្តទុកដាក់ឲ្យប្រជាពលរដ្ឋមានសិទ្ធិស្មើគ្នាតាមច្បាប់។ សិទ្ធិស្មើគ្នានេះ ពាក់ព័ន្ធមកពីប្រយោជន៍រួមរបស់សង្គម។ រដ្ឋអំណាចត្រូវប្រយ័ត្នមិនឲ្យគេរំលោភសិទ្ធិស្មើគ្នានេះ ដោយមូលហេតុសាសនាជាដាច់ខាត ទោះបីយ៉ាងច្បាស់ក្តី ឬយ៉ាងលាក់កំបាំងក្តី កុំឲ្យរើសមុខប្រជាពលរដ្ឋណាឡើយ។ ហេតុនេះហើយ បានជារដ្ឋអំណាចគ្មានសិទ្ធិប្រើកម្លាំង ឬគំរាមកំហែង ឬប្រើមធ្យោបាយផ្សេងៗទៀត ដើម្បីបង្ខំប្រជាពលរដ្ឋឲ្យកាន់សាសនាណាមួយ ឬហាមមិនឲ្យកាន់សាសនាណាមួយជាដាច់ខាត។ កុំឃាត់មនុស្សម្នាក់មិនឲ្យចូលសាសនាណាមួយ ឬចោលសហគមន៍សាសនាណាមួយឲ្យសោះ។ អ្នកប្រើកម្លាំងដើម្បីបំផ្លាញសាសនាណាមួយ ឬរារាំងដំណើរនៃសាសនាណាមួយ ក្នុងមនុស្សជាតិទាំងមូលក្តី ក្នុងតំបន់ណាមួយក្តី ឬក្នុងក្រុមណាមួយក្តី តាមរបៀបណាក៏ដោយ ក៏អ្នកនោះច្បាស់ជាប្រព្រឹត្តប្រឆាំងនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយប្រឆាំងនឹងសិទ្ធិដ៏សក្ការៈរបស់មនុស្សម្នាក់ៗ និងរបស់ក្រុមគ្រួសារប្រជាជាតិទាំងមូលយ៉ាងប្រាកដមែន។

## ៧-សេរីភាពសាសនាមានព្រំដែន

មនុស្សតែងតែប្រើសិទ្ធិសេរីភាពខាងសាសនានៅក្នុងសង្គម។ ហេតុនេះហើយ បានជាត្រូវប្រើសិទ្ធិសេរីភាពខាងសាសនានោះ តាមសេចក្តីណែនាំខ្លះដែលកំណត់ព្រំដែនសិទ្ធសេរីភាពនោះ។ មនុស្សត្រូវប្រើសិទ្ធិសេរីភាពគ្រប់យ៉ាង ដោយអនុវត្តតាមគោលការណ៍ខាងសីលធម៌មួយ គឺថាមនុស្សម្នាក់ៗ និងសង្គមត្រូវទទួលការខុសត្រូវ។ វិន័យសីលធម៌បញ្ជាឲ្យមនុស្សគ្រប់ៗរូប និងគ្រប់ក្រុមក្នុងសង្គម ប្រើសិទ្ធិរបស់ខ្លួន ដោយនឹកគិតដល់សិទ្ធិរបស់អ្នកដទៃ និងដោយនឹកគិតដល់ភារកិច្ចរបស់ខ្លួនចំពោះអ្នកដទៃ និងចំពោះប្រយោជន៍រួមរបស់មនុស្សទាំងអស់។ ត្រូវប្រព្រឹត្តចំពោះមនុស្សទាំងអស់តាមយុត្តិធម៌ និងតាមមនុស្សធម៌ទៀតផង។

លើសពីនេះទៅទៀត សង្គមស៊ីលមានសិទ្ធិការពារខ្លួនមិនឲ្យរងគ្រោះ ដោយមានគេយកសេរីភាពខាងសាសនាធ្វើជាលេសមកបំពានលើសិទ្ធិសង្គម។ រដ្ឋអំណាចមានភារកិច្ចការពារសង្គមមុនគេបង្អស់ តែរដ្ឋអំណាចមិនត្រូវការពារសិទ្ធិសង្គមនោះដោយប្រើអំណាចតាមចិត្ត ឬដោយយោគយល់បែបអយុត្តិធម៌ដល់ក្រុមមួយនោះទេ តែត្រូវប្រើក្បួនច្បាប់ស្របតាមសីលធម៌ដ៏ពិតប្រាកដ ទើបរដ្ឋអំណាចអាចរក្សាការពារសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់យ៉ាងស័ក្តិសិទ្ធ ហើយក៏ធ្វើឲ្យសិទ្ធិប្រជាពលរដ្ឋទាំងអស់ចុះសម្រុងគ្នាដោយសន្តិវិធីទៀតផង។ រដ្ឋអំណាចក៏ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងស្វែងរកសន្តិសុខសាធារណៈយ៉ាងត្រឹមត្រូវ ដែលមានន័យថា ប្រជាពលរដ្ឋរស់នៅរួមគ្នា ដោយយកយុត្តិធម៌ដ៏ពិតប្រាកដមកធ្វើជាមូលដ្ឋាន និងយកសីលធម៌សាជារណៈមកការពារប្រជាពលរដ្ឋទៀតដែរ។ សេចក្តីទាំងនោះ ជាគ្រឹះមួយនៃប្រយោជន៍រួម ហើយក៏ជាផ្នែកមួយនៃសណ្តាប់ធ្នាប់សាធារណៈដែរ។ សរុបសេចក្តីមក ត្រូវអនុវត្តតាមក្បួនច្បាប់ទូទៅដែលផ្តល់សេរីភាពពេញទីក្នុងសង្គម គឺតាមក្បួនច្បាប់នេះ ត្រូវទទួលស្គាល់សេរីភាពរបស់បុគ្គលម្នាក់ៗជាអតិបរមា។ ត្រូវដាក់ព្រំដែនដល់សេរីភាពនោះ តាមតម្រូវការ ហើយតាមកម្រិតនៃតម្រូវការនោះ។

### ៨-ការអប់រំមនុស្សឲ្យចេះប្រើសេរីភាព

សព្វថ្ងៃ មានកត្តាជាច្រើនកៀបសង្កត់មនុស្ស រហូតដល់គេព្រួយបារម្ភថា គេលែងមានសេរីភាពក្នុងការវិនិច្ឆ័យដោយខ្លួនឯងបាន។ ម្យ៉ាងវិញទៀត មានមនុស្សជាច្រើន មិនព្រមគោរពអ្នកកាន់អំណាចឬច្បាប់ឡើយ ដោយយកសេរីភាពធ្វើជាលេស គេមិនព្រមស្ដាប់តាមវិន័យ និងច្បាប់ដែលមនុស្សត្រូវការជាចាំបាច់សម្រាប់ការរស់នៅក្នុងសង្គម។ ហេតុនេះហើយ បានជាមហាសន្និបាតវ៉ាទីកង់នេះ សូមផ្ដែផ្ដាំមនុស្សទាំងអស់ ជាពិសេសផ្ដែផ្ដាំអស់អ្នកដែលទទួលបេសកកម្មអប់រំអ្នកដទៃ។ សូមដាស់តឿនអ្នកទាំងនោះ ឲ្យអប់រំមនុស្សឲ្យចេះស្ដាប់បង្គាប់រដ្ឋអំណាចដ៏ត្រឹមត្រូវតាមច្បាប់ ទាំងស្ថិតនៅក្រោមអំណាចនៃសីលធម៌ផង និងឲ្យយកចិត្តទុកដាក់ស្វែងរកសេរីភាពដ៏ពិតប្រាកដផង។ សូមអប់រំមនុស្សឲ្យចេះវិនិច្ឆ័យដោយខ្លួនឯង អំពីអត្ថន័យនៃព្រឹត្តិការណ៍នានា តាមពន្លឺនៃសេចក្ដីពិត និងឲ្យប្រព្រឹត្តកិច្ចការដោយមានចិត្តគំនិតទទួលខុសត្រូវ ហើយឲ្យគេសង្វាតស្វែងរកអ្វីៗដ៏ពិតប្រាកដ និងដ៏យុត្តិធម៌ ទាំងសុខចិត្តសហការជាមួយអ្នកដទៃដោយចិត្តរីករាយទៀតផង។

សេរីភាពខាងសាសនាមានគោលដៅ និងជួយតម្រង់មនុស្សឲ្យបំពេញភារកិច្ចរបស់ខ្លួនតាមការរស់នៅក្នុងសង្គម ដោយទទួលខុសត្រូវកាន់តែខ្លាំងឡើងៗ ក្នុងគ្រប់កិច្ចការដែលគេប្រព្រឹត្តនោះ។

## ២-សេរីភាពខាងសាសនាតាមពន្លឺ នៃសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់

៩-លទ្ធិអំពីសិទ្ធិសេរីភាពខាងសាសនា ចាក់ឫសក្នុងសេចក្ដីដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់ មហាសន្និបាតវ៉ាទីកង់ប្រកាសសេចក្ដីទាំងប៉ុន្មានអំពីសិទ្ធិសេរីភាពខាងសាសនា ចាក់គ្រឹះនៅលើកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ។ បទពិសោធន៍របស់មនុស្សតាមដំណើរនៃប្រវត្តិសាស្ត្រ បានសម្ដែងសេចក្ដីទាមទារនៃកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗនោះ ឲ្យកាន់តែច្បាស់ឡើងៗជានិច្ច។ លើសពីនេះទៅទៀត លទ្ធិអំពីសិទ្ធិសេរីភាពនេះ ចាក់ឫសក្នុងសេចក្ដីពិតដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់ថែមទៀតផង ជាមូលហេតុនាំឲ្យគ្រីស្តបរិស័ទកាន់តែស្មោះត្រង់នឹងសេរីភាពដ៏វិសុទ្ធនោះ។ ទោះបី ព្រះជាម្ចាស់មិនសម្ដែងឲ្យបានច្បាស់ថា គ្មាននរណាខាងក្រៅ មានសិទ្ធិបង្ខំមនុស្សក្នុងវិស័យសាសនាក្ដី ក៏ព្រះអង្គបានសម្ដែងអំពីកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗយ៉ាងទូលំទូលាយដែរ។ ព្រះគ្រីស្តក៏បានគោរពសេរីភាពរបស់មនុស្សយ៉ាងខ្លាំង ក្នុងពេលគេបំពេញភារកិច្ចរបស់ខ្លួន គឺនៅពេលគេធ្វើជីវិតលើព្រះបន្ទូលរស់របស់ព្រះជាម្ចាស់។ ព្រះអង្គក៏បង្ហាញឲ្យដឹងថា សាវ័ករបស់បរមគ្រូដ៏អស្ចារ្យនេះ ត្រូវមានគំនិតបែបណាជ្រួតជ្រាបក្នុងចិត្តគេនៅគ្រប់កិច្ចការដែលគេប្រព្រឹត្ត។ សេចក្ដីទាំងនេះពិតជាបញ្ជាក់យ៉ាងច្បាស់នូវគោលការណ៍ទូទៅជាមូលដ្ឋាន នៃលទ្ធិដែលមហាសន្និបាតប្រកាសអំពីសេរីភាព ខាងសាសនានេះ។ មុនដំបូងបង្អស់ សេរីភាពខាងសាសនាក្នុងសង្គម ស្របទាំងស្រុងនឹងសេរីភាពរបស់អ្នកដែលធ្វើជីវិតលើព្រះគ្រីស្ត។

### ១០-សេរីភាពនិងការធ្វើជីវិតលើព្រះគ្រីស្ត

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងគ្រូបាធ្យាយតែងតែបង្រៀនឥតឈប់ឈរថា អ្នកតបឆ្លើយនឹងព្រះជាម្ចាស់ គឺធ្វើជីវិតលើព្រះអង្គ ត្រូវតែសម្រេចដោយបំណងប្រាថ្នារបស់ខ្លួនផ្ទាល់ ដោយគ្មាននរណាបង្ខំ។ នេះពិតជាប្រការមួយដ៏សំខាន់ជាងគេក្នុងលទ្ធិកាតូលិកយើង។ ហេតុនេះហើយ បានជាគ្មាននរណាម្នាក់ត្រូវគេបង្ខំ ឲ្យ

ទទួលជំនឿទាំងទាស់ចិត្តបានឡើយ។ អ្នកផ្ញើជីវិតលើព្រះជាម្ចាស់ តាមលក្ខណៈនៃការផ្ញើជីវិតនោះ ត្រូវតែសម្រេចថា ខ្លួនជឿដោយបំណងប្រាថ្នារបស់ខ្លួនផ្ទាល់ ព្រោះព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះបានរំដោះមនុស្ស ហើយព្រះអង្គក៏ត្រាស់ហៅមនុស្សឲ្យទៅជាបុត្រធីតារបស់ព្រះបិតាដែរ។ គេអាចផ្ចង់ចិត្តនឹងព្រះជាម្ចាស់ដែលសម្តែងព្រះអង្គ ឲ្យគេស្គាល់នោះ លុះត្រាតែគេផ្ញើជីវិតលើព្រះអង្គ ដោយខ្លួនបានរិះគិតពិចារណា និងដោយខ្លួនបានសម្រេចដោយសេរី ទាំងមានព្រះបិតាទាក់ទាញចិត្តគេថែមទៀតផង។ សេចក្តីនេះ ពិតជាស្របទាំងស្រុងតាមលក្ខណៈផ្ទាល់នៃជំនឿមែន។ ហេតុនេះ អំពីរឿងសាសនា គ្មានមនុស្សណាមានសិទ្ធិបង្ខំអ្នកដទៃជាដាច់ខាត ទោះបីជាបង្ខំតាមបែបណាក៏ដោយ។ រដ្ឋដែលគោរពសេរីភាពសាសនា ពិតជាជួយបង្កើតបរិយាកាសបណ្តោយឲ្យមនុស្សអាចផ្ញើជីវិតលើព្រះគ្រីស្តបានដោយគ្មានអ្វីរារាំងគេ។ គេក៏អាចផ្ចង់ចិត្តនឹងជំនឿនោះ ដោយមានសេរីភាពពេញទី ព្រមទាំងអាចកាន់តាមជំនឿនោះយ៉ាងក្លៀវក្លា ដោយប្រព្រឹត្តគ្រប់កិច្ចប្រចាំជីវិតតាមជំនឿនេះដែរ។

### ១១-របៀបព្រះគ្រីស្តនិងក្រុមគ្រីស្តទូតបានប្រព្រឹត្ត

ព្រះជាម្ចាស់ពិតជាត្រាស់ហៅ មនុស្សឲ្យបម្រើព្រះអង្គតាមវិញ្ញាណ និងតាមសេចក្តីពិត។ មនុស្សត្រូវតែតបឆ្លើយនឹងព្រះអង្គដែលត្រាស់ហៅនោះ តាមមនសិការរបស់ខ្លួន ព្រះអង្គមិនបង្ខំគេទេ។ ព្រះជាម្ចាស់គោរពកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ ដែលព្រះអង្គប្រតិស្ឋានមក។ មនុស្សក៏ត្រូវតែកាន់កិរិយាមារយាទតាមខ្លួនវិនិច្ឆ័យ និងដោយប្រើសេរីភាពរបស់ខ្លួនដែរ។ សេចក្តីនេះ បានលេចមកឲ្យឃើញយ៉ាងច្បាស់ក្រៃលែងក្នុងព្រះគ្រីស្តយេស៊ូ គឺព្រះជាម្ចាស់បានសម្តែងព្រះអង្គផ្ទាល់យ៉ាងពេញលេញក្នុងអង្គព្រះគ្រីស្ត ព្រះជាម្ចាស់ក៏បានបង្ហាញមាគ៌ារបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់ក្នុងអង្គព្រះគ្រីស្តដែរ។ ព្រះគ្រីស្តពិតជាព្រះបរមគ្រូ និងជាព្រះអម្ចាស់របស់យើងមែន (យហ ១៣, ១៣) ព្រះអង្គស្លូត ហើយសុភាពទៀត (មថ ១១, ២៩) ព្រះអង្គអញ្ជើញ និងទាក់ទាញចិត្តក្រុមសាវ័កទាំងមានព្រះហឫទ័យអត់ធ្មត់ខន្តីផង (មថ ១១, ២៨-៣០ ; យហ ៦, ៦៧-៦៨)។ ព្រះអង្គប្រព្រឹត្តការអស្ចារ្យទាំងប៉ុន្មានមកគាំទ្រ និងមកបញ្ជាក់អត្ថន័យនៃធម្មទេសនារបស់ព្រះអង្គ ដើម្បីលើកស្ទួយអ្នកស្តាប់ឲ្យមានជំនឿផ្ញើជីវិតលើព្រះអង្គ និងដើម្បីពង្រឹងជំនឿរបស់គេទៀតផង។ ព្រះអង្គសម្តែងការអស្ចារ្យមិនមែន ដើម្បីបង្ខំគេឲ្យជឿទេ (មថ ២៨-២៩; មក ៩, ២៣-២៤; ៦, ៥៦)។ ពិតមែនហើយ ព្រះអង្គស្តីបន្ទោសអស់អ្នកស្តាប់ដែលមិនព្រមជឿ តែព្រះអង្គទុកឲ្យព្រះជាម្ចាស់ដាក់ទណ្ឌកម្មគេ នៅថ្ងៃព្រះអង្គវិនិច្ឆ័យទោសមនុស្សលោក (មថ ១១, ២០-២៤; រម ១២, ១៩-២០; ២ថស ១, ៨)។ ពេលព្រះអង្គចាត់ក្រុមគ្រីស្តទូត ឲ្យចេញទៅប្រកាសដំណឹងល្អក្នុងពិភពលោក ព្រះអង្គមានព្រះបន្ទូលទៅកាន់គេថា៖ «អ្នកណាជឿហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនព្រមជឿនឹងត្រូវទទួលទោស» (មក ១៦, ១៦)។ ប៉ុន្តែ ព្រះអង្គទទួលស្គាល់ថា មារបានសាបព្រោះស្រងែលាយជាមួយស្រូវពូជល្អ ហើយបញ្ជាឲ្យគេទុកស្រងែ និងស្រូវពូជល្អដុះឡើងជាមួយគ្នា រហូតដល់ពេលចម្រូតនៅអវសានកាលនៃពិភពលោក (មថ ១៣, ៣០ និង ៤០)។ ព្រះអង្គក៏មិនសព្វព្រះហឫទ័យឲ្យអ្នកស្រុកយល់ច្រឡំថា ព្រះអង្គជាព្រះគ្រីស្តតាមផ្លូវនយោបាយ ដែលបង្ក្រាបមនុស្សលោកដោយប្រើកម្លាំង (មថ ៤, ៨-១០; យហ ៦, ១៥) ព្រះអង្គសព្វព្រះហឫទ័យហៅព្រះអង្គផ្ទាល់ថា ជាបុត្រមនុស្សដែល «មកក្នុងពិភពលោកនេះមិនមែន ដើម្បីឲ្យគេបម្រើលោកឡើយ គឺលោកមកបម្រើគេវិញ ព្រមទាំងបូជាជីវិតដើម្បីរំដោះមនុស្សទាំងអស់ផង» (មក ១០, ៤៥)។ ព្រះអង្គបង្ហាញឲ្យគេដឹងថា ព្រះអង្គជាអ្នកបម្រើសុភាពរាបសាដ៏ពេញលក្ខណៈរបស់ព្រះជាម្ចាស់ (អស ៤២, ១-៤) ដែល «មិនកាច់ដើមត្រែងណា ដែលទក់ហើយនោះឡើយ ហើយក៏មិនផ្លុំពន្លត់ភ្លើង

ណា ដែលហៀបនឹងរលត់នោះដែរ» (មថ ១២, ២០)។ ព្រះអង្គទទួលស្គាល់សិទ្ធិនៃរដ្ឋអំណាច ហើយក៏បញ្ជាឲ្យគេបង់ពន្ធជាថ្វាយព្រះចៅអធិរាជដែរ ទាំងរំឭកគេថា ត្រូវគោរពសិទ្ធិរបស់ព្រះជាម្ចាស់ដែលប្រសើរជាងសិទ្ធិនៃរដ្ឋអំណាចដោយមានព្រះបន្ទូលថា «អ្វីៗដែលជារបស់ព្រះចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់វិញដែរ» (មថ ២២, ២១)។ មិនតែប៉ុណ្ណោះ ពេលព្រះអង្គបង្ហើយកិច្ចរំដោះមនុស្សលោកដោយបូជាព្រះជន្មនៅលើឈើឆ្កាង ជាកិច្ចដែលសង្គ្រោះមនុស្សលោក និងផ្ដល់ឲ្យមនុស្សលោកបានសេរីភាពដ៏ពិតប្រាកដ ព្រះអង្គក៏បង្ហើយសម្ដែងសេចក្ដីដែលព្រះអង្គត្រូវសម្ដែងនោះដែរ។ ព្រះអង្គផ្ដល់សក្ខីភាពអំពីសេចក្ដីពិត (យហ ១៨, ៣៧) ប៉ុន្តែ ព្រះអង្គមិនសព្វព្រះហឫទ័យយកកម្លាំងមកបង្ខំឲ្យអ្នកប្រកែកមិនព្រមទទួលសេចក្ដីពិតនោះទេ។ អ្នកផ្ញើជីវិតលើព្រះអង្គ មិនត្រូវប្រើអាវុធមកការពាររាជសម្បត្តិរបស់ព្រះអង្គទេ តែព្រះអង្គគ្រងរាជ្យលើមនុស្សដែលស្ដាប់សេចក្ដីពិត និងដែលផ្ដល់សក្ខីភាពអំពីសេចក្ដីពិតនោះ។ ព្រះគ្រីស្ដក៏លាតសន្ធឹងព្រះរាជ្យរបស់ព្រះអង្គដោយព្រះហឫទ័យស្រឡាញ់ ដែលត្រូវគេលើកឡើងនៅលើឈើឆ្កាង ហើយដែលទាក់ទាញចិត្តមនុស្សទាំងអស់វិញ (យហ ១២, ៣២)។

ក្រុមគ្រីស្ដទូតទទួលការអប់រំដោយព្រះគ្រីស្ដមានព្រះបន្ទូល និងដោយព្រះអង្គធ្វើគំរូឲ្យគេមើល គេក៏ដើរតាមមាគ៌ាដដែលនោះ។ នៅខាងដើមព្រះសហគមន៍ សាវ័កព្រះគ្រីស្ដមិនបានបង្ខិតបង្ខំអ្នកស្រុក ហើយក៏មិនប្រើកលល្បិច ដែលមិនសមនឹងដំណឹងល្អ ដើម្បីណែនាំមនុស្សឲ្យប្រែចិត្តគំនិត និងប្រកាសថា គេផ្ញើជីវិតលើព្រះគ្រីស្ដ ទុកជាព្រះអម្ចាស់ទេ តែជាពិសេសបំផុត គេយកឫទ្ធានុភាពនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់មកប្រើវិញ (១ករ ២, ៣-៥; ១ថស ២, ៣-៥)។ គេប្រកាសអំពីគម្រោងការរបស់ព្រះជាម្ចាស់ ដែលសង្គ្រោះមនុស្សលោក គឺព្រះអង្គ «ដែលទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ និងស្គាល់សេចក្ដីពិតយ៉ាងច្បាស់» (១ធម ២, ៤)។ នៅពេលជាមួយគ្នានេះ ពួកគេតែងតែគោរពអ្នកទន់ខ្សោយ ទោះបីអ្នកទាំងនោះ រស់នៅទាំងវង្វេងជំនឿក្ដី។ គេតែងតែបង្ហាញអំពីរបៀប «យើងម្នាក់ៗត្រូវរៀបរាប់ទូលព្រះជាម្ចាស់នូវអំពើ ដែលខ្លួនយើងម្នាក់ៗបានប្រព្រឹត្ត» (រម ១៤, ១-២៣; ១ករ ៨, ៩-១៣; ១០, ២៣-៣៣)។ ហេតុនេះហើយ បានជាម្នាក់ៗត្រូវតែស្ដាប់តាមមនសិការរៀងៗខ្លួន។ ក្រុមគ្រីស្ដទូតក៏ដូចព្រះគ្រីស្ដដែរ គឺអស់លោកតែងតែយកចិត្តទុកដាក់ផ្ដល់សក្ខីភាពអំពីសេចក្ដីពិតរបស់ព្រះជាម្ចាស់ជានិច្ច។ អស់លោកមានសេចក្ដីក្លាហាន «នាំគ្នាថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយចិត្តអង់អាច» (កក ៤, ៣១; អភ ៦, ១៩-២០) នៅចំពោះប្រជាជន និងនៅចំពោះអ្នកដឹកនាំរបស់គេ។ អស់លោកមានជំនឿយ៉ាងរឹងប៉ឹង ដែលជំរុញអស់លោកឲ្យចាត់ដំណឹងល្អទុកជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដើម្បីសង្គ្រោះអស់អ្នកជឿ (រម ១, ១៦)។ អស់លោកលះបង់ «អាវុធខាងលោកីយ៍» ទាំងប៉ុន្មាន (២ករ ១០, ៤; ១ថស ៥, ៨-៩) យកតម្រាប់តាមព្រះគ្រីស្ដជាអ្នកស្លូតបូតសុភាពរាបសា ហើយនាំគ្នាប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយជឿជាក់ថា ព្រះបន្ទូលនោះពិតជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលអាចបំផ្លាញអំណាចនានាដែលជំទាស់នឹងព្រះអង្គ (អភ ៦, ១១-១៧) ព្រមទាំងអាចណែនាំមនុស្សឲ្យផ្ញើជីវិតលើព្រះគ្រីស្ដ និងឲ្យបម្រើព្រះអង្គផង (២ករ ១០, ៣-៥)។ ក្រុមគ្រីស្ដទូតក៏ដូចព្រះបរមគ្រូដែរ គឺបានទទួលស្គាល់រដ្ឋអំណាចតែងតាំងយ៉ាងត្រឹមត្រូវ៖ «មនុស្សគ្រប់ៗរូប ត្រូវស្ដាប់បង្គាប់អាជ្ញាធរ... អ្នកប្រឆាំងនឹងអាជ្ញាធរ ក៏ដូចជាប្រឆាំងនឹងរបៀបរៀបរយដែលព្រះជាម្ចាស់បានចាត់ចែងនោះដែរ» (រម ១៣, ១-២; ១សល ២, ១៣-១៧)។ តែនៅពេលជាមួយគ្នានោះ អស់លោកមិនខ្លាចជំទាស់ប្រឆាំងនឹងរដ្ឋអំណាច ដែលជំទាស់នឹងព្រះហឫទ័យដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ហើយថ្លែងថា៖ «យើងខ្ញុំត្រូវស្ដាប់

បង្គាប់ព្រះជាម្ចាស់ ជាជាងស្ដាប់បង្គាប់មនុស្ស» (កក ៥, ២៩; ៤, ១៩-២០)។ មានមរណសាក្សីជាច្រើនឥតគណនា និងមានអ្នកផ្ញើជីវិតលើព្រះគ្រីស្ដជាច្រើនបានដើរតាមមាគ៌ានេះ នៅគ្រប់សម័យ និងនៅគ្រប់ទីកន្លែងផង។

### ១២-ព្រះសហគមន៍យកតម្រាប់តាមព្រះគ្រីស្ត និងតាមក្រុមគ្រីស្តទូត

ហេតុនេះហើយ បានជាព្រះសហគមន៍ស្មោះត្រង់នឹងសេចក្ដីពិតនៃដំណឹងល្អ តែងតែដើរតាមមាគ៌ារបស់ព្រះគ្រីស្ដ និងរបស់គ្រីស្ដទូត ដោយទទួលស្គាល់គោលការណ៍នៃសេរីភាពខាងសាសនា ព្រោះសេរីភាពនោះស្រប តាមកិត្ដិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ ហើយក៏ស្របតាមសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់នោះដែរ។ ព្រះសហគមន៍ក៏លើកទឹកចិត្តមនុស្សឲ្យកាន់តាមសេរីភាពនោះ ព្រះសហគមន៍បានទទួលលទ្ធិនេះពីព្រះគ្រីស្ដ និងពីក្រុមគ្រីស្ដទូតមក ហើយបានរក្សាទុកនិងបញ្ជូនបន្តតាមដំណើរនៃប្រវត្តិសាស្ត្រ។

តាមប្រវត្តិសាស្ត្រនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលតែងតែធ្វើដំណើរក្នុងប្រវត្តិសាស្ត្រមនុស្សជាតិដ៏មិនទៀងទាត់ ហើយតែងតែប្រែប្រួលនោះ ជួនកាលព្រះសហគមន៍បានប្រព្រឹត្តតាមរបៀបមិនសូវស្របនឹងដំណឹងល្អមែន ជួនកាលក៏ព្រះសហគមន៍បានប្រព្រឹត្តផ្ទុយនឹងគោលគំនិតនៃដំណឹងល្អទៀតដែរ។ក៏ប៉ុន្តែ ព្រះសហគមន៍នៅតែបង្រៀនជានិច្ចថា មនុស្សម្នាក់ផ្ញើជីវិតលើព្រះគ្រីស្ដ ដោយមិនត្រូវបានគេបង្ខិតបង្ខំឡើយ។

ដូច្នេះ មេនៃដំណឹងល្អ ប្រែចិត្តគំនិតមនុស្ស ដូចមេធ្វើឲ្យម្សៅដោរឡើងដូច្នោះដែរ ហើយបានជួយយ៉ាងសន្ធឹកឲ្យមនុស្សទទួលស្គាល់កិត្ដិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ កាន់តែច្បាស់ឡើងៗ តាមដំណើរនៃប្រវត្តិសាស្ត្រ។ យូរៗទៅ គោលគំនិតតាមដំណឹងល្អបាននាំឲ្យមនុស្សជឿជាក់ច្បាស់ថា គ្មាននរណាម្នាក់អាចបង្ខិតបង្ខំមនុស្សអំពីរឿងសាសនានៅក្នុងសង្គមបានជាដាច់ខាត។

### ១៣-សេរីភាពរបស់ព្រះសហគមន៍

ព្រះសហគមន៍ត្រូវមានសេរីភាពគ្រប់យ៉ាងដែលខ្លួនត្រូវការ ដើម្បីយកចិត្តទុកដាក់ប្រព្រឹត្តកិច្ចការ ដែលនាំការសង្គ្រោះដល់មនុស្សលោក។ សិទ្ធិសេរីភាពរបស់ព្រះសហគមន៍នេះ ច្បាស់ជាសិទ្ធិដ៏សំខាន់ជាងគេក្នុងចំណោមសេចក្ដីទាំងប៉ុន្មាន ដែលត្រូវរក្សាទុកនិងការពារនៅគ្រប់ទីកន្លែងជានិច្ច ដោយគ្មាននរណាអាចរំលោភបានឡើយ ព្រោះសិទ្ធិសេរីភាពនោះពាក់ព័ន្ធនឹងផលប្រយោជន៍របស់ព្រះសហគមន៍ ហើយលើសពីនេះទៅទៀត ក៏ពាក់ព័ន្ធនឹងផលប្រយោជន៍សង្គមនៅលើផែនដីនេះដែរ។ សេរីភាពនោះពិតជាសក្ការៈ ព្រោះព្រះបុត្រាតែមួយព្រះអង្គគត់របស់ព្រះជាម្ចាស់បានប្រគល់សេរីភាពនោះឲ្យព្រះសហគមន៍ ដែលព្រះអង្គបានរំដោះដោយសារព្រះលោហិតព្រះអង្គ។ សេរីភាពនោះ ពិតជាលក្ខណៈផ្ទាល់របស់ព្រះសហគមន៍ ហេតុនេះហើយ បានជាអស់អ្នកប្រឆាំងនឹងសេរីភាពនោះក៏ប្រព្រឹត្តខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ សេរីភាពនៃព្រះសហគមន៍ពិតជាគោលការណ៍មូលដ្ឋាន ក្នុងទំនាក់ទំនងរវាងព្រះសហគមន៍នឹងរដ្ឋអំណាចនានា ហើយក្នុងទំនាក់ទំនងជាមួយសង្គមទាំងមូលផង។

ព្រះសហគមន៍ទាមទារសេរីភាពក្នុងសង្គមមនុស្ស និងនៅចំពោះរដ្ឋអំណាចគ្រប់យ៉ាង គឺក្នុងឋានៈខ្លួនជាអំណាចខាងវិញ្ញាណ ដែលព្រះគ្រីស្ដជាអម្ចាស់បានតែងតាំង ហើយដែលព្រះជាម្ចាស់ផ្ញើបន្ទុកឲ្យចេញទៅប្រកាសដំណឹងល្អដល់សត្វលោកទាំងឡាយដែរ (មក ១៦, ១៥; មថ ២៨, ១៨-២០)។ ព្រះសហគមន៍ក៏ទាមទារសេរីភាពនោះ ក្នុងឋានៈជាសមាគមរបស់មនុស្ស ដែលមានសិទ្ធិរស់នៅក្នុងសង្គមតាមបញ្ញានៃជំនឿគ្រីស្ដសាសនាដែរ។

ហេតុនេះហើយ ប្រទេសណាដែលប្រកាសថាខ្លួនគោរពសេរីភាពខាងសាសនា ឬមានច្បាប់បញ្ជាក់អំពីសេរីភាពនោះ មិនត្រូវគ្រាន់តែប្រកាសប៉ុណ្ណោះទេ តែត្រូវអនុវត្តយ៉ាងពិតប្រាកដនិងយ៉ាងស្មោះ ឲ្យមានសេរីភាពខាងសាសនាមែន។ នៅក្នុងប្រទេសទាំងនោះ ព្រះសហគមន៍ពិតជាមានលក្ខន្តិកៈយ៉ាងមាំមួន តាមច្បាប់និងយ៉ាងពិតប្រាកដ អាចបំពេញបេសកកម្មដែលខ្លួនទទួលពីព្រះជាម្ចាស់បាន ដោយគ្មាននរណាបង្ខិតបង្ខំឡើយ។ តាមដំណើរនៃប្រវត្តិសាស្ត្រ អ្នកកាន់អំណាចក្នុងព្រះសហគមន៍បានទាមទារ កាន់តែខ្លាំងឡើងៗឲ្យព្រះសហគមន៍មានឯករាជ្យនេះក្នុងសង្គម។ នៅពេលជាមួយគ្នានោះ អស់អ្នកផ្ញើជីវិតលើព្រះគ្រីស្ត ដូចមនុស្សឯទៀតៗទាំងអស់ ក៏មានសិទ្ធិតាមច្បាប់ក្នុងសង្គម អាចរស់នៅតាមមនសិការរបស់ខ្លួន ដោយគ្មាននរណាឃាត់បានឡើយ។ ហេតុនេះហើយបានជាសេរីភាពរបស់ព្រះសហគមន៍ និងសេរីភាពខាងសាសនាស្របគ្នា។ ត្រូវទទួលស្គាល់សេរីភាពសម្រាប់មនុស្សទាំងអស់ និងសម្រាប់គ្រប់សហគមន៍សាសនាដែរ ទុកជាសិទ្ធិមួយដែលត្រូវមានច្បាប់កំណត់បញ្ជាក់ទៀតផង។

## ១៤-មុខងាររបស់ព្រះសហគមន៍

ព្រះសហគមន៍ត្រូវធ្វើតាមព្រះបញ្ជារបស់ព្រះយេស៊ូថា «ចូរចេញទៅបង្រៀនមនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ក» (មថ ២៨, ១៩) គឺព្រះសហគមន៍មិនត្រូវខ្លាចការនឿយហត់ ហើយត្រូវខិតខំធ្វើឲ្យ «ព្រះបន្ទូលរបស់ព្រះអម្ចាស់បន្តដំណើរយ៉ាងឆាប់រហ័សតទៅទៀត និងទទួលសិរីរុងរឿង» (២ថស ៣, ១)។

ហេតុនេះហើយ បានជាព្រះសហគមន៍ដាស់តឿនយ៉ាងជាក់ច្បាស់ដល់បុត្រធីតាថា «ចូរទូលសូមព្រះជាម្ចាស់ អធិដ្ឋាន និងអង្វរព្រះអង្គទាំងអរព្រះគុណសម្រាប់មនុស្សទាំងអស់ផង... នេះហើយជាការល្អនិងគាប់ព្រះហឫទ័យព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង ដែលទ្រង់សព្វព្រះហឫទ័យឲ្យមនុស្សទាំងអស់ទទួលការសង្គ្រោះ និងបានស្គាល់សេចក្ដីពិតយ៉ាងច្បាស់» (១ធម ២, ១-៤)។

ក៏ប៉ុន្តែ អស់អ្នកផ្ញើជីវិតលើព្រះគ្រីស្ត ត្រូវយកចិត្តទុកដាក់អប់រំមនសិការរបស់ខ្លួន ដោយគិតគូរយ៉ាងខ្លាំងអំពីលទ្ធិដ៏វិសុទ្ធនិងដ៏ពិតប្រាកដរបស់ព្រះសហគមន៍ដែរ។ ព្រះសហគមន៍នេះពិតជាគ្រូបង្រៀនសេចក្ដីពិត តាមព្រះហឫទ័យព្រះគ្រីស្តចាត់ចែង ដូច្នេះ ព្រះសហគមន៍ក៏មានទទួលបន្ទុកបង្ហាញ និងបង្រៀនយ៉ាងត្រឹមត្រូវនូវសេចក្ដីពិត គឺព្រះគ្រីស្តតែម្ដង។ នៅពេលជាមួយគ្នានេះ ព្រះសហគមន៍មានអំណាចប្រកាសនិងគាំទ្រគោលការណ៍នានានៃសីលធម៌ដែលហូរពីលក្ខណៈផ្ទាល់របស់មនុស្ស។ លើសពីនេះទៅទៀត គ្រីស្តបរិស័ទត្រូវចេញទៅជួបអស់អ្នកនៅខាងក្រៅ ទាំងប្រើប្រាជ្ញារបស់ខ្លួន «ដោយរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ដោយមានសេចក្ដីស្រឡាញ់ឥតពុតត្បុត និងប្រកាសសេចក្ដីពិត» (២ករ ៦, ៦-៧) ខិតខំទៅផ្សព្វផ្សាយពន្លឺនៃជីវិត ដោយចិត្តអង់អាចមោះមុត (កក ៤, ២៩) និងដោយចិត្តក្លាហានក្នុងឋានៈជាគ្រីស្តទូតរហូតដល់ហ៊ានបូជាជីវិតថែមទៀតផង។

សាវ័កម្នាក់ៗមានភារកិច្ចដ៏ធ្ងន់ចំពោះព្រះគ្រីស្ត ជាព្រះបរមគ្រូរបស់ខ្លួន គឺត្រូវស្គាល់សេចក្ដីពិតឲ្យកាន់តែច្បាស់ឡើងៗជានិច្ច ជាសេចក្ដីពិតដែលគេបានទទួលពីព្រះអង្គ និងប្រកាសសេចក្ដីពិតនោះយ៉ាងស្មោះព្រមទាំងការពារដោយស្វាហាប់ ដោយមិនព្រមប្រើមធ្យោបាយណាផ្ទុយនឹងគោលគំនិតនៃដំណឹងល្អឡើយ។ ប៉ុន្តែ ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តជំរុញឲ្យសាវ័កប្រព្រឹត្តដោយសេចក្ដីស្រឡាញ់ ដោយប្រុងប្រយ័ត្ន ដោយចិត្តអត់ធ្មត់ចំពោះអស់អ្នកដែលវង្វេង ឬអ្នកមិនស្គាល់ជំនឿ។ គ្រីស្តបរិស័ទក៏ត្រូវយកចិត្តទុកដាក់គិតគូរអំពីភារកិច្ចរបស់ខ្លួនចំពោះព្រះគ្រីស្ត ជាព្រះបន្ទូលដែលផ្ដល់ជីវិត និងជាកម្រិតនៃព្រះហឫទ័យប្រណីសន្ដោស ដែលព្រះជាម្ចាស់បាន

ចែកប្រទានដល់មនុស្សលោក ដោយសារព្រះគ្រីស្ត គឺព្រះអង្គអញ្ជើញមនុស្សឲ្យទទួល និងឲ្យប្រកាសជំនឿ ដោយសម្រេចចិត្តខ្លួនឯងទាំងស្រុង។

## ១៥-ពាក្យបញ្ចប់

សព្វថ្ងៃច្បាស់ណាស់ មនុស្សតែងតែប៉ងប្រាថ្នាកាន់តាមសាសនារបស់ខ្លួនដោយសេរី ទាំងម្នាក់ឯង ទាំងរួមជាមួយអ្នកដទៃជាសាធារណៈដែរ។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញស្ទើតែគ្រប់ប្រទេសទាំងអស់តែងប្រកាសថា សេរីភាពខាងសាសនាជាសិទ្ធិក្នុងសង្គម។ ឯកសារអន្តរជាតិក៏ទទួលស្គាល់សេរីភាពខាងសាសនានេះដែរ។ ប៉ុន្តែមានរបបនយោបាយខ្លះ ទោះបីរដ្ឋធម្មនុញ្ញរបស់គេទទួលស្គាល់សេរីភាពខាងសាសនាក្តី ក៏នៅតែខិតខំបង្វែរប្រជាពលរដ្ឋ មិនឲ្យកាន់សាសនា ហើយបង្កើតឧបសគ្គជាច្រើន បណ្តាលឲ្យសហគមន៍សាសនាពិបាករស់នៅ ហើយក៏រស់នៅមិនទៀងទាត់ទៀតផង។

មហាសន្និបាតដ៏វិសុទ្ធមានអំណរសប្បាយ ដោយឃើញសញ្ញាសម្គាល់ដ៏ល្អក្នុងសម័យឥឡូវ ប៉ុន្តែ ក៏បន្ទោសជាសាធារណៈទាំងទុក្ខព្រួយថា រដ្ឋអំណាចខ្លះមិនគោរពសេរីភាពសាសនាទេ។ មហាសន្និបាតក្រើនដាស់តឿនគ្រីស្តបរិស័ទកាតូលិក និងអង្វរមនុស្សទាំងអស់យ៉ាងខ្លាំង សូមពិនិត្យពិច័យឲ្យមែនទែនអំពីសេរីភាពខាងសាសនាដែលជាការមួយដ៏ចាំបាច់ ជាពិសេសក្នុងសភាពការណ៍បច្ចុប្បន្ននៃមហាគ្រួសាររបស់មនុស្សជាតិ។

ប្រជាជននានាសព្វថ្ងៃជាក់ច្បាស់ថា មានបំណងរួបរួមគ្នាកាន់ខ្លាំងឡើងៗជានិច្ច។ ប្រជាជាតិដែលមានវប្បធម៌ និងកាន់សាសនាប្លែកៗពីគ្នា ក៏មានទំនាក់ទំនងជាមួយគ្នាកាន់តែជិតស្និទ្ធដែរ។ ម្នាក់ៗដឹងខ្លួនកាន់តែច្បាស់ឡើងៗអំពីការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់។ ហេតុនេះហើយ បានជានៅគ្រប់កន្លែង ត្រូវឲ្យមានក្បួនច្បាប់ធានាសេរីភាពខាងសាសនាជាចាំបាច់ និងយ៉ាងស័ក្តិសិទ្ធទៀតផង។ រដ្ឋអំណាចត្រូវគោរពភារកិច្ចនិងសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុតរបស់មនុស្សឲ្យកាន់សាសនារបស់ខ្លួនក្នុងសង្គមដោយសេរី។ ធ្វើដូច្នេះ ទើបទំនាក់ទំនងប្រកបដោយសេចក្តីសុខសាន្ត និងដោយសន្តិភាព កើតមានឡើងក្នុងមនុស្សជាតិឲ្យកាន់តែស្ថិតស្ថេររឹងប៉ឹងទៅៗ។

សូមព្រះជាម្ចាស់ ជាព្រះបិតា ប្រោសប្រទានឲ្យក្រុមគ្រួសារមនុស្សលោក រស់នៅក្នុងសង្គមដែលធានាសិទ្ធិសេរីភាពខាងសាសនា។ ដូច្នេះ មនុស្សជាតិអាចឈានទៅដល់សេរីភាព ដ៏ប្រសើរខ្ពង់ខ្ពស់បំផុតនៃលោកខាងមុខដែលស្ថិតស្ថេរអស់កល្បជានិច្ច ដោយព្រះគ្រីស្តប្រោសប្រណី និងដោយអានុភាពនៃព្រះវិញ្ញាណជួយផង គឺជា «សេរីភាពប្រកបដោយសិរីរុងរឿង នៃបុត្រធីតារបស់ព្រះជាម្ចាស់» (រម ៨, ២១)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងសេចក្តីប្រកាសទាំងមូលនេះ ព្រមទាំងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាល ដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រមហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលា ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# នៅសម័យយើងនេះ

(អំពីទំនាក់ទំនងជាមួយសាសនាដទៃ)

## NOSTRA AETATE

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ សូមប្រកាសសេចក្ដីនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ។

## សេចក្ដីប្រកាស
## អំពីទំនាក់ទំនងគ្រីស្តសាសនា និងសាសនាដទៃ

**១-បុព្វកថា**

នៅសម័យយើងនេះ មនុស្សលោករួមគ្នាកាន់តែជិតស្និទ្ធឡើង ៗជារៀងរាល់ថ្ងៃ ប្រជាជនទាំងអស់ក៏មានទំនាក់ទំនងគ្នាកាន់តែជិតស្និទ្ធច្រើនឡើង ៗជាលំដាប់ដែរ។ ដូច្នេះ ព្រះសហគមន៍ពិចារណាឲ្យកាន់តែជ្រៅអំពីទំនាក់ទំនងរបស់ខ្លួនជាមួយនឹងសាសនាឯទៀត ៗដែលប្លែកពីគ្រីស្តសាសនា។ ព្រះសហគមន៍ទទួលបន្ទុកលើកស្ទួយមនុស្សលោក និងជាពិសេសប្រជាជាតិនានាឲ្យរួបរួមគ្នាជាធ្លុងតែមួយ ព្រមទាំងឲ្យស្រឡាញ់គ្នាទៅវិញទៅមកទៀតផង។ ដូច្នេះមុនដំបូងបង្អស់ ព្រះសហគមន៍ពិនិត្យពិច័យអំពីលក្ខណៈដែលមនុស្សគ្រប់ ៗរូបមានដូចគ្នា ជាលក្ខណៈជំរុញគេឲ្យរួមរស់ជាមួយគ្នា តាមវាសនារបស់គេដែរ។

ប្រជាជនទាំងអស់រួបរួមគ្នាជាសហគមន៍តែមួយមែន គេមានប្រភពតែមួយ ព្រោះព្រះជាម្ចាស់បានប្រោសឲ្យមនុស្សជាតិរស់នៅពាសពេញលើផែនដីទាំងមូល (កក ១៧, ២៦)។ ជីវិតមនុស្សគ្រប់ ៗរូប មានទិសដៅចុងក្រោយបំផុតតែមួយ គឺរួមរស់ជាមួយព្រះជាម្ចាស់។ ព្រះអង្គណែនាំថែរក្សាមនុស្សទាំងអស់ ទ្រង់សម្តែងព្រះហឫទ័យមេត្តាករុណាសប្បុរសចំពោះមនុស្សទាំងអស់ ហើយក៏គ្រោងទុកសង្គ្រោះមនុស្សទាំងអស់ដែរ (បញ ៨, ១; កក ១៤, ១៧; រម ២, ៦-៧; ១ធម ២, ៤) រហូតដល់ពេលអស់អ្នកដែលព្រះអង្គបានជ្រើសរើស រួមគ្នានៅក្នុងបុរីដ៏វិសុទ្ធ។ ពេលនោះសិរីរុងរឿងរបស់ព្រះអង្គនឹងបំភ្លឺបុរីនោះ ហើយជាតិសាសន៍នានានឹងដើរក្នុងពន្លឺព្រះអង្គ (វវ ២១, ២៣ត)។ មនុស្សនៅលើផែនដីទាំងប៉ុន្មាននៅតែទន្ទឹងរង់ចាំចង់ឲ្យសាសនានីមួយ ៗ ជួយដោះស្រាយប្រស្នាដ៏អាថ៌កំបាំងនៃវាសនាមនុស្សជាតិ។ នៅសម័យមុន ៗ ក៏ដូចនៅសម័យបច្ចុប្បន្ននេះដែរ មនុស្សផងទាំងពួងតែងតែបារម្ភយ៉ាងខ្លាំងក្នុងចិត្ត និងសួរខ្លួនឯងថា៖ តើអ្វីទៅមនុស្ស? តើជីវិតមនុស្សយើងមានអត្ថន័យយ៉ាងណា? តើជីវិតមនុស្សយើងមានទិសដៅទៅណាដែរ?

តើអ្វីទៅបុណ្យ អ្វីទៅបាប? តើទុក្ខវេទនាកើតពីប្រភពណាមក ហើយមានទិសដៅយ៉ាងណា? តើមានមាគ៌ាណាអាចនាំមនុស្សយើងឆ្ពោះទៅកាន់សុភមង្គលដ៏ពិតប្រាកដបាន? តើអ្វីជាសេចក្ដីស្លាប់? ក្រោយពីស្លាប់ តើមានវិនិច្ឆ័យកាត់ទោសនិងទទួលរង្វាន់ឬយ៉ាងណា? តើអ្វីជាការអាថ៌កំបាំងដ៏អស្ចារ្យចុងក្រោយបំផុតនៃជីវិតមនុស្សដែលរកថ្លែងពុំបាន? ការអាថ៌កំបាំងដ៏អស្ចារ្យនេះជាប្រភពនៃជីវិតយើងឬទេ? តើយើងកំពុងតម្រង់ទៅរកការអាថ៌កំបាំងនោះទៀតដែរឬ?។

## ២-សាសនាផ្សេងៗ ក្រៅពីគ្រីស្ដសាសនា

តាំងពីបុរាណកាលរហូតមកទល់សព្វថ្ងៃ មនុស្សគ្រប់ជាតិសាសន៍ តែងតែយល់ឃើញម៉្យាងថា មានឥទ្ធិពលដ៏អាថ៌កំបាំង ដែលណែនាំពិភពលោកនិងណែនាំព្រឹត្តិការណ៍ប្រចាំជីវិតមនុស្សយើងដែរ។ មានប្រជាជនខ្លះទទួលស្គាល់ថាមានព្រះមួយអង្គដ៏ខ្ពង់ខ្ពស់បំផុត ឬមានព្រះបិតាទៀតផង។ ការយល់ឃើញនិងទទួលស្គាល់ដូច្នេះ ជ្រួតជ្រាបក្នុងការរស់នៅរបស់គេ រហូតដល់គេមានចិត្តគំនិតយល់គិតយ៉ាងជ្រៅអំពីសាសនា។ មានសាសនាខ្លះកើតឡើង ដោយភ្ជាប់នឹងវប្បធម៌ដែលចម្រើនឡើង ខិតខំរកដំណោះស្រាយបញ្ហាជីវិតដដែល ដោយប្រើទស្សនៈខ្ពង់ខ្ពស់ និងប្រើពាក្យពេចន៍ដ៏ប្រសើរ។ ដូច្នេះ តាមសាសនាឥណ្ឌា មនុស្សរិះគិតពិចារណាអំពីការអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ហើយពន្យល់សេចក្ដីដែលពួកគេបានរកឃើញនោះ ដោយបង្កើតរឿងនិទានជាច្រើនអនេក ព្រមទាំងខិតខំស្រាវជ្រាវយ៉ាងជ្រៅតាមទស្សនវិជ្ជាផង។ ពួកគេរកផ្លូវរំដោះមនុស្សឲ្យបានរួចផុតពីការតប់ប្រមល់ទាំងឡាយនៃសភាពការណ៍មនុស្សយើង ដោយបំពេញតបៈធម៌តាមរបៀបតាបសឥសី ដោយធ្វើសមាធិយ៉ាងជ្រៅ ឬដោយជ្រកកោនក្រោមម្លប់នៃព្រះជាម្ចាស់ដោយចិត្តស្រឡាញ់ និងដោយផ្ញើជីវិតទាំងស្រុងលើព្រះអង្គផង។ ពុទ្ធសាសនាតាមនិកាយផ្សេងៗទទួលស្គាល់ថា ជីវិតសត្វលោកសុទ្ធតែទុក្ខ មិនទៀងទាត់ហើយតែងតែប្រែប្រួលជានិច្ច គ្មានអ្វីនឹងអាចធ្វើឲ្យមនុស្សស្ងប់ចិត្តបានឡើយ។ ពុទ្ធសាសនាបង្ហាញមាគ៌ាមួយណែនាំមនុស្សឲ្យមានចិត្តធម៌ ឲ្យពឹងផ្អែកទាំងស្រុងលើកុសល ផលបុណ្យរបស់ខ្លួន ដើម្បីឲ្យខ្លួនអាចរួចផុតពីតណ្ហា អាចត្រាស់ដឹង និងអាចឈានទៅដល់បរិនិព្វានបានផង។ ពុទ្ធបរិស័ទខ្លះយល់ឃើញថា គេអាចត្រាស់ដឹងបានដោយមានជំនួយមកពីខាងលើ។ នៅក្នុងពិភពលោកយើងនេះ ក៏មានសាសនាឯទៀតៗជាច្រើន ខិតខំទប់ទល់នឹងការព្រួយបារម្ភក្នុងចិត្តមនុស្សតាមរបៀបផ្សេងៗ ទាំងបង្ហាញមាគ៌ាផ្សេងៗ គឺលទ្ធិ ក្បួនវិន័យ និងពិធីបុណ្យដ៏សក្ការៈផ្សេងៗទៀតផង។

ព្រះសហគមន៍កាតូលិកមិនទាត់ចោលអ្វីៗដ៏ពិតប្រាកដ និងអ្វីៗដ៏វិសុទ្ធដែលមានកប់ទុកក្នុងសាសនាទាំងនោះទេ។ ផ្ទុយទៅវិញ ព្រះសហគមន៍គោរពយ៉ាងស្មោះនូវរបៀបប្រព្រឹត្ត និងរបៀបរស់នៅតាមសាសនាទាំងនោះ មានវិន័យនិងលទ្ធិជាដើម។ ទោះបីរបៀបប្រព្រឹត្តនិងរបៀបរស់នៅ វិន័យនិងលទ្ធិទាំងនោះ ខុសប្លែកគ្រង់ប្រការជាច្រើន ពីរបៀបប្រព្រឹត្តនិងរបៀបរស់នៅ ពីវិន័យនិងលទ្ធិដែលព្រះសហគមន៍កាន់និងប្រៀនប្រដៅក្ដី ក៏អ្វីៗទាំងនោះតែងតែនាំមកនូវរស្មីនៃពន្លឺរបស់សេចក្ដីពិតតែមួយ ដែលបំភ្លឺមនុស្សលោកទាំងអស់។ ប៉ុន្តែព្រះសហគមន៍ប្រកាសព្រះគ្រីស្ដ ហើយមានភារកិច្ចប្រកាសព្រះគ្រីស្ដដោយឥតឈប់ឈរ ព្រោះព្រះអង្គពិតជា *"មាគ៌ា ជាសេចក្ដីពិត និងជាជីវិត"* (យហ ១៤, ៦)។ មនុស្សទាំងអស់មុខជានឹងរកឃើញជីវិតខាងសាសនាយ៉ាងពេញលក្ខណៈក្នុងអង្គព្រះគ្រីស្ដ ព្រោះព្រះជាម្ចាស់បានសម្រុះសម្រួលសត្វលោកទាំងអស់ ឲ្យជានានឹងព្រះអង្គក្នុងអង្គព្រះគ្រីស្ដនេះឯង (២ករ ៥, ១៨-១៩)។

ហេតុនេះហើយ បានជាព្រះសហគមន៍ដាស់តឿនបុត្រធីតារបស់ខ្លួន ឲ្យទទួលស្គាល់និងថែរក្សានូវសេចក្ដីដ៏ថ្លៃថ្នូរទាំងខាងផ្លូវវិញ្ញាណ ខាងសីលធម៌ និងខាងសង្គម និងវប្បធម៌ដែលមានកប់ទុកក្នុងសាសនាទាំងនោះ។ ព្រះសហគមន៍ក៏ត្រូវធ្វើឲ្យសេចក្ដីដ៏ថ្លៃថ្នូរទាំងនោះចម្រើនឡើងទៀតផង។ គ្រីស្ដបរិស័ទត្រូវសន្ទនានិងសហការជាមួយអ្នកកាន់សាសនា

ឯទៀតៗ ដោយប្រយ័ត្ននិងដោយចិត្តស្រឡាញ់ ទាំងផ្ដល់សក្ខីភាពអំពីជំនឿ និងអំពីរបៀបរស់នៅរបស់ខ្លួនតាមគ្រីស្ដសាសនា។

### ៣-សាសនាឥស្លាម

ព្រះសហគមន៍ក៏គោរពរាប់អានបរិស័ទឥស្លាមដែរ។ បរិស័ទឥស្លាមតែងតែគោរពប្រណិប័តន៍ក្រាបថ្វាយបង្គំព្រះជាម្ចាស់តែមួយព្រះអង្គគត់ ជាព្រះដែលមានព្រះជន្មគង់នៅ ហើយដែលស្ថិតស្ថេរនៅដោយផ្ទាល់ព្រះអង្គ ព្រះអង្គមានព្រះហឫទ័យមេត្តាករុណា និងមានតេជានុភាពសព្វប្រការ ទ្រង់បានប្រតិស្ឋានមេឃនិងដី ហើយក៏មានព្រះបន្ទូលមកកាន់មនុស្សលោកដែរ។ បងប្អូនក៏យកចិត្តទុកដាក់ចុះចូលនឹងក្រិត្យក្រមរបស់ព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត ទោះបីក្រិត្យក្រមទាំងនោះនៅទីលាក់កំបាំងក្ដី ដូចលោកអប្រាហាំជាបុព្វបុរសខាងជំនឿ ដែលគេចូលចិត្តនឹករឭកបាន ចុះចូលដូច្នោះដែរ។ ទោះបីគេមិនទទួលស្គាល់ថា ព្រះយេស៊ូជាព្រះជាម្ចាស់ក៏ដោយ ក៏គេតែងតែគោរពប្រណិប័តន៍ ព្រះអង្គទុកជាព្យាការីមួយរូបដែរ។ គេក៏គោរពនាងព្រហ្មចារិនីម៉ារីជាព្រះមាតាព្រះអង្គ ហើយមានក្រុមខ្លះក៏អង្វរព្រះនាងទាំងគោរពប្រណិប័តន៍ដែរ។ គេក៏ទន្ទឹងរង់ចាំថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យមនុស្សលោក គឺពេលព្រះអង្គប្រទានរង្វាន់ដល់អស់អ្នកដែលនឹងមានជីវិតថ្មី។ ហេតុនេះ គេរាប់រកការរស់នៅតាមសីលធម៌យ៉ាងខ្លាំង ហើយគោរពបម្រើព្រះជាម្ចាស់ជាពិសេសដោយសូត្រធម៌ ដោយធ្វើបុណ្យទាន និងដោយធ្វើពិធីតមអាហារទៀតផង។

អស់រយៈពេលជាយូរសតវត្សកន្លងមក គ្រីស្ដបរិស័ទនិងឥស្លាមបរិស័ទខ្វែងគំនិតគ្នា និងស្អប់គ្នាជាច្រើនដងហើយ។ ប៉ុន្តែ មហាសន្និបាតដ៏វិសុទ្ធ ក្រើនដាស់តឿនទាំងគ្រីស្ដបរិស័ទ ទាំងបរិស័ទឥស្លាម ឲ្យបំភ្លេចរឿងពីអតីតកាលចោល និងខិតខំយោគយល់គ្នាទៅវិញទៅមកដោយចិត្តស្មោះ។ ដូច្នេះ គ្រីស្ដបរិស័ទ និងឥស្លាមបរិស័ទអាចរួមគ្នាការពារនិងលើកស្ទួយយុត្តិធម៌ក្នុងសង្គម តម្លៃដ៏ថ្លៃថ្នូរនៃសីលធម៌ សន្តិភាព និងសេរីភាព ជូនមនុស្សលោកទាំងអស់បាន។

### ៤-សាសនាយូដា

មហាសន្និបាតបានពិនិត្យពិច័យគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ អំពីព្រះសហគមន៍ ហើយរំឭកគ្រីស្ដបរិស័ទថា ប្រជាជននៃសម្ពន្ធមេត្រីថ្មីជាប់ចំណងទាក់ទងខាងផ្លូវវិញ្ញាណ នឹងពូជពង្សរបស់លោកអប្រាហាំហើយ។ ព្រះសហគមន៍របស់ព្រះគ្រីស្ដទទួលស្គាល់ថា អស់លោកបុព្វបុរស លោកម៉ូសេ និងអស់លោកព្យាការី គឺនៅខាងដើមជំនឿរបស់ខ្លួន ហើយក៏នៅខាងដើមនៃជម្រើសរបស់ព្រះជាម្ចាស់ ដែលជ្រើសរើសព្រះសហគមន៍ តាមគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ។ ព្រះសហគមន៍តែងតែប្រកាសថា អស់អ្នកដែលផ្ញើជីវិតលើព្រះគ្រីស្ដ ក៏ជាពូជពង្សលោកអប្រាហាំខាងជំនឿដែរ (កាឡ ៣, ៧)។ ពេលព្រះជាម្ចាស់ត្រាស់ហៅលោកអាប្រាហាំ នោះព្រះអង្គក៏បានត្រាស់ហៅគ្រីស្ដបរិស័ទរួមជាមួយលោកដែរ។ ពេលព្រះជាម្ចាស់ប្រោសប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស ឲ្យរួចចេញពីស្រុកដែលគេធ្វើជាទាសាទាសីនោះ ក៏ដូចជាព្រះអង្គប្រទានប្រផ្នូលយ៉ាងលាក់កំបាំង អំពីការសង្គ្រោះនៃព្រះសហគមន៍ដែរ។ ហេតុនេះហើយ បានជាព្រះសហគមន៍ពុំអាចបំភ្លេចថា ខ្លួនបានទទួលសេចក្ដី ដែលព្រះជាម្ចាស់បានសម្ដែងឲ្យមនុស្សលោកស្គាល់តាមសម្ពន្ធមេត្រីចាស់ តាមរយៈប្រជារាស្ត្រអ៊ីស្រាអែលនោះទេ។ ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យមេត្តាករុណាដែលរកថ្លែងពុំបាន ព្រះអង្គប្រណីសន្តោសចងសម្ពន្ធមេត្រីពីដើមជាមួយប្រជាជននោះ។ ព្រះសហគមន៍ចិញ្ចឹមជីវិតរបស់ខ្លួន ដោយស្រូបជីជាតិពីឫសនៃដើមអូលីវដែលគេកាត់មែកចោល និងយកមែកអូលីវព្រៃ គឺសាសន៍ដទៃមកផ្សាំជំនួសវិញ (រម ១១, ១៧-២៤)។ ព្រះសហគមន៍ជឿថា ព្រះគ្រីស្ដដែលជាសន្តិភាពរបស់យើង ព្រះអង្គបាន

សម្រុះសម្រួលជនជាតិយូដានឹងសាសន៍ដទៃ ឲ្យរួមគ្នាជាប្រជារាស្ត្រតែមួយក្នុងព្រះអង្គផ្ទាល់ ដោយព្រះគ្រីស្តសោយទិវង្គតនៅលើឈើឆ្កាង ( អភ ២, ១៤-១៦ )។

ព្រះសហគមន៍នៅតែនឹកគិតដល់គ្រីស្តទូតប៉ូល ដែលថ្លែងអំពីបងប្អូនរួមជាតិរបស់លោកថា៖ *"ព្រះជាម្ចាស់បានប្រោសពួកគេឲ្យទៅជាបុត្រធីតារបស់ព្រះអង្គឲ្យគេមានសិរីរុងរឿង ហើយព្រះអង្គក៏បានចងសម្ពន្ធមេត្រីនានា ជាមួយពួកគេ និងប្រទានធម៌វិន័យឲ្យគេចេះគោរពបម្រើព្រះអង្គ ឲ្យគេបានទទួលព្រះបន្ទូលសន្យាផ្សេងៗឲ្យគេមានបុព្វបុរស ហើយព្រះគ្រីស្តក៏ប្រសូតមកជាមនុស្សក្នុងពូជពង្សរបស់ពួកគេដែរ"* (រម ៩, ៤-៥) ហើយព្រះអង្គក៏ជាបុត្ររបស់ព្រះនាងព្រហ្មចារិនីម៉ារីថែមទៀតផង។ ព្រះសហគមន៍តែងរំឭកថា គ្រីស្តទូតទាំងប៉ុន្មានដែលជាគ្រឹះ និងជាសរសរនៃព្រះសហគមន៍ ក៏កើតមកក្នុងប្រជាជនយូដានេះ សាវ័កដើមដំបូងជាច្រើនក៏ជាជនជាតិយូដាដែរ គឺពួកគេបានប្រកាសដំណឹងល្អអំពីព្រះគ្រីស្តឲ្យមនុស្សលោកទាំងមូលដឹងឮផង។

តាមគម្ពីរជាសាក្សី អ្នកក្រុងយេរូសាឡឹម មិនបានទទួលស្គាល់ពេលកំណត់ ដែលព្រះជាម្ចាស់យាងមកសង្គ្រោះគេឡើយ (លក ១៩, ៤៤)។ ជនជាតិយូដាភាគច្រើនក៏មិនព្រមទទួលដំណឹងល្អដែរ ហើយក៏មានជនជាតិយូដាជាច្រើននាំគ្នាប្រឆាំងមិនឲ្យគ្រីស្តទូតផ្សព្វផ្សាយដំណឹងល្អនេះទៀតផង (រម ១១, ២៨)។ ក៏ប៉ុន្តែ តាមគ្រីស្តទូតប៉ូលថ្លែងទុកមកថា ព្រះជាម្ចាស់នៅតែសព្វព្រះហឫទ័យនឹងជនជាតិយូដាយ៉ាងខ្លាំង មកពីព្រះអង្គនឹកគិតដល់បុព្វបុរសរបស់គេ។ *"កាលណាព្រះជាម្ចាស់ប្រទានព្រះអំណោយទានរួចហើយ ព្រះអង្គមិនដកហូតវិញទេ ហើយកាលណាព្រះអង្គ ត្រាស់ហៅទ្រង់ក៏មិនប្រែប្រួលព្រះហឫទ័យដែរ"* (រម ១១, ២៨-២៩; ពន្លឺ ១៦)។ រួមជាមួយអស់លោកព្យាការី និងជាមួយគ្រីស្តទូតប៉ូលដដែលនេះ ព្រះសហគមន៍ក៏រង់ចាំថ្ងៃដែលប្រជាជនទាំងអស់ រួមសម្លេងអង្វរព្រះជាម្ចាស់ជាមួយគ្នា ហើយព្រមព្រៀងគ្នាគោរពបម្រើព្រះអង្គទាំងអស់គ្នាផង ( សផ ៣, ៩; អស ៦៦, ២៣; ទន ៦៥, ៤; រម ១១, ១១ , ៣២ )។

គ្រីស្តបរិស័ទ និងជនជាតិយូដា បានទទួលបេតិកភ័ណ្ឌរួមខាងព្រះវិញ្ញាណដ៏ល្អប្រសើរបំផុត។ ហេតុនេះ មហាសន្និបាតដ៏វិសុទ្ធនេះ មានបំណងចង់ផ្តើផ្តាំនិងគាំទ្រ ឲ្យបរិស័ទសាសនាទាំងពីរយកចិត្តទុកដាក់ស្គាល់គ្នា និងគោរពរាប់អានគ្នាទៅវិញទៅមក ជាពិសេសដោយសិក្សាគម្ពីរនិងទេវវិទ្យា ព្រមទាំងដោយសន្ទនាពិភាក្សាគ្នាដូចបងប្អូនបង្កើតផង។

ទោះបីអ្នកដឹកនាំប្រជាជនយូដា និងបក្សពួកគេបានញុះញង់ប្រជាជនឲ្យធ្វើគុតព្រះគ្រីស្តក្តី ( យហ ១៩, ៦ ) ក៏មិនត្រូវចោទជនជាតិយូដាទាំងអស់ ដែលរស់នៅក្នុងសម័យនោះ ឬជនជាតិយូដាសព្វថ្ងៃថា គេបានសម្លាប់ព្រះអង្គទេ។ ទោះបីព្រះសហគមន៍ពិតជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់ក្តី ក៏មិនត្រូវសំអាងលើគម្ពីរមកចាត់ជនជាតិយូដាទុកជាប្រជាជនដែលព្រះអង្គដាក់ទោស ឬដាក់បណ្តាសាឡើយ។ ដូច្នេះ សូមគ្រីស្តបរិស័ទទាំងអស់នៅពេលអប់រំជំនឿក្តី នៅពេលធ្វើពិធីអត្ថាធិប្បាយគម្ពីរក្តី ក៏ត្រូវយកចិត្តទុកដាក់បង្រៀនតែសេចក្តីស្របតាមសេចក្តីពិត ដែលមានចែងទុកក្នុងគម្ពីរដំណឹងល្អ និងស្របតាមគោលគំនិតរបស់ព្រះគ្រីស្តប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ព្រះសហគមន៍មិនយល់ស្របឲ្យគេបៀតបៀនធ្វើបាបគ្រប់យ៉ាង ចំពោះមនុស្សទាំងអស់ជាដាច់ខាត ទោះជាជាតិសាសន៍ណាក៏ដោយ។ ព្រះសហគមន៍ក៏មិនអាចបំភ្លេចបេតិកភ័ណ្ឌរួមជាមួយជនជាតិយូដាដែរ។ ព្រះសហគមន៍ គ្មានមូលហេតុខាងនយោបាយអ្វីណែនាំឡើយ មានតែសេចក្តីស្រឡាញ់តាមសាសនា ដែលហូរចេញមកពីដំណឹងល្អប៉ុណ្ណោះទេ ជំរុញខ្លួនឲ្យស្តីបន្ទោសអស់អ្នកដែលស្អប់ជនជាតិយូដា អស់អ្នកដែលបៀតបៀនធ្វើបាបគេ និងអ្នកដែលបង្ហាញគំនិតទាស់ប្រឆាំងនឹងជនជាតិនេះ។ ទោះជានៅសម័យណា និងជានរណាក៏ដោយ ក៏ព្រះសហគមន៍ស្តីបន្ទោសដែរ។

សព្វថ្ងៃនេះ ក៏ដូចព្រះសហគមន៍ធ្លាប់ជឿកាលពីដើមដែរ ហើយនៅតែជឿជានិច្ចថា ដោយព្រះគ្រីស្តមានព្រះហឫទ័យស្រឡាញ់យ៉ាងខ្លាំងលើសលប់ ព្រះអង្គសព្វព្រះហឫទ័យរងទុក្ខលំបាកនិងសោយទិវង្គត ព្រោះតែអំពើបាបរបស់មនុស្សលោកទាំងអស់ និងដើម្បីសង្គ្រោះមនុស្សលោកដែរ។ ដូច្នេះ ព្រះសហគមន៍មានភារកិច្ចប្រកាសនិងជូនដំណឹងថា ឈើឆ្កាងរបស់ព្រះគ្រីស្តជាសញ្ញាសម្គាល់បង្ហាញព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោកទាំងអស់ ហើយក៏ជាប្រភពនៃព្រះហឫទ័យប្រណីសន្តោសគ្រប់យ៉ាងទៀតផង។

## ៥-ត្រូវស្រឡាញ់អ្នកផងទាំងពួង ដោយមិនរើសមុខនរណាសោះឡើយ

ប្រសិនបើយើងមិនព្រមគោរពមនុស្សមួយក្រុមទុកជាបងប្អូនបង្កើត គឺមនុស្សដែលព្រះជាម្ចាស់ប្រតិស្ឋាន ជារូបតំណាងរបស់ព្រះអង្គនោះ យើងក៏ពុំអាចអង្វរព្រះជាម្ចាស់បានសោះឡើយ ព្រោះព្រះអង្គជាព្រះបិតារបស់មនុស្សទាំងអស់។ មនុស្សម្នាក់ៗអាចទាក់ទងជាមួយព្រះបិតាបាន លុះត្រាតែខ្លួនទាក់ទងជាមួយមនុស្សឯទៀតៗយ៉ាងស្រួលដែរ ដូចមានចែងក្នុងគម្ពីរថា *"អ្នកដែលមិនចេះស្រឡាញ់គេ ក៏មិនស្គាល់ព្រះជាម្ចាស់ដែរ"* (១យហ ៤, ៨)។

ដូច្នេះ គម្ពីររំលាយគ្រឹះនៃទ្រឹស្តីទាំងអស់ និងគ្រឹះនៃការប្រព្រឹត្តទាំងប៉ុន្មាន ដែលបណ្តាលឲ្យមនុស្សរើសអើងគ្នា គឺឲ្យមនុស្សប្រកាន់មនុស្ស ប្រជាជនមួយប្រកាន់ប្រជាជនមួយទៀត សរុបសេចក្តីមក គឺប្រកាន់អំពីកិត្តិយសដ៏ថ្លៃថ្នូរ និងអំពីសិទ្ធិដែលហូរមកពីកិត្តិយសដ៏ថ្លៃថ្នូរនេះ។

ហេតុនេះ ព្រះសហគមន៍បដិសេធជំទាស់យ៉ាងម៉ឺងម៉ាត់ការរើសមុខ ប្រកាន់មើលងាយជាតិសាសន៍ ពណ៌សម្បុរ ឋានៈវណ្ណៈ ឬសាសនា ទុកជាកិច្ចផ្ទុយស្រឡះនឹងគោលគំនិតរបស់ព្រះគ្រីស្ត។ ហេតុនេះហើយ បានជាមហាសន្និបាតដ៏វិសុទ្ធ ដោយយកតម្រាប់តាមសន្តគ្រីស្តទូតសិលានិងប៉ូល សូមអំពាវនាវដល់គ្រីស្តបរិស័ទទាំងអស់យ៉ាងខ្លាំងក្លាថា *"ឲ្យកាន់កិរិយាមារយាទឲ្យបានថ្លៃថ្នូរ នៅក្នុងចំណោមសាសន៍ដទៃ"* (១សល ២, ១២) និងតាមចំណែករបស់បងប្អូន នោះបងប្អូនរស់នៅដោយសុខសាន្តជាមួយមនុស្សទាំងអស់ (រម ១២, ១៨) ដើម្បីឲ្យបងប្អូនទៅជាបុត្រធីតារបស់ព្រះបិតាដែលគង់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុតពិតមែន (មថ ៥, ៤៥)។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងសេចក្តីប្រកាសទាំងមូលនេះទាំងមូលនេះ ហើយនឹងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផងក៏យល់ព្រមដែរ ហើយក៏សម្រេចប្រកាសសេចក្តីនេះចេញទុកជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះ ត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារ សន្តៈសិលា ថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

(ហត្ថលេខារបស់លោកអភិបាល)

# បញ្ញាដ៏ធ្ងន់ធ្ងរបំផុត

**(អំពីការអប់រំតាមបែបគ្រីស្តសាសនា)**

## GRAVISSIMUM MOMENTUM

## ខ្ញុំប៉ូល ជាអភិបាល ជាអ្នកបម្រើនៃអ្នកបម្រើរបស់ព្រះជាម្ចាស់ រួមជាមួយអស់លោកអភិបាលដែលជួបជុំគ្នាក្នុងមហាសន្និបាតដ៏វិសុទ្ធនេះ ប្រកាសសេចក្តីនេះ ដើម្បីឲ្យគេនឹកចងចាំរហូតតរៀងទៅ

## សេចក្តីប្រកាស
## អំពីការអប់រំតាមបែបគ្រីស្តសាសនា

### បុព្វកថា

ការអប់រំមានសារៈសំខាន់យ៉ាងខ្លាំងជាទីបំផុត ក្នុងការរស់នៅរបស់មនុស្ស ហើយក៏មានឥទ្ធិពលកាន់តែខ្លាំងឡើងៗ ទៅលើការអភិវឌ្ឍន៍នៃសង្គមទំនើបយើងដែរ។ ហេតុនេះហើយ បានជាមហាសន្និបាតសកល យកចិត្តទុកដាក់រិះគិតអំពីការអប់រំនេះ។ តាមពិតសភាពការណ៍ជីវភាពនាបច្ចុប្បន្នកាល បណ្តាលឲ្យការអប់រំយុវជនយុវនារី និងការអប់រំអចិន្ត្រៃយ៍របស់មនុស្សពេញវ័យកាន់តែស្រួល និងមានលក្ខណៈកាន់តែជាបន្ទាន់ឡើងៗទៀតផង។ មនុស្សដឹងខ្លួន អំពីកិត្តិយសដ៏ថ្លៃថ្នូររបស់ខ្លួន និងអំពីសិទ្ធិទទួលខុសត្រូវលើខ្លួនឯងកាន់តែច្បាស់ឡើងៗដែរ គេមានបំណងចង់រួមចំណែកកាន់តែសកម្មជារៀងរាល់ថ្ងៃ ក្នុងការរស់នៅក្នុងសង្គម ហើយជាពិសេសក្នុងការរស់នៅខាងសេដ្ឋកិច្ច និងខាងនយោបាយទៀតដែរ។ បច្ចេកទេស និងការស្វែងរកតាមវិទ្យាសាស្ត្រចម្រើនឡើងយ៉ាងអស្ចារ្យ មានមធ្យោបាយថ្មីៗខាងទូរមនាគមន៍ក្នុងសង្គម ផ្តល់ឲ្យមនុស្សដែលមានពេលទំនេរកាន់តែច្រើនឡើងៗ អាចចូលទៅកាន់បេតិកភ័ណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌខាងវិញ្ញាណរបស់មនុស្សជាតិបាន។ ដោយក្រុមមនុស្ស និងក្រុមមនុស្ស ប្រជាជន និងប្រជាជន ទាក់ទងគ្នាកាន់តែជិតស្និទ្ធឡើងៗ គេអាចជួយគ្នាទៅវិញទៅមកឲ្យចម្រើនឡើង។

ហេតុនេះហើយ បានជានៅគ្រប់ប្រទេស មនុស្សខិតខំលើកស្ទួយការអប់រំឲ្យកាន់តែច្រើនឡើងជាលំដាប់។ ឯកសារជាផ្លូវការ ទទួលស្គាល់សិទ្ធិជាគ្រឹះរបស់មនុស្ស ឲ្យទទួលការអប់រំ ជាពិសេសសិទ្ធិកុមារកុមារី ឲ្យទទួលការអប់រំ និងសិទ្ធិឪពុកម្តាយឲ្យអប់រំកូនរបស់ខ្លួនដែរ។ ដោយចំនួនកូនសិស្សចម្រើនឡើងយ៉ាងលឿនជាលំដាប់ គេសាងសង់សាលារៀនកាន់តែច្រើនឡើងៗ នៅគ្រប់ទីកន្លែង។ សាលាទាំងនោះ ក៏កាន់តែប្រសើរឡើងៗដែរ។ គេបង្កើតស្ថាប័នអប់រំជាច្រើនទៀតផង។ គេពិសោធន៍ការអប់រំតាមរបៀបថ្មី គេអភិវឌ្ឍវិធីអប់រំ និងវិធីបង្រៀន។ ទោះបីក្មេងៗ និងយុវជនយុវនារី មិនទាន់ទទួលការអប់រំបឋមទាំងអស់គ្នាក្តី ហើយទោះបី មានយុវជនយុវនារីឯទៀតៗជាច្រើន ខ្វះការអប់រំ

ដ៏ពិតប្រាកដក្តី ក៏គេនៅតែខិតខំយ៉ាងល្អប្រសើរ ផ្តល់ផលល្អនៃការអប់រំជូនមនុស្សទាំងអស់ដែរ។ មានតែការអប់រំដ៏ពិតប្រាកដទេ ដែលធ្វើឱ្យសេចក្តីពិតនិងសេចក្តីស្រឡាញ់ចម្រើនឡើងបាន។

ប៉ុន្តែ ព្រះសហគមន៍ជាមាតាដ៏វិសុទ្ធរបស់យើង ត្រូវយកចិត្តទុកដាក់ថែទាំជីវិតមនុស្សទាំងស្រុង សូម្បីតែកង្វល់ខាងលោកីយ៍របស់គេ ក៏ព្រះសហគមន៍ត្រូវយកចិត្តទុកដាក់ដែរ (ពន្លឺ ១៧) ព្រោះកង្វល់ទាំងនោះ ជាប់ពាក់ព័ន្ធនឹងទិសដៅនៃជីវិតមនុស្ស តាមព្រះជាម្ចាស់បានត្រាស់ហៅ។ ទិសដៅជីវិតមនុស្សហួសពីលោកីយ៍នេះ។ ធ្វើដូច្នេះ ទើបព្រះសហគមន៍អាចបំពេញបេសកកម្ម ប្រកាសអំពីគម្រោងការនៃការសង្គ្រោះឱ្យមនុស្សទាំងអស់បាន ព្រមទាំងប្រមូលអ្វីៗទាំងអស់ក្នុងអង្គព្រះគ្រីស្តដែរ។ ព្រះអម្ចាស់ដែលតែងតាំងព្រះសហគមន៍ បានផ្ញើទុកបេសកកម្មនេះមកព្រះសហគមន៍។ ហេតុនេះហើយ បានជាព្រះសហគមន៍ មានតួនាទីអភិវឌ្ឍការអប់រំឱ្យចម្រើនឡើង។ មហាសន្និបាត សូមប្រកាសគោលការណ៍ជាមូលដ្ឋាន របស់ការអប់រំបែបគ្រីស្តសាសនា ជាពិសេសអំពីអ្វីៗដែលទាក់ទិននឹងការសិក្សា។ ក្រោយពីមហាសន្និបាតចប់សព្វគ្រប់ហើយ ត្រូវបង្កើតគណៈកម្មាធិការមួយពិសេស ដើម្បីលាតត្រដាងគោលការណ៍ទាំងនោះយ៉ាងពិស្តារ។ ក្រុមអភិបាលនៅប្រទេសនីមួយៗ ត្រូវយកចិត្តទុកដាក់អនុវត្តតាមគោលការណ៍ទាំងនោះ ដោយគិតគូរដល់សភាពការណ៍នៅក្នុងប្រទេសរបស់អស់លោក។

## ១-សិទ្ធិជាទូទៅឲ្យទទួលការអប់រំ

មនុស្សគ្រប់ៗរូប ទោះជាជាតិណា មានអាយុ ឬមានលក្ខណៈបែបណាក៏ដោយ ក៏មានសិទ្ធិទទួលការអប់រំ ស្របតាមឧបនិស្ស័យរបស់ខ្លួន ស្របតាមទេពកោសល្យ តាមភេទ តាមវប្បធម៌ និងតាមប្រពៃណីជាតិរបស់ខ្លួន។ សិទ្ធិនេះមិនអាចដកចេញបាន ព្រោះមកពីតម្លៃដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ។ ការអប់រំនេះ ក៏ត្រូវនាំឱ្យមនុស្សអាចផ្លាស់ប្តូរយោបល់ជាមួយប្រជាជាតិឯទៀតៗដូចបងប្អូន ដើម្បីជួយឱ្យមនុស្សរួបរួមគ្នាជាធ្លុងតែមួយយ៉ាងពិតប្រាកដ និងដើម្បីកសាងសន្តិភាព ក្នុងពិភពលោកទៀតផង។

ការអប់រំដ៏ពិតប្រាកដ មានគោលដៅអប់រំបុគ្គលម្នាក់ៗ ដោយនឹកដល់ទិសដៅដ៏ខ្ពង់ខ្ពស់បំផុតរបស់ខ្លួន និងនឹកដល់ប្រយោជន៍ក្រុមផ្សេងៗ ដែលអ្នកនោះជាសមាជិក។ នៅពេលគេពេញវ័យហើយ គេនឹងបំពេញសកម្មភាពរបស់ខ្លួនបម្រើក្រុមទាំងនោះ។

ហេតុនេះត្រូវអប់រំក្មេងៗ និងយុវជន យុវនារី ដោយគិតគូរដល់ចិត្តសាស្ត្រ ដល់គរុកោសល្យ និងដល់របៀបបង្រៀន ដែលតែងតែចម្រើនឡើងតាមលំដាប់លំដោយ គឺត្រូវជួយក្មេងៗ និងយុវជន យុវនារី ឲ្យពង្រីកសម្បទា ទាំងខាងរូបកាយ ទាំងខាងសីលធម៌ ទាំងខាងប្រាជ្ញាយ៉ាងសុខដុមរមនា និងណែនាំឲ្យគេយល់កាន់តែច្បាស់អំពីការទទួលខុសត្រូវ។ ត្រូវខិតខំបង្ហាត់គេដោយឥតឈប់ឈរ ឲ្យណែនាំការរស់នៅផ្ទាល់ខ្លួនយ៉ាងល្អប្រសើរ និងឲ្យគេមានសេរីភាពដ៏ពិតប្រាកដ ទាំងពុះពារឧបសគ្គទាំងអស់ ដោយចិត្តក្លាហាន និងចិត្តទូលាយ។

សូមអប់រំក្មេងៗ និងយុវជន យុវនារីអំពីរឿងភេទ ដោយគិតដល់តម្លៃដ៏ប្រសើរល្អរបស់ភេទ និងដោយប្រុងប្រយ័ត្នស្របតាមតែវ័យរបស់គេដែលចម្រើនតាមលំដាប់។ លើសពីនេះទៅទៀត ត្រូវអប់រំគេឲ្យចេះរស់នៅក្នុងសង្គម គឺឲ្យគេស្គាល់យ៉ាងសមរម្យ នូវបច្ចេកទេសដ៏ចាំបាច់នៃការរស់នៅក្នុងសង្គម។ ធ្វើដូច្នេះ គេអាចចូលរួមយ៉ាងសកម្មក្នុងក្រុមនានាដែលជាផ្នែកនៃសហគមន៍មនុស្សលោក។ គេក៏ចេះសន្ទនាជាមួយអ្នកដទៃ និងសុខចិត្តសហការ ដើម្បីជាប្រយោជន៍រួមដោយចិត្តរីករាយ។

មហាសន្និបាត ក៏ប្រកាសតាមរបៀបដដែលថា ក្មេងៗ និងយុវជន យុវនារី មានសិទ្ធិឲ្យមានគេដាស់តឿន ឲ្យ

ចេះថ្លឹងថ្លែងយ៉ាងត្រឹមត្រូវ អំពីតម្លៃដ៏ថ្លៃថ្នូរខាងសីលធម៌ ដោយមានមនសិការទៀងត្រង់ ព្រមទាំងឲ្យសុខចិត្តអនុវត្តតាមដោយចិត្តស្មោះ និងដោយខ្លួនឯង។ ក្មេងៗ និងយុវជន យុវនារី មានសិទ្ធិស្គាល់ ហើយស្រឡាញ់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងៗទៀតផង។ ហេតុនេះហើយ បានជាមហាសន្និបាតទទូច សូមឲ្យអស់លោកអ្នកដែលគ្រប់គ្រងប្រជាជននានា និងអស់លោកអ្នកដែលណែនាំការអប់រំ សូមកុំឲ្យយុវជនយុវនារីបាត់បង់សិទ្ធិដ៏សក្ការៈនេះជាដាច់ខាត។ មហាសន្និបាតក៏ដាស់តឿនបុត្រធីតានៃព្រះសហគមន៍ ឲ្យជួយក្នុងគ្រប់វិស័យនៃការអប់រំដោយចិត្តទូលាយ ជាពិសេសដើម្បីផ្សព្វផ្សាយយ៉ាងឆាប់រហ័សនូវលទ្ធផលដ៏ល្អនៃការអប់រំ និងនៃការបង្រៀនយ៉ាងសមរម្យ ដល់មនុស្សទាំងអស់ក្នុងពិភពលោកទាំងមូល។

## ២-ការអប់រំបែបគ្រីស្តសាសនា

គ្រីស្តបរិស័ទទាំងអស់ មានសិទ្ធិទទួលការអប់រំបែបគ្រីស្តសាសនា ព្រោះគេជាសត្វលោកថ្មី គេបានកើតជាថ្មីដោយទឹក និងដោយព្រះវិញ្ញាណ គេមានឈ្មោះជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយគេពិតជាបុត្រធីតាព្រះអង្គមែន។ ការអប់រំបែបគ្រីស្តសាសនា មិនគ្រាន់តែមានគោលដៅផ្តល់ឲ្យក្មេង និងយុវជន យុវនារី ជាបុគ្គលពេញវ័យដូចមានចែងខាងលើទេ តែចំពោះអ្នកដែលទទួលអគ្គញ្ញាជ្រមុជទឹក ការអប់រំបែបគ្រីស្តសាសនា មានគោលដៅណែនាំឲ្យគេ ទទួលចំណេះបន្តិចម្តងៗ អំពីគម្រោងការដ៏អស្ចារ្យនៃការសង្គ្រោះ និងឲ្យគេដឹងខ្លួនកាន់តែច្បាស់ជារៀងរាល់ថ្ងៃអំពីជំនឿ ជាព្រះអំណោយទាន ដែលគេបានទទួលនោះ។ ការអប់រំបែបគ្រីស្តសាសនា មានគោលដៅឲ្យគេបង្ហាត់ខ្លួន ឲ្យក្រាបប្រណិប័តន៍ព្រះជាម្ចាស់ជាព្រះបិតា តាមព្រះវិញ្ញាណ និងសេចក្តីពិត (យហ ៤, ២៣) ជាពិសេសដោយគេចូលក្នុងពិធីបុណ្យនានា។ មានគោលដៅឲ្យគេប្រែចិត្តគំនិត ដើម្បីណែនាំការរស់នៅដោយផ្ទាល់ខ្លួន ស្របតាមឋានៈរបស់ខ្លួនជាមនុស្សថ្មី ដោយសេចក្តីសុចរិត និងបែបវិសុទ្ធមកពីសេចក្តីពិត (អភ ៤, ២២-២៤)។ ធ្វើដូច្នេះ គេទៅជាមនុស្សដ៏ពេញលក្ខណៈនោះពេញវ័យឡើង ទៅដល់កម្ពស់របស់ព្រះគ្រីស្តដែលបំពេញអ្វីៗទាំងអស់ (អភ ៤, ១៣)។ គេក៏អាចរួមកម្លាំង ធ្វើឲ្យព្រះកាយដ៏អាថ៌កំបាំងរបស់ព្រះគ្រីស្តចម្រើនឡើងបាន។ លើសពីនេះទៅទៀត គេដឹងខ្លួនអំពីឧបនិស្ស័យរបស់ខ្លួន តាមព្រះជាម្ចាស់ត្រាស់ហៅគេ។ គេធ្លាប់ផ្តល់សក្ខីភាព អំពីសេចក្តីសង្ឃឹម ដែលស្ថិតនៅក្នុងគេ (១សល ៣, ១៥) គេក៏ជួយប្រែពិភពលោក តាមព្រះហឫទ័យព្រះគ្រីស្តដែរ។ ក្នុងការប្រែនេះ គេយកអ្វីៗដែលមានតម្លៃធម្មតា បញ្ចូលក្នុងទស្សនៈអំពីមនុស្សទាំងស្រុង ដែលព្រះគ្រីស្តបានរំដោះ គេក៏អាចរួមកម្លាំង ដើម្បីជាប្រយោជន៍ដល់សង្គមទាំងមូល (ពន្លឺ ៣៦)។ ហេតុនេះហើយ បានជាមហាសន្និបាតរំឭកអស់គង្វាល អំពីភារកិច្ចដ៏ធ្ងន់ធ្ងររបស់ខ្លួន គឺប្រើគ្រប់មធ្យោបាយ ឲ្យគ្រីស្តបរិស័ទទាំងអស់ ជាពិសេសយុវជន យុវនារី ដែលជាទីសង្ឃឹមនៃព្រះសហគមន៍ (អភិបាល ១២-១៤) ទទួលការអប់រំបែបគ្រីស្តសាសនានោះ។

## ៣-អ្នកទទួលខុសត្រូវលើការអប់រំ

ឪពុកម្តាយមានភារកិច្ចដ៏ធ្ងន់ធ្ងរបំផុតអប់រំកូនរបស់គាត់ ព្រោះគាត់បានផ្តល់ជីវិតឲ្យកូន។ ហេតុនេះ ត្រូវទទួលស្គាល់ឪពុកម្តាយទុកជាអ្នកអប់រំមុនគេ ហើយសំខាន់ជាងគេ។ ឪពុកម្តាយ មានមុខងារអប់រំកូនយ៉ាងសំខាន់បំផុត ប្រសិនបើគាត់មិនអប់រំកូនទេ ស្ទើរតែគ្មាននរណាអាចអប់រំជំនួសបាន។ ឪពុកម្តាយមានភារកិច្ចបង្កើតបរិយាកាសក្នុងក្រុមគ្រួសារ ដែលជួយការអប់រំរួមរបស់កូនៗ ទាំងក្នុងឋានៈជាបុគ្គលម្នាក់ៗ ទាំងក្នុងឋានៈជាសមាជិកនៃសង្គម ដោយមានសេចក្តីស្រឡាញ់ និងគោរពព្រះជាម្ចាស់ និងមនុស្សណែនាំ។ ហេតុនេះ ក្រុមគ្រួសារជាសាលារៀនទីមួយដែលអប់រំព្រហ្មវិហារធម៌ ដែលគ្រប់សង្គមត្រូវការ។ ប៉ុន្តែ ក្រុមគ្រួសារគ្រីស្តបរិស័ទ បានទទួលព្រះអំណោយទាន

និងកាតព្វកិច្ចជាច្រើន នៅពេលគេទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍។ ក្នុងក្រុមគ្រួសារនោះ កូនៗតាំងពីអាយុខ្ចីជាងគេ ត្រូវទទួលការអប់រំបង្ហាត់ខ្លួនឲ្យស្គាល់ព្រះជាម្ចាស់ និងគោរពបម្រើព្រះអង្គ ព្រមទាំងឲ្យស្រឡាញ់អ្នកដទៃ ស្របតាមជំនឿ ដែលគេបានទទួលនៅពេលទទួលអគ្គសញ្ញាជ្រមុជទឹក។ ក្នុងក្រុមគ្រួសារ កូនៗធ្វើបទពិសោធន៍ដើមដំបូង អំពីព្រះសហគមន៍ និងអំពីការរស់នៅក្នុងសង្គម ដែលមានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ។ ដោយក្រុមគ្រួសារ កូនៗចូលរួមក្នុងសហគមន៍មនុស្ស និងក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់បន្តិចម្តងៗ។ ហេតុនេះ សូមអ្នកជាឪពុក ជាម្តាយយល់ដឹងយ៉ាងជាក់ច្បាស់ថា ក្រុមគ្រួសារជាគ្រីស្តបរិស័ទដ៏ពិតប្រាកដ មានសារៈសំខាន់ជាខ្លាំង ដើម្បីឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់រស់នៅ និងចម្រើនឡើង (ពន្លឺ ១១ និង ៣៥)។

បន្ទុកអប់រំកូនៗ មុនដំបូងជាភារកិច្ចរបស់ក្រុមគ្រួសារ ប៉ុន្តែ ត្រូវសង្គមទាំងមូលជួយផងដែរ។ ឪពុកម្តាយមានសិទ្ធិ ហើយអ្នកអប់រំកូន គឺជាអ្នកដែលឪពុកម្តាយផ្ញើបន្ទុកអប់រំរបស់ខ្លួនមួយចំណែក ក៏មានសិទ្ធិដែរ។ ក៏ប៉ុន្តែ សង្គមដែលមានតួនាទីចាត់ចែងអ្វីៗតាមតម្រូវការរួម ដើម្បីជាប្រយោជន៍រួមតាមលោកីយ៍ ក៏ត្រូវទទួលខុសត្រូវ និងមានសិទ្ធិយ៉ាងច្បាស់លើការអប់រំកូនដែរ។ ក្នុងចំណោមបន្ទុកទាំងនោះ សង្គមមានភារកិច្ចលើកស្ទួយការអប់រំយុវជន យុវនារី តាមរបៀបជាច្រើន។ សង្គមធានារ៉ាប់រងភារកិច្ច និងសិទ្ធិឪពុកម្តាយ និងរបស់អ្នកឯទៀតៗ ដែលចូលរួមក្នុងការអប់រំ។ សង្គមក៏ជួយអ្នកទាំងនោះ តាមគោលដៅនោះ។ តាមគោលការណ៍ «អ្នកធំជួយជំនួសអ្នកតូចតែនៅពេលគេធ្វើមិនកើត» ប្រសិនបើ ឪពុកម្តាយមិនបំពេញមុខងាររបស់ខ្លួន ឬប្រសិនបើក្រុមឯទៀតៗមិនជួយទេនោះ គឺសង្គមត្រូវធានារ៉ាប់រងការអប់រំជំនួស ទាំងគិតគូរអំពីបំណងប្រាថ្នាឪពុកម្តាយដែរ។ លើសពីនេះទៅទៀត សង្គមត្រូវសាងសង់សាលារៀន និងស្ថាប័នអប់រំផ្ទាល់ តាមតែប្រយោជន៍រួមទាមទារឲ្យសងនោះ។

ព្រះសហគមន៍ ក៏ជាប់ទាក់ទិនយ៉ាងពិសេសនឹងបន្ទុកអប់រំទាំងនោះ ព្រោះថា ព្រះសហគមន៍ក៏ជាសង្គមម្យ៉ាងដែរ ហេតុនេះត្រូវទទួលស្គាល់ថា ព្រះសហគមន៍មានសមត្ថភាពក្នុងវិស័យអប់រំនោះ។ ជាពិសេស ព្រះសហគមន៍មានបន្ទុកប្រកាសអំពីមាគ៌ាឆ្ពោះទៅកាន់ការសង្គ្រោះដល់មនុស្សលោក ហើយមានបន្ទុកចែកចាយព្រះជន្មរបស់ព្រះគ្រីស្ត ឲ្យអ្នកផ្ញើជីវិតលើព្រះអង្គ ព្រមទាំងយកចិត្តទុកដាក់ឥតឈប់ឈរ ជួយឲ្យគេទៅដល់ជីវិតក្នុងអង្គព្រះគ្រីស្តនោះបានពេញលក្ខណៈ។ ហេតុនេះហើយ បានជាព្រះសហគមន៍ក្នុងឋានៈជាមាតា មានភារកិច្ចធានារ៉ាប់រងការអប់រំបុត្រធីតារបស់ខ្លួន ដែលណែនាំការរស់នៅរបស់គេ ដោយឲ្យមានគោលគំនិតរបស់ព្រះគ្រីស្ត ជ្រួតជ្រាបក្នុងចិត្តគំនិតគេ។ នៅពេលជាមួយគ្នានេះ ព្រះសហគមន៍ក៏សុខចិត្តរួមសហការជាមួយមនុស្សទាំងអស់ លើកស្ទួយតម្លៃដ៏ថ្លៃថ្នូររបស់បុគ្គលម្នាក់ៗ ឲ្យបានពេញលក្ខណៈ ហើយរកប្រយោជន៍សង្គមនៅលើផែនដីនេះ ព្រមទាំងកសាងពិភពលោក ដែលកាន់តែប្រកបដោយលក្ខណៈជាមនុស្សជាលំដាប់។

## ៤-ព្រះសហគមន៍មាននយោបាយផ្សេងៗដើម្បីអប់រំតាមគ្រីស្តសាសនា

ក្នុងកិច្ចការបំពេញបន្ទុកអប់រំរបស់ខ្លួន ព្រះសហគមន៍ខិតខំប្រើប្រាស់គ្រប់មធ្យោបាយដ៏សមគួរ តាមតម្រូវការជាពិសេសយកចិត្តទុកដាក់ប្រើមធ្យោបាយរបស់ខ្លួនផ្ទាល់។ មធ្យោបាយទីមួយ គឺអប់រំជំនឿ (អភិបាល ១៣ និង ១៤) ដែលបំភ្លឺ និងពង្រឹងជំនឿ ចិញ្ចឹមជីវិតតាមគោលគំនិតរបស់ព្រះគ្រីស្ត ហើយណែនាំគេឲ្យចូលរួមយ៉ាងសកម្ម និងដោយដឹងខ្លួនក្នុងគម្រោងការដ៏អស្ចារ្យនៃពីធីបុណ្យ (ពិធី ១៤) ព្រមទាំងដាស់តឿនគេឲ្យបំពេញកិច្ចការជាគ្រីស្តទូតទៀតផង។ ក៏ប៉ុន្តែ ព្រះសហគមន៍ក៏យកចិត្តទុកដាក់យ៉ាងខ្លាំងនឹងមធ្យោបាយអប់រំឯទៀតៗ មានមធ្យោបាយទំនាក់ទំនងក្នុងសង្គមជាដើម (ទរ ១៣ និង ១៤) មានអង្គការផ្សេងៗ ដែលមានគោលដៅអភិវឌ្ឍន៍ទាំងកាយ ទាំងវិញ្ញាណ មានចលនា

យុវជន យុវនារី ហើយជាពិសេសមានសាលារៀនទៀតផង។ មធ្យោបាយអប់រំទាំងនោះ ជាបេតិកភ័ណ្ឌរួមនៃមនុស្សជាតិ ដែលអាចជួយអប់រំវិញ្ញាណ និងចិត្តមនុស្ស។ ព្រះសហគមន៍ក៏ខិតខំយកគោលគំនិតរបស់ខ្លួន មកជ្រួតជ្រាបមធ្យោបាយអប់រំទាំងនោះ និងលើកយកឲ្យមានកម្រិតខ្ពស់។

## ៥-សារៈសំខាន់នៃសាលារៀន

សាលារៀនមានសារៈសំខាន់យ៉ាងពិសេស ក្នុងចំណោមមធ្យោបាយអប់រំឯទៀតៗទាំងអស់។ តាមបេសកកម្មរបស់ខ្លួន សាលារៀនជាកន្លែងព្យាយាមអភិវឌ្ឍសម្បទាខាងប្រាជ្ញា។ នៅពេលជាមួយគ្នានេះ សាលារៀនជួយបង្ហាត់កូនសិស្ស ឲ្យចេះវិនិច្ឆ័យថ្លឹងថ្លែងតម្លៃនៃអ្វីទាំងអស់ និងណែនាំគេឲ្យចូលក្នុងបេតិកភណ្ឌវប្បធម៌ ជាកេរមរតកពីដូនតាមក។ សាលារៀនលើកស្ទួយឲ្យកូនសិស្សយល់អំពីអ្វីៗ ដែលជាតម្លៃប្រចាំការរស់នៅ ព្រមទាំងរៀបចំគេឲ្យមានអាជីវកម្មនៅពេលក្រោយ។ សាលារៀនជួយបង្កើតឲ្យកូនសិស្សដែលមានចរិតលក្ខណៈ និងឋានៈវណ្ណប្លែកពីគ្នាក្នុងសង្គម រួបរួមជាមិត្តភ័ក្តិ និងណែនាំគេឲ្យយល់ចិត្តគំនិតគ្នាទៅវិញទៅមក។ លើសពីនេះទៅទៀត សាលារៀនហាក់ដូចជាមណ្ឌលមួយ គឺក្រុមគ្រួសារនានា លោកគ្រូ អ្នកគ្រូ ក្រុមផ្សេងៗដែលកើតមក ដើម្បីអភិវឌ្ឍជីវិតវប្បធម៌ ជីវិតប្រជាពលរដ្ឋ និងជីវិតសាសនា សង្គមស៊ីវិល និងសហគមន៍មនុស្សទាំងមូល អាចជួបជុំគ្នាដើម្បីចែកចាយខុសត្រូវក្នុងការចាត់ចែង និងការចម្រើននៃសាលារៀននោះ។

អស់អ្នកដែលអប់រំកូនសិស្សតាមសាលារៀន គឺជួយមាតាបិតាឲ្យបំពេញភារកិច្ចរបស់ខ្លួន និងជាតំណាងសហគមន៍មនុស្ស ពិតជាបំពេញមុខងារដ៏ប្រសើរ ប៉ុន្តែ ជាមុខងារដ៏ធ្ងន់ធ្ងរ តាមព្រះជាម្ចាស់ត្រាស់ហៅឲ្យបំពេញនោះ។ អ្នកបំពេញមុខងារនេះ ត្រូវមានគុណសម្បត្តិពិសេស ខាងផ្លូវចិត្ត និងខាងផ្លូវវិញ្ញាណ ត្រូវទទួលការអប់រំដោយយកចិត្តទុកដាក់ជាទីបំផុត និងត្រូវមានសម្បទាឲ្យផ្លាស់ប្រែជាថ្មី ដោយឥតឈប់ឈរ និងសម្រាប់ខ្លួនតាមតម្រូវការជានិច្ច។

## ៦- ភារកិច្ចនិងសិទ្ធិមាតាបិតា

មាតាបិតាមានភារកិច្ច និងសិទ្ធិអប់រំកូនរបស់ខ្លួន ជាសិទ្ធិដើមដំបូងមុនគេ ដែលដកចេញពីគាត់ មិនបានជាដាច់ខាត។ ហេតុនេះហើយ បានមាតាបិតាមានសេរីភាពយ៉ាងពិតប្រាកដ ក្នុងការជ្រើសរើសសាលារៀនសម្រាប់កូនរៀន។ រដ្ឋអំណាចមានតួនាទីការពារ និងរក្សាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ហេតុនេះ រដ្ឋអំណាចត្រូវទទួលខុសត្រូវលើយុត្តិធម៌ ដោយចែកចាយធនធានសាធារណៈ តាមរបៀបដែលមាតាបិតាមានសិទ្ធិសេរីភាពដ៏ពិតប្រាកដ ក្នុងជម្រើសសាលារៀនសម្រាប់កូន តាមមនសិការរបស់ខ្លួន។

រដ្ឋអំណាច ក៏មានតួនាទីប្រុងប្រយ័ត្នឲ្យប្រជាពលរដ្ឋទាំងអស់ មានលទ្ធភាពអាចទទួលចំណែកយ៉ាងពិតប្រាកដនៃផលដ៏ល្អនៃវប្បធម៌ និងរៀបចំខ្លួនតាមសេចក្តីត្រូវការឲ្យបំពេញភារកិច្ច និងប្រើសិទ្ធិរបស់ខ្លួនជាប្រជាពលរដ្ឋ។ ហេតុនេះ រដ្ឋអំណាចត្រូវធានាការពារសិទ្ធិរបស់ក្មេងៗ ឲ្យទទួលការអប់រំតាមសាលារៀនយ៉ាងសមស្របតាមតម្រូវការ។ រដ្ឋអំណាច ក៏ត្រូវប្រុងប្រយ័ត្នឲ្យលោកគ្រូអ្នកគ្រូមានសមត្ថភាពគ្រប់គ្រាន់ ហើយក៏ត្រូវប្រុងប្រយ័ត្នឲ្យសាលាមានកម្រិតសិក្សាល្មម ព្រមទាំងឲ្យកូនសិស្សមានសុខភាពល្អ។ ជាទូទៅ រដ្ឋអំណាចមានភារកិច្ចអភិវឌ្ឍន៍រចនាសម្ពន្ធនៃការសិក្សាទាំងមូល ដោយមិនបំភ្លេចគោលការណ៍ «អ្នកធំធ្វើការជំនួសអ្នកតូច តែនៅពេលដែលអ្នកតូចធ្វើមិនកើតប៉ុណ្ណោះ»។ ហេតុនេះ ត្រូវហាមមិនឲ្យនរណា ឬអង្គការណាមួយ ត្រួតលើរចនាសម្ពន្ធសិក្សាផ្តាច់មុខឡើយ។ អង្គការណា ឬក្រុមណាដែលត្រួតលើការសិក្សាផ្តាច់មុខបែបនោះ ពិតជាប្រឆាំងនឹងសិទ្ធិទាំងឡាយ ដែលបុគ្គលម្នាក់ៗមានតាំងពីកើតមក ហើយ

ក៏រាំងមិនឲ្យវប្បធម៌ចម្រើននិងត្រូវផ្សព្វផ្សាយបាន។ ការត្រួតផ្ដាច់មុខបែបនេះរាំងប្រជាពលរដ្ឋមិនឲ្យរស់នៅ ដោយសេចក្ដីសុខសាន្ត និងជំទាស់នឹងរបៀបរស់នៅតាមបែបប្លែកៗពីគ្នា ដូចតែងតែមានក្នុងសង្គមជាច្រើននាបច្ចុប្បន្នកាល។

ហេតុនេះហើយ បានជាមហាសន្និបាតដាស់តឿនគ្រីស្ដបរិស័ទ ឲ្យស្ម័គ្រចិត្តជួយតាមដាននិងគាំទ្រអ្វីៗ ដែលពាក់ព័ន្ធនឹងកិច្ចការក្នុងសាលារៀន មានការស្វែងរកវិធីគរុកោសល្យថ្មី និងមានការចាត់ចែងការសិក្សាឲ្យបានប្រសើរជាងពីមុន ហើយមានការហ្វឹកហ្វឺនលោកគ្រូអ្នកគ្រូ ដែលអាចអប់រំយុវជនយុវនារីជាដើម ជាពិសេស មានការអប់រំសីលធម៌ ដែលគ្រូត្រូវអប់រំនោះ។ គេអាចជួយយ៉ាងពិសេសបាន ដោយចូលរួមក្នុងសមាគមមាតាបិតាទ្រទ្រង់សាលា។

## ៧- ការអប់រំសីលធម៌ និងខាងសាសនានៅសាលារៀន

ព្រះសហគមន៍ដឹងខ្លួនអំពីភារកិច្ចដ៏ធ្ងន់ធ្ងររបស់ខ្លួន នឹងព្យាយាមយកចិត្តទុកដាក់អប់រំបុត្រធីតាទាំងអស់ផ្នែកខាងសីលធម៌ និងខាងសាសនា។ ហេតុនេះហើយ បានជាព្រះសហគមន៍ត្រូវតែមានវត្តមាន ដោយចិត្តស្រឡាញ់នៅក្បែរក្មេងៗជាច្រើនអនេក ដែលមិនទទួលការអប់រំក្នុងសាលារៀនកាតូលិក និងជួយគេយ៉ាងពិសេស។ ព្រះសហគមន៍មានវត្តមានបែបនេះ ដោយលោកគ្រូអ្នកគ្រូ និងនាយកសាលារៀនផ្ដល់សក្ខីភាព និងដោយមិត្តភ័ក្ដិរបស់ក្មេងៗទាំងនោះបំពេញកិច្ចការជាគ្រីស្ដទូត។ ព្រះសហគមន៍មានវត្តមានយ៉ាងពិសេស ដោយសារបូជាចារ្យនិងគ្រីស្ដបរិស័ទធម្មតា ដែលបញ្ជូនបន្ទូលទិព្វអំពីការសង្គ្រោះដល់ក្មេងទាំងនោះ ដោយប្រើវិធីសមស្របតាមអាយុក្មេងៗ និងស្របតាមសភាពការណ៍ ហើយដែលជួយគេខាងផ្លូវវិញ្ញាណ ដោយបង្កើតកិច្ចផ្សេងៗស្របតាមកាលៈទេសៈ និងទីកន្លែង។

ប៉ុន្តែ ព្រះសហគមន៍រំឭកមាតាបិតាអំពីភារកិច្ចដ៏ធ្ងន់ធ្ងររបស់ខ្លួន ដែលត្រូវឲ្យកូនៗអាចទទួលជំនួយខាងវិញ្ញាណទាំងនោះ និងឲ្យកូនៗអាចចម្រើនឡើងបាន ក្នុងការអប់រំតាមឋានៈរបស់ខ្លួនជាគ្រីស្ដបរិស័ទ ដូចគេចម្រើនឡើង ក្នុងការសិក្សាខាងផ្លូវលោកីយ៍។ ជូនកាលត្រូវទាមទារជំនួយទាំងនោះ។ ហេតុនេះហើយ បានជាព្រះសហគមន៍សរសើររដ្ឋអំណាច និងសង្គមស៊ីវិលទាំងប៉ុន្មាន ដែលយល់ដល់លក្ខណៈសង្គមទំនើបដែលមានរបៀបរស់នៅប្លែកពីគ្នាជាច្រើន ហើយដែលជួយក្រុមគ្រួសារឲ្យផ្ដល់ការអប់រំដល់កូនៗ ស្របតាមគោលការណ៍របស់មាតាបិតាត្រង់សីលធម៌ និងសាសនាក្នុងគ្រប់សាលារៀន។

## ៨- សាលារៀនកាតូលិក

ព្រះសហគមន៍សម្ដែងវត្តមានរបស់ខ្លួន ក្នុងវិស័យអប់រំយ៉ាងពិសេស ដោយសារសាលារៀនកាតូលិក។ សាលារៀនកាតូលិក ក៏ដូចសាលារៀនឯទៀតៗទាំងអស់ មានទិសដៅអប់រំយុវជនឲ្យស្គាល់វប្បធម៌ និងអប់រំឲ្យគេមានលក្ខណៈជាមនុស្សសុទ្ធសាធ។ លក្ខណៈពិសេសរបស់សាលារៀនកាតូលិក គឺបង្កើតបរិយាកាសប្រកបដោយសេរីភាព និងដោយសេចក្ដីស្រឡាញ់ ស្របតាមគោលគំនិតនៃដំណឹងល្អ ជូនសហគមន៍សិក្សា។ សាលារៀនកាតូលិក ក៏មានទិសដៅមួយទៀត គឺជួយធ្វើឲ្យបុគ្គលិកលក្ខណៈរបស់កូនជំទង់រីកចម្រើនឡើង ទាំងជួយឲ្យជីវិតថ្មី ដែលគេមានតាំងពីពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក ដុះឡើងកាន់តែខ្លាំងឡើងៗ។ សាលារៀនកាតូលិកក៏មានទិសដៅ តម្រង់វប្បធម៌ទាំងមូលរបស់មនុស្សលោក ទៅតាមការប្រកាសដំណឹងល្អអំពីការសង្គ្រោះ។ ដូច្នេះពន្លឺនៃជំនឿ មុខជានឹងបំភ្លឺចំណេះចេះដឹងរបស់កូនសិស្សអំពីពិភពលោក និងអំពីជីវិត ហើយអំពីមនុស្សទៀតផង។ សាលារៀនកាតូលិកក៏ទទួលស្គាល់ការចម្រើនរបស់មនុស្សលោកសម័យទំនើបយ៉ាងសមរម្យ ហើយអប់រំកូនសិស្សឲ្យខិតខំធ្វើការ ប្រកបដោយប្រសិទ្ធភាព ដើម្បីជាប្រយោជន៍ដល់លោកនេះដែរ។ នៅពេលជាមួយគ្នានោះ សាលារៀនកាតូលិក រៀបចំកូនសិស្សឲ្យព្រះជាម្ចាស់លាតសន្ធឹង

ព្រះរាជ្យរបស់ព្រះអង្គ។ ដោយគេបង្ហាត់ខ្លួនឲ្យរស់នៅតាមរបៀបជាគំរូ និងធ្វើកិច្ចការជាគ្រីស្តទូត គេដូចជាមេម្សៅនៃការសង្គ្រោះសម្រាប់មនុស្សជាតិ។

ក្នុងសភាពការណ៍យើងរស់នៅសព្វថ្ងៃ សាលារៀនកាតូលិកមានសារៈសំខាន់យ៉ាងខ្លាំង ព្រោះសាលារៀនកាតូលិកទាំងនោះ អាចជួយឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់បំពេញបេសកកម្មរបស់ខ្លួនឲ្យបានសម្រេច ព្រមទាំងអាចជួយឲ្យព្រះសហគមន៍និយាយសន្ទនាជាមួយសហគមន៍មនុស្សលោក ដើម្បីជាប្រយោជន៍ដល់សហគមន៍ទាំងពីរ។ ហេតុនេះហើយ បានជាមហាសន្និបាតប្រកាសម្តងទៀតថា ព្រះសហគមន៍មានសិទ្ធិតែងតាំង និងណែនាំសាលារៀនគ្រប់យ៉ាង និងគ្រប់កម្រិត ដូចក្រុមអ្នកបង្រៀនព្រះសហគមន៍ធ្លាប់ប្រកាសបញ្ជាក់ក្នុងឯកសារជាច្រើនរួចហើយ។ មហាសន្និបាតរំឭកថាសិទ្ធិនេះ ជាប់ពាក់ព័ន្ធជាមួយសិទ្ធិសេរីភាពនៃមនសិការរបស់មនុស្ស និងធានារ៉ាប់រងសិទ្ធិមាតាបិតា ព្រមទាំងពាក់ព័ន្ធជាមួយការចម្រើននៃវប្បធម៌ដែរ។

ប៉ុន្តែ សូមអស់លោកគ្រូអ្នកគ្រូ កុំភ្លេចថា សាលារៀនកាតូលិកអាចបំពេញតួនាទីតាមគោលដៅ និងតាមគម្រោងការរបស់ខ្លួនបាន អាស្រ័យតែលើលោកគ្រូអ្នកគ្រូតែម្តង។ ហេតុនេះ សូមយកចិត្តទុកដាក់ហ្វឹកហ្វឺនលោកគ្រូអ្នកគ្រូយ៉ាងពិសេស ឲ្យមានចំណេះចេះដឹងទាំងខាងផ្លូវលោក ទាំងខាងផ្លូវសាសនា ដោយមានសញ្ញាប័ត្រតាមសមគួរ ព្រមទាំងឲ្យគេចេះបង្រៀនតាមគរុកោសល្យ ស្របតាមអ្វីដែលមានរកឃើញថ្មីៗនោះ។ សូមលោកគ្រូអ្នកគ្រូរួបរួមគ្នា និងរួបរួមជាមួយសិស្សានុសិស្សរបស់ខ្លួនដោយចំណងនៃសេចក្តីស្រឡាញ់។ សូមឲ្យគំនិតជាគ្រីស្តទូតជ្រួតជ្រាបក្នុងចិត្តគំនិតលោកគ្រូអ្នកគ្រូ ដើម្បីឲ្យគេផ្តល់សក្ខីភាពថ្វាយព្រះគ្រីស្តជាព្រះបរមគ្រូ ដោយការរស់នៅនិងដោយការបង្រៀនរបស់ខ្លួន។ សូមអស់លោកអ្នករួមសហការគ្នា ជាពិសេសសហការជាមួយមាតាបិតារបស់សិស្ស។ ពេលលោកគ្រូអ្នកគ្រូអប់រំកូនៗ ដោយរួមជាមួយមាតាបិតា សូមចាប់អារម្មណ៍អំពីភេទកូនសិស្ស អំពីព្រះជាម្ចាស់ដែលថែរក្សាណែនាំមនុស្សលោក គឺព្រះអង្គបានត្រាស់ហៅបុរស និងស្ត្រីឲ្យបំពេញមុខងារប្លែកៗពីគ្នាក្នុងក្រុមគ្រួសារ និងក្នុងសង្គម។ សូមលោកគ្រូអ្នកគ្រូយកចិត្តទុកដាក់ណែនាំកូនសិស្ស ឲ្យចេះសម្រេចសេចក្តីនិងប្រព្រឹត្តកិច្ចការដោយខ្លួនឯងផង។ ពេលកូនសិស្សចប់ការសិក្សារួចហើយ លោកគ្រូអ្នកគ្រូក៏ត្រូវនៅទាក់ទងជាមួយគេដោយផ្តល់ពាក្យទូន្មាន និងដោយសេចក្តីស្រឡាញ់។ លោកគ្រូអ្នកគ្រូក៏ត្រូវជួយគេដោយបង្កើតសមាគមពិសេស ដែលមានគំនិតជ្រួតជ្រាបដោយវិញ្ញាណដ៏ពិតប្រាកដរបស់ព្រះសហគមន៍ទៀតផង។ មហាសន្និបាតប្រកាសថា ប្រសិនបើលោកគ្រូអ្នកគ្រូយល់ឃើញ អំពីមុខងារបង្រៀនរបស់ខ្លួនតាមបែបនេះ មុខងារជាលោកគ្រូអ្នកគ្រូ ពិតជាបំពេញកិច្ចការជាគ្រីស្តទូតយ៉ាងជាក់ច្បាស់មែន ជាមុខងារដ៏ចាំបាច់បំផុត និងស្របតាមសម័យឥឡូវ។ អ្នកបង្រៀនកូនៗ ពិតជាបម្រើសង្គមយ៉ាងពិតប្រាកដមែន។ មហាសន្និបាតសូមរំឭកមាតាបិតាកាតូលិកថា គាត់មានភារកិច្ចផ្ញើកូនៗឲ្យសាលារៀនកាតូលិក ប្រសិនបើគាត់អាចធ្វើបាននៅកន្លែងគាត់។ គាត់ក៏មានភារកិច្ចទ្រទ្រង់សាលារៀនកាតូលិកទាំងនោះ តាមធនធានរបស់ខ្លួន ព្រមទាំងសហការជាមួយសាលារៀនទាំងនោះ ដើម្បីជាប្រយោជន៍ដល់កូនៗទៀតផង។

### ៩-មានសាលារៀនកាតូលិកប្លែកៗពីគ្នា

សូមឲ្យសាលារៀនទាំងប៉ុន្មា នដែលនៅក្រោមឱវាទនៃព្រះសហគមន៍តាមបែបណាក៏ដោយ ខិតខំតោងទៅកាន់ឧត្តមគតិនេះ ទោះបីមានសភាពកាណ៍ប្លែកៗពីគ្នាតាមកាលៈទេសៈ និងតាមកន្លែងយ៉ាងណាក៏ដោយ។ ព្រះសហគមន៍ស្រឡាញ់យ៉ាងខ្លាំងសាលារៀនទាំងប៉ុន្មាន ដែលទទួលកូនសិស្សដែលមិនមែនជាកាតូលិក ជាពិសេសនៅតំបន់មនុស្សភាគច្រើនមិនស្គាល់ព្រះគ្រីស្ត។

ពេលតែងតាំង និងចាត់ចែងសាលារៀនកាតូលិក ត្រូវគិតគូរដល់តម្រូវការនៃការវិវឌ្ឍន៍នាសម័យរបស់យើងនេះ។ ដូច្នេះ ទោះបីត្រូវនៅចាប់អារម្មណ៍នឹងសាលាបឋមសិក្សា និងវិទ្យាល័យដែលជាមូលដ្ឋាននៃការអប់រំក្តី ក៏ត្រូវយកចិត្តទុកដាក់នឹងការសិក្សាតាមសភាពការណ៍បច្ចុប្បន្នទាមទារ ឧបមាថា ត្រូវការសាលាបច្ចេកទេស និងសាលាបណ្តុះបណ្តាលអាជីវកម្ម ត្រូវការគ្រឹះស្ថានសម្រាប់បង្រៀនអក្សរដល់មនុស្សពេញវ័យ គ្រឹះស្ថានពិសេសសម្រាប់ទទួលក្មេងៗអនាថាក្រៅសង្គម ត្រូវការសាលាអប់រំគ្រូដែលបង្រៀនគ្រូឲ្យចេះបង្រៀនសាសនា ឬអប់រំតាមរបៀបផ្សេងទៀត។ល។

ហេតុនេះហើយ បានជាមហាសន្និបាតអញ្ជើញយ៉ាងក្លៀវក្លា អស់គង្វាលនិងគ្រីស្តបរិស័ទទាំងអស់ មិនឲ្យសំចៃកម្លាំងក្នុងការជួយសាលារៀនកាតូលិកឲ្យបំពេញបន្ទុករបស់ខ្លួនកាន់តែស្មោះជារៀងរាល់ថ្ងៃ គឺមុនដំបូងឲ្យតបឆ្លើយនឹងសេចក្តីត្រូវការរបស់អស់អ្នកដែលគ្មានធនធាន ឬជនដែលគ្មាននរណារាប់រក គ្មានក្រុមគ្រួសារទ្រទ្រង់ ឬដែលមិនស្គាល់ជំនឿយើង។

## ១០-មហាវិទ្យាល័យនិងសកលវិទ្យាល័យកាតូលិក

ព្រះសហគមន៍យកចិត្តទុកដាក់យ៉ាងពិសេសលើឧត្តមសិក្សា ជាពិសេសលើសកលវិទ្យាល័យនិងមហាវិទ្យាល័យ។ ព្រះសហគមន៍មានបំណងចាត់ចែងសកលវិទ្យាល័យ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន តាមរបៀបស្របតាមប្រាជ្ញា គឺត្រូវធ្វើការតាមមុខវិជ្ជានីមួយៗ ស្របតាមគោលការណ៍និងតាមកម្មវិធីពិសេសនៃមុខវិជ្ជានោះ ដោយមានសេរីភាពពេញទីជាលក្ខណៈផ្ទាល់នៃការស្រាវជ្រាវតាមវិទ្យាសាស្រ្ត។ ធ្វើដូច្នេះ ទើបគេអាចមានចំណេះនៃវិទ្យានោះកាន់តែជ្រៅទៅៗ និងគ្រប់គ្រងវិជ្ជានោះបានផង។ ត្រូវសិក្សាយ៉ាងហ្មត់ចត់នូវបញ្ហាថ្មីៗនិងការស្រាវជ្រាវថ្មីៗ ដែលកើតមកពីការចម្រើនរបស់មនុស្សលោកទំនើប។ ត្រូវយល់កាន់តែច្បាស់អំពីរបៀបជំនឿ និងប្រាជ្ញារួមភ្ជាប់ជាមួយគ្នា ដើម្បីតម្រង់ទៅកាន់សេចក្តីពិតតែមួយ។ ធ្វើដូច្នេះ ទើបអ្នកប្រាជ្ញដើរតាមមាគ៌ារបស់គ្រូបាធ្យាយនៃព្រះសហគមន៍កាលពីមុន ជាពិសេសរបស់សន្តៈថូម៉ាស នៅអាឃីណូ។ ដូច្នេះ គោលគំនិតតាមគ្រីស្តសាសនា ហាក់ដូចជាមានវត្តមានជាសាធារណៈ ដែលនៅស្ថិតស្ថេរ និងសកលទៀត ក្នុងការខិតខំរបស់អ្នកប្រាជ្ញដែលឈានទៅកាន់វប្បធម៌កម្រិតខ្ពង់ខ្ពស់បំផុត។ ត្រូវអប់រំនិស្សិត នៅគ្រឹះស្ថានទាំងនោះឲ្យស្ទាត់ជំនាញ ដោយចំណេះចេះដឹងរបស់ខ្លួន និងឲ្យប្រុងខ្លួនទទួលបន្ទុកដ៏ធ្ងន់ជាងគេក្នុងសង្គម ព្រមទាំងឲ្យទៅជាសាក្សីអំពីជំនឿក្នុងពិភពលោកនេះផងដែរ។

ក្នុងសកលវិទ្យាល័យ ដែលគ្មានមហាវិទ្យាល័យបង្រៀនទេវវិទ្យា ត្រូវឲ្យមានគ្រឹះស្ថាន ឬអាសនៈបង្រៀនទេវវិទ្យាសម្របតាមសេចក្តីត្រូវការរបស់និស្សិតជាគ្រីស្តបរិស័ទធម្មតា។ វិទ្យាសាស្ត្រតែងតែចម្រើនឡើង ដោយការស្រាវជ្រាវឯកទេសដែលមានឥទ្ធិពលយ៉ាងខ្លាំងតាមវិទ្យាសាស្ត្រ។ ហេតុនេះ សូមឲ្យសាកលវិទ្យាល័យកាតូលិក ជួយយ៉ាងទូលំទូលាយដល់គ្រឹះស្ថាន ដែលមានគោលដៅទីមួយលើកស្ទួយការស្រាវជ្រាវតាមវិទ្យាសាស្ត្រ។

មហាសន្និបាតផ្តែផ្តាំយ៉ាងខ្លាំង ឲ្យពង្រីកសកលវិទ្យាល័យនិងវិទ្យាល័យកាតូលិក ដែលត្រូវចាត់ចែងយ៉ាងសមរម្យនៅគ្រប់កន្លែងក្នុងពិភពលោកទាំងមូល។ សូមឲ្យសកលវិទ្យាល័យ និងវិទ្យាល័យកាតូលិកមានឈ្មោះល្បី មិនមែនមកពីមានចំនួនច្រើនទេ តែដោយការបង្រៀនក្នុងសកលវិទ្យាល័យ និងវិទ្យាល័យកាតូលិកទាំងនោះមានគុណភាពល្អវិញ។ សូមជួយនិស្សិតដែលមានប្រាជ្ញាអាចមានលទ្ធភាពរៀនខ្ពង់ខ្ពស់បាន ទោះបីគេក្រីក្រក៏ដោយ ជាពិសេសប្រសិនបើនិស្សិតទាំងនោះកើតមកនៅប្រជាជាតិកំពុងអភិវឌ្ឍន៍។

ដោយអនាគតព្រះសហគមន៍ និងអនាគតសង្គមជាប់យ៉ាងស្អិតល្មួតនឹងការចម្រើនរបស់យុវជនយុវនារី ដែលរៀន

ខាងឧត្តមសិក្សា អស់លោកអភិបាលនៃព្រះសហគមន៍ មិនគ្រាន់តែត្រូវយកចិត្តទុកដាក់ដោយឥតសំចៃនូវការរស់នៅតាមព្រះវិញ្ញាណរបស់និស្សិតនៃសកលវិទ្យាល័យកាតូលិកប៉ុណ្ណោះទេ តែត្រូវយកចិត្តទុកដាក់ ដល់ការអប់រំកូនចៅទាំងអស់ខាងផ្លូវព្រះវិញ្ញាណដែរ។ ហេតុនេះហើយ បានជាអស់លោកអភិបាលត្រូវពិគ្រោះគ្នា បង្កើតគ្រឹះស្ថាននិស្សិត ឬមណ្ឌលសកលវិទ្យាល័យកាតូលិក នៅក្បែរសកលវិទ្យាល័យដែលមិនមែនជាកាតូលិក។ នៅកន្លែងទាំងនោះ ត្រូវមានបូជាចារ្យ បព្វជិតបព្វជិតា និងគ្រីស្តបរិស័ទធម្មតា ដែលគេបានជ្រើសរើសយ៉ាងពិសេស និងដែលបានទទួលការអប់រំដើម្បីជួយយុវជនយុវនារីជានិស្សិត ទាំងខាងការសិក្សា ទាំងខាងជីវិតតាមព្រះវិញ្ញាណ។ ប្រសិនបើយុវជនយុវនារី ដែលមានប្រាជ្ញាឆ្លាតវាងវៃជាងគេ ក្នុងសកលវិទ្យាល័យកាតូលិក ឬក្នុងសកលវិទ្យាល័យឯទៀតៗ មានទេពកោសល្យ អាចបង្រៀន និងអាចស្រាវជ្រាវបាន ត្រូវជួយគេយ៉ាងពិសេស។ ត្រូវដាស់តឿនគេឲ្យទៅជាសាស្ត្រាចារ្យទៀតផង។

## ១១-មហាវិទ្យាល័យខាងទេវវិទ្យា

ព្រះសហគមន៍ពឹងលើសកម្មភាពនៃមហាវិទ្យាល័យបង្រៀនវិទ្យាសាស្ត្រដ៏សក្ការៈ។ ព្រះសហគមន៍តែងតែធ្វើឲ្យមហាវិទ្យាល័យអប់រំនិស្សិតរបស់ខ្លួន គឺមិនគ្រាន់តែរៀបចំគេឲ្យទៅជាបូជាចារ្យប៉ុណ្ណោះទេ តែជាពិសេសឲ្យគេអាចបង្រៀនតាមអាសនៈឧត្តមសិក្សានៃព្រះសហគមន៍ទៀតដែរ និងឲ្យស្រាវជ្រាវដោយខ្លួនឯងខាងវិទ្យាសាស្ត្រព្រមទាំងឲ្យបំពេញបន្ទុកក្នុងកិច្ចការជាគ្រីស្តទូតក្នុងចំណោមបញ្ញវ័ន្ត ជាបន្ទុកទាមទារឲ្យគេមានចំណេះយ៉ាងខ្ពស់។ មហាវិទ្យាល័យនៃទេវវិទ្យាមានតួនាទីសិក្សា តាមមុខវិទ្យាផ្សេងៗនៃវិទ្យាដ៏សក្ការៈ ដើម្បីឲ្យព្រះសហគមន៍យល់កាន់តែជ្រៅទៅៗ នូវសេចក្តីដែលព្រះជាម្ចាស់បានសម្តែងមក។ មហាវិទ្យាល័យមានតួនាទី បើកផ្លូវឲ្យមនុស្សលោកអាចចូលទៅកាន់បេតិកភណ្ឌនៃប្រាជ្ញារបស់គ្រីស្តសាសនាជាមរតកពីដូនតាមក។ មហាវិទ្យាល័យក៏មានតួនាទី លើកស្ទួយការសន្ទនាជាមួយបងប្អូនដែលបែកចេញពីយើង និងជាមួយអ្នកដែលគ្មានជំនឿ ព្រមទាំងផ្តល់ចម្លើយយ៉ាងសមរម្យ ស្របតាមសំណួរដែលវិទ្យាសាស្ត្រចោទឡើង។

ហេតុនេះ មហាវិទ្យាល័យនៃព្រះសហគមន៍ ត្រូវកែសម្រួលធម្មនុញ្ញរបស់ខ្លួនតាមតម្រូវការ ហើយពង្រីកវិទ្យាដ៏សក្ការៈយ៉ាងខ្លាំង និងពង្រីកមុខវិទ្យាដែលភ្ជាប់នឹងវិទ្យាដ៏សក្ការៈទាំងនោះ។ មហាវិទ្យាល័យក៏ត្រូវប្រើវិធីទំនើបបំផុត មកអប់រំនិស្សិតឲ្យចេះស្រាវជ្រាវសេចក្តីយ៉ាងជ្រៅ។

## ១២-ការរួមសហការក្នុងវិស័យសាលារៀន

សព្វថ្ងៃ នៅភូមិភាគនានា និងក្នុងប្រជាជាតិ ហើយនៅក្នុងសហប្រជាជាតិ ត្រូវសហការគ្នាកាន់តែសកម្មឡើងៗ។ ក្នុងវិស័យសិក្សាក៏ត្រូវសហការដែរ។ ហេតុនេះ ត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងឲ្យសាលារៀនកាតូលិករួមសហការគ្នា និងពង្រឹងសហការជាមួយសាលារៀនឯទៀតៗដែរ តាមតែប្រយោជន៍រួមរបស់មនុស្សជាតិទាំងមូលទាមទារ។

ការសហការកាន់តែខ្លាំង និងការខិតខំធ្វើការរួមគ្នេនេះ មុខជានឹងផ្តល់លទ្ធផលកាន់តែច្រើនឡើង ជាពិសេសនៅគ្រឹះស្ថានកម្រិតឧត្តមសិក្សា។ សូមឲ្យមហាវិទ្យាល័យទាំងប៉ុន្មានក្នុងគ្រប់សកលវិទ្យាល័យ ជួយគ្នាទៅវិញទៅមក តាមតែឯកទេសនៃមុខវិជ្ជានីមួយៗអនុញ្ញាតឲ្យ។ លើសពីនេះទៅទៀត សកលវិទ្យាល័យទាំងប៉ុន្មានត្រូវព្រមព្រៀងគ្នា បង្រួមសកម្មភាពនានារបស់ខ្លួន និងរួមគ្នាចាត់ចែងប្រជុំអន្តរជាតិ ចែកចាយការស្រាវជ្រាវតាមវិស័យផ្សេងៗនៃវិទ្យាសាស្ត្រព្រមទាំងផ្តល់ដំណឹងទៅវិញទៅមកអំពីអ្វីៗដែលគេរកឃើញ ផ្លាស់ប្តូរសាស្ត្រាចារ្យមួយរយៈពេលទៅវិញទៅមក គឺពង្រីកអ្វីៗទាំងអស់ដែលអាចជួយឲ្យសហការកាន់តែខ្លាំងឡើងៗ។

# ពាក្យបញ្ចប់

មហាសន្និបាតដាស់តឿនយុវជនយុវនារីយ៉ាងខ្លាំង សូមដឹងខ្លួនអំពីតម្លៃដ៏ខ្ពង់ខ្ពស់របស់ការងារបង្រៀន។ ចូរប្រុងខ្លួនបំពេញការងារនេះដោយចិត្តក្លាហាន និងដោយចិត្តទូលាយ ជាពិសេសនៅតំបន់ដែលខ្វះគ្រូ ហើយដែលក្មេងៗមិនអាចរៀនបានទេ។

មហាសន្និបាតសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះបូជាចារ្យ បព្វជិតបព្វជិតា គ្រីស្តបរិស័ទធម្មតា ដែលមានចិត្តលះបង់តាមដំណឹងល្អ និងយកចិត្តទុកដាក់បង្រៀនអប់រំគេ នៅសាលារៀនគ្រប់ប្រភេទ និងគ្រប់កម្រិត។ការបង្រៀនពិតជាកិច្ចការដ៏ប្រសើរជាងគេបំផុត។ មហាសន្និបាតក៏លើកទឹកចិត្តអ្នកទាំងនោះឲ្យបន្តបំពេញបន្ទុកនេះដោយចិត្តទូលាយ។ សូមខិតខំឲ្យបានប្រសើរជាងគេ ដោយមានបំណងឲ្យគោលគំនិតធ្វើឲ្យព្រះគ្រីស្តជ្រួតជ្រាបក្នុងចិត្តគំនិតកូនសិស្ស ដោយមានគរុកោសល្យល្អ និងដោយសិក្សាវិទ្យាសាស្ត្រ។ ដូច្នេះ គេមិនគ្រាន់តែជួយព្រះសហគមន៍ឲ្យប្រែជាថ្មីពីខាងក្នុងប៉ុណ្ណោះទេ តែគេពង្រឹងនិងបម្រើវត្តមានដ៏សប្បុរសរបស់ព្រះសហគមន៍ក្នុងពិភពលោកនាបច្ចុប្បន្ននេះ ជាពិសេសក្នុងវិស័យវប្បធម៌។

អស់លោកអភិបាលដែលរួមក្នុងមហាសន្និបាត ពេញចិត្តនឹងសេចក្តីប្រកាសទាំងមូលនេះ ហើយនឹងគោលការណ៍នីមួយៗផង។ រីឯយើងវិញ ស្របតាមអំណាចដែលព្រះគ្រីស្តបានប្រគល់ឲ្យយើងក្នុងឋានៈជាគ្រីស្តទូត រួមជាមួយអស់លោកអភិបាលដោយមានព្រះវិញ្ញាណរួមជាមួយផង ក៏យល់ព្រម ហើយសម្រេចចេញជាក្រឹត្យក្រមដែរ។ យើងបង្គាប់ឲ្យសេចក្តីដែលមហាសន្និបាតបានចាត់ចែងនេះត្រូវផ្សព្វផ្សាយ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ជានិច្ចនិរន្តរ៍តរៀងទៅ។

ធ្វើនៅក្រុងរ៉ូម នៅព្រះវិហារសន្តៈ សិលា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៦៥

ខ្ញុំប៉ូល អភិបាលនៃព្រះសហគមន៍កាតូលិក

( ហត្ថលេខារបស់លោកអភិបាល )

# សារនៃមហាសន្និបាត

## នៅថ្ងៃបញ្ចប់

## ថ្ងៃទី៨ ធ្នូ ១៩៦៥

### ពាក្យផ្ដើម

អស់លោកអភិបាលជាបងប្អូនដ៏ជាទីគោរពសក្ការៈ ដល់ពេលអស់លោកត្រូវចាកចេញ និងបែកខ្ញែកទៅក្នុងពិភពលោកទាំងមូល។ បន្ដិចទៀត អស់លោកចេញពីអង្គមហាសន្និបាត ទៅជួបមនុស្សជាតិ និងប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ដ។ យើងរួមគ្នាអស់បួនឆ្នាំមកហើយ យើងខិតខំរិះគិតកែសម្រួលព្រះសហគមន៍ឲ្យបានជាថ្មី។ អស់លោកក៏នឹងយកដំណឹងល្អអំពីព្រះសហគមន៍របស់ព្រះគ្រីស្ដ ដែលកែសម្រួលជាថ្មីនោះទៅជូនដល់គេ។

ពេលនេះ ពិតជាពេលនៃប្រវត្តិសាស្ត្រដ៏មានអត្ថន័យខ្ពង់ខ្ពស់រកអ្វីមកប្រៀបផ្ទឹមមិនបាន។ អង្គប្រជុំសកលនេះ ពិតជាពេល និងជាកន្លែងដ៏អស្ចារ្យមែន គឺអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលបានជួបជុំគ្នា។ យើងនឹកអំពីអតីតកាល ព្រោះព្រះសហគមន៍របស់ព្រះគ្រីស្ដរួបរួមគ្នានៅទីនេះ ដោយមានប្រពៃណីរបស់ខ្លួន មានប្រវត្តិសាស្ត្រ មានមហាសន្និបាតនានាពីសម័យមុនៗមក មានគ្រូបាធ្យាយ មានសន្តបុគ្គល។ល។ រួមគ្នានៅទីនេះ។ យើងនឹកគិតអំពីបច្ចុប្បន្នកាល ព្រោះយើងបែកចេញពីគ្នាទៅកាន់មនុស្សលោកយើងសព្វថ្ងៃ ដែលជួបការលំបាក ដែលកើតទុក្ខវេទនា ដែលជាប់នឹងអំពើបាប។ល។ តែមនុស្សលោកនេះ ក៏ចម្រើនឡើងយ៉ាងអស្ចារ្យ និងកាន់តាមគោលការណ៍របស់ខ្លួន ដែលមានតម្លៃដ៏ថ្លៃថ្នូរ ហើយក៏មានគុណធម៌របស់ខ្លួនដែរ។ល។ យើងនឹកដល់អនាគតកាល ព្រោះប្រជាជននានាបន្លឺសំឡេងយ៉ាងខ្លាំង ទាមទារយុត្តិធម៌ ចង់បានសន្តិភាព ទោះបីគេដឹងខ្លួនក្ដី ឬមិនដឹងខ្លួនក្ដី ក៏គេនៅតែស្រេកឃ្លានចង់បានជីវិតដ៏ប្រសើរជាងពីមុន គឺគេច្បាស់ជាស្រេកឃ្លាន ចង់បានជីវិតដែលព្រះសហគមន៍របស់ព្រះគ្រីស្ដអាច និងមានបំណងចង់ផ្ដល់ឲ្យគេនោះ។

យើងហាក់ដូចជាឮសម្រែកយ៉ាងខ្លាំងនេះ ពីគ្រប់កន្លែងក្នុងពិភពលោកទាំងមូល តែជាសម្រែកមិនច្បាស់ គឺអស់អ្នកដែលសម្លឹងមើលមកមហាសន្និបាត សួរយើងទាំងខ្វល់ខ្វាយក្នុងចិត្តថា តើអស់លោកមានសេចក្ដីមួយណា មកប្រាប់យើង ឬក៏អត់? តើអស់លោកមានសេចក្ដីមួយណាមកប្រាប់យើង ជាអ្នកណែនាំប្រទេសឬក៏អត់? តើអស់លោកមានសេចក្ដីមួយណាមកប្រាប់យើងជាបញ្ញវន្ត ជាពលករ ជាសិល្បករ។ល។ ឬក៏អត់? តើអស់លោកមានសេចក្ដីមួយណាមកប្រាប់យើងជាស្ត្រីឬក៏អត់? តើអស់លោកមានសេចក្ដីមួយណាមកប្រាប់យើងជាយុវជនយុវនារី ជាអ្នកមានជំងឺ ជាអ្នកក្រីក្រឬក៏អត់?

យើងមានបំណងចង់តបឆ្លើយនឹងពាក្យអង្វរទាំងនោះ ហេតុដូច្នេះហើយ មហាសន្និបាតខិតខំរិះគិតអស់រយៈពេល

បួនឆ្នាំមកហើយ ដើម្បីជាប្រយោជន៍ដល់ក្រុមទាំងនោះ។ មហាសន្និបាតបានតែង *"ធម្មនុញ្ញអំពីព្រះសហគមន៍ ក្នុងពិភពលោកនាបច្ចុប្បន្ន"* ជាឯកសារដែលយើងបានប្រកាសផ្សព្វផ្សាយពីម្សិលមិញ ដោយអង្គប្រជុំទះដៃអបអរសាទរ ទាំងរំភើបចិត្តផង។

យើងបាននឹកស្មឹងស្មាធ៏អំពីព្រះគ្រីស្ត និងអំពីព្រះសហគមន៍របស់ព្រះអង្គយ៉ាងយូរ។ ពីការស្មឹងស្មាធ៏នោះ មានចេញសារដើមដំបូងនៅពេលនេះ។ សារនេះនាំដំណឹងអំពីសន្តិភាព និងអំពីការសង្គ្រោះសម្រាប់មនុស្សច្រើនឥតគណនាដែលកំពុងតែរង់ចាំ។ មុនបែកចេញពីគ្នា មហាសន្និបាតចង់បំពេញមុខងាររបស់ខ្លួនជាព្យាការី ដោយប្រកាសសារខ្លីៗតាមភាសាសាមញ្ញ ដែលមនុស្សទាំងអស់ស្រួលស្តាប់ អំពីដំណឹងល្អដែលមហាសន្និបាតសូមជូនដល់មនុស្សលោក។ មានតំណាងដ៏ប្រសើរនៃមហាសន្និបាត នឹងប្រកាសក្នុងនាមយើងចំពោះមនុស្សជាតិទាំងមូល។

# សារគោរពជូនចំពោះអស់លោកអ្នកដឹកនាំប្រទេស

នៅក្នុងពេលដ៏មហាឱឡារិកនេះ យើងសូមគោរពជូនទាំងមានសេចក្ដីសង្ឃឹម មកអស់លោកអ្នកដែលកាន់វាសនារបស់មនុស្សលោកនៅលើផែនដីនេះ គឺអស់លោកអ្នកដែលកាន់អំណាចលោកីយ៍។ យើងជាអភិបាលដែលជួបជុំគ្នា ក្នុងមហាសន្និបាតសកល លើកទី២១ នៃព្រះសហគមន៍កាតូលិក នៅពេលហៀបនឹងបែកខ្ញែងគ្នា ក្រោយពីបានខិតខំរិះគិតអស់បួនឆ្នាំមកហើយ។ យើងសូមគោរពជូនសារនេះ ដោយដឹងខ្លួនយ៉ាងច្បាស់ អំពីបេសកកម្មរបស់យើង ចំពោះមនុស្សជាតិ។

យើងសូមប្រកាសយ៉ាងជាក់ច្បាស់ថា យើងគោរពអំណាច និងភាពជាម្ចាស់ការរបស់អស់លោកអ្នក។ យើងក៏គោរពមុខងារដ៏ប្រសើររបស់អស់លោកអ្នកដែរ យើងទទួលស្គាល់ច្បាប់ដ៏ត្រឹមត្រូវរបស់អស់លោកអ្នក។

យើងរាប់អស់លោកអ្នកដែលបង្កើតច្បាប់ និងអស់លោកអ្នកដែលអនុវត្តតាមច្បាប់ទាំងនោះទុកថា មានតម្លៃផងដែរ។ ក៏ប៉ុន្តែ យើងសូមជម្រាបជូនអស់លោកអ្នក នូវសេចក្ដីមួយដ៏សក្ការៈបំផុតដែលមានដូចតទៅ៖ មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ដ៏ប្រសើរឧត្ដម។ មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ជាដើម និងជាទិសដៅចុងបំផុតនៃជីវិតមនុស្សលោក។ មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ ជាប្រភពនៃអំណាចរបស់អស់លោកអ្នក និងជាមូលដ្ឋានគ្រឹះនៃច្បាប់ របស់អស់លោកអ្នកដែរ។

អស់លោកអ្នកមានភារកិច្ចលើកស្ទួយឲ្យមានរបៀបរៀបរយ និងសន្តិភាពក្នុងចំណោមមនុស្សនៅលើផែនដី។ ប៉ុន្តែ សូមកុំភ្លេចថា មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ជាព្រះបិតារបស់មនុស្សទាំងអស់ ព្រះអង្គមានព្រះជន្មគង់នៅ និងជាព្រះដ៏ពិតប្រាកដ។ មានតែព្រះគ្រីស្តមួយព្រះអង្គទេ យាងមកប្រាប់និងបង្រៀនយើងឲ្យដឹងថា យើងទាំងអស់គ្នាសុទ្ធតែជាបងប្អូនគ្នា។ ព្រះអង្គជាព្រះបុត្រារបស់ព្រះជាម្ចាស់តាំងពីអស់កល្បជានិច្ច គឺព្រះគ្រីស្តនេះហើយ ដែលអាចបង្កើតរបៀបរៀបរយ និងកសាងសន្តិភាពនៅលើផែនដីបាន ដ្បិតព្រះអង្គណែនាំប្រវត្តិសាស្ត្ររបស់មនុស្សលោក។ មានតែព្រះគ្រីស្តមួយព្រះអង្គទេ ដែលអាចទាក់ទាញចិត្តមនុស្សឲ្យលះបង់កិលេសតណ្ហា គឺចិត្តលោភលន់ កំហឹង និងអវិជ្ជាដែលបណ្ដាលឲ្យកើតសង្គ្រាម និងកើតទុក្ខ។ ព្រះអង្គយកនំបុ័ងរបស់មនុស្សជាតិ មកប្រសិទ្ធិពរ គឺព្រះអង្គប្រោសឲ្យការងារ និងទុក្ខលំបាករបស់មនុស្សលោកបានវិសុទ្ធ ព្រះអង្គក៏ប្រទានអំណរឲ្យមនុស្សលោក ជាអំណរដែលអស់លោកអ្នកមិនអាចផ្ដល់ឲ្យគេបានទេ។ នៅពេលគេកើតទុក្ខ ព្រះអង្គលើកទឹកចិត្តគេតាមរបៀប អស់លោកអ្នកមិនអាចសម្រាលទុក្ខគេបានឡើយ។

ក្នុងប្រទេសរបស់អស់លោកអ្នកដែលស្ថិតនៅក្នុងលោកនេះ ដែលតែងតែកន្លងទៅ ព្រះគ្រីស្តកំពុងសាងសង់ព្រះសហគមន៍ តាមរបៀបដ៏អាថ៌កំបាំង គឺព្រះសហគមន៍ជាបុរីខាងព្រះវិញ្ញាណ ដែលនៅស្ថិតស្ថេរអស់កល្បជានិច្ច។ អស់រយៈពេលជិតពីរពាន់ឆ្នាំមកហើយ ព្រះសហគមន៍មានបទពិសោធន៍ផ្សេងៗជាច្រើន ក្នុងការទាក់ទងជាមួយអស់លោកអ្នក ជាអ្នកកាន់អំណាចនៅលើផែនដី។ សព្វថ្ងៃ តើព្រះសហគមន៍សូមអ្វីពីសំណាក់អស់លោកអ្នក? ក្នុងឯកសារមួយដ៏សំខាន់នៃមហាសន្និបាតនេះ ព្រះសហគមន៍សូមសេរីភាពពីសំណាក់អស់លោកអ្នក គឺសេរីភាពខាងជំនឿ ជា

សេរីភាពប្រកាសជំនឿរបស់ខ្លួន សេរីភាពស្រឡាញ់ និងបម្រើព្រះរបស់ខ្លួន សេរីភាពក្នុងការរស់នៅ និងសេរីភាពប្រកាសសាររបស់ខ្លួន ដែលផ្ដល់ជីវិតដល់មនុស្សលោក។ សូមកុំខ្លាចព្រះសហគមន៍ឲ្យសោះ ព្រះសហគមន៍ ក៏ដូចព្រះបរមគ្រូរបស់ខ្លួនដែរ គឺព្រះអង្គមានសកម្មភាពដ៏អាថ៌កំបាំងម៉្យាង ព្រះអង្គមិនប៉ះពាល់ លុកលុយលើបុព្វសិទ្ធិ របស់អស់លោកអ្នកទេ តែព្រះអង្គព្យាបាលមនុស្សទាំងស្រុង ឲ្យបានរួចពីអ្វីៗដែលមិនទៀងទាត់ ព្រះអង្គប្រែទ្រង់ទ្រាយមនុស្ស ហើយផ្ដល់សេចក្ដីសង្ឃឹម សេចក្ដីពិត និងសោភ័ណភាពយ៉ាងពេញបរិបូណ៌ឲ្យមនុស្សលោកផងដែរ។

ចូរបណ្ដោយឲ្យព្រះគ្រីស្ដបំពេញសកម្មភាពដែលជម្រះសង្គម កុំបដិសេធព្រះអង្គ។ ប្រសិនបើអស់លោកអ្នកមិនព្រមទទួលព្រះអង្គ អស់លោកអ្នកដូចជាឆ្កាងព្រះអង្គម្ដងទៀត។ ប្រសិនបើអស់លោកអ្នកឆ្កាងព្រះអង្គម្ដងទៀតនោះ អស់លោកអ្នកមុខជាប្រមាថព្រះជាម្ចាស់ពុំខាន ដ្បិតព្រះអង្គពិតជាព្រះបុត្រារបស់ព្រះបិតាមែន។ ប្រសិនបើអស់លោកអ្នកឆ្កាងព្រះអង្គម្ដងទៀតនោះ ក៏ដូចជាអស់លោកអ្នកធ្វើអត្តឃាតកម្មដែរ ព្រោះព្រះអង្គពិតជាបុត្រមនុស្ស។ ចូរបណ្ដោយឲ្យយើងជាអ្នកបម្រើដ៏សុភាពរាបសាររបស់ព្រះអង្គ អាចផ្សព្វផ្សាយនូវដំណឹងល្អស្ដីអំពីសន្តិភាព ដោយគ្មានអ្វីរារាំងឡើយ ដូចយើងបានរិះគិតក្នុងមហាសន្និបាតនេះ។ ប្រជាជនរបស់អស់លោកអ្នក មុខជានឹងទទួលផលប្រយោជន៍មុនគេពុំខានពីព្រះសហគមន៍ ដ្បិតព្រះសហគមន៍តែងតែអប់រំប្រជាពលរដ្ឋជូនអស់លោកអ្នក គឺឲ្យគេមានចិត្តស្មោះត្រង់ នឹងរដ្ឋអំណាច ឲ្យស្រឡាញ់សន្តិភាពក្នុងសង្គម និងឲ្យស្រឡាញ់ការចម្រើនឡើងនៃប្រទេស។

នៅថ្ងៃបង្ហើយមហាសន្និបាតសកល ទី២១ ជាថ្ងៃដ៏មហាឱឡារិកនេះ ព្រះសហគមន៍សូមយកសេចក្ដីស្រឡាញ់ ការបម្រើ កម្លាំងខាងវិញ្ញាណ និងខាងសីលធម៌ មកជូនអស់លោកអ្នកតាមរយៈយើង។ ព្រះសហគមន៍សូមគោរពជូនសារនៃការសង្គ្រោះ និងសូមគោរពជូនពរដល់អស់លោកអ្នក។ ព្រះសហគមន៍ជូនពរដោយមានចិត្តរីករាយ និងចិត្តស្មោះត្រង់យ៉ាងណា សូមអស់លោកអ្នកទទួលពរដោយចិត្តរីករាយ និងដោយចិត្តស្មោះយ៉ាងនោះដែរ។ សូមយកសារ និងពរទាំងនោះ ទៅចែកចាយដល់ប្រជាជនរបស់អស់លោកអ្នកឲ្យយើងផង។

# សារគោរពជូនចំពោះបញ្ញវន្ត និងអ្នកវិទ្យាសាស្ត្រ

ព្រះសហគមន៍សូមគោរពជម្រាបយ៉ាងពិសេស ដល់អស់លោកអ្នកដែលស្វែងរកសេចក្ដីពិត គឺអស់លោកអ្នកជាបញ្ញវន្ត ជាអ្នករិះគិតយ៉ាងជ្រាលជ្រៅ និងជាអ្នកវិទ្យាសាស្ត្រ ជាអ្នកស្វែងរក និងសិក្សាអំពីមនុស្ស រុករកឲ្យស្គាល់កន្លែងថ្មីក្នុងពិភពលោក ជាអ្នកស្វែងរកខាងប្រវត្តិសាស្ត្រ។ល។ អស់លោកអ្នកពិតជាអ្នកធ្វើបូជនីយយេសចរទៅរកពន្លឺ។ ព្រះសហគមន៍ ក៏សូមគោរពអស់លោកអ្នកដែលឈប់តាមផ្លូវ លែងស្វែងរកពន្លឺ ព្រោះអស់លោកអ្នកអស់កម្លាំងពេក ឬខកចិត្ត ព្រោះបានស្វែងរកដោយឥតបានផលតាមបំណងប្រាថ្នា។ ហេតុអ្វីព្រះសហគមន៍ សូមគោរពជម្រាបមកអស់លោកអ្នកយ៉ាងពិសេសដូច្នេះ? ព្រះសហគមន៍ជម្រាបមកយ៉ាងពិសេសដូច្នេះ ដ្បិតយើងទាំងអស់គ្នាជាអភិបាល ដែលជួបជុំគ្នាក្នុងមហាសន្និបាតនេះ ក៏ខិតខំស្ដាប់សេចក្ដីពិតដែរ។ អស់រយៈបួនឆ្នាំហើយ យើងបានខិតខំស្វែងរកអត្ថន័យ ឲ្យបានកាន់តែជ្រៅ ទៅដោយប្រុងប្រយ័ត្ន ជាសារនៃសេចក្ដីពិត ដែលព្រះគ្រីស្ដបានផ្ញើទុកមកព្រះសហគមន៍។ យើងក៏ខិតខំស្ដាប់តាមព្រះវិញ្ញាណនៃសេចក្ដីពិត បំភ្លឺយើងដោយចិត្តស្មោះទ្បើងៗទៀតដែរ។

ហេតុនេះហើយ បានជាយើងត្រូវតែនិយាយជាមួយបងប្អូន ដោយមិនរាក់ខានឡើយ។ ផ្លូវរបស់បងប្អូនក៏ជាផ្លូវរបស់យើងដែរ ផ្លូវរបស់បងប្អូនមិនដែលប្លែកពីផ្លូវរបស់យើងទេ។ យើងក៏ជាមិត្តសម្លាញ់របស់បងប្អូន ដែលស្វែងរកតាមឧបនិស្ស័យរបស់បងប្អូនរៀងៗខ្លួន យើងក៏រួមសាមគ្គីជាមួយបងប្អូន ដែលតែងនឿយហត់ យើងក៏ស្ងើចសរសើរបងប្អូន នៅពេលបងប្អូនមានជ័យជម្នះដោយរកឃើញអ្វីមួយថ្មី។ ពេលបងប្អូនធ្លាក់ទឹកចិត្ត ឬបរាជ័យ យើងក៏លើកទឹកចិត្តបងប្អូន និងសម្រាលទុក្ខបងប្អូនដែរ។

យើងមានសារគោរពជូនបងប្អូនដូចតទៅ៖ ចូរស្វែងរកបន្តទៅទៀតទៅ កុំអស់សង្ឃឹមពេលអ្នករកមិនឃើញសេចក្ដីពិតភ្លាមៗតាមបំណង! ចូរចងចាំប្រសាសន៍របស់សន្តៈអូហ្គូស្តាំង ជាមិត្តសម្លាញ់ដ៏ប្រសើររបស់បងប្អូនថា៖ *"យើងនាំគ្នាខិតខំស្វែងរក ដោយមានបំណងចង់រកឲ្យឃើញ។ បើយើងរកឃើញហើយ យើងនាំគ្នាស្វែងរកតទៅទៀត"*។ អស់អ្នកដែលបានរកឃើញសេចក្ដីពិតហើយ តែនៅតែស្វែងរកសេចក្ដីពិតនេះតទៅទៀត ពិតជាមានសុភមង្គលហើយ។ គេខិតខំយល់សេចក្ដីពិតនេះឲ្យកាន់តែជ្រៅទៅៗ និងរកពន្យល់តាមរបៀបថ្មី មកចែកចាយដល់អ្នកដទៃទៀត។ អស់អ្នកដែលស្វែងរកសេចក្ដីពិត តែមិនទាន់ឃើញ ប៉ុន្តែ នៅតែដើររកដោយចិត្តស្មោះ ពិតជាមានសុភមង្គលហើយ! សូមស្វែងរកពន្លឺសម្រាប់បំភ្លឺថ្ងៃស្អែក ដោយយកពន្លឺថ្ងៃនេះមកបំភ្លឺ រហូតតទៅដល់ពន្លឺដ៏ពេញលក្ខណៈលេចឡើង។

ប៉ុន្តែសូមកុំភ្លេចថា បញ្ញាវន្តជាអ្នករិះគិត ពិតជាបំពេញកិច្ចការមួយដ៏ប្រសើរបំផុត ហើយក៏ត្រូវដឹងច្បាស់ថាការរិះគិត គឺជាភារកិច្ចមួយដ៏សំខាន់ជាងគេដែរ។ អ្នកបិទភ្នែក ដោយមិនព្រមឃើញពន្លឺ ពិតជាជនអព្ទមង្គលមែន។ អ្នករិះគិតពិតជាទទួលខុសត្រូវយ៉ាងទម្ងន់ម៉្យាងដែរ អស់អ្នកប្រើឧបាយកលផ្សេងៗជាច្រើន បណ្ដាលឲ្យអ្នកដទៃធ្លាក់ទឹកចិត្ត ពិតជានាំឲ្យគេអួតបំប៉ោង បញ្ឆោតគេ ហើយក៏បង្ខូចចិត្តគំនិតគេទៀត។ អស់អ្នកស្វែងរកខាងវិទ្យាសាស្ត្រ ត្រូវកាន់តាមគោលការណ៍តែមួយថា គឺត្រូវខិតខំរិះគិតឲ្យបានត្រឹមត្រូវជានិច្ច។ ហេតុនេះហើយ បានជាយើងគ្មានបំណងចង់ឲ្យបងប្អូនវិលវល់ក្នុងចិត្តទេ យើងក៏មិនចង់ឲ្យបងប្អូនស្រវាំង ភ្នែកដោយសារពន្លឺរបស់យើងចាំងទៅលើនោះឡើយ។ យើង

គ្រាន់តែសូមជូនពន្លឺនៃចង្កៀងដ៏អាចកំបាំងរបស់យើងមកបងប្អូន គឺជូនពន្លឺនៃជំនឿរបស់យើងតែប៉ុណ្ណោះ។ យើងជាសាវ័កដ៏សុភាពរាបសាររបស់ព្រះបរមគ្រូជាអម្ចាស់ ដ៏ខ្ពង់ខ្ពស់នៃការរិះគិត ព្រះអង្គបានផ្ញើពន្លឺនេះមកយើង។ ព្រះអង្គជាមនុស្សតែម្នាក់គត់ ដែលមានប្រសាសន៍ថា *"ខ្ញុំជាពន្លឺបំភ្លឺមនុស្សលោក ខ្ញុំជាមាគ៌ា ខ្ញុំជាសេចក្តីពិត និងជាជីវិត"*។

ប្រសាសន៍នេះ ពិតជាមានប្រយោជន៍សម្រាប់បងប្អូន។ តាំងពីដើមរៀងមក មនុស្សមិនដែលមានលទ្ធភាព ធ្វើឲ្យវិទ្យាសាស្ត្រដ៏ពិតប្រាកដ និងជំនឿដ៏ពិតប្រាកដ អាចទាក់ទងគ្នាដូចសព្វថ្ងៃនេះបាន។ វិទ្យាសាស្ត្រ និងជំនឿបម្រើសេចក្តីពិតតែមួយគត់។ កុំឃាត់ឃាំងមិនឲ្យវិទ្យាសាស្ត្រនិងជំនឿជួបជុំគ្នាឡើយ! ចូរទុកចិត្តលើជំនឿជាមិត្តសម្លាញ់យ៉ាងជិតស្និទ្ធនៃប្រាជ្ញារបស់មនុស្ស! ចូរយកជំនឿធ្វើជាពន្លឺរបស់ខ្លួន ដើម្បីឲ្យបានយល់សេចក្តីពិតទាំងមូល។ យើងជាអភិបាលនៃពិភពលោកទាំងមូល ដែលមកជួបជុំគ្នាជាមហាសន្និបាតនៅក្រុងរ៉ូមនេះ មុននឹងបែកខ្ញែងពីគ្នា យើងសូមជូនពរដល់បងប្អូន សូមលើកទឹកចិត្តបងប្អូន សូមឲ្យបងប្អូនមានសេចក្តីសង្ឃឹមជានិច្ចផង។

# សារគោរពជូនចំពោះសិល្បករ

សូមគោរពជូនមកបងប្អូនទាំងអស់ជាសិល្បករ។ បងប្អូនចូលចិត្តសោភ័ណភាពជាខ្លាំង ហើយតែងតែបម្រើសោភ័ណភាពនោះផង។ បងប្អូនជាកវី ជាអ្នកនិពន្ធ ជាវិចិត្រករ ជាស្ថាបត្យករ ជាដូរ្យតន្ត្រីករ ជាអ្នកលេងល្ខោន ជាអ្នកផលិតខ្សែភាពយន្ត។ល។ មហាសន្និបាតនៃព្រះសហគមន៍ ក៏ជម្រាបជូនមកបងប្អូនតាមរយៈយើងថា ប្រសិនបើបងប្អូនស្រឡាញ់សិល្បៈដ៏ពិតប្រាកដ នោះបងប្អូនពិតជាមិត្តសម្លាញ់របស់យើងមែន។

តាំងពីយូរយារណាស់មកហើយ ព្រះសហគមន៍ចងសម្ពន្ធមេត្រីជាមួយបងប្អូន។ បងប្អូនបានស្ថាបនា និងតែងលម្អវិហាររបស់យើង។ បងប្អូនបានលើកតម្កើងសេចក្ដី បញ្ជាក់នៃលទ្ធិជំនឿរបស់យើង ធ្វើឲ្យពិធីគោរពប្រណិប័តន៍របស់យើងកាន់តែប្រសើរឡើងៗ។ បងប្អូនបានជួយព្រះសហគមន៍ ឲ្យបកស្រាយអត្ថន័យព្រះបន្ទូល ដែលមកពីព្រះជាម្ចាស់តាមរូបគំនូរ និងតាមរូបភាព បងប្អូនក៏នាំឲ្យមនុស្សលោកអាចស្គាល់ពិភព ដែលភ្នែកមនុស្សមើលមិនឃើញទៀតដែរ។

សព្វថ្ងៃក៏ដូចកាលពីមុនដែរ ព្រះសហគមន៍ត្រូវការបងប្អូន ហើយក៏បែរមុខមករកបងប្អូន។ ព្រះសហគមន៍ជម្រាបជូនមកបងប្អូនតាមរយៈយើងថា កុំបណ្ដោយឲ្យសម្ព័ន្ធមេត្រីរបស់យើងដាច់ឡើយ ព្រោះសម្ព័ន្ធមេត្រីនេះ បានបង្កើតលទ្ធផលដ៏ប្រសើរលើសអ្វីៗទាំងអស់រួចមកហើយ។ កុំបដិសេធយកទេពកោសល្យរបស់ខ្លួន មកបម្រើសេចក្ដីពិតរបស់ព្រះជាម្ចាស់ឡើយ។ កុំបិទចិត្តគំនិតមិនឲ្យខ្យល់នៃព្រះវិញ្ញាណដ៏វិសុទ្ធចូលឡើយ។

ពិភពលោកយើងនេះ ត្រូវការសោភ័ណភាព កុំឲ្យខ្លួនធ្លាក់ទឹកចិត្តអស់សង្ឃឹម។ សោភ័ណភាពក៏ដូចសេចក្ដីពិតដែរ គឺផ្ដល់ឲ្យមនុស្សមានចិត្តសប្បាយរីករាយ។ សោភ័ណភាពពិតជាផលដ៏ប្រសើរ ដែលមិនចេះចាស់ជរា និងបណ្ដោយឲ្យមនុស្សគ្រប់ជំនាន់អាចទាក់ទងគ្នាបាន និងអាចរួបរួមគ្នាស្ញើចសរសើរទៀតផង។ កិច្ចការទាំងនោះ ពិតជាស្នាដៃរបស់បងប្អូនមែន។

សូមបងប្អូនបង្កើតស្នាដៃស្អាតបរិសុទ្ធជានិច្ច កុំចង់រកតែផលប្រយោជន៍សម្រាប់ខ្លួនឯងឡើយ។ សូមបងប្អូននឹកចងចាំជានិច្ចថា បងប្អូនពិតជារក្សាសោភ័ណភាពក្នុងពិភពលោកនេះ។ សូមឲ្យគំនិតនេះ ជួយរំដោះបងប្អូនឲ្យមានសេរីភាពយ៉ាងពេញលេញ កុំផ្ចង់ចិត្តនឹងចំណូលចិត្តដែលតែងតែប្រែប្រួល និងគ្មានតម្លៃដ៏ពិតប្រាកដឡើយ។ សូមបងប្អូនរំដោះខ្លួន ឲ្យរួចពីបំណងប្រាថ្នាលោកីយ៍ ដែលសម្ដែងសេចក្ដីយ៉ាងចម្លែកអស្ចារ្យពេកនិងមិនសមរម្យ។

សូមបងប្អូនបានសមតាមឧត្ដមគតិដ៏ខ្ពង់ខ្ពស់របស់បងប្អូនជានិច្ច និងនៅគ្រប់ទីកន្លែង។ ធ្វើដូច្នេះ បងប្អូនក៏សមរម្យទៅជាបុត្រធីតារបស់ព្រះសហគមន៍ ដែលគោរពជូនសាររបស់ខ្លួន ជាសារសម្ដែងសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅសម្ដែងការសង្គ្រោះ និងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់មកបងប្អូន។ នៅថ្ងៃនេះ ព្រះសហគមន៍ក៏ប្រទានពរមកបងប្អូនតាមរយៈយើងដែរ។

# សារគោរពជូនចំពោះស្ត្រីទាំងឡាយ

ឥឡូវនេះ យើងសូមជម្រាបមកស្ត្រីទាំងឡាយ គឺស្ត្រីគ្រប់ឋានៈ វណ្ណៈ ស្ត្រីនៅលីវ ឬស្ត្រីមានគ្រួសារ ស្ត្រីមានកូន និងស្ត្រីមេម៉ាយ។ សូមជម្រាបមកស្ត្រីព្រហ្មចារី ដែលថ្វាយខ្លួនចំពោះព្រះជាម្ចាស់ និងស្ត្រីដែលរស់នៅម្នាក់ឯងដែរ។ ចំនួននាង គឺពាក់កណ្តាលនៃមហាគ្រួសាររបស់មនុស្សជាតិហើយ!

នារីទាំងឡាយដឹងច្បាស់ថា ព្រះសហគមន៍មានកិត្តិយស ដោយបានលើកតម្កើង និងរំដោះនារីហើយ។ តាមប្រវត្តិសាស្រ្តដ៏យូរអង្វែងមក ព្រះសហគមន៍តែងតែប្រកាសថា ទោះបីបុរសនិងស្ត្រីមានចរិតលក្ខណៈ និងទេពកោសល្យប្លែកពីគ្នាក៏ដោយ ក៏ស្ត្រីមានតម្លៃស្មើនឹងបុរសយ៉ាងពិតប្រាកដ។ ប៉ុន្តែដល់ពេល គឺឥឡូវនេះហើយ ដែលឧបនិស្ស័យរបស់ស្ត្រីកើតជារូបរាងយ៉ាងពេញលក្ខណៈ។ ស្ត្រីមានឥទ្ធិពលយ៉ាងខ្លាំងក្នុងសង្គមស្ត្រីៗមានកិត្តិយស ដូចពន្លឺសាយភាយឡើង និងមានអំណាចដែលមិនធ្លាប់មានកាលពីសម័យមុនៗនៅឡើយ។

សព្វថ្ងៃ មនុស្សជាតិប្រែប្រួលយ៉ាងខ្លាំង។ ហេតុនេះហើយបានជាស្ត្រីដែលមានគោលគំនិតនៃដំណឹងល្អជ្រួតជ្រាបក្នុងចិត្តគំនិត បានជួយមនុស្សជាតិយ៉ាងសម្បើម កុំឲ្យមនុស្សជាតិធ្លាក់ដុនដាប។ បងប្អូនជាស្ត្រីៗអើយ! អ្នកនៅតែមានភារកិច្ចរក្សាក្រុមគ្រួសារជានិច្ច គឺអ្នកស្រឡាញ់ប្រភពនៃជីវិត និងតែងតែស្រឡាញ់ទារក។ អ្នកមានវត្តមាននៅពេលជីវិតចាប់ផ្តើមឡើងយ៉ាងអស្ចារ្យ។ ពេលមនុស្សទទួលមរណភាពក៏អ្នកចេះលួងលោមគេដែរ។ ប្រសិនបើយើងមិនប្រយ័ត្នបច្ចេកទេសរបស់យើង អាចបណ្តាលឲ្យជីវិតមនុស្សបាត់លក្ខណៈជាមនុស្ស។ ចូរអ្នករំឭកមនុស្សលោកឲ្យគោរពតម្លៃនៃជីវិត ជាពិសេសយើងអង្វរបងប្អូន សូមរក្សាការពារអនាគតនៃពូជមនុស្សយើងឲ្យនៅគង់វង្ស។ សូមឃាត់ដៃរបស់អស់អ្នកដែលចង់បំផ្លាញអរិយធម៌របស់មនុស្សជាតិ នៅគ្រាដែលគេបាត់ស្មារតី។

ស្ត្រីៗដែលមានគ្រួសារ និងមានកូន អ្នកជាអ្នកអប់រំមនុស្សជាតិមុនគេបង្អស់ ក្នុងទីលាក់កំបាំងនៃក្រុមគ្រួសារ។ ចូរបញ្ជូនបន្តប្រពៃណីដូនតាឲ្យកូនប្រុស កូនស្រីយល់ដឹង។ នៅពេលជាមួយគ្នានោះ អ្នកនឹងអប់រំកូនៗ គឺរៀបចំកូនៗឲ្យប្រឈមមុខនឹងអនាគត ដែលគ្មាននរណាដឹងជាមុន។ ចូរនឹកចងចាំជានិច្ចថា ម្តាយតែងភ្ជាប់នឹងអនាគតរបស់កូនដែលនាងប្រហែលនឹងមើលមិនឃើញឡើយ។

ចំពោះស្ត្រីៗនៅលីវ ចូរដឹងថា អ្នកអាចបំពេញឧបនិស្ស័យរបស់ខ្លួនបាន គឺបម្រើអ្នកដទៃដោយចិត្តទូលាយ។ សង្គមហៅរកអ្នកពីគ្រប់មជ្ឈដ្ឋាន ប្រសិនបើគ្មានស្ត្រីណានៅលីវមកជួយទេ មានក្រុមគ្រួសារខ្លះមិនអាចរស់ នៅបានឡើយ។

ជាពិសេសស្ត្រីៗព្រហ្មចារី ដែលញែកខ្លួនថ្វាយព្រះម្ចាស់ សូមអ្នករក្សាភាពបរិសុទ្ធ ជាអ្នកមិនរកប្រយោជន៍ផ្ទាល់ខ្លួន និងជាអ្នកគោរពព្រះបំណិប័តន៍ព្រះជាម្ចាស់ ក្នុងពិភពយើងនេះដែលមានមនុស្សជាច្រើន រាប់ទុកការត្រេកត្រអាលភ្លើតភ្លើនតាមកាមគុណថោកទាប ទុកជាផ្លូវធម្មតារបស់មនុស្សលោក។ ព្រះយេស៊ូបានប្រោសប្រទានឲ្យសេចក្តីស្រឡាញ់របស់គូស្វាមីភរិយាមានតម្លៃពេញលក្ខណៈ ព្រះអង្គក៏បានលើកតម្កើងការលះបង់ស្នេហា តាមលោកីយ៍ដែរ លុះត្រា អ្នកលះបង់សេចក្តីស្នេហានោះ តម្រង់ខ្លួនទៅរកសេចក្តីស្រឡាញ់ដ៏អនន្ត និងនាំឲ្យបម្រើអ្នកដទៃទាំងអស់។

ចំពោះស្ត្រី ៗកំពុងរងទុក្ខលំបាក សូមអ្នកក្រោកឈរត្រង់ឡើងនៅក្បែរឈើឆ្កាង ដូចនាងម៉ារីដែរ។ តាមប្រវត្តិសាស្ត្រ ពួកនាងជាច្រើនបានប្រគល់ឲ្យបុរស ៗ មានកម្លាំងអាចតស៊ូវាយតយុទ្ធរហូតដល់ទីបំផុត គឺរហូតដល់បូជាជីវិតក៏មាន។ ចូរជួយបុរស ៗម្តងទៀតឲ្យមានចិត្តក្លាហាន ហ៊ានធ្វើការយ៉ាងអស្ចារ្យ ព្រមទាំងឲ្យគេមានចិត្តអត់ធ្មត់ខន្តី ដោយដឹងជានិច្ចថា អ្នកចង់ធ្វើកិច្ចការដ៏ធំអស្ចារ្យ ត្រូវចាប់ផ្តើមដោយធ្វើការតូច ៗយ៉ាងសុភាពរាបសាឡើងទៅ។ បងប្អូនជាស្ត្រី ៗ អើយ! បងប្អូនចេះធ្វើឲ្យសេចក្តីពិត បានស្រួលស្តាប់ ថ្នាក់ថ្នម លួងលោមចិត្តគេ។ សូមអ្នកជាប់ចិត្តនឹងចង់ធ្វើឲ្យគោលគំនិតនៃមហាសន្និបាតជ្រួតជ្រាបក្នុងស្ថាប័ន ក្នុងសាលារៀន ក្នុងក្រុមគ្រួសារ ក្នុងការរស់នៅរបស់មនុស្សជារៀងរាល់ថ្ងៃ។

បងប្អូនជាស្ត្រី ៗនៃភិភពលោកទាំងមូលអើយ ទាំងគ្រីស្តបរិស័ទក្តី មិនមែនគ្រីស្តបរិស័ទក្តី ព្រះជាម្ចាស់បានផ្ញើជីវិតទុកឲ្យនាងហើយ។ ក្នុងគ្រាដ៏សែនធ្ងន់ធ្ងរនៃប្រវត្តិសាស្ត្រយើងនេះ នាងមានភារកិច្ចសង្គ្រោះសន្តិភាពនៃពិភព លោកហើយ!

# សារគោរពជូនចំពោះពលករទាំងឡាយ

យើងជាអភិបាលនៃព្រះសហគមន៍កាតូលិក ពីទ្វីបទាំងប្រាំ បានរិះគិតរួមជាមួយគ្នាក្នុងមហាសន្និបាតនេះ។ ក្នុងចំណោមប្រធានបទទាំងប៉ុន្មាន យើងបានរិះគិតអំពីបញ្ហាដ៏ធ្ងន់ធ្ងរ ដែលចោទឡើងលើមនសិការមនុស្សជាតិ គឺបានរិះគិតអំពីបញ្ហាសភាពការណ៍សេដ្ឋកិច្ច និងសង្គមក្នុងពិភពលោកសព្វថ្ងៃ អំពីបញ្ហាប្រជាជាតិត្រូវរស់នៅជាមួយគ្នាដោយសុខសន្តិភាព ព្រមទាំងអំពីបញ្ហាសាស្ត្រាវុធ បញ្ហាសង្គ្រាម និងសន្តិភាព។ យើងដឹងច្បាស់ថា ដំណោះស្រាយបញ្ហាទាំងនោះមុខជានឹងមានឥទ្ធិពលយ៉ាងខ្លាំង លើការរស់នៅធម្មតារបស់ពលករ ពលការិនី ក្នុងពិភពលោកទាំងមូលពុំខាន។ ហេតុនេះហើយ បានជានៅពេលបញ្ចប់ការពិគ្រោះគ្នានេះ យើងសូមផ្ញើសារនេះ សម្ដែងសេចក្ដីទុកចិត្ត និងសេចក្ដីស្រឡាញ់របស់យើងមកបងប្អូនជាពលករទាំងឡាយ។ សូមបងប្អូនពលករបានប្រកបដោយសុខសន្តិភាព។

កូនដ៏ជាទីស្រឡាញ់! មុនដំបូង សូមបងប្អូនដឹងឲ្យបានច្បាស់ថា ព្រះសហគមន៍ស្គាល់ទុក្ខវេទនា ការតយុទ្ធ និងសេចក្ដីសង្ឃឹមរបស់ប្អូនៗ។ ព្រះសហគមន៍ក៏ចូលចិត្តយ៉ាងខ្លាំងនូវគុណធម៌ ដែលផ្ដល់ឲ្យជីវិតបងប្អូនមានតម្លៃដ៏ថ្លៃថ្នូរ គឺបងប្អូនមានសេចក្ដីក្លាហាន ចិត្តលះបង់សម្រាប់អ្នកដទៃ មនសិការក្នុងអាជីវកម្ម ចិត្តស្រឡាញ់យុត្តិធម៌។ ព្រះសហគមន៍ក៏ទទួលស្គាល់យ៉ាងច្បាស់ នូវជំនួយដ៏ធំមហិមារបស់ប្អូនចំពោះសង្គមទាំងមូល គឺប្អូនម្នាក់ៗតាមកន្លែងរៀងៗខ្លួន ទោះបីមនុស្សទូទៅមិនសូវស្គាល់ការងាររបស់បងប្អូនក្ដី ជាការងារថោកទាបដែលគេតែងមើលងាយទៀតផង ក៏បងប្អូនតែងតែបម្រើសង្គមទាំងមូលយ៉ាងល្អប្រសើរដែរ។ ព្រះសហគមន៍ដឹងគុណ ហើយសូមអរគុណបងប្អូនតាមរយៈយើង។

ប៉ុន្មានឆ្នាំកន្លងមក ព្រះសហគមន៍នៅតែគិតគូរអំពីបញ្ហាទាំងអស់ របស់ពលករ ពលការិនីក្នុងពិភពលោកទាំងមូល ជាបញ្ហាកាន់តែស្មុគស្មាញឡើងៗ។ ក្នុងចំណោមបងប្អូនមានអ្នកខ្លះ បានចាប់អារម្មណ៍នឹងសារលិខិតនៃអភិបាលព្រះសហគមន៍ក្រុងរ៉ូម។ បងប្អូនទាំងនោះបញ្ជាក់ថា ចិត្តគំនិតរបស់ពលករពលការិនី ត្រូវនឹងចិត្តគំនិតអ្នកដឹកនាំដ៏ខ្ពង់ខ្ពស់ ខាងវិញ្ញាណរបស់មនុស្សលោក។ លោកយ៉ូហាន ទី២៣ បានសរសេរសារលិខិតដែលមានតម្លៃរកអ្វីមកប្រៀបផ្ទឹមពុំបាន មកបន្ថែមក្នុងបេតិកភ័ណ្ឌនៃព្រះសហគមន៍។ លោកបានរកផ្លូវឲ្យបងប្អូនចាប់អារម្មណ៍។ លោកសម្ដែងយ៉ាងត្រចះត្រចង់ នូវសេចក្ដីស្រឡាញ់របស់ព្រះសហគមន៍ទាំងមូល ចំពោះបងប្អូនជាពលករពលការិនី។ លោកក៏បានសម្ដែងសេចក្ដីស្រឡាញ់របស់ព្រះសហគមន៍ ចំពោះសេចក្ដីពិត យុត្តិធម៌ សេរីភាព សេចក្ដីស្រឡាញ់ ជាគ្រឹះសម្រាប់សាងសង់សន្តិភាពក្នុងពិភពលោក។ យើងក៏ចង់ទៅជាសាក្សីនៃសេចក្ដីស្រឡាញ់របស់ព្រះសហគមន៍ ចំពោះបងប្អូនជាពលករពលការិនីដែរ ហើយសូមប្រកាសដោយស្មោះអស់ពីចិត្តថា ព្រះសហគមន៍ជាមិត្តសម្លាញ់របស់បងប្អូន។ ចូរជឿទុកចិត្តលើព្រះសហគមន៍ចុះ! នៅសម័យបុរាណ គួរឲ្យស្ដាយណាស់ យើងពលករពលការិនី និងព្រះសហគមន៍ស្ដាប់គ្នាមិនបានបណ្ដាល ឲ្យមិនទុកចិត្តគ្នាទៅវិញទៅមកទេ។ វណ្ណៈកម្មករ និងព្រះសហគមន៍បានរងទុក្ខទាំងសងខាង។ ឥឡូវដល់ពេលសម្រុះសម្រួលគ្នាវិញហើយ ព្រះសហគមន៍នៃមហាសន្និបាត អញ្ជើញបងប្អូនឲ្យលើកតម្កើងការសម្រុះសម្រួលនេះ ដោយគ្មានគំនិតវៀចវេរឡើយ។

ព្រះសហគមន៍ ខិតខំស្គាល់បងប្អូនឲ្យកាន់តែច្បាស់ឡើងៗ។ ប៉ុន្តែ បងប្អូនក៏ត្រូវខិតខំយល់អំពីមុខងារ ព្រះ

សហគមន៍សម្រាប់បងប្អូនជាប្រជាពលករដែរ។ បងប្អូនពិតជាអ្នកដ៏សំខាន់ជាងគេ ក្នុងកិច្ចបង្កើតការប្រែប្រួលដ៏អស្ចារ្យនៃពិភពលោកនាបច្ចុប្បន្នកាលយើងនេះ។ បងប្អូនជ្រាបច្បាស់ថា ប្រសិនបើគ្មានខ្យល់ដ៏ខ្លាំងពូកែនៃព្រះវិញ្ញាណផ្ដល់ជីវិតរស់រវើកទេនោះ ការប្រែប្រួលនិងសមិទ្ធផលទាំងនោះ មុខជានឹងបណ្ដាលឲ្យអន្តរាយដល់មនុស្សជាតិជាពុំខាន មិននាំសុភមង្គលឡើយ។ ការស្អប់គ្នាមិនអាចសង្គ្រោះមនុស្សលោកបានទេ! អាហារខាងលោកីយ៍តែមួយមុខ ក៏មិនអាចធ្វើឲ្យមនុស្សស្កប់ចិត្តបានឡើយ។

ហេតុនេះ សូមបងប្អូនទទួលសាររបស់ព្រះសហគមន៍ដោយអនុគ្រោះ។ ចូរទទួលជំនឿដែលព្រះសហគមន៍សូមជូនមកបងប្អូន ទុកជាពន្លឺសម្រាប់បំភ្លឺផ្លូវជីវិតរបស់បងប្អូន។ ជំនឿនេះ ពិតជាជំនឿរបស់អ្នកបន្តមុខងារពីគ្រីស្តទូតសិលាមក ជាជំនឿរបស់អភិបាលពីរពាន់នាក់ ដែលប្រជុំគ្នាជាមហាសន្និបាត និងជាជំនឿរបស់ប្រជាជនគ្រីស្តបរិស័ទទាំងមូល សូមឲ្យជំនឿនេះបំភ្លឺចិត្តគំនិតបងប្អូន សូមឲ្យជំនឿនេះណែនាំបងប្អូន។ សូមឲ្យជំនឿនេះ ណែនាំបងប្អូនឲ្យស្គាល់ព្រះយេស៊ូគ្រីស្ត ជាមិត្តសំឡាញ់រួមការងាររបស់បងប្អូន ជាព្រះបរមគ្រូ និងជាព្រះសង្គ្រោះមនុស្សជាតិទាំងមូល។

# សារគោរពជូនចំពោះជនក្រីក្រ អ្នកជំងឺ និងអស់អ្នកដែលកើតទុក្ខលំបាក

មហាសន្និបាតសូមគោរពជូនសារយ៉ាងពិសេស មកអស់បងប្អូនដែលកើតទុក្ខនិងឈឺចុកចាប់គ្រប់យ៉ាង។ មហាសន្និបាតឃើញបងប្អូនសម្លឹងមកយើង ទាំងអង្វរ ទាំងភ្នែកស្រវាំងដោយគ្រុនក្ដៅ ឬដោយអស់កម្លាំង ហើយសួរថា ហេតុអ្វីមនុស្សកើតទុក្ខដូច្នេះ? បងប្អូនតប់ប្រមល់ក្នុងចិត្តហើយសួរទៀតថា តើនរណា នៅពេលណាមានគេមកសម្រាលទុក្ខនេះពីយើងបាន? តែគ្មានពាក្យឆ្លើយសោះ។ បងប្អូនដ៏ជាទីស្រឡាញ់ ក្នុងឋានៈយើងជាឪពុក និងជាគង្វាល យើងព្រួយបារម្ភជាខ្លាំងដោយឮស្នូរសម្រែក និងស្នូរត្អូញត្អែររបស់បងប្អូន។ យើងរឹតតែព្រួយចិត្តដោយនឹកឃើញថា យើងគ្មានសមត្ថភាពអាចផ្ដល់សុខភាពដល់រូបកាយបងប្អូន ឬធ្វើឲ្យបងប្អូនបានធូរស្រាល។ មានតែគ្រូពេទ្យ គិលានុបដ្ឋាក គិលានុបដ្ឋាកយិកា និងអស់អ្នកដែលខិតខំជួយព្យាបាលជំងឺទេ ដែលអាចសម្រាលទុក្ខក្នុងរូបកាយបងប្អូនបាន។

ប៉ុន្តែ យើងមានថ្នាំដ៏ប្រសើរជាង និងដែលមានតម្លៃថ្លៃជាង ផ្ដល់មកបងប្អូន គឺជំនឿដែលជាសេចក្ដីពិតតែមួយអាចតបឆ្លើយនឹងការអាថ៌កំបាំងនៃទុក្ខលំបាក។ ជំនឿនេះ ក៏អាចសម្រាលទុក្ខបងប្អូនដោយមិនភាន់ច្រឡំឡើយ។ ចូរផ្ញើជីវិតលើព្រះគ្រីស្ដ ជាមនុស្សដែលរងទុក្ខលំបាក ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែលត្រូវគេឆ្កាង ព្រោះតែអំពើបាបរបស់យើង និងដើម្បីសង្គ្រោះយើង។

ព្រះគ្រីស្ដមិនបានលប់បំបាត់ទុក្ខទេ ព្រះអង្គក៏មិនសព្វព្រះហឫទ័យបកស្រាយអត្ថន័យយ៉ាងពិស្ដានៃទុក្ខដែរ តែព្រះអង្គបានផ្ទុកទុក្ខលំបាករបស់មនុស្សលោកលើព្រះអង្គ។ ដូច្នេះ គ្រប់គ្រាន់ហើយ ដើម្បីឲ្យយើងយល់អំពីតម្លៃដ៏ថ្លៃថ្នូរនៃទុក្ខលំបាក។

បងប្អូនកំពុងរងទុក្ខអើយ! បងប្អូនដូចជាលីឈើឆ្កាងដ៏ធ្ងន់ធ្ងរដែរ។ បងប្អូនជាអ្នកក្រីក្រ និងជាអ្នកដែលគ្មាននរណារាប់រក បងប្អូនដែលកំពុងយំសោក បងប្អូនដែលត្រូវគេបៀតបៀនធ្វើបាប ព្រោះតែសេចក្ដីសុចរិតបងប្អូន ដែលគ្មាននរណានិយាយរក បងប្អូនដែលកំពុងរងទុក្ខតែគ្មាននរណាដឹងឮ ចូរមានចិត្តក្លាហានឡើង! ព្រះជាម្ចាស់ស្រឡាញ់បងប្អូនលើសគេទាំងអស់ ព្រះអង្គប្រទានសេចក្ដីសង្ឃឹម សុភមង្គល និងជីវិតព្រះអង្គឲ្យគ្រងរាជ្យលើបងប្អូនហើយ! បងប្អូនពិតជាបងប្អូនរបស់ព្រះគ្រីស្ដ ដែលកំពុងតែរងទុក្ខមែន! ប្រសិនបើបងប្អូនសុខចិត្ត បងប្អូនក៏អាចសង្គ្រោះមនុស្សលោកបានរួមជាមួយព្រះអង្គដែរ។

នេះជាចំណេះរបស់គ្រីស្ដបរិស័ទអំពីទុក្ខ ជាចំណេះតែមួយដែលអាចផ្ដល់សេចក្ដីសុខសាន្តមកបងប្អូន។ ចូរដឹងជាក់ច្បាស់ថា បងប្អូនមិននៅម្នាក់ឯងទេ បងប្អូនក៏មិនរស់នៅដាច់ឡែកពីគេដែរ គេមិនលះបង់បងប្អូនចោលទេ កុំនិយាយថា បងប្អូនគ្មានប្រយោជន៍ឡើយ! ផ្ទុយទៅវិញ ព្រះគ្រីស្ដហៅបងប្អូន បងប្អូនពិតជារូបតំណាងដែលមានជីវិតរស់រវើករបស់ព្រះអង្គ ហើយបណ្ដោយឲ្យគេឃើញព្រះអង្គបានទៀតផង។ ក្នុងនាមព្រះគ្រីស្ដ មហាសន្និបាតសូមគោរពជម្រាបដល់បងប្អូនដោយសេចក្ដីស្រឡាញ់។ មហាសន្និបាតក៏អរគុណបងប្អូន និងបញ្ជាក់ថា ពិតជាស្រឡាញ់បងប្អូនមែន! ព្រះសហគមន៍ជួយគាំទ្របងប្អូន និងជូនពរដល់បងប្អូនទៀតផង។

# សារគោរពជូនយុវជនយុវនារីទាំងឡាយ

នៅទីបញ្ចប់ មហាសន្និបាតសូមគោរពជូនសារចុងក្រោយនេះ មកប្អូនៗក្មួយៗជាយុវជនយុវនារីក្នុងពិភពលោកទាំងមូល។ គឺប្អូនៗក្មួយៗនេះហើយ នឹងទទួលចង្កៀងពន្លឺពីបងៗ ហើយនឹងរស់នៅក្នុងពិភពលោកនាសម័យដែលប្រែប្រួលយ៉ាងសម្បើមអស្ចារ្យយើងនេះ តាមប្រវត្តិសាស្ត្រមិនដែលមានប្រែប្រួលបែបនេះទេ។ ប្អូនៗក្មួយៗ មុខជានឹងទទួលយកគំរូដ៏ល្អជាងគេ ពីសេចក្ដីបង្រៀនរបស់ឪពុកម្ដាយ និងរបស់គ្រូបាធ្យាយមកបង្កើតសង្គមនៅថ្ងៃអនាគតកាល។ ប្អូនៗក្មួយៗ មុខជានឹងរួមសង្គ្រោះខ្លួនឯងក៏បាន ឬក៏រួមអន្តរាយជាមួយសង្គមនោះក៏បានដែរ។

អស់បួនឆ្នាំមកហើយព្រះសហគមន៍ខិតខំរិះគិត ដើម្បីកែទ្រង់ទ្រាយរបស់ខ្លួនឲ្យបានជាថ្មី ក្នុងគោលបំណងបានស្របតាមគម្រោងការរបស់ព្រះគ្រីស្ដឲ្យកាន់តែច្បាស់ឡើងៗ គឺព្រះគ្រីស្ដដែលបានតែងតាំងព្រះសហគមន៍។ ព្រះអង្គមានព្រះជន្មគង់នៅយ៉ាងអស្ចារ្យ និងនៅក្នុងយុវវ័យជានិច្ចនិរន្តរ៍។ ពេលបញ្ចប់ការរិះគិតអំពីការរស់នៅរបស់ខ្លួន ព្រះសហគមន៍បែរមករកប្អូនៗក្មួយៗជាយុវជន យុវនារី ដោយសារមហាសន្និបាតនេះ ព្រះសហគមន៍ទើបនឹងបានអុជចង្កៀងមួយជាពិសេសអុជចង្កៀងសម្រាប់ប្អូនៗក្មួយៗ គឺជាចង្កៀងផ្ដល់ពន្លឺបំភ្លឺអនាគត ជាអនាគតរបស់ប្អូនៗក្មួយៗនេះហើយ!

ព្រះសហគមន៍ប្រាថ្នាចង់ឲ្យសង្គម ដែលប្អូនៗក្មួយៗនឹងសាងសង់នៅពេលអនាគតនោះ គោរពតម្លៃដ៏ថ្លៃថ្នូរសេរីភាព និងសិទ្ធិរបស់បុគ្គលគ្រប់ៗរូប។ បុគ្គលទាំងនោះ គឺប្អូនៗក្មួយៗនេះឯង!

ព្រះសហគមន៍ប្រាថ្នាចង់ឲ្យសង្គមនាអនាគតកាលនោះ បណ្ដោយឲ្យជំនឿអាចលេចចាំងពន្លឺឡើង គឺជំនឿ ដែលមានតម្លៃដ៏ថ្លៃថ្នូរជានិច្ច ទាំងនៅអតីតកាល ទាំងនៅអនាគតកាល។ សូមឲ្យជំនឿបំភ្លឺចិត្តគំនិតប្អូនៗក្មួយៗដោយសេរី និងផ្ដល់សេចក្ដីសុខសាន្តឲ្យប្អូនៗក្មួយៗផង។ ព្រះសហគមន៍សង្ឃឹមថា ប្អូនៗក្មួយៗ មុខជានឹងទទួលកម្លាំងយ៉ាងខ្លាំង និងបានអំណរសប្បាយយ៉ាងក្រៃលែងបានដែរ។ បើដូច្នេះ ប្អូនៗក្មួយមិនចាញ់ការល្បួងដូចបងៗខ្លះ គឺប្អូនៗក្មួយៗមិនបណ្ដោយខ្លួនតាមទស្សនវិជ្ជាដែលទាក់ទាញចិត្ត គឺទស្សនវិជ្ជានាំឲ្យគិតតែពីខ្លួនឯង ឲ្យគិតតែពីការភ្លើតភ្លើនសប្បាយតាមកាមគុណថោកទាប ឬទស្សនវិជ្ជាបណ្ដាលឲ្យអស់សង្ឃឹម និងនាំឲ្យវាសនាខ្លួនសាបសូន្យ។ មានលទ្ធិមួយប្រកាសថាគ្មានព្រះទាល់តែសោះ។ លទ្ធិនេះជាអភូតហេតុកើតពីមនុស្សដែលណាយចិត្តនឹងជីវិត នឹងជាអភូតហេតុរបស់ពួកចាស់ជរា។ ព្រះសហគមន៍សង្ឃឹមថា នៅចំពោះលទ្ធិនោះ ប្អូនៗក្មួយៗមុខជានឹងចេះប្រកាសបញ្ជាក់ជំនឿរបស់ខ្លួន ទៅលើជីវិត និងទៅលើអ្វីៗដែលផ្ដល់ឲ្យជីវិតមានអត្ថន័យដ៏ថ្លៃថ្នូរ គឺជំនឿយ៉ាងជាក់ច្បាស់ថា មានព្រះបិតាប្រកបដោយព្រះហឫទ័យស្រឡាញ់ និងសុចរិត ព្រះអង្គមានព្រះជន្មគង់នៅពិតប្រាកដមែន។

យើងសូមដាស់តឿនប្អូនៗក្មួយៗក្នុងនាមព្រះបិតានេះ និងក្នុងនាមព្រះយេស៊ូជាព្រះបុត្រាព្រះអង្គដែរ សូមលាតត្រដាងចិត្តគំនិតប្អូនៗក្មួយៗ តាមទំហំពិភពលោកទាំងមូល ចូរស្ដាប់ពាក្យស្រែកហៅរបស់បងប្អូន។ សូមប្អូនៗក្មួយៗសម្រេចចិត្តយកថាមពលថ្មីរបស់ប្អូនៗក្មួយៗ មកបម្រើគេដោយចិត្តក្លាហាន។ សូមប្រឆាំងនឹងអត្តទត្តបុគ្គល និយមគ្រប់យ៉ាង។ កុំបណ្ដោយខ្លួនតាមទោសៈ និងការស្អប់គ្នា ដែលបណ្ដាលឲ្យកើតសង្គ្រាម និងទុក្ខវេទនាគ្រប់យ៉ាង។ ចូរមានចិត្តទូលំទូលាយ បរិសុទ្ធ ចេះគោរពអ្នកដទៃ និងស្មោះត្រង់ជានិច្ច។ ចូរយកចិត្តទុកដាក់សាងសង់ ពិភពលោកដ៏ល្អប្រសើរ

ជាងពិភពរបស់បងៗ។

ព្រះសហគមន៍មើលប្អូនៗក្មួយៗទាំងទុកចិត្ត និងដោយសេចក្តីស្រឡាញ់។ ព្រះហគមន៍មានអតីតកាលដ៏យូរអង្វែង ដែលមានតម្លៃដ៏ថ្លៃថ្នូរ ហើយនៅតែរក្សាតម្លៃដ៏ថ្លៃថ្នូរនៃអតីតកាលនេះក្នុងខ្លួន។ ព្រះសហគមន៍ធ្វើដំណើរតាមកាលៈទេសៈ ទាំងនាំមនុស្សលោកឲ្យបានពេញលក្ខណៈជាមនុស្ស និងនាំគេទៅកាន់ទិសដៅចុងបំផុតនៃប្រវត្តិសាស្ត្រ និងនៃជីវិត។ ព្រះសហគមន៍ពិតជាយុវវ័យនៃពិភពលោកមែន។ ព្រះសហគមន៍មានអ្វីៗដែលផ្តល់កម្លាំង និងធ្វើឲ្យមនុស្សពេញចិត្តស្រឡាញ់យុវជនយុវនារី គឺព្រះសហគមន៍មានសមត្ថភាពអរសប្បាយដោយឃើញអ្វីៗ ដែលកើតឡើង មានសមត្ថភាពចែកចាយអ្វីៗដោយមិនទាមទារសុគុណពីគេ មានសមត្ថភាពកែខ្លួនឲ្យបានជាថ្មីជានិច្ច និងបន្តដំណើរទៅមុខ ដើម្បីឲ្យបានជ័យជម្នះជាថ្មីតទៅទៀត។ ចូរសម្លឹងមើលព្រះសហគមន៍មើល៍! ប្អូនៗក្មួយៗមុខជានឹងឃើញព្រះភ័ក្ត្រព្រះគ្រីស្តក្នុងព្រះសហគមន៍ពុំខាន។ ព្រះគ្រីស្តជាវិរបុរសដ៏ពិតប្រាកដមែន ព្រះអង្គប្រកបដោយចិត្តសុភាពរាបសា មានប្រាជ្ញាដ៏វាងវៃ ជាព្យាការីប្រកាសសេចក្តីពិតនិងសេចក្តីស្រឡាញ់ ជាអ្នកធ្វើដំណើរជាមួយ យុវជនយុវនារី និងជាមិត្តសម្លាញ់របស់ប្អូនៗក្មួយៗ។ ក្នុងនាមព្រះគ្រីស្តនេះហើយ យើងសូមជម្រាបមកប្អូនៗក្មួយៗ សូមដាស់តឿនប្អូនៗក្មួយៗ និងប្រទានពរឲ្យប្អូនៗក្មួយៗផងដែរ។